# គន្ថីទី ១ បទប្បញ្ញត្តិទូទៅ

## ជំពូកទី ១ គោលបំណងនៃក្រមនីតិវិធីរដ្ឋប្បវេណី គោលបំណងនៃបណ្ដឹងរដ្ឋប្បវេណី ការទទួលខុសត្រូវរបស់តុលាការ និង គូភាគី

**មាត្រា ១.-** គោលបំណងនៃក្រមនីតិវិធីរដ្ឋប្បវេណី

នីតិវិធីដែលទាក់ទងទៅនឹងបណ្ដឹងរដ្ឋប្បវេណី ត្រូវធ្វើតាមបញ្ញត្តិនៃក្រមនេះ លើកលែងតែក្នុងករណីដែលច្បាប់ផ្សេងបានកំណត់ពិសេស ។(1)(2)

(កំណត់)

(1) មាត្រានេះ មានគោលបំណងបង្ហាញថា ក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសកម្ពុជា ជាច្បាប់ទូទៅដែលបញ្ញត្តអំពីនីតិវិធីរដ្ឋប្បវេណីដែលអនុវត្តនៅព្រះរាជាណាចក្រកម្ពុជា ។ ម្យ៉ាងទៀត នៅក្នុងនីតិរដ្ឋ នីតិវិធីរដ្ឋប្បវេណីដែលអនុវត្តដោយតុលាការ ត្រូវអនុលោមតាមច្បាប់ដែលត្រូវបានអនុម័តដោយសភាដែលជានីតិបញ្ញត្តិ ។ មាត្រានេះកំណត់ផងដែរថា នៅពេលតុលាការនៃប្រទេសកម្ពុជាអនុវត្តនីតិវិធីរដ្ឋប្បវេណី ជាគោលការណ៍ តុលាការត្រូវអនុលោមតាមបញ្ញត្តិនានា ដែលបានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនេះ ។
ប៉ុន្តែ ប្រសិនបើមានបញ្ញត្តិពិសេសអំពីនីតិវិធីនៃបណ្ដឹងចំពោះរឿងក្ដីប្រភេទណាពិសេស ដែលបានកំណត់ដោយច្បាប់ផ្សេង តុលាការត្រូវអនុលោមទៅតាមបញ្ញត្តិពិសេសនោះ ដើម្បីអនុវត្តនីតិវិធីនៃរឿងក្ដីប្រភេទនោះ នៅក្នុងទំហំដែលបានកំណត់ ។ ជាឧទាហរណ៍ នាអនាគត បើច្បាប់ស្ដីពីនីតិវិធីនៃបណ្ដឹងឋានៈបុគ្គលដែលជាច្បាប់ពិសេសអំពីរឿងក្ដីទាក់ទងនឹងគ្រួសារ ដូចជាបណ្ដឹងអំពីទំនាក់ទំនងអាពាហ៍ពិពាហ៍ និង បណ្ដឹងអំពីបុត្តភាព ត្រូវបានអនុម័ត ឬ បើច្បាប់ស្ដីពីតុលាការពាណិជ្ជកម្មដែលបញ្ញត្តអំពីនីតិវិធីពិសេសចំពោះបណ្ដឹងផ្នែកពាណិជ្ជកម្ម ត្រូវបានអនុម័ត នោះតុលាការត្រូវអនុលោមទៅតាមបញ្ញត្តិនោះ ចំពោះចំណុចដែលបានកំណត់ដោយបញ្ញត្តិពិសេស នៅពេលធ្វើនីតិវិធីនៃបណ្ដឹងចំពោះរឿងក្ដីប្រភេទនោះ ។

(2) ក្នុងចំណោមចំណុចនៃគោលការណ៍នៃនីតិវិធីរដ្ឋប្បវេណី ចំណុចដែលចែងអំពីឯករាជ្យភាពនៃចៅក្រម មានចែងក្នុងមាត្រា ១២៨ វាក្យខណ្ឌទី ១ និង មាត្រា ១៣២ មាត្រា ១៣៣ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។ រីឯចំណុចដែលចែងអំពីការជម្រះក្ដីដោយគោរពច្បាប់ ក៏មានចែងក្នុងមាត្រា ១២៩ វាក្យខណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញនេះហើយដែរ ។ ដូច្នេះមិនចាំបាច់ចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនេះម្ដងទៀតទេ ។

<u>Code of Civil Procedure (Japan)</u>
**Article 1** (Tenor)

Procedures relating to civil actions shall, except as otherwise provided by other laws or ordinances, be governed by the provisions of this Act.

## **មាត្រា ២.-** គោលបំណងនៃបណ្តឹងរដ្ឋប្បវេណី សិទ្ធិពឹងពាក់តុលាការ

១- បណ្តឹងរដ្ឋប្បវេណីមានគោលបំណងឱ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណី ដោយផ្អែកលើច្បាប់ ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន ។ (1)

២- ជនគ្រប់រូបត្រូវបានធានានូវសិទ្ធិពឹងពាក់តុលាការចំពោះវិវាទរដ្ឋប្បវេណី ។ (2)

(កំណត់)

(1) មាត្រានេះ មានគោលបំណងបញ្ជាក់ឱ្យបានច្បាស់នូវទស្សនៈនៃនីតិវិធីរដ្ឋប្បវេណីថា បណ្តឹងរដ្ឋប្បវេណីមានគោលបំណង "ការពារសិទ្ធិឯកជន" ។ នៅក្នុងនីតិរដ្ឋ បើសិទ្ធិដែលច្បាប់ទទួលស្គាល់ចំពោះបុគ្គលឯកជន ត្រូវគេបំពាន ឬ ក្លាយជាកម្មវត្ថុនៃវិវាទ ការការពារដោយតុលាការ ត្រូវតែផ្តល់ទៅបុគ្គលនោះ ដោយឆ្លើយតបនឹងការទាមទាររបស់បុគ្គលនោះ ។ មាត្រានេះបញ្ជាក់ថា ប្រព័ន្ធនៃនីតិវិធីរដ្ឋប្បវេណីត្រូវទទួលបន្ទុកនូវតួនាទីការពារសិទ្ធិនោះ ។

(2) ការដោះស្រាយវិវាទផ្នែករដ្ឋប្បវេណី មិនអនុញ្ញាតឱ្យបុគ្គលឯកជនណាមួយ ធ្វើការដោះស្រាយដោយខ្លួនឯង ដោយប្រើកម្លាំងហិង្សា ឬ អំណាច បំពានទៅលើបុគ្គលផ្សេងទៀត ។ ការការពារសិទ្ធិឯកជន ដោយនីតិវិធីរដ្ឋប្បវេណី មិនមែនជាអំណោយដែលបានផ្តល់ពីរដ្ឋទេ ។ ផ្ទុយទៅវិញ បុគ្គលឯកជនមានសិទ្ធិប្តឹងទៅតុលាការ និងទាមទារការការពារដោយការជំនុំជម្រះ នៅពេលដែលសិទ្ធិរបស់ខ្លួន ត្រូវបានបំពានដោយវិវាទរដ្ឋប្បវេណី ហើយរដ្ឋមានករណីយកិច្ចត្រូវឆ្លើយតប និង ធ្វើការវិនិច្ឆ័យ ។ កថាខណ្ឌទី ២ នៃមាត្រានេះ ចែងដោយផ្អែកលើទស្សនៈនេះ ។ មាត្រា 32 នៃរដ្ឋធម្មនុញ្ញប្រទេសជប៉ុន ក៏ចែងអត្ថន័យដូចគ្នាដែរ ។

Constitution (Japan)
**Article 32**
No person shall be denied the right of access to the courts.

## **មាត្រា ៣.-** សិទ្ធិទាមទារឱ្យសាកសួរ គោលការណ៍ចំពោះមុខ

១- ភាគីណាក៏មិនអាចត្រូវបានជម្រះក្តីដោយមិនបានសាកសួរ ឬ កោះហៅឡើយ ។ (1)

២- ក្នុងករណីណាក៏ដោយ តុលាការត្រូវគោរពគោលការណ៍ចំពោះមុខ ។ (2)

(កំណត់)

(1) ភាគីនៃបណ្តឹងរដ្ឋប្បវេណី អាចទទួលឥទ្ធិពលដល់សិទ្ធិរបស់ខ្លួន ដោយអានុភាពនៃការសម្រេចសេចក្តី ហេតុដូច្នេះជាគោលការណ៍ ភាគីត្រូវទទួលឱកាសបញ្ចេញមតិរបស់ខ្លួន អំពីចំណុចដែលនឹងវិនិច្ឆ័យដោយតុលាការនៅក្នុង

បណ្ដឹងនោះ ហើយឆ្លើយតបនឹងមតិដែលថ្លែងដោយភាគីម្ខាងទៀត មុនពេលតុលាការសម្រេចសេចក្ដី ។ ដូច្នេះ ភាគីនៃបណ្ដឹង មានសិទ្ធិទាមទារឱ្យមានឱកាសបញ្ចេញមតិរបស់ខ្លួន និង ឆ្លើយតបនឹងមតិដែលថ្លែងដោយភាគីម្ខាងទៀត ។ សិទ្ធិនេះ ត្រូវហៅថា សិទ្ធិទាមទារឱ្យសាកសួរ ។ ការធានាសិទ្ធិទាមទារឱ្យសាកសួរ ជាគោលការណ៍មូលដ្ឋានមួយនៃប្រព័ន្ធនីតិវិធីបណ្ដឹង នៅនីតិរដ្ឋប្រជាធិបតេយ្យសម័យទំនើប ហើយមាត្រា 103 កថាខណ្ឌទី 1 នៃច្បាប់មូលដ្ឋាន (Grundgesetz) នៃប្រទេសអាឡឺម៉ង់ និង មាត្រា 14 នៃក្រមនីតិវិធីរដ្ឋប្បវេណីបារាំង ក៏មានអត្ថន័យប្រហាក់ប្រហែលគ្នាដែរ ។ កថាខណ្ឌទី ១ នៃមាត្រានេះ កំណត់អំពីគោលការណ៍នេះ ។

ប៉ុន្តែ បើត្រូវការភាពឆាប់រហ័ស មានករណីខ្លះដែលអនុញ្ញាតឱ្យធ្វើការសម្រេចសេចក្ដីសិន ហើយសាកសួរភាគីដែលនឹងទទួលការខូចខាតដល់ផលប្រយោជន៍របស់ខ្លួនដោយសេចក្ដីសម្រេចនោះ នៅពេលក្រោយ ។ ឧ. ដីកាសម្រេចដាស់តឿនដែលបានកំណត់នៅក្នុងមាត្រា ៣២៣ នៃក្រមនេះ និង ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន (មាត្រា ៥៤៥) ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន (មាត្រា ៥៣៨) ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ (មាត្រា ៥៥០) និង ការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ (មាត្រា ៥៥២) ។

(2) ដើម្បីធានាដោយមានប្រសិទ្ធិភាពនូវសិទ្ធិទាមទារឱ្យសាកសួរ គួរតែវិនិច្ឆ័យ ដោយគូភាគីមានវត្តមាននៅកាលបរិច្ឆេទមួយ និង ចំពោះមុខទៅវិញទៅមក ។ម្យ៉ាងទៀត បើច្បាប់អនុញ្ញាតឱ្យតុលាការកោះហៅភាគីតែម្ខាង និង សួរមតិយោបល់ នៅកាលបរិច្ឆេទ និង ទីកន្លែងដែលភាគីម្ខាងទៀតអវត្តមាន នោះទំនុកចិត្តអំពីភាពមិនលំអៀងក្នុងការវិនិច្ឆ័យ អាចបាត់បង់ ។ ហេតុដូច្នេះ កថាខណ្ឌទី ២ នៃមាត្រានេះ ចែងថា ក្នុងករណីណាក៏ដោយ តុលាការត្រូវគោរពគោលការណ៍ចំពោះមុខ ។ មាត្រា 16 វាក្យខណ្ឌទី 1 នៃក្រមនីតិវិធីរដ្ឋប្បវេណីបារាំង មានអត្ថន័យដូចគ្នា ។ ប៉ុន្តែ ដូចនឹងកថាខណ្ឌទី ១ ក្នុងករណីពិសេស ច្បាប់ទទួលស្គាល់ករណីលើកលែង ។

Code de Procédure Civile (France)

**Article 14**

Nulle partie ne peut être jugée sans avoir été entendue ou appelée.

**Article 16**

Le juge doit, en toutes circonstances, faire observer et observer lui-même le principe de la contradiction.

Il ne peut retenir, dans sa décision, les moyens, les explications et les documents invoqués produits par les parties que si celles-ci ont été à même d'en débattre contradictoirement.

Il ne peut fonder sa désicions sur les moyens de droit qu'il a relevés d'office sans avoir au préalable invité les parties à présenter leurs observations.

**មាត្រា ៤.-** ការទទួលខុសត្រូវរបស់តុលាការ និង ភាគី

តុលាការត្រូវប្រឹងប្រែង ដើម្បីរ៉ាប់រងបណ្ដឹងរដ្ឋប្បវេណីឱ្យប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌និងឆាប់រហ័ស ឯភាគីត្រូវអនុវត្តបណ្ដឹងរដ្ឋប្បវេណីដោយសុចរិតនិងស្មោះត្រង់ ។ (1)

(កំណត់)

(1) តុលាការ ក្នុងនាមជាម្ចាស់អនុវត្តនីតិវិធី ត្រូវប្រឹងប្រែង ដើម្បីរ៉ាប់រងបណ្តឹងរដ្ឋប្បវេណីឱ្យប្រព្រឹត្តទៅ ដោយមានភាពយុត្តិធម៌ និង ភាពឆាប់រហ័ស ។ តុលាការ មិនមែនតែមិនត្រូវអនុវត្តនីតិវិធីបណ្តឹង ដោយមានភាពអយុត្តិធម៌ប៉ុណ្ណោះទេ គឺគប្បីជៀសវាងសម្តី ឬ អំពើណាដែលអាចត្រូវគេសង្ស័យថាមានភាពអយុត្តិធម៌ផងដែរ ។ ម្យ៉ាងទៀត ដូចមានសុភាសិតច្បាប់ថា យុត្តិធម៌យឺតយ៉ាវ ស្មើនឹងការបដិសេធយុត្តិធម៌ (Justice delayed, justice denied) តុលាការត្រូវអនុវត្តនីតិវិធី ដោយមានភាពឆាប់រហ័ស ។ មាត្រានេះចែងអំពីចំណុចខាងលើនេះដែលជាការទទួលខុសត្រូវរបស់តុលាការ ។ ប៉ុន្តែ ការសម្រេចសេចក្តីចំពោះបណ្តឹង និង នីតិវិធីនៃការសម្រេចសេចក្តីនោះ ត្រូវមានភាពត្រឹមត្រូវ ហេតុដូច្នេះ ក្នុងករណីជាក់ស្តែង តុលាការគប្បីធ្វើឱ្យមានភាពចុះសម្រុងនឹងគ្នារវាងភាពឆាប់រហ័សនៃនីតិវិធី និង ការទាមទារឱ្យមានភាពត្រឹមត្រូវនៃការសម្រេចសេចក្តី និង នីតិវិធីនៃការសម្រេចសេចក្តីនោះ ។

(2) នៅក្នុងបណ្តឹងរដ្ឋប្បវេណី ភាគីត្រូវបានទទួលស្គាល់នូវសេរីភាពក្នុងការអនុវត្តបណ្តឹងរដ្ឋប្បវេណី សម្រាប់ផលប្រយោជន៍របស់ខ្លួន ដើម្បីទទួលសាលក្រមឱ្យខ្លួនឈ្នះក្តី ។ ប៉ុន្តែ ភាគីមិនត្រូវគេអនុញ្ញាតឱ្យធ្វើសកម្មភាពដោយទុច្ចរិតនិងមិនស្មោះត្រង់ ចំពោះភាគីម្ខាងទៀតឡើយ ។ មាត្រានេះ ចែងអំពីចំណុចដែលជាការទទួលខុសត្រូវរបស់ភាគី ។ បញ្ហាថា តើសកម្មភាពណា ជាសកម្មភាពទុច្ចរិត ឬ មិនស្មោះត្រង់ នោះត្រូវបានវិនិច្ឆ័យ តាមករណីជាក់ស្តែងនីមួយៗ ។ ប៉ុន្តែ នៅក្នុងចំណោមបញ្ញត្តិនៃក្រមនេះ មានបញ្ញត្តិខ្លះដែលចាត់ទុកសកម្មភាពមួយចំនួនរបស់ភាគី ថា ផ្ទុយនឹងការទទួលខុសត្រូវនៃភាពសុចរិតនិងស្មោះត្រង់ ហើយឱ្យមានការខូចខាតដល់ផលប្រយោជន៍របស់ភាគីនោះ ដូចជា មាត្រា ៩៤ មាត្រា ១០៨ និង មាត្រា ១៩៣ ជាដើម ។

Code of Civil Procedure (Japan)
**Article 2** (Responsibility of court and parties)
Courts shall make efforts to secure that civil actions be conducted with justice and speed, and parties shall conduct civil actions in accordance with good faith and trust.

**មាត្រា ៥.-** ភាសាដែលប្រើក្នុងតុលាការ សិទ្ធិរបស់ភាគីក្នុងការស្នើសុំឱ្យមានអ្នកបកប្រែ

១- នៅក្នុងតុលាការ ត្រូវប្រើភាសាខ្មែរ ។

២- ភាគីដែលមិនអាចយល់ភាសាខ្មែរ អាចស្នើសុំរកអ្នកបកប្រែភាសាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ហើយប្រសិនបើសាមីខ្លួនពុំមានលទ្ធភាពរកខ្លួនឯងបានទេ រដ្ឋត្រូវរកជំនួស ។

(កំណត់)

(1) នៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ចែងថា នៅក្នុងតុលាការ ត្រូវប្រើភាសាខ្មែរ ។ ន័យនេះ សំដៅទៅលើការគោរពតាម មាត្រា ៥ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា ភាសា និង អក្សរដែលប្រើជាផ្លូវការ គឺ ភាសា និង អក្សរខ្មែរ ។

(2) កថាខណ្ឌទី ២ នៃមាត្រានេះ បង្កលក្ខណៈឱ្យភាគីដែលមិនចេះភាសាខ្មែរអាចស្នើសុំអ្នកបកប្រែ ដើម្បីអាចឆ្លើយ និង ថ្លែងនូវយោបល់របស់ខ្លួន តាមរយៈអ្នកបកប្រែ ។

(3) បើតុលាការជ្រើសតាំងអ្នកបកប្រែភាសាសម្រាប់ភាគីដែលមិនអាចយល់ភាសាខ្មែរ តុលាការតម្រូវឱ្យភាគីបង់ជាមុន នូវកម្រៃនៃការបកប្រែភាសា សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ និង សោហ៊ុយស្នាក់នៅ ដែលត្រូវ ប្រគល់ឱ្យអ្នកបកប្រែ (កថាខណ្ឌទី ១ និង ទី ២ នៃមាត្រា ៦២) ។ ភាគីដែលបានទទួលការសង្គ្រោះលើបណ្តឹង អាចពន្យារពេលបង់ ឬ ត្រូវបានអនុគ្រោះមិនបាច់ឱ្យបង់ (កថាខណ្ឌទី ១ នៃមាត្រា ៧០) ។ កម្រៃនៃការបកប្រែ ភាសា សោហ៊ុយធ្វើដំណើរ ជាដើម សម្រាប់អ្នកបកប្រែ ត្រូវបានរាប់បញ្ចូលនៅក្នុងប្រាក់ប្រដាប់ក្តីតុលាការ ។ មាត្រា ១០០ ចែងដូចគ្នា ចំពោះអ្នកដែលពាក់ព័ន្ធនឹងបណ្តឹង ក្រៅពីភាគី ។

**មាត្រា ៦.-** ការចូលរួមរបស់តំណាងអយ្យការ

១- ក្នុងករណីដែលយល់ឃើញថា ចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ តុលាការត្រូវជូនដំណឹងទៅតំណាង អយ្យការថា ពាក្យបណ្តឹងត្រូវបានទទួល ។

២- ទោះបីជាគ្មានការជូនដំណឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះពីតុលាការក៏ដោយ ក៏តំណាងអយ្យការ អាចចូលរួមក្នុងនីតិវិធីនៃបណ្តឹងរដ្ឋប្បវេណី និង បញ្ចេញយោបល់បានដែរ ប្រសិនបើខ្លួនយល់ឃើញថា ចាំបាច់ត្រូវ ការពារផលប្រយោជន៍សាធារណៈ ។(1)(2)

(កំណត់)

(1) នៅប្រទេសជប៉ុន មានតែបណ្តឹងដែលទាក់ទងនឹងឋានៈបុគ្គលទេ ដែលរដ្ឋអាជ្ញាអាចចូលរួមក្នុងនីតិវិធីនៃបណ្តឹងបាន (សូមមើលមាត្រា 5 និង មាត្រា 6 នៃច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលនៃប្រទេសជប៉ុន) ។ ក្នុង នីតិវិធីនៃបណ្តឹងធម្មតា រដ្ឋអាជ្ញាមិនអាចចូលរួមទេ ។ ប៉ុន្តែ នៅព្រះរាជាណាចក្រកម្ពុជា ព្រះរាជអាជ្ញាអាចចូលរួម ក្នុងនីតិវិធីនៃបណ្តឹងធម្មតាដែរ ហើយមានគំនិតរក្សាទុកតទៅថ្ងៃមុខក៏ដូចគ្នាដែរ ហេតុដូច្នេះកំណត់ក្នុងមាត្រានេះ ។ ភាគីជប៉ុនយល់ឃើញថា មាត្រា ៤២ នៃសេចក្តីព្រាងច្បាប់ស្តីពីការចាត់តាំងតុលាការ មិនមានភាពផ្ទុយនឹងមាត្រា ៦ នេះទេ តែប្រសិនបើភាគីកម្ពុជាទទួលយកមតិយោបល់របស់ភាគីជប៉ុន (ដែលត្រូវបានបញ្ជូនទៅភាគីកម្ពុជា នៅខែវិច្ឆិកា ឆ្នាំ ២០០០) ហើយកែប្រែតាមមតិនោះ នោះភាពស្របគ្នារវាងសេចក្តីព្រាងច្បាប់ស្តីពីការចាត់តាំង តុលាការ និង ក្រមនីតិវិធីរដ្ឋប្បវេណី នឹងមានភាពកាន់តែច្បាស់លាស់ ។

(2) ព្រះរាជអាជ្ញាចូលរួមក្នុងនីតិវិធីនៃបណ្តឹង ក្នុងនាមជាតំណាងនៃផលប្រយោជន៍សាធារណៈ ។ ក្នុងករណីដែល ភាគីជាអនីតិជន ជាដើម អ្នកដែលមានតួនាទីត្រូវការពារភាគីនោះ មិនមែនជាព្រះរាជអាជ្ញាទេ គឺអ្នកតំណាង ដែលច្បាប់បានកំណត់ ដូចជា អ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាល ជាដើម (កថាខណ្ឌទី ៣ នៃមាត្រា

៣២ ( សមត្ថភាពភាគី សមត្ថភាពក្នុងការធ្វើបណ្តឹង ការតំណាងដែលច្បាប់បានកំណត់សម្រាប់ជនដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹង)) ។ ប៉ុន្តែ បើគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ ហើយគ្មានអ្នកណាសមធ្វើជាអ្នកតំណាងពិសេស ( មាត្រា ៣៦ ( អ្នកតំណាងពិសេស)) ទេ តុលាការអាចជ្រើសតាំងព្រះរាជអាជ្ញាធ្វើជាអ្នកតំណាងពិសេសបាន ។

Law of Procedure in Actions Relating to Personal Status (Japan)
**Article 5**
1. In proceedings relating to marriage the public procurator must attend the hearing and express his opinion.
2. The public procurator may attend at the examinations held before a commissioned judge or a requisitioned judge.
3. Notice of the subject matter and the time of the hearing must be given to the public procurator, and if he attends, his name and any application made by him must be inserted in the protocol.

**Article 6**
Even though the public procurator is not a party to the action, he has a right to allege facts and to produce evidence in support of the marriage.

## ជំពូកទី ២ តុលាការ

### ផ្នែកទី ១ សមត្ថកិច្ចសាលាជម្រះក្តី

**មាត្រា ៧.-** និយមន័យនៃតុលាការដែលមានសមត្ថកិច្ច

តុលាការដែលមានសមត្ថកិច្ច គឺជាតុលាការដែលអាចទទួលដោយស្របច្បាប់នូវពាក្យបណ្តឹង វិនិច្ឆ័យលើរឿងក្តី ហើយចេញសាលក្រម ឬ សាលដីកាបាន ។

( កំណត់)

នីតិវិធីរដ្ឋប្បវេណីជប៉ុន គ្មានមាត្រាណាដែលចែងដូចមាត្រានេះទេ ។ មាត្រានេះគឺជាការពន្យល់សំរាយអំពីសមត្ថកិច្ចសាលាជម្រះក្តី ។

**មាត្រា ៨.-** សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍

បណ្តឹងចំពោះចុងចម្លើយដែលបានកំណត់ក្នុងចំណុចខាងក្រោមនេះ ត្រូវដាក់ពាក្យបណ្តឹងទៅសាលាដំបូង ដែលមានសមត្ថកិច្ចជម្រះក្តីនៅទីកន្លែងដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

**ក-** រូបវន្តបុគ្គល :

- លំនៅឋានរបស់ចុងចម្លើយ ។
- ទីសំណាក់ បើពុំមានលំនៅឋាន ឬ មានលំនៅឋានមិនពិតប្រាកដនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

- លំនៅឋានចុងក្រោយ បើពុំមានទីសំណាក់ ឬ មានទីសំណាក់មិនពិតប្រាកដ ។

ខ- នីតិបុគ្គលក្នុងប្រទេស ៖

- ទីតាំងនៃទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មជាចម្បង ។
- លំនៅឋានរបស់អ្នកតំណាង ឬ របស់អ្នកទទួលខុសត្រូវភារកិច្ចចាត់ចែងការងារជាចម្បង បើគ្មានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មទេ ។

គ- នីតិបុគ្គលបរទេស ៖

- ទីតាំងនៃទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មជាចម្បង ។
- លំនៅឋានរបស់អ្នកតំណាងប្រចាំព្រះរាជាណាចក្រកម្ពុជា ឬ របស់អ្នកទទួលខុសត្រូវភារកិច្ចចាត់ចែងការងារជាចម្បងក្នុងព្រះរាជាណាចក្រកម្ពុជា បើគ្មានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ។

(កំណត់)

សូមមើលមាត្រា 4 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

គោលបំណងនៃមាត្រានេះគឺការចែងអំពីសមត្ថកិច្ចសាលាជម្រះក្តីជាមូលដ្ឋាន ដោយផ្អែកលើលំនៅឋាន ទីសំណាក់ជាដើម ចំពោះរូបវន្តបុគ្គល ទីតាំងនៃទីស្នាក់ការកណ្តាល លំនៅឋានរបស់អ្នកតំណាង ជាអាទិ៍ ចំពោះនីតិបុគ្គលក្នុងប្រទេស និង នីតិបុគ្គលបរទេស ។ ក្នុងច្បាប់កម្ពុជាបច្ចុប្បន្ន ពុំមានចែងឱ្យបានច្បាស់លាស់ដូចមាត្រានេះទេ ។

អនុសញ្ញាស្តីពីទំនាក់ទំនងអន្តរជាតិដែលធ្វើឡើងនៅទីក្រុង Vienna នៅឆ្នាំ ១៩៦១ (Vienna Convention on Diplomatic Relations, 1961) មាត្រា 31 និង មាត្រា 37 ។ល។ បានកំណត់អំពីករណីដែលអ្នកការទូតមិនមានអភ័យឯកសិទ្ធិ ក្នុងចំណោមបណ្តឹងរដ្ឋប្បវេណីដែលទាក់ទងនឹងអ្នកការទូត ជាដើម ហើយទទួលស្គាល់នូវសិទ្ធិជម្រះក្តីនៃប្រទេស ដែលទទួលអ្នកការទូតនោះ ។ ក្នុងករណីនេះ តុលាការកម្ពុជាដែលមានសមត្ថកិច្ចសាលាជម្រះក្តីលើបណ្តឹងខាងលើនេះ ត្រូវបានកំណត់តាមបញ្ញត្តិនៃមាត្រា ៨ នេះ និង មាត្រា ៩ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមទ្រព្យសម្បត្តិ ជាអាទិ៍) ។

Code of Civil Procedure (Japan)

**Article 4** (Jurisdiction by general forum) (excerpt)

1. A suit shall be subject to the jurisdiction of the court governing the place of the defendant's general forum.
2. The general forum of a person shall be determined by such person's domicile, or by the place of residence when there is no domicile in Japan or the domicile is unknown, or by the last domicile when there is no place of residence in Japan or the place of residence is unknown.
4. The general forum of a juridical person or any other association or foundation shall be determined by the location of its principal office or principal place of business, or when there is no such office or place of business, by the domicile of the representative or principal person in charge of its affairs.

Vienna Convention on Diplomatic Relations, 1961

**Article 31**

1. A diplomatic agent shall enjoy immunity from the criminal jurisdiction of the receiving State. He shall also enjoy immunity from its civil and administrative jurisdiction, except in the case of:

a real action relating to private immovable property situated in the territory of the receiving State, unless he holds it on behalf of the

sending State for the purpose of the mission;
an action relating to succession in which the diplomatic agent is involved as executor, administrator, heir or legatee as a private person and not on behalf of the sending State;
an action relating to any professional or commercial activity exercised by the diplomatic agent in the receiving State outside his official functions.
2. A diplomatic agent is not obliged to give evidence as a witness.
3. No measures of execution may be taken in respect of a diplomatic agent except in the cases coming under subparagraph (a), (b) and (c) of paragraph 1 of this Article, and provided that the measures concerned can be taken without infringing the inviolability of his person or of his residence.
4. The immunity of a diplomatic agent from the jurisdiction of the receiving State does not exempt him from the jurisdiction of the sending State.

**Article 37**

1. The members of the family of a diplomatic agent forming part of his household shall, if they are not nationals of the receiving State, enjoy the privileges and immunities specified in Article 29 to 36.
2. Members of the administrative and technical staff of the mission, together with members of their families forming part of their respective households, shall, if they are not nationals of or permanently resident in the receiving State, enjoy the privileges and immunities specified in Article 29 to 35, except that the immunity from civil and administrative jurisdiction of the receiving State specified in paragraph 1 of Article 31 shall not extent to acts performed outside the course of their duties. They shall also enjoy the privileges specified in Article 336, paragraph 1, in respect of articles imported at the time of first installation.
3. Members of the service staff of the mission who are not nationals of or permanently resident in the receiving State shall enjoy immunity in respect of acts performed in the course of their duties, exemption from dues and taxes on the emoluments they receive by reason of their employment and the exemption contained in Article 33.
4. Private servants of members of the mission shall, if they are not nationals of or permanently resident in the receiving State, be exempt from dues and taxes on the emoluments they receive by reason of their employment. In other respects, they may enjoy privileges and immunities only to the extent admitted by receiving State. However, the receiving State must exercise its jurisdiction over those persons in such a manner as not to interfere unduly with the performance of the functions of the mission.

**មាត្រា ៩.-** សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមទ្រព្យសម្បត្តិ ជាអាទិ៍

ក្រៅពីតុលាការដែលបានកំណត់ក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍) ខាងលើនេះ ពាក្យបណ្តឹងដែលបានកំណត់ក្នុងចំណុចខាងក្រោមនេះ អាចប្តឹងនៅតុលាការដែលមានសមត្ថកិច្ចនៅទីកន្លែងដែលបានកំណត់ក្នុងចំណុចនីមួយៗ ក៏បានដែរ :

**ក**- បណ្តឹងទាមទារឱ្យអនុវត្តកាតព្វកិច្ច : កន្លែងដែលត្រូវអនុវត្តកាតព្វកិច្ច ។

**ខ**- បណ្តឹងទាមទារឱ្យបង់ប្រាក់ដោយរូបិយាណត្តិ ឬ មូលប្បទានប័ត្រ : កន្លែងបង់រូបិយាណត្តិ ឬ មូលប្បទានប័ត្រ ។

**គ**- បណ្តឹងទាមទារឱ្យអនុវត្តកាតព្វកិច្ច ចំពោះបុគ្គលដែលពុំមានលំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជា ឬ លំនៅឋានមិនពិតប្រាកដ : កន្លែងដែលកម្មវត្ថុនៃការទាមទារ ឬ កម្មវត្ថុនៃប្រាតិភោគដែលធានាលើការទាមទារនោះ ឬ ទ្រព្យរបស់ចុងចម្លើយដែលអាចរឹបអូសបាន ស្ថិតនៅ ។

**ឃ**- បណ្តឹងទាមទារឱ្យអនុវត្តកាតព្វកិច្ច ចំពោះនីតិបុគ្គលដែលពុំមានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មមិនពិតប្រាកដ : កន្លែងដែលកម្មវត្ថុនៃការទាមទារ ឬ កម្មវត្ថុនៃប្រាតិភោគដែលធានាលើការទាមទារនោះ ឬ ទ្រព្យរបស់ចុងចម្លើយដែលអាចរឹបអូសបានស្ថិតនៅ ។

**ង**- បណ្តឹងចំពោះបុគ្គលដែលមានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មដែលទាក់ទងនឹងសកម្មភាពការងាររបស់ទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនោះ : ទីតាំងនៃទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនោះ ។

**ច**- បណ្តឹងទាក់ទងនឹងអំពើអនីត្យានុកូល : កន្លែងដែលអំពើអនីត្យានុកូលកើតឡើង ។

**ឆ**- បណ្តឹងទាក់ទងនឹងអចលនវត្ថុ : កន្លែងដែលអចលនវត្ថុនោះស្ថិតនៅ ។

ង- បណ្តឹងទាក់ទងនឹងការចុះបញ្ជី : កន្លែងដែលត្រូវចុះបញ្ជី ។

ឈ- បណ្តឹងទាក់ទងនឹងមតិក : លំនៅឋានរបស់មតកជន នៅពេលសន្តតិកម្មត្រូវចាប់ផ្តើម ឬ ទីសំណាក់ បើមតកជនពុំមានលំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជា ឬ មានលំនៅឋានមិនពិតប្រាកដ ឬ លំនៅឋានចុងក្រោយ បើមតកជននោះពុំមានទីសំណាក់ ក្នុងព្រះរាជាណាចក្រកម្ពុជា ឬ មានទីសំណាក់មិនពិតប្រាកដ ។

( កំណត់ )

មាត្រានេះដោយរួមជាមួយនឹង មាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍) មានន័យថា ដើមចោទអាចជ្រើសរើសយកតុលាការដែលមានសមត្ថកិច្ចមួយ ក្នុងចំណោមតុលាការច្រើន ។ មាត្រានេះមានអត្ថន័យដូចគ្នានឹងមាត្រា 5 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

ចំពោះ "បណ្តឹងទាក់ទងនឹងអំពើអនីត្យានុកូល" ដែលបានកំណត់នៅក្នុងចំណុច ច គ្រាន់តែមានការអះអាងរបស់ដើមចោទ អំពីអំពើអនីត្យានុកូលនោះ ជាការគ្រប់គ្រាន់ហើយ ពីព្រោះអត្ថិភាពនៃអំពើអនីត្យានុកូល ត្រូវបានសម្រេចតាមការវិនិច្ឆ័យ ។

ម្យ៉ាងទៀត ចំពោះសមត្ថកិច្ចសាលាជម្រះក្តីអន្តរជាតិ សាលដីកានៃសភាទី ២ នៃតុលាការកំពូល (រឿងក្តីទាមទារបញ្ជាក់នូវសិទ្ធិនិពន្ធ ជាអាទិ៍) នៅថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០០១ បានសន្និដ្ឋានថា ដើម្បីទទួលស្គាល់នូវសមត្ថកិច្ចសាលាជម្រះក្តីអន្តរជាតិនៃតុលាការជប៉ុន ដោយយោងទៅតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ស្តីពីសមត្ថកិច្ចសាលាជម្រះក្តី លើកន្លែងដែលអំពើអនីត្យានុកូលកើតឡើង ជាគោលការណ៍ គ្រាន់តែបញ្ជាក់នូវទំនាក់ទំនងនៃអង្គហេតុដែលបង្ហាញថា មានការខូចខាតកើតឡើងចំពោះផលប្រយោជន៍តាមច្បាប់របស់ដើមចោទ ដោយសារអំពើដែលចុងចម្លើយបានធ្វើនៅក្នុងប្រទេសជប៉ុន ជាការគ្រប់គ្រាន់ហើយ ។

យើងត្រូវគិតពិចារណា ថាតើត្រូវកំណត់បញ្ញត្តិពិសេសស្តីពីសមត្ថកិច្ចសាលាជម្រះក្តី លើរឿងក្តីដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា ឬអត់ នៅពេលក្រោយដែលមានភាពចាំបាច់កើតឡើង ដោយយោងទៅតាមច្បាប់ស្តីពីការចាត់តាំងតុលាការថ្មី ។

Code of Civil Procedure (Japan)

**Article 5** (Jurisdiction of suit concerning property right, etc.)

A suit perscribed by either of the following items may be filed before the court governing the place designated by the respective applicable items:

i. a suit concerning a property right......
the place of performance of the obligation;

ii. a suit for the purpose if claiming monetary payment of bills or checks......
the place for payment of the bills or checks;

iii. a suit against a member of a ship's crew and which concerns a property right......
the place of the ship's registry;

iv. a suit against a person who has no domicile (in cases where the suit is filed against a juridical person, office or place of business; hereinafter in this item the same shall apply) in Japan or whose domicile is unknown and which concerns a property right......
the place where the subject matter of the claim, the subject matter of the security therefor, or any of defendant's property which may be attached is located;

v. a suit against a person maintaining an office or place of business and which concerns the affairs of such office or place of business......
the place where the office or place of business is located;

vi. a suit against a ship-owner or any other person using a ship and which concerns the ship or voyage......
the place of the ship's registry;

vii. a suit concerning a company or any other association or foundation and which is prescribed as follows
a. a suit by a company or other association against a member of such organization or a person who was a member, or a suit by a member against a member or a person who was a member, or a suit by a person who was a member against a member, and which is based on membership status:
b. a suit by an association or a foundation against an officer or a person who was an officer, and which is based on official status:
c. a suit by company against a promoter or a person who was a promoter, or an inspector or a person who was an inspector, and which is based on the status of the promoter or inspector:
d. a suit by an obligee of a company or other association against a member or a person who was a member of such organization, and which is based on membership status:......
the place of the general forum of the association or the foundation;

ix. a suit relating to a tort......
the place of the tort;

x. a suit for damages based on a collision of ships or any other accident at sea......
the place where the damaged ship first arrived;

xi. a suit relating to salvage......
the place where the salvage was effected or the place where the salvaged ship first arrived;

xii. a suit relating to immovables......
the place where the immovable is located;

xiii. a suit relating to a registration......
the place where such registration is to be made;

xiv. a suit relating to an inheritance right or legal share, or a suit relating to a legacy or any other act that shall take effect upon death......
the place of the decedent's general forum at the time of commencement of succession;

xv. insofar as it does not come within the provisions of the preceding item, a suit relating to an obligation-right against a decedent's estate, or other encumbrance upon the estate (provided the whole or a part of the decedent's estate exists in the district of the court governing the place prescribed by the preceding item)......
the place prescribed by the preceding item.

**មាត្រា ១០.-** សមត្ថកិច្ចសាលាជម្រះក្ដីពិសេសលើរឿងក្ដីលែងលះគ្នា និង រឿងក្ដីអំពីបុគ្គភាព

១- បណ្ដឹងលែងលះគ្នា និង បណ្ដឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃបុគ្គភាព ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្ដាច់មុខ របស់សាលាដំបូងដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គលដែលពាក់ព័ន្ធនឹងបណ្ដឹងនោះ ឬ លំនៅឋាននាពេលដែលភាគីនោះទទួលមរណភាព ។

២- បើលំនៅឋានដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ លំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាមិនពិតប្រាកដទេ សមត្ថកិច្ចសាលាជម្រះក្ដី ត្រូវកំណត់តាមទីសំណាក់ ។ បើពុំមានទីសំណាក់ ឬ ទីសំណាក់មិនពិតប្រាកដទេ សមត្ថកិច្ចនោះត្រូវកំណត់តាមលំនៅឋានចុងក្រោយ ។

( កំណត់)

សូមមើលមាត្រា ៤ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលនៃប្រទេសកម្ពុជា និង មាត្រា 4 នៃច្បាប់ស្ដីពីនីតិវិធីនៃបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលនៃប្រទេសជប៉ុន ។

មាត្រានេះជាបញ្ញត្តិពិសេសអំពីសមត្ថកិច្ចសាលាជម្រះក្ដី ចំពោះរឿងក្ដីលែងលះ និង រឿងក្ដីទាមទារឱ្យបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃបុគ្គភាពដែលយើងស្មានថា នឹងកើតឡើងជាច្រើន ក្នុងចំណោមបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ។

ចំពោះសមត្ថកិច្ចសាលាជម្រះក្តីលើបណ្តឹងទាក់ទងនឹងឋានៈបុគ្គលផ្សេងទៀត មានបញ្ញត្តិពិសេស នៅក្នុងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ។

**មាត្រា ១១.-** សមត្ថកិច្ចសាលាជម្រះក្តីចំពោះការទាមទារច្រើនចំណុចដោយបញ្ចូលជាមួយគ្នា

ចំពោះបណ្តឹងមួយដែលមានការទាមទារច្រើនចំណុច ដែលស្ថិតនៅក្រោមសមត្ថកិច្ចសាលាជម្រះក្តីផ្សេងគ្នា អាចប្តឹងទៅតុលាការដែលមានសមត្ថកិច្ចលើការទាមទារណាមួយក៏បានដែរ ដោយបញ្ចូលការទាមទារផ្សេងទៀតជាមួយគ្នា ។

(កំណត់)

មាត្រានេះមិនអាចត្រូវបានអនុវត្តចំពោះករណីណាដែលមានភាគីដើមចោទ ឬ ភាគីចុងចម្លើយច្រើននាក់ទេ ។ មាត្រានេះ កំណត់សម្រាប់តែបណ្តឹងដែលមានគូភាគីដូចគ្នាតែប៉ុណ្ណោះ (បណ្តឹងដែលមានដើមចោទតែម្នាក់ និង ចុងចម្លើយតែម្នាក់) ។ មាត្រានេះមានអត្ថន័យដូចគ្នានឹងមាត្រា 7 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន តែមិនបញ្ចូលករណីដែលមានដើមចោទ ឬ ចុងចម្លើយច្រើននាក់ទេ ។

Code of Civil Procedure (Japan)
**Article 7** (Jurisdiction for joint claims)
in cases where several claims are asserted in one suit, such suit may be filed before any court having jurisdiction over any one of such claims in accordance with the provisions of the preceding three articles. However, with regard to a suit by several persons or a suit against several persons, this shall be limited to only those cases where such suit comes under the first half of the provisions in Article 38.

**មាត្រា ១២.-** ការកំណត់តុលាការដែលមានសមត្ថកិច្ច

ក្នុងករណីដែលតុលាការមានសមត្ថកិច្ចមិនអាចអនុវត្តនូវសិទ្ធិជម្រះក្តីបានដោយសារច្បាប់ ឬ ហេតុការណ៍ពិត ឬ ករណីដែលសមត្ថកិច្ចសាលាជម្រះក្តីមិនអាចកំណត់បានដោយសារដែនសមត្ថកិច្ចនៃតុលាការមិនពិតប្រាកដ តុលាការកំពូលត្រូវកំណត់តុលាការដែលមានសមត្ថកិច្ច ដោយដីកាសម្រេច តាមពាក្យសុំ ។

(កំណត់)

នៅក្នុងមាត្រានេះ យើងទទួលស្គាល់សិទ្ធិស្នើសុំរបស់ភាគី ដោយសារតែមានសំណូមពរ ពីតុលាការខេត្តកំពង់ស្ពឺ នៅពេលដែលអនុគណៈកម្មាធិការបានចុះទៅធ្វើការសម្ភាសន៍តាមខេត្ត ។ សូមមើលមាត្រា 10 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

ករណីដែលមិនអាចអនុវត្តនូវសិទ្ធិជម្រះក្តីដោយសារច្បាប់ ដូចជាគ្រប់ចៅក្រមនៅសាលាជម្រះក្តីនោះដកខ្លួន ដោយមានមូលហេតុតាមច្បាប់ ដែលនាំឱ្យការដោះស្រាយរឿងក្តីមិនអាចមានដំណើរការបាន ។

ករណីដែលមិនអាចអនុវត្តនូវសិទ្ធិជម្រះក្តីដោយហេតុការណ៍ពិត ដូចជាទីតាំងរបស់តុលាការទទួលរងគ្រោះធម្មជាតិ ។

ករណីដែលសមត្ថកិច្ចសាលាជម្រះក្តីមិនអាចកំណត់បាន ដោយសារដែនសមត្ថកិច្ចនៃតុលាការមិនពិតប្រាកដ ដូចជាអំពើអនីត្យានុកូលដែលកើតឡើង នៅលើទីកន្លែងដែលមិនអាចកំណត់ថាជាដែនសមត្ថកិច្ចនៃតុលាការណាមួយ ។

Code of Civil Procedure (Japan)
**Article 10** (Designation of court with jurisdiction)
1. In cases where a court with jurisdiction is legally or actually unable to exercise jurisdiction, the immediately superior court over the court shall, upon motion, by ruling, determine the court of proper jurisdiction.
2. In cases where a court with jurisdiction cannot be determined because the jurisdictional district is not clear, the immediately superior court over all courts concerned shall, upon motion, by ruling, determined the court of proper jurisdiction.
3. No appeal may be made against the ruling referred to in the preceding two paragraphs.

**មាត្រា ១៣.-** ការព្រមព្រៀងក្នុងការកំណត់តុលាការដែលមានសមត្ថកិច្ច

១- ការព្រមព្រៀងដែលកំណត់តុលាការដែលមានសមត្ថកិច្ចជម្រះក្តី នឹងមានអានុភាព លុះត្រាតែការព្រមព្រៀងនោះត្រូវបានធ្វើឡើងរវាងពាណិជ្ជករនិងពាណិជ្ជករ ឬ នីតិបុគ្គលនិងនីតិបុគ្គល ឬ ពាណិជ្ជករនិងនីតិបុគ្គល ចំពោះតែការជំនុំជម្រះក្តីលើកទី ១ ។

២- ការព្រមព្រៀងដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ នឹងមានអានុភាព លុះត្រាតែការព្រមព្រៀងនោះត្រូវបានធ្វើឡើង ចំពោះបណ្តឹងដែលផ្អែកលើទំនាក់ទំនងគតិយុត្តដែលបានកំណត់ ហើយត្រូវបានធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ។

( កំណត់)

មាត្រានេះចែងសម្រាយស្រួលយល់ជាងមាត្រា 48 នៃក្រមនីតិវិធីរដ្ឋប្បវេណីបារាំង ។ គោលសេចក្តីនៃមាត្រានេះគឺការកម្រិតឱ្យតែអ្នកជំនួញទេ ដែលអាចធ្វើការព្រមព្រៀងអំពីសមត្ថកិច្ចសាលាជម្រះក្តី ។ រីឯមាត្រា 38 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាឡឺម៉ង់ (វិសោធនកម្មនៅឆ្នាំ 1974) វិញ ជាគោលការណ៍ អនុញ្ញាតឱ្យតែអ្នកជំនួញ និង នីតិបុគ្គលសាធារណៈទេ ដែលអាចធ្វើកិច្ចព្រមព្រៀងជ្រើសរើសតុលាការដែលមានសមត្ថកិច្ចបាន ។ មាត្រានេះ មានអត្ថន័យដូចគ្នានឹងមាត្រា 11 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនដែរ ប៉ុន្តែ ក្រមជប៉ុនមិនកម្រិតប្រភេទនៃប្រធានដែលអាចព្រមព្រៀងនូវសមត្ថកិច្ចសាលាជម្រះក្តីទេ ។ ចំពោះក្រមនេះវិញ មាត្រានេះទទួលស្គាល់តែការព្រមព្រៀងរវាងអ្នកជំនួញ ឬ នីតិបុគ្គល តែប៉ុណ្ណោះ ដោយគិតពិចារណានូវស្ថានភាពនៃប្រទេសកម្ពុជា ។

ជាគោលការណ៍ មាត្រា 38 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាឡឺម៉ង់ (វិសោធនកម្មនៅឆ្នាំ 1974) និង មាត្រា 48 នៃក្រមនីតិវិធីរដ្ឋប្បវេណីបារាំង (វិសោធនកម្មនៅឆ្នាំ 1975) មិនទទួលស្គាល់នូវអានុភាពនៃការព្រមព្រៀងអំពីសមត្ថកិច្ចសាលាជម្រះក្តី រវាងរូបវន្តបុគ្គលដែលមិនមែនជាពាណិជ្ជករ ជាមួយពាណិជ្ជករ ឬ នីតិបុគ្គល និង រវាងរូបវន្តបុគ្គលដែលមិនមែនជាពាណិជ្ជករសងខាង តាមទស្សនៈនៃការការពារអ្នកប្រើប្រាស់ ។ មាត្រានេះ ក៏ចែងអំពីគោលគំនិតនោះផងដែរ ។

Code de Procédure Civile (France)
**Article 48**
Toute clause qui, directement ou indirectement, déroge aux règles de compétence territoriale est réputée non écrite à moins qu'elle n'ait été convenue entre des personnes ayant toutes contracté en qualité de commerçant et qu'elle n'ait été spécifiée de façon très apparente dans l'engagement de la partie à qui elle est opposée.)

Code of Civil Procedure Rules (Germany)
**Article 38** (Permitted agreement on jurisdiction) (excerpt)
1. A court of first instance, which in itself has no jurisdiction, becomes competent by express or implied agreement of the parties, if the parties to the agreement are merchants who do not belong to the traders designated in §4 of the Commercial Code, juristic persons of the public law or separate estates created under the public law.

Code of Civil Procedure (Japan)
**Article 11** (Agreement upon jurisdiction)
1. The parties may be agreement determine a court which will have jurisdiction only insofar as concerns the court of the first instance.
2. The agreement in the preceding paragraph shall not be valid unless it is made with regard to a suit based on a specific legal relationship and is made in writing.

**មាត្រា ១៤.-** សមត្ថកិច្ចសាលាជម្រះក្តីដែលបានកើតឡើងដោយគ្មានការតវ៉ាពីចុងចម្លើយ

នៅពេលដែលចុងចម្លើយបានធ្វើសេចក្តីដោះសារអំពីអង្គសេចក្តី នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬបានឆ្លើយទាញហេតុផលអំពីអង្គសេចក្តីនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់រួចហើយ នៅតុលាការនៃការជំនុំជម្រះលើកទី ១ ដោយគ្មានការតវ៉ាអំពីកំហុសនៃសមត្ថកិច្ចសាលាជម្រះក្តីនោះ តុលាការនេះត្រូវមានសមត្ថកិច្ចជម្រះក្តី ។

(កំណត់)

មាត្រានេះមានអត្ថន័យដូចគ្នានឹងមាត្រា 12 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

ក្នុងករណីដែលចុងចម្លើយបានធ្វើសេចក្តីដោះសារអំពីអង្គសេចក្តីដែលដើមចោទលើកឡើង ដោយគ្មានការតវ៉ាអំពីកំហុសនៃសមត្ថកិច្ចសាលាជម្រះក្តី នោះមានភាពចាំបាច់ធានាស្ថិរភាពនៃនីតិវិធី ហេតុដូច្នេះ នៅក្រោយពេលនេះ ចុងចម្លើយមិនអាចធ្វើវិវាទអំពីកំហុសនៃសមត្ថកិច្ចសាលាជម្រះក្តីបានឡើយ ។

"ការតវ៉ាអំពីកំហុសនៃសមត្ថកិច្ចសាលាជម្រះក្តី" ក្នុងមាត្រានេះ មិនចាំបាច់បញ្ជាក់ឱ្យច្បាស់លាស់នូវការតវ៉ាទេ គឺគ្រាន់តែការបង្ហាញអាកប្បកិរិយាថា មានបញ្ហាអំពីសមត្ថកិច្ច ជាការគ្រប់គ្រាន់ហើយ ។

Code of Civil Procedure (Japan)
**Article 12** (Forum in case of defendant's response)
In cases where the defendant proceeds orally, or makes statements in the preparations for argument proceedings, upon the merits without first pleading lack of jurisdiction in the court of first instance, such court shall have jurisdiction.

**មាត្រា ១៥.-** ករណីលើកលែងនៃការអនុវត្តចំពោះសមត្ថកិច្ចផ្តាច់មុខរបស់សាលាជម្រះក្តី ដែលច្បាប់បានកំណត់

បញ្ញត្តិនៃមាត្រា ១៣ (ការព្រមព្រៀងក្នុងការកំណត់តុលាការដែលមានសមត្ថកិច្ច) និង មាត្រា ១៤ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកើតឡើងដោយគ្មានការតវ៉ាពីចុងចម្លើយ) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះ

ករណីដែលមានបញ្ញត្តិនៃច្បាប់កំណត់សមត្ថកិច្ចផ្តាច់មុខចំពោះបណ្តឹង ។

(កំណត់)

មាត្រានេះមានអត្ថន័យដូចគ្នានឹងមាត្រា 13 នៃក្រមនីតិវិធីរដ្ឋប្បវេណីប្រទេសជប៉ុន ។ សមត្ថកិច្ចផ្តាច់មុខមានដូចជា : សមត្ថកិច្ចលើបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី (មាត្រា ៣០៩) នីតិវិធីដាស់តឿន (មាត្រា ៣២០) ការអនុវត្តដោយបង្ខំ (មាត្រា ៣៤៦) ការចាត់ចែងរក្សាការពារ (មាត្រា ៥៣៣) ជាអាទិ៍ ។

<u>Code of Civil Procedure (Japan)</u>
**Article 13** (Exception in case of exclusive jurisdiction)
The provisions of Article 4, paragraph 1, Article 5 to 7 inclusive, and the preceding two articles shall not apply to a suit for which exclusive jurisdiction is provided by laws or ordinances.

**មាត្រា ១៦.-** ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ

តុលាការអាចពិនិត្យភស្តុតាងចំពោះបញ្ហាដែលទាក់ទងនឹងសមត្ថកិច្ចសាលាជម្រះក្តី ដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។

(កំណត់)

មាត្រានេះមានអត្ថន័យដូចគ្នានឹងមាត្រា 14 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

មាត្រានេះ មានន័យថា តុលាការដែលទទួលពាក្យបណ្តឹង មានករណីយកិច្ចស្រាវជ្រាវអំពីអត្ថិភាព ឬ នត្ថិភាពនៃសមត្ថកិច្ចសាលាជម្រះក្តី ហើយអាចពិនិត្យភស្តុតាងចំបាច់សម្រាប់ការស្រាវជ្រាវនោះ ដោយឆន្ទានុសិទ្ធិបាន ទោះបីជាគ្មានពាក្យសុំអំពីបញ្ហាសមត្ថកិច្ចក៏ដោយ ។

មាត្រា ១២៤ (ការពិនិត្យភស្តុតាង) កថាខណ្ឌទី ២ ចែងថា "ប្រសិនបើតុលាការពុំអាចសម្រេចលើការទទួលស្គាល់អង្គហេតុដែលអះអាងដោយភស្តុតាងដែលគូភាគីបានស្នើសុំឱ្យពិនិត្យថាពិតឬមិនពិតទេ ឬ បើយល់ឃើញថា មានការចាំបាច់ផ្សេងទៀត នោះតុលាការអាចធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិបាន" ។ បញ្ញត្តិនេះមានន័យថា ជាគោលការណ៍ ការពិនិត្យភស្តុតាងអំពីអង្គសេចក្តី ត្រូវបានធ្វើឡើងដោយផ្អែកលើការស្នើសុំឱ្យពិនិត្យភស្តុតាងរបស់ភាគី ហើយឱ្យភាគីទទួលខុសត្រូវចម្បងក្នុងការដាក់ (ជូន) ភស្តុតាង ។ ប៉ុន្តែ មាត្រា ១៦ នេះ ពុំមានអត្ថន័យដូចមាត្រា ១២៤ កថាខណ្ឌទី ២ ទេ ។

<u>Code of Civil Procedure (Japan)</u>
**Article 14** (Examination of evidence upon the court's own authority)
The court may examine evidence upon its own authority with regard to matters relating to its jurisdiction.

**មាត្រា ១៧.-** មូលដ្ឋាននៃពេលវេលាសម្រាប់កំណត់សមត្ថកិច្ចសាលាជម្រះក្តី

សមត្ថកិច្ចសាលាជម្រះក្តីត្រូវកំណត់តាមពេលដាក់ពាក្យបណ្តឹង ។

（កំណត់）

មាត្រានេះមានអត្ថន័យដូចគ្នានឹងមាត្រា 15 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

ពេលដាក់ពាក្យបណ្តឹង គឺជាពេលដែលដើមចោទដាក់លិខិតពាក្យបណ្តឹងទៅតុលាការ ។ ក្នុងករណីដែលដាក់ពាក្យបណ្តឹងដោយផ្ទាល់មាត់ នៅក្នុងរឿងក្តីចំនួនទឹកប្រាក់តិច（មាត្រា ២២៥（ការដាក់ពាក្យបណ្តឹងដោយផ្ទាល់មាត់ ចំណុចដែលត្រូវបញ្ជាក់ច្បាស់លាស់នៅពេលដាក់ពាក្យបណ្តឹង）） ពេលដែលក្រឡាបញ្ជីកត់ត្រានូវសេចក្តីថ្លែងការណ៍របស់ដើមចោទ ក្នុងកំណត់ហេតុ គឺជាពេលដាក់ពាក្យបណ្តឹង ដោយយោងតាមកថាខណ្ឌទី ៣ នៃមាត្រា ២២៥ ។

<u>Code of Civil Procedure (Japan)</u>
**Article 15** (Time of determination of jurisdiction)
The jurisdiction of a court shall be determined according to standards existing at the time of institution of the suit.

**មាត្រា ១៨.-** ការចាត់ចែងបណ្តឹងខុសសមត្ថកិច្ចសាលាជម្រះក្តី

១- ប្រសិនបើតុលាការយល់ឃើញថា បណ្តឹងទាំងមូល ឬ ផ្នែកណាមួយ មិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនទេ តុលាការនេះត្រូវផ្ទេរបណ្តឹងនោះទៅតុលាការដែលមានសមត្ថកិច្ច តាមពាក្យសុំរបស់ភាគី ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

២- ពាក្យសុំផ្ទេរបណ្តឹងត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ លើកលែងតែករណីដែលដាក់ពាក្យសុំនៅកាលបរិច្ឆេទ ។ នៅពេលធ្វើពាក្យសុំនេះ ត្រូវបញ្ជាក់ឱ្យច្បាស់លាស់អំពីមូលហេតុនៃពាក្យសុំនោះ ។

（កំណត់）

មាត្រានេះមានអត្ថន័យដូចគ្នានឹងមាត្រា 16 នៃនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

មាត្រានេះ សំដៅលើការចាត់ចែងរបស់តុលាការ ចំពោះបណ្តឹងដែលខុសសមត្ថកិច្ច ។ ប្រសិនបើតុលាការត្រូវលើកពាក្យបណ្តឹងចោលដោយយកមូលហេតុថា ខ្លួនគ្មានសមត្ថកិច្ច ភាគីត្រូវដាក់ពាក្យបណ្តឹងទៅតុលាការដែលមានសមត្ថកិច្ចជាថ្មីឡើងវិញ ដែលជាហេតុនាំឱ្យភាគីទទួលការខូចខាតផលប្រយោជន៍ ទាំងពេលវេលា និង ផ្នែកសេដ្ឋកិច្ច ។ ដូចនេះ យើងកំណត់ឱ្យតុលាការត្រូវផ្ទេរបណ្តឹងនោះ ទៅតុលាការដែលមានសមត្ថកិច្ច ។

ទោះបីជាផ្នែកណាមួយនៃបណ្តឹងមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនក៏ដោយ តុលាការអាចទទួលបណ្តឹងនោះមកដោះស្រាយបាន ដោយយោងតាមបញ្ញត្តិនៃមាត្រា ១១（សមត្ថកិច្ចសាលាជម្រះក្តីចំពោះការទាមទារច្រើនចំណុចដោយបញ្ចូលជាមួយគ្នា） ។ ប៉ុន្តែ ប្រសិនបើផ្នែកណាមួយនៃបណ្តឹងនោះ ស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់តុលាការណាមួយផ្សេងទៀត នោះតុលាការដែលទទួលពាក្យបណ្តឹង ត្រូវផ្ទេរផ្នែកនោះ ទៅតុលាការដែលមានសមត្ថកិច្ច ។

Code of Civil Procedure (Japan)
**Article 16** (Treatment in case of lack of jurisdiction) (excerpt)
1. The court shall, upon determining that the whole or a part of a suit does not fall under its jurisdiction, upon motion or upon its own authority, transfer such suit to a court with jurisdiction.

## **មាត្រា ១៩.~** ការផ្ទេរដើម្បីជៀសវាងពីការយឺតយ៉ាវ ជាអាទិ៍

១- ទោះបីជាបណ្តឹងណាមួយស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនក៏ដោយ ប្រសិនបើតុលាការនៃការជំនុំជម្រះលើកទី ១ យល់ឃើញថាចាំបាច់ដើម្បីជៀសវាងពីការយឺតយ៉ាវហួសហេតុនៃនីតិវិធី ឬ ដើម្បីធ្វើឱ្យមានសមធម៌រវាងគូភាគី ដោយពិចារណាអំពីលំនៅឋានរបស់ភាគីនិងសាក្សីដែលត្រូវសាកសួរ ទីតាំងនៃវត្ថុដែលនឹងត្រូវបានត្រួតពិនិត្យ និង កាលៈទេសៈផ្សេងៗ តុលាការនោះអាចផ្ទេរបណ្តឹងទាំងមូល ឬ ផ្នែកណាមួយ ទៅតុលាការផ្សេងទៀត ដែលមានសមត្ថកិច្ច តាមពាក្យសុំរបស់ភាគី ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។

២- ក្នុងករណីដែលមានពាក្យសុំ ដែលបានកំណត់ក្នុងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវសម្រេច ដោយសួរយោបល់របស់ភាគីម្ខាងទៀត ។ ក្នុងករណីដែលតុលាការសម្រេចនូវការផ្ទេរដែលបានកំណត់ក្នុងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន នោះតុលាការអាចសួរយោបល់គូភាគីបាន ។

(កំណត់)

មាត្រានេះមានអត្ថន័យដូចគ្នានឹងមាត្រា 17 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

ក្នុងការសម្រេចផ្ទេរបណ្តឹង ប្រសិនបើយើងទទួលស្គាល់នូវឆន្ទានុសិទ្ធិរបស់ចៅក្រមឱ្យបានទូលាយទៅ នឹងមានបញ្ហាដែរ ។ ក្នុងករណីនេះ យើងអាចបញ្ជាក់បន្ថែមឱ្យច្បាស់លាស់អំពីល័ក្ខខ័ណ្ឌក្នុងការផ្ទេរ ឬ កម្រិតករណីនៃការផ្ទេរ ។

ប៉ុន្តែ ចំណុចសំខាន់ គឺ ការអនុវត្តនូវប្រព័ន្ធនៃការផ្ទេរឱ្យស្របទៅតាមកាលៈទេសៈ ដើម្បីឱ្យមានភាពស្មើគ្នារវាងដើមចោទ និង ចុងចម្លើយ ដោយសារដើមចោទអាចជ្រើសរើសតុលាការដែលមានសមត្ថកិច្ចមួយ ក្នុងចំណោមតុលាការច្រើនដោយសេរី ។

Code of Civil Procedure (Japan)
**Article 17** (Transfer in order to avoid delay, etc.)
A court of the first instance may, even when a suit falls under the jurisdiction of such court, upon motion or upon its own authority, transfer the whole or a part of such suit to another court with jurisdiction upon determining it necessary to do so in order to avoid considerable delay of the suit or in order to serve fairness to the parties, in consideration of the domicile of the parties and the witnesses who may be examined or the location of the objects which may be inspected or any other circumstances.

## **មាត្រា ២០.~** ការកម្រិតនូវការផ្ទេរក្នុងករណីសមត្ថកិច្ចផ្តាច់មុខដែលបានកំណត់ដោយច្បាប់

បញ្ញត្តិនៃមាត្រា ១៩ (ការផ្ទេរដើម្បីជៀសវាងពីការយឺតយ៉ាវ ជាអាទិ៍) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបណ្តឹងស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខដែលបានកំណត់ដោយច្បាប់របស់តុលាការដែលចាត់ការបណ្តឹងនោះ ។

( កំណត់ )

មានអត្ថន័យដូចគ្នានឹងមាត្រា 20 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

មាត្រានេះហាមឃាត់តុលាការដែលមានសមត្ថកិច្ចផ្តាច់មុខផ្ទេររឿងក្តីទៅតុលាការផ្សេងទៀត ទោះបីជាមានហេតុដែលបញ្ញត្តនៅក្នុងមាត្រា ១៩ ( ការផ្ទេរដើម្បីជៀសវាងពីការយឺតយ៉ាវ ជាអាទិ៍ ) ក៏ដោយ ។ សមត្ថកិច្ចផ្តាច់មុខមានដូចជា សមត្ថកិច្ចសាលាជម្រះក្តីពិសេសលើរឿងក្តីលែងលះ រឿងក្តីអំពីបុគ្គភាព ដូចមានចែងនៅក្នុងមាត្រា ១០ ជាដើម ។

មាត្រានេះចែងអំពីវិធីដោះស្រាយ ចំពោះករណីនៃការរំលោភសមត្ថកិច្ចផ្តាច់មុខដែលបានកំណត់ដោយការព្រមព្រៀង ។ ក្រៅពីការចែងដូចមាត្រានេះ តាមបច្ចេកទេសនីតិកម្ម យើងក៏អាចយកបញ្ញត្តិដែលមិនទទួលស្គាល់នូវអានុភាពនៃការកំណត់សមត្ថកិច្ចផ្តាច់មុខ ដោយការព្រមព្រៀងបានដែរ ។ ប៉ុន្តែ ក្រមនេះមិនមានបញ្ញត្តិដូច្នោះទេ ។ ហើយក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ១៩ ( ការផ្ទេរដើម្បីជៀសវាងពីការយឺតយ៉ាវ ជាអាទិ៍ ) អានុភាពនៃការព្រមព្រៀងអំពីសមត្ថកិច្ចផ្តាច់មុខ ត្រូវបានកម្រិត និង មាត្រា ២០ នេះមិនយកមកអនុវត្តចំពោះករណីនេះ ។

Code of Civil Procedure (Japan)
**Article 20** (Restriction on transfer in case of exclusive jurisdiction)
The provisions of the preceding three articles shall not apply to a suit which falls under the exclusive jurisdiction (except as decided by agreement of the parties in accordance with the provisions of Article 11) of the court before which the suit is pending.

**មាត្រា ២១.-** បណ្តឹងជំទាស់

ចំពោះដីកាសម្រេចផ្ទេរ និង ដីកាសម្រេចលើកចោលពាក្យសុំផ្ទេរ អាចប្តឹងជំទាស់បាន ។

( កំណត់ )

មាត្រានេះមានអត្ថន័យដូចគ្នានឹងមាត្រា 21 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

មាត្រានេះសង្ឃឹមទៅលើការអនុវត្តសិទ្ធិត្រួតពិនិត្យនៃសាលាឧទ្ធរណ៍ ចំពោះការសម្រេចសេចក្តី ( អំពីការផ្ទេរ ) របស់តុលាការនៃការជំនុំជម្រះលើកទី ១ ។ ការកំណត់តុលាការដែលទទួលបន្ទុកការវិនិច្ឆ័យរឿងក្តី មានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងការងាយស្រួលក្នុងការតទល់និងការការពារខ្លួនក្នុងបណ្តឹង និង មានករណីខ្លះ អាចពាក់ព័ន្ធនឹងលទ្ធផលនៃបណ្តឹងក៏មានដែរ ហេតុដូច្នេះ ចាំបាច់កំណត់បញ្ញត្តិដូចមាត្រានេះ ។

Code of Civil Procedure (Japan)
**Article 21** (Immediate *kokoku*-appeal)
An immediate *kokoku*-appeal may be made against a ruling to transfer or a ruling having dismissed a motion of transfer.

**មាត្រា ២២.-** អានុភាពនៃដីកាសម្រេចផ្ទេរ ជាអាទិ៍

១- ដីកាសម្រេចស្ថាពរនៃការផ្ទេរ ត្រូវមានអានុភាពឱ្យតុលាការដែលទទួលការផ្ទេរប្រតិបត្តិតាម ។

២- តុលាការដែលបានទទួលការផ្ទេរ មិនអាចផ្ទេររឿងក្តីទៅតុលាការផ្សេងទៀតបានទេ ។

៣- នៅពេលដីកាសម្រេចផ្ទេរចូលជាស្ថាពរ បណ្តឹងនោះត្រូវចាត់ទុកថាតុលាការដែលទទួលការផ្ទេរ ចាត់ការតាំងពីដើម ។

៤- នៅពេលដីកាសម្រេចផ្ទេរចូលជាស្ថាពរ តុលាការដែលបានសម្រេចការផ្ទេរត្រូវបញ្ជូនសំណុំរឿងអំពីបណ្តឹងនេះ ទៅតុលាការដែលទទួលការផ្ទេរ ។

(កំណត់)

មាត្រានេះមានអត្ថន័យដូចគ្នានឹងមាត្រា 22 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ ចំពោះកថាខណ្ឌទី ៤ នេះ សូមមើល មាត្រា 9 នៃបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។

មានបញ្ហាមួយក្នុងករណីដែលតុលាការផ្ទេរបណ្តឹងដែលស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់ខ្លួន ទៅតុលាការផ្សេង ដោយមានកំហុស តើតុលាការផ្សេងដែលទទួលការផ្ទេរនេះ អាចផ្ទេរបណ្តឹងទៅតុលាការដែលមានសមត្ថកិច្ចផ្តាច់មុខវិញ ដោយមិនទទួលអានុភាពនៃដីកាសម្រេចផ្ទេរ ដែរឬទេ ? បញ្ហានេះ មានមតិផ្ទុយគ្នា នៅបណ្ឌិតសភានៅប្រទេសជប៉ុន ។ សព្វថ្ងៃនេះ មតិភាគច្រើនទទួលស្គាល់អានុភាពដែលធ្វើឱ្យតុលាការដែលទទួលការផ្ទេរប្រតិបត្តិតាមដីកាសម្រេចផ្ទេរ ។ មតិនេះ ផ្អែកលើគោលគំនិតមិនឱ្យផ្ទេរទៅវិញទៅមកច្រើនដង ។ ម្យ៉ាងទៀត មានមតិសំខាន់មួយទៀតដែលទទួលស្គាល់ លទ្ធភាពក្នុងការវិនិច្ឆ័យម្តងទៀត នៅក្នុងជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ និង បណ្តឹងសាទុក្ខ ។

Code of Civil Procedure (Japan)
**Article 22** (Binding effect of transfer decision)
1. A decision to transfer, which has become final and binding, shall be binding upon the court to which such suit has been transferred.
2. The court to which a suit has been transferred shall not transfer the suit further to another court.
3. When the decision to transfer has become final and binding, the suit shall be deemed to have been pending *ab initio* before the court to which it has been transferred.

Rules of Civil Procedure (Japan)
**Article 9** (Forwarding of record by transfer / The Code Article 22)
When the decision to transfer has become final and binding, the court clerk of the court which has rendered the decision to transfer, shall forward the record of the case to the court clerk of the court to which the case has been transferred.

## ផ្នែកទី ២ រចនាសម្ព័ន្ធនៃតុលាការ

**មាត្រា ២៣.-** ការជម្រះក្តីលើកទី ១ ដោយចៅក្រមមួយរូប ឬ ដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម (1)

១- នៅសាលាដំបូង រឿងក្តីត្រូវទទួលបន្ទុកដោះស្រាយដោយចៅក្រមម្នាក់ លើកលែងតែករណីដែលបានកំណត់ក្នុង កថាខណ្ឌទី ២ ខាងក្រោមនេះ ។(2)

២- ចំពោះរឿងក្តីខាងក្រោមនេះ ត្រូវទទួលបន្ទុកដោះស្រាយដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម :

**ក**- រឿងក្តីដែលកម្មវត្ថុនៃបណ្តឹងមានតម្លៃមិនតិចជាង ៥.០០០.០០០ (ប្រាំលាន) រៀល ហើយដែលតុលាការទទួលស្គាល់ថា គួរតែត្រូវបានវិនិច្ឆ័យនិងជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដោយគិតពិចារណាអំពីចំនួននៃគូភាគី និង បញ្ហាផ្សេងទៀត ។(3)

**ខ**- រឿងក្តីដែលច្បាប់កំណត់ថាត្រូវវិនិច្ឆ័យ និង ជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ។(4)

៣- ក្នុងក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដែលបានកំណត់ក្នុងបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវមានចៅក្រម ៣ (បី) នាក់ ហើយចាត់តាំងម្នាក់ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។(5)

៤- ដីកាសម្រេចឱ្យវិនិច្ឆ័យ និង ជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមដោយយោងតាមចំណុច **ក** នៃ កថាខណ្ឌទី ២ ខាងលើនេះ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សា ។

(កំណត់)

(1) ចំពោះសមាសភាពនៃការជម្រះក្តីនៃបណ្តឹងឧទ្ធរណ៍ (សាលាឧទ្ធរណ៍) និង ការជម្រះក្តីនៃបណ្តឹងសាទុក្ខ (តុលាការកំពូល) សេចក្តីព្រាងច្បាប់ស្តីពីការចាត់តាំងតុលាការនៃព្រះរាជាណាចក្រកម្ពុជា កំណត់អំពីចំនួនចៅក្រម ក្នុងក្រុមប្រឹក្សាជំនុំជម្រះ និង កំណត់សមាសភាពតាមសភានីមួយៗ ដូចជាសភារដ្ឋប្បវេណីនិងសង្គម សភាព្រហ្មទណ្ឌ សភាពាណិជ្ជកម្ម ជាដើម ។ ហេតុដូច្នេះ ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនេះ យើងកំណត់តែក្រុមប្រឹក្សាជំនុំជម្រះរឿងក្តីរដ្ឋប្បវេណីនៃតុលាការនៃការជំនុំជម្រះលើកទី ១ តែប៉ុណ្ណោះ ។

(2) មាត្រានេះយកជាមូលដ្ឋានពីមាត្រា 26 នៃច្បាប់ស្តីពីការចាត់តាំងតុលាការនៃប្រទេសជប៉ុន ។ ម្យ៉ាងទៀត នៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីការចាត់តាំងតុលាការនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៧ វាក្យខណ្ឌទី ១ នៃជំពូកទី ៤ កំណត់ថា "សាលាដំបូង សម្រេចក្តីដោយមានចៅក្រមតែម្នាក់គត់" ប៉ុន្តែ កថាខណ្ឌទី ២ នៃមាត្រា ១ នេះ គឺជាករណីលើកលែង នៃមាត្រា ៣៧ វាក្យខណ្ឌទី ១ នៃសេចក្តីព្រាងច្បាប់ស្តីពីការចាត់តាំងតុលាការ ហេតុដូច្នេះ គួរតែថែមល័ក្ខខ័ណ្ឌ "លើកលែងតែក្នុងករណីដែលមានចែងក្នុងច្បាប់ផ្សេង" ជាការប្រសើរ ។ ជាឧទាហរណ៍ជាក់ស្តែង ចំពោះរឿងក្តីព្រហ្មទណ្ឌ មាត្រា ៣៧ កថាខណ្ឌទី ៣ នៃសេចក្តីព្រាងច្បាប់ស្តីពីការចាត់តាំងតុលាការនោះ មានកំណត់ថា "នៅក្នុងរឿងក្តីឧក្រិដ្ឋ សាលាដំបូងសម្រេចសេចក្តី ដោយមានចៅក្រមបីនាក់" ។

(3) នេះគឺជារឿងក្តីដែលត្រូវបានជំនុំជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះ ដោយឆន្ទានុសិទ្ធិ ។ កថាខណ្ឌនេះមានគោលបំណងឱ្យតុលាការអាចសម្រេចដោយឆន្ទានុសិទ្ធិខ្លួនបាន នូវការជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះចំពោះរឿងក្តីដែលកម្មវត្ថុនៃបណ្តឹងមានតម្លៃលើសពី ៥.០០០.០០០ រៀល (ប្រាំលានរៀល) (មាត្រា ៦០ (ការគណនាតម្លៃកម្មវត្ថុនៃបណ្តឹង ការគណនាតម្លៃក្នុងករណីបណ្តឹងទាមទារច្រើនចំណុច)) និង ដែលមានភាពស្មុគស្មាញ ។ ការសម្រេចជ្រើសរើសយកការជម្រះក្តីដោយក្រុមប្រឹក្សានេះ ត្រូវសម្រេចដោយក្រុមប្រឹក្សាដែរ ។

(4) នេះគឺជារឿងក្ដីដែលច្បាប់កំណត់ថាជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ។ ជាឧទាហរណ៏ ដូចជាករណីដែលមានកំណត់ក្នុងមាត្រា ៣០ (ការសម្រេចសេចក្ដីអំពីពាក្យសុំដកហូត ឬ បណ្ដឹងជិតចិត្ត) កថាខណ្ឌទី ១ ឬ មាត្រា ៩១ (បណ្ដឹងតវ៉ាចំពោះការដឹកនាំនីតិវិធីបណ្ដឹង) (គឺជាករណីដែលភាគីប្ដឹងតវ៉ាចំពោះការដឹកនាំនីតិវិធីបណ្ដឹងដោយក្រុមប្រឹក្សាជំនុំជម្រះ) នៃក្រមនីតិវិធីរដ្ឋប្បវេណីនេះដែរ ។ ម្យ៉ាងទៀត ករណីដែលបង្កើត តុលាការជំនាញពិសេស ដូចជាតុលាការពាណិជ្ជកម្ម ហើយជំនុំជម្រះ និង ចេញសាលក្រម ចំពោះការជំនុំជម្រះលើកទី ១ គឺជាឧទាហរណ៏មួយនៃចំណុច **៩** កថាខណ្ឌទី ២ នៃមាត្រានេះដែរ ។

(5) របៀបជ្រើសតាំងចៅក្រមនៃក្រុមប្រឹក្សា និង ចាត់តាំងប្រធានក្រុមប្រឹក្សានោះ ត្រូវបានកំណត់ជាមុនដោយស្ថាប័នរដ្ឋណាដែលសមរម្យ ។ នៅប្រទេសជប៉ុន តុលាការកំពូលបានកំណត់ "បទប្បញ្ញត្តិស្ដីពីវិធានការចាត់ចែងការងារក្នុងតុលាការជាន់ទាប" ហើយតាមបទប្បញ្ញត្តិនេះ តុលាការខេត្តក៏មានសភាដែរ និង តុលាការចាត់ចែងចៅក្រមនៅសភានីមួយៗឱ្យមានចំនួនចៅក្រមល្មមដើម្បីបង្កើតក្រុមប្រឹក្សាជំនុំជម្រះ ហើយក្នុងចំណោមនេះមានចៅក្រមម្នាក់ជាអ្នកទទួលខុសត្រូវនូវការចាត់ចែងការងារក្នុងសភានោះ (ប្រធានសភា) ។ រីឯក្រុមប្រឹក្សាជំនុំជម្រះវិញ ត្រូវបានបង្កើតដោយចៅក្រមក្នុងសភា ហើយប្រធានសភាត្រូវធ្វើជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

<u>Court Organization Law (Japan)</u>
**Article 26** (Single judge and collegiate court systems) (excerpt)
1. A District Court shall, except in the cases prescribed in paragraph 2, handle cases through a single judge.
2. The following cases shall be handled by a collegiate court of judges; however, if there are special provisions contrary to the above in other laws, such provisions shall apply, unless they are connected with hearing or decision to be made by the court:
i. Cases in which a collegiate court has made a ruling to the effect that it will conduct hearing and render decisions by a collegiate court;
ii. Cases regarding offenses liable to capital punishment, penal servitude or imprisonment for life or for a minimum period not less than one year (except offenses or attempts thereof mentioned in..............);
iii. Cases of appeals (koso) from the judgements rendered by Summary Courts or complaints against the rulings and orders of Summary Courts;
iv. Other cases which, as elsewhere provided for by law, are to be heard and decided through a collegiate court.
3. The number of judges of a collegiate court mentioned in the preceding paragraph shall be three, one of whom shall be the presiding judge thereof.

## **មាត្រា ២៤.~** ការពិភាក្សានៃក្រុមប្រឹក្សាជំនុំជម្រះ

១- ការពិភាក្សានៃក្រុមប្រឹក្សាជំនុំជម្រះមិនត្រូវបានធ្វើជាសាធារណៈទេ ។

២- ការពិភាក្សាត្រូវបានបើក និង ដឹកនាំដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

៣- ចៅក្រមម្នាក់ៗត្រូវបញ្ចេញមតិយោបល់របស់ខ្លួនក្នុងការពិភាក្សានេះ ។

៤- ដំណើរការនៃការពិភាក្សា មតិយោបល់របស់ចៅក្រមម្នាក់ៗ និង ចំនួនសំឡេងនៃមតិ ត្រូវរក្សាទុកជាសម្ងាត់ ។

(កំណត់)

សូមមើលមាត្រា 75 និង 76 នៃច្បាប់ស្ដីពីការចាត់តាំងតុលាការនៃប្រទេសជប៉ុន ។

Court Organization Law (Japan)
**Article 75** (Secrecy of deliberation)
1. The deliberation of decisions in a collegiate court shall not take place in public; however, the presence of judicial apprentices may be permitted.
2. Deliberation shall be begun and regulated by the presiding judge. Except as otherwise provided for in this law, strict secrecy shall be observed in respect of the proceedings of deliberation, the opinion of each judge and the number of opinions.
**Article 76** (Duty to express opinions)
Judges shall express their opinions in deliberations.

**មាត្រា ២៥.-** ការសម្រេចនៃក្រុមប្រឹក្សាជំនុំជម្រះ

១- ការសម្រេចត្រូវធ្វើឡើងដោយមតិភាគច្រើនរបស់ចៅក្រមក្នុងក្រុមប្រឹក្សាជំនុំជម្រះ ។ (1)

២- ចៅក្រមម្នាក់ៗក្នុងក្រុមប្រឹក្សាជំនុំជម្រះនេះ ត្រូវមានសិទ្ធិសម្រេចស្មើគ្នា ។

(កំណត់)

(1) សូមមើលមាត្រា 77 កថាខណ្ឌទី 1 នៃច្បាប់ស្តីពីការចាត់តាំងតុលាការនៃប្រទេសជប៉ុន ។

Court Organization Law (Japan)
**Article 77** (Decision) (excerpt)
1. Except in cases where the Supreme Court has enacted special regulations in relation to Supreme Court decision, decisions shall be rendered by a majority of opinions.

## ផ្នែកទី ៣ ការបែងចែករឿងក្តី និង ការដកហូតសមត្ថកិច្ចជំនុំជម្រះ និង បណ្តឹងជំទាស់

**មាត្រា ២៦.-** ការបែងចែករឿងក្តី

១- ការបែងចែករឿងក្តីនៅតុលាការមួយ និង លំដាប់សម្រាប់ជំនួសក្នុងករណីដែលចៅក្រមណាម្នាក់មានធុរៈ ត្រូវកំណត់ទុកជាមុនជារៀងរាល់ឆ្នាំដោយដីកាសម្រេចរបស់ប្រធានតុលាការនោះ ។

២- រឿងក្តីនីមួយៗត្រូវបានបែងចែកឱ្យចៅក្រមម្នាក់ៗទទួលបន្ទុកជាស្វ័យប្រវត្តិ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

៣- ការបែងចែករឿងក្តីនៅតុលាការមួយ និង លំដាប់សម្រាប់ជំនួសក្នុងករណីដែលចៅក្រមណាម្នាក់មានធុរៈដែលត្រូវបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចត្រូវប្តូរក្នុងឆ្នាំនោះបានឡើយ លើកលែងតែក្នុងករណីដែលចៅក្រមណាម្នាក់មានការងារច្រើនពេក ឬ ករណីដែលចៅក្រមត្រូវឈប់ ឬ ប្តូរទៅតុលាការផ្សេង ឬ ករណីដែលចៅក្រមបន្តមានធុរៈ ដោយសារហេតុផលដូចជាត្រូវឈប់សម្រាកក្នុងរយៈពេលវែង ជាអាទិ៍ ។ ការប្តូរចំពោះករណីនេះត្រូវកំណត់ដោយដីកាសម្រេចរបស់ប្រធានតុលាការ ។

(កំណត់)

មាត្រានេះកំណត់អំពីគោលការណ៍ក្នុងការបែងចែករឿងក្តីនៅតុលាការ (នៅប្រទេសជប៉ុន មានបញ្ញត្តិដែលមានអត្ថន័យដូចគ្នា នៅក្នុងបទប្បញ្ញត្តិស្តីពីវិធានការចាត់ចែងការងារក្នុងតុលាការជាន់ទាប ដែលបានកំណត់ដោយតុលាការកំពូល) ។ កថាខណ្ឌទី ១ ចែងអំពីរបៀបបែងចែករឿងក្តី និង របៀបជំនួសពេលណាមានចៅក្រមណាម្នាក់ មិនអាចបំពេញមុខងារដោយសារមានជម្ងឺជាដើម ដែលបានកំណត់ជាវិធានការមួយដែលកំណត់ជារៀងរាល់ឆ្នាំ ក្នុងកិច្ចការរដ្ឋបាលនៃអំណាចតុលាការ ។ ប្រសិនបើតុលាការចាត់តាំងចៅក្រមទទួលបន្ទុក បន្ទាប់ពីពេលទទួលបណ្តឹងនីមួយៗ ការសម្រេចចាត់តាំងនោះ នឹងអាចមានការលំអៀង ហេតុដូច្នេះ ការបែងចែករឿងក្តីឱ្យចៅក្រមទទួលបន្ទុកជាស្វ័យប្រវត្តិ តាមរបៀបដែលបានកំណត់ទុកជាមុន (កថាខណ្ឌទី ២) នាំឱ្យតុលាការអាចរក្សាអព្យាក្រិតភាព ។ ប៉ុន្តែ មានករណីខ្លះ ដែលមិនអាចរក្សាធ្វើតាមរបៀបបែងចែករឿងក្តីបាន ដោយសារមូលហេតុដែលមិនអាចស្មានទុកជាមុនបាន (ដូចជា ការផ្តុំការងារទៅលើចៅក្រមណាម្នាក់ ការឈប់ ឬ ការផ្លាស់ប្តូរនៃចៅក្រម ការឈប់សម្រាកក្នុងរយៈពេលវែង ជាដើម) តុលាការអាចប្តូរបាន ប៉ុន្តែ ក្នុងករណីនេះដែរ តុលាការមិនត្រូវប្តូរតាមរឿងក្តីនីមួយៗទេ តែត្រូវប្តូរតាមវិធានការរដ្ឋបាលនៃអំណាចតុលាការ ដូចដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ដែរ ។ម្យ៉ាងទៀត ក្នុងករណីដែលមានការដកហូត ឬ ការជិតចិត្ត តាមបញ្ញត្តិចាប់ពីមាត្រា ២៧ (ការដកហូតចៅក្រមពីសមត្ថកិច្ចជំនុំជម្រះ) ទៅ ការចាត់តាំងចៅក្រមត្រូវបានអនុវត្ត តាមលំដាប់សម្រាប់ជំនួសដែលបានកំណត់ក្នុងបញ្ញត្តិនៃកថាខណ្ឌទី ១ ។

**មាត្រា ២៧.-** ការដកហូតចៅក្រមពីសមត្ថកិច្ចជំនុំជម្រះ

១- ចៅក្រមត្រូវដកហូតពីការអនុវត្តមុខការរបស់ខ្លួន ក្នុងករណីដែលបានកំណត់ដូចខាងក្រោមនេះ :

- **ក**- កាលណាចៅក្រម ឬ សហព័ទ្ធរបស់ចៅក្រម ឬ អតីតសហព័ទ្ធរបស់ចៅក្រមជាភាគីណាមួយក្នុងរឿងក្តី ។
- **ខ**- កាលណាចៅក្រមជាញាតិលោហិតក្នុងថ្នាក់ទី ៦ (ប្រាំមួយ) ឬ ញាតិពន្ធក្នុងថ្នាក់ទី ៣ (បី) ឬ អតីតញាតិពន្ធក្នុងថ្នាក់ទី ៣ (បី) របស់ភាគីណាមួយ ។
- **គ**- កាលណាចៅក្រមជាអ្នកអាណាព្យាបាលរបស់ភាគីណាមួយ ។
- **ឃ**- កាលណាចៅក្រមដែលទទួលបន្ទុករឿងក្តី ធ្លាប់ ឬ កំពុងមានវិវាទនៅតុលាការជាមួយភាគីណាមួយ ។
- **ង**- កាលណាចៅក្រមបានធ្វើជាសាក្សី ឬ ធ្វើជាអ្នកជំនាញក្នុងរឿងក្តី ។
- **ច**- កាលណាចៅក្រមជាអ្នកតំណាង ឬ ធ្លាប់ជាអ្នកតំណាង ឬ ជាអ្នកជំនួយឱ្យភាគីចំពោះរឿងក្តី ។
- **ឆ**- កាលណាចៅក្រមបានចូលរួមក្នុងការសម្រេចសេចក្តីមជ្ឈត្តករចំពោះរឿងក្តី ឬ បានចូលរួមក្នុងការសម្រេចសេចក្តីនៅក្នុងការជំនុំជម្រះលើកទី ១ ដែលបានឧបាស្រ័យ ឬ ការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ដែលបានឧបាស្រ័យ ឬ បង្ហាញមតិយោបល់ណែនាំផ្នែកច្បាប់ ចំពោះរឿងក្តី ។

២- ក្នុងករណីដូចមានមូលហេតុនៃការដកហូត ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវសម្រេច

សេចក្តីអំពីការដកហូតនោះ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

( កំណត់)

សូមមើលមាត្រា 23 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

មាត្រានេះកំណត់អំពីការដកហូតចៅក្រមមិនឱ្យអនុវត្តមុខងាររបស់ខ្លួនជាស្វ័យប្រវត្តិ ក្នុងករណីដែលមានមូលហេតុមួយចំនួនដែលបានកំណត់ ។ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីប្រទេសណាក៏ដូចគ្នាដែរ ក្នុងការកំណត់អំពីការដកចៅក្រមមិនឱ្យទទួលបន្ទុករឿងក្តីណាមួយ ប្រសិនបើមានការសង្ស័យអំពីយុត្តិធម៌ និង អព្យាក្រិតភាពរបស់ចៅក្រមដែលបានចាត់ការរឿងក្តីនោះ ។ ប្រទេសមួយចំនួនដូចជា អាមេរិក ជាដើម មានកំណត់តែបណ្តឹងជិតចិត្តដែលបានកំណត់ខាងក្រោយនេះប៉ុន្តែ ការដកហូតជារបបមួយដែលអាចសម្រេចឱ្យបានស្រួល ដោយសារកំណត់អំពីការដកចៅក្រមជាស្វ័យប្រវត្តិ ចំពោះករណីដែលកើតឡើងជាញឹកញាប់ ( មាត្រា 41 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសអាឡឺមង់, មាត្រា 20 នៃច្បាប់ស្តីពីយុត្តាធិការជំនុំជម្រះនៃប្រទេសអូទ្រីស, មាត្រា 51 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសអ៊ីតាលី, មាត្រា 341 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសបារាំង ជាដើម) ។ កថាខណ្ឌទី ១ ចំណុច **ក** ដល់ **ឃ** កំណត់អំពីមូលហេតុដែលទាក់ទងនឹងទំនាក់ទំនងរវាងចៅក្រមនិងភាគីនៃរឿងក្តី (ចំណុច **ឃ** កំណត់អំពីករណីដែលចៅក្រមចូលរួមក្នុងរឿងក្តីជាភាគីម្ខាងក្នុងនាមជាបុគ្គលឯកជនមួយ) រីឯចំណុច **ខ** ដល់ **ឆ** កំណត់អំពីមូលហេតុដែលទាក់ទងនឹងរឿងក្តី ។ កថាខណ្ឌទី ២ មានគោលបំណងដើម្បីបញ្ជាក់ការដកហូតឱ្យបានច្បាស់លាស់ ដោយសម្រេចការដកហូតតាមការជម្រះក្តី ។ បើយកបញ្ញត្តិនៃមាត្រានេះ យើងចាំបាច់ត្រូវកែតម្រូវបញ្ញត្តិនៃមាត្រា ៩៣ នៃសេចក្តីព្រាងច្បាប់ស្តីពីការចាត់តាំងតុលាការ ដើម្បីឱ្យមានភាពស្របគ្នានឹងក្រមនេះ ដោយបន្ថែមពាក្យ ដូចជា "លើកលែងតែករណីដែលច្បាប់ផ្សេងបានកំណត់ផ្សេង" ។

Code of Civil Procedure (Japan)
**Article 23** (Exclusion of judge)
Judges shall be excluded from the exercise of their functions in the following cases. However in the cases prescribed by item vi, such judges shall not be precluded from acting as appointed judges at the request of another court.
i. when the judge or the spouse or former spouse of such judge is a party to the case, or a co-obligee or a co-obligor with a party to the case, or a person bound to make a reimbursement to a party to the case
ii. when the judge is or was related within the fourth degree of consanguinity, or is or was related by affinity within the third degree of relationship to a party, or is or was a relative of a party with whom such judge resides or resided
iii. when the judge is the guardian, supervisor of guardianship, or curator of a party
iv. when the judge has acted as a witness or an expert in the case
v. when the judge is or was the representative of or an assistant to a party in the case
vi. when the judge participated in an arbitration award in the case or in the decision of the previous instance against which an appeal has been made
2. In cases where there is cause for exclusion prescribed by the preceding paragraph, the court shall, upon motion or upon its own authority, render a decision of exclusion.

Code of Civil Procedure Rules (Germany)
**Article 41** (Exclusion from exercising judicial power)
A judge is excluded from the exercise of his judicial functions by virtue of the law:
i. in matters in which he is a party or in which he stands in capacity of a co-interested party, joint debtor or a party liable to recourse;
ii. in matters concerning his spouse, also when the mariage no longer subsists;
iii. in matters concerning a person who is his direct relative or is a relative in the collateral line up to the third degree or is or was a relative by marriage up to the second degree;
iv. in matters in which he was apointed as counsel or advisor of one of the parties or he is or was authorized to appear as the legal

representative of a party;
v. in matters in which he is called upon to be a witness or expert;
vi. in matters in which he collaborated in a previous instance or in an arbitration proceeding regarding the issuance of the contested decision, insofar as it does not refer to the activity or an appointed or petitioned judge.

Code de Procédure Civile (France)
**Article 341**
La récusation d'un juge n'est admise que pour les causes déterminées par la loi.
(Décr. n° 78-330 du 16 mars 1978) Comme il est dit à l'article L.731-1 du Code de l'organisation judiciare «sauf dispositions particulières à certaines jurisdictions la récusation d'un juge peut être demandée :
«1° Si lui-même ou son conjoint a un intérêt personnel à la contestation ;
«2° Si lui-même ou son conjoint est créancier, débiteur, héritier présomptif ou donataire de l'une des parties ;
«3 ° Si lui-même ou son conjoint est parent ou allié de l'une des parties ou de son conjoint jusqu'au quatrième degré inclusivement ;
«4° S'il y a eu ou s'il y a procès entre lui ou son conjoint et l'une des parties ou son conjoint ;
«5° S'il a précédemment connu de l'affaire comme juge ou comme arbitre ou s'il a conseillé l'une des parties ;
«6° Si le juge ou son conjoint est chargé d'administrer les biens de l'une des parties ;
«7° S'il existe un lien de subordination entre le juge ou son conjoint et l'une des parties ou son conjoint ;
«8° S'il y a amitié ou inimitié notoire entre le juge et l'une des parties ;
«Le ministère public, partie jointe, peut être récusé dans les mêmes cas.»

Codice di Procedura Civile (Italy)
**Art. 51** Astensione del giudice
Il giudice ha l`obbligo di astenersi (78 att.):
1) se ha interesse nella causa o in altra vertente su identica questione di diritto;
2) se egli stesso o la moglie è parente fino al quarto grado (Cod. Civ. 74 e seguenti) o legato da vincoli di affiliazione (Cod. Civ. 404 e seguenti) o è convivente o commensale abituale di una delle parti o di alcuno dei difensori;
3) se egli stesso o la moglie ha causa pendente o grave inimicizia o rapporti di credito o debito con una delle parti o alcuno dei suoi difensori;
4) se ha dato consiglio o prestato patrocinio (82) nella causa, o ha deposto in essa come testimone, oppure ne ha conosciuto come magistrato in altro grado del processo o come arbitro (810) o vi ha prestato assistenza come consulente tecnico (61);
5) se è tutore (Cod. Civ. 343 e seguenti), curatore (Cod. Civ. 392), procuratore, agente o datore di lavoro di una delle parti se, inoltre, è amministratore o gerente di un ente, di un`associazione anche non riconosciuta (Cod. Civ. 36 e seguenti), di un comitato (Cod. Civ. 39), di una società (Cod. Civ. 2247 e seguenti) o stabilimento che ha interesse nella causa.
In ogni altro caso in cui esistono gravi ragioni di convenienza, il giudice può richiedere al capo ufficio l`autorizzazione ad astenersi; quando l`astensione riguarda il capo dell`ufficio, l`autorizzazione è chiesta al capo dell`ufficio superiore.

**មាត្រា ២៨.-** បណ្តឹងជំទាស់ចៅក្រម

១- ក្នុងករណីដែលមានកាលៈទេសៈដែលបណ្តាលឱ្យមានការលំអៀងក្នុងការជម្រះក្តី ចំពោះចៅក្រមណាម្នាក់ នោះភាគីអាចប្តឹងជំទាស់ចៅក្រមនោះបាន ។

២- ក្នុងករណីដែលភាគីបានឆ្លើយទាញហេតុផលចំពោះមុខចៅក្រម ឬ បានធ្វើសេចក្តីដោះសានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលចំពោះមុខចៅក្រមរួចហើយ នោះភាគីមិនអាចប្តឹងជំទាស់ចៅក្រមនោះបានឡើយ ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីនោះមិនបានដឹងអំពីមូលហេតុដែលអាចប្តឹងជំទាស់ ឬ ករណីដែលមូលហេតុនៃបណ្តឹងជំទាស់បានកើតឡើងនៅពេលក្រោយ ។

(កំណត់)

សូមមើលមាត្រា 24 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

មាត្រានេះ កំណត់អំពីបណ្តឹងជំទាស់ចៅក្រមមិនឱ្យអនុវត្តមុខងាររបស់ខ្លួន ក្នុងករណីដែលមាន "កាលៈទេសៈដែលបណ្តាលឱ្យមានការលំអៀងក្នុងការជម្រះក្តី" ទោះបីជាគ្មានមូលហេតុដែលបានកំណត់ក្នុងមាត្រា ២៧ (ការដកហូត

ចៅក្រមពីសមត្ថកិច្ចជំនុំជម្រះ) ក៏ដោយ ។ យើងមិនអាចរៀបរាប់មូលហេតុនៃការដកហូតទាំងអស់បានទេ ហេតុដូច្នេះ ដើម្បីបំពេញចន្លោះនេះ របបបណ្តឹងជិតចិត្តនេះត្រូវតែមានជាចាំបាច់ (មាត្រា 42 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសអាល្លឺម៉ង់ មាត្រា 21 នៃច្បាប់ស្តីពីសមត្ថកិច្ចជម្រះក្តីនៃប្រទេសអូទ្រីស និង ជំពូកទី 28 មាត្រា 144 នៃក្រមសហរដ្ឋអាមេរិក (United States Code) ជាដើម) ។ មូលហេតុនៃបណ្តឹងជិតចិត្តនេះ មានលក្ខណៈអរូបី ពីព្រោះកំណត់តែកាលៈទេសៈដែលបណ្តាលឱ្យមានការលំអៀង ក្នុងការជម្រះក្តី ។ ករណីជាក់ស្តែង គឺករណីដែលចៅក្រមជាមិត្តស្និទ្ធស្នាលនឹងភាគីណាម្នាក់ ឬ ជាសត្រូវ ឬ ករណីដែលចៅក្រមមានការទាក់ទងនឹងផលប្រយោជន៍ផ្នែកទ្រព្យសម្បត្តិក្នុងរឿងក្តីនោះ (ដូចជាករណីដែលចៅក្រមជាម្ចាស់ហ៊ុនចម្បងនៃក្រុមហ៊ុនរបស់ភាគីណាមួយ ជាដើម) ។ល។ ប៉ុន្តែ ជាគោលការណ៍ ចំពោះការចាត់ចែងដឹកនាំនីតិវិធីវិញ ភាគីមិនអាចយកមកធ្វើជាមូលហេតុនៃបណ្តឹងជិតចិត្តបានទេ ។ ម្យ៉ាងទៀត បញ្ញត្តិនៃកថាខណ្ឌទី ២ មានគោលបំណងកំណត់នូវពេលវេលាដើម្បីប្តឹងជិតចិត្ត ដែលត្រូវធ្វើមុនពេលចាប់ផ្តើមការវិនិច្ឆ័យនូវអង្គសេចក្តី ពីព្រោះប្រសិនបើឱ្យសិទ្ធិប្តឹងជិតចិត្តពេលណាក៏បានដែរនោះ នឹងអាចធ្វើឱ្យមានភាពស្មុគស្មាញក្នុងនីតិវិធី (លើកលែងតែចំពោះករណីដែលភាគីនោះ មិនបានដឹងអំពីមូលហេតុដែលអាចប្តឹងជិតចិត្ត ឬ ករណីដែលមូលហេតុនៃបណ្តឹងជិតចិត្តបានកើតឡើងនៅពេលក្រោយ ដោយសារគ្មានលទ្ធភាពប្តឹងមុន) ។

Code of Civil Procedure (Japan)
**Article 24** (Challenge of judge)
1. Any party may challenge a judge in cases where there are circumstances regarding to the judge which would obstruct the impartiality of the judge's decision.
2. A party who has proceeded orally or has made a statement in the preparations for argument proceedings before the judge, may not challenge such judge. However, this shall not apply in cases where the existence of the cause for challenge was unknown to the party, or where the cause for challenge has arisen thereafter.

Code of Civil Procedure Rules (Germany)
**Article 42** (Challenge of a judge)
1. A judge may be challenged on the ground of apprehension of prejudice as well as in the cases in which he is excluded from the exercise of judicial functions by law.
2. The challenge on account of apprehension of prejudice is allowable if there is cause that is appropriate to justify distrust with respect to the impartiality of a judge.
3. Both parties have the right of challenge in every case.

United States Code (United States)
**Title 28, Article 144** (Bias or prejudice of judge)
Whenever a party to any proceeding in a district court makes and files a timely and sufficient affidavit that the judge before whom the matter is pending has a personal bias or prejudice either against him or in favor of any adverse party, such judge shall proceed no further therein, but another judge shall be assigned to hear such proceeding.
The affidavit shall state the facts and the reasons for the belief that bias or prejudice exists, and shall be filed not less than ten days before the beginning of the term at which the proceeding is to be heard, or good cause shall be shown for failure to file it within such time. A party may file only one such affidavit in any case. It shall be accompanied by a certificate of counsel of record stating that it is made in good faith.

## **មាត្រា ២៩.-** ការដកខ្លួនរបស់ចៅក្រម

ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៧ (ការដកហូតចៅក្រមពីសមត្ថកិច្ចជំនុំជម្រះ) ឬ កថាខណ្ឌទី ១ នៃមាត្រា ២៨ (បណ្តឹងជិតចិត្តចៅក្រម) នៃក្រមនេះ ចៅក្រមអាចដកខ្លួនបាន ដោយទទួលការអនុញ្ញាតពី

ប្រធានតុលាការដែលខ្លួនស្ថិតនៅក្រោម ។

（កំណត់）

សូមមើលមាត្រា 12 នៃបទប្បញ្ញត្តិនៃនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

ប្រទេសភាគច្រើនមានរបបដកខ្លួនដែលឱ្យចៅក្រមឈប់ជំនុំជម្រះដោយខ្លួនឯង ដោយមានការអនុញ្ញាតពីតុលាការដែលចៅក្រមនោះស្ថិតនៅក្រោម ប្រសិនបើចៅក្រមនោះយល់ឃើញថាមានមូលហេតុនៃការដកហូតសមត្ថកិច្ចជំនុំជម្រះ ឬ បណ្ដឹងជំទាស់ចិត្ត（មាត្រា 48 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសអាល្លឺម៉ង់, មាត្រា 339 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសបារាំង, ជំពូកទី 28 មាត្រា 455 នៃក្រមសហរដ្ឋអាមេរិក（United States Code）ជាដើម）។ ប៉ុន្តែរបបនេះអាចធ្វើឱ្យវិធីបែងចែករឿងក្ដីដែលបានកំណត់នៅក្នុងមាត្រា ២៦（ការបែងចែករឿងក្ដី） ក្លាយទៅជាគ្មានខ្លឹមសារទៅវិញ ដោយសារចៅក្រមដកខ្លួនដោយចេតនា ឬ ដកខ្លួនដោយងាយស្រួលមិនវិនិច្ឆ័យឱ្យហ្មត់ចត់ នៅពេលណាមានបណ្ដឹងជំទាស់ចិត្តពីភាគី ។ ហេតុដូច្នេះ ប្រធានតុលាការត្រូវសម្រេចអំពីអត្ថិភាពនៃមូលហេតុនៃការដកហូត ឬ ហេតុដែលអាចប្ដឹងជំទាស់ចិត្ត ដោយហ្មត់ចត់ ។

<u>Rules of Civil Procedure (Japan)</u>
**Article 12** (Withdrawal of judge)
In the cases prescribed by Article 23 (Exclusion of judge), paragraph 1 or Article 24 (Challenge of judge), paragraph 1 of the Code, a judge may withdraw with the permission of the court which has authority to supervise him or her.

<u>Code of Civil Procedure Rules (Germany)</u>
**Article 48** (Self-exclusion; decision of exclusion)
1. The court competent to deal with a petition of challenge shall also decide when such a petition is not presented, but a judge puts forward information concerning a relationship which would justify his challenge or if doubt arises for othere reasons concerning whether or not a judge would be disqualified pursuant to law.
2. The decision is made without hearing the parties.

<u>Code de procédure civile (France)</u>
**Article 339** (L'abstention)
Le juge qui suppose en sa personne une cause de récusation ou estime en conscience devoir s'abstenir se fait remplacer par un autre juge que désigne le président de la jurisdiction à laquelle il appartient. Le remplaçant d'un juge d'instance est désigné par le président du tribunal de grande instance à défaut de juge ditecteur.

<u>United States Code (United States)</u>
**Title 28, Article 455** (Disqualification of justice, judge, or magistrate judge)
(a) Any justice, judge, or magistrate judge of the United States shall disqualify himself in any proceeding in which his impartiality might reasonably be questioned.
(b) He shall also disqualify himself in the following circumstances:
(1) Where he has a personal bias or prejudice concerning a party, or personal knowledge of disputed evidentiary facts concerning the proceeding;
(2) Where in private practice he served as lawyer in the matter in controversy, or a lawyer with whom he previously practiced law served during such association as a lawyer concerning the matter, or the judge or such lawyer has been a material witness concerning it;
(3) Where he has served in governmental employment and in such capacity participated as counsel, adviser or material witness concerning the proceeding or expressed an opinion concerning the merits of the particular case in controversy;
(4) He knows that he, individually or as a fiduciary, or his spouse or minor child residing in his household, has a financial interest in the subject matter in controversy or in a party to the proceeding, or any other interest that could be substantially affected by the outcome of the proceeding;
(5) He or his spouse, or a person within the third degree of relationship to either of them, or the spouse of such a person:
(i) Is a party to the proceeding, or an officer, director, or trustee of a party;
(ii) Is acting as a lawyer in the proceeding;

(iii) Is known by the judge to have an interest that could be substantially affected by the outcome of the proceeding;
(iv) Is to the judge’s knowledge likely to be a material witness in the proceeding.

(c) A judge should inform himself about his personal and fiduciary financial interests, and make a reasonable effort to inform himself about the personal financial interests of his spouse and minor children residing in his household.

(d) For the purposes of this section the following words or phrases shall have the meaning indicated:

(1) “proceeding” includes pretrial, trial, appellate review, or other stages of litigation;
(2) the degree of relationship is calculated according to the civil law system;
(3) “fiduciary” includes such relationships as executor, administrator, trustee, and guardian;
(4) “financial interest” means ownership of a legal or equitable interest, however small, or a relationship as director, adviser, or other active participant in the affairs of a party, except that:

(i) Ownership in a mutual or common investment fund that holds securities is not a “financial interest” in such securities unless the judge participates in the management of the fund;
(ii) An office in an educational, religious, charitable, fraternal, or civic organization is not a “financial interest” in securities held by the organization;
(iii) The proprietary interest of a policyholder in a mutual insurance company, of a depositor in a mutual savings association, or a similar proprietary interest, is a “financial interest” in the organization only if the outcome of the proceeding could substantially affect the value of the interest;
(iv) Ownership of government securities is a “financial interest” in the issuer only if the outcome of the proceeding could substantially affect the value of the securities.

(e) No justice, judge, or magistrate judge shall accept from the parties to the proceeding a waiver of any ground for disqualification enumerated in subsection (b). Where the ground for disqualification arises only under subsection (a), waiver may be accepted provided it is preceded by a full disclosure on the record of the basis for disqualification.

(f) Notwithstanding the preceding provisions of this section, if any justice, judge, magistrate judge, or bankruptcy judge to whom a matter has been assigned would be disqualified, after substantial judicial time has been devoted to the matter, because of the appearance or discovery, after the matter was assigned to him or her, that he or she individually or as a fiduciary, or his or her spouse or minor child residing in his or her household, has a financial interest in a party (other than an interest that could be substantially affected by the outcome), disqualification is not required if the justice, judge, magistrate judge, bankruptcy judge, spouse or minor child, as the case may be, divests himself or herself of the interest that provides the grounds for the disqualification.

**មាត្រា ៣០.-** ការសម្រេចសេចក្ដីអំពីពាក្យសុំដកហូត ឬ បណ្ដឹងជិតចិត្ត

១- ចំពោះការដកហូតចៅក្រម ឬ បណ្ដឹងជិតចិត្តចំពោះចៅក្រម ក្រុមប្រឹក្សាជំនុំជម្រះនៅតុលាការដែលចៅក្រមនោះស្ថិតនៅក្រោម ត្រូវសម្រេចសេចក្ដី ដោយដីកាសម្រេច ។

២- ចៅក្រមមិនអាចចូលរួមក្នុងការសម្រេចសេចក្ដីអំពីការដកហូត ឬ បណ្ដឹងជិតចិត្តចំពោះខ្លួនបានទេ ។ ប៉ុន្តែ ចៅក្រមនោះអាចបញ្ចេញមតិយោបល់អំពីពាក្យសុំនូវការដកហូត ឬ បណ្ដឹងជិតចិត្តបាន ។

៣- ពាក្យសុំនូវការដកហូត ឬ បណ្ដឹងជិតចិត្ត ត្រូវបានធ្វើឡើងដោយធ្វើសេចក្ដីបញ្ជាក់ដំបូងជាលាយល័ក្ខណ៍អក្សរនូវមូលហេតុ ។

៤- ពេលដែលមានពាក្យសុំនូវការដកហូត ឬ បណ្ដឹងជិតចិត្ត នីតិវិធីនៃបណ្ដឹងត្រូវបានផ្អាករហូតដល់ពេលដែលដីកាសម្រេចអំពីបណ្ដឹងនេះ ចូលជាស្ថាពរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសកម្មភាពដែលត្រូវការជាបន្ទាន់ ដូចជាការថែរក្សាការពារភស្តុតាង ជាអាទិ៍ ។

៥- ចំពោះដីកាសម្រេចដែលសម្រេចថា ការដកហូត ឬ បណ្ដឹងជិតចិត្តមានមូលហេតុត្រឹមត្រូវនោះ មិនអាចប្ដឹងឧបាស្រ័យឡើយ ។

៦- ចំពោះដីកាសម្រេចដែលសម្រេចថា ការដកហូត ឬ បណ្ដឹងជិតចិត្តពុំត្រឹមត្រូវ អាចប្ដឹងជំទាស់បាន ។

(កំណត់)

សូមមើលមាត្រា 25 និង 26 នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃប្រទេសជប៉ុន ។

មាត្រានេះកំណត់អំពីនីតិវិធីនៃការដកហូត និង បណ្ដឹងជិតចិត្ត ។ កថាខណ្ឌទី ១ កំណត់ថា ការសម្រេចសេចក្ដីអំពីការដកហូត និង បណ្ដឹងជិតចិត្ត ត្រូវធ្វើដោយក្រុមប្រឹក្សាជំនុំជម្រះនៅតុលាការដែលចៅក្រមដែលត្រូវបានប្ដឹងនោះស្ថិតនៅក្រោម ។ ចំណុចនេះ អាចកំណត់ឱ្យក្រុមប្រឹក្សាជំនុំជម្រះរបស់តុលាការជាន់ខ្ពស់សម្រេចសេចក្ដីក៏បានដែរ (ដូចមាត្រា 349 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសបារាំង) ប៉ុន្តែដើម្បីឱ្យបានស្រួល និង ឱ្យបានឆាប់រហ័សក្នុងការសម្រេចសេចក្ដី មាត្រានេះកំណត់ឱ្យតុលាការដដែលសម្រេច ។

កថាខណ្ឌទី ២ កំណត់អំពីការហាមមិនឱ្យចៅក្រមដែលត្រូវគេប្ដឹងជិតចិត្ត ចូលរួមក្នុងការសម្រេចសេចក្ដីនៃបណ្ដឹងជិតចិត្ត ជាដើម ។ នេះជាបញ្ញត្តិមួយដែលត្រូវតែមាន ដើម្បីឱ្យមានភាពមិនលំអៀង និង អព្យាក្រឹតភាព ក្នុងការសម្រេចសេចក្ដី ចំពោះបណ្ដឹងជិតចិត្ត ជាដើម ប៉ុន្តែ ចៅក្រមសាមីខ្លួនអាចបញ្ចេញមតិយោបល់បាន ក្នុងឋានៈដូចជាភាគីដែរ ។ ម្យ៉ាងទៀត នៅក្នុងចំណោមសាលាដំបូង មានតុលាការខ្លះដែលមានចំនួនចៅក្រមមិនគ្រប់គ្រាន់ដើម្បីបង្កើតក្រុមប្រឹក្សាជំនុំជម្រះ បើមិនឱ្យចៅក្រមដែលត្រូវគេប្ដឹងចូលរួម ហេតុដូច្នេះ ត្រូវមានបញ្ញត្តិ នៅក្នុងសេចក្ដីព្រាងច្បាប់ស្ដីពីការចាត់តាំងតុលាការ ដែលកំណត់ថា ក្នុងករណីដូចខាងលើនេះ ចៅក្រមនៃតុលាការផ្សេងអាចបំពេញការងារ ជាបណ្ដោះអាសន្ននៅតុលាការដែលខ្វះចៅក្រមបាន (នៅប្រទេសជប៉ុន ហៅថា "転補 ("tempo": temporary transfer for supplement)") ។

កថាខណ្ឌទី ៣ មានគោលបំណងកុំឱ្យមានបណ្ដឹងជិតចិត្តដោយរំលោភបំពាន និង ឱ្យការវិនិច្ឆ័យអំពីបណ្ដឹងជិតចិត្ត ជាដើម ត្រូវបានធ្វើឡើងរហ័ស ដោយសារការទាមទារនូវការបញ្ជាក់មូលហេតុនៃបណ្ដឹងជិតចិត្ត ។ល ។

កថាខណ្ឌទី ៤ កំណត់អំពីការផ្អាកនីតិវិធីនៃបណ្ដឹងអង្គសេចក្ដីនៅក្នុងពេលធ្វើនីតិវិធីនៃបណ្ដឹងជិតចិត្ត ជាដើម ។ បើបន្តនីតិវិធីនៃបណ្ដឹងអង្គសេចក្ដី និង តុលាការសម្រេចថា បណ្ដឹងជិតចិត្តនោះមានមូលហេតុត្រឹមត្រូវនោះ សកម្មភាពបណ្ដឹងទាំងអស់ដែលចៅក្រមនោះបានធ្វើហើយ នឹងក្លាយជាមោឃៈ និង គ្មានប្រយោជន៍ ហេតុដូច្នេះ ដើម្បីកុំឱ្យមានបញ្ហានេះ កំណត់ផ្អាកនីតិវិធីនោះសិន ។ ប៉ុន្តែ សកម្មភាពបណ្ដឹងខ្លះ ដែលជាចាំបាច់ត្រូវធ្វើ នៅទាន់ពេលវេលា ដូចជាការថែរក្សាការពារភស្ដុតាង ជាដើម ត្រូវទុកជាករណីលើកលែងដែលអាចធ្វើបាន នៅក្នុងពេលនៃនីតិវិធីនៃបណ្ដឹងជិតចិត្ត ជាដើម ។

កថាខណ្ឌទី ៥ និង ទី ៦ កំណត់អំពីបណ្ដឹងឧបាស្រ័យចំពោះការសម្រេចសេចក្ដីអំពីបណ្ដឹងជិតចិត្ត ជាដើម ។ កថាខណ្ឌទី ៥ កំណត់មិនឱ្យចៅក្រមធ្វើឧបាស្រ័យចំពោះការសម្រេចសេចក្ដីដែលសម្រេចថា ការដកហូត ឬ បណ្ដឹងជិតចិត្ត មានមូលហេតុត្រឹមត្រូវ និង ភាគីម្ខាងទៀត (ដែលមិនមែនជាភាគីដាក់ពាក្យសុំដកហូត ឬ ប្ដឹងជិតចិត្ត) ក៏គ្មានផលប្រយោជន៍ក្នុងការធ្វើឧបាស្រ័យ ហេតុដូច្នេះ មិនឱ្យធ្វើឧបាស្រ័យដែរ ។ រីឯកថាខណ្ឌទី ៦ វិញ កំណត់អំពីសិទ្ធិរបស់ភាគីដែលបានធ្វើពាក្យសុំប្ដឹង ក្នុងការធ្វើឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចំពោះការសម្រេចសេចក្ដីដែលសម្រេចថា ការដកហូត ឬ បណ្ដឹងជិតចិត្ត ពុំមានមូលហេតុត្រឹមត្រូវ ។

Code of Civil Procedure (Japan)

**Article 25** (Adjudication for exclusion or challenge)
1. With respect to exclusion or challenge of a judge who is a constituent member of a panel court, or of a district court judge sitting alone, the court to which such judge belongs shall decide by ruling, and with respect to that of a judge of a summary court, the district court having jurisdiction over the district where the sumary court is situated shall decide by ruling.
2. The decision referred to in the preceding paragraph in the district court shall be made by panel.
3. No judge shall participate in a decision relating to his or her own exclusion or challenge.
4. No appeal may be made against a ruling in favor of an exclusion or challenge.
5. An immediate *kokoku*-appeal may be made agasint a ruling which denies an exclustion or challenge.
**Article 26** (Stay of proceedings)
In cases where a motion for exclustion or challenge has been made, the proceedings shall be stayed until such time as the deiciosn on the motion becomes final and binding. However, this shall not apply to such acts as may require immediate attention.

Code de Procédure Civile (France)
**Article 349**
Si le juge s'oppose à la récusation ou ne répond pas, la demande de récusation est jugée sans délai par la cour d'appel ou, si elle est dirigée contre un assesseur d'une juridiction échevinale, par le président de cette juridiction qui se prononce sans appel.

**មាត្រា ៣១.~** ការអនុវត្តដូចគ្នាចំពោះក្រឡាបញ្ជី

បញ្ញត្តិនៃផ្នែកនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះក្រឡាបញ្ជី ។ ក្នុងករណីនេះ ការសម្រេចសេចក្តីអំពីពាក្យសុំនូវការដកហូត ឬ បណ្តឹងជិតចិត្ត ត្រូវធ្វើដោយតុលាការដែលក្រឡាបញ្ជីនោះស្ថិតនៅក្រោម ។

( កំណត់)

សូមមើលមាត្រា 27 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។

មាត្រានេះមានគោលបំណងអនុវត្តបញ្ញត្តិនៃផ្នែកទី ៣ នេះ ស្តីពីការបែងចែករឿងក្តី ការដកហូតសមត្ថកិច្ចជំនុំជម្រះ និង បណ្តឹងជិតចិត្ត ចំពោះក្រឡាបញ្ជី ( មាត្រា 49 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសអាឡឺម៉ង់ មាត្រា 26 នៃច្បាប់ស្តីពីសមត្ថកិច្ចជម្រះក្តីនៃប្រទេសអូទ្រីស ជាដើម) ។ ក្រឡាបញ្ជីមិនទាក់ទងនឹងការសម្រេចសេចក្តីទេ ប៉ុន្តែ ក្រឡាបញ្ជីមានមុខងារទទួលបន្ទុកយ៉ាងទូលាយនូវសកម្មភាពបញ្ជាក់ ដែលជាមុខងារសំខាន់សម្រាប់ធានាភាពមិនលំអៀងនៃនីតិវិធីបណ្តឹង ហេតុដូច្នេះ ចាំបាច់ត្រូវរក្សាភាពត្រឹមត្រូវ និង អព្យាក្រិតភាពនៃក្រឡាបញ្ជីដែរ ។

Code of Civil Procedure (Japan)
**Article 27** (*Mutatis mudandis* application to court clerks)
The provisions of this section shall apply *mutatis mutandis* to court clerks. In such cases, the decision shall be rendered by the court to which the clerk belongs.

Code of Civil Procedure Rules (Germany)
**Article 49** (Clerks of the court)
The provisions of this title are also analogously applicable to the clerks of the court's registry; the decision is made by the court at which he is employed.

# ជំពូកទី ៣ ភាគី

## ផ្នែកទី ១ សមត្ថភាពភាគី និង សមត្ថភាពក្នុងការធ្វើបណ្ដឹង

**មាត្រា ៣២.-** សមត្ថភាពភាគី សមត្ថភាពក្នុងការធ្វើបណ្ដឹង ការតំណាងដែលច្បាប់បានកំណត់សម្រាប់ជនដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្ដឹង

១- បុគ្គលដែលអាចមានសិទ្ធិ និង ករណីយកិច្ច តាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និង ច្បាប់ផ្សេងទៀត អាចជាដើមចោទ ឬ ចុងចម្លើយនៅក្នុងបណ្ដឹងរដ្ឋប្បវេណី ។

២- បុគ្គលដែលមានសមត្ថភាពធ្វើសកម្មភាពដោយខ្លួនឯង តាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និង ច្បាប់ផ្សេងទៀត អាចដាក់ពាក្យបណ្ដឹងដោយខ្លួនឯងដោយតាំងខ្លួនជាដើមចោទ ឬ អាចឆ្លើយដោះសាចំពោះបណ្ដឹង ដោយតាំងខ្លួនជាចុងចម្លើយ ឬ អាចធ្វើសកម្មភាពបណ្ដឹងផ្សេងទៀតដែលជាចាំបាច់ ។

៣- អនីតិជន និង ជននៅក្រោមអាណាព្យាបាលទូទៅ អាចធ្វើសកម្មភាពបណ្ដឹងសុពលបាន លុះត្រាតែត្រូវបានធ្វើដោយអ្នកតំណាងដែលច្បាប់បានកំណត់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអនីតិជនអាចធ្វើសកម្មភាពដោយឯករាជ ។

៤- បញ្ញត្តិនៃក្រមរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងទៀត ត្រូវយកមកអនុវត្ត ចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ និង សិទ្ធិតំណាងរបស់អ្នកតំណាងនោះ ។

(កំណត់)

(1) សូមមើលមាត្រា 28 និង មាត្រា 31 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(2) កថាខណ្ឌទី ១ កំណត់អំពីសមត្ថភាពភាគី ឯកថាខណ្ឌទី ២ កំណត់អំពីសមត្ថភាព ក្នុងការធ្វើបណ្ដឹង ។

(3) តាមក្រមរដ្ឋប្បវេណី មាត្រា ១៥ គន្លីទី ២ បានប្រើពាក្យ "សកម្មភាព" ដោយសំដៅទៅលើកិច្ចសន្យា និង សកម្មភាពឯកតោភាគី ។ ហេតុដូច្នេះ កថាខណ្ឌទី ២ នៃមាត្រានេះ ក៏ប្រើពាក្យ "សកម្មភាព" ដែរ ។

(4) កថាខណ្ឌទី ៣ ចែងថា អនីតិជន និង ជននៅក្រោមអាណាព្យាបាលទូទៅ គឺជាជនដែលគ្មានសមត្ថភាព ក្នុងការធ្វើបណ្ដឹង ហើយមិនអាចធ្វើសកម្មភាពបណ្ដឹង លើកលែងតែត្រូវបានធ្វើឡើងដោយអ្នកតំណាងដែលច្បាប់បានកំណត់ ដោយយោងទៅតាមមាត្រា ១៨ និង មាត្រា ២៦ គន្លីទី ២ នៃក្រមរដ្ឋប្បវេណី ។ ករណីដែលអនីតិជនអាចធ្វើសកម្មភាពដោយឯករាជ គឺជាករណីដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាល អនុញ្ញាតឱ្យអនីតិជនចាត់ចែងទ្រព្យសម្បត្តិមួយចំនួន (មាត្រា ១៩ នៃក្រមដដែល) និង ករណីដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាល អនុញ្ញាតឱ្យអនីតិជនប្រកបជំនួញ (មាត្រា ២០) ។

(5) យើងបន្ថែមពាក្យ "សុពល" ក្នុងកថាខណ្ឌទី ៣ ដោយយកលទ្ធផលនៃការពិភាក្សាអំពីពាក្យពេចន៍ ។

<u>Code of Civil Procedure (Japan)</u>
**Article 28** (General principles)
Except as otherwise provided by this Act, the capacity to be a party, the capacity to litigate and the legal representation of a person without the capacity to litigate shall be governed by the provisions of the Civil Code (Law No. 89, 1896) and other laws and ordinances. The same shall apply to the authorization necessary to conduct an act of litigation.
**Article 31** (Capacity of minor and incompetent person to litigate)
A minor or incompetent person may conduct acts of litigation only through a legal representative. However, this shall not apply to cases where a minor is empowered to conduct juristic acts independently.

**មាត្រា ៣៣.-** បញ្ញត្តិពិសេសស្តីពីសកម្មភាពបណ្តឹងរបស់ជននៅក្រោមហិតូបត្ថម្ភ និង អ្នកតំណាងដែលច្បាប់បានកំណត់

១- ជននៅក្រោមហិតូបត្ថម្ភ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ អាចធ្វើសកម្មភាពបណ្តឹង ចំពោះបណ្តឹង ឬ បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលត្រូវបានធ្វើដោយភាគីម្ខាងទៀត ដោយគ្មានការយល់ព្រមពីហិតូបត្ថម្ភកៈ ឬ អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល ឬ ការប្រគល់សិទ្ធិផ្សេងទៀត ។

២- ជននៅក្រោមហិតូបត្ថម្ភ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ត្រូវមានការប្រគល់សិទ្ធិពិសេសដើម្បីធ្វើសកម្មភាពបណ្តឹងខាងក្រោមនេះ :

**ក-** ការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ ឬ ការទទួលស្គាល់នូវការទាមទារ ។

**ខ-** ការដកពាក្យបណ្តឹងឧទ្ធរណ៍ ឬ ពាក្យបណ្តឹងសាទុក្ខ ។

(កំណត់)

(1) សូមមើលមាត្រា 32 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(2) កថាខណ្ឌទី ១ នៃមាត្រានេះ គឺជាបញ្ញត្តិការពារភាគីដែលមានបំណងធ្វើសកម្មភាពបណ្តឹង ចំពោះជននៅក្រោមហិតូបត្ថម្ភ ។ ជាទូទៅ ជននៅក្រោមហិតូបត្ថម្ភ ចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈ ដើម្បីធ្វើសកម្មភាពបណ្តឹង ហើយសកម្មភាពបណ្តឹងណាដែលជននៅក្រោមហិតូបត្ថម្ភ បានធ្វើដោយគ្មានការយល់ព្រមពីហិតូបត្ថម្ភកៈ គឺជាសកម្មភាពមោឃៈ (កថាខណ្ឌទី ២ នៃមាត្រា ៣២ និង កថាខណ្ឌទី ២ នៃមាត្រា ២៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី និង មាត្រា ៣០ នៃក្រមរដ្ឋប្បវេណី) ។ ប៉ុន្តែ តាមគោលការណ៍ទូទៅនេះ ប្រសិនបើហិតូបត្ថម្ភកៈមិនយល់ព្រម ភាគីម្ខាងទៀតមិនអាចធ្វើសកម្មភាពបណ្តឹងចំពោះជននៅក្រោមហិតូបត្ថម្ភ ហើយបាត់បង់ផ្លូវដើម្បីដោះស្រាយវិវាទ (ហិតូបត្ថម្ភកៈមិនមែនជាអ្នកតំណាងទេ ហេតុដូច្នេះ ភាគីនោះមិនអាចធ្វើសកម្មភាពបណ្តឹង ដោយយកហិតូបត្ថម្ភកៈធ្វើជាអ្នកតំណាងបានឡើយ) ។ ហេតុដូច្នេះ កថាខណ្ឌទី ១ នៃមាត្រានេះ ដោះស្រាយអំពី អលទ្ធភាពរបស់ភាគីម្ខាងក្នុងការធ្វើសកម្មភាពបណ្តឹងដោយសារគ្មានការយល់ព្រមពីហិតូបត្ថម្ភកៈ ដោយចែងថា ជននៅក្រោមហិតូបត្ថម្ភមិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈ ក្នុងការធ្វើសកម្មភាពបណ្តឹង ចំពោះបណ្តឹង ឬ បណ្តឹងឧបាស្រ័យទៅតុលាការ

ជាន់ខ្ពស់ដែលត្រូវបានធ្វើដោយភាគីម្ខាងទៀត ។ បញ្ហាបែបនេះ អាចកើតឡើង ក្នុងករណីដែលអ្នកអាណាព្យាបាលត្រូវធ្វើសកម្មភាពបណ្តឹង ក្នុងនាមជាអ្នកតំណាងដែលច្បាប់បានកំណត់ តែអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលមិនផ្តល់ការយល់ព្រម ហេតុដូច្នេះ កថាខណ្ឌទី ១ ចែងអំពីបញ្ហានោះផងដែរ ។

(3) ការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ ការទទួលស្គាល់នូវការទាមទារ ការដកពាក្យបណ្តឹងឧទ្ធរណ៍ និង ពាក្យបណ្តឹងសាទុក្ខ គឺជាសកម្មភាពបណ្តឹងដែលអាចប៉ះពាល់ធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់ជននៅក្រោមហិតូបត្ថម្ភ និង ជនដែលត្រូវគេតំណាងតាមច្បាប់ ហេតុដូចនេះ កថាខណ្ឌទី ២ នៃមាត្រានេះ ទាមទារឱ្យមានការប្រគល់សិទ្ធិពិសេស ។

ចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ ហើយមិនចាំបាច់មានអ្នកត្រួតពិនិត្យ ដូចជាអ្នកមានអំណាចមេបា និង អ្នកតំណាងដែលច្បាប់បានកំណត់ ហើយគ្មានអ្នកត្រួតពិនិត្យ ដូចជាអ្នកអាណាព្យាបាលដែលគ្មានអ្នកត្រួតពិនិត្យនោះពុំចាំបាច់មានការប្រគល់សិទ្ធិពិសេសឡើយ ។

Code of Civil Procedure (Japan)

**Article 32** (Special provisions for act of litigation if quasi-incompetent person and legal representative)

1. A quasi-incompetent person or legal representative may conduct acts of litigation in a suit or appeal filed by an adversary party without the consent of the curator or the supervisor of guardianship, or any other authorization.

2. A quasi-incompetent person or legal representative must have special authorization to conduct the following acts of litigation:

   i. a withdrawal of a suit, a compromise, an abandonment or acknowledgment of a claim, or a withdrawal under the provision of Article 48 (including those cases to which it applies *mutatis mutandis* in Article 50, paragraph 3 and Article 51);

   ii. a withdrawal of a *koso*-appeal, a *jokoku*-appeal or a motion under the provisions of Article 318, paragraph 1;

   iii. a withdrawal of objection under the provisions of Article 360 (including those cases to which it applies *mutatis mutandis* in Article 367, paragraph 2 and Article 378, paragraph 2) or a consent to such a withdrawal.

**មាត្រា ៣៤.-** បញ្ញត្តិពិសេសស្តីពីសមត្ថភាពក្នុងការធ្វើបណ្តឹងរបស់ជនបរទេស

ជនបរទេសត្រូវទុកជាបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើបណ្តឹង ប្រសិនបើជននោះត្រូវមានសមត្ថភាពក្នុងការធ្វើបណ្តឹងស្របទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ទោះបីជាជននោះគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹងតាមច្បាប់នៃប្រទេសរបស់ខ្លួនក៏ដោយ ។

(កំណត់)

(1) សូមមើលមាត្រា 33 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(2) មាត្រានេះចែងអំពីសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹងរបស់ជនបរទេស ដែលត្រូវតែគោរព និង ប្រតិបត្តិទៅតាមច្បាប់នៃប្រទេសកម្ពុជា ដូច្នេះ ឱ្យតែជននោះមានសមត្ថភាព តាមក្រមនីតិវិធីរដ្ឋប្បវេណីនេះ អាចធ្វើសកម្មភាពបណ្តឹងបាន ដោយពុំគិតពីលក្ខណៈផ្ទុយនឹងច្បាប់នៃប្រទេសរបស់ជននោះឡើយ ។

Code of Civil Procedure (Japan)

**Article 33** (Special provisions for capacity of alien to litigate)

In cases where an alien shall have the capacity to litigate under Japanese law, but has no capacity to litigate under the laws of the country of which such person is a citizen, such person shall be deemed to be a person having the capacity to litigate.

**មាត្រា ៣៥.–** វិធានការក្នុងករណីដែលខ្វះសមត្ថភាពក្នុងការធ្វើបណ្ដឹង ជាអាទិ៍

១- ក្នុងករណីដែលមានការខ្វះសមត្ថភាពក្នុងការធ្វើបណ្ដឹង ឬ សិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ ការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្ដឹង តុលាការត្រូវបង្គាប់ឱ្យកែតម្រូវនូវចំណុចខ្វះនោះ ដោយកំណត់អំឡុងពេល ។ ក្នុងករណីនេះ ប្រសិនបើមានការខូចខាតណាមួយអាចកើតឡើងដោយសារការយឺតយ៉ាវ តុលាការអាចឱ្យបុគ្គលដែលមានការខ្វះនោះ ធ្វើសកម្មភាពបណ្ដឹងជាបណ្ដោះអាសន្នបាន ។

២- សកម្មភាពបណ្ដឹងណាដែលត្រូវបានធ្វើឡើងដោយបុគ្គលដែលខ្វះសមត្ថភាពក្នុងការធ្វើបណ្ដឹង ឬ ខ្វះសិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ ខ្វះការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្ដឹង ត្រូវមានអានុភាពប្រតិសកម្មតាំងពីពេលដែលសកម្មភាពនោះបានធ្វើឡើង បើមានការទទួលស្គាល់នៅពេលក្រោយ ដោយភាគីដែលបានទទួលសមត្ថភាពក្នុងការធ្វើបណ្ដឹង ឬ ដោយអ្នកតំណាងដែលបានទទួលសិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ ការប្រគល់សិទ្ធិ ។

៣- សិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ ការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្ដឹង ត្រូវបានបញ្ជាក់ដោយលិខិតជាលាយល័ក្ខណ៍អក្សរ ។

(កំណត់)

(1) សូមមើលមាត្រា 34 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន និង មាត្រា 15 នៃបទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(2) មាត្រានេះធានានូវសិទ្ធិចាត់ចែងរបស់ភាគី និង គោលការណ៍ចំពោះមុខ ដើម្បីធានានូវសិទ្ធិស្មើគ្នាចំពោះមុខតុលាការ ប៉ុន្តែ បើភាគីម្ខាងមានសមត្ថភាព ហើយភាគីម្ខាងទៀតខ្វះសមត្ថភាពក្នុងការធ្វើបណ្ដឹង ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់ភាគីម្ខាងទៀតនោះ ខ្វះសិទ្ធិតំណាង ឬ ការប្រគល់សិទ្ធិចាំបាច់ គឺតម្រូវឱ្យតុលាការត្រូវពិនិត្យនូវចំណុចខ្វះខាត ដោយឆន្ទានុសិទ្ធិ និង បង្គាប់ឱ្យកែតម្រូវលើចំណុចខ្វះខាតនោះ ដោយកំណត់ពេលសមរម្យ ។ បើតុលាការយល់ឃើញថា អាចមានការខូចខាតកើតឡើង ដោយការយឺតយ៉ាវ នោះតុលាការអាចអនុញ្ញាតឱ្យជនដែលខ្វះសមត្ថភាព ធ្វើសកម្មភាពបណ្ដឹងជាបណ្ដោះអាសន្នសិន ។

(3) ទាក់ទងនឹងការធ្វើសកម្មភាពបណ្ដឹងជាបណ្ដោះអាសន្នខាងលើ បើក្រោយមក បានកែតម្រូវនូវចំណុចខ្វះខាតហើយនោះ សកម្មភាពបណ្ដឹងដែលមានពីមុនមក ត្រូវចាត់ទុកថា មានលក្ខណៈត្រឹមត្រូវ ដោយការទទួលស្គាល់របស់ភាគីដែលបានទទួលសមត្ថភាពក្នុងការធ្វើបណ្ដឹង ឬ ដោយអ្នកតំណាងដែលច្បាប់បានកំណត់ ដែលបានទទួលសិទ្ធិតំណាង ឬ ការប្រគល់សិទ្ធិ ។

Code of Civil Procedure (Japan)
**Article 34** (Measures in case of defect in the capacity to litigate, etc.)
1. In cases where there is a defect in the capacity to litigate, in the authority as a legal representative, or in the authorization necessary to conduct acts of litigation, the court shall order that it be corrected within a period to be designated by the court. In such cases, if

there exists a danger of damage being caused by delay, the court may permit the act of litigation to be conducted *pro tempore*.
2. Any act of litigation conducted by a person who has a defect in the capacity to litigate, in the authority as a legal representative, or in the authorization necessary to conduct acts of litigation, shall have retroactive effect if such act is ratified by such person after such defect has ceased to exist or by the legal representative.
3. The provisions of the preceding two paragraphs shall apply *mutatis mutandis* to such cases where an appointed party conducts acts of litigation.

Rules of Civil Procedure (Japan)
**Article 15** (Certification of authority of legal representative, etc. / The Code Article 34)
The authority of a legal representative or the authorization necessary to conduct acts of litigation shall be certified in writing, The same shall apply to the appointment or change of an appointed party.

## **មាត្រា ៣៦.-** អ្នកតំណាងពិសេស

១- ក្នុងករណីដែលគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ ឬ ករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ ពុំអាចប្រតិបត្តិនូវសិទ្ធិតំណាងនោះ បុគ្គលដែលមានបំណងធ្វើសកម្មភាពបណ្តឹងចំពោះបុគ្គលដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹង អាចដាក់ពាក្យសុំទៅតុលាការដែលបានទទួលបណ្តឹង ឱ្យជ្រើសតាំងអ្នកតំណាងពិសេស ដោយធ្វើសេចក្តីបញ្ជាក់ដំបូងថា ការខូចខាតអាចនឹងកើតឡើងដោយសារការយឺតយ៉ាវនោះ ។

២- តុលាការអាចផ្លាស់ប្តូរអ្នកតំណាងពិសេស នៅពេលណាក៏បាន ។

៣- ការសម្រេចសេចក្តីអំពីការជ្រើសតាំង ឬ ការផ្លាស់ប្តូរអ្នកតំណាងពិសេសនឹងត្រូវបានជូនដំណឹងឱ្យអ្នកតំណាងពិសេសផងដែរ ។

៤- អ្នកតំណាងពិសេសត្រូវមានការប្រគល់សិទ្ធិដូចអាណាព្យាបាល ដើម្បីធ្វើសកម្មភាពបណ្តឹង ។

(កំណត់)

(1) សូមមើលមាត្រា 35 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន និង មាត្រា 16 នៃបទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(2) អនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ គ្មានសមត្ថភាពក្នុងការធ្វើបណ្តឹងឡើយ គឺត្រូវធ្វើសកម្មភាពបណ្តឹងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ ។ ប៉ុន្តែ បើគ្មានអ្នកតំណាងឱ្យជននេះ ឬ អ្នកតំណាងមិនអាចប្រតិបត្តិនូវសិទ្ធិតំណាងនោះ ភាគីម្ខាងទៀតដែលមានបំណងធ្វើសកម្មភាពបណ្តឹងចំពោះជននោះ មានភាពលំបាក ហេតុដូច្នេះមាត្រានេះអនុញ្ញាតឱ្យភាគីអាចដាក់ពាក្យសុំទៅតុលាការឱ្យជ្រើសតាំងអ្នកតំណាងពិសេស ហើយចែងអំពីល័ក្ខខ័ណ្ឌនៃការជ្រើសតាំង និង សិទ្ធិរបស់អ្នកតំណាងពិសេសនោះ ។ អ្នកតំណាងពិសេស គឺជាអ្នកតំណាង ជំនួសអ្នកតំណាងដែលច្បាប់បានកំណត់ ហេតុនេះ មានសិទ្ធិអំណាចដូចអ្នកតំណាងដែលច្បាប់បានកំណត់ដែរ ។

(3) តាមបញ្ញត្តិនៃមាត្រានេះ តុលាការអាចជ្រើសតាំងព្រះរាជអាជ្ញាជាអ្នកតំណាងពិសេសបាន ។

(4) ចំពោះពាក្យ "សេចក្តីបញ្ជាក់ដំបូង" សូមមើលមាត្រា ១៣១ (សេចក្តីបញ្ជាក់ដំបូង) ។

Code of Civil Procedure (Japan)
**Article 35** (Special Representative)
Any person who intends to conduct acts of litigation against a minor or incompetent person where such minor or incompetent person has no legal representative, or where the legal representative is unable to exercise authority, may apply to the presiding judge of the

court before which the suit is pending for the appointment of a special representative by offering a preliminary showing that there exists a danger of damage being caused by delay.
2. The court may at any time replace the special representative.
3. The special representative shall have the same authorization as a guardian in order to conduct acts of litigation.

<u>Rules of Civil Procedure (Japan)</u>
**Article 16** (Notice of adjudication to appoint or replace special representative. / The Code Article 35)
The special representative shall be informed by notice of the decision to appoint or replace him or her.

## **មាត្រា ៣៧.-** ការជូនដំណឹងអំពីការរលត់នៃសិទ្ធិតំណាងដែលច្បាប់បានកំណត់

១- ការរលត់នៃសិទ្ធិតំណាងដែលច្បាប់បានកំណត់ មិនត្រូវមានអានុភាព បើគ្មានការជូនដំណឹងអំពីការរលត់សិទ្ធិនោះ ពីសាមីខ្លួន ឬ អ្នកតំណាង ទៅភាគីម្ខាងទៀត ។

២- បុគ្គលដែលជូនដំណឹងអំពីការរលត់នៃសិទ្ធិតំណាងដែលច្បាប់បានកំណត់ ត្រូវរាយការណ៍ទៅតុលាការ អំពីការជូនដំណឹងអំពីការរលត់សិទ្ធិនោះ ជាលាយល័ក្ខណ៍អក្សរ ។

(កំណត់)

(1) សូមមើលមាត្រា 36 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន និង មាត្រា 17 នៃបទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(2) តាមក្រមរដ្ឋប្បវេណី សិទ្ធិតំណាងដែលច្បាប់បានកំណត់ ត្រូវរលត់នៅពេលដែលហេតុនៃការរលត់សិទ្ធិតំណាង បានកើតឡើង ដូចជា មរណភាពនៃអ្នកតំណាងដែលច្បាប់បានកំណត់ ។ ប៉ុន្តែ ដើម្បីធានាស្ថិរភាពនៃនីតិវិធីបណ្តឹង កថាខណ្ឌទី ១ នៃមាត្រានេះ ទាមទារឱ្យមានការជូនដំណឹងអំពីការរលត់សិទ្ធិនោះ ទៅភាគីម្ខាងទៀត ។ម្យ៉ាងទៀត កថាខណ្ឌទី ២ ទាមទារឱ្យរាយការណ៍អំពីការជូនដំណឹងនោះ ទៅតុលាការ ។

<u>Code of Civil Procedure (Japan)</u>
**Article 36** (Notice of termination of legal representative's authority)
The termination of a legal representative's authority shall not take effect unless notice of the fact is given by the principal or its representative to the adversary party.

<u>Rules of Civil Procedure (Japan)</u>
**Article 17** (Notification of termination of authority of legal representative, etc. / The Code Article 36)
A person who has given notice of the termination of the authority of a legal representative shall notify the court of that fact in writing. The same shall apply to a person who has given notice of the appointment or change of an appointed party.

## **មាត្រា ៣៨.-** ការអនុវត្តដូចគ្នាចំពោះអ្នកតំណាងនៃនីតិបុគ្គល

បញ្ញត្តិនៃក្រមនេះដែលទាក់ទងនឹងការតំណាងដែលច្បាប់បានកំណត់ និង អ្នកតំណាងដែលច្បាប់បានកំណត់ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកតំណាងនៃនីតិបុគ្គល ។

(កំណត់)

(1) សូមមើលមាត្រា 37 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(2) ដូចជា ការរលត់សិទ្ធិតំណាងនៃនីតិបុគ្គល ត្រូវមានអានុភាព នៅពេលដែលបានជូនដំណឹង ។

Code of Civil Procedure (Japan)
**Article 37** (*Mutatis mutandis* application to juridical person's representative, etc.)
The provisions in this Act relating to legal representation and legal representatives shall apply *mutatis mutandis* to the representative of a juridical person and the representative or administrator of an association or foundation which is not a juridical person and which may sue or be sued in its own name.

## ផ្នែកទី ២ សហបណ្តឹង

**មាត្រា ៣៩.-** លក្ខខណ្ឌទូទៅនៃសហបណ្តឹង

បើមានមូលហេតុណាមួយរវាងបុគ្គលច្រើននាក់ដូចមានចែងខាងក្រោមនេះ បុគ្គលទាំងនោះអាចប្តឹង ឬ អាចត្រូវគេប្តឹង ក្នុងនាមជាអ្នកសហបណ្តឹង :

**ក-** បើសិទ្ធិ ឬ កាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្តឹងនោះ ដូចគ្នា ។

**ខ-** បើសិទ្ធិ ឬ កាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្តឹងនោះ ផ្អែកលើមូលហេតុដូចគ្នាលើអង្គហេតុ និង អង្គច្បាប់ ។

**គ-** បើសិទ្ធិ ឬ កាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្តឹងនោះ មានប្រភេទដូចគ្នា ហើយផ្អែកលើមូលហេតុ ដែលមានប្រភេទដូចគ្នាលើអង្គហេតុ និង អង្គច្បាប់ ។

(កំណត់)

សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 38 ។

សហបណ្តឹង គឺជាបណ្តឹងមួយប្រភេទ ដែលមានដើមចោទ ឬ/និង ចុងចម្លើយច្រើននាក់ ហើយគេអាចហៅថា ការបញ្ចូលបណ្តឹងដោយអញ្ញថាភាព ។ មាត្រានេះចែងអំពីលក្ខខណ្ឌទូទៅដើម្បីធ្វើសហបណ្តឹង ថា បុគ្គលច្រើននាក់នោះត្រូវមានទំនាក់ទំនងដែលត្រូវបានទទួលស្គាល់ថា មានភាពសមហេតុផលក្នុងការជម្រះរួម ។

ឧទាហរណ៍នៃចំណុច **ក** មានដូចជា បណ្តឹងដើម្បីបញ្ជាក់កម្មសិទ្ធិលើវត្ថុតែមួយចំពោះចុងចម្លើយច្រើននាក់ ករណីទាមទារឱ្យកូនបំណុលច្រើននាក់ដោយសាមគ្គីភាពបំពេញកាតព្វកិច្ចរបស់ខ្លួន ។ ឧទាហរណ៍នៃចំណុច **ខ** មានដូចជា ករណីទាមទារសំណងនៃការខូចខាតចំពោះក្រុមហ៊ុនអាកាសចរណ៍ ដោយអ្នករងគ្រោះថ្នាក់ដោយយន្តហោះ មានចំនួនច្រើននៅក្នុងគ្រោះថ្នាក់តែមួយ ។ ឧទាហរណ៍នៃចំណុច **គ** មានដូចជា ករណីដែលម្ចាស់អាគារដែលមានផ្ទះល្វែងច្រើនទាមទារថ្លៃឈ្នួលផ្ទះ ពីអ្នកជួលផ្ទះល្វែងនីមួយៗ ។

សហបណ្តឹងត្រូវធ្វើឡើងដោយបញ្ចូលការទាមទារច្រើនចំណុច (ការបញ្ចូលបណ្តឹងដោយកម្មវិស័យភាព) ហេតុនេះ លក្ខខណ្ឌនៃការបញ្ចូលដោយកម្មវិស័យភាពនោះដូចជា ការទាមទារត្រូវចាត់ចែងដោយនីតិវិធីប្រភេទដូចគ្នា (មាត្រា ៧៧ (ការបញ្ចូលការទាមទារច្រើនចំណុចទៅក្នុងបណ្តឹងតែមួយ)) និង ត្រូវមានការទទួលស្គាល់នូវសមត្ថកិច្ចសាលាជម្រះក្តី

រួមគ្នា លើការទាមទារទាំងអស់ផង ។ ម្យ៉ាងទៀត សមត្ថកិច្ចសាលាជម្រះក្តីចំពោះបណ្តឹងដែលបានបញ្ចូលចំណុចទាមទារច្រើន (មាត្រា ១១ (សមត្ថកិច្ចសាលាជម្រះក្តីចំពោះការទាមទារច្រើនចំណុចដោយបញ្ចូលជាមួយគ្នា)) មិនត្រូវយកមកអនុវត្ត ចំពោះករណីបញ្ចូលការទាមទារទៅបណ្តឹងមួយដោយអញ្ញថាភាពទេ ។

Code of Civil Procedure (Japan)
**Article 38** (Conditions of joint litigation)
If the rights or duties which are the subject matters of a suit are common to two or more persons, or are based on the same grounds in fact and in law, each of such persons may sue or be sued as joint parties. The same shall apply when the rights or duties which are the subject matters of a suit are of the same type and are based on the same type of grounds in fact and in law.

**មាត្រា ៤០.-** ឋានៈនៃអ្នកធ្វើសហបណ្តឹង ក្នុងសហបណ្តឹងធម្មតា

សកម្មភាពបណ្តឹងដែលបុគ្គលម្នាក់ក្នុងចំណោមអ្នកធ្វើសហបណ្តឹងបានធ្វើ សកម្មភាពបណ្តឹងរបស់ភាគីម្ខាងទៀត ដែលបានធ្វើចំពោះបុគ្គលម្នាក់ក្នុងចំណោមអ្នកធ្វើសហបណ្តឹង និង ហេតុដែលកើតមានឡើងចំពោះបុគ្គលម្នាក់ក្នុងចំណោមអ្នកធ្វើសហបណ្តឹង ពុំមានឥទ្ធិពលទៅលើអ្នកធ្វើសហបណ្តឹងផ្សេងទៀតទេ ។

(កំណត់)

សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 39 ។

ការធ្វើជាសហបណ្តឹង មិនមែនជាល័ក្ខខ័ណ្ឌចាំបាច់ទេ គឺតាមការពិត អាចប្តឹងគេ ឬ អាចត្រូវគេប្តឹងដោយឡែកៗបាន ហើយទោះបីជាបានធ្វើសហបណ្តឹងក៏ដោយ ក៏មិនមានភាពចាំបាច់តាមច្បាប់ ក្នុងការដោះស្រាយរួមគ្នានូវចំណោមការទាមទារនីមួយៗរវាងអ្នកធ្វើសហបណ្តឹងម្នាក់ៗ និង ភាគីម្ខាងទៀត (=សិទ្ធិ ឬ កាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្តឹង) ដែរ នោះត្រូវគេហៅថា សហបណ្តឹងធម្មតា ។

សហបណ្តឹងធម្មតា គឺជាករណីដែលបុគ្គលម្នាក់ៗនៃសហបណ្តឹងនោះ មានសិទ្ធិចាត់ចែងសិទ្ធិ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹង ដាច់ដោយឡែកពីគ្នាបាន ។ ដូច្នេះហើយ មាត្រានេះបានចែងអំពីគោលការណ៍ឯករាជ្យភាពនៃអ្នកធ្វើសហបណ្តឹងធម្មតា ។ មានន័យថា ចំពោះសហបណ្តឹងធម្មតា ឧទាហរណ៍ ការអះអាង (ឬ ការត្រូវគេអះអាង) អំពីអង្គហេតុរបស់បុគ្គលម្នាក់ក្នុងចំណោមអ្នកចូលរួមក្នុងសហបណ្តឹងនោះ ពុំមានឥទ្ធិពលទៅលើភាគីសហបណ្តឹងផ្សេងទៀតទេ ។ ហេតុនេះហើយ គ្មានការធានានូវការដោះស្រាយជាទូទៅទាំងអស់ក្នុងសាលក្រមទេ (ប៉ុន្តែ ការវាយតម្លៃភស្តុតាងដើម្បីធ្វើការទទួលស្គាល់អង្គហេតុរួមមួយ ដែលត្រូវធ្វើដោយផ្អែកលើគោលការណ៍សេរីភាពនៃជំនឿទុកចិត្ត អាចធ្វើរួមដោយអ្នកធ្វើសហបណ្តឹងបាន ហើយតាមការជាក់ស្តែង បើធ្វើការវាយតម្លៃដូច្នោះ នោះមានផលប្រយោជន៍សម្រាប់ការដោះស្រាយទូទៅរួមគ្នាបាន ។ នេះគេហៅថា ភស្តុតាងរួមរវាងអ្នកធ្វើសហបណ្តឹង) ។

ម្យ៉ាងទៀត ហេតុនៃការផ្អាកនីតិវិធីដែលកើតមានឡើងចំពោះបុគ្គលម្នាក់ក្នុងចំណោមអ្នកធ្វើសហបណ្តឹង ក៏គ្មានឥទ្ធិពលទៅលើអ្នកធ្វើសហបណ្តឹងផ្សេងទៀតដែរ ។ ហេតុនេះហើយ គេអាចបែងចែកការទាញហេតុផល ឬ អាចជម្រះ

ក្តីមួយភាគបាន ។ ដូច្នេះហើយ គ្មានការធានាតាមច្បាប់ថា អាចដឹកនាំនីតិវិធីនៃបណ្តឹង ដោយបញ្ចូលជាមួយគ្នារវាងអ្នកធ្វើសហបណ្តឹងទាំងអស់ឡើយ ។

Code of Civil Procedure (Japan)
**Article 39** (Status of joint parties)
Acts of litigation conducted by one of the joint parties, acts of litigation conducted by the adversary party against one of the joint parties, and matters arising with regard to one of the joint parties, do not have any influence upon the other joint parties.

**មាត្រា ៤១.-** បទបញ្ញត្តិពីការវិនិច្ឆ័យលើសហបណ្តឹងចាំបាច់

១- ក្នុងករណីដែលសិទ្ធិ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹង នឹងត្រូវបានសម្រេចជាស្ថាពរទាល់តែមានការរួមគ្នាចំពោះអ្នកធ្វើសហបណ្តឹងទាំងអស់ ទោះជាមានបញ្ញត្តិដូចមាត្រា ៤០ (ឋានៈនៃអ្នកធ្វើសហបណ្តឹង ក្នុងសហបណ្តឹងធម្មតា) ខាងលើនេះក៏ដោយ ក៏សកម្មភាពនៃបណ្តឹងរបស់បុគ្គលម្នាក់ក្នុងចំណោមអ្នកធ្វើសហបណ្តឹង មានអានុភាពតែក្នុងករណីណាដែលមានផលប្រយោជន៍រួមតែប៉ុណ្ណោះ ។

២- ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ សកម្មភាពបណ្តឹងរបស់ភាគីម្ខាងទៀតដែលបានធ្វើចំពោះបុគ្គលម្នាក់ក្នុងចំណោមអ្នកធ្វើសហបណ្តឹង មានអានុភាពទៅលើបុគ្គលទាំងអស់ ។

៣- ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើមានមូលហេតុក្នុងការផ្អាក ឬ បង្អង់នូវនីតិវិធីនៃបណ្តឹងចំពោះបុគ្គលម្នាក់ក្នុងចំណោមអ្នកធ្វើសហបណ្តឹង ការផ្អាក ឬ ការបង្អង់នោះ មានអានុភាពទៅលើបុគ្គលទាំងអស់ ។

(កំណត់)

សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 40 កថាខណ្ឌទី 1 ដល់កថាខណ្ឌទី 3 ។

សហបណ្តឹង "ក្នុងករណីដែលសិទ្ធិ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹង នឹងត្រូវបានសម្រេចជាស្ថាពរ ទាល់តែមានការរួមគ្នា ចំពោះអ្នកធ្វើសហបណ្តឹងទាំងអស់នោះ" ត្រូវគេហៅថា សហបណ្តឹងជាចាំបាច់ ។ សហបណ្តឹងជាចាំបាច់នេះមានដូចជា : ①ករណីដែលភាគីនីមួយៗមានលក្ខណៈអាចធ្វើបណ្តឹងដោយឡែកពីគ្នា ប៉ុន្តែ ពេលដែលបានធ្វើសហបណ្តឹងត្រូវដោះស្រាយជារួមមួយចំពោះអ្នកដែលបានធ្វើសហបណ្តឹងនោះ (ឧទាហរណ៍ នៅប្រទេសជប៉ុន ម្ចាស់ហ៊ុនច្រើននាក់បានធ្វើបណ្តឹងទាមទារឱ្យលុបចោលនូវសេចក្តីសម្រេចនៃមហាសន្និបាតម្ចាស់ហ៊ុន ជាដើម) និង ② ករណីដែលបណ្តឹងនឹងខុសច្បាប់ ដោយសារតែខ្វះលក្ខណៈជាភាគី បើអ្នកទាំងអស់គ្នាមិនចូលរួមជាដើមចោទ ឬ ជាចុងចម្លើយទេនោះ (ឧទាហរណ៍ នៅជប៉ុន បណ្តឹងដើម្បីបែងចែកវត្ថុរួមមួយរវាងសហកម្មសិទ្ធិករ និង បណ្តឹងដើម្បីបញ្ជាក់មតិករវាងទាយាទទាំងឡាយ ជាដើម) (ករណី ① ត្រូវគេហៅថា "សហបណ្តឹងជាចាំបាច់ដោយប្រភេទដូចគ្នា (Prozeßrechtlich Notwendige Streitgenossenschaft 類似必要的共同訴訟) រីឯ ករណី ② ត្រូវគេហៅថា "សហបណ្តឹងជាចាំបាច់ដោយពិត (Materiellrechtlich Notwendige Streitgenossenschaft 固有必要的共同訴訟)") ។ ក្នុងករណីណាក៏ដោយ ក៏ត្រូវធ្វើការវិនិច្ឆ័យ និង ចេញសាល-

ក្រុម ដោយបញ្ចូលគ្នា និង ដោយគ្មានភាពផ្ទុយគ្នា ចំពោះភាគីទាំងអស់ដែរ ហេតុនេះហើយបានជាត្រូវចែងបញ្ញត្តិពិសេសក្នុងមាត្រានេះ ។

សកម្មភាពបណ្ដឹងដែលមានប្រយោជន៍ដែលធ្វើដោយបុគ្គលម្នាក់ក្នុងចំណោមអ្នកធ្វើសហបណ្ដឹងទាំងអស់ នឹងមានអានុភាព ចំពោះអ្នកទាំងអស់ រីឯសកម្មភាពដែលធ្វើឱ្យខូចប្រយោជន៍ បើមិនធ្វើទាំងអស់គ្នាទេ គ្មានអានុភាពទេ (កថាខណ្ឌទី ១) ។ សកម្មភាពបណ្ដឹងដែលភាគីម្ខាងទៀតបានធ្វើចំពោះបុគ្គលណាម្នាក់ ក្នុងចំណោមអ្នកធ្វើសហបណ្ដឹងទាំងអស់ ទោះបីជាមានប្រយោជន៍ក៏ដោយ គ្មានប្រយោជន៍ក៏ដោយ ក៏មានអានុភាពទៅលើបុគ្គលទាំងអស់នោះដែរ (កថាខណ្ឌទី ២) ។

Code of Civil Procedure (Japan)
**Article 40** (Necessary joint litigation) (excerpt)
1. In cases where the subject matter of a suit shall be determined only jointly with regard to all of the joint parties, any acts of litigation conducted by one of them shall take effect only if in favor of all of them.
2. In the cases referred to in the preceding paragraph, any acts of litigation conducted by an adversary party against one of the joint parties shall take effect with regard to all of them.
3. In the cases referred to in paragraph 1, when any reason for interruption or suspension of proceedings exists with regard to one of the joint parties, such interruption or suspension shall be effective with regard to all of them.

**មាត្រា ៤២.-** ការជ្រើសរើសភាគី

១- បុគ្គលច្រើននាក់ដែលមានផលប្រយោជន៍រួមមួយ អាចធ្វើការជ្រើសរើសបុគ្គលម្នាក់ ឬ ច្រើននាក់ ពីក្នុងចំណោមបុគ្គលទាំងនោះ ដើម្បីធ្វើជាដើមចោទ ឬ ចុងចម្លើយសម្រាប់បុគ្គលទាំងនោះបាន ។

២- ប្រសិនបើបានជ្រើសរើសដើមចោទ ឬ ចុងចម្លើយ តាមកថាខណ្ឌទី ១ ខាងលើនេះ នៅពេលដែលតុលាការកំពុងចាត់ការបណ្ដឹង ភាគីផ្សេងទៀតត្រូវដកខ្លួនពីបណ្ដឹងនោះដោយស្វ័យប្រវត្តិ ។

៣- អ្នកដែលបានធ្វើការជ្រើសរើសដើមចោទ ឬ ចុងចម្លើយតាមកថាខណ្ឌទី ១ ខាងលើនេះ អាចលុបចោលនូវការជ្រើសរើស ឬ អាចផ្លាស់ប្ដូរភាគីដែលត្រូវបានជ្រើសរើសនោះបាន ។

៤- ក្នុងចំណោមភាគីដែលត្រូវបានជ្រើសរើស ប្រសិនបើមានអ្នកណាបានបាត់បង់នូវលក្ខណៈជាភាគីដែលត្រូវបានជ្រើសរើស ដោយសារបានទទួលមរណភាព ឬ ដោយសារហេតុផ្សេងទៀត ភាគីដែលត្រូវបានជ្រើសរើសផ្សេងទៀតអាចធ្វើសកម្មភាពបណ្ដឹងសម្រាប់បុគ្គលទាំងអស់បាន ។

(កំណត់)

សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 30 ។ ប្រព័ន្ធជ្រើសរើសភាគីនេះ ជាប្រភេទនៃប្រព័ន្ធមួយដែលទទួលបន្ទុកបណ្ដឹងដោយស្ម័គ្រចិត្ត ។ អ្នកជ្រើសរើសមិនមែនជាភាគីតាំងពីដំបូងទេ ក្នុងករណីនៃកថាខណ្ឌទី ១ ឬ ក្នុងករណីនៃកថាខណ្ឌទី ២ វិញ ពេលធ្វើការជ្រើសរើសហើយ អ្នកជ្រើសរើស ត្រូវដកខ្លួនពីបណ្ដឹង ហើយភាគីដែលត្រូវបានជ្រើសរើស ធ្វើបណ្ដឹងសម្រាប់ខ្លួនផង និង សម្រាប់អ្នកជ្រើសរើសផងដែរ ។ ហេតុនេះហើយ សាលក្រម ឬ សាលដីកា

ដែលអ្នកត្រូវបានជ្រើសរើសបានទទួល ក៏មានអានុភាពទៅលើអ្នកជ្រើសរើសដែរ (សូមមើលមាត្រា ១៩៨ (វិសាលភាពបុគ្គលដែលត្រូវទទួលអានុភាពរបស់សាលក្រមស្ថាពរ) ចំណុច ២ ដែលចែងអំពី "អានុភាពនៃសាលក្រមស្ថាពរ ចំពោះតតិយជនដែលត្រូវគេទទួលបន្ទុក ក្នុងករណីដែលភាគីទទួលបន្ទុកក្នុងការធ្វើជាដើមចោទ ឬ ចុងចម្លើយសម្រាប់តតិយជននោះ") ។

ឧទាហរណ៍ ចំពោះករណីគ្រោះថ្នាក់ដែលមានអ្នករងគ្រោះច្រើន ប្រសិនបើអ្នករងគ្រោះច្រើននាក់នោះប្រើប្រព័ន្ធជ្រើសរើសនេះ ការងារទាក់ទងនឹងបណ្ដឹងនេះ នឹងអាចចាត់ចែងបានស្រួលជាងពេលដែលអ្នករងគ្រោះទាំងអស់ធ្វើជាភាគីនៃបណ្ដឹង ។ ម្យ៉ាងទៀត បើសិនជាភាគីទាំងអស់អាចព្រមព្រៀងគ្នាធ្វើការជ្រើសរើសអ្នកតំណាងដោយអាណត្តិរួមម្នាក់ (មេធាវី) ក៏អាចសម្រួលដល់បណ្ដឹងដូចគ្នាដែរ ។

Code of Civil Procedure (Japan)
**Article 30** (Appointed party)
1. Several parties having a common interest and not included under the provisions of the preceding article, may appoint from among themselves one or more persons who will act as plaintiff(s) or defendant(s) for the entire body.
2. In cases where a person(s) has (or have) been appointed to act as plaintiff(s) or defendant(s) in accordance with the provisions of the preceding paragraph subsequent to the pendency of the suit, the other parties shall withdraw the suit by operation of law.
3. Persons who possess an interest in common with the plaintiff(s) or defendant(s) in a pending suit, and who are not parties thereto, may appoint such plaintiff(s) or defendant(s) to act as the plaintiff(s) or defendant(s) also in there stead.
4. Persons (hereinafter referred to as "appointers") who have appointed another person(s) who will act as plaintiff(s) or defendant(s) in accordance with the provisions of paragraph 1 or the preceding paragraph, may cancel the appointment or change such parties (hereinafter referred to as the "appointed parties") appointed.
5. In cases where any of the appointed parties has lost the capacity as such due to death or any other reason, the remaining appointed parties may conduct acts of litigation for the entire body.

## ផ្នែកទី ៣ ការចូលរួមអន្តរាគមន៍ក្នុងបណ្ដឹង

**មាត្រា ៤៣.-** ការចូលរួមជួយអន្តរាគមន៍

តតិយជនណាដែលមានការទាក់ទងនឹងផលប្រយោជន៍តាមផ្លូវច្បាប់ អំពីលទ្ធផលនៃបណ្ដឹង អាចចូលរួមអន្តរាគមន៍ក្នុងបណ្ដឹង ដើម្បីជួយភាគីម្ខាងណាមួយបាន ។

(កំណត់)

សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 42 ។

ការចូលរួមជួយអន្តរាគមន៍គឺ តតិយជនដែលមាន "ការទាក់ទងនឹងផលប្រយោជន៍តាមផ្លូវច្បាប់" អំពីលទ្ធផលនៃបណ្ដឹងរបស់អ្នកផ្សេង ចូលរួមក្នុងបណ្ដឹងនោះ ដើម្បីជួយភាគីម្ខាង (អ្នកដែលត្រូវបានចូលរួមជួយអន្តរាគមន៍) ឱ្យបានឈ្នះ ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ។

ទំនាក់ទំនងនឹងផលប្រយោជន៍នេះ ត្រូវជាផលប្រយោជន៍តាមផ្លូវច្បាប់ ហើយលទ្ធផលនៃបណ្ដឹងនឹងមានឥទ្ធិពល តាម

ច្បាប់សារធាតុ ទៅលើសិទ្ធិ ឬ កាតព្វកិច្ចរបស់បុគ្គលដែលចូលរួមជួយអន្តរាគមន៍នោះ ទើបអាចទទួលស្គាល់បាន (គេហៅថា ផលប្រយោជន៍ក្នុងការចូលរួមជួយអន្តរាគមន៍) ។ ឧទាហរណ៍ ចំពោះបណ្តឹងទាមទារអនុវត្តកាតព្វកិច្ចធានា ចំពោះអ្នកធានាដែលធ្វើឡើងដោយម្ចាស់បំណុល ប្រសិនបើអ្នកធានាចាញ់បណ្តឹងនោះ កូនបំណុលដែលមានកាតព្វកិច្ចចម្បងនឹងត្រូវអ្នកធានាទាមទារឱ្យសងវិញ ហេតុនេះហើយ កូនបំណុលដែលមានកាតព្វកិច្ចចម្បង មានផលប្រយោជន៍ ក្នុងការចូលរួមជួយអន្តរាគមន៍ក្នុងបណ្តឹងនោះ ។ រីឯករណីដែលជនម្នាក់ចង់ចូលរួមជួយអន្តរាគមន៍ដល់ញាតិ ឬ មិត្តនោះ គឺគ្រាន់តែជាផលប្រយោជន៍ខាងផ្លូវចិត្តទេ ដូច្នេះគេមិនអាចទទួលស្គាល់ថាជាផលប្រយោជន៍ក្នុងការចូលរួមជួយអន្តរាគមន៍បានទេ ។

ម្យ៉ាងទៀត អ្នកនោះនឹងត្រូវទទួលឥទ្ធិពលនៃការពង្រីកអានុភាពនៃសាលក្រម ឬ មិនទទួលនោះ គ្មានទាក់ទងនឹងផលប្រយោជន៍ ក្នុងការចូលរួមជួយអន្តរាគមន៍ទេ ។

Code of Civil Procedure (Japan)
**Article 42** (Assisting intervention)
A third person having an interest affected by the result of a suit may intervene in order to assist either party.

**មាត្រា ៤៤.-** ពាក្យសុំចូលរួមជួយអន្តរាគមន៍

១- ពាក្យសុំចូលរួមជួយអន្តរាគមន៍ ត្រូវធ្វើទៅតុលាការដែលខ្លួននឹងត្រូវធ្វើសកម្មភាពបណ្តឹង តាមការចូលរួមជួយអន្តរាគមន៍ ដោយមានបញ្ជាក់ថា តើចូលរួមជួយអន្តរាគមន៍ សម្រាប់ភាគីណានៃបណ្តឹងណា ព្រមទាំងបញ្ជាក់នូវមូលហេតុនៃការចូលរួមឱ្យបានច្បាស់លាស់ផង ។

២- ពាក្យសុំចូលរួមជួយអន្តរាគមន៍ អាចធ្វើឡើងបាន ព្រមជាមួយគ្នានឹងសកម្មភាពបណ្តឹងដែលអ្នកចូលរួមជួយអន្តរាគមន៍អាចធ្វើបាន ។

(កំណត់)

សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 43 ។

សំណើសុំចូលរួមជួយអន្តរាគមន៍ ត្រូវធ្វើទៅតុលាការដែលខ្លួននឹងត្រូវធ្វើសកម្មភាពបណ្តឹង ក្រោយពីចូលរួម ជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ ។ ឧទាហរណ៍ ក្រោយពីការប្រកាសសាលក្រមនៅសាលាដំបូងហើយ នៅក្នុងអំឡុងពេលដែលអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍ (អ្នកចាញ់ក្តី) អាចប្តឹងឧទ្ធរណ៍បាន នោះអ្នកចង់ចូលរួមជួយអន្តរាគមន៍ត្រូវដាក់ពាក្យសុំចូលរួមទៅតុលាការនៃបណ្តឹងឧទ្ធរណ៍ ព្រមជាមួយគ្នានឹងការដាក់ពាក្យបណ្តឹងឧទ្ធរណ៍នោះ ។

"មូលហេតុនៃការចូលរួម" ដែលមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ មានន័យថាជាទំនាក់ទំនងអង្គហេតុដែលអាចបញ្ជាក់គ្រប់គ្រាន់អំពីការទាក់ទងនឹងផលប្រយោជន៍តាមផ្លូវច្បាប់ (=ផលប្រយោជន៍ក្នុងការចូលរួមជួយអន្តរាគមន៍) ដែលមានចែងក្នុងមាត្រា ៤៣ (ការចូលរួមជួយអន្តរាគមន៍) និង មានបញ្ជាក់ក្នុងកំណត់នៃមាត្រា ៤៣ ។

លក្ខខណ្ឌទូទៅដើម្បីធ្វើសកម្មភាពបណ្ដឹង ដូចជាសមត្ថភាពក្នុងការធ្វើបណ្ដឹង និង សិទ្ធិតំណាង ជាដើម គឺជាចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិ ហេតុដូច្នេះ ប្រសិនបើមានការសង្ស័យ នៅពេលមានពាក្យសុំចូលរួមជួយអន្តរាគមន៍ តុលាការត្រូវចេញដីកាសម្រេចបង្គាប់ឱ្យកែតម្រូវចំណុចខ្វះនោះដោយឆន្ទានុសិទ្ធិ ។ ប្រសិនបើ អ្នកចូលរួមជួយអន្តរាគមន៍មិនធ្វើតាមដីកាសម្រេចនោះ តុលាការនឹងលើកចោលពាក្យសុំ ចូលរួមជួយអន្តរាគមន៍ ។

ចំពោះមូលហេតុនៃការចូលរួមជួយអន្តរាគមន៍ (ផលប្រយោជន៍ក្នុងការចូលរួមជួយអន្តរាគមន៍) ប្រសិនបើមានការបញ្ជាញអំពីទំនាក់ទំនងនៃអង្គហេតុដែលចង្អុលនូវមូលហេតុនោះ ពាក្យសុំនឹងត្រូវបានទទួលស្គាល់ លើកលែងតែមូលហេតុនោះច្បាស់ជាមានភាពផ្ទុយនឹងច្បាប់ ហើយមានតែពេលដែលភាគីតវ៉ាទេ តុលាការត្រូវពិនិត្យអំពីមូលហេតុនៃការចូលរួមជួយអន្តរាគមន៍ ដោយតម្រូវឱ្យអ្នកចូលរួមជួយអន្តរាគមន៍ ធ្វើសេចក្ដីបញ្ជាក់ដំបូង អំពីមូលហេតុនោះ ។ ប្រសិនបើគ្មានការតវ៉ាពីភាគីទេ តុលាការអាចចាត់ទុកអ្នកដែលដាក់ពាក្យសុំចូលរួមជួយអន្តរាគមន៍ ជាអ្នកចូលរួមជួយអន្តរាគមន៍បាន ។ ក្នុងន័យនេះ ទោះបីជាមូលហេតុនៃការចូលរួមជួយអន្តរាគមន៍ មានភាពមិនច្បាស់លាស់ក៏ដោយ ក៏អាចមានករណីដែលតុលាការចាត់ទុកអ្នកដែលដាក់ពាក្យសុំចូលរួមជួយអន្តរាគមន៍ ជាអ្នកចូលរួមជួយអន្តរាគមន៍ដែរ ។

Code of Civil Procedure (Japan)
**Article 43** (Application for assisting intervention)
1. An application for an assisting intervention shall clearly indicate the import and grounds therefor to the court where acts of litigation by the assisting intervention are to be conducted.
2. An application for an assisting intervention may be made with other acts of litigation which may be conducted by an assisting intervener.

**មាត្រា ៤៥.-** បណ្ដឹងតវ៉ានឹងការចូលរួមជួយអន្តរាគមន៍ ជាអាទិ៍

១- ប្រសិនបើភាគីប្ដឹងតវ៉ានឹងការចូលរួមជួយអន្តរាគមន៍ តុលាការត្រូវសម្រេចសេចក្ដីនូវការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យចូលរួមជួយអន្តរាគមន៍ ដោយដីកាសម្រេច ។ ក្នុងករណីនេះ អ្នកចូលរួមជួយអន្តរាគមន៍ត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីមូលហេតុនៃការចូលរួម ។

២- បណ្ដឹងតវ៉ាដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចធ្វើបានឡើយ ក្រោយពេលភាគីបានធ្វើសេចក្ដីដោះសានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ បានធ្វើការឆ្លើយទាញហេតុផលនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ដោយគ្មានប្ដឹងតវ៉ានោះ ។

៣- ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

(កំណត់)

សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 44 ។

មាត្រានេះ មានន័យថា បើមានតតិយជនដាក់ពាក្យសុំចូលរួមជួយអន្តរាគមន៍ ខាងដើមចោទ ឬ ចុងចម្លើយ តុលាការមិនធ្វើការវិនិច្ឆ័យពីការអនុញ្ញាត ឬ មិនអនុញ្ញាតឡើយ បើពុំមានការតវ៉ាពីភាគី ។ ដូច្នេះ បើមានការតវ៉ា

ដើម្បីឱ្យតុលាការមានមូលដ្ឋានក្នុងការសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យតតិយជននោះ ចូលរួមជួយអន្តរាគមន៍ តម្រូវឱ្យតតិយជនធ្វើសេចក្តីបញ្ជាក់ដំបូងពីមូលហេតុនៃការចូលរួមជួយអន្តរាគមន៍របស់ខ្លួន ។

Code of Civil Procedure (Japan)
**Article 44** (Objection to assisting intervention, etc.)
1. In cases where a party raises an objection to an assisting intervention, a court shall decide, by ruling, whether to permit or reject such assisting intervention. In such cases, an assisting intervener shall offer a preliminary showing on the grounds for intervention.
2. The objection referred to in the preceding paragraph shall not be raised after such party has proceeded orally or has made statements in the preparations for argument proceedings without raising the objection.
3. An immediate *kokoku*-apeal may be made against the ruling referred to in paragraph 1.

**មាត្រា ៤៦.-** សកម្មភាពបណ្តឹងនៃអ្នកចូលរួមជួយអន្តរាគមន៍

១- អ្នកចូលរួមជួយអន្តរាគមន៍អាចដាក់វិធីតទល់ ឬ ការពារខ្លួន អាចធ្វើការប្តឹងតវ៉ា អាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ អាចទាមទារឱ្យធ្វើការជំនុំជម្រះសាជាថ្មី និង អាចធ្វើសកម្មភាពបណ្តឹងផ្សេងទៀតដែលទាក់ទងនឹងបណ្តឹងនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសកម្មភាពដែលអ្នកត្រូវគេជួយចូលរួមអន្តរាគមន៍មិនអាចធ្វើបាន នៅពេលដែលខ្លួនបានចូលរួមជួយអន្តរាគមន៍ ។

២- ប្រសិនបើសកម្មភាពបណ្តឹងដែលធ្វើដោយអ្នកចូលរួមជួយអន្តរាគមន៍ បានប៉ះពាល់ប្រឆាំងនឹងសកម្មភាពបណ្តឹងរបស់អ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍ សកម្មភាពនោះពុំមានអានុភាពឡើយ ។

៣- ទោះជាមានការប្តឹងតវ៉ាចំពោះការចូលរួមជួយអន្តរាគមន៍ក៏ដោយ ក៏អ្នកចូលរួមជួយអន្តរាគមន៍អាចធ្វើសកម្មភាពបណ្តឹងបានដែរ រហូតដល់ពេលដែលការសម្រេចសេចក្តីរបស់តុលាការថា មិនអនុញ្ញាតឱ្យចូលរួមជួយអន្តរាគមន៍នោះចូលជាស្ថាពរ ។

៤- សកម្មភាពបណ្តឹងរបស់អ្នកចូលរួមជួយអន្តរាគមន៍ ទោះជាការសម្រេចសេចក្តីរបស់តុលាការថា មិនអនុញ្ញាតឱ្យចូលរួមជួយអន្តរាគមន៍ ចូលជាស្ថាពរក៏ដោយ ក៏សកម្មភាពនោះ នឹងមានអានុភាពដែរ ប្រសិនបើភាគីបានលើកឡើងនូវសកម្មភាពនោះ ។

(កំណត់)

សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 45 ។

អ្នកចូលរួមជួយអន្តរាគមន៍ជាអ្នកដែលចូលជួយភាគីដើមចោទ ឬ ចុងចម្លើយ (អ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍) ហេតុនេះហើយ អ្នកនេះគឺជាភាគីបន្ទាប់បន្សំ (ដែលជាឋានៈបន្ទាប់បន្សំ) ដែលមិនមែនជាភាគីដើមនៃបណ្តឹងឡើយ ។ ដូច្នេះហើយ សកម្មភាពដែលអ្នកចូលរួមជួយអន្តរាគមន៍នោះអាចធ្វើបាន គឺមានកម្រិត ។

ក្នុងកថាខណ្ឌទី ១ វាក្យខណ្ឌទី ២ ("ប៉ុន្តែ បញ្ញត្តិនេះ .... អន្តរាគមន៍ ។") ចែងថា ចំពោះសកម្មភាពអ្វីៗដែលអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍ (ដើមចោទ ឬ ចុងចម្លើយ) មិនអាចធ្វើបានពេលដែលចូលរួមជួយអន្តរាគមន៍

អ្នកចូលរួមជួយអន្តរាគមន៍ក៏មិនអាចធ្វើបានដែរ ។ ឧទាហរណ៍ វិធីតទល់ និង ការពារខ្លួនដែលអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍ (ដើមចោទ ឬ ចុងចម្លើយ) បានដាក់ តែត្រូវតុលាការលើកចោលដោយសារតែហួសពេលសមរម្យដើម្បីដាក់នោះ អ្នកចូលរួមជួយអន្តរាគមន៍ក៏មិនអាចដាក់វិធីនោះបានដែរ ហើយប្រសិនបើអំឡុងពេលដែលអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍អាចធ្វើបណ្តឹងឧទ្ធរណ៍បាននោះ បានកន្លងផុតទៅហើយ អ្នកចូលរួមជួយអន្តរាគមន៍ ក៏មិនអាចធ្វើបណ្តឹងឧទ្ធរណ៍បានដែរ ។

ម្យ៉ាងទៀត តាមកថាខណ្ឌទី ២ ចំពោះអង្គហេតុដែលអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍មិនទាន់បានសារភាពនោះ ទោះបីជាអ្នកចូលរួមជួយអន្តរាគមន៍មិនទទួលស្គាល់ក៏ដោយ ប៉ុន្តែ ប្រសិនបើក្រោយមកអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍នោះ បានសារភាព ការមិនទទួលស្គាល់របស់អ្នកចូលរួមជួយអន្តរាគមន៍នោះនឹងត្រូវបាត់បង់អានុភាព ។

ក្រៅពីនេះ អ្នកចូលរួមជួយអន្តរាគមន៍មិនអាចដកបណ្តឹង មិនអាចលះបង់ការទាមទារ ឬ ទទួលស្គាល់ការទាមទារ មិនអាចផ្សះផ្សាលើបណ្តឹង មិនអាចផ្លាស់ប្តូរបណ្តឹង ជាដើម បានឡើយ ។

Code of Civil Procedure (Japan)
**Article 45** (Acts of litigation by assisting intervener)
1. An assisting intervener may, with respect to the suit, advance offensive or defensive measures, raise objections, file appeals, file petitions for retrial and conduct all other acts of litigation. However, this shall not apply to such acts as may not be done at the stage of the suit at which the assisting intervention is made.
2. Acts of litigation conducted by an assisting intervener shall not take effect when they are inconsistent with those of the party in whose favor the assisting intervener has intervened.
3. An assisting intervener may, until a decision rejecting the intervention becomes final and binding, conduct acts of litigation even where there has been an objection to such intervention.
4. Acts of litigation by an assisting intervener shall, in cases where a party has quoted them, take effect, even when the decision rejecting the intervention becomes final and binding.

**មាត្រា ៤៧.-** អានុភាពនៃការសម្រេចសេចក្តីទៅលើអ្នកចូលរួមជួយអន្តរាគមន៍

ចំពោះបណ្តឹងដែលមានការចូលរួមជួយអន្តរាគមន៍ បើសាលក្រមដែលសម្រេចឱ្យមានការខូចផលប្រយោជន៍របស់អ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍ បានចូលជាស្ថាពរហើយ សេចក្តីវិនិច្ឆ័យរបស់សាលក្រមនោះមានចំណងទៅលើអ្នកចូលរួមជួយអន្តរាគមន៍ ក្នុងទំនាក់ទំនងជាមួយនឹងអ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍ លើកលែងតែក្នុងករណីដែលមានចែងដូចខាងក្រោមនេះ :

**ក-** បើអ្នកចូលរួមជួយអន្តរាគមន៍ មិនអាចធ្វើសកម្មភាពបណ្តឹង ដោយបញ្ញត្តិនៃវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ មាត្រា ៤៦ (សកម្មភាពបណ្តឹងនៃអ្នកចូលរួមជួយអន្តរាគមន៍) ខាងលើនេះ ។

**ខ-** បើសកម្មភាពបណ្តឹងរបស់អ្នកចូលរួមជួយអន្តរាគមន៍ គ្មានអានុភាព ដោយបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៤៦ (សកម្មភាពបណ្តឹងនៃអ្នកចូលរួមជួយអន្តរាគមន៍) ខាងលើនេះ ។

**គ-** បើអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍ បានរារាំងសកម្មភាពបណ្តឹងរបស់អ្នកចូលរួមជួយអន្តរាគមន៍ ។

**ឃ-** បើអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍ មិនបានធ្វើសកម្មភាពបណ្តឹងដែលអ្នកចូលរួមជួយអន្តរាគមន៍មិនអាចធ្វើ

បាន ដោយចេតនា ឬ ដោយកំហុសរបស់ខ្លួន ។

（កំណត់）

សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 46 ។

សាលក្រមនៃបណ្តឹងដែលអ្នកចូលរួមជួយអន្តរាគមន៍បានចូលរួម មានអានុភាពឱ្យចូលជាស្ថាពរទៅលើដើមចោទ និងចុងចម្លើយ ប៉ុន្តែក្រៅពីនេះ មានអានុភាពពិសេសដែរ គឺអានុភាពនៃការចូលរួមជួយអន្តរាគមន៍ ។ អានុភាពនៃការចូលរួមជួយអន្តរាគមន៍ គឺ ពេលណាអ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍ចាញ់ក្តី អ្នកចូលរួមជួយអន្តរាគមន៍ក៏ត្រូវទទួលខុសត្រូវចំពោះការចាញ់ក្តីជាមួយគ្នាដែរ ដើម្បីឱ្យមានសមភាព ។ ហេតុនេះហើយ អានុភាពនេះត្រូវកើតឡើង រវាងអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍ និង អ្នកចូលរួមជួយអន្តរាគមន៍ ចំពោះតែករណីដែលអ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍ចាញ់ក្តីតែប៉ុណ្ណោះ ។ នេះខុសពីអានុភាពឱ្យចូលជាស្ថាពរ គឺមានអានុភាពមិនត្រឹមតែលើសេចក្តីវិនិច្ឆ័យក្នុងសេចក្តីសម្រេចបញ្ចប់ (formal disposition, forme de dispositif) នៃសាលក្រមតែប៉ុណ្ណោះទេ គឺមានអានុភាពលើសេចក្តីវិនិច្ឆ័យក្នុងមូលហេតុនៃសាលក្រមផងដែរ ។ ឧទាហរណ៍ ដូចជាករណីដែលបានបញ្ជាក់ក្នុងកំណត់នៃមាត្រា ៤៣ (ការចូលរួមជួយអន្តរាគមន៍) កូនបំណុលដែលមានកាតព្វកិច្ចចម្បង ហើយបានចូលរួមជួយអន្តរាគមន៍សម្រាប់អ្នកធានាក្នុងបណ្តឹងស្តីពីអត្ថិភាពនៃកាតព្វកិច្ចចម្បង ប្រសិនបើអ្នកធានាបានចាញ់ក្តីនោះ ហើយអ្នកធានាបានធ្វើបណ្តឹងទាមទារឱ្យអ្នកមានកាតព្វកិច្ចចម្បងឱ្យសងសំណងនោះ អ្នកមានកាតព្វកិច្ចចម្បងមិនអាចធ្វើវិវាទអំពីអត្ថិភាពនៃកាតព្វកិច្ចចម្បងនោះបានទេ ដោយសារតែមានអានុភាពនៃការចូលរួមជួយអន្តរាគមន៍ ។

ប៉ុន្តែ តាមគោលការណ៍ អានុភាពនេះ ត្រូវបានទទួលស្គាល់ដោយមូលហេតុនៃសមភាពក្នុងការទទួលខុសត្រូវ ចំពោះការចាញ់ក្តី ហេតុដូច្នេះ ប្រសិនបើអ្នកចូលរួមជួយអន្តរាគមន៍មិនបានធ្វើសកម្មភាពបណ្តឹងដោយសេរីទេនោះ ហើយឱ្យអ្នកចូលរួមជួយអន្តរាគមន៍នោះទទួលខុសត្រូវចំពោះការចាញ់ក្តីថែមទៀត នោះវាផ្ទុយនឹងសមភាព ហេតុដូច្នេះ អានុភាពនៃការចូលរួមជួយអន្តរាគមន៍ មិនត្រូវកើតមានឡើយ ។ ចំណុចនីមួយៗនៃមាត្រានេះ ចែងអំពីករណីលើកលែងដែលមិនត្រូវអនុវត្តតាមគោលការណ៍នេះ ។

Code of Civil Procedure (Japan)
**Article 46** (Effect of judgment on assisting intervener)
The judgment of the court in the suit in which an assisting intervention was made shall bind the assisting intervener except in the following cases:

i. in cases where the assisting intervener could not conduct acts of litigation in accordance with the provisions of the proviso of paragraph 1 of the preceding article;
ii. in cases where the assisting intervener's acts of litigation were ineffective in accordance with the provisions of the preceding article, paragraph 2;
iii. in cases where the party in whose favor the intervention was made obstructed the acts of litigation conducted by the assisting intervener;
iv. in cases where the party in whose favor the intervention was made failed, wither intentionally or negligently, to conduct the acts of litigation which the assisting intervener was barred from conducting.

**មាត្រា ៤៨.–** ការចូលរួមជួយអន្តរាគមន៍ក្នុងលក្ខណៈដូចជាសហបណ្ដឹង

១- បើសាលក្រមមានអានុភាពស្ថាពររវាងអ្នកចូលរួមជួយអន្តរាគមន៍ និង ភាគីម្ខាងទៀតនៃអ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍ ឋានៈរបស់អ្នកចូលរួមជួយអន្តរាគមន៍លើបណ្ដឹងមានដូចគ្នានឹងអ្នកធ្វើសហបណ្ដឹងដែលបានកំណត់នៅក្នុងបញ្ញត្តិនៃមាត្រា ៤១ (បទបញ្ញាស្ដីពីការវិនិច្ឆ័យលើសហបណ្ដឹងចាំបាច់) នៃក្រមនេះ ។

២- ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ កថាខណ្ឌទី ២ នៃមាត្រា ៤៦ (សកម្មភាពបណ្ដឹងនៃអ្នកចូលរួមជួយអន្តរាគមន៍) និង ចំណុច **ខ** និង ចំណុច **គ** នៃមាត្រា ៤៧ (អានុភាពនៃការសម្រេចសេចក្ដីទៅលើអ្នកចូលរួមជួយអន្តរាគមន៍) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ។

(កំណត់)

សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា 69 (នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន គ្មានចែងជាលាយលក្ខណ៍អក្សរទេ ប៉ុន្តែតាមការបកស្រាយទូទៅលើករណីយុត្តិសាស្ត្រ និង តាមការវិនិច្ឆ័យមុនៗ គេទទួលស្គាល់ការចូលរួមជួយអន្តរាគមន៍ក្នុងលក្ខណៈដូចជាសហបណ្ដឹង (Streitgenössische Nebenintervention)) ។

ក្នុងករណីដែលសាលក្រមមានអានុភាពស្ថាពរទៅលើអ្នកចូលរួមជួយអន្តរាគមន៍ និង ភាគីម្ខាងទៀតនៃអ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍ ត្រូវតែធានាឱ្យអ្នកចូលរួមជួយអន្តរាគមន៍មានឱកាសចូលរួមក្នុងបណ្ដឹងឱ្យបានគ្រប់គ្រាន់ក្នុងទំនាក់ទំនងជាមួយភាគីម្ខាងទៀត ។ ពេលនោះត្រូវតែទទួលស្គាល់ឋានៈដែលមានឯករាជ្យភាពរបស់អ្នកចូលរួមជួយអន្តរាគមន៍នោះ ខ្លាំងជាងអ្នកចូលរួមជួយអន្តរាគមន៍ធម្មតា ។ កថាខណ្ឌទី ១ ទទួលស្គាល់ឋានៈអ្នកចូលរួមជួយអន្តរាគមន៍ស្មើនឹងឋានៈអ្នកធ្វើសហបណ្ដឹងជាចាំបាច់ (ពេលណាតតិយជននោះមានលក្ខណៈជាភាគីហើយ តតិយជននោះអាចចូលរួមក្នុងសហបណ្ដឹងបាន តាមការចែងក្នុងមាត្រា ៤៩ (ការចូលរួមអន្តរាគមន៍ក្នុងសហបណ្ដឹង) ប៉ុន្តែ ប្រសិនបើគ្មានលក្ខណៈនេះទេ អត្ថិភាពនៃបញ្ញត្តិស្ដីពីការចូលរួមជួយអន្តរាគមន៍ក្នុងលក្ខណៈដូចជាសហបណ្ដឹង នឹងមានអត្ថន័យ) ។

ឧទាហរណ៍ នៅប្រទេសជប៉ុន មានដូចជាករណីដែលអ្នកដឹកនាំក្រុមហ៊ុនបានចូលរួមជួយអន្តរាគមន៍ខាងភាគីក្រុមហ៊ុនដែលជាចុងចម្លើយ ក្នុងបណ្ដឹងទាមទារឱ្យលុបចោលនូវការសម្រេចនៃមហាសន្និបាតនៃអ្នកចូលហ៊ុន ដែលបានសម្រេចជ្រើសរើសអ្នកដឹកនាំនោះ (សូមមើលច្បាប់ពាណិជ្ជកម្មជប៉ុន មាត្រា 247 និង មាត្រា 109 ។ បើចូលរួមជួយអន្តរាគមន៍ខាងដើមចោទ (ម្ចាស់ហ៊ុន) នឹងក្លាយទៅជាការចូលរួមក្នុងសហបណ្ដឹង) ឬ ករណីដែលកូនបំណុលបានចូលរួមជួយអន្តរាគមន៍ ក្នុងបណ្ដឹងឧបាទេសកម្មនៃម្ចាស់បំណុល (មាត្រា ១៩៨ (វិសាលភាពបុគ្គលដែលត្រូវទទួលអានុភាពរបស់សាលក្រមស្ថាពរ) ចំណុច **ខ**) ។ល។

ក្នុងករណីដែលបានចូលរួមជួយអន្តរាគមន៍ក្នុងលក្ខណៈដូចសហបណ្ដឹង :

① សកម្មភាពបណ្ដឹងរបស់អ្នកចូលរួមជួយអន្តរាគមន៍ ទោះបីជាមានប៉ះពាល់នឹងសកម្មភាពបណ្ដឹងរបស់អ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍ក៏ដោយ ឱ្យតែអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍មានផលប្រយោជន៍ អានុភាពនេះនឹងកើតមាន

ឡើង (សូមមើលកថាខណ្ឌទី ២ នៃមាត្រានេះ និង មាត្រា ៤១ (បទបញ្ញាស្តីពីការវិនិច្ឆ័យលើសហបណ្តឹងចាំបាច់) កថាខណ្ឌទី ១) ។ ឧទាហរណ៍ ទោះបីជាអ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍ បានបោះបង់នូវសិទ្ធិប្តឹងឧទ្ធរណ៍ក៏ដោយ ក៏អ្នកចូលរួមជួយអន្តរាគមន៍អាចធ្វើបណ្តឹងឧទ្ធរណ៍បានដែរ ហើយពេលនោះ អ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍នោះ មិនអាចដកពាក្យបណ្តឹងឧទ្ធរណ៍នោះមកវិញបានទេ ។

② អំឡុងពេលដែលអ្នកចូលរួមជួយអន្តរាគមន៍អាចប្តឹងឧទ្ធរណ៍បាននោះ ត្រូវគិតផ្សេងដោយឡែកពីអំឡុងពេលដែលអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍អាចប្តឹងឧទ្ធរណ៍បាន ។

③ ប្រសិនបើមូលហេតុនៃការផ្អាក ឬ បង្អង់នូវនីតិវិធី កើតឡើងចំពោះអ្នកចូលរួមជួយអន្តរាគមន៍ តុលាការអាចបង្គាប់ឱ្យបង្អង់នូវនីតិវិធីបណ្តឹងនោះបាន (ចំពោះការផ្អាក ការបង្អង់ និង ការទទួលបន្តនូវនីតិវិធី សូមមើលគន្លឹទី ២ ជំពូកទី ៤ ស្តីពី "ការផ្អាក និង បង្អង់នីតិវិធីនៃបណ្តឹង" (មាត្រា ១៧៣ (ការផ្អាក និង ការទទួលបន្តនីតិវិធីនៃបណ្តឹង) ទៅ)) ។

Code of Civil Procedure Rules (Germany)
**Article 69** (Joinder by joint parties)
Insofar as under the provisions of the civil law the validity of the decision given in the main action is effective as regards the legal relation between the intervening third party and the opponent, the intervening third party is regarded within the meaning of §61 as joint party with the main party.

Commercial Code (Japan)
**Article 247** (Action to quash resolution; bringing of action, etc.)
1. A shareholder, director or auditor may bring an action seeking to quash a resolution of a general meeting in the following cases:
i. where the procedures for convening or voting at the meeting contravene the Articles of Incorporation or any law or ordinance, or are grossly unfair;
ii. where the content of the resolution contravenes the Articles of Incorporation;
iii. where the resolution is grossly inappropriate in consequence of the exercise of voting rights by a shareholder with a special interest in the resolution.
2. The provisions of Article 88, of paragraph 3 and 4 of Article 105. and of Article 109 shall apply *mutatis mutandis* to the action provided for in the preceding paragraph.
**Article 109** (Effect of judgment as against third party
1. A judgment declaring the nullity of a merger shall also have effect as against a third party.
2. Where the plaintiffs' action has failed and they have acted in bad faith or with gross negligence, they shall be jointly and severally liable in damages to the company.

## **មាត្រា ៤៩.–** ការចូលរួមអន្តរាគមន៍ក្នុងសហបណ្តឹង

១- ក្នុងករណីដែលសិទ្ធិ ឬ កាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្តឹង នឹងត្រូវបានសម្រេចជាស្ថាពរ ទាល់តែមានការរួមគ្នាចំពោះភាគីណាមួយ និង តតិយជន តតិយជននោះអាចចូលរួមអន្តរាគមន៍ក្នុងបណ្តឹងនោះ ក្នុងនាមជាអ្នកធ្វើសហបណ្តឹងបាន ។

២- បញ្ញត្តិនៃមាត្រា ៤៤ (ពាក្យសុំចូលរួមជួយអន្តរាគមន៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះពាក្យសុំចូលរួមអន្តរាគមន៍ក្នុងបណ្តឹង តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

៣- ពាក្យសុំចូលរួមអន្តរាគមន៍ក្នុងបណ្តឹងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ។

៤- ពាក្យសុំជាលាយល័ក្ខណ៍អក្សរដែលបានកំណត់នៅកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវបញ្ជូនទៅអ្នកផ្សេងដែលធ្វើ

សហបណ្តឹង និង ភាគីម្ខាងទៀត ។

(កំណត់)

សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 52 ។

ការចូលរួមជួយអន្តរាគមន៍ក្នុងសហបណ្តឹង គឺជាករណីដែលតតិយជនដែលនឹងត្រូវទទួលអានុភាពនៃសាលក្រម (អានុភាពស្ថាពរ) ចូលរួមជាមួយភាគីម្ខាងនៃបណ្តឹងដែលកំពុងតែចាត់ការ ក្នុងនាមជាអ្នកធ្វើសហបណ្តឹង ។ ចំណុចដែលចូលរួមក្នុងនាមជាភាគីនេះ ជាចំណុចមួយខុសនឹងការចូលរួមជួយអន្តរាគមន៍ក្នុងលក្ខណៈដូចជាសហបណ្តឹងដែលមានចែងក្នុងមាត្រា ៤៨ (ការចូលរួមជួយអន្តរាគមន៍ក្នុងលក្ខណៈដូចជាសហបណ្តឹង) ។

"ក្នុងករណីដែលសិទ្ធិ ឬ កាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្តឹង ត្រូវបានសម្រេចជាស្ថាពរ ទាល់តែមានការរួមគ្នាចំពោះភាគីណាមួយ និង តតិយជន" គឺជាករណីនៃសហបណ្តឹងជាចាំបាច់ ដែលមានចែងក្នុងមាត្រា ៤១ (បទបញ្ញត្តិពីការវិនិច្ឆ័យលើសហបណ្តឹងជាចាំបាច់) ហើយមានន័យថា : ករណីដែល ①អ្នកដែលអាចធ្វើជាអ្នកធ្វើសហបណ្តឹង តែមិនទាន់ចូលរួមក្នុងសហបណ្តឹងនោះ ឬ ②អ្នកដែលត្រូវក្លាយជាអ្នកធ្វើសហបណ្តឹង តែមិនទាន់ចូលរួមក្នុងសហបណ្តឹងនោះ ។ ចំពោះករណី ① ប្រសិនបើអ្នកនោះបានចូលរួមអន្តរាគមន៍ក្នុងសហបណ្តឹងនោះ គេហៅថាជា "សហបណ្តឹងជាចាំបាច់ដោយមានប្រភេទដូចគ្នា? (Prozeßrechtlich Notwendige Streitgenossenschaft 類似必要的共同訴訟)" (ឧទាហរណ៍ ករណីដែលបណ្តឹងត្រូវបានធ្វើឡើងដោយម្ចាស់ហ៊ុនមួយចំនួនដើម្បីទាមទារឱ្យលុបចោលនូវការសម្រេចនៃមហាសន្និបាត ហើយម្ចាស់ហ៊ុនផ្សេងបានចូលរួមអន្តរាគមន៍ជាដើមចោទក្នុងសហបណ្តឹង) ។ រីឯចំពោះករណី ② វិញ ប្រសិនបើអ្នកនោះ បានចូលរួមអន្តរាគមន៍ក្នុងសហបណ្តឹងនោះ វិការៈទាក់ទងនឹងលក្ខណៈនៃភាគី ដោយសារខ្វះវត្តមាននៃបុគ្គលដែលត្រូវក្លាយជាដើមចោទ ឬ ចុងចម្លើយនៃ "សហបណ្តឹងជាចាំបាច់ដោយពិត? (Materiellrechtlich Notwendige Streitgenossenschaft 固有必要的共同訴訟)" នោះ ត្រូវបានជួសជុល ។

<u>Code of Civil Procedure (Japan)</u>
**Article 52** (Intervention as joint party)
1. In cases where the subject matter of a suit is to be determined only jointly with regard to either of the parties and a third person, such third person may intervene in the suit as a joint party.
2. The provisions of Article 43 and Article 47, paragraph 2 and 3 shall apply *mutatis mutandis* to applications for intervention under the preceding paragraph.

**មាត្រា ៥០.-** ការជូនដំណឹងអំពីបណ្តឹង

១- ភាគីអាចជូនដំណឹងអំពីបណ្តឹង ទៅតតិយជនដែលអាចចូលរួមអន្តរាគមន៍ក្នុងបណ្តឹងនោះបាន នៅពេលដែលតុលាការកំពុងចាត់ការបណ្តឹង ។

២- ការជូនដំណឹងអំពីបណ្តឹង ត្រូវធ្វើឡើងដោយដាក់លិខិតជាលាយលក្ខណ៍អក្សរដែលបញ្ជាក់អំពីមូលហេតុក្នុងការជូនដំណឹង និង អំពីដំណើរការនៃបណ្តឹងនោះ ទៅតុលាការ ។ តុលាការត្រូវបញ្ជូនលិខិតនេះទៅអ្នកដែលត្រូវទទួលដំណឹង

និង ភាគីម្ខាងទៀតនៃបណ្តឹង ។
៣- ទោះបីជាអ្នកទទួលដំណឹងអំពីបណ្តឹងនេះមិនបានចូលរួមអន្តរាគមន៍ក៏ដោយ ចំពោះការអនុវត្តបញ្ញត្តិនៃមាត្រា ៤៧ (អានុភាពនៃការសម្រេចសេចក្តីទៅលើអ្នកចូលរួមជួយអន្តរាគមន៍) នៃក្រមនេះ អ្នកទទួលដំណឹងអំពីបណ្តឹងនេះត្រូវបានចាត់ទុកថា បានចូលរួមហើយ នៅពេលអ្នកនោះអាចចូលរួមបាន ។

(កំណត់)

សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 53 និង បទប្បញ្ញត្តិនៃនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 22 ។

ការជូនដំណឹងអំពីបណ្តឹងនេះ មានផលប្រយោជន៍ដូចតទៅ :

① អាចផ្តល់ឱកាសចំពោះតតិយជន (អ្នកដែលទទួលដំណឹង) ឱ្យចូលរួមអន្តរាគមន៍ក្នុងបណ្តឹង ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ។

② ចំពោះអ្នកជូនដំណឹងវិញ ក្នុងករណីដែលបានកំណត់ ទោះបីជាអ្នកជូនដំណឹងចាញ់ក្តីក៏ដោយ ក៏អាចធ្វើឱ្យអ្នកដែលត្រូវទទួលដំណឹងនោះ ទទួលនូវអានុភាពនៃការចូលរួមអន្តរាគមន៍បានដែរ ហេតុដូច្នេះ អ្នកនោះអាចការពារកុំឱ្យមានជម្លោះពេលក្រោយ ។

អ្នកដែលបានទទួលដំណឹងនេះ មិនមែនក្លាយជាអ្នកចូលរួមជួយអន្តរាគមន៍ក្នុងបណ្តឹងនោះ ដោយស្វ័យប្រវត្តិទេ គឺអ្នកនោះមានសេរីភាពក្នុងការចូលរួម ឬ មិនចូលរួម ប៉ុន្តែ ទោះបីជាមិនចូលរួមក៏ដោយ ក៏អ្នកនោះត្រូវទទួលអានុភាពនៃការចូលរួមអន្តរាគមន៍ ដូចក្នុងករណីដែលខ្លួនបានចូលរួមដោយគ្មានការយឺតយ៉ាវក្រោយពេលទទួលដំណឹងដែរ (កថាខណ្ឌទី ៣ នៃមាត្រានេះ) ។ ឧទាហរណ៍ ចំពោះបណ្តឹងដែលម្ចាស់បំណុលទាមទារឱ្យអ្នកធានា បំពេញកាតព្វកិច្ចធានារបស់ខ្លួន បើអ្នកធានាជូនដំណឹងស្តីពីបណ្តឹងនោះទៅកូនបំណុលដែលមានកាតព្វកិច្ចចម្បង ទោះបីជាអ្នកមានកាតព្វកិច្ចចម្បងនោះមិនបានចូលរួមជួយអន្តរាគមន៍ក្នុងបណ្តឹងនោះ ហើយអ្នកធានានោះចាញ់ក្តីក៏ដោយ ក៏អ្នកមានកាតព្វកិច្ចចម្បងត្រូវទទួលនូវអានុភាពនៃការចូលរួមអន្តរាគមន៍ដែរ នៅពេលដែលអ្នកធានាធ្វើបណ្តឹងទាមទារនូវសំណងពីអ្នកមានកាតព្វកិច្ចចម្បងនោះ ។ ប៉ុន្តែ ទោះបីជាបានជូនដំណឹងទៅតតិយជនដែលគ្មានផលប្រយោជន៍ក្នុងការចូលរួមជួយអន្តរាគមន៍ក៏ដោយ ក៏អានុភាពនៃការចូលរួមអន្តរាគមន៍ ដែលមានចែងក្នុងកថាខណ្ឌទី ៣ នៃមាត្រានេះ ពុំកើតមានឡើងដែរ ។

Code of Civil Procedure (Japan)
**Article 53** (Notice of suit)
1. The parties to a suit may, during its pendency, give notice of the suit to third persons entitled to intervene.
2. Any person who has received a notice of a suit may, in turn, give notice of the suit [to other third persons].
3. The notice of a suit shall be given by filing documents with the court setting forth the reason for giving such notice and the stage of the suit.
4. With regard to the application of the provisions of Article 46, a person who has received notice of a suit shall be deemed to have intervened at the time such person should have done so, even though such person did not intervene.

Rules of Civil Procedure (Japan)
**Article 22** (Service, etc., of document for notice of suit / The Code Article 53)
1. A document for notice of a suit shall be served on the person who is to be given the notice.

2. The service referred to in the preceding paragraph shall be made by use of a duplicate copy submitted by the person who has made notice of the suit.
3. The court shall send the document referred to in paragraph 1 to the adversary party.

**មាត្រា ៥១.–** បណ្ដឹងដែលមានដើមចោទ និង ចុងចម្លើយ ជាសហចុងចម្លើយ

១- តតិយជនដែលអះអាងថា ចំពោះសិទ្ធិដែលជាកម្មវត្ថុនៃបណ្ដឹងរវាងភាគីដទៃ សិទ្ធិទាំងមូល ឬ មួយភាគជាសិទ្ធិរបស់ខ្លួន អាចដាក់ពាក្យបណ្ដឹងចំពោះភាគីទាំងសងខាងនៃបណ្ដឹងខាងលើនោះ ជាសហចុងចម្លើយ ទៅតុលាការនៃការជំនុំជម្រះលើកទី ១ ដែលបានទទួលពាក្យបណ្ដឹងរវាងភាគីដទៃនោះ នៅពេលបណ្ដឹងនោះកំពុងនៅក្រោមការចាត់ការរបស់តុលាការណាមួយ ។

២- ក្នុងករណីដែលមានការដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើតុលាការនៃការជំនុំជម្រះលើកទី ១ កំពុងចាត់ការបណ្ដឹងរវាងភាគីដទៃនោះ តុលាការដែលទទួលពាក្យបណ្ដឹងពីតតិយជននោះ អាចបញ្ចូលបណ្ដឹងទាំងពីរជាមួយគ្នាបាន ។

(កំណត់)

ចំពោះសមត្ថកិច្ចសាលាជម្រះក្ដី ជាមូលដ្ឋាន ត្រូវយោលទៅតាមបញ្ញត្តិនៃមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្ដីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍) និង មាត្រា ៩ (សមត្ថកិច្ចសាលាជម្រះក្ដីដែលបានកំណត់ទៅតាមទ្រព្យសម្បត្តិជាអាទិ៍) តែកថាខណ្ឌទី ១ នៃមាត្រានេះ កំណត់អំពីសមត្ថកិច្ចសាលាជម្រះក្ដីពិសេស ចំពោះករណីដែលបានកំណត់ ។

តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រានេះ បណ្ដឹងដែលតតិយជនដាក់ មិនមែនជាការចូលរួមអន្តរាគមន៍ទេ គឺជាសហបណ្ដឹង ។ ឧទាហរណ៍ ក្នុងករណីដែល X, Y និង Z អះអាងកម្មសិទ្ធិរបស់ខ្លួនចំពោះដីតែមួយ បណ្ដឹងរវាង X និង Y និង បណ្ដឹងរបស់ Z ចំពោះសហចុងចម្លើយ X និង Y គឺបណ្ដឹងដោយឡែកពីគ្នា ហើយមិនត្រូវបានវិនិច្ឆ័យ ដោយបញ្ចូលគ្នាជាស្វ័យប្រវត្តិទេ ។ ប៉ុន្តែ តុលាការដែលទទួលបណ្ដឹងទាំងពីរនោះ អាចបញ្ចូលបណ្ដឹងនោះ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៩៩ (ការបំបែក និង ការរួមបញ្ចូលរឿងក្ដី) ហើយអាចវិនិច្ឆ័យតាមនីតិវិធីរួមគ្នាបាន ។ កថាខណ្ឌទី ២ នៃមាត្រានេះ បញ្ជាក់អំពីចំណុចនេះ ។ ទោះបីបញ្ចូលបណ្ដឹងទាំងពីរក៏ដោយ ក៏លក្ខណៈនៃបណ្ដឹងនេះ មិនមែនជាសហបណ្ដឹងជាចាំបាច់ដែរ ហេតុដូច្នេះ គ្មានការធានាក្នុងការចេញសាលក្រមដែលគ្មានភាពផ្ទុយគ្នា រវាង X, Y និង Z ឡើយ ប៉ុន្តែ ដោយសារតាមការជាក់ស្ដែង សហបណ្ដឹងដែលជាការបញ្ចូលបណ្ដឹងទាំងពីរនោះ ត្រូវបានវិនិច្ឆ័យដោយចៅក្រម (ឬ ក្រុមប្រឹក្សាជំនុំជម្រះ) តែមួយ នៅកាលបរិច្ឆេទតែមួយ នោះអាចសង្ឃឹមច្រើនថា នឹងមានការដោះស្រាយដោយមានភាពស្របគ្នាបាន ។

Old Code of Civil Procedure (Japan, 1890, last amendment: 1992)
**Article 60** (Suit against both parties of the other pending suit)
A person who claims for himself the whole or a part of the subject matter of a suit between others may, during the pendency of such suit, file a suit against the both parties as co-defendants with the court of the suit of the first instance where the said suit is pending.

## ផ្នែកទី ៤ អ្នកតំណាងដោយអាណត្តិ និង អ្នកជំនួយ

**មាត្រា ៥២.-** សកម្មភាពបណ្តឹងដែលបានធ្វើដោយអ្នកតំណាងដោយអាណត្តិ

១- ភាគីអាចធ្វើរាល់សកម្មភាពដែលទាក់ទងនឹងបណ្តឹង ដោយខ្លួនឯងផ្ទាល់ ឬ ឆ្លងតាមរយៈអ្នកតំណាងដោយអាណត្តិដែលខ្លួនបានជ្រើសតាំង ។(1)

២- ទោះបីភាគីបានជ្រើសតាំងអ្នកតំណាងដោយអាណត្តិក៏ដោយ ក៏ភាគីនោះអាចចូលរួមទៅតុលាការ និង ឆ្លើយទាញហេតុផលដោយខ្លួនឯងបានដែរ ។(2)

៣- សកម្មភាពបណ្តឹងដែលអ្នកតំណាងដោយអាណត្តិបានធ្វើ ត្រូវបង្កើតអានុភាពដូចគ្នាជាមួយសកម្មភាពបណ្តឹងដែលភាគីបានធ្វើដោយផ្ទាល់ខ្លួន ។ ប៉ុន្តែ ការសារភាព និង ចម្លើយដទៃទៀតស្តីពីអង្គហេតុដែលអ្នកតំណាងដោយអាណត្តិបានធ្វើ ពុំមានអានុភាពឡើយ ប្រសិនបើភាគីលុបចោល ឬ កែតម្រូវភ្លាមៗ ។(3)

(កំណត់)

(1) ភាគីអាចជ្រើសតាំងអ្នកតំណាងដោយអាណត្តិបាន តែការជ្រើសតាំងនេះមិនមែនជាកាតព្វកិច្ចតម្រូវចំពោះភាគីទេ ហើយភាគីក៏អាចធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងបានដែរ ។ មានន័យថា មិនយកគោលការណ៍ដែលតម្រូវឱ្យមានមេធាវីជាចាំបាច់ទេ ។ សូមមើលមាត្រា 26 កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីប្រទេសអូទ្រីស ។

(2) សូមមើលមាត្រា 26 កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីប្រទេសអូទ្រីស ។

(3) កថាខណ្ឌទី ៣ នេះ មានអត្ថន័យដូចគ្នានឹងមាត្រា 57 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ សូមមើលមាត្រា 85 នៃក្រមនីតិវិធីរដ្ឋប្បវេណីប្រទេសអាឡឺម៉ង់ផងដែរ ។ មានន័យថា អ្នកតំណាងដោយអាណត្តិ ត្រូវបានជ្រើសតាំងដោយភាគីផ្ទាល់ ដើម្បីធ្វើសកម្មភាពបណ្តឹងជំនួសខ្លួន ដូច្នេះ រាល់សកម្មភាពរបស់អ្នកតំណាងដោយអាណត្តិនេះត្រូវចាត់ទុកជាសកម្មភាពរបស់ភាគី ។ ប៉ុន្តែ ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិបានសារភាព ឬ ផ្តល់ចម្លើយទាក់ទងអង្គហេតុ តែភាគីកែតម្រូវ ឬ លុបចោលភ្លាម នោះការសារភាព ឬ ចម្លើយរបស់អ្នកតំណាងដោយអាណត្តិគ្មានអានុភាពឡើយ ដោយហេតុថា ភាគីគឺជាអ្នកដែលបានដឹងច្បាស់អំពីអង្គហេតុ ។

(4) ពាក្យ "ភ្លាម" ក្នុងកថាខណ្ឌនេះ មានន័យថា : បើភាគីមានវត្តមានជាមួយអ្នកតំណាងដោយអាណត្តិ គឺត្រូវកែតម្រូវ ឬ លុបចោល នៅកាលបរិច្ឆេទនោះតែម្តង បើភាគីអវត្តមាន ភាគីអាចកែតម្រូវ ឬ លុបចោលនៅកាលបរិច្ឆេទបន្ទាប់ ។

<u>Code of Civil Procedure (Austria)</u>
**Article 26** (Acts of litigation by representative, statements of party)
1. A party may conduct acts of litigation by himself/herself or through his/her representative unless otherwise provided in this law.
2. Representation by a representative shall not preclude a party from appearing in the court with the representative or making statements orally with the representative.

Code of Civil Procedure (Japan)
**Article 57** (Rectifying statement by party)
Any statement of facts made by an advocate shall be ineffective if it is immediately cancelled or rectified by the principal.

Code of Civil Procedure Rules (Germany)
**Article 85** (Effect of the power of attorney to conduct proceedings)
1. Pleadings undertaken by the holder of the power of attorney are binding on the party to the same extent as if the party himself had made them. This is valid as regards confessions and other factual declarations to the extent that they are not immediately withdrawn or corrected by the party simultaneously appearing in the court.
2. The fault of the holder of the power of attorney is deemed the same as the fault of the party.

**មាត្រា ៥៣.-** លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ

១- អ្នកតំណាងដោយអាណត្តិដែលបានកំណត់ក្នុងបញ្ញត្តិនៃមាត្រា ៥២ (សកម្មភាពបណ្ដឹងដែលបានធ្វើដោយអ្នកតំណាងដោយអាណត្តិ) ខាងលើនេះ ត្រូវតែជាមេធាវី លើកលែងតែករណីដែលបានកំណត់ក្នុងចំណុចនីមួយៗ ដូចខាងក្រោម :

**ក**- ករណីដែលក្រមនេះ ឬ ច្បាប់ដទៃទៀត អនុញ្ញាតឱ្យតតិយជនដែលមិនមែនជាមេធាវី ធ្វើសកម្មភាពបណ្ដឹងជំនួសភាគី ។(1)

**ខ**- ករណីដែលភាគីជារដ្ឋ ស្ថាប័ននីតិរដ្ឋបាល ឬ ស្ថាប័នរដ្ឋដទៃទៀត និង ដែលស្ថាប័ននោះ ឬ អ្នកតំណាងនៃស្ថាប័ននោះ តែងតាំងបុគ្គលិកនៃស្ថាប័ននោះជាអ្នកតំណាង ។(2)

**គ**- ករណីដែលតុលាការអនុញ្ញាតឱ្យមានការតំណាងដោយតតិយជនដែលមិនមែនជាមេធាវី ក្នុងរឿងក្ដីដែលតម្លៃកម្មវត្ថុនៃបណ្ដឹងតិចជាង ១.០០០.០០០ (មួយលាន) រៀល ។(3)

២- សិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិ ត្រូវបញ្ជាក់ជាលាយលក្ខណ៍អក្សរ ។(4)

៣- តុលាការអាចលុបចោលការអនុញ្ញាត ដែលបានកំណត់ក្នុងចំណុច **គ** នៃកថាខណ្ឌទី ១ ខាងលើនេះ នៅពេលណាក៏បាន ។(5)

(កំណត់)

(1) ករណីដែលអនុញ្ញាតឱ្យអ្នកក្រៅពីមេធាវីធ្វើជាអ្នកតំណាងដោយអាណត្តិ មានឧទាហរណ៍ នៅក្នុងចំណុច **ខ** និង **គ** កថាខណ្ឌទី ១ នៃមាត្រានេះ ហើយក្រៅពីនេះ មានបញ្ញត្តិនៃចំណុច **ខ** និង **គ** កថាខណ្ឌទី ១ នៃមាត្រា ៣៤៨ ។ មាត្រា ៣៤៨ ពង្រីកវិសាលភាពនៃបុគ្គលដែលមានលក្ខណសម្បត្តិអាចក្លាយជាអ្នកតំណាងដោយអាណត្តិ ឱ្យទូលាយជាងមាត្រានេះ ចំពោះនីតិវិធីនៃការអនុវត្តដោយបង្ខំ ។

(2) នេះគឺជាបញ្ញត្តិដែលកំណត់អំពីអ្នកតំណាងដែលបានតែងតាំង ក្នុងករណីដែលរដ្ឋ ឬ ស្ថាប័នរដ្ឋបាល ជាភាគី ។

(3) នេះគឺជាបញ្ញត្តិដែលមានន័យប្រហាក់ប្រហែលគ្នានឹងវាក្យខណ្ឌទី ២ នៃមាត្រា 54 កថាខណ្ឌទី 1 នៃក្រមនីតិវិធីរដ្ឋប្បវេណីប្រទេសជប៉ុន ។ ប៉ុន្តែ ដោយហេតុថានៅប្រទេសកម្ពុជា គ្មានសាលាលហុ (summary court) ទើបយករឿងក្ដីដែលតម្លៃកម្មវត្ថុនៃបណ្ដឹងតិចជាងការកំណត់ ។ ម្យ៉ាងទៀត ការតំណាងទៅវិញទៅមករវាងសហព័ទ្ធដោយគ្មានសំបុត្រប្រគល់អំណាច ដែលបានកំណត់នៅក្នុងបញ្ញត្តិនៃមាត្រា ១៣៣ និង មាត្រា ២២៩ នៃក្រមពិភាក្សា

រដ្ឋប្បវេណីកម្ពុជាឆ្នាំ ១៩៦៣ មិនអាចយកមកអនុវត្តបានឡើយ ពីព្រោះរឿងក្តីដែលមានការប្រឈមមុខគ្នា ចំពោះផលប្រយោជន៍រវាងប្តីនិងប្រពន្ធ កើតឡើងជាញឹកញាប់ និង ជាការជាក់ស្តែង បញ្ញត្តិយ៉ាងនេះហាក់ដូចជាការទទួលស្គាល់អំណាចរបស់ប្តីលើប្រពន្ធ ។

(4) កថាខណ្ឌនេះមានអត្ថន័យដូចគ្នានឹងបញ្ញត្តិនៃមាត្រា 23 កថាខណ្ឌទី 1 នៃបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។

(5) សូមមើលមាត្រា 54 កថាខណ្ឌទី 2 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

Code of Civil Procedure (Japan)
**Article 54** (Qualification of advocate)
1. With the exception of representatives who may effect juridical acts in court according to the provisions of law and ordinances, no person other than a lawyer may act as an advocate. However, in a summary court a person who is not a lawyer may be appointed as an advocate with the permission of such court.
2. The permission referred to in the preceding paragraph may be cancelled at any time.

Rules of Civil Procedure (Japan)
**Article 23** (Certification , etc., of authority of advocate / The Code Article 54, etc.) (excerpt)
1. The authority of an advocate shall be certified in writing.

ក្រមពិភាក្សារដ្ឋប្បវេណី ( កម្ពុជា, ១៩៦៤)

**មាត្រា ១៣៣** ( សេចក្តីដកស្រង់)

......នឹងជាពិសេសស្វាមីភរិយា អាចដំណាងគ្នាទៅវិញទៅមកបាន មិនបាច់មានសំបុត្រប្រគល់អំណាចទេ......

**មាត្រា ២២៩** ( សេចក្តីដកស្រង់)

......ប្តីប្រពន្ធអាចមកជាតំណាងគ្នាទៅវិញទៅមកបាន ដោយមិនចាំបាច់មានលិខិតសុំឱ្យជំនួសទេ ប៉ុន្តែត្រូវជូនលិខិតអាពាហ៍ពិពាហ៍ជាសំអាង ។ ........

## មាត្រា ៥៤.- សិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិ

១- អ្នកតំណាងដោយអាណត្តិមានសិទ្ធិអំណាចក្នុងការធ្វើរាល់សកម្មភាពបណ្តឹង ព្រមទាំងការដាក់ពាក្យបណ្តឹង ការឆ្លើយដោះសាចំពោះបណ្តឹង ការប្តឹងតប ការចូលរួមអន្តរាគមន៍បណ្តឹង ការប្តឹងទៅតុលាការជាន់ខ្ពស់ ការផ្សះផ្សា ការលះបង់ការទាមទារ និង ការទទួលស្គាល់នូវការទាមទារ ចំពោះរឿងក្តីដែលខ្លួនបានទទួលអាណត្តិ ។ ( 1)

២- សិទ្ធិតំណាងដែលត្រូវបានប្រគល់សម្រាប់បណ្តឹងរាប់បញ្ចូលទាំងសិទ្ធិលើការចាត់ចែងរក្សាការពារ ការអនុវត្តដោយបង្ខំ ការជ្រើសតាំងអនុតំណាង និង ការទទួលនូវការសង ។ ( 2)

៣- ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិជាមេធាវី ភាគីពុំអាចកម្រិតនូវសិទ្ធិតំណាងបានទេ លើកលែងតែករណីទាក់ទងនឹងការដាក់ពាក្យបណ្តឹងតប ការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ ការទទួលស្គាល់នូវការទាមទារ ការដកខ្លួនពីបណ្តឹង ការដាក់ពាក្យបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ការដកពាក្យបណ្តឹងឧបាស្រ័យពីតុលាការជាន់ខ្ពស់ និង ការជ្រើសតាំងអនុតំណាង ។ ( 3)

៤- ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិមិនមែនជាមេធាវី ភាគីក៏អាចឱ្យអ្នកតំណាងដោយអាណត្តិនោះ ធ្វើតំណាងចំពោះតែសកម្មភាពបណ្តឹងមួយចំនួនដែលបានកំណត់ដោយឡែកៗដោយភាគីបានដែរ ។(4)

៥- បញ្ញត្តិនៃកថាខណ្ឌទាំងបួនខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះអ្នកតំណាងដែលត្រូវបានអនុញ្ញាតដោយច្បាប់ក្នុងការធ្វើសកម្មភាពបណ្តឹងជំនួសភាគី ។(5)

(កំណត់)

(1) តុលាការមិនអាចស៊ើបអង្កេតអំពីអត្ថិភាពនៃសិទ្ធិតំណាងដោយអាណត្តិ ចំពោះសកម្មភាពនៃបណ្តឹងនីមួយៗដែលមានជាច្រើនប្រភេទបានទេ ហេតុដូច្នេះ ត្រូវការចាំបាច់ឱ្យមានការកំណត់ដោយច្បាប់នូវទំហំនៃសិទ្ធិតំណាង (កថាខណ្ឌទី ១) និង ការហាមឃាត់នូវការកម្រិត (កថាខណ្ឌទី ៣) ។ សូមមើលមាត្រា 81 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាឡឺម៉ង់ ។

(2) កថាខណ្ឌនេះអាចបញ្ចូលក្នុងបញ្ញត្តិនៃកថាខណ្ឌទី ១ ក៏បានដែរ ប៉ុន្តែ យើងកំណត់ដោយឡែកតាមមាត្រា 82 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាឡឺម៉ង់ ដើម្បីបែងចែកជាមួយសិទ្ធិតំណាងនូវបណ្តឹងនៃអង្គសេចក្តី ។

(3) ការហាមឃាត់នូវការកម្រិតសិទ្ធិតំណាងរបស់មេធាវីនេះ មានអត្ថន័យដូចគ្នាជាមួយនឹងមាត្រា 55 កថាខណ្ឌទី 3 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ពីព្រោះ ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិជាមេធាវី យើងអាចសង្ឃឹមថាមានការទុកចិត្តលើការតំណាង ។ សូមមើលមាត្រា 83 កថាខណ្ឌទី 1 ផងដែរ ។

(4) សូមមើលមាត្រា 33 កថាខណ្ឌទី 1 នៃក្រមនីតិវិធីរដ្ឋប្បវេណីអូទ្រីស ។

(5) នេះគឺជាបញ្ញត្តិដែលមានន័យដូចគ្នានឹងមាត្រា 55 កថាខណ្ឌទី 4 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

Code of Civil Procedure Rules (Germany)

**Article 81** (Extent of the power to conduct proceedings)

The power of attorney to conduct proceedings empowers to make all pleadings related to the lawsuit, including those occasioned by a crossclaim, a reopening of the proceedings, and the execution; to appoint a representative, as well as a holder of a power of attorney for the higher instances; to the settlement of the lawsuit by compromise, renunciation of the object of litigation or admission of the claim asserted by the opponent; to accept costs repayable by the opponent.

**Article 82** (Validity for auxiliary proceedings)

The power of attorney for the main lawsuit includes authority for proceedings concerning one interpleader, one distraint order or one tempoary injuction.

**Article 83** (Limitations on powers of attorney to conduct proceedings)

1. A limitation placed on the legal scope of the power of attorney is legally effective as against the opponent only insofar as such limitation concerns the elimination of the lawsuit by compromise, renunciation of the object of litigation or admission of the claim asserted by the opponent.
2. Insofar as representation by lawyer is not required, a power of attorney may be conferred for specific pleadings.

Code of Civil Procedure (Japan)

**Article 55** (Scope of advocate's authority) (excerpt)

3. No limitation shall be imposed upon the authority of an advocate. However, this shall not apply to an advocate who is not a lawyer.
4. The provisions of the preceding three paragraphs shall not preclude a representative entitled to conduct juridical acts in court according to the provisions of laws and ordinances from exercising its powers.

Code of Civil Procedure (Austria)

**Article 33** (Representation by non-lawyers) (excerpt)

1. A party may authorize a person who is not a lawyer to represent in litigation or aurhorize that person to conduct the sepcific acts of litigation respectively authorized by the party.

## មាត្រា ៥៥.- ករណីដែលសិទ្ធិតំណាងដោយអាណត្តិមិនរលត់

សិទ្ធិអំណាចនៃអ្នកតំណាងដោយអាណត្តិមិនត្រូវរលត់ឡើយ ទោះបីជាមានករណីដែលភាគីទទួលមរណភាព ឬ បាត់បង់សមត្ថភាពក្នុងការធ្វើបណ្តឹង ឬ មានករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវបានប្តូរ ជាអាទិ៍ ក៏ដោយ ។ (1) (2)

(កំណត់)

(1) នេះជាបញ្ញត្តិដែលមានអត្ថន័យប្រហាក់ប្រហែលគ្នាជាមួយនឹងមាត្រា 58 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 35 កថាខណ្ឌទី 1 នៃក្រមនីតិវិធីរដ្ឋប្បវេណីអូទ្រីស និង មាត្រា 86 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាឡឺម៉ង់ ។ មាត្រានេះចែងអំពីករណីលើកលែង ចំពោះគោលការណ៍នៃការតំណាង ដែលត្រូវបានកំណត់ដោយក្រមរដ្ឋប្បវេណី ។ ចំពោះការតំណាងដោយអាណត្តិក្នុងបណ្តឹង ដោយសារមានភាពចាំបាច់ក្នុងការធ្វើឱ្យនីតិវិធីបណ្តឹង មានភាពងាយស្រួលនិងឆាប់រហ័ស និង ដោយសារ ជាគោលការណ៍ មានតែមេធាវីទេដែលអាចមានសិទ្ធិតំណាង ហេតុដូច្នេះ ទោះបីជាសិទ្ធិតំណាងត្រូវរលត់តាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណីក៏ដោយ ក៏សិទ្ធិតំណាងដោយអាណត្តិក្នុងបណ្តឹង មិនត្រូវរលត់ដែរ ។

(2) បញ្ញត្តិនេះគ្រាន់តែលើកជាឧទាហរណ៍ ។

<u>Code of Civil Procedure (Japan)</u>
**Article 58** (Nontermination of advocate's authority) (excerpt)
1. The authority of an advocate shall not be terminated by following reasons:
death of the party or loss of the party's capacity to litigate;
termination through amalgamation of a juridical person which is the party;
conclusion of trust duties of a trustee who is the party;
death, or loss of capacity to litigate of a legal representative or termination or change of such representative's authority.

<u>Code of Civil Procedure (Austria)</u>
**Article 59** (Death of conferor, loss of capacity of litigation and change of legal representative) (excerpt)
1. The power of representative shall not be terminated by the death of the conferor, the loss of capacity of the conferor, or a change regarding to legal representation of the conferor.

<u>Code of Civil Procedure Rules (Germany)</u>
**Article 86** (Continuity of the power of attorney)
The power of attorney is not cnacelled by the death of the conferor or by a change in his capacity to sue or of his legal representation; the holder of the power of attorney shall, howeer, produce a power of attorney of the successor if he appears on his behalf in the lawsuit after a stay of proceedings.

## មាត្រា ៥៦.- ហេតុនៃការរលត់នូវសិទ្ធិតំណាងដោយអាណត្តិ

១- សិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិត្រូវរលត់ ដោយហេតុដូចជាមរណភាពនៃអ្នកតំណាង ការបាត់បង់លក្ខណសម្បត្តិរបស់អ្នកតំណាង ឬ ការបញ្ចប់កិច្ចការអាណត្តិ ជាអាទិ៍ ។ (1)

២- ភាគីអាចដកសិទ្ធិតំណាងដោយអាណត្តិនៅពេលណាក៏បាន រីឯអ្នកតំណាងដោយអាណត្តិអាចឈប់ធ្វើជាអ្នកតំណាងនៅពេលណាក៏បានដែរ ។(2)

៣- ការរលត់នូវសិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិ មិនត្រូវមានអានុភាពឡើយ ប្រសិនបើគ្មានការជូនដំណឹងអំពីការរលត់សិទ្ធិនោះ ពីសាមីខ្លួន ឬ អ្នកតំណាង ទៅភាគីម្ខាងទៀត ។(3)

(កំណត់)

(1) បញ្ញត្តិនេះគ្រាន់តែលើកជាឧទាហរណ៍ ។

(2) ក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសអ៊ីតាលី កំណត់អត្ថន័យនេះយ៉ាងច្បាស់លាស់ក្នុងមាត្រា 85 ។

(3) នេះជាបញ្ញត្តិដែលមានន័យដូចគ្នានឹង មាត្រា 59 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ដែលយកមាត្រា 36 កថាខណ្ឌទី 1 នៃក្រមដដែល មកអនុវត្តដូចគ្នា ។ មាត្រា 87 កថាខណ្ឌទី 1 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាឡឺម៉ង់ និង មាត្រា 36 នៃក្រមអូទ្រីស ។

Code of Civil Procedure (Italy)
**Article 85** (Termination and abandonment of power of representation in litigation)
The power of representation in litigation may at any time be terminated and a defender may at any time abandon the power of representation. However, such termination or abandonment shall not be effective against the other party unless there is a subrogation of defenders.

Code of Civil Procedure (Japan)
**Article 36** (Notice of termination of legal representative's authority) > *see the note for Article 37*
**Article 59** (*Mutatis mutandis* application of the provisions concerning legal representative)
The provisions of Article 34, paragraphs 1 and 2, and Article 36, paragraph 1 shall apply *mutatis mutandis* to representation in litigation.

Code of Civil Procedure Rules (Germany)
**Article 87** (Expiration of the power of attorney) (excerpt)
1. The termination of the power of attorney contract becomes legally effective, as against the opponent, pon notifivation of the espiration of the pwoer of attorney; in a litigation by lawyers, upon and by means of a notification of the appointment of another lawyer.

Codice di Procedura Civile (Italy)
**Art. 85** Revoca e rinuncia alla procura
La procura può essere sempre revocata e il difensore può sempre rinunciarvi, ma la revoca e la rinuncia non hanno effetto (301) nei confronti dell`altra parte finché non sia avvenuta la sostituzione del difensore (Cod. Civ. 1396).

## **មាត្រា ៥៧.-** វិធានការក្នុងករណីនៃការខ្វះសិទ្ធិតំណាង

១- ក្នុងករណីដែលមានការសង្ស័យនៃការខ្វះសិទ្ធិតំណាងដោយអាណត្តិ តុលាការត្រូវស្រាវជ្រាវអំពីអត្ថិភាពនៃសិទ្ធិតំណាង ដោយឆន្ទានុសិទ្ធិ ទោះបីជាការសង្ស័យនោះកើតឡើង នៅក្នុងដំណាក់កាលណាមួយក្នុងបណ្តឹងក៏ដោយ ។(1)

២- បើមានការខ្វះសិទ្ធិតំណាងដោយអាណត្តិ តុលាការត្រូវណែនាំកែតម្រូវនូវចំណុចខ្វះនោះ ដោយកំណត់អំឡុងពេល ។ ក្នុងករណីនេះ តុលាការអាចអនុញ្ញាតឱ្យបុគ្គលដែលខ្វះសិទ្ធិតំណាងនោះធ្វើសកម្មភាពបណ្តឹងជាបណ្តោះអាសន្នបាន ។(2)

៣- សកម្មភាពបណ្តឹងណាដែលត្រូវបានធ្វើឡើងដោយបុគ្គលដែលមានការខ្វះសិទ្ធិតំណាងដោយអាណត្តិ ត្រូវមានអានុភាព

ប្រតិសកម្មតាំងពីពេលដែលសកម្មភាពនោះបានធ្វើឡើងដោយយោងទៅតាមសច្ចានុមតិរបស់ភាគី ។(2)

(កំណត់)

(1) បញ្ញត្តិនៃមាត្រា 88 កថាខណ្ឌទី 2 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាឡឺម៉ង់ និង មាត្រា 37 នៃក្រមអូទ្រីស កំណត់ដូចកថាខណ្ឌនេះ ។

(2) កថាខណ្ឌទី ២ និង ទី ៣ នៃមាត្រានេះ កំណត់ដូចគ្នានឹងមាត្រា 59 នៃក្រមជប៉ុនដែលយកមាត្រា 34 កថាខណ្ឌទី 1 និង កថាខណ្ឌទី 2 មកអនុវត្តដូចគ្នា ។

(3) សូមមើលកំណត់នៃមាត្រា ៣៥ ។

Code of Civil Procedure Rules (Germany)
**Article 88** (Verification of the power of attorney for a lawsuit) (excerpt)
2. The court shall consider the want fo power of attorney on its own motion if no lawyer appears as the holder of the power of attorney.

Code of Civil Procedure (Japan)
**Article 34** (Measures in case of defect in the capacity to litigate, etc.) > *see the note for Article 35*
**Article 59** (Mutatis mutandis application of the provisions concerning legal representative) > *see the note for Article 56.*

## មាត្រា ៥៨.- អ្នកជំនួយ

១- បើមានភាពចាំបាច់ដើម្បីឱ្យបំភ្លឺនូវទំនាក់ទំនងនៃបណ្ដឹងឱ្យបានច្បាស់លាស់ នោះភាគី ឬ អ្នកតំណាងដោយអាណត្តិ អាចចូលទៅតុលាការជាមួយអ្នកជំនួយ ដោយមានការអនុញ្ញាតពីតុលាការ ។(1)

២- ការអនុញ្ញាតដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចលុបចោលនៅពេលណាក៏បានដែរ ។

៣- សេចក្ដីថ្លែងការណ៍របស់អ្នកជំនួយ ត្រូវទុកជាសេចក្ដីថ្លែងការណ៍ដែលភាគី ឬ តំណាងដោយអាណត្តិ បានធ្វើឡើងដោយខ្លួនឯង លើកលែងតែករណីដែលភាគី ឬ តំណាងដោយអាណត្តិ លុបចោល ឬ កែតម្រូវភ្លាមៗ ។(2)

(កំណត់)

(1) សូមមើលមាត្រា 60 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ អ្នកជំនួយ គឺជាជនដែលចូលរួមក្នុងតុលាការ ជាមួយភាគី ឬ អ្នកតំណាងដោយអាណត្តិ ដើម្បីជួយភាគី ឬ អ្នកតំណាងដោយអាណត្តិ ។ ប្រព័ន្ធនៃអ្នកជំនួយនេះ ត្រូវបានប្រើប្រាស់ក្នុងករណីដែលភាគី ឬ អ្នកតំណាងដោយអាណត្តិគ្មានចំណេះដឹងខាងបច្ចេកទេស ក្នុងបណ្ដឹងដែលចាំបាច់មានចំណេះដឹងខាងបច្ចេកទេស ដូចជាបណ្ដឹងទាក់ទងនឹងកម្មសិទ្ធិបញ្ញា ឬ ករណីដែលភាគីជាជនពិការក្នុងការនិយាយ ឬ ក្នុងការស្ដាប់ ហើយត្រូវមានអ្នកជំនួយដើម្បីបន្ថែមសេចក្ដីថ្លែងការណ៍របស់ជននោះ ។ តុលាការមានឆន្ទានុសិទ្ធិក្នុងការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យមានអ្នកជំនួយ ហេតុដូច្នេះ បើភាគី ឬ អ្នកតំណាងដោយអាណត្តិ មានបំណងឱ្យអ្នក

ជំនួយចូលរួមក្នុងតុលាការ អ្នកនោះត្រូវទទួលការអនុញ្ញាតពីតុលាការ ហើយតុលាការអាចលុបចោលការអនុញ្ញាតនោះនៅពេលណាក៏បានដែរ ។

(2) មាត្រា 89 នៃក្រមអាឡឺម៉ង់ក៏កំណត់ប្រហាក់ប្រហែលគ្នាដែរ ។

<u>Code of Civil Procedure (Japan)</u>
**Article 60** (Assistant)
1. A party or an advocate may , with the permission of the court, appear with an assistant.
2. The permission referred to in the preceding paragraph may be cancelled at any time.
3. A statement of an assistant shall be deemed to have been made by the party or advocate itself unless such party or advocate cancels or rectifies it immediately.

<u>Code of Civil Procedure Rules (Germany)</u>
**Article 89** (Representative without a power of attorney)
1. If a person is acting as a business agent without mandate for a party or as an authorized agent without presenting a power of attorney, he may be allowed temporarily to participate in the conduct of proceedings with or without giving security for costs and damages. The final ruling may only be given after expiration of the time fixed for presenting the approval. If at the time of issuance of the final ruling the approval has not been produced, the person temporarily admitted to the conduct of proceedings shall be adjudged to reimbursement of the costs incurred by the opponent resulting from his admission; he also shall compensate the opponent for damages arising from such admission.
2. A party must allow the conduct of proceedings against himself also when it was only orally conferred or if he expressly or impliedly consented to the conduct of the proceedings.

# ជំពូកទី ៤ ប្រាក់ប្រដាប់ក្តី

## ផ្នែកទី ១ អត្ថន័យ និង ប្រភេទនៃប្រាក់ប្រដាប់ក្តី

**មាត្រា ៥៩.-** ទំហំ និង ចំនួននៃប្រាក់ប្រដាប់ក្តីរដ្ឋប្បវេណីដែលភាគី ឬ បុគ្គលផ្សេងត្រូវទទួលបន្ទុក

យោងទៅតាមបញ្ញត្តិនៃមាត្រា ៦៤ (ភាគដែលត្រូវទទួលបន្ទុក និង ការសងវិញនូវប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយ) នៃក្រមនេះ ភាគី ឬ បុគ្គលផ្សេង ត្រូវទទួលបន្ទុកក្នុងការបង់ប្រាក់ប្រដាប់ក្តីតុលាការដែលបានកំណត់នៅក្នុងមាត្រា ៦១ (ពន្ធដាក់ពាក្យសុំ) និង មាត្រា ៦២ (ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ) និង ប្រាក់ប្រដាប់ក្តីភាគីដែលបានកំណត់នៅក្នុងមាត្រា ៦៣ (ប្រាក់ប្រដាប់ក្តីភាគី) នៃក្រមនេះ ។

(កំណត់)

ទំហំ (ប្រភេទ) នៃប្រាក់ប្រដាប់ក្តី គឺ ពន្ធ (មាត្រា ៦១ (ពន្ធដាក់ពាក្យសុំ) និង ប្រាក់បង់មុន (មាត្រា ៦២ (ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ)) ដែលជាប្រាក់ប្រដាប់ក្តីតុលាការ និង ប្រាក់ប្រដាប់ក្តីភាគី (មាត្រា ៦៣ (ប្រាក់ប្រដាប់ក្តីភាគី)) ។ ការបែងចែកប្រាក់ប្រដាប់ក្តីតុលាការ និង ប្រាក់ប្រដាប់ក្តីភាគីឱ្យដាច់គ្នានេះ មានប្រយោជន៍ដោយសារតែប្រាក់ប្រដាប់ក្តីតុលាការជាសោហ៊ុយដែលអាចជួយសង្គ្រោះបាន រីឯប្រាក់ប្រដាប់ក្តីភាគីវិញ គឺជាប្រាក់ដែលមិនអាចជួយសង្គ្រោះបានទេ (សូមមើលកថាខណ្ឌទី ១ មាត្រា ៧០ (ខ្លឹមសារនៃជំនួយសង្គ្រោះលើបណ្តឹង)) ។ "បុគ្គល

ផ្សេង" សំដៅទៅលើអ្នកតំណាងដោយអាណត្តិ និង ក្រឡាបញ្ជី ដែលមានចែងនៅក្នុងកថាខណ្ឌទី ៤ មាត្រា ៦៤ (ភាគដែលត្រូវទទួលបន្ទុក និង ការសងវិញនូវប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយ) ។

ជាគោលការណ៍ រដ្ឋត្រូវចំណាយដើម្បីធានាសិទ្ធិពឹងពាក់តុលាការរបស់បុគ្គល ។ ដោយសារបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងផលប្រយោជន៍របស់បុគ្គលឯកជន ដូចនេះ ភាគីត្រូវទទួលបន្ទុកនូវចំនួនណាមួយនៃចំណាយសម្រាប់កិច្ចការបណ្តឹងរដ្ឋប្បវេណី ។

**មាត្រា ៦០.-** ការគណនាតម្លៃកម្មវត្ថុនៃបណ្តឹង ការគណនាតម្លៃក្នុងករណីបណ្តឹងទាមទារច្រើនចំណុច

១- តម្លៃកម្មវត្ថុនៃបណ្តឹងត្រូវបានគណនា ដោយផ្អែកលើមូលដ្ឋាននៃផលប្រយោជន៍ដែលបានទាមទារក្នុងបណ្តឹងនោះ ។ ក្នុងករណីដែលការទាមទារច្រើនចំណុចក្នុងបណ្តឹងតែមួយ តម្លៃសរុបនៃការទាមទារទាំងនោះ ត្រូវបានចាត់ទុកជាតម្លៃកម្មវត្ថុនៃបណ្តឹង ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះការទាមទារនីមួយៗ ក្នុងករណីដែលផលប្រយោជន៍ដែលបានទាមទារ មានលក្ខណៈដូចគ្នាចំពោះការទាមទារនីមួយៗនោះ ។

២- ក្នុងករណីដែលការទាមទារលើផល សំណងនៃការខូចខាត ប្រាក់ធានាសងក្នុងករណីបំពានកិច្ចសន្យា ឬ សោហ៊ុយ គឺជាកម្មវត្ថុបន្ទាប់បន្សំនៃបណ្តឹង នោះតម្លៃទាំងនោះមិនត្រូវបូកសរុបលើការគណនាតម្លៃកម្មវត្ថុនៃបណ្តឹងឡើយ ។

៣- ក្នុងករណីដែលមានការពិបាកក្នុងការគណនាតម្លៃដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវកំណត់តម្លៃនោះ ដោយឆន្ទានុសិទ្ធិសមហេតុផល ។ ក្នុងករណីដែលតម្លៃនោះមិនអាចគណនាបានទេ នោះត្រូវចាត់ទុកថាមានចំនួន ៥.៥០០.០០០ (ប្រាំលានប្រាំសែន) រៀល ។

(កំណត់)

ការគណនាតម្លៃកម្មវត្ថុនៃបណ្តឹង មានប្រយោជន៍ ក្នុងការគណនាប្រាក់ប្រដាប់ក្តី (មាត្រា ៦១ (ពន្ធដាក់ពាក្យសុំ)) ការសម្រេចថាតើរឿងក្តីត្រូវជំនុំជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះ ឬទេ ដោយឆន្ទានុសិទ្ធិ (មាត្រា ២៣ (ការជម្រះក្តីលើកទី ១ ដោយចៅក្រមមួយរូប ឬ ដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម) កថាខណ្ឌទី ២ ចំណុច **ក**) ការសម្រេចថាតើគោលការណ៍នៃការតំណាងតែដោយមេធាវីត្រូវយកមកអនុវត្តចំពោះរឿងក្តីនោះ ឬទេ (មាត្រា ៥៣ (លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ) កថាខណ្ឌទី ១ ចំណុច **ឃ**) ឬ ថាត្រូវអនុវត្តតាមបញ្ញត្តិពិសេសស្តីពីរឿងក្តីចំនួនទឹកប្រាក់តិច (មាត្រា ២២៤ (ល័ក្ខខ័ណ្ឌនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច ជាអាទិ៍) កថាខណ្ឌទី ១) ឬ ថាតើបណ្តឹងនោះត្រូវបិទផ្លូវឧទ្ធរណ៍ ឬទេ (មាត្រា ២៦០ (សាលក្រមដែលអាចប្តឹងឧទ្ធរណ៍បាន ជាអាទិ៍) កថាខណ្ឌទី ១ ចំណុច **ខ**) ។ល ។

ឧទាហរណ៍នៃវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ មានដូចជា បណ្តឹងទាមទារប្រាក់ពីកូនបំណុលផង ពីអ្នកធានាផង ។ ករណីនេះ មិនអាចបូកបញ្ចូលគ្នានូវតម្លៃនៃកម្មវត្ថុបណ្តឹង ដើម្បីគណនាប្រាក់ប្រដាប់ក្តីទេ ។

ចំនួនទឹកប្រាក់ ៥.៥០០.០០០ (ប្រាំលានប្រាំសែន) រៀល ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ នេះ គឺជាចំនួន

ដែលមិនបិទផ្លូវឧទ្ធរណ៍ ហើយមិនធ្លាក់ទៅរឿងក្តីចំនួនទឹកប្រាក់តិចទេ គឺត្រូវធ្លាក់ទៅរឿងក្តីដែលត្រូវបានវិនិច្ឆ័យ ដោយក្រុមប្រឹក្សាជំនុំជម្រះដោយឆន្ទានុសិទ្ធិ ។

សូមមើលមាត្រា ៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។

**មាត្រា ៦១.-** ពន្ធដាក់ពាក្យសុំ

១- ពេលដែលដាក់ពាក្យបណ្តឹង ត្រូវបង់ពន្ធដែលមានចំនួនប្រាក់ដោយគណនាទៅតាមតម្លៃកម្មវត្ថុនៃបណ្តឹង ដែលបានកំណត់ក្នុងចំណុចនីមួយៗខាងក្រោមនេះ ទៅតុលាការ :

- **ក-** ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្តឹងដល់ ១០.០០០.០០០ (ដប់លាន) រៀល ក្នុងចំនួន ១០០.០០០ (មួយសែន) រៀល ត្រូវបង់ ១.០០០ (មួយពាន់) រៀល ។
- **ខ-** ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្តឹងដែលលើស ១០.០០០.០០០ (ដប់លាន) រៀលដល់ ១០០.០០០.០០០ (មួយរយលាន) រៀល ក្នុងចំនួន ១០០.០០០ (មួយសែន) រៀល ត្រូវបង់ ៧០០ (ប្រាំពីររយ) រៀល ។
- **គ-** ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្តឹងដែលលើស ១០០.០០០.០០០ (មួយរយលាន) រៀលដល់ ១.០០០.០០០.០០០ (មួយពាន់លាន) រៀល ក្នុងចំនួន ១០០.០០០ (មួយសែន) រៀល ត្រូវបង់ ៣០០ (បីរយ) រៀល ។
- **ឃ-** ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្តឹងដែលលើស ១.០០០.០០០.០០០ (មួយពាន់លាន) រៀល ក្នុងចំនួន ១០០.០០០ (មួយសែន) រៀល ត្រូវបង់ ១០០ (មួយរយ) រៀល ។

២- តម្លៃកម្មវត្ថុនៃបណ្តឹង ដែលជាមូលដ្ឋានដើម្បីធ្វើការគណនាពន្ធដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវគណនាតាមបញ្ញត្តិនៃមាត្រា ៦០ (ការគណនាតម្លៃកម្មវត្ថុនៃបណ្តឹង ការគណនាតម្លៃក្នុងករណីបណ្តឹងទាមទារច្រើនចំណុច) នៃក្រមនេះ ។

៣- ចំពោះការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ត្រូវបង់ពន្ធ ១,៥ ដង (មួយក្បៀសប្រាំដង) នៃពន្ធដែលបានគណនាតាមកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ រីឯចំពោះការដាក់ពាក្យបណ្តឹងសាទុក្ខវិញ ត្រូវបង់ពន្ធ ២ ដង (ពីរដង) នៃពន្ធដែលបានគណនាតាមកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ទៅតុលាការ ។

៤- ចំពោះការដាក់ពាក្យបណ្តឹងជំនុំជម្រះសាជាថ្មី ត្រូវបង់ ១០.០០០ (មួយម៉ឺន) រៀលទៅតុលាការ ។

៥- ចំពោះការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ត្រូវបង់ពន្ធដែលមានចំនួន ១ ភាគ ២ (មួយភាគពីរ) នៃចំនួនប្រាក់ដោយគណនាតាមកថាខណ្ឌទី ១ ខាងលើនេះ ទៅតាមតម្លៃកម្មវត្ថុនៃការទាមទារ ។ បើចាត់ទុកថាមានការដាក់ពាក្យបណ្តឹង តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣២៧ (អានុភាពនៃពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន) ឬ មាត្រា ៣៣១ (ការផ្ទេរនីតិវិធីដាស់តឿនទៅនីតិវិធីនៃបណ្តឹង ដោយពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជា

បណ្តោះអាសន្ន) នៃក្រមនេះ អ្នកដែលបានដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ត្រូវបង់ពន្ធចំនួនប្រាក់ដែលគណនា ដោយដកចំនួនពន្ធដែលខ្លួនបានបង់ចំពោះការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ពីចំនួនពន្ធដែលបានគណនាតាមកថាខណ្ឌទី ១ ខាងលើនេះ ។

៦- ចំពោះករណីដាក់ពាក្យសុំទៅតុលាការឱ្យសម្រេចសេចក្តី ក្រៅពីការកំណត់នៅក្នុងបញ្ញត្តិនៃកថាខណ្ឌទី ១ និង បញ្ញត្តិពីកថាខណ្ឌទី ៣ ទៅទី ៥ ត្រូវបង់ ៥.០០០ (ប្រាំពាន់) រៀលទៅតុលាការ ។

៧- ការបង់ពន្ធត្រូវធ្វើដោយការបង់ជាប្រាក់នៅកន្លែងទទួលពាក្យនៃតុលាការ ។ ពាក្យសុំដែលមិនបានបង់ពន្ធនៅពេលដាក់ទេ ត្រូវចាត់ទុកថាជាពាក្យសុំមិនស្របច្បាប់ ។

៨- ក្នុងករណីដែលបានរៀបរាប់ខាងក្រោមនេះ យោលទៅតាមពាក្យសុំរបស់អ្នកដែលបានបង់ តុលាការនឹងត្រូវសងនូវពន្ធដែលកំណត់ដោយចំណុចខាងក្រោមនេះ :

**ក**- ករណីដែលបង់ពន្ធលើស : សងពន្ធដែលបានបង់លើសទៅវិញ ។

**ខ**- ករណីដែលការផ្សះផ្សាបានលទ្ធផលមុនពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ករណីដែលដកពាក្យបណ្តឹងមុនពេលចប់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់លើកដំបូង និង ករណីដែលសេចក្តីសម្រេចលើកចោលពាក្យបណ្តឹងដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ចូលជាស្ថាពរ : សងពាក់កណ្តាលនៃពន្ធដែលបានបង់ហើយទៅវិញ ។

(កំណត់)

មាត្រានេះមានការទាក់ទងទៅនឹងកថាខណ្ឌទី 1 នៃមាត្រា 2 កថាខណ្ឌទី 1 នៃមាត្រា 3 តារាងឧបសម្ព័ន្ធទី 1 និង មាត្រា 6 នៃច្បាប់ស្តីពីប្រាក់ប្រដាប់ក្តីនៃបណ្តឹងរដ្ឋប្បវេណីជប៉ុន ។

"ពាក្យសុំ" ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៦ រាប់បញ្ចូលផងដែរនូវពាក្យបណ្តឹងជំទាស់ចំពោះចៅក្រមពាក្យបណ្តឹងតវ៉ា ចំពោះសាលក្រមស្ថាពរអំពីរឿងក្តីចំនួនទឹកប្រាក់តិច ពាក្យបណ្តឹងទាមទារឱ្យថែរក្សាការពារភស្តុតាង និង ពាក្យបណ្តឹងជំទាស់ ។

ម្យ៉ាងទៀត ចំពោះពន្ធនៃការដាក់ពាក្យបណ្តឹងដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នេះ យើងអាចយកប្រព័ន្ធកំណត់ចំនួនតែមួយ ជំនួសប្រព័ន្ធ regressive ។ ប្រសិនបើយើងកំណត់ពន្ធនៃការដាក់ពាក្យបណ្តឹងជាចំនួនតែមួយ ត្រូវកំណត់ចំនួនតិចល្មម ដើម្បីកុំឱ្យរារាំងការទាមទារតម្លៃតិច ។ ក្នុងក្រុមការងារនៃភាគីជប៉ុន មានមតិផ្សេងគ្នា ចំពោះការយកប្រព័ន្ធនេះ ដោយសារមានបញ្ហាសមភាព បើយកពន្ធតិចល្មមនោះ សម្រាប់ការទាមទារតម្លៃតិចផង ការទាមទារតម្លៃច្រើនផង ។ ហេតុដូច្នេះ ក្រមនេះ យកប្រព័ន្ធ regressive ។ រួមទាំងចំណុចនេះ សូមមើលកំណត់នៅក្នុងមាត្រា ៦៤ (ភាគដែលត្រូវទទួលបន្ទុក និង ការសងវិញនូវប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយ) ។

មាត្រានេះកំណត់ខុសប្លែកពីការកំណត់នៃច្បាប់ស្តីពីប្រាក់ប្រដាប់ក្តីរបស់កម្ពុជា ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៣

ដែលកំណត់ឱ្យភាគីដាក់ពាក្យបណ្ដឹងបង់ប្រាក់ប្រដាប់ក្ដី នៅក្រោយពេលដែលការផ្សះផ្សាពុំបានសម្រេច ។ ផ្ទុយទៅវិញ មាត្រានេះកំណត់ឱ្យភាគីដែលបានដាក់ពាក្យបណ្ដឹង ត្រូវបង់ពន្ធនៃការដាក់ពាក្យសុំ ដែលជាប្រភេទមួយនៃប្រាក់ប្រដាប់ក្ដី នៅក្នុងពេលដែលខ្លួនបានដាក់ពាក្យបណ្ដឹងទៅតុលាការ ។

ការជ្រើសរើសយកប្រព័ន្ធនេះ ធ្វើឱ្យមានភាពងាយស្រួលដល់ដំណើរការនៃនីតិវិធី ម្យ៉ាងជួយសម្រាលបន្ទុករបស់រដ្ឋដែលត្រូវចំណាយក្នុងកិច្ចការនេះ ហើយម្យ៉ាងទៀតអាចរារាំងបាន ចំពោះភាគីដែលបានដាក់ពាក្យបណ្ដឹងដោយមិនត្រឹមត្រូវ និង បង្កភាពលំបាក ដល់ការអនុវត្តនីតិវិធីរបស់តុលាការ ។

**មាត្រា ៦២.-** ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ

១- ភាគី ឬ បុគ្គលដែលទាក់ទងនឹងរឿងក្ដី ត្រូវបង់ប្រាក់ប្រដាប់ក្ដីខាងក្រោមនេះ ទៅតាមចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការ :

- **ក-** ចំនួនទឹកប្រាក់ចាំបាច់ដើម្បីឱ្យតុលាការធ្វើការពិនិត្យភស្តុតាង ការបញ្ជូនឯកសារ ឬ សកម្មភាពផ្សេងទៀត តាមនីតិវិធីក្នុងបណ្ដឹងរដ្ឋប្បវេណី ។
- **ខ-** ចំនួនទឹកប្រាក់ស្មើនឹងសោហ៊ុយធ្វើដំណើរ និង សោហ៊ុយស្នាក់នៅដែលចាំបាច់សម្រាប់ចៅក្រម និង ក្រឡាបញ្ជី ក្នុងករណីដែលត្រូវធ្វើការពិនិត្យភស្តុតាង ការស្រាវជ្រាវអង្គហេតុ ឬ សកម្មភាពផ្សេងទៀត ដែលប្រព្រឹត្តទៅនៅក្រៅតុលាការ ។

២- ភាគី ឬ បុគ្គលដែលទាក់ទងនឹងរឿងក្ដី ដែលត្រូវបង់ប្រាក់ប្រដាប់ក្ដីដូចបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះប្រាក់ប្រដាប់ក្ដីសម្រាប់សកម្មភាពដែលធ្វើឡើងដោយពាក្យសុំ គឺអ្នកដាក់ពាក្យសុំ រីឯចំពោះប្រាក់ប្រដាប់ក្ដីសម្រាប់សកម្មភាពដែលធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការ គឺអ្នកដែលតុលាការបានកំណត់ឱ្យបង់ ។

៣- ចំពោះសកម្មភាពដែលត្រូវបង់ប្រាក់ប្រដាប់ក្ដីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវបង្គាប់ឱ្យភាគី ឬ បុគ្គលដែលទាក់ទងនឹងរឿងក្ដី បង់ចំនួននោះជាមុន ។

៤- ក្នុងករណីដែលតុលាការបានបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្ដីជាមុន តាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ តែសាមីខ្លួនមិនបានបង់ជាមុនទេនោះ តុលាការអាចមិនធ្វើនូវសកម្មភាពដែលចាំបាច់ត្រូវមានប្រាក់ប្រដាប់ក្ដីនោះបាន ។

៥- ចំពោះប្រាក់ប្រដាប់ក្ដីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ដែលមិនបានបង់ជាមុនទេ តុលាការអាចប្រមូលពីអ្នកដែលត្រូវទទួលបន្ទុកលើការបង់ប្រាក់ប្រដាប់ក្ដីនោះបាន ដោយអាស្រ័យលើដីកាសម្រេចរបស់តុលាការ តាមបញ្ញត្តិនៃមាត្រា ៦៤ (ភាគដែលត្រូវទទួលបន្ទុក និង ការសងវិញនូវប្រាក់ប្រដាប់ក្ដីដែលបានបង់រួចហើយ) នៃក្រមនេះ ។

(កំណត់)

មាត្រានេះតម្រូវទៅតាមមាត្រា 11 មាត្រា 12 មាត្រា 14 និង មាត្រា 15 នៃច្បាប់ស្ដីពីប្រាក់ប្រដាប់ក្ដីនៃបណ្ដឹង

រដ្ឋប្បវេណីជប៉ុន ។

ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ គឺជាប្រាក់ប្រដាប់ក្ដីតុលាការដែលភាគី ឬ បុគ្គលដែលទាក់ទងនឹងរឿងក្ដីត្រូវបង់ជាមុនសម្រាប់ការចំណាយរបស់តុលាការដែលធ្វើសកម្មភាពតាមនីតិវិធីនៅក្នុងបណ្ដឹងរដ្ឋប្បវេណី ដូចជាចំនួនប្រាក់ចាំបាច់សម្រាប់ការពិនិត្យភស្តុតាង ការបញ្ជូនឯកសារ សោហ៊ុយសម្រាប់ធ្វើដំណើរ ស្នាក់នៅរបស់ចៅក្រម ក្រឡាបញ្ជីក្នុងការពិនិត្យភស្តុតាង ស្រាវជ្រាវអង្គហេតុ សាកសួរសាក្សី ដែលប្រព្រឹត្តនៅក្រៅតុលាការ ។

សកម្មភាពតាមនីតិវិធីក្នុងបណ្ដឹងរបស់តុលាការខាងលើអាចត្រូវបានធ្វើឡើង តាមពាក្យសុំរបស់ភាគី ដែលទាក់ទងនឹងរឿងក្ដី ឬ ដោយឆន្ទានុសិទ្ធិរបស់តុលាការ ។ ក្នុងករណីដែលសកម្មភាពនេះត្រូវបានធ្វើឡើងដោយពាក្យសុំនោះជនដែលបានដាក់ពាក្យសុំត្រូវបង់ប្រាក់ប្រដាប់ក្ដីមុន តាមការបង្គាប់របស់តុលាការ ។ ករណីដែលសកម្មភាព នៅក្នុងនីតិវិធី ត្រូវបានធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការ នោះតុលាការអាចកំណត់ឱ្យភាគី ឬ បុគ្គលដែលទាក់ទងនឹងរឿងក្ដីបង់មុន ។ តុលាការអាចពិនិត្យលើលទ្ធភាព ស្ថានភាពសេដ្ឋកិច្ច ជាដើម ដើម្បីកំណត់ឱ្យជនណាមួយបង់ប្រាក់នេះមុន សម្រាប់សកម្មភាពនីតិវិធី ។

**មាត្រា ៦៣.-** ប្រាក់ប្រដាប់ក្ដីភាគី

ក្រៅពីការកំណត់នៅក្នុងមាត្រា ៦១ (ពន្ធដាក់ពាក្យសុំ) និង មាត្រា ៦២ (ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ) ខាងលើនេះ ចំនួនទឹកប្រាក់ដែលតុលាការកំណត់ថាសមរម្យដោយគិតពិចារណានូវលក្ខណៈនៃរឿងក្ដី ឬ លទ្ធភាពទ្រព្យធនរបស់ភាគី ជាអាទិ៍ ក្នុងចំណោមការកំណត់ក្នុងចំណុចខាងក្រោមនេះ ក៏ត្រូវចាត់ទុកថាជាប្រាក់ប្រដាប់ក្ដីដែរ :

**ក-** ថ្លៃធ្វើលិខិត ដូចជា លិខិតពាក្យបណ្ដឹង លិខិតពាក្យសុំផ្សេងទៀត ឬ ឯកសារផ្សេងៗ ដូចជា ឯកសារត្រៀមជាអាទិ៍ និង ថ្លៃដាក់ឯកសារនោះទៅតុលាការ ។

**ខ-** សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ និង សោហ៊ុយស្នាក់នៅសម្រាប់ភាគីនិងអ្នកតំណាង ដើម្បីបង្ហាញខ្លួនតាមកាលបរិច្ឆេទដែលបានកំណត់ ។

**គ-** សោហ៊ុយផ្សេងទៀត ដែលតុលាការទទួលស្គាល់ថាជាសោហ៊ុយចាំបាច់សម្រាប់ការអនុវត្តនូវនីតិវិធីបណ្ដឹង ។

(កំណត់)

ការរៀបរាប់អំពីប្រាក់ប្រដាប់ក្ដីភាគីទាំងអស់លំអិតពេកនាំឱ្យមានការស្មុគស្មាញខ្លាំង ហេតុដូច្នេះ ចំណុច **ក** និង ចំណុច **ខ** គ្រាន់តែដាក់ជាឧទាហរណ៍តែប៉ុណ្ណោះ ។ រីឯនៅចំណុច **គ** ចែងអំពីលក្ខណៈទូលាយនៃសោហ៊ុយ ហើយក្នុងចំណោមសោហ៊ុយទាំងនោះ ចែងតែទៅលើទំហំទឹកប្រាក់ដែលតុលាការទទួលស្គាល់ ទើបអាចចាត់ទុកជាប្រាក់ប្រដាប់ក្ដី ។ សោហ៊ុយដែលអាចបញ្ចូលក្នុងចំណុច **គ** នេះ មានដូចជា ពន្ធដើម្បីទទួលឯកសារ ឬ សំបុត្របញ្ជាក់ផ្សេងៗពីក្រសួង ឬ ស្ថាប័នសាធារណៈផ្សេង (ឧទាហរណ៍ ដូចជាលិខិតចម្លងនៃការចុះបញ្ជីអចលនវត្ថុ

លិខិតបញ្ជាក់ការបង់ពន្ធ ជាដើម គឺជាសោហ៊ុយដែលបានកំណត់ក្នុងច្បាប់ស្ដីពីប្រាក់ប្រដាប់ក្ដីនៃបណ្ដឹងរដ្ឋប្បវេណីជប៉ុន មាត្រា 2 ចំណុចទី 8) ថ្លៃសម្រាប់ផ្ញើឯកសារ ឬ វត្ថុ ( មាត្រា 2 ចំណុចទី 10 នៃច្បាប់ដដែល) សោហ៊ុយវាស់វែងដី និង សោហ៊ុយសម្រាប់ធ្វើការស្រាវជ្រាវអំពីទំនាក់ទំនងនៃអង្គហេតុ ដើម្បីរៀបចំធ្វើនីតិវិធី ជាដើម ។

ចំពោះថ្លៃពឹងពាក់មេធាវីវិញ មិនបញ្ចូលក្នុងប្រាក់ប្រដាប់ក្ដីទេ តែត្រូវទុកជាបន្ទុករបស់ភាគី តាមមតិយោបល់របស់ភាគីកម្ពុជា នៅពេលធ្វើសិក្ខាសាលាលើកទី ៦ ( នៅខែ សីហា ឆ្នាំ ២០០០) ។

ប្រាក់ប្រដាប់ក្ដីភាគីជាប្រភេទមួយនៃប្រាក់ប្រដាប់ក្ដី ហើយចំនួនទឹកប្រាក់ត្រូវបានកំណត់ដោយតុលាការ ដោយពិចារណាលើលក្ខណៈរឿងក្ដី លទ្ធភាពនៃទ្រព្យធនរបស់ភាគី ដែលជាសោហ៊ុយសម្រាប់ការអនុវត្តនីតិវិធីនៃបណ្ដឹង ។

ប្រាក់ប្រដាប់ក្ដីភាគី មិនអាចជួយសង្គ្រោះបានឡើយ ដែលផ្ទុយគ្នាពីប្រាក់ប្រដាប់ក្ដីតុលាការដែលជួយសង្គ្រោះបាន ( សូមមើលមាត្រា ៧០ ( ខ្លឹមសារនៃជំនួយសង្គ្រោះលើបណ្ដឹង)) ។

## ផ្នែកទី ២ បន្ទុកនៃប្រាក់ប្រដាប់ក្ដី

**មាត្រា ៦៤.-** ភាគដែលត្រូវទទួលបន្ទុក និង ការសងវិញនូវប្រាក់ប្រដាប់ក្ដីដែលបានបង់រួចហើយ

១- ប្រាក់ប្រដាប់ក្ដី គឺជាបន្ទុករបស់ភាគីចាញ់ក្ដី ។ ក្នុងករណីដែលបានចាញ់ក្ដីតែមួយភាគទេ តុលាការត្រូវសម្រេចនូវបន្ទុកដែលភាគីម្នាក់ៗត្រូវទទួល ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

២- ទោះបីមានកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏តុលាការអាចសម្រេចតាមកាលៈទេសៈ ឱ្យភាគីឈ្នះក្ដីទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្ដីទាំងអស់ ឬ មួយភាគបាន ក្នុងករណីដែលភាគីឈ្នះក្ដីនោះបានប្រព្រឹត្តសកម្មភាពបណ្ដឹងណាមួយ ដែលមិនចាំបាច់ក្នុងការតទល់ ឬ ការការពារខ្លួន ឬ បានធ្វើនីតិវិធីនៃបណ្ដឹងឱ្យមានការយឺតយ៉ាវ ។

៣- អ្នកដែលធ្វើសហបណ្ដឹងត្រូវទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្ដីស្មើភាគគ្នា ។ ប៉ុន្តែ តុលាការអាចសម្រេចតាមកាលៈទេសៈ ឱ្យភាគីដែលធ្វើសហបណ្ដឹងទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្ដី ដោយសាមគ្គីភាពបាន ឬ អាចសម្រេចឱ្យភាគីណាមួយដែលបានប្រព្រឹត្តសកម្មភាពបណ្ដឹងណាដែលមិនចាំបាច់ក្នុងការតទល់ ឬ ការការពារខ្លួន ទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្ដីច្រើនជាងភាគីដែលធ្វើសហបណ្ដឹងផ្សេងទៀតបាន ។

៤- ក្នុងករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកតំណាងដោយអាណត្តិ ឬ ក្រឡាបញ្ជី បានធ្វើឱ្យចំនួនទឹកប្រាក់ប្រដាប់ក្ដីដែលគ្មានប្រយោជន៍កើតឡើង ដោយចេតនា ឬ ដោយមានកំហុសធ្ងន់ធ្ងររបស់ខ្លួន តុលាការដែលបានទទួលពាក្យបណ្ដឹង អាចបង្គាប់ឱ្យអ្នកនោះសងនូវចំនួននៃប្រាក់ប្រដាប់ក្ដីនោះវិញបាន ដោយដីកាសម្រេច តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

៥- ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

(កំណត់)

មាត្រានេះតម្រូវទៅតាមមាត្រា 61 ដល់មាត្រា 65 និង មាត្រា 69 កថាខណ្ឌទី 1 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

តាមការអនុវត្តជាក់ស្តែងនៅកម្ពុជាសព្វថ្ងៃនេះ (តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី) ពន្ធចុះបញ្ជីក្តី (ពន្ធដើម្បីដាក់ពាក្យបណ្តឹង) ជាចំនួនប្រាក់កំណត់ ហើយក្រោយពេលដែលដើមចោទបានឈ្នះក្តី ដើមចោទនោះត្រូវបង់នូវពន្ធសមាមាត្រដែលជាប្រាក់ប្រដាប់ក្តី ទៅតាមភាគរយនៃចំនួនផលប្រយោជន៍ដែលខ្លួនទទួលបានមកពីការឈ្នះក្តី ។ នេះគឺជារបៀបឱ្យបង់ ២ ជាន់ (២ លើក) និង ជារបៀបរបបសមហេតុផលមួយដើម្បីជៀសវាងឧបសគ្គក្នុងការប្តឹង ដោយសារភាគីនោះត្រូវបង់ប្រាក់ប្រដាប់ក្តីជាចំនួនច្រើន ។ ប៉ុន្តែ មួយចំណែកទៀត តាមរបៀបនោះ ដែលកំណត់ថា ដើមចោទត្រូវបង់ប្រាក់ប្រដាប់ក្តី តាមសមាមាត្រនៃផលប្រយោជន៍ដែលខ្លួនបានទទួលពីការឈ្នះក្តី នោះយើងមានការព្រួយបារម្ភត្រង់ចំណុចថា វាអាចបណ្តាលឱ្យចៅក្រមមានចិត្តចង់ឱ្យដើមចោទឈ្នះក្តី ។ ដោយសារការព្រួយបារម្ភបែបនេះនៅក្នុងមាត្រានេះ យើងចែងថា ជាទូទៅត្រូវឱ្យអ្នកចាញ់ក្តីបង់ប្រាក់ប្រដាប់ក្តីវិញ ។

បញ្ញត្តិនេះមានភាពដូចគ្នាទៅនឹងច្បាប់ស្តីពីប្រាក់ប្រដាប់ក្តីរបស់កម្ពុជាបច្ចុប្បន្ន ត្រង់ចំណុច "ជាបន្ទុករបស់ភាគីដែលចាញ់ក្តី" ។ ប៉ុន្តែ បញ្ហាថ្មីដែលត្រូវបានកំណត់ក្នុងមាត្រានេះ គឺបន្ទុករបស់ភាគីដែលចាញ់ក្តីតែមួយភាគដែលនៅក្នុងច្បាប់ប្រដាប់ក្តីកម្ពុជាបច្ចុប្បន្នមិនមានកំណត់ច្បាស់លាស់ឡើយ ។ ការកំណត់បែបនេះអាចរារាំងមិនឱ្យភាគីដាក់ពាក្យបណ្តឹងទាមទារតាមតែទំនើងចិត្តរបស់ខ្លួន ដោយពុំមានភាពសមហេតុផល ដូចជាការទាមទារឱ្យភាគីណាមួយសងតម្លៃវត្ថុដែលខូចខាតដោយអំពើអនីត្យានុកូល ក្នុងតម្លៃហួសប្រមាណពីតម្លៃជាក់ស្តែងនៃវត្ថុដែលតុលាការទទួលស្គាល់ ។ ករណីបែបនេះ ភាគីដើមបណ្តឹងអាចទទួលបន្ទុកប្រាក់ប្រដាប់ក្តីមួយភាគចំពោះចំណែកដែលខ្លួនចាញ់ក្តី ។

<u>Code of Civil Procedure (Japan)</u>
**Article 61** (Basic principle of imposition of court costs)
The losing party shall bear the court costs.
**Article 62** (Imposition in case where unnecessary act was performed)
The court may, depending on the circumstances, charge the winning party with all or a part of court costs incurred by acts which were unnecessary for the assertion or defense of such party's rights or incurred by acts which were necessary, at the stage of litigation at the time the acts were performed, for the assertion or defense of the adversary party's rights.
**Article 63** (Imposition in case where a party has delayed the litigation)
In cases where a party has delayed the litigation by failing to advance offensive or defensive measures at the appropriate time, or by failing to observe designated dates or terms or for any other reason attributable to such party, the court may impose upon such party all or a part of the court costs arising from such delay even when such party in the winning party.
**Article 64** (Imposition in case of partial defeat)
In the case of a partial defeat, the court costs chargeable against each party shall be designated at the discretion of the court. However, depending on the circumstances, the court may impose all of the court costs upon wither party.
**Article 65** (Imposition in case of joint litigation)
1. Joint parties shall bear court costs in equal proportion. However, depending on the circumstances, the court may impose the court costs jointly and severally or in any other way upon the joint parties.
2. Notwithstanding the provisions of the preceding paragraph, the court may charge a party who haws performed acts unnecessary for the assertion or defense of such party's rights with the court costs incurred therefor.
**Article 69** (Reimbursement of costs by legal representative, etc.) (excerpt)
1. In cases where a legal representative, advocates, court clerk or execution officer incurs unnecessary court costs intentionally or through gross negligence, the court before which the suit has been filed may, upon motion or upon its owm authority, order such person to reimburse the amount of such costs.

**មាត្រា ៦៥.-** ការសម្រេចសេចក្តីលើបន្ទុកនៃការបង់ប្រាក់ប្រដាប់ក្តី

១- ក្នុងការសម្រេចសេចក្តីដើម្បីបញ្ចប់រឿងក្តី តុលាការត្រូវធ្វើការសម្រេចសេចក្តីអំពីបន្ទុកនៃប្រាក់ប្រដាប់ក្តីទាំងអស់នៅថ្នាក់នៃការជម្រះក្តីនោះ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

២- ក្នុងករណីដែលតុលាការជាន់ខ្ពស់បានផ្លាស់ប្តូរសេចក្តីសម្រេចអង្គសេចក្តី តុលាការត្រូវធ្វើការសម្រេចអំពីបន្ទុកនៃប្រាក់ប្រដាប់ក្តីទាំងអស់ឡើងវិញ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលតុលាការដែលទទួលបណ្តឹងដែលត្រូវបានបញ្ជូនត្រឡប់មកវិញ ឬ ត្រូវបានផ្ទេរ សម្រេចសេចក្តីដើម្បីបញ្ចប់រឿងក្តីនោះ ។

៣- ក្នុងករណីដែលរឿងក្តីនោះបានចប់ដោយមិនធ្វើទៅតាមការសម្រេចសេចក្តីទេនោះ តុលាការនៃការជំនុំជម្រះលើកទី១ ត្រូវបង្គាប់ឱ្យទទួលបន្ទុកក្នុងការបង់ប្រាក់ប្រដាប់ក្តីនោះ តាមពាក្យសុំ ដោយដីកាសម្រេច ។ ប៉ុន្តែ ចំពោះបណ្តឹងដែលបានផ្សះផ្សាគ្នាហើយនោះ ប្រាក់ប្រដាប់ក្តីត្រូវបានបង់ទៅតាមការព្រមព្រៀងគ្នា ហើយប្រសិនបើគ្មានការព្រមព្រៀងគ្នាទេ ភាគីនីមួយៗត្រូវទទួលបន្ទុកក្នុងការបង់រៀងៗខ្លួន ។

(កំណត់)

មាត្រានេះមានការទាក់ទងនឹងមាត្រា 67 (មាត្រា 68) និង មួយភាគនៃមាត្រា 73 កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ ករណីដែលកំណត់ថា "ករណីដែលរឿងក្តីនោះបានចប់ដោយមិនធ្វើទៅតាមការសម្រេចសេចក្តីទេ" រាប់បញ្ចូលការដកពាក្យបណ្តឹង ការលះបង់ការទាមទារ ឬ ការទទួលស្គាល់ការទាមទារ និង ការផ្សះផ្សាលើបណ្តឹង (សូមមើលកំណត់នៃមាត្រា ២២២ (អានុភាពនៃកំណត់ហេតុស្តីពីការសះជា ជាអាទិ៍)) ។

ជាទូទៅការសម្រេចអំពីបន្ទុកនៃប្រាក់ប្រដាប់ក្តីទាំងអស់ ជាសមត្ថកិច្ចរបស់តុលាការនៅថ្នាក់ជម្រះក្តី នៅក្នុងការសម្រេចសេចក្តីបញ្ចប់រឿងក្តី ។ ប៉ុន្តែ ការសម្រេចសេចក្តីរបស់ថ្នាក់ជម្រះក្តីណាមួយ (សាលាដំបូង ឬ សាលាឧទ្ធរណ៍) អាចត្រូវបានប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ហើយតុលាការជាន់ខ្ពស់អាចផ្លាស់ប្តូរសេចក្តីសម្រេចអង្គសេចក្តី ដូចនេះ តុលាការត្រូវសម្រេចប្រាក់ប្រដាប់ក្តីទាំងអស់ឡើងវិញ ដោយពិចារណា និង អនុលោមតាមមាត្រា ៦៤ ។

<u>Code of Civil Procedure (Japan)</u>

**Article 67** (Decision on imposition of court costs)

1. In a decision which terminates a case, the court shall decide upon the whole of the court costs in the particular instance upon its own authority. However, depending on the circumstances, it may decide on the court costs relating to a part of the case or to an interlocutory dispute in a decision on such part or dispute.
2. In cases where a superior court changes the decision upon the merits of a suit, such court shall decide on the whole of the court costs. The same shall apply to those cases where the court to which a case has been remanded or transferred is to render a decision terminating the case.

**Article 68** (Imposition in case of compromise)

In cases where the parties have effected a compromise in court and have not made any particular arrangement with regard to the imposition of the costs of compromise or the court costs, each party shall bear those costs which they have individually incurred.

**Article 73** (Treatment of case where a suit is terminated other than by decision or compromise, etc.)

1. In cases where a suit is terminated other than by a decision or a compromise, the court of the first instance shall, upon motion, by ruling, charge the court costs, and, after such ruling has become executable, the court clerk in the court shall fix the amount of the imposition thereof. The same shall apply to cases where there has been a withdrawal of an application for assisting intervention or a withdrawal of an objection to assisting intervention.
2. The provisions of Articles 61 to 66 inclusive and Article 71, paragraph 7, shall apply *mutatis mutandis* to a ruling relating to the

motion referred to in the preceding paragraph; and the provisions of Article 71, paragraph 2 and 3 shall apply *mutatis mutandis* to a disposition by a court clerk relating to the motion referred to in the preceding paragraph; and the provisions of Article 71, paragraph 4 to 7 inclusive shall apply *mutatis mutandis* to an objection to such a disposition.

**មាត្រា ៦៦.-** នីតិវិធីដើម្បីកំណត់ជាស្ថាពរនូវចំនួនប្រាក់ប្រដាប់ក្ដី

១- ចំនួនប្រាក់ប្រដាប់ក្ដីដែលត្រូវទទួលបន្ទុកបង់ ត្រូវកំណត់ដោយក្រឡាបញ្ជីរបស់តុលាការនៃការជំនុំជម្រះលើកទី ១ តាមពាក្យសុំ នៅក្រោយពេលដែលសេចក្ដីសម្រេចអំពីបន្ទុកនោះបានបង្កើតអានុភាពនៃការអនុវត្ត ។

២- ចំពោះករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើគូភាគីទាំងសងខាងទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្ដី ប្រាក់ដែលភាគីនីមួយៗត្រូវទទួលបន្ទុកបង់នោះ ត្រូវបានចាត់ទុកថា បានធ្វើការទូទាត់ជាមួយនឹងគ្នា ចំពោះចំនួនទឹកប្រាក់ដែលត្រូវគ្នារួចហើយ ។

៣- ការចាត់ចែងលើពាក្យសុំដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ នឹងមានអានុភាព បន្ទាប់ពីបានជូនដំណឹងតាមរបៀបដែលអាចចាត់ទុកថាសមរម្យ ។

៤- ការធ្វើបណ្ដឹងតវ៉ាចំពោះការចាត់ចែងដែលបានកំណត់ក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) សប្ដាហ៍ ក្រោយពីបានទទួលដំណឹងនោះ ។ ក្នុងករណីដែលតុលាការទទួលស្គាល់ថា បណ្ដឹងតវ៉ានោះមានមូលហេតុត្រឹមត្រូវ តុលាការត្រូវកំណត់ចំនួននៃបន្ទុកប្រាក់ប្រដាប់ក្ដី ដោយខ្លួនឯង ។

៥- អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

(កំណត់)

មាត្រានេះមានការទាក់ទងនឹងមាត្រា 71 និង មួយភាគនៃមាត្រា 73 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ ចំពោះបណ្ដឹងតវ៉ាអំពីការចាត់ចែងរបស់ក្រឡាបញ្ជី ដែលបានកំណត់ក្នុងកថាខណ្ឌទី ៤ សូមមើលមាត្រា ២១៥ (បណ្ដឹងតវ៉ាអំពីការចាត់ចែងរបស់ក្រឡាបញ្ជី) ។

នៅក្នុងការអនុវត្តជាក់ស្ដែង របស់កម្ពុជានាពេលបច្ចុប្បន្ន នោះតុលាការមិនត្រឹមតែកំណត់អំពីបន្ទុកនៃប្រាក់ប្រដាប់ក្ដី នៅក្នុងសេចក្ដីសម្រេចបញ្ចប់រឿងប៉ុណ្ណោះទេ តុលាការថែមទាំងសម្រេចអំពីចំនួនប្រាក់ប្រដាប់ក្ដីដែលភាគីណាមួយត្រូវទទួលបន្ទុកបង់ទៀតផង ។ ប៉ុន្តែ នៅក្នុងមាត្រានេះ អ្នកដែលមានភារៈកំណត់អំពីចំនួនប្រាក់ប្រដាប់ក្ដីដែលភាគីត្រូវទទួលបន្ទុកបង់ គឺក្រឡាបញ្ជី ក្រោយពេលដែលសេចក្ដីសម្រេចអំពីបន្ទុកនេះបានបង្កើតអានុភាពនៃការអនុវត្ត តាមពាក្យសុំ ។

ការចាត់ចែងលើពាក្យសុំ នឹងមានអានុភាព បន្ទាប់ពីបានជូនដំណឹងតាមរបៀបដែលអាចចាត់ទុកថាសមរម្យ ពោលគឺមិនទាមទារឱ្យគោរពដាច់ខាត តាមបញ្ញត្តិស្ដីពីការបញ្ជូន ដែលមានចែងនៅក្នុងផ្នែកទី ២ ជំពូកទី ៨ នៃក្រមនេះឡើយ ។ នៅក្នុងករណីដែលមានការប្ដឹងតវ៉ា ចំពោះការចាត់ចែងរបស់ក្រឡាបញ្ជី នៅក្នុងអំឡុងពេលដែលច្បាប់បានកំណត់ ហើយការតវ៉ានេះត្រូវបានតុលាការទទួលស្គាល់ថា មានមូលហេតុត្រឹមត្រូវ នោះការកំណត់អំពីចំនួនប្រាក់ប្រដាប់ក្ដីគឺជាភារៈរបស់តុលាការ ។

Code of Civil Procedure (Japan)
**Article 71** (Procedure to fix amount of court costs)
1. The court clerk in the court of the first instance shall fix the amount of the imposition of the court costs upon a motion after the decision in which the imposition was decided has become executable.
2. Except those cases prescribed by the Rules of the Supreme Court, in cases referred to in the preceding paragraph, when each party bears court costs, the costs to be borne respectively by the parties shall be deemed to be set-off to the extent that such costs are borne by each party.
3. A disposition relating to the motion referred to in paragraph 1 shall take effect when notice thereof is given in such manner as may be deemed proper.
4. An objection to the disposition referred to in the preceding paragraph must be raised within one week of the peremptory term from the day on which notice is given.
5. The obejection referred to in the preceding paragraph shall have the effect of staying the execution.
6. In cases where the court deems that there are grounds for the objection to the disposition to fix the amount under the provisions of paragraph 1, if the amount of the imposition of court costs must be fixed, the court shall fix such amount itself.
7. An immediate *kokoku*-appeal may be made against a ruling relating to the objection referred to in paragraph 4.
**Article 73** > *see the note for the preceding article*

## ផ្នែកទី ៣ ប្រាតិភោគលើប្រាក់ប្រដាប់ក្ដី

**មាត្រា ៦៧.-** ដីកាសម្រេចបង្គាប់ឱ្យដាក់ប្រាតិភោគ

១- ប្រសិនបើដើមចោទគ្មានលំនៅឋាន ទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជាទេ តុលាការត្រូវបង្គាប់ឱ្យដើមចោទដាក់ប្រាតិភោគលើប្រាក់ប្រដាប់ក្ដី តាមពាក្យសុំរបស់ចុងចម្លើយ ដោយដីកាសម្រេច ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលប្រាតិភោគនោះមានការខ្វះខាត ។

២- ប្រសិនបើចុងចម្លើយបានធ្វើសេចក្ដីដោះសានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ បានឆ្លើយទាញហេតុផលអំពីអង្គសេចក្ដីនៃបណ្ដឹងនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ក្រោយពីបានដឹងថា មានមូលហេតុដែលតម្រូវឱ្យដាក់ប្រាតិភោគ នោះចុងចម្លើយមិនអាចដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបានឡើយ ។

៣- ចុងចម្លើយដែលបានដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចបដិសេធមិនព្រមតទល់នឹងបណ្ដឹងនេះរហូតដល់ពេលដែលដើមចោទដាក់ប្រាតិភោគបាន ។

៤- តុលាការត្រូវកំណត់នូវចំនួននៃប្រាតិភោគ និង អំឡុងពេលដែលត្រូវដាក់ប្រាតិភោគ នៅក្នុងដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៥- ចំនួននៃប្រាតិភោគ ត្រូវកំណត់ដោយយកចំនួនសរុបនៃប្រាក់ប្រដាប់ក្ដីដែលចុងចម្លើយត្រូវចំណាយនៅគ្រប់ថ្នាក់នៃការជំនុំជម្រះ ជាមូលដ្ឋាន ។

៦- ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

( កំណត់)

មាត្រានេះត្រូវនឹងមាត្រា 75 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន（ប៉ុន្តែ កថាខណ្ឌទី 2 នៃមាត្រា 75 មិនសូវមានភាពចាំបាច់ទេ ហេតុនេះហើយមិនបញ្ចូលក្នុងក្រមនេះទេ）។

កថាខណ្ឌទី ១ : ប្រសិនបើដើមចោទពុំមានលំនៅឋាន ឬ ទីស្នាក់ការអាជីវកម្មនៅក្នុងប្រទេសទេ ទោះបីជាចុងចម្លើយឈ្នះបណ្តឹងក៏ដោយ ក៏អាចមានការពិបាកក្នុងការទទួលសំណងនៃប្រាក់ប្រដាប់ក្តីដែលខ្លួនបានចេញដែរ ហេតុដូច្នេះ ក្នុងករណីនេះ តុលាការអាចបង្គាប់ឱ្យដើមចោទដាក់ប្រាតិភោគ តាមពាក្យសុំរបស់ចុងចម្លើយបាន ។

កថាខណ្ឌទី ២ : ប្រសិនបើមិនទៀងថាភាពដែលអាចប្រើសិទ្ធិបដិសេធមិនព្រមតទល់នឹងបណ្តឹងវិញ ដែលមានចែងក្នុងកថាខណ្ឌទី ៣ កើតឡើងពេលណា នោះអាចនាំឱ្យនីតិវិធីនៃបណ្តឹងមានការរអាក់រអួល ហេតុនេះហើយ កថា-ខណ្ឌនេះ ចែងថា បិទសិទ្ធិដាក់ពាក្យសុំឱ្យដាក់ប្រាតិភោគ នៅពេលដែលចុងចម្លើយបានតទល់នឹងបណ្តឹងចំពោះអង្គសេចក្តី ។

កថាខណ្ឌទី ៣ : ប្រសិនបើចុងចម្លើយបានដាក់ពាក្យសុំឱ្យដាក់ប្រាតិភោគ ហើយដើមចោទមិនទាន់ដាក់ប្រាតិភោគទេ តែចុងចម្លើយនៅតែត្រូវតទល់នឹងបណ្តឹងដោយចេញចំណាយប្រាក់ប្រដាប់ក្តីដោយខ្លួនឯង នោះទោះបីជាចុងចម្លើយឈ្នះបណ្តឹងក៏ដោយ ក៏អាចមិនបានទទួលនូវសំណងនៃប្រាក់ប្រដាប់ក្តីដែរ ហេតុនេះហើយ កថាខណ្ឌនេះទទួលស្គាល់សិទ្ធិបដិសេធមិនព្រមតទល់នឹងបណ្តឹងរបស់ចុងចម្លើយ រហូតដល់ពេលដែលដើមចោទ ដាក់ប្រាតិភោគហើយ ។

កថាខណ្ឌទី ៤ និង ទី ៥ : តុលាការអាចសម្រេចចំនួននៃប្រាតិភោគ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ដោយគិតថាចុងចម្លើយនឹងត្រូវចេញចំណាយប្រាក់ប្រដាប់ក្តីចំនួនប៉ុន្មានចំពោះបណ្តឹងនោះ នៅគ្រប់ ៣ ថ្នាក់នៃការជំនុំជម្រះក្តី（អាចមានករណីដូចជា ប្រសិនបើដើមចោទបានប្តូរលំនៅឋានទៅក្រៅប្រទេស ពេលកំពុងចាត់ការបណ្តឹងឧទ្ធរណ៍ ការគណនាប្រាតិភោគនេះគិតត្រឹមការជំនុំជម្រះនៅ ២ ថ្នាក់តែប៉ុណ្ណោះ គឺការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ និង បណ្តឹងសាទុក្ខ）។

តាមការចែងក្នុងអនុសញ្ញាស្តីពីនីតិវិធីរដ្ឋប្បវេណីនៃឆ្នាំ 1954（Convention on Civil Procedure, Hague, 1954）មាត្រា 17 ប្រសិនបើដើមចោទជាប្រជាជននៃប្រទេសណាមួយដែលបានចុះអនុសញ្ញា ហើយមានលំនៅឋាននៅប្រទេសណាមួយដែលបានចុះអនុសញ្ញានោះ មិនមានកាតព្វកិច្ចដាក់ប្រាតិភោគលើប្រាក់ប្រដាប់ក្តីទេ ។

<u>Code of Civil Procedure (Japan)</u>
**Article 75** (Order to offer security)
1. In cases where a plaintiff does not have a domicile, office or place of business in Japan, the court shall, upon motion by a defendant, by ruling, order such plaintiff to provide security for court costs. The same shall apply to cases where such security has become inadequate.
2. The provisions of the preceding paragraph shall not apply in cases where there is no dispute regarding a part of a claim of monetary payment and the amount thereof constitutes sufficient security.
3. In cases where the defendant has proceeded orally or made statements in the preparations for argument proceedings upon the merits of the suit after such defendant knew that there are reasons for which security should be provided, such defendant may not make a motion referred to in paragraph 1.
4. A defendant who has made a motion referred to in paragraph 1 may refuse to respond until the plaintiff provides such security.
5. In the ruling under the provisions of paragraph 1, the court shall fix the amount of such security and the period within which such security should be provided.
6. The amount of such security shall be fixed on the basis of the total amount of court costs the defendant will incur in all instances.
7. An immediate *kokoku*-appeal may be made against a ruling regarding the motion referred to in paragraph 1.

<u>Convention relative a la procédure civile, 1954</u>
**Article 17**
Aucune caution ni dépôt, sous quelque dénomination que ce soit, ne peut être imposé à raison, soit de leur qualité d'étrangers, soit du

défaut de domicile ou de résidence dans le pays, auz nationauz d'un destats contractants, ayant leur domicile dans l'un de ces Etats, qui seront demanteurss ou intervenants devant les tribunaux d'un autre de ces Etats.
La même règle s'applique au versement, qui serait exigé des demandeurs ou intervenants, pour garantir les frais judiciares.
Les Conventions. par lesquelles des Etats contractants auraient stipulé pour leurs ressortissants la dispense de la caution *judicatum solvi* ou du versement des frais judiciares sans condition de domicile, continueront à s'appliquer.

**មាត្រា ៦៨.-** អានុភាពនៃការមិនដាក់ប្រាតិភោគ

ប្រសិនបើដើមចោទ មិនបានដាក់ប្រាតិភោគ ក្នុងអំឡុងពេលដែលត្រូវដាក់នោះទេ តុលាការអាចលើកចោលនូវបណ្តឹងដោយសាលក្រម ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់បាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលប្រាតិភោគត្រូវបានដាក់មុនពេលចេញសាលក្រម ។

(កំណត់)

មាត្រានេះត្រូវនឹងមាត្រា 78 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ "អំឡុងពេលដែលត្រូវដាក់ប្រាតិភោគ" ត្រូវបានកំណត់ តាមកថាខណ្ឌទី ៤ នៃមាត្រា ៦៧ (ដីកាសម្រេចបង្គាប់ឱ្យដាក់ប្រាតិភោគ) ខាងលើនេះ ។ ការមិនដាក់ប្រាតិភោគ គឺជាចំណុចមួយដែលអាចវិនិច្ឆ័យដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់បាន ហេតុដូច្នេះហើយ អាចលើកចោលបណ្តឹងបាន ដោយទុកជាករណីលើកលែងនៃគោលការណ៍ចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១១៤ (ភាពចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់)) ។

Code of Civil Procedure (Japan)
**Article 78** (Effect of failure to provide security)
In cases where a plaintiff fails to provide security within the required period, the court may dismiss the suit by judgment without proceeding to oral argument. However, this shall not apply to cases where security has been provided prior to rendering such judgment.

## ផ្នែកទី ៤ ជំនួយសង្គ្រោះលើបណ្តឹង

**មាត្រា ៦៩.-** ការផ្តល់ជំនួយសង្គ្រោះលើបណ្តឹង

១- ចំពោះបុគ្គលដែលគ្មានលទ្ធភាពទ្រព្យធននឹងបង់ប្រាក់ដែលចាំបាច់ដើម្បីរៀបចំ និង ប្រព្រឹត្តទៅនីតិវិធីបណ្តឹង ឬ បុគ្គលដែលអាចមានការលំបាកយ៉ាងខ្លាំងក្នុងការទ្រទ្រង់ជីវភាព ដោយសារការបង់ប្រាក់នេះ តុលាការអាចចេញដីកាសម្រេចឱ្យជួយសង្គ្រោះលើបណ្តឹង តាមពាក្យសុំ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលច្បាស់ជាគ្មានលទ្ធភាពនឹងឈ្នះក្តីសោះ ។

២- ដីកាសម្រេចឱ្យជួយសង្គ្រោះនេះ ត្រូវធ្វើឡើងតាមថ្នាក់នៃការជំនុំជម្រះនីមួយៗ ។

៣- ចំពោះហេតុនៃការផ្តល់ជំនួយសង្គ្រោះលើបណ្តឹង ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង ។

(កំណត់)

មាត្រានេះមានការទាក់ទងនឹងមាត្រា 82 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន និង មាត្រា 30 នៃបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

ជាគោលការណ៍ នៅពេលដាក់ពាក្យបណ្តឹងទាមទារណាមួយ ឬ ដាក់ពាក្យសុំឱ្យតុលាការធ្វើសកម្មភាព នៅក្នុងនីតិវិធីនៃបណ្តឹងរដ្ឋប្បវេណី អ្នកប្តឹង ឬ អ្នកសុំត្រូវបង់ពន្ធនៃការដាក់ពាក្យសុំ ឬ បង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ (ប្រាក់ប្រដាប់ក្តីតុលាការ) ។ ប៉ុន្តែ ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន និង ធានានូវសិទ្ធិពឹងពាក់តុលាការរបស់បុគ្គលដែលមានការលំបាកយ៉ាងខ្លាំងក្នុងការទ្រទ្រង់ជីវភាព ដោយសារការបង់ប្រាក់ នោះយើងបានបញ្ញត្តអំពីការជួយសង្គ្រោះលើបណ្តឹងដោយវិធីពីរយ៉ាងដូចមានចែងនៅក្នុងមាត្រា ៧០ នៃក្រមនេះ តាមពាក្យសុំរបស់អ្នកដែលពុំមានលទ្ធភាព ។

ក្នុងករណីនេះ រាល់ការចំណាយសម្រាប់សកម្មភាពនៃនីតិវិធីនៃបណ្តឹង ត្រូវជាបន្ទុករបស់រដ្ឋជាបណ្តោះអាសន្ន ប៉ុន្តែ ប្រាក់ប្រដាប់ក្តី តុលាការអាចយកបានមកវិញ នៅក្នុងករណីអ្នកប្តឹងឈ្នះក្តី ទាំងស្រុង ឬ មួយចំណែក ។ ផ្ទុយទៅវិញក្នុងករណីដែលអ្នកប្តឹងចាញ់ក្តីទាំងស្រុង នោះប្រាក់ប្រដាប់ក្តីពុំអាចយកបានឡើយ ដូចនេះ ទើបមាត្រានេះបញ្ញត្តមិនឱ្យមានការជួយសង្គ្រោះលើបណ្តឹងឡើយ នៅក្នុងករណីដែលច្បាស់ថាអ្នកប្តឹងគ្មានលទ្ធភាពនឹងឈ្នះក្តីសោះ ។

Code of Civil Procedure (Japan)
**Article 82** (Grant of Aid)
1. The court may, upon motion, render a ruling to grant aid in litigation for a person who does not possess the means to pay costs necessary for preparation and conduct of a suit, or who will incur extreme hardship in life by paying such costs. However, this shall be limited when it cannot be stated that there is no prospect of success in the suit.
2. Aid in litigation shall be granted in the court of each instance.

Rules of Civil Procedure (Japan)
**Article 30** (Preliminary showing as to cause for aid / The Code Article 82)
A preliminary showing shall be made as to cause for aid in litigation.

## មាត្រា ៧០.‐ ខ្លឹមសារនៃជំនួយសង្គ្រោះលើបណ្តឹង

១- ដីកាសម្រេចឱ្យជួយសង្គ្រោះលើបណ្តឹង ត្រូវមានអានុភាពទៅតាមការកំណត់ក្នុងដីកាសម្រេចដូចខាងក្រោមនេះ :

**ក**- ការពន្យារពេលបង់ប្រាក់ប្រដាប់ក្តីតុលាការ ។

**ខ**- ការអនុគ្រោះមិនបាច់ឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការ ។ ប៉ុន្តែ ការសម្រេចនេះ អាចធ្វើបានចំពោះតែករណីណាដែលតុលាការបានយល់ឃើញថាសមរម្យ ដោយគិតពិចារណាលើលទ្ធភាពទ្រព្យធនរបស់ភាគី ជាអាទិ៍ នៅក្រោយពេលដែលការពន្យារពេលនេះបានរលត់ ។

២- ដីកាសម្រេចឱ្យជួយសង្គ្រោះលើបណ្តឹងនេះ អាចមានអានុភាពទៅលើតែបុគ្គលដែលបានទទួលដីកានោះតែប៉ុណ្ណោះ ។

៣- ក្នុងករណីដែលបុគ្គលដែលបានទទួលដីកាសម្រេចឱ្យជួយសង្គ្រោះលើបណ្តឹង ត្រូវបានយល់ឃើញថា គ្មានល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងមាត្រា ៦៩ (ការផ្តល់ជំនួយសង្គ្រោះលើបណ្តឹង) ខាងលើនេះ ឬ បុគ្គលនោះបានបាត់បង់ល័ក្ខខ័ណ្ឌនោះ

តុលាការដែលមានសំណុំរឿង អាចលុបចោលដីកាសម្រេចឱ្យជួយសង្គ្រោះលើបណ្ដឹងនេះ ហើយបង្គាប់ឱ្យភាគីនោះបង់ប្រាក់ដែលតុលាការបានពន្យារ ឬ អនុគ្រោះមិនឱ្យបង់ នៅពេលណាក៏បាន តាមពាក្យសុំរបស់បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ដោយដីកាសម្រេច ។

៤- ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងមាត្រា ៦៩ (ការផ្ដល់ជំនួយសង្គ្រោះលើបណ្ដឹង) នៃក្រមនេះ និង មាត្រានេះ អាចប្ដឹងជំទាស់បាន ។

(កំណត់)

មាត្រានេះមានការទាក់ទងនឹងមាត្រា 83 កថាខណ្ឌទី ១ ចំណុចទី ១ និង កថាខណ្ឌទី ២ មាត្រា 84 និង មាត្រា 86 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ ចំណុច ២ នៃកថាខណ្ឌទី ២ មានន័យថា តាមបញ្ញត្តិនៃមាត្រា ៦៩ (ការផ្ដល់ជំនួយសង្គ្រោះលើបណ្ដឹង) កថាខណ្ឌទី ២ នៃផ្នែកនេះ ដីកាសម្រេចឱ្យជួយសង្គ្រោះលើបណ្ដឹង មានអានុភាពតាមថ្នាក់នៃការជំនុំជម្រះនីមួយៗ ហេតុដូច្នេះ ភាគីអាចត្រូវបានអនុគ្រោះមិនបាច់ឱ្យបង់ប្រាក់ប្រដាប់ក្ដីបាន លុះត្រាតែករណីដែលភាគីនោះនៅតែគ្មានលទ្ធភាពទ្រព្យធន នៅពេលបញ្ចប់រឿងក្ដីនៅថ្នាក់នៃការជំនុំជម្រះនោះ ។

Code of Civil Procedure (Japan)
**Article 83** (Effect, etc., of aid) (excerpt)
1. A ruling to grant aid in litigation shall have the following effects with regard to litigation and compulsory execution in accordance with the decision therein:
i. deferment of payment of costs to be paid to the court, execution officer's fees and other expenses necessary for execution of such execution officer's duties;
ii. deferment of payment of remuneration or expenses of a lawyer whom the court has ordered to assist the party;
iii. exemption from the duty to provide security for court costs.
2. A ruling to grant aid in litigation shall be effective only for the benefit of the person who has obtained it.
**Article 84** (Cancellation of ruling to grant aid)
In cases where a person who has obtained a ruling to grant aid in litigation has been found not to have qualification under the main clause of the provision of Article 82, paragraph 1, or has lost such qualification, the court which possesses the record of the case may, upon motion of an interested person or upon its own authority, by ruling, at any time, cancel such ruling to grant aid in litigation and order the person who has obtained such aid to pay the costs deferred.
**Article 86** (Immediate *kokoku*-appeal)
An immediate *kokoku*-appeal may be made against such rulings as provided for in this section.

## ជំពូកទី ៥ ប្រាតិភោគលើបណ្ដឹង

**មាត្រា ៧១.-** វិធីដាក់ប្រាតិភោគ និង ការប្ដូរប្រាតិភោគ

១- ការដាក់ប្រាតិភោគ ត្រូវធ្វើតាមវិធីតម្កល់ជាប្រាក់ ឬ ជាឧបករណ៍អាចជួញដូរបានដែលតុលាការទទួលស្គាល់ថាសមរម្យ នៅកន្លែងតម្កល់ ឬ វិធីផ្ញើប្រាក់ ឬ ឧបករណ៍អាចជួញដូរបានដែលតុលាការទទួលស្គាល់ថាសមរម្យ នៅតុលាការ ឬ វិធីដែលបានកំណត់ផ្សេង ។

២- តុលាការអាចបង្គាប់ឱ្យប្ដូរប្រាតិភោគ តាមពាក្យសុំរបស់អ្នកដែលបានដាក់ប្រាតិភោគនោះដោយដីកាសម្រេចបាន ។

ប៉ុន្តែ បញ្ញត្តិនេះមិនបិទសិទ្ធិរបស់ភាគី ក្នុងការប្តូរប្រាតិភោគនោះ ទៅប្រាតិភោគផ្សេងទៀត តាមកិច្ចសន្យាឡើយ ។

(កំណត់)

"ប្រាតិភោគលើបណ្តឹង" ត្រូវអនុវត្តចំពោះករណីដូចតទៅ :

- ប្រាតិភោគលើប្រាក់ប្រដាប់ក្តី (គន្ថីទី ១ ជំពូកទី ៤ ផ្នែកទី ៣ "ប្រាតិភោគលើប្រាក់ប្រដាប់ក្តី")
- ប្រាតិភោគដែលម្ចាស់បំណុលបានដាក់ ដើម្បីអនុវត្តសាលក្រមជាបណ្តោះអាសន្ន (មាត្រា ១៩៦ (ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន) កថាខណ្ឌទី ១)
- ប្រាតិភោគដែលកូនបំណុលបានដាក់ ដើម្បីរួចខ្លួនពីការអនុវត្តសាលក្រមជាបណ្តោះអាសន្ន (មាត្រា ១៩៦ (ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន) កថាខណ្ឌទី ២)
- ការផ្អាកការអនុវត្តសាលក្រមដោយបង្ខំ ដោយសារមានបណ្តឹងទាស់ ចំពោះសាលក្រមកំបាំងមុខដែលបានភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន (ចំណុច ឃ កថាខណ្ឌទី ១ មាត្រា ៣៦៦ (ការសម្រេចសេចក្តីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹងជំនុំជម្រះសាជាថ្មី ជាអាទិ៍))
- ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ក្នុងសាលដីកានៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ (មាត្រា ២៨២ (ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នក្នុងសាលដីកានៃការជំនុជម្រះបណ្តឹងឧទ្ធរណ៍))
- ការផ្អាកការអនុវត្តដោយបង្ខំ ដោយសារមានការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ឬ ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី (ចំណុច ក និង ចំណុច ខ កថាខណ្ឌទី ២ នៃមាត្រា ៣៨៣ (បញ្ញត្តិពិសេសស្តីពីបណ្តឹងជំទាស់នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ))
- ប្រាតិភោគផ្សេងៗនៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ និង ការអនុវត្តសិទ្ធិប្រាតិភោគ (កថាខណ្ឌទី ២ នៃមាត្រា ៣៦១ (ល័ក្ខខ័ណ្ឌនៃការចាប់ផ្តើមអនុវត្តដែលស្ថាប័នអនុវត្តត្រូវស្រាវជ្រាវ) វាក្យខណ្ឌទី ១ កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ នៃមាត្រា ៣៦៦ (ការសម្រេចសេចក្តីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹងជំនុំជម្រះសាជាថ្មី ជាអាទិ៍) កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ នៃមាត្រា ៣៦៧ (ការសម្រេចសេចក្តីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍) មាត្រា ៣៦៩ (ការសម្រេចសេចក្តីផ្អាកការអនុវត្តដោយការដាក់ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត ជាអាទិ៍) ចំណុច ច កថាខណ្ឌទី ១ នៃមាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) មាត្រា ៣៧៧ (ការដាក់ប្រាតិភោគ) កថាខណ្ឌទី ៣ នៃមាត្រា ៣៨១ (ការប្តូរទំហំនៃចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស) កថាខណ្ឌទី ៣ នៃមាត្រា ៣៨៣ (ការផ្លាស់ប្តូរទំហំនៃសិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស)) កថាខណ្ឌទី ១ នៃមាត្រា ៤២៩ (ការចាត់ចែងការរក្សាការពារ))
- ប្រាតិភោគផ្សេងៗនៅក្នុងនីតិវិធីរក្សាការពារជាបណ្តោះអាសន្ន (មាត្រា ៥៣៦ (ការផ្តល់នូវប្រាតិភោគ) មាត្រា ៥៤២ (ប្រាតិភោគសម្រាប់ដីកាសម្រេចរក្សាការពារ) កថាខណ្ឌទី ១ នៃមាត្រា ៥៥១ (ការសម្រេចសេចក្តី

អំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) កថាខណ្ឌទី ២ នៃមាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) កថាខណ្ឌទី ១ នៃមាត្រា ៥៥៩ (ការលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដោយសារស្ថានភាពពិសេស))

កថាខណ្ឌទី ១ ត្រូវនឹងក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 76 រីឯកថាខណ្ឌទី ២ ត្រូវនឹងក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 80 ។

កថាខណ្ឌទី ១ ចែងអំពីវិធីដាក់ប្រាតិភោគ ២ ដែលមានដូចតទៅ :

(1) ការតម្កល់ (*fr.* consignation) ឬ ការផ្ញើ (*fr.* dépôt)

នេះគឺជារបបមួយ ដែលអ្នកមានករណីយកិច្ចដាក់ប្រាតិភោគ ដាក់លុយ ឬ ឧបករណ៍អាចជួញដូរបាន (*eng.* valuable instruments, *fr.* valeurs mobilières) ដូចជាប័ណ្ណបំណុលជាតិ ជាដើម តម្កល់ទុកនៅកន្លែងតម្កល់ ហើយអ្នកមានសិទ្ធិលើប្រាតិភោគនោះ (ចំពោះនិយមន័យនៃ "អ្នកមានសិទ្ធិលើប្រាតិភោគ" សូមមើលមាត្រា ៧៣ (ការលុបចោលនូវប្រាតិភោគ)) មានសិទ្ធិទាមទារយកវត្ថុដែលតម្កល់ទុកនោះបាន ។ នេះជារបបមួយ ដូចការតម្កល់ ក្នុងរបបតម្កល់ដើម្បីសង នៅក្នុងក្រមរដ្ឋប្បវេណីដែរ ។ កន្លែងតម្កល់នេះ ត្រូវសម្រេចទៅតាមស្ថានភាពនៃប្រទេសកម្ពុជា (ឧទាហរណ៍ : កន្លែងតម្កល់ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់តុលាការដែលបង្គាប់ឱ្យតម្កល់ប្រាតិភោគនោះ) ។ ចំពោះខ្លឹមសារនៃសិទ្ធិរបស់អ្នកមានសិទ្ធិលើប្រាតិភោគនោះ មានចែងក្នុងមាត្រា ៧២ (សិទ្ធិរបស់អ្នកដែលទទួលការផ្តល់ប្រាតិភោគ) ខាងក្រោមនេះ ។ ប្រសិនបើប្រទេសកម្ពុជាមិនទាន់មានគម្រោងបង្កើតកន្លែងតម្កល់ទេ ប្រាតិភោគនោះត្រូវផ្ញើនៅតុលាការ ។

(2) វិធីដែលបានកំណត់ផ្សេង

សូមបញ្ជាក់ថា នៅប្រទេសជប៉ុន មានចែងអំពីវិធីធ្វើកិច្ចសន្យាអាណត្តិធានាបង់ ជាមួយនឹងស្ថាប័នហិរញ្ញវត្ថុ (ធនាគារ ក្រុមហ៊ុនធានារ៉ាប់រង ជាដើម) (បទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណី មាត្រា 29 កថាខណ្ឌទី 1) ។

កថាខណ្ឌទី ២ គឺជាបញ្ញត្តិសម្រាប់ករណីដូចជា : ដោយសារឧបករណ៍អាចជួញដូរបាន (*eng.* valuable instruments, *fr.* valeurs mobilières) ដែលបានតំកល់នោះឡើងថ្លៃ ហើយដើម្បីប្តូរជាទឹកប្រាក់វិញ គេយកឧបករណ៍អាចជួញដូរបានផ្សេង ឬ យកប្រាក់ទៅតម្កល់ទុកជំនួសបាន ។

Code of Civil Procedure (Japan)
**Article 76** (Means of providing security)
Security shall be provided by depositing money or such negotiable securities as the court deems proper at the official depository in the jurisdiction of the district court governing the place where the court which has ordered the security to be provided is located, or by means provided for by the Rules of the Supreme Court*. However, if the parties have entered into a contract which provides otherwise, such contract shall govern.
[*Rules of Civil Procedure §29 prescribes such means as entering into a contract of payment bond fulfilling certain conditions with a bank, insurance company, etc., with the permission of the court.]
**Article 80** (Substitution of security)
The court may, upon motion of the person who provided security, by ruling, order the substitution of another item for such security. However, this shall not preclude the substitution by contract of another item for the item previously provided for security.

Rules of Civil Procedure (Japan)
**Article 29** (Means of providing security prescribed by the Rules of the Supreme Court referred to in the Code Article 76) (excerpt)
1. Security under the provisions of Article 76 (Means of providing security) of the Code may, with the permission of the court, be provided by the person who has been ordered to provide the security entering into a contract of payment bond fulfilling the following conditions with a bank, an insurance company, the Norin Chukin Bank, the Shoko Chukin Bank, a nationwide federation of credit unions, a credit union, or a workers' credit union (hereinafter in Article 29 : "a bank, etc."):
i) the bank, etc., shall, on behalf of the person who has been ordered to provide the security, within the limit designated by the court, pay the person who is entitled to such security the amount of money indicated in the obligation title which relates to the right of recourse of court costs for which the security is to be provided or in things which confirm the existence of such right of recourse of court costs and have the same effect as a final and biding judgment;
ii) the contract shall lose effect when a ruling canceling the security has become final and binding;
iii) the contract shall not otherwise be changed or canceled;
iv) in cases where the person who is entitled to the security so requests, the bank, etc. shall deliver the person a document which certified that the contract has been entered into.

## មាត្រា ៧២.- សិទ្ធិរបស់អ្នកដែលទទួលការផ្ដល់ប្រាតិភោគ

បុគ្គលដែលទទួលការផ្ដល់ប្រាតិភោគដើម្បីជាផលប្រយោជន៍របស់ខ្លួន មានសិទ្ធិជាអាទិភាពទៅលើម្ចាស់បំណុលផ្សេងទៀត ក្នុងការទទួលការសងចំពោះប្រាក់ ឬ ឧបករណ៍អាចជួញដូរបានដែលត្រូវបានតម្កល់ ឬ ផ្ញើ តាមបញ្ញត្តិនៃមាត្រា ៧១ (វិធីដាក់ប្រាតិភោគ និង ការប្ដូរប្រាតិភោគ) ខាងលើនេះ ដើម្បីសងចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានា ។

(កំណត់)

មាត្រានេះ ត្រូវនឹងមាត្រា 77 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ មាត្រានេះចែងថា ក្នុងករណីដែលសិទ្ធិលើបំណុលបានកើតឡើង ចំពោះអ្នកមានសិទ្ធិលើប្រាតិភោគ អ្នកនោះអាចទទួលការសងដោយមានអាទិភាព ចំពោះសិទ្ធិលើបំណុលរបស់ខ្លួនបាន ដោយទទួលវត្ថុដែលត្រូវបានតម្កល់ ឬ ផ្ញើវិញ ។ "ករណីដែលសិទ្ធិលើបំណុលបានកើតឡើង ចំពោះអ្នកមានសិទ្ធិលើប្រាតិភោគធានា" មានឧទាហរណ៍ដូចជា :

- ក្រោយពេលដែលចុងចម្លើយបានបង់ប្រាក់ប្រដាប់ក្ដីរួចហើយ ហើយខ្លួនបានឈ្នះក្ដីនោះ សិទ្ធិទទួលប្រាក់ប្រដាប់ក្ដីនោះ ត្រូវកើតឡើងចំពោះចុងចម្លើយនោះវិញ
- ពេលដែលសាលក្រមដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្នបានចូលជាស្ថាពរ ហើយការខូចខាតបានកើតឡើងដោយសារការអនុវត្តជាបណ្ដោះអាសន្ននោះ សិទ្ធិទាមទារសំណងការខូចខាតនោះ ត្រូវកើតឡើង ។

Code of Civil Procedure (Japan)
**Article 77** (Defendant's right to security)
With respect to court costs, the defendant shall have the right to obtain satisfaction in preference to other obligees out of the money or securities deposited under the provisions of the preceding article.

## មាត្រា ៧៣.- ការលុបចោលនូវប្រាតិភោគ

១- អ្នកមានសិទ្ធិលើប្រាតិភោគ ក្នុងមាត្រានេះ សំដៅទៅលើបុគ្គលដែលទទួលការផ្ដល់ប្រាតិភោគ ដើម្បីជាផលប្រយោជន៍របស់ខ្លួន ។

២- ប្រសិនបើអ្នកដែលបានដាក់ប្រាតិភោគ បានបញ្ជាក់នូវការរលត់នៃហេតុដែលត្រូវដាក់ប្រាតិភោគ តុលាការត្រូវចេញដីកាសម្រេចលុបចោលនូវប្រាតិភោគនោះ តាមពាក្យសុំ ។
៣- បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នា ចំពោះករណីអ្នកដែលបានដាក់ប្រាតិភោគ បានបញ្ជាក់ថា ខ្លួនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិលើប្រាតិភោគអំពីការលុបចោលប្រាតិភោគនោះ ។
៤- ក្រោយពីហេតុដែលអ្នកមានសិទ្ធិលើប្រាតិភោគអាចប្រើសិទ្ធិរបស់ខ្លួននោះ បានកើតមានឡើង ប្រសិនបើតុលាការជូនដំណឹងឱ្យអ្នកមានសិទ្ធិលើប្រាតិភោគថា ខ្លួនត្រូវប្រើសិទ្ធិរបស់ខ្លួននោះក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ តាមពាក្យសុំរបស់អ្នកដែលបានដាក់ប្រាតិភោគ តែអ្នកមានសិទ្ធិលើប្រាតិភោគនោះមិនបានប្រើសិទ្ធិរបស់ខ្លួនទេ អ្នកមានសិទ្ធិលើប្រាតិភោគនោះ ត្រូវបានចាត់ទុកថា បានយល់ព្រមចំពោះការលុបចោលនូវប្រាតិភោគនោះ ។
៥- ចំពោះដីកាសម្រេច ដែលបានកំណត់នៅកថាខណ្ឌទី ២ និង ទី ៣ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

(កំណត់)

មាត្រានេះត្រូវនឹងមាត្រា 79 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ មាត្រានេះចែងថា អ្នកដែលបានដាក់ប្រាតិភោគនោះ (បើគិតជាបណ្ដឹងវិញ គឺដើមចោទ) អាចទាមទារឱ្យលុបចោលនូវប្រាតិភោគនោះ ដោយខ្លួនឯងបាន ក្នុងករណីទាំង ៣ ខាងក្រោមនេះ :

(1) ការរលត់នៃហេតុដែលត្រូវដាក់ប្រាតិភោគ

មានន័យថា ភាពចាំបាច់ដែលតម្រូវឱ្យដាក់ប្រាតិភោគពីដំបូង បានរលត់ ។ ឧទាហរណ៍ :

- ចំពោះប្រាក់ប្រដាប់ក្ដី គឺករណីដែលដើមចោទមានលំនៅឋាននៅក្នុងប្រទេសកម្ពុជា ឬ មានទីកន្លែងអាជីវកម្មនៅកម្ពុជា ឬ ក៏ករណីដែលដើមចោទបានឈ្នះក្ដីទាំងស្រុង ហើយសេចក្ដីសម្រេចដែលកំណត់ថាចុងចម្លើយគ្មានសិទ្ធិទាមទារយកប្រាក់ប្រដាប់ក្ដីវិញ បានចូលជាស្ថាពរ ។
- ចំពោះប្រាតិភោគដើម្បីធ្វើការអនុវត្តជាបណ្ដោះអាសន្ន (មាត្រា ១៩៦ (ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន) កថាខណ្ឌទី ១) គឺករណីដែលសាលក្រមដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ននោះ បានចូលជាស្ថាពរហើយ ។
- ចំពោះប្រាតិភោគដែលកូនបំណុលបានដាក់ដើម្បីរួចខ្លួនពីការអនុវត្តជាបណ្ដោះអាសន្ន (មាត្រា ១៩៦ (ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន) កថាខណ្ឌទី ២) គឺករណីដែលការលុបចោលសាលក្រមដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ននោះ បានចូលជាស្ថាពរ ។

(2) ការយល់ព្រមពីអ្នកមានសិទ្ធិលើប្រាតិភោគ

ប្រសិនបើអ្នកមានសិទ្ធិលើប្រាតិភោគ យល់ព្រមឱ្យលុបចោលនូវប្រាតិភោគនោះ ប្រាតិភោគនោះមិនចាំបាច់ឱ្យបន្តមានទៀត ហេតុនេះហើយត្រូវលុបចោល ។

（3）ការចាត់ទុកថាអ្នកមានសិទ្ធិលើប្រាតិភោគបានយល់ព្រម

នេះជាបញ្ញត្តិដើម្បីដោះស្រាយស្ថានភាពមិនទៀងទាត់ ដូចជាសិទ្ធិលើបំណុលដែលត្រូវបានធានាបានកើតឡើងហើយ តែអ្នកមានសិទ្ធិលើប្រាតិភោគមិនដឹងថាពេលណាសិទ្ធិលើបំណុលនោះត្រូវបានអនុវត្ត ។ ពាក្យ "ប្រើសិទ្ធិ" មានន័យជាជាក់ស្តែងថា ចំពោះប្រាក់ប្រដាប់ក្តី គឺនីតិវិធីដើម្បីកំណត់ជាស្ថាពរនូវចំនួនប្រាក់ប្រដាប់ក្តី（មាត្រា ៦៦（នីតិវិធីដើម្បីកំណត់ជាស្ថាពរនូវចំនួនប្រាក់ប្រដាប់ក្តី）） ហើយចំពោះប្រាតិភោគដើម្បីអនុវត្តជាបណ្តោះអាសន្នវិញ គឺការដាក់ពាក្យបណ្តឹងទាមទារសំណងនៃការខូចខាតដែលបានទទួលដោយសារការអនុវត្តជាបណ្តោះអាសន្ននោះ ។

<u>Code of Civil Procedure (Japan)</u>
**Article 79** (Cancellation of security)
1, In cases where a person who provided security proves that the reason for such security as ceased to exist, the court shall, upon motion, render a ruling canceling such security.
2. The preceding paragraph shall also apply to cases where a person who provided security proves, with regard to the cancellation of such security, receipt of the consent of the person who is entitled to such security.
3. In cases where the court, following termination of the suit and upon motion of the person who provided security, calls upon the person who is entitled to the security to exercise such right within a designated period, and such person fails to carry out such exercise, the person entitled to the security shall be deemed to have consented to the cancellation of the security.
4. An immediate *kokoku*-appeal may be made against a ruling under the provisions of paragraphs 1 and 2.

# គន្ថីទី ២ នីតិវិធីនៃការជម្រះក្តីលើកទី ១

## ជំពូកទី ១ បណ្តឹង

**មាត្រា ៧៤.-** ផលប្រយោជន៍នៃបណ្តឹង

បណ្តឹងអាចធ្វើឡើងបាន ក្នុងករណីដែលបណ្តឹងនោះមានកម្មវត្ថុជាវិវាទតាមផ្លូវច្បាប់ជាក់ស្តែង និង ដែលវិវាទនោះអាចដោះស្រាយដោយសាលក្រម ។

(កំណត់)

ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន គ្មានមាត្រាណាដែលចែងឱ្យបានច្បាស់លាស់អំពីចំណុចនេះ ដូចមាត្រានេះទេ ។

ជាគោលការណ៍ បណ្តឹងរដ្ឋប្បវេណីមានគោលបំណងឱ្យតុលាការដោះស្រាយវិវាទផ្នែករដ្ឋប្បវេណីដោយផ្អែកលើច្បាប់ ដូចនេះ ដើម្បីឱ្យតុលាការអាចដោះស្រាយតាមគោលបំណងនេះបាន លុះត្រាតែការប្តឹងទាមទារនោះមានកម្មវត្ថុជាវិវាទទាក់ទងនឹងសិទ្ធិរបស់បុគ្គលឯកជន ។ ការចែងមាត្រានេះឡើង ដោយសារមានវិវាទខ្លះដែលមិនអាចដោះស្រាយដោយសាលក្រម ហើយមានកម្មវត្ថុ មិនមែនជាវិវាទតាមផ្លូវច្បាប់ជាក់ស្តែង ដូចជា វិវាទអំពីការបកស្រាយទ្រឹស្តីណាមួយ វិវាទអំពីអត្ថិភាពនៃព្រះអាទិទេព ជាដើម ។

**មាត្រា ៧៥.-** របៀបដាក់ពាក្យបណ្តឹង និង ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង

១- ការប្តឹង ត្រូវធ្វើដោយដាក់ពាក្យបណ្តឹងជាលាយល័ក្ខណ៍អក្សរ ទៅតុលាការ ។

២- នៅក្នុងលិខិតនៃពាក្យបណ្តឹង ត្រូវសរសេរបញ្ជាក់នូវចំណុចខាងក្រោមនេះ :

- **ក-** ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។
- **ខ-** ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និង អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ។

៣- នៅក្នុងពាក្យបណ្តឹង ក្រៅពីចំណុចដែលបានកំណត់នៅក្នុងចំណុច **ខ** នៃកថាខណ្ឌទី ២ ខាងលើនេះ ដើមចោទគប្បីសរសេរបញ្ជាក់ឱ្យច្បាស់លាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង តាមចំណុចដែលត្រូវការបញ្ជាក់ភស្តុតាង គប្បីសរសេរបញ្ជាក់នូវអង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង ភស្តុតាង ។

៤- ពាក្យបណ្ដឹងដែលមានសរសេរអំពីមធ្យោបាយតទល់ ឬ ការពារខ្លួន ត្រូវចាត់ជាឯកសារត្រៀមផងដែរ ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន មាត្រា 133 និង បទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន មាត្រា 53 ។

កថាខណ្ឌទី ១ ទាមទារឱ្យភាគីប្ដឹង ដោយដាក់ពាក្យបណ្ដឹងជាលាយល័ក្ខណ៍អក្សរ ដោយហេតុថា នីតិវិធីនៃបណ្ដឹងទាមទារឱ្យមានភាពច្បាស់លាស់ ។

កថាខណ្ឌទី ២ កំណត់ពីទម្រង់នៃបណ្ដឹងដែលតម្រូវឱ្យរាល់បណ្ដឹងរដ្ឋប្បវេណីត្រូវតែគោរពទៅតាមការកំណត់នៃមាត្រានេះជាដាច់ខាត ។ ហេតុដូចនេះហើយបានជាមានមាត្រាក្រោយៗ បានចែងតម្រូវឱ្យអ្នកប្ដឹង ធ្វើការកែតម្រូវបើតុលាការពិនិត្យឃើញថា ពាក្យបណ្ដឹងនោះមានភាពខុសឆ្គង ឬ ខ្វះចន្លោះ ។ បើអ្នកសរសេរពាក្យបណ្ដឹងបានគោរពតាមមាត្រានេះ គឺក្នុងន័យថា មានអត្ថប្រយោជន៍ច្រើនដល់សកម្មភាពបណ្ដឹង ឬ ដល់ចំណាត់ការរបស់តុលាការ ព្រោះថាបើមានភាពច្បាស់លាស់នៃចំណុចទាមទារ និង ភាពច្បាស់លាស់នៃអង្គហេតុនោះ គឺជាការមួយធ្វើឱ្យតុលាការដែលទទួលពាក្យបណ្ដឹងនោះ មានភាពងាយស្រួលនៅក្នុងការពិនិត្យពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការទាមទារមុនពេលតុលាការចាប់ផ្ដើមចាត់ការលើបណ្ដឹងនោះ ហើយម្យ៉ាងទៀតក៏ជាការធ្វើឱ្យភាគីម្ខាងទៀតនៃបណ្ដឹង ងាយយល់ពីការទាមទារ និង អាចឆ្លើយតបចំពោះការទាមទារនោះ ។

Code of Civil Procedure (Japan)
**Article 133** (Method of filing suit)
1. A suit shall be filed by submitting a written complaint to the court.
2. A written complaint shall include the following matters:
the parties and their legal representatives;
the import and the grounds of the claim.

Rules of Civil Procedure (Japan)
**Article 53** (Matters to be included in written complaint / The Code Article 133)
1. A written complaint shall include, in addition to the import of the claim and the grounds of the claim (this means facts which are necessary for identifying the claim), the concrete facts which form the basis of the claim, and, corresponding to every fact to be proved, important facts which are relevant to such facts and evidence.
2. When stating allegations relating to facts in a written complaint, to whatever extent possible, allegations relating to facts which form the basis of the claim and allegations relating to facts which are relevant to such facts shall be distinguished.
3. A written complaint which includes offensive or defensive measures shall double as a preliminary document.
4. A written complaint shall include, in addition to the maters referred to in paragraph 1, the zip code and the telephone number (including the facsimile number) of the plaintiff or the advocate thereof.

**មាត្រា ៧៦.-** បណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិកនៅពេលអនាគត

បណ្ដឹងទាមទារការផ្ដល់តាវកាលិកនៅពេលអនាគត អាចធ្វើឡើងបាន លុះត្រាតែមានភាពចាំបាច់តម្រូវឱ្យធ្វើការទាមទារនោះជាមុន ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន មាត្រា 135 ។

Code of Civil Procedure (Japan)
**Article 135** (Suit for future performance)
A suit demanding future performance may be filed only where it is necessary to make such a demand in advance.

**មាត្រា ៧៧.-** ការបញ្ចូលការទាមទារច្រើនចំណុចទៅក្នុងបណ្តឹងតែមួយ

ការទាមទារច្រើនចំណុច អាចយកមកបញ្ចូលក្នុងបណ្តឹងតែមួយបាន លុះត្រាតែបណ្តឹងនោះដោះស្រាយដោយនីតិវិធីប្រភេទដូចគ្នា ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន មាត្រា 136 ។

បើមានការទាមទារច្រើនចំណុចខុសគ្នា តែបើការទាមទារនោះត្រូវយកទៅដោះស្រាយតាមនីតិវិធីប្រភេទដូចគ្នា នោះអាចបញ្ចូលទៅក្នុងបណ្តឹងតែមួយបាន ។ "នីតិវិធីប្រភេទដូចគ្នា" ដែលបានកំណត់នៅក្នុងមាត្រានេះ មិនមែនតែសំដៅលើន័យថា តាមនីតិវិធីរដ្ឋប្បវេណីដូចគ្នាទេ ។ ឧទាហរណ៍ៈ បណ្តឹងទាក់ទងនឹងទ្រព្យសម្បត្តិ គឺជាបណ្តឹងរដ្ឋប្បវេណី ហើយបណ្តឹងទាមទារលែងលះ ក៏បណ្តឹងរដ្ឋប្បវេណីដែរ ប៉ុន្តែ បណ្តឹងទាំងពីរនេះ មិនអាចបញ្ចូលគ្នាបានទេ ។

ចំពោះការទាមទារលែងលះ ការទាមទារបែងចែកទ្រព្យសម្បត្តិ និង ការទាមទារសិទ្ធិអំណាចមេបាលើកូន តុលាការអាចធ្វើការសម្រេចសេចក្តី តាមនីតិវិធីដូចគ្នាបាន ហេតុដូច្នេះ ការទាមទារទាំងនោះ អាចបញ្ចូលគ្នាបាន ។

Code of Civil Procedure (Japan)
**Article 136** (Consolidation of claims)
Several claims may be consolidated in one suit to the extent that the same type of litigation proceedings are applicable to such claims.

**មាត្រា ៧៨.-** ការពិនិត្យពាក្យបណ្តឹង

១- ក្នុងករណីដែលពាក្យបណ្តឹងផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៧៥ (របៀបដាក់ពាក្យបណ្តឹង និង ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង) ខាងលើនេះ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឱ្យកែតម្រូវចំណុចខ្វះចំពោះពាក្យបណ្តឹងនោះ ក្នុងអំឡុងពេលនោះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលពន្ធសម្រាប់ដាក់ពាក្យបណ្តឹង មិនត្រូវបានបង់តាមបញ្ញត្តិនៃមាត្រា ៦១ (ពន្ធដាក់ពាក្យសុំ) នៃក្រមនេះ ។

២- ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើដើមចោទមិនបានកែតម្រូវចំណុចខ្វះទេ តុលាការត្រូវលើកពាក្យបណ្តឹងចោល ដោយដីកាសម្រេច ។

៣- ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

(កំណត់)

មាត្រានេះ មានអត្ថន័យដូចគ្នានឹងក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន មាត្រា 137 ។

នៅពេលទទួលបណ្តឹង ជាបឋម តុលាការត្រូវពិនិត្យលើទម្រង់នៃពាក្យបណ្តឹង ហើយបើឃើញថា មានភាពខ្វះចន្លោះផ្នែកទម្រង់ ឬ ភាពខុសឆ្គងនៃការបង់ពន្ធនៃការដាក់ពាក្យសុំ នោះតុលាការត្រូវបង្គាប់ឱ្យអ្នកធ្វើបណ្តឹង កែតម្រូវក្នុងអំឡុងពេលសមរម្យ ។ អំឡុងពេលសមរម្យ អាស្រ័យដោយឆន្ទានុសិទ្ធិរបស់តុលាការ ។

ការមិនកែតម្រូវ គឺជាមូលហេតុនៃការលើកបណ្តឹងចោលដោយដីកាសម្រេច ។

Code of Civil Procedure (Japan)
**Article 137** (Presiding judge's right to investigate written complaint)
1. In cases where a written complaint fails to fulfill the provisions of Article 133, paragraph 2, the presiding judge shall designate an appropriate period and order the correction of the defect within such period. The same shall apply to cases where the fee for filing the written complaint has not been paid as required in accordance with the provions of the Civil Procedure Costs Acts (Law No. 40, 1971).
2. In cases referred to in the preceding paragraph, if the plaintiff fails to correct the defect, the presiding judge shall dismiss the written compalint by order.
3. An immediate *kokoku*- appeal may be made againt the order referred to in the preceding paragraph.

**មាត្រា ៧៩.-** ការបញ្ជូនពាក្យបណ្តឹង

១- ពាក្យបណ្តឹងត្រូវបញ្ជូនទៅចុងចម្លើយជាចាំបាច់ ។

២- បញ្ញត្តិនៃមាត្រា ៧៨ (ការពិនិត្យពាក្យបណ្តឹង) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលពាក្យបណ្តឹងមិនអាចបញ្ជូនទៅបាន ។ បញ្ញត្តិនោះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលដើមចោទមិនបានបង់ប្រាក់សម្រាប់បញ្ជូនពាក្យបណ្តឹងទុកជាមុន ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន មាត្រា 138 ។

ពាក្យបណ្តឹងត្រូវបញ្ជូនទៅចុងចម្លើយជាចាំបាច់ ព្រោះការបញ្ជូននេះ គឺជាការឱ្យភាគីម្ខាងទៀតបានដឹងអំពីបណ្តឹងថាតើបុគ្គលណាជាអ្នកប្តឹង កម្មវត្ថុនៃបណ្តឹងជាអ្វី មធ្យោបាយតទល់របស់អ្នកប្តឹងនោះ ជាដើម ហើយជាការផ្តល់ឱកាសឱ្យភាគីម្ខាងទៀតនោះឆ្លើយដោះសារ និង រៀបចំមធ្យោបាយការពារខ្លួន ។ ពេលពាក្យបណ្តឹងត្រូវបានបញ្ជូនទៅដល់ចុងចម្លើយ ទើបបណ្តឹងនោះត្រូវបានចាត់ការ ។

ករណីដែលមិនអាចបញ្ជូនពាក្យបណ្តឹងបាន មានដូចជា ករណីដែលអាសយដ្ឋានរបស់ចុងចម្លើយ ដែលដើមចោទផ្តល់ឱ្យ មិនមានភាពច្បាស់លាស់ ករណីដែលចុងចម្លើយជាអសមត្ថជនដែលគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ ឬ ករណីដែលចុងចម្លើយជាជនបរទេសដែលមានអភ័យឯកសិទ្ធិ ហើយបដិសេធការទទួលការបញ្ជូនពាក្យបណ្តឹង ។

Code of Civil Procedure (Japan)

**Article 138** (Service of written complaint)
1. The written complaint shall be served on the defendant.
2. The provisions of the preceding article shall apply *mutatis mutandis* to cases where the written complaint cannot be served (including cases where the fee necessary for serving the written complaint has not been prepaid).

**មាត្រា ៨០.–** ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង
១- នៅពេលដែលពាក្យបណ្តឹងត្រូវបានដាក់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលយ៉ាងរហ័ស និង កោះហៅគូភាគី ។
២- កាលបរិច្ឆេទដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវកំណត់ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃបន្ទាប់ពីថ្ងៃដែលពាក្យបណ្តឹងត្រូវបានដាក់ លើកលែងតែក្នុងករណីដែលមានមូលហេតុពិសេស ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន មាត្រា 139 និង បទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 60 មានចែងដូចគ្នាជាមួយនឹងមាត្រានេះ អំពីការកំណត់កាលបរិច្ឆេទសម្រាប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។

នៅប្រទេសជប៉ុន ការទាញហេតុផលដោយផ្ទាល់មាត់ (oral argument, débat oral, Mündliche Verhandlung) ជាដំណាក់កាលសម្រាប់វិនិច្ឆ័យបណ្តឹង ។ ប្រសិនបើចុងចម្លើយមិនបានចូលមកនៅកាលបរិច្ឆេទនៃការទាញហេតុផលលើកទី ១ ដោយគ្មានមូលហេតុច្បាស់លាស់ ហើយមិនបានដាក់ឯកសារទៅតុលាការថាខ្លួនដោះសាចំពោះបណ្តឹងនោះទេ ច្បាប់ចាត់ទុកថា ចុងចម្លើយទទួលស្គាល់នូវការទាមទាររបស់ដើមចោទ (ការចាត់ទុកថាបានសារភាព) ហើយតុលាការនឹងចេញសាលក្រម ទៅតាមការចាត់ទុកនោះ ។ ក្នុងករណីដែលមានចំណុចវិវាទរវាងគូភាគី ហើយចាំបាច់ធ្វើការរៀបចំចំណុចវិវាទ តាមធម្មតា ការរៀបចំនោះនឹងធ្វើដោយនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។ តាមកិច្ចការជាក់ស្តែង នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ នឹងត្រូវបានធ្វើឡើងនៅកាលបរិច្ឆេទផ្សេង ក្រោយកាលបរិច្ឆេទនៃការទាញហេតុផលលើកទី ១ ។

ប៉ុន្តែ ដើម្បីរក្សានូវគោលគំនិតនៃនីតិវិធីរដ្ឋប្បវេណីដែលព្រះរាជាណាចក្រកម្ពុជាធ្លាប់អនុវត្តកន្លងមក ដោយបើកការទាញហេតុផល (សវនាការ) ក្រោយពីធ្វើនីតិវិធីស៊ើបសួរនោះ ក្រមនេះកំណត់ថា ជាដំបូង ត្រូវធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមុន ហើយប្រសិនបើត្រូវការរៀបចំចំណុចវិវាទ នោះត្រូវរៀបចំចំណុចវិវាទឱ្យហើយក្នុងនីតិវិធីត្រៀមនេះ ហើយបន្ទាប់មកនឹងបើកការទាញហេតុផលដោយល្អិតល្អន់ ។

ម្យ៉ាងទៀត មានបញ្ហាមួយគឺ តើគួរបញ្ចូលគោលការណ៍នៃការផ្សះផ្សាជាមុន នៅដំណាក់កាលណាមួយក្នុងនីតិវិធី ។ ដូចដែលមានចែងខាងក្រោយនេះ ក្រមនេះចែងថា តុលាការមានការទទួលខុសត្រូវក្នុងការសាកល្បងធ្វើការផ្សះផ្សាក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (គឺ ធ្វើពេលដំបូងក៏បាន ធ្វើនៅពាក់កណ្តាលទីក៏បាន ធ្វើពេលជិតចប់នីតិវិធីត្រៀមនេះក៏បាន) ។ មានន័យថា យើងខ្ញុំគោរពតាមគោលគំនិតនៃភាគីកម្ពុជា (សូមមើលមាត្រា ១០៤

（ការសាកល្បងផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល）） ។

ការកំណត់កាលបរិច្ឆេទលើកទី ១ ត្រូវធ្វើឡើងដោយគិតពិចារណាអំពីអំឡុងពេលដែលចុងចម្លើយត្រូវការ ដើម្បីត្រៀមការពារខ្លួន ដូចជាការជ្រើសតាំងមេធាវី ការរៀបចំឯកសារត្រៀមដែលចុងចម្លើយត្រូវដាក់លើកដំបូង ហើយយកទៅដាក់នៅតុលាការ ជាអាទិ៍ ។ ហើយប្រសិនបើយល់ឃើញថាចាំបាច់ តុលាការអាចកំណត់អំឡុងពេលនេះ វែងជាង ៣០ ថ្ងៃក៏បានដែរ ។

Code of Civil Procedure (Japan)
**Article 139** (Designation of the date for oral argument)
In cases where a suit has been filed, the presiding judge shall designate the date for oral argument and summon the parties to appear.

Rules of Civil Procedure (Japan)
**Article 60** (Designation of initial date for oral argument / The Code Article 139)
1. When a suit has been filed, the presiding judge shall promptly designate the date for oral argument. However, this shall not apply in the event that the case is referred to in prepartion for argument proceedings (this shall be limited to when the parties have no objection against the reference) or the event that the case is referred to in preparatory proceedings by document.
2. Except for cases in which special reasons exist, the date referred to in the preceding paragraph shall be designated within 30 days of the institution of the suit.

**មាត្រា ៨១.-** ការលើកបណ្ដឹងចោល ដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់

ក្នុងករណីដែលបណ្ដឹងមានលក្ខណៈផ្ទុយនឹងច្បាប់ ហើយចំណុចខ្វះខាតនោះមិនអាចកែតម្រូវបានទេ តុលាការអាចលើកបណ្ដឹងនោះចោល ដោយសាលក្រម ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់បាន ។

（កំណត់）

ក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន មាត្រា 140 ។

Code of Civil Procedure (Japan)
**Article 140** (Dismissal of suit without proceeding to oral argument)
In cases where a suit is illegitimate and such defect cannot be corrected, the court may dismiss the suit by judgment without proceeding to oral argument.

**មាត្រា ៨២.-** ការលើកបណ្ដឹងចោលក្នុងករណីដែលមិនបានបង់ជាមុននូវប្រាក់សម្រាប់ធ្វើការកោះហៅ

១- ក្នុងករណីដែលតុលាការបានបង្គាប់ឱ្យដើមចោទបង់ជាមុននូវប្រាក់ ដែលជាចាំបាច់សម្រាប់កោះហៅភាគីឱ្យចូលមកនៅកាលបរិច្ឆេទតាមបញ្ញត្តិនៃក្រមនេះ ដោយកំណត់អំឡុងពេលសមរម្យ តែដើមចោទមិនបានបង់ប្រាក់នោះជាមុនទេ តុលាការអាចលើកចោលបណ្ដឹងដោយដីកាសម្រេចបាន លុះត្រាតែចុងចម្លើយគ្មានការតវ៉ា ។

២- ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

（កំណត់）

ក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន មាត្រា 141 ។ នៅក្នុងនីតិវិធីនៃបណ្ដឹង ក្រោយពេលតុលាការបញ្ជូនពាក្យបណ្ដឹងទៅចុងចម្លើយហើយ នោះដើមចោទត្រូវបង់ជាមុននូវប្រាក់ (ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ) ដែលចាំបាច់សម្រាប់ការកោះហៅភាគី ។ ប្រសិនបើដើមចោទមិនបានបង់ប្រាក់តាមការបង្គាប់របស់តុលាការជាមុនទេ នោះតុលាការអាចលើកបណ្ដឹងចោល ដោយដីកាសម្រេចបាន ។ ប៉ុន្តែ ប្រសិនបើមានការតវ៉ាពីសំណាក់ចុងចម្លើយ នោះតុលាការមិនអាចលើកបណ្ដឹងចោលបានឡើយ ដោយហេតុថា ក្នុងករណីខ្លះ ការលើកចោលពាក្យបណ្ដឹងធ្វើឱ្យប៉ះពាល់ផលប្រយោជន៍របស់ចុងចម្លើយ ដូចជាចុងចម្លើយចង់បានសាលក្រមបញ្ជាក់អង្គហេតុ ជាដើម ។

Code of Civil Procedure (Japan)
**Article 141** (Dismissal of suit in case of failure to prepay fee for summons)
1. In cases where the court has ordered the plaintiff to prepay the fee necessary for the summons upon the party to appear on a date as required in accordance with the provisions of the Civil Procedure Costs Act within an appropriate period designated by the court, when the prepayment has failed, the court may dismiss the suit by ruling unless the defendant has objected.
2. An immediate *kokoku*-appeal may be made against the ruling referred to in the preceding paragraph.

**មាត្រា ៨៣.-** ការហាមបណ្ដឹងជាន់គ្នា

ចំពោះរឿងក្ដីដែលតុលាការកំពុងចាត់ការ ភាគីមិនអាចប្ដឹងទៀតបានឡើយ ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន មាត្រា 142 ។

មាត្រានេះបញ្ញត្តហាមឃាត់មិនឱ្យភាគីប្ដឹងចំពោះរឿងក្ដីដែលមានកម្មវត្ថុ និង ភាគីដូចគ្នានឹងបណ្ដឹងដែលខ្លួនបានប្ដឹងទៅតុលាការណាមួយ ហើយតុលាការនោះកំពុងចាត់ការ ។ ឧទាហរណ៍: លោក ក ប្ដឹងទាមទារឱ្យលោក ខ អនុវត្តកិច្ចសន្យាខ្ចីចងការប្រាក់ទៅតុលាការក្រុងភ្នំពេញ ហើយតុលាការក្រុងភ្នំពេញកំពុងចាត់ការលើបណ្ដឹងនោះ ។ ក្នុងអំឡុងពេលនៃនីតិវិធីចាត់ការលើបណ្ដឹង ស្រាប់តែលោក ខ បានផ្លាស់ប្ដូរលំនៅរបស់ខ្លួន ទៅនៅខេត្តកណ្ដាល ។ ក្នុងរឿងដដែលនេះ លោក ក បានដាក់ពាក្យបណ្ដឹងមួយទៀត ទៅតុលាការខេត្តកណ្ដាលតទល់នឹងលោក ខ ។ ក្នុងករណីនេះ តុលាការខេត្តកណ្ដាលត្រូវលើកចោលពាក្យបណ្ដឹង ដោយសាលក្រម តាមបញ្ញត្តិនៃមាត្រា ៨១ ។

Code of Civil Procedure (Japan)
**Article 142** (prohibition of double suits)
No party shall file a suit concerning a matter presently pending before a court.

**មាត្រា ៨៤.-** ការបន្ថែម ឬ ការផ្លាស់ប្ដូរនូវកម្មវត្ថុនៃបណ្ដឹង

១- ដើមចោទអាចបន្ថែម ឬ ផ្លាស់ប្ដូរនូវកម្មវត្ថុនៃបណ្ដឹង រហូតដល់ពេលចប់ការទាញហេតុផលដោយផ្ទាល់មាត់បាន លុះត្រាតែមិនមានការប្ដូរមូលដ្ឋាននៃការទាមទារ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលធ្វើឱ្យនីតិវិធីនៃបណ្ដឹងមានការយឺតយ៉ាវខ្លាំងដោយសារការបន្ថែម ឬ ការផ្លាស់ប្ដូរនោះ ។

២- ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ។
៣- ឯកសារដែលបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើ ត្រូវបញ្ជូនទៅភាគីម្ខាងទៀត ។
៤- ពេលដែលយល់ឃើញថា ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង មិនត្រឹមត្រូវទេ តុលាការត្រូវចេញដីកាសម្រេចមិនយល់ព្រមនឹងការបន្ថែម ឬ ការផ្លាស់ប្តូរនោះ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

（កំណត់）

ក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន មាត្រា 143 ។ ការបន្ថែមកម្មវត្ថុនៃបណ្តឹង គឺដើមចោទរក្សាទុកការទាមទារដើម ហើយបន្ថែមការទាមទារថ្មី ។ ឧទាហរណ៍ ក្នុងបណ្តឹងទាមទារឱ្យចេញពីផ្ទះ ដោយសារមិនបង់ថ្លៃឈ្នួល ដើមចោទបន្ថែមការទាមទារប្រាក់សំណងការខូចខាតស្មើនឹងថ្លៃឈ្នួលរហូតដល់ពេលអ្នកជួលចេញពីផ្ទះនោះ ។ ការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង គឺដើមចោទដកការទាមទារដើម ហើយដាក់ការទាមទារថ្មី ។ ឧទាហរណ៍ ក្នុងបណ្តឹងទាមទារចេញពីផ្ទះដោយសារមិនបង់ថ្លៃឈ្នួល ប្រសិនបើមានអគ្គីភ័យឆេះផ្ទះអស់ ដោយមានកំហុសរបស់ចុងចម្លើយ នៅពេលតុលាការកំពុងចាត់ការរឿងក្តីនេះ ដើមចោទផ្លាស់ប្តូរការទាមទាររបស់ខ្លួនទាំងស្រុង ទៅការទាមទារសំណងការខូចខាត ដោយសារការបាត់បង់ផ្ទះ ។ ក្នុងករណីណាក៏ដោយ ក៏តុលាការនឹងសម្រេចថា អនុញ្ញាត ឬ មិនអនុញ្ញាត តាមបញ្ញត្តិនៃមាត្រានេះ ។ ឧទាហរណ៍ទាំង ២ ខាងលើនេះ គឺជាករណីដែលតុលាការនឹងអនុញ្ញាត ។

Code of Civil Procedure (Japan)
**Article 143** (Amendment of suit)
1. To the extent the basis of the claim is not changed, the plaintiff may amend such claim or the grounds of such claim up to the time of the conclusion of oral argument. However, this shall not apply to cases where a considerable delay in the litigation proceedings may thereby result.
2. An amendment of a claim shall be made in writing.
3. The document referred to in the preceding paragraph shall be served on the adversary party.
4. The court shall, upon determining that an amendment of a claim or grounds of a claim is improper, upon motion or upon its own authority, render a ruling to the effect that such amendment shall not be permitted.

**មាត្រា ៨៥.-** ការប្តឹងទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្តាលទី

១- ក្នុងករណីដែលការសម្រេចសេចក្តី អាស្រ័យទៅលើអត្ថិភាព ឬ នត្ថិភាពនៃទំនាក់ទំនងគតិយុត្តដែលជាចំណុចវិវាទក្នុងដំណើរការពាក់កណ្តាលទី ដើមចោទអាចពង្រីកការទាមទារ ឬ ចុងចម្លើយអាចប្តឹងតប ដើម្បីឱ្យតុលាការបញ្ជាក់ពីអត្ថិភាព ឬ នត្ថិភាពនៃទំនាក់ទំនងគតិយុត្តដែលជាចំណុចវិវាទ នៅក្នុងសាលក្រមបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការទាមទារការបញ្ជាក់នោះ ស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់តុលាការដទៃទៀតតាមច្បាប់ ។
២- បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៨៤（ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង）នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការពង្រីកការទាមទារតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន មាត្រា 145 ។

Code of Civil Procedure (Japan)
**Article 145** (Interlocutory confirmation suit)
1. In cases where a decision depends upon the establishment or non-establishment of a legal relationship which relationship has become a point at issue in the course of the litigation, the party may apply for a judgment confirming the legal relationship by enlarging or extending its claim. However, this shall not apply to cases in which the claim for confirmation falls under the exclusive jurisdiction (except as decided by agreement of the parties in accordance with the provisions of Article 11) of another court.
2. The provisions of Article 143, paragraph 2 and 3 shall apply *mutatis mutandis* to the enlargement of the extension of a claim under the provisions of the preceding paragraph.

**មាត្រា ៨៦.-** បណ្តឹងតប

១- ចុងចម្លើយអាចប្តឹងតប ទៅតុលាការដែលកំពុងចាត់ការបណ្តឹងដើម រហូតដល់ពេលចប់ការទាញហេតុផលដោយផ្ទាល់មាត់បាន លុះត្រាតែការទាមទារដែលជាកម្មវត្ថុនៃបណ្តឹងតបនោះទាក់ទងនឹងការទាមទារដែលជាកម្មវត្ថុនៃបណ្តឹងដើម ឬមធ្យោបាយការពារខ្លួនសម្រាប់បណ្តឹងដើម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការទាមទារជាកម្មវត្ថុនៃបណ្តឹងតបនោះ ស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់តុលាការដទៃទៀតតាមច្បាប់ ឬ ករណីដែលការប្តឹងតបនោះនឹងធ្វើឱ្យមានការយឺតយ៉ាវយ៉ាងខ្លាំងក្នុងនីតិវិធីនៃបណ្តឹង ។

២- បញ្ញត្តិដែលទាក់ទងនឹងបណ្តឹង ត្រូវយកមកអនុវត្ត ចំពោះបណ្តឹងតប ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន មាត្រា 146 បទប្បញ្ញត្តិនីតិវិធីនៃប្រទេសជប៉ុន មាត្រា 59 ។

បណ្តឹងតប ជាបណ្តឹងដែលត្រូវបានធ្វើឡើងដោយភាគីម្ខាងទៀតនៃបណ្តឹងដើម ។ ល័ក្ខខ័ណ្ឌក្នុងការធ្វើបណ្តឹងតបនេះគឺលុះត្រាណាតែការទាមទារដែលជាកម្មវត្ថុនៃបណ្តឹងតបនោះទាក់ទងនឹងការទាមទារដែលជាកម្មវត្ថុនៃបណ្តឹងដើម ឬ ជាមធ្យោបាយការពារខ្លួន ដែលត្រូវធ្វើឡើងសម្រាប់បណ្តឹងដើមនោះ ។ ឧទាហរណ៍ : លោក **ក** បានទាមទារឱ្យលោក **ខ** ចុះចេញពីផ្ទះខ្លួន ដោយលើកសំអាងថា ផុតអាណត្តិនៃកិច្ចសន្យាជួល ហើយលោក **ខ** ប្តឹងទាមទារឱ្យបន្តកិច្ចសន្យាជួលដោយលើកហេតុផលថា កិច្ចសន្យាបានកំណត់ពីសិទ្ធិអាទិភាពរបស់ភាគីអ្នកសុំជួល ក្នុងការបន្តកិច្ចសន្យា ជាដើម ។ បណ្តឹងរបស់លោក **ខ** ជាបណ្តឹងតប ។

Code of Civil Procedure (Japan)
**Article 146** (Cross action)
1. The defendant may file a cross action in the court where the principal action is pending up to the time of the conclusion of oral argument only when the claim forming the subject matter of the cross action is relevant to the claim forming the subject matter or the measures of defense of the principal action. However, this shall not apply to cases where the claim forming the subject matter of the cross action falls under the exclusive jurisdiction (except as decided by agreement of the parties in accordance with the provisions of Article 11) of another court or cases where a considerable delay in the litigation proceedings may result by the filing of the cross

action.
2. The provisions relating to actions shall apply to cross actions.

<u>Rules of Civil Procedure (Japan)</u>
**Article 59** (Cross action / The Code Article 146)
The provisions relating to actions shall apply to cross actions.

**មាត្រា ៨៧.-** ពេលនៃការបង្កើតអានុភាពនៃការផ្អាកអាជ្ញាយុកាល ជាអាទិ៍

ការទាមទារតាមផ្លូវតុលាការដែលចាំបាច់សម្រាប់ការផ្អាកអាជ្ញាយុកាល ឬ សម្រាប់ការប្រព្រឹត្តទៅតាមអំឡុងពេលគតិយុត្ត នឹងបង្កើតអានុភាពនៅពេលបានដាក់ពាក្យបណ្ដឹង ឬ ពេលដែលដាក់ទៅតុលាការនូវឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ មាត្រា ៨៤ (ការបន្ថែម ឬ ការផ្លាស់ប្ដូរនូវកម្មវត្ថុនៃបណ្ដឹង) ឬ កថាខណ្ឌទី ២ មាត្រា ៨៤ (ការបន្ថែម ឬ ការផ្លាស់ប្ដូរនូវកម្មវត្ថុនៃបណ្ដឹង) ដែលត្រូវយកមកអនុវត្តដូចគ្នា នៅក្នុងបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៨៥ (ការប្ដឹងទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្ដាលទី) នៃក្រមនេះ ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន មាត្រា 147 ។ ចំពោះការផ្អាកអាជ្ញាយុកាល ត្រូវចែងក្នុងក្រមរដ្ឋប្បវេណី (ដូចជា ចំណុច ១ មាត្រា ១៦៦ នៃក្រមរដ្ឋប្បវេណី) ប៉ុន្តែ ចំពោះការដាក់ពាក្យបណ្ដឹង អាចមានបញ្ហាថាតើមានអានុភាពនៃការផ្អាកអាជ្ញាយុកាល នៅពេលដាក់ពាក្យបណ្ដឹង ឬ ពេលបញ្ជូនពាក្យបណ្ដឹងទៅចុងចម្លើយ ហេតុដូច្នេះ មាត្រានេះបញ្ជាក់ច្បាស់ថា បង្កើតអានុភាពនៅពេលដាក់ពាក្យបណ្ដឹង ។
ចំពោះការបន្ថែម ឬ ការផ្លាស់ប្ដូរកម្មវត្ថុនៃបណ្ដឹង ឬ ការប្ដឹងទាមទារការបញ្ជាក់ក្នុងដំណើការពាក់កណ្ដាលទី ក៏អានុភាពនៃការផ្អាកអាជ្ញាយុកាលត្រូវកើតឡើងនៅពេលដាក់ឯកសារទៅតុលាការដែរ ។

<u>Code of Civil Procedure (Japan)</u>
**Article 147** (Time of effecting interruption of prescription, etc.)
A judicial claim which is necessary for interruption of a prescription or compliance with a legal period shall take effect from the time of filing the suit or after the submission of documents according to the provisions of Article 143, paragraph 2 (including those cases to which it applies *mutatis mutandis* in Article 144, paragraph 3 and Article 145, paragraph 2).

**មាត្រា ៨៨.-** អនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនៃវិវាទ ជាអាទិ៍

១- ទោះបីបណ្ដឹងកំពុងត្រូវបានចាត់ការក៏ដោយ ក៏ភាគីនៃបណ្ដឹងមិនត្រូវបានរារាំងក្នុងការធ្វើអនុប្បទាន ឬ ការផ្ទេរវត្ថុដែលជាកម្មវត្ថុនៃវិវាទ ឬ សិទ្ធិឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្ដឹងនោះដែរ ។

២- អនុប្បទាន ឬ ការផ្ទេរដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំមានឥទ្ធិពលទៅលើបណ្ដឹងទេ ។ អ្នកដែលបានធ្វើអនុប្បទាន ឬ ផ្ទេរ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ក៏នៅតែមានឋានៈជាភាគីនៃបណ្ដឹងដដែល ក្រោយពីបានផ្ទេរ ។

៣- បញ្ញត្តិនៃមាត្រា ៤៨ (ការចូលរួមជួយអន្តរាគមន៍ក្នុងលក្ខណៈដូចជាសហបណ្ដឹង) នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះករណីដែលអ្នកដែលបានទទួលអនុប្បទាន ឬ ការផ្ទេរដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្លាយជាអ្នកចូលរួមជួយអន្តរាគមន៍ ។

(កំណត់)

សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា 265 និង មាត្រា 325 ។

ការចែងច្បាប់ស្ដីពីអនុប្បទាន ឬ ការផ្ទេរវត្ថុ ឬ សិទ្ធិផ្សេងៗ ដែលជាកម្មវត្ថុនៃវិវាទទៅឱ្យតតិយជន បន្ទាប់ពីបណ្ដឹងនោះត្រូវបានតុលាការចាត់ការហើយ អាចធ្វើទៅបានតាមគោលការណ៍ ២ គឺ គោលការណ៍កំណត់ភាគីបណ្ដឹង និង គោលការណ៍ទទួលបណ្ដឹងបន្ត ។ គោលការណ៍កំណត់ភាគីបណ្ដឹង គឺជាគោលការណ៍មួយមិនគិតពិចារណាអំពីអនុប្បទាន ឬ ការផ្ទេរនោះក្នុងបណ្ដឹង ហេតុនេះហើយ ភាគីដែលជាអ្នកធ្វើអនុប្បទាន ឬ អ្នកផ្ទេរ ក៏នៅតែមានលក្ខណៈជាដើមចោទ ឬ ចុងចម្លើយនៃបណ្ដឹងដដែល រីឯបណ្ដឹងក៏នៅតែបន្តទៅទៀតរវាងគូភាគីដូចមុនដដែល ហើយអានុភាពនៃសាលក្រមនៃបណ្ដឹងនោះក៏មានទៅលើប្រតិសិទ្ធិ (អ្នកទទួលអនុប្បទាន ឬ ការផ្ទេរ) ដែរ ដែលជាវិធីដោះស្រាយនៃជម្លោះមួយ ។ រីឯគោលការណ៍ទទួលបណ្ដឹងបន្តវិញ គឺជាគោលការណ៍មួយទទួលស្គាល់ការស្នងនូវលក្ខណៈជាភាគីនៃបណ្ដឹង ដោយប្រតិសិទ្ធិ (អ្នកទទួលអនុប្បទាន ឬ ការផ្ទេរ) ហេតុនេះហើយប្រតិសិទ្ធិចូលរួមក្នុងបណ្ដឹងជំនួសម្ចាស់ដើមលើវត្ថុ ឬ សិទ្ធិ (អ្នកធ្វើអនុប្បទាន ឬ អ្នកផ្ទេរ) ហើយភាគីម្ខាងទៀតអាចទាមទារឱ្យប្រតិសិទ្ធិនោះទទួលបណ្ដឹងបន្ត មានន័យថា ឱ្យអ្នកដែលមានផលប្រយោជន៍ពិត (អ្នកទទួលអនុប្បទាន ឬ ការផ្ទេរ) ក្លាយជាភាគីនៃបណ្ដឹង ដើម្បីដោះស្រាយជម្លោះ ។ ប្រទេសជប៉ុនបានយកគោលការណ៍ទទួលបណ្ដឹងបន្តជាមូលដ្ឋាន (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា 49 ដល់ មាត្រា 51) ប៉ុន្តែ ទោះបីជាមានហេតុផលដែលត្រូវទទួលបន្តក៏ដោយ តាមការជាក់ស្ដែង មិនមានករណីច្រើនដែលការចូលរួមអន្តរាគមន៍ក្នុងបណ្ដឹង ឬ ការទទួលបន្តបណ្ដឹងមិនមានដំណើរ ហើយដែលអាចធ្វើឱ្យនីតិវិធីគ្មានប្រយោជន៍ ម្យ៉ាងទៀត អនុប្បទាន ឬ ការផ្ទេរនឹងអាចត្រូវបានធ្វើជាបន្តបន្ទាប់ ហេតុនេះហើយ ដើមចោទត្រូវដាក់ពាក្យសុំវិធានការបណ្ដោះអាសន្នហាមមិនឱ្យចាត់ចែង ឬ ហាមមិនឱ្យផ្ទេរការកាន់កាប់ ដើម្បីការពារមិនឱ្យមានការផ្ទេរនេះ ជាដើម ។ នេះគឺជាបញ្ហាមួយ ចំពោះក្រមនីតិវិធីជប៉ុនសព្វថ្ងៃនេះ ។

ហេតុនេះហើយ ចំពោះកម្ពុជាវិញ ដើម្បីកុំឱ្យមានភាពស្មុគស្មាញ យើងខ្ញុំបានយកគោលការណ៍កំណត់ភាគី មកធ្វើជាមូលដ្ឋាននៃក្រមនេះ តាមក្រមនីតិវិធីរដ្ឋប្បវេណីអាល្លឺម៉ង់ ហើយចែងតឹងជាងក្រមអាល្លឺម៉ង់ (សូមមើលកថាខណ្ឌទី ២ នៃមាត្រានេះ) ។

ម្យ៉ាងទៀត ក្នុងករណីយកគោលការណ៍កំណត់ភាគីបណ្ដឹង មកធ្វើជាមូលដ្ឋាន ការពង្រីកនៃអានុភាពនៃសាលក្រមចំពោះប្រតិសិទ្ធិ (អ្នកទទួលបណ្ដឹងបន្ត) មានចែងក្នុងមាត្រា ១៩៨ (វិសាលភាពបុគ្គលដែលត្រូវទទួលអានុភាពរបស់សាលក្រមស្ថាពរ) ចំណុច **គ** ។

បុគ្គលដែលបានទទួលអនុប្បទាន ឬ ការផ្ទេរ អាចចូលរួមជួយអន្តរាគមន៍បាន ។ តាមច្បាប់អាល្លឺម៉ង់ គេចែងថាជាការចូលរួមជួយអន្តរាគមន៍ធម្មតា ប៉ុន្តែ ប្រសិនបើឱ្យតម្លៃទៅលើការធានាសិទ្ធិនីតិវិធីនៃអ្នកទទួលអនុប្បទាន ឬ ការផ្ទេរដែលទទួលនូវឥទ្ធិពលនៃការពង្រីកអានុភាពសាលក្រមវិញ ត្រូវចាត់ទុកថាជាការចូលរួមជួយអន្តរាគមន៍ក្នុងលក្ខណៈដូចជាសហបណ្តឹង ទៅវិញជាការល្អ ហេតុនេះហើយ ត្រូវធ្វើការបញ្ជាក់ក្នុងនេះ (កថាខណ្ឌទី ៣ នៃមាត្រានេះ) ។

Code of Civil Procedure Rules (Germany)
**Article 265** (Transfer of the disputed thing)
1. Pendency does not exclude the right of either party to transfer the thing in litigation or to assign the asserted claim.
2. The transfer or assignment does not affect the lawsuit. The legal successor is not entitled to assume the position of his predecessor as the main party in the lawsuit or to enter an interpleader without the consent of the opponent. If the legal successor acts as an intervening third party, §69 shall not be applicable.
3. If the plaintiff made the transfer or assignment, it may be pleaded against him, insofar as the judgment pursuant to §325 would not be effective against the legal successor, that he is not entitled any more to enforce the claim.
**Article 325** (Finality and legal successors)
1, The final judgment is effective for and against the parties and the persons who became legal successors of the parties after the occurrence of pendency of the action or acquired possession of a thing involved in the litigation in such a manner that one of the parties or his legal successor became the indirect possessor.
2. The provisions of the civil law for the benefit of those who derive rights from an unauthorized person are applicable *mutatis mutandis*.
3. If the judgment concerns a claim arising from a registered realty charge, mortgage, land charge or annuity charge, then it is effective in case of a transfer or the encumbered real property with respect to the real property against the legal successor, also if the latter had no knowledge of the pendency of the action. The judgment is effective against the purchaser of a real property sold by an auction ordered by the court only when the pendency of the case was announced not later than the time fixed for the auction before the invitation to make bids.
4. If the judgment concerns a claim arising from a registered ship mortgage, subparagraph 3 first sentence is applicable *mutatis mutandis*.

Code of Civil Procedure (Japan)
**Article 49** (Interrupting running of prescription, etc., in case of intervention by transferee of right)
During the pendency of a suit, in the event of an intervention in the suit under the provisions of Article 47, paragraph 1, in which the whole or a part of the right which is the subject matter of such suit is claimed to have been transferred, such intervention shall have the effect of interrupting the running of any prescription or of fulfilling any requirement of compliance within the period of time specified by law retroactively from the beginning of the pendency.
**Article 50** (Assumption of suit by successor of obligation)
1. In cases where a third person has succeeded to the whole or a part of the obligation which is the subject matter of a suit during the pendency of the suit, the court may, upon motion of either party, by ruling, have such third person assume the suit.
2. If the court renders a ruling under the provisions of the preceding paragraph, it shall interrogate the parties and the third person.
3. The provisions of Article 41, paragraph 1 and 3 and the preceding two articles shall apply *mutatis mutandis* to cases in which there is a ruling recognizing the assumption of a suit under the provisions of paragraph 1.
**Article 51** (Intervention by successor of obligation and asumption of suit by transferee of right)
The provisions of Article 47 to 49 inclusive shall apply *mutatis mutandis* to cases of the intervention in a suit by a third person who claims to have succeeded to the whole or a part of the obligation which is the subject matter of a suit during the pendency of the suit; and the provisions of the preceding article shall apply *mutatis mutandis* to cases where a third person has succeeded to the whole or a part of the right which is the subject matter of a suit during the pendency of the suit.

## ជំពូកទី ២ ការទាញហេតុផលដោយផ្ទាល់មាត់ និង ការរៀបចំ

### ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ

**មាត្រា ៨៩.-** ការដឹកនាំនីតិវិធីនៃបណ្តឹងដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ

១- ប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវដឹកនាំចាត់ចែងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ត្រូវដឹកនាំចាត់ចែងការទាញហេតុផលដោយផ្ទាល់មាត់ ។(1)

២- ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអនុញ្ញាតឱ្យជនណាម្នាក់និយាយបាន និង អាចហាមជនដែលមិនស្តាប់បញ្ជារបស់ខ្លួនមិនឱ្យនិយាយបាន ។(2)

(កំណត់)

(1) សូមមើលមាត្រា 148 និង មាត្រា 170 កថាខណ្ឌទី ៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 136 នៃក្រមនីតិវិធីអាល្លឺម៉ង់ និង មាត្រា 440 នៃក្រមនីតិវិធីបារាំង ។ មាត្រានេះយោងទៅតាមការអនុវត្តនូវ "គោលការណ៍ដឹកនាំដោយឆន្ទានុសិទ្ធិ" ចំពោះការដឹកនាំនីតិវិធី ។ ពាក្យ "ប្រធានក្រុមប្រឹក្សាជំនុំជម្រះ" ជាពាក្យដែលប្រើក្នុងការជម្រះក្តីដោយក្រុមប្រឹក្សាចៅក្រម រីឯចំពោះការជម្រះក្តីដោយចៅក្រមតែម្នាក់វិញ គឺចៅក្រមនោះផ្ទាល់ជាអ្នកទទួលបន្ទុករឿងក្តី ។ មាត្រាខាងក្រោមនេះវិញ ក៏ត្រូវចាំបាច់បកស្រាយ ដូចគ្នាដែរ ។ម្យ៉ាងទៀត បើរឿងក្តីត្រូវបានជំនុំជម្រះដោយក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សាជំនុំជម្រះនោះ អនុវត្តសិទ្ធិដឹកនាំនីតិវិធី ក្នុងនាមជាក្រុមប្រឹក្សានោះ ។

(2) ករណីដែលមានអ្នកមិនស្តាប់តាមការដឹកនាំរបស់ប្រធានចៅក្រមក្នុងសាលាជម្រះក្តី នៅប្រទេសជប៉ុន "ច្បាប់ស្តីពីការរក្សាសណ្តាប់ធ្នាប់នៅក្នុងសាលាជម្រះក្តី ជាអាទិ៍" ចែងថា អ្នកនោះនឹងត្រូវបានឃាត់ខ្លួន ក្រោម ២០ ថ្ងៃ ឬ ពិន័យជាប្រាក់ចំនួនស្មើ ឬ តិចជាង ៣០,០០០ យ៉េន ។

Code of Civil Procedure (Japan)
**Article 148** (Presiding judge's authority to control litigation proceed)
1. The presiding judge shall control the oral argument.
2. The presiding judge may allow statements or prohibit persons who do not comply with orders from making statements.
**Article 170** (Acts of litigation, etc., in preparations for argument proceedings) (excerpt)
6. The provisions of Article 148 to 151 inclusive, Article 152, paragraph 1, and Article 153 to 159 inclusive, 162, 165 and 166 shall apply *mutatis mutandis* to preparations for argument proceedings.

Code of Civil Procedure Rules (Germany)
**Article 136** (Conduct of proceedings by the presiding judge)
1. The presiding judge shall open and conduct the oral proceedings.
2. He grants permission to speak and he may withhold it from persons who fail to comply with his order.
3. He shall see to it that the matter is thoroughly argued and the proceeding is completed without interruption; when necessary, he shall immediately fix the date for the continuation of the proceeding.
4. He closes the proceeding if, in view of the court, the matter has been thoroughly argued, and proclaims the judgments and orders of the court.

Code de Procédure Civile (France)
**Article 440**
Le président dirige les débats. Il donne la parole au rapporteur dans le cas où un rapport doit être fait.
Le demandeur, puis le défendeur, sont ensuite invités à exposer leur prétentions.
Lorsque la juridintion s'estime éclairée, le président fait cesser les plaidoiries ou les observations présentées par les parties pour leur défense.

**មាត្រា ៩០.-** សិទ្ធិឱ្យបំភ្លឺ ជាអាទិ៍

១- ដើម្បីឱ្យចំណុចនៃអង្គហេតុ និង អង្គច្បាប់ដែលទាក់ទងនឹងបណ្ដឹង មានភាពច្បាស់លាស់ តុលាការអាចសាកសួរភាគី ឬ ឱ្យភាគីអះអាង ឬ បញ្ជាក់ភស្តុតាង ចំពោះចំណុចនោះ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ការទាញហេតុផលដោយផ្ទាល់មាត់បាន ។ (1)

២- ភាគីអាចទាមទារឱ្យតុលាការសួរសំណួរចាំបាច់ទៅភាគីម្ខាងទៀត នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ការទាញហេតុផលដោយផ្ទាល់មាត់បាន ។ (2)

៣- នៅក្រៅពីកាលបរិច្ឆេទ តុលាការអាចបង្គាប់ឱ្យភាគីត្រៀមខ្លួននឹងរៀបចំការឆ្លើយបំភ្លឺ នៅកាលបរិច្ឆេទបន្ទាប់ ដោយបញ្ជាក់ចំណុចដែលតុលាការយល់ឃើញថា ត្រូវការឱ្យបំភ្លឺជាចាំបាច់ ។ (3)

(កំណត់)

សូមមើលមាត្រា 149 និង មាត្រា 170 កថាខណ្ឌទី 6 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 8 មាត្រា 13 និង មាត្រា 442 នៃក្រមនីតិវិធីរដ្ឋប្បវេណីបារាំង និង មាត្រា 139 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាល្លឺម៉ង់ ។

(1) ការអះអាងអង្គហេតុដែលក្លាយជាមូលដ្ឋានសម្រាប់ចេញសាលក្រម គឺជាកាតព្វកិច្ចរបស់ភាគី (គោលការណ៍នៃការទាញហេតុផល សូមមើលមាត្រា ៩៥ (អង្គហេតុដែលអាចយកមកធ្វើជាមូលដ្ឋាននៃសាលក្រម)) ។ ដើម្បីឱ្យភាគីអាចបំពេញកាតព្វកិច្ចរបស់ខ្លួនបាននោះ តុលាការអាចសួរអំពីចំណុចមិនច្បាស់នៃអង្គហេតុដែលភាគីបានអះអាង ឬ ចំណុចដែលមានភាពបដិវាទកម្ម (ហៅថា ការឱ្យបំភ្លឺអកម្ម) ហើយម្យ៉ាងទៀត តុលាការអាចជំរុញឱ្យធ្វើការអះអាងអង្គហេតុសមរម្យថ្មីទៀត ឬ ការដាក់ភស្តុតាងថ្មីបាន (ហៅថា ការឱ្យបំភ្លឺសកម្ម) ។ ដើម្បីឱ្យការជម្រះក្ដីមានភាពត្រឹមត្រូវ និង មានសមភាព ការប្រើ "សិទ្ធិឱ្យបំភ្លឺ" នេះ ត្រូវបានយល់ឃើញថាជាករណីយកិច្ចរបស់តុលាការ ក្នុងករណីមួយចំនួនដែរ ។

(2) សិទ្ធិរបស់ភាគីនេះ ត្រូវគេហៅថា "សិទ្ធិទាមទារសួរ" ។

(3) សូមមើលមាត្រា 128 (ដីកាបង្គាប់ឱ្យត្រៀមបំភ្លឺ) នៃក្រមនីតិវិធីជប៉ុនចាស់ ។

Code of Civil Procedure (Japan)
**Article 149** (Authority to ask for explanation, etc.)
1. The presiding judge may question the parties or require them to present evidence on matters of fact and law, on a date set for oral argument or on an occasion other than such date, in order to clarify the relationships involved in the litigation.
2. An associate judge of the panel may take the measures prescribed in the preceding paragraph after so informing the presiding judge.
3. The parties may ask the presiding judge to make any necessary questions on a date set for oral argument or on an occasion other than such date.
4. In cases where the presiding judge or an associate judge of the panel has taken measures on an occasion other than the date set for oral argument in accordance with the provisions of paragraph1 or 2 relating to matters which tend to cause a considerable change on the offensive or defensive measures, the judge shall notify the adversary party of the contents thereof.
**Article 170** (excerpt) > *see the note for Article 89*

Code de Procédure Civile (France)
**Article 8**

Le juge peut inviter les parties à fournir les explications de fait qu'il estime nécessaires à la solution du litige.
**Article 13**
Le juge peut inviter les parties à fournir les explications de droit qu'il estime nécessaires à la solution du litige.
**Article 442**
Le président et les juges peuvent inviter les parties à fournir les explications de droit ou de fait qu'ils estiment nécessaires ou à préciser ce qui paraît obscur.

<u>Code of Civil Procedure Rules (Germany)</u>
**Article 139** (Duty of clarification by the judge)
1. The presiding judge shall ensure that the parties completely disclose all relevant facts and make the pertinent motions, and especially also supplement insufficient particulars concerning asserted facts and describe the evidence. He shall, for this purpose, to such extent as required, discuss with the parties the factual and legal relations of the dispute according to its factual and legal aspects and to put questions.
2. The presiding judge shall also draw attention to considertations which obtain with respect to points to be taken into account *ex officio*.
3. He shall allow each member of the court to ask questions, if the latter so desires.

<u>Old Code of Civil Procedure (Japan, 1890, last amendment: 1992)</u>
**Article 128** (Order to prepare for explanation)
The presiding judge may indicate matters to be explained by parties in accordance with the provisions of the preceding Article and order them to prepare prior to the date of oral argument.

## **មាត្រា ៩១.-** បណ្ដឹងតវ៉ាចំពោះការដឹកនាំនីតិវិធីបណ្ដឹង

ក្នុងករណីដែលភាគីបានធ្វើបណ្ដឹងតវ៉ា ចំពោះការដឹកនាំការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ការទាញហេតុផលដោយផ្ទាល់មាត់ ឬ ចំពោះការចាត់ចែងរបស់តុលាការ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៩០ (សិទ្ធិឱ្យបំភ្លឺជាអាទិ៍) ខាងលើនេះ តុលាការត្រូវសម្រេចសេចក្ដី ចំពោះបណ្ដឹងតវ៉ានោះ ដោយដីកាសម្រេច ។

(កំណត់)

សូមមើលមាត្រា 150 មាត្រា 170 កថាខណ្ឌទី 6 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ មាត្រានេះមានន័យថាឱ្យភាគីមានសិទ្ធិទាមទារឱ្យតុលាការគិតពិចារណាម្ដងទៀត អំពីការដឹកនាំរបស់ក្រុមប្រឹក្សាជំនុំជម្រះ ឬ ចៅក្រមទទួលបន្ទុករឿងក្ដី ។ បណ្ដឹងតវ៉ាចំពោះការដឹកនាំរបស់ក្រុមប្រឹក្សាជំនុំជម្រះ ត្រូវបានសម្រេចដោយដីកាសម្រេចដោយក្រុមប្រឹក្សានោះ រីឯបណ្ដឹងតវ៉ាចំពោះការដឹកនាំរបស់ចៅក្រមទទួលបន្ទុករឿងក្ដីតែមួយនាក់ ត្រូវបានសម្រេចដោយដីកាសម្រេច ដោយចៅក្រមនោះ ។

ម្យ៉ាងទៀត ចំពោះដីកាសម្រេចអំពីការតវ៉ាដែលបានកំណត់ក្នុងមាត្រានេះ មិនអាចប្ដឹងជំទាស់បានទេ ។

<u>Code of Civil Procedure (Japan)</u>
**Article 150** (Objection to controlling litigation proceedings, etc.)
In cases where a party raise an objection to an order of the presiding judge with regard to the control of oral argument or to measures taken by the presiding judge or an associate judge of the panel under the provisions of paragraph 1 or 2 of the preceding article, the court shall render a decision by ruling with regard to the objection.
**Article 170** (excerpt) > *see the note for Article 89*

## **មាត្រា ៩២.-** ករណីយកិច្ចស្រាវជ្រាវរបស់ភាគី

ភាគីត្រូវធ្វើការស្រាវជ្រាវឱ្យបានលំអិតជាមុន នូវទំនាក់ទំនងនៃអង្គហេតុចំពោះសាក្សី និង ភស្តុតាងផ្សេងៗ ដើម្បីធ្វើការអះអាង និង បញ្ជាក់ឱ្យបានគ្រប់គ្រាន់ច្បាស់លាស់ក្នុងបណ្តឹង ។

(កំណត់)

សូមមើលមាត្រា 85 នៃបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

មាត្រានេះ តម្រូវឱ្យភាគី ធ្វើការសិក្សាស្រាវជ្រាវ និង រៀបចំជាមុននូវយុទ្ធសាស្ត្រ និង មធ្យោបាយតទល់ ឬ ការពាររបស់ខ្លួន មុនពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ សម្រាប់ការពារ និង បំពេញការអះអាងរបស់ខ្លួន ។

Rules of Civil Procedure (Japan)
**Article 85** (Duty of investigation)
Parties shall, in advance, investigate facts in detail with regard to witnesses and any other evidences in order to complete allegations and the presentation of evidence.

**មាត្រា ៩៣.-** ពេលដែលត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន

មធ្យោបាយតទល់ ឬ ការពារខ្លួន (1) ត្រូវដាក់ឱ្យតុលាការនៅពេលណាមួយដែលសមរម្យ ទៅតាមដំណើរការនៃបណ្តឹង ។(2)

(កំណត់)

សូមមើលមាត្រា 156 មាត្រា 170 កថាខណ្ឌទី 6 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន និង មាត្រា 282 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាល្លឺម៉ង់ ។

(1) ពាក្យ "មធ្យោបាយតទល់ ឬ ការពារខ្លួន" អាចនិយាយម្យ៉ាងទៀតថា "ប្រភពជាមូលដ្ឋាននៃសាលក្រម" ក៏បានដែរ ។ មធ្យោបាយតទល់ ជាអ្វីៗទាំងឡាយដែលដើមចោទដាក់ទៅតុលាការ ដើម្បីយកមកធ្វើជាមូលដ្ឋាននៃពាក្យសុំរបស់ខ្លួន (ឧ. បណ្តឹង) រីឯមធ្យោបាយការពារខ្លួន គឺជាអ្វីៗទាំងឡាយដែលចុងចម្លើយដាក់ទៅតុលាការ ដើម្បីយកមកធ្វើជាមូលដ្ឋាននៃពាក្យសុំប្រឆាំងវិញ (ឧ. ពាក្យសុំឱ្យលើកចោលបណ្តឹង ពាក្យសុំឱ្យច្រានចោលការទាមទារ) ។ ជាពិសេស អង្គហេតុ និង ភស្តុតាង គឺជាមធ្យោបាយសំខាន់ៗ ក្នុងចំណោមមធ្យោបាយតទល់ ឬ ការពារខ្លួនទាំងមូល ។

(2) មាត្រានេះបានកំណត់ទស្សនាទានដែលហៅថា "គោលការណ៍ដាក់តាមកាលៈទេសៈសមរម្យ" ចំពោះពេលវេលាដែលត្រូវដាក់មធ្យោបាយតទល់ និង ការពារខ្លួន ។ រីឯមាត្រា 137 នៃក្រមនីតិវិធីរដ្ឋប្បវេណីចាស់របស់ជប៉ុនវិញ បានកំណត់យក "គោលការណ៍ដាក់ពេលណាក៏បាន" (មាត្រា 72 និង មាត្រា 123 នៃក្រមនីតិវិធីបារាំងក៏ដូចគ្នាដែរ) ។ ប៉ុន្តែ ប្រសិនបើគេអនុវត្តតាមន័យរបស់ពាក្យ "ដាក់ពេលណាក៏បាន" គេមិនអាចរក្សានូវអាកប្បកិរិយាដ៏សុចរិតរបស់គូភាគីក្នុងការធ្វើបណ្តឹងបានទេ ហើយដែលអាចនាំឱ្យមានការយឺតយ៉ាវក្នុងការជម្រះក្តី ហើយម្យ៉ាងទៀតអាច

មានឧបសគ្គដល់ការការពារខ្លួនរបស់ភាគីម្ខាងទៀតដែរ ។ ហេតុដូច្នេះហើយ ក្រុមជប៉ុនសព្វថ្ងៃនេះ បានជ្រើសរើសយកគោលការណ៍ទៅតាមកាលៈទេសៈសមរម្យទៅវិញ ។

<u>Code of Civil Procedure (Japan)</u>
**Article 156** (Time for advancing offensive or defensive measures)
Offensive or defensive measures shall be advanced at the appropriate time in accordance with the progress of the litigation.
**Article 170** (excerpt) > *see the note for Article 89*

<u>Code of Civil Procedure Rules (Germany)</u>
**Article 282** (Timeliness of presentation)
1. Each party shall present at the oral hearing its means of attack and of defense, especially allegations, denials, pleas, objections, evidence and objections to evidence, in such a timely manner as in the state of the case it would be in accordance with a careful conduct of proceedings calculated to expedite the legal process.
2. Petitions as well as means of attack and of defense, to which the opponent is presumably unable to declare himself without prior inquiries, shall be communicated in written pleadings in a timely manner, which still enables the opponent to gather the necessary information.
3. Protests which concern the admissibility of the claim shall be presented by the defendant at the same time and before his oral hearing of the main issue. If he was granted a limited period for entering a statement of defense, he must assert his protests already within the limited period.

<u>Old Code of Civil Procedure (Japan, 1980, last amendment: 1992)</u>
**Article 137** (Period for production of means of attack or defense)
Except otherwise provided for, the means of attack or defense may be produced up to the closing of oral argument.

<u>Code de Procédure Civile (France)</u>
**Article 72**
Les défenses au fond peuvent être proposées en tout état de cause.
**Article123**
Les fins de non-recevoir peuvent être proposées en tout état de cause, sauf la possibilité pour le juge de condamner à des dommages-intérêt ceux qui se seraient abstenus, dans une intention dilatoire, de les soulever plus tôt.

**មាត្រា ៩៤.-** ការលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួនដែលបានដាក់យឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ

១- ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនដែលបានដាក់ទៅតុលាការយឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ ដោយចេតនា ឬ ដោយកំហុសដ៏ធ្ងន់ធ្ងររបស់ភាគី តុលាការអាចចេញដីកាសម្រេចលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួនបានតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ប្រសិនបើតុលាការយល់ឃើញថា ការដាក់មធ្យោបាយនោះ ធ្វើឱ្យមានការយឺតយ៉ាវក្នុងការបញ្ចប់នីតិវិធីនៃបណ្តឹង ។

២- បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដែរ ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនដែលមានអត្ថន័យមិនច្បាស់លាស់ ក្នុងករណីដែលភាគីមិនបានធ្វើការបំភ្លឺចាំបាច់ ឬ មិនបង្ហាញខ្លួនតាមកាលបរិច្ឆេទដែលបានកោះហៅឱ្យមកបំភ្លឺទេ ។

(កំណត់)

សូមមើលមាត្រា 157 និង មាត្រា 170 កថាខណ្ឌទី 6 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន និង មាត្រា 296 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាល្លឺម៉ង់ ។ នេះគឺជាវិធីជាក់ស្តែងទូទៅមួយដើម្បីធានាដល់គោលការណ៍ដាក់មធ្យោបាយតទល់

ឬ ការពារខ្លួនតាមពេលសមរម្យដែលមានចែងក្នុង មាត្រា ៩៣ (ពេលដែលត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន) ។

ចំពោះដីកាសម្រេចលើកចោលដែលបានកំណត់ក្នុងមាត្រានេះ មិនអាចប្តឹងជំទាស់បានទេ ។

<u>Code of Civil Procedure (Japan)</u>
**Article 157** (Rejection of offensive or defensive measures)
1. With regard to offensive or defensive measures advanced by a party intentionally or through gross negligence after the proper time, when the conclusion of the litigation is deemed to have been delayed thereby, the court may, upon motion or upon its own authority, render a ruling of dismissal.
2. The preceding paragraph shall also apply to cases where with regard to offensive or defensive measures of which the import is unclear, a party does not furnish any necessary explanations or does not appear on the date when such party is to furnish such explanations.
**Article 170** (excerpt) > *see the note for Article 89*

<u>Code of Civil Procedure Rules (Germany)</u>
**Article 296** (Rejection of means of attack and of defense)
1. Means of attack and of defense which were first presented after the expiration of the time limit set therefor (Article 73(2) no. 1, Article 275(1) first sentence, (3) and (4), Article 276(1) second sentence, (3) and Article 277), may only be admitted if, at the free discretion of the court, their admission would not delay the completion of the litigation or if the party can adequately justify the delay.
2. Means of attack or of defense which have not been presented on time contrary to Article 282(1) or have not been notified contrary to Article 282(2) may be rejected if their admission would, at the court's free discretion, delay the completion of the litigation and the tardiness was the result of gross negligence.
3. Late complaints which concern the admissibility of a claim and which can be waived by the defendant shall only be admitted if the defendant sufficiently justifies the delay.
4. In the cases under subparagraphs (1) and (3), the excuse shall be justified when the court so requires.

**មាត្រា ៩៥.-** អង្គហេតុដែលអាចយកមកធ្វើជាមូលដ្ឋាននៃសាលក្រម

តុលាការមិនអាចយកអង្គហេតុណា ដែលភាគីណាមួយមិនបានអះអាង មកធ្វើជាមូលដ្ឋាននៃសាលក្រមបានឡើយ ។

(កំណត់)

នៅប្រទេសជប៉ុន នៅក្នុងនីតិវិធីរដ្ឋប្បវេណីធម្មតា (បណ្តឹងរដ្ឋប្បវេណីអំពីទំនាក់ទំនងគតិយុត្តចំពោះទ្រព្យសម្បត្តិ) គេអនុវត្តគោលការណ៍ដែលមានន័យថា ការអះអាងអង្គហេតុ និង ការបង្ហាញភស្តុតាងជាសិទ្ធិ និង ការទទួលខុសត្រូវរបស់ភាគី ។ គោលការណ៍នេះត្រូវបានហៅថា "គោលការណ៍នៃការទាញហេតុផល" ។ មូលហេតុនៃការយកគោលការណ៍នេះ គឺថា ចំពោះទំនាក់ទំនងសិទ្ធិ និង ទំនាក់ទំនងគតិយុត្តដែលភាគីអាចចាត់ចែងដោយសេរីអាស្រ័យទៅលើច្បាប់សារធាតុ (substantive law, droit fondamental) គំនិតនៃភាគីត្រូវគោរពក្នុងការជ្រើសរើសអង្គហេតុ និង ភស្តុតាងដើម្បីយកជាមូលដ្ឋាននៃសាលក្រម ។

អំពីអង្គហេតុ "គោលការណ៍នៃការទាញហេតុផល" មានវិធាន ២ នៅក្នុងនោះ ។ មួយគឺការចែងនៅក្នុងមាត្រានេះ ។ វិធាននេះយោងទៅតាមបទប្បញ្ញត្តិនេះ ចំពោះភាគីវិញ អង្គហេតុណាដែលភាគីមិនបានយកមកធ្វើជាសេចក្តីសំអាង គេមិនអាចយកមកធ្វើជាមូលដ្ឋាននៃសាលក្រមទេ ហេតុដូច្នេះ អាចនាំឱ្យខូចប្រយោជន៏ដល់ភាគី ។ ពោលគឺវាមានមុខនាទីធ្វើឱ្យមានការទទួលខុសត្រូវក្នុងការអះអាង (ជាការទទួលខុសត្រូវលើលទ្ធផល) តាមការពិត យើងគួរតែចែងនៅក្នុងមាត្រាស្តីអំពីសាលក្រមវិញក៏មិនដឹង ។ ប៉ុន្តែ ដើម្បីជំរុញឱ្យភាគីយកអំណះអំណាងអង្គហេតុទាំងអស់ ដែល

ចាំបាច់ក្នុងដំណើការនៃការជំនុំជម្រះក្ដី ការចែងនៅក្នុងមាត្រានេះជាការសមរម្យ ដោយយើងយកចិត្តទុកដាក់ទៅលើមុខនាទីនៃការទទួលខុសត្រូវលើអំពើនោះ (តាមច្បាប់ប្រទេសជប៉ុន វិធាននេះជាគោលការណ៍ដែលត្រូវគោរពជាធម្មតាទៅហើយ ដូច្នេះច្បាប់ជប៉ុនមិនបានចែងជាលាយល័ក្ខណ៍អក្សរ ដូចមាត្រានេះទេ) ។

វិធានមួយទៀតនៃ "គោលការណ៍នៃការទាញហេតុផល" នេះ គឺជាអង្គហេតុដែលភាគីបានសារភាព ត្រូវចងភ្ជាប់តុលាការ ដូច្នេះចំពោះអង្គហេតុដែលភាគីបានសារភាពហើយនោះ មិនបាច់ត្រូវបានទទួលស្គាល់ដោយការបញ្ជាក់ភស្តុតាងឡើយ ។ មានន័យថា ប្រសិនបើភាគីសងខាងមានឯកភាពក្នុងការអះអាងចំពោះអត្ថិភាពនៃអង្គហេតុណាមួយ នោះតុលាការត្រូវគោរពគំនិតរបស់គូភាគី និង មិនអាចធ្វើការពិចារណានូវភាពត្រឹមត្រូវនៃអង្គហេតុនោះទៀតបានឡើយ ។ ចំពោះវិធាននេះ សូមមើលមាត្រា ១២៣ (គោលការណ៍សម្រេចសេចក្ដីដោយភស្តុតាង) កថាខណ្ឌទី ២ ។

ម្យ៉ាងទៀត ប្រទេសជប៉ុន និង ប្រទេសភាគច្រើនទៀត ចំពោះភស្តុតាងដើម្បីទទួលស្គាល់អង្គហេតុ ក៏បានយកវិធានថា ជាគោលការណ៍យកតែភស្តុតាងដែលភាគីបានដាក់ប៉ុណ្ណោះ (នៅប្រទេសជប៉ុន វិធាននេះក៏អាចបញ្ចូលក្នុងគោលការណ៍នៃការទាញហេតុផលដែរ) ។ ប៉ុន្តែ ដោយសារនៅព្រះរាជាណាចក្រកម្ពុជា សមត្ថភាពប្រមូលភស្តុតាងរបស់គូភាគី នៅទាបពេក ក្រមនេះទទួលស្គាល់ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិរបស់តុលាការ ក្នុងករណីជាចាំបាច់ (មាត្រា ១២៤ (ការពិនិត្យភស្តុតាង) កថាខណ្ឌទី ២) ហេតុដូច្នេះ យើងមិនយក "គោលការណ៍នៃការទាញហេតុផល" ចំពោះភស្តុតាងឡើយ ។ ច្បាប់បារាំង និង អ៊ីតាលីក៏មានប្រភេទដូចនេះដែរ ។

ម្យ៉ាងទៀត នៅប្រទេសជប៉ុន ចំពោះបណ្ដឹងដែលមានទំនាក់ទំនងខ្លាំងនឹងប្រយោជន៍សាធារណៈ ដូចជាបណ្ដឹងដែលទាក់ទងនឹងឋានៈបុគ្គល ជាដើម គេមិនអនុវត្ត "គោលការណ៍នៃការទាញហេតុផល" ទេ គឺយក "គោលការណ៍នៃការស្រាវជ្រាវរកដោយឆន្ទានុសិទ្ធិរបស់តុលាការ" មកអនុវត្តវិញ ។

**មាត្រា ៩៦.-** ការចាត់ទុកថាបានសារភាព

១- ក្នុងករណីដែលភាគីមិនបានបង្ហាញច្បាស់លាស់ នូវឆន្ទៈតវ៉ាអំពីអង្គហេតុដែលភាគីម្ខាងទៀតបានអះអាង នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ការទាញហេតុផលដោយផ្ទាល់មាត់ទេ ភាគីនោះត្រូវបានចាត់ទុកថា បានសារភាពអំពីអង្គហេតុនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតុលាការគិតពិចារណាអំពីដំណើរការ និង ខ្លឹមសារនៃរឿងក្ដី ហើយយល់ឃើញថា ភាគីនោះបានតវ៉ាអំពីអង្គហេតុ ។

២- ក្នុងករណីដែលភាគីធ្វើសេចក្ដីថ្លែងការណ៍ថា ខ្លួនមិនដឹងអំពីអង្គហេតុដែលភាគីម្ខាងទៀតបានអះអាង ភាគីនោះត្រូវបានសន្មតថា បានតវ៉ាអំពីអង្គហេតុនោះ ។

(កំណត់)

សូមមើលមាត្រា 159 កថាខណ្ឌទី 1 និង ទី 2 និង មាត្រា 170 កថាខណ្ឌទី 6 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

ក្នុងករណីដែលភាគីធ្វើសេចក្តីថ្លែងការណ៍បដិសេធអង្គហេតុ ឬ បង្ហាញឆន្ទៈតវ៉ាដោយប្រយោល តាមសកម្មភាពបណ្តឹងទាំងមូល នោះមិនចាត់ទុកថាបានសារភាពឡើយ ។

ក្នុងករណីដែលមិនបដិសេធនៅក្នុងនីតិវិធីតៀមសម្រាប់ការទាញហេតុផល អាចធ្វើសេចក្តីថ្លែងការណ៍បដិសេធនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ពេលក្រោយ ឬ មិនធ្វើ គឺ អាស្រ័យលើអានុភាពបាត់បង់សិទ្ធិនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (មាត្រា ១០៨ (អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល)) និង ការលើកចោល ឬ មិនលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួនដែលបានដាក់យឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ (មាត្រា ៩៤ (ការលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួនដែលបានដាក់យឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ)) ។ ក្នុងករណីដែលបាត់បង់សិទ្ធិ ឬ លើកចោល ត្រូវចាត់ទុកថាបានសារភាព រីឯក្នុងករណីដែលមិនបាត់បង់សិទ្ធិ ឬ លើកចោល ភាគីអាចធ្វើសេចក្តីថ្លែងការណ៍បដិសេធបាន ហេតុដូច្នេះមិនត្រូវចាត់ទុកថាបានសារភាពឡើយ ។

ចំពោះអង្គហេតុដែលត្រូវបានចាត់ទុកថាភាគីបានសារភាព មិនចាំបាច់បញ្ជាក់ភស្តុតាងទេ ។ នេះផ្អែកលើគោលការណ៍នៃការទាញហេតុផល ហេតុដូច្នេះ ចំពោះចំណុចដែលតុលាការអាចស្រាវជ្រាវដោយឆន្ទានុសិទ្ធិ មិនអាចត្រូវបានចាត់ទុកថាបានសារភាពបានឡើយ ។

<u>Code of Civil Procedure (Japan)</u>
**Article 159** (Construction of admission) (excerpt)
1. In cases where a party does not make it clear that such party contests the facts asserted by the adversary party at oral argument, such party shall be deemed to have admitted such facts. However, this shall not apply to cases where, in view of the overall import of the argument, the facts should be deemed to have been contested.
2. A person who has made a statement to the effect that such person is ignorant of the facts shall be presumed to have contested such facts.
**Article 170** (Acts of litigation, etc., in preparations for argument proceedings) (excerpt) > *see the note for Article 89*

## **មាត្រា ៩៧.-** ការសាកល្បងធ្វើការផ្សះផ្សា

តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន ទោះបីជាបណ្តឹងស្ថិតនៅក្នុងដំណាក់កាលណាក៏ដោយ ។

(កំណត់)

សូមមើលមាត្រា 89 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 21 មាត្រា 127 និង មាត្រា 128 នៃក្រមនីតិវិធីរដ្ឋប្បវេណីបារាំង (រីឯមាត្រា 279 នៃក្រមនីតិវិធីអាល្លឺមង់វិញ មានចែងការសាកល្បងធ្វើការផ្សះផ្សាជាកាតព្វកិច្ច ប៉ុន្តែគ្មានចែងអំពីពិន័យពេលធ្វើខុសច្បាប់នេះទេ ដូច្នេះហើយមាត្រានេះចែងដូចក្រមជប៉ុន និង ក្រមបារាំងដែរ) ។

មាត្រានេះគឺជាបទប្បញ្ញត្តិទូទៅនៃនីតិវិធីក្នុងការធ្វើបណ្តឹង ។ រីឯនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលវិញ យើងចែងថា ជាគោលការណ៍ តុលាការត្រូវសាកល្បងធ្វើការផ្សះផ្សា ។ សូមមើលមាត្រា ១០៤ (ការសាកល្បងផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) ។

Code of Civil Procedure (Japan)
**Article 89** (Attempt to compromise)
The court may, at any stage of the suit, attempt to effect a compromise or have a commissioned judge or an assigned judge attempt to effect a compromise.

Code de Procédure Civile (France)
**Article 21**
Il entre dans la mission du juge de concilier les parties.
**Article 127**
Les parties peuvent se concilier, d'elles-mêmes ou à l'initiative du juge, tout au long de l'instance.
**Article 128**
La conciliation est tentée, sauf disposition particulière, au lieu et au moment que le juge estime favorables.

Code of Civil Procedure Rules (Germany)
**Article 279** (Amicable settlement; attempt at conciliation)
1. The court shall near in mind in every stage of the proceedings an amicable settlement of the case or of individual points of controversy. It can refer the parties for an attempt of amicable settlement to a commissioned judge or a requested judge.
2. The personal appearance of the parties may be ordered for an attempt of amicable settlement. If such appearance is ordered, Article 142(2) is applicable *mutatis mutandis*.

## មាត្រា ៩៨.- ការបាត់បង់នូវសិទ្ធិប្តឹងតវ៉ាស្តីអំពីនីតិវិធីនៃបណ្តឹង

១- ក្នុងករណីដែលភាគីម្ខាង ឬ តុលាការបានធ្វើសកម្មភាពបណ្តឹងណាមួយដែលផ្ទុយពីបញ្ញត្តិអំពីនីតិវិធីនៃបណ្តឹង ភាគីអាចប្តឹងតវ៉ាចំពោះសកម្មភាពនោះទៅតុលាការ ហើយអាចអះអាងអំពីមោឃភាពនៃសកម្មភាពនោះបាន ។

២- ក្នុងករណីដែលភាគីដឹង ឬ អាចដឹងអំពីភាពខុសច្បាប់ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ហើយមិនបានធ្វើការប្តឹងតវ៉ានៅពេលសមរម្យទេ ភាគីនោះត្រូវបាត់បង់សិទ្ធិប្តឹងតវ៉ានេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលមិនអាចបោះបង់សិទ្ធិនេះបាន ។

（កំណត់）

សូមមើលមាត្រា 90 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

សិទ្ធិក្នុងការអះអាងភាពផ្ទុយពីបញ្ញត្តិអំពីនីតិវិធីនៃបណ្តឹង និង ការប្តឹងជំទាស់ ត្រូវគេហៅថា ជាសិទ្ធិប្តឹងតវ៉ា（責問権 Rügerecht）（កថាខណ្ឌទី ១）។

ចំណុចសំខាន់នៃមាត្រានេះ គឺកថាខណ្ឌទី ២ ។ ប្រសិនបើភាគីដែលអាចប្តឹងតវ៉ា តែមិនបានប្តឹងតវ៉ា ហើយនៅតែអនុញ្ញាតឱ្យប្តឹងតវ៉ាបាននៅពេលក្រោយ នោះអាចប៉ះពាល់ដល់ស្ថិរភាពនៃនីតិវិធីនៃបណ្តឹង ហើយផ្ទុយនឹងផលប្រយោជន៍សេដ្ឋកិច្ចក្នុងនីតិវិធី ហេតុដូច្នេះ មានចែងកថាខណ្ឌទី ២ ដូចខាងលើនេះ ។ ប៉ុន្តែ វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២ មានន័យថា ក្នុងករណីដែលភាពខុសច្បាប់នេះផ្ទុយពីបញ្ញត្តិបង្ខំ（mandatory/obligatory provisions）ដែលទាក់ទងយ៉ាងខ្លាំងទៅនឹងផលប្រយោជន៍សាធារណៈ ទោះបីជាមានការយឺតយ៉ាវក្នុងការតវ៉ាក៏ដោយ ក៏មិនបាត់បង់នូវសិទ្ធិតវ៉ាដែរ（ឧ. រចនាសម្ព័ន្ធនៃតុលាការ ការដកហូតចៅក្រម និង សមត្ថកិច្ចផ្តាច់មុខ ជាដើម）។

Code of Civil Procedure (Japan)
**Article 90** (Loss of right to raise objection with regard to proceeding)
In cases where a party is aware of a contravention of procedural provisions or has reason to know of such contravention and fails to

object without delay, such party shall lose the right to do so. However, this shall not apply to cases where such right may not be waived.

**មាត្រា ៩៩.-** ការបំបែក និង ការរួមបញ្ចូលរឿងក្តី

១- តុលាការអាចបង្គាប់ឱ្យបំបែក ឬ បញ្ចូលរឿងក្តី ដោយដីកាសម្រេច ឬ អាចលុបចោលដីកាសម្រេចនោះបាន ។

២- ក្នុងករណីតុលាការបានបង្គាប់ឱ្យបញ្ចូលរឿងក្តីដែលមានភាគីខុសគ្នា នៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ នៅពេលភាគីដែលមិនមានឱកាសសាកសួរសាក្សី ដោយសារសាក្សីនោះត្រូវបានសាកសួររួចហើយមុនពេលបញ្ចូលរឿងក្តី បានដាក់ពាក្យសុំសាកសួរសាក្សីនោះ តុលាការត្រូវសាកសួរសាក្សីនោះ ។

(កំណត់)

សូមមើលមាត្រា 152 និង មាត្រា 170 កថាខណ្ឌទី 6 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នេះ មិនអាចប្តឹងជំទាស់បានឡើយ ។ កថាខណ្ឌទី ២ នេះ សំដៅទៅលើសិទ្ធិរបស់ភាគីដែលតុលាការអនុញ្ញាតឱ្យសាកសួរទៅលើសាក្សីដែលតុលាការបានសួររួចហើយមុនពេលបញ្ចូលរឿងក្តីជាថ្មីម្តងទៀត ក្នុងករណីដែលមានពាក្យសុំសាកសួរសាក្សីនោះ ។

Code of Civil Procedure (Japan)
**Article 152** (Consolidation, etc., of oral argument)
1. The court may order the limitation, separation or consolidation of oral argument or cancel such order.
2. In cases where the court orders consolidation of oral argument with regard to cases in which the parties are different, when a party who has had no opportunity to examine a witness makes a motion to examine a witness who has been previously examined, the court shall conduct such examination.
**Article 170** (excerpt) > *see the note for Article 89*

**មាត្រា ១០០.-** ការចូលរួមរបស់អ្នកបកប្រែ ជាអាទិ៍

១- ប្រសិនបើជនដែលទាក់ទងនឹងនីតិវិធីរដ្ឋប្បវេណី មិនអាចយល់ភាសាខ្មែរ ឬ ថ្លង់ ឬ គ តុលាការត្រូវឱ្យមានអ្នកបកប្រែដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ចូលរួមជាមួយនឹងជននោះ ។ ប៉ុន្តែ តុលាការអាចសួរជនដែលថ្លង់ ជាអក្សរ ឬ ឱ្យជនដែលគ ធ្វើសេចក្តីថ្លែងការណ៍ ជាអក្សរបាន ។

២- បញ្ញត្តិស្តីពីអ្នកធ្វើកោសលវិច័យនៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកបកប្រែ លើកលែងតែមានភាពផ្ទុយនឹងលក្ខណៈនោះ ។

(កំណត់)

សូមមើលមាត្រា 154 និង កថាខណ្ឌទី 6 នៃមាត្រា 170 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

ជនមិនអាចយល់ភាសាខ្មែរ ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ សំដៅទៅលើជនបរទេសដែលមិនអាចយល់ភាសាខ្មែរ

ឬ ជនជាតិខ្មែរដែលជាជនជាតិភាគតិចមិនយល់ភាសាខ្មែរ ជាដើម ។

បញ្ញត្តិស្តីពីសម្បថរបស់អ្នកធ្វើកោសលវិច័យ និង បណ្តឹងជំទាស់ចំពោះអ្នកធ្វើកោសលវិច័យ (ឧ. មាត្រា ១៤៥ (បណ្តឹងផាត់ចោលអ្នកជំនាញខាងកោសលវិច័យ) និង មាត្រា ១៤៧ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីការសាកសួរសាក្សី ទម្រង់សម្បថ) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកបកប្រែ ។

Code of Civil Procedure (Japan)
**Article 154** (Attendance of interpreter, etc.)
1. In cases where a person participating in oral argument does not understand Japanese, or is deaf or mute, an interpreter shall be required to attend. However, a deaf or mute person may be questioned or caused to make statements in writing.
2. The provisions relating to an expert witness shall apply *mutatis mutandis* to an interpreter.
**Article 170** (excerpt) > *see the note for Article 89*

## ផ្នែកទី ២ ឯកសារត្រៀម

**មាត្រា ១០១.-** ឯកសារត្រៀម

១- នៅពេលធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចបង្គាប់ឱ្យភាគីដាក់ឯកសារត្រៀមបាន ។

២- នៅក្នុងឯកសារត្រៀម ត្រូវមានសរសេរអំពីមធ្យោបាយតទល់ ឬ ការពារខ្លួន និង សេចក្តីថ្លែងការណ៍ ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនរបស់ភាគីម្ខាងទៀត ។

៣- នៅក្នុងឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការលើកដំបូង ត្រូវមានសរសេរអំពីការឆ្លើយតប ចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរទាមទារនៅក្នុងពាក្យបណ្តឹង និង ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង និង អង្គហេតុដើម្បីតវ៉ាចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង ជាអាទិ៍ ។

(កំណត់)

សូមមើលមាត្រា 161 និង មាត្រា 170 កថាខណ្ឌទី 1 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ ឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការលើកដំបូង (កថាខណ្ឌទី ៣) ត្រូវហៅថា "ឯកសារចម្លើយ" ។ មាត្រានេះកំណត់អំពីសិទ្ធិអំណាចរបស់តុលាការក្នុងការបង្គាប់ឱ្យភាគីដាក់ឯកសារត្រៀម និង អំពីខ្លឹមសារនៃឯកសារត្រៀមរបស់ដើមចោទ និង ចុងចម្លើយ ។ ឯកសារត្រៀម ជាឯកសារផ្ទុកនូវចំណុចជាក់លាក់សម្រាប់ការពារការទាមទារ តទល់រវាងភាគី ។ ឯកសារត្រៀមមានសារៈសំខាន់សម្រាប់ដំណើរការដោះស្រាយបណ្តឹងឱ្យបានឆាប់រហ័ស ដោយហេតុថា តុលាការពឹងផ្អែកទៅលើឯកសារទាំងនោះ ដើម្បីរៀបចំនូវចំណុចវិវាទនៃរឿងក្តី អង្គហេតុដែលមាន ឬ គ្មានវិវាទ ដើម្បីឈានទៅដំណាក់កាលបន្ទាប់នៃនីតិវិធី ។

Code of Civil Procedure (Japan)
**Article 161** (Preliminary document)
1. Oral argument shall be prepared for in writing.
2. Preliminary documents shall include the following matters:
i. offensive or defensive measures;
ii. statements against the claims and offensive or defensive measures of the adversary party.
3. During an oral argument at which the adversary party is not present in court, facts shall not be asserted except those facts written in preliminary documents (provided that they have been served on the adversary party or the adversary party submits a document stating that they were received by the adversary party).
**Article 170** (Acts of litigation, etc., in preparations for argument proceedings) (excerpt)
1. The court may cause the parties to submit preliminary documents.

**មាត្រា ១០២.-** ពេលវេលាដែលត្រូវដាក់ឯកសារត្រៀម ជាអាទិ៍

តុលាការអាចកំណត់អំឡុងពេលដែលត្រូវដាក់ឯកសារត្រៀមលើកដំបូងរបស់ចុងចម្លើយ ឬ ឯកសារត្រៀមដែលមានសរសេរអំពីការអះអាងចំពោះចំណុចជាក់លាក់ណាមួយ ឬ ត្រូវធ្វើការស្នើសុំឱ្យពិនិត្យភស្តុតាងដែលទាក់ទងនឹងចំណុចជាក់លាក់ណាមួយ ។

(កំណត់)

សូមមើលមាត្រា 162 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ ការកំណត់នូវពេលវេលាដែលត្រូវដាក់ឯកសារត្រៀម ដែលសរសេរអំពីចំណុចពិសេស ឬ ត្រូវដាក់ភស្តុតាងដោយតុលាការនោះ មានសារៈសំខាន់ណាស់ ដើម្បីធ្វើឱ្យបណ្តឹងមានដំណើរការយ៉ាងឆាប់ និង មានផលយ៉ាងល្អផង ។

Code of Civil Procedure (Japan)
**Article 162** (Period of submittal of preliminary document)
The presiding judge may designate the period within which a written answer or a preliminary document in which an assertion relating to a particular matter is written must be submitted or evidence relating to a particular matter must be offered.

## ផ្នែកទី ៣ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

**មាត្រា ១០៣.-** គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវរៀបចំនូវសេចក្តីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលគូភាគីយល់មិនស្របគ្នា និង រៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តីនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានល្អិតល្អន់ ។

(កំណត់)

មាត្រានេះ គឺជាបញ្ញត្តិដែលចែងអំពីគោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង បញ្ជាក់ឱ្យបាន

ច្បាស់លាស់ថា នីតិវិធីត្រៀមនេះជានីតិវិធីដែលត្រូវរៀបចំនូវចំណុចវិវាទនៃរឿងក្តី និង ភស្តុតាង ហើយកំណត់អំពីការទទួលខុសត្រូវរបស់តុលាការផងដែរ ។

**មាត្រា ១០៤.-** ការសាកល្បងផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវសាកល្បងផ្សះផ្សាជាដំបូងសិន លើកលែងតែយល់ឃើញថាមិនសមរម្យ ។

(កំណត់)

សូមមើលមាត្រា ៩៧ (ការសាកល្បងធ្វើការផ្សះផ្សា) ដែលមានចែងជាបទប្បញ្ញត្តិទូទៅអំពីការសាកល្បងផ្សះផ្សា ។ រីឯមាត្រានេះ ជំរុញការផ្សះផ្សា ដោយមានចែងថា តុលាការត្រូវធ្វើការផ្សះផ្សាជាបឋមនៅពេលធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល លើកលែងតែរឿងក្តីដែលបានកំណត់ ឬ ករណីពិសេសណាមួយ ។ មាត្រា 840 នៃក្រមនីតិវិធីរដ្ឋប្បវេណីបារាំង (tribunal d'instance) និង មាត្រា 279 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាល្លឺមង់ មានចែងអំពីករណីយកិច្ចរបស់តុលាការក្នុងការធ្វើការផ្សះផ្សា ។

មាត្រានេះគឺជាមាត្រាមួយជំនួស "គោលការណ៍ដែលត្រូវធ្វើការផ្សះផ្សាមុនជាដាច់ខាត" (ដែលប្រទេសកម្ពុជាកំពុងអនុវត្ត) ។ តាមលក្ខណៈនៃរឿងក្តី ឬ បំណងនៃភាគី មានករណីខ្លះដែលមិនអាចធ្វើការផ្សះផ្សាជាដំបូងបាន ឬ មិនគួរធ្វើការផ្សះផ្សាជាដំបូង ។ ដូច្នេះហើយ ប្រសិនបើយើងចែងអំពីនីតិវិធីដែលតម្រូវឱ្យធ្វើការផ្សះផ្សា ជាដាច់ខាតមុននឹងធ្វើការពិនិត្យ និង ជំនុំជម្រះក្តីនោះ វានឹងអាចនាំឱ្យមានការយឺតយ៉ាវទៅវិញ ដោយសារត្រូវកំណត់កាលបរិច្ឆេទសម្រាប់ការផ្សះផ្សាចំពោះរឿងក្តីដែលមិនបាច់ធ្វើការផ្សារផ្សាមុន ។ ហើយម្យ៉ាងទៀត ប្រសិនបើដើមចោទមិនបានបង្ហាញខ្លួននាកាលបរិច្ឆេទដែលត្រូវធ្វើការផ្សះផ្សានោះទេ ត្រូវចាត់ទុកថា ដើមចោទបានដកបណ្តឹងទៅវិញ នេះគឺជាការមួយមិនសមហេតុសមផលទេ (ប្រសិនបើមិនអាចផ្សះផ្សាបានទេ ត្រូវតែធ្វើការជំនុំជម្រះហើយចេញសាលក្រមវិញ) ។ សឹងតែគ្រប់ប្រទេស ពេលចូលដល់ដំណាក់កាលជំនុំជម្រះ តុលាការនឹងរកឱកាសធ្វើការផ្សះផ្សា (យោងទៅតាមច្បាប់ប្រទេសបារាំង ពីមុនគេយក "គោលការណ៍ដែលត្រូវធ្វើការផ្សះផ្សាមុនជាដាច់ខាត" ប៉ុន្តែនាទសវត្សឆ្នាំ 1970 គេបាននិរាករប្រព័ន្ធនោះ ហើយសព្វថ្ងៃនេះ ភាគីដើមចោទអាចជ្រើសរើស ការផ្សះផ្សាជាមុន ឬ មិនធ្វើការផ្សះផ្សាជាមុនដោយខ្លួនឯងបាន) ។

នៅក្នុងមាត្រានេះ មានចែងថា "លើកលែងតែក្នុងករណីដែលយល់ឃើញថាមិនសមរម្យ" នេះមានន័យដូចជាករណីដែលសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលដើមចោទទាមទារដោយការប្តឹង មិនអាចអនុញ្ញាតឱ្យគូភាគីដោះស្រាយ តាមការព្រមព្រៀងរវាងគូភាគីតែប៉ុណ្ណោះបាន ឬ ករណីដែលច្បាស់ជាគូភាគីគ្មានបំណងនឹងស្រុះស្រួលគ្នាសោះ ជាដើម ។ ចំពោះករណីក្រៅពីករណីដែលយល់ឃើញថាមិនសមរម្យនេះ តុលាការគួរតែរកឱកាសធ្វើការផ្សះផ្សា ទៅតាមកាលៈទេសៈ

ទោះបីជានៅដំណាក់កាលដំបូងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលក្តី ឬ ពេលកំពុងធ្វើនីតិវិធីត្រៀមក្តី ឬ នៅដំណាក់កាលចុងក្រោយនៃនីតិវិធីត្រៀមក្តី ។

នៅពេលកំពុងធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប្រសិនបើចៅក្រមយល់ឃើញថា មានលទ្ធភាពច្រើនក្នុងការផ្សះផ្សា ចៅក្រមគួរគិតពិចារណាប្តូរគោលបំណងនៃកាលបរិច្ឆេទនោះ ពីនីតិវិធីត្រៀមទៅជាកាលបរិច្ឆេទនៃការផ្សះផ្សាវិញ ។ នៅក្នុងនីតិវិធីធ្វើការផ្សះផ្សា តុលាការអាចសួរម្តងម្នាក់បាន (សួរភាគីម្ខាងដោយឱ្យភាគីម្ខាងទៀតចេញក្រៅ) ប៉ុន្តែរបៀបធ្វើនេះនឹងអាចមានឧបសគ្គធំ ដូច្នេះហើយគួរតែចែងថា ប្រសិនបើគ្មានការយល់ព្រមពីភាគីទាំងសងខាងទេ មិនអាចសួរម្តងម្នាក់បាននោះទេ ។

Code de Procédure Civile (France)
**Article 840**
Le juge s'efforce de concilier les parties.
La tentative de conciliation peut avoir lieu das le cabinet du juge.

Code of Civil Procedure Rules (Germany)
**Article 279** (Amicable settlement; attempt at conciliation)
1. The court shall near in mind in every stage of the proceedings an amicable settlement of the case or of individual points of controversy. It can refer the parties for an attempt of amicable settlement to a commissioned judge or a requested judge.
2. The personal appearance of the parties may be ordered for an attempt of amicable settlement. If such appearance is ordered, Article 142(2) is applicable *mutatis mutandis*.

**មាត្រា ១០៥.–** កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

១- នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីសងខាងអាចចូលរួមបាន ។(1)

២- កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មិនចាំបាច់បើកជាសាធារណៈទេ ។ ប៉ុន្តែ តុលាការអាចអនុញ្ញាតឱ្យអ្នកដែលតុលាការយល់ឃើញថាសមរម្យ ចូលស្តាប់ជាអ្នកសង្កេតការណ៍បាន ។(2)

(កំណត់)

សូមមើលមាត្រា 169 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(1) ដោយយោងទៅតាមការគោរពគោលការណ៍ចំពោះមុខ (មាត្រា ៣ (សិទ្ធិទាមទារឱ្យសាកសួរ គោលការណ៍ចំពោះមុខ) កថាខណ្ឌទី ២) តុលាការត្រូវផ្តល់ឱកាសឱ្យភាគីសងខាងចូលរួមក្នុងការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (ដែលហៅថា ការធ្វើជាសាធារណៈចំពោះភាគី) ហេតុដូច្នេះ តុលាការត្រូវកំណត់កាលបរិច្ឆេទ ដើម្បីធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយកោះហៅភាគីសងខាង ។ ប៉ុន្តែ ទោះបីនៅកាលបរិច្ឆេទដែលបានកំណត់ ភាគីម្ខាងអវត្តមានក៏ដោយ ក៏ស្របទៅនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ នេះដែរ ។

(2) នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ខុសពីការទាញហេតុផលដោយផ្ទាល់មាត់ និង មិនបាច់ធ្វើនៅក្នុងសាលសវនាការទេ គឺអាចធ្វើនៅក្នុងបន្ទប់ធម្មតាណាមួយដែលដាក់ឈ្មោះថា "ជាបន្ទប់ត្រៀម" ក៏បានដែរ ។ ប៉ុន្តែ

មិនចាំបាច់ហាមឃាត់មិនឱ្យអ្នកផ្សេងចូលស្តាប់ជាអ្នកសង្កេតការណ៍ទេ គឺការអនុញ្ញាតឱ្យអ្នកផ្សេងចូលស្តាប់ ឬ មិនឱ្យ គឺជាការសម្រេចដោយឆន្ទានុសិទ្ធិរបស់តុលាការ ប៉ុន្តែ តុលាការត្រូវគិតពិចារណាលើមូលហេតុដែលអ្នកនោះចង់ស្តាប់ ឬ ឆន្ទៈរបស់ភាគី ជាដើម ។ ប្រសិនបើអ្នកដែលមានទំនាក់ទំនងជាមួយនឹងរឿងក្តី ស្នើសុំចូលស្តាប់ជាអ្នកសង្កេតការណ៍ ហើយការឱ្យចូលស្តាប់នោះមិននាំឱ្យមានឧបសគ្គក្នុងការជំនុំជម្រះទេ តុលាការអាចអនុញ្ញាតឱ្យអ្នកនោះចូលស្តាប់ជាអ្នកសង្កេតការណ៍បាន ។ ប៉ុន្តែ ក្នុងករណីដែលការចូលស្តាប់របស់អ្នកនោះ នឹងអាចធ្វើឱ្យភាគីណាមួយមានភាពរួញរាខាងផ្លូវចិត្ត មិនត្រូវអនុញ្ញាតឱ្យចូលស្តាប់ជាអ្នកសង្កេតការណ៍ទេ ។

Code of Civil Procedure (Japan)
**Article 169** (Date set for preparations for argument proceedings)
1. Preparations for argument proceedings shall be conducted at a date which both parties are able to attend.
2. The court may admit such persons, as deemed proper, to listen to the proceedings. However, with regard to a person whom a party has requested to attend, unless it deems that there exists danger of causing hindrance to the conduct of prceedings, the court sahll admit such person to listen.

**មាត្រា ១០៦.-** សកម្មភាពនៃបណ្តឹង ជាអាទិ៍ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការអាចចេញដីកាសម្រេចដែលទាក់ទងនឹងការស្នើសុំឱ្យពិនិត្យភស្តុតាង (1) ឬ ដីកាសម្រេចផ្សេងទៀតដែលអាចសម្រេចបាន ក្រៅពីកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ (2) និង អាចពិនិត្យភស្តុតាងជាឯកសារ ដោយមានកម្រិតចាំបាច់ដើម្បីរៀបចំចំណុចវិវាទនៃរឿងក្តី និងភស្តុតាង ។(3)

(កំណត់)

សូមមើលមាត្រា 170 កថាខណ្ឌទី 2 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(1) ឧទាហរណ៍ ដីកាសម្រេចបង្គាប់ឱ្យដាក់ឯកសារ ការស្នើសុំឱ្យផ្ញើឯកសារ ការប្រគល់កិច្ចការកោសលវិច័យ ដីកាសម្រេចយក ឬ មិនយកភស្តុតាងដែលភាគីស្នើសុំឱ្យពិនិត្យ ជាដើម ។

(2) ឧទាហរណ៍ ការសម្រេចសេចក្តីស្តីពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យបន្ថែម ឬ ប្តូរកម្មវត្ថុនៃបណ្តឹង ការសម្រេចសេចក្តីស្តីពីការអនុញ្ញាតការចូលរួមជួយអន្តរាគមន៍ ឬ មិនអនុញ្ញាត ជាដើម ។

(3) តាមធម្មតា ការពិនិត្យភស្តុតាងត្រូវធ្វើឡើងក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលធ្វើជាសាធារណៈ ប៉ុន្តែ ការពិនិត្យភស្តុតាងជាឯកសារ ត្រូវធ្វើឡើងដោយការអានឯកសារនោះដោយចៅក្រម ហេតុដូច្នេះបើប្រៀបធៀបទៅនឹងការសាកសួរសាក្សី ជាដើម មិនសូវមានទំនាក់ទំនងខ្លាំងនឹងគោលការណ៍បើកជាសាធារណៈទេ ហើយម្យ៉ាងទៀត ដើម្បីរៀបចំចំណុចវិវាទនៃរឿងក្តីឱ្យបានត្រឹមត្រូវ ភាគច្រើនគេត្រូវការភស្តុតាងជាឯកសារ ដូច្នេះហើយបានជាមាត្រានេះមានគោលបំណង អនុញ្ញាតឱ្យតុលាការពិនិត្យភស្តុតាងជាឯកសារ ដោយមានកម្រិតចាំបាច់ដើម្បីរៀបចំចំណុចវិវាទនៃរឿងក្តី ។

Code of Civil Procedure (Japan)
**Article 170** (Acts of litigation, etc., in preparations for argument proceedings) (excerpt)
2. On a date set for the preparations for argument proceedings, the court may render decisions with regard to the offering of evidence or any other decisions which may be rendered on an occasion other that a date set for oral argument, and may examine documents (including articles prescribed in Article 231).

**មាត្រា ១០៧.-** ការបញ្ជាក់អំពីអង្គហេតុដែលនឹងត្រូវបំភ្លឺ ជាអាទិ៍

នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយបានបញ្ចប់ការរៀបចំចំណុចវិវាទនៃរឿងក្ដី និង ភស្តុតាងហើយ នោះតុលាការត្រូវធ្វើការបញ្ជាក់ជាមួយភាគី នូវអង្គហេតុដែលនឹងត្រូវបំភ្លឺនៅពេលពិនិត្យភស្តុតាង នៅពេលក្រោយ ។

(កំណត់)

សូមមើលមាត្រា 170 កថាខណ្ឌទី 6 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ដែលមានចែងឱ្យអនុវត្តតាមមាត្រា 165 ។ គោលគំនិតនៃមាត្រានេះគឺ បន្ទាប់ពីបានរៀបចំចំណុចវិវាទនៃរឿងក្ដីហើយ តុលាការត្រូវសួរបញ្ជាក់ភាគីសងខាង អំពីលទ្ធផលនៃការរៀបចំនេះ ដើម្បីឱ្យមានឯកភាពគ្នា និង ដើម្បីត្រៀមធ្វើការពិនិត្យលើភស្តុតាងឱ្យបានល្អិតល្អន់ នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ។

Code of Civil Procedure (Japan)
**Article 165** (Confirmation of facts which should be proven, etc.)
1. The court shall confirm with the parties the facts which should be proven by the following examination of evidence at the end of the preliminary oral argument.
2. The presiding judge may, upon determining it proper, cause the parties to submit a document which summarizes the conclusions of the arrangement of points at issue and evidence in the preliminary oral argument at the conclusion thereof.
**Article 170** (Acts of litigation, etc., in preparations for argument proceedings) (excerpt)
6. The provisions of Articles 148 to 151 inclusive, Article 152, paragraph 1, and Articles 153 to 159 inclusive, 162, 165 and 166 shall apply *mutatis mutandis* to preparations for argument proceedings.

**មាត្រា ១០៨.-** អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ក្រោយពីបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហើយ ភាគីមិនអាចដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មីបានទៀតទេ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមធ្យោបាយនោះ ទាក់ទងនឹងចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់ខ្លួន ឬ ករណីដែលការដាក់មធ្យោបាយថ្មីនោះ មិនធ្វើឱ្យមានការយឺតយ៉ាវដល់នីតិវិធីនៃបណ្ដឹង ឬ ករណីដែលភាគីបានធ្វើសេចក្ដីបញ្ជាក់ដំបូងថា ខ្លួនមិនអាចដាក់មធ្យោបាយនោះមុនពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយគ្មានកំហុសធ្ងន់ធ្ងរឡើយ ។

(កំណត់)

មាត្រា 174 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចែងថា "ភាគីដែលបានដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន ក្រោយពីបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវពន្យល់ទៅភាគីម្ខាងទៀតនូវមូលហេតុដែលខ្លួនមិនអាចដាក់មធ្យោបាយនោះមុនពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប្រសិនបើភាគីម្ខាងទៀតទាមទារ" ។ បញ្ញត្តិនេះមិនចែងពិសេសអំពីអានុភាពបាត់បង់សិទ្ធិដាក់មធ្យោបាយនោះទេ ។ បញ្ញត្តិនេះត្រូវបានកែប្រែពីបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីចាស់ ដោយសារគេយល់ឃើញថា តាមច្បាប់ចាស់ ការបិទសិទ្ធិដាក់មធ្យោបាយក្រោយនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះ ធ្វើឱ្យភាគីដាក់ឯកសារដែលមិនសូវមានសារៈសំខាន់ដល់បណ្ដឹងជាច្រើន ហើយនាំឱ្យមានការយឺតយ៉ាវក្នុងការរៀបចំចំណុចវិវាទនៃរឿងក្ដីទៅវិញ ហេតុដូច្នេះគេមិនសូវប្រើនីតិវិធីត្រៀមដែលធ្វើឡើងដោយស្រេចលើចិត្តរបស់ភាគីទេ ។ ប៉ុន្តែ មាត្រា 174 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនសព្វថ្ងៃនេះ ចែងមិនច្បាស់លាស់អំពីកាតព្វកិច្ចពន្យល់មូលហេតុនោះទេ ហើយមានការលំបាកក្នុងការអនុវត្តផងដែរ ដូច្នេះហើយ ចំពោះព្រះរាជាណាចក្រកម្ពុជាវិញ មិនសមរម្យនឹងធ្វើតាមនេះទេ ។ ក្នុងចំណោមច្បាប់ប្រទេសផ្សេងៗទៀត ភាគច្រើនក៏ចែងអំពីអានុភាពបាត់បង់សិទ្ធិដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនដែរ ។ម្យ៉ាងទៀត នៅក្នុងក្រមនេះ មានចែងថា មុនពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវតែធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាចាំបាច់ ដូច្នេះហើយ មូលដ្ឋាននៃបញ្ញត្តិនេះខុសគ្នាពីច្បាប់ជប៉ុន ហេតុនេះហើយបានជាមាត្រា 174 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុននោះ មិនអាចយកទៅអនុវត្តនៅព្រះរាជាណាចក្រកម្ពុជាបានទេ ។

ប៉ុន្តែ ពិតមែនហើយថា មានការលំបាកក្នុងការសម្របសម្រួលរវាងអានុភាពបាត់បង់សិទ្ធិ និង ផលនៃការជំនុំជម្រះ ។ ដូច្នេះ នៅប្រទេសកម្ពុជា ចំពោះថា តើត្រូវបន្ដឹងអានុភាពបាត់បង់សិទ្ធិត្រឹមណា (តើត្រូវអនុញ្ញាតឱ្យមានករណីលើកលែងត្រឹមណា?) គួរតែយកទៅគិតពិចារណាដោយសមស្របទៅនឹងការយល់ឃើញរបស់អ្នកច្បាប់នៅប្រទេសកម្ពុជានៅពេលអនាគតតទៅទៀត ។ ទោះជាយ៉ាងណាក៏ដោយ ក៏មាត្រានេះបានចែងជួយអ្នកដែលមិនបានដាក់មធ្យោបាយ ដោយគ្មានហេតុដែលឱ្យមានការទទួលខុសត្រូវទៅអ្នកនោះ ជាដើម ដែរ ។

<u>Code of Civil Procedure (Japan)</u>
**Article 167** (Advancement of offensive or defensive measures after conclusion of preliminary oral argument)
A party who advanced offensive or defensive measures after the conclusion of preliminary oral argument shall, if the adversary party requests, explain to the adversary party the reason why such measures could not have been advanced before the conclusion of preliminary oral argument.
**Article 174** (Advancement of offensive or defensive measures after conclusion of preparations for argument proceedings)
The provisions of Article 167 shall apply *mutatis mutandis* to a party who advanced offensive or defensive measures after the conclusion of preparations for argument proceedings.

**មាត្រា ១០៩.-** កំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

តុលាការត្រូវឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅគ្រប់កាលបរិច្ឆេទនីមួយៗ ។

(កំណត់)

សូមមើលមាត្រា 88 នៃបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន និង មាត្រា 160 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ នៅក្នុងកាលបរិច្ឆេទនីមួយៗនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មានសកម្មភាពច្រើនដែលបានកើតឡើងដោយចៅក្រម ភាគី ឬ អ្នកតំណាង អ្នកជំនួយការ សកម្មភាពទាំងនេះអាចបញ្ជាក់បាន ប្រសិនបើមិនមានកត់ត្រាទុកដូចនេះ ទើបមាត្រានេះកំណត់ឱ្យតុលាការបង្គាប់ឱ្យក្រឡាបញ្ជីកត់ត្រានៅក្នុងកំណត់ហេតុ ។ កំណត់ហេតុនេះមានសារៈសំខាន់ផងដែរ សម្រាប់តុលាការជាន់ខ្ពស់ក្នុងការពិនិត្យអំពីចំណាត់ការរបស់តុលាការដែលបានធ្វើកំណត់ហេតុនោះ ។

<u>Rules of Civil Procedure (Japan)</u>
**Article 88** (Record of preparations for argument proceedings, etc./The Code Article 170, etc.) (excerpt)
1. In the record of preparations for argument proceedings, the matters designated in Article 161 (Preliminary document), paragraph 2 of the Codes shall be entered according to the statement of the parties, and in particular, with regard to evidence, the offering thereof shall be clearly indicated.
4. In addition to the provisions of paragraph 1 and the preceding paragraph, Article 160 (Record of oral argument) of the Code and the provisions relating to a record of oral argument in these Rules shall apply *mutatis mutandis* to a record of the preparations for argument proceedings.

<u>Code of Civil Procedure (Japan)</u>
**Article 160** (Record of oral argument)
1. The court clerk shall compile a record regarding oral argument for each of the dates.
2. In cases where a party or any other interested person objects to a statement in the record, such fact shall be entered in the record.
3. Compliance with the provisions relating to the formalities of oral argument may be proved only by means of the record. However, this shall not apply in cases where the record is lost or destroyed.

**មាត្រា ១១០.–** ចំណុចជារូបមន្តនៃកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

១- នៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវកត់ត្រានូវចំណុចខាងក្រោមនេះ :

**ក**- សញ្ញាណរឿងក្តី ។

**ខ**- ឈ្មោះចៅក្រម និង ក្រឡាបញ្ជី ។

**គ**- ឈ្មោះភាគី អ្នកតំណាង អ្នកជំនួយការ និង អ្នកបកប្រែដែលបានបង្ហាញខ្លួន ។

**ឃ**- ពេលវេលា និង ទីកន្លែង ។

២- ប្រធានក្រុមប្រឹក្សាជំនុំជម្រះ និង ក្រឡាបញ្ជី ត្រូវចុះហត្ថលេខាលើកំណត់ហេតុដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

សូមមើលមាត្រា 88 និង មាត្រា 66 នៃបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

កំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវបានចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ និង ក្រឡាបញ្ជី រីឯ ភាគី អ្នកតំណាង ជំនួយការ អ្នកបកប្រែ មិនតម្រូវឱ្យចុះហត្ថលេខាឡើយ ។

<u>Rules of Civil Procedure (Japan)</u>
**Article 88** (Record of preparations for argument proceedings, etc./The Code Article 170, etc.) (excerpt) > see the note for Article *109*

**Article 66** (Formal matters to be entered in record of oral argument/The Code Article 160)
1. The following matters shall be entered in the record of oral argument:
i. indication of the case;
ii. names of the judge and the court clerk;
iii. name of the public prosecutor;
iv. names of the parties, representatives, assistants, and interpreters who have appeared;
v. the date, time and place of argument; and
vi. a statement that the argument has been open to the public, or in cases where it has not been open, that fact and the reasons therefore.
2. The court clerk shall enter his or her name and affix his or her seal on the record referred to in the preceding paragraph, and the presiding judge shall affix his or her seal of confirmation thereon.
3. In cases referred to in the preceding paragraph, when the presiding judge is unable to affix his or her seal, an associate judge of the panel shall affix his or her seal of confirmation stating the reason for doing so. When the judges are unable to affix their seal, it is sufficient that the court clerk states that fact.

**មាត្រា ១១១.-** ចំណុចសារធាតុនៃកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវកត់ត្រានូវសេចក្ដីសង្ខេបអំពីសកម្មភាពដែលបានធ្វើឡើងនៅកាលបរិច្ឆេទនីមួយៗ ហើយជាពិសេស ត្រូវកត់ត្រាឱ្យបានច្បាស់លាស់នូវចំណុចខាងក្រោមនេះ :

**ក-** ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និង ចម្លើយតបរបស់ចុងចម្លើយចំពោះការទាមទារនោះ ។

**ខ-** ខ្លឹមសារនៃអង្គហេតុដែលបានអះអាង និង ការស្នើសុំឱ្យពិនិត្យភស្ដុតាង ។

**គ-** ការទទួលស្គាល់ ឬ មិនទទួលស្គាល់របស់ភាគី ចំពោះអង្គហេតុដែលបានអះអាងដោយភាគីម្ខាងទៀត និង ការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះភាពត្រឹមត្រូវនៃឯកសារ ។

**ឃ-** ការដកពាក្យបណ្ដឹង ការផ្សះផ្សា ការលះបង់ការទាមទារ និង ការទទួលស្គាល់ការទាមទារ ។

**ង-** ចំណុចដែលតុលាការបានបង្គាប់ឱ្យកត់ត្រា និង ចំណុចដែលតុលាការអនុញ្ញាតឱ្យកត់ត្រា តាមការទាមទាររបស់ភាគី ។

**ច-** ការសម្រេចសេចក្ដីដែលបានធ្វើឡើងនៅកាលបរិច្ឆេទនោះ ដោយមិនធ្វើជាលាយល័ក្ខណ៍អក្សរ ។

(កំណត់)

សូមមើលមាត្រា 88 និង មាត្រា 67 កថាខណ្ឌទី 1 នៃបទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

ឧទាហរណ៍នៃចំណុច **ច** មានដូចជា ដីកាសម្រេចលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួនដែលបានដាក់យឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ និង ដីកាសម្រេចយក ឬ មិនយកភស្ដុតាងដែលភាគីស្នើសុំឱ្យពិនិត្យ ជាដើម ។

Rules of Civil Procedure (Japan)
**Article 88** (Record of preparations for argument proceedings, etc./The Code Article 170, etc.) (excerpt) > *see the note for Article 109*
**Article 67** (Substantive matters to be entered in record of oral argument/The Code Article 160)
1. In the record of oral argument, the summary of the argument shall be entered, and in particular, the following matters shall be indicated clearly:
i. withdrawal of the suit, compromise, abandonment or acknowledgment of the claim, and admission;
ii. testimonies of witness, the parties themselves and expert witnesses;
iii. whether oaths of witnesses, the parties themselves and expert witnesses were administered or not, and if not, the reason for

which oaths of the witnesses or the expert witnesses were not administered;
iv. result of inspection;
v. matters the presiding judge has ordered to be included and matters permitted to be included upon request of the party;
vi. decisions rendered other than by written means; and
vii. pronouncements of decisions.

2. Notwithstanding the provisions of the preceding paragraph, in cases where the suit has concluded other than by a decision, the testimonies of witnesses, the parties themselves and expert witnesses, and the result of inspection may be omitted from the record with the permission of the presiding judge, However, this shall not apply to cases where a party requests, within a week of the day it knows of the conclusion of the suit, the entry thereof.

**មាត្រា ១១២.-** ការប្ដឹងតវ៉ាចំពោះសេចក្ដីកត់ត្រានៃកំណត់ហេតុ ស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជាអាទិ៍

១- ក្នុងករណីដែលភាគី ឬ អ្នកដទៃទៀតដែលពាក់ព័ន្ធ ប្ដឹងតវ៉ាចំពោះសេចក្ដីកត់ត្រានៅក្នុងកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះ ត្រូវកត់សេចក្ដីប្ដឹងតវ៉ានេះ នៅក្នុងកំណត់ហេតុនោះ ។

២- ភាពត្រឹមត្រូវក្នុងការអនុវត្តតាមបញ្ញត្តិទាក់ទងនឹងរបៀបធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល អាចបញ្ជាក់បាន ដោយកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលតែប៉ុណ្ណោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកំណត់ហេតុនេះបានបាត់ ឬ បានវិនាស ។

(កំណត់)

សូមមើលមាត្រា 88 នៃបទប្បញ្ញត្តិស្ដីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន និង មាត្រា 160 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

នៅពេលមានការតវ៉ាអំពីកំណត់ហេតុ ប្រសិនបើក្រឡាបញ្ជីយល់ឃើញថា ការតវ៉ានេះត្រឹមត្រូវ ឬ ចៅក្រមយល់ឃើញថា ការតវ៉ានេះត្រឹមត្រូវ ហើយបង្គាប់ឱ្យក្រឡាបញ្ជីកែតម្រូវ នោះក្រឡាបញ្ជីត្រូវកែតម្រូវ តែបើយល់ឃើញថា ការតវ៉ានោះមិនត្រឹមត្រូវ នោះក្រឡាបញ្ជីត្រូវកត់ត្រាសេក្ដីតវ៉ានៅក្នុងកំណត់ហេតុនេះ ។

Rules of Civil Procedure (Japan)
**Article 88** (Record of preparations for argument proceedings, etc./The Code Article 170, etc.) (excerpt) > *see the note for Article 109*

Code of Civil Procedure (Japan)
**Article 160** (Record of oral argument) > see the note for Article 109

## ផ្នែកទី ៤ ការទាញហេតុផលដោយផ្ទាល់មាត់

**មាត្រា ១១៣.-** ការកំណត់កាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់

នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានចប់សព្វគ្រប់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅគូភាគីមកចូលរួម ។

(កំណត់)

ការដឹកនាំនីតិវិធី គឺជាតួនាទីរបស់តុលាការ ដូចនេះ នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវកំណត់កាលបរិច្ឆេទសម្រាប់នីតិវិធីបន្ទាប់ គឺ ការទាញហេតុផលដោយផ្ទាល់មាត់ ។

**មាត្រា ១១៤.-** ភាពចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់

១- ដើម្បីចេញសាលក្រមទៅលើបណ្តឹង តុលាការចាំបាច់ត្រូវតែឆ្លងកាត់នូវការទាញហេតុផលដោយផ្ទាល់មាត់ ។ ប៉ុន្តែ ចំពោះរឿងក្តី ឬ ចំណុចណាដែលត្រូវសម្រេចដោយដីកាសម្រេច តុលាការត្រូវកំណត់ថា ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬ មិនត្រូវធ្វើ ។(1)

២- ក្នុងករណីដែលមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដោយអនុលោមទៅតាមវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចសួរភាគីបាន ។(2)

៣- បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ ។(3)

(កំណត់)

(1) សូមមើលមាត្រា 87 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ នីតិវិធីរដ្ឋប្បវេណី ជាគោលការណ៍ ចាំបាច់ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ និង ត្រូវចេញសាលក្រម (ការទាញហេតុផលដោយផ្ទាល់មាត់ជាចាំបាច់ = នីតិវិធីចេញសាលក្រម) ។ រីឯដីកាសម្រេចដែលជាប្រភេទមួយនៃការសម្រេចសេចក្តី ត្រូវបានប្រើ ក្នុងករណីដែលសម្រេចអំពីចំណុចបន្ទាប់បន្សំនៃនីតិវិធីរដ្ឋប្បវេណី (ឧទាហរណ៍ មាត្រា ១៨ (ការចាត់ចែងបណ្តឹងខុសសមត្ថកិច្ចសាលាជម្រះក្តី) និង មាត្រា ១៩ (ការផ្ទេរដើម្បីជៀសវាងពីការយឺតយ៉ាវ ជាអាទិ៍)) ឬ ចំណុចទាក់ទងនឹងការដឹកនាំនីតិវិធី (ឧទាហរណ៍ មាត្រា ៩១ (បណ្តឹងតវ៉ាចំពោះការដឹកនាំនីតិវិធីបណ្តឹង)) ហើយក្នុងករណីដូចនេះ តុលាការអាចសម្រេច ដោយមិនចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់បាន (ការទាញហេតុផលដោយផ្ទាល់មាត់តាមឆន្ទៈរបស់ចៅក្រម = នីតិវិធីចេញដីកាសម្រេច) ។ម្យ៉ាងទៀត នីតិវិធីនៃវិធានការបណ្តោះអាសន្ន និង នីតិវិធីនៃការអនុវត្តដោយបង្ខំ ក៏ជានីតិវិធីចេញដីកាសម្រេចដែរ ។

(2) ការសួរ (ក្នុងកថាខណ្ឌទី ២ នេះ) គឺជាការឱ្យភាគីមានឱកាសធ្វើសេចក្តីថ្លែងការណ៍ ដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរ ដោយឡែកៗ មិនតាមទម្រង់ដែលបានកំណត់ ។ ហេតុដូច្នេះ តុលាការមិនចាំបាច់បើកកាលបរិច្ឆេទជាសាធារណៈ ឬ ឱ្យគូភាគីទាំងសងខាងចូលរួមឡើយ ។

(3) ឧទាហរណ៍ មាត្រា ៨១ (ការលើកបណ្តឹងចោល ដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់) គឺជាករណីលើកលែងនៃវាក្យខណ្ឌទី ១ កថាខណ្ឌទី ១ នៃមាត្រានេះ ។

Code of Civil Procedure (Japan)
**Article 87** (Necessity of oral argument)
1. The parties shall conduct oral argument in court with regard to the suit. However, in a case which is to be decided by a ruling, the court shall decide whether or not oral argument should be conducted.
2. In cases where no oral argument is conducted in accordance with the proviso of the preceding paragraph, the court may interrogate the parties.
3. The provisions of the preceding two paragraphs shall not apply to those cases where there is a special provision to the contrary.

**មាត្រា ១១៥.-** ការទាញហេតុផលដោយផ្ទាល់មាត់

១- ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីសងខាងអាចមានវត្តមានបាន ។

២- ការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវធ្វើឡើង នៅសាលសវនាការជាសាធារណៈ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាពជាសាធារណៈនេះ បណ្តាលឱ្យខូចសណ្តាប់ធ្នាប់សាធារណៈ ឬ ករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ ។(1)

(កំណត់)

(1) នៅក្នុងមាត្រា ៤ នៃសេចក្តីព្រាងច្បាប់ស្តីពីការចាត់តាំងតុលាការនៃព្រះរាជាណាចក្រកម្ពុជានោះមានចែងអំពីគោល-ការណ៍សាធារណៈ ប៉ុន្តែ ត្រូវកំណត់ឱ្យបានច្បាស់លាស់ក្នុងច្បាប់ អំពីករណីលើកលែងដែលអនុញ្ញាតឱ្យធ្វើការទាញហេតុផលដោយផ្ទាល់មាត់មិនចំហជាសាធារណៈ ។
ម្យ៉ាងទៀត ប្រសិនបើតុលាការធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដោយមិនចំហជាសាធារណៈ ដោយយោងទៅតាមបញ្ញត្តិដែលបានកំណត់ក្នុងច្បាប់ នោះតុលាការត្រូវកត់អំពីហេតុការណ៍នេះ ព្រមទាំងមូលហេតុ នៅក្នុងកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ (សូមមើលមាត្រា ១១៨ (ចំណុចជារូបមន្តនៃកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់) កថាខណ្ឌទី ១ ចំណុច **ច**) ។

**មាត្រា ១១៦.-** សេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ការទាញហេតុផល

១- នៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។(1)

២- សេចក្តីថ្លែងការណ៍ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើងដោយចង្អុលបង្ហាញឱ្យបានច្បាស់លាស់នូវអង្គហេតុដែលនឹងត្រូវបញ្ជាក់ដោយការពិនិត្យភស្តុតាងនៅពេលក្រោយ នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ។(2)

៣- នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ភាគីអាចអះអាងបន្ថែមទៀតអំពីអង្គហេតុ និង ដាក់ភស្តុតាងមកទៀតបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការអះអាងអង្គហេតុ ឬ ការដាក់

ភស្តុតាងនោះ ផ្ទុយនឹងមាត្រា ១០៨ (អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) នៃក្រមនេះ ។ (3)

៤- ក្រោយពីបានពិនិត្យភស្តុតាងនៅក្នុងកាលបរិច្ឆេទធ្វើការទាញហេតុផលដោយផ្ទាល់មាត់ហើយ បើយល់ឃើញថា ត្រូវការជាចាំបាច់ពិសេស តុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាថ្មីម្តងទៀតបាន ដោយដីកាសម្រេច ។ (4)

៥- តុលាការអាចអនុញ្ញាតឱ្យភាគីនីមួយៗធ្វើការទាញហេតុផលចុងក្រោយបាន មុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ។

(កំណត់)

(1) សូមមើលមាត្រា 173 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ ដោយសារការធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផល (សេចក្តីថ្លែងការណ៍ដោយសង្ខេប) នេះ ការអះអាងអង្គហេតុ ការដាក់ភស្តុតាង លទ្ធផលនៃការពិនិត្យភស្តុតាងជាឯកសារ និង លទ្ធផលនៃការរៀបចំចំណុចវិវាទដែលបានធ្វើឡើងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហើយនោះ ក៏អាចចាត់ទុកថា បានធ្វើទាំងអស់ហើយនៅក្នុងកាលបរិច្ឆេទធ្វើការទាញហេតុផលដោយផ្ទាល់មាត់នោះដែរ ទោះបីមិនធ្វើឡើងវិញម្តងទៀតនៅកាលបរិច្ឆេទធ្វើការទាញហេតុផលដោយផ្ទាល់មាត់ក៏ដោយ ។ សេចក្តីថ្លែងការណ៍អំពីលទ្ធផលនេះ មិនចាំបាច់ធ្វើឡើងដោយភាគីសងខាងទេ គឺភាគីតែម្ខាងអាចធ្វើជាតំណាងក៏បាន ។

(2) សូមមើលមាត្រា 89 នៃបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ នេះគឺជាការទាមទារកម្រិតអប្បបរមា (តូចបំផុត) គឺត្រូវតែថ្លែងឱ្យបានច្បាស់លាស់អំពីខ្លឹមសារនៃរឿងក្តី (សាច់រឿង) ខ្លឹមសារនៃការអះអាងរបស់ភាគីនីមួយៗ ចំណុចវិវាទ អ្វីដែលជារបៀបបញ្ជាក់ភស្តុតាង (ជាពិសេស ចំពោះសាក្សី និង ភាគីផ្ទាល់) និង ទំនាក់ទំនងរវាងរបៀបបញ្ជាក់ភស្តុតាងនិងចំណុចវិវាទ ជាដើម ។ ម្យ៉ាងទៀត ក្នុងការអនុវត្តនៃបញ្ញត្តិនេះ យើងអាចគិតថា ប្រសិនបើភាគីគ្មានសមត្ថភាពនឹងថ្លែងទេ តុលាការអាចពន្យល់ជំនួសក៏បានដែរ ដោយសួរបញ្ជាក់ថាតើគូភាគីយល់ស្របឬទេ ពេលបានពន្យល់ហើយ ។

(3) នៅពេលដែលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ គូភាគីអាចអះអាងអំពីអង្គហេតុ ឬ ដាក់ភស្តុតាងបាន ប៉ុន្តែដើម្បីឱ្យការជំនុំជម្រះពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់មានដំណើរការស្រួលមិនរអាក់រអួល ច្បាប់បានបង្កើតឱ្យមាននីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលជារយៈពេលសម្រាប់រៀបចំចំណុចវិវាទ និង ភស្តុតាងដែលទាក់ទងនឹងអង្គហេតុ ហើយម្យ៉ាងទៀត មាត្រា ១០៨ (អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) ចែងអំពីអានុភាពនៃការបាត់បង់សិទ្ធិដែរ ដូច្នេះហើយ ត្រូវតែគោរពទៅតាមការកម្រិតទាំងនោះ ។ ហេតុនេះហើយបានជា ក្នុងករណីដែលបានធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រឹមត្រូវហើយ ចំពោះបណ្តឹងភាគច្រើន សកម្មភាពដែលធ្វើឡើងនៅកាលបរិច្ឆេទធ្វើការទាញហេតុផលដោយផ្ទាល់មាត់ នៅសល់តែការពិនិត្យលើ

ភស្តុតាងដូចជាការសួរចម្លើយទៅលើសាក្សីដែលបានត្រៀមទុកជាមុនជាដើម (សូមមើលគន្លឹះទី ២ ជំពូកទី ៣ (ភស្តុតាង)) និង ការធ្វើការទាញហេតុផលជាចុងក្រោយ (សេចក្តីថ្លែងការណ៍ជាចុងក្រោយ) តែប៉ុណ្ណោះ ។

(4) មានន័យថា តាមលទ្ធផលនៅក្រោយពេលដែលបានធ្វើការពិនិត្យភស្តុតាងរួចហើយ បានរកឃើញនូវចំណុចវិវាទសំខាន់ថ្មីផ្សេងទៀតដែលមានការស្មុគស្មាញក្នុងការដោះស្រាយ នៅក្នុងកាលបរិច្ឆេទធ្វើការទាញហេតុផលដោយផ្ទាល់មាត់នោះ តុលាការអាចបើកធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលម្តងទៀតបាន ។ ចំពោះដីកាសម្រេចនេះ មិនអាចប្តឹងជំទាស់បានឡើយ ។

Code of Civil Procedure (Japan)
**Article 173** (Statement of conclusion of preparations for argument proceedings)
The parties shall state the results of preparations for argument proceedings in oral argument.

Rules of Civil Procedure (Japan)
**Article 89** (Statement of conclusion of preparations for argument proceedings/The Code Article 173)
When stating the results of preparations for argument proceedings in oral argument, after conclusion of preparations for argument proceedings, the facts which should be proved by the subsequent examination of evidence shall be clearly indicated.

## **មាត្រា ១១៧.-** កំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់

១- តុលាការត្រូវឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ នៅគ្រប់កាលបរិច្ឆេទនីមួយៗ ។

២- បញ្ញត្តិនៃមាត្រា ១១២ (ការប្តឹងតវ៉ាចំពោះសេចក្តីកត់ត្រានៃកំណត់ហេតុ ស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់នេះ ។

(កំណត់)

សូមមើលមាត្រា 160 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ សូមមើលកំណត់នៃមាត្រា ១០៩ ដែលមានអត្ថន័យប្រហាក់ប្រហែលគ្នា ។

Code of Civil Procedure (Japan)
**Article 160** (Record of oral argument) > see the note for Article 109

## **មាត្រា ១១៨.-** ចំណុចជារូបមន្តនៃកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់

១- នៅក្នុងកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវកត់ត្រានូវចំណុចខាងក្រោមនេះ :

**ក-** សញ្ញាណរឿងក្តី ។

**ខ-** ឈ្មោះចៅក្រម និង ក្រឡាបញ្ជី ។

**គ-** ឈ្មោះតំណាងអយ្យការដែលបានចូលរួម ប្រសិនបើមាន ។

ឃ- ឈ្មោះភាគី អ្នកតំណាង អ្នកជំនួយការ និង អ្នកបកប្រែដែលបានបង្ហាញខ្លួន ។

ង- ពេលវេលា និង ទីកន្លែងនៃការទាញហេតុផលដោយផ្ទាល់មាត់ ។

ច- ហេតុការណ៍ដែលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ ឬ ហេតុការណ៍ និង មូលហេតុ ដែលមិនបានធ្វើជាសាធារណៈក្នុងករណីមិនធ្វើជាសាធារណៈ ។

២- ប្រធានក្រុមប្រឹក្សាជំនុំជម្រះ និង ក្រឡាបញ្ជី ត្រូវចុះហត្ថលេខានៅក្នុងកំណត់ហេតុ ដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

សូមមើលមាត្រា 66 នៃបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ សូមមើលកំណត់នៃមាត្រា ១១០ ដែលមានអត្ថន័យប្រហាក់ប្រហែលគ្នា ។

Rules of Civil Procedure (Japan)
**Article 66** (Formal matters to be entered in record of oral argument/The Code Article 160) > *see the note for Article 109*

**មាត្រា ១១៩.-** ចំណុចសារធាតុនៃកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់

១- នៅក្នុងកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវកត់ត្រានូវសេចក្តីសង្ខេបអំពីការទាញហេតុផលនីមួយៗ ហើយជាពិសេស ត្រូវកត់ត្រាឱ្យបានច្បាស់លាស់នូវចំណុចខាងក្រោមនេះ :

ក- ការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ ការទទួលស្គាល់ការទាមទារ និង ការសារភាព ។

ខ- សេចក្តីថ្លែងការណ៍របស់សាក្សី របស់ភាគីផ្ទាល់ខ្លួន និង របស់អ្នកធ្វើកោសលវិច័យ ។

គ- ការធ្វើសម្បថ ឬ មិនធ្វើសម្បថរបស់សាក្សី របស់ភាគីផ្ទាល់ខ្លួន និង របស់អ្នកធ្វើកោសលវិច័យ និង មូលហេតុដែលមិនបានឱ្យសាក្សី និង អ្នកធ្វើកោសលវិច័យធ្វើសម្បថ ។

ឃ- លទ្ធផលនៃការត្រួតពិនិត្យ ។

ង- ចំណុចដែលតុលាការបានបង្គាប់ឱ្យកត់ត្រា និង ចំណុចដែលតុលាការអនុញ្ញាត ឱ្យកត់ត្រាតាមការទាមទាររបស់ភាគី ។

ច- ការសម្រេចសេចក្តីដែលបានធ្វើឡើងដោយមិនបានធ្វើជាលាយល័ក្ខណ៍អក្សរ ។

ឆ- ការប្រកាសសេចក្តីសម្រេច ។

២- ទោះបីមានបញ្ញត្តិនៅកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក្នុងករណីដែលបណ្តឹងត្រូវបានបញ្ចប់ដោយមិនតាមការសម្រេចសេចក្តីទេ សេចក្តីថ្លែងការណ៍របស់សាក្សី របស់ភាគីផ្ទាល់ខ្លួន និង របស់អ្នកធ្វើកោសលវិច័យ និង លទ្ធផលនៃការត្រួតពិនិត្យ អាចមិនសរសេរក្នុងកំណត់ហេតុបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវ

យកមកអនុវត្តឡើយ ចំពោះករណីដែលភាគីទាមទារឱ្យកត់ត្រាក្នុងកំណត់ហេតុ ក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលខ្លួនបានដឹងថាបណ្តឹងនោះត្រូវបានចប់ ។

(កំណត់)

សូមមើលមាត្រា 67 នៃបទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

Rules of Civil Procedure (Japan)
**Article 67** (Substantive matters to be entered in record of oral argument/The Code Article 160) (excerpt) > *see the note for Article 111*

**មាត្រា ១២០.-** ការកត់ត្រាដោយថតខ្សែអាត់ ជាអាទិ៍ ជំនួសកំណត់ហេតុ

១- ទោះបីមានបញ្ញត្តិដូចកថាខណ្ឌទី ១ នៃមាត្រា ១១៩ (ចំណុចសារធាតុនៃកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់) ខាងលើនេះក៏ដោយ ប្រសិនបើមានការអនុញ្ញាតពីតុលាការ ក្រឡាបញ្ជីអាចថតខ្សែអាត់ ឬ ខ្សែវីដេអូនូវសេចក្តីថ្លែងការណ៍របស់សាក្សី របស់ភាគីផ្ទាល់ ឬ របស់អ្នកធ្វើកោសលវិច័យ ដើម្បីជំនួសកំណត់ហេតុជាលាយល័ក្ខណ៍អក្សរបាន ។ ក្នុងករណីនេះ នៅពេលដែលតុលាការអនុញ្ញាត ភាគីអាចបញ្ចេញមតិយោបល់របស់ខ្លួនបាន ។

២- ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើមានការស្នើសុំរបស់ភាគី រហូតដល់បណ្តឹងនេះបានបញ្ចប់ ក្រឡាបញ្ជីត្រូវធ្វើឯកសារដែលកត់សេចក្តីថ្លែងការណ៍របស់សាក្សី របស់ភាគីផ្ទាល់ ឬ របស់អ្នកធ្វើកោសលវិច័យជាលាយល័ក្ខណ៍អក្សរ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលតុលាការជាន់ខ្ពស់យល់ឃើញថាចាំបាច់ នៅពេលតុលាការជាន់ខ្ពស់នេះកំពុងចាត់ការបណ្តឹងនោះ ។

(កំណត់)

សូមមើលមាត្រា 68 នៃបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

Rules of Civil Procedure (Japan)
**Article 68** (Record on recording tape, etc., in lieu of entry in record)
1. Notwithstanding the provisions of paragraph 1 of the preceding article (Substantive matters to be entered in record of oral argument), when the presiding judge so permits, the court clerk may record the testimonies of witnesses, the parties themselves and expert witnesses (hereinafter: "witnesses, etc.") on recording tapes or video tapes (including articles on which certain matters can be recorded by corresponding methods; hereinafter: "recording tapes, etc."), and substitute them for entry in the record of oral argument. In such cases, the parties may state their opinions when the presiding judge permit.
2. In cases referred to in the preceding paragraph, if the party has so requested before the conclusion of the suit, a document stating the testimonies of witnesses, etc., shall be made. This shall apply to cases, when the suit is pending before an appellate court, where the appellate court has deemed it necessary.

**មាត្រា ១២១.-** ការយកឯកសារ ជាអាទិ៍ ជាអាគតដ្ឋាន និង ការភ្ជាប់ជាឧបសម្ព័ន្ធ

ឯកសារ រូបថត ខ្សែអាត់ ខ្សែវីដេអូ ឬ វត្ថុផ្សេងទៀតដែលតុលាការយល់ឃើញថាសមរម្យ អាចយកធ្វើជាផ្នែកមួយនៃកំណត់ហេតុស្ដីពីការទាញហេតុផលដោយផ្ទាល់មាត់ ដោយយកធ្វើជាអាគតដ្ឋានក្នុងកំណត់ហេតុនោះ ហើយភ្ជាប់ជាមួយសំណុំរឿងជាឧបសម្ព័ន្ធបាន ។

(កំណត់)

សូមមើលមាត្រា 69 នៃបទប្បញ្ញត្តិស្ដីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

Rules of Civil Procedure (Japan)
**Article 69** (Reference to and attachment of documents, etc.)
Documents, photographs, recording tapes, video tapes and any other articles which the court deems appropriate may be made a part of the record of oral argument by being referred to in that record and attached to the record of the case.

**មាត្រា ១២២.-** ការកម្រិតនៃការថតរូប ជាអាទិ៍ ក្នុងសាលសវនាការ

ការថតរូប ការកត់ជាជវលេខ ការថតខ្សែអាត់ ការថតខ្សែវីដេអូ ឬ ការផ្សាយបន្តផ្ទាល់ ក្នុងសាលសវនាការ មិនអាចធ្វើបានឡើយ បើគ្មានការអនុញ្ញាតពីតុលាការ ។

(កំណត់)

សូមមើលមាត្រា 77 នៃបទប្បញ្ញត្តិស្ដីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ ដើម្បីធានាការពារសិទ្ធិរបស់បុគ្គលឯកជន ទើបទាមទារឱ្យមានការកម្រិតក្នុងការថត ឬ ផ្សព្វផ្សាយ ។

Rules of Civil Procedure (Japan)
**Article 77** (Restriction on photographing, etc. in courtroom)
Photographing, stenographing, recording, video recording, or broadcasting in the courtroom shall not be made without a permission of the presiding judge.

## ជំពូកទី ៣ ភស្តុតាង

### ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ

**មាត្រា ១២៣.-** គោលការណ៍សម្រេចសេចក្ដីដោយភស្តុតាង

១- តុលាការត្រូវទទួលស្គាល់អង្គហេតុដោយផ្អែកលើភស្តុតាងជាមូលដ្ឋាន ។ ប៉ុន្តែ តុលាការអាចពិចារណាអំពីស្ថានភាពទាំងមូល ដែលបានលេចឡើងនៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់បាន ។

២- អង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការ និង អង្គហេតុដែលតុលាការយល់ឃើញថា មានភាពជាក់

ស្តែង តុលាការពុំចាំបាច់ទទួលស្គាល់អង្គហេតុនោះដោយផ្អែកលើភស្តុតាងទេ ។

៣- ភាគីអាចដកសេចក្តីសារភាពបាន ក្នុងករណីដូចខាងក្រោមនេះ :

**ក**- ភាគីម្ខាងទៀតពុំតវ៉ា ។

**ខ**- ការសារភាពនោះ ផ្ទុយនឹងការពិត ដោយភាន់ច្រឡំ ។

**គ**- ការសារភាពនេះបណ្តាលមកពីសកម្មភាពបទល្មើសរបស់អ្នកដទៃ ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 179 ។

មាត្រានេះបង្ហាញអំពីគោលការណ៍សម្រេចសេចក្តីដោយភស្តុតាង ដែលពុំមានការប្រែប្រួលដោយទទួលយកនូវការពិតដែលយោងទៅលើភស្តុតាងជាមូលដ្ឋាន ។ ប៉ុន្តែ គេអាចពិចារណាអំពីស្ថានភាពនៃការធ្វើការទាញហេតុផលដោយផ្ទាល់មាត់ និង ទទួលស្គាល់អង្គហេតុ ដោយមិនផ្អែកលើភស្តុតាងបាន ។ ឧទាហរណ៍: ភាគីវិវាទទៅលើវត្តមាននៃរឿងពិតតែការវិវាទនោះពុំមានភាពធ្ងន់ធ្ងរពេកទេ ក្នុងករណីនេះ តុលាការអាចទទួលស្គាល់រឿងពិតបានដោយមិនបាច់យោលទៅតាមភស្តុតាងទេ ។

ម្យ៉ាងទៀត គេទទួលស្គាល់វត្តមាននៃការសារភាពរបស់គូភាគី ឆ្លងកាត់តាមគោលការណ៍ទាញហេតុផលដែលមិនត្រូវការចាំបាច់យោងទៅលើភស្តុតាងជាមូលដ្ឋានទេ ។ គេមិនអនុញ្ញាតឱ្យតុលាការទទួលស្គាល់រឿងពិតឯទៀតក្រៅពីរឿងពិតដែលបានមកពីការសារភាពរបស់គូភាគីឡើយ ។ ម្យ៉ាងទៀតតុលាការពុំបាច់ធ្វើសេចក្តីវិនិច្ឆ័យ (លទ្ធផល) រឿងពិតដូចជាថ្ងៃខែនៃភយន្តរាយកើតឡើងដែលគេដឹងគ្រប់ៗគ្នា និង ការពិតដែលទាក់ទងនឹងកិច្ចការរបស់ចៅក្រមដែលកំពុងធ្វើឡើយ ។

នៅពេលដែលបានសារភាពរួចហើយ តុលាការនឹងវិនិច្ឆ័យសេចក្តីដោយយោលទៅតាមការសារភាពនោះ ចំណែកឯភាគីម្ខាងទៀតវិញ នឹងធ្វើការតទល់ និង ការពារខ្លួនដោយជឿលើសេចក្តីសារភាពនោះ ដូច្នេះយើងមិនអាចទទួលស្គាល់ឱ្យភាគីនោះដកសេចក្តីសារភាព ដោយគ្មានល័ក្ខខ័ណ្ឌបានឡើយ ។ ប៉ុន្តែ នៅក្នុងករណីដែលភាគីម្ខាងទៀតមិនប្តឹងតវ៉ាជាពិសេសទេ យើងអាចទទួលស្គាល់ការដកសេចក្តីសារភាពនោះបាន ។ បើការសារភាពនោះផ្ទុយនឹងការពិត និង ដោយផ្អែកលើការភាន់ច្រឡំ វាដូចជាឃោរឃៅពេកបើឱ្យភាគីចងការសារភាពរបស់ខ្លួននោះ ដូច្នេះហើយ នៅទីនេះយើងទទួលស្គាល់ការដកចេញនូវសេចក្តីសារភាព ចំណែកឯករណីដែលសេចក្តីសារភាពនោះធ្វើឡើង ដោយសារលទ្ធផលនៃសកម្មភាពបទល្មើស ដូចជាការបោកបញ្ឆោត ឬ ដោយសារការគម្រាមកំហែង ក៏អនុវត្តដូចគ្នាដែរ ។

Code of Civil Procedure (Japan)
**Article 179** (Fact which need not be proven)
Facts admitted to in court by the parties and obvious facts need not be proven.

**មាត្រា ១២៤.-** ការពិនិត្យភស្តុតាង

១- ការពិនិត្យភស្តុតាង ត្រូវធ្វើឡើងតាមការស្នើសុំឱ្យពិនិត្យរបស់ភាគី ។

២- ប្រសិនបើតុលាការពុំអាចសម្រេចថា ត្រូវទទួលស្គាល់ ឬ មិនទទួលស្គាល់នូវការអះអាងអំពីអង្គហេតុ ដោយភស្តុតាងដែលគូភាគីបានស្នើសុំឱ្យពិនិត្យ ឬ បើយល់ឃើញថា មានការចាំបាច់ផ្សេងទៀត នោះតុលាការអាចធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិបាន ។

(កំណត់)

ជាគោលការណ៍ ការពិនិត្យភស្តុតាងត្រូវធ្វើទៅតាមការស្នើសុំឱ្យពិនិត្យភស្តុតាងរបស់ភាគី ។ ការដាក់ភស្តុតាងគឺជាគោលការណ៍ដំណាក់កាលលើកទី ១ ដែលទាមទារឱ្យភាគីទទួលខុសត្រូវ ។

ប៉ុន្តែ នៅពេលដែលតុលាការ ពុំមានការជឿជាក់ទៅលើភស្តុតាងដែលគូភាគីទាមទារឱ្យពិនិត្យទេ ឬ ករណីផ្សេងទៀត តុលាការអាចធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។ យោលទៅតាមស្ថានភាពជាក់ស្តែងដែលប្រទេសកម្ពុជាកំពុងជួបប្រទះ យើងគិតថា ការអនុវត្តកិច្ចការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ គឺជាកិច្ចការដែលមិនអាចជៀសវាងបាន នៅក្នុងពេលនេះ ។ ប៉ុន្តែទៅអនាគតខាងមុខត្រូវយកមកអនុវត្តតាមកថាខណ្ឌទី ១ នៃមាត្រានេះ (នៅប្រទេសជប៉ុនគេបានលុបបញ្ញត្តិដូចកថាខណ្ឌទី ២ នេះចោល នៅឆ្នាំ ១៩៤៧) ។ ម៉្យាងទៀត នៅពេលអនុវត្ត ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ រដ្ឋមានបន្ទុកត្រូវបង់នូវសោហ៊ុយដើម្បីពិនិត្យភស្តុតាង (សោហ៊ុយសម្រាប់សាក្សី សោហ៊ុយសម្រាប់អ្នកធ្វើកោសលវិច័យ ប្រាក់សម្រាប់ធ្វើដំណើរ ចំពោះចៅក្រមដែលទៅធ្វើការពិនិត្យទីកន្លែង ជាដើម) យើងត្រូវគិតថា តើរដ្ឋាភិបាលអាចធ្វើបានដែរ ឬទេ ? យើងត្រូវគិតទៅលើថវិកាជាតិផងដែរ ។

**មាត្រា ១២៥.-** ការស្នើសុំឱ្យពិនិត្យភស្តុតាង

១- ភាគីដែលស្នើសុំឱ្យពិនិត្យភស្តុតាង ត្រូវតែកំណត់ឱ្យបានជាក់លាក់អំពីអង្គហេតុដែលត្រូវបញ្ជាក់ ។

២- ភាគីដែលស្នើសុំឱ្យពិនិត្យភស្តុតាង គប្បីបំភ្លឺឱ្យច្បាស់លាស់អំពីអង្គហេតុដែលត្រូវបញ្ជាក់ និង ទំនាក់ទំនងរវាងអង្គហេតុនោះនិងភស្តុតាង ។

៣- ការស្នើសុំឱ្យពិនិត្យភស្តុតាង ក៏អាចធ្វើមុនកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ មុនកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់បានដែរ ។

៤- ការស្នើសុំឱ្យសាកសួរសាក្សី និង សាមីភាគី បើអាចធ្វើបាន ត្រូវធ្វើជាមួយគ្នាឱ្យស្រេចតែម្តង ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 180 បទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 99 និង មាត្រា 100 ។

មាត្រានេះបញ្ញត្តអំពីបែបបទដើម្បីស្នើសុំឱ្យពិនិត្យភស្តុតាង ។ បើយើងមិនបានបំភ្លឺឱ្យច្បាស់លាស់អំពីទំនាក់ទំនងរឿងពិតជាមួយនឹងភស្តុតាងទេ យើងមិនអាចសម្រេចបាននូវការទទួលយកបាន ឬ មិនបាន ទៅលើភាពចាំបាច់របស់ភស្តុតាងនោះឡើយ (សូមមើលមាត្រា ១២៦ (ការទទួលយកភស្តុតាង)) ។ ឯចំពោះពេលវេលាដើម្បីស្នើសុំឱ្យពិនិត្យភស្តុតាង ក៏អាចធ្វើបាននៅមុនកាលបរិច្ឆេទដែរ ហើយក៏ជាមូលហេតុជំរុញឱ្យសេចក្តីសម្រេចទទួលយកបាន ឬ មិនបានទៅលើភស្តុតាងដែរ ហើយងាយស្រួលលើការសាកសួរទៅលើសាក្សី និង ការពិនិត្យភស្តុតាងដែលស្នើសុំដោយគូភាគី និងសំរួលការពិនិត្យដោយប្រមូលផ្តុំទៅលើភស្តុតាង (សូមមើលមាត្រា ១២៧ (ការពិនិត្យភស្តុតាងដោយសមូហវិធី )) ។ ក្នុងមាត្រាខាងលើ កថាខណ្ឌទី ១ ដែលសរសេរថា "ត្រូវតែកំណត់" និង កថាខណ្ឌទី ២ ដែលសរសេរថា "គប្បីបំភ្លឺ" មានន័យថា កថាខណ្ឌទី ១ គឺជាបញ្ញត្តិដែលចែងអំពីកាតព្វកិច្ចដែលត្រូវបំពេញ (មានន័យថា ការស្នើសុំឱ្យពិនិត្យភស្តុតាងដែលមិនបានកំណត់ឱ្យបានជាក់លាក់ នឹងត្រូវលើកចោល) ចំណែកឯ កថាខណ្ឌទី ២ គឺជាបញ្ញត្តិបង្ហាញថា "ទោះជាមិនបានបំភ្លឺឱ្យច្បាស់លាស់ ក៏មិនលើកចោលដែរ" ។

Code of Civil Procedure (Japan)
**Article 180** (Offering evidence)
1. Evdence shall be offered by specifying the fact to be proven thereby.
2. Evidence may also be offered before th appointed date.

Rules of Civil Procedure (Japan)
**Article 99** (Offering evidence / The Code Article 180)
1. Evidence shall be offered by clearly and concretely indicating the relation between the facts to be proven and the evidence.
2. The provisions of Article 83 (Sending directly of preliminary document) shall also apply to a document including the offering of evidence.
**Article 100** (*En bloc* offering of examination of witnesses and parties themselves / The Code Article 182)
To whatever extent possible, offering examination of witnesses and the parties themselves should be made *en bloc*.

**មាត្រា ១២៦.-** ការទទួលយកភស្តុតាង

តុលាការត្រូវពិនិត្យភស្តុតាងដែលភាគីបានស្នើសុំឱ្យពិនិត្យ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្ត ចំពោះភស្តុតាងដែលគ្មានទំនាក់ទំនងជាមួយនឹងអង្គហេតុដែលនឹងត្រូវបញ្ជាក់ និង ភស្តុតាងឯទៀតដែលតុលាការយល់ឃើញថាមិនចាំបាច់ឡើយ ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 181 កថាខណ្ឌទី 1 ។

ជាគោលការណ៍ ការពិនិត្យភស្តុតាងត្រូវយោលទៅតាមការស្នើសុំរបស់គូភាគី (មាត្រា ១២៤ (ការពិនិត្យភស្តុតាង)) នេះឆ្លុះឱ្យឃើញថា ជាគោលការណ៍ តុលាការត្រូវពិនិត្យភស្តុតាងដែលស្នើសុំដោយគូភាគី ។ ប៉ុន្តែ ប្រសិនបើភស្តុតាងនោះគ្មានទំនាក់ទំនងជាមួយនឹងអង្គហេតុដែលនឹងត្រូវបានបញ្ជាក់ទេ ឬ ក៏ជាភស្តុតាងណាដើម្បីបញ្ជាក់អង្គហេតុដែលតុលាការជឿទុកចិត្តរួចទៅហើយ នោះជាករណីពិសេសដែលតុលាការមិនចាំបាច់ធ្វើការពិនិត្យភស្តុតាងទេ ពីព្រោះ

ទោះជាពិនិត្យភស្តុតាងនោះក៏ដោយ ក៏គ្មានប្រយោជន៏ទៅលើការវិនិច្ឆ័យដែរ ។ ចំណែកករណីដែលពុំដឹងថាសាក្សីដែលសំខាន់នៅឯណាដែលនាំឱ្យរាំងស្ទះដល់ការពិនិត្យភស្តុតាង នោះពុំចាំបាច់ធ្វើការពិនិត្យភស្តុតាងទេ ។ ប៉ុន្តែចំណុចនេះមិនបានចែងនៅក្នុងបញ្ញត្តិនេះទេ ដោយសារវាជារឿងដែលទៀងទាត់ហើយមិនចាំបាច់ចែង ។

Code of Civil Procedure (Japan)
**Article 181** (Occasions in which evidence need not be examined)
1. The court need not examine evidence offered by a party upon determining it unnecessary to do so.
2. In cases where there is an obstacle of an indefinite duration with regard to the examination of evidence, the court may dispense with the examination of evidence.

**មាត្រា ១២៧.\-** ការពិនិត្យភស្តុតាងដោយសមូហវិធី

១- តុលាការត្រូវធ្វើឱ្យការពិនិត្យភស្តុតាងអាចប្រព្រឹត្តទៅជាបន្ទាន់ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ដំបូង បន្ទាប់ពីបានបញ្ចប់ការរៀបចំចំណុចវិវាទ និង ភស្តុតាងរួចហើយ ។

២- ការសាកសួរទៅលើសាក្សី ឬ សាមីភាគី បើអាចធ្វើបាន ត្រូវតែធ្វើដោយសមូហវិធី ។

៣- ឯកសារដែលបម្រុងនឹងប្រើនៅក្នុងការសាកសួរសាក្សី ជាអាទិ៍ ត្រូវដាក់ជូននៅក្នុងអំឡុងពេលដែលសមរម្យមុនពេលចាប់ផ្តើមធ្វើការសាកសួរទៅលើសាក្សី ជាអាទិ៍ នោះ លើកលែងតែឯកសារដែលនឹងប្រើជាភស្តុតាង ដើម្បីប្រជែងលើភាពជំនឿនៃសេចក្តីថ្លែងការណ៍របស់សាក្សី ជាអាទិ៍ ។

（កំណត់）

ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 182 និង បទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 101 និង មាត្រា 102 ។

ការពិនិត្យភស្តុតាងជាគោលការណ៍ត្រូវធ្វើឡើងភ្លាមៗ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ បន្ទាប់ពីការបញ្ចប់ការរៀបចំចំណុចវិវាទនៅនីតិវិធីត្រៀមដើម្បីធ្វើការទាញហេតុផល ឬ បន្ទាប់ពីការបញ្ចប់ការរៀបចំចំណុចវិវាទ នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ក្រោយពេលនៃនីតិវិធីត្រៀមដើម្បីធ្វើការទាញហេតុផល ។ ចំណុចនេះគឺជាគន្លឹះដើម្បីធ្វើឱ្យកិច្ចការបណ្តឹងមានភាពរហ័ស និង ត្រឹមត្រូវ ។ ហើយជាពិសេស ការសាកសួរទៅលើសាក្សីដែលជាសកម្មភាពសំខាន់បំផុតក្នុងចំណោមការពិនិត្យភស្តុតាង ត្រូវតែធ្វើដោយសមូហវិធី ។ ហេតុដូច្នេះហើយ ភស្តុតាងជាឯកសារដែលត្រូវប្រើប្រាស់ក្នុងការសាកសួរសាក្សី ជាដើម ចាំបាច់ត្រូវដាក់ជូនទៅតុលាការ ក្នុងអំឡុងពេលសមរម្យមុននឹងកាលបរិច្ឆេទសម្រាប់ការពិនិត្យភស្តុតាងដោយសមូហវិធី ដើម្បីឱ្យភាគីម្ខាងទៀតអាចរៀបចំបាន ។ ប៉ុន្តែ ចំពោះភស្តុតាងដែលច្បាស់ជាអាចបដិសេធខ្លឹមសារនៃចម្លើយជាកសិណសាក្សីដែលសាក្សីនឹងធ្វើ ហើយដែលអាចបញ្ជាក់ បានថាចម្លើយរបស់សាក្សីនោះមិនគួរត្រូវបានជឿទុកចិត្តទេ（ជាទូទៅ ហៅថា "ភស្តុតាងប្រកាន់（弾劾証拠 evidence for pursposes, preuve accuation）"）ច្បាប់ទទួលស្គាល់ករណីលើកលែង ហើយភាគីអាចដាក់ភស្តុតាងនោះ នៅពេលសាកសួរសាក្សីនោះបាន ។

Code of Civil Procedure (Japan)
**Article 182** (Concentrated examination of evidence)
To the extent possible, examination of witnesses and the parties themselves should be made in concentration after conclusion of the arrangement of points at issue and evidence.

Rules of Civil Procedure (Japan)
**Article 101** (Preparation for examination of evidence)
In relation to a case regarding which arrangement proceedings of the points at issue and evidence have been conducted, the court shall attempt to undertake examination of evidence immediately on the initial date set for oral argument subsequent to the conclusion of arrangement proceedings of the points at issue and evidence.
**Article 102** (Time to produce document, etc.)
Documents which are expected to be used in examination of a witness, etc., excluding documents which are used as evidence which impeach the credibility of a statement by the witness, etc., shall be produced with an allowance for a proper period of time before the commencement of such examination of witness, etc. However, in case where such documents cannot be produced, it is sufficient to produce copies thereof.

**មាត្រា ១២៨.-** សិទ្ធិចូលរួមរបស់ភាគី

១- តុលាការត្រូវផ្ដល់ឱកាសឱ្យមានវត្តមានរបស់ភាគី ដើម្បីចូលរួមក្នុងការពិនិត្យភស្តុតាង ។

២- ការពិនិត្យភស្តុតាង អាចធ្វើទៅបាន ទោះជាក្នុងករណីដែលភាគីមិនបានចូលខ្លួនតាមកាលបរិច្ឆេទក៏ដោយ ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 183 ។

ក្នុងករណីធ្វើការពិនិត្យភស្តុតាង តុលាការត្រូវតែផ្ដល់ឱកាសចូលរួមជាវត្តមានរបស់គូភាគី ។ ឧ. នៅពេលសាកសួរសាក្សី តុលាការត្រូវតែផ្ដល់ឱកាសដើម្បីឱ្យភាគីទាំងសងខាងបានចូលរួម ដើម្បីផ្ដល់ឱកាសឱ្យភាគីនីមួយៗ សាកសួរសាក្សី ឬ នៅពេលធ្វើការត្រួតពិនិត្យ (inspection, vérifications personnelles du juge) នៅក្រៅតុលាការ ក៏ចាំបាច់ត្រូវផ្ដល់ឱកាសចូលរួមជាវត្តមានដល់គូភាគីដែរ ។ ចំណុចនេះយើងអាចនិយាយថា គឺជាសិទ្ធិបណ្ដឹងជាមូលដ្ឋាន ដើម្បីធានាលើសិទ្ធិតទល់ និង ការពាររបស់គូភាគី ។ ប៉ុន្តែ ទោះជាបានផ្ដល់ឱកាសចូលរួមជាវត្តមានក៏ដោយ តែប្រសិនបើភាគីមិនបានចូលខ្លួនតាមកាលបរិច្ឆេទទេ ដូចជាករណីដែលមានវត្តមានរបស់ភាគីតែម្ខាង ឬ គ្មានវត្តមានរបស់គូភាគីទាំងសងខាងក៏ដោយ ក៏តុលាការអាចធ្វើការពិនិត្យភស្តុតាងបានដែរ ។ ក្នុងករណីនេះ បើយើងចែងថា មិនអាចធ្វើការពិនិត្យភស្តុតាងបាន នោះធ្វើឱ្យរំខានដល់សាក្សីដែលមានវត្តមាន ហើយអាចឱ្យបណ្ដឹងមានការយឺតយូរ ។

Code of Civil Procedure (Japan)
**Article 183** (Treatment in case of nonappearance of party)
Examination of evidence may be made even in the case of the nonappearance of a party on the appointed date.

**មាត្រា ១២៩.-** ការពិនិត្យភស្តុតាងនៅបរទេស

១- ការពិនិត្យភស្តុតាងដែលត្រូវធ្វើនៅបរទេស តុលាការត្រូវប្រគល់កិច្ចការនេះទៅក្រសួង ឬ ស្ថាប័នដែលមាន

សមត្ថកិច្ចនៃប្រទេសនោះ ឬ ឯកអគ្គរាជទូត ភារធារី ឬ កុងស៊ុលរបស់ព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេសនោះ ។
២- ការពិនិត្យភស្តុតាងដែលបានធ្វើនៅបរទេស ទោះបីជាក្នុងករណីដែលការពិនិត្យភស្តុតាងនោះខុសច្បាប់របស់ប្រទេសនោះក៏ដោយ ក៏នៅតែមានសុពលភាពដែរ បើការពិនិត្យភស្តុតាងនោះមិនផ្ទុយនឹងក្រមនេះទេ ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 184 ។

មាត្រានេះគឺជាបទប្បញ្ញត្តិនៅពេលធ្វើការពិនិត្យភស្តុតាងនៅបរទេស ។ ប៉ុន្តែដោយសារការពិនិត្យភស្តុតាងនៅបរទេស ជាការអនុវត្តនូវអធិបតេយ្យភាពជាតិ យើងចាំបាច់ត្រូវទទួលការយល់ព្រមពីសំណាក់ប្រទេសនោះ ហើយត្រូវយោលទៅតាមកិច្ចព្រមព្រៀង ឬ សន្ធិសញ្ញាដែលបានចុះកន្លងមក (ចំពោះអនុសញ្ញាពហុប្រទេសដូចនេះ មានអនុសញ្ញាស្តីពីនីតិវិធីរដ្ឋប្បវេណី (Convention on Civil Procedure, Hague, 1954) និង អនុសញ្ញាស្តីពីការប្រមូលភស្តុតាង (Convention on the Taking of Evdence Abroad in Civil or Commercial Matters, Hague, 1970)) ។ កថាខណ្ឌទី ២ នេះ គ្រាន់តែបំភ្លឺអំពីច្បាប់ស្តីពីភស្តុតាងរបស់កម្ពុជានៅពេលដែលច្បាប់នេះខុសគ្នាជាមួយនឹងច្បាប់បរទេស ទោះជាលទ្ធផលនៃការពិនិត្យភស្តុតាងនៅបរទេស មិនស្របច្បាប់របស់ប្រទេសនោះក៏ដោយ ប្រសិនបើវាស្របច្បាប់ស្តីពីភស្តុតាងរបស់ប្រទេសកម្ពុជា គឺអាចយកមកអនុវត្តលើនីតិវិធីបាន ។

Code of Civil Procedure (Japan)
**Article 184** (Examination of evidence in foreign country)
1. Examination of evidence in a foreign country shall be entrusted to the competent government office of the country or to the Japanese ambassador, minister envoy or consul stationed in the country.
2. Examination of evidence in a foreign country shall be valid insofar as it is consistent with this Act, even if it contravenes the laws of such country.

**មាត្រា ១៣០.-** ការប្រគល់កិច្ចការស្រាវជ្រាវ

តុលាការអាចប្រគល់កិច្ចការស្រាវជ្រាវដែលចាំបាច់ ទៅស្ថាប័នក្នុងប្រទេស ឬ ស្ថាប័នបរទេសបាន ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 186 ។

មាត្រានេះក្រៅពីកំណត់អំពីបទបញ្ជាទៅលើរបៀបពិនិត្យភស្តុតាង ចាប់ពីផ្នែកខាងក្រោមទៅនេះ គឺគេទទួលស្គាល់ការប្រគល់កិច្ចការស្រាវជ្រាវឱ្យទៅស្ថាប័នរដ្ឋក្នុង និង ក្រៅប្រទេស ដែលជាហេតុងាយស្រួលលើកិច្ចការពិនិត្យភស្តុតាង ។ ការទទួលស្គាល់របៀបនេះ គេកំណត់តែទៅលើលក្ខណៈដែលស្របទៅនឹងអង្គហេតុដែលគ្មានមន្ទិលចំពោះយុត្តិធម៌ ក្នុងការពិនិត្យលើតែប៉ុណ្ណោះ ។ ឧ. ចំណុចវិវាទទៅលើអាកាសធាតុ យើងអាចប្រគល់ទៅក្រសួងដែលទទួលបន្ទុកផ្នែកព្យាករណ៍ឧតុនិយមឱ្យគេជួយស្រាវជ្រាវបាន ។ ចំណែកមាត្រានេះកំណត់យកតែភាគីជាប្រទេស ឬ ជាស្ថាប័នរដ្ឋ

តែប៉ុណ្ណោះ ប៉ុន្តែ ឆ្លងកាត់តាមការអនុវត្តក៏អាចពង្រីកនឹងរាប់បញ្ចូលផងដែរចំពោះរចនាសម្ព័ន្ធសាធារណៈដទៃទៀត (មាត្រា 186 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ទទួលស្គាល់ការប្រគល់កិច្ចការស្រាវជ្រាវលើសាលារៀន កន្លែងធ្វើជំនួញ និង សមាគមឯទៀត) ។

Code of Civil Procedure (Japan)
**Article 186** (Entrustment of investigation)
The court may entrust a government agency, public office, foreign government agency or public office, or school, chamber of commerce, exchange or any other organization with necessary investigation.

**មាត្រា ១៣១.-** សេចក្តីបញ្ជាក់ដំបូង

សេចក្តីបញ្ជាក់ដំបូង ត្រូវធ្វើឡើងដោយភស្តុតាងដែលអាចពិនិត្យភ្លាមៗបាន ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 188 ។

សេចក្តីបញ្ជាក់ដំបូង (Preliminary showing, Glaubhaftmachung) គឺជារបៀបទទួលស្គាល់អង្គហេតុ ទោះជាសេចក្តីបញ្ជាក់ដំបូងនោះ មានកម្រិតទាបជាងការបញ្ជាក់ (ស្នបន្ទាល់/តឹកតាង) ចំពោះកម្រិតនៃជំនឿទុកចិត្ត (ភាពគួរជឿបាន) ក៏ដោយ ។ ជាពិសេស ចំពោះនីតិវិធី ដែលចាំបាច់ត្រូវចាត់ការបន្ទាន់ ហើយត្រូវការចាំបាច់សម្រេចនូវការទទួលស្គាល់ គឺគេយកសេចក្តីបញ្ជាក់ដំបូងនេះ មកអនុវត្ត (ឧទាហរណ៍ៈ វិធានការរក្សាការពារ ល័ក្ខខ័ណ្ឌក្នុងការសង្គ្រោះទៅលើបណ្តឹងមូលហេតុរក្សាការពារភស្តុតាង ជាដើម) ។ ដោយសេចក្តីបញ្ជាក់ដំបូង តម្រូវឱ្យមានភាពជាបន្ទាន់នោះ ចំពោះរបៀបពិនិត្យភស្តុតាងវិញ គឺគេកំណត់ ឱ្យពិនិត្យតែទៅលើភស្តុតាងដែលអាចពិនិត្យបានភ្លាមៗតែប៉ុណ្ណោះ ។ ម្ល៉ោះហើយ ចំពោះការប្រគល់កិច្ចការស្រាវជ្រាវ ដីកាសម្រេចដែលបង្គាប់ឱ្យដាក់ឯកសារ ការសាកសួរលើសាក្សីដែលតុលាការត្រូវកោះហៅ ជាដើមនោះ គេមិនទទួលស្គាល់សេចក្តីបញ្ជាក់ដំបូងនេះទេ ។

Code of Civil Procedure (Japan)
**Article 188** (Preliminary showing)
A preliminary showing shall be offered by evidence of such nature as admits immediate examination.

## ផ្នែកទី ២ ការសាកសួរសាក្សី

**មាត្រា ១៣២.-** ករណីយកិច្ចរបស់សាក្សី

១- លើកលែងតែក្នុងករណីដែលមានកំណត់ពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេង តុលាការអាចសាកសួរជនណាមួយជាសាក្សីក៏បាន ។

២- តុលាការអាចបង្គាប់ឱ្យនាំខ្លួនសាក្សីដែលមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ ដោយដីកាសម្រេចបាន ។

៣- ប្រសិនបើសាក្សីមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ១.000.000 ( មួយលាន) រៀលបាន ដោយដីកាសម្រេច ។

៤- ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ឬ ទី ៣ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

( កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 190 មាត្រា 192 និង មាត្រា 193 ។

មាត្រានេះកំណត់អំពីកាតព្វកិច្ចរបស់សាក្សីចំពោះជនគ្រប់រូប ។ ករណីយកិច្ចរបស់សាក្សី គឺជាករណីយកិច្ចលើច្បាប់សាធារណៈចំពោះរដ្ឋ ដែលសាក្សីត្រូវចូលខ្លួនទៅតុលាការដើម្បីឆ្លើយជាកសិណសាក្សី ។ ប៉ុន្តែ មានករណីលើកលែងចំពោះអ្នកការទូតបរទេសដែលមានអភ័យឯកសិទ្ធិ ឬ មន្ត្រីរាជការដែលពុំអាចទទួលការអនុញ្ញាតពីស្ថាប័នដែលគ្រប់គ្រង (សូមមើលមាត្រា ១៣៣ (ការសាកសួរសាក្សីជាមន្ត្រីរាជការ)) ។ ចំពោះសាក្សីដែលមិនព្រមចូលខ្លួនមកតុលាការដើម្បីអនុវត្តករណីយកិច្ចរបស់ខ្លួន ដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចយកសាក្សីនោះមកតុលាការដោយបង្ខំបាន ហើយសាក្សីនោះ អាចនឹងត្រូវទទួលពិន័យជាប្រាក់ទៀតផង ។

សាក្សីមានសិទ្ធិបដិសេធក្នុងការផ្តល់ចម្លើយជាកសិណសាក្សីបានមានចែងនៅក្នុង មាត្រា ១៣៤ នៃក្រមនេះ ។

Code of Civil Procedure (Japan)
**Article 190** (Duty to be witness)
Except as otherwise provided, the court may examine any person as a witness.
**Article 192** (Nonpenal fine, tec., for nonappearance)
1. In cases where a witness fails to appear without justifiable reason, the court shall order , by ruling, the bearing of court costs arising therefrom, and furthere impose a nompenal fine not to exceed one hudred thousand yen.
2. An immediate *kokoku*-appeal may be made against the ruling under the preceding paragraph.
**Article 193** (Fine, etc., for nonappearance)
1. In cases where a witness fails to appear without justifiable reason, a fine not exceeding one hundred thousand yen or imprisonment shall be imposed.
2. A person committing the offense rederred to in the preceding paragraph may be punished, according to the circumstances, by both a fine and imprisonment.

**មាត្រា ១៣៣.-** ការសាកសួរសាក្សីជាមន្ត្រីរាជការ

១- ក្នុងករណីសាកសួរសាក្សីជាមន្ត្រីរាជការ ឬ អតីតមន្ត្រីរាជការ អំពីកិច្ចការសម្ងាត់ក្នុងមុខនាទីនោះ តុលាការត្រូវទទួលការយល់ព្រមពីសំណាក់ស្ថាប័នដែលគ្រប់គ្រងលើសាក្សីនោះ ។

២- ស្ថាប័នគ្រប់គ្រងដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ គឺព្រឹទ្ធសភា ចំពោះសមាជិកព្រឹទ្ធសភា ឬ អតីតសមាជិកព្រឹទ្ធសភា រដ្ឋសភា ចំពោះសមាជិករដ្ឋសភា ឬ អតីតសមាជិករដ្ឋសភា រីឯចំពោះសមាជិករាជរដ្ឋាភិបាល ឬ អតីតសមាជិករាជរដ្ឋាភិបាលវិញ គឺគណៈរដ្ឋមន្ត្រី ។

៣- ការយល់ព្រមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចបដិសេធបានឡើយ លើកលែងតែក្នុងករណីដែលអាចធ្វើឱ្យខូចផលប្រយោជន៍សាធារណៈ ឬ បណ្តាលឱ្យមានឧបសគ្គធ្ងន់ធ្ងរក្នុងការបំពេញការងាររដ្ឋ ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 191 ។

មាត្រានេះបញ្ញត្តអំពីការសាកសួរទៅលើសាក្សីជាមន្ត្រីរាជការ (នៅក្នុងមាត្រានេះ ពាក្យ "មន្ត្រីរាជការ" រាប់បញ្ចូលសមាជិកសភា និង សមាជិករាជរដ្ឋាភិបាល) ។ ដោយអ្នករាជការមានករណីយកិច្ចត្រូវរក្សានូវកិច្ចការសម្ងាត់ គេមិនអាចអនុញ្ញាតឱ្យបង្ហាញនូវការសម្ងាត់នោះឡើយ ។ ប៉ុន្តែ ក្នុងការវិនិច្ឆ័យក៏មានករណីចាំបាច់តម្រូវឱ្យបំភ្លឺការពិតដែលទាក់ទងទៅនឹងកិច្ចការសម្ងាត់ផងដែរ ។ ហេតុនេះហើយ យើងកំណត់ថា ការសាកសួរនេះ អាចធ្វើទៅបាន បើបានទទួលសេចក្តីអនុញ្ញាតពីសំណាក់ស្ថាប័នដែលគ្រប់គ្រងនោះ (មានន័យថា ចំពោះសមាជិកសភា ត្រូវទទួលសេចក្តីអនុញ្ញាតពីសភា ចំពោះសមាជិករាជរដ្ឋាភិបាល ត្រូវទទួលសេចក្តីអនុញ្ញាតពីគណៈរដ្ឋមន្ត្រី) ។ ឯការទទួលសេចក្តីអនុញ្ញាតពីសំណាក់ស្ថាប័នដែលគ្រប់គ្រង ក៏គេមិនឱ្យមានភាពសេរីទៅលើសេចក្តីសម្រេចដែរ ។ មានតែករណីដែលអាចធ្វើឱ្យខូចផលប្រយោជន៍សាធារណៈ ឬ បណ្តាលឱ្យមានឧបសគ្គក្នុងដំណើរការការងាររដ្ឋ បើបង្ហាញនូវកិច្ចការសម្ងាត់នោះតែប៉ុណ្ណោះដែលស្ថាប័នដែលគ្រប់គ្រងអាចបដិសេធបាន ។

Code of Civil Procedure (Japan)
**Article 191** (Examination of public official)
1. In cases of examining a public official or a person who was a public official as a witness regarding official secrets, the court shall obtain approval from the competent supervising government agency (regarding a member of former member of the House of Representatives or the House of Councillors, the respective house; regarding the Prime Minister, other ministers of state, or persons who formerly occupied such office, the Cabinet).
2. The approval referred to in the preceding paragraph shall not be rejected unless there exists danger of giving rise to damage to the public interest or a considerable hindrance to the performance of a public duty.

**មាត្រា ១៣៤.-** សិទ្ធិបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សី

១- ប្រសិនបើការផ្តល់នូវចម្លើយជាកសិណសាក្សី ទាក់ទងនឹងហេតុដែលធ្វើឱ្យសាក្សី ឬ សហព័ទ្ធរបស់សាក្សី ឬ ញាតិឯទៀតរបស់សាក្សី អាចទទួលរងនូវការចោទប្រកាន់អំពីបទអាជ្ញា ឬ ទទួលការផ្តន្ទាទោស នោះសាក្សីអាចបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សីបាន ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះការផ្តល់ចម្លើយជាកសិណសាក្សីទាក់ទងនឹងហេតុដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលដែលបានរៀបរាប់ខាងលើនេះ ឬ បណ្តាលឱ្យមានការបែកបាក់ធ្ងន់ធ្ងរដល់ទំនាក់ទំនងគ្រួសារ ។

២- សាក្សីអាចបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សីបាន :

**ក-** ក្នុងករណីដូចកថាខណ្ឌទី ១ នៃមាត្រា ១៣៣ (ការសាកសួរសាក្សីជាមន្ត្រីរាជការ) ខាងលើ ។

**ខ-** ក្នុងករណីដែលវេជ្ជបណ្ឌិត ទន្តបណ្ឌិត ឆ្មប គិលានុបដ្ឋាយិកា គិលានុបដ្ឋាក ឱសថការី មេធាវី

អ្នកមានមុខងារក្នុងសាសនា ឬ អ្នកដែលធ្លាប់មានមុខងារខាងលើនេះ ត្រូវទទួលការសាកសួរអំពីអង្គហេតុដែលបានដឹង ក្នុងការបំពេញតួនាទីរបស់ខ្លួន ហើយដែលត្រូវលាក់ការសម្ងាត់ ។

**គ-** ក្នុងករណីដែលសាកសួរអំពីហេតុដែលទាក់ទងនឹងការសម្ងាត់ក្នុងបច្ចេកទេស ឬ វិជ្ជាជីវៈ ។

៣- បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសាក្សីទទួលការលើកលែងពីករណីយកិច្ចលាក់ការសម្ងាត់ ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 196 និង មាត្រា 197 ។

មាត្រានេះជាករណីដែលលើកលែងចំពោះករណីយកិច្ចសាក្សីជាទូទៅនៃមាត្រា ១៣២ (ករណីយកិច្ចរបស់សាក្សី) ដែលកំណត់អំពីសាក្សីដែលអាចបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សីបាន ។ កថាខណ្ឌទី ១ នេះកំណត់ថា ប្រសិនបើការផ្តល់ចម្លើយរបស់សាក្សី ធ្វើឱ្យសាក្សី ឬ សហព័ទ្ធរបស់សាក្សី ឬ ញាតិឯទៀតរបស់សាក្សី (ទំហំនៃញាតិដែលអាចបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សីបាន មានការទាក់ទងទៅនឹងបញ្ញត្តិដែលចែងនៅក្នុងក្រមរដ្ឋប្បវេណី) ទទួលការផ្តន្ទាទោស ឬ ធ្វើឱ្យខូចដល់កិត្តិយសរបស់សាក្សី សហព័ទ្ធរបស់សាក្សី ឬ ញាតិរបស់សាក្សី ក្នុងករណីនោះ សាក្សីអាចបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សីបាន ។ ម៉្យាងទៀត សាក្សីក៏អាចបដិសេធនូវការផ្តល់ចម្លើយបានក្នុងករណីដែលគេទទួលស្គាល់នូវករណីយកិច្ចលាក់ការសម្ងាត់របស់សាក្សី (នៅក្នុងកថាខណ្ឌទី ២ ចំណុច ខ នេះ តើយើងត្រូវទទួលស្គាល់ទៅលើជនដល់កម្រិតណាដែលអាចបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សីនោះ វាទាក់ទងទៅនឹងរបៀបរបបច្បាប់លាក់ការសម្ងាត់ និង ស្ថានភាពនៅប្រទេសកម្ពុជា ។ នៅប្រទេសជប៉ុន គេកំពុងតែរើកញែកផងដែរ អំពីការទទួលស្គាល់ ឬ មិនទទួលស្គាល់សិទ្ធិបដិសេធការផ្តល់ចម្លើយជាកសិណសាក្សីរបស់អ្នកសារព័ត៌មាន) ។

Code of Civil Procedure (Japan)
**Article 196** (Right to refuse to testify)
A witness may refuse to testify in cases where the testimony relates to matters which threaten that the witness or a person who has nay of the following relation to such witness will be prosecuted for crime or adjudged guilty. The same shall apply to testimony related to such matters as will bring disgrace upon any such persons:

i. any relation which is or was, spousal, or within the fourth degree of consanguinity or within the third degree of affinity;
ii. any relation as guardian or ward.

**Article 197** (*ibid*)
1. A witness may refuse to testify in the following cases:

i. in cases under Article 191, paragraph 1;
ii. in cases where the witness is questioned as to the knowledge of facts which, such witness, who is or was, a doctor, dentist, pharmacist, pharmacy, mid-wife, lawyer (including foreign law business lawyer), patent agent, advocate, notary or an occupant of a post connected with religion, prayer or worship, has obtained in the exercise of the professional duties and which facts should remain secret;
iii. in cases where the witness is questioned with respect to matters relating to technical or professional secrets.

2. The provisions of the preceding paragraph shall not apply to cases where the witness has been released from the duty of secrecy.

**មាត្រា ១៣៥.-** ដីកាសម្រេចទៅលើការបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សី

១- មូលហេតុនៃការបដិសេធនូវការផ្ដល់ចម្លើយជាកសិណសាក្សី ត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូង ។
២- លើកលែងតែក្នុងករណីនៃចំណុច **ក** កថាខណ្ឌទី ២ នៃមាត្រា ១៣៤ (សិទ្ធិបដិសេធនូវការផ្ដល់ចម្លើយជាកសិណសាក្សី) មុននេះ តុលាការដែលទទួលបណ្ដឹង ត្រូវសាកសួរទៅលើភាគី ហើយសម្រេចដោយដីកាសម្រេចអំពីការបដិសេធនូវការផ្ដល់ចម្លើយជាកសិណសាក្សីថា ត្រឹមត្រូវ ឬ មិនត្រឹមត្រូវ ។
៣- ភាគី និង សាក្សី អាចប្ដឹងជំទាស់ ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះបាន ។
៤- បញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ១៣២ (ករណីយកិច្ចរបស់សាក្សី) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសាក្សីបដិសេធនូវការផ្ដល់ចម្លើយជាកសិណសាក្សីដោយគ្មានមូលហេតុត្រឹមត្រូវ ក្រោយពេលដែលដីកាសម្រេចរបស់តុលាការដែលបានសម្រេចថា ពុំមានមូលហេតុក្នុងការបដិសេធនូវការផ្ដល់ចម្លើយជាកសិណសាក្សី ចូលជាស្ថាពរ ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 198 រហូតដល់មាត្រា 200 ។

មាត្រានេះ កំណត់នូវនីតិវិធីសម្រាប់អនុវត្តការទទួលស្គាល់សិទ្ធិបដិសេធចម្លើយជាកសិណសាក្សីដែលមានចែងនៅក្នុងមាត្រា ១៣៤ (សិទ្ធិបដិសេធនូវការផ្ដល់ចម្លើយជាកសិណសាក្សី) ។ សាក្សីដែលបដិសេធចម្លើយជាកសិណសាក្សី ត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូង ចំណែកឯតុលាការវិញ ត្រូវសម្រេចដោយយកសេចក្ដីនោះជាមូលដ្ឋាន (ចំពោះមន្ត្រីរាជការស្ថាប័នមានសិទ្ធិសម្រេច) ហើយចំពោះសេចក្ដីសម្រេចនេះ គេអនុញ្ញាតឱ្យប្ដឹងជំទាស់បាន ។

Code of Civil Procedure (Japan)
**Article 198** (Preliminary showing of grounds for refusal to testify)
The grounds for refusal to testify shall be explained by a preliminary showing.
**Article 199** (Adjudication on refusal to testify)
1. Except for the cases referred to in Article 197, paragraph 1, item i, the court before which the suit is pending shall, after interrogation to the parties, by ruling, adjudicate the propriety of refusal to testify.
2. The parties and the witness may make an immediate *kokoku*-appeal against the adjudication under the preceding paragraph.
**Article 200** (Sanction against refusal to testify)
The provisions of Article 192 and 193 shall apply *mutatis mutandis* to cases where a witness refuses to testify without justifiable reason after a decision adjudicating such witness's refusal to testify groundless has become final and binding.

## មាត្រា ១៣៦.- ការសាកសួរសាក្សីនៅក្រៅតុលាការ

១- តុលាការអាចសាកសួរសាក្សីនៅក្រៅតុលាការបាន ក្នុងករណីដូចខាងក្រោមនេះ :

**ក**- សាក្សីគ្មានករណីយកិច្ចចូលខ្លួនទៅតុលាការដែលទទួលបណ្ដឹង ឬ មានមូលហេតុត្រឹមត្រូវ ដែលមិនអាចចូលខ្លួនទៅតុលាការបាន ។

**ខ**- ការចូលខ្លួនរបស់សាក្សីទៅតុលាការដែលទទួលបណ្ដឹង បណ្ដាលឱ្យមានការចំណាយទៅលើពេលវេលា ឬ សោហ៊ុយមិនសមរម្យ ។

**គ-** គូភាគីពុំមានការតវ៉ា ។

២- ចំពោះបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចឱ្យចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ ទៅធ្វើការសាកសួរសាក្សីនៅក្រៅតុលាការបាន ។

៣- ក្នុងករណីចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ ធ្វើការសាកសួរសាក្សី ចៅក្រមនោះត្រូវបំពេញមុខនាទីរបស់តុលាការ ឬ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 195 និង មាត្រា 206 ។

ជាគោលការណ៍ការពិនិត្យភស្តុតាងត្រូវធ្វើជាសាធារណៈនៅក្នុងតុលាការ ។ មាត្រានេះកំណត់អំពីករណីដែលតុលាការអាចទៅធ្វើការសាកសួរសាក្សីនៅក្រៅតុលាការបាន ។ រូបមន្តនៃកថាខណ្ឌទី ១ ចំណុច **ក** នេះ គឺជាករណីដែលសាក្សីមិនអាចចូលខ្លួនមកតុលាការបានដោយសារភាពចាស់ជរា ឬ ដោយសារជម្ងឺ ។ ប៉ុន្តែ ដោយការសាកសួរសាក្សីនៅតុលាការ ជាគោលការណ៍ចម្បង យើងមិនអាចពង្រីកការបកស្រាយទៅលើមូលហេតុនៃកថាខណ្ឌទី ១ ទេ ។ នៅពេលធ្វើការសាកសួរសាក្សីនៅក្រៅតុលាការ បើចៅក្រមក្នុងក្រុមប្រឹក្សាជំនុំជម្រះចូលរួមទាំងអស់គ្នា នាំឱ្យចំណាយសោហ៊ុយច្រើន ដូច្នេះ គេអនុញ្ញាតឱ្យចៅក្រមម្នាក់ក្នុងចំណោមចៅក្រមក្នុងក្រុមប្រឹក្សាជំនុំជម្រះ (ចៅក្រមដែលទទួលបញ្ជា) ឬ ចៅក្រមណាដែលមានកន្លែងនៅក្បែរលំនៅដ្ឋានរបស់សាក្សី (ចៅក្រមដែលទទួលការប្រគល់សិទ្ធិ) បំពេញកិច្ចការនេះ ។

Code of Civil Procedure (Japan)
**Article 195** (Examination of witness by commissioned judge, etc.)
The court may have a commissioned judge or an assigned judge examine a witness outside the court only in the following cases:
i. in cases where the witness is not obligated to appear or is unable to appear with justifiable reason before the court before which the suit is pending;
ii. in cases where undue expense or time is necessary for the witness to appear before the court before which the suit is pending;
iii. in cases where it is necessary to examine the witness at the scene in order to discover facts;
iv. in cases where the parties have no objection.
**Article 206** (Authority of commissioned judge, etc.)
In cases where a commissioned judge or assigned judge examines a witness, such judge performs the duty of the court and the presiding judge. However, adjudication with regard to an objection under the provisions of Article 202, paragraph 3 shall be rendered by the court before which the suit is spending.

**មាត្រា ១៣៧.-** សម្បថ

១- តុលាការត្រូវឱ្យសាក្សីធ្វើសម្បថ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេស ។

២- ក្នុងករណីសាក្សីដែលនឹងត្រូវសួរ ជាជនដែលមានអាយុក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ ឬ ជនដែលមិនយល់អំពីអត្ថន័យនៃសម្បថ តុលាការមិនអាចឱ្យសាក្សីនោះធ្វើសម្បថបានឡើយ ។

៣- នៅពេលសាកសួរសាក្សីដែលត្រូវនឹងល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងបញ្ញត្តិនៃមាត្រា ១៣៤ (សិទ្ធិបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សី) នៃក្រមនេះ ហើយសាក្សីនោះមិនប្រើសិទ្ធិបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សី

តុលាការអាចមិនឱ្យធ្វើសម្បថបាន ។
៤- សម្បថរបស់សាក្សី ត្រូវធ្វើនៅមុនពេលសាកសួរ ។ ប៉ុន្តែ បើមានមូលហេតុពិសេស អាចធ្វើនៅក្រោយពេលសាកសួរបាន ។
៥- ទម្រង់នៃការធ្វើសម្បថ ត្រូវធ្វើតាមការកំណត់ក្នុងឧបសម្ព័ន្ធនៃក្រមនេះ ។
៦- មុនពេលធ្វើសម្បថ ប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវពន្យល់អំពីគោលបំណងនៃសម្បថ ហើយប្រាប់ឱ្យដឹងជាមុន អំពីការផ្តន្ទាទោសចំពោះការផ្តល់សក្ខីភាពក្លែងក្លាយ ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 201 បទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 112 ។

មាត្រានេះកំណត់អំពីនីតិវិធីនៃសម្បថរបស់សាក្សី ។ នៅក្នុងច្បាប់ជប៉ុន សាក្សីត្រូវក្រោកឈរអានទូវពាក្យសម្បថដែលបានកំណត់នៅក្នុងសាលសវនាការ ជាដើម ។ ប៉ុន្តែ ប្រទេសកម្ពុជាអនុវត្តរបៀបផ្សេង នៅពេលធ្វើសម្បថនោះ ហើយចំណុចនេះទាក់ទងនឹងសាសនាដែរ ហេតុដូច្នេះ យើងទុកចំណុចនេះឱ្យភាគីកម្ពុជាកំណត់ច្បាស់លាស់ នៅក្នុងតារាងនៃឧបសម្ព័ន្ធនៃក្រមនីតិវិធីរដ្ឋប្បវេណីនេះ ។ តែទោះជាយ៉ាងណាក៏ដោយ សម្បថនេះចាំបាច់ត្រូវធ្វើនៅចំពោះមុខចៅក្រម ឬ ធ្វើទៅតាមរបៀបណាដែលក្រឡាបញ្ជីអាចបញ្ជាក់បានថា សាក្សីនោះបានស្បថរួចហើយដែរ ។ ឯកថាខណ្ឌទី ៦ ដែលសរសេរអំពីទោសនៃការក្លែងបន្លំពាក្យសម្បថ ដោយយើងសន្និដ្ឋានជាមុនថា នៅក្នុងក្រមព្រហ្មទណ្ឌមានចែងអំពីទោសនៃការក្លែងបន្លំពាក្យសម្បថនេះ ។

<u>Code of Civil Procedure (Japan)</u>
**Article 201** (Oath)
1. Except as otherwise provided, an oath shall be administered to a witness.
2. An oath shall not be administered in cases where a person who is under 16 years of age or a person who is unable to comprehend the meaning of the oath is examined as a witness.
3. An oath need not be administered when examining a witness who comes within the purview of Article 196 and who does not exercise the right to refuse testimony.
4. A witness may refuse to take oath if the witness is to be questioned regarding matters having a vital relation to the interests of such witness or a person who has a relationship specified in any item of Article 196.
5.The provision of Article 198 and 199 shall apply *mutatis mutandis* to cases where a witness refuses to take the oath; the provisions of Article 192 and 193 shall apply *mutatis mutandis* to cases where after a decision which adjudicates that a witness has refused without grounds to take the oath has become final and binding, such witness refuses to take the oath without justifiable reason.

<u>Rules of Civil Procedure (Japan)</u>
**Article 112** (Oath / The Code Article 201)
1. The oath of a witness shall be administered before the examination. However, in cases where a special reason exists, it may be administered after the examination.
2. The oath shall be solemnly administered while standing.
3. The presiding judge shall have the witness read the written oath and sign his or her name and affix his or her seal thereon. In cases where the witness cannot read the written oath, the presiding judge shall have the court clerk read it.
4. The written oath referred to in the preceding paragraph shall include a statement to the effect that the witness swears that he or she will conscientiously speak the truth and neither conceal nor add anything.
5. The presiding judge shall, prior to the oath, instruct as to the purport of taking the oath and warn of the penalty attaching to perjury.

**មាត្រា ១៣៨.-** វិធីសាកសួរសាក្សី

១- ការស្នើសុំសាកសួរសាក្សី ត្រូវធ្វើឡើង ដោយកំណត់ឱ្យបានច្បាស់លាស់ទៅលើសាក្សីណាមួយ ។

២- អ្នកដែលស្នើសុំសាកសួរសាក្សី ត្រូវភ្ជាប់ជាមួយនូវឯកសារដែលកំណត់អំពីចំណុចត្រូវសាកសួរ ។

៣- សាក្សីត្រូវទទួលការកោះហៅយ៉ាងតិច ២ (ពីរ) សប្តាហ៍ មុនថ្ងៃសាកសួរ ។

៤- ដីកាកោះហៅសាក្សី ត្រូវសរសេរនូវកំណត់សំគាល់ដូចខាងក្រោម ហើយត្រូវភ្ជាប់មកជាមួយនូវឯកសារដែលកំណត់អំពីចំណុចសាកសួរ :

  **ក-** ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ។

  **ខ-** ពេលវេលា និង ទីកន្លែងដែលត្រូវចូលខ្លួន ។

  **គ-** ទណ្ឌកម្មដែលកំណត់ដោយច្បាប់ នឹងកើតមាន បើមិនចូលខ្លួន ។

៥- ការសាកសួរសាក្សីត្រូវធ្វើតាមលំដាប់ : ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ភាគីដែលស្នើសុំឱ្យសាកសួរសាក្សីនោះ និង ភាគីម្ខាងទៀត ។ ចៅក្រមប្រឹក្សាអាចសាកសួរទៅសាក្សីបាន នៅក្រោយពេលបានជម្រាបទៅប្រធានក្រុមប្រឹក្សាជំនុំជម្រះឱ្យបានដឹងហើយ ។

៦- ប្រសិនបើយល់ឃើញថាត្រឹមត្រូវ តុលាការអាចកែសម្រួលលំដាប់ដែលត្រូវសាកសួរសាក្សី ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៥ ខាងលើនេះបាន ។

៧- សាក្សីមិនអាចឆ្លើយដោយយកឯកសារមកអានធ្វើជាមូលដ្ឋានបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការអនុញ្ញាតពីតុលាការ ។

៨- ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការអាចអនុញ្ញាតឱ្យសាក្សីដែលត្រូវបានសាកសួរហើយ ឬ សាក្សីដែលបម្រុងនឹងត្រូវសាកសួរ ឱ្យនៅក្នុងសាលសវនាការបាន ។

៩- នៅពេលដែលតុលាការទទួលស្គាល់ថា សាក្សីពុំអាចឆ្លើយឱ្យគ្រប់គ្រាន់បាន នៅចំពោះមុខអ្នកសង្កេតការណ៍ណាម្នាក់ ដោយសារតែអ្នកនោះជាហេតុនាំឱ្យមានការភ័យព្រួយ តុលាការអាចបង្គាប់ឱ្យអ្នកសង្កេតការណ៍នោះចេញក្រៅសាលសវនាការ នៅពេលដែលសាក្សីនោះឆ្លើយ ។

១០- នៅពេលដែលយល់ឃើញថាចាំបាច់ តុលាការអាចបង្គាប់ឱ្យធ្វើការសាកសួរសាក្សី និង សាក្សីផ្សេងទៀត នៅពេលជាមួយគ្នាបាន ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 202 និង មាត្រា 203 បទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 106 រហូតដល់មាត្រា 108 មាត្រា 118 មាត្រា 120 និង មាត្រា 121 ។

មាត្រានេះកំណត់ពីរបៀបសាកសួរលើសាក្សី ។ ចំពោះកថាខណ្ឌទី ៥ នៃមាត្រានេះ ក្នុងលំដាប់លំដោយ នៃការសួរ

សាក្សី គេយកទម្រង់ដែលជាដំបូងប្រធានក្រុមប្រឹក្សាជំនុំជម្រះ (ឬ ចៅក្រមអម) សាកសួរជាមុន ហើយបន្ទាប់មកគូភាគីនីមួយៗជាអ្នកសាកសួរ ។ ក្រៅពីនេះមានរបៀបធ្វើដោយឱ្យភាគីនីមួយៗសាកសួរជាមុន ។ ការអនុវត្តដូចខាងដើម ដោយយកទម្រង់ច្បាប់ស៊ីវិល (បារាំង អាល្លឺម៉ង់) ឯទម្រង់ខាងក្រោយ តាមទម្រង់ច្បាប់អាមេរិក និង អង់គ្លេស (ប្រទេសជប៉ុនធ្លាប់អនុវត្តតាមទម្រង់ខាងដើមដែរ មុនពេលសង្គ្រាមលោកលើកទី ២ ប៉ុន្តែ ក្រោយពីសង្គ្រាមនោះ គេបានប្តូរទៅទម្រង់ខាងក្រោយវិញ) ។ បើយោលទៅតាមសភាពការណ៍បច្ចុប្បន្នរបស់ប្រទេសកម្ពុជា យើងគិតថាគួរយករបៀបដោយឱ្យចៅក្រមធ្វើការសាកសួរជាដំបូង ជាកិច្ចការដែលជាសភាពពិត ។ ប៉ុន្តែ លំដាប់ដែលចែងនៅកថាខណ្ឌទី ៦ អាចផ្លាស់ប្តូរបាន ហើយរបៀបឱ្យភាគីនីមួយៗសាកសួរជាមុន អាចអនុវត្តបាននៅអនាគតនៅពេលដែលចំនួនមេធាវីមានចំនួនច្រើន និង សមត្ថភាពគ្រប់គ្រាន់ ។ ឯចំពោះកថាខណ្ឌទី ១០ វិញ គឺបញ្ញត្តិអំពីសម្មុខីកម្ម (confrontation) ដែលជារបៀបសាកសួរទល់មុខ ដែលអាចសាកសួរសាក្សី និង សាក្សីឯទៀត នៅក្នុងពេលតែមួយអំពីចំណុចសាកសួរដូចគ្នា ដើម្បីងាយស្រួលនឹងស្វែងរកចំណុចដែលផ្ទុយគ្នា ។

<u>Code of Civil Procedure (Japan)</u>

**Article 202** (Order of examination)

1. A witness shall be examined in the order of the party who offered such witness for examination, the other party, and the presiding judge.
2. The presiding judge may, upon determining it proper, after hearing opinions of the parties, change the order referred to in the preceding paragraph.
3. In cases where a party has objected to the change under the provisions of the preceding paragraph, the court shall adjudicate the objection by ruling.

**Article 203** (Prohibition of testimony based upon written document)

A witness shall not testify based upon written documents. However, this shall not apply to cases where permission of the presiding judge has been obtained.

<u>Rules of Civil Procedure (Japan)</u>

**Article 106** (Offering of examination of witness)

Examination of a witness shall be offered by designating the person to be examined and clearly indicating the expected period of time necessary for the examination.

**Article 107** (Document in which examined matters are recorded)

1. When offering examination of a witness, at the same time, two documents in which examined matters are recorded (this shall mean a document including the matters to be examined) shall be submitted. However, in cases where unavoidable reasons exist, it is sufficient that it be submitted within a period the presiding judge designates.
2. A document in which examined matters are recorded shall be written separately and concretely to whatever extent possible.
3. The party who offers in accordance with the provisions of paragraph 1 shall directly send the document in which examined matters are recorded.

**Article 108** (Matters to be included in writ of summons)

A writ of summons shall include the following matters, and the document in which examined matters are recorded shall be attached to it:

i. indication of the parties;
ii. the date and time and place to appear;
iii. legal sanction to be imposed in the case of nonappearance.

**Article 118** (Simultaneous examination of multiple witnesses)

1. The presiding judge may, upon determining it necessary, order witnesses to be questioned simultaneously.
2. In cases where the simultaneous examination has be ordered in accordance with the provisions of preceding paragraph, that fact shall have to be entered in the record.
3. When the simultaneous examination is conducted, the presiding judge may question the witness at the start.

**Article 120** (Treatment of witness who will be subsequently examined)

The presiding judge may, upon determining it necessary, permit witnesses who will subsequently be examined to be present in the court.

**Article 121** (Requiring auditor to leave court)

The presiding judge may, upon determining that the witness cannot make a sufficient statement due to his or he being overawed by a certain auditor, after hearing the opinions of the parties, have the auditor leave court during the statement of the witness.

**មាត្រា ១៣៩.-** ការកម្រិតទៅលើសំណួរ

១- ចំពោះសំណួរ បើអាចធ្វើបាន ត្រូវធ្វើដាច់ដោយឡែក និង ច្បាស់លាស់ ។

២- លើកលែងតែករណីដែលមានមូលហេតុត្រឹមត្រូវ មិនអាចសាកសួរបានឡើយនូវសំណួរខាងក្រោមនេះ :

**ក-** សំណួរដែលប្រមាថមើលងាយ ឬ ធ្វើឱ្យច្របូកច្របល់ដល់សាក្សី ។

**ខ-** សំណួរនាំមុខ ។

**គ-** សំណួរច្រំដែល ។

**ឃ-** សំណួរដែលគ្មានទំនាក់ទំនងនឹងចំណុចវិវាទ ។

**ង-** សំណួរដែលទាមទារឱ្យថ្លែងយោបល់របស់សាក្សីផ្ទាល់ខ្លួន ។

**ច-** សំណួរដែលទាមទារឱ្យថ្លែងនូវយោបល់អំពីអង្គហេតុដែលសាក្សីពុំបានជួបប្រទះផ្ទាល់ ។

៣- តុលាការអាចកម្រិតនូវសំណួរ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិបាន នៅពេលដែលយល់ឃើញថា សំណួរនោះផ្ទុយនឹងបញ្ញត្តិដែលមានចែងនៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ។

៤- ភាគីអាចតវ៉ា ចំពោះការកម្រិតដែលធ្វើទៅតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះបាន ។

(កំណត់)

បទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 115 និង មាត្រា 117 ។

មាត្រានេះបញ្ញត្តអំពីការកម្រិតសំណួរទៅលើសាក្សី ។ ក្នុងកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ កម្រិតអំពីសំណួរសាកសួរដោយចៅក្រមនិងគូភាគី ។ ឯចំណែកកថាខណ្ឌទី ៣ និង កថាខណ្ឌទី ៤ កំណត់អំពីរបៀបដើម្បីកម្រិតសំណួររបស់គូភាគី ។

Rules of Civil Procedure (Japan)

**Article 115** (Limitation of question)

1. Questions shall be asked as separately and concretely as possible.

2. The parties shall not ask any of the following questions. However, with regard to the questions described by the items 2 to 6 inclusive, this shall not apply to cases where there is a justifiable reason for asking such question.

i. questions which insult or embarrass the witness
ii. leading question
iii. questions which duplicate a question which has already been made
iv. questions which are irrelevant to the point at issue
v. questions which request statement of opinion
vi. questions which request statement relating to a fact the witness has not experienced directly

3. The presiding judge may, upon determining that a question contravenes the provisions of the preceding paragraph, upon motion or upon the authority, restrict the scope of such question.

**Article 117** (Objection / The Code Article 202)

1. The parties may raise an objection to the adjudication of the presiding judge under the provisions of Article 113 (Order of examination), paragraph 2 and 3, Article 114 (Limitation of question), paragraph 2, Article 115 (Limitation of question), paragraph 3 and paragraph 1 of the preceding article (Utilization of document, etc. for question).

2. The court shall, upon ruling, render an adjudication immediately as to the objection referred to in the preceding paragraph.

## ផ្នែកទី ៣ ការសាកសួរភាគី

**មាត្រា ១៤០.-** ការសាកសួរសាមីភាគី

១- តុលាការអាចធ្វើការសាកសួរសាមីភាគីបាន ។ នៅក្នុងករណីនេះ តុលាការអាចឱ្យភាគីនោះស្បថបាន ។

២- ក្នុងករណីដែលធ្វើការសាកសួរសាមីភាគី បើភាគីនោះពុំចូលខ្លួន ឬ បដិសេធនូវការធ្វើសម្បថ ឬ ផ្តល់ចម្លើយដោយគ្មានមូលហេតុត្រឹមត្រូវ នោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន ។

៣- ប្រសិនបើភាគីដែលបានស្បថក្លែងបន្លំសេចក្តីថ្លែងការណ៍ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ២.០០០.០០០ (ពីរលាន) រៀលបាន ដោយដីកាសម្រេច ។

៤- ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 207 រហូតដល់មាត្រា 209 ។

មាត្រានោះបញ្ញត្តអំពីការសាកសួរទៅលើភាគីសាមីខ្លួនផ្ទាល់ ។ គេអាចប្រមើលមើលបានថា ភាគីសាមីខ្លួនផ្ទាល់នឹងថ្លែងនូវយោបល់នៃអង្គហេតុណាដែលជាផលប្រយោជន៍របស់ខ្លួនតែប៉ុណ្ណោះ ។ ដូច្នេះ ការសាកសួរទៅលើភាគីគឺជារបៀបញ្ជាក់មួយដែលឆ្លងកាត់តាមភាពលំអៀង (ចំពោះចំណុចនេះ ច្បាប់នៃប្រទេសខ្លះចែងថា ការសាកសួរភាគីនេះអាចអនុវត្តត្រឹមតែដើម្បីបង្គ្រប់ប៉ុណ្ណោះ) ។ ប៉ុន្តែ ក្នុងករណីច្រើន ភាគីគឺជាសាក្សីដែលមានព័ត៌មានទាក់ទងនឹងអង្គហេតុច្រើនជាងគេបំផុត ។ ហេតុនេះហើយ មាត្រានេះពុំបានកំណត់អ្វីជាពិសេសទេ ហើយអាចធ្វើការសាកសួរទៅលើគូភាគីបាន (ដោយយើងស្មានជាមុនថា គូភាគីនឹងអាចបញ្ចេញសេចក្តីសំអាងរបស់ខ្លួនបានគ្រប់គ្រាន់ នៅក្នុងពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) ។ ជាទូទៅ ចំពោះការមិនបង្ហាញខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ ការបដិសេធមិនស្បថ ឬ ការមិនព្រមធ្វើសេចក្តីសំអាង ភាគីនោះនឹងទទួលរងនូវទណ្ឌកម្ម ដោយសន្មតថា ការអះអាងរបស់ភាគីម្ខាងទៀតជាការពិត ។ ប៉ុន្តែ នៅក្នុងកថាខណ្ឌទី ១ ប្រសិនបើគូភាគីនោះបានស្បថហើយ តែក្លែងបន្លំសេចក្តីសំអាង យើងគិតថា ចាំបាច់បញ្ញត្តនូវទណ្ឌកម្មណាមួយ ប៉ុន្តែវាជាការមិនត្រឹមត្រូវទេ បើសិនជាយើងដាក់ទណ្ឌកម្មឱ្យជាប់គុក ។ ហេតុដូច្នេះ ត្រូវមានទណ្ឌកម្មណាមួយដែលមិនមែនជាទណ្ឌកម្មព្រហ្មទណ្ឌ ដូចជាការផាកពិន័យស៊ីវិល ។

Code of Civil Procedure (Japan)
**Article 207** (Examination of party)
1. The court may, upon motion or upon its own authority, examine the parties themselves. In such cases, the party to be examined

may be required to take an oath.
2. In cases where witnesses and the parties themselves are examined, the witnesses are examined first. However, if it is deemed proper, after hearing opinions of the parties, the parties themselves may be examined first.
**Article 208** (Effect of nonappearance, etc.)
In case where a party itself is examined, when the party, without justifiable reason, fails to appear or has refused to testify or take an oath, the court may deem the allegations of the adversary party relating to the matters examined to be true.
**Article 209** (Nonpenal fine for false statement)
1. In cases where a party who has taken an oath has made a false statement, the court shall, by ruling, impose a nonpenal fine not exceeding on hundred thousand yen.
2. An immediate *kokoku*-appeal may be made against the ruling under the preceding paragraph.
3. In the cases referred to in paragraph 1, when the party who made the false statement recognizes that such statement was false, depending on the circumstances, the court may cancel the ruling referred to in the paragraph.

**មាត្រា ១៤១.-** ការអនុវត្តដូចគ្នានឹងបញ្ញត្តិស្ដីពីការសាកសួរសាក្សី ជាអាទិ៍

១- បញ្ញត្តិនៃមាត្រា ១៣៦ (ការសាកសួរសាក្សីនៅក្រៅតុលាការ) មាត្រា ១៣៧ (សម្បថ) (ក្រៅពីកថាខណ្ឌទី ១ និង កថាខណ្ឌទី ៣) មាត្រា ១៣៨ (វិធីសាកសួរសាក្សី) (ក្រៅពីកថាខណ្ឌទី ៨ និង កថាខណ្ឌទី ១០) និង មាត្រា ១៣៩ (ការកម្រិតទៅលើសំណួរ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការសាកសួរសាមីភាគី ។

២- នៅពេលយល់ឃើញថាចាំបាច់ តុលាការអាចបង្គាប់ឱ្យធ្វើការសាកសួរសាមីភាគី ជាមួយនឹងភាគីម្ខាងទៀត ឬ ជាមួយនឹងសាក្សី នៅពេលជាមួយគ្នាបាន ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 210 បទប្បញ្ញត្តិស្ដីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 126 និង មាត្រា 127 ។

ការសាកសួរលើគូភាគីវាមានភាពខុសគ្នាពិតមែនទៅលើការសាកសួរតតិយជន ឬ ក៏គូភាគី តែករណីនេះមានផ្នែកជាច្រើន ដែលដូចគ្នានឹងការសាកសួរលើសាក្សី ។ ហេតុដូច្នេះហើយ មាត្រានេះយកបញ្ញត្តិជាច្រើនអំពីការសាកសួរសាក្សីមកអនុវត្តដូចគ្នា ចំពោះការសាកសួរសាមីភាគី ។ ប៉ុន្តែ ចំណុចដែលមានភាពមិនត្រឹមត្រូវចំពោះកិច្ចការសាកសួរសាមីភាគី (ដូចជាមាត្រា ១៣៧ (សម្បថ) កថាខណ្ឌទី ១ និង កថាខណ្ឌទី ៣ ជាដើម) ត្រូវបានដកចេញ ដោយមិនឱ្យអនុវត្តនៅទីនេះទេ ។ នៅក្នុងកថាខណ្ឌទី ២ គឺបញ្ញត្តិអំពីសម្មុខីកម្ម (confrontation) (សូមមើលមាត្រា ១៣៨ (វិធីសាកសួរសាក្សី) កថាខណ្ឌទី ១០ និង កំណត់នៃមាត្រានោះ) ចំណែកនៅកថាខណ្ឌទី ២ នេះ ដើម្បីបញ្ជាក់ឱ្យច្បាស់លាស់ថាសាមីភាគី និង សាក្សីអាចសាកសួរដោយទល់មុខគ្នាបាន យើងសរសេរផ្ទាល់ឱ្យចំៗតែម្ដងដោយមិនសរសេរថាជាបញ្ញត្តិដែលអនុវត្តដូចគ្នានោះឡើយ ។

Code of Civil Procedure (Japan)
**Article 210** (*Mutatis mutandis* application of provisions relating to examination of witness)
The provisions of Article 195, Article 201, paragraph 2, Articles 202 to 204 inclusive and 206 shall apply *mutatis mutandis* to examination of the parties themselves.

Rules of Civil Procedure (Japan)
**Article 126** (Simultaneous examination of parties together or of a party and witness)
The presiding judge may, upon determining it necessary, order the parties themselves or the party and a witness to be questioned simultaneously.
**Article 127** (*Mutatis mutandis* application of provisions relating to examination of witness / The Code Article 210)

Except as otherwise provided, the provisions of the preceding section (Examination of witness) shall apply *mutatis mutandis* to examination of the parties themselves. However, Articles 111 (Arrest and production of nonappearing witness), 120 (Treatment of witness who will be subsequently examined), and 124 (Examination in writing) shall not apply as such.

**មាត្រា ១៤២.-** ការសាកសួរអ្នកតំណាងដែលច្បាប់បានកំណត់

បញ្ញត្តិអំពីការសាកសួរសាមីភាគីនៅក្នុងក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ ហើយធ្វើជាតំណាងរបស់ភាគីនៅក្នុងបណ្តឹង ។ ប៉ុន្តែ បញ្ញត្តិនេះពុំមានការរារាំងដល់ការសាកសួរសាមីភាគី ឡើយ ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 211 ។

ចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ (អ្នកមានអំណាចមេបា អ្នកអាណាព្យាបាល ជាដើម) ដែលធ្វើតំណាងឱ្យអ្នកដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹង (អនីតិជន ជននៅក្រោមអាណាព្យាបាល ជាដើម) ឬ ចំពោះអ្នកដែលជាតំណាងនីតិបុគ្គល (នាយកតំណាងក្រុមហ៊ុន ជាដើម) ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងសាមីខ្លួនផ្ទាល់ គឺមិនយោលទៅតាមការសាកសួរសាក្សីជាតតិយជនទេ គឺអនុវត្តដូចគ្នានឹងបញ្ញត្តិស្តីពីការសាកសួរសាមីភាគី ។ ប៉ុន្តែក្នុងករណីនេះក៏ដោយ ក៏អាចសាកសួរសាមីភាគីផ្ទាល់ (ដែលជាអសមត្ថជនក្នុងការធ្វើបណ្តឹង) បានដែរ ។

Code of Civil Procedure (Japan)
**Article 210** (Examination of legal representative)
The provisions in this Act relating to examination of the parties themselves shall apply *mutatis mutandis* to examination of a legal representative of a party to the litigation. However, this shall not preclude the examination of the party itself.

## ផ្នែកទី ៤ កោសលវិច័យ

**មាត្រា ១៤៣.-** ការស្នើសុំឱ្យធ្វើកោសលវិច័យ ចំណុចធ្វើកោសលវិច័យ

១- តុលាការអាចបង្គាប់ឱ្យធ្វើកោសលវិច័យ តាមពាក្យសុំរបស់ភាគីបាន ។

២- ពេលស្នើសុំឱ្យធ្វើកោសលវិច័យ ភាគីដែលស្នើសុំត្រូវភ្ជាប់ជាមួយនូវឯកសារដែលកំណត់អំពីចំណុចដែលសុំឱ្យធ្វើកោសលវិច័យ ។ ប៉ុន្តែ ប្រសិនបើមានមូលហេតុដែលពុំអាចជៀសវាងបាន ឯកសារនោះអាចដាក់ នៅក្នុងអំឡុងពេលដែលតុលាការបានកំណត់ ។

៣- តុលាការត្រូវសួរយោបល់របស់ភាគីម្ខាងទៀត អំពីការស្នើសុំដែលមានចែងនៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ។

៤- តុលាការត្រូវកំណត់នូវចំណុចដែលត្រូវធ្វើកោសលវិច័យ ដោយយោងទៅតាមឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ហើយពិចារណាអំពីយោបល់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ។ ក្នុងករណីនេះ តុលាការត្រូវផ្ញើឯកសារអំពីចំណុចដែលត្រូវធ្វើកោសលវិច័យនោះ ទៅអ្នកជំនាញ ។

(កំណត់)

សូមមើលមាត្រា 129 នៃបទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

កោសលវិច័យ គឺជាការពិនិត្យភស្តុតាងមួយដើម្បីបង្គ្រប់ចំណេះដឹងរបស់ចៅក្រមដែលបង្គាប់ឱ្យតតិយជនដែលមានបច្ចេកទេសផ្តល់នូវបទពិសោធន៍ជំនាញ និង ចំណេះដឹង ឬ ការវាយតម្លៃលើចំណុចណាមួយដោយផ្អែកលើបទពិសោធន៍ និង ចំណេះដឹងនោះ ។ ការធ្វើកោសលវិច័យ ជាប្រភេទមួយនៃការពិនិត្យភស្តុតាង ដូច្នេះ កោសលវិច័យក៏មានលក្ខណៈដូចគ្នានឹងការពិនិត្យលើភស្តុតាងឯទៀតដែរ គឺ ជាគោលការណ៍ ត្រូវធ្វើឡើងដោយការស្នើសុំរបស់ភាគី ប៉ុន្តែ តុលាការអាចបង្គាប់ដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន បើយល់ឃើញថាចាំបាច់បន្ថែម ។ សូមមើលមាត្រា ១២៤ (ការពិនិត្យភស្តុតាង) កថាខណ្ឌទី ២ ។ មុននឹងតុលាការកំណត់នូវចំណុចដែលត្រូវធ្វើកោសលវិច័យ យោងតាមឯកសារស្នើសុំរបស់ភាគី តុលាការក៏ត្រូវសួរយោបល់ពីភាគីម្ខាងទៀត ដើម្បីផ្តល់ឱកាសឱ្យភាគីនោះបញ្ចេញនូវមតិយោបល់របស់ខ្លួនផងដែរ ។

Rules of Civil Procedure (Japan)
**Article 129** (Matters of expert testimony)
1. When offering expert testimony, a document which includes matters on which the expert testimony is offered, shall be submitted simultaneously. However, in cases where unavoidable reasons exist, it is sufficient that it be submitted within a period designated by the presiding judge.
2. Parties who offer in accordance with the provisions of the preceding paragraph shall directly send the document referred to in the paragraph.
3. The adversary party shall, if it has any opinion with regard to the document referred to in paragraph 1, submit a document stating such opinion to the court.
4. The court shall, on the basis of the document referred to in paragraph 1, and also considering the opinion referred to in the preceding paragraph, designate matters on which expert testimony shall be given. In such cases, a document which includes the matters on which expert testimony shall be given shall be sent to the expert witness.

**មាត្រា ១៤៤.-** ការចាត់តាំងអ្នកជំនាញខាងកោសលវិច័យ ករណីយកិច្ចធ្វើកោសលវិច័យ

១- អ្នកជំនាញខាងកោសលវិច័យត្រូវបានចាត់តាំងដោយតុលាការ ។

២- ជនដែលមានចំណេះវិជ្ជា និង បទពិសោធន៍ចាំបាច់ក្នុងការធ្វើកោសលវិច័យមានករណីយកិច្ចធ្វើកោសលវិច័យ ។

៣- ជនទាំងឡាយពុំអាចធ្វើជាអ្នកជំនាញខាងកោសលវិច័យបាន ក្នុងករណីដូចខាងក្រោមនេះ :

**ក-** ការធ្វើកោសលវិច័យនោះ បណ្តាលឱ្យអ្នកជំនាញផ្ទាល់ខ្លួន ឬ សហព័ទ្ធ ឬ ញាតិឯទៀតរបស់ខ្លួន អាចទទួលរងនូវការចោទប្រកាន់អំពីបទអាជ្ញា ឬ ទទួលការផ្តន្ទាទោស ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការធ្វើកោសលវិច័យនោះ អាចធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលដែលបានរៀបរាប់ខាងលើនេះ ឬ បណ្តាលឱ្យមានការបែកបាក់ធ្ងន់ធ្ងរដល់ទំនាក់ទំនងគ្រួសារ ។

**ខ-** ចំណុចដែលត្រូវធ្វើកោសលវិច័យនោះ មានការពាក់ព័ន្ធទៅនឹងកិច្ចការសម្ងាត់ក្នុងមុខនាទីរបស់ខ្លួន ជាមន្ត្រីរាជការ ឬ អតីតមន្ត្រីរាជការ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលជនទាំងនេះបានទទួលនូវការយល់ព្រមពីសំណាក់ក្រសួង ឬ ស្ថាប័នគ្រប់គ្រង ។ ក្រសួង ឬ ស្ថាប័នគ្រប់គ្រង មិនអាច

បដិសេធមិនផ្តល់ការយល់ព្រមបានឡើយ លើកលែងតែក្នុងករណីដែលអាចធ្វើឱ្យខូចផលប្រយោជន៍សាធារណៈ ឬ បណ្តាលឱ្យមានឧបសគ្គធ្ងន់ធ្ងរក្នុងការបំពេញការងាររដ្ឋ ។

**គ**- ចំណុចដែលត្រូវធ្វើកោសលវិច័យនោះ មានការពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានដឹងដោយវេជ្ជបណ្ឌិត ទន្តបណ្ឌិត ឱសថការី គិលានុបដ្ឋាយិកា គិលានុបដ្ឋាក ឆ្មប មេធាវី អ្នកមានមុខងារក្នុងសាសនា ឬ អ្នកដែលធ្លាប់មានមុខងារខាងលើនេះ ក្នុងការបំពេញតួនាទីរបស់ខ្លួន ហើយដែលត្រូវលាក់ការសម្ងាត់ ។

**ឃ**- ចំណុចដែលត្រូវធ្វើកោសលវិច័យនោះ មានការពាក់ព័ន្ធនឹងការសម្ងាត់ក្នុងបច្ចេកទេស ឬ វិជ្ជាជីវៈ ។

៤- ស្ថាប័នគ្រប់គ្រងដែលបានកំណត់ក្នុងកថាខណ្ឌទី ៣ ចំណុច **ខ** គឺព្រឹទ្ធសភា ចំពោះសមាជិកព្រឹទ្ធសភា ឬ អតីតសមាជិកព្រឹទ្ធសភា រដ្ឋសភា ចំពោះសមាជិករដ្ឋសភា ឬ អតីតសមាជិករដ្ឋសភា រីឯចំពោះសមាជិករាជរដ្ឋាភិបាល ឬ អតីតសមាជិករាជរដ្ឋាភិបាលវិញ គឺគណៈរដ្ឋមន្ត្រី ។

៥- បញ្ញត្តិនៃចំណុច **ខ គ** និង **ឃ** នៃកថាខណ្ឌទី ៣ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកជំនាញខាងកោសលវិច័យនោះ ទទួលការលើកលែងពីករណីយកិច្ចលាក់ការសម្ងាត់ ។

(កំណត់)

សូមមើលមាត្រា 212 និង មាត្រា 213 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

មាត្រានេះចែងអំពីកម្រិត (ទំហំ) របស់អ្នកទទួលកាតព្វកិច្ចធ្វើកោសលវិច័យ ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងការចែងបញ្ញត្តិនៃករណីយកិច្ចរបស់សាក្សីដែរ ។ សូមមើលមាត្រា ១៣២ ១៣៣ និង ១៣៤ នៃក្រមនេះ

<u>Code of Civil Procedure (Japan)</u>
**Article 212** (Duty to give expert testimony)
1. Any person possessing the professional knowledge and/or experience necessary to give expert testimony has a duty to give such testimony.
2. No person in the same position as those who may refuse to testify or to take an oath in accordance with the provisions of Article 1966 or Article 201, paragraph 4, or as referred to in paragraph 2 of the article may be an expert witness.
**Article 213** (Designation of expert)
An expert witness shall be designated by the court before which the suit is pending or by a commissioned judge or an assigned judge.

## **មាត្រា ១៤៥.-** បណ្តឹងផាត់ចោលអ្នកជំនាញខាងកោសលវិច័យ

១- ក្នុងករណីមានហេតុដែលរារាំងសច្ចភាពនៃការធ្វើកោសលវិច័យរបស់អ្នកជំនាញ ភាគីអាចប្តឹងផាត់ចោលអ្នកជំនាញខាងកោសលវិច័យនោះបាន នៅមុនពេលដែលអ្នកជំនាញនោះធ្វើសេចក្តីសន្និដ្ឋានអំពីចំណុចដែលត្រូវធ្វើកោសលវិច័យ ។ ទោះជាក្នុងករណីដែលអ្នកជំនាញខាងកោសលវិច័យបានធ្វើសេចក្តីសន្និដ្ឋានរួចហើយក៏ដោយ ក៏បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមូលហេតុនៃបណ្តឹងផាត់ចោលនោះ បានកើតឡើងនៅពេលក្រោយ ឬ ភាគីបានដឹងអំពីមូលហេតុនោះ ក្រោយពេលដែលអ្នកជំនាញនោះបានធ្វើសេចក្តីសន្និដ្ឋានរួច ។

២- ពាក្យសុំផាត់ចោលត្រូវតែធ្វើជាលាយល័ក្ខណ៍អក្សរ លើកលែងតែក្នុងករណីដែលពាក្យសុំនោះត្រូវបានធ្វើឡើងនៅក្នុង

កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ។
៣- ភាគីដែលដាក់ពាក្យសុំផាត់ចោល ត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីមូលហេតុនៃបណ្ដឹងផាត់ចោលនោះ ។
៤- ចំពោះដីកាសម្រេចដែលសម្រេចថា បណ្ដឹងផាត់ចោលមានមូលហេតុត្រឹមត្រូវ មិនអាចធ្វើបណ្ដឹងឧបាស្រ័យបានទេ ។
៥- ចំពោះដីកាសម្រេចដែលសម្រេចថា បណ្ដឹងផាត់ចោលគ្មានមូលហេតុត្រឹមត្រូវ អាចប្ដឹងជំទាស់បាន ។

( កំណត់)

(1) សូមមើលមាត្រា 214 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន និង មាត្រា 130 នៃបទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(2) យើងបានសរសេរពាក្យ "ត្រឹមត្រូវ" បន្ថែមនៅក្នុងកថាខណ្ឌទី ៤ និង ទី ៥ ដោយយោលទៅតាមមតិនៃការប្រជុំសម្រេចលើពាក្យ ។

(3) អ្នកជំនាញខាងកោសល្យវិច័យត្រូវបានជ្រើសតាំងឡើងដោយតុលាការ ប៉ុន្តែ បើភាគីយល់ឃើញថា មានហេតុដែលរារាំងសច្ចភាពនៃការធ្វើកោសល្យវិច័យរបស់អ្នកជំនាញ ភាគីនោះអាចប្ដឹងសុំផាត់ចោលអ្នកជំនាញនោះបាន តែបណ្ដឹងត្រូវប្ដឹងនៅមុនពេលដែលអ្នកជំនាញបានធ្វើសេចក្ដីសន្និដ្ឋានអំពីចំណុចដែលត្រូវធ្វើកោសល្យវិច័យរួច ។ លើកលែងតែមូលហេតុនៃបណ្ដឹងផាត់ចោលនោះ បានកើតឡើងនៅពេលក្រោយ ឬ ភាគីបានដឹងអំពីមូលហេតុនោះ ក្រោយពេលដែលអ្នកជំនាញបានធ្វើសេចក្ដីសន្និដ្ឋានរួច នោះបណ្ដឹងសុំផាត់ចោលអ្នកជំនាញនៅតែអាចធ្វើបាន ។
ចំពោះដីកាសម្រេចដែលតុលាការបានសម្រេចថា បណ្ដឹងផាត់ចោលនោះមានមូលហេតុត្រឹមត្រូវ មិនអនុញ្ញាតឱ្យធ្វើបណ្ដឹងឧបាស្រ័យបានឡើយ ។ ការកំណត់បែបនេះ គឺក្នុងគោលបំណងការពារផលប្រយោជន៍របស់ភាគី និងជៀសវាងនូវការអូសបន្លាយពេលវេលាយូរ ។

Code of Civil Procedure (Japan)
**Article 214** (Challenge)
1. In cases where circumstances which present an expert witness from faithfully testifying exist, the parties may challenge such expert witness before such witness makes any statement relating to the matter on which testimony shall be given. The same shall apply to cases where, even after the expert witness makes a statement, a cause for challenge subsequently arises or the parties subsequently discover the existence of such cause.
2. A motion for challenge shall be made to the court before which the suit is pending, or to the commissioned judge or the assigned judge.
3. No appeal may be made against a ruling upholding the challenge.
4. An immediate *kokoku*-appeal may be made against a ruling finding that the challenge has no grounds.

Rules of Civil Procedure (Japan)
**Article 130** (Form of motion for challenge / The Code Article 214)
1. A motion for challenge of an expert testimony shall, except for cases where it is made on an appointed date, be made in writing.
2. A preliminary showing shall be made as to the cause for challenge.

**មាត្រា ១៤៦.-** ទម្រង់នៃសេចក្ដីសន្និដ្ឋានរបស់អ្នកជំនាញខាងកោសល្យវិច័យ និង សំណួររបស់អ្នកជំនាញ ជាអាទិ៍
១- តុលាការអាចឱ្យអ្នកជំនាញខាងកោសល្យវិច័យ បញ្ចេញយោបល់ជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់បាន ។
២- ក្នុងករណីដែលមានការចាំបាច់សម្រាប់កិច្ចការធ្វើកោសល្យវិច័យ អ្នកជំនាញខាងកោសល្យវិច័យអាចចូលរួមក្នុង

សវនាការ ហើយអាចស្នើសុំឱ្យតុលាការធ្វើការសាកសួរសាក្សី ឬ សាមីភាគី ឬ ដោយទទួលការអនុញ្ញាតពីតុលាការ អាចសាកសួរដោយផ្ទាល់ទៅលើជនទាំងនោះបាន ។

(កំណត់)

(1) សូមមើលមាត្រា 215 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 132 មាត្រា 133 នៃបទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(2) ដើម្បីឱ្យអ្នកជំនាញខាងកោសលវិច័យបញ្ចេញយោបល់ដោយផ្ទាល់មាត់ នៅក្នុងមតិនៃការប្រជុំសម្រេចលើពាក្យបានស្នើសុំចែងឱ្យបានច្បាស់នូវការចាំបាច់កោះហៅដោយតុលាការ ។ តែដោយនៅមាត្រា ១៤៧ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្ដីពីការសាកសួរសាក្សី ទម្រង់សម្បថ) ខាងក្រោមនេះ មានចែងអំពីការអនុវត្តដូចគ្នាតាមបញ្ញត្តិស្ដីពីការសាកសួរសាក្សីរួចហើយនោះ នៅទីនេះយើងពុំចាំបាច់ចែងឱ្យបានច្បាស់ត្រង់ចំណុចនេះឡើយ ។

Code of Civil Procedure (Japan)
**Article 215** (Method of expert witness statement)
The presiding judge may cause an expert witness to state opinions in writing or orally.

Rules of Civil Procedure (Japan)
**Article 132** (Method of expert witness statement / The Code Article 215)
The presiding judge may have expert witnesses state opinions jointly or separately.
**Article 133** (Question by expert witness)
The expert witness may, in cases where it is necessary for expert testimony, attend the trial, and request the presiding judge to question witnesses or the parties themselves, or, upon permission of the presiding judge, directly question such persons.

**មាត្រា ១៤៧.-** ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្ដីពីការសាកសួរសាក្សី ទម្រង់សម្បថ

បញ្ញត្តិនៃផ្នែកទី ២ (ការសាកសួរសាក្សី) ជំពូកទី ៣ គន្ថីទី ២ នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការធ្វើកោសលវិច័យ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេស ។ ប៉ុន្តែ បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ១៣២ (ករណីយកិច្ចរបស់សាក្សី) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ។

(កំណត់)

មាត្រានេះ កំណត់អំពីបញ្ញត្តិស្ដីពីការសាកសួរសាក្សី ត្រូវអនុវត្តដូចគ្នា ចំពោះកោសលវិច័យ លើកលែងតែក្នុងករណីមានបញ្ញត្តិពិសេស ដោយហេតុថា អ្នកជំនាញ មានលក្ខណៈជាសាក្សីផង និង ជាជំនួយការតុលាការផង ។ ប៉ុន្តែមានការលើកលែងបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ១៣២ (ករណីយកិច្ចរបស់សាក្សី) ដែលមិនយកមកអនុវត្ត ។ អ្នកជំនាញ មានលក្ខណៈខុសគ្នាពីសាក្សី ដែលតុលាការចាត់តាំងអ្នកជំនាញផ្សេងមកជំនួសបាន ។ម្យ៉ាងទៀត ការនាំខ្លួនអ្នកជំនាញដើម្បីធ្វើកោសលវិច័យ អាចនាំឱ្យលទ្ធផលនៃកោសលវិច័យនោះមិនមានភាពត្រឹមត្រូវ ។

សូមមើលមាត្រា 216 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 131 មាត្រា 134 នៃបទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

Code of Civil Procedure (Japan)
**Article 216** (*Mutatis mutandis* application of provisions relating to examination of witness)
Except as otherwise provided, the provisions of Section 2 shall apply *mutatis mutandis* to expert testimony. However, Articles 194 and 205 shall not apply as such.

Rules of Civil Procedure (Japan)
**Article 131** (Form of oath)
1. The written oath shall include a statement to the effect that the expert witness swears to give expert testimony conscientiously and faithfully.
2. An oath of an expert witness may also have to be made in written form and then submitted to the court. In such cases, instructions as to the purport of taking the oath and a warning of the penalty attaching to perjury by the presiding judge, shall be made by sending a document which includes such matters to the expert witness.
**Article 134** (*Mutatis mutandis* application of provisions relating to examination of witness / The Code Article 216)
Except as otherwise provided, the provisions of Section 2 (Examination of witness) shall apply *mutatis mutandis* to expert testimony. However, Article 111 (Arrest and production of nonappearing witness) and 124 (Examination in writing) shall not apply as such.

## ផ្នែកទី ៥ ភស្តុតាងជាឯកសារ

**មាត្រា ១៤៨.-** ការស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារ ជាអាទិ៍

១- ការស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារ ត្រូវធ្វើឡើងដោយផ្តល់នូវឯកសារដែលសាមីភាគីមាន ឬ ដោយដាក់ពាក្យសុំទៅតុលាការឱ្យបង្គាប់ឱ្យម្ចាស់ឯកសារផ្តល់ឯកសារនោះមក ។

២- ទោះបីជាមានបញ្ញត្តិក្នុងកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏ការស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារនេះអាចធ្វើបានដោយដាក់ពាក្យសុំទៅតុលាការឱ្យស្នើសុំឱ្យម្ចាស់ឯកសារផ្ញើឯកសារនោះមក ។

៣- ក្នុងករណីដែលយល់ឃើញថាចាំបាច់ តុលាការអាចឃាត់ទុកនូវឯកសារដែលបានផ្តល់មក ឬ ដែលបានផ្ញើមកបាន ។

( កំណត់)

(1) សូមមើលមាត្រា 219 មាត្រា 226 មាត្រា 227 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន និង មាត្រា 143 នៃបទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(2) មាត្រានេះ ចែងយ៉ាងច្បាស់លាស់អំពីរបៀបស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារគឺ ①ជារបៀបដែលសាមីខ្លួន ខ្លួនឯងផ្តល់នូវឯកសារដែលមាន ②ជារបៀបដែលដាក់ពាក្យសុំទៅតុលាការឱ្យបង្គាប់ឱ្យផ្តល់ឯកសារដែលអ្នកដទៃទៀតកាន់កាប់ និង ③ជារបៀបធ្វើពាក្យសុំទៅតុលាការដើម្បីស្នើសុំឱ្យម្ចាស់ឯកសារផ្ញើឯកសារនោះមក ។ របៀបទី ③ ខុសពីរបៀបទី ② ដោយមិនមានកម្លាំងបង្ខិតបង្ខំ ទៅលើភាគីម្ខាងទៀត (ម្ចាស់ឯកសារ) ទេ គឺជានីតិវិធីរង់ចាំទទួលការយល់ព្រមចំពោះការស្នើសុំផ្ញើឯកសារពីម្ចាស់ឯកសារ ។ ជាទូទៅ របៀបនេះនឹងអាចអនុវត្តបាន ក្នុងករណីដែលម្ចាស់ឯកសារជាស្ថាប័នរដ្ឋ ដូចជាក្រសួង ជាដើម ដែលយើងអាចសង្ឃឹមថា នឹងសហប្រតិបត្តិការជាមួយតុលាការ ក្នុងការសម្រេចសេចក្តី ។

(3) អំពីការស្នើសុំឱ្យម្ចាស់ឯកសារផ្ញើឯកសារនេះ តាមមតិសមហេតុសមផលមួយក្នុងការបកស្រាយអំពីច្បាប់ជប៉ុន

ឯកសារដែលបានផ្ញើមកនោះ គឺទាល់តែមានសកម្មភាពការផ្តល់ជូនទៅតុលាការដោយភាគី ទើបអាចក្លាយជាកម្មវត្ថុនៃការពិនិត្យភស្តុតាងបាន ហេតុដូច្នេះ ការស្នើសុំឱ្យផ្ញើឯកសារនោះ គ្រាន់តែជាអំពើត្រៀមសម្រាប់ការពិនិត្យភស្តុតាងជាឯកសារតែប៉ុណ្ណោះ មិនមែនជាការផ្តល់ភស្តុតាងជាឯកសារផ្ទាល់ឡើយ ។ មតិដូចគ្នានេះ ក៏សង្កត់ផងដែរទៅលើដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ។ ប៉ុន្តែ ការដោះស្រាយបញ្ហាលំអិតនេះ ជាកិច្ចសមរម្យ ដោយភារកិច្ចនេះត្រូវដោះស្រាយតាមកិច្ចការអនុវត្តជាក់ស្តែងនៅប្រទេសកម្ពុជា ។

មួយចំណែកទៀត ចំពោះក្រមនីតិវិធីរដ្ឋប្បវេណីនេះ ការពិនិត្យភស្តុតាងជាឯកសារ ក៏ដូចគ្នានឹងរបៀបពិនិត្យភស្តុតាងឯទៀតដែរ ដែលតុលាការអាចបំពេញភារកិច្ចបន្ថែមដោយឆន្ទានុសិទ្ធិបាន (សូមមើលមាត្រា ១២៤ (ការពិនិត្យភស្តុតាង) កថាខណ្ឌទី ២) ។ ក្នុងទំនាក់ទំនងជាមួយនឹងចំណុចនេះ ការជជែកបញ្ហាបកស្រាយអំពីការស្នើសុំឱ្យម្ចាស់ឯកសារផ្ញើឯកសារនោះ ឬ ពាក្យសុំដីកាសម្រេចបង្គាប់ឱ្យផ្តល់នូវឯកសារ ដែលរៀបរាប់ខាងលើនេះ ជាការវែកញែកដែលមានសភាពខ្សត់ខ្សោយលើផលប្រយោជន៍ (ដោយសារ ទោះជាឯកសារដែល ត្រូវបានផ្ញើមក ឬ បានផ្តល់មកនោះ ភាគីមិនដាក់ជូនជាភស្តុតាងជាឯកសារក៏ដោយ តុលាការនៅតែអាចពិនិត្យ ដោយឆន្ទានុសិទ្ធិបាន) ។

សរុបសេចក្តីទៅ មាត្រានេះយើងបានចែងអំពីរបៀបស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារជា ៣ ប្រភេទ ដោយសម្លឹងធ្ងន់ទៅលើការងាយស្រួលយល់ ។

(4) យើងបានបន្ថែមពាក្យ "ទៅតុលាការ" នៅកថាខណ្ឌទី ១ និង ទី ២ ដោយយោលទៅតាមមតិនៃក្រុមការងារពិនិត្យពាក្យពេចន៍ ។

<u>Code of Civil Procedure (Japan)</u>
**Article 219** (Offer of documentary evidence)
Documentary evidence shall be offered by presentation of the document or by an application for a production order addressed to the person who has possession of the document.
**Article 226** (Request for transmission of document)
Documentary evidence may be offered by applying to the court to request the holder's transmission of a document notwithstanding the provisions of Article 219. However, this shall not apply to cases where the party is entitled to demand delivery of an authenticated copy or a transcript of the document by virtue of laws or ordinances.
**Article 227** (Retention of document)
The court may, upon determining it necessary, retain a document produced or transmitted.

<u>Rules of Civil Procedure (Japan)</u>
**Article 143** (Method of production, etc., of document)
1. Production or transmission of a document shall be made by the original or an authenticated copy, or exemplification.
2. Notwithstanding the provisions of the preceding paragraph, the court may order the production or transmission of the original document.

**មាត្រា ១៤៩.-** ការភ្ជាប់មកជាមួយនូវឯកសារបកប្រែ ជាអាទិ៍

១- ក្នុងករណីដែលការស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារដែលសរសេរជាភាសាបរទេស ភាគីដែលស្នើសុំត្រូវភ្ជាប់មកជាមួយនូវសេចក្តីបកប្រែត្រង់ចំណុចដែលខ្លួនសុំឱ្យពិនិត្យនោះ ។

២- ក្នុងករណីដែលភាគីម្ខាងទៀត មានយោបល់អំពីភាពត្រឹមត្រូវនៃសេចក្តីបកប្រែដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១

ខាងលើនេះ ភាគីនោះត្រូវដាក់ជូនតុលាការនូវយោបល់របស់ខ្លួនជាលាយល័ក្ខណ៍អក្សរ ។

(កំណត់)

សូមមើលមាត្រា 137 មាត្រា 138 នៃបទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(1) មាត្រា ៥ នៃរដ្ឋធម្មនុញ្ញ ចែងថា ភាសា និង អក្សរដែលប្រើជាផ្លូវការ គឺ ភាសា និង អក្សរខ្មែរ ។ ដូចនេះ ដើម្បីឱ្យតុលាការអាចពិនិត្យភស្តុតាងជាឯកសារដែលសរសេរជាភាសាបរទេសបាន ភាគីដែលស្នើសុំត្រូវភ្ជាប់សេចក្តីបកប្រែត្រង់ចំណុចដែលខ្លួនសុំឱ្យពិនិត្យនោះ ។ ការបកប្រែនេះ មិនទាមទារឱ្យត្រូវធ្វើឡើងដោយស្ថាប័នផ្លូវការឡើយ ។

(2) ក្នុងករណីដែលភាគីម្ខាងទៀតយល់ថា ការបកប្រែនោះខុសពីអត្ថន័យនៃឯកសារដើម ភាគីនោះអាចតវ៉ាលើចំណុចនេះទៅតុលាការបាន ។

Rules of Civil Procedure (Japan)
**Article 137** (Offer, etc., of documentary evidence / The Code Article 219)
1. When offering documentary evidence by presenting a document, up to the time of such offer, two copies (in cases where the number of the adversary parties to whom such document shall be sent is two or more than two, the number of copies shall be on plus the number of the adversary parties) shall be submitted, and, two explanatory notes which indicate the title and writer of the document and those matters which the document is intended to prove (in cases where the number of the adversary parties to whom such explanatory notes of evidence shall be sent is two or more than two, the number of notes shall be one plus the number of the adversary parties) shall be submitted except for cases where such matters are clearly acknowledged by the contents of such document. However, in cases where unavoidable reasons exist, it is sufficient that they be submitted within a period designated by the presiding judge.
2. The party who makes the offer referred to in the preceding paragraph may directly send the copy of the document and the explanatory note relating to that document which are to be sent to the adversary party.
**Article 138** (Attachment of translation, etc.)
1. When offering documentary evidence by presenting a document which is written in a foreign language, the translation of the part of the document with respect to which evidence is offered shall be attached. In such cases, when sending directly in accordance with the provisions of paragraph 2 of the preceding article (Offer, etc., of documentary evidence), the translation shall be sent directly and simultaneously.
2. The adversary party shall, in cases where it has opinions with regard to the accuracy of the translation referred to in the preceding paragraph, submit a document stating those opinions to the court.

**មាត្រា ១៥០.-** ករណីយកិច្ចផ្តល់ឯកសារ

១- បុគ្គលដែលជាម្ចាស់ឯកសារ ពុំអាចបដិសេធនូវការផ្តល់ឯកសារបានឡើយ លើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេង ។

២- បុគ្គលដែលជាម្ចាស់ឯកសារ អាចបដិសេធនូវការផ្តល់ឯកសារបាន នៅក្នុងករណីដែលឯកសារនោះត្រូវនឹងចំណុចណាមួយដូចខាងក្រោមនេះ :

**ក-** ឯកសារមានសរសេរអំពីហេតុដែលបណ្តាលឱ្យម្ចាស់ឯកសារ ឬ សហព័ទ្ធ ឬ ញាតិដទៃទៀតរបស់ខ្លួន អាចទទួលរងនូវការចោទប្រកាន់អំពីបទអាជ្ញា ឬ ទទួលការផ្តន្ទាទោស ឬ ហេតុដែលអាចនឹងធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលដែលរៀបរាប់ខាងលើ ឬ អាចបណ្តាលឱ្យមានការបាក់បែកធ្ងន់ធ្ងរដល់ទំនាក់ទំនងគ្រួសារ ។

**ខ**- ឯកសារមានការពាក់ព័ន្ធទៅនឹងកិច្ចការសម្ងាត់ក្នុងមុខនាទីរបស់មន្ត្រីរាជការ ហើយការផ្តល់ឯកសារនោះ អាចបណ្តាលឱ្យមានឧបសគ្គធ្ងន់ធ្ងរក្នុងការបំពេញការងាររដ្ឋ ។

**គ**- ឯកសារមានសរសេរអំពីអង្គហេតុដែលបានដឹងដោយវេជ្ជបណ្ឌិត ទន្តបណ្ឌិត ឆ្មប គិលានុបដ្ឋាយិកា គិលានុបដ្ឋាក ឱសថការី មេធាវី អ្នកមានមុខងារក្នុងសាសនា ឬ អ្នកដែលធ្លាប់មានមុខងារខាងលើនេះ នៅក្នុងការបំពេញតួនាទីរបស់ខ្លួន ហើយដែលខ្លួនមិនបានទទួលការលើកលែងពីករណីយកិច្ចលាក់ការសម្ងាត់ ឬ ហេតុដែលពាក់ព័ន្ធទៅនឹងការសម្ងាត់ក្នុងបច្ចេកទេស ឬ វិជ្ជាជីវៈ ហើយដែលខ្លួនមិនបានទទួលការលើកលែងពីករណីយកិច្ចលាក់ការសម្ងាត់ ។

(កំណត់)

(1) សូមមើលមាត្រា 220 និង សេចក្តីព្រាងវិសោធនកម្មរបស់មាត្រានេះនៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(2) មាត្រានេះបញ្ជាក់ច្បាស់អំពីកាតព្វកិច្ចដែលត្រូវផ្តល់ឯកសារជាទូទៅ ទោះបីឯកសារនោះជាឯកសារសាធារណៈ ឬ ជាឯកសារឯកជនក៏ដោយ ប្រសិនបើម្ចាស់ឯកសារនោះពុំមានមូលហេតុដូចដែលចែងក្នុងមាត្រានេះទេ ។

(3) ចំណុច **ក** កថាខណ្ឌទី ២ នៃមាត្រានេះ ចែងអំពីសិទ្ធិបដិសេធនូវការផ្តល់ឯកសារ ក្នុងករណីដែលមានលក្ខណៈដូចមាត្រា ១៣៤ (សិទ្ធិបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សី) កថាខណ្ឌទី ១ ហើយចំណុច **គ** នៃមាត្រានេះក៏ចែងអំពីសិទ្ធិបដិសេធនូវការផ្តល់ឯកសារ ក្នុងករណីដែលមានលក្ខណៈដូច មាត្រា ១៣៤ កថាខណ្ឌទី ២ ចំណុច **ខ** និង ចំណុច **គ** ដែរ ។

(4) មាត្រា ១៣៣ (ការសាកសួរសាក្សីជាមន្ត្រីរាជការ) កថាខណ្ឌទី ២ ចែងថា ក្នុងករណីដែលការសាកសួរអំពីការសម្ងាត់ក្នុងមុខនាទីរបស់ខ្លួនជាមន្ត្រីរាជការ អាចបណ្តាលឱ្យមានឧបសគ្គធ្ងន់ធ្ងរ ក្នុងការបំពេញការងាររដ្ឋនោះក្រសួង ឬ ស្ថាប័នដែលគ្រប់គ្រងជននោះអាចបដិសេធនូវសេចក្តីអនុញ្ញាតបាន ។ ដោយពិចារណាអំពីមាត្រា ១៣៣ នេះ ចំណុច **ខ** កថាខណ្ឌទី ២ នៃមាត្រា ១៥០ នេះ ក៏មានខ្លឹមសារថា ករណីដូចគ្នានេះ អាចបដិសេធនូវកាតព្វកិច្ចផ្តល់ឯកសារបានដែរ ។

<u>Code of Civil Procedure (Japan)</u>

**Article 220** (Duty to produce document)

The holder of a document may not refuse the production thereof in the following cases:

i. in cases where a party to the litigation is in possession of the document referred by such party to in such litigation;

ii. in cases where the party who offers the evidence is entitled to demand delivery from the holder of the document or to demand perusal thereof;

iii. in cases where the document has been drawn from the benefit of the party who offers the evidence or with regard to the legal relations between such party and the holder thereof;

iv. in addition to the cases referred to in the preceding three items, in cases where the document (except for documents in custody or possession of a public official or a person who was a public official in relation to such person's duty) is not specified in any of the following items:

a. a document in which those matters referred to in Article 196 are written relating to the holder thereof or to a person who has a relation specified in any item of the article to such holder;

b. a document in which those facts referred to in Article 197, paragraph 1, item ii or those matters referred to in item iii of the paragraph and not exempted from the duty of secrecy are written;

c. a document which is solely for the sake of the use of the holder of such document.

**មាត្រា ១៥១.-** ពាក្យសុំដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ

១- ពាក្យសុំដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ត្រូវធ្វើឡើងដោយបញ្ជាក់ឱ្យបានច្បាស់លាស់នូវចំណុចខាងក្រោមនេះ :

**ក-** ចំណងជើង និង ខ្លឹមសារនៃឯកសារ ។

**ខ-** ម្ចាស់ឯកសារ ។

**គ-** អង្គហេតុដែលត្រូវបញ្ជាក់បំភ្លឺ ។

២- ពាក្យសុំដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ។

៣- បើភាគីម្ខាងទៀតមានយោបល់ស្តីពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើ ភាគីនោះត្រូវដាក់ជូនទៅតុលាការនូវយោបល់របស់ខ្លួនជាលាយល័ក្ខណ៍អក្សរ ។

(កំណត់)

(1) សូមមើលមាត្រា 221 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន និង មាត្រា 140 នៃបទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(2) ជាលក្ខណៈផ្ទុយពីច្បាប់ប្រទេសជប៉ុន ដោយសារកាតព្វកិច្ចដាក់ជូនឯកសារត្រូវបានគេចាត់ទុកជាកាតព្វកិច្ចទូទៅ (មាត្រា ១៥០ (ករណីយកិច្ចផ្តល់ឯកសារ)) ហេតុដូច្នេះ អ្នកដែលដាក់ពាក្យសុំដីកាបង្គាប់ឱ្យផ្តល់ឯកសារ ពុំចាំបាច់សរសេរនៅក្នុងពាក្យសុំនោះ អំពីនត្ថិភាពនៃមូលហេតុបដិសេធដែលបានកំណត់នៅក្នុងមាត្រា ១៥០ (ករណីយកិច្ចផ្តល់ឯកសារ) ទេ ។ ផ្ទុយទៅវិញ ចំពោះអត្ថិភាពនៃមូលហេតុនៃការបដិសេធនេះ ភាគីម្ខាងទៀត (ម្ចាស់ឯកសារ) ត្រូវអះអាង និង បញ្ជាក់ ។

Code of Civil Procedure (Japan)

**Article 221** (Motion for order to produce document)

1. A motion for order to produce a document shall be made clearly indicating the following matters:
   i. designation of document;
   ii. gist of document;
   iii. holder of document;
   iv. fact to be proven;
   v. grounds for duty to produce document.
2. A motion for an order to produce a document based on a duty to produce the document in cases which come within the purview of item iv of the preceding article shall not be made unless the offer of such document by a motion for an order to produce the document is necessary.

Rules of Civil Procudure (Japan)

**Article 140** (Form, etc., of motion for order to produce document / The Code Article 221, etc.)

1. A motion for an order to produce a document shall be made in writing.
2. The adversary party shall, in cases where it has opinions with regard to the motion referred to in the preceding paragraph, submit a document stating such opinions to the court.
3. The provisions of Article 99 (Offering evidence), paragraph 2 and the preceding two paragraphs shall apply *mutatis mutandis* to offers under the provisions of Article 222 (Proceedings to specify document), paragraph 1 of the Code.

**មាត្រា ១៥២.-** ដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ជាអាទិ៍

១- ក្នុងករណីដែលតុលាការយល់ឃើញថា ពាក្យសុំដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារមានមូលហេតុត្រឹមត្រូវ តុលាការត្រូវបង្គាប់ដោយដីកាសម្រេច ឱ្យម្ចាស់ឯកសារផ្តល់ឯកសារនោះ ។ ក្នុងករណីនេះ បើមានផ្នែកខ្លះនៃឯកសារដែលតុលាការយល់ឃើញថា មិនចាំបាច់ពិនិត្យ ឬ មានផ្នែកខ្លះដែលពុំអាចទទួលស្គាល់ថា មានករណីយកិច្ចក្នុងការផ្តល់ជូននោះតុលាការអាចបង្គាប់ឱ្យផ្តល់ដោយលើកលែងចោលនូវផ្នែកនោះបាន ។

២- ក្នុងករណីដែលតុលាការមានបំណងនឹងបង្គាប់ឱ្យតតិយជនផ្តល់ឯកសារ តុលាការ ត្រូវសួរតតិយជននោះ ។

៣- ចំពោះដីកាសម្រេចអំពីពាក្យសុំដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ អាចប្តឹងជំទាស់បាន ។

(កំណត់)

(1) សូមមើលមាត្រា 223 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 141 នៃបទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ ការសម្រេចបង្គាប់ឱ្យផ្តល់ឯកសារទាំងមូល ឬ ផ្នែកខ្លះនៃឯកសារ អាស្រ័យទៅដោយភាពត្រឹមត្រូវនៃមូលហេតុនៃការស្នើសុំ និង ភាពចាំបាច់ក្នុងការពិនិត្យ ។

(2) ចំពោះឯកសារសាធារណៈ ដើម្បីពិនិត្យមូលហេតុនៃការបដិសេធ ដែលបានកំណត់នៅក្នុងមាត្រា ១៥០ (ករណីយកិច្ចផ្តល់ឯកសារ) កថាខណ្ឌទី ២ ចំណុច **ខ** គេអាចគិតដល់ការបង្កើតនូវនីតិវិធីពិសេស (សូមមើលកថាខណ្ឌទី 3 នៃមាត្រា 223 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន) ។

Code of Civil Procedure (Japan)
**Article 223** (Order to produce document, etc.)
1. The court shall, upon determining that there are grounds for a motion for an order to produce a document, by ruling, order the holder of the document to produce it. In such cases, if there is part which is unnecessary to be examined or if a duty to produce a part of the document is not found, the court may order the production of the document except for such part.
2. In cases where the court intends to order a third person to produce a document, the court shall interrogate the third person.
3. The court may cause the holder of a document to present it upon determining it necessary for determining whether or not the document under a motion for an order to produce falls under any of the document refereed to in Article 220, item iv, a to c inclusive. In such cases, no person may request disclosure of the document presented.
4. An immediate *kokoku*-appeal may be made against a ruling regarding a motion for an order to produce a document.

Rules of Civil Procudure (Japan)
**Article 141** (Custody of document presented / The Code Article 223)
The court may, upon determining it necessary, temporarily take a document which has been presented in accordance with the provisions of the first half of paragraph 3 of Article 223 (Order to produce document, etc.) of the Code, into custody.

**មាត្រា ១៥៣.-** អានុភាពនៅក្នុងករណីដែលភាគីមិនអនុវត្តតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ជាអាទិ៍

១- ក្នុងករណីដែលភាគីមិនអនុវត្តតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារទេ តុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងរបស់ភាគីម្ខាងទៀតដែលពាក់ព័ន្ធនឹងខ្លឹមសារក្នុងឯកសារនោះ ជាការពិតបាន ។

២- បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលភាគីបានធ្វើឱ្យវិនាសបាត់បង់នូវឯកសារដែលខ្លួនមានករណីយកិច្ចត្រូវផ្តល់ ឬ ធ្វើឱ្យឯកសារនោះមិនអាចប្រើប្រាស់បាន ក្នុងគោលបំណងរារាំងដល់ការ

ប្រើប្រាស់របស់ភាគីម្ខាងទៀត ។

៣- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ បើភាគីម្ខាងទៀតមានការពិបាកយ៉ាងខ្លាំង ក្នុងការធ្វើសេចក្តីអះអាងឱ្យបានច្បាស់លាស់អំពីខ្លឹមសារក្នុងឯកសារនោះ និង ក្នុងការបំភ្លឺអង្គហេតុដែលត្រូវបញ្ជាក់ដោយឯកសារនោះ ទោះបីប្រើភស្តុតាងផ្សេងទៀតក៏ដោយ នោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងរបស់ភាគីម្ខាងទៀតដែលពាក់ព័ន្ធនឹងអង្គហេតុនោះជាការពិតបាន ។

(កំណត់)

(1) សូមមើលមាត្រា 224 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(2) មាត្រានេះចែងអំពីអានុភាពចំពោះភាគី ក្នុងករណីដែលបានទទួលដីកាសម្រេចបង្គាប់ឱ្យផ្តល់នូវឯកសារហើយ តែមិនព្រមផ្តល់ឯកសារតាមដីកាសម្រេចនោះ ឬ ធ្វើឱ្យវិនាសបាត់បង់ ឬ ធ្វើឱ្យប្រើប្រាស់លែងកើតដោយវិធីផ្សេងទៀត ។ម្យ៉ាងទៀត យោលទៅតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ គេពុំអាចអនុវត្តរបៀបបង្ខំឱ្យម្ចាស់ឯកសារផ្តល់ឯកសារបានទេ ។ ចំពោះអានុភាពដែលភាគីម្ខាងមិនផ្តល់ឯកសារនោះ កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ កំណត់ជាមូលដ្ឋានថា ការអះអាងរបស់អ្នកដែលស្នើសុំឱ្យផ្តល់ភស្តុតាងដើម្បីបញ្ជាក់អំពីសេចក្តីថ្លែងការណ៍ក្នុងឯកសារ (ភាគីដែលធ្វើពាក្យសុំដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ) ត្រូវបានទទួលស្គាល់ថាជារឿងពិត និង អាចចាត់ទុកថាដូចជាស្ថានភាពដែលឯកសារត្រូវបានផ្តល់ជាភស្តុតាងដែរ ។ ប៉ុន្តែ ចំពោះការទទួលស្គាល់អង្គហេតុដែលឯកសារចង់បញ្ជាក់ និង បំភ្លឺថាជារឿងពិត ឬ មិនពិត វាជាការពឹងផ្អែកទៅលើការវិនិច្ឆ័យយោលទៅតាមសេរីភាព ក្នុងជំនឿទុកចិត្តរបស់ចៅក្រម ។ ប៉ុន្តែ ក្នុងករណីដែលអ្នកស្នើសុំឱ្យពិនិត្យភស្តុតាង មានការពិបាកបំផុតក្នុងការធ្វើសេចក្តីអះអាងយ៉ាងច្បាស់លាស់អំពីអត្ថបទដែលចារក្នុងឯកសារនោះ ឬ ក្នុងការបញ្ជាក់អំពីអង្គហេតុដែលនឹងត្រូវបញ្ជាក់ដោយឯកសារនោះ ដោយយកភស្តុតាងឯទៀតជាជំនួស តុលាការអាចទទួលស្គាល់ករណីពិសេសដែលចាត់ទុកថាអង្គហេតុដែលភាគីម្ខាងទៀតអះអាង ត្រូវបានបញ្ជាក់ថាជាការពិតបាន (កថាខណ្ឌទី ៣) ។

Code of Civil Procedure (Japan)
**Article 224** (Effect in cases where a party does not comply with an order to produce a document, etc.)
1. In cases where a party does not comply with an order to produce a document, the court may deem the allegations of the adversary party relating to a statement within such document to be true.
2. The same shall apply as under the preceding paragraph to cases where a party has destroyed a document which such party is bound to produce or has otherwise rendered it impossible for use for the purpose of preventing its use by the adversary party.
3. In cases prescribed in the preceding two paragraphs, when it is considerably difficult for the adversary party to make concrete allegations relating to a statement in such document and to prove the fact to be proven by such document by other evidence, the court may deem the allegations of the adversary party relating to such fact to be true.

**មាត្រា ១៥៤.-** ប្រាក់ពិន័យក្នុងករណីដែលតតិយជនមិនគោរពតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ

១- ក្នុងករណីដែលតតិយជនមិនគោរពតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើស

ពី ២.000.000 (ពីរលាន) រៀល ដោយដីកាសម្រេចបាន ។

២- ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

(កំណត់)

(1) សូមមើលមាត្រា 225 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(2) ជាករណីដែលខុសពីមាត្រា ១៨៣ (អានុភាពនៅក្នុងករណីដែលភាគីមិនអនុវត្តតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ជាអាទិ៍) ក្នុងករណីដែលតតិយជនជាម្ចាស់ឯកសារ ច្បាប់គ្រាន់តែអាចជម្រុញឱ្យតតិយជនផ្តល់ឯកសារដោយប្រយោល តាមទណ្ឌកម្មជាពិន័យស៊ីវិលបានតែប៉ុណ្ណោះ ។

Code of Civil Procedure (Japan)
**Article 225** (Nonpenal fine in cases where a third person does not comply with an order to produce a document)
1. In cases where a third person does not comply with an order to produce a document, the court shall, by ruling, impose a nonpenal fine not exceeding two hundred thousand yen.
2. An immediate *kokoku*-appeal may be made against the ruling under the preceding paragraph.

**មាត្រា ១៥៥.-** ភាពត្រឹមត្រូវក្នុងការធ្វើឯកសារ

១- ភាគីដែលបានស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារ ត្រូវបញ្ជាក់ថា ឯកសារនោះត្រូវបានធ្វើឡើងដោយត្រឹមត្រូវ ។

២- បើទទួលស្គាល់ថា ឯកសារត្រូវបានធ្វើឡើងដោយមន្ត្រីរាជការនៅក្នុងមុខនាទី ដោយផ្អែកលើទម្រង់ និង ខ្លឹមសារនៃឯកសារ នោះត្រូវសន្មតថាជាឯកសារសាធារណៈដែលបានធ្វើឡើងដោយត្រឹមត្រូវ ។

៣- បើមានមន្ទិលសង្ស័យទៅលើភាពត្រឹមត្រូវក្នុងការធ្វើឯកសារសាធារណៈ នោះតុលាការអាចសួរដោយឆន្ទានុសិទ្ធិ ទៅក្រសួង ឬ ស្ថាប័នដែលពាក់ព័ន្ធបាន ។

៤- ចំពោះឯកសារឯកជនដែលមានចុះហត្ថលេខារបស់សាមីខ្លួនផ្ទាល់ ឬ អ្នកតំណាង ត្រូវសន្មតថាជាឯកសារដែលបានធ្វើឡើងដោយត្រឹមត្រូវ ។

៥- បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះឯកសារដែលត្រូវទទួលស្គាល់ថា ត្រូវបានធ្វើឡើងដោយក្រសួង ឬ ស្ថាប័នបរទេស ។

(កំណត់)

(1) សូមមើលមាត្រា 228 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(2) មាត្រានេះចែងអំពីភាពចាំបាច់ក្នុងការបញ្ជាក់ភាពត្រឹមត្រូវនៃឯកសារ ហើយចែងអំពីបញ្ញត្តិនៃភស្តុតាងចំពោះចំណុចនេះ ។ ភាពត្រឹមត្រូវក្នុងការធ្វើឯកសារ មានន័យថា ឯកសារនោះត្រូវបានធ្វើឡើង ដោយផ្អែកលើឆន្ទៈរបស់ជនដែលធ្វើឯកសារនោះក្នុងនាមរបស់ខ្លួន ។ ប៉ុន្តែ ទោះជាគេទទួលស្គាល់ថា ឯកសារត្រូវបាន

ធ្វើឡើងដោយត្រឹមត្រូវក៏ដោយ ក៏ពុំមែនបានន័យថា គេទទួលស្គាល់អត្ថន័យដែលចុះលើឯកសារនោះជាការពិតភ្លាមទេ ។ គឺជាបញ្ហាដែលគេអាចជឿជាក់លើអត្ថបទនៃឯកសារនោះបាន ឬ មិនបាន ហើយសម្រេចទៅលើការវិនិច្ឆ័យ ដោយយោលទៅតាមសេរីភាពក្នុងការជឿទុកចិត្តរបស់ចៅក្រម ។

(3) បានកែពាក្យក្នុងកថាខណ្ឌទី ១ ដោយយោលតាមមតិនៃការប្រជុំកែពាក្យ ។

Code of Civil Procedure (Japan)

**Article 228** (Execution of document)

1. A document must be proven to be authentically executed.
2. If deemed on the grounds of its form and purport to be drawn by a public official in the exercise of official functions, such document shall be presumed to be an authentically executed official document.
3. If there is a doubt as to the authenticity of the execution of a public document, the court may, upon its own authority, inquire of the government agency or public office concerned.
4. An unofficial document shall, if it bears the signature or seal of the principal or its representative, be presumed to be authentically executed.
5. The provisions of paragraphs 2 and 3 shall apply *mutatis mutandis* to documents which shall be deemed to have been drawn by a foreign government agancy or public office.

**មាត្រា ១៥៦.-** ការបញ្ជាក់ដោយប្រៀបធៀបអក្សរដែលសរសេរដោយដៃ

១- ភាពត្រឹមត្រូវក្នុងការធ្វើឯកសារ ក៏អាចបញ្ជាក់ដោយការប្រៀបធៀបអក្សរដែលសរសេរដោយដៃបានដែរ ។

២- បញ្ញត្តិនៃមាត្រា ១៤៨ (ការស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារ ជាអាទិ៍) មាត្រា ១៥២ (ដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ជាអាទិ៍) និង កថាខណ្ឌទី ១ និង ទី ២ នៃមាត្រា ១៥៣ (អានុភាពនៅក្នុងករណីដែលភាគីមិនអនុវត្តតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការដាក់ ឬ ផ្ញើនូវឯកសារ ឬ វត្ថុឯទៀត ដែលមានសរសេរអក្សរដោយដៃ ដើម្បីប្រើប្រាស់ក្នុងការប្រៀបធៀប ។

៣- បើគ្មានអក្សរដែលសរសេរដោយដៃរបស់ភាគីម្ខាងទៀត ដែលមានលក្ខណៈសមរម្យដើម្បីធ្វើការប្រៀបធៀប តុលាការអាចបង្គាប់ឱ្យភាគីនោះសរសេរអក្សរដើម្បីប្រើប្រាស់ក្នុងការប្រៀបធៀប ដោយដីកាសម្រេចបាន ។

៤- ក្នុងករណីដែលភាគីម្ខាងទៀតពុំព្រមធ្វើតាមដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ដោយគ្មានមូលហេតុត្រឹមត្រូវទេ តុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីភាពត្រឹមត្រូវក្នុងការធ្វើឯកសាររបស់អ្នកស្នើសុំឱ្យពិនិត្យឯកសារ ជាការពិត ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការសរសេរអក្សរនោះកែរូបរាង ។

៥- ក្នុងករណីដែលតតិយជនពុំព្រមធ្វើតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៥៣ (អានុភាពនៅក្នុងករណីដែលភាគីមិនអនុវត្តតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា នៅក្នុងបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រានេះ ដោយគ្មានមូលហេតុត្រឹមត្រូវទេ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ២.០០០.០០០ (ពីរលាន) រៀល ដោយដីកាសម្រេចបាន ។

៦- ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៥ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

( កំណត់ )

(1) សូមមើលមាត្រា 229 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(2) មាត្រានេះចែងថា ក្រៅពីតាមវិធីបញ្ជាក់ថា ជនដែលធ្វើឯកសារក្នុងនាមរបស់ខ្លួន ពិតជាធ្វើឯកសារនោះ ដោយយកជននោះ ឬ តតិយជន មកសាកសួរជាសាក្សី ភាពត្រឹមត្រូវក្នុងការធ្វើឯកសារ "ក៏អាចបញ្ជាក់ ដោយការប្រៀបធៀបអក្សរដែលសរសេរដោយដៃបានដែរ" ។

<u>Code of Civil Procedure (Japan)</u>
**Article 229** (Proof by comparing handwriting, etc.)
1. The authenticity of the execution of a document may also be proven by comparing handwriting or seal impressions.
2. The provisions of Articles 219 and 233, Article 224, paragraphs1 and 2, and Articles 226 and 227 shall apply *mutatis mutandis* to the production or transmission of a document or any other article prepared with handwriting or a seal impression to be used for comparison.
3. In cases where there is no suitable handwriting of the adversary party for comparison, the court may order the adversary party to draft letters to be used for comparison.
4. In cases where a party, without justifiable reason, does not comply with the order under the preceding paragraph, the court may deem true the allegations of the party who has offered the evidence relating to the authenticity of the execution of the document. The same shall apply to cases where the writing has been disguised.
5. In cases where a third person, without justifiable reason, does not comply with the order to produce a document under the provisions of Article 223, paragraph 1 as applied *mutatis mutandis* in paragraph 2 of this article, the court shall, by ruling, impose a nonpenal fine not exceeding one hundred thousand yen.
6. An immediate *kokoku*-appeal may be made against the ruling under the preceding paragraph.

**មាត្រា ១៥៧.-** ប្រាក់ពិន័យចំពោះអ្នកប្រកែកនឹងភាពត្រឹមត្រូវក្នុងការធ្វើឯកសារ

១- ក្នុងករណីដែលភាគី ឬ អ្នកតំណាងរបស់ភាគីនោះប្រកែកនឹងភាពត្រឹមត្រូវក្នុងការធ្វើឯកសារ ដោយផ្ទុយពីការពិត ដោយចេតនា ឬ ដោយកំហុសធ្ងន់ធ្ងរ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ១.000.000 ( មួយលាន ) រៀល ដោយដីកាសម្រេចបាន ។

២- ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៣- ចំពោះករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើភាគី ឬ អ្នកតំណាង ដែលប្រកែកនឹងភាពត្រឹមត្រូវក្នុងការធ្វើឯកសារ បានទទួលស្គាល់ថា ឯកសារនោះ មានភាពត្រឹមត្រូវវិញ នៅក្នុងពេលដែលបណ្តឹងកំពុងត្រូវបានចាត់ការ នោះតុលាការអាចលុបចោលនូវដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយយោលទៅតាមស្ថានភាពបាន ។

( កំណត់ )

(1) សូមមើលមាត្រា 230 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(2) ចំពោះការពិន័យជាប្រាក់ សូមមើលមាត្រា ១៤០ ( ការសាកសួរសាមីភាគី ) ។

(3) ឯកសារជាភស្តុតាងដ៏សំខាន់មួយក្នុងនីតិវិធីរដ្ឋប្បវេណី ។ ការប្រកែកអំពីភាពត្រឹមត្រូវនៃឯកសារ ធ្វើឱ្យប៉ះពាល់

ទៅដល់ផលប្រយោជន៍នៃភាគីម្ខាង និង ភាពឆាប់រហ័សនៃនីតិវិធី ។ ដូច្នេះ ទើបមាត្រានេះកំណត់ដាក់ទណ្ឌកម្មពិន័យស៊ីវិលចំពោះជនដែលប្រកែកនឹងភាពត្រឹមត្រូវក្នុងការធ្វើឯកសារ ដែលផ្ទុយពីការពិត ដោយចេតនា ឬ ដោយកំហុសធ្ងន់ធ្ងរ ដោយដីកាសម្រេច ។ ប៉ុន្តែ ប្រសិនបើមានការទទួលស្គាល់ថា ឯកសារនោះមានភាពត្រឹមត្រូវវិញ ក្នុងអំឡុងពេលបណ្តឹងកំពុងត្រូវបានចាត់ការ តុលាការអាចលុបចោលដីកាសម្រេចនោះបាន ។

Code of Civil Procedure (Japan)
**Article 230** (Nonpenal fine against a person who disputes authenticity of execution of document)
1. In cases where a party or the representative of a party intentionally or through gross negligence falsely disputes the authenticity of the execution of a document, the court shall, by ruling, impose a nonpenal fine not exceeding one hundred thousand yen.
2. An immediate *kokoku*-appeal may be made against the ruling under the preceding paragraph.
3. In the cases referred to in paragraph1, when the party or the representative who has disputed the authenticity of the execution of the document has recognized the authenticity thereof during the pendency of the suit, the court may, depending on the circumstances, cancel the ruling referred to in the paragraph.

**មាត្រា ១៥៨.-** ការអនុវត្តដូចគ្នាចំពោះវត្ថុដែលទុកដូចជាឯកសារ

បញ្ញត្តិនៃផ្នែកនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះវត្ថុដែលមិនមែនជាឯកសារ ដូចជាប្លង់ រូបថត ខ្សែអាត់ ខ្សែវីដេអូ និង វត្ថុឯទៀតដែលបង្កើតឡើងសម្រាប់ផ្តល់ព័ត៌មាន ។

(កំណត់)

(1) សូមមើលមាត្រា 231 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន និង មាត្រា 147 នៃបទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(2) មាត្រានេះចែងអំពីរបៀបនៃភស្តុតាងដែលផ្សេងពីឯកសារដោយមិនប្រើតួអក្សរ ឬ តួសញ្ញា ហើយអនុញ្ញាតឱ្យយកវត្ថុដែលសម្រាប់កត់ត្រាថតទុកនូវព័ត៌មានទាំងនោះមកប្រើប្រាស់ជាភស្តុតាង ។ ចំពោះការពិនិត្យភស្តុតាងបែបនេះ ជាគោលការណ៍ គេអនុវត្តដូចគ្នានឹងឯកសារផងដែរ ។ បញ្ញត្តិនៃមាត្រានេះ គ្រាន់តែលើកជាឧទាហរណ៍តែប៉ុណ្ណោះ ហើយអាចយកមកអនុវត្តបាន ចំពោះគ្រឿងផ្សេងៗដើម្បីផ្សាយព័ត៌មានដែលបានប្រើប្រាស់ក្នុងកុំព្យូទ័រ ជាដើម ។

Code of Civil Procedure (Japan)
**Article 231** (*Mutatis mutandis* application to article corresponding to document)
The provisions of this section shall apply *mutatis mutandis* to drawings, photographs, recording tapes, video tapes, and any other articles which are made in order to express information and which are not documents.

Rules of Civil Procedure (Japan)
**Article 147** (*Mutatis mutandis* application to article corresponding to document / The Code Article 231)
Except as otherwise provided, the provisions of Article 137 to the preceding article inclusive shall apply *mutatis mutandis* to articles referred to in Article 231( *Mutatis mutandis* application to article corresponding to document) of the Code.

**មាត្រា ១៥៩.-** របៀបចាត់ចែងក្នុងករណីដែលមានការស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារ ដែលកត់ចម្លងពីខ្សែអាត់ជាអាទិ៍

ភាគីដែលស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារ ដោយដាក់ឯកសារដែលកត់ចម្លងជាលាយល័ក្ខណ៍អក្សរ ពីខ្សែអាត់ ឬ

ខ្សែវីដេអូ ឬ វត្ថុដែលអាចថតរូបធាតុដែលទៀងទាត់បានតាមវិធីផ្សេងទៀត កាលបើភាគីម្ខាងទៀតសុំឱ្យផ្ដល់នូវវត្ថុចម្លងពីវត្ថុទាំងឡាយនោះ ភាគីត្រូវផ្ដល់វត្ថុចម្លងនោះ ទៅភាគីម្ខាងទៀត ។

(កំណត់)

(1) សូមមើលមាត្រា 68 មាត្រា 144 នៃបទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(2) មាត្រានេះមិនមែនចែងថា ភាគីអាចស្នើសុំឱ្យពិនិត្យភស្តុតាងជាខ្សែអាត់ ជាអាទិ៍ទេ តែទទួលស្គាល់នូវសិទ្ធិទាមទារឱ្យផ្ដល់វត្ថុចម្លងពីខ្សែអាត់ ជាអាទិ៍នោះ ដើម្បីឱ្យភាគីម្ខាងទៀតពិនិត្យឯកសារដែលកត់ចម្លងជាលាយល័ក្ខណ៍អក្សរពីខ្សែអាត់ ជាអាទិ៍នោះ ប្រសិនបើមានការស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារដែលកត់ចម្លងជាលាយល័ក្ខណ៍អក្សរពីខ្សែអាត់ ជាអាទិ៍ ។

Rules of Civil Procedure (Japan)
**Article 68** (Record on recording tape, etc., in lieu of entry in record) > *see the note for Article 120*
**Article 144** (Treatment in cases where documentary evidence relating to a document which is a translation of a recording tape, etc., has been offered)
A party who has offered documentary evidence by presenting a document which is translation of a recording tape, etc., shall, in cases where the adversary party has requested delivery of a duplication of the tape, etc., deliver it to the adversary party.

**មាត្រា ១៦០.-** ការដាក់ឯកសារពន្យល់អំពីអត្ថន័យនៃខ្សែអាត់ ជាអាទិ៍

១- ភាគីដែលស្នើសុំឱ្យពិនិត្យភស្តុតាងជាខ្សែអាត់ ឬ ខ្សែវីដេអូ ឬ វត្ថុដែលអាចថតរូបធាតុដែលទៀងទាត់បានតាមវិធីផ្សេងទៀត បើមានសំណូមពរពីតុលាការ ឬ ភាគីម្ខាងទៀត ភាគីនោះត្រូវដាក់ជូននូវឯកសារដែលបានកត់ចម្លងអត្ថន័យចេញពីវត្ថុនោះ ឬ ឯកសារដែលពន្យល់អំពីអត្ថន័យនៃវត្ថុនោះ ។

២- ប្រសិនបើភាគីម្ខាងទៀត មានយោបល់អំពីសេចក្ដីពន្យល់អត្ថន័យនៅក្នុងឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ភាគីនោះត្រូវដាក់ជូនទៅតុលាការនូវឯកសារដែលសរសេរអំពីយោបល់របស់ខ្លួន ។

(កំណត់)

សូមមើលមាត្រា 68 និងមាត្រា 149 នៃបទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(1) ការពិនិត្យភស្តុតាងជាខ្សែអាត់ ជាអាទិ៍ ត្រូវធ្វើដោយចាក់ខ្សែអាត់ ជាអាទិ៍ នៅសាលសវនាការ ហើយប្រសិនបើភាគីដាក់ជូននូវឯកសារដែលបានកត់ចម្លងអត្ថន័យចេញពីវត្ថុនោះ ឬ ឯកសារដែលពន្យល់អំពីអត្ថន័យនៃវត្ថុនោះ មានផលប្រយោជន៍ក្នុងការពិនិត្យភស្តុតាងនោះដោយមានភាពឆាប់រហ័ស ។ ហេតុនេះ កថាខណ្ឌទី ១ នៃមាត្រានេះ កំណត់នូវករណីយកិច្ចរបស់ភាគី ក្នុងការសហការ ដើម្បីឱ្យពិនិត្យភស្តុតាងដោយមានភាពឆាប់រហ័ស ដោយតម្រូវឱ្យភាគីដែលស្នើសុំឱ្យពិនិត្យភស្តុតាងជាខ្សែអាត់ ជាអាទិ៍ ផ្ដល់នូវឯកសារខាងលើនេះ ប្រសិនបើមានសំណូមពរពីតុលាការ ឬ ពីភាគីម្ខាងទៀត ។

(2) បើភាគីម្ខាងទៀតមានយោបល់ ទៅលើឯកសារដែលបានកត់ចម្លងអត្ថន័យ ឬ ឯកសារពន្យល់អត្ថន័យពីខ្សែអាត់ជាអាទិ៍នោះ ភាគីនោះត្រូវដាក់ជូនតុលាការនូវយោបល់របស់ខ្លួន ជាលាយល័ក្ខណ៍អក្សរ ។

Rules of Civil Procedure (Japan)
**Article 68** (Record on recording tape, etc., in lieu of entry in record) > *see the note for Article 120*
**Article 149** (Submission, etc., of document explaining contents of recording tape, etc.)
1. A party who has offered examination of evidence relating to a recording tape, ect., shall, in cases where the court or the adversary party has so requested, submit a document in chich the contents of that tape, etc., are explained (including a translation of that tape, etc.).
2. The party referred to in the preceding paragraph shall directly send the document referred to in the paragraph.
3. The adversary party shall, in cases where it has opinions with regard to the contents of explanation in the document referred to in paragraph 1, submit a document stating those opinions to the court.

## ផ្នែកទី ៦ ការត្រួតពិនិត្យ

**មាត្រា ១៦១.-** ការស្នើសុំឱ្យត្រួតពិនិត្យ

ការស្នើសុំឱ្យត្រួតពិនិត្យត្រូវធ្វើឡើង ដោយចង្អុលបង្ហាញនូវកម្មវត្ថុដែលត្រូវត្រួតពិនិត្យ ។

(កំណត់)

(1) សូមមើលមាត្រា 150 នៃបទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(2) ការត្រួតពិនិត្យ (inspection, vérifications personnelles du juge) គឺប្រភេទមួយនៃការពិនិត្យភស្តុតាង ដែលជាការពិនិត្យផ្ទាល់ទៅលើលក្ខណៈ ធាតុរបស់វត្ថុដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ ដោយវិញ្ញាណទាំង ៥ របស់ចៅក្រម ហើយយកអត្ថន័យដែលបានអំពីលទ្ធផលនៃការត្រួតពិនិត្យនោះ មកធ្វើជាភស្តុតាង ។ ទោះជាឯកសារក៏ដោយ បញ្ហាមិនស្ថិតនៅលើអត្ថន័យ ដែលសរសេរនៅលើឯកសារនោះទេ ប្រសិនបើជាវិធីស្រាវជ្រាវភស្តុតាងលើលក្ខណៈនៃក្រដាស ឬ អក្សរសរសេរដៃ ឯកសារនោះគឺជាកម្មវត្ថុនៃការត្រួតពិនិត្យ ។ ចំពោះរូបវន្តបុគ្គល ក្នុងករណីដែលមានបញ្ហាលើអត្ថន័យ នៃសេចក្តីសំអាង យើងធ្វើដោយវិធីសាកសួរសាក្សី ឬ សាកសួរសាមីភាគី តែបើជាបញ្ហាលើរូបរាងកាយ ឬ លើភិនភាគវិញ គឺជាកម្មវត្ថុនៃការត្រួតពិនិត្យ ។

Rules of Civil Procedure (Japan)
**Article 150** (Form of offer of inspection)
Inspection shall be offered by indicating the object to be inspected.

**មាត្រា ១៦២.-** ការបង្ហាញនូវកម្មវត្ថុដែលត្រូវត្រួតពិនិត្យ ជាអាទិ៍

១- បញ្ញត្តិនៃមាត្រា ១៤៨ (ការស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារ ជាអាទិ៍) មាត្រា ១៥២ (ដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ជាអាទិ៍) និង មាត្រា ១៥៣ (អានុភាពនៅក្នុងករណីដែលភាគីមិនអនុវត្តតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ

ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការបង្ហាញ ឬ ការផ្ញើមកនូវកម្មវត្ថុដែលត្រូវត្រួតពិនិត្យ ។

២- ក្នុងករណីដែលតតិយជនមិនព្រមធ្វើតាមដីកាសម្រេចបង្គាប់ឱ្យបង្ហាញ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៥២ (ដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា នៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ដោយគ្មានមូលហេតុត្រឹមត្រូវទេ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ២.000.000 (ពីរលាន) រៀល ដោយដីកាសម្រេចបាន ។

៣- ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

(កំណត់)

(1) សូមមើលមាត្រា 232 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(2) មាត្រានេះកំណត់ថា បញ្ញត្តិនៃភស្តុតាងជាឯកសារ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការបង្ហាញ និងផ្ញើវត្ថុដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ ។ ប៉ុន្តែ មាត្រានេះមិនតម្រូវឱ្យយកបញ្ញត្តិស្តីពីភស្តុតាងជាឯកសារទាំងអស់មកអនុវត្តឡើយ ។ ការដែលមាត្រា ១៥0 មិនត្រូវយកមកអនុវត្តដូចគ្នា ដោយហេតុថា កិច្ចសហប្រតិបត្តិការក្នុងការត្រួតពិនិត្យ គឺជាករណីយកិច្ចទូទៅរបស់បុគ្គល ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការ ។

Code of Civil Procedure (Japan)
**Article 232** (Presentation, etc., of objects to be inspected)
1. The provisions of Articles 219, 223, 224, 226 and 227 shall apply *mutatis mutandis* to the presentation or transmission of objects to be inspected.
2. In cases where a third person, without justifiable reason, does not comply with the order to present under the provisions of Article 223, paragraph 1 as applied *mutatis mutandis* in the preceding paragraph, the court shall, by ruling, impose a nonpenal fine not exceeding two hundred thousand yen.
3. An immediate *kokoku*-appeal may be made against the ruling under the preceding paragraph.

## ផ្នែកទី ៧ ការថែរក្សាការពារភស្តុតាង

**មាត្រា ១៦៣.-** ការថែរក្សាការពារភស្តុតាង

១- ក្នុងករណីដែលតុលាការយល់ឃើញថា មានស្ថានភាពដែលនឹងមានការលំបាកក្នុងការប្រើប្រាស់ភស្តុតាង បើមិនធ្វើការពិនិត្យភស្តុតាងនោះជាមុនទេ នោះតុលាការអាចធ្វើការពិនិត្យភស្តុតាងជាមុនបាន តាមពាក្យសុំ ដោយអនុលោមតាមបញ្ញត្តិនៃជំពូកនេះ ។

២- លទ្ធផលនៃការពិនិត្យភស្តុតាងដែលធ្វើឡើង ដោយអនុលោមទៅតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវមានប្រសិទ្ធភាពនៅក្នុងបណ្តឹងអង្គសេចក្តី ។

៣- ក្នុងការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងអង្គសេចក្តី ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃការពិនិត្យភស្តុតាងដែលបានធ្វើឡើង ដោយអនុលោមទៅតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

(1) សូមមើលមាត្រា 234 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 152 នៃបទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(2) ការពិនិត្យភស្តុតាង នឹងត្រូវធ្វើឡើង តាមការស្នើសុំរបស់ភាគី នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ។ ប៉ុន្តែមានករណីពិសេសខ្លះ ដែលអាចធ្វើការពិនិត្យភស្តុតាង មុនពេលដាក់ពាក្យបណ្តឹងបាន ក្នុងគោលដៅថែរក្សាការពារភស្តុតាងដែលអាចនឹងបាត់បង់ ឬ កែក្រឡៃបាន ដូចជាការសាកសួរសាក្សីដែលស្ថិតនៅស្ថានភាពគ្រោះថ្នាក់ដល់ជីវិត ឯកសារតាមដានការព្យាបាលអ្នកជំងឺ ជាដើម ។

(3) លទ្ធផលនៃការពិនិត្យភស្តុតាងដែលត្រូវបានធ្វើឡើង ដើម្បីថែរក្សាការពារភស្តុតាងនោះ មានប្រសិទ្ធិភាពចំពោះបណ្តឹងអង្គសេចក្តី (កថាខណ្ឌទី ២) តែដើម្បីឱ្យមានប្រសិទ្ធិភាព ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃការពិនិត្យភស្តុតាង ក្នុងការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងអង្គសេចក្តី (កថាខណ្ឌទី ៣) ។ នេះគឺជាហេតុដែលនាំឱ្យគេយកតែអ្វីដែលបានមកពីការទាញហេតុផលដោយផ្ទាល់មាត់តែប៉ុណ្ណោះ មកធ្វើជាមូលដ្ឋាននៃសាលក្រម ហើយចៅក្រមដែលចេញសាលក្រម ជាចាំបាច់គឺជាចៅក្រមដែលជាប់ពាក់ព័ន្ធនឹងការទាញហេតុផលដោយផ្ទាល់មាត់ គឺជានីតិវិធីដែលចាំបាច់ក្នុងគោលការណ៍និយមធ្វើផ្ទាល់ (មានករណីខ្លះដែលចៅក្រមទទួលបន្ទុកក្នុងការពិនិត្យភស្តុតាងដែលធ្វើឡើងដើម្បីថែរក្សាការពារ ជាចៅក្រមផ្សេងពីចៅក្រមដែលទទួលបន្ទុកចំពោះបណ្តឹងអង្គសេចក្តី) ។ ត្រង់ចំណុចនេះ កថាខណ្ឌទី ៣ នេះ មានគោលបំណងស្រដៀងគ្នានឹងសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ពេលក្រោយ (មាត្រា ១១៦ (សេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ការទាញហេតុផល)) ។

Code of Civil Procedure (Japan)
**Article 234** (Preservation of evidence)
The court, upon determining that circumstances exist which make the availability of evidence difficult unless examination thereof is made before the time for examination in the ordinary course of the proceedings, may, upon motion, conduct such examination according to the procedures established by this chapter.

Rules of Civil Procedure (Japan)
**Article 152** (Examination of evidence in proceedings of presentation of evidence / The Code Article 234)
The provisions of this chapter shall apply to the examination of evidence in proceedings for the preservation of evidence.

## មាត្រា ១៦៤.- តុលាការមានសមត្ថកិច្ច

១- ពាក្យសុំឱ្យថែរក្សាការពារភស្តុតាងដែលធ្វើក្រោយពេលដាក់ពាក្យបណ្តឹង ត្រូវធ្វើនៅតុលាការនៃលំដាប់ថ្នាក់ដែលភស្តុតាងនោះនឹងត្រូវបានប្រើប្រាស់ ។

២- ពាក្យសុំឱ្យថែរក្សាការពារភស្តុតាងដែលធ្វើមុនពេលដាក់ពាក្យបណ្តឹង ត្រូវធ្វើនៅសាលាដំបូងដែលមានសមត្ថកិច្ចនៅទីសំណាក់របស់បុគ្គលដែលត្រូវទទួលការសាកសួរ ឬ របស់បុគ្គលដែលជាម្ចាស់ឯកសារ ឬ នៅទីកន្លែងនៃវត្ថុដែលជា

កម្មវត្ថុនៃការត្រួតពិនិត្យ ។

៣- ក្នុងករណីដែលមានស្ថានភាពជាបន្ទាន់ ទោះជានៅក្រោយពេលបានដាក់ពាក្យបណ្ដឹងក៏ដោយ ក៏ពាក្យសុំឱ្យថែរក្សាការពារភស្តុតាង អាចធ្វើនៅសាលាដំបូងដូចបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះបានដែរ ។

(កំណត់)

(1) សូមមើលមាត្រា 235 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ មាត្រានេះកំណត់អំពីសមត្ថកិច្ចរបស់តុលាការក្នុងការថែរក្សាការពារភស្តុតាង ។

(2) កថាខណ្ឌទី ៣ គឺជាករណីលើកលែងរបស់កថាខណ្ឌទី ១ ដែលចែងថា ក្នុងករណីដែលមានស្ថានភាពបន្ទាន់ ទោះជានៅក្រោយការដាក់ពាក្យបណ្ដឹងក៏ដោយ ក៏ពាក្យសុំឱ្យថែរក្សាការពារភស្តុតាង អាចធ្វើបានដែរ នៅសាលាដំបូងដែលមានសមត្ថកិច្ចលើទីសំណាក់របស់បុគ្គលដែលត្រូវទទួលការសាកសួរ ឬ របស់បុគ្គលដែលជាម្ចាស់ឯកសារ ឬ លើទីកន្លែងនៃវត្ថុដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ ។

Code of Civil Procedure (Japan)
**Article 235** (Court with jurisdiction, etc.)
1. A motion for preservation of evidence after the institution of a suit shall be made to the court of instance before which the evidence is to be employed. However, it shall be made to the court before which the suit is pending after the first date has been set for oral argument, or the case has been referred to preparations for argument proceedings or preparatory proceedings by document, and before the oral argument are concluded.
2. A motion for preservation of evidence before the institution of a suit shall be made to the district court or the summary court which has jurisdiction over the place of residence of the person to be examined or the person who holds the document to be examined, or the place where the article to be inspected exists.
3. In cases where urgent circumstances exist, a motion for preservation of evidance may be made to the district court or the summary court referred to in the preceding paragraph even after the institution of a suit.

## **មាត្រា ១៦៥.-** របៀបដាក់ពាក្យសុំឱ្យថែរក្សាការពារភស្តុតាង

១- ពាក្យសុំឱ្យថែរក្សាការពារភស្តុតាង ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ។

២- ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសរសេរនូវចំណុចដូចខាងក្រោមនេះ :

**ក**- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគីម្ខាងទៀត ។

**ខ**- អង្គហេតុដែលត្រូវបញ្ជាក់ ។

**គ**- ភស្តុតាងដែលត្រូវថែរក្សាការពារ ។

**ឃ**- មូលហេតុនៃការថែរក្សាការពារភស្តុតាង ។

៣- មូលហេតុនៃការថែរក្សាការពារភស្តុតាង ត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូង ។

(កំណត់)

សូមមើលមាត្រា 153 នៃបទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

Rules of Civil Procedure (Japan)
**Article 153** (Form of motion for preservation of evidence / The Code Article 235)
1. A motion for the preservation of evidence shall be made in writing.
2. The document referred to in the preceding paragraph shall include the following matters:
   i. indication of the adversary party
   ii. facts to be proven
   iii. evidence
   iv. reasons for preservation of the evidence
3. A preliminary showing shall be made as to the reason for preservation of the evidence.

**មាត្រា ១៦៦.-** វិធីចាត់ចែងក្នុងករណីដែលពុំអាចកំណត់ភាគីម្ខាងទៀតបាន

ពាក្យសុំឱ្យថែរក្សាការពារភស្តុតាងអាចធ្វើទៅបាន ទោះជាមិនអាចកំណត់ភាគីម្ខាងទៀតបានក៏ដោយ ។ ក្នុងករណីនេះ តុលាការអាចជ្រើសតាំងអ្នកតំណាងពិសេសសម្រាប់ជនដែលនឹងក្លាយជាភាគីម្ខាងទៀតបាន ។

(កំណត់)

សូមមើលមាត្រា 236 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

ជាធម្មតា ភាគីដែលដាក់ពាក្យសុំអោយថែរក្សាការពារភស្តុតាង ត្រូវកំណត់បុគ្គលដែលជាភាគីម្ខាងទៀត ។ តែមាត្រានេះ កំណត់អំពីសិទ្ធិអំណាចរបស់តុលាការក្នុងការជ្រើសតាំង អ្នកតំណាងពិសេស (មាត្រា ៣៦) សម្រាប់ជនដែលនឹងក្លាយជាភាគីម្ខាងទៀត ក្នុងករណីភាគីដែលស្នើសុំអោយថែរក្សាការពារភស្តុតាងនោះ ពុំអាចកំណត់ភាគីម្ខាងទៀតបាន ។

Code of Civil Procedure (Japan)
**Article 236** (Treatment in case of impossibility of designation of adversary party)
A motion for preservation of evidence may be made even when the adversary party cannot be designated. In such cases, the court may appoint a special representative for the person to be the adversary party.

**មាត្រា ១៦៧.-** ការថែរក្សាការពារភស្តុតាងដោយឆន្ទានុសិទ្ធិ

នៅពេលដែលបណ្តឹងកំពុងចាត់ការ បើយល់ឃើញថាចាំបាច់ តុលាការអាចចេញដីកាសម្រេចឱ្យថែរក្សាការពារភស្តុតាង ដោយឆន្ទានុសិទ្ធិបាន ។

(កំណត់)

សូមមើលមាត្រា 237 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

មាត្រានេះកំណត់អំពីឆន្ទានុសិទ្ធិរបស់តុលាការ ។ បើយល់ឃើញថាចាំបាច់ តុលាការអាចចេញដីកាសម្រេចឱ្យ

ថែរក្សាការពារភស្តុតាងបាន ដោយមិនចាំបាច់មានពាក្យសុំអោយថែរក្សាការពារភស្តុតាងពីភាគីឡើយ ។

Code of Civil Procedure (Japan)
**Article 237** (Preservation of evidence upon the court's own authority)
The court may, upon determining it necessary, render a ruling for the preservation of evidence upon its own authority during the pendancy of the suit.

**មាត្រា ១៦៨.-** ការធ្វើឧបាស្រ័យ

ចំពោះដីកាសម្រេចលើកចោលពាក្យសុំឱ្យថែរក្សាការពារភស្តុតាង អ្នកដាក់ពាក្យសុំអាចប្តឹងជំទាស់បាន ។

(កំណត់)

សូមមើលមាត្រា 238 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

មាត្រានេះផ្តល់សិទ្ធិឱ្យភាគីដែលដាក់ពាក្យសុំឱ្យថែរក្សាការពារភស្តុតាង ប្តឹងជំទាស់នឹងដីកាសម្រេចលើកចោលពាក្យសុំឱ្យថែរក្សាការពារភស្តុតាង ។

Code of Civil Procedure (Japan)
**Article 238** (Prohibition of appeal)
No appeal may be made against a ruling concerning preservation of evidence.

**មាត្រា ១៦៩.-** ការកោះហៅតាមកាលបរិច្ឆេទ

នៅកាលបរិច្ឆេទពិនិត្យភស្តុតាង តុលាការត្រូវធ្វើការកោះហៅអ្នកដាក់ពាក្យសុំ និង ភាគីម្ខាងទៀត ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីចាំបាច់បន្ទាន់ ។

(កំណត់)

សូមមើលមាត្រា 240 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ ការរក្សាការពារភស្តុតាង គឺជាប្រភេទមួយនៃការពិនិត្យភស្តុតាង ដូចនេះ អ្នកស្នើសុំ និង ភាគីម្ខាងទៀត មានសិទ្ធិចូលរួមតាមកាលបរិច្ឆេទ ។ ប៉ុន្តែ ក្នុងករណីចាំបាច់បន្ទាន់ ដូចជា សាក្សីអាចនឹងទទួលមរណភាព វត្ថុអាចនឹងវិនាស ឬ បាត់បង់ដោយការបំផ្លាញ ជាដើម នោះតុលាការអាចធ្វើការពិនិត្យភស្តុតាងបាន ដោយមិនចាំបាច់កោះហៅអ្នកដាក់ពាក្យសុំ ឬ ភាគីម្ខាងទៀតឡើយ ។

Code of Civil Procedure (Japan)
**Article 240** (Summons for date)
The moving party and the adversary party shall be summoned for the date of examination of evidence. However, this shall not apply in cases of urgency.

**មាត្រា ១៧០.-** សោហ៊ុយសម្រាប់ថែរក្សាការពារភស្តុតាង

សោហ៊ុយដែលពាក់ព័ន្ធនឹងការថែរក្សាការពារភស្តុតាង គឺជាផ្នែកមួយនៃប្រាក់ប្រដាប់ក្តី ។

(កំណត់)

សូមមើលមាត្រា 241 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

Code of Civil Procedure (Japan)
**Article 241**(Expense for preservation of evidence)
Expenses incurred in preservation of evidence shall be made a part of court costs.

**មាត្រា ១៧១.-** ការសាកសួរសាជាថ្មីនៅពេលទាញហេតុផលដោយផ្ទាល់មាត់

ចំពោះសាក្សីដែលបានសាកសួរនៅក្នុងនីតិវិធីនៃការថែរក្សាការពារភស្តុតាង បើភាគីស្នើសុំឱ្យសាកសួរនៅពេលទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវសាកសួរសាក្សីនោះ ។

(កំណត់)

(1) សូមមើលមាត្រា 242 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(2) ចំពោះលទ្ធផលនៃការពិនិត្យភស្តុតាងដែលបានធ្វើតាមនីតិវិធីនៃការថែរក្សាការពារភស្តុតាងនេះ ត្រូវមានប្រសិទ្ធិភាពនៅក្នុងបណ្តឹងអង្គសេចក្តី (សូមមើលមាត្រា ១៦៣ (ការថែរក្សាការពារភស្តុតាង) កថាខណ្ឌទី ២) ។ ប៉ុន្តែចំពោះការសាកសួរសាក្សី ការស្តាប់សេចក្តីថ្លែងការណ៍របស់សាក្សីផ្ទាល់ ដោយចៅក្រមដែលទទួលបន្ទុកក្នុងការវិនិច្ឆ័យ និង ចេញសាលក្រម គឺជាចំណុចសំខាន់ក្នុងការធ្វើឱ្យមានជំនឿទុកចិត្តដោយត្រឹមត្រូវ ។ ហេតុដូច្នេះមាត្រានេះសម្លឹងធ្ងន់ទៅលើគោលការណ៍និយមផ្ទាល់ ហើយចែងថា បើភាគីទាមទារឱ្យសាកសួរសាក្សីសាជាថ្មី តុលាការត្រូវធ្វើការសាកសួរសាក្សីនោះ ។

Code of Civil Procedure (Japan)
**Article 242** (Re-examination at oral argument)
In cases where during the oral argument a party has offered examination of a witness who was previously examined during proceedings for preservation of evidence, the court shall examine such witness.

**មាត្រា ១៧២.-** ការផ្ញើកំណត់ហេតុស្តីពីការថែរក្សាការពារភស្តុតាង

ក្នុងករណីដែលធ្វើការពិនិត្យភស្តុតាងដើម្បីថែរក្សាការពារភស្តុតាង តុលាការដែលបានធ្វើការពិនិត្យភស្តុតាង ត្រូវផ្ញើនូវកំណត់ហេតុស្តីពីការពិនិត្យភស្តុតាងនោះ ទៅតុលាការដែលរក្សាទុកនូវសំណុំរឿងនៃបណ្តឹងអង្គសេចក្តី ។

( កំណត់)

(1) សូមមើលមាត្រា 154 នៃបទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(2) មាត្រានេះ យកហេតុដែលលទ្ធផលនៃការពិនិត្យភស្តុតាងដែលបានធ្វើតាមនីតិវិធីនៃការថែរក្សាការពារភស្តុតាងដែលមានប្រសិទ្ធិភាព នៅក្នុងបណ្តឹងអំពីអង្គសេចក្តី ( សូមមើលមាត្រា ១៦៣ ( ការថែរក្សាការពារភស្តុតាង) កថាខណ្ឌទី ២) ធ្វើជាមូលដ្ឋាន ហើយចែងអំពីការធ្វើកំណត់ហេតុពីតុលាការដែលបានធ្វើការពិនិត្យភស្តុតាង ដើម្បីថែរក្សាការពារភស្តុតាង ទៅតុលាការដែលកំពុងចាត់ការបណ្តឹងអង្គសេចក្តី ។

Rules of Civil Procedure (Japan)
**Article 154** (Transmission of record or presentation of evidence)
In cases where an examination of evidence for the preservation of evidence has been conducted, the court clerk in the court which has conducted such examination shall transmit the related record to the court clerk in the court where the record of the case on the merits exists.

## ជំពូកទី ៤ ការផ្អាក និង បន្តនីតិវិធីនៃបណ្តឹង

**មាត្រា ១៧៣.-** ការផ្អាក និង ការទទួលបន្តនីតិវិធីនៃបណ្តឹង

១- នីតិវិធីនៃបណ្តឹងត្រូវផ្អាក ពេលមានហេតុដូចចំណុចខាងក្រោមនេះ :

**ក**- មរណភាពរបស់ភាគី ។

**ខ**- ការរំលត់នីតិបុគ្គលដែលជាភាគី ដោយការរួមបញ្ចូលនីតិបុគ្គល ។

**គ**- ការបាត់បង់នូវសមត្ថភាពក្នុងការធ្វើបណ្តឹងរបស់ភាគី ឬ មរណភាពរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ឬ ការរលត់នូវសិទ្ធិតំណាង ។

**ឃ**- មរណភាព ឬ ការបាត់បង់នូវលក្ខណសម្បត្តិដោយហេតុផ្សេងរបស់បុគ្គលដែលមានលក្ខណសម្បត្តិដែលបានកំណត់ ហើយធ្វើបណ្តឹងក្នុងនាមផ្ទាល់ខ្លួន ជំនួសអ្នកដទៃ ។

**ង**- មរណភាព ឬ ការបាត់បង់នូវលក្ខណសម្បត្តិដោយហេតុផ្សេងរបស់ភាគីដែលត្រូវបានជ្រើសរើសទាំងអស់ ដោយបញ្ញត្តិនៃមាត្រា ៤២ ( ការជ្រើសរើសភាគី) នៃក្រមនេះ ។

២- ពេលមានហេតុដូចបានកំណត់នៅចំណុចនីមួយៗនៃកថាខណ្ឌទី ១ ខាងលើនេះ បុគ្គលដែលត្រូវទទួលបន្តនីតិវិធីនៃបណ្តឹង គឺ :

**ក**- បើមរណភាពរបស់ភាគី គឺ សន្តតិជន ឬ បុគ្គលដែលត្រូវបន្តបណ្តឹងតាមច្បាប់ ឬ បទដ្ឋានផ្សេងទៀត ។

**ខ**- បើការរំលត់នីតិបុគ្គលដែលជាភាគី ដោយការរួមបញ្ចូលនីតិបុគ្គល គឺ នីតិបុគ្គលដែលទទួលបន្តនូវសិទ្ធិ និង កាតព្វកិច្ចក្រោយការរួមបញ្ចូលនីតិបុគ្គល ។

**គ**- បើការបាត់បង់នូវសមត្ថភាពក្នុងការធ្វើបណ្តឹងរបស់ភាគី ឬ មរណភាពរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ឬ

ការរលត់នូវសិទ្ធិតំណាង គឺ អ្នកតំណាងដែលច្បាប់បានកំណត់ ឬ ភាគីដែលមានសមត្ថភាពក្នុងការធ្វើបណ្តឹងឡើងវិញ ។

**ឃ**- បើមរណភាព ឬ ការបាត់បង់នូវលក្ខណសម្បត្តិដោយហេតុផ្សេងរបស់បុគ្គលដែលមានលក្ខណសម្បត្តិដែលបានកំណត់ ហើយធ្វើបណ្តឹងក្នុងនាមផ្ទាល់ខ្លួនជំនួសអ្នកដទៃ គឺ បុគ្គលដែលមានលក្ខណសម្បត្តិដូចគ្នា ។

**ង**- បើមរណភាព ឬ ការបាត់បង់នូវលក្ខណសម្បត្តិដោយហេតុផ្សេងរបស់ភាគីដែលត្រូវបានជ្រើសរើសទាំងអស់ ដោយបញ្ញត្តិនៃមាត្រា ៤២ (ការជ្រើសរើសភាគី) នៃក្រមនេះ គឺ អ្នកដែលបានជ្រើសរើសទាំងអស់ ដោយមាត្រា ៤២ ឬ ភាគីដែលត្រូវបានជ្រើសរើសសាជាថ្មីដោយមាត្រា ៤២ ។

៣- បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានអ្នកតំណាងដោយអាណត្តិ ។ ប៉ុន្តែ អ្នកតំណាងដោយអាណត្តិ ត្រូវរាយការណ៍ទៅតុលាការ អំពីការកើតឡើងនូវហេតុដែលបានកំណត់ក្នុងចំណុចនីមួយៗ នៃកថាខណ្ឌទី ១ ខាងលើនេះ ។

៤- ទោះបីជាមានហេតុដូចបានកំណត់ក្នុងចំណុច **ក** នៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏សន្តតិជនមិនអាចទទួលបន្តនីតិវិធីនៃបណ្តឹងបានដែរ ក្នុងអំឡុងពេលដែលសន្តតិជននោះអាចបោះបង់ចោលនូវសន្តតិកម្មបាន ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 124 បទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី មាត្រា 52 ។

មាត្រានេះចែងអំពីមូលហេតុនៃការផ្អាកនូវនីតិវិធីនៃបណ្តឹង និង អ្នកទទួលបន្តនូវនីតិវិធីនៃបណ្តឹងក្នុងករណីដែលមានមូលហេតុនោះ ។ ប្រសិនបើមានកើតមូលហេតុដូចខាងក្រោមនេះ ហើយមិនផ្អាកនូវនីតិវិធីមួយរយៈសិន រហូតដល់ភាគីថ្មីអាចមានមធ្យោបាយតទល់ និង ការពារខ្លួនទេ គេមិនអាចធានានូវសិទ្ធិរបស់ភាគីចំពោះនីតិវិធីបានឡើយ ។ ការផ្អាក នឹងត្រូវធ្វើឡើងដោយស្វ័យប្រវត្តិ (មិនចាំបាច់ធ្វើការសម្រេចសេចក្តី) ក្នុងករណីដែលមានកើតមូលហេតុដូចតទៅ :

(1) ក្នុងករណីដែលភាគីបានទទួលមរណភាព ត្រូវផ្អាកនីតិវិធីនៃបណ្តឹង (កថាខណ្ឌទី ១ ចំណុច **ក**) លើកលែងតែករណីដែលគ្មានអ្នកណាបន្តសិទ្ធិ និង កាតព្វកិច្ច (ឧទាហរណ៍ បណ្តឹងសុំលែងលះគ្នា) ជាដើម (សូមមើលមាត្រា ១៧៤ (ការបញ្ចប់នូវនីតិវិធីនៃបណ្តឹងដោយស្វ័យប្រវត្តិ)) ។ ក្នុងករណីនេះ ជាគោលការណ៍ សន្តតិជនជាអ្នកទទួលបន្តបណ្តឹង ប៉ុន្តែ ក្នុងអំឡុងពេលដែលសន្តតិជនអាចបោះបង់ចោលនូវសន្តតិកម្ម សន្តតិជនក៏មិនទាន់បានកំណត់ឡើយ ហេតុនេះហើយ មិនអាចបន្តបណ្តឹងបានទេ (កថាខណ្ឌទី ៣) ។ "បុគ្គលដែលត្រូវបន្តបណ្តឹងតាមច្បាប់ ឬ បទដ្ឋានផ្សេងទៀត (ចំណុចទី ១)" គឺ បុគ្គលដូចជាអ្នកដែលត្រូវតុលាការចាត់តាំងដើម្បីគ្រប់គ្រងមតិក ក្នុងករណីដែលគ្មានសន្តតិជន ជាដើម ។ ដោយបញ្ញត្តិទាំងឡាយនេះចែងដោយប្រមាណជាមុនថា មានប្រព័ន្ធបោះបង់ចោល ឬ ប្រព័ន្ធទទួលបន្ត សន្តតិកម្មនោះ យើងចាំបាច់ត្រូវសម្រួលជាមួយនឹងប្រព័ន្ធច្បាប់សន្តតិកម្មដែលចែងនៅក្នុងក្រមរដ្ឋប្បវេណី ។

(2) ក្នុងករណីដែលភាគីជានីតិបុគ្គល ហើយដែលត្រូវរលត់ដោយសារការរួមបញ្ចូលជាមួយនឹងនីតិបុគ្គលផ្សេង នីតិវិធីនៃបណ្តឹងក៏ត្រូវផ្អាកដែរ (កថាខណ្ឌទី ១ ចំណុច ខ) ។ ក្នុងករណីនៃការរួមបញ្ចូលនីតិបុគ្គល នីតិបុគ្គលដែលទទួលបន្តសិទ្ធិ និង កាតព្វកិច្ចទូទៅទាំងអស់ក្រោយពេលរួមបញ្ចូល ត្រូវទទួលបន្តនីតិវិធីនៃបណ្តឹងនោះ ។

(3) ក្នុងករណីដែលភាគីបានបាត់បង់នូវសមត្ថភាពក្នុងការធ្វើបណ្តឹង ឬ អ្នកតំណាងដែលច្បាប់បានកំណត់បានទទួលមរណភាព ឬ បានបាត់បង់នូវសិទ្ធិតំណាង ភាគីនៅដដែល ប៉ុន្តែ មានបញ្ហាក្នុងការធានាសិទ្ធិរបស់ភាគីចំពោះនីតិវិធី ប្រសិនបើធ្វើនីតិវិធីបន្តទៅទៀត ។ ហេតុនេះហើយត្រូវផ្អាកនីតិវិធីនៃបណ្តឹង ហើយអ្នកតំណាងដែលច្បាប់បានកំណត់ថ្មី ត្រូវទទួលបន្ត ឬ ក្នុងករណីដែលសមត្ថភាពនៃភាគីបានស្តារឡើងវិញ ហើយសិទ្ធិតំណាងដែលច្បាប់បានកំណត់ក៏ត្រូវរលត់ នោះសាមីខ្លួនជាអ្នកទទួលបន្តបណ្តឹង (កថាខណ្ឌទី ១ ចំណុច គ) ។

(4) ក្នុងករណីដែលតតិយជនមានលក្ខណសម្បត្តិជាភាគីតាមផ្លូវច្បាប់ដោយមានលក្ខណៈដែលបានកំណត់ ហើយទទួលបន្ទុកបណ្តឹងតាមច្បាប់ (ឧទាហរណ៍ អ្នកអនុវត្តមតកសាសន៍ ក្នុងករណីដែលមានមតកសាសន៍) ហើយបុគ្គលនោះបានបាត់បង់នូវលក្ខណសម្បត្តិនោះ (ឧទាហរណ៍ ករណីដែលអ្នកអនុវត្តមតកសាសន៍បានសុំលាលែង) នីតិវិធីនៃបណ្តឹងត្រូវផ្អាក ហើយអ្នកដែលទទួលភារកិច្ចបន្ត ជាអ្នកទទួលបន្តបណ្តឹងនោះ (កថាខណ្ឌទី ១ ចំណុច ឃ) ។

(5) ក្នុងករណីដែលភាគីដែលបានជ្រើសរើសខ្លះ បានទទួលមរណភាព ឬ បានបាត់បង់នូវលក្ខណសម្បត្តិ ដោយបញ្ញត្តិនៃមាត្រា ៤២ (ការជ្រើសរើសភាគី) អ្នកដែលត្រូវបានជ្រើសរើសផ្សេងអាចធ្វើសកម្មភាពបណ្តឹងបាន (មាត្រា ៤២ កថាខណ្ឌទី ៤) ប៉ុន្តែ ក្នុងករណីដែលភាគីដែលត្រូវបានជ្រើសរើសទាំងអស់បានទទួលមរណភាព ឬ បានបាត់បង់នូវលក្ខណសម្បត្តិ ត្រូវផ្អាកនូវនីតិវិធីនៃបណ្តឹង ហើយភាគីដែលត្រូវបានជ្រើសរើសសាជាថ្មីត្រូវបន្ត ឬ បើមិនបានធ្វើការជ្រើសរើសថ្មីទេ អ្នកដែលបានធ្វើការជ្រើសរើសត្រូវទទួលបន្តនូវបណ្តឹងនោះ (កថាខណ្ឌទី ១ ចំណុច ង) ។ ក្នុងករណីដែលមានកើតមូលហេតុដូចដែលបានរៀបរាប់ខាងលើនេះ ប៉ុន្តែ បើមានអ្នកតំណាងដោយអាណត្តិសម្រាប់ភាគីដែលមានមូលហេតុនោះ ទោះបីជាបន្តនីតិវិធីនៃបណ្តឹងក៏ដោយ ក៏អ្នកតំណាងដោយអាណត្តិនោះអាចអនុវត្តមធ្យោបាយតទល់ និង ការពារខ្លួនបានត្រឹមត្រូវដែរ ហេតុនេះហើយគ្មានបញ្ហាទេ ។ ហេតុដូច្នេះហើយ ក្នុងករណីដែលមានអ្នកតំណាងដោយអាណត្តិ មិនត្រូវផ្អាកនីតិវិធីនៃបណ្តឹងទេ (កថាខណ្ឌទី ២) ។ ប៉ុន្តែ ទោះក្នុងករណីនេះក៏ដោយ ក៏នៅតែមានសេចក្តីចាំបាច់ក្នុងការរាយការណ៍ទៅតុលាការអំពីមូលហេតុខាងលើនេះដែរ ហេតុដូច្នេះហើយ កថាខណ្ឌទី ២ ចែងអំពីករណីយកិច្ចរបស់អ្នកតំណាងដោយអាណត្តិ ក្នុងការរាយការណ៍នោះ ។

(6) កថាខណ្ឌទី ៣ (ទី ៤) នៃមាត្រានេះ កំណត់អំពីការមិនអនុញ្ញាតឱ្យសន្តតិជនទទួលបន្តនីតិវិធីនៃបណ្តឹង នៅក្នុងអំឡុងពេលដែលសន្តតិជនអាចបោះបង់សន្តតិកម្មបាន ។ បើយើងអនុញ្ញាតឱ្យសន្តតិជនទទួលបន្តនីតិវិធីនៅក្នុងអំឡុងពេលនេះ ហើយសន្តតិជននោះបានជ្រើសរើសយកការបោះបង់សន្តតិកម្ម នោះការទទួលបន្តនីតិវិធីនៃបណ្តឹងនោះគ្មានផលប្រយោជន៍អ្វីដែលទាក់ទងដល់រូបគេឡើយ ។

**Article 124** (Interruption and taking over of litigation proceedings)
1. In cases where any of reasons prescribed by the following items exists, the litigation proceedings shall be interrupted. In such cases, any person designated by the respective applicable items shall take over the litigation proceedings:
  i. death of a party......
    such party's heir, the administrator of such party's estate, or any other person bound by laws or ordinances to continue the action;
  ii. termination through amalgamation of a juridical person which is a party......
    the juridical person established through such amalgamation or the juridical person who continues to exist following such amalgamation;
  iii. party's loss of capacity to litigate, death of a legal representative, or termination of such representative's authority......
    such party's legal representative or the party upon regaining the capacity to litigate;
  iv. conclusion of trust duties of a trustee who is a party......
    the new trustee;
  v. death of a person who possessed a certain qualification and had been a party to the action in his own name on behalf of another person, or loss of such qualification due to any other reason......
    another person who possesses the same qualification;
  vi. death of all appointed parties, or loss of qualification of such parties due to any other reason......
    all of the appointers or newly appointed parties.
2. The provisions of the preceding paragraph shall not apply while there is an advocate.
3. Even if there is a season prescribed by paragraph 1, item i, an heir shall not take over litigation proceedings during the period within which such heir is entitled to waive succession.
4. The provisions of paragraph 1, item ii shall not apply in cases where an amalgamation cannot be set up against the adversary party.

Rules of Civil Procedure (Japan)
Article 52 (Notification of reason of interruption by advocate / The Code Article 124)
In cases where any of the reason prescribed by either of the items of the paragraph 1, Article 124 (Interruption and taking over of litigation proceedings) of the Code has occurred, the advocate shall notify the court thereof in writing.

**មាត្រា ១៧៤.-** ការបញ្ចប់នូវនីតិវិធីនៃបណ្ដឹងដោយស្វ័យប្រវត្តិ

ក្នុងករណីដែលភាគីបានទទួលមរណភាព ឬ បានរលត់ដោយការរួមបញ្ចូលនៃនីតិបុគ្គល ហើយគ្មានអ្នកទទួលបន្តនូវសិទ្ធិឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្ដឹង ឬ សិទ្ធិឬកាតព្វកិច្ចនោះបានធ្លាក់ទៅលើបុគ្គលតែម្នាក់ នោះនីតិវិធីនៃបណ្ដឹងត្រូវបានបញ្ចប់ ។ ក្នុងករណីនេះ តុលាការត្រូវចេញសាលក្រមប្រកាសបញ្ចប់បណ្ដឹងនោះ ។

(កំណត់)

ទោះបីជាភាគីបានទទួលមរណភាព (ឬ នីតិបុគ្គលបានរលត់) ក៏ដោយ ប្រសិនបើទំនាក់ទំនងនៃសិទ្ធិ និង កាតព្វកិច្ចត្រូវបានទទួលបន្តដោយសន្តតិជន ជាដើម ក៏នីតិវិធីនៃបណ្ដឹងត្រូវបានបន្តតាមបញ្ញត្តិនៃមាត្រា ១៧៣ (ការផ្អាក និង ការទទួលបន្តនីតិវិធីនៃបណ្ដឹង) ដែរ ។ ប៉ុន្តែ ក្នុងករណីដែលគ្មានការបន្តដូច្នេះទេ (ឧទាហរណ៍ បណ្ដឹងលែងលះគ្នា) ភាគីសល់តែម្នាក់ ហេតុនេះហើយ នីតិវិធីនៃបណ្ដឹងត្រូវបានបញ្ចប់ ។ ចំពោះបណ្ដឹងរវាងឪពុក ឬ ម្ដាយ និង កូន ប្រសិនបើឪពុក ឬ ម្ដាយនោះបានទទួលមរណភាព ហើយកូនដែលជាភាគីម្ខាងទៀតក្លាយជាសន្តតិជនតែម្នាក់ឯងទេ នីតិវិធីនៃបណ្ដឹងក៏ត្រូវបានបញ្ចប់ពេលនោះដែរ ។ ចំពោះចំណុចនេះ ក្រមនីតិវិធីជប៉ុន គ្មានចែងអ្វីច្បាស់លាស់ទេ ប៉ុន្តែ គេអាចទទួលស្គាល់បាន តាមករណីយុត្តិសាស្ត្រនៃសាលក្រមជាស្ថាពរ ។ ចំពោះការរួមបញ្ចូលនៃនីតិបុគ្គល នៅប្រទេសជប៉ុន បណ្ដឹងទាមទារមោឃភាពនៃការបង្កើតសហគ្រាស ឬ បណ្ដឹងទាមទារការលុបចោលសេចក្ដីសម្រេចនៃសន្និបាតម្ចាស់ហ៊ុន ជាដើម មិនត្រូវបានបន្តទៅនីតិបុគ្គលថ្មីឡើយ ។ ចំពោះប្រទេសកម្ពុជាវិញ ចំណុចនេះត្រូវកំណត់នៅក្នុងច្បាប់ស្ដីពី

សាហាគ្រាស ហើយប្រសិនបើគ្មានបញ្ញត្តិដូចច្បាប់ជប៉ុនទេ ពាក្យក្នុងមាត្រានេះថា "គ្មានអ្នកទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្ដឹង" មិនមានទាក់ទងនឹងនីតិបុគ្គលឡើយ ។

ម្យ៉ាងទៀត ក្នុងករណីទាំងនេះ ពេលដែលភាគីនោះបានទទួលមរណភាព ជាដើម នីតិវិធីនៃបណ្ដឹងក៏ត្រូវបញ្ឈប់ភ្លាមៗ ប៉ុន្តែ ដើម្បីឱ្យបានច្បាស់លាស់ ការបញ្ឈប់បណ្ដឹងនេះត្រូវធ្វើឡើងដោយសាលក្រមប្រកាសបញ្ចប់បណ្ដឹង ។ សាលក្រមនេះត្រូវបានបញ្ជូនទៅភាគីម្ខាងទៀតដែលនៅសល់ ។ ក្រៅពីនេះ ប្រសិនបើមានអ្នកទាមទារបន្តនូវទំនាក់ទំនងនៃសិទ្ធិ និង កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្ដឹងនោះ បុគ្គលនោះអាចប្ដឹងឧទ្ធរណ៍ចំពោះសាលក្រមប្រកាសបញ្ចប់បណ្ដឹងនោះបាន ។

**មាត្រា ១៧៥.-** នីតិវិធីដើម្បីទទួលបន្ត

១- ការដាក់ពាក្យសុំទទួលបន្តនីតិវិធីនៃបណ្ដឹង អាចធ្វើឡើងដោយបុគ្គលដែលមានបំណងទទួលបន្ត ឬ ដោយភាគីម្ខាងទៀត ។

២- ប្រសិនបើមានពាក្យសុំទទួលបន្តនីតិវិធីនៃបណ្ដឹង តុលាការត្រូវជូនដំណឹងទៅភាគីម្ខាងទៀត ។

៣- ប្រសិនបើមានពាក្យសុំទទួលបន្តនូវនីតិវិធីនៃបណ្ដឹង តុលាការត្រូវធ្វើការស្រាវជ្រាវ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ហើយបើយល់ឃើញថា គ្មានមូលហេតុត្រឹមត្រូវទេ តុលាការត្រូវលើកចោលនូវពាក្យសុំនោះ ដោយដីកាសម្រេច ។ ចំពោះដីកាសម្រេចនេះ អាចប្ដឹងជំទាស់បាន ។

៤- ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ប្រសិនបើយល់ឃើញថា មានមូលហេតុត្រឹមត្រូវ តុលាការត្រូវអនុញ្ញាតការទទួលបន្តនីតិវិធីនៃបណ្ដឹងនោះ ដោយដីកាសម្រេច ។

៥- ក្នុងករណីដែលមានពាក្យសុំទទួលបន្តនីតិវិធីនៃបណ្ដឹងដែលត្រូវបានផ្អាក ក្រោយការបញ្ជូនសាលក្រម តុលាការដែលបានចេញសាលក្រមនោះ ត្រូវធ្វើការសម្រេចសេចក្ដីអំពីពាក្យសុំនោះ ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 126 មាត្រា 127 និង មាត្រា 128 ។

មាត្រានេះចែងអំពីនីតិវិធីដើម្បីទទួលបន្តបណ្ដឹង ។ ជាដំបូង បុគ្គលដែលមានសិទ្ធិដាក់ពាក្យសុំទទួលបន្តបណ្ដឹងគឺជាភាគីម្ខាងទៀតនៃភាគីដែលមានហេតុផ្អាកនីតិវិធី ដូចជាបានទទួលមរណភាព ជាដើម ឬ បុគ្គលដែលមានលក្ខណៈទទួលបន្តនូវបណ្ដឹងដូចដែលបានចែងក្នុងមាត្រា ១៧៣ (ការផ្អាក និង ការទទួលបន្តនីតិវិធីនៃបណ្ដឹង) ជាដើម (កថាខណ្ឌទី ១) ។ ភាគីម្ខាងទៀតក៏មានផលប្រយោជន៍ដែរ ក្នុងការជំរុញនីតិវិធីនៃបណ្ដឹងនោះឱ្យបានលឿន ហេតុនេះហើយបានជាមានសិទ្ធិដាក់ពាក្យសុំឱ្យទទួលបន្តនូវនីតិវិធីនេះដែរ ។ ពេលណាមានពាក្យសុំ តុលាការត្រូវជូនដំណឹង (កថាខណ្ឌទី ២) ។ ប្រសិនបើពាក្យសុំនេះត្រូវបានធ្វើឡើងដោយអ្នកមានលក្ខណៈទទួលបន្តបណ្ដឹង តុលាការត្រូវជូនដំណឹងទៅភាគី

ម្ខាងទៀត រីឯចំពោះពាក្យសុំរបស់ភាគីម្ខាងទៀតវិញ ត្រូវជូនដំណឹងទៅបុគ្គលដែលមានលក្ខណៈទទួលបន្តបណ្ដឹងនោះ (ម្យ៉ាងទៀត បើភាគីម្ខាងទៀតដាក់ពាក្យសុំឱ្យទទួលបន្ត ភាគីនោះត្រូវកំណត់បុគ្គលដែលមានលក្ខណៈទទួលបន្ត) ។ ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវការទទួលបន្តបណ្ដឹងនេះ គឺជាការសម្រេចសេចក្ដីអំពីនីតិវិធីនៃបណ្ដឹង ហេតុនេះហើយត្រូវធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ ហើយត្រូវសម្រេចដោយដីកាសម្រេច ។ បើសិនជាស្រាវជ្រាវទៅ ឃើញថាគ្មានមូលហេតុទទួលបណ្ដឹងបន្តបានទេ តុលាការត្រូវលើកចោលនូវពាក្យសុំនោះ (កថាខណ្ឌទី ៣) ហើយបើយល់ឃើញថាមានមូលហេតុត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេចឱ្យទទួលបន្តនូវបណ្ដឹងនោះ (កថាខណ្ឌទី ៤) ។ ម្យ៉ាងទៀត ប្រសិនបើការផ្អាកបណ្ដឹងបានកើតឡើងក្រោយការបញ្ជូនសាលក្រមហើយ តុលាការដែលបានចេញសាលក្រមនោះ ត្រូវទទួលខុសត្រូវក្នុងការទទួលពាក្យសុំទទួលបន្ត និង ក្នុងការសម្រេចសេចក្ដីអំពីពាក្យសុំនោះ មិនមែនតុលាការដែលត្រូវទទួលបណ្ដឹងឧទ្ធរណ៍ទេ (កថាខណ្ឌទី ៥) (ក្រោយការប្ដឹងឧទ្ធរណ៍ តុលាការដែលទទួលបណ្ដឹងឧទ្ធរណ៍ ត្រូវចេញដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតការទទួលបន្ត) ។

Code of Civil Procedure (Japan)
**Article 126** (Motion for taking over by adversary party)
A motion for taking over the litigation proceedings may also be made by the adversary party.
**Article 127** (Notification of taking over)
In cases where a motion for taking over the litigation proceedings has been made, the court shall notify the adversary party thereof.
**Article 128** (Decision relating to taking over)
1. In cases where a motion for taking over the litigation proceedings has been made, the court shall investigate upon its own authority, and when it deems such motion to be groundless, it shall dismiss it by ruling.
2. In case of a motion for taking over the litigation proceedings which have been interrupted subsequent to service of a judgment paper or a record referred to in Article 254, paragraph 2 (including those cases to which it applies *mutatis mutandis* in Article 374, paragraph 2), the court which rendered such judgment shall render a decision on the motion.

**មាត្រា ១៧៦.-** ការបង្គាប់ឱ្យបន្តដោយឆន្ទានុសិទ្ធិ

ទោះបីជាភាគីទាំងសងខាងមិនបានដាក់ពាក្យសុំទទួលបន្តនីតិវិធីនៃបណ្ដឹងក៏ដោយ ក៏តុលាការអាចបង្គាប់ឱ្យបន្តនីតិវិធីនៃបណ្ដឹង ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ដោយដីកាសម្រេចបានដែរ ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 129 ។

ចំពោះដំណើរការនៃនីតិវិធីនៃបណ្ដឹង ជាគោលការណ៍ តុលាការត្រូវជម្រុញដំណើរការនៃនីតិវិធីនោះ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ហេតុនេះហើយ មាត្រានេះចែងថា ប្រសិនបើពិតជាមានអ្នកមានលក្ខណៈបន្តបណ្ដឹង តែគ្មានពាក្យសុំទទួលបន្តទាំងពីបុគ្គលដែលមានលក្ខណៈ និង ទាំងពីភាគីម្ខាងទៀតទេ នោះតុលាការអាចបង្គាប់ឱ្យបន្តនីតិវិធីនៃបណ្ដឹង ដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។

Code of Civil Procedure (Japan)

**Article 129** (Continuation order upon court's authority)
Even in cases where the parties do not make a motion for taking over the litigation proceedings, the court may, upon its own authority, order that the litigation proceedings be continued.

**មាត្រា ១៧៧.-** ការបង្អង់នីតិវិធីនៃបណ្តឹង

១- ប្រសិនបើតុលាការមិនអាចបំពេញកិច្ចការរបស់ខ្លួន ដោយសារគ្រោះមហន្តរាយធម្មជាតិ ឬ ហេតុផ្សេងទៀត នីតិវិធីនៃបណ្តឹងត្រូវបានបង្អង់រហូតដល់ហេតុនោះរលត់ ។

២- ប្រសិនបើភាគីមិនអាចបន្តនីតិវិធីនៃបណ្តឹង ដោយសារឧបសគ្គដែលមានរយៈពេលវែង ហើយមិនអាចប៉ាន់ស្មានបានថា ពេលណាចប់ តុលាការអាចបង្គាប់ឱ្យបង្អង់នូវនីតិវិធីនៃបណ្តឹងនោះ ដោយដីកាសម្រេចបាន ។ ក្នុងករណីនេះ ពេលដែលឧបសគ្គនោះត្រូវបានកន្លងផុតទៅ តុលាការអាចលុបចោលនូវដីកាសម្រេចនោះបាន ។

៣- ប្រសិនបើរឿងក្តីព្រហ្មទណ្ឌដែលទាក់ទងនឹងអង្គហេតុ ដែលជាមូលដ្ឋាននៃការទាមទារណាមួយក្នុងរឿងក្តីរដ្ឋប្បវេណីកំពុងត្រូវបានចាត់ការ នោះតុលាការអាចបង្គាប់ឱ្យបង្អង់នូវនីតិវិធីនៃបណ្តឹងរបស់រឿងក្តីរដ្ឋប្បវេណីនោះ ដោយដីកាសម្រេចបាន ។ នៅក្នុងករណីនេះ ពេលដែលរឿងក្តីព្រហ្មទណ្ឌនោះត្រូវបានបញ្ចប់ តុលាការអាចលុបចោលនូវដីកាសម្រេចនោះបាន ។

( កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 130 និង មាត្រា 131 ។

ប្រសិនបើមានមូលហេតុដែលមានកំណត់ ហើយដែលមិនឱ្យមានអ្នកបន្តនីតិវិធីដូចការផ្អាកបណ្តឹងទេ តែមានភាពចាំបាច់តម្រូវឱ្យនីតិវិធីចប់មួយរយៈដើម្បីធានានូវសិទ្ធិរបស់ភាគីចំពោះនីតិវិធី នោះនីតិវិធីនៃបណ្តឹងត្រូវបានបង្អង់ ។ មាត្រានេះ ចែងអំពីការបង្អង់នីតិវិធីនេះ ។

(1) ប្រសិនបើតុលាការមិនអាចបំពេញកិច្ចការរបស់ខ្លួនបាន ដោយសារតំបន់ដែលជាទីតាំងនៃតុលាការបានទទួលមហន្ត-រាយធម្មជាតិ ដូចជាមហាអគ្គិភ័យ ទឹកជំនន់ ឬ ការរញ្ជួយផែនដី ជាដើម ឬ ក៏ដោយសារមានសង្គ្រាម សង្គ្រាមស៊ីវិលកុបកម្ម ជាដើម នីតិវិធីនៃបណ្តឹងត្រូវតែបង្អង់តាមច្បាប់ ដោយមិនចាំបាច់មានការសម្រេចសេចក្តី ដោយតុលាការទេ (កថាខណ្ឌទី ១) ។ ចំពោះករណីផ្ទាល់ខ្លួនរបស់ចៅក្រមម្នាក់ៗ (ឧទាហរណ៍ ជម្ងឺ ជាដើម) មិនបញ្ចូលក្នុងករណីនេះទេ ។ ពេលណាមូលហេតុដែលមានចែងខាងលើនេះត្រូវបានរលត់ ការបង្អង់នីតិវិធីនេះក៏ត្រូវរលាយដែរ ហើយនីតិវិធីនៃបណ្តឹងក៏ត្រូវធ្វើបន្តទៀត ។

(2) ប្រសិនបើតំបន់ដែលភាគីរស់នៅ មានឧបសគ្គក្នុងការធ្វើចរាចរដោយសារតែមហន្តរាយធម្មជាតិ ឬ ក៏ភាគីត្រូវបំបែកពីប្រជាជនធម្មតាដោយសារជម្ងឺឆ្លង ជាដើម ដែលជាទូទៅ គេយល់ថា ភាគីមិនអាចបន្តបណ្តឹងបាន ហើយដែលមិនអាចប៉ាន់ស្មាននូវពេលវេលាដែលមូលហេតុនោះរលត់ នោះនីតិវិធីនៃបណ្តឹងត្រូវបានបង្អង់ដែរ ដើម្បីការពារសិទ្ធិរបស់ភាគីចំពោះនីតិវិធី (កថាខណ្ឌទី ២) ។ ក្នុងករណីដែលភាគីបានធ្វើដំណើរដើរលេង ឬ មានជម្ងឺ

តែមួយរយៈពេល ជាដើម មិនបញ្ចូលក្នុងករណីនេះទេ ។ ក្នុងករណីនៃការបង្អង់នេះ តុលាការត្រូវបង្អង់នីតិវិធីដោយដីកាសម្រេច ហើយពេលណាមូលហេតុនោះបានរលត់ តុលាការក៏ត្រូវលុបចោលនូវដីកាសម្រេចបង្អង់នោះដោយដីកាសម្រេចដែរ ដើម្បីបន្តនីតិវិធីនៃបណ្តឹងទៀត ។ម្យ៉ាងទៀត ចំពោះដីកាសម្រេចបង្អង់ ឬដីកាសម្រេចលុបចោលការបង្អង់នេះ មិនអាចឧបាស្រ័យបានទេ ។

(3) នៅក្នុងករណីដែលរឿងក្តីព្រហ្មទណ្ឌកំពុងត្រូវបានចាត់ការ អ្នករងគ្រោះដោយសាររឿងក្តីនោះអាចទាមទារឱ្យភ្ជាប់នូវការទាមទារសំណងរដ្ឋប្បវេណីក្នុងរឿងព្រហ្មទណ្ឌបាន ហើយក៏អាចដាក់ពាក្យបណ្តឹងនោះតាមបណ្តឹងរដ្ឋប្បវេណីធម្មតាបានដែរ ។ ប៉ុន្តែ ទោះក្នុងករណីដាក់ពាក្យបណ្តឹងនោះតាមបណ្តឹងរដ្ឋប្បវេណីធម្មតាក៏ដោយ ក៏សាលក្រមព្រហ្មទណ្ឌដែលសម្រេចឱ្យមានទោសនោះ នឹងមានចំណងទៅលើរឿងក្តីរដ្ឋប្បវេណីដែរ ដែលតម្រូវឱ្យយើងគួរចែងថាអាចបង្អង់បាននូវដំណើរការនៃនីតិវិធីបណ្តឹងរដ្ឋប្បវេណីនោះ ។ តែបើយើងកំណត់ថា បណ្តឹងរដ្ឋប្បវេណីនោះត្រូវបានបង្អង់ដោយស្វ័យប្រវត្តិនោះ វានាំឱ្យមានគោលបំណងពន្យារបណ្តឹង ដែលអាចជាហេតុនាំឱ្យមានបណ្តឹងព្រហ្មទណ្ឌដែលមិនគួរឱ្យមានឡើយ ដូចនេះយោលទៅតាមការវិនិច្ឆ័យរបស់តុលាការ យើងបានចែងអំពីការអាចបង្អង់នូវនីតិវិធីនៃបណ្តឹងរបស់រឿងក្តីនោះបាន ( កថាខណ្ឌទី ៣) ។

<u>Code of Civil Procedure (Japan)</u>
**Article 130** (Suspension due to inability of court to perform its function)
In cases where the court is unable to perform its function by reason of natural disaster or any other reason, the litigation proceedings shall be suspended until such reason ceases to exist.
**Article 131** (Suspension due to impediment on party's side)
1. In cases where a party is unable to continue the proceedings by reason of an impediment of indefinite duration, the court may order by ruling the suspension of such proceedings.
2. The court may cancel the ruling referred to in the preceding paragraph.

**មាត្រា ១៧៨.-** អានុភាពនៃការផ្អាក ឬ បង្អង់នីតិវិធីនៃបណ្តឹង

១- នៅពេលដែលមានការផ្អាក ឬ បង្អង់នីតិវិធីនៃបណ្តឹង ភាគី និង តុលាការ មិនអាចធ្វើសកម្មភាពបណ្តឹងបានឡើយ ។ ប៉ុន្តែ តុលាការអាចប្រកាសសាលក្រមបាន ទោះបីជានីតិវិធីនៃបណ្តឹងនោះត្រូវបានផ្អាកក៏ដោយ ។

២- នៅពេលដែលមានការផ្អាក ឬ បង្អង់នីតិវិធីនៃបណ្តឹង អំឡុងពេលក៏ត្រូវបញ្ឈប់ដំណើរការដែរ ។ ក្នុងករណីនេះ អំឡុងពេលទាំងអស់នោះត្រូវចាប់ផ្តើមពីដំបូងវិញ ចាប់ពីពេលដែលធ្វើការជូនដំណឹងស្តីពីការទទួលបន្តនូវនីតិវិធីនៃបណ្តឹង ឬ ពេលដែលបន្តនូវនីតិវិធីនៃបណ្តឹងនោះ ។

( កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 132 ។

មាត្រានេះចែងអំពីអានុភាពនៃការផ្អាក ឬ បង្អង់នីតិវិធីនៃបណ្តឹង ។ ការផ្អាក ឬ ការបង្អង់នីតិវិធីនេះ គឺជារបបមួយដើម្បីធានានូវសិទ្ធិរបស់ភាគីចំពោះនីតិវិធីនៃបណ្តឹង ហេតុនេះហើយបានជាពេលដែលនីតិវិធីនៃបណ្តឹងត្រូវផ្អាក ឬ បង្អង់

ជាគោលការណ៍ សកម្មភាពបណ្ដឹងមិនអាចធ្វើបានទេ (កថាខណ្ឌទី ១) ហើយអំឡុងពេលក៏មិនត្រូវឱ្យដើរដែរ (កថាខណ្ឌទី ២) ។ ហេតុដូច្នេះ សកម្មភាពបណ្ដឹងដែលបានធ្វើឡើងនៅពេលដែលនីតិវិធីត្រូវបានផ្អាក ឬ បង្អង់ ជាគោលការណ៍ ត្រូវចាត់ទុកជាមោឃៈ ប៉ុន្តែ ចំពោះការប្រកាសសាលក្រមវិញ មិនបាច់គិតដល់សិទ្ធិរបស់ភាគី ចំពោះនីតិវិធីទេ ហើយច្បាប់ចែងទាមទារថាឱ្យធ្វើការប្រកាសឱ្យបានរហ័ស ហេតុនេះហើយ ទោះបីជាពេលកំពុងផ្អាក នីតិវិធីក៏ដោយ ក៏អាចធ្វើការប្រកាសសាលក្រមបានដែរ (ករណីលើកលែង) ។ ក្រៅពីនេះ សកម្មភាពរបស់តុលាការមួយចំនួន ដូចជា ដីកាសម្រេចឱ្យទទួលបន្តនីតិវិធី ការដកខ្លួនរបស់ចៅក្រម ជាដើម និង សកម្មភាពរបស់ភាគីមួយចំនួន ដែលមិនប៉ះពាល់ផលប្រយោជន៍របស់ភាគីម្ខាងទៀត ដូចជា ការដាក់ពាក្យសុំ ទទួលបន្តនីតិវិធី ការចាត់តាំងអ្នកតំណាងដោយអាណត្តិ ពាក្យសុំជួយសង្គ្រោះលើបណ្ដឹង ជាដើម អាចធ្វើបាន ។ម្យ៉ាងទៀត អំឡុងពេលត្រូវបញ្ឈប់ដំណើរ ហើយត្រូវចាប់ផ្ដើមពីដំបូងវិញ ចាប់ពីពេលដែលបានបញ្ចប់នូវការផ្អាក ឬ ការបង្អង់នីតិវិធីនោះ ។ ឧទាហរណ៍ ប្រសិនបើអំឡុងពេលដែលអាចប្ដឹងឧទ្ធរណ៍ មាន ១ ខែ ហើយអំឡុងពេលនេះបានកន្លង ៣ សប្ដាហ៍ ហើយនៅសល់តែ ១ សប្ដាហ៍ទៀត ស្រាប់តែមានមូលហេតុដែលត្រូវផ្អាក ឬ បង្អង់នីតិវិធី ពេលដែលមូលហេតុនោះ បានរលត់ នោះអំឡុងពេលដើម្បីប្ដឹងឧទ្ធរណ៍ ត្រូវបានទទួលស្គាល់ ១ ខែទៀត ដោយគិតចាប់ពីពេលរលត់ (មិនមែននៅសល់តែ ១ សប្ដាហ៍នោះទេ) ។

Code of Civil Procedure (Japan)
**Article 132** (Effect of interruption and suspension)
1. Pronouncement of a judgment may be made even when litigation proceedings are under interruption.
2. In cases of interruption or suspension of litigation proceedings, terms cease to run. In such cases, terms shall newly begin running again from the time when the notice of the taking over of the litigation proceedings is given or when the proceedings are continued.

## ជំពូកទី ៥ ការសម្រេចសេចក្ដី

### ផ្នែកទី ១ បទប្បញ្ញត្តិទូទៅស្ដីពីការសម្រេចសេចក្ដី

**មាត្រា ១៧៩.-** ប្រភេទនៃការសម្រេចសេចក្ដី

១- សាលក្រម គឺជាការសម្រេចសេចក្ដី ដែលតុលាការធ្វើលិខិតសាលក្រមដែលមានលក្ខណៈគ្រប់គ្រាន់ ទៅតាមទម្រង់ដែលច្បាប់បានកំណត់ ដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់ លើកលែងតែក្នុងករណីដែលមានកំណត់ពិសេសនៅក្នុងក្រមនេះ ឬ នៅក្នុងច្បាប់ផ្សេង ហើយកើតអានុភាព ដោយការប្រកាស ដោយផ្អែកលើលិខិតសាលក្រមនោះ ។ (1)

២- ដីកាសម្រេច គឺជាការសម្រេចសេចក្ដីដែលតុលាការ ឬ ចៅក្រមអាចធ្វើដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់បាន ហើយមិនមែនជាសាលក្រម ។(2)

( កំណត់)

(1) ចំពោះបណ្ដឹងធម្មតា ជាគោលការណ៍ ការវិនិច្ឆ័យទៅលើបណ្ដឹងរបស់ដើមចោទថា មានលក្ខណៈបណ្ដឹងគ្រប់គ្រាន់ ហើយត្រឹមត្រូវទៅតាមច្បាប់ឬទេ ឬ ក៏ការវិនិច្ឆ័យទៅលើការទាមទាររបស់ដើមចោទនោះថាត្រឹមត្រូវទៅតាមច្បាប់ឬទេ គឺធ្វើដោយសាលក្រម ។

(2) ចំពោះចំណុចបន្ទាប់បន្សំ ឬ ចំណុចដែលងាយស្រួល ជាគោលការណ៍ គឺធ្វើដោយដីកាសម្រេច ។ ដីកាសម្រេចនឹងមានអានុភាព ដោយរបៀបជូនដំណឹងទៅគូភាគី ដែល ( តុលាការ) ទទួលស្គាល់ថា ជាការសមរម្យ ។

## ផ្នែកទី ២ បទប្បញ្ញត្តិទូទៅស្ដីពីសាលក្រម

**មាត្រា ១៨០.-** សាលក្រមចុងក្រោយ

១- បើយល់ឃើញថា ត្រូវបញ្ចប់ការវិនិច្ឆ័យដោយផ្អែកលើលទ្ធផលដែលបានមកពីការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យលើភស្តុតាង តុលាការត្រូវបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ហើយចេញសាលក្រមចុងក្រោយ ។ ( 1)

២- បើយល់ឃើញថា ត្រូវបញ្ចប់ការវិនិច្ឆ័យចំពោះការទាមទារមួយ ក្នុងចំណោមការទាមទារច្រើនដែលត្រូវបានបញ្ចូលគ្នា តុលាការអាចចេញសាលក្រមសម្រេចដល់អង្គសេចក្ដីចំពោះការទាមទារតែមួយនោះបាន ។ ( 2)

៣- បើយល់ឃើញថា មានការចាំបាច់ដើម្បីចេញសាលក្រមចុងក្រោយ តុលាការអាចបង្គាប់ឱ្យធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដែលត្រូវបានបញ្ចប់ហើយនោះ សាជាថ្មីឡើងវិញបាន ។ ( 3)

( កំណត់)

សូមមើលមាត្រា 243 និង មាត្រា 153 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(1) កថាខណ្ឌទី ១ នេះគឺជាបញ្ញត្តិដែលចែងអំពី "សាលក្រម ( ឬ សាលដីកា) សម្រេចអង្គសេចក្ដី ( final judgment, jugement définitif) " ដែលត្រូវបញ្ចប់នីតិវិធីនៃបណ្ដឹងដែលតុលាការជាន់ណាមួយកំពុងចាត់ការ ។ ទស្សនទានផ្ទុយពីសាលក្រមចុងក្រោយ ( final judgment, jugement définitif) នេះ គឺ "សាលក្រមរបៀប ( interlocutory judgment, jugement interlocutoire) " ដែលយើងបញ្ញត្តនៅមាត្រាខាងក្រោមនេះ ។ ចំពោះសាលក្រមចុងក្រោយ គេទុកផ្លូវសម្រាប់ឱ្យធ្វើបណ្ដឹងឧបាស្រ័យ ទៅតុលាការជាន់ខ្ពស់បាន តែចំពោះសាលក្រមរបៀបវិញ គេមិនទទួលស្គាល់ការប្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដោយឯកឯងឡើយ ។ ប្រភេទនៃសាលក្រមចុងក្រោយដែលចែងនៅទីនេះ មានដូចជា សាលក្រមលើកចោលពាក្យបណ្ដឹង សាលក្រមច្រានចោលការទាមទារ សាលក្រមទទួលស្គាល់ការទាមទារ ជាដើម ។ សូមមើលផងដែរនូវកថាខណ្ឌទី ១ នៃមាត្រា 390 នៃក្រមនីតិវិធីរដ្ឋប្បវេណីអូទ្រីស និង មាត្រា 183 នៃក្រមនីតិវិធីរដ្ឋប្បវេណីកូរ៉េ ។

(2) សាលក្រមចុងក្រោយនេះ ក្រៅពី "សាលក្រមសម្រេចទាំងមូល" ដែលបញ្ចប់ការវិនិច្ឆ័យចំពោះបណ្តឹងទាំងអស់ គឺមាន "សាលក្រមសម្រេចតែមួយផ្នែក" ដែលបញ្ចប់ការវិនិច្ឆ័យចំពោះតែមួយផ្នែក ។ កថាខណ្ឌទី ២ នេះ ចែងអំពីបញ្ញត្តិស្តីអំពីសាលក្រមសម្រេចតែមួយផ្នែក ។

(3) សូមមើលមាត្រា 153 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

Code of Civil Procedure (Japan)
**Article 243** (Final judgment)
1. The court shall render a final judgment when a suit is ripe for decision.
2. In cases where a part of a suit is ripe for decision, the court may render a final judgment as to such part.
3. The provisions of the preceding paragraph shall apply *mutatis mutandis* to cases where the oral arguments of several suits are consolidated and one of such suits has become ripe for decision, and cases where the principal suit or a cross action has become ripe for decision.
**Article 153** (Reopening of oral argument)
The court may order the reopening of oral argument which have been concluded.

## **មាត្រា ១៨១.-** សាលក្រមរបៀប

បើមានវិវាទអំពីហេតុណាមួយដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ តុលាការអាចបញ្ចប់ការវិនិច្ឆ័យចំពោះតែហេតុនោះសិន ហើយចេញសាលក្រមរបៀបបាន :

**ក-** អត្ថិភាពនៃការទាមទារក្នុងករណីដែលមានវិវាទលើអត្ថិភាព និង ចំនួនទឹកប្រាក់នៃការទាមទារ ។(1)

**ខ-** មធ្យោបាយតទល់ ឬ ការពារខ្លួនដែលអាចវិនិច្ឆ័យដោយឯករាជ្យបាន ។(2)

**គ-** អត្ថិភាព ឬ នត្ថិភាពនៃល័ក្ខខ័ណ្ឌបណ្តឹង ។(3)

**ឃ-** ហេតុដែលទាក់ទងនឹងការបញ្ចប់បណ្តឹង ។(4)

(កំណត់)

សូមមើលមាត្រា 245 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(1) សាលក្រមរបៀបតាមមាត្រានេះ មានលក្ខណៈខុសគ្នាដាច់ស្រឡះពី "សាលក្រមរបៀប" ដែលតុលាការកម្ពុជាធ្លាប់អនុវត្តកន្លងមក ។

(2) ក្នុងករណីដែលមានចំណុចវិវាទទាំងលើមូលហេតុនៃការទាមទារ និង ទាំងលើចំនួនទឹកប្រាក់នៃការទាមទារ ហើយការវិនិច្ឆ័យអំពីចំនួនទឹកប្រាក់នោះមានការស្មុគ្រស្មាញ និង បណ្តាលឱ្យប្រើប្រាស់រយៈពេលវែង ប្រសិនបើតុលាការវិនិច្ឆ័យទាំងមូលហេតុ និង ទាំងចំនួនទឹកប្រាក់ ហើយការវិនិច្ឆ័យនោះត្រូវបានសន្និដ្ឋានថា ការទាមទារគ្មានមូលហេតុវិញ នោះវាបណ្តាលឱ្យការវិនិច្ឆ័យអំពីចំនួនទឹកប្រាក់នោះត្រូវអសារបង់ ។ ដូច្នេះ ជាដំបូង គេទទួលស្គាល់នូវការចេញសាលក្រមរបៀប (interlocutory judgment, jugement interlocutoire) អំពីមូលហេតុនៃការទាមទារសិន ដើម្បីកុំឱ្យមានបញ្ហាដូចខាងលើនេះ ។ បញ្ញត្តិនេះ មានគោលបំណងគិតទៅលើសេដ្ឋកិច្ចនៃបណ្តឹង ។ សូមមើលមាត្រា

393 នៃក្រមនីតិវិធីរដ្ឋប្បវេណីអូទ្រីស ។

(3) ពាក្យ "អាចវិនិច្ឆ័យដោយឯករាជ្យបាន" ក្នុងចំណុចនេះ មានន័យថា អត្ថិភាព ឬ នត្ថិភាពនៃមធ្យោបាយតទល់ ឬ ការពារខ្លួន អាចបង្កើត ផ្លាស់ប្តូរ ឬ រំលត់នូវទំនាក់ទំនងសិទ្ធិដោយស្វ័យប្រវត្តិ ។ ឧទាហរណ៍ : ក្នុងករណីរឿងក្តីដែលដើមចោទទាមទារការបញ្ជាក់កម្មសិទ្ធិ មូលហេតុលទ្ធកម្មនៃកម្មសិទ្ធិ ដូចជាការលក់ទិញ ឬ លទ្ធកម្មដោយអាជ្ញាយុកាល ជាដើម គឺជាចំណុចដែលអាចវិនិច្ឆ័យដោយឯករាជ្យបាន ។

(4) ឧទាហរណ៍ : រឿងក្តីដែលកំពុងចាត់ការ បើមានវិវាទទៅលើល័ក្ខខ័ណ្ឌនៃបណ្តឹងដូចជា អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិជម្រះក្តីរបស់តុលាការប្រទេសកម្ពុជា ឬ សមត្ថភាពរបស់ភាគីថាមានឬគ្មាន ឬ ការបញ្ជូនពាក្យបណ្តឹងនោះមានសុពលភាពឬគ្មាន តុលាការអាចចេញសាលក្រមបរបៀបចំពោះអត្ថិភាពនៃល័ក្ខខ័ណ្ឌនៃបណ្តឹងនោះបាន ។ ផ្ទុយទៅវិញ បើតុលាការវិនិច្ឆ័យទៅលើល័ក្ខខ័ណ្ឌនៃបណ្តឹងថាគ្មានអត្ថិភាពទេ តុលាការនឹងចេញសាលក្រមចុងក្រោយ លើកចោលនូវបណ្តឹងនោះ ។

(5) បើមានវិវាទទៅលើសុពលភាព ឬ មោឃភាពនៃការដកពាក្យបណ្តឹង ការផ្សះផ្សាលើបណ្តឹង ការលះបង់ការទាមទារ ឬ ទទួលស្គាល់ការទាមទារ ជាដើម តុលាការអាចបន្តបណ្តឹងនោះ ដោយចេញសាលក្រមរបៀបថា វាមោឃភាព ។ ផ្ទុយទៅវិញ បើវិនិច្ឆ័យថា មានសុពលភាព តុលាការនឹងប្រកាសបញ្ចប់បណ្តឹងនោះ ដោយសាលក្រមចុងក្រោយ ។

(6) ទោះបីជាមានវិវាទដែលបានកំណត់នៅក្នុងមាត្រានេះក៏ដោយ ក៏តុលាការមិនចាំបាច់ចេញសាលក្រមរបៀប ហើយបន្តនីតិវិធីរហូតដល់ពេលចេញសាលក្រមចុងក្រោយបានដែរ ។

Code of Civil Procedure (Japan)
**Article 245** (Interlocutory judgment)
In cases where an independent offensive or defensive measures, or any other interlocutory dispute is ripe for decision, the court may render an interlocutory judgment. The same shall apply with regard to the grounds on which a claim is based when a dispute exists over such grounds and the amount of claim.

**មាត្រា ១៨២.-** ចំណុចដែលត្រូវវិនិច្ឆ័យដោយសាលក្រម

១- តុលាការត្រូវចេញសាលក្រមចំពោះការទាមទារទាំងអស់ដែលភាគីបានសុំ ។ (1)

២- តុលាការមិនអាចចេញសាលក្រមចំពោះចំណុចណាដែលភាគីមិនបានសុំឡើយ ។ (2)

៣- តុលាការត្រូវសម្រេចសេចក្តីអំពីករណីយកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្តី ទោះបីជាគ្មានពាក្យសុំរបស់ភាគីក៏ដោយ ។ (3)

(កំណត់)

សូមមើលមាត្រា 246 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(1) បញ្ញត្តិនេះចែងអំពីករណីយកិច្ចរបស់តុលាការដែលត្រូវឆ្លើយនូវរាល់ការទាមទារទាំងឡាយដែលភាគីបានសុំ ។ សូម

មើលមាត្រា 112 នៃក្រមនីតិវិធីរដ្ឋប្បវេណីអ៊ីតាលី និង មាត្រា 153 នៃក្រមនីតិវិធីរដ្ឋប្បវេណីបារាំង ។ កថាខណ្ឌទី ១ នេះ ក្លាយជាមូលដ្ឋានតក្កៈនៃមាត្រា ១៨៣ (ការខកខានវិនិច្ឆ័យ) ខាងក្រោមនេះ ។

(2) បញ្ញត្តិនេះមានអត្ថន័យថា ជាគោលការណ៍ ចំណុចដែលភាគីសុំ និង ចំណុចនៃសាលក្រមរបស់តុលាការ ត្រូវតែមានភាពដូចគ្នា ហើយម្យ៉ាងទៀត មានអត្ថន័យបញ្ជាក់ច្បាស់លាស់អំពីគោលការណ៍នៃសិទ្ធិចាត់ចែងថា "គ្មានបណ្ដឹង គ្មានការសម្រេចសេចក្ដី" ។

(3) សូមមើលកថាខណ្ឌទី 2 មាត្រា 308 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាល្លឺម៉ង់ ។

(4) កថាខណ្ឌទី ៣ នៃមាត្រានេះ កំណត់ថា តុលាការត្រូវសម្រេចអំពីបន្ទុកប្រាក់ប្រដាប់ក្ដី ដោយមិនចាំបាច់មានពាក្យសុំរបស់ភាគី យោងតាមជំពូកស្ដីពីប្រាក់ប្រដាប់ក្ដី ដែលច្បាប់តម្រូវឱ្យភាគីចាញ់ក្ដីជាអ្នកទទួលបន្ទុក (មើល មាត្រា ៦៤ កថាខណ្ឌទី ១) ។

<u>Code of Civil Procedure (Japan)</u>
**Article 246** (Matter to be adjudicated)
The court shall not render judgment on any matters not advanced by the parties.

<u>Codici di Procedura Civile (Italy)</u>
**Art. 112** Corrispondenza tra il chiesto e il pronunciato
Il giudice deve (55) pronunciare su tutta la domanda e non oltre i limiti di essa (277; Cod. Civ. 2907); e non può pronunciare d`ufficio su eccezioni, che possono essere proposte soltanto dalle parti (38; Cod. Civ. 2938, 2969).

<u>Code de Procédure Civile (France)</u>
<u>Article 5</u>
Le juge doit se prononcer sur tout ce qui est demandé et seulement sur ce qui est demandé.
(The judge must rule on all that is demanded, and only on that which is demanded.)

<u>The Code of Civil Procedure Rules (Germany)</u>
**Article 308** (Decision without a petition) (excerpt)
(2) The court must decide on the obligation to bear costs of the action also without a petition.

## **មាត្រា ១៨៣.-** ការខកខានវិនិច្ឆ័យ

បើតុលាការខកខានមិនបានធ្វើការវិនិច្ឆ័យលើការទាមទារផ្នែកណាមួយ ផ្នែកនៃការទាមទារដែលខកខាននោះ ត្រូវបានចាត់ការបន្តនៅតុលាការនោះតទៅទៀត ។(1)

(កំណត់)

សូមមើលមាត្រា 258 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(1) មាត្រានេះចែងអំពីការធ្វេសប្រហែសរបស់តុលាការ នៅក្នុងករណីដែលមិនបានវិនិច្ឆ័យទៅលើផ្នែកណាមួយនៃការទាមទារ ដែលយើងហៅថា "ការខកខានវិនិច្ឆ័យ" គឺបញ្ជាក់ច្បាស់ថា ផ្នែកនៃការទាមទារដែលត្រូវបានខកខាន ត្រូវបានបន្តចាត់ការទៅទៀតនៅតុលាការនោះ ។ ហេតុដូច្នេះ កាលណាតុលាការធ្វើការវិនិច្ឆ័យដោយចេញសាលក្រមទៅលើផ្នែកដែលត្រូវបានខកខាននោះ ទើបការចាត់ការនៃបណ្ដឹង ត្រូវបានបញ្ចប់ ។ សាលក្រមដែលវិនិច្ឆ័យ

ជាក្រោយលើផ្នែកដែលត្រូវខកខាននោះ យើងហៅថា "សាលក្រមបន្ថែម" ។

Code of Civil Procedure (Japan)
**Article 258** (Omission in decision) (excerpt)
1. In cases where a court has failed to render a decision on a part of a claim, the case shall remain pending before the court with regard to such part of the claim.

## មាត្រា ១៨៤.- គោលការណ៍ជំនឿទុកចិត្តដោយសេរី

ក្នុងការចេញសាលក្រម តុលាការត្រូវវិនិច្ឆ័យទទួលស្គាល់ ឬ មិនទទួលស្គាល់ថាការអះអាងអំពីអង្គហេតុ មាន ឬ គ្មានភាពពិត ដោយគិតពិចារណាយ៉ាងហ្មត់ចត់នូវលទ្ធផលនៃការពិនិត្យភស្តុតាង និង ដំណើរការនិងខ្លឹមសារនៃការទាញហេតុផលដោយផ្ទាល់មាត់ តាមជំនឿទុកចិត្តដោយសេរីរបស់ខ្លួន ។

(កំណត់)

គោលការណ៍ជំនឿទុកចិត្តដោយសេរី គឺជាគោលការណ៍ដែលចៅក្រម (តុលាការ) វិនិច្ឆ័យទៅលើវត្ថុទាំងឡាយដែលត្រូវបានដាក់ ដោយស្របច្បាប់ ដោយសេរី ហើយចៅក្រម (តុលាការ) អាចទទួលស្គាល់អង្គហេតុដែលជាមូលដ្ឋាននៃសាលក្រម ដោយផ្អែកលើជំនឿទុកចិត្តនោះ ។ គោលការណ៍មួយទៀតដែលផ្ទុយនឹងគោលការណ៍នៃសេរីភាពក្នុងការធ្វើជំនឿទុកចិត្តនោះ គឺគោលការណ៍បញ្ជាក់ដោយភស្តុតាងដែលច្បាប់បានកំណត់ ដោយកម្រិតប្រភេទនៃភស្តុតាង ឬ អានុភាពក្នុងការបញ្ជាក់ដោយភស្តុតាង ។ ឧ. ភស្តុតាងក្រៅពីឯកសារមិនអាចបញ្ជាក់នូវអនុប្បទានអចលនវត្ថុ ។ គោលការណ៍បញ្ជាក់ដោយភស្តុតាងដែលច្បាប់បានកំណត់នេះ ត្រូវបានយកនៅបណ្តាប្រទេសអឺរ៉ុប នៅមជ្ឈិមសម័យ ប៉ុន្តែក្រោយពេលនីតិវិធីរដ្ឋប្បវេណីប្រទេសបារាំង យកគោលការណ៍ជំនឿទុកចិត្តដោយសេរី នៅសតវត្សទី ១៩ នីតិវិធីរដ្ឋប្បវេណីគ្រប់ប្រទេសនៅសម័យទំនើបនេះ យកគោលការណ៍ជំនឿទុកចិត្តដោយសេរី ។ សូមមើលមាត្រា 247 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

Code of Civil Procedure (Japan)
**Article 247** (Principle of free determination)
In rendering a judgment, the court shall, considering the entire import of the oral argument and the result of the examination of evidence, and based upon its freely determined conviction, decide whether or not the allegations of fact are true.

## មាត្រា ១៨៥.- គោលការណ៍វិនិច្ឆ័យដោយផ្ទាល់

១- មានតែចៅក្រមដែលបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដែលជាមូលដ្ឋាននៃសាលក្រមនោះតែប៉ុណ្ណោះ ទើបអាចចេញសាលក្រមបាន ។ (1)

២- ក្នុងករណីដែលមានការផ្លាស់ប្តូរចៅក្រមនៅមុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍នូវលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលបានធ្វើពីមុនមក ។ (2)

៣- ក្នុងករណីដែលចៅក្រមទទួលបន្ទុកមានតែម្នាក់ត្រូវបានផ្លាស់ប្ដូរ ឬ ករណីដែលចៅក្រមក្នុងក្រុមប្រឹក្សាជំនុំជម្រះត្រូវបានផ្លាស់ប្ដូរលើសពីពាក់កណ្ដាល ប្រសិនបើភាគីដាក់ពាក្យសុំសាកសួរសាក្សីដែលបានសាកសួរពីមុនមករួចហើយ តុលាការត្រូវសាកសួរសាក្សីនោះឡើងវិញ ។

(កំណត់)

សូមមើលមាត្រា 249 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(1) បញ្ញត្តិនេះចែងថា មានតែចៅក្រមដែលទាក់ទងនឹងការទាញហេតុផលដោយផ្ទាល់មាត់ដែលជាមូលដ្ឋាននៃសាលក្រមតែប៉ុណ្ណោះទេ ដែលអាចចេញសាលក្រមបាន ។ សូមមើលមាត្រា 309 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាល្លឺម៉ង់ និងមាត្រា 412 កថាខណ្ឌទី 1 នៃក្រមនីតិវិធីរដ្ឋប្បវេណីអូទ្រីស ។

(2) គឺជាបញ្ញត្តិដែលចែងដូចគ្នានឹងមាត្រា 249 កថាខណ្ឌទី 2 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន តែដើម្បីបញ្ជាក់អំពីពេលវេលាឱ្យច្បាស់លាស់ យើងបន្ថែមពាក្យថា "មុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់" ។

(3) ទោះបីសាក្សីដែលបានសួររួចហើយក៏ដោយ បើមានពាក្យសុំពីភាគី តម្រូវឱ្យតុលាការសាកសួរសាក្សីនោះឡើងវិញ ដើម្បីឱ្យចៅក្រមទទួលបន្ទុកបន្ត បានស្ដាប់ ឬ សួរដោយផ្ទាល់ សម្រាប់ជាមូលដ្ឋានពិចារណាក្នុងការសម្រេចសេចក្ដីផ្អែកលើគោលការណ៍ជំនឿទុកចិត្តដោយសេរី របស់ចៅក្រមនោះ ។

Code of Civil Procedure (Japan)
**Article 249** (Principle of direct trial)
1. A judgment shall be rendered by such judge or judges as have participated in the oral argument forming the basis for such judgment.
2. In cases where any change in the judges occurs, the parties shall state the results of the forgoing oral argument.
3. In cases where a single judge is changed or where a majority of the judges of a panel are changed, if a party applies for re-examination of a witness who was previously examined, the court shall make such examination.

Code of Civil Procedure Rules (Germany)
**Article 309** (Deciding judges)
The judgment may be delivered only by those judges who were present at the proceedings upon which the judgment is based.

## ផ្នែកទី ៣ ការប្រកាសសាលក្រម

**មាត្រា ១៨៦.-** កំណើតអានុភាពនៃសាលក្រម

សាលក្រមនឹងមានអានុភាពដោយការប្រកាស ។ (1)

(កំណត់)

សូមមើលមាត្រា 250 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(1) មាត្រានេះមានន័យថា សាលក្រមនឹងមានអានុភាព ដោយ "ការប្រកាស" ដែលជាទម្រង់នៃការជូនដំណឹងពិសេស ដូចដែលបានចែងនៅក្នុងមាត្រា ១៨៧ (កាលបរិច្ឆេទនៃការប្រកាស) ទៅ ហើយមានន័យថា ទម្រង់ណាក្រៅពីការប្រកាសនេះ មិនបណ្តាលឱ្យមានអានុភាពឡើយ ។ ចំពោះនិយមន័យ និង អត្ថន័យ/ខ្លឹមសារនៃអានុភាពនៃសាលក្រមនេះ យើងចែងនៅ ផ្នែកទី ៤ (អានុភាពនៃសាលក្រម) ជំពូកទី ៥ នៃគន្ថីទី ២ ខាងក្រោមនេះ ។

Code of Civil Procedure (Japan)
**Article 250** (Taking effect of judgment)
A judgment shall take effect by pronouncement.

## មាត្រា ១៨៧.- កាលបរិច្ឆេទនៃការប្រកាស

ការប្រកាសសាលក្រមត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់នូវការទាញហេតុផលដោយផ្ទាល់មាត់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះរឿងក្តីដែលមានភាពស្មុគស្មាញខ្លាំង ឬ មានកាលៈទេសៈពិសេសផ្សេងទៀត ។(1)

(កំណត់)

សូមមើលមាត្រា 251 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន

(1) ការប្រកាសសាលក្រមត្រូវធ្វើឡើង ដោយកោះហៅគូភាគី តាមកាលបរិច្ឆេទដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះ (ឬ ចៅក្រមទទួលបន្ទុក ក្នុងករណីដែលរឿងក្តីត្រូវបានជំនុំជម្រះដោយចៅក្រមតែម្នាក់) បានកំណត់ ។ មាត្រានេះចែងថា ជាគោលការណ៍ កាលបរិច្ឆេទនៃការប្រកាស ត្រូវកំណត់ក្នុងអំឡុងពេល ១ ខែ បន្ទាប់ពីថ្ងៃដែលបានបញ្ចប់នូវការទាញហេតុផលដោយផ្ទាល់មាត់ ។ អំឡុងពេលនេះជាការទុកឱកាសឱ្យតុលាការ (ចៅក្រមទទួលបន្ទុក) ពិចារណាទាំងអង្គហេតុ និង អង្គច្បាប់ ដើម្បីសរសេរសាលក្រមឱ្យបានល្អត្រឹមត្រូវ ។

Code of Civil Procedure (Japan)
**Article 251** (Date of pronouncement) (excerpt)
1. The pronouncement of a judgment shall be made within two months of the day on which oral argument is concluded. However, this shall not apply in the event that the case is complicated or when any other special circumstances exist.
2. The pronouncement of a judgment may be made even when the parties are not present in court.

## មាត្រា ១៨៨.- របៀបនៃការប្រកាស

១- ការប្រកាសសាលក្រមត្រូវធ្វើឡើងតាមកាលបរិច្ឆេទ នៅក្នុងសាលសវនាការដែលបើកជាសាធារណៈ ដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះជាអ្នកអានសេចក្តីសម្រេចបញ្ចប់ ដោយផ្អែកលើច្បាប់ដើមនៃមូលសាលក្រម ។ ប៉ុន្តែ ក្នុងករណីដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះមានធុរៈ ចៅក្រមប្រឹក្សាអាចអានជំនួសបាន ។(1)

២- ការប្រកាសសាលក្រមអាចធ្វើបាន ទោះបីជាគ្មានវត្តមានរបស់គូភាគីនៅក្នុងសាលសវនាការក៏ដោយ ។(2)

៣- ប្រសិនបើយល់ឃើញថាសមរម្យ ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអានសំអាងហេតុនៃសាលក្រម ឬ អាចពន្យល់ខ្លឹមសារនៃសំអាងហេតុនោះដោយផ្ទាល់មាត់បាន ។(3)

(កំណត់)

សូមមើលមាត្រា 251 កថាខណ្ឌទី ២ និង មាត្រា ២៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន និង មាត្រា 155 នៃបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(1) បញ្ចូលជាមួយគ្នានូវបញ្ញត្តិរបស់មាត្រា 252 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន និង មាត្រា 155 នៃបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(2) ជាគោលការណ៍ នៅក្នុងករណីដែលគូភាគីទាំងសងខាងពុំមាននៅវត្តមាននៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ទេ ពុំអាចធ្វើសកម្មភាពបណ្តឹងបានឡើយ ។ ប៉ុន្តែ ចំពោះការប្រកាសសាលក្រមនេះ ពុំចាំបាច់មានសកម្មភាពបណ្តឹងរបស់គូភាគី ដូច្នេះកថាខណ្ឌនេះចែងថា ជាករណីពិសេស ទោះជាគ្មានវត្តមានរបស់គូភាគី នៅក្នុងសាលសវនាការក៏ដោយ តុលាការអាចប្រកាសសាលក្រមបាន ។ សូមមើលមាត្រា 251 កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(3) ពាក្យថា "ប្រសិនបើយល់ឃើញថាសមរម្យ" គឺជាករណីដែលសង្គមមានការចាប់អារម្មណ៍ចំពោះរឿងក្តីនោះ ហើយមានការចូលរួមស្តាប់ការវិនិច្ឆ័យក្តីនោះពីសំណាក់ពលរដ្ឋច្រើន ឬ ករណីដែលមានវត្តមានរបស់ភាគី នៅកាលបរិច្ឆេទក្នុងសាលសវនាការ ហើយភាគីមានបំណងពិសេសចង់ឱ្យបង្ហាញជាសាធារណៈនូវមូលហេតុ នៅសាលសវនាការជាដើម ។

(4) ការអនុញ្ញាតឱ្យចៅក្រមប្រឹក្សា អាចអានជំនួសប្រធានក្រុមប្រឹក្សាជំនុំជម្រះនូវសាលក្រម ក្នុងករណីដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះមានធុរៈ ពុំមានឥទ្ធិពលអ្វី ធ្វើឱ្យផ្លាស់ប្តូរនូវអត្ថន័យនៃសេចក្តីសម្រេចរបស់សាលក្រមឡើយ ព្រោះក្រុមប្រឹក្សាជំនុំជម្រះបានពិភាក្សា និង សម្រេចរួចហើយ ដូច្នេះ ការអាន គឺជាការប្រកាសតាមតែការសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះតែប៉ុណ្ណោះ ។

Code of Civil Procedure (Japan)
**Article 251** (Date of pronouncement) (excerpt)
2. The pronouncement of a judgment may be made even when the parties are not present in court.
**Article 252** (Method of pronouncement of judgment)
The pronouncement of a judgment shall be founded upon an original judgment paper.

Rules of Civil Procedure (Japan)
**Article 155** (Method of pronouncement of judgment/The Code Article 252, etc.)
1. The pronouncement of a judgment shall be made by the presiding judge, reading aloud the formal disposition of the judgment.
2. The presiding judge may, upon determining it proper, read aloud the reasons for the judgment or orally summarize such reasons.
3. Notwithstanding the preceding two paragraphs, the pronouncement of a judgment under the provisions of Article 254 (Special provisions for method of pronouncement of judgment), paragraph 1 of the Code shall be made by the presiding judge, summarizing the formal disposition and reason for the judgment.

**មាត្រា ១៨៩.-** លិខិតសាលក្រម

១- នៅក្នុងលិខិតសាលក្រម ត្រូវសរសេរចំណុចដូចខាងក្រោមនេះ :

**ក-** តុលាការ ។

**ខ-** ថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ។

**គ-** ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

**ឃ-** អង្គហេតុ និង ចំណុចវិវាទ ។

**ង-** សំអាងហេតុ ។

**ច-** សេចក្តីសម្រេចបញ្ចប់ ។

២- ចំពោះអង្គហេតុ និង ចំណុចវិវាទ ត្រូវសរសេរខ្លឹមសារសំខាន់ៗដោយផ្អែកលើសេចក្តីថ្លែងការណ៍របស់ភាគី ។

៣- ចៅក្រមដែលចេញសាលក្រមត្រូវចុះហត្ថលេខាលើលិខិតសាលក្រមនោះ ។

៤- ក្នុងករណីដែលចៅក្រមណាម្នាក់ក្នុងចំណោមក្រុមប្រឹក្សាជំនុំជម្រះ មានធុរៈក្នុងការចុះហត្ថលេខាលើលិខិតសាលក្រម ចៅក្រមផ្សេងទៀតត្រូវចុះហត្ថលេខា ដោយចុះនិទ្ទេសអំពីហេតុដែលចៅក្រមនោះមិនអាចចុះហត្ថលេខាបាន ។

(កំណត់)

សូមមើលមាត្រា 253 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន និង មាត្រា 157 នៃបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ ម្យ៉ាងទៀតសូមមើលផងដែរនូវនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ មាត្រា 191 ។ ចំណុចដែលបានរៀបរាប់នៅក្នុងកថាខណ្ឌទី ១ គឺចំណុចដែលចាំបាច់សរសេរក្នុងលិខិតសាលក្រម ហើយក្រៅពីចំណុចទាំងនោះ តុលាការអាចសរសេរចំណុចផ្សេងទៀត ដូចជា លេខសំណុំរឿង ប្រភេទនៃសាលក្រម ជាដើម ។ បើសិនណាមិនបានសរសេរចំណុចចំបាច់ណាមួយនាំឱ្យខុសពីទម្រង់នៃសាលក្រម ។

Code of Civil Procedure (Japan)
**Article 253** (Judgment paper)
1. A judgment paper shall include the following matters:
  i. formal disposition;
  ii. facts;
  iii. reason;
  iv. the day on which oral argument was concluded;
  v. parties and their legal representatives;
  vi. identity of the court.
2. The inclusion of facts shall be made by clearly designating the claim and by summarizing the allegations which are necessary for showing that the formal disposition is just.

Rules of Civil Procedure (Japan)
**Article 157** (Judgment paper / The Code Article 253)
1. The judge who has rendered the judgment shall sign his or her name and affix his or her seal to the judgment paper.

2. In cases where a judge who is a member of the panel is unable to sign his or her name and affix his or her seal to the judgment paper, another judge shall, recording that reason, sign his or her name and affix his or her seal to the judgment paper.

Old Code of Civil Procedure (Japan, 1890, last amendament: 1992)
**Article 191** (Matters to be entered in a judgment)
1. The following matters shall be entered in a judgment and the judge who rendered the judgment shall sign and seal thereon:
   (1) Text;
   (2) Facts and points at issue;
   (3) Reasons;
   (4) Parties and their legal representatives;
   (5) The court.
2. Entry of facts and points at issue shall be made by stating the gist thereof on the basis of the statement of the parties made at their oral argument. Provided that, with respect to the matters concerning evidences, the statement of a protocol in the record of proceedings may be quoted.
3. In case any judge is incapacitated to sign and seal on the judgment, other judge shall state the reasons therefor and sign and seal thereon.

## **មាត្រា ១៩០.-** ការបញ្ជូនលិខិតសាលក្រម

១- លិខិតសាលក្រមត្រូវបញ្ជូនទៅឱ្យគូភាគី ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានប្រកាសសាលក្រមនោះ ។ (1)

២- ការបញ្ជូនដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានធ្វើឡើងដោយអនុសារសាលក្រម ។

(កំណត់)

សូមមើលមាត្រា 255 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន និង មាត្រា 159 នៃបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(1) សាលក្រមត្រូវប្រកាស ដោយអាននូវសេចក្តីសម្រេចបញ្ចប់ (formal disposition, forme de dispositif) ឯចំណែកសំអាងហេតុនៃសាលក្រមវិញ មិនតម្រូវឱ្យប្រកាសគ្រប់តែករណីឡើយ ។ ហើយសេចក្តីប្រកាសសាលក្រម អាចធ្វើឡើងបាន ទោះជាគ្មានវត្តមានរបស់គូភាគីនៅក្នុងសាលសវនាការក៏ដោយ ។ ត្រង់ចំណុចនេះ តុលាការត្រូវបញ្ជូនលិខិតសាលក្រមទៅគូភាគី ដើម្បីឱ្យដំណឹងអំពីអត្ថន័យរបស់សាលក្រម ទោះបីមាន ឬ គ្មានវត្តមានរបស់ភាគីនៅពេលប្រកាសសាលក្រមក៏ដោយ ។ម្យ៉ាងទៀត ឆ្លងតាមការបញ្ជូននេះ អំឡុងពេលដែលអាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចាប់ដំណើរការ ហើយភាគីឈ្នះក្តីអាចធ្វើការអនុវត្តដោយបង្ខំបាន ។

<u>Code of Civil Procedure (Japan)</u>
**Article 255** (Service of judgment paper)
1. A judgment paper or a record referred to in paragraph 2 of the preceding article shall be served on the parties.
2. Service prescribed by the preceding paragraph shall be carried out by an authenticated copy of the judgment paper or a transcript of the record referred to in paragraph 2 of the preceding article.

<u>Rules of Civil Procedure (Japan)</u>
**Article 159** (Service of judgment paper, etc. / The Code Article 255)
1. Service of a judgment paper or a record referred to in Article 254 (Special provisions for method of pronouncement of judgment), paragraph 2 of the Code (including those cases to which it applies *mutatis mutandis* in Article 374 (Pronouncement of judgment), paragraph 2 of the Code) (hereinafter: "record in lieu of judgment paper") shall be made by the court clerk within two weeks of the day on which thee judgment paper was delivered or the judgment was pronounced.
2. Service of a record in lieu of judgment paper may be carried out by authenticated copies of that record.

# ផ្នែកទី ៤ អានុភាពនៃសាលក្រម

**មាត្រា ១៩១.-** អត្តពន្ធភាពនៃសាលក្រម

លើកលែងតែក្នុងករណីដែលបានកំណត់ក្នុងមាត្រា ១៩២ (ដីកាសម្រេចកែតម្រូវ) នៃក្រមនេះ តុលាការដែលបានចេញសាលក្រម មិនអាចលុប ឬ កែប្រែសាលក្រមនោះបានទេ ។(1)

(កំណត់)

(1) បញ្ញត្តិនេះចែងថា សាលក្រមមានអានុភាពចងតុលាការដែលបានប្រកាសសាលក្រមខ្លួនឯងផងដែរ ។ម្យ៉ាងទៀត ទោះបីមានបញ្ញត្តិអំពីដីកាសម្រេចកែតម្រូវដែលបានកំណត់ក្នុងមាត្រា ១៩២ (ដីកាសម្រេចកែតម្រូវ) ខាងក្រោមនេះក៏ដោយ ក៏តុលាការត្រូវយកគោលការណ៍អត្តពន្ធភាពនៃសាលក្រមធ្វើជាមូលដ្ឋាន ។

**មាត្រា ១៩២.-** ដីកាសម្រេចកែតម្រូវ

១- ក្នុងករណីដែលសាលក្រមមានការគណនាលេខខុស ឬ កត់ខុស ឬ កំហុសជាក់ស្តែងផ្សេងទៀតដែលមានប្រភេទប្រហាក់ប្រហែលគ្នា តុលាការអាចចេញដីកាសម្រេចកែតម្រូវសាលក្រម តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន។ (1)(2)

២- ចំពោះដីកាសម្រេចកែតម្រូវសាលក្រម អាចប្តឹងជំទាស់បាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានបណ្តឹងឧទ្ធរណ៍ស្របច្បាប់ចំពោះសាលក្រមនោះ ។(3)

៣- ដីកាសម្រេចកែតម្រូវត្រូវសរសេរបន្ថែមនៅលើច្បាប់ដើមនៃមូលសាលក្រម និង អនុសារសាលក្រម ។ ប៉ុន្តែ ប្រសិនបើយល់ឃើញថាសមរម្យ តុលាការអាចធ្វើដីកាសម្រេចនេះជាលិខិត ជំនួសការសរសេរបន្ថែមនៅលើច្បាប់ដើមនៃមូលសាលក្រម និង អនុសារសាលក្រម ហើយបញ្ជូនឯកសារចម្លងយថាភូតនៃដីកាសម្រេចនេះ ទៅឱ្យគូភាគីបាន ។(4)

(កំណត់)

សូមមើលមាត្រា 257 នៃក្រមនីតិវិធីរដ្ឋប្បវេណី និង មាត្រា 160 នៃបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(1) សាលក្រមមានអានុភាពចងដោយខ្លួនឯងមែន តែការកែតម្រូវកំហុសជាក់ស្តែងក្នុងការសរសេរ ពុំមែនជាការផ្លាស់ប្តូរខ្លឹមសាររបស់សាលក្រមឡើយ ។ ក្នុងករណីនេះ បើយើងតម្រូវឱ្យឆ្លងកាត់ការវិនិច្ឆ័យរបស់តុលាការជាន់ខ្ពស់នោះ កិច្ចការនេះទាមទារឱ្យយើងចំណាយនូវពេលវេលា និង ពលកម្មដែលគ្មានប្រយោជន៍យ៉ាងច្រើន ដូច្នេះហើយ បញ្ញត្តិនេះ ទទួលស្គាល់ការកែតម្រូវសាលក្រមរបស់តុលាការដែលបានចេញសាលក្រមនោះដោយខ្លួនឯង ។

(2) ដោយសារអ្នកដែលស្វែងរកឃើញនូវការសរសេរខុសនៅលើសាលក្រម ភាគច្រើនជាភាគី ហើយភាគីជាអ្នកដែល

ទទួលការខូចផលប្រយោជន៍ដោយសារការសរសេរខុសនោះ ដូច្នេះយើងទទួលស្គាល់នូវសិទ្ធិដាក់ពាក្យសុំរបស់ភាគី ។

(3) ភាគីដែលបានទទួលការខូចផលប្រយោជន៍ដោយសារដីកាសម្រេចកែតម្រូវសាលក្រម អាចប្តឹងជំទាស់ ចំពោះដីកាសម្រេចនោះបាន តែបើមានការប្តឹងឧទ្ធរណ៍ស្របច្បាប់ចំពោះសាលក្រមនោះ ភាពត្រឹមត្រូវនៃដីកាសម្រេចកែតម្រូវសាលក្រមនោះ ក៏នឹងត្រូវបានវិនិច្ឆ័យ នៅពេលដែលតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍សម្រេចសេចក្តីអំពីបណ្តឹងឧទ្ធរណ៍នោះដែរ ហេតុដូច្នេះ បញ្ញត្តិនេះមិនអនុញ្ញាតឱ្យភាគីធ្វើបណ្តឹងជំទាស់ចំពោះដីកាសម្រេចកែតម្រូវដោយឯកឯងឡើយ នៅពេលមានការប្តឹងឧទ្ធរណ៍ ។

(4) ដីកាសម្រេចកែតម្រូវក្លាយជាសេចក្តីវិនិច្ឆ័យតែមួយ ដោយសរសេរបន្ថែមលើលិខិតសាលក្រម ហើយបង្កើតអានុភាពដូចបានចេញសាលក្រមដែលមានអត្ថន័យដែលបានកែតម្រូវហើយតាំងពីពេលដំបូង ។ ក្នុងករណីដែលបានធ្វើលិខិតដីកាសម្រេចកែតម្រូវ ការភ្ជាប់ជាមួយនឹងលិខិតសាលក្រមពុំចាំបាច់ឡើយ ។

Code of Civil Procedure (Japan)
**Article 257** (Ruling of correction)
1. In cases where a judgment is found to contain a miscalculation, clerical error or any other similar obvious error, the court may, upon motion or upon its own authority, render a ruling of correction at any time.
2. An immediate *kokoku*-appeal may be made against a ruling of correction. However, this shall not apply in cases where a legitimate *koso*-appeal has been filed against the judgement.

Rules of Civil Procedure (Japan)
**Article 160** (Form of motion referred to in Article 258, paragraph 2 of the Code)
1. A ruling of correction shall be added to the original and the authenticated copies of the judgment paper. However, the court may, upon determining it proper, in lieu of addition to the original and the authenticated copies of the judgment paper, make a ruling paper and serve authenticated copies thereof on the parties.
2. The provisions of the preceding paragraph shall apply *mutatis mutandis* to a supplemental ruling under the provisions of Article 259 (Declaration of provisional execution), paragraph 5 of the Code.

## **មាត្រា ១៩៣.-** ពេលដែលសាលក្រមចូលជាស្ថាពរ

១- សាលក្រមមិនអាចចូលជាស្ថាពរ នៅមុនពេលផុតអំឡុងពេលដែលបានកំណត់សម្រាប់ការប្តឹងឧបាស្រ័យ ទៅតុលាការជាន់ខ្ពស់ដែលស្របច្បាប់ ឬ ការប្តឹងទាស់ដែលស្របច្បាប់បានទេ ។

២- ការចូលជាស្ថាពរនៃសាលក្រម ត្រូវបានបង្អាក់ ដោយការដាក់ពាក្យបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ឬ ពាក្យបណ្តឹងទាស់ ដែលត្រូវបានធ្វើឡើងក្នុងអំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

សូមមើលមាត្រា 116 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 498 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ជាងគេ (1890) និង មាត្រា 705 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាល្លឺម៉ង់ ។

មាត្រានេះមានន័យថា នៅក្នុងអំឡុងពេលដែលច្បាប់បានផ្តល់សិទ្ធិឱ្យភាគីធ្វើបណ្តឹងឧបាស្រ័យ ឬ បណ្តឹងទាស់ដោយស្របច្បាប់ សាលក្រមមិនចូលជាស្ថាពរឡើយ ។

ប៉ុន្តែ ក្នុងសហបណ្តឹងធម្មតា ដែលតុលាការបានចេញសាលក្រមតែមួយចំពោះភាគីសហបណ្តឹងទាំងអស់ ប្រសិនបើភាគីសហបណ្តឹងណាមួយប្តឹងឧបាស្រ័យ ហើយភាគីសហបណ្តឹងផ្សេងទៀតមិនបានប្តឹងឧបាស្រ័យ នោះសាលក្រមចូលជាស្ថាពរ ចំពោះភាគីសហបណ្តឹងដែលមិនបានប្តឹងឧបាស្រ័យនោះ នៅពេលផុតអំឡុងពេលឧបាស្រ័យស្របច្បាប់ ។

Code of Civil Procedure (Japan)
**Article 116** (When judgment becomes final and binding)
1. A judgment shall not become final and binding prior to the expiration of the period designated for filing a *koso*-appeal or *jokoku*-appeal (excluding *jokoku*-appeals referred to in Article 327, paragraph 1 (including those cases to which it applies *mutatis mutandis* in Article 380, paragraph 2)), making a motion referred to in Article 318, paragraph 1, or raising an objection under Article 357 (including those cases to which it applies *mutatis mutandis* in Article 367, paragraph 2) or Article 378, paragraph 1.
2. A judgment shall be prevented from becoming final and binding upon the filing of a *koso*-appeal, the filing of a *jokoku*-appeal referred to in the preceding paragraph, or the making a motion [including the raising of objections] referred to in the paragraph within the period referred to in the paragraph.

The Code of Civil Procedure Rules (Germany)
**Article 705** (Formal binding form of judgments)
Judgments do not obtain a final binding effect before the expiry of the period allowed for filing admissible appeals or admissible objections. The incidence of binding effect shall be delayed by the timely filing of appeal or objection.

**មាត្រា ១៩៤.-** អាជ្ញាអស់ជំនុំនៃចំណុចដែលត្រូវបានវិនិច្ឆ័យដោយសាលក្រម

១- នៅពេលសាលក្រមចូលជាស្ថាពរហើយ អានុភាពនៃអាជ្ញាអស់ជំនុំត្រូវបានកើតឡើង ។

២- អាជ្ញាអស់ជំនុំដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវកំណត់ជាស្ថាពរនូវទំនាក់ទំនងសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត នាពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ។

៣- ទំហំនៃអាជ្ញាអស់ជំនុំដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មានត្រឹមតែទំហំដែលបានវិនិច្ឆ័យនៅក្នុងសេចក្តីសម្រេចបញ្ចប់ ចំពោះការទាមទារដែលបានសុំដោយពាក្យបណ្តឹង ឬ ពាក្យបណ្តឹងតបតែប៉ុណ្ណោះ ហើយអានុភាពនៃអាជ្ញាអស់ជំនុំនេះ មិនអាចមានទៅលើសេចក្តីវិនិច្ឆ័យក្នុងសំអាងហេតុនៃសាលក្រមបានទេ ។

៤- ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះក៏ដោយ បើចុងចម្លើយទាមទារការទូទាត់ ដោយសិទ្ធិលើបំណុលតប សេចក្តីវិនិច្ឆ័យក្នុងសាលក្រមស្ថាពរដែលសម្រេចថា គ្មានសិទ្ធិលើបំណុលតបទេនោះ ត្រូវបង្កើតអានុភាពនៃអាជ្ញាអស់ជំនុំ លើចំនួនប្រាក់ដែលបានតវ៉ាដោយការទូទាត់នោះ ។

(កំណត់)

សូមមើលមាត្រា 114 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន និង មាត្រា 322 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាល្លឺម៉ង់ ។

(1) កថាខណ្ឌទី ៣ នេះ ចែងអំពីគោលការណ៍ថា ការវិនិច្ឆ័យក្នុងសំអាងហេតុនៃសាលក្រម ពុំមានអានុភាពនៃអាជ្ញាអស់ជំនុំ ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នេះទេ ។ ការចែងអំពីគោលការណ៍នេះ ដោយហេតុថា : បើយើងចែងថា មិនឱ្យការវិនិច្ឆ័យក្នុងសំអាងហេតុនៃសាលក្រម មានអានុភាពនៃអាជ្ញាអស់ជំនុំនោះ ភាគីអាចធ្វើសកម្មភាពបណ្តឹងដោយសេរីបាន ដោយទុកមធ្យោបាយតទល់ ឬ ការពារខ្លួននោះគ្រាន់តែជាមធ្យោបាយមួយតែប៉ុណ្ណោះ ហើយធ្វើ

សកម្មភាពបណ្តឹងគិតតែអំពីលទ្ធផលចុងក្រោយតែប៉ុណ្ណោះ ។ ឯតុលាការវិញ អាចដឹកនាំបណ្តឹងតាមកាលៈទេសៈ ដោយស្វែងរកលទ្ធផលនៃការវិនិច្ឆ័យដោយអាចចាប់ផ្តើមពិនិត្យពីចំណុចវិវាទដែលងាយជាងគេបាន ។

(2) កថាខណ្ឌទី ៤ ចែងអំពីករណីលើកលែង នៃគោលការណ៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ។ ពោលគឺ បើមានការវិនិច្ឆ័យអំពីការតវ៉ាដោយការទូទាត់ នៅក្នុងសំអាងហេតុនៃសាលក្រម វាជាករណីលើកលែង ហើយ អានុភាពនៃអាជ្ញាអស់ជំនុំនឹងកើតមានឡើង ។ ការទទួលស្គាល់ឱ្យមានជាករណីលើកលែងនេះ ដោយសារមូលហេតុ ដូចតទៅ ។ នៅពេលដែលការតវ៉ាដោយការទូទាត់ត្រូវបានទទួលស្គាល់ សិទ្ធិទាមទាររបស់ដើមចោទ និង សិទ្ធិទាមទាររបស់ចុងចម្លើយ នឹងរលត់នៅក្នុងពេលជាមួយគ្នា ។ ក្នុងករណីនេះ សិទ្ធិទាមទាររបស់ដើមចោទដែល រលត់នោះ ត្រូវបានវិនិច្ឆ័យក្នុងសេចក្តីសម្រេចបញ្ចប់ ហើយបង្កើតឱ្យមានអានុភាពនៃអាជ្ញាអស់ជំនុំ តាមបញ្ញត្តិនៃ កថាខណ្ឌទី ១ ។ រីឯសិទ្ធិទាមទាររបស់ចុងចម្លើយដែលរលត់ ត្រូវបានវិនិច្ឆ័យក្នុងសំអាងហេតុនៃសាលក្រម បើយើង អនុវត្តតាមគោលការណ៍នៃកថាខណ្ឌទី ៣ អានុភាពអាជ្ញាអស់ជំនុំពុំកើតមានឡើយ ដែលជាហេតុនាំឱ្យខ្វះនូវភាព ស្មើគ្នា ។ ដូច្នេះ នៅក្នុងកថាខណ្ឌទី ៤ នេះ យើងចែងអំពីករណីលើកលែងថា ចំពោះតែករណីដែលមានការអះអាង អំពីការតវ៉ាដោយការទូទាត់ទេ ដែលជាករណីលើកលែង គឺទទួលស្គាល់អានុភាពអាជ្ញាអស់ជំនុំ លើការវិនិច្ឆ័យក្នុង សំអាងហេតុនៃសាលក្រម ។

<u>Code of Civil Procedure (Japan)</u>
**Article 114** (Scope of res judicata)
1. A judgment that has become final and binding has the effect of res judicata only concerning the matters contained in the formal disposition.
2. An adjudication upon the validity or invalidity of a claim asserted for set-off has the effect of res judicata with regard to the amount pleaded with regard to such set-off.

<u>The Code of Civil Procedure Rules (Germany)</u>
Article 322 (Substantive validity)
(1) Judgments have legal force only to such extent as they decide the demand raised by the statement of claim or counterclaim.
(2) If the defendant asserted the set-off of a counterdemand, the decision that the counterdemand does not obtain is legally valid up to the amount for which the set-off was asserted.

**មាត្រា ១៩៥.-** ពេលដែលអានុភាពអនុវត្តកើតឡើង

លើកលែងតែមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ សាលក្រមអាចអនុវត្តបាន ចាប់តាំងពីពេលដែលអាជ្ញាអស់ជំនុំបានកើត ឡើង ដូចបានកំណត់ក្នុងមាត្រា ១៩៤ (អាជ្ញាអស់ជំនុំនៃចំណុចដែលត្រូវបានវិនិច្ឆ័យដោយសាលក្រម) នៃក្រមនេះ ។

(កំណត់)

សូមមើលមាត្រា 501 នៃក្រមនីតិវិធីរដ្ឋប្បវេណីបារាំង ។ ករណីលើកលែង មានដូចជា ករណីដែលបានកំណត់នៅក្នុង កថាខណ្ឌទី ១ នៃមាត្រា ២៣៧ (ការពន្យារពេលបង់ប្រាក់ដោយសាលក្រម) ជាដើម ។

Code de Procédure Civile (France)
**Article 501**
Le jugement est exécutoire, sous les conditions qui suivent, à partie du moment où il passe en force de chose jugée à moins que le débiteur ne bénéficie d'un délai de grâce ou le créancier de l'exécution provisoire.
(The judgment is executory under the following conditions, from the moment it becomes *res judicata*, unless the debtor enjoys the benefit of a period of grace or the creditor enjoys the benefit of immediate execution.)

**មាត្រា ១៩៦.-** ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន (1)

១- ចំពោះសាលក្រមដែលសម្រេចអំពីការទាមទារសិទ្ធិលើទ្រព្យសម្បត្តិ បើយល់ឃើញថាចាំបាច់ តុលាការអាចប្រកាសថា សាលក្រមនោះអាចអនុវត្តជាបណ្តោះអាសន្នបាន ដោយឱ្យដើមចោទដែលឈ្នះក្តីដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។ (2)

២- តុលាការអាចប្រកាសថា ភាគីអាចរួចផុតពីការអនុវត្តជាបណ្តោះអាសន្នបាន ដោយឱ្យដាក់ប្រាតិភោគ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

៣- ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ត្រូវចែងនៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រម ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការប្រកាសដែលបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ។

៤- ក្នុងករណីដែលមិនបានសម្រេចសេចក្តីអំពីពាក្យសុំប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ឬ ក្នុងករណីដែលត្រូវប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នដោយឆន្ទានុសិទ្ធិ តែមិនបានធ្វើ តុលាការត្រូវចេញដីកាសម្រេចបន្ថែម តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលតុលាការមិនបានសម្រេចសេចក្តីអំពីពាក្យសុំដែលបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ។

(កំណត់)

សូមមើលមាត្រា 259 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(1) ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ននៃមាត្រានេះ គឺជាមធ្យោបាយមួយដើម្បីឱ្យដើមចោទដែលឈ្នះក្តីនៅការជម្រះក្តីលើកទី ១ អាចទទួលបានឆាប់នូវផលប្រយោជន៍ដែលជាសិទ្ធិរបស់ខ្លួន ។ ចុងចម្លើយដែលចាញ់ក្តីនៅការជម្រះក្តីលើកទី ១ ត្រូវបានអនុញ្ញាតឱ្យប្តឹងឧទ្ធរណ៍ ។ ប៉ុន្តែ ប្រសិនបើមានបណ្តឹងឧទ្ធរណ៍ ការចូលជាស្ថាពរនៃសាលក្រម ត្រូវពន្យារពេល ហើយការបង្កើតអានុភាពអនុវត្តដែលនឹងកើតឡើងដោយការចូលជាស្ថាពរនៃសាលក្រមនោះ ក៏មានការយឺតយ៉ាវដែរ ដែលជាហេតុធ្វើឱ្យរាំងស្ទះនូវការអនុវត្តសិទ្ធិរបស់អ្នកឈ្នះក្តី ។ ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ននេះ គឺជាប្រព័ន្ធមួយដើម្បីការពារអ្នកដែលបានឈ្នះក្តីកុំឱ្យមានការខូចផលប្រយោជន៍ និង ដើម្បីរក្សាតុល្យភាពជាមួយនឹងផលប្រយោជន៍របស់អ្នកចាញ់ក្តី ក្នុងការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ។

(2) ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន អាចធ្វើបានតែទៅលើការទាមទារសិទ្ធិលើទ្រព្យសម្បត្តិតែប៉ុណ្ណោះ ពីព្រោះការទាមទារសិទ្ធិលើទ្រព្យសម្បត្តិ ខុសពីការទាមទារលើឋានៈបុគ្គល ទោះជានៅក្រោយពេលសាលក្រមបានអនុវត្តជាបណ្តោះអាសន្ន ហើយតុលាការថ្នាក់លើបានច្រានចោលការទាមទារក៏ដោយ ក៏វាមានការងាយស្រួលក្នុងបដិទាន

ស្ថានភាពដើមរបស់វាវិញ ឬ អាចដោះស្រាយបានដោយសំណងជាទឹកប្រាក់ដែរ ។

Code of Civil Procedure (Japan)
**Article 259** (Declaration of provisional execution)
1. With regard to a judgment concerning a claim on a property right, the court may, upon determining it necessary, upon motion or upon its own authority, declare that a provisional execution may be carried out with or without security being provided.
2. With regard to a judgment concerning a claim on the monetary payment of a bill or a check and indemnification of damages incurred incidental thereto at an interest rate provided for by law, the court shall, upon its own authority, declare that a provisional execution may be carried out without security being provided. However, the court may, upon determining it proper, make its grant of such provisional execution contingent on security being provided.
3. The court may, upon motion or upon its own authority, declare that the provisional execution may be immunized with security being provided.
4. The declaration of provisional execution shall be included in the formal disposition of the judgment. The same shall apply to the declaration under the provisions of the preceding paragraph.
5. In cases where a decision has not been rendered with respect to a motion for the declaration of provisional execution, or where the declaration of provisional execution has not been made upon the court's own authority when it should do so, the court shall, upon motion or upon its own authority, render a supplemental ruling. The same shall apply to cases where a decision has not been rendered with referred to the motion referred to in paragraph 3.
6. The provisions of Article 76. 77, 79 and 80 shall apply *mutatis mutandis* to the security referred to in paragraphs 1 to 3 inclusive.

**មាត្រា ១៩៧.-** ការបាត់បង់អានុភាពនៃការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន និង បដិទានស្ថានភាពដើម

១- ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នត្រូវបាត់បង់អានុភាព ដោយការប្រកាសសាលដីការបស់តុលាការជាន់ខ្ពស់ដែលសម្រេចផ្លាស់ប្តូរការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ននោះ ឬ សាលក្រមសម្រេចអង្គសេចក្តី តាមទំហំនៃការផ្លាស់ប្តូរ ។(1)

២- ក្នុងករណីដែលតុលាការផ្លាស់ប្តូរសាលក្រមសម្រេចអង្គសេចក្តី តុលាការត្រូវបង្គាប់ក្នុងសាលដីកាឱ្យដើមចោទសងតាវកាលិកដែលចុងចម្លើយបានផ្តល់ ដោយផ្អែកលើការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន និង ឱ្យសងការខូចខាតដែលចុងចម្លើយបានទទួល ដោយសារការអនុវត្តជាបណ្តោះអាសន្ន ឬ ដើម្បីធ្វើឱ្យរួចផុតពីការអនុវត្តជាបណ្តោះអាសន្ននោះ តាមពាក្យសុំរបស់ចុងចម្លើយ ។(2)

៣- ក្នុងករណីដែលតុលាការបានផ្លាស់ប្តូរតែចំពោះការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នប៉ុណ្ណោះ បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះសាលដីកាដែលផ្លាស់ប្តូរសាលក្រមសម្រេចអង្គសេចក្តីនៅពេលក្រោយ ។(3)

(កំណត់)

សូមមើលមាត្រា 260 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(1) បើការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នត្រូវបានផ្លាស់ប្តូរ មុនពេលសាលក្រមដែលបង្គាប់ឱ្យផ្តល់តាវកាលិក ចូលជាស្ថាពរ ឬ បើសាលក្រមសម្រេចអង្គសេចក្តីដែលជាមូលដ្ឋាននៃការប្រកាសនោះ ត្រូវបានផ្លាស់ប្តូរ ការប្រកាសនោះនឹងត្រូវបាត់បង់អានុភាព តាមទំហំដែលបានធ្វើការផ្លាស់ប្តូរដោយតុលាការ ។

(2) ក្នុងករណីដែលការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នត្រូវបានបាត់បង់អានុភាព ចុងចម្លើយអាចទាមទារឱ្យដើម

ចោទសងតាវកាលិកដែលចុងចម្លើយបានផ្តល់ និង សងការខូចខាតដែលខ្លួនបានទទួលដោយសារការអនុវត្តជាបណ្តោះអាសន្ន ឬ ដើម្បីធ្វើឱ្យរួចផុតពីការអនុវត្តជាបណ្តោះអាសន្ននោះ ។

(3) សាលដីកាដែលផ្លាស់ប្តូរការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន មិនត្រូវចាំបាច់ចេញជាមួយនឹងសាលដីកាដែលផ្លាស់ប្តូរសាលក្រមសម្រេចអង្គសេចក្តីទេ គឺ អាចចេញជាសាលដីកាសម្រេចមួយផ្នែក ដោយបំបែកការទាញហេតុផលមុននឹងសាលដីកាដែលសម្រេចអង្គសេចក្តីបានដែរ ។ ក្នុងករណីនេះ ទោះបីជាការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នត្រូវបានលុបចោលក៏ដោយ បើសាលក្រមសម្រេចអង្គសេចក្តីមិនត្រូវបានផ្លាស់ប្តូរទេ ក៏ករណីយកិច្ចរបស់ដើមចោទក្នុងការធ្វើបដិទាន ឬ សងសំណងការខូចខាត មិនត្រូវកើតឡើងដែរ ។ ប៉ុន្តែ ប្រសិនបើសាលក្រមសម្រេចអង្គសេចក្តីត្រូវបានផ្លាស់ប្តូរនៅពេលក្រោយ ហើយការអនុវត្តដែលបានធ្វើរួចហើយ ត្រូវបានចាត់ទុកថា មិនត្រឹមត្រូវនោះតុលាការត្រូវទទួលស្គាល់បដិទាន ឬ សំណងនៃការខូចខាត ដូចករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ។ នេះជាអត្ថន័យនៃកថាខណ្ឌទី ៣ ។

Code of Civil Procedure (Japan)
**Article 260** (Loss of effect of declaration of the provisional execution, and restitution, etc.)
1. A declaration of provisional execution shall lose its effect to the extent that it is changed by a pronouncement of a judgment changing either such declaration or a judgment upon the merits of the suit.
2. In a judgment which changes a judgment upon the merits of the suit, the court shall, upon motion of the defendant, order the plaintiff to return the thing given by the defendant by virtue of the declaration of provisional execution and to make compensation for any damage sustained by the defendant either by virtue of such execution or by virtue of measures taken to avoid such execution.
3. In cases where only a declaration of provisional execution has been changed, the provisions of the preceding paragraph shall apply to the subsequent judgment changing the judgment upon the merits of the suit.

**មាត្រា ១៩៨.–** វិសាលភាពបុគ្គលដែលត្រូវទទួលអានុភាពរបស់សាលក្រមស្ថាពរ

សាលក្រមស្ថាពរមានអានុភាពចំពោះបុគ្គលដែលបានកំណត់ដូចខាងក្រោមនេះ :

**ក-** ភាគី ។(1)

**ខ-** តតិយជន ក្នុងករណីដែលភាគីធ្វើជាដើមចោទ ឬ ចុងចម្លើយនៃបណ្តឹង ជំនួសតតិយជននោះ ។(2)

**គ-** បុគ្គលដែលទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ច ពីអ្នកដែលបានកំណត់ក្នុងចំណុចទាំងពីរខាងលើនេះ ក្រោយពីបណ្តឹងត្រូវបានចាត់ការ ។(3)

**ឃ-** បុគ្គលដែលកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការទាមទារ សម្រាប់ផលប្រយោជន៍របស់បុគ្គលដែលបានកំណត់ក្នុងចំណុចទាំងបីខាងលើនេះ ។(4)

(កំណត់)

សូមមើលមាត្រា 115 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(1) ជាគោលការណ៍ អានុភាពនៃសាលក្រមស្ថាពរមានតែទៅលើគូភាគីតែប៉ុណ្ណោះ នេះគេហៅថាជាគោលការណ៍

នៃសាបេក្ខភាព (ភាពមិនដាច់ខាត) របស់អានុភាពសាលក្រម ។ នេះពីព្រោះតែវាគ្រប់គ្រាន់ណាស់ទៅហើយ បើអានុភាពនៃសាលក្រមមានទៅលើគូភាគីដែលជាគូវិវាទនោះ ហើយបើយើងបណ្តោយឱ្យអានុភាពនៃសាលក្រម មានទៅលើតតិយជនដែលមិនបានធ្វើបណ្តឹងផងនោះ វាអាចឱ្យយើងបំពានទៅលើការធានានៃនីតិវិធីរបស់ជននោះ ។

(2) បញ្ញត្តិនេះចែងថា ក្នុងករណីជនដែលមិនមែនជាប្រធាននៃទំនាក់ទំនងសិទ្ធិដែលជាកម្មវត្ថុនៃវិវាទទេ តែត្រូវបាន អនុញ្ញាតឱ្យធ្វើបណ្តឹងអំពីទំនាក់ទំនងសិទ្ធិរបស់អ្នកដទៃក្នុងនាមជាភាគីនៃបណ្តឹង (ការទទួលបន្ទុកនីតិវិធីនៃបណ្តឹង) អានុភាពនៃសាលក្រមដែលអ្នកដែលទទួលបន្ទុកនីតិវិធីនៃបណ្តឹងបានទទួលក្នុងនាមជាភាគី ត្រូវមានទៅលើប្រធាន នៃទំនាក់ទំនងសិទ្ធិ ។ ឧទាហរណ៍ "ភាគីដែលត្រូវបានជ្រើសរើស" ដែលបានកំណត់នៅក្នុងមាត្រា ៤២ (ការជ្រើសរើសភាគី) គឺជាអ្នកទទួលបន្ទុកនីតិវិធីបណ្តឹងមួយប្រភេទ ។ ក្នុងករណីនេះ "ភាគីដែលត្រូវបានជ្រើសរើស ដើម្បីធ្វើជាដើមចោទ ឬ ចុងចម្លើយ" គឺ "ភាគី" ដែលចែងក្នុងចំណុច ១ នៃមាត្រា ១៩៨ នេះ ហើយ "អ្នកដែលបានធ្វើការជ្រើសរើស" គឺជា "តតិយជន" ដែលចែងក្នុងចំណុច ២ នេះ ។

(3) ជាគោលការណ៍ "អ្នកដែលទទួលបន្ត" ដែលនិយាយក្នុងចំណុចនេះ គឺជាបុគ្គលដែលបន្តសិទ្ធិ ឬ កាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្តឹង ។ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជានេះ យកគោលការណ៍កំណត់ភាគីបណ្តឹង ដូចបានកំណត់នៅ ក្នុងមាត្រា ៨៨ (អនុប្បទានទូវវត្ថុដែលជាកម្មវត្ថុនៃវិវាទ ជាអាទិ៍) ។ តាមគោលការណ៍នេះ ទោះបីជាទំនាក់ទំនង សិទ្ធិ ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទ ត្រូវបានធ្វើអនុប្បទានទៅតតិយជន នៅពេលបណ្តឹងកំពុងចាត់ការក៏ដោយ ក៏អនុប្បទាននេះមិនត្រូវមានឥទ្ធិពលដល់លក្ខណៈជាដើមចោទ ឬ ចុងចម្លើយឡើយ ។ ហេតុដូច្នេះ ភាគីនៅតែមាន សិទ្ធិបន្តនីតិវិធី ហើយសាលក្រមដោយផ្អែកលើការបន្តនីតិវិធីនោះ មានអានុភាពទៅលើអ្នកដែលទទួលបន្ត នៅ ក្រោយពេលបណ្តឹងនោះត្រូវបានចាត់ការ ។

(4) ពាក្យថា "បុគ្គលដែលកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការទាមទារ" គឺជាបុគ្គលដែលកាន់កាប់ចលនវត្ថុ ឬ អចលនវត្ថុ ដែលជាកម្មវត្ថុនៃការទាមទារក្នុងបណ្តឹង សម្រាប់តែភាគីណាមួយ ដោយគ្មានផលប្រយោជន៍ផ្ទាល់ខ្លួនក្នុងការ កាន់កាប់នោះទេ ។ ឧទាហរណ៍ អ្នកគ្រប់គ្រង អ្នកចាំផ្ទះ អ្នកជិតខាងដែលទទួលរបស់ផ្ញើមួយរយៈ ជាដើម ។ ដោយជនទាំងឡាយនោះពុំមានផលប្រយោជន៍ផ្ទាល់ចំពោះកម្មវត្ថុនោះទេ ទោះជាសាលក្រមចំពោះគូភាគីមាន អានុភាពទៅលើជននោះក៏ដោយ ក៏គ្មានបញ្ហាដែរ ។

(5) ពាក្យថា "ក្រោយពីបណ្តឹងត្រូវបានចាត់ការ" គឺចាប់ពីពេលដែលភាគីចុងចម្លើយបានទទួលការបញ្ជូនពាក្យបណ្តឹង ។

Code of Civil Procedure (Japan)
**Article 115** (Scope of persons bound by final and binding judgment, etc.)
1. A judgment which has become final and binding shall be effective against the following persons:
   i. the parties;
   ii. in cases where a party become a plaintiff or defendant on behalf of another person, such other person;
   iii. successors who succeeded any persons in the preceding two items following the conclusion of oral argument;
   iv. persons who, on behalf of any persons in the preceding three items, possess the subject matter of the claim.
2. The provisions of the preceding paragraph shall apply *mutatis mutandis* to declaration of provisional execution.

**មាត្រា ១៩៩.~** អានុភាពនៃសាលក្រមស្ថាពររបស់តុលាការបរទេស

សាលក្រមស្ថាពររបស់តុលាការបរទេស ត្រូវមានអានុភាព លុះត្រាតែបានបំពេញល័ក្ខខ័ណ្ឌទាំងអស់ ដូចខាងក្រោមនេះ :

**ក-** បើសិទ្ធិជម្រះក្ដីរបស់តុលាការបរទេសត្រូវបានទទួលស្គាល់ ដោយច្បាប់ ឬ សន្ធិសញ្ញា ឬ អនុសញ្ញា ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ។

**ខ-** បើចុងចម្លើយដែលចាញ់ក្ដី បានទទួលការបញ្ជូនដីកាកោះហៅ ឬ ដីកាបង្គាប់ដែលចាំបាច់ដើម្បីចាប់ផ្ដើមនីតិវិធី ឬ មិនបានទទួលទេ តែបានឆ្លើយដោះសាតបចំពោះបណ្ដឹងនោះ ។

**គ-** បើខ្លឹមសារនៃសាលក្រម និង នីតិវិធីនៃបណ្ដឹងនោះ មិនប៉ះពាល់សណ្ដាប់ធ្នាប់សាធារណៈ ឬ ទំនៀមទម្លាប់ល្អនៃព្រះរាជាណាចក្រកម្ពុជា ។

**ឃ-** បើមានការធានាទៅវិញទៅមករវាងព្រះរាជាណាចក្រកម្ពុជា និង បរទេស ។

(កំណត់)

សូមមើលមាត្រា 118 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(1) ជាធម្មតា រដ្ឋគ្មានករណីយកិច្ចទទួលស្គាល់សាលក្រម ឬ សាលដីការបស់តុលាការបរទេស ។ ប៉ុន្តែ មាត្រានេះទទួលស្គាល់នូវអានុភាពនៃសាលក្រម ឬ សាលដីការបស់តុលាការបរទេសដែលបំពេញល័ក្ខខ័ណ្ឌមួយចំនួន ដោយសាររឿងក្ដីត្រូវបានដោះស្រាយចប់សព្វគ្រប់ម្ដងហើយ ហើយបើឱ្យតុលាការទទួលដោះស្រាយរឿងក្ដីនោះម្ដងទៀត ជាហេតុនាំឱ្យខាតបង់ពេលវេលាផង និង ដើម្បីកុំឱ្យមានភាពផ្ទុយគ្នានៃសេចក្ដីសម្រេចរបស់តុលាការផង ដើម្បីធានានូវស្ថេរភាពនៃកិច្ចការជំនួញអន្តរជាតិផង ។

(2) ចំពោះការអនុវត្តដោយបង្ខំដោយផ្អែកលើសាលក្រម ឬ សាលដីការបស់តុលាការបរទេស ម្ចាស់បំណុលនៃការអនុវត្តត្រូវទទួលសាលក្រមអនុវត្ត (សូមមើលមាត្រា ៣៥២) ។

(3) ចំណុច **ខ** នេះកំណត់ថា ភាគីចាញ់ក្ដីស្ថិតក្រោមអានុភាពនៃសាលក្រមស្ថាពររបស់តុលាការបរទេស តុលាការបរទេសបានគោរពសិទ្ធិការពារផលប្រយោជន៍របស់ខ្លួន តាមគោលការណ៍ចំពោះមុខហើយឬនៅ ? បើមិនដូច្នេះទេ គឺជាការរំលោភសិទ្ធិភាគីចាញ់ក្ដីក្នុងការការពារខ្លួនចំពោះតុលាការ ។

(4) បើសាលក្រម ឬ សាលដីការបស់តុលាការបរទេសប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ ឬ ទំនៀមទម្លាប់ល្អនៃព្រះរាជាណាចក្រកម្ពុជា នោះសាលក្រម ឬ សាលដីការបស់តុលាការបរទេសមិនមានអានុភាពឡើយ ។

(5) ចំណុច **ឃ** ជាគោលការណ៍អន្តរជាតិដែលប្រទេសមួយ និង ប្រទេសមួយទៀត មានការគោរពគ្នាទៅវិញទៅមកក្នុងគោលបំណងការពារផលប្រយោជន៍របស់ប្រទេសទាំងសងខាង ឬ ផលប្រយោជន៍ឯកជនរបស់ពលរដ្ឋនៃប្រទេសទាំងសងខាង ។

Code of Civil Procedure (Japan)
**Article 118** (Effect of foreign court's final and biding judgment)
A final and binding judgment of a foreign court shall be valid only upon the fulfillment of all of the following conditions:
i. the foreign court's jurisdiction is allowed by laws and ordinances or by treaty;
ii. the defeated defendant has received service (except for service by publication of notice or any similar means) of summons or any other necessary orders to commence procedures or has responded in the action without receiving service thereof;
iii. the contents of the judgment and the procedures of the litigation are not contrary to the public order or morals of Japan;
iv. there is reciprocity.

## ផ្នែកទី ៥ សាលក្រមកំបាំងមុខ

**មាត្រា ២០០.-** សាលក្រមកំបាំងមុខដើមចោទ

១- បើដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី ១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការត្រូវច្រានចោលការទាមទាររបស់ដើមចោទនោះ ដោយសាលក្រមកំបាំងមុខ ។(1)

២- បើដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទដើម្បីបន្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការអាចបញ្ឈប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយភ្លាមៗ ហើយកំណត់នូវកាលបរិច្ឆេទលើកទី ១ នៃការទាញហេតុផលដោយផ្ទាល់មាត់បាន ។(2)

៣- បើដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ទេ តុលាការត្រូវច្រានចោលការទាមទាររបស់ដើមចោទនោះ ដោយសាលក្រមកំបាំងមុខ ។(3)

(កំណត់)

សូមមើលមាត្រា 246 និង មាត្រា 247 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ជាងគេ (1890) មាត្រា 330 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាឡឺម៉ង់ និង មាត្រា 396 នៃក្រមនីតិវិធីរដ្ឋប្បវេណីអូទ្រីស ។

(1) ប្រសិនបើដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី ១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការនឹងច្រានចោលការទាមទាររបស់ដើមចោទនោះដោយសាលក្រមកំបាំងមុខ ដោយសន្មតថា ដើមចោទគ្មានឆន្ទៈក្នុងការធ្វើទៅតាមនីតិវិធីនៃបណ្តឹង ។ នេះជាករណីលើកលែងចំពោះគោលការណ៍នៃការទាញហេតុផលដោយផ្ទាល់មាត់ចាំបាច់ ។

(2) ប្រសិនបើដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទដើម្បីបន្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការមិនអាចសន្មតដោយភ្លាមៗថា ដើមចោទគ្មានឆន្ទៈក្នុងការធ្វើទៅតាមនីតិវិធីនៃបណ្តឹងបានទេ ផ្ទុយទៅវិញ ក៏អាចគិតថា ដើមចោទមានបំណងឱ្យតុលាការវិនិច្ឆ័យនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ដោយសារដើមចោទបានឃើញថា បានរៀបចំចំណុចវិវាទល្មមហើយ ហេតុដូច្នេះ តុលាការមិនអាចចេញសាលក្រមកំបាំងមុខដោយភ្លាមៗ បានទេ ។

(3) បញ្ញត្តិនេះនឹងអនុវត្ត មិនមែនតែចំពោះករណីដែលដើមចោទមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទលើកទី ១ នៃការទាញហេតុផលដោយផ្ទាល់មាត់ប៉ុណ្ណោះទេ តែព្រមទាំងករណីដែលដើមចោទមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទលើកក្រោយទៀតដែរ ។ ប៉ុន្តែ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការធ្វើការពិនិត្យភស្តុតាងដោយសម្ភារិធី ហេតុដូច្នេះមិនសូវមានកាលបរិច្ឆេទលើកក្រោយទៀតទេ ។

(4) ពាក្យថា "ភាគីមិនបានបង្ហាញខ្លួន" ដែលចែងក្នុងមាត្រានេះ និង មាត្រា ២០១ (សាលក្រមកំបាំងមុខចុងចម្លើយ) ទៅ ត្រូវរាប់បញ្ចូលករណីដែលមិនអាចសន្និដ្ឋានថា បានបង្ហាញខ្លួនដោយពិត ដូចជាករណីដែលភាគីបានបង្ហាញខ្លួនមែន តែបានចេញពីសាលសវនាការ ដោយមិនបានធ្វើការទាញហេតុផល ឬ ធ្វើសេចក្តីថ្លែងការណ៍ ។

The Code of Civil Procedure Rules (Germany)
**Article 330** (Default judgment against the plaintiff)
If the plaintiff fails to appear at the session fixed for hearing, there shall be entered upon petition a default judgment to the effect that the plaintiff's claim is dismissed.

**មាត្រា ២០១.‐** សាលក្រមកំបាំងមុខចុងចម្លើយ

១‐ បើចុងចម្លើយមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី ១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការត្រូវបញ្ឈប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយភ្លាមៗ ហើយកំណត់នូវកាលបរិច្ឆេទលើកទី ១ នៃការទាញហេតុផលដោយផ្ទាល់មាត់ ។(1)

២‐ បើចុងចម្លើយមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវចាត់ទុកថាចុងចម្លើយបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទដែលទាក់ទងនឹងអង្គហេតុ ហើយបើយល់ឃើញថា ការទាមទាររបស់ដើមចោទត្រឹមត្រូវ តុលាការត្រូវទទួលស្គាល់ការទាមទាររបស់ដើមចោទ ដោយសាលក្រមកំបាំងមុខ តែបើយល់ឃើញថា ការទាមទាររបស់ដើមចោទមិនត្រឹមត្រូវទេ តុលាការត្រូវច្រានចោលការទាមទារនោះ ។(2) ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលចុងចម្លើយធ្វើវិវាទលើការអះអាងរបស់ដើមចោទ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ពីមុនមក ។(3)

(កំណត់)

សូមមើលមាត្រា 246 និង មាត្រា 248 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ជាងគេ (1890) មាត្រា 331 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាឡឺម៉ង់ និង មាត្រា 396 នៃក្រមនីតិវិធីរដ្ឋប្បវេណីអូទ្រីស ។

(1) ក្នុងករណីដែលចុងចម្លើយមិនបានចូលរួមក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយសារអាចមានករណីដែលការទាមទាររបស់ដើមចោទមិនសមហេតុផលសោះក្នុងការអះអាងឯកឯង តុលាការមិនអាចចេញសាលក្រម

កំបាំងមុខដោយភ្លាមៗបានទេ ។ ម្យ៉ាងទៀត តុលាការក៏មិនអាចចេញសាលក្រមដែលទទួលស្គាល់ការទាមទារ ដោយមិនធ្វើទៅតាមការទាញហេតុផលដោយផ្ទាល់មាត់បានដែរ ហេតុដូច្នេះហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់វិញ ។

(2) ក្នុងករណីដែលចុងចម្លើយមិនបានចូលរួមក្នុងការទាញហេតុផលដោយផ្ទាល់មាត់ទេ តុលាការនឹងចាត់ទុកថា អង្គហេតុទាំងឡាយដែលដើមចោទអះអាង ត្រូវបានសារភាពដោយចុងចម្លើយ ហើយប្រសិនបើយល់ឃើញថា ការទាមទាររបស់ដើមចោទត្រឹមត្រូវ តុលាការនឹងទទួលស្គាល់ការទាមទាររបស់ដើមចោទ ដោយចេញសាលក្រមកំបាំងមុខ ។ ប៉ុន្តែ ទោះបីជាបានសន្មតថា អង្គហេតុទាំងឡាយដែលដើមចោទអះអាង ត្រូវបានសារភាពដោយចុងចម្លើយក៏ដោយ ប្រសិនបើគ្មានមូលហេតុត្រឹមត្រូវក្នុងការទាមទារទេ តុលាការត្រូវច្រានចោលការទាមទាររបស់ដើមចោទ ។ ក្នុងករណីនេះ សាលក្រមដែលច្រានចោលការទាមទារនោះ មិនមែនជាសាលក្រមកំបាំងមុខទេ តែគឺជាសាលក្រមធម្មតា ។

(3) ក្នុងករណីដែលមិនដឹងថា ចុងចម្លើយបដិសេធការអះអាងរបស់ដើមចោទ ឬ ទទួលសារភាព ដោយសារចុងចម្លើយមិនបានចូលរួមក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីកុំឱ្យមានការស្ទះក្នុងការវិនិច្ឆ័យ បញ្ញត្តិនេះអនុញ្ញាតឱ្យតុលាការអាចចេញសាលក្រមទទួលស្គាល់ ឬ ច្រានចោលការទាមទារ ដោយចាត់ទុកថា ចុងចម្លើយបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទដែលទាក់ទងនឹងអង្គហេតុ ។ ហេតុដូច្នេះ ឧ. ប្រសិនបើចុងចម្លើយបានបដិសេធការអះអាងរបស់ដើមចោទ នៅកាលបរិច្ឆេទនៃនីតិវិធីសម្រាប់ការទាញហេតុផល ឬ ការទាញហេតុផលដោយផ្ទាល់មាត់ពីមុន ទោះបីជាចុងចម្លើយនោះ មិនបានចូលរួមក្នុងការទាញហេតុផលដោយផ្ទាល់មាត់ នៅពេលក្រោយក៏ដោយ ក៏ការបដិសេធពីមុននោះនៅតែមានអានុភាព ហើយមិនត្រូវចាត់ទុកថាជាការសារភាពឡើយ ។ ម្យ៉ាងទៀត ក្នុងករណីដែលចុងចម្លើយបានបដិសេធការទាមទាររបស់ដើមចោទ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះ ត្រូវបានថ្លែងការណ៍ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ១១៦ (សេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ការទាញហេតុផល) អានុភាពនៃការបដិសេធ នៅតែមានអត្ថិភាពដែរ ។ ក្នុងករណីទាំងនេះ តុលាការអាចចេញសាលក្រម ដោយផ្អែកលើការអះអាងពីមុនមករបស់ចុងចម្លើយ ។ សាលក្រមនេះ មិនមែនជាសាលក្រមកំបាំងមុខទេ គឺ សាលក្រមធម្មតា ។

<u>The Code of Civil Procedure Rules (Germany)</u>
**Article 331** (Default judgment against the defendant)
(1) If the plaintiff petitions for a default judgment against the defendant who failed to appear at the session fixed for the oral hearing, the orally made allegations of facts by the plaintiff shall be accepted as admitted. This does not apply to allegations concerning the jurisdictions of the court under §§ 29(2) and 38.
(2) Decision shall be given for the claim to the extent that the statement of claim justifies it; to the extent that this is not the case, the claim shall be dismissed.
(3) If the defendant fails to make a timely notification in violation of § 276(1) first sentence and (2) that he intends to defend against the claim, the court shall decide upon petition of the plaintiff without an oral hearing; this does not apply if the declaration of the defendant is received before the judgment signed by the judges is delivered to the registry. The petition may already be entered in the

statement of claim.

**មាត្រា ២០២.-** ករណីដែលមិនអាចចេញសាលក្រមកំបាំងមុខ

បើមានករណីណាមួយដូចខាងក្រោមនេះ តុលាការមិនអាចចេញសាលក្រមកំបាំងមុខបានឡើយ :

**ក-** ភាគីដែលមិនបានបង្ហាញខ្លួន មិនបានទទួលការកោះហៅស្របច្បាប់ ។(2)

**ខ-** ភាគីដែលមិនបានបង្ហាញខ្លួន មានមូលហេតុដែលអាចទទួលស្គាល់ថា ពិតជាមិនអាចបង្ហាញខ្លួនបានមែន ដោយសារគ្រោះមហន្តរាយធម្មជាតិ ឬ កាលៈទេសៈផ្សេងទៀតដែលមិនអាចជៀសវាងបាន ។(3)

**គ-** បណ្តឹងមិនស្របច្បាប់ ។(4)

**ឃ-** ខ្លឹមសារនៃសេចក្តីថ្លែងការណ៍ ដែលដើមចោទបានធ្វើនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដែលចុងចម្លើយមិនបានបង្ហាញខ្លួន ហើយខ្លឹមសារនៃសេចក្តីថ្លែងការណ៍នោះមិនបានជូនដំណឹងទៅចុងចម្លើយមុនកាលបរិច្ឆេទនោះ ។(5)

(កំណត់)

សូមមើលមាត្រា 252 និង មាត្រា 254 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ជាងគេ (1890) មាត្រា 335 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាឡឺម៉ង់ ។

(1) មាត្រានេះ ផ្អែកលើមាត្រា ៣ (សិទ្ធិទាមទារឱ្យសាកសួរ គោលការណ៍ចំពោះមុខ) ។ សូមមើលកំណត់នៃមាត្រា ៣ ។

(2) នៅក្នុងដីកាកោះហៅ ត្រូវសរសេរថា អាចទទួលការខូចប្រយោជន៍ដោយសាលក្រមកំបាំងមុខ ប្រសិនបើមិនបង្ហាញខ្លួន ។ ចំណុច **ក** នេះ តាមមាត្រា 254 កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ជាងគេ (1890) ចែងថា គឺជាហេតុនៃការពន្យារកាលបរិច្ឆេទ ប៉ុន្តែ មាត្រា 335 កថាខណ្ឌទី ១ ចំណុចទី 2 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាឡឺម៉ង់ ចែងថា ជាហេតុនៃការលើកចោលពាក្យសុំចេញសាលក្រមកំបាំងមុខ ។ មាត្រា ២០២ នេះ ចែងតាមច្បាប់អាឡឺម៉ង់ ។

(3) មូលហេតុដែលបានកំណត់នៅក្នុងចំណុច **ខ** សំដៅទៅលើករណីដែលភាគីអវត្តមាន ដោយហេតុដែលមិនអាចជៀសវាងបានក្រៅឆន្ទៈរបស់ខ្លួន ។

(4) សូមមើលមាត្រា 252 កថាខណ្ឌទី 1 ចំណុចទី 1 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ជាងគេ (1890) និង មាត្រា 335 កថាខណ្ឌទី 1 ចំណុចទី 1 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាឡឺម៉ង់ ជាដើម ។ បណ្តឹងមិនស្របច្បាប់ រាប់បញ្ចូលទាំងករណីដែលខ្វះសមត្ថកិច្ចផ្តាច់មុខ សមត្ថភាពភាគី សមត្ថភាពក្នុងការធ្វើបណ្តឹង សិទ្ធិតំណាង ជាដើម ។ ក្នុងករណីទាំងនេះ តុលាការមិនអាចចេញសាលក្រមកំបាំងមុខទេ តែត្រូវសម្រេចសេចក្តី តាមករណីនីមួយៗ ដូចជាដីកាសម្រេចផ្ទេរបណ្តឹង (មាត្រា ១៨) សាលក្រមលើកបណ្តឹងចោលក្នុងករណីខ្វះសមត្ថភាពភាគី (មាត្រា ៨១) ជាដើម ។

(5) សូមមើលចំណុចទី 2 កថាខណ្ឌទី 1 មាត្រា 252 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ជាងគេ (1890) និង ចំណុចទី 3 កថាខណ្ឌទី 1 មាត្រា 335 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាឡឺម៉ង់ ។ ចំណុច **ឃ** នេះកំណត់ថា ទោះបីជាចុងចម្លើយមិនបានបង្ហាញខ្លួនក៏ដោយ ប្រសិនបើខ្លឹមសារនៃសេចក្ដីថ្លែងការណ៍របស់ដើមចោទ មិនត្រូវបានជូនដំណឹងទៅចុងចម្លើយ នៅមុនកាលបរិច្ឆេទទេ នោះតុលាការមិនត្រូវបានអនុញ្ញាតឱ្យចេញសាលក្រមកំបាំងមុខដែលទទួលស្គាល់ការទាមទាររបស់ដើមចោទ ដោយចាត់ទុកថា ចុងចម្លើយបានសារភាពតាមសេចក្ដីថ្លែងការណ៍របស់ដើមចោទដែលទាក់ទងនឹងអង្គហេតុ ។ មានន័យថា មិនត្រូវឱ្យចុងចម្លើយដែលមិនបានបង្ហាញខ្លួន ទទួលសាលក្រមកំបាំងមុខដោយផ្អែកលើអង្គហេតុដែលត្រូវបានអះអាងដោយដើមចោទ តែចុងចម្លើយមិនបានដឹងជាមុន ។ ឧទាហរណ៍ ចំពោះបណ្ដឹងដែលចំណុចនីមួយៗដែលត្រូវបានសរសេរក្នុងពាក្យបណ្ដឹង គ្មានភាពស៊ីសង្វាក់គ្នា ទោះបីជាដើមចោទអះអាងអង្គហេតុដែលមិនត្រូវបានសរសេរនៅក្នុងឯកសារត្រៀម នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលដើមចោទបានចូលរួម តែចុងចម្លើយមិនបានបង្ហាញខ្លួន ហើយបណ្ដឹងនេះមានភាពស៊ីសង្វាក់គ្នាវិញ ដោយសារការអះអាងអង្គហេតុថ្មីនោះក៏ដោយ ក៏តុលាការមិនអាចចេញសាលក្រមកំបាំងមុខដែលទទួលស្គាល់ការទាមទាររបស់ដើមចោទឡើយ ដោយសារអង្គហេតុនេះ មិនត្រូវបានជូនដំណឹងជាមុនទៅចុងចម្លើយ ។ ក្នុងករណីនេះ ដោយសារបណ្ដឹងរបស់ដើមចោទ មានភាពស៊ីសង្វាក់គ្នាវិញ ដោយការអះអាងអង្គហេតុថ្មី តុលាការមិនអាចចេញសាលក្រមដែលច្រានចោលការទាមទារបានឡើយ ហេតុដូច្នេះ តុលាការត្រូវបន្តនីតិវិធីនៃការវិនិច្ឆ័យ ។

The Code of Civil Procedure Rules (Germany)
**Article 335** (When default judgment is excluded)
(1) The petition for the issuance of a default judgment or a decision on the record shall be denied:
1. if the party who appeared was unable to produce the information required on a circumstance which must be taken into account by the court on its own motion;
2. if the absent party has not been summoned in the proper manner, especially not in due time;
3. if the absent party was not notified in due course of an orally made allegation of fact or a petition by means of written pleadings;
4. if, in the case under § 331(3), the defendant has not been notified of the time limit under § 276(1) first sentence or has not been warned pursuant to § 276(2).
(2) If the hearing is adjourned, the absent party shall be summoned to appear at the new session.

## **មាត្រា ២០៣.-** ការពន្យារកាលបរិច្ឆេទ

១- បើយល់ឃើញថា អំឡុងពេលនៃការកោះហៅមានរយៈពេលខ្លីពេក ឬ យល់ឃើញថា ភាគីមិនអាចមកបង្ហាញខ្លួនបានដោយគ្មានកំហុសទេ តុលាការអាចពន្យារកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់បាន ។

២- បើតុលាការបានពន្យារកាលបរិច្ឆេទតាមកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវធ្វើការកោះហៅភាគីដែលមិនបានបង្ហាញខ្លួននោះ តាមកាលបរិច្ឆេទថ្មី ។

(កំណត់)

សូមមើលមាត្រា 252 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ជាងគេ (1890) មាត្រា 337 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាឡឺម៉ង់ ។ គោលបំណងនៃមាត្រានេះ ទុកឱកាសសមរម្យឱ្យភាគីមានលទ្ធភាពចូលមកបង្ហាញខ្លួនតាមកាលបរិច្ឆេទ ។

The Code of Civil Procedure Rules (Germany)
**Article 337** (Adjournment ex officio)
The court shall adjourn the hearing on the petition for the issuance of a default judgment or for a decision on the record if it is of the opinion that the period fixed by the presiding judge for joining the issue or summoning the parties as estimated was too short or that the party is presented from appearing without his fault. The party which failed to appear shall be summoned to appear at a new session.

**មាត្រា ២០៤.-** បណ្តឹងទាស់

១- បើភាគីមិនបានបង្ហាញខ្លួនតាមកាលបរិច្ឆេទទាន់ពេលវេលា ដោយសារមានហេតុដែលមិនអាចព្យាករបាន ឬ ហេតុដែលមិនអាចជៀសវាងបាន ហើយបានទទួលសាលក្រមកំបាំងមុខ ភាគីនោះអាចប្តឹងទាស់ចំពោះសាលក្រមនោះបាន ។ (1) (2)

២- បណ្តឹងទាស់ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើងក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនសាលក្រមកំបាំងមុខនោះ ។ (3) អំឡុងពេលនេះពុំអាចពន្យារបានឡើយ ។

៣- បើសាលក្រមកំបាំងមុខ ត្រូវបានបញ្ជូនតាមរយៈការបិទប្រកាសជាសាធារណៈ ឬ តាមរយៈការបញ្ជូននៅបរទេស តុលាការត្រូវកំណត់អំឡុងពេលដែលអាចប្តឹងទាស់ នៅក្នុងសាលក្រមកំបាំងមុខនោះ ។ (4)

(កំណត់)

សូមមើលមាត្រា 255 និង មាត្រា 256 កថាខណ្ឌទី 1 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ជាងគេ (1890) មាត្រា 338 និង មាត្រា 339 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាឡឺម៉ង់ និង មាត្រា 146 កថាខណ្ឌទី 1 នៃក្រមនីតិវិធីរដ្ឋប្បវេណីអូទ្រីស ។

(1) ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ជាងគេ (1890) និង ក្រមនីតិវិធីរដ្ឋប្បវេណីអាឡឺម៉ង់ អនុញ្ញាតឱ្យមានបណ្តឹងទាស់ (petition to set aside, opposition contre le jugement par défault) ដោយសេរី និង ដោយមិនគិតអំពីមូលហេតុទេ ប៉ុន្តែប្រសិនបើចែងដូច្នោះ ភាគីអាចពន្យារពេលនីតិវិធីដោយគ្មានកម្រិត ដោយមិនបង្ហាញខ្លួនដដែលៗតាមកាលបរិច្ឆេទ និង ប្តឹងទាស់ទៀត ។ ហេតុដូច្នេះ តាមមាត្រា 146 កថាខណ្ឌទី 1 នៃក្រមនីតិវិធីរដ្ឋប្បវេណីអូទ្រីស ក្រមនេះកម្រិតករណីដែលអាចប្តឹងទាស់ គឺករណីដែលភាគីមិនបានបង្ហាញខ្លួនតាមកាលបរិច្ឆេទទាន់ពេលវេលា ដោយសារមានហេតុដែលមិនអាចព្យាករបាន ឬ ហេតុដែលមិនអាចជៀសវាងបាន ។

(2) ទោះបីជាករណីដែលបណ្តឹងទាស់មិនត្រូវបានទទួលស្គាល់ក៏ដោយ ក៏ច្បាប់អនុញ្ញាតឱ្យប្តឹងឧបាស្រ័យទៅតុលាការជាន់

ខ្ពស់ចំពោះសាលក្រមកំបាំងមុខបានដែរ ។ ក្នុងករណីដែលបណ្តឹងទាស់ត្រូវបានធ្វើឡើង អំឡុងពេលនៃការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ត្រូវគិតចាប់ពីថ្ងៃដែលការសម្រេចសេចក្តីអំពីបណ្តឹងទាស់ចូលជាស្ថាពរ ។ ចំណុចទាំងនេះ នឹងចែងក្នុងជំពូកស្តីពីបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ។

(3) សូមមើលមាត្រា 255 កថាខណ្ឌទី 2 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ជាងគេ (1890) ។

(4) សូមមើលមាត្រា 255 កថាខណ្ឌទី 4 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ជាងគេ (1890) និង មាត្រា 339 កថាខណ្ឌទី 2 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាឡឺម៉ង់ ។

The Code of Civil Procedure Rules (Germany)
**Article 338** (Petition to set aside)
The party against whom a default judgment was issued is entitled to petition for setting it aside.
**Article 339** (Period allowed for petition to set aside)
(1) The period allowed for the petition to set aside is two weeks; it is a statutory period and it begins to run upon the service of the default judgment.
(2) If the service is to be effected in a foreign state or by public notice, the court shall fix the time allowed for the appeal in the default judgment or subsequently by a special order, which can be issued without an oral hearing.

## **មាត្រា ២០៥.-** របៀបប្តឹងទាស់

១- ការប្តឹងទាស់ត្រូវធ្វើឡើងដោយដាក់ពាក្យបណ្តឹងទាស់ទៅតុលាការដែលបានចេញសាលក្រមកំបាំងមុខ ។

២- នៅក្នុងពាក្យបណ្តឹងទាស់ ត្រូវសរសេរចំណុចដូចខាងក្រោម :

**ក-** ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់គូភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

**ខ-** សញ្ញាណសាលក្រមកំបាំងមុខដែលជាកម្មវត្ថុនៃការប្តឹងទាស់ ។

**គ-** បំណងនៃការប្តឹងទាស់ចំពោះសាលក្រមដែលបានកំណត់ក្នុងចំណុច **ខ** ខាងលើនេះ ។

**ឃ-** មូលហេតុដែលមិនអាចមកបង្ហាញខ្លួនតាមកាលបរិច្ឆេទទាន់ពេលវេលា ។

(កំណត់)

សូមមើលមាត្រា 256 កថាខណ្ឌទី 1 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ជាងគេ (1890) និង មាត្រា 340 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាឡឺម៉ង់ ។

(1) បណ្តឹងទាស់មានលក្ខណៈដូចគ្នាជាមួយនឹងបណ្តឹងឧទ្ធរណ៍ និង បណ្តឹងសាទុក្ខដែរ ដោយសារបណ្តឹងទាំងនោះ គឺជាឧបាស្រ័យចំពោះសាលក្រម (ឬ សាលដីកា) ។ ហេតុដូច្នេះ ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹងទាស់ គឺជាចំណុចដែលចាំបាច់សរសេរ ដូចចំណុចចាំបាច់ដែលត្រូវសរសេរក្នុងពាក្យបណ្តឹងឧទ្ធរណ៍ និង ពាក្យបណ្តឹងសាទុក្ខ ហើយប្រសិនបើមានការខ្វះខាតក្នុងការសរសេរចំណុចណាមួយ បណ្តឹងទាស់នោះ ត្រូវទុកជាមោឃៈ (សូមមើលមាត្រា ២០៦ (ការពិនិត្យ និង ការបញ្ជូនពាក្យបណ្តឹងទាស់) ខាងក្រោយ) ។

(2) មាត្រា ២០៤ (បណ្ដឹងទាស់) ខាងលើ បានចែងថា ដើម្បីប្ដឹងទាស់ ភាគីត្រូវមាន "ហេតុដែលមិនអាចព្យាករបាន ឬ ហេតុដែលមិនអាចជៀសវាងបាន" ដែលនាំឱ្យភាគី "មិនបានបង្ហាញខ្លួនតាមកាលបរិច្ឆេទទាន់ពេលវេលា" ហេតុដូច្នេះ ចំណុចទី ៣ នេះ ក៏តម្រូវឱ្យមានការសរសេរមូលហេតុនោះក្នុងពាក្យបណ្ដឹងទាស់ដែរ ។ ទម្រង់នៃពាក្យបណ្ដឹងទាស់ ត្រូវមានភាពជាក់លាក់ជាងការប្ដឹងទាស់តាមនីតិវិធីដែលធ្លាប់អនុវត្តកន្លងមក ហើយមូលហេតុនៃបណ្ដឹងទាស់ ក៏មាន ភាពតឹងតែងជាងការប្ដឹងទាស់តាមនីតិវិធីដែលធ្លាប់អនុវត្តកន្លងមកផងដែរ ។

The Code of Civil Procedure Rules (Germany)
**Article 340** (The petition to set aside)
(1) The petition is entered by the filing of a written petition with the trail court.
(2) The written petition shall contain:
1.the indication of the judgment against which the petition to set aside is directed;
2.the declaration that a petition to set aside is entered against this judgment.
If only a part of the judgment is contested, the extent of the contestation shall be indicated.
(3) The party shall present in the petition to set aside all his means of attack and defense insofar as it is in conformity with a careful conduct of the case calculated to expedite proceedings in accordance with the state of the litigation, as well as notices of defects concerning the admissibility of the claim. The presiding judge may, upon petition, extend the period for giving reasons, of at his discretion he decides that the litigation will not be delayed by the extension or if the party shows material reasons. §296(1), (3) and (4) shall apply *mutatis mutandis*. When service is made of the default judgment, warning shall be given of the consequences of a default.

**មាត្រា ២០៦.-** ការពិនិត្យ និង ការបញ្ជូនពាក្យបណ្ដឹងទាស់

១- ក្នុងករណីដែលពាក្យបណ្ដឹងទាស់មិនស្របនឹងបញ្ញត្តិនៃមាត្រា ២០៥ (របៀបប្ដឹងទាស់) នៃក្រមនេះ តុលាការ ត្រូវកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតនៃពាក្យបណ្ដឹងនោះ ក្នុងអំឡុងពេលនោះ ។

២- ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើភាគីដែលប្ដឹងទាស់មិនបានកែតម្រូវចំណុចខ្វះខាត ទេ តុលាការត្រូវលើកពាក្យបណ្ដឹងទាស់នោះចោល ដោយដីកាសម្រេច ។

៣- ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

៤- ក្នុងករណីដែលពាក្យបណ្ដឹងទាស់គ្មានចំណុចខ្វះខាតទេ តុលាការត្រូវបញ្ជូនពាក្យបណ្ដឹងទាស់នោះទៅភាគីម្ខាងទៀត ហើយកំណត់កាលបរិច្ឆេទថ្មីដើម្បីវិនិច្ឆ័យបណ្ដឹងទាស់នោះ និង កោះហៅគូភាគី ។

(កំណត់)

សូមមើលមាត្រា 257 និង មាត្រា 258 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ជាងគេ (1890) ។ កថាខណ្ឌទី ១ ទី ២ និង ទី ៣ មានអត្ថន័យប្រហាក់ប្រហែលគ្នានឹងមាត្រា ៧៨ (ការពិនិត្យពាក្យបណ្ដឹង) ។ ការពិនិត្យពាក្យបណ្ដឹងទាស់ គឺ ការពិនិត្យទៅលើតែទម្រង់ប៉ុណ្ណោះ ។

**មាត្រា ២០៧.-** ការវិនិច្ឆ័យ និង ការសម្រេចសេចក្ដីលើបណ្ដឹងទាស់

១- តុលាការត្រូវធ្វើការស្រាវជ្រាវ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន អំពីភាពត្រឹមត្រូវនៃពាក្យបណ្តឹងទាស់តាមទម្រង់ និង អំឡុងពេលដែលកំណត់ដោយច្បាប់ និង អំពីភាពត្រឹមត្រូវនៃមូលហេតុបណ្តឹងទាស់ ។

២- តុលាការត្រូវលើកចោលនូវបណ្តឹងទាស់ ដោយដីកាសម្រេច ប្រសិនបើយល់ឃើញថា ពាក្យបណ្តឹងទាស់នោះមិនត្រឹមត្រូវតាមច្បាប់ តែបើយល់ឃើញថា ពាក្យបណ្តឹងទាស់នោះ គ្មានមូលហេតុត្រឹមត្រូវទេ តុលាការត្រូវច្រានចោលបណ្តឹងនោះដោយដីកាសម្រេច ។

(កំណត់)

សូមមើលមាត្រា 259 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ជាងគេ (1890) និង មាត្រា 341 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាឡឺម៉ង់ ។ ភាពត្រឹមត្រូវតាមច្បាប់ សំដៅទៅលើទម្រង់ រីឯមូលហេតុត្រឹមត្រូវ សំដៅលើមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ២០៤ (បណ្តឹងទាស់) ។

The Code of Civil Procedure Rules (Germany)

**Article 341** (Examination of petition to set aside)

(1) The court shall examine on its own motion whether the petition properly considered is admissible and whether it was entered in the proper legal form and within the time limit. If it lacks any of these requirements, the petition to set aside shall be dismissed as inadmissible.

(2) The decision may be given also without an oral hearing by a ruling. It is in this case subject to immediate appeal, insofar as an appeal would be against a judgment dealing with the same matter.

**មាត្រា ២០៨.-** អានុភាពនៃបណ្តឹងទាស់ដែលត្រូវបានទទួលស្គាល់

១- ក្នុងករណីដែលពាក្យបណ្តឹងទាស់ត្រូវបានទទួលស្គាល់ នីតិវិធីនៃបណ្តឹងនោះត្រូវត្រឡប់ទៅសភាពដើមវិញ ពីត្រឹមពេលអវត្តមាននោះកើតឡើង ។

២- ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវកំណត់កាលបរិច្ឆេទថ្មីដើម្បីចាប់ផ្តើមអនុវត្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ដើម្បីចាប់ផ្តើមធ្វើការទាញហេតុផលដោយផ្ទាល់មាត់ឡើងវិញ ហើយត្រូវជូនដំណឹងនេះទៅឱ្យគូភាគី ។

(កំណត់)

សូមមើលមាត្រា 260 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ជាងគេ (1890) និង មាត្រា 341a និង មាត្រា 342 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាឡឺម៉ង់ ។

នៅពេលដែលមូលហេតុដែលនាំឱ្យមានអវត្តមានត្រូវបានទទួលស្គាល់ថា ត្រឹមត្រូវតាមច្បាប់ ដោយការវិនិច្ឆ័យរបស់តុលាការ នោះនីតិវិធីត្រូវចាប់ផ្តើមបន្តពីពេលដែលភាគីអវត្តមាន ដើម្បីរក្សានូវគោលការណ៍ចំពោះមុខឱ្យបានត្រឹមត្រូវឡើងវិញ ។

The Code of Civil Procedure Rules (Germany)
**Article 341a** (Session fixed for hearing the petition)
If a petition to set aside was not dismissed by a ruling due to its inadmissibility, a time shall be fixed for an oral hearing on the petition to set aside and on the main matter of the litigation, and the parties shall be notified thereof.
**Article 342** (Effect of an admitted petition to set aside)
If the petition to set aside is admissible, the proceeding shall, to the extent of the scope of the petition, be reinstated in the same standing it was before the default occurred.

## មាត្រា ២០៩.- សាលក្រមថ្មី

១- បើសាលក្រមដែលត្រូវចេញដោយផ្អែកលើការជំនុំជម្រះជាថ្មី បន្ទាប់ពីចាប់ផ្តើមអនុវត្តនីតិវិធីឡើងវិញ មានលទ្ធផលដូចសាលក្រមកំបាំងមុខ នោះតុលាការត្រូវចេញសាលក្រមថ្មីដែលប្រកាសថា តម្កល់សាលក្រមកំបាំងមុខនោះទុកជាបានការ ។

២- បើសាលក្រមដែលត្រូវចេញដោយផ្អែកលើការជំនុំជម្រះជាថ្មី បន្ទាប់ពីចាប់ផ្តើមអនុវត្តនីតិវិធីឡើងវិញ គ្មានលទ្ធផលដូចសាលក្រមកំបាំងមុខទេ នោះតុលាការត្រូវលុបចោលសាលក្រមកំបាំងមុខនោះនៅក្នុងសាលក្រមថ្មី ។(1)

(កំណត់)

សូមមើលមាត្រា 261 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ជាងគេ (1890) និង មាត្រា 343 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាឡឺម៉ង់ ។

(1) ក្នុងករណីដែលតុលាការលុបចោលសាលក្រមកំបាំងមុខ អាចមានករណីពីរ គឺករណីដែលលុបចោលទាំងអស់ និងករណីដែលលុបចោលតែមួយភាគ ។

The Code of Civil Procedure Rules (Germany)
**Article 343** (New decision)
Insofar as the decision which was made on the basis of the new hearings is in conformity with the decision arrived at in the default judgment, it shall be adjudged that this decision will stand. Insofar as this condition does not obtain, the default judgment shall be set aside in the new judgment.

## មាត្រា ២១០.- សោហ៊ុយដែលកើតឡើងដោយសារអវត្តមាន

បើសាលក្រមកំបាំងមុខត្រូវបានធ្វើឡើងស្របតាមទម្រង់ដែលច្បាប់បានកំណត់ ទោះបីជាត្រូវលុបចោលសាលក្រមនោះ ដោយផ្អែកលើពាក្យបណ្តឹងទាស់ក៏ដោយ ក៏សោហ៊ុយដែលកើតឡើងដោយសារអវត្តមាន ត្រូវជាបន្ទុករបស់ភាគីដែលមិនបានបង្ហាញខ្លួនដែរ លើកលែងតែករណីដែលសោហ៊ុយនោះបានកើតឡើង ដោយសារសកម្មភាពបណ្តឹងមិនត្រឹមត្រូវរបស់ភាគីម្ខាងទៀត ។

(កំណត់)

សូមមើលមាត្រា 262 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ជាងគេ (1890) និង មាត្រា 344 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាឡឺម៉ង់ ។

(1) សោហ៊ុយដែលកើតឡើងដោយសារអវត្តមាន ដូចជា សោហ៊ុយសម្រាប់ការបញ្ជូនពាក្យបណ្ដឹងទាស់ សោហ៊ុយស្រាវជ្រាវមូលហេតុនៃបណ្ដឹងទាស់ ជាដើម ត្រូវជាបន្ទុករបស់ភាគីអវត្តមាន ដោយហេតុថា ភាគីម្ខាងទៀតមិនមានកំហុសនាំឱ្យមានចំណាយបន្ថែមនោះឡើយ ។

The Code of Civil Procedure Rules (Germany)
**Article 344** (Cost of default)
If the default judgment was issued in a lawful manner, the costs caused by the default, to the extent that they did not result from an unsubstantiated opposition of the opponent, shall be imposed on the defaulting party also when, as the consequence of the petition to set aside, an amended decision is issued.

**មាត្រា ២១១.-** សាលក្រមកំបាំងមុខលើកទី ២ (1)

១- បើភាគីដែលបានប្ដឹងទាស់ មិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទដំបូងក្រោយពេលចាប់ផ្ដើមអនុវត្តនីតិវិធីឡើងវិញទេ តុលាការត្រូវច្រានចោលបណ្ដឹងទាស់ ដោយសាលក្រមកំបាំងមុខម្ដងទៀត លើកលែងតែក្នុងករណីដែលបានកំណត់ក្នុងមាត្រា ២០២ (ករណីដែលមិនអាចចេញសាលក្រមកំបាំងមុខ) និង កថាខណ្ឌទី ២ នៃមាត្រា ២០៣ (ការពន្យារកាលបរិច្ឆេទ) នៃក្រមនេះ ។

២- ចំពោះសាលក្រមកំបាំងមុខលើកទី ២ ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចប្ដឹងទាស់បានទៀតទេ ។

(កំណត់)

សូមមើលមាត្រា 263 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ជាងគេ (1890) និង មាត្រា 345 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាឡឺម៉ង់ ។

(1) ក្នុងករណីភាគីដែលបានប្ដឹងទាស់ មិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទដំបូងក្រោយពេលបើកនីតិវិធីថ្មីទេ តុលាការអាចធ្វើតាមមាត្រានេះបាន ប៉ុន្តែ ប្រសិនបើភាគីនោះបានបង្ហាញខ្លួននៅកាលបរិច្ឆេទដំបូង ហើយអវត្តមាននៅកាលបរិច្ឆេទក្រោយទៀត តុលាការមិនអាចធ្វើតាមកថាខណ្ឌទី ១ នៃមាត្រានេះបានទេ ។ ក្នុងករណីនេះ តុលាការនឹងចេញសាលក្រមកំបាំងមុខធម្មតាវិញ ។ ចំពោះសាលក្រមកំបាំងមុខធម្មតានេះ បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រានេះ មិនត្រូវយកមកអនុវត្តទេ ហេតុដូច្នេះ មានមតិខ្លះចង្អុលថា ភាគីអាចប្ដឹងទាស់ម្ដងទៀតបាន ដើម្បីតែពន្យារពេលនូវនីតិវិធីនៃបណ្ដឹងតែប៉ុណ្ណោះ ។ ប៉ុន្តែ ក្នុងក្រមនេះ មានបញ្ញត្តិដែលចែងថា ដើម្បីប្ដឹងទាស់ ភាគីត្រូវមាន "ហេតុដែលមិនអាចព្យាករបាន ឬ ហេតុដែលមិនអាចជៀសវាងបាន" ដែលនាំឱ្យភាគី "មិនបានបង្ហាញខ្លួនតាមកាលបរិច្ឆេទទាន់ពេលវេលា" (មាត្រា ២០៤ (បណ្ដឹងទាស់)) ហេតុដូច្នេះហើយ យើងអាចសន្និដ្ឋានថាករណីនៃការបំពានសិទ្ធិប្ដឹងទាស់ដែលបានចង្អុលដូចខាងលើនេះ ស្ទើរតែគ្មានទេ ។

The Code of Civil Procedure Rules (Germany)
**Article 345** (Second default judgment)
A party which entered the petition to set aside, but fails to appear at the session set for the oral hearing or any session to which the hearing is adjourned or fails to plead to the main issue, will not be entitle to enter a further petition to set aside against the default judgment which would be set aside as the result of the petition.

**មាត្រា ២១២.-** បញ្ញត្តិដែលអនុវត្តដូចគ្នា

១- បញ្ញត្តិស្តីពីការដកពាក្យបណ្តឹងឧទ្ធរណ៍ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការដកពាក្យបណ្តឹងទាស់ ។

២- បញ្ញត្តិនៃផ្នែកនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងតប ។

(កំណត់)

សូមមើលមាត្រា 264 និង មាត្រា 265 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ជាងគេ (1890) មាត្រា 346 និង មាត្រា 347 នៃក្រមនីតិវិធីរដ្ឋប្បវេណីអាល្លឺម៉ង់ ។ សូមមើលកំណត់នៃមាត្រា ២៦៩ (ការដកពាក្យបណ្តឹងឧទ្ធរណ៍) ។

The Code of Civil Procedure Rules (Germany)
**Article 346** (Waiver and withdrawal)
As regards waiver and withdrawal of the petition to set aside, the provisions concerning waiver and withdrawal of appeals shall apply *mutatis mutandis*.
**Article 347** (Counterclaim; interlocutory proceedings)
(1) The provisions of this title are analogously applicable to a proceeding, the subject of which is a counterclaim or the determination of the amount of a claim which in substance has already been established.
(2) If a time has bee fixed only for a hearing on the interlocutory proceedings, the default hearing and the default judgment is limited to the disposition of this interlocutory proceeding. The provisions of this title apply *mutatis mutandis*.

## ផ្នែកទី ៦ ដីកាសម្រេច

**មាត្រា ២១៣.-** ការជូនដំណឹងអំពីដីកាសម្រេច

១- ដីកាសម្រេចនឹងមានអានុភាព លុះត្រាតែត្រូវបានជូនដំណឹងតាមវិធីដែលអាចទទួលស្គាល់ថាសមរម្យ ។(1)

២- ក្នុងករណីចេញដីកាសម្រេចជាលាយល័ក្ខណ៍អក្សរ ចៅក្រមដែលបានចេញដីកាសម្រេច ត្រូវចុះហត្ថលេខាលើដីកាសម្រេចនោះ ។

៣- នៅពេលជូនដំណឹងអំពីដីកាសម្រេច ក្រឡាបញ្ជីត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នូវហេតុការណ៍ និង វិធីនៃការជូនដំណឹងនោះ ដាក់នៅក្នុងសំណុំរឿង ។(2)

(កំណត់)

សូមមើលមាត្រា 119 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន និង មាត្រា 50 នៃបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(1) ដីកាសម្រេចគឺជាការសម្រេចសេចក្ដីដើម្បីចាត់ការលើការដឹកនាំនីតិវិធី ឬ ដើម្បីចាត់ចែងចំណុចបន្ទាប់បន្សំក្នុងការវិនិច្ឆ័យបណ្ដឹង ហើយមិនមែនជាការសម្រេចសេចក្ដីសំខាន់ៗដូចសាលក្រមដែលវិនិច្ឆ័យអង្គសេចក្ដីនៃរឿងក្ដីទេ ។ ហេតុដូច្នេះ វិធីជូនដំណឹងក៏អាចមានភាពងាយស្រួល ហើយអានុភាពក៏កើតឡើងភ្លាមៗ ដោយមិនចាំបាច់រង់ចាំចូលជាស្ថាពរឡើយ ។ ប៉ុន្តែ មានករណីលើកលែង ដូចជា ដីកាសម្រេចដាស់តឿន ត្រូវមានអានុភាពនៅពេលដែលបានបញ្ជូនទៅដល់កូនបំណុល (មាត្រា ៣២៥) ។

(2) ការបញ្ជាក់ច្បាស់លាស់ "នៅក្នុងសំណុំរឿង" មានន័យថា មិនចាំបាច់កត់ក្នុងកំណត់ហេតុទេ តែត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នៅក្នុងសំណុំរឿងដោយវិធីណាមួយ ។ ហេតុដូច្នេះ ក្នុងករណីដែលការជូនដំណឹងត្រូវបានធ្វើឡើងដោយបញ្ជូនលិខិតនៃដីកាសម្រេច ក្រឡាបញ្ជីអាចភ្ជាប់របាយការណ៍នៃការបញ្ជូន ជាមួយនឹងសំណុំរឿង ក៏បានដែរ ។

<u>Code of Civil Procedure (Japan)</u>
**Article 119** (Notice of ruling and order)
A ruling or order shall take effect when notice thereof is given in such a manner as may be deemed proper.

<u>Rules of Civil Procedure (Japan)</u>
**Article 50** (Form, etc., of ruling and order / The Code Article 119, etc.)
1. On a ruling paper or an order paper, the judge who has rendered such ruling or order shall enter his or her name and affix his or her seal.
2. When a notice of a ruling or an order has been given, the court clerk shall clearly indicate both that fact and how the notice was made in the record of the case.
3. In addition to the provisions of the preceding two paragraphs, the provisions relating to judgment shall apply *mutatis mutandis* to rulings and orders insofar as such provisions are not inconsistent with the nature of such dispositions.

## **មាត្រា ២១៤.-** ការលុបចោលនូវដីកាសម្រេចទាក់ទងនឹងការដឹកនាំនីតិវិធី

ដីកាសម្រេចទាក់ទងនឹងការដឹកនាំនីតិវិធីនៃបណ្ដឹង អាចលុបចោលនាពេលណាក៏បាន ។(1)

(កំណត់)

សូមមើលមាត្រា 120 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(1) ចំពោះសាលក្រម គេទទួលស្គាល់អត្តពន្ធភាព ហើយជាគោលការណ៍ តុលាការមិនអាចកែប្រែ ឬ លុបចោលសាលក្រមបានទេ ទោះបីជាសាលក្រមនោះត្រូវបានចេញដោយតុលាការនោះក៏ដោយ (មាត្រា ១៩១ (អត្តពន្ធភាពនៃសាលក្រម)) ។ ផ្ទុយទៅវិញ ដីកាសម្រេចស្ដីពីការដឹកនាំនីតិវិធី ត្រូវបានធ្វើឡើងដើម្បីឱ្យមានភាពងាយស្រួលក្នុងដំណើរការនៃបណ្ដឹង ហើយមិនសម្រេចអង្គហេតុ ឬ ចំណុចណាឱ្យចូលជាស្ថាពរទេ ហេតុដូច្នេះហើយគួរអាចលុបចោលបានដោយសេរី ប្រសិនបើដីកាសម្រេចនេះ ក្លាយជាមិនចាំបាច់ ឬ មិនសមរម្យ នៅពេលក្រោយ ។ មាត្រានេះចែងឱ្យច្បាស់អំពីចំណុចនេះ ។ ម្យ៉ាងទៀត អត្តពន្ធភាពនៃដីកាសម្រេចដែលមិនមែនទាក់ទងនឹងការដឹកនាំនីតិវិធី ត្រូវគិត និង សម្រេច តាមភាពសំខាន់ និង ខ្លឹមសារ ហើយមិនអាចសម្រេចតែម្ដងបានទេ ។

Code of Civil Procedure (Japan)
**Article 120** (Cancellation of decision relating to control of litigation)
Any ruling or order relating to the control of litigation may be cancelled at any time.

## មាត្រា ២១៥.- បណ្តឹងតវ៉ាអំពីការចាត់ចែងរបស់ក្រឡាបញ្ជី

ចំពោះបណ្តឹងតវ៉ាអំពីការចាត់ចែងរបស់ក្រឡាបញ្ជី តុលាការដែលក្រឡាបញ្ជីនោះស្ថិតនៅក្រោមឱវាទ ត្រូវសម្រេចសេចក្តី ដោយដីកាសម្រេច ។

（កំណត់）

សូមមើលមាត្រា 121 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ ដោយសារនៅក្នុងសកម្មភាពនីតិវិធីបណ្តឹង ក្រឡាបញ្ជីគឺជាមន្ត្រីសំខាន់ម្នាក់ដែលទាក់ទងផ្ទាល់ដល់ការរក្សា និង ចំណាត់ការខ្លះនៅក្នុងសំណុំរឿង ទើបមាត្រានេះកំណត់សិទ្ធិតវ៉ាចំពោះការចាត់ចែងរបស់ក្រឡាបញ្ជី ហើយការដោះស្រាយលើបណ្តឹងតវ៉ានេះ ជាសមត្ថកិច្ចរបស់សាមីតុលាការដែលក្រឡាបញ្ជីនោះស្ថិតនៅក្រោមឱវាទ ។

Code of Civil Procedure (Japan)
**Article 121** (Objection to disposition taken by court clerk)
With regard to an objection to any disposition taken by the court clerk, the court to which such clerk belongs shall render a decision by ruling.

## មាត្រា ២១៦.- ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីសាលក្រម

បញ្ញត្តិស្តីពីសាលក្រមត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេច លើកលែងតែបញ្ញត្តិស្តីពីសាលក្រមនោះមានភាពផ្ទុយពីលក្ខណៈនៃដីកាសម្រេច ។（1）

（កំណត់）

សូមមើលមាត្រា 122 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(1) ករណីដែលបញ្ញត្តិស្តីពីសាលក្រម （សាលដីកា） មិនយកមកអនុវត្តដូចគ្នា ចំពោះដីកាសម្រេច ដោយសារមានលក្ខណៈផ្ទុយគ្នានឹងដីកាសម្រេច គឺ ជាឧទាហរណ៍ បញ្ញត្តិទាំងឡាយស្តីពីការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ។ ពោលគឺ ដោយដីកាសម្រេចនឹងកើតមានអានុភាពដោយការជូនដំណឹងនោះ （មាត្រា ២១៣ （ការជូនដំណឹងអំពីដីកាសម្រេច）） យើងពុំចាំបាច់ភ្ជាប់សេចក្តីប្រកាសអនុវត្តបណ្តោះអាសន្នជាមួយនឹងដីកាសម្រេចទេ ។ បញ្ញត្តិផ្សេងពីនេះ ជាគោលការណ៍ ត្រូវយកមកអនុវត្តដូចគ្នា តែការអនុវត្តជាក់ស្តែងនោះ គឺស្ថិតនៅលើការវិនិច្ឆ័យទៅលើករណីនីមួយៗនោះ ។

Code of Civil Procedure (Japan)

**Article 122** (*Mutatis mutandis* application of the provisions relating to judgment)
The provisions relating to judgment shall apply *mutatis mutandis* to rulings and orders insofar as such provisions are not inconsistent with the nature of such disposition.

## ជំពូកទី ៦ ការបញ្ចប់នីតិវិធីដោយមិនធ្វើទៅតាមការសម្រេចសេចក្ដី

**មាត្រា ២១៧.-** ការដកពាក្យបណ្ដឹង

១- ដើមចោទអាចដកពាក្យបណ្ដឹងទាំងអស់ ឬ មួយផ្នែកបាន រហូតដល់ពេលដែលសាលក្រមចូលជាស្ថាពរ ។

២- ក្រោយពីចុងចម្លើយបានដាក់ឯកសារត្រៀមអំពីអង្គសេចក្ដី ឬ បានឆ្លើយក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលអំពីអង្គសេចក្ដី ឬ បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់អំពីអង្គសេចក្ដីហើយ ការដកពាក្យបណ្ដឹង មិនត្រូវមានអានុភាពឡើយ លើកលែងតែបានទទួលការយល់ព្រមពីចុងចម្លើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះការដកពាក្យបណ្ដឹងតបក្នុងករណីដែលដើមចោទបានដកពាក្យបណ្ដឹងដើម ។

៣- ការដកពាក្យបណ្ដឹង ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ។ ប៉ុន្តែ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សា ការដកពាក្យបណ្ដឹងអាចធ្វើឡើងដោយផ្ទាល់មាត់ក៏បាន ។

៤- ក្នុងករណីដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ២ ខាងលើនេះ ប្រសិនបើការដកពាក្យបណ្ដឹងត្រូវបានធ្វើឡើងជាលាយល័ក្ខណ៍អក្សរ តុលាការត្រូវបញ្ជូនលិខិតនេះទៅចុងចម្លើយ ហើយប្រសិនបើការដកពាក្យបណ្ដឹងត្រូវបានធ្វើឡើងដោយផ្ទាល់មាត់នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សា តុលាការត្រូវបញ្ជូនឯកសារចម្លងនៃកំណត់ហេតុនៃកាលបរិច្ឆេទនេះ ទៅចុងចម្លើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការដកពាក្យបណ្ដឹង ត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សា ហើយចុងចម្លើយបានចូលរួមនៅក្នុងកាលបរិច្ឆេទនោះ ។

៥- ប្រសិនបើចុងចម្លើយមិនបានប្ដឹងតវ៉ា ក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ បន្ទាប់ពីបានទទួលលិខិតដកពាក្យបណ្ដឹងដែលត្រូវបានបញ្ជូនទេ នោះត្រូវចាត់ទុកថា ចុងចម្លើយបានយល់ព្រមនឹងការដកពាក្យបណ្ដឹងនេះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដែរ ចំពោះករណីដែលការដកពាក្យបណ្ដឹង ត្រូវបានធ្វើឡើងដោយផ្ទាល់មាត់នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សា ហើយចុងចម្លើយមិនបានប្ដឹងតវ៉ា ក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ បន្ទាប់ពីថ្ងៃដែលមានការដកពាក្យបណ្ដឹង ប្រសិនបើចុងចម្លើយក៏បានចូលរួមនៅកាលបរិច្ឆេទនោះដែរ ឬ ក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ បន្ទាប់ពីបានទទួលការបញ្ជូនឯកសារចម្លងដែលបានកំណត់ក្នុងកថាខណ្ឌទី ៤ ខាងលើនេះ ប្រសិនបើចុងចម្លើយមិនបានចូលរួមនៅកាលបរិច្ឆេទនោះទេ ។

(កំណត់)

មាត្រានេះ ចែងដូចមាត្រា 261 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

ដើមចោទអាចដកពាក្យបណ្ដឹងដែលស្នើសុំឱ្យតុលាការចេញសាលក្រម និង អាចរំលត់ការចាត់ការរឿងក្ដីដោយប្រតិសកម្ម តាំងពីពេលដាក់ពាក្យបណ្ដឹង ។ ការដកពាក្យបណ្ដឹងអាចធ្វើឡើងបានរហូតដល់ពេលសាលក្រមចុងក្រោយ (final judgment, jugement définitif) ចូលជាស្ថាពរ (កថាខណ្ឌទី ១) ។ មានន័យថា អាចដកពាក្យបណ្ដឹង មិនមែនតែមុនពេលចេញសាលក្រមចុងក្រោយប៉ុណ្ណោះទេ តែព្រមទាំងក្រោយពេលចេញសាលក្រមនៃការជំនុំជម្រះលើកទី ១ នៅពេលដែលចាត់ការរឿងក្ដីនៅតុលាការនៃបណ្ដឹងឧទ្ធរណ៍ ឬ តុលាការកំពូលបានផងដែរ ។ ការដកពាក្យបណ្ដឹង ត្រូវបានធ្វើឡើងដោយការបង្ហាញឆន្ទៈរបស់ភាគីដើមចោទតែម្ខាង ។ ក្រៅពីកាលបរិច្ឆេទ ការដកពាក្យបណ្ដឹង ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរដើម្បីឱ្យមានភាពងាយស្រួលក្នុងការបញ្ជាក់ (កថាខណ្ឌទី ៣) ។ ប៉ុន្តែ ក្រោយពេលចុងចម្លើយបានឆ្លើយដោះសាចំពោះអង្គសេចក្ដីហើយ ដើមចោទមិនអាចដកពាក្យបណ្ដឹង ដោយគ្មានការយល់ព្រមរបស់ចុងចម្លើយ បានទេ ដោយសារតុលាការអាចចេញសាលក្រមដែលឱ្យចុងចម្លើយឈ្នះ (កថាខណ្ឌទី ២) ។ កថាខណ្ឌទី ៥ កំណត់អំពីករណីដែលត្រូវចាត់ទុកថា ចុងចម្លើយបានយល់ព្រម ។

នៅក្នុងសិក្ខាសាលាលើកទី ៧ (ខែ វិច្ឆិកា ឆ្នាំ ២000) ភាគីកម្ពុជាបានស្នើសុំថា "ដោយមានអ្នកតំណាងដកពាក្យបណ្ដឹងដោយចិត្តឯង ដែលជាហេតុនាំឱ្យមានផលវិបាក ត្រូវមានបញ្ញត្តិដែលអាចការពារភាគីផង (ប្រព័ន្ធជូនដំណឹងទៅភាគី ជាដើម)" ។ តែក្រោយពីបានពិភាក្សាជាមួយក្រុមការងារផ្នែកនីតិវិធីរដ្ឋប្បវេណីរួចមក បើយើងចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនេះ នឹងធ្វើឱ្យមានភាពច្របូកច្របល់ពេកអំពីបញ្ញត្តិស្ដីពីអានុភាពនៃការដកពាក្យបណ្ដឹង មតិរបស់យើងគឺមិនចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនេះទេ គឺទុកឱ្យភាគីកម្ពុជាជជែកអំពីបញ្ហានេះជាបញ្ហាទូទៅ នៅក្នុងក្រមសីលធម៌មេធាវី ឬ នៅក្នុងសំណងការខូចខាតធម្មតា ។

Code of Civil Procedure (Japan)
**Article 261** (Withdrawal of suit)
1. A suit may be withdrawn in whole or in part until the judgment becomes final and binding.
2. After the adversary party has, upon the merits of the suit, submitted a preliminary document, made statements in the preparations for argument proceedings, or presented oral argument, unless consent of such party is received, withdrawal of the suit shall not take effect. However, this shall not apply to withdrawal of a cross action in cases where the principal aciton has been withdrawn.
3. Withdrawal of a suit shall be made in writing. However, this shall not preclude it from being effected orally on a date set for oral argument, preparations for argument proceedings, or compromise (hereinaft4er in this chapter referred as "a date set for oral argument, etc.").
4. In the cases referred to in the main clause of paragraph 2, if the withdrawal of the suit has been made in writing, the document shall be served on the adversary party, or, if the withdrawal of the suit has been made orally on a date set for oral argument, etc. (except for when the party has appeared on the date), a transcript of the record for the date shall be served on such party.
5. In the cases where the adversary party does not raise an objection within two weeks from the day on which the document for withdrawal of a suit was served, such party shall be deemed to have consented thereto. The same shall apply to cases where the withdrawal of a suit has been made orally on a date set for oral argument, etc., if the adversary party had appeared on the date and the adversary party does not raise an objection within two weeks from the day on which the withdrawal of the suit was made, or if the party had not appeared on the date, from the day on which the transcript referred to in the preceding paragraph was served.

**មាត្រា ២១៨.-** អានុភាពនៃការដកពាក្យបណ្ដឹង

១- ផ្នែកដែលត្រូវបានដកពាក្យបណ្ដឹង ត្រូវចាត់ទុកថា មិនបានចាត់ការតាំងពីដំបូង ។
២- ភាគីដែលបានដកពាក្យបណ្ដឹងក្រោយពីចេញសាលក្រមចុងក្រោយអំពីអង្គសេចក្ដី មិនអាចដាក់ពាក្យបណ្ដឹងដូចគ្នាម្ដងទៀតបានទេ ។

(កំណត់)

មាត្រានេះ ចែងដូចមាត្រា 262 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

អានុភាពទី ១ នៃការដកពាក្យបណ្ដឹង គឺការចាត់ការរឿងក្ដីត្រូវរលត់ដោយប្រតិសកម្មតាំងពីពេលដាក់ពាក្យបណ្ដឹង (កថាខណ្ឌទី ១) ។ អានុភាពទី ២ គឺ ក្នុងករណីដែលដកពាក្យបណ្ដឹងក្រោយពេលចេញសាលក្រមចុងក្រោយ មិនអាចដាក់ពាក្យបណ្ដឹងដូចគ្នាទៀតបានទេ ។ បញ្ញត្តិនេះ មានគោលគំនិតកុំឱ្យដើមចោទដែលលុបអានុភាពនៃសាលក្រមសម្រេចអង្គសេចក្ដីដោយដកពាក្យបណ្ដឹង អាចដាក់ពាក្យបណ្ដឹងម្ដងទៀត និង នាំឱ្យតុលាការនិងចុងចម្លើយចូលក្នុងនីតិវិធីដដែលៗបាន ។ ប៉ុន្តែ ប្រសិនបើមានសេចក្ដីត្រូវការចាំបាច់ក្នុងការដាក់ពាក្យបណ្ដឹងថ្មីកើតឡើង ត្រូវអនុញ្ញាតឱ្យដាក់ពាក្យបណ្ដឹងដូចគ្នា ។ ឧ- ក្រោយពេលដាក់ពាក្យបណ្ដឹង ដើមចោទ និង ចុងចម្លើយបានផ្សះផ្សាគ្នាក្រៅនីតិវិធីនៅតុលាការ ហើយដើមចោទបានដកពាក្យបណ្ដឹង ដោយយល់ព្រមការពន្យារពេលសង ប៉ុន្តែ ចុងចម្លើយមិនបានសងនៅពេលកំណត់ ។ ក្នុងករណីដូចនេះ ដើមចោទអាចដាក់ពាក្យបណ្ដឹងម្ដងទៀតដើម្បីទាមទារតាវកាលិកដូចគ្នានឹងបណ្ដឹងមុន ។

<u>Code of Civil Procedure (Japan)</u>
**Article 262** (Effect of withdrawal of suit)
1. If withdrawn, a suit is deemed never to have been pending as far as the part withdrawn is concerned.
2. A party who has withdrawn a suit after final judgment was rendered upon the merits may not bring the same suit again.

**មាត្រា ២១៩.-** ការចាត់ទុកថា ដកពាក្យបណ្ដឹង

ក្នុងករណីដែលភាគីទាំងសងខាងមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយមិនបានដាក់ពាក្យសុំឱ្យតុលាការកំណត់កាលបរិច្ឆេទជាថ្មីទៀតក្នុងអំឡុងពេល ១ (មួយ) ខែទេ នោះត្រូវចាត់ទុកថា បានដកពាក្យបណ្ដឹង ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរចំពោះករណីដែលភាគីទាំងសងខាងមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ពីរដងជាប់គ្នា ។

(កំណត់)

មាត្រានេះ ចែងដូចមាត្រា 263 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

ដើមចោទនិងចុងចម្លើយមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ នីតិវិធីត្រៀម

សម្រាប់ការទាញហេតុផល ហើយមិនបានដាក់ពាក្យសុំឱ្យតុលាការកំណត់កាលបរិច្ឆេទជាថ្មីទៀតក្នុងអំឡុងពេលដែលកំណត់ នោះត្រូវចាត់ទុកថា បានដកពាក្យបណ្ដឹង ដោយសន្និដ្ឋានថា គូភាគីទាំងសងខាងគ្មានចំណង់ និង សេចក្ដីត្រូវការក្នុងការធ្វើទៅតាមនីតិវិធីនៃបណ្ដឹង ។ ក្នុងករណីដែលគូភាគីសងខាងមិនបានបង្ហាញខ្លួនជាប់២គ្នាប៉ុន្មានដងដែលបានកំណត់ ក៏ត្រូវចាត់ទុកថា បានដកពាក្យបណ្ដឹងដែរ ។

ពាក្យថា "មិនបានបង្ហាញខ្លួន" ក្នុងមាត្រានេះ រាប់បញ្ចូល ①ករណីដែលភាគីមិនបានមកបង្ហាញខ្លួននៅសាលសវនាការព្រមទាំង ②ករណីដែលភាគីបានបង្ហាញខ្លួនមែន តែបានចេញពីសាលសវនាការ ដោយមិនបានឆ្លើយដោះសា នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ដោយមិនបានធ្វើសេចក្ដីថ្លែងការណ៍នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ។

Code of Civil Procedure (Japan)
**Article 263** (Construction of withdrawal of suit)
In cases where both parties do not appear on the date set for oral argument or preparations for argument proceedings, or have left the court or the seat without making any argument or any statement in preparations for argument proceedings, and do not within one month make any motion for designating the date therefor, the suit shall be deemed to have been withdrawn. The same shall apply to cases where both parties, on two consecutive occasions, do not appear on the date set for oral argument or preparations for argument proceedings, or have left the court or the seat without making any argument or any statement in preparations for argument proceedings.

## **មាត្រា ២២០.-** ការផ្សះផ្សាលើបណ្ដឹង

១- ភាគីអាចធ្វើការផ្សះផ្សានៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សាបាន ។

២- ការផ្សះផ្សាដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើនៅក្រៅទីតាំងតុលាការក៏បានដែរ ប្រសិនបើតុលាការយល់ឃើញថាសមរម្យ ។

(កំណត់)

កថាខណ្ឌទី ១ បញ្ជាក់ច្បាស់លាស់ថា គូភាគីអាចបញ្ចប់នីតិវិធីដោយសម្រុះសម្រួលគ្នាចំពោះទំនាក់ទំនងនៃសិទ្ធិដែលជាចំណុចវិវាទ នៅពេលណាក៏បានក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សា ។ ចំពោះមាត្រា ៩៧ (ការសាកល្បងធ្វើការផ្សះផ្សា) និង មាត្រា ១០៤ (ការសាកល្បងផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) វិញ បញ្ញត្តិទាំងពីរនេះគឺបញ្ញត្តិ ដែលចែងអំពីការសាកល្បងធ្វើការផ្សះផ្សាដោយតុលាការ ។

កថាខណ្ឌទី ២ ដែលចែងដូចមាត្រា 32 កថាខណ្ឌទី 2 នៃបទប្បញ្ញត្តិស្ដីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន គឺបញ្ញត្តិអំពីការផ្សះផ្សា មួយប្រភេទដែលហៅថា "ការផ្សះផ្សានៅទីកន្លែង" ។ ឧ- ក្នុងករណីដែលចំណុចវិវាទជាការកំណត់ព្រំដី ឬវិការៈក្នុងការសង់សំណង់ ការពិភាក្សាគ្នាដើម្បីធ្វើការផ្សះផ្សា ដោយត្រួតពិនិត្យស្ថានភាពជាក់ស្ដែងនៅទីកន្លែង មានភាពប្រសើរជាង ។ ឬមួយ ក្នុងករណីដែលភាគីមិនអាចមកតុលាការបានដោយសារមានជម្ងឺធ្ងន់ ការពិភាក្សាគ្នាសម្រាប់

ការផ្សះផ្សាចំពោះមុខសាមីខ្លួន អាចមានលទ្ធផលល្អជាងធ្វើការផ្សះផ្សានៅតុលាការ ។

ម្យ៉ាងទៀត អាចមានបញ្ញត្តិដូចមាត្រា 264 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ដែលកំណត់ថា "ក្នុងករណីដែលបានយល់ឃើញថា ភាគីមានភាពលំបាកក្នុងការបង្ហាញខ្លួនដោយសារភាគីនោះមានលំនៅឋានឆ្ងាយ (ពីតុលាការ) ឬ ដោយសារមានមូលហេតុផ្សេងទៀត ប្រសិនបើភាគីនោះបានដាក់លិខិតដែលទទួលយល់ព្រមនូវសេចក្តីព្រាងអំពីចំណុចនៃការផ្សះផ្សាដែលត្រូវបានបង្ហាញជាមុនដោយតុលាការ ឬ ដោយចៅក្រមដែលទទួលបញ្ជា ឬ ដោយចៅក្រមដែលទទួលការប្រគល់សិទ្ធិ ហើយភាគីម្ខាងទៀតបានបង្ហាញខ្លួននៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ជាអាទិ៍ និងទទួលយល់ព្រមនូវសេចក្តីព្រាងអំពីចំណុចនៃការផ្សះផ្សានេះ ត្រូវចាត់ទុកថា ការផ្សះផ្សាត្រូវបានសម្រេចរវាងគូភាគីទាំងសងខាង" ។ ប៉ុន្តែ ក្នុងក្រុមការងារនៃភាគីជប៉ុនដើម្បីរៀបចំសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី មានមតិសំខាន់មួយថា អាចមានករណីដែលមានភាពលំបាកក្នុងការបញ្ជាក់ឆន្ទៈពិតប្រាកដ (សូមមើលមាត្រា 163 នៃបទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណីជប៉ុន) ហេតុដូច្នេះហើយ ក្រមនេះ មិនចែងបញ្ញត្តិដូច្នោះទេ ។

នៅក្នុងសិក្ខាសាលាលើកទី ៧ (ខែ វិច្ឆិកា ឆ្នាំ ២000) មានមតិជាច្រើនចង់ឱ្យចែងអំពីបទប្បញ្ញត្តិប្រភេទនេះ ។ យើងបានយកមតិនេះមកពិភាក្សា ជាមួយនឹងក្រុមការងារផ្នែកនីតិវិធីរដ្ឋប្បវេណីរួចមក អំពីការផ្សះផ្សាដែលតម្រូវឱ្យមានវត្តមានរបស់គូភាគីនោះ នៅពេលដែលការអនុវត្តកិច្ចការនេះ មានទម្លាប់ (ធ្លាប់) រួចហើយនោះ ចាំចាប់គិតអំពីបញ្ញត្តិដូចមាត្រា 264 របស់ក្រមនីតិវិធីរដ្ឋប្បវេណីនេះជាការប្រសើរជាង ។ មតិយើងគិតថាបច្ចុប្បន្ននេះពុំចាំបាច់គិតវាទេ ។

<u>Rules of Civil Procedure (Japan)</u>
**Article 32** (Measures for compromise / The Code Article 89) (excerpt)
2. The court or a commissioned or assigned judge may, upon determining it proper, effect a compromise outside of the court.

<u>Code of Civil Procedure (Japan)</u>
**Article 264** (Acceptance in writing of proposed terms of compromise)
In cases where it is deemed to be difficult for a party to appear for the reason of having residence in a remote place or for any other reason, when such party submits a document stating acceptance of the proposed terms of compromise presented in advance by the court or a commissioned judge or assigned judge, and the other party appearing on a date set for oral argument, etc., has accepted the proposed terms of compromise, it shall be deemed that a compromise has been arranged between the parties.

<u>Rules of Civil Procedure (Japan)</u>
**Article 163** (Acceptance in writing of proposed terms of compromise/The Code Article 264)
1. In cases where the court or a commissioned judge or assigned judge (hereinafter in this chapter : "the court, etc.") presents proposed terms of compromise in accordance with the provisions of Article 264 (Acceptance in writing of proposed terms of compromise) of the Code, they shall be presented in writing. The effect prescribed in the article shall be stated in the document.
2. In the cases referred to in the preceding paragraph, when a document stating acceptance of the proposed terms of compromise has been submitted, the court, etc., shall confirm the true intention of the party who has submitted the document.
3. In cases where it has been deemed that a compromise has been arranged between the parties in accordance with the provisions of Article 264 of the Code, the court clerk shall enter such compromise in the record. In such cases, the court clerk shall, without delay, give notice of the fact that the compromise has been deemed to be arranged to the party who submitted document stating acceptance of the proposed terms of compromise.

**មាត្រា ២២១.-** ការលះបង់ ឬ ការទទួលស្គាល់នូវការទាមទារ

ការលះបង់នូវការទាមទារ ឬ ការទទួលស្គាល់នូវការទាមទារ ត្រូវធ្វើឡើងនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សា ។

(កំណត់)

មាត្រានេះ ចែងដូចមាត្រា 266 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

ការលះបង់ការទាមទារ គឺ ដើមចោទបញ្ចប់នីតិវិធីដោយទទួលស្គាល់ថា ការទាមទាររបស់ខ្លួនគ្មានមូលហេតុត្រឹមត្រូវ ។ មានន័យថា ដើមចោទទទួលស្គាល់ថា ខ្លួនចាញ់ក្តី ។ ហេតុដូច្នេះ ការលះបង់ការទាមទារនេះ ខុសពីការដកពាក្យបណ្តឹង ។ ការទទួលស្គាល់នូវការទាមទារ គឺ ចុងចម្លើយបញ្ចប់នីតិវិធីដោយទទួលស្គាល់ថា ការទាមទាររបស់ដើមចោទ មានមូលហេតុត្រឹមត្រូវ ។ ការលះបង់នូវការទាមទារ និង ការទទួលស្គាល់នូវការទាមទារ ត្រូវធ្វើឡើងនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការផ្សះផ្សា ។

Code of Civil Procedure (Japan)
**Article 266** (Abandonment or acknowledgment of claim)
1. An abandonment or acknowledgment of a claim shall be made on a date set for oral argument, etc.
2. In cases where a party who has submitted a document including the statement that it abandons or acknowledges the claim does not appear on a date set for oral argument, etc., the court or a commissioned judge or an assigned judge may deem the party as having made such statement.

**មាត្រា ២២២.-** អានុភាពនៃកំណត់ហេតុស្តីពីការសះជា ជាអាទិ៍

ក្នុងករណីដែលមានការសះជា ការលះបង់នូវការទាមទារ ឬ ការទទួលស្គាល់នូវការទាមទារ ត្រូវបានកត់ត្រានៅក្នុងកំណត់ហេតុ កំណត់ត្រានេះ មានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ ។

(កំណត់)

មាត្រានេះ ចែងដូចមាត្រា 267 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

ការផ្សះផ្សា ការលះបង់នូវការទាមទារ និង ការទទួលស្គាល់នូវការទាមទារ ពុំមានអានុភាពដោយខ្លួនវាទេ ប៉ុន្តែពេលកត់ត្រាក្នុងកំណត់ហេតុ ត្រូវមានអានុភាពដូចគ្នានឹងសាលក្រមជាស្ថាពរ ។ "អានុភាពដូចគ្នានឹងសាលក្រមជាស្ថាពរ" រាប់បញ្ចូលទាំងអានុភាពបញ្ចប់នីតិវិធី ហើយក្នុងករណីនៃការផ្សះផ្សាដែលឱ្យភាគីម្ខាងមានកាតព្វកិច្ចត្រូវផ្តល់តាវកាលិក ឬ ករណីនៃការទទួលស្គាល់នូវការទាមទារចំពោះបណ្តឹងដែលទាមទារឱ្យផ្តល់តាវកាលិក កំណត់ត្រានេះត្រូវមានអានុភាពអនុវត្ត និង អាចអនុវត្តដោយបង្ខំដោយផ្អែកលើកំណត់នៅក្នុងកំណត់ហេតុ ។ ចំពោះអាជ្ញាអស់ជំនុំ (res judicata, autorité de chose jugée) មានការបកស្រាយដូចតទៅ : ត្រូវមានអាជ្ញាអស់ជំនុំក្នុងន័យថា កំណត់នៅក្នុងកំណត់ហេតុ នឹងចងទំនាក់ទំនងគតិយុត្តរវាងគូភាគីក្រោយពេលបានកត់ ប៉ុន្តែ គ្មានអាជ្ញាអស់ជំនុំ ក្នុងន័យថា អាចទាមទារឱ្យលុបចោលការផ្សះផ្សាដោយផ្អែកលើការភាន់ច្រឡំ ដោយមិនចាំបាច់ធ្វើទៅតាមបណ្តឹងសើរើ (ការជំនុំជម្រះសាជាថ្មី retrial, révision) ឬ អាចអះអាងទំនាក់ទំនងនៃសិទ្ធិផ្សេងពីខ្លឹមសារនៃការផ្សះផ្សា ដោយរំលាយកិច្ចសន្យាផ្សះផ្សា ដោយផ្អែកលើ

ការមិនអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យាផ្សះផ្សានោះ ។

នៅក្នុងសិក្ខាសាលាលើកទី ៧ (ខែ វិច្ឆិកា ឆ្នាំ ២០០០) មានមតិស្នើសុំឱ្យចែងថា "ច្បាប់បច្ចុប្បន្ន លិខិតកំណត់ហេតុផ្សះផ្សាពុំមានអានុភាពអនុវត្តឡើយ ហើយច្បាប់បានចែងថា ត្រូវមានដីកាសម្រេចរបស់តុលាការលើលទ្ធផលនៃការផ្សះផ្សានោះ ទើបអាចមានអានុភាពស្ថាពរដូចគ្នានឹងសាលក្រមស្ថាពរដែរ ហើយបើអាច ចង់រក្សាទុកនូវស្ថានភាពដើមនោះ" ។

ប៉ុន្តែ ក្រមនេះមិនយកប្រព័ន្ធដែលឱ្យការផ្សះផ្សាមានអានុភាពដូចគ្នាទាំងស្រុងជាមួយនឹងសាលក្រមស្ថាពរទេ ។ ដោយហេតុថា បើយើងទទួលស្គាល់ថា មានអានុភាពដូចគ្នាទាំងស្រុងនឹងសាលក្រម ក្នុងករណីដែលមានការភាន់ច្រឡំលើការលះបង់នូវការទាមទារ ការទទួលស្គាល់នូវការទាមទារ ឬ ការផ្សះផ្សានេះ ការអះអាងអំពីការលុបចោលដោយសារតែការភាន់ច្រឡំនេះ នឹងត្រូវបានបដិសេធ ដោយសារមានអាជ្ញាអស់ជំនុំ ហេតុដូច្នេះ វាជាការមិនត្រឹមត្រូវឡើយ បើមិនអាចអះអាងអំពីការលុបចោលដោយការភាន់ច្រឡំ ចំពោះរឿងហេតុដែលតុលាការពុំបានចូលរួមគ្រប់គ្រាន់ទេ ។

Code of Civil Procedure (Japan)
**Article 267** (Effect of record of compromise, etc.)
In cases where a compromise, or an abandonment or acknowledgment of a claim has been entered in the record, such entry shall have the same effect as a final and binding judgment.

## ជំពូកទី ៧ បទប្បញ្ញត្តិពិសេសស្តីពីរឿងក្តីចំនួនទឹកប្រាក់តិច

**មាត្រា ២២៣.-** គោលបំណងនៃនីតិវិធី

នីតិវិធីនៃរឿងក្តីចំនួនទឹកប្រាក់តិច មានគោលបំណងដើម្បីដោះស្រាយវិវាទដ៏ឆាប់រហ័សតាមនីតិវិធីសង្ខេប ។

(កំណត់)

មាត្រានេះ យោងតាមមាត្រា 270 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។

ការអនុវត្តចំពោះរឿងក្តីចំនួនទឹកប្រាក់តិច នៅប្រទេសអភិវឌ្ឍន៍មួយចំនួន គឺជាសមត្ថកិច្ចសាលាលហុ ប៉ុន្តែ ដោយសារប្រទេសកម្ពុជាពុំមានសាលាលហុ (Summary Court) នោះ បទប្បញ្ញត្តិពិសេសស្តីពីរឿងក្តីចំនួនទឹកប្រាក់តិច នឹងចែងជាបទប្បញ្ញត្តិពិសេសស្តីពីនីតិវិធីនៃសាលាដំបូង ។ មាត្រានេះ ចែងពីការដោះស្រាយវិវាទឱ្យបានឆាប់រហ័សតាមនីតិវិធីសង្ខេប ពុំចាំបាច់មាននីតិវិធីត្រៀមសម្រាប់ការទាញហេតុផល រីឯការផ្សះផ្សាក៏មិនតម្រូវឱ្យមានក្នុងនីតិវិធីនេះដែរ ។ ហើយជាពិសេស ក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ គឺធ្វើឡើងតែក្នុងរយៈពេលមួយថ្ងៃប៉ុណ្ណោះ លើកលែងមានករណីពិសេស ដែលតុលាការពុំអាចបញ្ចប់ការជំនុំជម្រះបាន ។

ដូចចែងក្នុងមាត្រា ២៣៨ (ការហាមឃាត់ចំពោះឧបាស្រ័យ) ចំពោះសាលក្រមចុងក្រោយ (final judgment, jugement

définitif）នៃរឿងក្តីចំនួនទឹកប្រាក់តិច គេពុំអាចឧបាស្រ័យបានសោះឡើយ ។

<u>Code of Civil Procedure (Japan)</u>
Book II, Chapter VII : Special Provisions Concerning Litigation Proceedings in Summary Court
**Article 270** (Characteristic of procedure)
In a summary court, a dispute shall be settled promptly by summary procedures.

**មាត្រា ២២៤.-** ល័ក្ខខ័ណ្ឌនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច ជាអាទិ៍

១- ចំពោះបណ្តឹងដែលមានគោលបំណងទាមទារសំណងជាទឹកប្រាក់មិនលើសពី ១.000.000 （មួយលាន） រៀល ដែលជាតម្លៃកម្មវត្ថុនៃបណ្តឹង ដើមចោទអាចស្នើសុំការជំនុំជម្រះ និង សម្រេចសេចក្តី តាមនីតិវិធីនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចបាន ។

២- សេចក្តីថ្លែងការណ៍ដែលស្នើសុំការជំនុំជម្រះ និង សម្រេចសេចក្តី តាមនីតិវិធីនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច ត្រូវធ្វើឡើងនៅពេលដាក់ពាក្យបណ្តឹង ។

（កំណត់）

មាត្រានេះចែងប្រហាក់ប្រហែលគ្នានឹងមាត្រា 368 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។

មាត្រានេះកំណត់អំពីចំនួនតម្លៃកម្មវត្ថុនៃបណ្តឹងដែលដើមចោទអាចស្នើសុំឱ្យវិនិច្ឆ័យ តាមនីតិវិធីនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចបាន （មិនលើសពី ១ លានរៀល） ។ ដោយសារបញ្ញត្តិនេះ ចំនួនតម្លៃកម្មវត្ថុនៃបណ្តឹងដែលបិទផ្លូវឧទ្ធរណ៍ ដែលបានកំណត់នៅក្នុងមាត្រា ៣៥ វាក្យខណ្ឌទី ២ នៃសេចក្តីព្រាងច្បាប់ស្តីពីការចាត់តាំងតុលាការ ក៏ត្រូវកែប្រែដែរ（ជាបណ្តោះអាសន្ន ការកំណត់ ៥ លានរៀល គឺជាការសមរម្យ） ។ ក្នុងករណីនេះ ចំពោះរឿងក្តីដែលតម្លៃកម្មវត្ថុនៃបណ្តឹងមានចំនួនទឹកប្រាក់តិចជាង ៥ លានរៀល មានការបិទផ្លូវឧទ្ធរណ៍ តាមបញ្ញត្តិនៃមាត្រា ៣៥ វាក្យខណ្ឌទី ២ នៃសេចក្តីព្រាងច្បាប់ស្តីពីការចាត់តាំងតុលាការ ហេតុនេះហើយ រឿងក្តីបែបនេះ ត្រូវសម្រេចជាស្ថាពរដោយជំនុំជម្រះតែ ១ លើក ។ ម្យ៉ាងទៀត ប្រសិនបើទទួលស្គាល់ពាក្យសុំប្តឹងតវ៉ា នៅក្នុងនីតិវិធីនៃបណ្តឹងនៃរឿងក្តីចំនួនទឹកប្រាក់តិច ចំពោះរឿងក្តីទៅលើចំនួនទឹកប្រាក់តិចជាង ១ លានរៀល តុលាការដដែលនឹងជំនុំជម្រះ តាមនីតិវិធីធម្មតា ។ ហេតុដូច្នេះ យើងមិនទទួលស្គាល់ពាក្យសុំប្តឹងតវ៉ាទេ ។

<u>Code of Civil Procedure (Japan)</u>
**Article 368** (Requirements, etc., of action on small claim)
1. In a summary court, with respect to a suit for the purpose of claiming the payment of money which has a value of no more than three hundred thousand yen as the subject matter of the suit, a trail and decision in an action on a small claim may be demanded. However, no such action may be demanded in any one summary court more than a specified number of times in one year as provided for in the Rules of the Supreme Court.
2. A statement demanding a trial and decision in an action on a small claim shall be made at the time of institution of the suit.
3. When the statement referred to in the preceding paragraph is made, a notice shall be submitted of the number of times in such year in which trials and decisions in actions on small claims have been demanded to the summary court before which the suit is filed.
Book III, Chapter III : *Kokoku*-Appeal
**Article 333** (Rectification by original court, etc.)

The court or presiding judge who rendered the original decision shall rectify such decision upon finding that there are grounds for the *kokoku*-appeal.

**មាត្រា ២២៥.-** ការដាក់ពាក្យបណ្ដឹងដោយផ្ទាល់មាត់ ចំណុចដែលត្រូវបញ្ជាក់ច្បាស់លាស់នៅពេលដាក់ពាក្យបណ្ដឹង

១- ការដាក់ពាក្យបណ្ដឹងនៃរឿងក្ដីចំនួនទឹកប្រាក់តិច អាចធ្វើដោយផ្ទាល់មាត់បាន ។

២- ចំពោះការដាក់ពាក្យបណ្ដឹងនៃរឿងក្ដីចំនួនទឹកប្រាក់តិច ទោះបីជាមានបញ្ញត្តិនៅក្នុងចំណុច **ខ** កថាខណ្ឌទី ២ នៃមាត្រា ៧៥ (របៀបដាក់ពាក្យបណ្ដឹង និង ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង) នៃក្រមនេះក៏ដោយ ក៏ជាការគ្រប់គ្រាន់ហើយ កាលបើមានការបង្ហាញឱ្យបានច្បាស់លាស់អំពីចំណុចសំខាន់ៗនៃវិវាទនោះ ។

៣- នៅពេលដែលដើមចោទដាក់ពាក្យបណ្ដឹងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវកត់ត្រានូវសេចក្ដីថ្លែងការណ៍របស់ដើមចោទនោះក្នុងកំណត់ហេតុ ។ ក្នុងករណីនេះ កំណត់ហេតុនោះ ត្រូវបានចាត់ទុកថាជាពាក្យបណ្ដឹង ។

(កំណត់)

មាត្រានេះថែងប្រហាក់ប្រហែលគ្នាជាមួយនឹងមាត្រា 271 និង មាត្រា 272 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

មាត្រានេះ ជាករណីលើកលែងចំពោះគោលការណ៍ដែលបានកំណត់នៅក្នុងបញ្ញត្តិនៃកថាខណ្ឌទី ២ ចំណុច **ខ** នៃមាត្រា ៧៥ (របៀបដាក់ពាក្យបណ្ដឹង និង ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង) ។

ទោះជាមានបញ្ញត្តិនៃកថាខណ្ឌទី ២ ក៏ដោយ ក៏អង្គហេតុដែលចាំបាច់សម្រាប់សំគាល់ការទាមទារ (អង្គហេតុដែលក្លាយជាមូលដ្ឋាននៃការទាមទារ) ត្រូវបានអះអាងមុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីប្រកាសសាលក្រមសម្រេចអង្គសេចក្ដី (សាលក្រមទទួលស្គាល់ការទាមទារ) ដែរ ។

ជាគោលការណ៍ ដើមចោទត្រូវដាក់ពាក្យបណ្ដឹង (តើយើងប្រើទម្រង់លិខិតជាកំណត់នៃពាក្យបណ្ដឹងឬទេ ?) ដោយសរសេរ ① ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និង អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ② សេចក្ដីសង្ខេប (ចំណុចសំខាន់ៗ) នៃវិវាទ ③ គោលបំណងដែលស្នើសុំឱ្យវិនិច្ឆ័យ និង សម្រេចសេចក្ដីតាមនីតិវិធីនៃរឿងក្ដីចំនួនទឹកប្រាក់តិច នៅក្នុងពាក្យបណ្ដឹង ប៉ុន្តែ តាមមាត្រានេះ ដើមចោទអាចដាក់ពាក្យបណ្ដឹងដោយផ្ទាល់មាត់បានដែរ ។ ក្នុងករណីនេះ ដើមចោទត្រូវធ្វើសេចក្ដីថ្លែងការណ៍ ចំពោះមុខក្រឡាបញ្ជីដែលទទួលពាក្យបណ្ដឹង ហើយក្រឡាបញ្ជីនឹងសរសេរក្នុងកំណត់ហេតុ (មាត្រា 1 កថាខណ្ឌទី 2 នៃបទប្បញ្ញត្តិស្ដីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន) ។

<u>Code of Civil Procedure (Japan)</u>
**Article 270** (Oral institution of suit)
A suit may be filed orally.
**Article 271** (Matters to be clearly indicated at institution of suit)
When a suit is filed, it is sufficient to clearly state summary of the dispute in lieu of the grounds of the claim.

<u>Rules of Civil Procedure (Japan)</u>
**Article 1** (Form of motion, etc.)
1. Except as otherwise provided, a motion or any other statement may be made in writing or orally.
2. An oral statement shall be made before the court clerk. In such cases, the court clerk shall compile a record and enter his or her

name and affix his or her seal thereon.

**មាត្រា ២២៦.‐** ការចង្អុលបង្ហាញអំពីនីតិវិធី

១- ក្រឡាបញ្ជីត្រូវប្រគល់ទៅភាគីនូវលិខិតលាយល័ក្ខណ៍អក្សរដែលពន្យល់នូវអត្ថន័យនៃនីតិវិធីនៃការជំនុំជម្រះ និងការសម្រេចសេចក្ដីតាមរឿងក្ដីចំនួនទឹកប្រាក់តិច នៅពេលកោះហៅតាមកាលបរិច្ឆេទដំបូងសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅក្នុងរឿងក្ដីចំនួនទឹកប្រាក់តិច ។

២- នៅពេលដំបូងនៃកាលបរិច្ឆេទដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវពន្យល់ភាគីនូវចំណុចដូចខាងក្រោមនេះ :

- **ក**- លើកលែងតែក្នុងករណីដែលមានសភាពការណ៍ពិសេស តុលាការត្រូវបញ្ចប់នូវការជំនុំជម្រះនៅកាលបរិច្ឆេទដំបូងសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ។
- **ខ**- ចំពោះសាលក្រមចុងក្រោយនៃរឿងក្ដីចំនួនទឹកប្រាក់តិច ភាគីពុំអាចធ្វើឧបាស្រ័យបានឡើយ លើកលែងតែបណ្ដឹងទាស់ចំពោះសាលក្រមកំបាំងមុខ ។
- **គ**- ការពិនិត្យភស្តុតាង អាចធ្វើបានចំពោះតែភស្តុតាងដែលអាចពិនិត្យបានភ្លាមៗប៉ុណ្ណោះ ។
- **ឃ**- ចុងចម្លើយអាចធ្វើសេចក្ដីថ្លែងការណ៍ឱ្យផ្ទេរបណ្ដឹង ទៅនីតិវិធីបណ្ដឹងធម្មតាបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលចុងចម្លើយបានធ្វើការឆ្លើយទាញហេតុផលនៅកាលបរិច្ឆេទដំបូងសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ឬ ក្រោយពេលកាលបរិច្ឆេទនោះបានបញ្ចប់ហើយ ។

(កំណត់)

មាត្រានេះចែងប្រហាក់ប្រហែលគ្នាជាមួយនឹងមាត្រា 222 នៃបទប្បញ្ញត្តិស្ដីពីនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។

កថាខណ្ឌទី ១ នៃមាត្រានេះតម្រូវឱ្យក្រឡាបញ្ជីណែនាំដើមចោទ ឱ្យបានដឹងអំពីការអនុវត្តនីតិវិធីនៃរឿងក្ដីចំនួនទឹកប្រាក់តិច រីឯកថាខណ្ឌទី ២ នៃមាត្រានេះ ចែងថា តុលាការត្រូវមានភារកិច្ចពន្យល់អត្ថន័យនៃការចង្អុលបង្ហាញនៃនីតិវិធីនៃរឿងក្ដីទឹកប្រាក់តិច ។

អត្ថន័យនៃការចង្អុលបង្ហាញអំពីនីតិវិធីនោះគឺ :

១- គោលការណ៍នៃការជំនុំជម្រះតាមកាលបរិច្ឆេទតែមួយថ្ងៃ (មាត្រា ២២៩ (គោលការណ៍នៃការជំនុំជម្រះតាមកាលបរិច្ឆេទតែមួយថ្ងៃ)) ។

២- ការមិនអនុញ្ញាតឱ្យឧបាស្រ័យ ចំពោះសាលក្រមចុងក្រោយ (មាត្រា ២៣៨ (ការហាមឃាត់ចំពោះឧបាស្រ័យ)) ។

៣- ការកម្រិតនូវការពិនិត្យភស្តុតាង (មាត្រា ២៣១ (ការកម្រិតនូវការពិនិត្យភស្តុតាង)) ។

៤- ការផ្ទេរបណ្ដឹងទៅនីតិវិធីធម្មតា ដោយសេចក្ដីថ្លែងការណ៍របស់ចុងចម្លើយ (មាត្រា ២៣៣ (ការផ្ទេរបណ្ដឹងទៅ

នីតិវិធីធម្មតា ដោយសេចក្ដីថ្លែងការណ៍របស់ចុងចម្លើយ)) ។

"ករណីដែលមានសភាពការណ៍ពិសេស" នៅក្នុងចំណុច ឥ នៃកថាខណ្ឌទី ២ ជាឧទាហរណ៍ គឺ ① ករណីដែលភាពចាំបាច់សាកសួរសាក្សីដែលមិនបានគិតដល់ ត្រូវបានកើតឡើង ក្រោយពេលពិនិត្យភស្តុតាង ឬ ② ករណីដែលសាក្សីដែលត្រូវមកជាមួយនឹងភាគី មិនបានបង្ហាញខ្លួន ដោយសារបញ្ហាសុខភាព ជាដើម ។

Rules of Civil Procedure (Japan)
**Article 222** (Instruction of procedures)
1. The court clerk shall, at the time of summons to appear on the initial date set for oral argument in an action on a small claim, deliver a document which explains the procedures of trial and decisions in actions on small claims to the parties.
2. The judge shall, at the beginning of the date referred to in the preceding paragraph, explain to the parties that:
i. the examination of evidence may be conducted only with respect to evidence which can be examined immediately;
ii. the defendant may make a statement that the litigation is to be transferred to ordinary procedures, however, this shall not apply after the defendant has proceeded with argument on the initial date set for oral argument nor after such date has concluded;
iii. an objection against the final judgment in an action on a small claim may be raised to the court which has rendered the judgment, within the peremptory term of two weeks from the day on which a judgment paper or a record in lieu of judgment paper is served.

### **មាត្រា ២២៧.-** ការហាមឃាត់ចំពោះបណ្ដឹងតប

នៅក្នុងរឿងក្ដីចំនួនទឹកប្រាក់តិច ការប្ដឹងតបមិនអាចធ្វើបានឡើយ ។

(កំណត់)

មាត្រានេះចែងដូចគ្នានឹងមាត្រា 369 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។

នៅក្នុងនីតិវិធីនៃរឿងក្ដីទឹកប្រាក់តិច គឺជានីតិវិធីមួយដែលតម្រូវឱ្យតុលាការចាត់ការឆាប់រហ័ស ។ ភស្តុតាងដែលភាគីដាក់ជូនមកតុលាការ គឺជាភស្តុតាងដែលតុលាការអាចពិនិត្យភ្លាមៗបាន ដោយមិនចាំបាច់ធ្វើការស្រាវជ្រាវទេ ។ ប្រសិនបើតុលាការអនុញ្ញាតឱ្យចុងចម្លើយប្ដឹងតប ហើយដើមចោទស្វែងរកភស្តុតាង ឬ អ្វីៗបន្ថែមមកទៀត ដើម្បីឆ្លើយតបនោះ ធ្វើឱ្យរឿងក្ដីនេះមានភាពស្មុគស្មាញ និង ចំណាយពេលវេលាច្រើនដែលមិនអាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ក្នុងរយៈពេលតែមួយថ្ងៃបាន ។

Code of Civil Procedure (Japan)
**Article 369** (Prohibition of cross action)
A cross action may not be filed in an action on a small claim.

### **មាត្រា ២២៨.-** ការកំណត់កាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់

១- នៅពេលដែលមានការដាក់ពាក្យបណ្ដឹង តុលាការត្រូវកំណត់កាលបរិច្ឆេទសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានឆាប់រហ័ស និង ត្រូវធ្វើការកោះហៅភាគី ។

២- កាលបរិច្ឆេទដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើនៅក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ

គិតចាប់ពីថ្ងៃដែលបានដាក់ពាក្យបណ្ដឹង លើកលែងតែក្នុងករណីដែលមានសភាពការណ៍ពិសេស ។

(កំណត់)

មាត្រានេះ ជាគោលការណ៍គ្រឹះនៃបទបញ្ញត្តិពិសេសស្ដីពីរឿងក្ដី មានន័យថា រឿងក្ដីចំនួនទឹកប្រាក់តិចនេះ មិនបាច់ឆ្លងកាត់តាមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ គឺធ្វើតាមការទាញហេតុផលដោយផ្ទាល់មាត់ នៅពេលឆាប់ៗតែម្ដង ។ ប៉ុន្តែ ក៏មានករណីលើកលែងដែរ មានសភាពការណ៍ពិសេស សូមមើលកំណត់មាត្រា ២២៩ ។

**មាត្រា ២២៩.-** គោលការណ៍នៃការជំនុំជម្រះតាមកាលបរិច្ឆេទតែមួយថ្ងៃ

១- ចំពោះរឿងក្ដីចំនួនទឹកប្រាក់តិច តុលាការត្រូវតែបញ្ចប់នូវការជំនុំជម្រះ នៅកាលបរិច្ឆេទដំបូងសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់លើកទី ១ លើកលែងតែក្នុងករណីដែលមានសភាពការណ៍ពិសេស ។

២- ភាគីត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនទាំងអស់ នៅមុន ឬ ក្នុងកាលបរិច្ឆេទដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការទាញហេតុផលដោយផ្ទាល់មាត់ត្រូវបានបន្ត ។

(កំណត់)

មាត្រានេះចែងដូចគ្នានឹងមាត្រា 370 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។

"ករណីដែលមានសភាពការណ៍ពិសេស" ដូចបានចែងនៅកថាខណ្ឌទី ១ នោះគឺ ① ករណីដែលកើតឡើងនូវភាពចាំបាច់ក្នុងការសាកសួរសាក្សីដែលគេមិនបានស្មានទុកជាមុន កាលដែលកំពុងធ្វើការពិនិត្យភស្ដុតាង ② ករណីដែលសាក្សីដែលបម្រុងមកជាមួយពុំអាចបង្ហាញខ្លួនបានដោយសារមូលហេតុសុខភាព ជាដើម ។

<u>Code of Civil Procedure (Japan)</u>
**Article 370** (Principle of one day trial)
1. In an action on a small claim, except for cases in which special circumstances exist, the trial shall be concluded on the first day set for oral argument.
2. The parties shall advance all offensive or defensive measures before or on the date referred to in the preceding paragraph. However, this shall not apply to cases where the oral argument has been continued.

**មាត្រា ២៣០.-** ការបង្គាប់ឱ្យសាមីភាគីបង្ហាញខ្លួន

ទោះបីជាអ្នកតំណាងដោយអាណត្តិត្រូវបានជ្រើសតាំងក៏ដោយ ក៏តុលាការអាចបង្គាប់ឱ្យសាមីភាគី ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់ភាគីនោះ បង្ហាញខ្លួនបានដែរ ។

(កំណត់)

មាត្រានេះចែងដូចគ្នានឹងមាត្រា 224 នៃបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។

ដើម្បីដោះស្រាយរឿងក្តីចំនួនទឹកប្រាក់តិច ទោះបីជាអ្នកតំណាងដោយអាណត្តិត្រូវបានជ្រើសតាំងក៏ដោយ ចាំបាច់ឱ្យមានលទ្ធភាពក្នុងការសួរសាមីភាគីដែលជាប្រធាននៃនីតិវិធីបណ្តឹងផង ភស្តុតាងដ៏សំខាន់ផង អំពីស្ថានភាពជុំវិញ ឬ មតិរបស់ខ្លួន ។ ហេតុដូច្នេះ មាត្រានេះ ចែងថា តុលាការអាចបង្គាប់ឱ្យសាមីភាគីបង្ហាញខ្លួនបាន ។

Rules of Civil Procedure (Japan)
**Article 224** (Order of appearance of party itself)
The court may order the party itself or its legal representative to appear even if an advocate is appointed.

**មាត្រា ២៣១.-** ការកម្រិតនូវការពិនិត្យភស្តុតាង

ការពិនិត្យភស្តុតាង អាចធ្វើបានចំពោះតែភស្តុតាងដែលអាចពិនិត្យបានភ្លាមៗប៉ុណ្ណោះ ។

(កំណត់)

មាត្រានេះចែងដូចគ្នានឹងមាត្រា 371 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។

យើងកំណត់អំពីភស្តុតាងដែលអាចពិនិត្យបានភ្លាមៗ នៅក្នុងមាត្រា ១៣១ (សេចក្តីបញ្ជាក់ដំបូង Preliminary Showing, Glaubhaftmachung) ។ សូមមើលកំណត់នៃមាត្រា ១៣១ ។

Code of Civil Procedure (Japan)
**Article 371** (Restriction upon examination of evidence)
Examination of evidence may be conducted only with respect to evidence which can be examined immediately.

**មាត្រា ២៣២.-** ការស្នើសុំសាកសួរសាក្សី និង ការសាកសួរសាក្សី

១- ភាគីមិនចាំបាច់ដាក់ឯកសារដែលកំណត់អំពីចំណុចត្រូវសាកសួរឡើយ នៅពេលដែលស្នើសុំសាកសួរសាក្សី ។

២- តុលាការអាចសាកសួរសាក្សីបាន ដោយមិនចាំបាច់ឱ្យធ្វើសម្បថ ។

(កំណត់)

កថាខណ្ឌទី ១ ចែងដូចគ្នានឹងមាត្រា 225 នៃបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។

កថាខណ្ឌទី ១ ជាករណីលើកលែងនៃកថាខណ្ឌទី ២ មាត្រា ១៣៨ (វិធីសាកសួរសាក្សី) ។

កថាខណ្ឌទី ២ ចែងដូចគ្នានឹងកថាខណ្ឌទី 1 មាត្រា 372 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។

ដោយនីតិវិធីនៃការដោះស្រាយរឿងក្តីដែលមានទឹកប្រាក់តិច ត្រូវធ្វើដោយឆាប់រហ័ស នោះសម្បថរបស់សាក្សីមិនចាំបាច់ធ្វើក៏បានដែរ ។ ការកំណត់ឱ្យសាក្សីស្បថ ឬ មិនឱ្យស្បថ គឺអាស្រ័យលើតុលាការជាអ្នកពិនិត្យទៅលើសាក្សីនោះ ។

Rules of Civil Procedure (Japan)
**Article 225** (Offer of examination of witness)
When offering examination of witness, a document in which examined matters are recorded need not be submitted.

Code of Civil Procedure (Japan)
**Article 372** (Examination of witness, etc.) (excerpt)
1. The examination of a witness may be made without administrating an oath.

**មាត្រា ២៣៣.–** ការផ្ទេរបណ្ដឹងទៅនីតិវិធីធម្មតា ដោយសេចក្ដីថ្លែងការណ៍របស់ចុងចម្លើយ

១- ចុងចម្លើយអាចធ្វើសេចក្ដីថ្លែងការណ៍ឱ្យផ្ទេរបណ្ដឹងទៅនីតិវិធីធម្មតាបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលចុងចម្លើយនោះបានឆ្លើយទាញហេតុផលនៅកាលបរិច្ឆេទដំបូងសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ។

២- សេចក្ដីថ្លែងការណ៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ លើកលែងតែករណីដែលធ្វើនៅក្នុងកាលបរិច្ឆេទ ។

៣- នៅពេលដែលមានសេចក្ដីថ្លែងការណ៍ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្រឡាបញ្ជីត្រូវជូនដំណឹងទៅដើមចោទភ្លាម អំពីការដែលផ្ទេរបណ្ដឹងនេះទៅនីតិវិធីធម្មតាវិញ ដោយសេចក្ដីថ្លែងការណ៍នោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសេចក្ដីថ្លែងការណ៍នោះត្រូវបានធ្វើឡើង នៅកាលបរិច្ឆេទដែលដើមចោទបានបង្ហាញខ្លួន ។

(កំណត់)

មាត្រានេះចែងអំពីការផ្ទេរបណ្ដឹងទៅនីតិវិធីធម្មតាដោយសេចក្ដីថ្លែងការណ៍របស់ចុងចម្លើយ ដែលចែងប្រហាក់ប្រហែលគ្នាជាមួយនឹងកថាខណ្ឌទី 1 និង ទី 2 នៃមាត្រា 373 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ព្រមទាំងកថាខណ្ឌទី 1 និងកថាខណ្ឌទី 2 នៃមាត្រា 228 នៃបទប្បញ្ញត្តិស្ដីពីនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។

ក្រោយពេលចុងចម្លើយធ្វើសេចក្ដីថ្លែងការណ៍ឱ្យផ្ទេរបណ្ដឹងទៅនីតិវិធីធម្មតាហើយ នោះចុងចម្លើយមិនអាចដកសេចក្ដីថ្លែងការណ៍នោះវិញបានទេ ។

ដើមចោទមានសិទ្ធិជ្រើសរើសការប្ដឹងចុងចម្លើយ នូវនីតិវិធីរឿងក្ដីចំនួនទឹកប្រាក់តិច រីឯចុងចម្លើយមានសិទ្ធិប្ដឹងសុំទាមទារឱ្យតុលាការផ្ទេរបណ្ដឹងពីនីតិវិធីរឿងក្ដីចំនួនទឹកប្រាក់តិច ទៅនីតិវិធីធម្មតាបាន ។ ប៉ុន្តែ បើចុងចម្លើយបានធ្វើការឆ្លើយទាញហេតុផល នៅកាលបរិច្ឆេទដំបូងសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ចុងចម្លើយមិនអាចផ្ទេរនីតិវិធីនោះទៅនីតិវិធីធម្មតាបានឡើយ ។

Code of Civil Procedure (Japan)
**Article 373** (Transfer to ordinary procedures) (excerpt)
1. The defendant may make a statement setting forth that the litigation is to be transferred to ordinary procedures. However, this shall not apply after the defendant proceeded with argument on the first date set for oral argument nor after such date has concluded.
2. The litigation shall be transferred to ordinary procedures at the time the statement referred to in the preceding paragraph is made.

Rules of Civil Procedure (Japan)
**Article 228** (Transfer to ordinary procedures / The Code Article 373) (excerpt)
1. A statement of the defendant setting forth that the litigation is to be transferred to ordinary procedures shall, except for cases where it is made on an appointed date, be made in writing.
2. In cases where a statement referred to in the preceding paragraph has been made, the court clerk shall promptly give notice of the fact that the litigation has been transferred to ordinary procedures to the plaintiff. However, this shall not apply to cases where the statement has been made on an appointed date on which the plaintiff has appeared.

**មាត្រា ២៣៤.~** ការផ្ទេរបណ្ដឹងទៅនីតិវិធីធម្មតា ដោយដីកាសម្រេចរបស់តុលាការ

១- តុលាការត្រូវចេញដីកាសម្រេចដែលសម្រេចថា ការជំនុំជម្រះ និង ការសម្រេចសេចក្ដីលើបណ្ដឹងត្រូវធ្វើតាមនីតិវិធីធម្មតា ក្នុងករណីដូចខាងក្រោមនេះ :

- **ក**- ពេលដែលដើមចោទបានស្នើសុំឱ្យជំនុំជម្រះ និង សម្រេចសេចក្ដីតាមនីតិវិធីនៃបណ្ដឹងរឿងក្ដីចំនួនទឹកប្រាក់តិច ដោយផ្ទុយពីបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ២២៤ (ល័ក្ខខ័ណ្ឌនៃបណ្ដឹងរឿងក្ដីចំនួនទឹកប្រាក់តិច ជាអាទិ៍) ។
- **ខ**- ពេលដែលតុលាការមិនអាចកោះហៅចុងចម្លើយ តាមកាលបរិច្ឆេទដំបូងសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ប្រសិនបើការកោះហៅនោះពុំធ្វើដោយការបញ្ជូនតាមការផ្សាយជាសាធារណៈ ។
- **គ**- ពេលដែលតុលាការយល់ឃើញថា ការជំនុំជម្រះ និង សម្រេចសេចក្ដីតាមនីតិវិធីនៃបណ្ដឹងរឿងក្ដីចំនួនទឹកប្រាក់តិចនោះ មិនសមរម្យ ។

២- នៅពេលដែលមានដីកាសម្រេចដូចមានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្រឡាបញ្ជីត្រូវជូនដំណឹងអំពីការណ៍នេះទៅភាគីភ្លាម ។

(កំណត់)

មាត្រានេះចែងអំពីការផ្ទេរបណ្ដឹងទៅនីតិវិធីធម្មតាដោយដីកាសម្រេចរបស់តុលាការ ដែលចែងប្រហាក់ប្រហែលគ្នានឹងមាត្រា 373 កថាខណ្ឌទី 3 ទៅ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រមទាំងមាត្រា 228 កថាខណ្ឌទី 3 នៃបទប្បញ្ញត្តិស្ដីពីនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។ ពាក្យ "មិនសមរម្យ" នៅក្នុងចំណុច **គ** សំដៅទៅលើករណីដូចជាមានភស្តុតាងដែលត្រូវពិនិត្យនៅក្រៅតុលាការ ឬ ត្រូវការអ្នកជំនាញ ជាដើម ។

Code of Civil Procedure (Japan)
**Article 373** (Transfer to ordinary procedures) (excerpt)
3. In the following cases, the court shall render a ruling that the trial and decision of the litigation shall be conducted by ordinary procedures:
  i. in cases where a demand for a trial and decision in an action on a small claim has been made in contravention of the provisions of Article 368, paragraph 1;
  ii. in cases where notice to be submitted in accordance with the provisions of Article 368, paragraph 3 was ordered submitted within a proper designated period, and such notice was not submitted;
  iii. in cases where summons to appear on the first date set for oral argument cannot be made on the defendant other than by means of service by publication of notice;
  iv. in cases where it is deemed improper to carry out a trial and decision in an action on a small claim.
4. No appeal may be made against the ruling referred to in the preceding paragraph.
5. In the cases where the litigation is transferred to ordinary procedures, a date designated previously for an action on a small claim shall be deemed designated for the ordinary procedures.

Rules of Civil Procedure (Japan)
**Article 228** (Transfer to ordinary procedures / The Code Article 373) (excerpt)
3. in cases where the court has rendered a ruling that the trial and decision of the litigation are to be conducted by ordinary procedures, the court clerk shall promptly give notice of that fact to the parties.

## មាត្រា ២៣៥.\- ពេលនៃការផ្ទេរបណ្ដឹងទៅនីតិវិធីធម្មតា ជាអាទិ៍

១- នៅពេលដែលមានសេចក្ដីថ្លែងការណ៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៣៣ (ការផ្ទេរបណ្ដឹងទៅនីតិវិធីធម្មតា ដោយសេចក្ដីថ្លែងការណ៍របស់ចុងចម្លើយ) ឬ ដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៣៤ (ការផ្ទេរបណ្ដឹងទៅនីតិវិធីធម្មតា ដោយដីកាសម្រេចរបស់តុលាការ) នៃក្រមនេះ បណ្ដឹងត្រូវបានផ្ទេរទៅនីតិវិធីធម្មតា ។

២- នៅពេលដែលបណ្ដឹងត្រូវបានផ្ទេរទៅនីតិវិធីធម្មតា កាលបរិច្ឆេទដែលបានកំណត់រួចហើយសម្រាប់បណ្ដឹងនៃរឿងក្ដីចំនួនទឹកប្រាក់តិច ត្រូវចាត់ទុកថា បានកំណត់សម្រាប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៃនីតិវិធីធម្មតា ។

(កំណត់)

កថាខណ្ឌទី ១ មានអត្ថន័យដូចគ្នានឹងមាត្រា 373 កថាខណ្ឌទី 2 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

នៅពេលតុលាការសម្រេចផ្ទេរបណ្ដឹងរឿងក្ដីទឹកប្រាក់តិច ទៅនីតិវិធីធម្មតាវិញ ដោយឆន្ទានុសិទ្ធិ ភាគីមិនអាចប្ដឹងឧបាស្រ័យបានទេ ។

កថាខណ្ឌទី ២ ដែលមានចែងដូចនេះ គឺកុំឱ្យកាលបរិច្ឆេទដែលបានកំណត់រួចហើយ សម្រាប់បណ្ដឹងនៃរឿងក្ដីចំនួនទឹកប្រាក់តិចនៅទំនេរចោល ។

Code of Civil Procedure (Japan)
**Article 373** (Transfer to ordinary procedures) (excerpt) > *see the note for Article 233*

## មាត្រា ២៣៦.\- សាលក្រម និង ការប្រកាសសាលក្រម

១- តុលាការត្រូវប្រកាសសាលក្រមភ្លាម ក្រោយពេលដែលការទាញហេតុផលដោយផ្ទាល់មាត់បានបញ្ចប់ លើកលែងតែករណីដែលយល់ឃើញថាមិនសមរម្យ ។

២- ក្នុងករណីដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ ការប្រកាសសាលក្រមអាចធ្វើឡើងបាន ដោយមិនចាំបាច់ផ្អែកលើច្បាប់ដើមនៃមូលសាលក្រមឡើយ ។ ក្នុងករណីនេះ តុលាការត្រូវប្រកាសសាលក្រម ដោយប្រាប់សេចក្ដីសម្រេចបញ្ចប់ និង ខ្លឹមសារនៃសំអាងហេតុ ។

៣- នៅពេលធ្វើការប្រកាសសាលក្រម ដោយអនុលោមតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ តុលាការត្រូវឱ្យក្រឡាបញ្ជីកត់ត្រានូវហេតុដែលបានកំណត់ក្នុងចំណុចនីមួយៗខាងក្រោមនេះ ក្នុងកំណត់ហេតុនៃកាលបរិច្ឆេទសម្រាប់

ការទាញហេតុផលដោយផ្ទាល់មាត់ដែលតុលាការប្រកាសសាលក្រម ជំនួសការធ្វើលិខិតសាលក្រម :

**ក**- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

**ខ**- សាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ ។

**គ**- សេចក្តីសម្រេចបញ្ចប់ ។

៤- នៅលើលិខិតសាលក្រមនៃរឿងក្តីចំនួនទឹកប្រាក់តិច ឬ លើកំណត់ហេតុជំនួសលិខិតសាលក្រមនោះ ត្រូវសរសេរថាជាសាលក្រមនៃរឿងក្តីចំនួនទឹកប្រាក់តិច ។

(កំណត់)

មាត្រានេះចែងប្រហាក់ប្រហែលគ្នាជាមួយនឹងមាត្រា 374 នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រមទាំងមាត្រា 229 នៃបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។

ជាឧទាហរណ៍នៃ "ករណីដែលយល់ឃើញថាមិនសមរម្យ" ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ មានករណីនៃការសាកល្បងផ្សះផ្សា ក្រោយពីការជំនុំជម្រះបានបញ្ចប់ហើយ ជាដើម ។

Code of Civil Procedure (Japan)
**Article 374** (Pronouncement of judgment)
1. Except for cases deemed improper, the pronouncement of judgment shall be made immediately subsequent to the conclusion of oral argument.
2. In the cases referred to in the preceding paragraph, the pronouncement of a judgment may be made without being founded upon an original judgment paper. The provisions of Article 254, paragraph 2 and Article 255 shall apply *mutatis mutandis* to such cases.

Rules of Civil Procedure (Japan)
**Article 229** (Judgment / The Code Article 374)
1. A judgment paper or record in lieu of judgment paper in an action on a small claim shall include the fact that it its on a judgment in an action on a small claim.
2. The provisions of Article 155 (Method of pronouncement of judgment), paragraph 3 shall apply *mutatis mutandis* to cases where the pronouncement of a judgment is made without being founded upon an original judgment paper in an action on a small claim.

**មាត្រា ២៣៧.**- ការពន្យារពេលបង់ប្រាក់ដោយសាលក្រម

១- ក្នុងករណីដែលតុលាការចេញសាលក្រមទទួលស្គាល់ការទាមទាររបស់ដើមចោទ បើយល់ឃើញថា ចាំបាច់ពិសេសដោយគិតពិចារណានូវលទ្ធភាពទ្រព្យធន និង ស្ថានភាពផ្សេងទៀតរបស់ចុងចម្លើយ នោះតុលាការអាចកំណត់ចំណុច **ក** ឬ ចំណុច **ខ** ឬ កំណត់ចំណុច **គ** ដោយកំណត់ជាមួយគ្នានឹងចំណុច **ក** ឬ ចំណុច **ខ** ចំពោះការសងប្រាក់ អំពីការទាមទារដែលតុលាការទទួលស្គាល់ ក្នុងអំឡុងពេលមិនលើសពី ៣ (បី) ឆ្នាំ បន្ទាប់ពីថ្ងៃដែលតុលាការប្រកាសសាលក្រម :

**ក**- កំណត់ពេលបង់ប្រាក់ ។

ខ- កំណត់ការបង់ប្រាក់ដោយកាត់សងបណ្ដើរៗ ។

គ- នៅពេលដែលសងតាមបញ្ញត្តិនៃចំណុច ក ឬ ពេលដែលសងដោយមិនបាត់បង់តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងក្រោមនេះ នូវផលប្រយោជន៍នៃកំណត់ពេលដែលបានកំណត់នៅចំណុច ខ កំណត់ការអនុគ្រោះ ចំពោះកាតព្វកិច្ចនៃការសងការខូចខាតដោយសារការយឺតយ៉ាវ ក្រោយពេលដាក់ពាក្យបណ្ដឹង ។

២- នៅពេលដែលធ្វើការកំណត់ការបង់ប្រាក់ ដោយកាត់សងបណ្ដើរៗដែលបានកំណត់ក្នុងចំណុច ខ នៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវកំណត់អំពីការបាត់បង់ផលប្រយោជន៍នៃពេលកំណត់ក្នុងករណីដែលចុងចម្លើយមិនសង ។

(កំណត់)

មាត្រានេះប្រហាក់ប្រហែលគ្នាជាមួយនឹងមាត្រា 375 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។ ប៉ុន្តែ បានកែប្រែរបៀបចែង ។

បញ្ញត្តិនេះមានគោលបំណងជម្រុញឱ្យចុងចោទអនុវត្តខ្លឹមសារនៃសាលក្រមដោយស្ម័គ្រចិត្ត ។

នៅក្នុងវិវាទរដ្ឋប្បវេណី ភាគីឈ្នះក្ដីត្រូវការប្រមូលបំណុលរបស់គាត់ ឱ្យបានគ្រប់ចំនួន ។ មាត្រានេះផ្ដល់ឆន្ទានុសិទ្ធិឱ្យតុលាការអាចពន្យារពេលឱ្យភាគីចាញ់ក្ដីសងប្រាក់ទៅភាគីឈ្នះក្ដី ឬ កាត់សងតាមខែបាន ។ ការផ្ដល់ឆន្ទានុសិទ្ធិឱ្យតុលាការ ពីព្រោះតុលាការដឹងអំពីស្ថានភាព និង ជីវភាពរបស់ចុងចម្លើយ នៅពេលដែលចុងចម្លើយបាន បង្ហាញហេតុផលនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ។ នៅពេលដែលតុលាការសម្រេចអំពីការកាត់សងបណ្ដើរៗ តុលាការត្រូវកំណត់ទុកជាមុនឱ្យចុងចម្លើយបង់សងបន្ថែមនូវការខូចខាតផលប្រយោជន៍នៃការកំណត់ពេល ប្រសិនបើអ្នកចាញ់ក្ដីមិនអនុវត្តទៅតាមការសម្រេចរបស់តុលាការទេនោះ ។

Code of Civil Procedure (Japan)
**Article 375** (Deferment of payment by judgment)
1. In cases where the court renders a judgment which authorizes a claim, upon determining it specially necessary to do so in consideration of the defendant's financial means or any other circumstances, with respect to the payment of money regarding an authorized claim, the court may designate a provisions of time for the payment or installment payments within a frame not to exceed three years of the day of pronouncement of the judgment, or, in addition to such provision, may designate a provision exempting the defendant from the obligation to pay indemnification of damages for delay occurring subsequent to fling the suit if the defendant pays in accordance with the designated time or pays without losing, by virtue of the provision under the following paragraph, benefit of the term designated for installment payments.
2. Upon designation of the installment payments referred to in the preceding paragraph, a provision shall be designated regarding the loss of benefit of the term in cases where the defendant defaults on a payment.
3. No appeal may be made against a decision relating to the provisions under the preceding two paragraphs.

## **មាត្រា ២៣៨.-** ការហាមឃាត់ចំពោះឧបាស្រ័យ

ចំពោះសាលក្រមចុងក្រោយនៃរឿងក្ដីចំនួនទឹកប្រាក់តិច មិនអាចធ្វើឧបាស្រ័យបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះបណ្ដឹងទាស់ ។

(កំណត់)

មាត្រានេះចែងប្រហាក់ប្រហែលគ្នាជាមួយនឹងមាត្រា 377 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។

នៅក្នុងនីតិវិធីបណ្តឹងរឿងក្តីទឹកប្រាក់តិច ក្រឡាបញ្ជីត្រូវប្រគល់ទៅភាគីនូវលិខិតដែលពន្យល់អំពីនីតិវិធីនេះ ហើយតុលាការក៏ពន្យល់អំពីនីតិវិធីនេះ នៅកាលបរិច្ឆេទដំបូងដែរ ដូច្នេះ មាត្រានេះមិនអនុញ្ញាតឱ្យភាគីប្តឹងឧទ្ធរណ៍ ។ ម្យ៉ាងវិញទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា យើងមានតែសាលាឧទ្ធរណ៍មួយ និង តុលាការកំពូលមួយ បើយើងអនុញ្ញាតឱ្យគូភាគីប្តឹងឧទ្ធរណ៍ នូវរឿងក្តីដែលមានទឹកប្រាក់តិចនោះ សាលាឧទ្ធរណ៍ និង តុលាការកំពូលនឹងត្រូវបំពេញភារកិច្ចជាច្រើន ។ ប៉ុន្តែ មាត្រានេះ អនុញ្ញាតឱ្យគូភាគីប្តឹងទាស់នឹងសេចក្តីសម្រេចសាលក្រមកំបាំងមុខបាន ។

Code of Civil Procedure (Japan)
**Article 377** (Prohibition of *koso*-appeal)
A *koso*-appeal may not be made against the final judgment in an action on a small claim.

**មាត្រា ២៣៩.-** បញ្ញត្តិដែលមិនអនុវត្ត

បញ្ញត្តិពីមាត្រា ១០៣ (គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) ដល់មាត្រា ១១២ (ការប្តឹងតវ៉ាចំពោះសេចក្តីកត់ត្រានៃកំណត់ហេតុ ស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជាអាទិ៍) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះនីតិវិធីនៃរឿងក្តីចំនួនទឹកប្រាក់តិចដែលបានកំណត់នៅក្នុងជំពូកទី ៧ នេះ ។

(កំណត់)

គោលបំណងនៃមាត្រានេះ គឺការមិនអនុវត្តបញ្ញត្តិនៃការសាកល្បងផ្សះផ្សាជាមុន (មាត្រា ១០៤ (ការសាកល្បងផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល)) និង បញ្ញត្តិផ្សេងទៀតស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (ផ្នែកទី ៣ (នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) ជំពូកទី ២ គន្ថីទី ២) ជាដើម ចំពោះរឿងក្តីចំនួនទឹកប្រាក់តិច ។

# ជំពូកទី ៨ កាលបរិច្ឆេទ អំឡុងពេល និង ការបញ្ជូន

## ផ្នែកទី ១ កាលបរិច្ឆេទ និង អំឡុងពេល

**មាត្រា ២៤០.-** ការកំណត់កាលបរិច្ឆេទ

១- តុលាការត្រូវកំណត់កាលបរិច្ឆេទ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិ ។ ប៉ុន្តែ ចំពោះកាលបរិច្ឆេទនៃនីតិវិធីដែលត្រូវបានធ្វើឡើងដោយចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ ចៅក្រមនោះជាអ្នកកំណត់ ។

២- ក្នុងករណីដែលមិនអាចជៀសវាងបាន កាលបរិច្ឆេទនេះអាចកំណត់យកថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សម្រាកផ្សេងទៀតដែលកំណត់ដោយច្បាប់ ឬ បទដ្ឋានគតិយុត្តបាន ។

( កំណត់)

(1) សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 93 និង បទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 35 ។

(2) ការកំណត់កាលបរិច្ឆេទគឺជាការមួយមានសារៈសំខាន់ណាស់ ដើម្បីធ្វើឱ្យនីតិវិធីបណ្តឹងនោះ មានដំណើរការល្អ ។ មាត្រាបានយក "ការដឹកនាំបណ្តឹងគឺជាតួនាទីរបស់តុលាការ" មកធ្វើជាមូលដ្ឋាន ( គោលការណ៍ដឹកនាំបណ្តឹងដោយឆន្ទានុសិទ្ធិ) ហេតុនេះហើយ បានចែងថា ជាគោលការណ៍ ការកំណត់កាលបរិច្ឆេទ គឺជាសិទ្ធិអំណាចរបស់តុលាការ ។

(3) ករណីដែលមិនអាចជៀសវាងបាន មានដូចជា ករណីដែលអ្នកជំនាញ ឬ សាក្សីដែលត្រូវសាកសួរ អាចចូលមកតុលាការតែនៅថ្ងៃសៅរ៍ ឬ ថ្ងៃអាទិត្យ ឬ ករណីដែលការចុះត្រួតពិនិត្យអាចធ្វើទៅបានតែនៅថ្ងៃសៅរ៍ ឬ ថ្ងៃអាទិត្យប៉ុណ្ណោះ ។

Code of Civil Procedure (Japan)
**Article 93** (Designation and change of date)
1. Dates shall be designated by the presiding judge upon motion or upon such judge's own authority.
2. A Sunday or an other general holiday may be designated as a date only in unavoidable instances.
3. A change in the date set for oral argument and preparations for argument proceedings shall only be permitted where evident reasons exist. However, a change in the initial date shall also be permitted upon agreement between the parties.
4. Notwithstanding the provisions of the preceding paragraph, a change in the date set for oral argument in a case in which the prepataions for argument proceedings have been completed shall only be permitted where unavoidable reasons exist.

Rules of Civil Procedure (Japan)
**Article 35** (Designation of date by commissioned judge, etc. / The Code Article 93)
Dates on which proceedings are carried out by a commissioned or assigned judge shall be designated by such judge.

**មាត្រា ២៤១.-** ការប្តូរកាលបរិច្ឆេទ

១- បើភាគីបានដាក់ពាក្យសុំឱ្យប្តូរកាលបរិច្ឆេទ ភាគីនោះត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ អំពីមូលហេតុដែលការប្តូរកាលបរិច្ឆេទនោះត្រូវធ្វើជាចាំបាច់ ។

២- ការប្តូរកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ មិនត្រូវបានអនុញ្ញាតទេ លើកលែងតែករណីដែលមានមូលហេតុមិនអាចជៀសវាងបាន ។

៣- ការប្តូរកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង អាចអនុញ្ញាតឱ្យបាន ប្រសិនបើមានការព្រមព្រៀងគ្នាពីសំណាក់គូភាគី ។

( កំណត់)

(1) សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 93 បទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 36 និង 37 ។

(2) ប្រសិនបើយក "គោលការណ៍ដឹកនាំសវនាការដោយឆន្ទានុសិទ្ធិ" មកធ្វើជាមូលដ្ឋាន ជាទូទៅ កាលបរិច្ឆេទមិនត្រូវអនុញ្ញាតឱ្យប្តូរតាមឆន្ទៈគូភាគីទេ ។ មាត្រានេះចែងអំពីការប្តូរកាលបរិច្ឆេទក្នុងករណីពិសេសតែប៉ុណ្ណោះ ។

(3) តាមក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ការប្តូរកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ក៏ត្រូវបានអនុញ្ញាតដោយមាន "មូលហេតុជាក់លាក់ (evident reasons)" ផងដែរ ទោះបីជាមូលហេតុនេះ មិនមែនជា "មូលហេតុដែលមិនអាចជៀសវាងបាន" ក៏ដោយ ។ ប៉ុន្តែ ក្នុងក្រមនេះ ត្រូវធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាមុនសិន (សូមមើលមាត្រា ១១៣ (ការកំណត់កាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់)) ហើយម្យ៉ាងទៀតនៅប្រទេសជប៉ុន មូលហេតុទាំង ២ ប្រភេទនេះមានការពិបាកចែកឱ្យបានដាច់ស្រេចណាស់ ហេតុនេះហើយបានជាក្រមនេះទទួលស្គាល់តែការប្តូរកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដំបូងតែប៉ុណ្ណោះ ក្រៅពីនេះដើម្បីប្តូរកាលបរិច្ឆេទ ត្រូវមានមូលហេតុដែលមិនអាចជៀសវាងបាន ។

(4) ចំពោះការប្តូរកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង ទោះបីជាគ្មានមូលហេតុដែលមិនអាចជៀសវាងក៏ដោយ ឱ្យតែគូភាគីទាំងសងខាងយល់ព្រម អាចប្តូរបាន (កថាខណ្ឌទី ៣ នៃមាត្រានេះ) ។ នេះគឺដោយសារតែពេលដែលដើមចោទបានដាក់ពាក្យបណ្តឹងទៅតុលាការ ហើយតុលាការបានកំណត់កាលបរិច្ឆេទលើកដំបូងនេះ បន្ទាប់ពីបានពិនិត្យពាក្យបណ្តឹង ដោយមិនបានទាក់ទងនឹងចុងចម្លើយជាមុន ហេតុនេះហើយ ដើម្បីការពារផលប្រយោជន៍ចុងចម្លើយ ត្រូវចែងឱ្យបានធូរជាងធម្មតា ។

<u>Code of Civil Procedure (Japan)</u>
**Article 93** (Designation and change of date) > see the note for Article 240

<u>Rules of Civil Procedure (Japan)</u>
**Article 36** (Motion for change of date / The Code Article 93)
A motion for change in the appointed date shall clearly indicate the reason for which the change of date is necessary.
**Article 37** (Limitation on change of date / The Code Article 93)
A change in the appointed date shall not be permitted for the following reasons. However, this shall not apply to cases where unavoidable reasons also exist:

i. in cases where there are several advocates for wither of the parties, reasons for change have occurred with regard to one or more but not all of the advocates;
ii. reasons that, after such date was designated, the same date and time was designated for another case [in which the same party or advocate is involved].

## មាត្រា ២៤២.~ ការកោះហៅតាមកាលបរិច្ឆេទ

ការកោះហៅតាមកាលបរិច្ឆេទ ត្រូវធ្វើដោយបញ្ជូនដីកាកោះ ឬ ដោយជូនដំណឹងអំពីកាលបរិច្ឆេទ ទៅអ្នកដែលបានបង្ហាញខ្លួននៅតុលាការចំពោះបណ្តឹងដែលពាក់ព័ន្ធ ។

(កំណត់)

(1) សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 94 ។

(2) ការ "ជូនដំណឹងអំពីកាលបរិច្ឆេទ ទៅអ្នកដែលបានបង្ហាញខ្លួននៅតុលាការចំពោះបណ្តឹងដែលពាក់ព័ន្ធ" មានន័យថា តុលាការត្រូវប្រាប់ដោយផ្ទាល់មាត់អំពីកាលបរិច្ឆេទនោះ ។

(3) ក្រៅពីការចែងក្នុងមាត្រានេះ មានវិធីផ្សេងទៀតដែលងាយស្រួលជាងដែរ (សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 94) ឧទាហរណ៍ដូចជា ការប្រកាសតាមទូរស័ព្ទ តាមសំបុត្រប្រៃសណីយ៍ធម្មតា ឬ តាមរយៈបុគ្គលិកនៃការិយាល័យមេធាវី ជាដើម ក៏អាចទទួលស្គាល់បានដែរទៅអនាគត ។

Code of Civil Procedure (Japan)
**Article 94** (Summons to appear on date)
1. A summons to appear on an appointed date shall be made by serving a writ of summons, by informing a person who has already appeared in the case concerned, or by any other means deemed proper.
2. In cases where a summons to appear on an appointed date has been made by any means other than serving a writ of summons or informing a person who has already appeared in the case concerned, legal sanctions and other disadvantages due to nonappearance in court may not by imposed on any party, witness or expert witness who has not appeared in court on such date. However, this shall not apply to such a person who has submitted a document mentioning the receipt of a summons to appear on an appointed date.

**មាត្រា ២៤៣.-** ការគណនាអំឡុងពេល

១- ការគណនាអំឡុងពេល ត្រូវធ្វើតាមបញ្ញត្តិស្តីពីអំឡុងពេលនៃក្រមរដ្ឋប្បវេណី ។

២- ក្នុងការសម្រេចសេចក្តីដែលកំណត់អំឡុងពេល បើពុំបានកំណត់ពេលចាប់ផ្តើមទេ អំឡុងពេលនោះ ត្រូវគិតចាប់ពីពេលដែលអានុភាពនៃការសម្រេចសេចក្តីនោះមានដំណើរការឡើង ។

៣- ប្រសិនបើថ្ងៃចុងក្រោយនៃអំឡុងពេល ត្រូវនឹងថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សម្រាកដែលច្បាប់ ឬ បទដ្ឋានគតិយុត្តបានកំណត់ អំឡុងពេលនោះត្រូវចប់ នៅថ្ងៃបន្ទាប់ពីថ្ងៃឈប់នោះ ។

(កំណត់)

(1) សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 95 ។

(2) បើមានថ្ងៃខ្លះច្បាប់ពុំបានកំណត់ថាជាថ្ងៃឈប់ទេ ប៉ុន្តែ តាមធម្មតា គេមិនធ្វើនីតិវិធីនៃការសម្រេចសេចក្តីនៅថ្ងៃនោះទេ (ឧទាហរណ៍ៈដូចជានៅជប៉ុន គឺថ្ងៃទី ២ និង ៣ ខែ មករា ថ្ងៃទី ២៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ជាថ្ងៃឈប់ដែលច្បាប់មិនបានកំណត់) យើងចាំបាច់ត្រូវចែងក្នុងកថាខណ្ឌទី ៣ ។

(3) នៅក្នុងសិក្ខាសាលាលើកទី ១០ (ខែ កក្កដា ឆ្នាំ ២០០១) មានមតិជាច្រើនថា ការចែង "ថ្ងៃឈប់សម្រាកដែលច្បាប់បានកំណត់" នេះ វាចង្អៀតពេក ហើយចង់ឱ្យចែងថា "ថ្ងៃឈប់សម្រាកផ្លូវការ" ឬ "ថ្ងៃឈប់សម្រាកដែលច្បាប់ ឬ បទដ្ឋានគតិយុត្តបានកំណត់" ។ ហើយដោយហេតុថា នៅប្រទេសកម្ពុជា មានការបន្ថែមថ្ងៃឈប់សម្រាក ជារឿយៗនោះ យើងបានកែពាក្យនៅក្នុងកថាខណ្ឌទី ៣ ។

(4) ឧទាហរណ៍នៃកថាខណ្ឌទី ២ មានដូចជា ករណីដែលតុលាការចេញដីកាសម្រេចបង្គាប់ឱ្យកែតម្រូវពាក្យបណ្តឹង

ដោយកំណត់អំឡុងពេល តែមិនបានបញ្ជាក់អំពីកាលបរិច្ឆេទនៃការចាប់ផ្តើមគិត ។ ក្នុងករណីនេះ អំឡុងពេលនោះត្រូវគិតចាប់ពីពេលដែលដីកាសម្រេចនោះ ត្រូវបានជូនដំណឹងទៅដើមចោទ ។

<u>Code of Civil Procedure (Japan)</u>
**Article 95** (Calculation of term)
1. Calculation of terms shall be governed by the Civil Code provisions regarding terms.
2. In cases where the time for the commencement of a term has not been designated in the decision which designated such term, the term shall begin to run at the time when such decision takes effect.
3. In cases where the last day of a term falls on a Sunday, Saturday, or national holiday prescribed by the National Holiday Act (Law No. 178, 1948), or January 2, January 3 or December 29 to 31 inclusive, the term shall expire on the following day.

## **មាត្រា ២៤៤.-** ការពន្យារអំឡុងពេល

១- មានតែករណីដែលមិនអាចជៀសវាងបានប៉ុណ្ណោះទេ ទើបតុលាការអាចពន្យារអំឡុងពេលដែលច្បាប់បានកំណត់ ឬ អំឡុងពេលដែលតុលាការបានកំណត់ហើយបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ ។

២- មានតែករណីដែលមិនអាចជៀសវាងបានប៉ុណ្ណោះទេ ទើបចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិអាចពន្យារអំឡុងពេលដែលបានកំណត់ហើយនោះបាន ។

(កំណត់)

(1) សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 96 កថាខណ្ឌទី 1 និង បទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 38 ។

(2) "ករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់" ដែលចែងក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ នេះ មានដូចជា អំឡុងពេលអាចប្តឹងឧទ្ធរណ៍ (មាត្រា ២៦៤ (អំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍)) អំឡុងពេលដែលអាចប្តឹងសាទុក្ខ (មាត្រា ២៨៦ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍)) ។

<u>Code of Civil Procedure (Japan)</u>
**Article 96** (Extension or shortening of term and additional term) (excerpt)
1. The court may extend or shortn a term fixed by law or a term designated by the court itself. However, this shall not apply to a peremptory term.

<u>Rules of Civil Procedure (Japan)</u>
**Article 38** (Extension or shortening of term designated by presiding judge, etc. / The Code Article 96)
The presiding judge, or a commissioned judge or assigned judge may extend or shorten a term he or she designated.

## **មាត្រា ២៤៥.-** ការបំពេញនូវសកម្មភាពបណ្តឹងនៅពេលក្រោយ

១- ក្នុងករណីដែលមិនអាចគោរពតាមអំឡុងពេលដែលបានកំណត់ក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ មាត្រា ២៤៤ (ការពន្យារអំឡុងពេល) ខាងលើនេះ ដោយគ្មានកំហុសរបស់ភាគី ភាគីនោះអាចបំពេញនូវសកម្មភាពបណ្តឹងដែលគួរតែ

បានធ្វើនៅក្នុងអំឡុងពេលនោះបាន ក្នុងអំឡុងពេលតែ ១ (មួយ) សប្តាហ៍ ក្រោយពេលដែលមូលហេតុនោះរលត់ហើយ ។ ប៉ុន្តែ ចំពោះភាគីដែលនៅបរទេសវិញ អំឡុងពេលនោះ មានចំនួន ២ (ពីរ) ខែ ។

២- អំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើ មិនអាចពន្យារបានឡើយ ។

(កំណត់)

(1) សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 97 ។

(2) វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ មាត្រា ២៤៤ (ការពន្យារអំឡុងពេល) ទាមទារឱ្យគោរពតាមអំឡុងពេលដែលមិនអាចពន្យារបាន ដូចជាអំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍ ឬ ប្តឹងសាទុក្ខ ឬ អំឡុងពេលផ្សេងទៀត ដើម្បីចាត់ចែងទំនាក់ទំនងនឹងបណ្តឹងឱ្យមានភាពមិនផ្លាស់ប្តូរ ។ ប៉ុន្តែ មានករណីខ្លះដែលបង្ខំឱ្យគោរពតាមអំឡុងពេលនោះឃើញថាធ្ងន់ហួសហេតុចំពោះភាគីបណ្តឹង ។ មាត្រានេះចែងអំពីវិធីជួយសង្គ្រោះអ្នកទាំងនោះ នៅពេលដែលហួសកំណត់ពេលហើយ ។ ការបញ្ចប់តាមក្រោយនូវសកម្មភាពបណ្តឹង គឺជារបបមួយទទួលស្គាល់សកម្មភាពបណ្តឹងដែលបានធ្វើក្រោយពីការផុតអំឡុងពេល ថា ដូចជាបានធ្វើនៅក្នុងអំឡុងពេលដែលកំណត់ដែរ គឺ ដើម្បីការពារផលប្រយោជន៍របស់ភាគី ។

(3) កថាខណ្ឌទី ២ នៃមាត្រានេះបានចែងយ៉ាងច្បាស់លាស់ថា តុលាការមិនអាចពន្យារអំឡុងពេលដើម្បីឱ្យភាគីអាចបញ្ចប់តាមក្រោយនូវសកម្មភាពបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះបានទេ ។

<u>Code of Civil Procedure (Japan)</u>
**Article 97** (Subsequent completion of act of litigation)
1. In cases where a party was unable to observe the peremptory term due to reasons not imputable to it, such party may subsequently complete the act of litigation which it should conduct in the peremptory term within one week after such reasons have ceased to exist. However, this additional term shall be two months with regard to any party in a foreign country.
2. The provisions of the main clause of paragraph 1 of the preceding article shall not aply to tne term referred to in the preceding paragraph.

## ផ្នែកទី ២ ការបញ្ជូន

**មាត្រា ២៤៦.-** គោលការណ៍នៃការបញ្ជូនដោយឆន្ទានុសិទ្ធិ ជាអាទិ៍

១- ការបញ្ជូនត្រូវធ្វើដោយឆន្ទានុសិទ្ធិ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ ។

២- កិច្ចការបញ្ជូនត្រូវធ្វើឡើងដោយក្រឡាបញ្ជី ។

៣- ការបញ្ជូនត្រូវបានប្រតិបត្តិដោយបុគ្គលិកប្រៃសណីយ៍ អាជ្ញាសាលា ឬ ក្រឡាបញ្ជី ។

(កំណត់)

(1) សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 98 ។

(2) ករណីលើកលែងនៃបញ្ញត្តិនៃកថាខណ្ឌទី ១ គឺជា ការបញ្ជូនតាមការផ្សាយជាសាធារណៈ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៥៥ (ល័ក្ខខ័ណ្ឌដើម្បីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ)

(3) ស្ថាប័នដែលទាក់ទងនឹងការបញ្ជូននេះគឺ ស្ថាប័នទាក់ទងនឹងការងារបញ្ជូន (ស្ថាប័នចាត់ចែងកិច្ចការបញ្ជូន) និង ស្ថាប័នប្រតិបត្តិការបញ្ជូន (ស្ថាប័នប្រតិបត្តិការ) ។ តាមច្បាប់ជប៉ុន ក្រឡាបញ្ជីទទួលបន្ទុកក្នុងនាមជាស្ថាប័នចាត់ចែងកិច្ចការបញ្ជូន ហើយតាមធម្មតា បុគ្គលិកការងារប្រៃសណីយ៍ ឬ មន្ត្រីអនុវត្ត/អាជ្ញាសាលា (ក្នុងករណីពិសេសខ្លះ គឺក្រឡាបញ្ជី) ជាអ្នកទទួលបន្ទុកក្នុងនាមជាស្ថាប័នប្រតិបត្តិការ (ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 99 និង 100) ។

(4) កថាខណ្ឌទី ២ កំណត់ថា កិច្ចការបញ្ជូនត្រូវធ្វើឡើងដោយក្រឡាបញ្ជី ហើយកថាខណ្ឌទី ៣ ចែងថា ការបញ្ជូនត្រូវបានប្រតិបត្តិដោយបុគ្គលិកប្រៃសណីយ៍ អាជ្ញាសាលា ឬ ក្រឡាបញ្ជី ។ ចំពោះស្ថាប័នដែលត្រូវទទួលបន្ទុកនូវការប្រតិបត្តិកិច្ចការបញ្ជូន យើងត្រូវគិតពិចារណា តាមស្ថានភាពនៃការរៀបចំ និង ការប្រព្រឹត្តនៃប្រព័ន្ធប្រៃសណីយ៍ និង ស្ថានភាពនៃការរៀបចំប្រព័ន្ធអាជ្ញាសាលា ជាអាទិ៍ ។

Code of Civil Procedure (Japan)
**Article 98** (Principle of service based on the court's own authority)
1. Except as otherwise provided, service shall be made based on the court's own authority.
2. The court clerk shall administrate the affairs relating to service.
**Article 99** (Officials effecting service)
1. Except as otherwise provided, service shall be made either by mail or by an execution officer.
2. With regard to service by mail, persons engaged in the mailing business shall be deemed to be the official effecting such service.

**មាត្រា ២៤៧.-** គោលការណ៍នៃការបញ្ជូនដោយការប្រគល់

១- ការបញ្ជូនត្រូវធ្វើឡើង ដោយការប្រគល់នូវឯកសារដែលត្រូវបញ្ជូនទៅជនដែលត្រូវទទួលការបញ្ជូននោះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ ។

២- ឯកសារដែលត្រូវបញ្ជូន គឺជាឯកសារចម្លងទាំងអស់ដែលពាក់ព័ន្ធ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ ។

៣- ក្នុងករណីដែលអ្នកទទួលការបញ្ជូនមិនចេះអក្សរ មន្ត្រីទទួលបន្ទុកការបញ្ជូន គប្បីពន្យល់នូវខ្លឹមសារនៃឯកសារនោះ នៅពេលប្រគល់ឯកសារ ។

(កំណត់)

(1) សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 101 និង បទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 40 ។

(2) ការបញ្ជូន ជាគោលការណ៍ គឺត្រូវប្រគល់ឯកសារទៅឱ្យជនដែលត្រូវទទួលការប្រគល់នោះ (មាត្រានេះ) ចំណែកឯ

ករណីលើកលែង គឺមាត្រា ២៥២ (ការបញ្ជូនបង្គ្រប់កិច្ច និង ការបញ្ជូនដោយទុកចោល) និង ចាប់ពីមាត្រា ២៥៥ (ល័ក្ខខ័ណ្ឌដើម្បីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ) ឡើងទៅ ។

(3) ករណីលើកលែងនៃកថាខណ្ឌទី ២ មានដូចជាការកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៩០ (ការបញ្ជូនលិខិតសាលក្រម) ។

(4) ដោយបានទទួលយោបល់នៅក្នុងសិក្ខាសាលាលើកទី ១០ (ខែ កក្កដា ឆ្នាំ ២០០១) យើងបានបន្ថែមកថាខណ្ឌទី ៣ ។ ប៉ុន្តែ ទោះមានកថាខណ្ឌទី ៣ ក៏ដោយ ក៏ការបញ្ជូននឹងកើតមានអានុភាពឡើងដែរ ដោយការប្រគល់ឯកសារទៅអ្នកទទួល ។

<u>Code of Civil Procedure (Japan)</u>
**Article 101** (Principle of service by delivery)
Except as otherwise provided, service shall be effected by means of delivery of the document to be served to the person on whom service is to be made.

<u>Rules of Civil Procedure (Japan)</u>
**Article 40** (Document, etc., to be served / The Code Article 101)
1. Except as otherwise provided, a document which is to be served shall be transcript or a duplicate copy of such document.
2. In cases where a record has been compiled instead of filing a document which is to be served, the service shall be made by delivering a transcript or an excerpt of such record.

**មាត្រា ២៤៨.-** ការបញ្ជូនទៅបុគ្គលអសមត្ថភាពក្នុងបណ្ដឹង ជាអាទិ៍

១- ការបញ្ជូនទៅបុគ្គលអសមត្ថភាពក្នុងបណ្ដឹង ត្រូវធ្វើទៅចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ ។

២- ចំពោះករណីដែលអ្នកមានសិទ្ធិជាតំណាងរួមគ្នាច្រើននាក់ ការបញ្ជូនអាចធ្វើទៅចំពោះតែជនណាម្នាក់ ជាការគ្រប់គ្រាន់ ។

៣- ការបញ្ជូនទៅអ្នកជាប់ពន្ធនាគារ ត្រូវធ្វើទៅចំពោះប្រធានពន្ធនាគារ ។

(កំណត់)

(1) សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 102 ។

<u>Code of Civil Procedure (Japan)</u>
**Article 102** (Service on person without capacity to litigate, etc.)
1. Service on a person without capacity to litigate shall be made on such person's legal representative.
2. In cases where several persons are to jointly exercise representative authority, it shall suffice to effect service on any one of them.
3. Service on a person in prison shall be made on the prison warden.

**មាត្រា ២៤៩.-** កន្លែងបញ្ជូន

ការបញ្ជូនត្រូវធ្វើទៅលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការរបស់ជនដែលត្រូវទទួលការបញ្ជូន ។ ប៉ុន្តែ ចំពោះការបញ្ជូនទៅអ្នកតំណាងដែលច្បាប់បានកំណត់វិញ អាចធ្វើទៅទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការរបស់សាមីខ្លួន

បាន ។

（កំណត់）

(1) សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 103 កថាខណ្ឌទី 1 ។

(2) មាត្រានេះចែងថា ជាទូទៅ ការបញ្ជូនត្រូវធ្វើទៅលំនៅឋាន ជាអាទិ៍ របស់អ្នកដែលត្រូវទទួលការបញ្ជូន ។ សព្វថ្ងៃនេះ ក្នុងគ្រួសារនីមួយៗមានសមាជិកគ្រួសារកាន់តែតិចទៅៗ（ភាគច្រើនមានតែប្ដី ប្រពន្ធ និង កូនម្នាក់ ឬ តិចជាងនេះ）ហើយពេលថ្ងៃ គេចេញទៅធ្វើការទាំងអស់គ្នា អត់មានអ្នកនៅផ្ទះ ក្នុងស្ថានភាពនេះ ការទទួលស្គាល់ឱ្យធ្វើការបញ្ជូនទៅកន្លែងធ្វើការក៏ជាវិធីដោះស្រាយមួយដែរ（ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 103 កថាខណ្ឌទី 2）ក្នុងករណីនេះ បញ្ញត្តិនឹងមានការស្មុគស្មាញកាន់តែខ្លាំងឡើង ។

(3) ជាគោលការណ៍ ការបញ្ជូនត្រូវធ្វើនៅលំនៅឋានរបស់អ្នកដែលត្រូវទទួលការបញ្ជូន（មាត្រា ២៤៩（កន្លែងបញ្ជូន））។ ក្រៅពីនេះ ក៏មានការអនុញ្ញាតការបញ្ជូនតាមការដាក់ពាក្យកំណត់កន្លែងបញ្ជូន ជាដើម（មាត្រា ២៥០（ការជូនដំណឹងអំពីកន្លែងបញ្ជូន ជាអាទិ៍））ការបញ្ជូនទៅកន្លែងជួបប្រទះជនដែលត្រូវទទួលការបញ្ជូននោះ（មាត្រា ២៥១（ការបញ្ជូនទៅកន្លែងជួបប្រទះ））ដែលជាករណីលើកលែង ។

Code of Civil Procedure (Japan)
**Article 103** (Place of service) (excerpt)
1. Service shall be made at the domicile, residence, place of business or office (hereinafter in this section referred to as "domicile, etc.") of the person on whom it is to be made. However, service on a legal representative may also be made at the place of business or office of the principal.

## មាត្រា ២៥០.~ ការជូនដំណឹងអំពីកន្លែងបញ្ជូន ជាអាទិ៍

១- ភាគី ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ អាចជូនដំណឹងអំពីកន្លែងដែលខ្លួន ត្រូវទទួលការបញ្ជូននៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ អ្នកដែលទទួលការបញ្ជូន ទៅតុលាការទទួលបណ្ដឹង ។

២- ភាគី ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ អាចជូនដំណឹងដើម្បីប្ដូរកន្លែងដែលបានជូនដំណឹងថាជាកន្លែងដែលខ្លួនត្រូវទទួលការបញ្ជូន ឬ អ្នកដែលបានជូនដំណឹងថាជាអ្នកទទួលការបញ្ជូននោះបាន ។

៣- ការជូនដំណឹងដែលបានកំណត់ក្នុងកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ។

៤- ទោះជាមានបញ្ញត្តិនៃមាត្រា ២៤៩（កន្លែងបញ្ជូន）ខាងលើនេះក៏ដោយ ប្រសិនបើមានការជូនដំណឹងអំពីកន្លែងដែលត្រូវទទួលការបញ្ជូនតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ក៏ការបញ្ជូនត្រូវធ្វើទៅកន្លែងដែលបានកំណត់ ក្នុងដំណឹងនោះដែរ ។

（កំណត់）

(1) សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 104 និង បទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 41 កថាខណ្ឌទី 1 មាត្រា 42 កថាខណ្ឌទី 1 ។

(2) ការដាក់ពាក្យសុំដែលមានចែងក្នុងមាត្រានេះ អាចធ្វើបានដោយស្ម័គ្រចិត្ត ។ ប្រសិនបើភាគី ជាដើម មិនបានជូនដំណឹងទេ ការបញ្ជូនត្រូវធ្វើទៅលំនៅឋាន ជាអាទិ៍ របស់ជនដែលត្រូវទទួលការបញ្ជូននេះ តាមបញ្ញត្តិនៃមាត្រា ២៤៩ (កន្លែងបញ្ជូន) ។

Code of Civil Procedure (Japan)
**Article 104** (Report of place of service, etc.)
1. The party, legal representative, or advocate shall give notice of the place (being limited to within Japan) where service shall be received, to the court before which the suit has been filed. In such cases, notice of the person who will receive service may also be given.
2. In cases where the notice has been given under the first half of the preceding paragraph, notwithstanding the provisions of the preceding article, service shall be made at the place stated in such notice.
3. On a person who has not given notice under the first half of the paragraph 1, and who previously received service prescribed by either of the following items, notwithstanding the provisions of the preceding article, any subsequent service shall be made at the place designated by the respective applicable items:
i. service in accordance with the provisions of the preceding article......
the place at which the previous service has been made;
ii. service which is made at a post office by a person engaged in the mailing business as such service is in accordance with the provisions of the second half of the following article, and service in accordance with the second half of Article 106, paragraph 1......
the place at which such previous service should have been made according to such previous service;
iii. service in accordance with the provisions of Article 107, paragraph 1, item i......
the place to which such previous service was addressed.

Rules of Civil Procedure (Japan)
**Article 41** (Form of report of place of service, etc. / The Code Article 104) (excerpt)
1. Notice of the place where service shall be received and notice of the person who will receive service [on behalf of the party] shall be given in writing.
**Article 42** (Report of change of place of service, etc. / The Code Article 104) (excerpt)
1. The party, the legal representative or the advocate may give notice to change the place where service shall be received or the person who will receive service ]on behalf of the party].

**មាត្រា ២៥១.-** ការបញ្ជូននៅកន្លែងជួបប្រទះ

ទោះបីមានបញ្ញត្តិដូចមាត្រា ២៤៩ (កន្លែងបញ្ជូន) ខាងលើនេះក៏ដោយ ប្រសិនបើជនដែលត្រូវទទួលការបញ្ជូននោះ ពុំច្បាស់លាស់ថា មានលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការ នៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ការបញ្ជូនអាចធ្វើបាននៅកន្លែងដែលបានជួបប្រទះអ្នកនោះ លើកលែងតែករណីបញ្ជូនចំពោះអ្នកដែលបានជូនដំណឹង តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ២៥០ (ការជូនដំណឹងអំពីកន្លែងបញ្ជូន ជាអាទិ៍) ខាងលើនេះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាដែរ ចំពោះករណីដែលអ្នកដែលមានលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការ ច្បាស់លាស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ អ្នកដែលបានជូនដំណឹងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ២៥០ ដដែលនេះ មិនប្រកែកទទួលការបញ្ជូន ។

(កំណត់)

(1) សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 105 ។

(2) មាត្រានេះ ចែងករណីលើកលែងនៃមាត្រា ២៤៩ (កន្លែងបញ្ជូន) និង មាត្រា ២៥០ (ការជូនដំណឹងអំពីកន្លែងបញ្ជូនជាអាទិ៍) ដែលអនុញ្ញាតឱ្យធ្វើការបញ្ជូននៅកន្លែងដែលបានជួបប្រទះអ្នកដែលត្រូវទទួលការបញ្ជូននោះ ។

Code of Civil Procedure (Japan)

**Article 105** (Service at place the person has been found)

Notwithstanding the provisions of the preceding two articles, service on a person (except for such person who has given notice under the first half of the preceding article, paragraph 1) to whom the service is to be made, and with respect to whom it is not clear whether or not a domicile, etc., exists in Japan may be made at any place where such person is found. The same shall apply to cases where a person who clearly has a domicile, etc., in Japan or a person who has given notive under the first hald of the paragraph does not reject receiving the service.

**មាត្រា ២៥២.-** ការបញ្ជូនបង្គ្រប់កិច្ច និង ការបញ្ជូនដោយទុកចោល

១- ប្រសិនបើមិនបានជួបជនដែលត្រូវទទួលការបញ្ជូន នៅទីកន្លែងដែលត្រូវបញ្ជូនទេ មន្ត្រីទទួលបន្ទុកការបញ្ជូនអាចប្រគល់ឯកសារទៅឱ្យអ្នកបម្រើ ឬ អ្នកផ្សេងដែលធ្វើការនៅទីនោះ ឬ អ្នកនៅជាមួយ ដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនោះបាន ។

២- ប្រសិនបើជនដែលត្រូវទទួលការបញ្ជូន ឬ អ្នកដែលត្រូវទទួលការប្រគល់ឯកសារតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនព្រមទទួលការបញ្ជូនដោយគ្មានមូលហេតុត្រឹមត្រូវ ឯកសារនោះអាចទុកនៅកន្លែងដែលត្រូវបញ្ជូននោះបាន ។

(កំណត់)

(1) សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 106 និង បទប្បញ្ញត្តិស្ដីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 43 ។

(2) "អ្នកដែលមានការយល់ដឹងក្នុងការទទួលឯកសារ" គឺជាអ្នកដែលយល់ច្បាស់អំពីសារៈសំខាន់នៃការបញ្ជូន ឬ យល់នូវលក្ខណៈនៃឯកសារដែលបានទទួល ហើយអាចរំពឹងថាអ្នកនោះមានប្រាជ្ញានឹងយកឯកសារនោះ ទៅឱ្យជនដែលត្រូវទទួលការបញ្ជូនបាន ។ មិនចាំបាច់ជានីតិជន (មនុស្សពេញវ័យ) ទេ ។

Code of Civil Procedure (Japan)

**Article 106** (Supplemental service and service by leaving at place)

1. In cases where a person on whom service is to be made is not found at the place for service other than workplace, the document may be delivered to any employee or any other hired worker or a co-resident who possesses a proper understanding with regard to receiving the document. The same shall apply to cases where the document should be delivered at a post office by a person engaged in the mailing business.

2. In cases where a person on whom service is to be made is not found at the workplace (including cases where the place of which the notice has been given under the first half of Article 104, paragraph 1 is the workplace), when another person referred to in Article 103, paragraph 2 or such person's legal representative or employee or an other hired worker who possesses a proper understanding with regard to receiving the document does not refuse to receive the document, the document may be delivered to that person.

3. In cases where a person on whom service is to be made or a person who is to receive the delivery of a document according to the first half of paragraph 1 has, without justifiable reason, refused to receive such document, the document may be left at such place where the service is to be made.

Rules of Civil Procedure (Japan)

**Article 43** (Notice of supplemental service at workplace / The Code Article 106)
In cases where supplemental service has been made in accordance with the provisions of Article 106 (Supplemental service and service by leaving at place), paragraph 2 of the Code, the court clerk shall give notice thereof to the person on whom the service has been made.

## មាត្រា ២៥៣.- ការបញ្ជូនដែលត្រូវធ្វើនៅបរទេស

១- ចំពោះការបញ្ជូនដែលត្រូវធ្វើនៅបរទេស តុលាការត្រូវប្រគល់កិច្ចការនេះឱ្យក្រសួង ឬ ស្ថាប័នដែលមានសមត្ថកិច្ចនៃប្រទេសនោះ ឬ ឯកអគ្គរាជទូត ឬ ភារធារី ឬ កុងស៊ុលរបស់ព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនោះ ឱ្យធ្វើបាន ។

២- បើការបញ្ជូននៅបរទេសត្រូវបានធ្វើឡើង ក្នុងនីតិវិធីដែលចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ ត្រូវធ្វើ ចៅក្រមនោះអាចប្រគល់កិច្ចការបញ្ជូននេះ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបាន ។

（កំណត់）

(1) សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 108 និង បទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 45 ។

(2) ចំពោះការបញ្ជូនចំពោះបុគ្គលដែលនៅបរទេស អាចធ្វើតាមសន្ធិសញ្ញា ឬ អនុសញ្ញារវាងប្រទេសនោះ និងប្រទេសកម្ពុជា ឬ កិច្ចព្រមព្រៀងផ្សេងៗ ឬ តាមការជួយគ្នាទៅវិញទៅមកផ្អែកច្បាប់ដោយផ្អែកលើទំនៀមទម្លាប់ ។ តាមការជាក់ស្តែង មានវិធី ២ ដើម្បីធ្វើការបញ្ជូន : គឺ ① ការប្រគល់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចតាមផ្លូវច្បាប់ (ស្ថាប័នទទួលការប្រគល់) ឬ ស្ថាប័នកណ្តាលនៃប្រទេសនោះ ឬ ② ការបញ្ជូនដោយឯកអគ្គរាជទូត ភារធារី ឬ កុងស៊ុលរបស់ព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនោះ ។ តាមធម្មតា ការបញ្ជូនចំពោះជនបរទេសដែលនៅបរទេស នឹងធ្វើតាមវិធីទី ① រីឯការបញ្ជូនចំពោះអណិកជនខ្មែរនៅបរទេស នឹងធ្វើតាមវិធីទី ② ។

(3) ចំពោះប្រទេសកម្ពុជា ត្រូវគិតថាតើត្រូវចូលអនុសញ្ញាស្តីពីនីតិវិធីរដ្ឋប្បវេណី（Convention on Civil Procedure, Hague, 1954）ឬ ចូលអនុសញ្ញាស្តីពីការបញ្ជូន（Convention on the Service Abroad of Judicial and Extrajudicial Documents in Civil or Commercial Matters, Hague, 1965）ឬទេ ?

Code of Civil Procedure (Japan)
**Article 108** (Service in foreign country)
Service which is to be made in a foreign country shall be made by the presiding judge entrusting the matter to the competent governmental authorities of such country or to the Japanese ambassador, minister envoy or consul stationed in such country.

Rules of Civil Procedure (Japan)
**Article 45** (Authority of commissioned judge, etc., of service in foreign country / The Code Article 108)
In cases where service in a foreign country is to be made in proceedings carried out by a commissioned judge or assigned judge, such judge may also make entrustment referred to in Article 108 (Service in foreign country) of the Code.

## មាត្រា ២៥៤.- របាយការណ៍អំពីការបញ្ជូន ជាអាទិ៍

១- មន្ត្រីទទួលបន្ទុកការបញ្ជូនដែលបានធ្វើការបញ្ជូនរួចហើយ ត្រូវធ្វើរបាយការណ៍អំពីការបញ្ជូននោះ ជូនទៅតុលាការ ។

២- របាយការណ៍ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបញ្ជាក់អំពីចំណុចដូចតទៅ :

**ក**- សញ្ញាណនៃរឿងក្តី និង ឯកសារដែលបានបញ្ជូន ។

**ខ**- ជនដែលត្រូវទទួលការបញ្ជូន ។

**គ**- ថ្ងៃ ខែ ឆ្នាំ និង ទីកន្លែងដែលបានធ្វើការបញ្ជូន ។

**ឃ**- វិធីបញ្ជូន ។

**ង**- ចំណាត់ការតាមកថាខណ្ឌទី ៣ នៃមាត្រា ២៤៧ (គោលការណ៍នៃការបញ្ជូនដោយការប្រគល់) នៃក្រមនេះ នៅក្នុងករណីជនដែលត្រូវទទួលការបញ្ជូននោះមិនចេះអក្សរ ។

**ច**- ហត្ថលេខា ឬ ស្នាមមេដៃរបស់អ្នកដែលបានទទួលឯកសារ ។

**ឆ**- ហេតុការណ៍ដែលមិនព្រមទទួលការបញ្ជូន នៅក្នុងករណីជនដែលត្រូវទទួលការបញ្ជូន ឬ អ្នកដែលត្រូវទទួលការប្រគល់ឯកសារតាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ២៥២ (ការបញ្ជូនបង្គ្រប់កិច្ច និង ការបញ្ជូនដោយទុកចោល) នៃក្រមនេះ ប្រកែកមិនព្រមទទួល ។

**ជ**- ហេតុការណ៍ នៅក្នុងករណីដែលការបញ្ជូនបានធ្វើតាមបញ្ញត្តិនៃមាត្រា ២៥២ (ការបញ្ជូនបង្គ្រប់កិច្ច និង ការបញ្ជូនដោយទុកចោល) នៃក្រមនេះ ។

**ឈ**- ហត្ថលេខារបស់អ្នកដែលបានប្រតិបត្តិការបញ្ជូន ។

៣- ក្នុងករណីដែលបានព្យាយាមបញ្ជូន តែមិនអាចសម្រេចបាន មន្ត្រីទទួលបន្ទុកការបញ្ជូនត្រូវធ្វើរបាយការណ៍អំពីហេតុការណ៍នោះ និង ចំណុចដែលបានកំណត់នៅកថាខណ្ឌទី ២ ខាងលើ ចាប់ពីចំណុច **ក** រហូតដល់ចំណុច **ឃ** និង ចំណុច **ឈ** ជូនទៅតុលាការ ។

(កំណត់)

(1) សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 109 ។

(2) ចំណុច **ង** កថាខណ្ឌទី ២ នៃមាត្រានេះ ត្រូវបានបន្ថែម ដោយការបន្ថែមកថាខណ្ឌទី ៣ នៃមាត្រា ២៤៧ (គោលការណ៍នៃការបញ្ជូនដោយការប្រគល់) ។

(3) ដោយយោលទៅតាមមតិនៃសិក្ខាសាលាលើកទី ១០ (ខែ កក្កដា ឆ្នាំ ២០០១) កថាខណ្ឌទី ៣ នៃមាត្រានេះ ចែងថា ក្នុងករណីដែលមិនអាចធ្វើការបញ្ជូនកើត អ្នកដែលបានធ្វើការបញ្ជូនត្រូវធ្វើរបាយការណ៍សរសេរនូវការណ៍នោះ ដើម្បីបញ្ជាក់ហេតុការណ៍នោះឱ្យបានច្បាស់ ។

Code of Civil Procedure (Japan)
**Article 108** (Report of service)
The public official who has effected service shall draft a document containing the particulars relating to the service, and submit it to the court.

**មាត្រា ២៥៥.-** ល័ក្ខខ័ណ្ឌដើម្បីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ

១- ក្នុងករណីដូចខាងក្រោមនេះ ក្រឡាបញ្ជីអាចធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបាន តាមពាក្យសុំដោយទទួលការអនុញ្ញាតពីតុលាការ :

**ក-** ទោះបីបានខំប្រឹងប្រែងធ្វើការស្រាវជ្រាវរកលំនៅឋាន ឬ ទីសំណាក់របស់ភាគី ឬ កន្លែងផ្សេងទៀតដែលត្រូវធ្វើការបញ្ជូនក៏ដោយ ក៏នៅតែរកមិនឃើញ ។

**ខ-** មិនអាចបញ្ជូនតាមបញ្ញត្តិនៃមាត្រា ២៥២ (ការបញ្ជូនបង្គ្រប់កិច្ច និង ការបញ្ជូនដោយទុកចោល) នៃក្រមនេះ ។

**គ-** មិនអាចធ្វើការបញ្ជូន តាមបញ្ញត្តិនៃមាត្រា ២៥៣ (ការបញ្ជូនដែលត្រូវធ្វើនៅបរទេស) នៃក្រមនេះបាន ឬ ត្រូវបានទទួលស្គាល់ថា គ្មានលទ្ធភាពនឹងធ្វើបានតាមបញ្ញត្តិនោះ ក្នុងករណីដែលត្រូវធ្វើការបញ្ជូននៅបរទេស ។

**ឃ-** បានធ្វើការបញ្ជូនដោយប្រគល់ឱ្យក្រសួង ឬ ស្ថាប័នដែលមានសមត្ថកិច្ចនៅបរទេសឱ្យធ្វើតាមបញ្ញត្តិនៃមាត្រា ២៥៣ (ការបញ្ជូនដែលត្រូវធ្វើនៅបរទេស) នៃក្រមនេះ តែមិនបានទទួលលិខិតបញ្ជាក់អំពីការបញ្ជូននោះ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ចាប់តាំងពីពេលបញ្ជូននោះ ។

២- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើយល់ឃើញថា ចាំបាច់ដើម្បីជៀសវាងការយឺតយ៉ាវក្នុងដំណើរការនីតិវិធី តុលាការអាចបង្គាប់ឱ្យក្រឡាបញ្ជីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបាន ទោះបីជាគ្មានពាក្យសុំក៏ដោយ ។

៣- ក្នុងករណីដែលបានកំណត់នៅក្នុងចំណុច **ខ** នៃកថាខណ្ឌទី ១ ខាងលើនេះ ក្រឡាបញ្ជីគប្បីជូនដំណឹងដោយរបៀបសមរម្យមួយ អំពីហេតុការណ៍ដែលបានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ ទៅភាគីដែលត្រូវទទួលការបញ្ជូននោះ ។

៤- ការបញ្ជូនជាលើកទី ២ តាមការផ្សាយជាសាធារណៈចំពោះភាគីដដែល ត្រូវធ្វើដោយឆន្ទានុសិទ្ធិ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបានកំណត់ក្នុងចំណុច **គ** នៃកថាខណ្ឌទី ១ ។

(កំណត់)

(1) សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 110 ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ មាត្រា 178 ។

(2) ការបញ្ជូនតាមការផ្សាយជាសាធារណៈនេះ គឺជារបបមួយជាចាំបាច់ ដើម្បីឱ្យដើមចោទអាចធ្វើបណ្តឹងបាន ទោះបីជាមិនដឹងលំនៅឋាន ជាអាទិ៍ របស់ចុងចម្លើយ ហើយមិនអាចធ្វើការបញ្ជូនទៅតាមវិធីធម្មតាក៏ដោយ ។ ប៉ុន្តែ ការបញ្ជូនតាមការផ្សាយជាសាធារណៈ ត្រូវធ្វើតាមការចែងក្នុងមាត្រា ២៥៦ (របៀបបញ្ជូនតាមការផ្សាយជាសាធារណៈ) ហេតុនេះហើយ តាមការពិត មានការពិបាករំពឹងឱ្យជនដែលត្រូវទទួលការបញ្ជូននោះអាចដឹងបាន ។ ម្ល៉ោះហើយប្រព័ន្ធនេះ វាមានគ្រោះថ្នាក់បន្តិច ប្រសិនបើដើមចោទបានប្រើប្រព័ន្ធនេះដើម្បីធ្វើឱ្យការជម្រះក្តីនោះលំអៀងទៅរកទៅខ្លួន នៅពេលដែលចុងចម្លើយមិនបានដឹង ។ ហេតុនេះហើយ ដើម្បីការពារកុំឱ្យមានអំពើខិលខូច

នេះកើតមានឡើង តុលាការត្រូវតែធ្វើការពិនិត្យល័ក្ខខ័ណ្ឌធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈនេះ (មិនដឹងអាសយដ្ឋានភាគី ជាដើម) ឱ្យបានត្រឹមត្រូវ ។

(3) នៅក្នុងករណីដែលស្គាល់លំនៅឋាន ក្រោយពីបានសាកល្បងបញ្ជូនហើយ តែគ្មានអ្នកណានៅសោះនោះ យើងចាំបាច់ត្រូវអនុញ្ញាតឱ្យធ្វើតាមការផ្សាយជាសាធារណៈ ។ ដោយមានមតិនៅសិក្ខាសាលាលើកទី ១០ (ខែ កក្កដា ឆ្នាំ ២០០១) យើងបានបន្ថែមនៅក្នុងចំណុច ខ កថាខណ្ឌទី ១ នៃមាត្រានេះ ។ តែដោយហេតុថា គ្រាន់តែសាកល្បងបញ្ជូនតែមួយដងទៅលំនៅឋាននោះ ហើយអាចធ្វើតាមការផ្សាយជាសាធារណៈនោះ យើងបានបន្ថែមកថាខណ្ឌទី ៣ ថ្មី ដើម្បីការពារផលប្រយោជន៍របស់ជនដែលត្រូវទទួលការបញ្ជូន ដោយឱ្យធ្វើការជូនដំណឹងទៅជនដែលត្រូវទទួលការបញ្ជូននោះ ។

Code of Civil Procedure (Japan)
**Article 110** (Requirements for service by publication of notice)
1. In the following cases, the court clerk may, upon motion, make service by publication of notice:
   i. in cases where the domicile or residence of a party or any other place at which the service is to be made is unknown;
   ii. in cases where it is impossible to make service according to the provisions of Article 107, paragraph 1;
   iii. with regard to service which is to be made in a foreign country, in cases where it is impossible to do so according to the provisions of Article 108, or where it should be deemed impossible to make the service even in accordance with such provisions;
   iv. in cases where service is entrusted to a governmental authority of foreign country according to the provisions of Article 108 but the document proving that service has been made has not been received within six months of such entrustment.
2. In cases under the preceding paragraph, the court may, upon determining such procedure necessary to avoid delay in the suit, even when no motion has been made, order the court clerk to make service by publication of notice.
3. After the initial service by publication of notice, subsequent services to the same party shall be made based on the court's own authority. However, this shall not apply to the cases referred to in paragraph 1, item iv.

Old Code of Civil Procedure (Japan, 1890, last amendament 1992)
**Article 178** (Requirements for service by public notice)
1. In the event that the domicile, residence of a party, or any other place at which service is to be effected is unknown or that it is impossible to effect service in accordance with the provision of Article 172, or in the event that it is, with regard to the service to be effected in a foreign country, impossible to do so in accordance with the provision of Article 175 or that it is, even if made thereby, deemed ineffective, service by public notice may be effected upon motion by obtaining the permission from the presiding judge. The same shall also apply in cases where the document proving the service thereof has not been sent even if six months have elapsed after issue of commission to foreign competent agency.
2. The court may, if it deems in the case of preceding paragraph necessary for avoiding delay in the litigation, order to effect service by public notice even without motion.
3. The subsequent services by public notice to the same party shall be effected on its own authority. Provided that, this shall not apply in the latter clause of paragraph 1.

**មាត្រា ២៥៦.-** របៀបបញ្ជូនតាមការផ្សាយជាសាធារណៈ

១- ការបញ្ជូនតាមការផ្សាយជាសាធារណៈ ត្រូវបិទប្រកាសនៅកន្លែងសម្រាប់បិទប្រកាសរបស់តុលាការថា ក្រឡាបញ្ជីរក្សាទុកនូវឯកសារដែលត្រូវបញ្ជូន និង អាចប្រគល់ឯកសារនោះទៅជនដែលត្រូវទទួលការបញ្ជូន នៅពេលណាក៏បាន ។ ប៉ុន្តែ ចំពោះការបញ្ជូនដីកាកោះតាមការផ្សាយជាសាធារណៈវិញ ត្រូវបិទដីកាកោះនោះ នៅកន្លែងសម្រាប់បិទប្រកាស ។

២- នៅក្នុងករណីដែលធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ តាមបញ្ញត្តិនៃចំណុច ខ កថាខណ្ឌទី ១ នៃមាត្រា ២៥៥ (ល័ក្ខខ័ណ្ឌដើម្បីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ) នៃក្រមនេះ ការបិទប្រកាសដែលកំណត់នៅកថាខណ្ឌទី ១ នេះ អាចធ្វើបាននៅកន្លែងដែលតុលាការទទួលស្គាល់ថាសមរម្យ ក្រៅពីកន្លែងដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាង

លើនេះ ។

៣- តុលាការអាចចុះនៅក្នុងរាជកិច្ច ឬ ក្នុងសារព័ត៌មាន ផ្សាយថា បានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈហើយ ។ ចំពោះការបញ្ជូនដែលត្រូវធ្វើនៅបរទេស ក្រឡាបញ្ជីតុលាការអាចជូនដំណឹងថា បានធ្វើការបញ្ជូន តាមការផ្សាយជាសាធារណៈហើយ ជំនួសការប្រកាសផ្សាយនៅក្នុងរាជកិច្ច ឬ ក្នុងសារព័ត៌មាន ។

(កំណត់)

(1) សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 111 បទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 46 ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ មាត្រា 179 ។

(2) បានបន្ថែមកថាខណ្ឌទី ២ នៃមាត្រានេះ ដោយយោលតាមមតិនៃសិក្ខាសាលាលើកទី ១០ (ខែ កក្កដា ឆ្នាំ ២០០១) ។

Code of Civil Procedure (Japan)
**Article 111** (Method of service by publication of notice)
Service by publication of notice shall be made by posting on the notice-board of the court a notice stating that the court clerk has custody of the document to be served and is ready to make delivery at any time to the person on whom the service is to be made.

Rules of Civil Procedure (Japan)
**Article 46** (Method of service by publication of notice / The Code Article 111)
1. Service of a writ of summons by publication of notice shall be made by posting it on the notice-board.
2. The court clerk may publish the fact that the service by publication of notice has been made in the Official Gazette or newspapers. With regard to service which is to be made in a foreign country, the court clerk may give notice of the fact that the service by publication of notice has been made instead of publication in the Official Gazette or newspapers.

Old Code of Civil Procedure (Japan, 1890, last amendment: 1992)
**Article 179** (Method of service by public notice)
1. The service by public notice shall be made by putting up a notice on the notice-board of thecourt to the effect that the document to be served is in the custody of the court clerk and is ready to be delivered at any time to the person on whom the service is to be effected: Provided, that service of a writ of summons shall be effected by posting it on the notice-board.
2. The court may order to publish in the Official Gazette or newspapers the fact that the service by public notice has been made: Provided, that regarding to service to be effected in a foreign country, it may inform of the fact that the service by public notice has been made by mail.

**មាត្រា ២៥៧.-** ពេលដែលការបញ្ជូនតាមការផ្សាយជាសាធារណៈមានអានុភាព

១- ការបញ្ជូនតាមការផ្សាយជាសាធារណៈ នឹងមានអានុភាពនៅក្រោយអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃ ដែលបានបិទប្រកាសតាមបញ្ញត្តិនៃមាត្រា ២៥៦ (របៀបបញ្ជូនតាមការផ្សាយជាសាធារណៈ) ខាងលើនេះ ។ ប៉ុន្តែ ចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ នៃមាត្រា ២៥៥ (ល័ក្ខខ័ណ្ឌដើម្បីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ) នៃក្រមនេះ នឹងមានអានុភាពនៅថ្ងៃបន្ទាប់ពីថ្ងៃបិទប្រកាស ។

២- ចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈដែលបានធ្វើឡើង សម្រាប់ការបញ្ជូនដែលត្រូវធ្វើនៅបរទេសវិញ អំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ គឺ ៦ (ប្រាំមួយ) សប្តាហ៍ ។

( កំណត់)

(1) សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 112 ។

Code of Civil Procedure (Japan)
**Article 112** (Time which service by publication of notice takes effect)
1. Service by publication of notice shall take effect two weeks from the day on which such notice under the provisions of the preceding article has been made. However, service by publication of notice referred to in Article 110, paragraph 3 shall take effect on the day following the day on which such notice has been made.
2. In cases of service by publication of notice made with respect to service to be made in a foreign country, the period provided for in the preceding paragraph shall be six weeks.
3. The periods specified in the preceding two paragraphs may not be shortened.

## ជំពូកទី ៩ ការមើលសំណុំរឿង

**មាត្រា ២៥៨.-** ការទាមទារមើលសំណុំរឿងនៃបណ្ដឹង ជាអាទិ៍

១- ភាគីនៃបណ្ដឹង និង តតិយជនដែលធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ក្នុងបណ្ដឹង អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងបណ្ដឹងពីតុលាការបានដោយបង់ពន្ធ ។ ចំពោះឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ក្រឡាបញ្ជីត្រូវបញ្ជាក់ថាជាឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ ឬ ឯកសារដកស្រង់ ហើយនិងចុះហត្ថលេខា ។

២- បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្ត ចំពោះខ្សែអាត់ ខ្សែវីដេអូ ឬ វត្ថុដែលកត់ត្រាអំពីចំណុចដែលមានកំណត់ដោយវិធីប្រហែលគ្នា ក្នុងសំណុំរឿងឡើយ ។ ក្នុងករណីនេះ ប្រសិនបើមានការទាមទារពីសំណាក់ភាគីនៃបណ្ដឹង ឬ តតិយជនដែលធ្វើសេចក្ដីបញ្ជាក់ដំបូងថាមានការពាក់ព័ន្ធនឹងផលប្រយោជន៍ក្នុងបណ្ដឹង តុលាការត្រូវអនុញ្ញាតឱ្យថតចម្លងវត្ថុទាំងនោះ ។

៣- ការទាមទារមើល ចម្លង ថតចម្លងនូវសំណុំរឿង មិនអាចធ្វើបានឡើយ បើការនោះធ្វើឱ្យមានឧបសគ្គដល់ការរក្សាទុកសំណុំរឿង ឬ ដល់ការចាត់ចែងការងាររបស់តុលាការ ។

( កំណត់)

(1) សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា 299 ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 91 និង បទប្បញ្ញត្តិស្ដីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 33 ។

(2) មាត្រានេះចម្លងតាមក្រមនីតិវិធីរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា 299 ដែលទទួលស្គាល់តែលើសិទ្ធិភាគីបណ្ដឹង និង តតិយជនដែលធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ក្នុងបណ្ដឹងប៉ុណ្ណោះ ទើបអាចមើលសំណុំរឿង

និង អាចទាមទារថតសំណុំរឿងបាន ។ ច្បាប់ជប៉ុនមានភាពទូលាយជាង ដោយគេគិតថា តតិយជនទូទៅក៏មានសិទ្ធិអាចមើលសំណុំរឿងបាន ដែលជាប្រយោជន៍ធ្វើឱ្យមានតម្លាភាពក្នុងដំណើរការនៃនីតិវិធីបណ្តឹង ប៉ុន្តែដោយអាចធ្វើឱ្យតតិយជនដែលគ្មានផលប្រយោជន៍ក្នុងបណ្តឹង អាចដឹងបានអំពីបញ្ហាឯកជនរបស់ភាគីនៃបណ្តឹង ឬកិច្ចការសម្ងាត់ក្នុងការងារនោះ វាអាចបណ្តាលឱ្យកើតមានជាឧបសគ្គដល់ដំណើរការនៃបណ្តឹងរបស់ភាគី និងកិច្ចការវិនិច្ឆ័យរបស់តុលាការ ។ វិសោធនកម្មក្នុងច្បាប់ជប៉ុនលើកនេះ ដើម្បីការពារដល់កិច្ចការសម្ងាត់របស់ភាគី តុលាការអាចចាត់ចែងដោយហាមការមើលសំណុំរឿងបាន (នីតិវិធីការពារកិច្ចការសម្ងាត់, ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 92) តែការអនុវត្តនីតិវិធីនេះ ជាកិច្ចការពិបាកចំពោះចៅក្រម ហើយយើងគិតថា ចំពោះស្ថានភាពបច្ចុប្បន្នរបស់ប្រទេសកម្ពុជា វាមានការពិបាកក្នុងការពង្រីកការទទួលស្គាល់សិទ្ធិមើលសំណុំរឿង ហើយបញ្ចូលនូវនីតិវិធីការពារកិច្ចការសម្ងាត់នេះ ។ ដូច្នេះហើយ នៅក្នុងមាត្រានេះ ដោយគិតថា ការទាមទារតម្រូវឱ្យមានតម្លាភាពចំពោះនីតិវិធីនៃបណ្តឹងនោះ អាចសម្រេចបាននៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ យើងទទួលស្គាល់សិទ្ធិទាមទារមើលសំណុំរឿងនោះ ត្រឹមតែភាគីបណ្តឹង និង តតិយជនដែលធ្វើសេចក្តីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ក្នុងបណ្តឹងតែប៉ុណ្ណោះ ទើបអាចមើលសំណុំរឿងបាន ។

(3) ជាភាសាអង់គ្លេស ឯកសារចម្លងយថាភូតនៃឯកសារដើម គឺជា authenticated copy ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ប្រែថា transcript និង ឯកសារដកស្រង់ គឺជា excerpt ។

Code of Civil Procedure Rules (Germany)
**Article 299** ( Inspection of case files; copies)
1. The parties may inspect the court files and have the registry prepare for them duplicates, extracts and copies.
2. The presiding judge of the court may only permit inspection of the case file by a third party without the consent of the parties if a justified legal interest is shown.
3. Drafts of judgments, decisions and dispositions, materials delivered for their preparation, as well as the documente which concern voting, shall not be presented or notified in writing.

Code of Civil Procedure (Japan)
**Article 91** (Perusal, etc. of record of case)
1. Any person may make a request to the court clerk for perusal of the record of a case.
2. With regard to the record of a case regarding an oral argument which was closed to the public, only the parties and third persons who have offered a preliminary showing as to their interest in the case may make the request in accordance with the preceding paragraph.
3. The parties and third persons who have offered a preliminary showing as to their interest in the case may make a request to the court clerk for copy of the record of the case, or for delivery of an authenticated copy, transcript or excerpt thereof, or for delivery of a certification regarding matters relating to the case.
4. The provisions of the preceding paragraph shall not apply to recording tapes or video tapes (including materials recording typical matters by means analogous to them) in the record of the case. In such cases, when there is a request by the parties or third persons who have offered a preliminary showing as to their interest in the case, the court clerk shall permit their duplication.
5. In cases where perusal, copy or duplication of the record of a case interferes with the preservation of the record or the performance of court business, requests therefor shall not be made.
**Article 92** (Limitation on perusal, etc., for protection of secret)
1. In cases where a preliminary showing is offered as to the following reasons, the court may, upon motion by such party, by ruling, limit the scope of the persons who may make a request for perusal or copy of a part of the record of the case in chich such secret is written or recorded, for delivery of an authenticated copy, transcript or excerpt thereof, or for permission to duplicate it (hereinafter referred to as "perusal, etc., of a secret part") to the parties of the case:
   i. An important secret with regard to privacy of a party is written or recorded in the record of the case, and perusal, etc., of a secret part by a third person is likely to considerably interfere with the party's life in sociery;
   ii. A party's trade secret ("trade secret" refers to its meaning in the Unfair Competition Prevention Act (Law No. 47, 1993) Article 2, paragraph4) is written or recorded in the record of the case.

2. In cases where a motion is made under the provisions of the preceding paragraph, third persons ma not request for perusal, etc., of the secret part until the decision with respect to such motion is final and binding.
3. Third persons who intend to make a request for perusal, etc., of a secret part may, to the court in which the case record is located, for the reason that a requirement of paragraph 1 is not fulfilled or such requirement become unfulfilled, make a motion for canceling a ruling under the provisions of the paragraph.
4. An immediate *kokoku*-appeal may be made against a decision dismissing the motion referred to in paragraph 1, and any decision regarding the motion referred to in the preceding paragraph.
5. A decision canceling the ruling under the provisions of paragraph 1 shall have no effect until becoming final and binding.

Rules of Civil Procedure (Japan)
**Article 33** (Form of authenticated copy, etc., of record of case / The Code Article 91)
An authenticated copy, transcript or excerpt of the record of the case shall contain a statement identifying it as either an authenticated copy, transcript or excerpt, and the court clerk shall enter his or her name and affix his or her seal thereon.

# គន្ថីទី ៣ បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

## ជំពូកទី ១ បទប្បញ្ញត្តិទូទៅ

**មាត្រា ២៥៩.-** ប្រភេទនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

១- ប្រភេទនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចំពោះការសម្រេចសេចក្តីដែលមិនទាន់ចូលជាស្ថាពរ មានដូចខាងក្រោមនេះ :

**ក-** បណ្តឹងឧទ្ធរណ៍ ចំពោះសាលក្រមរបស់សាលាដំបូង ឬ បណ្តឹងសាទុក្ខ ក្នុងករណីមានការព្រមព្រៀងរវាងភាគីដែលបានកំណត់នៅក្នុងចំណុច **ក** កថាខណ្ឌទី ១ នៃមាត្រា ២៦០ (សាលក្រមដែលអាចប្តឹងឧទ្ធរណ៍បានជាអាទិ៍) នៃក្រមនេះ ។

**ខ-** បណ្តឹងសាទុក្ខ ចំពោះសាលដីការបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ ។

**គ-** បណ្តឹងជំទាស់ ចំពោះដីកាសម្រេច ។

២- បណ្តឹងជំទាស់ អាចធ្វើឡើងបាន លុះត្រាតែមានបញ្ញត្តិក្នុងច្បាប់ ។

៣- ចំពោះដីកាសម្រេចលើបណ្តឹងជំទាស់ មិនអាចប្តឹងជំទាស់ទៀតបានឡើយ ។

(កំណត់)

បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺជាឧបាស្រ័យចំពោះការសម្រេចសេចក្តីដែលមិនទាន់ចូលជាស្ថាពរ រីឯឧបាស្រ័យចំពោះការសម្រេចសេចក្តីដែលចូលជាស្ថាពរហើយ គឺជាបណ្តឹងជំនុំជម្រះសាជាថ្មី ។ ម្យ៉ាងទៀត បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺជាឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ហេតុដូច្នេះមានលក្ខណៈផ្សេងពីបណ្តឹងតវ៉ា ដែលជាឧបាស្រ័យទៅតុលាការដដែល ។

ចំពោះសាលក្រម ឬ សាលដីកា គេអាចធ្វើបណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងសាទុក្ខបាន ប៉ុន្តែ ចំពោះដីកាសម្រេច គេអាចធ្វើបណ្តឹងជំទាស់បាន លុះត្រាតែក្នុងករណីដែលមានចែងក្នុងច្បាប់ ។

ចំពោះការសម្រេចសេចក្តីរបស់តុលាការស្តីពីចំណុចណាដែលត្រូវបានសម្រេច នៅក្នុងដំណើរការរហូតដល់ចេញសាលក្រមចុងក្រោយវិញ ជាគោលការណ៍ ត្រូវទទួលការវិនិច្ឆ័យរបស់តុលាការជាន់ខ្ពស់ ជាមួយនឹងសាលក្រមចុងក្រោយ ប្រសិនបើមានឧបាស្រ័យចំពោះសាលក្រមចុងក្រោយ (មាត្រា ២៦២ (សេចក្តីសម្រេចដែលត្រូវទទួលការវិនិច្ឆ័យរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍)) ។ ប៉ុន្តែ ចំពោះចំណុចដែលត្រូវបានដោះស្រាយឆាប់រហ័ស ដើម្បីឱ្យមានស្ថេរភាពក្នុងដំណើរការនៃនីតិវិធី ក្នុងចំណោមចំណុចបន្ទាប់បន្សំដែលទាក់ទងនឹងដំណើរការនៃនីតិវិធីវិញ ប្រសិនបើតុលាការទទួលឧបាស្រ័យចំពោះចំណុចនេះដោយឡែកនឹងឧបាស្រ័យចំពោះសាលក្រមចុងក្រោយ ដើម្បីដោះស្រាយចំណុចបន្ទាប់

បន្ទុំឱ្យបានចូលជាស្ថាពរឆាប់រហ័ស វាមានភាពសមរម្យ ។ ការទទួលស្គាល់ឧបាស្រ័យដោយឡែកនេះ គឺដើម្បីបន្ថយនូវឧបាស្រ័យ ចំពោះសាលក្រមចុងក្រោយ ដោយសារតែមានបញ្ហាបន្ទាប់បន្សំប៉ុណ្ណោះ ។

កថាខណ្ឌទី ៣ បញ្ជាក់ពីបណ្តឹងជំទាស់ដែលអាចធ្វើបានតែមួយដង និង មិនទទួលស្គាល់បណ្តឹងជំទាស់ម្តងទៀត ។

## ជំពូកទី ២ បណ្តឹងឧទ្ធរណ៍

**មាត្រា ២៦០.-** សាលក្រមដែលអាចប្តឹងឧទ្ធរណ៍បាន ជាអាទិ៍

១- បណ្តឹងឧទ្ធរណ៍អាចធ្វើចំពោះសាលក្រមចុងក្រោយរបស់សាលាដំបូងបាន លើកលែងតែករណីដែលបានកំណត់ខាងក្រោមនេះ :

- **ក**- គូភាគីបានព្រមព្រៀងគ្នាមិនប្តឹងឧទ្ធរណ៍ ដោយរក្សាទុកនូវសិទ្ធិប្តឹងសាទុក្ខ ក្រោយពេលតុលាការបានចេញសាលក្រមចុងក្រោយ ។
- **ខ**- សាលក្រមចុងក្រោយនោះវិនិច្ឆ័យទៅលើរឿងក្តីរដ្ឋប្បវេណី ឬ ពាណិជ្ជកម្ម ដែលមានតម្លៃកម្មវត្ថុនៃបណ្តឹងមិនលើសពី ៥.០០០.០០០ ( ប្រាំលាន) រៀល ។

២- សេចក្តីព្រមព្រៀងដែលបានកំណត់នៅក្នុងចំណុច **ក** នៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ ប្រសិនបើមិនបានធ្វើលិខិតជាលាយល័ក្ខណ៍អក្សរ ។

( កំណត់)

តម្រូវនឹងមាត្រា 281 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ វាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ នេះគឺយោងទៅតាមមាត្រា ២០ វាក្យខណ្ឌទី ២ នៃសេចក្តីព្រាងច្បាប់ស្តីពីការចាត់តាំងតុលាការ ( សេចក្តីព្រាង 11/08/2000) ។ ចំណុច **ក** នៃកថាខណ្ឌទី ១ នេះ គឺជា "ការព្រមព្រៀងប្តឹងសាទុក្ខផ្លោះទៅតុលាការកំពូល" ដែលគូភាគីលះបង់នូវការវិនិច្ឆ័យទៅលើអង្គសេចក្តីលើកទី ២ របស់តុលាការនៃបណ្តឹងឧទ្ធរណ៍ ហើយអាចទាមទារការវិនិច្ឆ័យដោយតុលាការនៃបណ្តឹងសាទុក្ខបាន ។ បើគ្មានការព្រមព្រៀងបែបនេះទេ តែគ្រាន់តែព្រមព្រៀងថាមិនប្តឹងឧទ្ធរណ៍នោះ ក៏មិនអាចប្តឹងឧទ្ធរណ៍បានដែរ ។ ចំណុច **ខ** នៃកថាខណ្ឌទី ១ នេះ បានចែង ចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល ដោយយោលតាមការស្នើសុំរបស់ភាគីកម្ពុជា នៅក្នុងសិក្ខាសាលាហ្វឹកហ្វឺនអ្នករៀបចំសេចក្តីព្រាងច្បាប់ នៅថ្ងៃទី 29 ខែសីហា ឆ្នាំ ២០០១ ហើយចាំបាច់ត្រូវសម្រួល ជាមួយនឹងសេចក្តីព្រាងច្បាប់ស្តីពីការចាត់តាំងតុលាការ វាក្យខណ្ឌទី ២ នៃមាត្រា ៣៥ (សេចក្តីព្រាង 11/08/2001) ។ អំពីការធ្វើឧបាស្រ័យចំពោះសាលក្រមកំបាំងមុខនៅតុលាការនៃការជំនុំជម្រះលើកទី ១ វិញ ក្នុងករណីដែលជននោះមានល័ក្ខខ័ណ្ឌគ្រប់គ្រាន់ដើម្បីប្តឹងទាស់ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ២០៤ ( បណ្តឹងទាស់) ជននោះអាចប្តឹងឧទ្ធរណ៍បាន ដោយលះបង់នូវផលប្រយោជន៍ដែលបន្ត

ការវិនិច្ឆ័យនៅតុលាការនៃការជំនុំជម្រះលើកទី ១ ចំណែកជនដែលខ្វះល័ក្ខខ័ណ្ឌដើម្បីប្ដឹងជំទាស់ ក៏អាចប្ដឹងឧទ្ធរណ៍បានដែរ (សូមមើលកំណត់ទី (2) នៃមាត្រា ២០៤ (បណ្ដឹងទាស់) និង មាត្រា ២០២ (ករណីដែលមិនអាចចេញសាលក្រម កំបាំងមុខ)) ។ ចំពោះសាលក្រមចុងក្រោយ ក្រោយពេលប្ដឹងជំទាស់ចំពោះសាលក្រមកំបាំងមុខរួចហើយក៏ដោយ ក៏អាចប្ដឹងឧទ្ធរណ៍បានដែរ ។

Code of Civil Procedure (Japan)
**Article 281** (Judgment against which *koso*-appeal may be made, etc.)
1. A *koso*-appeal may be made against a final judgment rendered by a district court in the first instance or against a final judgment rendered by a summary court. However, this shall not apply to cases where both parties have, following the entry of a final judgment, agreed not to make a *koso*-appeal but reserved the right to make a *jokoku*-appeal.
2. The provisions of Article 11, paragraph 2 shall apply *mutatis mutandis* to the agreement referred to in the preceding paragraph.

**មាត្រា ២៦១.-** ការកម្រិតបណ្ដឹងឧទ្ធរណ៍ចំពោះសេចក្ដីសម្រេចលើបន្ទុកនៃប្រាក់ប្រដាប់ក្ដី

ចំពោះសេចក្ដីសម្រេចលើបន្ទុកនៃប្រាក់ប្រដាប់ក្ដី មិនអាចប្ដឹងឧទ្ធរណ៍ដោយឯករាជ្យតែឯកឯងបានឡើយ ។

(កំណត់)

តម្រូវនឹងមាត្រា 282 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ គឺជាអត្ថន័យដែលបញ្ជាក់ថា មិនអាចប្ដឹងឧទ្ធរណ៍ដោយឯករាជ្យតែឯងបាន ចំពោះសេចក្ដីសម្រេចអំពីបន្ទុកនៃប្រាក់ប្រដាប់ក្ដីដែលជាប់ជាមួយនឹងសាលក្រមចុងក្រោយ សម្រេចអំពីអង្គសេចក្ដីដែលឱ្យភាគីចាញ់ ឬ ឈ្នះក្ដី ។

Code of Civil Procedure (Japan)
**Article 282** (Restriction on *koso*-appeal against decision on the imposition of court costs)
No *koso*-appeal may be made solely against a decision on the imposition of court costs.

**មាត្រា ២៦២.-** សេចក្ដីសម្រេចដែលត្រូវទទួលការវិនិច្ឆ័យរបស់តុលាការនៃបណ្ដឹងឧទ្ធរណ៍

សេចក្ដីសម្រេចនៅមុនសាលក្រមចុងក្រោយ ត្រូវទទួលការវិនិច្ឆ័យរបស់តុលាការនៃបណ្ដឹងឧទ្ធរណ៍ ។ ប៉ុន្ដែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសេចក្ដីសម្រេចដែលមិនអាចធ្វើឧបាស្រ័យបាន និង សេចក្ដីសម្រេចដែលអាចធ្វើឧបាស្រ័យបានដោយការប្ដឹងជំទាស់ ។

(កំណត់)

តម្រូវនឹងមាត្រា 283 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ "ការសម្រេចសេចក្ដីនៅមុនសាលក្រមចុងក្រោយ" មាន ៣ ប្រភេទ គឺ (១) ការសម្រេចសេចក្ដីដែលអាចប្ដឹងឧបាស្រ័យជាមួយសាលក្រមចុងក្រោយ (២) ការសម្រេចសេចក្ដីដែលមិនអាចធ្វើឧបាស្រ័យបាន និង (៣) ការសម្រេចសេចក្ដីដែលអាចធ្វើឧបាស្រ័យបាន ដោយការប្ដឹងជំទាស់

ដោយឡែកពីសាលក្រមចុងក្រោយ ។ វាក្យខណ្ឌទី ១ នៃមាត្រានេះ ចែងអំពីការសម្រេចសេចក្តី ប្រភេទ (១) រីឯវាក្យខណ្ឌទី ២ ចែងអំពី (២) និង (៣) ។

ចំពោះ (២) "ការសម្រេចសេចក្តីដែលមិនអាចធ្វើឧបាស្រ័យវិញ" មានដូចជាមាត្រា ១២ (ការកំណត់តុលាការដែលមានសមត្ថកិច្ច) ដីកាសម្រេចដែលសម្រេចថា ការដកហូត ឬ បណ្តឹងជិតចិត្តមានមូលហេតុត្រឹមត្រូវ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៥ នៃមាត្រា ៣០ (ការសម្រេចសេចក្តីអំពីពាក្យសុំដកហូត ឬ បណ្តឹងជិតចិត្ត) ដីកាសម្រេចដែលសម្រេចថា បណ្តឹងផាត់ចោលអ្នកជំនាញកោសលវិច័យមានមូលហេតុត្រឹមត្រូវ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ នៃមាត្រា ១៤៥ (បណ្តឹងផាត់ចោលអ្នកជំនាញខាងកោសលវិច័យ)) ដីកាសម្រេចឱ្យថែរក្សាការពារភស្តុតាង ដែលបានកំណត់នៅក្នុងមាត្រា ១៦៨ (ការធ្វើឧបាស្រ័យ) ការសម្រេចសេចក្តីរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ស្តីពីការអនុវត្តជាបណ្តោះអាសន្ន ដែលបានកំណត់នៅក្នុងមាត្រា ២៧១ (ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នដោយតុលាការនៃបណ្តឹងឧទ្ធរណ៍) ជាដើម ។ ការសម្រេចសេចក្តីដែលបានកំណត់នៅក្នុងមាត្រា ១២ គឺជាការសម្រេចសេចក្តីដោយតុលាការកំពូល ហេតុដូច្នេះ មិនអាចប្តឹងឧបាស្រ័យបានឡើយ ។ ចំពោះការសម្រេចសេចក្តីផ្សេងទៀតដែលលើកឡើងខាងលើនេះ មិនអាចប្តឹងឧបាស្រ័យបាន ដោយសារមានភាពចាំបាច់ឱ្យចូលជាស្ថាពរភ្លាម ដើម្បីចាត់ចែងនីតិវិធីឱ្យបានឆាប់រហ័ស ។

ចំពោះ (៣) "ការសម្រេចសេចក្តីដែលអាចឧបាស្រ័យបានដោយសារបានប្តឹងជំទាស់" មានករណីច្រើនដូចជាដីកាសម្រេចផ្ទេរបណ្តឹង និង ដីកាសម្រេចលើកចោលពាក្យសុំផ្ទេរបណ្តឹង ដែលបានកំណត់នៅក្នុងមាត្រា ២១ (បណ្តឹងជំទាស់) ដីកាសម្រេចដែលសម្រេចថាការដកហូត ឬ បណ្តឹងជិតចិត្តគ្មានមូលហេតុ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៦ នៃមាត្រា ៣០ (ការសម្រេចសេចក្តីអំពីពាក្យសុំដកហូត ឬ បណ្តឹងជិតចិត្ត) ដីកាសម្រេចអំពីការជួយសង្គ្រោះលើបណ្តឹង ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ នៃមាត្រា ៧០ (ខ្លឹមសារនៃជំនួយសង្គ្រោះលើបណ្តឹង) ដីកាសម្រេចលើកចោលពាក្យបណ្តឹងដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ ដែលបានកំណត់នៅក្នុងមាត្រា ៧៨ (ការពិនិត្យពាក្យបណ្តឹង) ជាដើម ។ ការសម្រេចសេចក្តីទាំងនេះ ទាក់ទងនឹងចំណុចដែលតុលាការត្រូវសម្រេច ដោយឯករាជ្យតែឯង ដោយអនុញ្ញាតឱ្យភាគីប្តឹងឧបាស្រ័យដោយឡែកពីសាលក្រមចុងក្រោយ ។

ការសម្រេចសេចក្តីផ្សេងពី (២) និង (៣) គឺជា (១) "សេចក្តីសម្រេចនៅមុនសាលក្រមចុងក្រោយ" ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ១ ។ ការសម្រេចសេចក្តីប្រភេទនេះ មានដូចជាមាត្រា ៩១ (បណ្តឹងតវ៉ាចំពោះការដឹកនាំនីតិវិធីបណ្តឹង) មាត្រា ៩៤ (ការលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួនដែលបានដាក់យឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ) មាត្រា ១៨១ (សាលក្រមរបៀប) ជាដើម ។ ការសម្រេចសេចក្តីដូចបានរៀបរាប់ខាងលើនេះ គឺជាការសម្រេចសេចក្តីនៅពាក់កណ្តាលទីដែលក្លាយទៅជាមូលដ្ឋាននៃសាលក្រមសម្រេចអង្គសេចក្តី ហេតុដូច្នេះ ត្រូវធ្វើឧបាស្រ័យជាមួយនឹងសាលក្រមសម្រេចអង្គសេចក្តី ។

Code of Civil Procedure (Japan)
**Article 283** (Decision subject to adjudication of *koso*-appellate court)
A decision preceding a final judgment shall be subject to the adjudication of the *koso*-appellate court. However, this shall not apply

to either a decision against which making an appeal in prohibited, or a decision against which an appeal may be made by means of a *kokoku*-appeal.

**មាត្រា ២៦៣.~** ការលះបង់សិទ្ធិប្តឹងឧទ្ធរណ៍

១- ភាគីអាចលះបង់ចោលនូវសិទ្ធិប្តឹងឧទ្ធរណ៍របស់ខ្លួនបាន ។

២- នៅក្រោយពេលបានប្តឹងឧទ្ធរណ៍រួចហើយ សេចក្តីថ្លែងការណ៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើជាមួយគ្នានឹងការដកពាក្យបណ្តឹងឧទ្ធរណ៍ ។

(កំណត់)

កថាខណ្ឌទី ១ នេះតម្រូវនឹងមាត្រា 284 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ ចំពោះការអាចព្រមព្រៀងមិនប្តឹងឧទ្ធរណ៍នេះ សូមមើលកំណត់នៅមាត្រា ២៦០ (សាលក្រមដែលអាចប្តឹងឧទ្ធរណ៍បាន ជាអាទិ៍) ។ កថាខណ្ឌទី ២ នេះតម្រូវនឹងមាត្រា 173 កថាខណ្ឌទី ២ នៃបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

Code of Civil Procedure (Japan)
**Article 284** (Waiver of right to make *koso*-appeal)
The right to make a *koso*-appeal may be waived.

Rules of Civil Procedure (Japan)
Book III : Appeal (*Joso*), Chapter I : *Koso*-Appeal
**Article 173** (Waiver of right to make *koso*-appeal / The Code Article 284)
1. A waiver of the right to make a *koso*-appeal shall be effected by filing a statement to the effect with the court of first instance in cases where no *koso*-appeal has been filed, or with the court where the record of the case exists in cases where a *koso*-appeal has already been filed.
2. A statement referred to in the preceding paragraph after filing a *koso*-appeal shall be accompanied by a withdrawal of the *koso*-appeal.
3. In cases where a statement referred to in paragraph 1 has been filed, the court clerk shall give notice of that fact to the adversary party.

**មាត្រា ២៦៤.~** អំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍

១- បណ្តឹងឧទ្ធរណ៍ត្រូវធ្វើនៅក្នុងអំឡុងពេល ១ (មួយ) ខែ ដោយគិតចាប់តាំងពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រម ឬ ថ្ងៃដែលបានជូនដំណឹងអំពីដីកាសម្រេចច្រានចោល ឬ លើកចោលនូវបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ។ ប៉ុន្តែ ករណីនេះមិនមែនជាការរារាំងលើអានុភាពនៃបណ្តឹងឧទ្ធរណ៍ដែលបានដាក់នៅមុនអំឡុងពេលនេះឡើយ ។

២- អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

(កំណត់)

ក្រៅពីផ្នែកដែលចែងអំពីសាលក្រមកំបាំងមុខចេញ តម្រូវនឹងមាត្រា 285 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

ចំពោះផ្នែកដែលចែងអំពីសាលក្រមកំបាំងមុខ សូមមើលកំណត់ (2) នៃមាត្រា ២០៤ (បណ្តឹងទាស់) ។ ក្នុងករណី

ដែលភាគីគិតថាអាចប្តឹងទាស់ចំពោះសាលក្រមកំបាំងមុខបាន តែការប្តឹងទាស់នោះត្រូវតុលាការ ច្រានចោល ឬ លើកចោលវិញនោះ ហើយអំឡុងពេល ១ ខែ ដែលអាចធ្វើឧទ្ធរណ៍បាននោះ ក៏កន្លងហួសទៅ នេះជាហេតុមិនសមស្របមួយចំពោះអ្នកចាញ់ក្តីដោយសាលក្រមកំបាំងមុខ ប្រសិនបើជននេះមិនអាចប្តឹងឧទ្ធរណ៍បានទេ ។ ហេតុដូច្នេះហើយ យើងបានចែងថា អំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍ត្រូវគិតចាប់តាំងពីថ្ងៃដែលបានជូនដំណឹងអំពីដីកាសម្រេចច្រានចោល ឬ លើកចោលនូវបណ្តឹងទាស់លើសាលក្រមកំបាំងមុខ ។ កថាខណ្ឌទី ១ វាក្យខណ្ឌចុងក្រោយ មានន័យថា ភាគីអាចប្តឹងឧទ្ធរណ៍បាននៅមុនថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រម ឬ ថ្ងៃដែលបានជូនដំណឹងអំពីការសម្រេចច្រានចោល ឬ លើកចោលនូវបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ។ ម្យ៉ាងទៀត ភាគីដែលមានសិទ្ធិប្តឹងទាស់ តែបានលះបង់សិទ្ធិនេះ ក៏អាចធ្វើបណ្តឹងឧទ្ធរណ៍នៅមុនអំឡុងពេលនៃការប្តឹងឧទ្ធរណ៍បានដែរ ។

អំឡុងពេលប្តឹងនេះ ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនកំណត់ថា ២ សប្តាហ៍ ចំណែកឯក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ ព្រមទាំងក្រមនីតិវិធីរដ្ឋប្បវេណីអាល្លឺម៉ង់ ក្រមនីតិវិធីរដ្ឋប្បវេណីអូទ្រីស ក្រមនីតិវិធីរដ្ឋប្បវេណីអ៊ីតាលី ក្រមនីតិវិធីរដ្ឋប្បវេណីបារាំង និង បទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីអាមេរិកវិញ ចែងថា អំឡុងពេលដែលអាចប្តឹងឧទ្ធរណ៍បាន គឺ ១ ខែ ។

<u>Code of Civil Procedure (Japan)</u>
**Article 285** (Period for filing *koso*-appeal)
A *koso*-appeal shall be filed within the peremptory term of two weeks of the day on which the judgment paper or the record referred to in Article 254, paragraph 2 is served. However, this shall not obstruct the validity of a *koso*-appeal filed prior to the foregoing period.

**មាត្រា ២៦៥.-** របៀបប្តឹងឧទ្ធរណ៍

១- ដើម្បីប្តឹងឧទ្ធរណ៍ ភាគីត្រូវដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទៅតុលាការដើម ។ នៅក្នុងករណីនេះ តុលាការដើម ត្រូវផ្ញើឱ្យបានឆាប់រហ័សនូវពាក្យបណ្តឹងឧទ្ធរណ៍ និង សំណុំរឿង ទៅតុលាការនៃបណ្តឹងឧទ្ធរណ៍ ។

២- ពាក្យបណ្តឹងឧទ្ធរណ៍ត្រូវសរសេរនូវចំណុចដូចខាងក្រោមនេះ :

**ក-** ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

**ខ-** សញ្ញាណសាលក្រមនៃការជំនុំជម្រះលើកទី ១ និង សេចក្តីដែលប្តឹងឧទ្ធរណ៍ចំពោះសាលក្រមនោះ ។

៣- ក្នុងករណីដែលពុំបានសរសេរច្បាស់លាស់អំពីមូលហេតុនៃការទាមទារឱ្យលុបចោល ឬ ផ្លាស់ប្តូរនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ ក្នុងពាក្យបណ្តឹងឧទ្ធរណ៍ទេ ដើមបណ្តឹងឧទ្ធរណ៍គប្បីដាក់លិខិតជាលាយល័ក្ខណ៍អក្សរដែលសរសេរអំពីចំណុចនោះ ទៅតុលាការនៃបណ្តឹងឧទ្ធរណ៍ នៅក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់តាំងពីថ្ងៃដែលបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍នោះ ។

( កំណត់ )

កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ នេះ តម្រូវនឹងមាត្រា 286 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ ចំពោះពាក្យបណ្ដឹងឧទ្ធរណ៍ វាធ្វើឱ្យមានការងាយស្រួលចំពោះភាគីដែលប្ដឹងឧទ្ធរណ៍ បើគាត់អាចដាក់ពាក្យបណ្ដឹងនោះបាន នៅតុលាការនៃការជំនុំជម្រះលើកទី ១ ( សាលាដំបូង ) ដោយមិនបាច់ទៅឆ្ងាយ ។ ម៉្យាងទៀត កិច្ចការផ្ញើសំណុំរឿងដោយសាលាដំបូងក៏អាចធ្វើទៅបានលឿនដែរ ។ ឃ្លាខាងក្រោយនៃកថាខណ្ឌទី ១ នេះ មានអត្ថន័យដូចគ្នានឹងឃ្លាខាងក្រោយនៃមាត្រា ២៨៧ ( របៀបប្ដឹងសាទុក្ខ ) ។

កថាខណ្ឌទី ៣ នេះតម្រូវនឹងមាត្រា 182 នៃបទប្បញ្ញត្តិស្ដីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ ការដាក់លិខិតដែលសរសេរអំពីមូលហេតុនៃបណ្ដឹងឧទ្ធរណ៍នេះ គឺដើម្បីធ្វើឱ្យតុលាការនៃបណ្ដឹងឧទ្ធរណ៍ងាយស្រួលក្នុងការស្វែងរកចំណុចវិវាទនៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍បានឆាប់ ហើយដោយខុសអំពីការប្ដឹងសាទុក្ខ នៅក្នុងគន្លីដែលចែងអំពីបណ្ដឹងឧទ្ធរណ៍នេះ គេពុំបានចែងអំពីអានុភាពនៃការមិនដាក់លិខិតនេះឡើយ ដូច្នេះ ទោះជាពុំបានដាក់នូវលិខិតដែលសរសេរអំពីមូលហេតុនៃបណ្ដឹងឧទ្ធរណ៍ក៏ដោយ ក៏បណ្ដឹងឧទ្ធរណ៍នោះមិនមានភាពមិនស្របច្បាប់ ហើយមិនត្រូវបានលើកចោលដែរ ( មូលហេតុនៃបណ្ដឹងឧទ្ធរណ៍មិនមែនជាចំណុចចាំបាច់ដែលត្រូវសរសេរក្នុងពាក្យបណ្ដឹងឧទ្ធរណ៍ដូចមានចែងក្នុងកថាខណ្ឌទី ២ ឡើយ ) ។

Code of Civil Procedure (Japan)
**Article 286** (Method of filing *koso*-appeal)
1. A *koso*-appeal shall be filed by submittend a *koso*-appeal document to the court of the first instance.
2. The following matters shall be included in the *koso*-appeal document:
i. the parties and their legal representatives;
ii. the identification of the judgment in the first instance and a statement that the *koso*-appeal is being made against such judgment.

Rules of Civil Procedure (Japan)
**Article 182** (Document stating grounds for reversal of judgment in first instance)
in cases where a *koso*-appeal document does not include a concrete statement of grounds for requesting reversal or change of the judgment in the first instance, the *koso*-appellant shall submit a document stating such grounds to the *koso*-appellate court within 50 days after filing of the *koso*-appeal.

**មាត្រា ២៦៦.-** សិទ្ធិពិនិត្យពាក្យបណ្ដឹងឧទ្ធរណ៍របស់តុលាការនៃបណ្ដឹងឧទ្ធរណ៍

១- ក្នុងករណីដែលពាក្យបណ្ដឹងឧទ្ធរណ៍ផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ២៦៥ ( របៀបប្ដឹងឧទ្ធរណ៍ ) នៃក្រមនេះ តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវកំណត់អំឡុងពេលសមរម្យមួយ និង បង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតនៅក្នុងអំឡុងពេលនោះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលពន្ធសម្រាប់ដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ មិនត្រូវបានបង់តាមបញ្ញត្តិនៃកថាខណ្ឌទី ៤ មាត្រា ៦១ ( ពន្ធដាក់ពាក្យសុំ ) នៃក្រមនេះ ។

២- ករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើដើមបណ្ដឹងឧទ្ធរណ៍មិនបានកែតម្រូវចំណុចខ្វះខាតនោះទេ តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវលើកចោលពាក្យបណ្ដឹងឧទ្ធរណ៍នោះ ដោយដីកាសម្រេច ។

៣- ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើ អាចប្ដឹងជំទាស់បាន ។

(កំណត់)

យើងចែងឡើងវិញដោយមិនយកអត្ថន័យថាអនុវត្តដូចគ្នា ដូចមាត្រា 288 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ កថាខណ្ឌទី ២ នៃមាត្រានេះទទួលស្គាល់ថា នៅក្នុងករណីដែលភាគីនៃបណ្តឹងឧទ្ធរណ៍ពុំបានកែតម្រូវទៅលើចំណុចដែលខ្វះ ឬ មិនបានបង់ពន្ធសម្រាប់ដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ជាដើម ដែលជាស្ថានភាពច្បាស់ នោះតុលាការត្រូវលើកចោលពាក្យបណ្តឹងឧទ្ធរណ៍នោះ ដោយដីកាសម្រេច (សូមមើល មាត្រា ២៦៨ (ការលើកចោលបណ្តឹងឧទ្ធរណ៍ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់)) ។

Code of Civil Procedure (Japan)
**Article 288** (Right of presiding judge to examine *koso*-appeal document)
The provisions of Article 137 shall apply *mutatis mutandis* to cases where a *koso*-appeal document contravenes the provisions of Article 286, paragraph 2, and where the fee for filing the *koso*-appeal has not bee paid as required by the Civil Procedure Costs Act.

**មាត្រា ២៦៧.-** ការបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍

១- ពាក្យបណ្តឹងឧទ្ធរណ៍ត្រូវបញ្ជូនទៅចុងបណ្តឹងឧទ្ធរណ៍ ។

២- បញ្ញត្តិនៃមាត្រា ២៦៦ (សិទ្ធិពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍របស់តុលាការនៃបណ្តឹងឧទ្ធរណ៍) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមិនអាចបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍បាន រួមទាំងករណីដែលមិនបានបង់ជាមុននូវសោហ៊ុយចាំបាច់សម្រាប់បញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍ ។

(កំណត់)

តម្រូវនឹងមាត្រា 289 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ ការបញ្ជូនបណ្តឹងឧទ្ធរណ៍ទៅចុងបណ្តឹងឧទ្ធរណ៍ជាភារកិច្ចរបស់ក្រឡាបញ្ជី នៃតុលាការនៃបណ្តឹងឧទ្ធរណ៍ (សូមមើលមាត្រា ២៤៦ (គោលការណ៍នៃការបញ្ជូនដោយឆន្ទានុសិទ្ធិជាអាទិ៍)) ។ ករណីចែងក្នុងកថាខណ្ឌទី ២ នេះ តុលាការត្រូវលើកចោលពាក្យបណ្តឹងឧទ្ធរណ៍នោះដោយដីកាសម្រេច ។ ចំពោះករណីដែលមិនអាចបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍ សូមមើលកំណត់នៃមាត្រា ៧៩ (ការបញ្ជូនពាក្យបណ្តឹង) ។

Code of Civil Procedure (Japan)
**Article 289** (Service of *koso*-appeal document)
1. A *koso*-appeal document shall be served on the appellee.
2. The provisions of Article 137 shall apply *mutatis mutandis* to cases where a *koso*-appeal document cannot be served (including cases where the dee necessary for serving the *koso*-appeal document has not been prepaid.

**មាត្រា ២៦៨.-** ការលើកចោលបណ្តឹងឧទ្ធរណ៍ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់

ក្នុងករណីដែលបណ្តឹងឧទ្ធរណ៍មានលក្ខណៈផ្ទុយនឹងច្បាប់ ហើយចំណុចខ្វះខាតនោះមិនអាចកែតម្រូវបានទេ តុលាការនៃបណ្តឹងឧទ្ធរណ៍អាចលើកចោលបណ្តឹងឧទ្ធរណ៍នោះ ដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ ដោយ

សាលដីកាបាន ។

(កំណត់)

តម្រូវនឹងមាត្រា 290 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ ជាគោលការណ៍ ការវិនិច្ឆ័យទៅលើបណ្តឹងឧទ្ធរណ៍ថាត្រឹមត្រូវតាមច្បាប់ ឬអត់នោះ ត្រូវបើកការទាញហេតុផលដោយផ្ទាល់មាត់ (គោលការណ៍ចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១១៤ (ភាពចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់)) ប៉ុន្តែ ចំពោះបណ្តឹងដែលមិនអាចកែតម្រូវចំណុចខ្វះបាន ដូចជាករណីដែលបណ្តឹងឧទ្ធរណ៍នោះបានប្តឹងនៅក្រោយពេលដែលបានកំណត់ឱ្យប្តឹងឧទ្ធរណ៍ ជាដើម ទោះជាធ្វើការទាញហេតុផលដោយផ្ទាល់មាត់ក៏ដោយ វាមិនបានផលប្រយោជន៍អ្វីឡើយ ហេតុដូច្នេះ នៅក្នុងទីនេះ យើងទទួលស្គាល់លទ្ធភាពក្នុងការលើកចោលបណ្តឹងឧទ្ធរណ៍ដោយសាលដីកា ដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ ។ មាត្រា ២៦៦ (សិទ្ធិពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍របស់តុលាការនៃបណ្តឹងឧទ្ធរណ៍) និង មាត្រា ២៦៧ (ការបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍) បានចែងអំពីការលើកពាក្យបណ្តឹងឧទ្ធរណ៍ចោល ដោយដីកាសម្រេចរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ រីឯក្នុងមាត្រានេះវិញ យើងចែងអំពីការលើកចោលបណ្តឹងឧទ្ធរណ៍ដោយសាលដីការបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ ។

<u>Code of Civil Procedure (Japan)</u>
**Article 290** (Dismissal of *koso*-appeal without proceeding to oral argument)
In cases where a *koso*-appeal is illegitimate and it is impossible to rectify such defect, the *koso*-appellate court may dismiss the *koso*-appeal by judgment without proceeding to oral argument.

**មាត្រា ២៦៩._** ការដកពាក្យបណ្តឹងឧទ្ធរណ៍

១- បណ្តឹងឧទ្ធរណ៍អាចដកវិញបាន រហូតដល់ពេលដែលសាលដីកាចុងក្រោយរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវបានប្រកាស ។

២- ការដកពាក្យបណ្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ។ ប៉ុន្តែ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សា ការដកពាក្យបណ្តឹងឧទ្ធរណ៍នោះ អាចធ្វើឡើងដោយផ្ទាល់មាត់បាន ។

៣- ផ្នែកនៃបណ្តឹងឧទ្ធរណ៍ដែលត្រូវបានដកចេញ ត្រូវចាត់ទុកថាមិនបានចាត់ការតាំងពីដំបូងនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ។

៤- បញ្ញត្តិនៃមាត្រា ២១៩ (ការចាត់ទុកថា ដកពាក្យបណ្តឹង) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការចាត់ទុកថា ដកពាក្យបណ្តឹងឧទ្ធរណ៍ ។

(កំណត់)

តម្រូវនឹងមាត្រា 292 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ ការដកពាក្យបណ្ដឹងឧទ្ធរណ៍នេះ គឺជាការដកនូវសេចក្ដីឧបាស្រ័យទៅលើសាលក្រមនៃការជំនុំជម្រះលើកទី ១ ហើយដោយមូលហេតុដកពាក្យបណ្ដឹងឧទ្ធរណ៍នេះ នីតិវិធីនៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ត្រូវបានបញ្ចប់ ។ ការដកពាក្យបណ្ដឹងឧទ្ធរណ៍នេះពុំមានអានុភាពទៅលើនីតិវិធីនៃការជំនុំជម្រះលើកទី ១ ព្រមទាំងសាលក្រមនៃការជំនុំជម្រះលើកទី ១ ឡើយ ។ម្យ៉ាងទៀត ការដកពាក្យបណ្ដឹង (បណ្ដឹងដើម) នៅតុលាការនៃបណ្ដឹងឧទ្ធរណ៍ អាចធ្វើទៅបាន ។ ក្នុងករណីនេះ ការចាត់ការបណ្ដឹងទាំងមូល រួមទាំងសាលក្រមនៃការជំនុំជម្រះលើកទី ១ នឹងត្រូវរលត់ដោយអានុភាពប្រតិសកម្ម ។ ដូចគ្នានឹងបញ្ញត្តិនៃមាត្រា ២១៩ (ការចាត់ទុកថាដកពាក្យបណ្ដឹង) នៅក្នុងករណីដែលគូភាគីសងខាងមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទ ហើយមិនបានដាក់ពាក្យសុំឱ្យតុលាការកំណត់កាលបរិច្ឆេទជាថ្មីទៀតក្នុងអំឡុងពេល ១ ខែទេ និង ក្នុងករណីដែលគូភាគីសងខាងបានអវត្តមាននៅកាលបរិច្ឆេទ ២ ដងជាប់ៗគ្នា តុលាការត្រូវចាត់ទុកថា បណ្ដឹងឧទ្ធរណ៍នោះ ត្រូវបានដកចេញហើយ ។

<u>Code of Civil Procedure (Japan)</u>
**Article 292** (Withdrawal of *koso*-appeal)
1. A *koso*-appeal may be withdrawn before the entry of a final judgment in the *koso*-appeal instance.
2. The provisions of Article 261, paragraph 3, Article 262, paragraph 1, and Article 263 shall apply *mutatis mutandis* to a withdrawal of a *koso*-appeal.

**មាត្រា ២៧០.-** បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ

១- ចុងបណ្ដឹងឧទ្ធរណ៍ ទោះជាសិទ្ធិប្ដឹងឧទ្ធរណ៍នោះត្រូវបានរលត់ហើយក៏ដោយ ក៏អាចប្ដឹងឧទ្ធរណ៍បន្ទាប់បន្សំបានដែររហូតដល់ពេលដែលការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវបានបញ្ចប់ ។

២- បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំត្រូវអស់អានុភាព នៅក្នុងករណីដែលពាក្យបណ្ដឹងឧទ្ធរណ៍ ត្រូវបានដក ឬ នៅក្នុងករណីដែលបណ្ដឹងឧទ្ធរណ៍នោះ ត្រូវបានលើកចោលដោយសារមានភាពផ្ទុយនឹងច្បាប់ ។ ប៉ុន្តែ ចំពោះបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំដែលមានល័ក្ខខ័ណ្ឌនៃបណ្ដឹងឧទ្ធរណ៍គ្រប់គ្រាន់ ត្រូវចាត់ទុកថាជាបណ្ដឹងឧទ្ធរណ៍ឯករាជ្យ ។

៣- បញ្ញត្តិស្ដីពីបណ្ដឹងឧទ្ធរណ៍ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ ។

(កំណត់)

ដូចគ្នានឹងមាត្រា 293 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ (incidental *koso*-appeal, appel incident) គឺជាពាក្យសុំរបស់ចុងបណ្ដឹងឧទ្ធរណ៍ ដែលប្ដឹងដោយបន្ទាប់បន្សំជាមួយនឹងបណ្ដឹងឧទ្ធរណ៍ ដើម្បីផ្លាស់ប្ដូរនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ សម្រាប់ផលប្រយោជន៍របស់ខ្លួន ។ បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំនេះ នៅក្រោយពេលលះបង់សិទ្ធិប្ដឹងឧទ្ធរណ៍ (ដែលចែងនៅមាត្រា ២៦៣ (ការលះបង់សិទ្ធិប្ដឹងឧទ្ធរណ៍)) ឬ ក្រោយពេលហួសអំឡុងពេលសម្រាប់ប្ដឹងឧទ្ធរណ៍ (មាត្រា ២៦៤ (អំឡុងពេល

សម្រាប់ប្ដឹងឧទ្ធរណ៍)) ក៏ដោយ ប្រសិនបើដើមបណ្ដឹងឧទ្ធរណ៍បានប្ដឹងមក ភាគីម្ខាងទៀតនោះអាចដាក់បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំដោយភ្ជាប់ជាមួយនឹងបណ្ដឹងឧទ្ធរណ៍នោះបាន ។

ឧទាហរណ៍:

នៅក្នុងការជំនុំជម្រះលើកទី ១ ដើមចោទបានទាមទារឱ្យចុងចម្លើយសងនូវចំនួន 100 (ប្រាក់) តែតុលាការបានចេញសាលក្រមដែលទទួលស្គាល់តែចំនួន 70 ហើយច្រានចោលនូវចំនួន 30 ហើយចុងចម្លើយបានប្ដឹងឧទ្ធរណ៍នៅក្នុងអំឡុងពេលដែលអាចធ្វើបាន ។ សាលដីកានៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ដោយយោងទៅតាមគោលការណ៍ហាមឃាត់មិនឱ្យផ្លាស់ប្ដូរអ្វីដែលខូចប្រយោជន៍ (មាត្រា ២៧៨ (ទំហំនៃការផ្លាស់ប្ដូរសាលក្រមនៃការជំនុំជម្រះលើកទី ១)) នោះ តុលាការអាចជំនុំជម្រះដោយបង្គាប់ឱ្យសងតាមសាលដីកាបានត្រឹមតែចំនួន 70 ឬ ចំនួនក្រោម 70 នោះតែប៉ុណ្ណោះ ។ ប៉ុន្ដែ ប្រសិនបើដើមចោទ (ដែលជាចុងបណ្ដឹងឧទ្ធរណ៍) ប្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ ទៅលើចំនួន 30 ដែលជាផ្នែកដែលតុលាការនៃការជំនុំជម្រះលើកទី ១ បានច្រានចោលនោះ តុលាការនៃបណ្ដឹងឧទ្ធរណ៍ អាចចេញសាលដីកាបង្គាប់ឱ្យដើមបណ្ដឹងឧទ្ធរណ៍សងចំនួន 100 នោះ ក៏បានដែរ ។

បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ គឺការធ្វើឧបាស្រ័យដោយភ្ជាប់ជាមួយនឹងបណ្ដឹងឧទ្ធរណ៍របស់ភាគីម្ខាងទៀត ចំពោះចំណុចដែលភាគីនោះមិនបានប្ដឹងឧទ្ធរណ៍ដោយខ្លួនឯង ។ នៅត្រង់កន្លែងនេះ ប្រសិនបើ បណ្ដឹងឧទ្ធរណ៍ដែលជាមូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំនោះគ្មានទេ វាក៏នឹងអស់នូវអានុភាពដែរ ។ ប៉ុន្ដែ ប្រសិនបើបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំនោះធ្វើឡើងនៅក្នុងអំឡុងពេលដែលអនុញ្ញាតឱ្យប្ដឹងឧទ្ធរណ៍ ហើយមានគ្រប់គ្រាន់នូវល័ក្ខខ័ណ្ឌផ្សេងទៀតនៃបណ្ដឹងឧទ្ធរណ៍ បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំនោះត្រូវជាបណ្ដឹងឧទ្ធរណ៍ដែលឯករាជ្យវិញ ។

នៅពេលធ្វើបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ ត្រូវដាក់ពាក្យបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ (មាត្រា ២៦៥ (របៀបប្ដឹងឧទ្ធរណ៍)) ហើយប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវពិនិត្យ (មាត្រា ២៦៦ ((សិទ្ធិពិនិត្យពាក្យបណ្ដឹងឧទ្ធរណ៍របស់តុលាការនៃបណ្ដឹងឧទ្ធរណ៍)) ។ ជាមួយគ្នានេះ ចាំបាច់ត្រូវបញ្ជូនទៅឱ្យដើមបណ្ដឹងឧទ្ធរណ៍ (មាត្រា ២៦៧ (ការបញ្ជូនពាក្យបណ្ដឹងឧទ្ធរណ៍)) ។ មានន័យថា ចំពោះបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំនេះ បញ្ញត្តិស្ដីពីបណ្ដឹងឧទ្ធរណ៍ ត្រូវយកមកអនុវត្ត ។

Code of Civil Procedure (Japan)
**Article 293** (Incidental *koso*-appeal)
1. Even after the right to make a *koso*-appeal has extinguished, an appellee may make an incidental *koso*-appeal up to the time of the conclusion og oral argument.
2. An incidental *koso*-appeal shall become invalid in cases where the *koso*-appeal upon which it is based has been withdrawn or where there has been a dismissal of the *koso*-appeal due to its illegitimacy. However, an incidental *koso*-appeal which satisfied the requirements of a *koso*-appeal shall be deemed to be an independent *koso*-appeal.
3. The provisions concerning *koso*-appeal shall apply to an incidental *koso*-appeal. However, an incidental *koso*-appeal may be filed by submitting an incidental *koso*-appeal document to the *koso*-appellate court.

**មាត្រា ២៧១.-** ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្នដោយតុលាការនៃបណ្ដឹងឧទ្ធរណ៍

១- តុលាការនៃបណ្ដឹងឧទ្ធរណ៍អាចប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ត្រឹមតែផ្នែកដែលពុំមានពាក្យសុំប្ដឹងឧបាស្រ័យ

ចំពោះសាលក្រមនៃការជំនុំជម្រះលើកទី ១ បាន តាមពាក្យសុំ ដោយដីកាសម្រេច ។

២- ចំពោះការសម្រេចសេចក្ដីរបស់តុលាការនៃបណ្ដឹងឧទ្ធរណ៍អំពីការអនុវត្តជាបណ្ដោះអាសន្ន មិនអាចធ្វើឧបាស្រ័យបានឡើយ ។

（កំណត់）

តម្រូវនឹងមាត្រា 294 និង មាត្រា 295 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

ឧទាហរណ៍:

នៅតុលាការនៃការជំនុំជម្រះលើកទី ១ ដើមចោទបានទាមទារឱ្យសងនូវចំនួន 100（ប្រាក់）តែតុលាការបានចេញសាលក្រមដោយទទួលស្គាល់តែចំនួន 80 តែប៉ុណ្ណោះ ទោះជានៅក្នុងករណីដែលដើមចោទតែឯងបានប្ដឹងឧទ្ធរណ៍ក៏ដោយក៏សាលក្រមនៃការជំនុំជម្រះលើកទី ១ នេះពុំទាន់ស្ថាពរទាំងមូលឡើយ ។ យើងហៅថាជាគោលការណ៍អវិភាគនៃបណ្ដឹងឧទ្ធរណ៍ ។ ហើយជាគោលការណ៍ ចំពោះចំនួន 80 នេះ（ដែលសាលក្រមទទួលស្គាល់ និង ចុងចម្លើយមិនបានប្ដឹងឧទ្ធរណ៍）ក៏ពុំកើតមានអានុភាពដើម្បីអនុវត្តដែរ ។ ប៉ុន្ដែ ក្នុងករណីនេះ ចុងចម្លើយពុំបានប្ដឹងឧទ្ធរណ៍ទេ ហើយដោយសារមានគោលការណ៍ហាមឃាត់មិនឱ្យផ្លាស់ប្ដូរអ្វីដែលខូចផលប្រយោជន៍（មាត្រា ២៧៨（ទំហំនៃការផ្លាស់ប្ដូរសាលក្រមនៃការជំនុំជម្រះលើកទី ១））យើងអាចគិតថា ចំនួន 80 នេះនឹងមិនត្រូវបានលុបចោលនៅតុលាការនៃបណ្ដឹងឧទ្ធរណ៍ទេ ហេតុដូច្នេះ តុលាការអាចទទួលស្គាល់ការអនុវត្តជាបណ្ដោះអាសន្ន ចំពោះចំនួន 80 ដែលដើមចោទឈ្នះនេះបាន ។ កថាខណ្ឌទី ២ ដែលចែងថា មិនទទួលស្គាល់ពាក្យសុំប្ដឹងឧបាស្រ័យចំពោះការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ននេះ ព្រោះថាត្រូវធ្វើការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ឬ អត់នោះ ត្រូវសម្រេចជាមួយនឹងអង្គសេចក្ដីដូច្នេះការប្ដឹងឧបាស្រ័យដោយឯករាជ្យដាច់តែឯងនោះ ពុំត្រឹមត្រូវឡើយ ។ ដោយពុំបានចែងនៅក្នុងមាត្រានេះ ចំពោះដីកាសម្រេចលើកចោលពាក្យសុំប្រកាសឱ្យអនុវត្តបណ្ដោះអាសន្ននេះ មិនទទួលស្គាល់ការប្ដឹងជំទាស់ឡើយ ។

<u>Code of Civil Procedure (Japan)</u>
**Article 294** (Declaration of provisional execution of judgment in first instance)
The *koso*-appellate court may, upon motion, by ruling, make a declaration of provisional execution only regarding any part of the judgment in the first instance against which no appeal has been made.
**Article 295** (Appeal against decision relating to provisional execution)
No appeal may be made against a decision in the *koso*-appeal instance relating to provisional execution. However, an immediate *kokoku*-appeal may by made against the ruling dismissing a motion referred to in the preceding paragraph.

**មាត្រា ២៧២.-** ទំហំនៃការទាញហេតុផលដោយផ្ទាល់មាត់ ជាអាទិ៍

១- ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវធ្វើ ត្រឹមតែក្នុងទំហំដែលភាគីបានទាមទារឱ្យផ្លាស់ប្ដូរនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ តែប៉ុណ្ណោះ ។

២- ភាគីត្រូវធ្វើសេចក្ដីថ្លែងការណ៍អំពីលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់នៅក្នុងការជំនុំជម្រះលើកទី ១ ។

(កំណត់)

តម្រូវនឹងមាត្រា 296 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ កថាខណ្ឌទី ១ នេះ ដោយយោលទៅតាម "គោលការណ៍ហាមឃាត់មិនឱ្យផ្លាស់ប្តូរអ្វីដែលខូចប្រយោជន៍" (មាត្រា ២៧៨ (ទំហំនៃការផ្លាស់ប្តូរសាលក្រមនៃការជំនុំជម្រះលើកទី ១)) នោះ យើងចែងអំពីទំហំដែលចាំបាច់ត្រូវយកមកធ្វើការវិនិច្ឆ័យ ព្រោះហេតុថា តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវយកមកវិនិច្ឆ័យថា ត្រឹមត្រូវ ឬអត់ អំពីផ្នែកដែលត្រូវបានឧបាស្រ័យ ចំពោះសាលក្រមរបស់តុលាការនៃការជំនុំជម្រះលើកទី ១ នោះ ។ ឯកថាខណ្ឌទី ២ ចែងអំពី "ការជំនុំជម្រះបន្ត (resumed trial)" ។ តុលាការនៃបណ្តឹងឧទ្ធរណ៍តម្រូវឱ្យយកនូវឯកសារទាំងឡាយដែលបានប្រមូលនៅក្នុងការជំនុំជម្រះលើកទី ១ យកមកធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដើម្បីវិនិច្ឆ័យ (យើងហៅថា "ការទាញហេតុផលសាជាថ្មី") តុលាការនៃបណ្តឹងឧទ្ធរណ៍នឹងយកឯកសារនេះ និង ឯកសារដែលខ្លួនបានប្រមូល មកវិភាគ ដើម្បីទទួលស្គាល់ដោយខ្លួនឯងទៅលើអង្គហេតុ និង អង្គច្បាប់ ហើយសម្រេចថា បណ្តឹងឧទ្ធរណ៍នោះមានភាពត្រឹមត្រូវ ឬអត់ ដោយប្រៀបធៀបលទ្ធផលនៃការវិនិច្ឆ័យនោះ ជាមួយនឹងសាលក្រមនៃការជំនុំជម្រះលើកទី ១ ។ "ការទទួលស្គាល់ដោយខ្លួនឯង ទៅលើអង្គហេតុ" នេះ មានអត្ថន័យដូចគ្នានឹងមាត្រា ២០ វាក្យខណ្ឌទី ១ នៃសេចក្តីព្រាងច្បាប់ស្តីពីការចាត់តាំងតុលាការ (សេចក្តីព្រាង 11/08/2000) ។ ហើយនៅក្នុងមាត្រា ២៧៣ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីនីតិវិធីនៃការជំនុំជម្រះលើកទី ១) ខាងក្រោមនេះ ចែងថា ក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ក៏អាចប្រមូលឯកសារដូចគ្នានឹងការជំនុំជម្រះលើកទី ១ ដែរ ។ ហើយនៅក្នុងមាត្រា ២៧៤ (អានុភាពនៃសកម្មភាពបណ្តឹងនៅក្នុងការជំនុំជម្រះលើកទី ១ ជាអាទិ៍) ខាងក្រោមនេះ មានចែងអំពីអានុភាពរបស់សកម្មភាពបណ្តឹងនៅក្នុងការជំនុំជម្រះលើកទី ១ នៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ផងដែរ ។

Code of Civil Procedure (Japan)
**Article 296** (Scope, etc., of oral argument)
1. Oral argument shall be conducted only to the extent made necessary by the party's demand for change of the judgment rendered in the first instance.
2. The parties shall state the result of the oral argument in the first instance.

**មាត្រា ២៧៣.-** ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីនីតិវិធីនៃការជំនុំជម្រះលើកទី ១

លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេស បញ្ញត្តិនៃគន្ថីទី ២ (នីតិវិធីនៃការជម្រះក្តីលើកទី ១) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះមាត្រា ៨០ (ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង) មាត្រា ១០៤ (ការសាកល្បងផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) ផ្នែកទី ៥ (សាលក្រមកំបាំងមុខ) ជំពូកទី ៥ នៃគន្ថីទី ២ និង ជំពូកទី ៧ (បទប្បញ្ញត្តិពិសេសស្តីពីរឿងក្តីចំនួនទឹកប្រាក់តិច) នៃគន្ថីទី ២ នៃក្រមនេះ ។

( កំណត់)

ពាក្យថា "បញ្ញត្តិពិសេស" នេះឧទាហរណ៍ថា: មាត្រា ២៦៥ ( របៀបប្តឹងឧទ្ធរណ៍) ដែលចែងអំពីចំណុចត្រូវសរសេរក្នុងពាក្យបណ្តឹងឧទ្ធរណ៍ ហេតុដូចនេះ បញ្ញត្តិស្តីពីពាក្យបណ្តឹងក្នុងគន្លីទី ២ មិនត្រូវយកមកអនុវត្តឡើយ ។ តុលាការនៃបណ្តឹងឧទ្ធរណ៍អាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន នៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ។ ប៉ុន្តែ ដោយសារបានធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅតុលាការនៃការជំនុំជម្រះលើកទី ១ រួចហើយនោះ តុលាការនៃបណ្តឹងឧទ្ធរណ៍ពុំចាំបាច់ធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលសាជាថ្មីទៀតឡើយ ។ ម្ល៉ោះហើយ គោលការណ៍សាកល្បងផ្សះផ្សាជាមុន ( មាត្រា ១០៤ (ការសាកល្បងផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល)) ក៏មិនត្រូវយកមកអនុវត្តឡើយ ។ ឯចំណែករឿងក្តីចំនួនទឹកប្រាក់តិចវិញ ដោយវាជានីតិវិធីដែលត្រូវធ្វើតែនៅក្នុងការជំនុំជម្រះលើកទី ១ នោះ បទប្បញ្ញត្តិនេះពុំអនុវត្ត ចំពោះបណ្តឹងឧទ្ធរណ៍ឡើយ ។

អំពីការទទួលស្គាល់សាលក្រមកំបាំងមុខ នៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍នេះ យើងបានពិភាក្សាជាមួយក្រុមការងារផ្នែកនីតិវិធីរដ្ឋប្បវេណីហើយ លទ្ធផលគឺមិនទទួលស្គាល់ទេ ។ ឧទាហរណ៍ថា: យើងគិតអំពីករណីដែលដើមចោទបានឈ្នះក្តីនៅក្នុងការជំនុំជម្រះលើកទី ១ ហើយចុងចម្លើយបានប្តឹងឧទ្ធរណ៍ ។ ករណីនេះ យើងអាចគិតថា ដើមចោទបានឈ្នះក្តីនៅក្នុងការជំនុំជម្រះលើកទី ១ ហើយ នឹងមិនបង្ហាញខ្លួនឡើយ ដោយគាត់គ្មានអ្វីអះអាងផ្សេងថ្មីទៀត ។ ទោះជាមានការពិនិត្យគ្រប់គ្រាន់ដែលជាហេតុនាំឱ្យដើមចោទបានឈ្នះក្តី នៅក្នុងការជំនុំជម្រះលើកទី ១ ក៏ដោយ បើយើងយកមូលហេតុថា ដោយដើមចោទ (ចុងបណ្តឹងឧទ្ធរណ៍) នោះអវត្តមាននៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ហើយចេញសាលក្រមឱ្យដើមចោទ ( ចុងបណ្តឹងឧទ្ធរណ៍) នោះចាញ់ក្តីទៅវិញ វាជារឿងដែលមិនសមហេតុផលឡើយ ។

**មាត្រា ២៧៤.-** អានុភាពនៃសកម្មភាពបណ្តឹងនៅក្នុងការជំនុំជម្រះលើកទី ១ ជាអាទិ៍

១- សកម្មភាពបណ្តឹងដែលបានធ្វើនៅក្នុងការជំនុំជម្រះលើកទី ១ មានអានុភាពក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ។

២- នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលបានធ្វើនៅក្នុងការជំនុំជម្រះលើកទី ១ មានអានុភាពក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ។

( កំណត់)

តម្រូវនឹងមាត្រា 298 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ កថាខណ្ឌទី ១ នេះ មកពីប្រព័ន្ធនៃការជំនុំជម្រះបន្ត (resumed trial) ឧទាហរណ៍ថា: ចម្លើយសារភាពរបស់ចុងចម្លើយនៅតុលាការនៃការជំនុំជម្រះលើកទី ១ ក៏មានអានុភាពនៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ដែរ ដូច្នេះមិនអាចដកចម្លើយសារភាពនោះចេញដោយសេរីបានឡើយ ។

បើយើងអនុញ្ញាតឱ្យភាគីអាចបន្ថែមសេចក្តីអះអាងថ្មីទៀតបានដោយសេរី នៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍នោះ វានឹងបណ្តាលឱ្យការវិនិច្ឆ័យដែលធ្វើនៅសាលាដំបូងនោះពុំមានអត្ថន័យទៅវិញ ។ ម្ល៉ោះហើយ កថាខណ្ឌទី ២ នេះ ចែងថា

អានុភាពនៃការបាត់បង់សិទ្ធិដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន ក្នុងការជំនុំជម្រះលើកទី ១ (មាត្រា ១០៨ (អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល)) ក៏ត្រូវបានរក្សាក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ដែរ ។

Code of Civil Procedure (Japan)
**Article 298** (Effect of act of litigation conducted in the first instance)
1. Acts of litigation conducted in the first instance shall be given effect on *koso*-appeal.
2. The provisions of Article 167 shall apply *mutatis mutandis* to a party who advances offensive or defensive measures in the *koso*-appeal instance with regard to a case of which in the first instance preliminary oral argument has been concluded or preparations for argument proceedings have been concluded; and the provisions of Article 178 to a party who advances offensive or defensive measures in the *koso*-appeal instance with regard to a case of which in the first instance preparatory proceedings by document have been concluded and the statement or the affirmation referred to in the article has been made.

**មាត្រា ២៧៥.-** ការកម្រិតនូវការអះអាងស្តីពីអសមត្ថកិច្ចក្នុងការជំនុំជម្រះលើកទី ១

នៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ភាគីមិនអាចអះអាងអំពីអសមត្ថកិច្ចរបស់សាលាដំបូងបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសមត្ថកិច្ចផ្តាច់មុខ ។

(កំណត់)

តម្រូវនឹងមាត្រា 299 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ ទោះជាសាលាដំបូងនោះគ្មានសមត្ថកិច្ចក៏ដោយ បើនីតិវិធីដែលត្រូវធ្វើក្នុងការជំនុំជម្រះលើកទី ១ ត្រូវបានបញ្ចប់រួចហើយ ហើយយើងអនុញ្ញាតចំពោះការទាមទារលុបចោលនូវសាលក្រមរបស់សាលាដំបូង ដោយសារតែមូលហេតុគ្មានសមត្ថកិច្ចនោះ វានឹងធ្វើឱ្យការជំនុំជម្រះលើកទី ១ នោះអសារបង់ពុំបានការ ដូច្នេះ បញ្ញត្តិនេះចែងថា នៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ភាគីមិនអាចអះអាងអំពីការគ្មានសមត្ថកិច្ចរបស់សាលាដំបូងឡើយ ។ ប៉ុន្តែ បញ្ញត្តិស្តីពីសមត្ថកិច្ចផ្តាច់មុខ ដែលចែងក្នុងមូលហេតុដើម្បីផលប្រយោជន៍សាធារណៈវិញនោះ (មាត្រា ១៥ (ករណីលើកលែងនៃការអនុវត្តចំពោះសមត្ថកិច្ចផ្តាច់មុខរបស់សាលាជម្រះក្តី ដែលច្បាប់បានកំណត់)) យើងទទួលស្គាល់អំពីការអះអាងថាគ្មានសមត្ថកិច្ចនោះ ។

Code of Civil Procedure (Japan)
**Article 299** (Restraint on assertion of lack of jurisdiction in first instance)
The parties may not assert in the *koso*-appeal instance that the court of the first instance did not have jurisdiction. However, this shall not apply to cases of an exclusive jurisdiction (except as decided by agreement of the parties in accordance with the procisions of Article 11).

**មាត្រា ២៧៦.-** ការដាក់ពាក្យបណ្តឹងតប

១- ការដាក់ពាក្យបណ្តឹងតបនៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ អាចធ្វើបាន លុះត្រាតែមានការយល់ព្រមពីភាគីម្ខាងទៀត ។

២- បើភាគីម្ខាងទៀតមិនបានតវ៉ា តែបានធ្វើការទាញហេតុផលលើអង្គសេចក្តីអំពីការប្តឹងតប នោះត្រូវចាត់ទុកថា

ភាគីនោះបានយល់ព្រមនឹងការដាក់ពាក្យបណ្តឹងតប ។

（កំណត់）

តម្រូវនឹងមាត្រា 300 កថាខណ្ឌទី 1 និង ទី 2 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

ការប្តឹងតបនៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍នេះ ដោយបន្ថែមទៅលើល័ក្ខខ័ណ្ឌដែលចែងថា "លុះត្រាតែការទាមទារដែលជាកម្មវត្ថុនៃបណ្តឹងតបនោះទាក់ទងនឹងការទាមទារដែលជាកម្មវត្ថុនៃបណ្តឹងដើម ឬ មធ្យោបាយការពារខ្លួនសម្រាប់បណ្តឹងដើម"（មាត្រា ៨៦（បណ្តឹងតប）កថាខណ្ឌទី ១）ត្រូវមានល័ក្ខខ័ណ្ឌដែលតម្រូវឱ្យមានការយល់ព្រមពីភាគីម្ខាងទៀត ។ ក្នុងករណីដែល "ការទាមទារដែលជាកម្មវត្ថុនៃបណ្តឹងតបនោះ ទាក់ទងនឹងការទាមទារដែលជាកម្មវត្ថុនៃបណ្តឹងដើម ឬ មធ្យោបាយការពារខ្លួនសម្រាប់បណ្តឹងដើម" ជួនកាលវាអាចជាការទាមទារ ដោយពុំមានទំនាក់ទំនងលើបណ្តឹងដើម ហើយក្នុងករណីនេះ អាចបណ្តាលឱ្យទៅជាការរំលោភទៅលើផលប្រយោជន៍ ក្នុងដំណាក់កាលនៃការវិនិច្ឆ័យរបស់ភាគីម្ខាងទៀត ហេតុដូច្នេះ ទាល់តែនៅក្នុងករណីដែលភាគីម្ខាងទៀតយល់ព្រមបោះបង់ចោលនូវផលប្រយោជន៍ក្នុងដំណាក់កាលវិនិច្ឆ័យរបស់ខ្លួន ទើបអាចដាក់ពាក្យបណ្តឹងតបបាន ។

Code of Civil Procedure (Japan)
**Article 300** (Institution, etc., of cross action) (excerpt)
1. In the *koso*-appeal instance, a cross action may be filed only with the consent of the adversary party.
2. In cases where the adversary party has argued upon the merits of a cross action without raising an objection, it shall be deemed that the party has consented to the filing of the cross action.

**មាត្រា ២៧៧.-** ការច្រានចោលបណ្តឹងឧទ្ធរណ៍

១- តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវច្រានចោលនូវបណ្តឹងឧទ្ធរណ៍ ក្នុងករណីដែលយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី ១ ត្រឹមត្រូវ ។

២- ទោះជាក្នុងករណីដែលសំអាងហេតុនៃសាលក្រមនៃការជំនុំជម្រះលើកទី ១ មិនត្រឹមត្រូវក៏ដោយ ក៏តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវច្រានចោលនូវបណ្តឹងឧទ្ធរណ៍នោះដែរ បើយល់ឃើញថា សេចក្តីសម្រេចបញ្ចប់នៃសាលក្រមនោះត្រឹមត្រូវ ដោយផ្អែកលើសំអាងហេតុផ្សេងទៀត ។

（កំណត់）

តម្រូវនឹងមាត្រា 302 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ នៅក្នុងករណីដែលតុលាការនៃបណ្តឹងឧទ្ធរណ៍យល់ឃើញថា លទ្ធផល និង មូលហេតុរបស់សាលក្រមសាលាដំបូងត្រឹមត្រូវ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវច្រានចោលនូវបណ្តឹងឧទ្ធរណ៍នោះ ដោយហេតុថា វាគ្មានមូលហេតុក្នុងការធ្វើឧបាស្រ័យចំពោះសាលក្រមទេ ។ កថាខណ្ឌទី ១ នេះចែងអំពីចំណុចនេះ ។ កថាខណ្ឌទី ២ ដែលចែងដូចខាងលើនេះ យោលទៅតាមមាត្រា ១៩៤（អាជ្ញាអស់ជំនុំនៃចំណុច

ដែលត្រូវបានវិនិច្ឆ័យដោយសាលក្រម) ដែលចែងថា "ទំហំនៃអាជ្ញាអស់ជំនុំ មានត្រឹមតែទំហំដែលបានវិនិច្ឆ័យនៅក្នុងសេចក្តីសម្រេចបញ្ចប់ ចំពោះការទាមទារដែលបានសុំដោយពាក្យបណ្តឹង ឬ ពាក្យបណ្តឹងតបតែប៉ុណ្ណោះ ហើយអានុភាពនៃអាជ្ញាអស់ជំនុំនេះ មិនអាចមានទៅលើសេចក្តីវិនិច្ឆ័យក្នុងសំអាងហេតុនៃសាលក្រមទេ" ។ ពោលគឺអានុភាពនៃអាជ្ញាអស់ជំនុំនេះ មិនអាចមានទៅលើសេចក្តីវិនិច្ឆ័យ ក្នុងសំអាងហេតុនៃសាលក្រមទេ ហេតុដូច្នេះ តុលាការនៃបណ្តឹងឧទ្ធរណ៍មិនចាំបាច់ធ្វើសាលដីកាដែលរក្សាទុក សេចក្តីសម្រេចបញ្ចប់នៃការជំនុំជម្រះលើកទី ១ ដោយគ្រាន់តែប្តូរនូវមូលហេតុឡើយ ។ ហេតុដូច្នេះ តុលាការនៃបណ្តឹងឧទ្ធរណ៍អាចច្រានចោលបណ្តឹងឧទ្ធរណ៍បាន ។ ក្នុងករណីដែលអានុភាពនៃអាជ្ញាអស់ជំនុំនេះ មានទៅលើសេចក្តីវិនិច្ឆ័យក្នុងសំអាងហេតុនៃសាលក្រម (មាត្រា ១៩៤ (អាជ្ញាអស់ជំនុំនៃចំណុចដែលត្រូវបានវិនិច្ឆ័យដោយសាលក្រម) កថាខណ្ឌទី ៤) តាមការបកស្រាយទៅលើវាក្យខណ្ឌទី ២ នៃមាត្រានេះ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវប្រកាសសាលដីកា ដែលមានសេចក្តីសម្រេចបញ្ចប់ដូចនឹងសាលក្រមដើម ដោយប្តូរនូវសំអាងហេតុ ។

Code of Civil Procedure (Japan)
**Article 302** (Dismissal of *koso*-appeal)
1. The *koso*-appellate court shall dismiss a *koso*-appeal upon determining that the judgment in the first instance is appropriate.
2. Even in cases where the judgment in the first instance is inappropriate for the reason given, a *koso*-appeal shall be dismissed if such judgment is appropriate for other reason.

**មាត្រា ២៧៨.-** ទំហំនៃការផ្លាស់ប្តូរសាលក្រមនៃការជំនុំជម្រះលើកទី ១

ការផ្លាស់ប្តូរសាលក្រមនៃការជំនុំជម្រះលើកទី ១ អាចធ្វើបាន ត្រឹមតែកម្រិតនៃឧបាស្រ័យ ដោយបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំតែប៉ុណ្ណោះ ។

(កំណត់)

មាត្រានេះតម្រូវនឹងមាត្រា 304 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ហើយចែងអំពីគោលការណ៍ហាមឃាត់មិនឱ្យផ្លាស់ប្តូរអ្វីដែលឱ្យខូចប្រយោជន៍ ។ ដោយហេតុថា វាដូចគ្នានឹងកថាខណ្ឌទី ២ នៃមាត្រា ១៨២ (ចំណុចដែលត្រូវវិនិច្ឆ័យដោយសាលក្រម) ដែលចែងថា តុលាការមិនអាចចេញសាលក្រមដែលវិនិច្ឆ័យទៅលើការទាមទារ និង ចំណុចណាដែលភាគីមិនបានសុំឡើយ នោះតុលាការនៃបណ្តឹងឧទ្ធរណ៍អាចចេញសាលដីកាផ្លាស់ប្តូរសាលក្រមនៃការជំនុំជម្រះលើកទី ១ បាន ត្រឹមតែទំហំដែលដើមបណ្តឹងឧទ្ធរណ៍នោះបានធ្វើឧបាស្រ័យដោយបណ្តឹងឧទ្ធរណ៍តែប៉ុណ្ណោះ ហើយតុលាការនៃបណ្តឹងឧទ្ធរណ៍មិនអាចធ្វើការផ្លាស់ប្តូរឱ្យខូចខាតផលប្រយោជន៍របស់ដើមបណ្តឹងឧទ្ធរណ៍លើសាលក្រមនៃការជំនុំជម្រះលើកទី ១ បានឡើយ ។

ឧទាហរណ៍ :

នៅសាលាដំបូង ដើមចោទបានទាមទារឱ្យសងការខូចខាតនូវចំនួន 100 (ប្រាក់) តែតុលាការបានវិនិច្ឆ័យ

ដោយទទួលស្គាល់តែចំនួន 70 ហើយដើមចោទបានប្ដឹងឧទ្ធរណ៍ តែចុងចម្លើយមិនបានធ្វើបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំឡើយ ។ ដោយទំហំនៃបណ្ដឹងឧបាស្រ័យមានតែចំនួន 30 ប៉ុណ្ណោះ ដែលត្រូវបានច្រានចោលដោយសាលាដំបូង ទោះជាសាលាឧទ្ធរណ៍យល់ឃើញថា ប្រាក់ដែលត្រូវសងនោះមានចំនួនតិចជាង 70 ក៏ដោយ ក៏ពុំអាចធ្វើការវិនិច្ឆ័យផ្លាស់ប្ដូរឱ្យចំនួនទឹកប្រាក់នោះ តិចជាងចំនួន 70 ដែលជាសាលក្រមនៃការជំនុំជម្រះលើកទី ១ បានឡើយ ។ គឺអាចត្រឹមតែច្រានចោលនូវបណ្ដឹងឧទ្ធរណ៍នោះតែប៉ុណ្ណោះ (ដោយរក្សាសាលក្រមនៃការជំនុំជម្រះលើកទី ១) ។ ម្ល៉ោះហើយ ទំហំដែលសាលាឧទ្ធរណ៍ត្រូវធ្វើការវិនិច្ឆ័យនោះ ត្រូវបានកម្រិតត្រឹមទំហំនៃឧបាស្រ័យដោយបណ្ដឹងឧទ្ធរណ៍តែប៉ុណ្ណោះ (មាត្រា ២៧២ (ទំហំនៃការទាញហេតុផលដោយផ្ទាល់មាត់ ជាអាទិ៍) កថាខណ្ឌទី ១) ។ គោលការណ៍ហាមឃាត់មិនឱ្យផ្លាស់ប្ដូរអ្វីដែលឱ្យខូចប្រយោជន៍ គឺជាផ្នែកមួយនៃគោលការណ៍នៃសិទ្ធិចាត់ចែង (របស់ភាគី) ដែលមាននៅក្នុងការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ហេតុដូច្នេះ ចំពោះចំណុចស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់តុលាការ ដែលសិទ្ធិចាត់ចែងរបស់ភាគីពុំគ្របដណ្ដប់ គោលការណ៍ហាមឃាត់មិនឱ្យផ្លាស់ប្ដូរអ្វីដែលឱ្យខូចប្រយោជន៍នេះ ពុំយកមកអនុវត្តឡើយ ។

ដូចគ្នានឹងមាត្រា ១៨២ (ចំណុចដែលត្រូវវិនិច្ឆ័យដោយសាលក្រម) កថាខណ្ឌទី ២ តុលាការនៃបណ្ដឹងឧទ្ធរណ៍មិនអាចផ្លាស់ប្ដូរសាលក្រមដើម្បីឱ្យលើសទំហំនៃការប្ដឹងឧបាស្រ័យបានឡើយ (គោលការណ៍ហាមឃាត់មិនឱ្យផ្លាស់ប្ដូរអ្វីដែលបន្ថែមផលប្រយោជន៍) ។ ក្នុងករណីដែលដើមចោទបានដាក់ពាក្យប្ដឹងទៅលើចំណុច A និង B តែសាលក្រមនៃការជំនុំជម្រះលើកទី ១ បានច្រានចោលនូវការទាមទារទាំង ២ នេះ ហើយដើមចោទបានប្ដឹងឧទ្ធរណ៍តែទៅលើចំណុច A នោះ ច្បាប់មិនអនុញ្ញាតឱ្យតុលាការនៃបណ្ដឹងឧទ្ធរណ៍ទទួលស្គាល់លើការទាមទារចំណុច B ដោយលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ ឡើយ ។

Code of Civil Procedure (Japan)
**Article 304** (Scope of reversal and change of judgment in first instance)
Reversal and change of the judgment in the first instance may be made only to the extent of the appellant's appeal.

**មាត្រា ២៧៩.-** ការលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១

១- តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវលុបចោលនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ ក្នុងករណីដូចមានខាងក្រោមនេះ :

**ក**- បើយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី ១ មិនត្រឹមត្រូវ ។

**ខ**- បើនីតិវិធីនៅតុលាការជាន់ទី ១ នោះផ្ទុយនឹងច្បាប់ធ្ងន់ធ្ងរ ។

២- ក្នុងករណីដូចកថាខណ្ឌទី ១ ខាងលើនេះ តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវធ្វើការជំនុំជម្រះទៅលើបណ្ដឹងនោះ លើកលែងតែករណីដែលបានកំណត់នៅក្នុងមាត្រា ២៨០ (ការបញ្ជូនរឿងក្ដីត្រឡប់ទៅវិញ) ឬ មាត្រា ២៨១ (ការផ្ទេរដោយមូលហេតុខុសសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការនៃការជំនុំជម្រះលើកទី ១) នៃក្រមនេះ ។

(កំណត់)

កថាខណ្ឌទី ១ ចំណុច ក តម្រូវនឹងមាត្រា 305 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ ពាក្យថា សាលក្រមនៃការជំនុំជម្រះលើកទី ១ "មិនត្រឹមត្រូវ" មានន័យថា អត្ថន័យនៃការវិនិច្ឆ័យក្នុងសាលក្រមនៃការជំនុំជម្រះលើកទី ១ នោះមានកំហុស ។

បើលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ ហើយ បណ្ដឹងរបស់ដើមចោទនោះនឹងត្រឡប់ទៅស្ថានភាពដែលគ្មានការឆ្លើយតបវិញ ដូច្នេះតុលាការនៃបណ្ដឹងឧទ្ធរណ៍ចាំបាច់ត្រូវវិនិច្ឆ័យទៅលើបណ្ដឹងនោះ ។ ដោយសារយកប្រព័ន្ធបន្តការវិនិច្ឆ័យ（resumed trial）មកអនុវត្ត ជាគោលការណ៍ តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវវិនិច្ឆ័យដោយខ្លួនឯង ទៅលើបណ្ដឹងរបស់ដើមចោទនោះ ដោយផ្អែកលើឯកសារទាំងឡាយដែលបានប្រមូលនៅតុលាការនៃការជំនុំជម្រះលើកទី ១ និងឯកសារដែលបានប្រមូលនៅតុលាការនៃបណ្ដឹងឧទ្ធរណ៍ ។

Code of Civil Procedure (Japan)
**Article 305** (Reversal in case where judgment in first instance is inappropriate)
The *koso*-appellate court shall, if it finds the judgment in the first instance is inappropriate, reverse such judgment.

**មាត្រា ២៨០.-** ការបញ្ជូនរឿងក្ដីត្រឡប់ទៅវិញ

១- ក្នុងករណីដែលតុលាការនៃបណ្ដឹងឧទ្ធរណ៍លុបចោលនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ ដែលលើកចោលបណ្ដឹងដោយយល់ឃើញថា បណ្ដឹងនោះមិនត្រឹមត្រូវតាមច្បាប់ តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវបញ្ជូនរឿងក្ដីនោះ ត្រឡប់ទៅសាលាដំបូងវិញ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលគ្មានការចាំបាច់ត្រូវទាញហេតុផលបន្ថែមទៀតអំពីរឿងក្ដីនោះ ។

២- ក្រៅពីករណីដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ ក្នុងករណីដែលតុលាការនៃបណ្ដឹងឧទ្ធរណ៍លុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ បើមានភាពចាំបាច់ទាញហេតុផលបន្ថែមទៀត អំពីរឿងក្ដីនោះ តុលាការនៃបណ្ដឹងឧទ្ធរណ៍អាចបញ្ជូនរឿងក្ដីនោះត្រឡប់ទៅសាលាដំបូងវិញបាន ។

៣- ប្រសិនបើរឿងក្ដីនោះត្រូវបានបញ្ជូនត្រឡប់ទៅវិញ ដោយសារមូលហេតុថា នីតិវិធីបណ្ដឹងនៅសាលាដំបូងផ្ទុយនឹងច្បាប់ នីតិវិធីនៃបណ្ដឹងនោះត្រូវចាត់ទុកថា បានលុបចោល ដោយសារការបញ្ជូនត្រឡប់ទៅវិញ ។

（កំណត់）

កថាខណ្ឌទី ១ តម្រូវនឹងមាត្រា 307 កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣ តម្រូវនឹងមាត្រា 308 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

ក្នុងករណីដែលទទួលស្គាល់លើបណ្ដឹងឧទ្ធរណ៍ ហើយលុបចោលនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ នោះ ការប្ដឹងរបស់ដើមចោទនោះនឹងត្រឡប់ទៅស្ថានភាពដែលគ្មានការឆ្លើយតបវិញ ហេតុដូច្នេះ នៅក្រោមប្រព័ន្ធបន្តការវិនិច្ឆ័យជាគោលការណ៍ តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវធ្វើការវិនិច្ឆ័យដោយខ្លួនឯង ទៅលើការទាមទារនោះថាតើត្រឹមត្រូវ ឬអត់

(មាត្រា ២៧៩ (ការលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១) កថាខណ្ឌទី ២) ។ ប៉ុន្តែ នៅក្នុងករណីដែលសាលក្រមរបស់តុលាការនៃការជំនុំជម្រះលើកទី ១ នោះ លើកចោលបណ្តឹង ដោយខ្វះល័ក្ខខ័ណ្ឌនៃបណ្តឹងនោះ អាចមានករណីដែលតុលាការនៃការជំនុំជម្រះលើកទី ១ បានវិនិច្ឆ័យទៅលើអង្គហេតុនោះពុំទាន់គ្រប់គ្រាន់ទេ ហេតុដូច្នេះ ដើម្បីថែរក្សាផលប្រយោជន៍របស់ភាគីនៅដំណាក់កាលវិនិច្ឆ័យ ពោលគឺដើម្បីធានាទៅលើឱកាសដែលអាចធ្វើនីតិវិធីបាន ២ ដងក្នុងការវិនិច្ឆ័យរឿងពិត ទម្រាំទៅដល់ការវិនិច្ឆ័យនៅតុលាការនៃបណ្តឹងឧទ្ធរណ៍នោះ នៅក្នុងបញ្ញត្តិនេះ យើងចែងថាជាគោលការណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍បញ្ជូនត្រឡប់ទៅតុលាការនៃការជំនុំជម្រះលើកទី ១ វិញ ហើយធ្វើនីតិវិធីនោះសាជាថ្មីឡើងវិញ (វាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១) ។ ប៉ុន្តែ ក្នុងករណីដែលការវិនិច្ឆ័យទៅលើអង្គហេតុនោះគ្រប់គ្រាន់ហើយ ឬ ក្នុងករណីដែលគូភាគីពុំមានវិវាទអំពីទំនាក់ទំនងនៃអង្គហេតុទេ តុលាការនៃបណ្តឹងឧទ្ធរណ៍ពុំចាំបាច់បញ្ជូនត្រឡប់ទៅវិញឡើយ (វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១) ។

ក្រៅពីករណីដែលមានចែងនៅក្នុងកថាខណ្ឌទី ១ នេះ ករណីដែលលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ ដោយយោលទៅតាមកថាខណ្ឌទី ១ នៃមាត្រា ២៧៩ (ការលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១) មានករណីដូចជាករណីដែល "មានភាពចាំបាច់ទាញហេតុផលបន្ថែមទៀតអំពីរឿងក្តី" ។ ពោលគឺក្នុងករណីដែលត្រូវធានាលើផលប្រយោជន៍នៃដំណាក់កាលវិនិច្ឆ័យរបស់ភាគី តុលាការនៃបណ្តឹងឧទ្ធរណ៍អាចបញ្ជូនត្រឡប់រឿងក្តីនោះទៅតុលាការនៃការជំនុំជម្រះលើកទី ១ វិញបាន (កថាខណ្ឌទី ២) ។ បើមានមូលហេតុផ្ទុយនឹងច្បាប់ដែលចែងស្តីអំពីនីតិវិធីនៃការជំនុំជម្រះលើកទី ១ ហើយបញ្ជូនរឿងក្តីត្រឡប់ទៅវិញ នីតិវិធីនៃបណ្តឹងដែលផ្ទុយនឹងច្បាប់នោះ ត្រូវបានលុបចោលដោយស្វ័យប្រវត្តិ ហើយពុំមានសុពលភាពឡើយ (កថាខណ្ឌទី ៣) ។

Code of Civil Procedure (Japan)
**Article 307** (Remand of case)
The *koso*-appeal court shall, in cases where it reverses a judgment in the first instance which dismissed the suit by reason of procedural illegitimacy, remand the case to the court of the first instance. However, this shall not apply to cases where no further argument is necessary with respect to the case.
**Article 308** (Ibid.)
1. In addition to the cases provided in the main clause of the preceding article, the *koso*-appellate court may, in cases where it reverses a judgment in the first instance, if further argument is necessary with respect to the case, remand the case to the court of the first instance.
2. In cases where a case has been remanded by reason that the litigation proceedings in the court of the first instance have been illegitimate, such litigation proceedings shall be deemed to have been reversed thereby.

**មាត្រា ២៨១.-** ការផ្ទេរដោយមូលហេតុខុសសមត្ថកិច្ចផ្តាច់មុខរបស់តុលាការនៃការជំនុំជម្រះលើកទី ១

ប្រសិនបើតុលាការនៃបណ្តឹងឧទ្ធរណ៍លុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ ដោយមូលហេតុថា រឿងក្តីនោះខុសសមត្ថកិច្ចផ្តាច់មុខ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវចេញសាលដីកាផ្ទេររឿងក្តីនោះទៅតុលាការដែលមានសមត្ថកិច្ចវិញ ។

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនមាត្រា 309 ចែងអំពី "ការខុសសមត្ថកិច្ច" ប៉ុន្តែ ដោយសារមានបញ្ញត្តិដែលតម្រូវនឹងមាត្រា ២៧៥ (ការកម្រិតនូវការអះអាងស្តីពីអសមត្ថកិច្ចក្នុងការជំនុំជម្រះលើកទី ១) (គឺ ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 299) តាមការបកស្រាយក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន "ការខុសសមត្ថកិច្ច" នោះ ត្រូវបានកម្រិតតែករណី ដែល "ខុសសមត្ថកិច្ចផ្តាច់មុខ" ប៉ុណ្ណោះ ។ មាត្រា ២៨១ នេះបញ្ជាក់ឱ្យកាន់តែច្បាស់អំពីអត្ថន័យនេះ ។ បើបញ្ជូនត្រឡប់ទៅតុលាការនៃការជំនុំជម្រះលើកទី ១ ដែលគ្មានសមត្ថកិច្ច ហើយផ្ទេរទៅតុលាការដែលមានសមត្ថកិច្ចនោះ នាំឱ្យនីតិវិធីដែលធ្វើនោះមិនបានការ ដូច្នេះ ត្រូវផ្ទេរផ្ទាល់ទៅតុលាការដែលមានសមត្ថកិច្ច ។

Code of Civil Procedure (Japan)
**Article 309** (Transfer by reason of lack of jurisdiction in the first instance)
In cases where the *koso*-appellate court reverses a judgment in the first instance by reason of a jurisdictional error, the court shall, by judgment, transfer the case to the court with jurisdiction.

**មាត្រា ២៨២.-** ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នក្នុងសាលដីកានៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍

ចំពោះសាលដីកាអំពីការទាមទារសំណងជាប្រាក់ បើមានពាក្យសុំ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវប្រកាសថា សាលដីកាអាចអនុវត្តជាបណ្តោះអាសន្នបានដោយពុំចាំបាច់ឱ្យដាក់ប្រាតិភោគ លើកលែងតែករណីដែលយល់ឃើញថា ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ននោះមិនមានលក្ខណៈចាំបាច់ ។ ប៉ុន្តែ បើយល់ឃើញថាសមរម្យ តុលាការនៃបណ្តឹងឧទ្ធរណ៍ អាចកំណត់ល័ក្ខខ័ណ្ឌឱ្យដាក់ប្រាតិភោគសម្រាប់ការអនុវត្តជាបណ្តោះអាសន្ននោះបាន ។

(កំណត់)

តម្រូវនឹងមាត្រា 310 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ សាលដីកាដែលបង្គាប់ឱ្យសងសំណងជាប្រាក់នៅពេលជំនុំជម្រះបណ្តឹងឧទ្ធរណ៍នេះ គឺដោយសារបានឆ្លងកាត់ការជំនុំជម្រះលើកទី ១ និង ការជំនុំជម្រះបណ្តឹងឧទ្ធរណ៍រួចហើយ គំនិតរបស់មាត្រានេះគឺតម្រូវឱ្យចេញការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដើម្បីឱ្យដើមចោទអាចទទួលបាននូវសិទ្ធិរបស់ខ្លួនឱ្យបានឆាប់រហ័ស ។ ការដែលកម្រិតតែ "សាលដីកាអំពីការទាមទារសំណងជាប្រាក់" នេះ គឺមានគំនិតថា ទោះជារឿងក្តីនោះត្រូវប្តឹងសាទុក្ខ ហើយតុលាការកំពូលបានវិនិច្ឆ័យផ្សេងពីលទ្ធផលនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ក៏ដោយ ក៏វាមានការងាយស្រួលនឹងវិលត្រឡប់ទៅរកស្ថានភាពដើមរបស់វាវិញ (ព្រោះវាជាលុយ) ដែរ ។ ចំពោះការទាមទារសិទ្ធិលើទ្រព្យសម្បត្តិ ក្រៅពីការទាមទារប្រាក់នេះ បញ្ញត្តិនៃមាត្រា ១៩៦ (ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ តាមបញ្ញត្តិនៃមាត្រា ២៧៣ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីនីតិវិធីនៃការជំនុំជម្រះលើកទី ១) ហេតុដូច្នេះ ក្នុងករណីដែលយល់ឃើញថាចាំបាច់ តុលាការនៃបណ្តឹងឧទ្ធរណ៍អាចភ្ជាប់នូវការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នបាន ។

Code of Civil Procedure (Japan)
**Article 309** (Declaration of provisional execution in judgment in *koso*-appeal instance)

With regard to a judgment concerning a claim for monetary payment (except for the claim referred to in Article 259. paragraph 2), if a motion has been made, the *koso*-appellate court shall, unless determining it unnecessary, declare that a provisional execution may be carried out without security being provided. However, the *koso*-appellate court may, upon determining it proper, make its grant of such provisional execution contingent on security being provided.

## ជំពូកទី ៣ បណ្តឹងសាទុក្ខ

**មាត្រា ២៨៣.-** តុលាការនៃបណ្តឹងសាទុក្ខ

១- បណ្តឹងសាទុក្ខអាចធ្វើទៅតុលាការកំពូលបាន ចំពោះសាលដីកាចុងក្រោយដែលត្រូវបានជំនុំជម្រះលើកទី ២ ដោយសាលាឧទ្ធរណ៍ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះសាលដីកាចុងក្រោយដែលសាលាឧទ្ធរណ៍បានជំនុំជម្រះលើកទី ១ តាមបញ្ញត្តិនៃច្បាប់ពិសេស ។

២- ចំពោះសាលក្រមចុងក្រោយដែលត្រូវបានជំនុំជម្រះលើកទី ១ ដោយសាលាដំបូង នៅក្នុងករណីដែលគូភាគីបានព្រមព្រៀងគ្នាមិនប្តឹងឧទ្ធរណ៍នៅក្រោយពេលដែលតុលាការបានចេញសាលក្រមនោះ ដោយរក្សាទុកនូវសិទ្ធិប្តឹងសាទុក្ខ បណ្តឹងសាទុក្ខអាចធ្វើទៅតុលាការកំពូលដោយផ្ទាល់បាន ។

(កំណត់)

គោលបំណងនៃប្រព័ន្ធបណ្តឹងសាទុក្ខ គឺដើម្បីឱ្យមានភាពស្របគ្នាក្នុងការបកស្រាយច្បាប់ ការអនុវត្តច្បាប់ និងករណីយុត្តិសាស្ត្រ និង ការពារសិទ្ធិរបស់ដើមបណ្តឹងសាទុក្ខ ។

ប្រព័ន្ធនេះមិនទទួលស្គាល់នូវការទាមទាររបស់ព្រះរាជអាជ្ញាដែលជាតំណាងនៃផលប្រយោជន៍សាធារណៈ ក្នុងការបដិសេធសាលដីកាផ្ទុយនឹងច្បាប់ របស់តុលាការជាន់ទាប ដូចជាប្រព័ន្ធបដិសេធចោល (cassation) របស់សាលាបដិសេធចោល (cour de cassation) នៃប្រទេសបារាំងទេ ។

ការវិនិច្ឆ័យលើបណ្តឹងសាទុក្ខ គឺជាការវិនិច្ឆ័យតាមក្រោយ (ការវិនិច្ឆ័យដោយផ្អែកលើការអះអាងរបស់គូភាគី និងភស្តុតាងដែលត្រូវបានដាក់នៅតុលាការដើមតែប៉ុណ្ណោះ) ផង និង វិនិច្ឆ័យទៅលើអង្គច្បាប់ផង ។

មាត្រានេះតម្រូវនឹងក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 311 ។

មាត្រានេះមានអត្ថន័យកម្រិតលើការវិនិច្ឆ័យបណ្តឹងសាទុក្ខ ដែលអាចធ្វើទៅបានត្រឹមតែចំពោះសាលក្រមចុងក្រោយដែលបានធ្វើក្នុងការជំនុំជម្រះលើកទី ២ ឬ លើកទី ១ តែប៉ុណ្ណោះ ។

ចំពោះសាលក្រមរបៀប (interlocutory judgment) ដែលចេញមុនសាលក្រមចុងក្រោយ ពុំអាចធ្វើបណ្តឹងសាទុក្ខដោយឯករាជដាច់តែឯងបានឡើយ តែបើគេបានប្តឹងសាទុក្ខចំពោះសាលក្រមចុងក្រោយ សាលក្រមរបៀបនេះក៏ជាកម្មវត្ថុដែលត្រូវវិនិច្ឆ័យជាមួយគ្នានៅតុលាការកំពូលដែរ ។

កថាខណ្ឌទី ១ នេះ ចែងដូចខាងលើ ដោយយកឃ្លាទី ១ នៃវាក្យខណ្ឌទី ១ មាត្រា ៧ នៃសេចក្តីព្រាងច្បាប់ស្តីពីការ

ចាត់តាំងតុលាការ របស់ប្រទេសកម្ពុជា ។

នៅប្រទេសកម្ពុជា មានករណីដែលសាលាឧទ្ធរណ៍មានសមត្ថកិច្ចលើការជម្រះលើកទី ១ ដូចជារឿងក្តីរដ្ឋបាលដែលត្រូវបានកំណត់នៅក្នុងវាក្យខណ្ឌទី ៨ នៃមាត្រា ២០ នៃសេចក្តីព្រាងច្បាប់ស្តីពីការចាត់តាំងតុលាការ និង បណ្តឹងតវ៉ាចំពោះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ជាដើម ។ ដូចគ្នានឹង វាក្យខណ្ឌទី ២ មាត្រា ៧ នៃសេចក្តីព្រាងច្បាប់ដដែលនេះ និង មាត្រា ២៥ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

ចំពោះកថាខណ្ឌទី ២ ដែលចែងអំពីការព្រមព្រៀងធ្វើបណ្តឹងសាទុក្ខផ្លោះ គឺដោយសំអាងទៅលើកថាខណ្ឌទី ១ មាត្រា ២៦០ (សាលក្រមដែលអាចប្តឹងឧទ្ធរណ៍បាន ជាអាទិ៍) ។ សូមមើលមាត្រា 566a នៃក្រមនីតិវិធីរដ្ឋប្បវេណីអាល្លឺម៉ង់ ។

<u>Code of Civil Procedure (Japan)</u>
**Article 311** (Court of last resort)
1. A *jokoku*-appeal may be made to the Supreme Court against the final judgment of a high court acting in the second instance or the first instance, and to a high court against the final judgment of a district court acting in the second instance.
2. In cases of the proviso of the provisions of Article 281, paragraph 1, a *jokoku*-appeal may be made directly to the Supreme Court against the judgment of the district court and to the high court against the judgment of the summary court.

<u>Code of Civil Procedure Rules (Germany)</u>
**Article 566a** (Direct appeal to court of revision)
1. Direct appeal to the court of revision may be lodged against final judgments of districts courts, passing over the appellate instance under the following conditions;
2. Consent of the opposing party is required for passing over the intermediate appellate instance. The written declaration of consent must accompany the petition of appeal in the court of revision; it can also be given by the attorney of record in the first instance.
3. The court of revision may decline to accept the appeal to it is the case does not involve fundamental legal principles; §554b(2) and (3) are applicable. The appeal to the court of revision may not be based on a procedural defect.
4. Lodging the appeal to the court of revision and the declaration of consent (subparagraph (2)) are deemed to be a waiver of the right of remedy by intermediate appeal.
5. If the court of revision remits the case for further hearing and decision, the remittal may in its discretion be made to the provincial court of appeals which would have been competent to entertain the appeal. In such a case, the same principles are applicable to procedure before the provincial court of appeals as if the legal controversy had become pending before the provincial court of appeals by way of a regularly filed appeal.
6. The provision of §565(2) shall analogously apply in all cases of remittal.
7. The registry of the provincial court of appeals shall be notified by the registry of the court of revision with regard to the filing of the appeal to the latter within twenty-four hours.

### **មាត្រា ២៨៤.-** មូលហេតុទូទៅនៃបណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខអាចធ្វើបាន ដោយយកមូលហេតុនៃភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬ បទដ្ឋានគតិយុត្តដែលមានឥទ្ធិពលលើសាលដីកា ឬ សាលក្រម ។

(កំណត់)

តម្រូវទៅតាមមាត្រា 394 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ និង កថាខណ្ឌទី 1 និង ទី 3 មាត្រា 312 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

ច្បាប់នេះពុំកម្រិតលើបណ្តឹងសាទុក្ខដោយគិតទៅលើចំនួនប្រាក់ដែលជាកម្មវត្ថុនៃបណ្តឹង ឬ ចំនួនប្រាក់ដែលជាកម្មវត្ថុ

នៃការប្តឹងឧបាស្រ័យទេ ។

ប្រព័ន្ធនេះទទួលស្គាល់ទៅលើសិទ្ធិនៃបណ្តឹងសាទុក្ខរបស់ភាគី ដោយគ្មានទាក់ទងទៅនឹងការអនុញ្ញាតពីតុលាការកំពូលទេ (បណ្តឹងសាទុក្ខដោយសិទ្ធិរបស់ភាគី) ។

មាត្រានេះចែងអំពីមូលហេតុទូទៅនៃបណ្តឹងសាទុក្ខ ដោយកំណត់ហេតុនីមួយៗដែលក្លាយជាមូលហេតុនៃការធ្វើឧបាស្រ័យចំពោះសាលដីកាដើម (សាលក្រមដើម) (ហេតុដែលធ្វើឱ្យបានត្រឹមត្រូវក្នុងការបដិសេធចោលនូវសាលដីកាដើម (សាលក្រមដើម)) ។ មានន័យថា នៅក្នុងករណីដែលមានមូលហេតុដូចនេះមែន តុលាការនៃបណ្តឹងសាទុក្ខត្រូវបដិសេធចោលនូវសាលដីកាដើម (សាលក្រមដើម) ។ ផ្ទុយទៅវិញ ប្រសិនបើគ្មានមូលហេតុដូចនេះទេ តុលាការនៃបណ្តឹងសាទុក្ខត្រូវច្រានចោលនូវបណ្តឹងសាទុក្ខនោះ ។ អត្ថិភាពនៃមូលហេតុដើម្បីប្តឹងសាទុក្ខ មិនមែនជាល័ក្ខខ័ណ្ឌស្របច្បាប់ ដើម្បីដាក់បណ្តឹងសាទុក្ខទេ តែវាជាមូលហេតុនៃការបដិសេធចោលនូវសាលដីកាដើម (សាលក្រមដើម) ។

នៅប្រទេសកម្ពុជា មានប្រព័ន្ធនៃបណ្តឹងទៅលើធម្មនុញ្ញភាពចំពោះរឿងក្តីជាក់ស្តែងដែលទាក់ទងនឹងអធម្មនុញ្ញភាពទៅក្រុមប្រឹក្សាធម្មនុញ្ញ (ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ មាត្រា ១៩ និង មាត្រា ១៥) ។ យោងតាមច្បាប់នេះ រឿងក្តីត្រូវបានបញ្ជូនដោយឆ្លងកាត់តាមតុលាការកំពូល ទៅក្រុមប្រឹក្សាធម្មនុញ្ញ ហើយក៏អាចបញ្ជូនទៅដោយឆន្ទានុសិទ្ធិបានដែរ (ច្បាប់ដូចគ្នា មាត្រា ១៨ វាក្យខណ្ឌទី ១) ។

មាត្រានេះមិនមែនចែងអំពីល័ក្ខខ័ណ្ឌស្របច្បាប់នៃបណ្តឹងសាទុក្ខទេ ។

(ល័ក្ខខ័ណ្ឌស្របច្បាប់នៃបណ្តឹងសាទុក្ខ)

① សេចក្តីសម្រេចដើមមានលក្ខណៈអាចប្តឹងសាទុក្ខបាន (មិនអាចប្តឹងសាទុក្ខចំពោះសាលក្រមរបៀប ឬ ចំពោះដីកាសម្រេចដែលចេញនៅមុនពេលចេញសាលដីកា (សាលក្រម) សម្រេចអង្គសេចក្តី ដោយឯករាជ្យដាច់តែឯងបានទេ ។ ប្រសិនបើមានការខកខានក្នុងការសម្រេចសេចក្តីនូវការទាមទារណាមួយ តុលាការត្រូវចេញសាលដីកា (សាលក្រម) បន្ថែមទៀត គេមិនអាចធ្វើបណ្តឹងសាទុក្ខបានទេ) ។

② មានការដាក់ពាក្យបណ្តឹងសាទុក្ខទៅតុលាការដែលមានសមត្ថកិច្ច ។

③ ពាក្យបណ្តឹងសាទុក្ខ និង លិខិតបញ្ជាក់ពីមូលហេតុនៃបណ្តឹងសាទុក្ខ ត្រូវបានធ្វើទៅតាមទម្រង់ស្របច្បាប់ ហើយត្រូវបានដាក់ក្នុងអំឡុងពេលដែលបានកំណត់ ទៅតុលាការនៃបណ្តឹងសាទុក្ខ ។

④ មានសុពលទៅលើការដាក់ និង ការបញ្ជូនពាក្យបណ្តឹង ជាអាទិ៍ ។

⑤ ដើមបណ្តឹងសាទុក្ខមានសេចក្តីឧបាស្រ័យ ចំពោះការសម្រេចសេចក្តីរបស់តុលាការដើម ។

⑥ ដើមបណ្តឹងសាទុក្ខមិនបានលះបង់ចោលនូវសិទ្ធិប្តឹងសាទុក្ខរបស់ខ្លួន ឬ មិនមានការព្រមព្រៀងថា មិនប្តឹងសាទុក្ខ ។

⑦ មិនបានធ្វើបណ្តឹងសាទុក្ខត្រួតគ្នា ។

⑧ មិនបានបំពានសិទ្ធិប្តឹងសាទុក្ខ ។

⑨ មានល័ក្ខខ័ណ្ឌនៃបណ្តឹងត្រឹមត្រូវ ។

<u>Old Code of Civil Procedure (Japan, 1890, last amendment: 1992)</u>
**Article 394** (Ground for *jokoku*-appeal)
*Jokoku*-appeal may be filed only on the ground that there exists misinterpretation of the Constitution or any other contravention of the Constitution in the judgment or that there exists such contravention of laws and orders as effect clearly the judgment.

<u>Code of Civil Procedure (Japan)</u>
**Article 312** (Grounds for *jokoku*-appeal) (excerpt)
1. A *jokoku*-appeal may be made based upon the grounds that there is an alleged misinterpretation or any other contravention of the Consitution in the judgment.
3. A *jokoku*-appeal to a high court may also be made based upon the grounds that a contravention of lawss or ordinances clearly influences the judgment.
**Article 318** (Motion for acceptance of *jokoku*-appeal) (excerpt)
1. In cases where the court to which a *jokoku*-appeal shall be made is the Supreme Court, the Supreme Court may, upon motion, by ruling, and as the court of last resort, accept a case in which the original judgment includes adn adjudication wwhich contradicts the precedent of the Supreme Court (if there is no such precedent, the precedent of the *Taishin'in*, or of a high court as the court of last resort or the *koso*-appellate court), or any other case which is deemed to include an important matter relating to interpretation of laws or ordinances.
2. The motion referred to in the preceding paragraph (hereinafter referred to as "motion for acceptance of *jokoku*-appeal") shall not be made on the grounds provided for in Article 312, paragraphs 1 and 2.
3, In the cases referred to in paragraph 1, the Supreme Court may, upon determining that there are unimportant reasons among the reasons given for a motion for acceptance of *jokoku*-appeal, exclude the unimportant reasons.
4. In cases where there is a ruling under paragraph 1, it shall be deemed that the *jokoku*-appeal has been made. In such cases, with regard to the application of the provisions of Article 320, the reasons given in a motion for acceptance of a *jokoku*-appeal, except for reasons excluded under the preceding paragraph, shall be deemed the reasons for the *jokoku*-appeal.

**មាត្រា ២៨៥.-** មូលហេតុដាច់ខាតនៃបណ្ដឹងសាទុក្ខ

១- ក្នុងករណីណាមួយដូចបានកំណត់ខាងក្រោមនេះ ត្រូវចាត់ទុកថា មានមូលហេតុនៃបណ្ដឹងសាទុក្ខជាដរាប :

**ក**- តុលាការដែលចេញសាលដីកា ឬ សាលក្រម មិនត្រូវបានចាត់តាំង ដោយស្របទៅតាមច្បាប់ ។

**ខ**- ចៅក្រមដែលច្បាប់មិនអនុញ្ញាតឱ្យចូលរួមក្នុងការចេញសាលដីកា ឬ សាលក្រម តែបានចូលរួម ។

**គ**- ភាពផ្ទុយនឹងបញ្ញត្តិស្ដីពីសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការ ។

**ឃ**- ការខ្វះសិទ្ធិតំណាងដែលកំណត់ដោយច្បាប់ សិទ្ធិតំណាងដោយអាណត្តិ ឬ ការប្រគល់សិទ្ធិចាំបាច់សម្រាប់អ្នកតំណាងដើម្បីធ្វើសកម្មភាពបណ្ដឹង ។

**ង**- ភាពផ្ទុយនឹងបញ្ញត្តិស្ដីពីការបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ ។

**ច**- សាលដីកា ឬ សាលក្រម គ្មានសំអាងហេតុ ឬ មានសំអាងហេតុ តែផ្ទុយនឹងគ្នា ។

២- បញ្ញត្តិនៃចំណុច **ឃ** នៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការទទួលស្គាល់ពេលក្រោយ តាមបញ្ញត្តិកថាខណ្ឌទី ២ នៃមាត្រា ៣៥ (វិធានការក្នុងករណីដែលខ្វះសមត្ថភាពក្នុងការធ្វើបណ្ដឹងជាអាទិ៍) ឬ កថាខណ្ឌទី ៣ នៃមាត្រា ៥៧ (វិធានការក្នុងករណីនៃការខ្វះសិទ្ធិតំណាង) នៃក្រមនេះ ។

(កំណត់)

មាត្រានេះតម្រូវនឹងកថាខណ្ឌទី 2 មាត្រា 312 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។ សូមមើលផងដែរនូវមាត្រា 395 នៃក្រមនីតិវិធីរដ្ឋប្បវេណីចាស់ ។

បញ្ញត្តិនេះចែងអំពីហេតុដែលក្លាយជាមូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ ។ មានន័យថា ចំពោះការធ្វើផ្ទុយនឹងនីតិវិធីសំខាន់ៗ ភាគីមិនចាំបាច់ធ្វើការបញ្ជាក់ថា ភាពផ្ទុយនឹងនីតិវិធីនេះមានឥទ្ធិពលទៅលើសាលដីកា (សាលក្រម) ទេ ។ គោលការណ៍បើកចំហជាសាធារណៈនៅក្នុងចំណុច ៦ នៃកថាខណ្ឌទី ១ មានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ១១៥ (ការទាញហេតុផលដោយផ្ទាល់មាត់) ។

ការខ្វះសំអាងហេតុ ដែលចែងនៅក្នុងចំណុច ៧ នៃកថាខណ្ឌទី ១ មានន័យថា ខ្វះទាំងអស់ ឬ មួយផ្នែកនៃសំអាងហេតុដើម្បីធ្វើសេចក្តីសម្រេចបញ្ចប់ ដូចដែលមានចែងក្នុងចំណុច ៩ កថាខណ្ឌទី ១ នៃមាត្រា ១៨៩ (លិខិតសាលក្រម) ។ ហើយករណីដែលសំអាងហេតុផ្ទុយនឹងគ្នា មានន័យថា សំអាងហេតុអំពីហេតុសំខាន់ៗដែលត្រូវមានឥទ្ធិពលខ្លាំងទៅលើសាលដីកា (សាលក្រម) មានភាពផ្ទុយមិនស៊ីគ្នា (ចំពោះការខ្វះ ឬ ភាពមិនច្បាស់ ចំពោះមូលហេតុក្នុងការយក ឬ មិនយកភស្តុតាង មិនមែនជា "ករណីដែលសំអាងហេតុ ផ្ទុយនឹងគ្នា" ដែលចែងក្នុងបញ្ញត្តិនេះឡើយ) ។

Code of Civil Procedure (Japan)
**Article 312** (Grounds for *jokoku*-appeal) (excerpt)
2. A *jokoku*-appeal may also be made based upon any of the following grounds. However, with regard to the grounds referred to in item iv, this shall not apply to cases where ratification has been made in accordance with the provisions of Article 34, paragraph 2 (including those cases to which it applies *mutatis mutandis* in Article 59).
i) the court rendering judgment was not composed according to law
ii) a judge, who was prohibited by law from doing so, participated in the judgment
iii) provisions regarding exclusive jurisdiction have been contravened
iv) there existed some defect in the authorization of the legal representative or advocate, or in the necessary authority granted to such representative for the act of litigation
v) provisions concerning public oral argument have been contravened
vi) the judgment was made without giving the reason therefor, or where the reasons given are not consistent

Old Code of Civil Procedure (Japan, 1890, last amendment: 1992)
**Article 395** (Absolute grounds for *jokoku*-appeal)
1. *Jokoku*-appeal shall always be deemed to have the ground therefor in the following cases:
i) In case the court to render judgment is not constituted in compliance with the law;
ii) In case a judge who shall not participate in a judgment by virtue of the law has participated in the judgment;
iii) In case the provisions relating to the exclusive jurisdiction have been violated;
iv) In case there is a defect in the powers of legal representation or litigation representation, or necessary powers granted to a representative to conduct proceedings;
v) In case the provisions concerning open oral argument have been violated;
vi) In case the judgment has not been furnished with reasons or there are discrepancies in the reasons.
2. The provisions of item iv) of the preceding paragraph shall not apply to cases where the ratification as mentioned in Article 54 or Article 87 has been made.

## **មាត្រា ២៨៦.-** ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍

បញ្ញត្តិនៃជំពូកទី ២ នៃគន្ថីទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងសាទុក្ខ និង នីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខ លើកលែងតែមានបញ្ញត្តិពិសេស ។

(កំណត់)

មាត្រានេះតម្រូវនឹងមាត្រា 313 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

ការវិនិច្ឆ័យបណ្តឹងសាទុក្ខ គឺជាការវិនិច្ឆ័យទៅលើអង្គច្បាប់ ប៉ុន្តែ មានចំណុចជាច្រើនដូចគ្នានឹងបណ្តឹងឧទ្ធរណ៍ដែលជាបណ្តឹងឧបាស្រ័យចំពោះសាលក្រមនៃការជម្រះក្តីលើកទី ១ ហេតុនេះហើយ ជាគោលការណ៍ បញ្ញត្តិស្តីពីការវិនិច្ឆ័យបណ្តឹងឧទ្ធរណ៍ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការវិនិច្ឆ័យបណ្តឹងសាទុក្ខ ។

(បញ្ញត្តិនៃជំពូកទី ២ (បណ្តឹងឧទ្ធរណ៍) នៃគន្ថីទី ៣ ដែលត្រូវយកមកអនុវត្តដូចគ្នាចំពោះបណ្តឹងសាទុក្ខ)

កថាខណ្ឌទី ១ ចំណុច ក (ការព្រមព្រៀងមិនធ្វើបណ្តឹងឧទ្ធរណ៍) នៃមាត្រា ២៦០ (សាលក្រមដែលអាចប្តឹងឧទ្ធរណ៍បាន ជាអាទិ៍) មាត្រា ២៦១ (ការកម្រិតបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចលើបន្ទុកនៃប្រាក់ប្រដាប់ក្តី) មាត្រា ២៦២ (សេចក្តីសម្រេចដែលត្រូវទទួលការវិនិច្ឆ័យរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍) មាត្រា ២៦៣ (ការលះបង់សិទ្ធិប្តឹងឧទ្ធរណ៍) មាត្រា ២៦៤ (អំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍) កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣ នៃមាត្រា ២៦៥ (របៀបប្តឹងឧទ្ធរណ៍) (តែកថាខណ្ឌទី ១ នៃមាត្រា ២៦៥ មិនយកមកអនុវត្តដូចគ្នាទេ) មាត្រា ២៦៦ (សិទ្ធិពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍របស់តុលាការនៃបណ្តឹងឧទ្ធរណ៍) មាត្រា ២៦៧ (ការបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍) មាត្រា ២៦៩ (ការដកពាក្យបណ្តឹងឧទ្ធរណ៍) មាត្រា ២៧០ (បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ) កថាខណ្ឌទី ១ នៃមាត្រា ២៧២ (ទំហំនៃការទាញហេតុផលដោយផ្ទាល់មាត់ ជាអាទិ៍) (តែមានកម្រិតដោយមាត្រា ២៩៥ (ទំហំនៃការស្រាវជ្រាវ)) មាត្រា ២៧៣ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីនីតិវិធីនៃការជំនុំជម្រះលើកទី ១) (តែមានកម្រិតដោយសារតែបណ្តឹងសាទុក្ខជាបណ្តឹងដែលវិនិច្ឆ័យលើអង្គច្បាប់) កថាខណ្ឌទី ១ នៃមាត្រា ២៧៤ (អានុភាពនៃសកម្មភាពបណ្តឹងនៅក្នុងការជំនុំជម្រះលើកទី ១ ជាអាទិ៍) កថាខណ្ឌទី ២ នៃមាត្រា ២៧៧ (ការច្រានចោលបណ្តឹងឧទ្ធរណ៍) មាត្រា ២៧៨ (ទំហំនៃការផ្លាស់ប្តូរសាលក្រមនៃការជំនុំជម្រះលើកទី ១) ។

(បញ្ញត្តិដែលមិនត្រូវយកមកអនុវត្តដូចគ្នាចំពោះបណ្តឹងសាទុក្ខ)

វាក្យខណ្ឌទី ១ កថាខណ្ឌទី ១ នៃមាត្រា ២៦០ (សាលក្រមដែលអាចប្តឹងឧទ្ធរណ៍បាន ជាអាទិ៍) កថាខណ្ឌទី ១ នៃមាត្រា ២៦៥ (របៀបប្តឹងឧទ្ធរណ៍) មាត្រា ២៦៨ (ការលើកចោលបណ្តឹងឧទ្ធរណ៍ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់) មាត្រា ២៧១ (ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នដោយតុលាការនៃបណ្តឹងឧទ្ធរណ៍) កថាខណ្ឌទី ២ នៃមាត្រា ២៧២ (ទំហំនៃការទាញហេតុផលដោយផ្ទាល់មាត់ ជាអាទិ៍) កថាខណ្ឌទី ២ នៃមាត្រា ២៧៤ (អានុភាពនៃសកម្មភាពបណ្តឹងនៅក្នុងការជំនុំជម្រះលើកទី ១ ជាអាទិ៍) មាត្រា ២៧៥ (ការកម្រិតនូវការអះអាងស្តីពីអសមត្ថកិច្ចក្នុងការជំនុំជម្រះលើកទី ១) មាត្រា ២៧៦ (ការដាក់ពាក្យបណ្តឹងតប) កថាខណ្ឌទី ១ នៃមាត្រា ២៧៧ (ការច្រានចោលបណ្តឹងឧទ្ធរណ៍) មាត្រា ២៧៩ (ការលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១) មាត្រា ២៨០ (ការបញ្ជូនរឿងក្តីត្រឡប់ទៅវិញ) មាត្រា ២៨១ (ការផ្ទេរដោយមូលហេតុខុសសមត្ថកិច្ចផ្តាច់មុខរបស់តុលាការនៃការជំនុំជម្រះលើកទី ១) មាត្រា ២៨២ (ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នក្នុងសាលដីកានៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍) ។

**Article 313** (*Mutatis mutandis* application of provisions relating to *koso*-appeal)
Except as otherwise provided, the provision of the preceding chapter shall apply *mutatis mutandis* to a *jokoku*-appeal and the litigation proceedings in the *jokoku*-appeal instance.

## មាត្រា ២៨៧.- របៀបប្តឹងសាទុក្ខ

ដើម្បីប្តឹងសាទុក្ខ ភាគីត្រូវដាក់ពាក្យបណ្តឹងសាទុក្ខទៅតុលាការដើម ។ នៅក្នុងករណីនេះ តុលាការដើមត្រូវផ្ញើឱ្យបានឆាប់រហ័ស នូវពាក្យបណ្តឹងសាទុក្ខ និង សំណុំរឿងទៅតុលាការនៃបណ្តឹងសាទុក្ខ ។

(កំណត់)

មាត្រានេះគ្រាន់តែចែងថា ត្រូវដាក់ពាក្យបណ្តឹងសាទុក្ខទៅតុលាការដើម ហើយមិនមែនមានន័យថា យកគោលការណ៍ឱ្យតុលាការដើមពិនិត្យពាក្យបណ្តឹងតាមល័ក្ខខ័ណ្ឌនៃរូបមន្តឡើយ (យើងយកកិច្ចការដាក់ស្តែង នៅប្រទេសកម្ពុជាថា សាលាឧទ្ធរណ៍មិនពិនិត្យពាក្យបណ្តឹង តាមល័ក្ខខ័ណ្ឌនៃរូបមន្ត ឬ ល័ក្ខខ័ណ្ឌផ្សេងទៀតទេ តែត្រូវផ្ញើពាក្យបណ្តឹងសាទុក្ខ ដែលត្រូវបានដាក់ និង សំណុំរឿង ទៅតុលាការកំពូល) ។

មាត្រានេះ ខុសគ្នានឹងមាត្រា 314 កថាខណ្ឌទី 1 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ដែលកំណត់ឱ្យតុលាការដើមពិនិត្យល័ក្ខខ័ណ្ឌនៃបណ្តឹងសាទុក្ខថាតើស្របច្បាប់ ឬអត់ ផ្ទុយទៅវិញ បញ្ញត្តិនេះកំណត់ថា តុលាការនៃបណ្តឹងសាទុក្ខផ្ទាល់ត្រូវពិនិត្យ ហើយនៅពេលណាដែលពិនិត្យឃើញថា ត្រឹមត្រូវតាមច្បាប់ ទើបតុលាការនៃបណ្តឹងសាទុក្ខនោះយកបណ្តឹងនោះទៅជំនុំជម្រះ ។

ដោយមានបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ២៦៥ (របៀបប្តឹងឧទ្ធរណ៍) ដែលត្រូវយកមកអនុវត្តដូចគ្នា ចំពោះបណ្តឹងសាទុក្ខ ហេតុនេះហើយមិនបាច់ចែងអំពីចំណុចផ្សេងៗដែលត្រូវសរសេរក្នុងពាក្យបណ្តឹងសាទុក្ខទេ ។

Code of Civil Procedure (Japan)
**Article 314** (Method of filing *jokoku*-apeal, etc.) (excerpt)
1. A *jokoku*-appeal shall be filed by submitting a *jokoku*-appeal document to the original court.

## មាត្រា ២៨៨.- ការបញ្ជូនលិខិតទទួលពាក្យបណ្តឹងសាទុក្ខ ជាអាទិ៍

១- នៅក្នុងករណីដែលមានការដាក់ពាក្យបណ្តឹងសាទុក្ខ តុលាការនៃបណ្តឹងសាទុក្ខត្រូវបញ្ជូនលិខិតទទួលពាក្យបណ្តឹងសាទុក្ខទៅភាគី លើកលែងតែក្នុងករណីដែលលើកចោលពាក្យបណ្តឹងសាទុក្ខនោះ ។

២- នៅពេលដែលតុលាការបញ្ជូនលិខិតទទួលពាក្យបណ្តឹងសាទុក្ខទៅចុងបណ្តឹងសាទុក្ខ ដោយយោលតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការនៃបណ្តឹងសាទុក្ខត្រូវបញ្ជូនទាំងពាក្យបណ្តឹងសាទុក្ខទៅជាមួយផង ។

(កំណត់)

មាត្រានេះតម្រូវនឹងមាត្រា 189 នៃបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

នៅពេលតុលាការនៃបណ្ដឹងសាទុក្ខលើកចោលពាក្យបណ្ដឹងសាទុក្ខ តុលាការនៃបណ្ដឹងសាទុក្ខត្រូវពិនិត្យនូវចំណុចចាំបាច់ដែលត្រូវសរសេរក្នុងពាក្យបណ្ដឹងសាទុក្ខ និង ពិនិត្យថាតើមានបិទតែមប្រិ៍សារពើពន្ធឬគ្មាន និង ត្រូវបង្គាប់ឱ្យកែតម្រូវបើមានការខ្វះខាត ហើយប្រសិនបើភាគីមិនបានកែតម្រូវក្នុងអំឡុងពេលដែលបានកំណត់ទេ តុលាការនោះត្រូវលើកចោលពាក្យបណ្ដឹងសាទុក្ខនោះ ដោយដីកាសម្រេច ។

Rules of Civil Procedure (Japan)
**Article 189** (Service, etc., of written notice of filing of *jokoku*-appeal)
1.In cases where a *jokoku*-appeal has been filed, except for cases where an order to dismiss the *jokoku*-appeal document or a ruling to dismiss the *jokoku*-appeal under Artitcle 316 (Dismissal of *jokoku*-appeal by original court), paragraph 1, item 1 of the Code has been rendered, written notices of filing of a *jokoku*-appeal shall be served on the parties.
2. When a written notice of filing of a *jokoku*-appeal is served on the *jokoku*-respondent in accordance with the provisions of the preceding paragraph, the *jokoku*-appeal document shall be served simultaneously.
3. In cases where a *jokoku*-appeal was filed before the judgment paper or the record in lieu of judgment paper of the original court is served, the service of the written notices of filing of *jokoku*-appeal under the provisions of paragraph 1 shall be made together with the service of the judgment paper or the record in lieu of judgment paper.

**មាត្រា ២៨៩.-** ការសរសេរមូលហេតុនៃបណ្ដឹងសាទុក្ខ
១- ប្រសិនបើមិនបានសរសេរនូវមូលហេតុនៃបណ្ដឹងសាទុក្ខក្នុងពាក្យបណ្ដឹងសាទុក្ខទេ ដើមបណ្ដឹងសាទុក្ខត្រូវដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខនេះ ជូនទៅតុលាការនៃបណ្ដឹងសាទុក្ខ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃបន្ទាប់ពីបានទទួលការបញ្ជូននូវលិខិតទទួលពាក្យបណ្ដឹងសាទុក្ខ ។
២- ក្នុងករណីដែលបណ្ដឹងសាទុក្ខធ្វើឡើង ដោយយកមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ២៨៤ (មូលហេតុទូទៅនៃបណ្ដឹងសាទុក្ខ) ខាងលើនេះ ដើមបណ្ដឹងសាទុក្ខត្រូវសរសេរមូលហេតុនៃបណ្ដឹងសាទុក្ខនេះ ដោយបញ្ជាក់អំពីបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្ត និង ហេតុដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្តនោះ ។ នៅក្នុងករណីនេះ ប្រសិនបើហេតុនោះមានទំនាក់ទំនងនឹងនីតិវិធីនៃបណ្ដឹង ត្រូវសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់នូវអង្គហេតុដែលផ្ទុយនោះ ។
៣- ក្នុងករណីដែលបណ្ដឹងសាទុក្ខធ្វើឡើង ដោយយកមូលហេតុដូចចំណុចណាមួយដែលបានកំណត់នៅកថាខណ្ឌទី ១ នៃមាត្រា ២៨៥ (មូលហេតុដាច់ខាតនៃបណ្ដឹងសាទុក្ខ) នៃក្រមនេះ ដើមបណ្ដឹងសាទុក្ខត្រូវសរសេរមូលហេតុនៃបណ្ដឹងសាទុក្ខ ដោយបញ្ជាក់នូវចំណុចក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៨៥ និង អង្គហេតុដែលត្រូវនឹងចំណុចនោះ ។

(កំណត់)

កថាខណ្ឌទី ១ ត្រូវនឹងក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 315 និង បទប្បញ្ញត្តិស្ដីពីនីតិវិធីរដ្ឋប្បវេណី មាត្រា 194 ។ កថាខណ្ឌទី ២ និង ទី ៣ ត្រូវនឹងបទប្បញ្ញត្តិស្ដីពីនីតិវិធីរដ្ឋប្បវេណី មាត្រា 190 ។

មាត្រានេះកំណត់អំពីការដាក់មូលហេតុបណ្ដឹងសាទុក្ខជាដាច់ខាត ដើម្បីកុំឱ្យមានការយឺតយ៉ាវលើនីតិវិធី ដោយសារដាក់មូលហេតុនៃបណ្ដឹងសាទុក្ខជាបន្តបន្ទាប់ ។ ប្រសិនបើមិនបានសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់នូវមូលហេតុនៃ

បណ្ដឹងសាទុក្ខក្នុងពាក្យបណ្ដឹងសាទុក្ខ ហើយនៅតែមិនបានដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ ក្នុងអំឡុងពេល ៣០ ថ្ងៃទេ តុលាការនៃបណ្ដឹងសាទុក្ខអាចលើកចោលនូវបណ្ដឹងសាទុក្ខនោះបាន ដោយមិនបាច់ធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ( មាត្រា ២៩០ ( ការលើកចោលបណ្ដឹងសាទុក្ខ) ) ។

ចំពោះចំណុចដែលត្រូវសរសេរនៅក្នុងលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខវិញ សូមមើលមាត្រា 51 នៃបទប្បញ្ញត្តិស្ដីពីនីតិវិធីរដ្ឋប្បវេណីចាស់នៃប្រទេសជប៉ុន (ឈ្មោះ ឬ នាមករណ៍របស់ភាគី សញ្ញាណរឿងក្ដី មូលហេតុនៃបណ្ដឹងសាទុក្ខ សញ្ញាណនៃឯកសារដែលដាក់ភ្ជាប់ ថ្ងៃ-ខែ-ឆ្នាំ សញ្ញាណនៃតុលាការ) ។

Code of Civil Procedure (Japan)
**Article 315** (Statement of reason for *jokoku*-appeal)
1. In cases where the *jokoku*-appeal document does not include a statement of the reasons therefor, the *jokoku*-appellant must submit a document stating such reasons within the period of time prescribed by the Rules of the Supreme Court.
2. The reasons for the *jokoku*-appeal shall be stated in accordance with the form prescribed by the Rules of the Supreme Court.

Rules of Civil Procedure (Japan)
**Article 190** (Form of statement of reason for *jokoku*-appeal referred to in Article 312m paragraph 1 and 2 of the Code / The Code Article 315)
1. The statement of reasons for a *jokoku*-appeal which is made based upon the grounds that there is an alleged misinterpretation or any other contravention of the Constitution in the judgment shall indicate the clauses of the Constitution and such grounds of contravention of the Constitution. In such cases, when the grounds are related to the litigation proceedings, facts which contravene the Constitution shall be indicated.
2. The statement of reasons for a *jokoku*-appeal which is made based upon any of the grounds prescribed by the items of paragraph 2 of Article 312 (Grounds for *jokoku*-appeal) of the Code shall indicate such clauses ant the facts which fall under those clauses.
**Article 194** (Period of submitting document stating reason for *jokoku*-appeal / The Code Article 315)
The period within which a document stating reasons for a *jokoku*-appeal must be submitted shall be 50 days from the day when the written notice of filing of the *jokoku*-appeal has be served on the *jokoku*-appellant in accordance with Artice 189 (Service, etc., of written notice of filing of *jokoku*-appeal), paragraph 1.

**មាត្រា ២៩០.-** ការលើកចោលបណ្ដឹងសាទុក្ខ

ប្រសិនបើត្រូវនឹងចំណុចណាមួយខាងក្រោមនេះយ៉ាងជាក់ច្បាស់ តុលាការនៃបណ្ដឹងសាទុក្ខ ត្រូវលើកចោលបណ្ដឹងសាទុក្ខ ដោយដីកាសម្រេច :

**ក-** បើបណ្ដឹងសាទុក្ខនោះមិនស្របច្បាប់ ហើយមិនអាចកែតម្រូវចំណុចខ្វះខាតនោះបាន ។

**ខ-** បើមិនបានដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ២៨៩ (ការសរសេរមូលហេតុនៃបណ្ដឹងសាទុក្ខ) ខាងលើនេះ ឬ បើការសរសេរមូលហេតុនៃបណ្ដឹងសាទុក្ខ ផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ២៨៩ ។

(កំណត់)

បញ្ញត្តិនេះតម្រូវនឹងមាត្រា 399-3 នៃក្រមនីតិវិធីរដ្ឋប្បវេណីចាស់របស់ជប៉ុន និង កថាខណ្ឌទី 1 មាត្រា 317 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

បញ្ញត្តិនេះចែងអំពីដីកាសម្រេចលើកចោលនូវបណ្ដឹងសាទុក្ខ ដោយធ្វើការពិនិត្យឯកសារ តាមទម្រង់នៃពាក្យបណ្ដឹង ។

បណ្តឹងសាទុក្ខមិនស្របច្បាប់ ហើយមិនអាចកែតម្រូវបាន ដូចជា បណ្តឹងសាទុក្ខដែលដាក់ហួសអំឡុងពេលនៃបណ្តឹងសាទុក្ខ ភាគីខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹង ជាដើម ។

<u>Old Code of Civil Procedure (Japan, 1890, last amendment: 1992)</u>
**Article 399-3** (Turning down of *jokoku*-appeal by examination of documents)
The court of last resort may turn down *jokoku*-appeal by a judgment without resorting to oral argument in each case of Article 399 paragraph 1.

<u>Code of Civil Procedure (Japan)</u>
**Article 317** (Dismissal, etc. of *jokoku*-appeal by court of last resort) (excerpt)
1. The court of last resort may dismiss a *jokoku*-appeal by ruling in the cases referred to in each item of paragraph 1 of the preceding article.

**មាត្រា ២៩១.-** ដីកាសម្រេចបង្គាប់ឱ្យកែតម្រូវ

១- ប្រសិនបើការសរសេរមូលហេតុទាំងមូលនៃបណ្តឹងសាទុក្ខ ដែលត្រូវបានបញ្ជាក់ក្នុងពាក្យបណ្តឹងសាទុក្ខ ឬ ក្នុងលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ដែលត្រូវបានដាក់ក្នុងអំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៨៩ (ការសរសេរមូលហេតុនៃបណ្តឹងសាទុក្ខ) នៃក្រមនេះ ផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ២៨៩ នោះយ៉ាងជាក់ច្បាស់ តុលាការនៃបណ្តឹងសាទុក្ខ ត្រូវកំណត់អំឡុងពេលសមរម្យ ហើយបង្គាប់ឱ្យដើមបណ្តឹងសាទុក្ខកែតម្រូវនូវចំណុចខ្វះខាត ក្នុងអំឡុងពេលនោះ ដោយដីកាសម្រេច ។

២- ដីកាសម្រេចលើកចោលនូវបណ្តឹងសាទុក្ខដែលបានកំណត់ក្នុងចំណុច **ខ** នៃមាត្រា ២៩០ (ការលើកចោលបណ្តឹងសាទុក្ខ) ខាងលើនេះ ត្រូវធ្វើឡើង ក្នុងករណីដែលដើមបណ្តឹងសាទុក្ខមិនបានធ្វើការកែតម្រូវនូវចំណុចខ្វះខាត នៅក្នុងអំឡុងពេលដែលបានកំណត់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

មាត្រានេះតម្រូវនឹងមាត្រា 196 នៃបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

<u>Rules of Civil Procedure (Japan)</u>
**Article 196** (Order to correct / The Code Article 316)
1. In cases where the entire statement of reasons for a *jokoku*-appeal included in the *jokoku*-appeal document or the document stating reasons for the *jokoku*-appeal submitted within the period referred to in Article 194 (Period for submitting document stating reason for *jokoku*-appeal) clearly fails to fulfill the provisions of Article 190 (Form of statement of reason for *jokoku*-appeal referred to in Article 312, paragraphs 1 and 2 of the Code) or 191 (Form of statement of reason for *jokoku*-appeal referred to in Article 312, paragraph 3 of the Code), the original court shall, by ruling, designate an appropriate period and order the correction of the defect within such period.
2. The ruling to dismiss the *jokoku*-appeal under the provisions of Article 316 (Dismissal of *jokoku*-appeal by original court), paragraph 1, item 2 of the Code (being limited to a ruling on the grounds that the statement of the reasons for the *jokoku*-appeal clearly contravenes the provisions of Article 315 (Statement of reason for appeal) paragraph 2 of the Code) shall be rendered when the *jokoku*-appellant has not corrected the defect within the period designated in accordance with the provisions of the preceding paragraph.

**មាត្រា ២៩២.-** ការបញ្ជូនឯកសារចម្លងនៃលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ

ប្រសិនបើតុលាការនៃបណ្តឹងសាទុក្ខមិនចេញដីកាសម្រេចលើកចោលបណ្តឹងសាទុក្ខតាមបញ្ញត្តិនៃមាត្រា ២៩០ (ការលើកចោលបណ្តឹងសាទុក្ខ) នៃក្រមនេះទេ តុលាការនៃបណ្តឹងសាទុក្ខត្រូវបញ្ជូនឯកសារចម្លងនៃលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខនោះ ទៅចុងបណ្តឹងសាទុក្ខ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតុលាការនៃបណ្តឹងសាទុក្ខជំនុំជម្រះ និង សម្រេចសេចក្តី ដោយពុំឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ ហើយយល់ឃើញថា ពុំចាំបាច់បញ្ជូនឯកសារចម្លងនៃលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខនោះ ។

(កំណត់)

មាត្រានេះតម្រូវនឹងមាត្រា 198 នៃបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

ប្រសិនបើតុលាការបានយល់ឃើញថា បណ្តឹងសាទុក្ខត្រឹមត្រូវតាមច្បាប់ហើយ តុលាការត្រូវធ្វើការវិនិច្ឆ័យទៅលើមូលហេតុនៃបណ្តឹងសាទុក្ខ ហើយត្រូវបញ្ជូនឯកសារចម្លងនៃលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ទៅចុងបណ្តឹងសាទុក្ខ ។ ប៉ុន្តែ ឧទាហរណ៍ថា ប្រសិនបើក្រោយមកតុលាការឃើញថា បណ្តឹងសាទុក្ខនោះមិនស្របច្បាប់ តុលាការត្រូវចេញសាលដីកាលើកចោលនូវបណ្តឹងសាទុក្ខនោះ ហេតុដូច្នេះពុំចាំបាច់បញ្ជូនឯកសារចម្លងនោះឡើយ ។

Rules of Civil Procedure (Japan)
**Article 198** (Service of document stating reason for *jokoku*-appeal)
In cases where the court of last resort has received transmission of a case from the original court, unless the court of last resort renders a ruling to dismiss the *jokoku*-appeal under the provisions of Article 317 (Dismissal, etc., of *jokoku*-appeal by court of last resort), paragraph 1 of the Code or a ruling to dismiss the *jokoku*-appeal under the provisions of paragraph 2 of the article, a copy of the document stating the reasons for the *jokoku*-appeal shall be served on the *jokoku*-respondent. However, this shall not apply to cases where the court of last resort determines it unnecessary to do so when it tries and renders its decision without proceeding to oral argument.

**មាត្រា ២៩៣.-** ការបង្គាប់ឱ្យដាក់ឯកសារត្រៀម

តុលាការនៃបណ្តឹងសាទុក្ខអាចកំណត់អំឡុងពេលសមរម្យ ហើយបង្គាប់ឱ្យចុងបណ្តឹងសាទុក្ខដាក់ឯកសារត្រៀមលើកដំបូងបាន ។

(កំណត់)

មាត្រានេះតម្រូវនឹងមាត្រា 201 នៃបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

យោលតាមមាត្រា ២៩៤ (ការច្រានចោលបណ្តឹងសាទុក្ខដោយមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់) ខាងក្រោមនេះ ក្នុងករណីដែលតុលាការយល់ឃើញដោយពិនិត្យឯកសារថា បណ្តឹងសាទុក្ខគ្មានមូលហេតុទេ ហើយចេញសាលដីកាច្រានចោលនូវបណ្តឹងសាទុក្ខនោះ ដោយមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ជាគោលការណ៍ តុលាការពុំចាំបាច់បង្គាប់ឱ្យចុងបណ្តឹងសាទុក្ខដាក់ឯកសារត្រៀមទេ ។

ការបង្គាប់ឱ្យដាក់ ឬ មិនឱ្យដាក់ឯកសារត្រៀមនោះ គឺជាឆន្ទានុសិទ្ធិរបស់ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

Rules of Civil Procedure (Japan)
**Article 201** (Order to submit written answer)
The presiding judge of the court of last resort, or of the Supreme Court in cases where a motion for acceptance of a *jokoku*-appeal has been made may, designating an appropriate period, order the *jokoku*-respondent or the adversary party to submit a written answer.

**មាត្រា ២៩៤.-** ការច្រានចោលបណ្តឹងសាទុក្ខដោយមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់

តុលាការនៃបណ្តឹងសាទុក្ខអាចច្រានចោលបណ្តឹងសាទុក្ខដោយសាលដីកាបាន ដោយមិនចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ បើយល់ឃើញថា បណ្តឹងសាទុក្ខនោះគ្មានមូលហេតុ ក្រោយពីបានពិនិត្យពាក្យបណ្តឹងសាទុក្ខ លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ឯកសារត្រៀមដែលចុងបណ្តឹងសាទុក្ខបានដាក់លើកដំបូង ឬ ឯកសារផ្សេងទៀត ។

（កំណត់）

មាត្រានេះតម្រូវនឹងមាត្រា 319 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

ដើម្បីចេញសាលក្រមសម្រេចអង្គសេចក្តី តុលាការត្រូវឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ （មាត្រា ១១៤ （ភាពចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់）） ប៉ុន្តែ មាត្រានេះបញ្ញត្តិអំពីភាពគ្រប់គ្រាន់ដោយគ្រាន់តែពិនិត្យឯកសារ ដោយសារការជំនុំជម្រះបណ្តឹងសាទុក្ខជាការវិនិច្ឆ័យលើអង្គច្បាប់ ។

បញ្ញត្តិនេះគឺជាបញ្ញត្តិក្នុងករណីពិសេសដែលតុលាការច្រានចោលបណ្តឹងសាទុក្ខ រីឯក្នុងករណីដែលតុលាការបដិសេធចោលសាលដីកាដើម（សាលក្រមដើម）តុលាការចាំបាច់ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ។

Code of Civil Procedure (Japan)
**Article 319** (Dismissal of *jokoku*-appeal without oral argument)
The court of last resort may, upon determining from the *jokoku*-appeal document, the statement of reasons for the *jokoku*-appeal, the answer thereto or any other document, that the *jokoku*-appeal is groundless, dismiss the *jokoku*-appeal by judgment without proceeding to oral argument.

**មាត្រា ២៩៥.-** ទំហំនៃការស្រាវជ្រាវ

តុលាការនៃបណ្តឹងសាទុក្ខ ត្រូវធ្វើការស្រាវជ្រាវត្រឹមតែកម្រិតនៃឧបាស្រ័យ ដោយផ្អែកលើមូលហេតុនៃបណ្តឹងសាទុក្ខ ។

（កំណត់）

មាត្រានេះតម្រូវនឹងមាត្រា 320 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

បញ្ញត្តិនេះចែងថា តុលាការនៃបណ្តឹងសាទុក្ខត្រូវវិនិច្ឆ័យសាលដីកាដើម（សាលក្រមដើម）នៅក្នុងទំហំនៃឧបាស្រ័យ

របស់ភាគីថាតើត្រឹមត្រូវឬអត់ ហើយអាចបដិសេធចោលបាន ។

<u>Code of Civil Procedure (Japan)</u>
**Article 320** (Scope of investigation)
Based on the reasons for the *jokoku*-appeal, the court of last resort shall undertake investigations only to the extent assertied in the appeal.

**មាត្រា ២៩៦.-** ចំណងនៃអង្គហេតុស្ថាពររបស់សាលដីកាដើម ឬ សាលក្រមដើម

១- អង្គហេតុដែលបានចូលជាស្ថាពរដោយត្រឹមត្រូវតាមច្បាប់ក្នុងសាលដីកាដើម ឬ សាលក្រមដើម ត្រូវមានចំណងចំពោះតុលាការនៃបណ្តឹងសាទុក្ខ ។

២- ក្នុងករណីដែលមានបណ្តឹងសាទុក្ខដែលយោលទៅតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ២៨៣ (តុលាការនៃបណ្តឹងសាទុក្ខ) នៃក្រមនេះ តុលាការនៃបណ្តឹងសាទុក្ខមិនអាចបដិសេធចោលសាលក្រមដើមឡើយ ដោយយកមូលហេតុថាការចូលជាស្ថាពរនៃអង្គហេតុក្នុងសាលក្រមដើមនោះ ផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្ត ។

(កំណត់)

មាត្រានេះតម្រូវនឹងមាត្រា 321 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

កថាខណ្ឌទី ១ ចែងអំពីគោលការណ៍ដែលតុលាការនៃបណ្តឹងសាទុក្ខពុំអាចវិនិច្ឆ័យថាតើការទទួលស្គាល់អង្គហេតុ ក្នុងការវិនិច្ឆ័យដើម ត្រឹមត្រូវឬអត់ ដោយទាមទារឱ្យផ្តល់នូវឯកសារថ្មី ឬ ដោយពិនិត្យភស្តុតាង ដោយហេតុថា ការជំនុំជម្រះបណ្តឹងសាទុក្ខគឺជាការវិនិច្ឆ័យទៅលើអង្គច្បាប់ ថាតើសាលដីកាដើម (សាលក្រមដើម) នោះផ្ទុយនឹងច្បាប់ ឬ បទដ្ឋានគតិយុត្ត ឬអត់ ។

មាត្រា ៧ នៃសេចក្តីព្រាងច្បាប់ស្តីពីការចាត់តាំងតុលាការរបស់ប្រទេសកម្ពុជា ចែងថា "លើកលែងតែក្នុងករណីមានបណ្តឹងសាទុក្ខជាលើកទី ២ ទើបតុលាការនេះសម្រេចទាំងអង្គសេចក្តី និង ទាំងអង្គច្បាប់" ដែលអាចឱ្យយើងយល់ថាតុលាការកំពូលអាចសម្រេចទៅលើអង្គហេតុដែរ ក្នុងការជំនុំជម្រះបណ្តឹងសាទុក្ខលើកទី ២ ។ ចំណុចនេះជាបញ្ហាដែលត្រូវសម្រួល ដោយហេតុថា ការជំនុំជម្រះបណ្តឹងសាទុក្ខគឺជាការវិនិច្ឆ័យទៅលើអង្គច្បាប់ ។

កថាខណ្ឌទី ២ គឺជាករណីដែលប្តឹងផ្លោះទៅបណ្តឹងសាទុក្ខ ។ ក្នុងករណីនេះ ភាគីមិនអាចយកមូលហេតុថា សាលក្រមនៃការជំនុំជម្រះលើកទី ១ មានភាពផ្ទុយច្បាប់ក្នុងការទទួលស្គាល់អង្គហេតុ រីឯតុលាការនៃបណ្តឹងសាទុក្ខក៏មិនអាចបដិសេធចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ ដោយយកមូលហេតុនោះបានដែរ ។

<u>Code of Civil Procedure (Japan)</u>
**Article 321** (Bindingness of fact found in original judgment)
1. Facts legitimately found in the original judgment shall be binding upon the court of last resort.
2. In cases of *jokoku*-appeals in accordance with the provisions of Article 311, paragraph 2, the court of last resort shall not quash the judgment on the grounds that the finding of facts in the original judgment are in contravention of law.

**មាត្រា ២៩៧.‑** ករណីលើកលែងនៃការអនុវត្តចំពោះចំណុចដែលស្រាវជ្រាវដោយឆន្ទានុសិទ្ធិ

បញ្ញត្តិនៃមាត្រា ២៩៥ (ទំហំនៃការស្រាវជ្រាវ) និង មាត្រា ២៩៦ (ចំណងនៃអង្គហេតុស្ថាពររបស់សាលដីកាដើម ឬ សាលក្រមដើម) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះចំណុចដែលតុលាការត្រូវស្រាវជ្រាវ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

(កំណត់)

មាត្រានេះតម្រូវនឹងមាត្រា 322 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

បញ្ញត្តិនេះគឺជាករណីលើកលែងនៃមាត្រា ២៩៥ (ទំហំនៃការស្រាវជ្រាវ) ។ ចំពោះចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិនេះ តុលាការនៃបណ្តឹងសាទុក្ខចាំបាច់ត្រូវធ្វើការស្រាវជ្រាវចំណុចនេះ ដោយពុំមានទំនាក់ទំនងទៅនឹងការមាន ឬ គ្មានសេចក្តីអះអាងរបស់ភាគី ហើយក៏គ្មានទំនាក់ទំនងជាមួយនឹងការទទួលស្គាល់ ឬ មិនទទួលស្គាល់សេចក្តីអះអាងនោះដោយភាគីម្ខាងទៀតឡើយ ។

ឧទាហរណ៍ ការស្រាវជ្រាវទៅលើអត្ថិភាពនៃសិទ្ធិជម្រះក្តី ប្រយោជន៍នៃបណ្តឹងសាទុក្ខ ការគោរពលើអំឡុងពេលដាក់ពាក្យបណ្តឹង ការរៀបចំតុលាការចេញសាលក្រមត្រឹមត្រូវតាមច្បាប់ ឬអត់ ជាដើម នេះគឺជាផលប្រយោជន៍សាធារណៈដែលមិនអាចដោះស្រាយដោយសារតែការបាត់បង់នូវសិទ្ធិប្តឹងតវ៉ា (責問権 Rügerecht) របស់ភាគីទេ ។

Code of Civil Procedure (Japan)
**Article 322** (Exception relating to matters to be examined upon court's own authority)
The preceding two article s shall not apply to matters to be examined upon the court's own authority.

**មាត្រា ២៩៨.‑** ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

តុលាការនៃបណ្តឹងសាទុក្ខអាចប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន តាមពាក្យសុំ ដោយដីកាសម្រេចបាន ត្រឹមតែចំពោះផ្នែកដែលពុំមានឧបាស្រ័យនៅក្នុងសាលដីកាដើម ឬ សាលក្រមដើមតែប៉ុណ្ណោះ ។

(កំណត់)

មាត្រានេះតម្រូវនឹងមាត្រា 323 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន និង មាត្រា 406 នៃក្រមនីតិវិធីរដ្ឋប្បវេណីចាស់របស់ជប៉ុន ។

បញ្ញត្តិនេះមានអត្ថន័យដូចគ្នានឹងមាត្រា ២៧១ (ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នដោយតុលាការនៃបណ្តឹងឧទ្ធរណ៍) ។

Code of Civil Procedure (Japan)
**Article 323** (Declaration of provisional execution)
The court of last resort may, upon motion, by ruling, make a declaration of provisional execution regarding any part of the original judgment to which no appeal has been made.

Old Code of Civil Procedure (Japan, 1890, last amendment: 1992)
**Article 406** (Declaration of provisional execution)
The court of last resort may declare the provisional execution by ruling upon motion only on such part of the original judgment for which an appeal has not been made.

**មាត្រា ២៩៩.-** ការបដិសេធចោល ហើយបញ្ជូនត្រឡប់ទៅតុលាការដើមវិញ ជាអាទិ៍

១- នៅក្នុងករណីដែលមានមូលហេតុដែលបានកំណត់ក្នុងមាត្រា ២៨៤ (មូលហេតុទូទៅនៃបណ្តឹងសាទុក្ខ) ឬ មាត្រា ២៨៥ (មូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ) នៃក្រមនេះ តុលាការនៃបណ្តឹងសាទុក្ខត្រូវបដិសេធចោលនូវសាលដីកាដើម ឬ សាលក្រមដើម ហើយត្រូវបញ្ជូនរឿងក្តីត្រឡប់ទៅតុលាការដើមវិញ ឬ ផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានថ្នាក់ដូចគ្នា លើកលែងតែក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ៣០០ (ការបដិសេធចោល ហើយវិនិច្ឆ័យដោយខ្លួនឯង) នៃក្រមនេះ ។

២- តុលាការដែលបានទទួលរឿងក្តីដោយការបញ្ជូនត្រឡប់មកវិញ ឬ ការផ្ទេរ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើការសម្រេចសេចក្តីដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់សាជាថ្មីម្តងទៀត ។ ក្នុងករណីនេះ សេចក្តីវិនិច្ឆ័យលើអង្គហេតុ និង អង្គច្បាប់ ដែលតុលាការនៃបណ្តឹងសាទុក្ខយកជាមូលហេតុនៃការបដិសេធចោល មានចំណងទៅលើតុលាការដែលបានទទួលការបញ្ជូន ឬ ការផ្ទេរ ។

៣- ចៅក្រមដែលពាក់ព័ន្ធនឹងសាលដីកាដើម ឬ សាលក្រមដើម មិនអាចចូលរួមក្នុងការសម្រេចសេចក្តីដែលបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះទេ ។

(កំណត់)

មាត្រានេះតម្រូវនឹងមាត្រា 325 កថាខណ្ឌទី 1 ទី 3 និង ទី 4 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

បញ្ញត្តិនេះចែងអំពី (១) ការបដិសេធចោលនូវសាលដីកាដើម (សាលក្រមដើម) ដោយតុលាការនៃបណ្តឹងសាទុក្ខ ក្នុងករណីដែលបណ្តឹងសាទុក្ខមានមូលហេតុត្រឹមត្រូវ (២) ការបញ្ជូនរឿងក្តីត្រឡប់ទៅវិញ ឬ ការផ្ទេររឿងក្តី និង (៣) នីតិវិធីវិនិច្ឆ័យនៅក្រោយពេលការបញ្ជូន ឬ ផ្ទេររឿងក្តីនោះ ។

ក្នុងករណីដែលតុលាការនៃបណ្តឹងសាទុក្ខអាចសម្រេចសេចក្តីជំនួសសាលដីកាដើម (សាលក្រមដើម) ដោយសារតែអង្គហេតុដែលសាលដីកាដើម (សាលក្រមដើម) បានទទួលស្គាល់ហើយតែប៉ុណ្ណោះ តុលាការនៃបណ្តឹងសាទុក្ខអាចវិនិច្ឆ័យដោយខ្លួនឯងបាន (មាត្រា ៣០០ (ការបដិសេធចោល ហើយវិនិច្ឆ័យដោយខ្លួនឯង)) ។ ក្រៅពីករណីនេះ តុលាការត្រូវបញ្ជូនរឿងក្តីនោះត្រឡប់ទៅតុលាការដើមវិញ ឬ ផ្ទេររឿងក្តីនោះទៅតុលាការដែលមានថ្នាក់ដូចគ្នា តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ។

តុលាការដែលទទួលរឿងក្ដីគឺចង្អុលទៅលើតុលាការក្នុងភាពទូលាយ (មានករណីបញ្ជូនរឿងក្ដីនោះទៅតុលាការនៃការជំនុំជម្រះលើកទី ១ សូមមើលក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា 413) ។

ជាគោលការណ៍ ត្រូវបញ្ជូនរឿងក្ដីត្រឡប់ទៅតុលាការដើមវិញ ប៉ុន្តែ តាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ប្រសិនបើតុលាការដើម មិនអាចរកចៅក្រមផ្សេងមកជំនួសចៅក្រមដែលមានការទាក់ទងនឹងសាលដីកាដើម (សាលក្រមដើម) ដែលត្រូវបានបដិសេធចោល ដោយសារចំនួនចៅក្រមនៅតុលាការនោះមិនគ្រប់គ្រាន់ តុលាការនៃបណ្ដឹងសាទុក្ខត្រូវផ្ទេររឿងក្ដីនោះទៅតុលាការផ្សេងទៀតដែលមានថ្នាក់ដូចគ្នា ។

ម្យ៉ាងទៀត នៅកម្ពុជា សេចក្ដីព្រាងច្បាប់ស្ដីពីការចាត់តាំងតុលាការ មាត្រា ១៣ វាក្យខណ្ឌទី ៣ ចែងថា "កាលបើក្រោយពីតុលាការកំពូលបានបដិសេធសេចក្ដីសម្រេចលើកមុនរួច ហើយបញ្ជូនទៅឱ្យតុលាការថ្នាក់ក្រោមជំនុំជម្រះជាថ្មី តុលាការថ្នាក់ក្រោមមិនអនុលោមតាមសេចក្ដីសម្រេចរបស់តុលាការកំពូលទេ ហើយសេចក្ដីសម្រេចរបស់តុលាការថ្នាក់ក្រោមលើកក្រោយនេះក៏ត្រូវបានគេប្ដឹងតវ៉ាម្ដងទៀត តាមមធ្យោបាយដដែល" (មានន័យថា សេចក្ដីសម្រេចរបស់តុលាការកំពូល ពុំមានចំណងទៅលើតុលាការថ្នាក់ក្រោមឡើយ) ដែលធ្វើឱ្យយើងមានចម្ងល់ (សូមមើល "សំណើធ្វើវិសោធនកម្មមួយចំនួន លើសេចក្ដីព្រាងច្បាប់ស្ដីពីការចាត់តាំងតុលាការរបស់ប្រទេសកម្ពុជា" ដែលបានប្រគល់ជូនទៅភាគីកម្ពុជា នៅខែ ធ្នូ ឆ្នាំ ២០០០) ហេតុនេះយើងបានចែងនូវក្រមនេះដូចនៅក្នុងកថាខណ្ឌទី ២ នៃមាត្រានេះវិញ ។

Code of Civil Procedure (Japan)
**Article 325** (Remand after quashing, etc.) (excerpt)
1. In cases where grounds prescribed in Article 312, paragraphs 1 or 2 exist, the court of last resort shall quash the original judgment, and shall, except for the cases referred to in the following article, remand the case to the original court or transfer it to another court of the same level. The same shall apply to cases where a contravention of laws or ordinances exists which has been clearly influential in the judgment when a high court is the court of last resort.
2. Even if grounds prescribed in Artice 312, paragraphs 1 or 2o do not exist, when a contravention of laws or ordinances exists which has been clearly influential in the judgment, the Supreme Court as the court of last reosrt may quash the original judgment, and may, except in cases referred to in the following article, remand the case to the original court or transfer it to another court of the same level.
3. The court to which a case has been remanded or transferred in accordance with the preceding two paragraphs shall render a decision on the bases of new oral argument. In such cases, the factual and legal adjudications upon the grounds of which the court of last resort has quashed shall bind the court to which the case has been remanded or transferred.
4. Judges who participated in the original judgment shall not participate in the decision referred to in the preceding paragraph.

Code of Criminal Procedure (Japan)
**Article 413** (Remand, transfer, and rendering judgment)
In case the original judgment is to be quashed by the reason other than such reasons as stipulated in the preceding Article, the case shall be remanded to the original court or the first instance court, or transferred to the other court of the same level as these by a judgment: Provided that the court of last resort may, when deems that it may forthwith render a judgment according to the record of proceedings as well as evidence examined in the original court and the first instance court, render the judgment anew on the case.

Court Organization Law (Japan)
**Article 4** (Binding power of decision of superior court)
A conclusion in a decision of a superior court shall bind court below in respect of the case concerned.

**មាត្រា ៣០០.-** ការបដិសេធចោល ហើយវិនិច្ឆ័យដោយខ្លួនឯង

តុលាការនៃបណ្ដឹងសាទុក្ខត្រូវធ្វើការសម្រេចសេចក្ដីអំពីរឿងក្ដីផ្ទាល់ដោយខ្លួនឯង ចំពោះករណីដូចខាងក្រោមនេះ :

**ក-** តុលាការនៃបណ្តឹងសាទុក្ខបដិសេធចោលនូវសាលដីកាដើម ឬ សាលក្រមដើម ដោយយកមូលហេតុថា តុលាការនៃការជំនុំជម្រះដើមមានកំហុសក្នុងការអនុវត្តរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្ត ចំពោះអង្គហេតុ ដែលបានចូលជាស្ថាពរ ហើយតុលាការនៃបណ្តឹងសាទុក្ខអាចសម្រេចសេចក្តីអំពីរឿងក្តីនោះ ដោយផ្អែកលើអង្គហេតុនេះបាន ។

**ខ-** តុលាការនៃបណ្តឹងសាទុក្ខបដិសេធចោលនូវសាលដីកាដើម ឬ សាលក្រមដើម ដោយយកមូលហេតុថា រឿងក្តីនោះមិនស្ថិតនៅក្រោមសិទ្ធិជម្រះក្តីរបស់តុលាការ ។

(កំណត់)

មាត្រានេះតម្រូវនឹងមាត្រា 326 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

បញ្ញត្តិនេះចែងដើម្បីការពារកុំឱ្យមានការបញ្ជូនហួសសេចក្តីត្រូវការដែលពន្យារនូវពេលសម្រាប់កាត់ក្តី ។

ចំណុច **ក** គឺ "ករណីដែលមានកាលៈទេសៈល្អសម្រាប់តុលាការនៃបណ្តឹងសាទុក្ខក្នុងការសម្រេចសេចក្តី ដោយផ្អែកលើអង្គហេតុដែលតុលាការដើមបានទទួលស្គាល់" ។

ចំណុច **ខ** គឺជាបញ្ញត្តិចំពោះករណីដែលបដិសេធចោលសាលដីកាដើម ឬ សាលក្រមដើម ដោយយកមូលហេតុថាគ្មានសិទ្ធិជម្រះក្តីចំពោះរឿងក្តី ដូចជាករណីដែលមានអភ័យឯកសិទ្ធិពីសិទ្ធិជម្រះក្តីរបស់តុលាការបរទេស (sovereign immunity) និង ករណីដែលគ្មានសមត្ថកិច្ចជម្រះក្តីអន្តរជាតិ ជាដើម ។

Code of Civil Procedure (Japan)
**Article 326** (Quashing and fresh judgment)
In the following cases, the court of last resort shall render a decision on the case:
i) the judgment is to be quashed on the grounds that the Constitution or any other laws or ordinances have been misapplied to the facts found, and the case is ripe for decision on the basis of those facts;
ii) the judgment is to be quashed on the grounds that the case does not come under the jurisdiction of any court.

## ជំពូកទី ៤ បណ្តឹងជំទាស់

**មាត្រា ៣០១.-** របៀបប្តឹងជំទាស់

១- ដើម្បីប្តឹងជំទាស់ ភាគីត្រូវដាក់ពាក្យបណ្តឹងជំទាស់ទៅតុលាការដើម ។ នៅក្នុងករណីនេះ តុលាការដើម ត្រូវផ្ញើឱ្យបានឆាប់រហ័ស នូវពាក្យបណ្តឹងជំទាស់ និង សំណុំរឿង ទៅតុលាការនៃបណ្តឹងជំទាស់ ។(1)

២- ក្នុងករណីដែលពុំបានសរសេរច្បាស់លាស់អំពីមូលហេតុនៃការទាមទារឱ្យលុបចោល ឬ ផ្លាស់ប្តូរនូវដីកាសម្រេចដើម ក្នុងពាក្យបណ្តឹងជំទាស់ទេ ម្ចាស់បណ្តឹងជំទាស់គប្បីដាក់លិខិតជាលាយល័ក្ខណ៍អក្សរដែលសរសេរអំពីចំណុចនោះ ទៅតុលាការនៃបណ្តឹងជំទាស់ នៅក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ គិតចាប់តាំងពីថ្ងៃដែលបានដាក់ពាក្យបណ្តឹងជំទាស់នោះ ។(2)

(កំណត់)

សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ មាត្រា 416 ក្រមនីតិវិធីរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា 568 បទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 207 ។

(1) បណ្តឹងជំទាស់ (*kokoku*-appeal, Beschwerde) ត្រូវធ្វើឡើងដោយដាក់ពាក្យបណ្តឹងជំទាស់ទៅតុលាការជំនុំជម្រះរឿងក្តីដើម ។ ការធ្វើបណ្តឹងជំទាស់ដោយផ្ទាល់មាត់មិនត្រូវបានទទួលស្គាល់ឡើយ ។

(2) លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងជំទាស់ ត្រូវដាក់ទៅតុលាការនៃបណ្តឹងជំទាស់ (តុលាការជាន់ខ្ពស់ដែលមានសមត្ថកិច្ច) ។ អំឡុងពេល ២ (ពីរ) សប្តាហ៍ ដែលត្រូវដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងជំទាស់មានភាពសមរម្យ ដែលភាគីអាចធ្វើបាន ។

Old Code of Civil Procedure (Japan, 1890, last amendment: 1992)
**Article 416** (Method of filing *kokoku*-appeal, transmission to the original court)
1. *Kokoku*-appeal (excluding *kokoku*-appeal as mentioned in Article 413) shall be filed with the original court or the *kokoku*-appellate court in writing or orally.
2. In the event that the *kokoku*-appellate court receives *kokoku*-appeal and deems proper, it shall transmit the case to the original court.

Code of Civil Procedure Rules (Germany)
**Article 568** (Jurisdiction; further complaints)
1. The decision on the complaints shall be made by the court of next higher instance.
2. A further complaint against the decision of the court dealing with the complaint is not admissible unless it contains a new independent ground for a complaint.
3. Decisions of the district courts concerning court costs are not subject to further complaint.

Rules of Civil Procedure (Japan)
**Article 207** (Document stating grounds for reversal, etc., of original decision)
In cases where a *kokoku*-appeal other than a *kokoku*-appeal referred to in Article 330 (Further review of *kokoku*-appeal) of the Code is made, if the *kokoku*-appeal document does not include a concrete statement of the grounds for requesting a reversal or change of the original decision, the *kokoku*-appellant shall submit a document stating such grounds to the original court within 14 days after filing of the *kokoku*-appeal.

**មាត្រា ៣០២.-** បណ្តឹងឧបាស្រ័យចំពោះដីកាសម្រេចរបស់ចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ

១- ភាគីដែលមិនយល់ព្រមចំពោះដីកាសម្រេចរបស់ចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ អាចដាក់ពាក្យសុំប្តឹងតវ៉ាទៅតុលាការទទួលបណ្តឹងបាន តែក្នុងករណីដែលច្បាប់អនុញ្ញាតឱ្យប្តឹងជំទាស់ ប្រសិនបើដីកាសម្រេចនោះជាដីកាសម្រេចរបស់តុលាការទទួលបណ្តឹង ។ ប៉ុន្តែ ក្នុងករណីដែលតុលាការទទួលបណ្តឹងជាតុលាការកំពូល ឬ សាលាឧទ្ធរណ៍ ភាគីអាចដាក់ពាក្យសុំប្តឹងតវ៉ាបាន លុះត្រាតែច្បាប់អនុញ្ញាតឱ្យប្តឹងជំទាស់ ប្រសិនបើដីកាសម្រេចនោះជាដីកាសម្រេចរបស់សាលាដំបូង ។(1)(2)(3)

២- ចំពោះដីកាសម្រេចលើពាក្យសុំនៃកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើបណ្តឹងជំទាស់បាន ។(4)

(កំណត់)

មាត្រានេះតម្រូវនឹងមាត្រា 329 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

(1) ចំពោះដីកាសម្រេចរបស់ចៅក្រមទទួលបញ្ជា ឬ ចៅក្រមទទួលបន្ទុក (ឧទាហរណ៍ : ដីកាសម្រេចទៅលើការបដិសេធនូវការផ្ដល់ចម្លើយជាកសិណសាក្សី (មាត្រា ១៣៥) នេះគឺខុសគ្នានឹងដីកាសម្រេចរបស់តុលាការ ដោយនៅទីនេះយើងតម្រូវឱ្យមានការគ្រប់គ្រងពិនិត្យដោយតុលាការដែលទទួលបណ្ដឹង ហេតុដូច្នេះ បើភាគីមានសេចក្ដីតវ៉ា តុលាការដែលទទួលបណ្ដឹងត្រូវសម្រេចសេចក្ដី ដោយដីកាសម្រេច ។

(2) ចំពោះដីកាសម្រេចរបស់ចៅក្រមទទួលបញ្ជា ឬ ចៅក្រមទទួលបន្ទុកដែលត្រូវបានជ្រើសតាំងចំពោះរឿងក្ដីដែលសាលាឧទ្ធរណ៍ ឬ តុលាការកំពូលកំពុងចាត់ការវិញ ក៏ដូចគ្នានឹងករណីដែលសាលាដំបូងជាតុលាការទទួលបណ្ដឹងដែរ ភាគីអាចដាក់ពាក្យសុំប្ដឹងតវ៉ាទៅសាលាឧទ្ធរណ៍ ឬ តុលាការកំពូលដែលជាតុលាការដែលទទួលបណ្ដឹងបាន ។

(3) ចំពោះការស្នើសុំប្ដឹងតវ៉ាដែលមានចែងក្នុងមាត្រានេះ ប្រសិនបើដីកាសម្រេចនោះត្រូវបានធ្វើឡើងដោយតុលាការទទួលបណ្ដឹង នោះភាគីត្រូវធ្វើបណ្ដឹងជំទាស់ ហេតុដូច្នេះ ភាគីចាំបាច់ត្រូវធ្វើបណ្ដឹងតវ៉ា នៅក្នុងអំឡុងពេលដែលអាចប្ដឹងជំទាស់បាន ដែលកំណត់នៅក្នុងមាត្រា ៣០៣ (អំឡុងពេលសម្រាប់ប្ដឹងជំទាស់) ។

(4) ប្រសិនបើតុលាការទទួលបណ្ដឹងជាសាលាឧទ្ធរណ៍ ចំពោះតែករណីនៃកថាខណ្ឌទី ២ នៃមាត្រា ៣០៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្ដីពីបណ្ដឹងឧទ្ធរណ៍ ឬ បណ្ដឹងសាទុក្ខ) អាចប្ដឹងជំទាស់ចំពោះដីកាសម្រេចលើពាក្យសុំ នៃកថាខណ្ឌទី ១ បាន តែប្រសិនបើតុលាការទទួលបណ្ដឹងជាតុលាការកំពូលវិញ មិនអាចប្ដឹងជំទាស់បានឡើយ ។

<u>Code of Civil Procedure (Japan)</u>
**Article 329** (Objection against decision rendered by commissioned judge, etc.)
1. A party having an objection against a decision rendered by a commissioned judge or an assigned judge may raise an objection to the court before which the suit is pending. However, this shall be limited to cases where it would be possible to make a *kokoku*-appeal against the decision if such decision was a decision of the court before which the suit is pending.
2. A *kokoku*-appeal may be against the decision on the objection referred to in the preceding paragraph.
3. In the application of paragraph 1 in cases where the suit is pending before the Supreme Court or a high court, "the court before which the suit is pending" in the proviso of the paragraph shall be "the district court".

**មាត្រា ៣០៣.-** អំឡុងពេលសម្រាប់ប្ដឹងជំទាស់

១- បណ្ដឹងជំទាស់ត្រូវធ្វើក្នុងអំឡុងពេល ១ (មួយ) សប្ដាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលដំណឹងអំពីដីកាសម្រេច ។

២- អំឡុងពេលនៃកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យារបានឡើយ ។(1)

(កំណត់)

មាត្រានេះតម្រូវនឹងក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 332 ។

(1) ករណីនេះត្រូវនឹងវាក្យខណ្ឌទី ១ កថាខណ្ឌទី ១ នៃមាត្រា ២៤៤ (ការពន្យារអំឡុងពេល) ។

Code of Civil Procedure (Japan)
**Article 332** (Period for immediate *kokoku*-appeal)
A immediate *kokoku*-appeal must be filed within the peremptory term of one week from the day of notice of a deicison.

**មាត្រា ៣០៤.-** ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងសាទុក្ខ

១- បញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ និង នីតិវិធីនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងជំទាស់លើដីកាសម្រេចរបស់សាលាដំបូង និង នីតិវិធីនៃតុលាការនៃបណ្តឹងជំទាស់នោះ លើកលែងតែករណីដែលបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈបណ្តឹង ឬ នីតិវិធីនោះ ។(1)(2)

២- បញ្ញត្តិស្តីពីបណ្តឹងសាទុក្ខ និង នីតិវិធីទាក់ទងនឹងការជំនុំជម្រះបណ្តឹងសាទុក្ខនោះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងជំទាស់លើដីកាសម្រេចដែលសាលាឧទ្ធរណ៍បានចេញក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី ១ និង នីតិវិធីទាក់ទងនឹងបណ្តឹងជំទាស់នោះ លើកលែងតែករណីដែលបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈនៃបណ្តឹង ឬ នីតិវិធីនោះ ។(3)

(កំណត់)

សូមមើលក្រមនីតិវិធីជប៉ុន មាត្រា 331 ។

(1) បណ្តឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាដំបូង គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលជាតុលាការនៃការជំនុំជម្រះលើកទី ២ ដូចគ្នានឹងបណ្តឹងឧទ្ធរណ៍ ដូច្នេះត្រូវអនុវត្តដូចគ្នាទៅតាមបញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ និង នីតិវិធីនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ។ ប៉ុន្តែ គេទទួលស្គាល់ការលើកលែងចំពោះករណីដែលមានបញ្ញត្តិផ្សេងទៀត ឬ ករណីដែលមានលក្ខណៈផ្ទុយនឹងបណ្តឹងជំទាស់ ។ ករណីពិសេសគឺដូចជាអំឡុងពេលប្តឹងជំទាស់ (មាត្រា ៣០៣ (អំឡុងពេលសម្រាប់ប្តឹងជំទាស់)) អំឡុងពេលដែលត្រូវដាក់លិខិតបញ្ជាក់មូលហេតុប្តឹងជំទាស់ (មាត្រា ៣០១ (របៀបប្តឹងជំទាស់) កថាខណ្ឌទី ២) ការទាញហេតុផលដោយផ្ទាល់មាត់តាមឆន្ទៈស្ម័គ្រចិត្ត (មាត្រា ៣០៦ (ការទាញហេតុផលដោយផ្ទាល់មាត់តាមឆន្ទៈស្ម័គ្រចិត្ត និង ការសួរជំនួសការទាញហេតុផលដោយផ្ទាល់មាត់) កថាខណ្ឌទី ១) ការអនុញ្ញាតឱ្យសួរ (មាត្រាដដែល កថាខណ្ឌទី ២) ការសម្រេចសេចក្តីដោយដីកាសម្រេច (សូមមើលកថាខណ្ឌទី ៣ នៃមាត្រា ២៩៩ (ប្រភេទនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់) ជាដើម ។

(2) បញ្ញត្តិដែលអនុវត្តដូចគ្នាជាមួយនឹងបញ្ញត្តិនៃបណ្តឹងឧទ្ធរណ៍មាន ការលះបង់សិទ្ធិប្តឹងឧទ្ធរណ៍ (មាត្រា ២៦៣ (ការលះបង់សិទ្ធិប្តឹងឧទ្ធរណ៍)) ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង (មាត្រា ២៦៥ (របៀបប្តឹងឧទ្ធរណ៍) កថាខណ្ឌទី ២) សិទ្ធិពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍ (មាត្រា ២៦៦ (សិទ្ធិពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍របស់តុលាការនៃបណ្តឹងឧទ្ធរណ៍)) ការលើកចោលបណ្តឹងឧទ្ធរណ៍ (មាត្រា ២៦៨ (ការលើកចោលបណ្តឹងឧទ្ធរណ៍ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់)) បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ (មាត្រា ២៧០ (បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ))

ការអនុវត្តដូចគ្នាតាមបទប្បញ្ញត្តិរបស់នីតិវិធីនៃបណ្តឹង នៅតុលាការនៃការជំនុំជម្រះលើកទី ១ (មាត្រា ២៧៣ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីនីតិវិធីនៃការជំនុំជម្រះលើកទី ១)) ការច្រានចោលបណ្តឹងឧទ្ធរណ៍ (មាត្រា ២៧៧ (ការច្រានចោលបណ្តឹងឧទ្ធរណ៍)) ការលុបចោលសាលក្រមតុលាការដើម (មាត្រា ២៧៩ (ការលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១)) ការបញ្ជូនត្រឡប់រឿងក្តីទៅវិញ (មាត្រា ២៨០ (ការបញ្ជូនរឿងក្តីត្រឡប់ទៅវិញ)) ជាដើម ។

(3) ចំពោះដីកាសម្រេចរបស់សាលាឧទ្ធរណ៍ដែលជាតុលាការនៃបណ្តឹងជំទាស់ ភាគីមិនអាចប្តឹងឧបាស្រ័យបានទៀតទេ (កថាខណ្ឌទី ៣ នៃមាត្រា ២៥៩ (ប្រភេទនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់)) តែបើសាលាឧទ្ធរណ៍នោះជាតុលាការនៃការជំនុំជម្រះលើកទី ១ វិញ ភាគីអាចប្តឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាឧទ្ធរណ៍នោះបាន ។ ប៉ុន្តែ ដោយបណ្តឹងជំទាស់នេះ មានភាពដូចគ្នាទៅនឹងបណ្តឹងសាទុក្ខលើសាលដីកាចុងក្រោយរបស់សាលាឧទ្ធរណ៍ដែលជាតុលាការនៃការជំនុំជម្រះលើកទី ១ នោះ បើពុំមានមានភាពខុសនឹងលក្ខណៈនៃបណ្តឹងទេ បញ្ញត្តិស្តីពីបណ្តឹងសាទុក្ខ និង នីតិវិធីនៃបណ្តឹងសាទុក្ខ (គន្ថីទី ៣ ជំពូកទី ៣) ត្រូវយកមកអនុវត្តដូចគ្នា ។

ហេតុដូច្នេះ បណ្តឹងជំទាស់នេះត្រូវធ្វើទៅតុលាការកំពូល (សូមមើលកថាខណ្ឌទី១ មាត្រា ២៨៣ (តុលាការនៃបណ្តឹងសាទុក្ខ)) ហើយភាគីអាចប្តឹងជំទាស់បាន បើយកមូលហេតុផ្ទុយនឹងច្បាប់ ឬ បទដ្ឋានគតិយុត្តដែលមានឥទ្ធិពលទៅលើដីកាសម្រេចដើម (សូមមើលមាត្រា ២៨៤ (មូលហេតុទូទៅនៃបណ្តឹងសាទុក្ខ)) ។ ហើយដើម្បីដាក់ពាក្យបណ្តឹងជំទាស់នេះ ត្រូវដាក់ពាក្យបណ្តឹងនោះទៅតុលាការដើម (មាត្រា ២៨៧ (របៀបប្តឹងសាទុក្ខ)) ។ ក្រៅពីនេះ ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ (មាត្រា ២៨៦) ការបញ្ជូនលិខិតទទួលពាក្យបណ្តឹងសាទុក្ខ ជាអាទិ៍ (មាត្រា ២៨៨) ការសរសេរមូលហេតុនៃបណ្តឹងសាទុក្ខ (មាត្រា ២៨៩ កថាខណ្ឌទី ២ និង ទី ៣) ការលើកចោលនូវបណ្តឹងសាទុក្ខដោយតុលាការនៃបណ្តឹងសាទុក្ខ (មាត្រា ២៩០ (ការលើកចោលបណ្តឹងសាទុក្ខ)) ការបង្គាប់ឱ្យកែតម្រូវដោយតុលាការនៃបណ្តឹងសាទុក្ខ (មាត្រា ២៩១ (ដីកាសម្រេចបង្គាប់ឱ្យកែតម្រូវ)) ជាដើម ។

Code of Civil Procedure (Japan)
**Article 331** (*Mutatis mutandis* application of provisions relating to *koso*-appeal or *jokoku*-appeal)
The provisions of Chapter 1 shall apply *mutatis mutandis* to a *kokoku*-appeal and the litigation proceedings in the *kokoku*-appeal in stance insofar as is not inconsistent with the nature thereof. However, the provisions relating to a *jokoku*-appeal against a final judgment in the second or first instance and the litigation proceedings in such *jokoku*-appeal instance in the preceding chapter shall apply *mutatis mutandis* to the *kokoku*-appeal referred to in the preceding article and the litigation proceedings in such *kokoku*-appeal instance,

**មាត្រា ៣០៥.-** ការផ្អាកអានុភាពនៃដីកាសម្រេចដើម

១- បណ្តឹងជំទាស់ត្រូវផ្អាកអានុភាពនៃដីកាសម្រេចដើម ។

២- តុលាការនៃបណ្តឹងជំទាស់ ឬ តុលាការដែលបានចេញដីកាសម្រេចដើម អាចបង្គាប់ឱ្យផ្អាកជាបណ្តោះអាសន្ននូវការអនុវត្តដោយបង្ខំ ដោយផ្អែកលើដីកាសម្រេចដើម ឬ បង្គាប់ឱ្យចាត់ចែងជាចាំបាច់ផ្សេងទៀតបាន រហូតដល់ពេល

មានដីកាសម្រេចអំពីបណ្តឹងជំទាស់ ។

(កំណត់)

សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 334 ។

(1) ដីកាសម្រេច ជាគោលការណ៍ ក្រោយពីបានប្រកាសហើយ ទោះជាមិនចូលជាស្ថាពរក៏ដោយ ក៏មានអានុភាពអនុវត្តដែលចាំបាច់ដើម្បីបំពេញទៅតាមអត្ថន័យរបស់សេចក្តីសម្រេចដើម (មាត្រា ២១៣ (ការជូនដំណឹងអំពីដីកាសម្រេច) កថាខណ្ឌទី ១) ដែរ។ ជាទូទៅ ដីកាសម្រេចដែលអាចប្តឹងជំទាស់បាននោះ មានឥទ្ធិពលយ៉ាងខ្លាំងទៅលើផលប្រយោជន៍របស់ភាគី ហើយចាំបាច់ចូលជាស្ថាពរឱ្យបានឆាប់ ដូច្នេះគ្រាន់តែមានបណ្តឹងជំទាស់ តុលាការអាចទទួលស្គាល់ក្នុងការផ្អាកអានុភាពនៃដីកាសម្រេចដើមបាន (ឧទាហរណ៍ : បើតុលាការចេញដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ តែភាគីបានប្តឹងជំទាស់វិញនោះ ឯកសារដែលត្រូវបានតុលាការបង្គាប់នោះ មិនបាច់ផ្តល់ក៏បានដែរ) ។ ប៉ុន្តែ ក្នុងករណីដែលអានុភាពរបស់ដីកាសម្រេចត្រូវកើតឡើង មិនមែនដោយការជូនដំណឹង តែដោយចូលជាស្ថាពរហើយ ទោះជាយើងទទួលស្គាល់នូវការបញ្ឈប់អានុភាពនៅពេលដាក់ពាក្យប្តឹងជំទាស់ ក៏គ្មានន័យដែរ (ឧទាហរណ៍ : ដីកាសម្រេចការផ្ទេរបណ្តឹងទៅតុលាការផ្សេង តាមបញ្ញត្តិនៃមាត្រា ១៨ (ការចាត់ចែងបណ្តឹងខុសសមត្ថកិច្ចសាលាដម្រះក្តី) ទៅ) ។

(2) ក្នុងករណីដែលមានពាក្យសុំប្តឹងតវ៉ាចំពោះដីកាសម្រេចរបស់ចៅក្រមទទួលបញ្ជា ឬ ចៅក្រមទទួលបន្ទុក តាមបញ្ញត្តិនៃមាត្រា ៣០២ (បណ្តឹងឧបាស្រ័យចំពោះដីកាសម្រេចរបស់ចៅក្រមទទួលបញ្ជា ឬ ចៅក្រមទទួលការប្រគល់សិទ្ធិ) នោះនឹងមានអានុភាពផ្អាកអានុភាពនៃដីកាសម្រេចដើម ដោយសារពាក្យសុំតវ៉ានោះ ដោយអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីបណ្តឹងជំទាស់ ។

(3) នៅក្នុងករណីដែលការអនុវត្តដោយបង្ខំត្រូវបានចាប់ផ្តើម ដោយផ្អែកលើដីកាសម្រេចដើម ទោះបីជាដាក់ពាក្យបណ្តឹងជំទាស់ក៏ដោយ ក៏មិនអាចបញ្ឈប់ការអនុវត្តដោយបង្ខំនោះបានដែរ ហេតុដូច្នេះ ចាំបាច់ត្រូវធ្វើការសម្រេចសេចក្តីដើម្បីផ្អាកជាបណ្តោះអាសន្ននូវការអនុវត្តដោយបង្ខំដែរ ។

Code of Civil Procedure (Japan)
**Article 334** (Stay of execution of original decision)
1. A *kokoku*-appeal shall have the effect of staying the execution only if it is an immediate *kokoku*-appeal.
2. The *kokoku*-appellate court, or the court or the judge who rendered the original decision may stay execution of the decision or order any other necessary disposition until a ruling is jmade on the *kokoku*-appeal.

**មាត្រា ៣០៦.-** ការទាញហេតុផលដោយផ្ទាល់មាត់តាមឆន្ទៈស្ម័គ្រចិត្ត និង ការសួរជំនួសការទាញហេតុផលដោយផ្ទាល់មាត់

១- ការសម្រេចសេចក្តីលើបណ្តឹងជំទាស់ អាចធ្វើបាន ដោយមិនបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ ។

(1)

២- ក្នុងករណីដែលតុលាការនៃបណ្ដឹងជំទាស់មិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់អំពីបណ្ដឹងជំទាស់ទេ តុលាការអាចធ្វើការសួរម្ចាស់បណ្ដឹងជំទាស់ ឬ អ្នកផ្សេងទៀតដែលមានទំនាក់ទំនងនឹងផលប្រយោជន៍នៃបណ្ដឹងបាន ។(2)

(កំណត់)

សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 335 និង ក្រមនីតិវិធីអាល្លឺម៉ង់ មាត្រា 573 ។

(1) បណ្ដឹងជំទាស់ គឺជាបណ្ដឹងដែលត្រូវបញ្ចប់ដោយដីកាសម្រេច ហេតុនេះតុលាការអាចសម្រេចថាតើធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬអត់ ដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន (សូមមើលមាត្រា ១១៤ (ភាពចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់) វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១) ។

(2) ការសួរ គឺជាវិធីមួយសម្រាប់សួរហេតុផល ហើយគឺជាការផ្ដល់ឱកាសឱ្យបញ្ចេញយោបល់តាមសំដី ឬ តាមលិខិត (សូមមើលមាត្រា ១១៤ (ភាពចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់) កថាខណ្ឌទី ២) ។ ក្នុងករណីដែលតុលាការនៃបណ្ដឹងជំទាស់ ធ្វើការពិនិត្យវិនិច្ឆ័យដោយមិនធ្វើការឆ្លើយទាញហេតុផលដោយផ្ទាល់មាត់ទេ បើតុលាការយល់ឃើញថា មានភាពចាំបាច់ តុលាការអាចធ្វើការសួរអ្នកប្ដឹងជំទាស់ ឬ អ្នកផ្សេងទៀតដែលមានទំនាក់ទំនងនឹងផលប្រយោជន៍នៃបណ្ដឹងបាន ។ ប៉ុន្តែ តុលាការមិនអាចធ្វើការសួរតតិយជនដែលគ្មានការពាក់ព័ន្ធនឹងផលប្រយោជន៍នៃបណ្ដឹងឡើយ ។

Code of Civil Procedure (Japan)
**Article 335** (Interrogatory in lieu of oral argument)
The *kokoku*-appellate court may, in cases where no oral argument is to be conducted regarding to the *kokoku*-appeal, interrogate the *kokoku*-appellant or other interested person.

Code of Civil Procedure Rules (Germany)
**Article 573** (Procedure; exceptions from compulsory employment of lawyers)
1. The decision on the complaint may be made without an oral hearing.
2. If te court orders that a written explanation be given, it may be delivered by a lawyer who is admitted before the court ny which, or ny the presiding judge or which, the contested decision was issued. In cases in which the complaint may be placed on record in the registry, also the explanation may be placed on record in the registry

# គន្ថីទី ៤ ការជំនុំជម្រះសាជាថ្មី

## ជំពូកគោល ការជំនុំជម្រះសាជាថ្មី

**មាត្រា ៣០៧.-** មូលហេតុនៃការជំនុំជម្រះសាជាថ្មី (មួយ)

១- ភាគីអាចស្នើសុំប្តឹងឧបាស្រ័យ តាមបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបាន ចំពោះសាលក្រមចុងក្រោយ ឬ សាលដីកាចុងក្រោយដែលបានចូលជាស្ថាពរហើយ ក្នុងករណីដែលមានមូលហេតុណាមួយដូចរៀបរាប់ខាងក្រោមនេះ : (1)(2)(3)

**ក-** បើពុំបានចាត់តាំងតុលាការដែលបានចេញសាលក្រម ឬ សាលដីកា ទៅតាមច្បាប់កំណត់ ។

**ខ-** បើចៅក្រមដែលពុំអាចចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកាតាមច្បាប់ បានចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកានោះ ។

**គ-** បើខ្វះសិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ខ្វះការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្តឹង ឬ ខ្វះសិទ្ធិតំណាងដោយអាណត្តិ ។

**ឃ-** បើចៅក្រមដែលបានចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកា បានប្រព្រឹត្តអំពើល្មើសដែលពាក់ព័ន្ធនឹងមុខងាររបស់ខ្លួនចំពោះរឿងក្តី ។

**ង-** បើភាគីបានសារភាព ឬ ត្រូវបានរារាំងក្នុងការដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនដែលមានឥទ្ធិពលដល់សាលក្រម ឬ សាលដីកា ដោយសារបទល្មើសរបស់អ្នកដទៃ ។

**ច-** បើឯកសារ ឬ វត្ថុឯទៀតដែលបានក្លាយជាភស្តុតាងសម្រាប់សាលក្រម ឬ សាលដីកា ត្រូវបានក្លែង ឬ កែប្រែដោយបន្លំ ។(4)

**ឆ-** បើសេចក្តីថ្លែងការណ៍មិនពិតរបស់សាក្សី អ្នកធ្វើកោសលវិច័យ អ្នកបកប្រែ ភាគីដែលបានធ្វើសម្បថ ឬ របស់អ្នកតំណាងដែលច្បាប់បានកំណត់ដែលបានធ្វើសម្បថ បានក្លាយជាភស្តុតាងសម្រាប់សាលក្រម ឬ សាលដីកា ។

**ជ-** បើសាលក្រម ឬ សាលដីកា ឬ សេចក្តីសម្រេចឯទៀត ផ្នែករដ្ឋប្បវេណី ឬ ផ្នែកព្រហ្មទណ្ឌ ឬ ការចាត់ចែងផ្នែករដ្ឋបាល ដែលជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកា ត្រូវបានផ្លាស់ប្តូរ ដោយសារសេចក្តីសម្រេច ឬ ការចាត់ចែងផ្នែករដ្ឋបាលនៅពេលក្រោយ ។

**ឈ-** បើមានការភ្លេចបញ្ចូលសេចក្តីវិនិច្ឆ័យលើចំណុចសំខាន់ៗ ដែលអាចមានឥទ្ធិពលទៅលើសាលក្រម ឬ សាលដីកា ។(5)

**ញ-** បើសាលក្រម ឬ សាលដីកា ដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មានការប៉ះពាល់ដល់

សាលក្រម ឬ សាលដីកាមុនដែលបានចូលជាស្ថាពរហើយ ។

ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីបានធ្វើការអះអាងអំពីមូលហេតុនោះ នៅពេលធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ឬ ភាគីបានដឹងអំពីមូលហេតុនេះហើយ តែមិនធ្វើការអះអាង ។

២- ចំពោះមូលហេតុដែលបានកំណត់ពីចំណុច **ឃ** រហូតដល់ចំណុច **ឆ** នៃកថាខណ្ឌទី ១ ខាងលើនេះ ភាគីអាចដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបាន លុះត្រាតែមានករណីដូចបានរៀបរាប់ខាងក្រោមនេះ : (6)(7)

**ក**- ករណីដែលសាលក្រម ឬ សាលដីកាដែលផ្តន្ទាទោស ឬ សេចក្តីសម្រេចដាក់ប្រាក់ពិន័យបានចូលជាស្ថាពរចំពោះអំពើដែលត្រូវដាក់ទណ្ឌកម្ម ។

**ខ**- ករណីដែលមិនអាចទទួលបាននូវសាលក្រម ឬ សាលដីកាដែលផ្តន្ទាទោសជាស្ថាពរ ឬ សេចក្តីសម្រេច ដែលដាក់ប្រាក់ពិន័យជាស្ថាពរ ដោយសារមូលហេតុផ្សេងពីមូលហេតុថា គ្មានភស្តុតាង ។

៣- បើសាលដីកាសម្រេចអង្គសេចក្តីអំពីរឿងក្តី ត្រូវបានសម្រេចនៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍រួចហើយ ភាគីមិនអាចដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចំពោះសាលក្រមរបស់តុលាការនៃការជំនុំជម្រះលើកទី ១ បានឡើយ ។ (8)

(កំណត់)

សូមមើលមាត្រា 338 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន និង មាត្រា 420 នៃក្រមនីតិវិធីរដ្ឋប្បវេណីចាស់នៃប្រទេសជប៉ុន ។

(1) បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺជាមធ្យោបាយឧបាស្រ័យមិនប្រក្រតីមួយ ដែលភាគីប្តឹងទាមទារឱ្យតុលាការដែលចេញសាលក្រម ឬ សាលដីកាចុងក្រោយដែលបានចូលជាស្ថាពរ លុបចោលសាលក្រម ឬ សាលដីកានោះ និងឱ្យជំនុំជម្រះអំពីរឿងក្តីសាជាថ្មី ដោយយកមូលហេតុថា នីតិវិធីនៃបណ្តឹងនោះមានវិការៈធ្ងន់ធ្ងរ ឬ ឯកសារដែលជាមូលដ្ឋាននៃសេចក្តីវិនិច្ឆ័យនោះ មានការខ្វះខាតមិនប្រក្រតី ។ម្យ៉ាងទៀត ភាគីអាចដាក់ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីបាន ចំពោះដីកាសម្រេចដែលបានចូលជាស្ថាពរហើយ (សូមមើលមាត្រា ៣១៧ (ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីចំពោះដីកាសម្រេច)) ។

ការជំនុំជម្រះសាជាថ្មីនេះ ត្រូវបានអនុញ្ញាត ដោយកំណត់តែទៅលើករណីដែលមានការអះអាងនូវមូលហេតុ (មូលហេតុនៃការជំនុំជម្រះសាជាថ្មី) ដូចបានលើកឡើងនៅក្នុងកថាខណ្ឌទី ១ ។ បើបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីមានភាពផ្ទុយនឹងច្បាប់ បណ្តឹងនោះនឹងត្រូវលើកចោល ហើយប្រសិនបើតុលាការពុំអាចទទួលស្គាល់នូវមូលហេតុនៃការជំនុំជម្រះសាជាថ្មីដែលត្រូវបានអះអាងនោះទេ ការទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះ នឹងត្រូវតុលាការច្រានចោល ។ បើការអះអាងនូវមូលហេតុនៃការជំនុំជម្រះសាជាថ្មី ត្រូវបានទទួលស្គាល់ដោយតុលាការ ការទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះ មានមូលហេតុត្រឹមត្រូវ ហើយការពិនិត្យសាជាថ្មីទៅលើរឿងក្តី នឹងត្រូវចាប់ផ្តើម (សូមមើល

មាត្រា ៣១៤ (ការលើកចោលបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និង ការច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី) និង មាត្រា ៣១៥ (ដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី)) ។

(2) ទោះជាមានការពិតដែលត្រូវនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មីក៏ដោយ នៅក្នុងករណីដែលភាគីបានអះអាងមូលហេតុនោះ មុនពេលសាលក្រមនោះចូលជាស្ថាពរ ដោយធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ តែត្រូវតុលាការមិនទទួលស្គាល់ ឬ ក្នុងករណីដែលភាគីបានដឹងអំពីមូលហេតុនេះ តែមិនបានអះអាងនៅតុលាការជាន់ខ្ពស់ ច្បាប់មិនអនុញ្ញាតឱ្យភាគីអះអាងអំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មីឡើយ (វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១) ។ ពោលគឺមូលហេតុនៃការជំនុំជម្រះសាជាថ្មីនេះ ជាបឋម ត្រូវធ្វើការអះអាងនៅក្នុងបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ហើយក្នុងករណីដែលពុំអាចធ្វើការអះអាងបានតែប៉ុណ្ណោះ ទើបភាគីអាចអះអាងអំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មីចំពោះសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ និង ទាមទារឱ្យលុបចោលសាលក្រម ឬ សាលដីកានោះ (ភាពបង្គ្រប់កិច្ចនៃការជំនុំជម្រះសាជាថ្មី) ។

បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដែលចែងនៅលើវាក្យខណ្ឌចុងក្រោយ (ចាប់ពីឃ្លា "ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវ......។") នៃកថាខណ្ឌទី ១ នេះ ក្រៅអំពីបណ្តឹងឧទ្ធរណ៍ និង បណ្តឹងសាទុក្ខ ក៏រាប់បញ្ចូលទាំងបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ (សុំមើលកំណត់នៃមាត្រា ២៧០ (បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ)) និង បណ្តឹងសាទុក្ខបន្ទាប់បន្សំផងដែរ (មាត្រា ២៨៦ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍)) ។

(3) ចំណុច **ក** ដល់ចំណុច **គ** ស្របគ្នានឹងមូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ (មាត្រា ២៨៥ (មូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ) កថាខណ្ឌទី ១ ចំណុច **ក ខ** និង **ឃ**) ។ ចំណុច **ឃ** ដល់ចំណុច **ជ** គឺជាករណីដែលមានភាពមិនប្រក្រតីចំពោះឯកសារដែលជាមូលដ្ឋានសម្រាប់សាលក្រម ឬ សាលដីកា ហើយចំណែកឯចំណុច **ឈ** និង ចំណុច **ញ** គឺជាករណីដែលមានការខ្វះខាតក្នុងការវិនិច្ឆ័យផ្ទាល់តែម្តង ។

(4) "ដែលក្លាយជាភស្តុតាងសម្រាប់សាលក្រម ឬ សាលដីកា" នោះគឺជាករណីដែលឯកសារ ឬ វត្ថុឯទៀតនោះត្រូវបានយកមកជាមូលដ្ឋានក្នុងការទទួលស្គាល់នូវអង្គហេតុ ហើយការទទួលស្គាល់នូវអង្គហេតុនោះប៉ះពាល់ដល់សេចក្តីសម្រេចបញ្ចប់នៃសាលក្រម ឬ សាលដីកា ។

(5) ការភ្លេចបញ្ចូលសេចក្តីវិនិច្ឆ័យ គឺជាករណីដែលតុលាការពុំបានបង្ហាញសេចក្តីវិនិច្ឆ័យរបស់ខ្លួន ក្នុងសំអាងហេតុនៃសាលក្រម ឬ សាលដីកា ចំពោះចំណុចដែលជាមធ្យោបាយតទល់ ឬ ការពារខ្លួនដែលភាគីបានដាក់ក្នុងនីតិវិធីបណ្តឹងដោយស្របច្បាប់ ហើយប៉ះពាល់ដល់សេចក្តីសន្និដ្ឋាននៃសាលក្រម ឬ សាលដីកា ។

(6) មូលហេតុនៃចំណុច **ឃ** ដល់ចំណុច **ឆ** គឺចង្អុលទៅលើអត្ថិភាពនៃអំពើដែលគួរតែដាក់ទណ្ឌកម្ម ហេតុដូចេះដើម្បីបង្ការការពារកុំឱ្យអ្នកចាញ់ក្តីនោះ ចេះតែដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី តាមតែអំពើចិត្ត ដែលបង្កឱ្យអ្នកឈ្នះក្តីចូលនៅក្នុងការជំនុំជម្រះស្មុគ្រស្មាញអំពីអត្ថិភាពនៃអំពើនោះ ច្បាប់ទាមទារតម្រូវឱ្យមានភស្តុតាងច្បាស់លាស់ អំពីអំពើដែលគួរតែដាក់ទណ្ឌកម្មនោះ (វិធានការកុំឱ្យមានការបំពានសិទ្ធិប្តឹង) ។

ប៉ុន្តែ បញ្ហាថាតើមូលហេតុនៃចំណុចដែលបានលើកឡើងដោយចាត់ទុកថាជាអំពើដែលគួរដាក់ទណ្ឌកម្មនេះ អាចនឹងក្លាយជាមូលហេតុត្រឹមត្រូវនៃការជំនុំជម្រះសាជាថ្មី ឬយ៉ាងណានោះ ស្ថិតទៅតាមប្រភេទនៃបទល្មើសរបស់ប្រព័ន្ធច្បាប់ព្រហ្មទណ្ឌនៃប្រទេសកម្ពុជា ។

(7) "មូលហេតុផ្សេងទៀតក្រៅពីមូលហេតុថា គ្មានភស្តុតាង" មានដូចជា មរណភាពនៃជនសង្ស័យ ការផុតកំណត់អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា ការទទួលការលើកលែងទោស ក្រៅពីនេះមានការពន្យារចោទប្រកាន់ដោយយកមូលហេតុក្រៅអំពីមូលហេតុនៃភស្តុតាងមិនគ្រប់គ្រាន់ ជាដើម ។ តើមានករណីណាដែលត្រូវនឹងល័ក្ខខ័ណ្ឌនៃ "មូលហេតុផ្សេងទៀតក្រៅពីមូលហេតុថា គ្មានភស្តុតាង" នេះ គឺវាអាចនឹងប្រែប្រួល ទៅតាមការទទួលយក ឬ មិនទទួលយកនូវគោលការណ៍នៃការចោទប្រកាន់ដោយឆន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញា (principle of discretionary prosecution, opportunité des poursites, strafrechtliches Opportunitätsprinzip) នៅក្នុងប្រព័ន្ធច្បាប់នីតិវិធីព្រហ្មទណ្ឌនៃប្រទេសកម្ពុជា (មានន័យថា អនុញ្ញាតឆន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញាក្នុងការចោទប្រកាន់ និង ទទួលស្គាល់ការព្យួរការចោទប្រកាន់ឬអត់) ។

(8) កាលបើមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី ក្នុងសាលក្រមនៃការជំនុំជម្រះលើកទី ១ ហើយតុលាការនៃបណ្តឹងឧទ្ធរណ៍ចេញសាលដីកាច្រានចោលបណ្តឹងឧទ្ធរណ៍ មូលហេតុនៃការជំនុំជម្រះសាជាថ្មី ក៏ជាប់គ្នានឹងសាលដីកាច្រានចោលបណ្តឹងឧទ្ធរណ៍នោះដែរ ហេតុដូច្នេះ ក្នុងករណីនេះ ភាគីគួរតែប្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីចំពោះសាលដីកានៃបណ្តឹងឧទ្ធរណ៍ ហើយបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចំពោះសាលក្រមនៃការជំនុំជម្រះលើកទី ១ ពុំចាំបាច់ទទួលស្គាល់ទេ ។

<u>Code of Civil Procedure (Japan)</u>
**Article 338** (Grounds for retrial)
1. In cases where any of the following grounds exist, an appeal against a final judgment which has become final and binding may be made by means of a petition for retrial. However, this shall not apply to cases where the party asserted the grounds in a prior *koso*-appeal or *jokoku*-appeal, ore has not asserted them although such party had knowledge of thereof.
 i. the court rendering judgment was not composed according to law
 ii. a judge, who was prohibited by law from doing so, participated in the judgment
 iii. there existed some defect in the authority of the legal representative or advocate, or in the necessary authorization granted to such representative for the act of litigation
 iv. a judge who participated in the judgment committed a crime in connection with the judge's official duties in relation to the case
 v. the party was led to make a confession or was prevented from advancing offensive or defensive measures which would affect the judgment, by virtue of a criminally punishable act of another person
 vi. a document or any other object used as evidence for the judgment has been forged or fraudulently changed
 vii. evidence for the judgment was based on the false statement of a witness, an expert witness, an interpreter, or a sworn party or legal representative
 viii. a civil or criminal judgment or any other decision or administrative disposition on which the judgment was based has been changed by a subsequent decision or administrative disposition
 ix. the decision omitted major factors which might affect the judgment
 x. the judgment against which the appeal has been made contradicts a judgment which previously became final and binding
2. In cases where any of the grounds referred to in items iv to vii inclusive of the preceding paragraph exists, a petition for retrial may be filed only if, with regard to the acts to be punished, the judgment for conviction or decision for a nonpenal fine has become final and binding, or it is impossible to obtain a judgment for conviction or a decision for a nonpenal fine for reasons other than lack of evidence.
3. In cases where a judgment has been entered in the *koso*-appeal instance upon the merits of the suit, a petition for retrial against the judgment of the first instance my not be filed.

**មាត្រា ៣០៨.-** មូលហេតុនៃការជំនុំជម្រះសាជាថ្មី (ពីរ)

ក្នុងករណីដែលមានមូលហេតុដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣០៧ (មូលហេតុនៃការជំនុំជម្រះសាជាថ្មី (មួយ)) ខាងលើនេះ ចំពោះសេចក្ដីសម្រេចដែលជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកា ទោះជាមានការកំណត់នូវមធ្យោបាយនៃឧបាស្រ័យដោយឯកឯងចំពោះសេចក្ដីសម្រេចនោះក៏ដោយ ក៏ភាគីអាចយកមូលហេតុនោះមកធ្វើជាមូលហេតុនៃការជំនុំជម្រះសាជាថ្មីចំពោះសាលក្រម ឬ សាលដីកានោះបានដែរ ។

(កំណត់)

ស្របនឹងមាត្រា 339 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។

(1) សេចក្ដីសម្រេចដែលជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកា គឺចង្អុលទៅលើសេចក្ដីសម្រេចដែលជាមូលដ្ឋាននៃសាលក្រមចុងក្រោយ ឬ សាលដីកាចុងក្រោយដែលស្ថាពរ ហើយអាចនឹងប៉ះពាល់ទៅលើអត្ថន័យរបស់សាលក្រម ឬ សាលដីកានោះ ។ (ជាឧទាហរណ៍ សាលក្រមរបៀប (interlocutory judgment) (មាត្រា ១៨១) ឬ ដីកាសម្រេចអំពីនីតិវិធីបណ្ដឹងដែលសម្រេចមុននឹងសាលក្រមចុងក្រោយ ឬ សាលដីកាចុងក្រោយ (final judgment)) ។

ទោះជាសាលក្រម ឬ សាលដីកាចុងក្រោយ គ្មានមូលហេតុនៃការជំនុំជម្រះសាជាថ្មីក៏ដោយ បើមានមូលហេតុនៃការជំនុំជម្រះសាជាថ្មីដែលមានចែងនៅក្នុងកំណត់មាត្រា ៣០៧ (មូលហេតុនៃការជំនុំជម្រះសាជាថ្មី (មួយ)) នៅក្នុងសេចក្ដីសម្រេចដែលជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកានោះ ភាគីអាចប្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយយកមូលហេតុនោះ ដោយផ្ទាល់ចំពោះសាលក្រម ឬ សាលដីកាចុងក្រោយនោះបាន ។ បើអនុញ្ញាតឱ្យដាក់ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីដោយឯករាជ្យ ចំពោះសេចក្ដីសម្រេច ដែលជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកា ហើយសេចក្ដីសម្រេចនោះត្រូវបានលុបចោល នោះយើងត្រូវទទួលស្គាល់ផងដែរនូវបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចំពោះសាលក្រម ឬ សាលដីកាចុងក្រោយដែលបានចូលជាស្ថាពរ យោងទៅតាមចំណុច ៥ កថាខណ្ឌទី ១ នៃមាត្រា ៣០៧ (មូលហេតុនៃការជំនុំជម្រះសាជាថ្មី (មួយ)) ដែលជាហេតុនាំឱ្យខាតពេលច្រើន ព្រមទាំងមិនស្របនឹងសេដ្ឋកិច្ចនៃបណ្ដឹងទៀតផង ។

ប៉ុន្តែ ចំពោះដីកាសម្រេចដែលអាចប្ដឹងឧបាស្រ័យ តាមរយៈបណ្ដឹងជំទាស់ គេអាចដាក់ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីដោយឯករាជ្យបាន (សូមមើលមាត្រា ៣១៧ (ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីចំពោះដីកាសម្រេច)) ។

Code of Civil Procedure (Japan)

**Article 339** (Grounds for retrial)

In cases where any of the grounds provided for in paragraph 1 of the preceding arrticle exist with regard to any decision which is the basis of a judgment (incases where any of the grounds provided for in items iv to vii inclusive of the paragraph exist, provided that the case falls under paragraph 2 of the article), such grounds may be used as the reasons for retrial against the judgment even if an independent means of making an appeal against such decision is provided for.

**មាត្រា ៣០៩.-** តុលាការនៃការជំនុំជម្រះសាជាថ្មី

១- បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់តុលាការដែលបានចេញសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មីនោះ ។ (1)

២- បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីចំពោះសាលក្រម ឬ សាលដីកាអំពីរឿងក្តីតែមួយដែលត្រូវបានចេញដោយតុលាការច្រើនដែលមានថ្នាក់ខុសគ្នា តុលាការជាន់ខ្ពស់មានសមត្ថកិច្ចរួមបញ្ចូលនូវសាលក្រម ឬ សាលដីកាទាំងនោះ ។ (2) (3)

៣- ចៅក្រមដែលបានចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ពុំអាចចូលរួមក្នុងការជំនុំជម្រះ និង សម្រេចសេចក្តីអំពីបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះបានឡើយ ។ (4)

(កំណត់)

ស្របនឹងមាត្រា 340 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។

(1) ចំពោះការជំនុំជម្រះសាជាថ្មីនេះ ប្រសិនបើតុលាការទទួលស្គាល់អត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មី តុលាការនឹងវិនិច្ឆ័យសាជាថ្មីទៅលើរឿងក្តីដែលបានបញ្ចប់រួចម្តងមកហើយ ហេតុដូច្នេះ តុលាការដែលបានវិនិច្ឆ័យចំពោះរឿងក្តីនោះ ហើយបានចេញសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះ ត្រូវមានសមត្ថកិច្ចផ្តាច់មុខ (មាត្រា ១៥ (ករណីលើកលែងនៃការអនុវត្តចំពោះសមត្ថកិច្ចផ្តាច់មុខរបស់សាលាជម្រះក្តី ដែលច្បាប់បានកំណត់)) ។

(2) ឧទាហរណ៍ : កាលបើមានសាលក្រមសម្រេចអង្គសេចក្តីនៅតុលាការនៃការជំនុំជម្រះលើកទី ១ ហើយមានសាលដីកាលើកចោលបណ្តឹងឧទ្ធរណ៍ និង មានសាលដីកាច្រានចោលនូវបណ្តឹងសាទុក្ខ គេអាចប្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីទៅលើសាលក្រម ឬ សាលដីកានីមួយៗបាន ។ តែចំពោះបណ្តឹងនៃការជំនុំជម្រះសាជាថ្មីទៅលើសាលក្រម ឬ សាលដីកាដែលស្ថាពរទាំង ៣ ដែលធ្វើទៅតុលាការដែលមានលំដាប់ថ្នាក់ខុសគ្នា នៅក្នុងពេលតែមួយនេះ វាជាហេតុនាំមកនូវភាពច្របូកច្របល់ ។ ហេតុដូច្នេះ ក្នុងករណីដែលមានការប្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចំពោះទាំងសាលក្រម ទាំងសាលដីកាស្ថាពរដែលត្រូវបានសម្រេចដោយលំដាប់ថ្នាក់ជំនុំជម្រះខុសគ្នា គេទទួលស្គាល់លើសមត្ថកិច្ចរបស់តុលាការជាន់ខ្ពស់ ។ "តុលាការជាន់ខ្ពស់" រាប់បញ្ចូលតុលាការកំពូលដែលជាតុលាការនៃបណ្តឹងសាទុក្ខ ។

(3) ក្នុងករណីដែលតុលាការនៃបណ្តឹងសាទុក្ខ នឹងវិនិច្ឆ័យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី បើបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះ ស្របច្បាប់ តុលាការត្រូវស្រាវជ្រាវអំពីអត្ថិភាព ឬ នត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មី (មាត្រា ៣០៧ (មូលហេតុនៃការជំនុំជម្រះសាជាថ្មី (មួយ))) ។ តុលាការនៃបណ្តឹងសាទុក្ខ គឺជាតុលាការដែលវិនិច្ឆ័យអង្គច្បាប់ ប៉ុន្តែ ជាករណីលើកលែង តុលាការនៃបណ្តឹងសាទុក្ខ អាចវិនិច្ឆ័យអង្គហេតុ ចំពោះការស្រាវជ្រាវអំពីអត្ថិភាព ឬ នត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មី ។ម្យ៉ាងទៀត ចំពោះការវិនិច្ឆ័យអង្គសេចក្តី

ក្រោយពេលដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មីចូលជាស្ថាពរ ក្នុងបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនៅតុលាការនៃបណ្តឹងសាទុក្ខ សូមមើលកំណត់ (5) នៃមាត្រា ៣១៦ (ការវិនិច្ឆ័យ និង សម្រេចសេចក្តីលើអង្គសេចក្តី) ។

(4) សូមមើលមាត្រា ២៧ (ការដកហូតចៅក្រមពីសមត្ថកិច្ចជំនុំជម្រះ) ចំណុច ឆ នៃកថាខណ្ឌទី ១ ។

Code of Civil Procedure (Japan)
**Article 340** (Court with jurisdiction)
1. A petition for retrial shall be subject to the exclusive jurisdiction of the court which rendered the judgment relating to the appeal.
2. Petitions for retrial against judgments rendered in the same case by courts of diffrent levels shall all be subject to the jurisdiction of the superior court.

## មាត្រា ៣១០.- នីតិវិធីបណ្តឹងនៃការជំនុំជម្រះសាជាថ្មី

បញ្ញត្តិស្តីពីនីតិវិធីបណ្តឹងទៅតាមលំដាប់ថ្នាក់នៃការជំនុំជម្រះនីមួយៗ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីបណ្តឹងនៃការជំនុំជម្រះសាជាថ្មី លើកលែងតែបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈនៃបណ្តឹងនៃការជំនុំជម្រះសាជាថ្មី ។ (1) (2)

(កំណត់)

ស្របនឹងមាត្រា 341 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។

(1) ចំពោះនីតិវិធីបណ្តឹងនៃការជំនុំជម្រះសាជាថ្មី បើគ្មានភាពខុសនឹងលក្ខណៈបណ្តឹងទេ ត្រូវអនុវត្តដូចគ្នា ទៅតាមបញ្ញត្តិស្តីពីនីតិវិធីបណ្តឹងទៅតាមលំដាប់ថ្នាក់នៃការជំនុំជម្រះនីមួយៗ ។ មានន័យថា ចំពោះការជំនុំជម្រះសាជាថ្មីលើសាលក្រមតុលាការនៃការជំនុំជម្រះលើកទី ១ បញ្ញត្តិស្តីពីនីតិវិធីបណ្តឹងនៃការជំនុំជម្រះលើកទី ១ ត្រូវយកមកអនុវត្តដូចគ្នា និង ការជំនុំជម្រះសាជាថ្មីលើសាលដីកាតុលាការនៃការជំនុំជម្រះលើកទី ២ ត្រូវអនុវត្តដូចគ្នាទៅតាមបញ្ញត្តិស្តីពីនីតិវិធីបណ្តឹងនៃការជំនុំជម្រះលើកទី ២ ហើយចំពោះការជំនុំជម្រះសាជាថ្មីលើសាលដីការបស់តុលាការនៃបណ្តឹងសាទុក្ខ បញ្ញត្តិស្តីពីនីតិវិធីបណ្តឹងនៃបណ្តឹងសាទុក្ខ ត្រូវយកមកអនុវត្ត ។

(2) ជាឧទាហរណ៍នៃការអនុវត្តនោះ មានការលើកចោលនូវពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី (មាត្រា ៧៨ (ការពិនិត្យពាក្យបណ្តឹង)) ការលើកចោលនូវបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ៨១ (ការលើកបណ្តឹងចោល ដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់)) ការជំនុំជម្រះសាជាថ្មីបន្ទាប់បន្សំ (មាត្រា ២៧០ (បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ)) បណ្តឹងតបដោយចុងបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី (មាត្រា ៨៦ (បណ្តឹងតប)) ការដកពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី (មាត្រា ២១៧ (ការដកពាក្យបណ្តឹង)) ទំហំដែលអាចកែប្រែនៃសាលក្រម ឬ សាលដីកាដើម (ដែលត្រូវបានកម្រិតលើទំហំនៃការធ្វើឧបាស្រ័យ (មាត្រា ២៧៨ (ទំហំនៃការផ្លាស់ប្តូរសាលក្រមនៃការជំនុំជម្រះលើកទី ១)) ជាដើម ។

Code of Civil Procedure (Japan)
**Article 341** (Litigation proceedings for retrial)
The provisions relating to the litigation proceedings in each instance shall apply *mutatis mutandis* to the litigation proceedings for retrial insofar as is not inconsistent with the nature thereof.

**មាត្រា ៣១១.** អំឡុងពេលនៃការជំនុំជម្រះសាជាថ្មី

១- បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវធ្វើនៅក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ ដោយគិតចាប់ពីថ្ងៃដែលភាគីបានដឹងអំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មី ក្រោយពេលដែលសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរហើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដែលយកមូលហេតុដែលបានកំណត់នៅក្នុងចំណុច **គ** ឬ ចំណុច **ញ** កថាខណ្ឌទី ១ នៃមាត្រា ៣០៧ (មូលហេតុនៃការជំនុំជម្រះសាជាថ្មី (មួយ)) នៃក្រមនេះ ។(1) (2)

២- អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

៣- ភាគីពុំអាចប្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានឡើយ ប្រសិនបើអំឡុងពេល ៥ (ប្រាំ) ឆ្នាំ បានកន្លងផុត ដោយគិតពីថ្ងៃដែលសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរ ឬ គិតពីថ្ងៃដែលមូលហេតុនៃការជំនុំជម្រះសាជាថ្មីកើតឡើង ក្នុងករណីដែលមូលហេតុនោះកើតឡើងក្រោយពេលសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដែលយកមូលហេតុដែលបានកំណត់នៅក្នុងចំណុច **គ** ឬ ចំណុច **ញ** កថាខណ្ឌទី ១ នៃមាត្រា ៣០៧ (មូលហេតុនៃការជំនុំជម្រះសាជាថ្មី (មួយ)) នៃក្រមនេះ ។(3) (4)

(កំណត់)

ស្របនឹងមាត្រា 342 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។ សូមមើលមាត្រា 586 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសអាឡឺម៉ង់ ។

(1) ចំពោះអំឡុងពេលនេះ សូមមើលវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ មាត្រា ២៨៤ (ការពន្យារអំឡុងពេល) ។

(2) ចំពោះបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយយកមូលហេតុនៃការខ្វះសិទ្ធិតំណាង (មាត្រា ៣០៧ (មូលហេតុនៃការជំនុំជម្រះសាជាថ្មី (មួយ)) កថាខណ្ឌទី ១ ចំណុច **គ**) និង មូលហេតុនៃការប៉ះពាល់ដល់សាលក្រម ឬ សាលដីកាស្ថាពរ (កថាខណ្ឌដដែល ចំណុច **ញ**) ភាគីអាចដាក់ពាក្យបណ្ដឹងបាន ដោយពុំមានការទទួលនូវការកម្រិតអំពីអំឡុងពេលដែលមានចែងនៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះឡើយ ។ ក្នុងករណីដែលខ្វះសិទ្ធិតំណាងនេះ បណ្ដឹងនឹងត្រូវបានធ្វើបន្ត ដោយសាមីភាគី ឬ អ្នកតំណាងដែលច្បាប់បានកំណត់ពុំបានដឹងខ្លួនឡើយ បើអានុភាពនៃសាលក្រម ឬ សាលដីកាមានទៅលើភាគីនោះ វាជាការធ្ងន់ធ្ងរពេក ដូច្នេះ យើងចាំបាច់ត្រូវសង្គ្រោះទៅលើភាគីដោយមិនកម្រិតអំឡុងពេល ។ ក្នុងករណីដែលប៉ះពាល់សាលក្រម ឬ សាលដីកាស្ថាពរវិញ មានការ

ច្របូកច្របល់ ថាតើយកសាលក្រម ឬ សាលដីកាមួយណាដើម្បីសម្រេចទំនាក់ទំនងរវាងគូភាគី ដូច្នេះយើងពុំកម្រិតអំឡុងពេលទេ ។

ម្យ៉ាងទៀត ក្នុងករណីដែលខ្វះសិទ្ធិតំណាងវិញ បញ្ញត្តិស្តីពីការទទួលស្គាល់ពេលក្រោយ (មាត្រា ២៨៥ (មូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ) កថាខណ្ឌទី ២) ត្រូវយកមកអនុវត្ត ដោយសទិស (analogie) ។

(3) ឧទាហរណ៍ : ទោះជាភាគីពុំបានដឹងអំពីអត្ថិភាពរបស់មូលហេតុនៃការជំនុំជម្រះសាជាថ្មីក៏ដោយ ប្រសិនបើអំឡុងពេល ៥ ឆ្នាំ កន្លងផុត ក្រោយពេលសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរ ភាគីពុំអាចធ្វើបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីទៀតបានឡើយ ។ នេះជាវិធានការដើម្បីស្ថិរភាពច្បាប់ ។ អំឡុងពេល ៥ ឆ្នាំ នេះ ពុំអាចពន្យារ ឬ បង្រួញឱ្យខ្លីបានទេ ។ ម្យ៉ាងទៀត ទោះជាក្នុងករណីដែលភាគីពុំអាចគោរពទៅលើអំឡុងពេលនោះបាន ដោយសារហេតុដែលមិនមែនជាបន្ទុករបស់ខ្លួនក៏ដោយ ក៏ភាគីនោះពុំអាចធ្វើបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានឡើយ ។

(4) ចំពោះបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយយកមូលហេតុនៃការខ្វះសិទ្ធិតំណាង (មាត្រា ៣០៧ (មូលហេតុនៃការជំនុំជម្រះសាជាថ្មី (មួយ)) កថាខណ្ឌទី ១ ចំណុច **គ**) និង មូលហេតុនៃការប៉ះពាល់ដល់សាលក្រម ឬ សាលដីកាស្ថាពរ (កថាខណ្ឌដដែល ចំណុច **ញ**) ភាគីអាចដាក់ពាក្យបណ្តឹងបាន ដោយពុំមានការទទួលនូវការកម្រិតអំពីអំឡុងពេលដែលមានចែងនៅក្នុងកថាខណ្ឌទី ៣ នៃមាត្រានេះឡើយ ។ អត្ថន័យនេះដូចគ្នានឹងកំណត់ (2) ខាងលើនេះ ។

Code of Civil Procedure (Japan)
**Article 342** (Period for retrial)
1. A petition for retrial must be filed within the peremptory term of thirty days of the day on which a party learned of the grounds for retrial after the judgment became final and binding.
2. A petition for retrial may not be filed more than five years after the day on which the judgment became final and binding (in cases where the grounds for the retrial came into existence after the judgment became final and binding, the day on which the grounds came into existence).
3. The preceding two paragraphs shall not apply to a petition for retrial based on a defect in authority among the grounds provided for in Article 338, paragraph 1, item iii and based on the grounds provided for in item x of the paragraph.

Code of Civil Procedure Rules (Germany)
**Article 586** (Limitation of time)
(1) The action must be brought within a month before the expiring of the statutory period.
(2) The period begins to run on the day on which the party acquired knowledge of the ground for contestation; not, however, before the finality of the judgment. When five years have elapsed from the date on which the judgment became final, the actions are barred.
(3) The provisions of the subparagraph (2) are not applicable to actions for nullity on account of lack of representation; the period of limitation begins to run on the date on which the judgment is served on the party and, in case of lacking capacity to conduct proceedings, on his legal representative.

**មាត្រា ៣១២.-** ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

១- នៅក្នុងពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវសរសេរនូវចំណុចដូចខាងក្រោមនេះ : (1)

**ក-** ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។ (2)

**ខ**- សញ្ញាណនៃសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និង សេចក្ដីទាមទារឱ្យជំនុំជម្រះសាជាថ្មីចំពោះសាលក្រម ឬ សាលដីកានោះ ។

**គ**- អង្គហេតុដែលត្រូវនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មី ។(3)

២- ឯកសារចម្លងនៃសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវភ្ជាប់ជាមួយនឹងពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ។

(កំណត់)

ស្របនឹងមាត្រា 343 នៃក្រមនីតិវិធីរដ្ឋប្បវេណី កថាខណ្ឌទី ១ នៃមាត្រា 211 នៃបទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។ សូមមើលមាត្រា 588 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសអាឡឺម៉ង់ ។

(1) មាត្រានេះកំណត់ចំណុចចាំបាច់ដែលត្រូវសរសេរនៅក្នុងពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ។ ទំហំនៃសេចក្ដីឧបាស្រ័យ ឬ ការទាមទារដែលទាក់ទងនឹងអង្គសេចក្ដីនៃរឿងក្ដីនោះ គឺជាចំណុចដែលអាចសរសេរដោយស្ម័គ្រចិត្ត ។ នៅក្នុងករណីដែលមានការសរសេរខ្វះខាតទៅលើចំណុចចាំបាច់ តុលាការនឹងបង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតនោះ យោងទៅតាមពាក្យបណ្ដឹងធម្មតា ហើយប្រសិនបើភាគីមិនបានគោរពប្រតិបត្តិតាម ពាក្យបណ្ដឹងនោះនឹងត្រូវលើកចោលដោយដីកាសម្រេច (សូមមើលមាត្រា ៣១០ (នីតិវិធីបណ្ដឹងនៃការជំនុំជម្រះសាជាថ្មី)) ។

(2) នៅទីនេះ ភាគីមានន័យថា គឺដើមចោទ និង ចុងចម្លើយនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ។ ក្នុងករណីដែលភាគីនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ជាជនណាផ្សេងពីភាគីនៃសាលក្រមដើម ឬ សាលដីកាដើម នោះចាំបាច់ត្រូវសរសេរឱ្យបានច្បាស់អំពីទំនាក់ទំនងរវាងជននោះជាមួយនឹងភាគីនៃសាលក្រមដើម ឬ សាលដីកាដើមនោះ (ឧទាហរណ៍ : សន្តតិជនរបស់ភាគីនៃសាលក្រម ឬ សាលដីកា ជាដើម) ។

(3) ក្នុងពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ភាគីត្រូវតែសរសេរឱ្យបានច្បាស់លាស់នូវការអះអាងអំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មី ។ ប៉ុន្តែ មូលហេតុនៃការជំនុំជម្រះសាជាថ្មីដែលបានអះអាងនៅក្នុងពាក្យបណ្ដឹងនេះ អាចកែប្រែ នៅក្រោយពេលដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបាន (មាត្រា ៣១៣ (ការកែប្រែមូលហេតុនៃការជំនុំជម្រះសាជាថ្មី)) ។

Code of Civil Procedure (Japan)
**Article 343** (Matters to be stated in petition for retrial)
The following matters shall be included in a petition for retrial:
i. the parties and their legal representatives;
ii. the identification designation of the judgment against which an appeal has been made, and a statement that a retrial is requested for such judgment;
iii. the reasons for appeal.

Rules of Civil Procedure (Japan)
**Article 211** (Litigation proceedings for retrial / The Code Article 341) (excerpt)
1. A copy of the judgment against which an appeal has been made shall be attached to a petition for retrial.

Code of Civil Procedure Rules (Germany)
**Article 588** (Special provisions for the contents of the statement of claim)
(1) As a preparatory pleading, the statement of claim shall contain:
1. the description of the grounds of contestation;
2. the outline of the means of evidence for the facts showing the grounds and the compliance with the statutory period;
3. the declaration showing to what extent the setting aside of the contested judgment and which other decision in the main issue is demanded.

(2) The written pleadings by which an action for restitution is lodged shall be accompanied by the documents on which it is based, in original or copy. If the documents are not in the possession of the claimant, he shall explain what petition he is intending to make to bring about their production.

**មាត្រា ៣១៣.-** ការកែប្រែមូលហេតុនៃការជំនុំជម្រះសាជាថ្មី

ភាគីដែលបានដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី អាចកែប្រែមូលហេតុនៃការជំនុំជម្រះសាជាថ្មីបាន ។ (1)(2)

(កំណត់)

ស្របនឹងមាត្រា 344 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។

(1) មូលហេតុនៃការជំនុំជម្រះសាជាថ្មី ដែលបានសរសេរនៅក្នុងពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី (ចំណុច **គ** កថាខណ្ឌទី ១ នៃមាត្រា ៣១២ (ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី)) អាចកែប្រែបាន រហូតដល់ចុងបញ្ចប់នៃការទាញហេតុផលដោយផ្ទាល់មាត់ នៃការជំនុំជម្រះនៅលំដាប់ថ្នាក់នេះ ហើយការកែប្រែនេះក៏អាចធ្វើបាន នៅក្នុងការជំនុំជម្រះនៅតុលាការជាន់ខ្ពស់ដែរ ។

(2) នៅក្នុងករណីធ្វើការកែប្រែនូវមូលហេតុនៃការជំនុំជម្រះសាជាថ្មី អំពីការគោរពទៅលើអំឡុងពេលអាចប្ដឹង ឬ យ៉ាងណានោះ (មាត្រា ៣១១ (អំឡុងពេលនៃការជំនុំជម្រះសាជាថ្មី) កថាខណ្ឌទី ១) នៅប្រទេសជប៉ុន មតិភាគច្រើនគេគិតតាមពេលដែលបានធ្វើការកែប្រែនោះ ។

Code of Civil Procedure (Japan)
**Article 344** (Change of reason for appeal)
The party who filed the petition for retrial may change the reason for appeal.

**មាត្រា ៣១៤.-** ការលើកចោលបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និង ការច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី (1)

១- ក្នុងករណីដែលបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីមានភាពផ្ទុយនឹងច្បាប់ តុលាការត្រូវលើកចោលបណ្ដឹងនោះ ដោយដីកាសម្រេច ។(2)

២- ក្នុងករណីដែលគ្មានមូលហេតុនៃការជំនុំជម្រះសាជាថ្មី តុលាការត្រូវច្រានចោលនូវការទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយដីកាសម្រេច ។(3)

៣- ប្រសិនបើដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ចូលជាស្ថាពរហើយ ភាគីមិនអាចដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីទៀត ដោយយកមូលហេតុដូចគ្នាបានឡើយ ។(4)

៤- ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

(កំណត់)

ស្របនឹងមាត្រា 345 និង មាត្រា 347 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។

(1) ការវិនិច្ឆ័យលើការជំនុំជម្រះសាជាថ្មីនេះ មាន ២ ដំណាក់ គឺការអនុញ្ញាតឱ្យប្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ឬ អត់ និង ការវិនិច្ឆ័យលើអង្គសេចក្ដី បើការជំនុំជម្រះសាជាថ្មីត្រូវបានអនុញ្ញាត ។ ការអនុញ្ញាតឱ្យប្ដឹង ឬ អត់ គឺធ្វើតាមនីតិវិធីនៃដីកាសម្រេច ។ មាត្រានេះចែងអំពីការអនុញ្ញាតឱ្យប្ដឹងជំនុំជម្រះសាជាថ្មី ឬ អត់ និង នីតិវិធីវិនិច្ឆ័យសម្រាប់អនុញ្ញាត ឬ មិនអនុញ្ញាត ។ ដោយនីតិវិធីវិនិច្ឆ័យនេះជានីតិវិធីនៃដីកាសម្រេច ការវិនិច្ឆ័យនេះត្រូវធ្វើទៅតាមការទាញហេតុផលដោយផ្ទាល់មាត់តាមឆន្ទៈស្វ័គ្រចិត្ត (វាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ មាត្រា ១១៤ (ភាពចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់)) ។ ចំពោះការវិនិច្ឆ័យលើអង្គសេចក្ដី នៅក្នុងករណីដែលតុលាការអនុញ្ញាតឱ្យប្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីវិញ មាត្រា ៣១៦ (ការវិនិច្ឆ័យ និង សម្រេចសេចក្ដីលើអង្គសេចក្ដី) ។

(2) ជាបឋម តុលាការត្រូវពិនិត្យទៅលើបណ្ដឹងនៃការជំនុំជម្រះសាជាថ្មី ថាតើវាត្រឹមត្រូវទៅតាមច្បាប់ ឬ អត់ ។ នៅក្នុងករណីដែលមិនត្រឹមត្រូវតាមច្បាប់ តុលាការត្រូវលើកចោលបណ្ដឹងនោះ ដោយដីកាសម្រេច ហើយបើទទួលស្គាល់ថាត្រឹមត្រូវហើយ តុលាការត្រូវពិនិត្យលើការជំនុំជម្រះសាជាថ្មី ថាជាការសមរម្យ ឬ អត់ មានន័យថា តុលាការពិនិត្យនូវអត្ថិភាពនៃការជំនុំជម្រះសាជាថ្មី ។

(3) នៅក្នុងករណីដែលមានមូលហេតុត្រឹមត្រូវនៃការជំនុំជម្រះសាជាថ្មី តុលាការត្រូវចេញដីកាសម្រេចដើម្បីចាប់ផ្ដើមធ្វើការជំនុំជម្រះសាជាថ្មីនោះ (កថាខណ្ឌទី ១ នៃមាត្រា ៣១៥ (ដីកាសម្រេចចាប់ផ្ដើមជំនុំជម្រះសាជាថ្មី)) ។

(4) កថាខណ្ឌនេះ ជាបញ្ញត្តិដើម្បីការពារកុំឱ្យមានការបំពានសិទ្ធិប្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ។

Code of Civil Procedure (Japan)
**Article 345** (Dismissal, etc., of petition for retrial)
1. In cases where a petition for retrial is illegitimate, the court shall dismiss such petition by ruling.
2. In cases where no grounds for retrial exist, the court shall dismiss the petition for retrial by ruling.
3. In cases where the ruling referred to in the preceding paragraph has become final and binding, no further petition for retrial based on the same grounds for appeal shall be filed.
**Article 347** (Immediate *kokoku*-appeal)
An immediate *kokoku*-appeal may be made against the ruling under the Article 345, paragraph 1 and 2, and paragraph 11 of the preceding article.

## **មាត្រា ៣១៥.-** ដីកាសម្រេចចាប់ផ្ដើមជំនុំជម្រះសាជាថ្មី

១- ក្នុងករណីដែលមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី តុលាការត្រូវចេញដីកាសម្រេចដើម្បីចាប់ផ្តើមធ្វើការជំនុំជម្រះសាជាថ្មី ។

២- តុលាការត្រូវសួរភាគីម្ខាងទៀតជាមុន ក្នុងករណីចេញដីកាសម្រេចដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។ (1)

៣- ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

(កំណត់)

ស្របនឹងមាត្រា 346 និង 347 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។

(1) ដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មីនេះ គឺជាការវិនិច្ឆ័យដំបូងដែលអាចនាំឱ្យលុបចោលនូវសាលក្រម ឬ សាលដីកាស្ថាពរ ហេតុនេះហើយ ក្នុងករណីដែលចេញដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី តុលាការចាំបាច់ត្រូវសួរភាគីម្ខាងទៀត ។ ប៉ុន្តែ នៅក្នុងករណីដែលបានបើកការទាញហេតុផលដោយផ្ទាល់មាត់ (សូមមើលកំណត់ (1) នៃមាត្រា ៣១៤ (ការលើកចោលបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និង ការច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី)) ការសួរភាគីម្ខាងទៀតក្រៅពីការទាញហេតុផលដោយផ្ទាល់មាត់ ពុំចាំបាច់ឡើយ ។

Code of Civil Procedure (Japan)
**Article 346** (Ruling for commencement of retrial)
1. In cases where grounds for retrial exist, the court shall render a ruling for commencement of retrial.
2. The court shall interrogate the adversary party when rendering the ruling referred to in the preceding paragraph.
**Article 347** (Immediate *kokoku*-appeal) > *see the note for Article 314*

**មាត្រា ៣១៦.-** ការវិនិច្ឆ័យ និង សម្រេចសេចក្តីលើអង្គសេចក្តី

១- តុលាការត្រូវធ្វើការវិនិច្ឆ័យ និង សម្រេចសេចក្តីលើអង្គសេចក្តី តាមទំហំនៃឧបាស្រ័យ នៅក្នុងករណីដែលដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មីចូលជាស្ថាពរ ។(1)(2)(3)

២- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថា សាលក្រម ឬ សាលដីកាត្រឹមត្រូវ តុលាការត្រូវច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះ ។(4)

៣- លើកលែងតែក្នុងករណីដូចកថាខណ្ឌទី ២ ខាងលើនេះ តុលាការត្រូវលុបចោលនូវសាលក្រម ឬ សាលដីកា ហើយត្រូវសម្រេចសេចក្តីជាថ្មីទៀត ។(5)(6)

(កំណត់)

ស្របនឹងមាត្រា 348 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។

(1) នៅក្នុងករណីដែលដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី (កថាខណ្ឌទី ១ នៃមាត្រា ៣១៥ (ដីកាសម្រេចចាប់ផ្តើម

ជំនុំជម្រះសាជាថ្មី)) នេះ ចូលជាស្ថាពរ តុលាការត្រូវធ្វើការវិនិច្ឆ័យ និង សម្រេចលើអង្គសេចក្តី ។ ការវិនិច្ឆ័យលើអង្គសេចក្តីនេះ គឺជាការបន្តការវិនិច្ឆ័យទៅលើបណ្តឹងដែលមានពីមុន ដូច្នេះនីតិវិធីនៃបណ្តឹងមុននេះ មានអានុភាពលុះត្រាតែគ្មានពាក់ព័ន្ធទៅនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មីទេ ។ សូមមើលមាត្រា ៣១០ (នីតិវិធីបណ្តឹងនៃការជំនុំជម្រះសាជាថ្មី) ។

(2) ចុងចម្លើយទាមទារឱ្យជំនុំជម្រះសាជាថ្មី អាចពង្រីកនូវទំហំនៃការវិនិច្ឆ័យសម្រាប់អត្ថប្រយោជន៍របស់ខ្លួន ដោយបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបន្ទាប់បន្សំ (សូមមើលមាត្រា ២៧០ (បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ)) ។ម្យ៉ាងទៀត ចុងចម្លើយនោះអាចប្តឹងតបបាន ដោយយកមូលហេតុនៃការជំនុំជម្រះសាជាថ្មីដែលខ្លួនមាន (សូមមើលមាត្រា ៣១០ (នីតិវិធីបណ្តឹងនៃការជំនុំជម្រះសាជាថ្មី)) ។

(3) សាលក្រម ឬ សាលដីកាដែលធ្វើទៅតាមកថាខណ្ឌទី ១ នេះ ជាសាលក្រម ឬ សាលដីកានៅតាមលំដាប់ថ្នាក់នោះ ឧទាហរណ៍ : សាលដីកាដែលបានធ្វើឡើងលើបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីចំពោះសាលដីការបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ គឺជាសាលដីការបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ ហេតុដូច្នេះបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់គឺបណ្តឹងសាទុក្ខ ។

(4) ក្នុងករណីដែលការជំនុំជម្រះសាជាថ្មីមានមូលហេតុក៏ដោយ ប្រសិនបើការពិនិត្យលើអង្គសេចក្តីមានលទ្ធផលដូចគ្នានឹងសាលក្រមដើម ឬ សាលដីកាដើមដែលត្រូវបានប្តឹងឧបាស្រ័យ តុលាការត្រូវច្រានចោលនូវការទាមទារឱ្យជំនុំជម្រះសាជាថ្មី ។

ឧទាហរណ៍ : យោងទៅតាមច្បាប់ ចៅក្រមដែលពុំអាចចូលរួមចំណែកក្នុងការសម្រេចសេចក្តី បានចូលរួមក្នុងការសម្រេចសេចក្តីនោះ ប៉ុន្តែ ក្រោយពេលដែលតុលាការនៃការជំនុំជម្រះសាជាថ្មីនោះពិនិត្យមើលទៅលើខ្លឹមសារនៃការវិនិច្ឆ័យនោះឃើញថា អត្ថន័យនៃការវិនិច្ឆ័យលើសាលក្រមដើមនោះមានភាពត្រឹមត្រូវ ។

(5) កាលដែលមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី ហើយការសន្និដ្ឋាននោះទទួលបានលទ្ធផលខុសពីសាលក្រម ឬ សាលដីកាដើម តុលាការត្រូវលុបចោលនូវសាលក្រមដើម ហើយត្រូវវិនិច្ឆ័យលើអង្គសេចក្តីបន្ថែមទៀត ។

ប៉ុន្តែ ក្នុងករណីដែលតុលាការនៃបណ្តឹងសាទុក្ខ គឺជាតុលាការនៃការជំនុំជម្រះសាជាថ្មី បញ្ញត្តិស្តីពីនីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខ ត្រូវយកមកអនុវត្ត ចំពោះនីតិវិធីនៃការជំនុំជម្រះសាជាថ្មីដោយតុលាការនៃបណ្តឹងសាទុក្ខនោះ លើកលែងតែបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈនៃបណ្តឹងនៃការជំនុំជម្រះសាជាថ្មី ដោយយោងតាមបញ្ញត្តិនៃមាត្រា ៣១០ (នីតិវិធីបណ្តឹងនៃការជំនុំជម្រះសាជាថ្មី) ។ ហេតុដូច្នេះ បើតុលាការនៃបណ្តឹងសាទុក្ខមិនអាចធ្វើការសម្រេចសេចក្តីជំនួសសាលដីកាដើម ដោយមិនវិនិច្ឆ័យអង្គហេតុចំពោះរឿងក្តី តុលាការនោះចាំបាច់ត្រូវចេញសាលដីកាដែលបង្គាប់ឱ្យបញ្ជូនរឿងក្តីត្រឡប់ទៅតុលាការនៃការវិនិច្ឆ័យអង្គហេតុវិញ (មាត្រា ២៩៩ (ការបដិសេធចោល ហើយបញ្ជូនត្រឡប់ទៅតុលាការដើមវិញ ជាអាទិ៍) ដោយសារតុលាការនៃបណ្តឹងសាទុក្ខជាតុលាការដែលវិនិច្ឆ័យអង្គច្បាប់ ហើយ ជាគោលការណ៍ មិនអាចវិនិច្ឆ័យអង្គហេតុឡើយ ។ ហេតុដូច្នេះ "សម្រេច

សេចក្ដីជាថ្មី" ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រានេះ រាប់បញ្ចូលសាលដីកាដែលបដិសេធសាលដីកាដើម ឬ សាលក្រមដើមចោល ហើយបញ្ជូនរឿងក្ដីត្រឡប់ទៅវិញ ។

(6) ចំពោះសេចក្ដីសម្រេចអំពីប្រាក់ប្រដាប់ក្ដីដែលទាក់ទងនឹងសាលក្រមដើម ឬ សាលដីកាដើមដែលត្រូវបានលុបចោល តាមបញ្ញត្តិនៃកថាខណ្ឌទី ៣ នេះ តុលាការនៃការជំនុំជម្រះសាជាថ្មី ត្រូវសម្រេចសេចក្ដីសាជាថ្មីចំពោះប្រាក់ប្រដាប់ក្ដីនោះ ។

Code of Civil Procedure (Japan)
**Article 348** (Trial and decision upon merits)
1. In cases where a ruling for commencement of retrial has become final and binding, the court shal perform trial and decision upon the merits of the petition only to the extent of the appeal made.
2. The court shall, in the cases referred to in the preceding article, upon determining the judgment proper, dismiss the petition for retrial.
3. The court shall, except for the cases referred to in the preceding paragraph, reverse the judgment and render a further decision.

**មាត្រា ៣១៧.**- ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីចំពោះដីកាសម្រេច

១- ចំពោះដីកាសម្រេចដែលអាចប្ដឹងឧបាស្រ័យដោយបណ្ដឹងជំទាស់ ហើយបានចូលជាស្ថាពរ អាចដាក់ពាក្យសុំឱ្យជំនុំ-ជម្រះសាជាថ្មីបាន ។(1)

២- បញ្ញត្តិចាប់ពីមាត្រា ៣០៧ (មូលហេតុនៃការជំនុំជម្រះសាជាថ្មី (មួយ)) រហូតដល់មាត្រា ៣១៦ (ការវិនិច្ឆ័យ និងសម្រេចសេចក្ដីលើអង្គសេចក្ដី) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

ស្របនឹងមាត្រា 349 នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។

(1) នៅក្នុងចំណោមដីកាសម្រេច ដីកាសម្រេចដែលធ្វើឡើងដើម្បីជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកាចុងក្រោយ ហើយបើមានមូលហេតុនៃការជំនុំជម្រះសាជាថ្មីក្នុងដីកាសម្រេចនោះ ភាគីអាចប្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីចំពោះសាលក្រម ឬ សាលដីកាចុងក្រោយនោះដោយផ្ទាល់បាន (មាត្រា ៣០៨ (មូលហេតុនៃការជំនុំជម្រះសាជាថ្មី (ពីរ))) ។ ប៉ុន្តែ ចំពោះដីកាសម្រេចមានភាពជាចុងក្រោយ ហើយក្រោយមកទៀត ពុំភ្ជាប់ជាមួយនឹងសាលក្រម ឬ សាលដីកាចុងក្រោយ បើមានមូលហេតុនៃការជំនុំជម្រះសាជាថ្មីក្នុងដីកាសម្រេចនោះ ត្រូវអនុញ្ញាតឱ្យដាក់ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីដោយឯករាជ្យ ។ ឧទាហរណ៍ដូចជា : ដីកាសម្រេចដែលសម្រេចថា ពាក្យសុំដកហូត ឬ បណ្ដឹងជិតចិត្តគ្មានមូលហេតុត្រឹមត្រូវ (មាត្រា ៣០ (ការសម្រេចសេចក្ដីអំពីពាក្យសុំដកហូត ឬ បណ្ដឹងជិតចិត្ត) កថាខណ្ឌទី ៦) ដីកាសម្រេចលើកពាក្យបណ្ដឹងចោល (មាត្រា ៧៨ (ការពិនិត្យពាក្យបណ្ដឹង) កថាខណ្ឌទី ២) ដីកាសម្រេចអំពីការបដិសេធនូវការផ្ដល់ចម្លើយជាកសិណសាក្សី (មាត្រា ១៣៥ (ដីកាសម្រេចទៅលើការបដិសេធនូវការផ្ដល់ចម្លើយ

ជាកសិណសាក្សី ៈ ជាដើម ។

Code of Civil Procedure (Japan)
**Article 349** (Retrial against ruling or order)
1. A motion for retrial may be made against a ruling or order which may be appealed of by means of an immediate *kokoku*-appeal and which become final and binding.
2.. The provisions of Article 338 to the preceding article inclusive shall apply *mutatis mutandis* to the motion referred to in the preceding paragraph.

**មាត្រា ៣១៨.-** បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយតតិយជន

១- បើដើមចោទ និង ចុងចម្លើយបានទទួលនូវសាលក្រម ឬ សាលដីកា ដោយរួមគំនិតគ្នាក្នុងគោលបំណងធ្វើឱ្យបាត់បង់សិទ្ធិ ឬ ផលប្រយោជន៍របស់តតិយជន តតិយជននោះអាចធ្វើឧបាស្រ័យ ដោយបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចំពោះសាលក្រម ឬ សាលដីកាចុងក្រោយដែលបានចូលជាស្ថាពរនោះបាន ។(1)

២- បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដើមចោទ និង ចុងចម្លើយ ត្រូវក្លាយជាសហចុងចម្លើយ ។(2)

៣- បញ្ញត្តិនៃមាត្រា ៤១ (បទបញ្ញត្តិពីការវិនិច្ឆ័យលើសហបណ្ដឹងជាចាំបាច់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះជនដែលជាសហចុងចម្លើយតាមកថាខណ្ឌទី ២ ខាងលើ និង តតិយជនដែលបានដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីតាមកថាខណ្ឌទី ១ ខាងលើនេះ ។(3)

(កំណត់)

ក្រមនីតិវិធីរដ្ឋប្បវេណីចាស់ជាងគេ មាត្រា 483 ក្រមពាណិជ្ជកម្មជប៉ុន មាត្រា 268-3 និង ច្បាប់ស្ដីពីនីតិវិធីនៃបណ្ដឹងរដ្ឋបាលជប៉ុន មាត្រា 34 ។

(1) ក្នុងករណីដែលដើមចោទ និង ចុងចម្លើយ បានរួមគំនិតគ្នាធ្វើបណ្ដឹងក្នុងគោលបំណងបំពានទៅលើសិទ្ធិរបស់តតិយជន ហើយទទួលបានសាលក្រម ឬ សាលដីកាជាស្ថាពរ តតិយជនដែលត្រូវបានបំពានសិទ្ធិរបស់ខ្លួនដោយសារ សាលក្រម ឬ សាលដីកាស្ថាពរនោះ អាចទាមទារលុបចោលនូវសាលក្រម ឬ សាលដីកានោះ និង ទាមទារឱ្យពិនិត្យចំពោះរឿងក្ដីម្ដងទៀត តាមបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបាន ។ ប្រភេទនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយតតិយជននេះ យើងហៅថា "ការជំនុំជម្រះសាជាថ្មីកុំឱ្យមានការខូចខាតផលប្រយោជន៍" ។

(2) ករណីដែលប្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី តាមមាត្រានេះ តតិយជនដែលជាដើមបណ្ដឹងជំនុំជម្រះសាជាថ្មីនេះ អាចដាក់ពាក្យបណ្ដឹង ដោយប្ដឹងភាគីទាំងសងខាងនៃសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះ ។ ម្ល៉ោះហើយគឺជាទម្រង់មួយដែលជាប្រភេទនៃសហបណ្ដឹង (ចាប់ពីមាត្រា ៣៩ (ល័ក្ខខ័ណ្ឌទូទៅនៃសហបណ្ដឹង) ទៅ) ។

(3) ដើម្បីសម្រួលឱ្យរឿងក្ដីមានភាពស្របគ្នា រវាងតតិយជនដែលជាដើមបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និង

សហចុងចម្លើយនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី បញ្ញត្តិស្តីពីការវិនិច្ឆ័យលើសហបណ្តឹងជាចាំបាច់ ត្រូវយកមកអនុវត្តដូចគ្នាចំពោះបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីរបស់តតិយជននេះ ។

Commercial Code (Japan)
**Article 268-3** (Action for retrial)
1. Where an action as provided for in paragraph 1 of Article 268 has been brought and the plaintiff and defendant have colluded to bring about a judgment so as to damage the company's rights which are at issue in the action, the company or a shareholder may oppose the final judgment by means of an action for retrial.
2. The provisions of the preceding Article shall apply *mutatis mutandis* to the action provided for in the preceding paragraph.

Administrative Case Litigation Law (Japan)
**Article 34** (Suit for review by third person)
1. A third person whose right has been injured by the judgment revoking a disposition or decision and who has been unable to produce the means of attack or defense influencing on a judgment because of having been unable to intervene in a litigation by a reason not attributable to his own responsibility, may file an appeal by way of a suit for review to the conclusively final judgment, making it as a reason.
2. The suit of the preceding paragraph shall be filed within thirty days as from the day when he kwen such final judgment.
3. The period of the preceding paragraph shall be a peremptory term.
4. The suit under paragraph 1 shall not be filed in case one year has passed as from the day when the judgment became final and conclusive.

# គន្ថីទី ៥ នីតិវិធីដាស់តឿន

## ជំពូកគោល នីតិវិធីដាស់តឿន

**មាត្រា ៣១៩.-** ល័ក្ខខ័ណ្ឌនៃដីកាសម្រេចដាស់តឿន

ចំពោះការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ តុលាការអាចចេញដីកាសម្រេចដាស់តឿន តាមពាក្យសុំរបស់ម្ចាស់បំណុលបាន ។ ប៉ុន្តែ ករណីនេះអាចធ្វើទៅបាន លុះត្រាតែអាចធ្វើការបញ្ជូនដីកានោះនៅព្រះរាជាណាចក្រកម្ពុជាបាន តាមវិធីក្រៅពីការបញ្ជូនតាមការផ្សាយជាសាធារណៈ ។

(កំណត់)

មាត្រានេះមានន័យដូចគ្នានឹងក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនមាត្រា 382 (ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ មាត្រា 430) ។ ប្រព័ន្ធដាស់តឿននេះមាននៅបណ្តាប្រទេសដែលអនុវត្តប្រព័ន្ធច្បាប់អាល្លឺម៉ង់ (ប្រព័ន្ធច្បាប់បារាំងក៏មានរបបប្រហាក់ប្រហែលគ្នាដែរ) ។

គេអាចទទួលនូវលិខិតអនុវត្តដែលស្ថាប័នរដ្ឋទទួលស្គាល់ក្នុងការទាមទារបំណុល ដែលចាំបាច់ដើម្បីឱ្យអនុវត្តដោយបង្ខំ ហេតុនេះហើយ ក្នុងសង្គមដែលគេប្រើរបបឥណទានអ្នកប្រើប្រាស់ (consumer credit) ញឹកញាប់ គេបានប្រើប្រព័ន្ធដាស់តឿននេះជាច្រើន ដើម្បីទាមទារបំណុលដែលជំពាក់តាមការទិញដោយឥណទាន ។ ដោយសារតែគេច្រើនប្រើរបបនេះសម្រាប់ទាមទារបំណុលជាប្រាក់ ហេតុនេះហើយបានជាមាត្រានេះ មិនបញ្ចូល "ការទាមទារដែលមានគោលបំណងឱ្យសងជាវត្ថុផ្សេងជំនួស ឬ ឱ្យផ្តល់ឧបករណ៍អាចជួញដូរបាន (valuable instruments, negotiable instruments) ដែលបានកំណត់ចំនួន" ដែលចែងក្នុងមាត្រា 382 នៃច្បាប់ជប៉ុន ជាកម្មវត្ថុនៃនីតិវិធីដាស់តឿន ។

ដើម្បីអាចប្រើនីតិវិធីដាស់តឿននេះ ឧទាហរណ៍ ថាបើជាការទាមទារលើកម្មវត្ថុដែលជាប្រាក់ដូចជា សិទ្ធិលើបំណុលជាប្រាក់ថ្លៃលក់ទិញ ឬ ជាសិទ្ធិលើបំណុលនៃប្រាក់ខ្ចីនោះវាមិនអីទេ ដោយវាគ្មានកម្រិតចំនួនទាមទារជាអតិប្បរមា ឬក៏អប្បរមាឡើយ ។ ក្នុងករណីដែលគូភាគីគ្មានវិវាទទៅលើទំនាក់ទំនងនៃអង្គហេតុ គេអាចជ្រើសយកលិខិតអនុវត្តដែលរហ័សជាងការប្រើប្រាស់នីតិវិធីបណ្តឹងនេះ ។

ហើយនៅក្នុងប្រទេសកម្ពុជា ការដែលអាចបញ្ជូនដីកាដាស់តឿន ដោយមិនធ្វើតាមការបញ្ជូនតាមការផ្សាយជាសាធារណៈនេះ គឺជាល័ក្ខខ័ណ្ឌមួយនៃការប្រកាសដីកាដាស់តឿន ។

<u>Code of Civil Procedure (Japan)</u>
**Article 382** (Requirements of demand for payment)
With regard to a claim the object of which is for the payment of money or delivery of other fungible things or negotiable instruments in a fixed amount, upon motion of the obligee, the court clerk may issue a demand for payment. However this shall apply only when such demand for payment can be served in Japan in a manner other than by service by publication of notice.

Old Code of Civil Procedure (Japan, 1890, last amendment: 1992)
**Article 430** (Conditions for application)
In regard to a claim the object matter of which being the getting of payment of money or any other fungible things therefor or a certain amount of negotiable instruments, the court may, upon motion of the creditor, issue a payment order: Provided that this shall be done only when a service of the order is available in Japan instead of by the public notice.

**មាត្រា ៣២០.-** ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន

១- ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿនចំពោះកូនបំណុលដូចមានកំណត់ក្នុងចំណុចខាងក្រោម ត្រូវធ្វើទៅសាលាដំបូងដែលមានសមត្ថកិច្ចលើតំបន់ដែលបានកំណត់ក្នុងចំណុចនីមួយៗខាងក្រោមនេះ :

**ក-** រូបវន្តបុគ្គល : លំនៅឋាន ឬ បើពុំមានលំនៅឋាន ឬ មានលំនៅឋានមិនពិតប្រាកដនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ គឺទីសំណាក់ ។

**ខ-** នីតិបុគ្គលក្នុងប្រទេស : ទីស្នាក់ការកណ្តាល ឬ ទីកន្លែងអាជីវកម្មចម្បង ឬ បើពុំមានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មទេ គឺលំនៅឋានរបស់អ្នកតំណាង ឬ របស់អ្នកទទួលខុសត្រូវភារកិច្ចចាត់ចែងការងារជាចម្បង ។

**គ-** នីតិបុគ្គលបរទេស : ទីស្នាក់ការកណ្តាល ឬ ទីកន្លែងអាជីវកម្មចម្បងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ បើពុំមានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ គឺលំនៅឋានរបស់អ្នកតំណាងប្រចាំព្រះរាជាណាចក្រកម្ពុជា ឬ របស់អ្នកទទួលខុសត្រូវភារកិច្ចចាត់ចែងការងារជាចម្បងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿនអំពីការទាមទារដែលបានកំណត់ក្នុងចំណុចខាងក្រោមនេះ អាចធ្វើទៅសាលាដំបូងដែលមានសមត្ថកិច្ចលើតំបន់ដែលបានកំណត់ក្នុងចំណុចនីមួយៗខាងក្រោមនេះបានដែរ :

**ក-** ការទាមទារចំពោះបុគ្គលដែលមានទីស្នាក់ការ ឬ កន្លែងអាជីវកម្ម ហើយការទាមទារនោះទាក់ទងនឹងការងារនៃទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនោះ : កន្លែងដែលមានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនោះ ។

**ខ-** ការទាមទារឱ្យសងជាប្រាក់ដោយរូបិយាណត្តិ ឬ មូលប្បទានប័ត្រ និង ការទាមទារបន្ទាប់បន្សំដែលទាក់ទងនឹងវត្ថុទាំងនេះ : កន្លែងដែលត្រូវសងរូបិយាណត្តិ ឬ មូលប្បទានប័ត្រនោះ ។

៣- សមត្ថកិច្ចដែលកំណត់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ គឺជាសមត្ថកិច្ចផ្តាច់មុខ ។

（កំណត់）

មាត្រានេះមានគោលគំនិតដូចក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 383 ដែរ （ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ មាត្រា 431） ។ ជាគោលការណ៍ ពាក្យសុំនេះត្រូវធ្វើទៅតុលាការដែលមានសមត្ថកិច្ចលើតំបន់ដែលមានលំនៅដ្ឋានរបស់កូនបំណុល ។ នេះជាសមត្ថកិច្ចផ្តាច់មុខ ។ សូមមើលកំណត់នៅក្នុងមាត្រា ៨ និង មាត្រា ៩ ។

Code of Civil Procedure (Japan)
**Article 383** (Motion for demand for payment)
1. A motion for demand for payment shall be made to the court clerk in the summary court governing the place of the obligor's general forum.
2. A motion for demand for payment concerning claims prescribed by either of the following items may also be made to the court clerk in the summary court governing the place designated by the respective applicable items:
i. a claim against a person maintaining an office or place of business and which concerns the affairs of such office or place of business......
the place where the office or place of business is located;
ii. a claim for the purpose of claiming monetary payment of bills or checks and a claim incidental thereto......
the place for payment of the bills and checks.

Old Code of Civil Procedure (Japan, 1890, last amendment: 1992)
**Article 431** (Jurisdictional court)
1. The summary procedure shall be subject to the exclusive jurisdiction of the summary court of the place where the debtor has his general forum or to the jurisdictional summary court under the provisions of Article 9.
2. The summary procedure concerning claims on monetary payment of bills and cheques and on any incidental claims thereto shall be under the exclusive jurisdiction of the summary court of the preceding paragraph or of the summary court in the place of payment of bills or cheques.

**មាត្រា ៣២១.-** ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្ដីពីបណ្ដឹង

បញ្ញត្តិស្ដីពីបណ្ដឹង ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន លុះត្រាតែគ្មានភាពផ្ទុយនឹងលក្ខណៈរបស់ពាក្យសុំនោះ ។

(កំណត់)

មាត្រានេះមានគោលគំនិតដូចក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 384 ដែរ (ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ មាត្រា 432) ។ ទោះបីជានីតិវិធីដាស់តឿន គឺជានីតិវិធីសង្ខេបមួយក៏ដោយ ក៏នៅតែជាប្រភេទមួយក្នុងចំណោមនីតិវិធីនៃបណ្ដឹងដែរ ហេតុនេះហើយបានជាបញ្ញត្តិស្ដីពីបណ្ដឹងត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន លើកលែងតែករណីដែលមានភាពផ្ទុយនឹងលក្ខណៈនៃពាក្យសុំ ។

Code of Civil Procedure (Japan)
**Article 384** (*Mutatis mutandis* application of provisions relating to suit)
The provisions relating to a suit shall apply *mutatis mutandis* to the motion for demand for payment insofar as is not inconsistent with the nature thereof.

Old Code of Civil Procedure (Japan, 1890, last amendment: 1992)
**Article 432** (Motion for payment order)
In regard to a motion for payment order, the provisions relating to a suit shall apply *mutatis mutandis* insofar as they do not stand inconsistent with the nature thereof.

**មាត្រា ៣២២.-** ការលើកចោលនូវពាក្យសុំ

ក្នុងករណីដែលពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន មានភាពផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៣១៩ (ល័ក្ខខ័ណ្ឌនៃដីកាសម្រេចដាស់តឿន) ឬ មាត្រា ៣២០ (ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន) ខាងលើនេះ ឬ ក្នុងករណីដែលមានភាពច្បាស់លាស់ថា គ្មានមូលហេតុក្នុងការទាមទារ ដោយគិតអំពីខ្លឹមសារនៃពាក្យសុំទេ តុលាការត្រូវលើកចោល

ពាក្យសុំនេះ ដោយដីកាសម្រេច ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដែរ ចំពោះការទាមទារមួយភាគដែលមិនអាចចេញដីកាសម្រេចដាស់តឿនភាគនោះ ។

(កំណត់)

មាត្រានេះមានគោលគំនិតដូចក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 385 ដែរ (ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ មាត្រា 433) ។ ក្នុងករណីដែលពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿនមិនស្របច្បាប់ទេ តុលាការត្រូវលើកចោលពាក្យសុំនោះ ដោយដីកាសម្រេច ។ ចំពោះដីកាសម្រេចលើកចោលនេះ មិនអាចប្ដឹងតវ៉ាបានទេ ប៉ុន្តែ ម្ចាស់បំណុលអាចដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿនជាថ្មីទៀតបាន ។

Code of Civil Procedure (Japan)
**Article 385** (Dismissal of motion)
1. In case where a motion for a demand for payment contravenes the provisions of Article 382 or Article 383, or where it is clear that the claim therefor is groundless in view of the import of the motion, the motion shall be dismissed. The same shall apply to a part of a claim in cases where a demand for payment cannot be issued with regard to such part of the claim.
2. The disposition under the provisions of the preceding paragraph shall take effect when notice thereof is given in such a manner as may be deemed proper.
3. An objection against the disposition referred to in the preceding paragraph shall be raised within the peremptory term of one week of the day on which the notice thereof is given.
4. No appeal may made against a decision relating to the objection referred to in the preceding paragraph.

Old Code of Civil Procedure (Japan, 1890, last amendment: 1992)
**Article 433** (Turning down of the above motion)
1. In case a motion for payment order contravenes the provisions of Article 430 or the provisions concerning jurisdiction, or it is clear that the request therefor is groundless in view of the purport of the motion, the said motion shall be turned down. The same shall apply to a part of the claim in case the issuance of a payment order may not be executed with regard to a part of the claim.
2. No objection shall be filed against a ruling turning down the motion.

**មាត្រា ៣២៣.-** ការចេញដីកាសម្រេចដាស់តឿន ជាអាទិ៍

១- ដីកាសម្រេចដាស់តឿន ត្រូវចេញដោយមិនបាច់សួរកូនបំណុល ។

២- កូនបំណុលអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ទៅតុលាការដែលបានចេញដីកាសម្រេចនោះបាន ។

(កំណត់)

មាត្រានេះមានគោលគំនិតដូចក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 386 ដែរ (ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ មាត្រា 434) ។ ដីកាសម្រេចដាស់តឿននេះមានលក្ខណៈពិសេសមួយ មិនចាំបាច់ធ្វើការពិនិត្យនូវសិទ្ធិសារធាតុទេ គឺអាចសម្រេច ដោយមិនបាច់សាកសួរកូនបំណុលបាន ។ ប៉ុន្តែ ត្រូវធ្វើការធានាចំពោះកូនបំណុលដែលយល់ទាស់នឹងដីកាសម្រេចនោះ ហេតុនេះហើយ ត្រូវទទួលស្គាល់ការដាក់ពាក្យសុំតវ៉ាពីកូនបំណុល ដែលជាវិធីមួយដែលកូនបំណុលអាចផ្ទេរនីតិវិធីទៅនីតិវិធីនៃបណ្ដឹងធម្មតាដោយងាយស្រួល ។ កថាខណ្ឌទី ២ នៃមាត្រានេះ ទទួលស្គាល់មិនត្រឹមតែពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន មុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្នទេ គឺគេទទួលស្គាល់ពាក្យសុំតវ៉ាចំពោះដីកាសម្រេច

ដាស់តឿន ក្រោយការប្រកាសអនុវត្តដីកាសម្រេចដាស់តឿនជាបណ្តោះអាសន្នដែរ ។ ប្រសិនបើពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន មុនការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ត្រូវបានទទួលស្គាល់ថាស្របច្បាប់ នីតិវិធីនេះត្រូវផ្ទេរទៅបណ្តឹងធម្មតា ។ ក្នុងករណីនេះ ដីកាសម្រេចដាស់តឿន ត្រូវបាត់បង់នូវអានុភាពភ្លាមៗ ( មាត្រា ៣២៧ ( អានុភាពនៃពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន)) ហើយនីតិវិធីដាស់តឿនក៏ត្រូវបញ្ចប់ដែរ ។ ផ្ទុយទៅវិញ ចំពោះករណីដែលមានពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿននោះបានធ្វើឡើង ក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នវិញ ពាក្យសុំតវ៉ានោះរារាំងមិនឱ្យដីកាសម្រេចដាស់តឿននោះចូលជាស្ថាពរ ដោយផ្ទេរនីតិវិធីទៅបណ្តឹងធម្មតា ។ ក្នុងករណីនេះ តុលាការត្រូវសម្រេច ដោយសាលក្រមថាតើដីកាសម្រេចដាស់តឿននោះ បាត់បង់អានុភាព ឬ អត់ (មាត្រា ៣៣២ (សាលក្រមនៃបណ្តឹងដែលត្រូវបានផ្ទេរនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន)) ។

Code of Civil Procedure (Japan)
**Article 386** (Issue, etc., of demand for payment)
1. A demand for payment shall be issued without interrogating the obligor.
2. Against a demand for payment, the obligor may raise an objection to the demand before the summary court to which the court clerk who has issued such demand for payment belongs.

Old Code of Civil Procedure (Japan, 1890, last amendment: 1992)
**Article 434** (Examination unnecessary)
1. A payment order shall be issued without examination of the debtor.
2. The debtor may make an objection against a payment order.

**មាត្រា ៣២៤.-** ចំណុចដែលត្រូវសរសេរបញ្ជាក់ក្នុងដីកាសម្រេចដាស់តឿន

១- ដីកាសម្រេចដាស់តឿន ត្រូវសរសេរបញ្ជាក់នូវចំណុចដូចខាងក្រោមនេះ :

**ក-** ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

**ខ-** ដីកាសម្រេចដែលម្ចាស់បំណុលទាមទារឱ្យតុលាការចេញ និង អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារនេះ ។

**គ-** សេចក្តីបង្គាប់ឱ្យសងជាប្រាក់ដែលមានកំណត់នូវចំនួន ។

២- ក្នុងដីកាសម្រេចដាស់តឿននៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសរសេរបន្ថែមថា បើកូនបំណុលមិនបានដាក់ពាក្យប្តឹងតវ៉ាការដាស់តឿន ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ បន្ទាប់ពីបានទទួលការបញ្ជូននូវដីកាសម្រេចដាស់តឿននេះទេ នោះតុលាការត្រូវប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

(កំណត់)

មាត្រានេះមានគោលគំនិតដូចក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 387 ដែរ (ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ មាត្រា 435) ។ ប្រសិនបើដីកាសម្រេចដាស់តឿននោះភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នផងដែរ

នោះ ដីកាសម្រេចនោះនឹងក្លាយទៅជាលិខិតអនុវត្ត ហើយអាចអនុវត្តដោយបង្ខំបាន ។ ហេតុនេះហើយបានជាក្នុងមាត្រានេះ មានចែងយ៉ាងច្បាស់នូវចំណុចដែលត្រូវបញ្ជាក់ក្នុងដីកាសម្រេចដាស់តឿននោះ ។

Code of Civil Procedure (Japan)
**Article 387** (Matters to be included in demand for payment)
A demand for payment shall include the following matters and add the statement that a declaration of provisional execution shall be made upon a motion of the obligee if the obligor does not raise an objection to the demand within two weeks of the day on which the obligor receives the service of the demand for payment:
i. a statement that the payment referred to in Article 383 is ordered;
ii. the import and grounds of the claim;
iii. the parties and their legal representatives.

Old Code of Civil Procedure (Japan, 1890, last amendment: 1992)
**Article 435** (Matters to be entered in payment order)
In a payment order names of the parties, names of the legal representatives thereof and the purport of the claim and the ground therefor shall be stated, and the effect that in case the debtor does not raise an objection within two weeks from the day of service of the payment order, a declaration of provisional execution shall be made upon motion of the creditor shall be additionally noted.

**មាត្រា ៣២៥.-** ការបញ្ជូនដីកាសម្រេចដាស់តឿន

១- តុលាការត្រូវជូនដំណឹងអំពីដីកាសម្រេចដាស់តឿនទៅឱ្យម្ចាស់បំណុល ហើយត្រូវបញ្ជូនដីកាសម្រេចនោះ ទៅកូនបំណុលផងដែរ ។

២- ដីកាសម្រេចដាស់តឿននេះត្រូវមានអានុភាព នៅពេលដែលបានបញ្ជូនទៅដល់កូនបំណុល ។

៣- ប្រសិនបើមិនអាចបញ្ជូនដីកាសម្រេចដាស់តឿន ដោយសារគ្មានលំនៅឋាន ទីសំណាក់ ទីស្នាក់ការ ទីកន្លែងអាជីវកម្មរបស់កូនបំណុល ឬ លំនៅឋានរបស់អ្នកទទួលបន្ទុកភារកិច្ចការងារចម្បង នៅទីកន្លែងដែលម្ចាស់បំណុលបានរាយការណ៍ទេ តុលាការត្រូវជូនដំណឹងអំពីហេតុការណ៍នេះទៅម្ចាស់បំណុល ។ ក្នុងករណីនេះ ប្រសិនបើម្ចាស់បំណុលមិនបានរាយការណ៍អំពីទីកន្លែងដែលត្រូវបញ្ជូន ក្រៅពីទីកន្លែងដែលខ្លួនបានរាយការណ៍ពីមុន ក្នុងអំឡុងពេល ២ (ពីរ) ខែ ដោយគិតចាប់ពីថ្ងៃដែលម្ចាស់បំណុលទទួលដំណឹង ត្រូវចាត់ទុកថា ម្ចាស់បំណុលនោះបានដកពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿនវិញ ។

៤- អំឡុងពេលដែលបានកំណត់ក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ៣ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

(កំណត់)

មាត្រានេះមានគោលគំនិតដូចក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 388 (ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ មាត្រា 436) និង បទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា ២៣៤ កថាខណ្ឌទី ២ ។ ប្រសិនបើមិនអាចធ្វើការបញ្ជូនទៅបានទេ ម្ចាស់បំណុលត្រូវដកពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿនវិញ ។ វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ៣ ចែងថា ទោះបីជាម្ចាស់បំណុលមិនបានដកពាក្យសុំវិញក៏ដោយ ក៏ត្រូវចាត់ទុកថា ដកពាក្យសុំនោះដែរ ។

ជាគោលការណ៍ ភាគីអាចដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿនច្រើនដងបាន ។

ការបញ្ជូននៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះពុំមានរួមបញ្ចូលទាំងការបញ្ជូនតាមការផ្សាយជាសាធារណៈទេ ។ ក្នុងករណីដែលអាចបញ្ជូនតែតាមការផ្សាយជាសាធារណៈនេះ តុលាការពុំអាចចេញដីកាដាស់តឿនបានឡើយ ។

Code of Civil Procedure (Japan)
**Article 388** (Service of demand for payment)
1. A demand for payment shall be served on the obligor.
2. A demand for payment shall become effective when served on the obligor.
3. In cases where a demand for payment cannot be served because any of the obligor's domicile, residence, place of business or office or workplace do not exist at the place offered by the obligee, the court clerk shall give notice thereof to the obligee. In such cases, if within the peremptory term of two months of the day the obligee receives such notice the obligee does not offer a place, other than the place previously offered, at which the service shall be made, it shall be deemed that the obligee withdrew the motion for a demand for payment.

Old Code of Civil Procedure (Japan, 1890, last amendment: 1992)
**Article 436** (Service of payment order)
A payment order shall be served upon the both parties.

Rules of Civil Procedure (Japan)
**Article 234** (Service, etc., of demand for payment / The Code Article 388) (excerpt)
2. The court clerk shall, when a demand for payment has been issued, give notice of that fact to the obligee.

**មាត្រា ៣២៦.-** ការលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

១- ប្រសិនបើតុលាការយល់ឃើញថា ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន មិនស្របច្បាប់ទេ តុលាការត្រូវលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿននោះដោយដីកាសម្រេច ។

២- ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

(កំណត់)

មាត្រានេះមានគោលគំនិតដូចក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 394 ដែរ (ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ មាត្រា 441) ។ ប៉ុន្តែ ដើម្បីកុំឱ្យមានការច្រឡំរវាង "ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន" និង "ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន" ហើយដើម្បីឱ្យស្រួលយល់ផងដែរ យើងមានចែងផ្សេងពីគ្នា ។ មាត្រានេះចែងអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ។ ប្រសិនបើយល់ឃើញថា ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿននោះខុសច្បាប់ ទោះជាមុនការប្រកាសឱ្យអនុវត្តជាបណ្តោះ-អាសន្នក៏ដោយ ដែលបានធ្វើនៅក្រោយការប្រកាសក៏ដោយ ក៏តុលាការត្រូវលើកចោលពាក្យសុំនោះ ដោយដីកាសម្រេចដែរ ។ ហើយបើដីកាសម្រេចនោះចូលជាស្ថាពរ អានុភាពស្របច្បាប់នៃពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន មិនត្រូវកើតឡើងទេ ។

Code of Civil Procedure (Japan)
**Article 394** (Dismissal of objection to demand)
1. The summary court shall, upon deeming an objection to demand illegitimate, dismiss the objection too demand by ruling even in cases where the claim relating to the objection to demand falls under the jurisdiction of the district court.
2. An immediate *kokoku*-appeal may be made against the ruling referred to in the preceding paragraph.

Old Code of Civil Procedure (Japan, 1890, last amendment: 1992)
**Article 441** (Turning down of objection)
In case the summary court deems the objection illegal, it shall turn down the objection by ruling even if the claim belongs to the jurisdiction of the district court. An immediate *kokoku*-appeal may be made against this ruling.

**មាត្រា ៣២៧.-** អានុភាពនៃពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន

១- ប្រសិនបើមានពាក្យសុំតវ៉ាស្របច្បាប់ចំពោះដីកាសម្រេចដាស់តឿន នៅមុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ដីកាសម្រេចដាស់តឿននោះ ត្រូវបាត់បង់អានុភាពក្នុងទំហំនៃការតវ៉ានោះ ។

២- ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះការទាមទារដែលទាក់ទងនឹងការតវ៉ាចំពោះដីកាសម្រេចដាស់តឿន ត្រូវចាត់ទុកថា បានដាក់ពាក្យបណ្ដឹងទៅតុលាការដែលបានកំណត់នៅមាត្រា ៣២០ (ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន) នៃក្រមនេះ នៅពេលដែលមានពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ។ ក្នុងករណីនេះ ប្រាក់សោហ៊ុយសម្រាប់នីតិវិធីដាស់តឿន គឺជាផ្នែកមួយនៃប្រាក់ប្រដាប់ក្ដី ។

(កំណត់)

មាត្រានេះចែងអំពីអានុភាពនៃការតវ៉ាចំពោះដីកាសម្រេចដាស់តឿន មុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ។

កថាខណ្ឌទី ១ នៃមាត្រានេះ មានគោលគំនិតដូចក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 390 ដែរ (ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ មាត្រា 437) ។ ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន មុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ដែលស្របច្បាប់ ត្រូវលុបអានុភាពនៃដីកាសម្រេចដាស់តឿន ក្នុងទំហំនៃការតវ៉ានោះ ។ នីតិវិធីដាស់តឿនក៏ត្រូវចប់ដោយពាក្យសុំតវ៉ានោះដែរ ។

កថាខណ្ឌទី ២ នៃមាត្រានេះ មានគោលគំនិតដូចក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 395 ដែរ (ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ មាត្រា 442) ។ ប៉ុន្តែ ដើម្បីកុំឱ្យមានការច្រឡំរវាង "ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន" និង "ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន" ហើយដើម្បីឱ្យស្រួលយល់ផងដែរ ទើបយើងមានចែងផ្សេងពីគ្នា ។ មាត្រានេះចែងអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ។ បើមានពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលស្របច្បាប់ នីតិវិធីដាស់តឿននោះ នឹងផ្ទេរទៅនីតិវិធីនៃបណ្ដឹងធម្មតា ក្នុងទំហំនៃការតវ៉ានោះ ។

Code of Civil Procedure (Japan)
**Article 390** (Objection to demand before declaration of provisional execution)
Upon a legitimate objection to demand having been raised prior to a declaration of provisional execution, the demand for payment shall lose its effect to the extent of such objection.
**Article 395** (Transfer to litigation procedures due to objection to demand)
In cases where a legitimate objection to demand has been raised, with regard to a claim relating to the objection to demand, it shall be deemed that an action has been filed at the time when the motion for demand for payment was made with either, according to the value of the subject matter of the claim, the summary court to which the court clerk who issued the demand for payment belongs or the district court governing the location of such summary court. In such cases, the costs of the demand procedures shall constitute part of the court costs.

Old Code of Civil Procedure (Japan, 1890, last amendment: 1992)
**Article 437** (Objection raised before declaration of provisional execution)
In case a debtor has raised an objection before the declaration of provisional execution, the payment order shall lose its effect insofar as the said objection goes.
**Article 442** (Shifting to litigation procedure due to motion for objection)
1.In the event that a lawful objection has been filed against a payment order, a suit shall, as far as the claim against which an objection being pending is concerned, be deemed to have been instituted according to the price of object thereof to the summary court issuing the order, or the district court the jurisdiction of which covers the place of the summary court. In this case the costs of summary procedure incurred shall be made a part of the court costs.
2. In the event that a suit is deemed to have been instituted to the district court in accordance with the provisions of the preceding paragraph, the court clerk shall transmit the record of the case to the district court clerk without delay.

**មាត្រា ៣២៨.-** ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

១- ប្រសិនបើកូនបំណុលមិនបានដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ បន្ទាប់ពីថ្ងៃដែលបានទទួលការបញ្ជូនដីកាសម្រេចដាស់តឿន ឬបើដីកាសម្រេចដែលលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន មុនការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នបានចូលជាស្ថាពរ តុលាការត្រូវប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដោយកំណត់បញ្ជាក់បន្ថែមនូវប្រាក់សោហ៊ុយសម្រាប់នីតិវិធីដាស់តឿនលើដីកាសម្រេចដាស់តឿន ដោយឆន្ទានុសិទ្ធិ ។

២- ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ត្រូវបញ្ជាក់នៅក្នុងដីកាសម្រេចដាស់តឿន ហើយត្រូវបញ្ជូនទៅភាគី ។

៣- បញ្ញត្តិនៃមាត្រា ១៩៧ (ការបាត់បង់អានុភាពនៃការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន និង បដិទានស្ថានភាពដើម) និង កថាខណ្ឌទី ២ នៃមាត្រា ៣២៥ (ការបញ្ជូនដីកាសម្រេចដាស់តឿន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

មាត្រានេះចែងអំពីនីតិវិធីនៃការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដែលជាជំហានទី ២ នៃនីតិវិធីដាស់តឿន ។ មាត្រានេះ ឈរលើមូលដ្ឋាននៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 391 (ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ មាត្រា 438) ប៉ុន្តែ ខុសពីច្បាប់ជប៉ុនត្រង់ចំណុច "បើគ្មានពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ក្នុងអំឡុងដែលបានកំណត់មួយនោះ តុលាការត្រូវប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដោយឆន្ទានុសិទ្ធិរបស់ខ្លួន" ។ ជាធម្មតា ម្ចាស់បំណុលមិនមានព័ត៌មានគ្រប់គ្រាន់អំពីថ្ងៃដែលកូនបំណុលបានទទួលការបញ្ជូនដីកាសម្រេច ហើយប្រសិនបើម្ចាស់បំណុលត្រូវសួរបញ្ជាក់

ទៅតុលាការរៀងរាល់ពេល ថាតើអំឡុងពេលកំណត់ដែលអាចដាក់ពាក្យតវ៉ាចំពោះដីកាសម្រេចដាស់តឿន នៅមុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន បានកន្លងផុតហើយ ឬ អត់ នេះជាបន្ទុកមួយយ៉ាងធ្ងន់ចំពោះអ្នកនោះ ហេតុនេះហើយ មាត្រានេះចែងផ្សេងពីច្បាប់ជប៉ុន ។

<u>Code of Civil Procedure (Japan)</u>
**Article 391** (Declaration of provisional execution)
1. In cases where the obligor does not raise an objection to demand within two weeks of the day on which the obligor received the service of the demand for payment, the court clerk shall, upon motion of the obligee, add the costs of the procedure to the demand for payment and declare it provisionally executable. However, this shall not apply to cases where there has been an objection to demand prior to the declaration.
2. The declaration of provisional execution shall be entered in the demand for payment, and it shall be served on the parties.
3. The provisions of Article 385, paragraph 2 and 3 shall apply *mutatis mutandis* to a disposition dismissing the motion referred to in paragraph 1 and an objection against it.
4. An immediate *kokoku*-appeal may ne made against a decision relating to the objection referred to in the preceding paragraph.
5. The provisions of Article 260, and Article 388, paragraph 2 shall apply *mutatis mutandis* to the declaration of provisional execution referred to in paragraph 1.

<u>Old Code of Civil Procedure (Japan, 1890, last amendment: 1992)</u>
**Articled 438** (Declaration of provisional execution)
1. In cases the debtor does not raise an objection within two weeks from the day of service of a payment order, the court shall, upon motion of the creditor, declare provisional execution by additionally stating in the payment order the amount of cost for the procedure: Provided that this shall not apply in case an objection is raised prior to the said declaration.
2. The declaration of provisional execution shall be entered in the original and exemplification of a payment order and the said exemplification shall be served upon parties.
3. An immediate *kokoku*-appeal may be filed against a ruling turning down a motion for provisional execution.

**មាត្រា ៣២៩.**- ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះ-អាសន្ន

១- ពាក្យសុំតវ៉ាការដាស់តឿននៃកថាខណ្ឌទី ២ មាត្រា ៣២៣ (ការចេញដីកាសម្រេចដាស់តឿន ជាអាទិ៍) នៃក្រមនេះ ចំពោះដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ត្រូវធ្វើនៅក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ ក្រោយពីបានទទួលការបញ្ជូនដីកាសម្រេចដាស់តឿននោះ ។

២- អំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

(កំណត់)

មាត្រានេះមានគោលគំនិតដូចក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 393 ដែរ (ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ មាត្រា 440) ។ មាត្រានេះចែងថា ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនអាចធ្វើបានតែក្នុងអំឡុងពេលដែលមានកំណត់ច្បាស់លាស់ ហើយប្រសិនបើហួសកំណត់ គេមិនអាចដាក់ពាក្យសុំតវ៉ាបានទេ ។ ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន នៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន នឹងរារាំងមិនឱ្យដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ននោះ ចូលជាស្ថាពរ ។

<u>Code of Civil Procedure (Japan)</u>

**Article 393** (Objection to demand after declaration of provisional execution)
If the peremptory term of two weeks elapsed from the day on which service of the demand for payment accompanied by a declaration of provisional execution has been received, the obligor may not raise an objection to demand against such demand for payment.

Old Code of Civil Procedure (Japan, 1890, last amendment: 1992)
**Articled 440** (Objection post declaration of provisional execution)
1.In case two weeks have passed since the day of service of a payment order to which declaration or provisional execution had been attached, the debtor shall not raise an objection against the said objection.
2. The period as mentioned in the preceding paragraph shall be peremptory.

**មាត្រា ៣៣០.-** ការលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន

១- ប្រសិនបើតុលាការយល់ឃើញថា ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ននោះ មិនស្របច្បាប់ទេ តុលាការត្រូវលើកចោលពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿននោះ ដោយដីកាសម្រេច ។

២- ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

(កំណត់)

មាត្រានេះមានគោលគំនិតដូចក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 394 ដែរ (ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ មាត្រា 441) ។ ប៉ុន្តែ ដើម្បីកុំឱ្យមានការច្រឡំរវាង "ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន នៅមុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន" និង "ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន នៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះ-អាសន្ន" ទើបយើងមានចែងផ្សេងពីគ្នា ។ មាត្រានេះចែងអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿននៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ។

ករណីដែលពាក្យសុំតវ៉ាការដាស់តឿនមិនត្រឹមត្រូវតាមច្បាប់ មានដូចជាករណីដែលដាក់ពាក្យសុំតវ៉ា ក្រោយពេលដែលផុតអំឡុងពេលដែលត្រូវដាក់ពាក្យសុំ ដូចកំណត់នៅមាត្រា ៣២៩ (ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន) ។

Code of Civil Procedure (Japan)
**Article 394** (Dismissal of objection to demand) > see the note for Article 326

Old Code of Civil Procedure (Japan, 1890, last amendment: 1992)
**Articled 441** (Turning down of objection) > see the note for Article 326

**មាត្រា ៣៣១.-** ការផ្ទេរនីតិវិធីដាស់តឿនទៅនីតិវិធីនៃបណ្ដឹង ដោយពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន

ប្រសិនបើមានពាក្យសុំតវ៉ាស្របច្បាប់ចំពោះដីកាសម្រេចដាស់តឿន នៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះ-

អាសន្ន ការទាមទារដែលទាក់ទងនឹងការតវ៉ាចំពោះដីកាសម្រេចដាស់តឿន ត្រូវចាត់ទុកថា បានដាក់ពាក្យបណ្ដឹងទៅតុលាការដែលបានចេញដីកាសម្រេចដាស់តឿននោះ នៅពេលដែលមានពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ។ ក្នុងករណីនេះ ប្រាក់សោហ៊ុយសម្រាប់នីតិវិធីដាស់តឿន គឺជាផ្នែកមួយនៃប្រាក់ប្រដាប់ក្ដី ។

(កំណត់)

មាត្រានេះមានគោលគំនិតដូចក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 395 ដែរ (ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ មាត្រា 442) ។ ប៉ុន្តែ ដើម្បីកុំឱ្យមានការច្រឡំរវាង "ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន នៅមុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន" និង "ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន នៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន" ទើបយើងមានចែងផ្សេងពីគ្នា ។ មាត្រានេះចែងអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន នៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ។ បើមានពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលស្របច្បាប់ នីតិវិធីដាស់តឿននោះ នឹងផ្ទេរទៅនីតិវិធីនៃបណ្ដឹងធម្មតា ក្នុងទំហំនៃការតវ៉ានោះ ។ នៅក្នុងករណីនេះ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនឹងចាប់ផ្ដើមឡើង ។

Code of Civil Procedure (Japan)
**Article 395** (Dismissal of objection to demand) > see the note for Article 327

Old Code of Civil Procedure (Japan, 1890, last amendment: 1992)
**Articled 442** (Turning down of objection) > see the note for Article 327

**មាត្រា ៣៣២.-** សាលក្រមនៃបណ្ដឹងដែលត្រូវបានផ្ទេរ នៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន

១- ប្រសិនបើសាលក្រមនៃបណ្ដឹងដែលត្រូវបានផ្ទេរ តាមបញ្ញត្តិនៃមាត្រា ៣៣១ (ការផ្ទេរនីតិវិធីដាស់តឿនទៅនីតិវិធីនៃបណ្ដឹង ដោយពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន) ខាងលើនេះ ស្របគ្នានឹងដីកាសម្រេចដាស់តឿននោះ តុលាការត្រូវទទួលស្គាល់នូវដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ក្នុងសាលក្រមនេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលនីតិវិធីដាស់តឿនត្រូវបានធ្វើឡើងដោយខុសច្បាប់ ។

២- ក្នុងសាលក្រមនៃបណ្ដឹងដែលត្រូវបានផ្ទេរ តាមបញ្ញត្តិនៃមាត្រា ៣៣១ (ការផ្ទេរនីតិវិធីដាស់តឿនទៅនីតិវិធីនៃបណ្ដឹង ដោយពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន) នៃក្រមនេះ តុលាការត្រូវលុបចោលនូវដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន លើកលែងតែក្នុងករណីដែលតុលាការទទួលស្គាល់នូវដីកាសម្រេចដាស់តឿន ដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន អត់មានមាត្រាណាដែលចែងដូចនេះទេ ។ ប៉ុន្តែ គេច្រើនទទួលស្គាល់យោបល់នេះ ហើយតុលាការកំពូលក៏យល់ដូចគ្នា ក្នុងករណីយុត្តិសាស្ត្រ (សាលដីកា ថ្ងៃទី 16 ខែ មិថុនា ឆ្នាំ 1961) ។ មាត្រានេះ ចែងច្បាស់លាស់ថា នៅពេលចេញសាលក្រមចំពោះបណ្តឹងដែលបានផ្ទេរទៅនីតិវិធីនៃបណ្តឹងធម្មតានោះ តុលាការត្រូវ វិនិច្ឆ័យអំពីដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសអនុវត្តជាបណ្តោះអាសន្ន ។

**មាត្រា ៣៣៣.-** អានុភាពនៃដីកាសម្រេចដាស់តឿន

ប្រសិនបើគ្មានពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ឬ ប្រសិនបើដីកាសម្រេចលើកចោលនូវពាក្យសុំតវ៉ា ចំពោះដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាស ឱ្យអនុវត្តជាបណ្តោះអាសន្ន បានចូលជាស្ថាពរ ដីកាសម្រេចដាស់តឿននោះនឹងមានអានុភាពដូចសាលក្រមស្ថាពរដែរ ។

(កំណត់)

មាត្រានេះមានគោលគំនិតដូចក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា 396 ដែរ (ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនចាស់ មាត្រា 443) ។ ប្រសិនបើគ្មានពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្ត ជាបណ្តោះអាសន្ន ឬ ប្រសិនបើដីកាសម្រេចលើកចោលនូវពាក្យសុំតវ៉ា ចំពោះដីកាសម្រេចដាស់តឿន បានចូលជាស្ថាពរ នោះនីតិវិធីដាស់តឿនត្រូវបញ្ចប់ ហើយដីកាសម្រេចដាស់តឿនក៏ត្រូវចូលជាស្ថាពរ ហេតុដូច្នេះ មាត្រានេះទទួលស្គាល់ អានុភាពនៃដីកាសម្រេចដាស់តឿនដែលបានចូលជាស្ថាពរ ដូចសាលក្រមស្ថាពរ ។

Code of Civil Procedure (Japan)
**Article 396** (Effect of demand for payment)
If no objection to demand has been raised against a demand for payment accompanied by a declaration of provisional execution, or a ruling dismissing an objection to demand has become final and binding, the demand for payment shall have the same effect as that of a final and biding judgment.

Old Code of Civil Procedure (Japan, 1890, last amendment: 1992)
**Articled 443** (Payment order becoming irrevocable)
In case no objection has been raised against a payment order accompanying declaration of provisional execution or a ruling turning down the objection has become irrevocable, the said payment order shall have the same effect as that of a judgment irrevocable.

# គន្ថីទី ៦ ការអនុវត្តដោយបង្ខំ

## ជំពូកទី ១ បទប្បញ្ញត្តិទូទៅ

### ផ្នែកទី ១ គោលគំនិត

**មាត្រា ៣៣៤.-** គោលគំនិត

បុគ្គលដែលមានសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងទៀត អាចទាមទារឱ្យសម្រេចសិទ្ធិនោះដោយការអនុវត្តដោយបង្ខំ តាមបញ្ញត្តិនៃគន្ថីនេះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង ។(1)(2)(3)

(កំណត់)

(1) "ច្បាប់ផ្សេង" មានន័យថាជា"ច្បាប់ក្រៅពីក្រមនីតិវិធីរដ្ឋប្បវេណីនេះ" មិនមែនមានន័យថាជា "ច្បាប់ផ្សេងទៀត" ដែលចែងអំពីសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគដែលភាគីទាមទារឱ្យសម្រេចដោយការអនុវត្តដោយបង្ខំ នៅឃ្លាដើមត្រង់ចំណុច "ក្រមរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងទៀត" តែប៉ុណ្ណោះទេ ។

(2) សូមមើលច្បាប់ស្តីពីការអនុវត្តដោយបង្ខំនៃប្រទេសបារាំង មាត្រា 1 វាក្យខណ្ឌទី 1 (ច្បាប់ចុះនៅថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ១៩៩១) ។

(3) ក្នុងករណីដែលសិទ្ធិទាមទារដែលត្រូវបានអះអាងក្នុងបណ្តឹងរដ្ឋប្បវេណីដែលភ្ជាប់នឹងរឿងក្តីព្រហ្មទណ្ឌ ត្រូវបានទទួលស្គាល់ នៅក្នុងសាលក្រម ឬ សាលដីកាព្រហ្មទណ្ឌ ការអនុវត្តដោយបង្ខំនូវសិទ្ធិទាមទារនោះក៏ត្រូវធ្វើតាមគន្ថីទី ៦ នេះដែរ ។ សូមមើលកំណត់នៃមាត្រា ៣៥០ (លិខិតអនុវត្ត) ។ ការរក្សាការពារសិទ្ធិទាមទារដែលត្រូវបានទទួលស្គាល់នៅក្នុងបណ្តឹងរដ្ឋប្បវេណីដែលភ្ជាប់នឹងរឿងក្តីព្រហ្មទណ្ឌ ក៏ត្រូវធ្វើតាមគន្ថីទី ៧ (ការចាត់ចែងរក្សាការពារ) នៃក្រមនេះដែរ ។

<u>Procédure civiles d'execution (Loi n° 91-650 du 9 juillet 1991) (France)</u>
Article 1
Tout créancier peut, dans les conditions prévues par la loi, contraindre son débiteur défaillant à exécuter ses obligations à son égard.
Tout créancier peut pratiquer une mesure conservatoire pour assurer la sauvegarde de ses droits.
L'exécution forcée et le mesures conservatoire ne sont pas applicables aux personnes qui bénéficient d'une immunité d'exécution.

**មាត្រា ៣៣៥.-** ការអនុវត្តដូចគ្នា តាមបញ្ញត្តិពីគន្ថីទី ២ ដល់ គន្ថីទី ៤

បញ្ញត្តិពីគន្ថីទី ២ ដល់ គន្ថីទី ៤ នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការអនុវត្តដោយបង្ខំ

លើកលែងតែមានបញ្ញត្តិពិសេស ។

(កំណត់)

ក្នុងចំណោមបញ្ញត្តិនៅក្នុងគន្ថីទី ២ (នីតិវិធីនៃការជម្រះក្តីលើកទី ១) គន្ថីទី ៣ (បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់) និង គន្ថីទី ៤ (ការជំនុំជម្រះសាជាថ្មី) មានបញ្ញត្តិដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តដោយបង្ខំ តាមលក្ខណៈនៃបញ្ញត្តិទាំងនោះ ។ ហេតុដូច្នេះ មាត្រានេះចែងថា បញ្ញត្តិពីគន្ថីទី ២ ដល់ គន្ថីទី ៤ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការអនុវត្តដោយបង្ខំ លើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងគន្ថីទី ៦ នេះ ។ ឧទាហរណ៍នៃបញ្ញត្តិដែលត្រូវយកមកអនុវត្តដូចគ្នា មានដូចជា វាក្យខណ្ឌទី ១ កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ នៃមាត្រា ១១១ (ចំណុចសារធាតុនៃកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) ដែលចែងអំពីភាពមិនចាំបាច់ក្នុងការធ្វើការទាញហេតុផលដោយផ្ទាល់មាត់នៅក្នុងនីតិវិធីនៃដីកាសម្រេច និង ការសួរ ហើយនិង មាត្រា ២១៣ (ការជូនដំណឹងអំពីដីកាសម្រេច) ស្តីពីការជូនដំណឹងអំពីដីកាសម្រេច និង ជំពូកទី ៨ នៃគន្ថីទី ២ ស្តីពីកាលបរិច្ឆេទ អំឡុងពេល និង ការបញ្ជូន ជាដើម ។

## ផ្នែកទី ២ ស្ថាប័នអនុវត្ត

**មាត្រា ៣៣៦.-** ស្ថាប័នអនុវត្ត

១- ការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយស្ថាប័នអនុវត្ត តាមពាក្យសុំរបស់ភាគី ។

២- ស្ថាប័នអនុវត្ត គឺតុលាការអនុវត្ត ឬ អាជ្ញាសាលា ។

៣- សាលាដំបូងដែលត្រូវអនុវត្តដោយបង្ខំ តាមបញ្ញត្តិនៃគន្ថីនេះ គឺជាតុលាការអនុវត្ត ។

៤- ការសម្រេចសេចក្តីអំពីបណ្តឹងឧបាស្រ័យ ចំពោះការចាត់ចែងការអនុវត្តដែលធ្វើឡើងដោយអាជ្ញាសាលា ត្រូវធ្វើឡើងដោយសាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ ។

(កំណត់)

មាត្រានេះចែងប្រហាក់ប្រហែលនឹងច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 2 និង មាត្រា 3 ។

កថាខណ្ឌទី ២ នៃមាត្រានេះចែងថា ស្ថាប័នអនុវត្តមាន ២ ប្រភេទ គឺ តុលាការអនុវត្ត និង អាជ្ញាសាលា ។

អាជ្ញាសាលា គឺជាស្ថាប័នតុលាការដាច់ដោយឡែកមួយ ដែលទទួលបន្ទុកការងារអនុវត្តដោយបង្ខំ និង ការងារពាក់ព័ន្ធ ហើយដែលមានមន្ត្រីរាជការដែលមានឈ្មោះថា អាជ្ញាសាលា ។ អាជ្ញាសាលា គឺជាស្ថាប័នអនុវត្តមួយឯករាជ្យ មិនមែនជាស្ថាប័នជំនួយនៃតុលាការអនុវត្តទេ ។

ដើម្បីឱ្យមានមូលដ្ឋាននៃមាត្រានេះដែលចែងថា អាជ្ញាសាលាជាស្ថាប័នអនុវត្ត យើងត្រូវតាក់តែងច្បាប់ដោយឡែកមួយ ស្តីពីអាជ្ញាសាលា ដែលកំណត់អំពីវិធីជ្រើសរើសអាជ្ញាសាលាដែលជាមន្ត្រីរាជការ ប្រព័ន្ធប្រាក់បៀវត្ស សិទ្ធិអំណាចវិន័យការងារ និង លក្ខណៈផ្សេងៗដែលត្រូវការជាចាំបាច់ថែមទៀត ។ ចំពោះរបបអាជ្ញាសាលា (មន្ត្រីអនុវត្ត) នៅប្រទេសជប៉ុនវិញ បានបង្កើតឡើងដោយយកគំរូមកពីបារាំង ហើយក្រោយមក គេបានរំលាយរបបការិយាល័យអាជ្ញា-សាលានេះ ដោយបញ្ចូលទៅក្នុងតុលាការវិញ ម្យ៉ាងទៀត គេបានបំបាត់នូវគោលការណ៍ដែលម្ចាស់បំណុលដែលដាក់ពាក្យសុំឱ្យអនុវត្ត អាចជ្រើសរើសអាជ្ញាសាលាដោយសេរី ដោយពង្រឹងនូវលក្ខណៈនៃមន្ត្រីរាជការ (ប៉ុន្តែ គេនៅតែរក្សាទុកនូវរបបទទួលកម្រៃចាត់ចែងការងារជំនួសប្រាក់បៀវត្ស) ។ ក្រមនេះបានបង្កើតឡើង ដោយយករបបអាជ្ញាសាលាជប៉ុនជាគំរូ ។

តុលាការដែលអនុវត្តកិច្ចការដែលបានកំណត់ក្នុងកថាខណ្ឌទី ៤ ក៏ច្បាប់ជប៉ុនហៅថា តុលាការអនុវត្តដែរ ។ ប៉ុន្តែក្នុងករណីនេះ តុលាការមិនមែនជាស្ថាប័នទទួលបន្ទុកអនុវត្តដោយបង្ខំនោះទេ ហេតុនេះហើយ ដើម្បីឱ្យបានច្បាស់លាស់ គឺមិនប្រើពាក្យតុលាការអនុវត្តទេ ។

ម្យ៉ាងទៀត ពាក្យ "ការចាត់ចែងការអនុវត្ត" ដែលមានក្នុងគន្លឹះនេះ មាននិយមន័យទូលំទូលាយណាស់ គឺសកម្មភាពនៃស្ថាប័នអនុវត្តដើម្បីធ្វើនីតិវិធីអនុវត្ត ដូចជាការរឹបអូស ការប្តូរជាប្រាក់ ការចែកចំណែក ជាដើម ហើយក្រៅពីនេះ រាប់បញ្ចូលដីកាសម្រេចលើកចោលពាក្យសុំឱ្យអនុវត្ត ជាដើម ព្រមទាំងអំពើផ្សេងៗក្រៅពីការសម្រេចសេចក្តីផងដែរ ។

Civil Execution Act (Japan)
**Article 2** (Execution authority)
Upon motion, civil execution shall be carried out either by the court or by the execution officer.
**Article 3** (Execution court)
With regard to civil execution carried out by the court, the execution court shall be the court which is to make the disposition concerning the execution according to the provisions of this Act, and with regard to the disposition concerning the execution made by the execution officer, the district court to which such execution officer belongs shall be the execution court.

**មាត្រា ៣៣៧.-** ការសម្រេចសេចក្តីរបស់តុលាការអនុវត្ត ជាអាទិ៍

១- ការសម្រេចសេចក្តីរបស់តុលាការអនុវត្ត ត្រូវធ្វើឡើងដោយដីកាសម្រេច ។

២- បើយល់ឃើញថាចាំបាច់ នៅពេលចាត់ចែងធ្វើការអនុវត្ត តុលាការអនុវត្តអាចសួរជនដែលទាក់ទងនឹងផលប្រយោជន៍ ឬ ជនផ្សេងទៀតដែលពាក់ព័ន្ធបាន ។

៣- បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសាលាដំបូងត្រូវសម្រេចសេចក្តីអំពីឧបាស្រ័យ ចំពោះការចាត់ចែងការអនុវត្តដែលធ្វើឡើងដោយអាជ្ញាសាលា ។

(កំណត់)

មាត្រានេះចែងប្រហាក់ប្រហែលនឹងច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 4 និង មាត្រា 5 ។

នីតិវិធីនៃដីកាសម្រេច គឺជានីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់តាមឆន្ទៈស្ម័គ្រចិត្ត ហេតុដូច្នេះ តុលាការអាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់ក៏បាន ឬ មិនធ្វើក៏បានដែរ ។ ក្នុងករណីដែលមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចសួរភាគីបាន ។ សូមមើលមាត្រា ១១៤ (ភាពចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់) ។ កថាខណ្ឌទី ២ នៃមាត្រា ៣៣៧ នេះ ពង្រីកវិសាលភាពនៃជនដែលតុលាការអាចសួរបាន ដល់តុលាការអនុវត្តអាចសួរជនដែលទាក់ទងនឹងផលប្រយោជន៍ ឬ ជនដែលពាក់ព័ន្ធ ។

Civil Execution Act (Japan)
**Article 4** (Voluntary oral argument)
A decision of the execution court may be rendered without resorting to oral argument.
**Article 5** (Examination)
The execution court may, if it deems necessary when making disposition concerning execution, examine an interested person or other witnesses.

**មាត្រា ៣៣៨.-** ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍

១- ប្រសិនបើអាជ្ញាសាលាជួបប្រទះនឹងការប្រឆាំងនៅពេលបំពេញមុខនាទីរបស់ខ្លួន អាជ្ញាសាលានោះអាចប្រើកម្លាំង ឬ អាចសុំជំនួយពីនគរបាល ឬ កងកម្លាំងផ្សេងទៀតដែលមានសមត្ថកិច្ច ដើម្បីបំបាត់នូវការប្រឆាំងនោះបាន ។

២- ប្រសិនបើអ្នកក្រៅពីអាជ្ញាសាលាដែលបំពេញមុខនាទីពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ តាមការបង្គាប់របស់តុលាការអនុវត្ត ជួបប្រទះនឹងការប្រឆាំងនៅពេលបំពេញមុខនាទីរបស់ខ្លួន អ្នកនោះអាចសុំជំនួយពីអាជ្ញាសាលាបាន ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 6 ។

"អ្នកក្រៅពីអាជ្ញាសាលាដែលបំពេញមុខនាទីពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ តាមការបង្គាប់របស់តុលាការអនុវត្ត" ឧទាហរណ៍ មានដូចជា អ្នករក្សានាវាដែលត្រូវបានជ្រើសតាំងក្នុងការលក់ដេញថ្លៃនាវានោះដោយបង្ខំ ជាដើម ។ មាត្រា ៣៣៩ (អ្នកសង្កេតការណ៍) ដល់ មាត្រា ៣៤១ (ការយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណ ជាអាទិ៍) ដែលមានបន្ទាប់ពីនេះក៏ដូចគ្នាដែរ ។

អាជ្ញាសាលាដែលត្រូវបានសុំឱ្យជួយ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រានេះ អាចសុំជំនួយបន្តទៅនគរបាល តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ទៀតបាន ។

Civil Execution Act (Japan)
**Article 6** (Insuring performance; use of force)
1. In cases where an execution officer encounters resistance in performing official duties, the execution officer may apply force or demand police assistance in order to eliminate such resistance.
2. A person other than an execution officer who performs duties related to civil execution by virtue of an order of the execution court, may demand the assistance of an execution officer, if such person encounters resistance when performing official duties.

**មាត្រា ៣៣៩.-** អ្នកសង្កេតការណ៍

នៅពេលចូលទៅទីកន្លែងរស់នៅដើម្បីបំពេញមុខនាទីរបស់ខ្លួន បើមិនបានជួបនឹងអ្នកចម្បងនៃទីកន្លែងរស់នៅ ឬ អ្នកតំណាងរបស់អ្នកនោះ ឬ ញាតិនៅជាមួយឬអ្នកបម្រើឬអ្នកផ្សេងដែលធ្វើការនៅទីនោះដែលមានការយល់ដឹងសមរម្យទេ អាជ្ញាសាលា ឬ អ្នកក្រៅពីអាជ្ញាសាលាដែលបំពេញមុខនាទីពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ តាមការបង្គាប់របស់តុលាការអនុវត្ត ត្រូវឱ្យមានវត្តមានមន្ត្រីឃុំ សង្កាត់ មន្ត្រីនគរបាល ឬ អ្នកដទៃទៀតដែលអាចទទួលស្គាល់ថាជាសាក្សីសមរម្យ ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអាជ្ញាសាលាប្រើកម្លាំង ឬ បានទទួលជំនួយពីនគរបាល ឬ កងកម្លាំងផ្សេងទៀតដែលមានសមត្ថកិច្ច តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) នៃក្រមនេះ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 7 ។

Civil Execution Act (Japan)
**Article 7** (Witness)
In cases where an execution officer or a person performing duties related to civil execution by virtue of an order of the execution court (hereinafter referred to as "an execution officer or the like") does not encounter the principal of the dwelling or a representative of such principal or some relative with whom such principal resides or a servant or employee of such principal who can reasonably act on the principal's behalf, when entering a dwelling to perform official duties, such execution officer or the like must have an official of the city, town, or village, or policeman or any other person deemed proper as a witness be present. The same shall apply to cases where the execution officer uses force or demands the assistance of the police according to the provisions of paragraph 1 of the preceding Article.

**មាត្រា ៣៤០.-** ការអនុវត្តនៅថ្ងៃសម្រាក ឬ ពេលយប់

១- អាជ្ញាសាលា ឬ អ្នកក្រៅពីអាជ្ញាសាលាដែលបំពេញមុខនាទីពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ តាមការបង្គាប់របស់តុលាការអនុវត្ត ត្រូវទទួលការអនុញ្ញាតពីសាលាដំបូងដែលខ្លួនស្ថិតនៅ ឬ តុលាការអនុវត្តដែលចេញការបង្គាប់ ដើម្បីចូលទៅបំពេញមុខនាទីក្នុងទីកន្លែងរស់នៅ នៅថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សម្រាកដែលច្បាប់ ឬ បទដ្ឋានគតិយុត្ត បានកំណត់ ឬ ពីម៉ោងប្រាំមួយល្ងាច ដល់ម៉ោងប្រាំមួយព្រឹកនៃថ្ងៃបន្ទាប់ ។

២- នៅពេលបំពេញមុខនាទីរបស់ខ្លួន អាជ្ញាសាលា ឬ អ្នកក្រៅពីអាជ្ញាសាលាដែលបំពេញមុខនាទីពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ តាមការបង្គាប់របស់តុលាការអនុវត្ត ត្រូវបង្ហាញលិខិតដែលបញ្ជាក់ថា ខ្លួនបានទទួលការអនុញ្ញាត តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 8 ។ មាត្រានេះកំណត់ថា ក្នុងករណីចាំបាច់ អាជ្ញាសាលា ឬ អ្នកក្រៅពីអាជ្ញាសាលា ដែលបំពេញមុខនាទីពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ តាមការបង្គាប់របស់តុលាការនៃការអនុវត្ត អាចចុះបំពេញមុខនាទីរបស់ខ្លួន នៅពេលយប់ ឬ នៅថ្ងៃសម្រាកបាន ។ តុលាការត្រូវត្រួតពិនិត្យឱ្យបានច្បាស់មុននឹងអនុញ្ញាតឱ្យអនុវត្ត ដោយពិចារណាលើស្ថានភាពដែលមិនអាចអនុវត្តបាននៅពេលថ្ងៃ ឬ ថ្ងៃធ្វើការ ។ ការចែងបែបនេះ មិនមែនជាការបំពានលើសិទ្ធិបុគ្គលឡើយ ដោយហេតុថា នេះជាការធានាផលប្រយោជន៍ស្របច្បាប់របស់ម្ចាស់បំណុលនៃការអនុវត្ត ។

Civil Execution Act (Japan)
**Article 8** (Execution; holiday or night)
1. An execution officer or the like must obtain permission form the execution court in order to enter a dwelling to perform official duties on Sunday or any other holiday or at any time between 7 p.m. and 7 a.m.
2. When performing official duties, an execution officer or the like must present documents which prove that permission has been granted according to the provision of the preceding paragraph.

## មាត្រា ៣៤១.- ការយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណ ជាអាទិ៍

នៅពេលបំពេញមុខនាទីរបស់ខ្លួន អាជ្ញាសាលា ឬ អ្នកក្រៅពីអាជ្ញាសាលាដែលបំពេញមុខនាទីពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ តាមការបង្គាប់របស់តុលាការអនុវត្ត ត្រូវយកតាមខ្លួននូវលិខិតដែលបញ្ជាក់អត្តសញ្ញាណ ឬ លក្ខណសម្បត្តិរបស់ខ្លួន ហើយត្រូវបង្ហាញលិខិតនេះ ចំពោះជនដែលទាក់ទងនឹងផលប្រយោជន៍ បើជននោះទាមទារ ។

(កំណត់)

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 9 ។

គោលបំណងនៃមាត្រានេះ គឺការបង្ការទប់ស្កាត់នូវការក្លែងបន្លំធ្វើជាអ្នកអនុវត្ត ។

Civil Execution Act (Japan)
**Article 9** (Certificate of status)
When performing official duties, the execution officer or the like must have in his possession documents which prove his status or qualifications and must present such documents if an interested person so demands.

## មាត្រា ៣៤២.- ការស្នើសុំជំនួយពីក្រសួងមានសមត្ថកិច្ច

ក្នុងករណីដែលមានភាពចាំបាច់ក្នុងការអនុវត្តដោយបង្ខំ តុលាការអនុវត្តអាចស្នើសុំជំនួយពីក្រសួង ឬ ស្ថាប័នដែលមានសមត្ថកិច្ចបាន ។

(កំណត់)

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 18 កថាខណ្ឌទី 1 ។

មាត្រានេះ ចែងអំពីការស្នើសុំជំនួយឧបត្ថម្ភពីក្រសួងមានសមត្ថកិច្ច មានន័យថា នៅពេលដែលតុលាការចង់ធ្វើការអនុវត្តដោយបង្ខំ ទៅលើវត្ថុ ឬ របស់អ្វីមួយ ក៏ប៉ុន្តែ វត្ថុ ឬ របស់ទាំងអស់នោះ វាទាក់ទិនទៅនឹងការចុះបញ្ជី ឬ ពន្ធជាដើម នោះតុលាការអាចស្នើសុំជំនួយពីស្ថាប័នដែលគ្រប់គ្រងកិច្ចការទាំងអស់នោះបាន ។

ឧទាហរណ៍ ចំពោះតម្លៃសារពើពន្ធលើរថយន្តដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំនោះ ជាដើម អាចមានករណីដែលតុលាការអនុវត្តស្នើសុំឱ្យក្រសួងដែលមានសមត្ថកិច្ចចេញលិខិតបញ្ជាក់តម្លៃសារពើពន្ធនោះ (សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 18 កថាខណ្ឌទី 2) ។

Civil Execution Act (Japan)
**Article 18** (Assistance of government office)
1. The execution court may, if it deems necessary for civil execution, demand the assistance of a government or public office.
2. In such cases, the execution court or execution officer may demand from the government or public office in charge of such affairs necessary certificates regarding taxes and/or any public imposts charged on the property which is the subject matter of the execution.
3. The provisions of the preceding paragraph shall apply mutatis mutandis to case where a person who intends to make a motion for civil execution requires such certificate in order to make the motion.

**មាត្រា ៣៤៣.-** បញ្ញត្តិពិសេសស្តីពីបណ្តឹងជំទាស់នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ

១- ទោះជាមានបញ្ញត្តិនៃមាត្រា ៣០៥ (ការផ្អាកអានុភាពនៃដីកាសម្រេចដើម) នៃក្រមនេះក៏ដោយ ក៏បណ្តឹងជំទាស់ដែលបានកំណត់នៅក្នុងគន្លឹះនេះ មិនត្រូវផ្អាកអានុភាពនៃដីកាសម្រេចដើមឡើយ ។

២- ក្នុងអំឡុងពេលរហូតដល់សេចក្តីសម្រេចអំពីបណ្តឹងជំទាស់មានអានុភាព តុលាការនៃបណ្តឹងជំទាស់អាចចេញដីកាសម្រេចដែលបានកំណត់នៅក្នុងចំណុចខាងក្រោមនេះបាន :

- **ក-** បង្គាប់ឱ្យផ្អាកអានុភាពនៃដីកាសម្រេចដើម ដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគ ។
- **ខ-** បង្គាប់ឱ្យផ្អាកនីតិវិធីនៃការអនុវត្តដោយបង្ខំមួយផ្នែក ឬ ទាំងមូល ដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគ ។

(កំណត់)

មាត្រានេះចែងដោយការសម្រួលនូវមាត្រា 10 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

ចំពោះដីកាសម្រេចរបស់តុលាការអនុវត្តស្តីពីនីតិវិធីនៃការអនុវត្តដោយបង្ខំ អាចប្តឹងជំទាស់ ដោយយកមូលហេតុថាខុសនឹងបញ្ញត្តិស្តីពីនីតិវិធី ។ បណ្តឹងជំទាស់អាចធ្វើឡើងបានតែក្នុងករណីដែលមានបញ្ញត្តថា អាចប្តឹងជំទាស់ តែប៉ុណ្ណោះ (មាត្រា ២៥៩ (ប្រភេទនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់) កថាខណ្ឌទី ២) ហេតុដូច្នេះ ចំពោះដីកាសម្រេចណាក្នុងនីតិវិធីអនុវត្តដោយបង្ខំ ដែលអាចធ្វើបាន មានចែងនីមួយៗក្នុងមាត្រាបន្ទាប់ពីនេះ ។

អ្នកដែលអាចប្តឹងជំទាស់បានគឺ ម្ចាស់បំណុលដែលដាក់ពាក្យសុំឱ្យអនុវត្ត កូនបំណុលដែលត្រូវបានទាមទារឱ្យអនុវត្ត និង ក្នុងករណីខ្លះជាតតិយជន (ឧទាហរណ៍ : តតិយជនដែលត្រូវបានហាមនូវសំណង ដោយសារដីកាសម្រេចរឹបអូស

សិទ្ធិលើបំណុល ជាដើម ) ។

ចំពោះនីតិវិធីធ្វើបណ្តឹងជំទាស់ សូមមើលពីមាត្រា ៣០១ ( របៀបប្តឹងជំទាស់) ទៅ ។

កថាខណ្ឌទី ១ នៃមាត្រានេះ គឺជាអញ្ញត្រកម្ម ( ករណីលើកលែង) នៃកថាខណ្ឌទី ១ នៃមាត្រា ៣០៥ ( ការផ្អាកអានុភាពនៃដីកាសម្រេចដើម) ។ ប្រសិនបើគ្រាន់តែដាក់ពាក្យបណ្តឹងជំទាស់ ហើយអានុភាពនៃដីកាសម្រេចដើមត្រូវបានផ្អាកនោះ នឹងអាចធ្វើឱ្យមានការប្រើបណ្តឹងជំទាស់នេះផ្តេសផ្តាស ក្នុងគោលបំណងពន្យារការអនុវត្តដោយបង្ខំ ។

ប៉ុន្តែ ម្យ៉ាងទៀត ប្រសិនបើទោះជាក្នុងករណីណាក៏ដោយ ក៏ការអនុវត្តដោយបង្ខំមិនត្រូវបានផ្អាកដែរ មានករណីខ្លះដែលគ្មានប្រយោជន៍ក្នុងការជួយដល់ភាគីដែលធ្វើបណ្តឹង ហេតុនេះហើយបានជា ក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ យើងចែងថា តុលាការអាចសម្រួល ដោយចេញដីកាសម្រេចជាបណ្តោះអាសន្នដើម្បីផ្អាកការអនុវត្តបាន ។

ម្យ៉ាងទៀត មិនត្រឹមតែចែងដូចក្នុងចំណុច **ក** នៃកថាខណ្ឌទី ២ តែប៉ុណ្ណោះទេ គឺត្រូវមានចំណុច **ខ** ផងដែរ ។ នេះគឺដោយសារតែ ឧទាហរណ៍ ក្នុងករណីដែលម្ចាស់បំណុលដែលទាមទារឱ្យចែកចំណែក ប្តឹងជំទាស់ចំពោះដីកាសម្រេចដែលលើកចោលការទាមទារឱ្យចែកចំណែក អានុភាពនៃដីកាសម្រេចនឹងផ្អាក តាមបញ្ញត្តិនៃចំណុច **ក** នៃកថាខណ្ឌទី ២ ខាងលើនេះបាន ប៉ុន្តែ ដោយសារតែបញ្ញត្តិនេះមិនផ្អាកនីតិវិធីអនុវត្តដោយបង្ខំទេ នោះបណ្តឹងជំទាស់គ្មានន័យ នៅពេលដែលការចែកចំណែកត្រូវបានចប់សព្វគ្រប់ ។ ហេតុនេះហើយបានជា ត្រូវចែងដូចចំណុច **ខ** ខាងលើនេះ ដើម្បីផ្អាកនូវនីតិវិធីនៃការអនុវត្តទាំងមូល ( ឬ នីតិវិធីចែកចំណែក) ។

Civil Execution Act (Japan)
**Article 10** (Kōkoku-appeal concerning execution)
1. Kōkoku-appeal concerning execution may only be filed against a decision regarding civil execution procedure in cases which specially provide therefor.
6. Until a decision of the kōkoku-appeal concerning execution becomes effective, the appellate court may order a stay of execution of the original decision or a stay of the whole or a part of the procedure of the civil execution either upon or without security being provided, or order continuation of such execution or procedure upon security being provided. During the time that the record of the case is kept in the original court, such court may also order such disposition.

## **មាត្រា ៣៤៤.-** ការតវ៉ាចំពោះការអនុវត្ត

១- ចំពោះការចាត់ចែងការអនុវត្តរបស់តុលាការអនុវត្ត ដែលមិនអាចប្តឹងជំទាស់បាន អាចតវ៉ាទៅតុលាការអនុវត្តបាន ។

២- ចំពោះការចាត់ចែងការអនុវត្តរបស់អាជ្ញាសាលា និង ការយឺតយ៉ាវ ឬ ការធ្វេសប្រហែសក្នុងការចាត់ចែងអនុវត្តនោះ អាចតវ៉ាទៅសាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅបាន ។

៣- បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៤៣ ( បញ្ញត្តិពិសេសស្តីពីបណ្តឹងជំទាស់នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានការតវ៉ាចំពោះការអនុវត្ត ។

( កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 11 ។

ការតវ៉ាចំពោះការអនុវត្ត គឺជាវិធីឧបាស្រ័យមួយទាមទារឱ្យតុលាការអនុវត្ត ឬ សាលាដំបូង កែតម្រូវនូវការចាត់ចែងការអនុវត្តដែលមិនអាចប្តឹងជំទាស់បាន ដោយអះអាងថាខុសនឹងបញ្ញត្តិស្តីពីនីតិវិធី (កថាខណ្ឌទី ១ នៃមាត្រានេះ) ។ អំឡុងពេលដែលអាចតវ៉ាបាននេះគ្មានកំណត់ទេ គឺ ធ្វើពេលណាក៏បានដែរ ឱ្យតែមានផលប្រយោជន៍ក្នុងការតវ៉ា ។ តាមធម្មតា ការតវ៉ានេះត្រូវធ្វើឡើង ក្រោយពេលធ្វើការចាត់ចែងដែលជាកម្មវត្ថុនៃការតវ៉ា ហើយមុនពេលបញ្ចប់នីតិវិធីនៃការអនុវត្តដែលមានការចាត់ចែងក្នុងនោះ ។

ការតវ៉ាចំពោះការអនុវត្ត គឺជាវិធីឧបាស្រ័យមួយដែលស្រួលធ្វើ និង រហ័សជាងបណ្តឹងជំទាស់ ។ ការតវ៉ា គឺជាការធ្វើឧបាស្រ័យទៅតុលាការថ្នាក់ដដែល មិនមែនជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ទេ ។ ហេតុនេះហើយ ការតវ៉ាចំពោះការចាត់ចែងការអនុវត្តរបស់តុលាការអនុវត្ត ត្រូវពិនិត្យ និង សម្រេចសេចក្តី ដោយតុលាការអនុវត្តដដែល ។ ម្យ៉ាងទៀត ការតវ៉ាចំពោះការចាត់ចែងការអនុវត្តរបស់អាជ្ញាសាលា ត្រូវពិនិត្យ និង សម្រេចសេចក្តី ដោយសាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅក្រោម ។

បុគ្គលដែលអាចដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្ត គឺអ្នកដែលខាតប្រយោជន៍ដោយសារការចាត់ចែងការអនុវត្តខុសច្បាប់នោះ ឬ ដោយការយឺតយ៉ាវក្នុងការអនុវត្តនោះ ។ អ្នកដែលខាតប្រយោជន៍នោះ គឺមិនត្រឹមតែម្ចាស់បំណុលដែលដាក់ពាក្យសុំឱ្យអនុវត្ត និង កូនបំណុលដែលត្រូវបានទាមទារឱ្យអនុវត្តតែប៉ុណ្ណោះទេ គឺមានទាំងបុគ្គលផ្សេងដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍នោះផងដែរ ។

ចំពោះពាក្យសុំតវ៉ានឹងការអនុវត្ត តុលាការអនុវត្ត ឬ សាលាដំបូង ត្រូវសម្រេចសេចក្តី ដោយដីកាសម្រេចតាមនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ដោយស្ម័គ្រចិត្ត (សូមមើលមាត្រា ៣៣៧ (ការសម្រេចសេចក្តីរបស់តុលាការអនុវត្ត ជាអាទិ៍)) ។ ជាគោលការណ៍ ភាគីមិនអាចធ្វើឧបាស្រ័យ (បណ្តឹងជំទាស់) ចំពោះដីកាសម្រេចបានទៀតទេ (លើកលែងតែករណីដែលមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣៤៥ (បណ្តឹងជំទាស់ចំពោះដីកាសម្រេចលុបចោល ជាអាទិ៍)) ។

<u>Civil Execution Act (Japan)</u>
**Article 11** (Objection concerning execution)
1. An objection concerning execution may be raised to the execution court against a disposition of the execution court against which no kōkoku-appeal concerning execution may be filed. The same shall apply to a disposition concerning execution made by an execution officer and to the delay of such disposition.
2. The provisions of the preceding Article, paragraph 6, first sentence and paragraph 9 shall apply mutatis mutandis to cases where an objection according to the provisions of the preceding paragraph has been raised

**មាត្រា ៣៤៥.-** បណ្តឹងជំទាស់ចំពោះដីកាសម្រេចលុបចោល ជាអាទិ៍

១- ចំពោះដីកាសម្រេចដូចខាងក្រោមនេះ អាចប្តឹងជំទាស់បាន :

**ក**- ដីកាសម្រេចរបស់តុលាការអនុវត្ត ដែលលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ ។

**ខ**- ដីកាសម្រេចរបស់សាលាដំបូង ដែលបង្គាប់ឱ្យអាជ្ញាសាលាលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ ។

**គ-** ដីកាសម្រេចរបស់សាលាដំបូង ដែលលើកចោលពាក្យសុំតវ៉ាចំពោះការចាត់ចែងរបស់អាជ្ញាសាលា ដែលលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ ។

២- ដីកាសម្រេចដែលអាចប្តឹងជំទាស់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរទេ ។

(កំណត់)

មាត្រានេះ ត្រូវនឹងច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 12 ។

ដីកាសម្រេចអំពីបណ្តឹងតវ៉ាចំពោះការអនុវត្ត អាចធ្វើឡើងដើម្បីឱ្យជំនុំជម្រះតែប៉ុណ្ណោះ ហើយជាគោលការណ៍ គេមិនអាចធ្វើឧបាស្រ័យ (បណ្តឹងជំទាស់) ចំពោះដីកាសម្រេចនេះបានទៀតទេ ។ ប៉ុន្តែ កថាខណ្ឌទី ១ នៃមាត្រានេះ ចែងអំពីករណីពិសេសដែលអាចប្តឹងជំទាស់បាន ។ ការទទួលស្គាល់ករណីលើកលែងនេះ ដោយសារតែដីកាសម្រេចទាំងអស់នោះ គឺជាសេចក្តីសម្រេចសំខាន់ដែលបញ្ចប់នូវនីតិវិធីនៃការអនុវត្តដោយបង្ខំដោយចំពោះ ឬ ដោយប្រយោល ហេតុនេះហើយ ត្រូវតែមានការប្រយ័ត្នប្រុងប្រយ័ត្នហ្មត់ចត់ ។

ម្យ៉ាងទៀត ដីកាសម្រេចដែលបានកំណត់ក្នុងចំណុច **ក** នៃកថាខណ្ឌទី ១ នេះ មិនមែនត្រឹមតែដីកាសម្រេចលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ ដោយទទួលស្គាល់ពាក្យសុំប្តឹងតវ៉ាចំពោះការអនុវត្តតែប៉ុណ្ណោះទេ គឺព្រមទាំងដីកាសម្រេចលុបចោលនីតិវិធីនៃការអនុវត្ត ដោយឆន្ទានុសិទ្ធិ (ទោះបីមានពាក្យសុំប្តឹងតវ៉ាក៏ដោយ ឬ គ្មានក៏ដោយ) (ឧទាហរណ៍ : ករណីដែលមិនអាចដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវា ដែលបានចែងនៅក្នុងមាត្រា ៤៦៤ (ការលុបចោលនីតិវិធីលក់ដោយបង្ខំ នៅក្នុងករណីដែលពុំអាចដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍)) ។ ចំណុច **ខ** វិញ មានន័យថា ដីកាសម្រេចដែលបង្គាប់ឱ្យអាជ្ញាសាលាលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ ដោយទទួលស្គាល់ពាក្យសុំប្តឹងតវ៉ា ចំពោះការចាត់ចែងការអនុវត្តរបស់អាជ្ញាសាលានោះ ។

តាមកថាខណ្ឌទី ២ ដីកាសម្រេចដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នឹងមានអានុភាព ប្រសិនបើគ្មានបណ្តឹងជំទាស់ហើយអំឡុងពេល ១ សប្តាហ៍កន្លងផុត ប៉ុន្តែ បើបណ្តឹងជំទាស់ត្រូវបានដាក់ក្នុង ១ សប្តាហ៍នោះ ដីកាសម្រេចនេះមិនចូលជាស្ថាពរ ហើយមិនត្រូវបង្កើតអានុភាពរហូតដល់បណ្តឹងជំទាស់នោះត្រូវបានសម្រេចដាច់ស្រេច ។ ដោយសារដីកាសម្រេចដែលមានចែងក្នុងកថាខណ្ឌទី ១ ជាការសម្រេចសេចក្តីសំខាន់ ដូចរៀបរាប់ខាងលើនេះ ហេតុនេះហើយ បានជាត្រូវធ្វើឡើងឱ្យបានហ្មត់ចត់ ។

Civil Execution Act (Japan)
**Article 12** (Kōkoku-appeal concerning execution against a ruling to annul)
1. A kōkoku-appeal concerning execution may be filed against a ruling annulling the procedure of a civil execution. The same shall apply to a court decision dismissing a motion for an objection concerning execution again a disposition made by an execution officer which annulled the procedure of a civil execution, or to a ruling which orders the execution officer to annul the procedure of a civil execution.
2. A decision against which a kōkoku-appeal concerning execution may be filed according to the provisions of the preceding paragraph shall not become effective until such decision becomes final and binding.

**មាត្រា ៣៤៦.-** សមត្ថកិច្ចផ្តាច់មុខ

សមត្ថកិច្ចនៃតុលាការដែលបានកំណត់នៅក្នុងគន្ថីនេះ គឺជាសមត្ថកិច្ចផ្តាច់មុខ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 19 ។

មាត្រានេះ កំណត់អំពីសមត្ថកិច្ចផ្តាច់មុខរបស់តុលាការ នៅក្នុងគន្ថីទី ៦ នេះ គឺមានន័យថា គូភាគីមិនអាចព្រមព្រៀងគ្នា ជ្រើសរើសយកសមត្ថកិច្ចនៃតុលាការផ្សេងទៀត ដើម្បីធ្វើការអនុវត្តបានឡើយ ។

Civil Execution Act (Japan)
**Article 19** (Exclusive jurisdiction)
The jurisdiction of the court provided by this Act shall be exclusive.

## ផ្នែកទី ៣ ភាគីនៃការអនុវត្ត និង អ្នកតំណាង

**មាត្រា ៣៤៧.-** ឈ្មោះហៅរបស់ភាគី

នៅក្នុងគន្ថីនេះ ភាគីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវហៅថាម្ចាស់បំណុលនៃការអនុវត្ត រីឯភាគីម្ខាងទៀតត្រូវហៅថា កូនបំណុលនៃការអនុវត្ត ។

(កំណត់)

កូនបំណុលនៃការអនុវត្ត រាប់បញ្ចូលទាំងតតិយជនដែលដាក់វត្ថុ ឬ សិទ្ធិដើម្បីធានាបំណុលរបស់កូនបំណុលផ្សេងក្នុងករណីនៃការអនុវត្តសិទ្ធិប្រាតិភោគ ។

**មាត្រា ៣៤៨.-** អ្នកតំណាងដោយអាណត្តិក្នុងនីតិវិធីទាក់ទងនឹងការអនុវត្តដោយបង្ខំ

១- បញ្ញត្តិដែលបានកំណត់ខាងក្រោមនេះ ត្រូវយកមកអនុវត្តចំពោះការតំណាងដោយអាណត្តិក្នុងនីតិវិធីដែលទាក់ទងនឹងការអនុវត្តដោយបង្ខំ :

**ក-** បញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៣ (លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ) នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះនីតិវិធីនៃបណ្តឹង ឬ បណ្តឹងជំទាស់ដែលបានកំណត់នៅក្នុងគន្ថីទី ៦ នេះ ។

**ខ-** លើកលែងតែករណីដែលបានកំណត់នៅក្នុងចំណុច **ក** ខាងលើនេះ នៅក្នុងនីតិវិធីដែលតុលាការអនុវត្ត ឬ សាលាដំបូងធ្វើឡើងចំពោះការអនុវត្តដោយបង្ខំ អ្នកក្រៅពីអ្នកដែលអាចធ្វើជាអ្នកតំណាងដោយអាណត្តិ តាម

បញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៣ (លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ) នៃក្រមនេះ អាចធ្វើជាអ្នកតំណាងដោយអាណត្តិបាន ដោយទទួលការអនុញ្ញាតពីតុលាការអនុវត្ត ឬ សាលាដំបូង ។

**គ**- នៅក្នុងនីតិវិធីដែលធ្វើឡើងដោយអាជ្ញាសាលា អ្នកណាក៏អាចធ្វើជាអ្នកតំណាងដោយអាណត្តិបានដែរ ។

២- តុលាការអនុវត្ត ឬ សាលាដំបូង អាចលុបចោលការអនុញ្ញាតដែលបានកំណត់នៅចំណុច **ខ** នៃកថាខណ្ឌទី ១ ខាងលើនេះ នៅពេលណាក៏បានដែរ ។

(កំណត់)

មាត្រានេះត្រូវនឹងច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 13 ។

អ្នកតំណាងដោយអាណត្តិ ក្នុងនីតិវិធីទាក់ទងនឹងការអនុវត្តដោយបង្ខំនេះ គឺខុសគ្នាពីនីតិវិធីនៃបណ្តឹងដែលតម្រូវឱ្យអ្នកតំណាងដោយអាណត្តិជាមេធាវី ប៉ុន្តែ មាត្រានេះមិនតម្រូវឱ្យអ្នកតំណាងដោយអាណត្តិត្រូវតែជាមេធាវីទេ ដោយហេតុថា នីតិវិធីនៃការអនុវត្តគ្រាន់តែជាការអនុវត្តតាមសាលក្រមដែលចូលជាស្ថាពរ ឬ លិខិតយថាភូត ,,, តែប៉ុណ្ណោះ ។

ចំណុច **ក** : ឧទាហរណ៍ បណ្តឹងតវ៉ារបស់តតិយជន ត្រូវធ្វើទៅតុលាការអនុវត្ត ចំពោះការរឹបអូសដោយតុលាការអនុវត្ត ឬ ទៅសាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅក្រោម ចំពោះការរឹបអូសដោយអាជ្ញាសាលានោះ (សូមមើលមាត្រា ៣៦៥ (បណ្តឹងតវ៉ារបស់តតិយជន) កថាខណ្ឌទី ២) គឺត្រូវនឹងចំណុច **ក** នេះ ។

ចំណុច **ខ** : នីតិវិធីដែលធ្វើឡើងដោយសាលាដំបូងស្តីពីការអនុវត្តដោយបង្ខំ ក្នុងករណីដែលអនុវត្តចំពោះចលនវត្ថុ មានឧទាហរណ៍ដូចជា ការសម្រេចសេចក្តីអំពីការតវ៉ាចំពោះការអនុវត្ត (មាត្រា ៣៨៤ (ការតវ៉ាចំពោះការអនុវត្ត) កថាខណ្ឌទី ២) ការសម្រេចសេចក្តីប្តូរទំហំនៃចលនទ្រព្យដែលហាមរឹបអូស (មាត្រា ៣៨១ (ការប្តូរទំហំនៃចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស) ការចែកចំណែកក្នុងករណីដែលមិនបានសម្របសម្រួលគ្នារវាងម្ចាស់បំណុល (មាត្រា ៤០១ (ការជូនដំណឹងទៅសាលាដំបូង)) ជាដើម ។

កថាខណ្ឌទី ១ មានអត្ថន័យដូចតទៅ : ចំណុច **ក** ចែងថា ក្នុងករណីដែលចំបាច់ធ្វើតាមនីតិវិធីនៃការចេញសាលក្រម ឬ នីតិវិធីដែលត្រូវធ្វើដោយហ្មត់ចត់ដូចនីតិវិធីនៃការចេញសាលក្រម ក្នុងចំណោមនៃការចេញដីកាសម្រេច លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ ត្រូវអនុលោមតាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៥៣ ។ ផ្ទុយទៅវិញ នីតិវិធីផ្សេងទៀតនៃនីតិវិធីនៃការអនុវត្តដោយបង្ខំ គឺជានីតិវិធីកំណត់ ដែលត្រូវបានធ្វើឡើង ដោយឆន្ទានុសិទ្ធិរបស់ស្ថាប័នអនុវត្ត ហើយសកម្មភាពរបស់ភាគី ក៏មិនស្មុគស្មាញដែរ ។ ហេតុដូច្នេះ ចំពោះនីតិវិធីដែលតុលាការត្រូវទទួលបន្ទុក ចំណុច **ខ** រក្សាទុកនូវប្រព័ន្ធអនុញ្ញាតដូចកថាខណ្ឌទី ១ នៃមាត្រា ៥៣ តែទទួលស្គាល់វិសាលភាពនៃអ្នកតំណាង ឱ្យទូលាយជាងល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥៣ រីឯ ចំពោះនីតិវិធីដែលអាជ្ញាសាលាត្រូវទទួលបន្ទុកវិញ ចំណុច **គ** ទុកឱ្យភាគី ជ្រើសរើសដោយឆន្ទៈសេរី ដោយគ្មានកំណត់លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ ។ ចំពោះវិសាលភាពនៃអ្នកតំណាងដោយអាណត្តិ តាមចំណុច ខ តុលាការអាចសម្រេច ដោយឆន្ទានុសិទ្ធិ តាមស្ថានភាពជាក់ស្តែងនៃប្រទេស

កម្ពុជា ដោយគិតពិចារណានូវវិសាលភាពនៃអ្នកតំណាងដោយអាណត្តិដែលត្រូវអនុញ្ញាត ដោយយោងតាមចំណុច **គ** កថាខណ្ឌទី ១ នៃមាត្រា ៥៣ ។

Civil Execution Act (Japan)
**Article 13** (Representatives)
1. With regard to any procedure other than that relating to a suit or a kōkoku-appeal concerning execution, persons other than those who may serve as advocates according to the provisions of Article 79, paragraph 1 of the Code of Civil Procedure may serve as representatives with the permission of the execution court.
2. The execution court may at any time annul the permission referred to in the preceding paragraph.

## ផ្នែកទី ៤ លំនាំខណ្ឌនៃការអនុវត្តដោយបង្ខំ

**មាត្រា ៣៤៩.-** របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ

១- ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ។

២- នៅក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវមានបញ្ជាក់នូវចំណុចដូចខាងក្រោមនេះ ហើយត្រូវភ្ជាប់ជាមួយនឹងលិខិតចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្ត :

- **ក**- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋាន របស់ម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។
- **ខ**- សញ្ញាណនៃលិខិតអនុវត្ត ។
- **គ**- សេចក្តីសុំឱ្យអនុវត្ត តាមការបង្ខំដោយផ្ទាល់ ឬ ការអនុវត្តជំនួស ឬ វិធានបង្ខំដោយប្រយោល ។
- **ឃ**- សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និង វិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ ។
- **ង**- ខ្លឹមសារនៃសេចក្តីសម្រេចដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឱ្យអនុវត្តដោយបង្ខំ តាមការអនុវត្តជំនួស ឬ វិធានបង្ខំដោយប្រយោល ។

៣- ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តសុំឱ្យអនុវត្តដោយបង្ខំ ចំពោះផ្នែកណាមួយនៃសិទ្ធិទាមទារដែលបានសរសេរនៅក្នុងលិខិតអនុវត្តដែលបង្គាប់ឱ្យសងជាប្រាក់ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវសរសេរបញ្ជាក់អំពីសេចក្តីសុំ និងទំហំនៃសេចក្តីសុំនោះ ក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ ។

(កំណត់)

សូមមើលបទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណី មាត្រា 21 ។

"វិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ" ដែលមានចែងក្នុងចំណុច **ឃ** នៃកថាខណ្ឌទី ២ គឺ ការអនុវត្តដោយយកប្រាក់ ឬ ការអនុវត្តដោយមិនយកប្រាក់ ។ ឧទាហរណ៍នៃការសរសេរតាមចំណុច **ឃ** : "អចលនវត្ថុ

ដែលស្ថិតនៅកន្លែងកំណត់ និង ការអនុវត្តដោយយកប្រាក់ (ឬ ការអនុវត្តដោយឱ្យចេញពីអចលនវត្ថុ)" ។

**មាត្រា ៣៥០.-** លិខិតអនុវត្ត

១- ការអនុវត្តដោយបង្ខំត្រូវធ្វើឡើង ដោយផ្អែកលើលិខិតអនុវត្ត ។

២- លិខិតអនុវត្ត គឺជាលិខិតដែលបានកំណត់ខាងក្រោមនេះ :

**ក**- សាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកដែលបានចូលជាស្ថាពរ ។

**ខ**- សាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ។

**គ**- ដីកាសម្រេចបង្គាប់ឱ្យផ្តល់តាវកាលិក ។ ប៉ុន្តែ ចំពោះដីកាសម្រេចដែលមិនត្រូវមានអានុភាពបើមិនទាន់ចូលជាស្ថាពរវិញ មានកម្រិតតែដីកាសម្រេចនោះបានចូលជាស្ថាពរហើយ ។

**ឃ**- ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ។

**ង**- ការចាត់ចែងរបស់ក្រឡាបញ្ជីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៦៦ (នីតិវិធីដើម្បីកំណត់ជាស្ថាពរនូវចំនួនប្រាក់ប្រដាប់ក្តី) នៃក្រមនេះ ។

**ច**- លិខិតយថាភូតដែលធ្វើដោយសារការី ចំពោះការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់មានកំណត់ ។ ប៉ុន្តែ មានកម្រិតតែលិខិតដែលបញ្ជាក់សេចក្តីថ្លែងការណ៍ថា កូនបំណុលនឹងទទួលការអនុវត្តដោយបង្ខំភ្លាមៗ ។

**ឆ**- សាលក្រម ឬ សាលដីការបស់តុលាការបរទេស ដែលមានសាលក្រមអនុវត្ត ដែលបានចូលជាស្ថាពរ តាមបញ្ញត្តិនៃមាត្រា ៣៥២ (សាលក្រមអនុវត្តសាលក្រម ឬ សាលដីការបស់តុលាការបរទេស) នៃក្រមនេះ ។

**ជ**- សេចក្តីសម្រេចមជ្ឈត្តករ ដែលមានដីកាសម្រេចអនុវត្តដែលបានចូលជាស្ថាពរតាមបញ្ញត្តិនៃមាត្រា ៣៥៣ (ដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ) នៃក្រមនេះ ។

**ឈ**- កំណត់ហេតុដែលបានកំណត់នៅក្នុងមាត្រា ២២២ (អានុភាពនៃកំណត់ហេតុស្តីពីការសះជា ជាអាទិ៍) នៃក្រមនេះ និង កំណត់ហេតុផ្សេងទៀតដែលមានអានុភាពដូចសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 22 ។

ចំពោះចំណុច **ក** សូមមើលមាត្រា ១៩៥ (ពេលដែលអានុភាពអនុវត្តកើតឡើង) ។ ម្យ៉ាងទៀត ចំណុច **ក** រាប់បញ្ចូលផងដែរ នូវសាលក្រម ឬ សាលដីកាព្រហ្មទណ្ឌដែលទទួលស្គាល់ការទាមទារផ្នែករដ្ឋប្បវេណី ។ ហេតុដូច្នេះ សិទ្ធិទាមទារតាមច្បាប់ឯកជនដែលត្រូវបានអះអាងតាមបណ្តឹងរដ្ឋប្បវេណីដែលភ្ជាប់នឹងរឿងក្តីព្រហ្មទណ្ឌ ក៏អាចអនុវត្តដោយបង្ខំ តាមនីតិវិធីដែលបានកំណត់នៅក្នុងគន្ថីនេះបានដែរ ។

ចំពោះចំណុច **ខ** សូមមើលមាត្រា ១៩៦ (ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន) ។

ឧទាហរណ៍នៃចំណុច **គ** មានដូចជា ដីកាសម្រេចបង្គាប់ឱ្យប្រគល់នាវា ដីកាសម្រេចបង្គាប់ឱ្យបង់ជាមុននូវសោហ៊ុយសម្រាប់ការអនុវត្តជំនួស ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ពិន័យក្នុងករណីដែលបង្ខំដោយប្រយោល (astreinte) ជាដើម ។

ចំពោះចំណុច **ឃ** សូមមើលមាត្រា ៣២៨ (ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន) ។

លិខិតយថាភូតដែលស្របនឹងល័ក្ខខ័ណ្ឌក្នុងចំណុច **ច** គេហៅថា លិខិតអនុវត្ត ។ ចំពោះសារការី និង លិខិតយថាភូតត្រូវចែងដោយច្បាប់ផ្សេងទៀត ។

ឧទាហរណ៍នៃចំណុច **ឈ** មានដូចជា កំណត់ហេតុនៃការសះជា និង កំណត់ហេតុនៃការទទួលស្គាល់ការទាមទារ (មាត្រា ២២២ (អានុភាពនៃកំណត់ហេតុស្ដីពីការសះជា ជាអាទិ៍)) ។ ក្រៅពីនេះ នាអនាគត ពេលប្រទេសកម្ពុជាធ្វើច្បាប់ដែលទាក់ទងនឹងធនក្ស័យ ពេលនោះ អាចមានបញ្ញត្តិដែលចែងថា ការសរសេរនៅក្នុងបញ្ជីម្ចាស់បំណុលដែលបានចូលជាស្ថាពរ មានអានុភាពដូចសាលក្រមស្ថាពរដែរ ។ ក្នុងករណីនេះ បញ្ជីម្ចាស់បំណុលនោះ ក៏ត្រូវនឹងចំណុច **ឈ** នេះដែរ ។

Civil Execution Act (Japan)
**Article 22** (Obligation title)
Compulsory execution shall be effected by virtue of any of the following (hereinafter referred to as "obligation title"):
i. a final and binding judgment;
ii. a judgment accompanied by a declaration of provisional execution;
iii. a decision against which no appeal other than a kōkoku-appeal may be filed (In cases where a decision shall not be effected until it becomes final and binding, this shall not apply only when such decision becomes final and binding);
iv. a payment order accompanied by a declaration of provisional execution;
v. a document drawn up by a notary for a claim the subject matter of which is the payment of a certain amount of money or the delivery of a certain quantity of fungible thins or valuable instruments and which includes a statement that the obligor shall be immediately subject to compulsory execution (hereinafter referred to as an "execution document");
vi. a judgment of a foreign court or award accompanied by a judgment concerning execution which has become final and binding;
vii. anything which has the same effect as a final and binding judgment (except the decision referred to in item iii above).

**មាត្រា ៣៥១.-** វិសាលភាពនៃអ្នកដែលអាចអនុវត្តដោយបង្ខំ

១- ការអនុវត្តដោយបង្ខំ អាចធ្វើបាន ដោយចង្អុលអ្នកដែលបានកំណត់ខាងក្រោមនេះ ជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត ៖

**ក**- ភាគីដែលត្រូវបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត ។

**ខ**- តតិយជន ក្នុងករណីភាគីដែលត្រូវបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត ធ្វើជាភាគីសម្រាប់តតិយជននោះ ។

**គ**- អ្នកដែលទទួលបន្តសិទ្ធិ ឬ ករណីយកិច្ចពីបុគ្គលដែលបានកំណត់នៅក្នុងចំណុច **ក** និង ចំណុច **ខ** ក្រោយពីលិខិតអនុវត្តនោះត្រូវបានធ្វើឡើង ។ ប៉ុន្តែ ចំពោះលិខិតអនុវត្តដែលបានកំណត់នៅក្នុងចំណុច **ក ខ ឆ** និង **ជ** នៃមាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ គឺអ្នកទទួលបន្តសិទ្ធិ ឬ ករណីយកិច្ចក្រោយពីបណ្ដឹងត្រូវបានចាត់ការ ។

២- ការអនុវត្តដោយបង្ខំ ដោយផ្អែកលើលិខិតអនុវត្តដែលបានកំណត់នៅក្នុងចំណុច **ក ខ គ ឆ ជ** ឬ **ឈ** នៃមាត្រា

៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ អាចធ្វើចំពោះបុគ្គលដែលកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការទាមទារ សម្រាប់បុគ្គលដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ១ ខាងលើនេះបានដែរ ។

(កំណត់)

គោលគំនិតនៃមាត្រានេះដូចគ្នានឹងគោលគំនិតនៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 23 ដែរ ។ម្យ៉ាងទៀត មាត្រានេះចែងអំពីវិសាលភាពនៃបុគ្គលដែលទទួលអានុភាពនៃការអនុវត្ត ហើយជាគោលការណ៍ មាត្រានេះមានខ្លឹមសារ ដូចគ្នានឹងមាត្រា ១៩៨ (វិសាលភាពបុគ្គលដែលត្រូវទទួលអានុភាពរបស់សាលក្រមស្ថាពរ) ដែលចែងអំពីវិសាលភាពនៃបុគ្គលដែលទទួលអានុភាពស្ថាពរ ។

Civil Execution Act (Japan)
**Article 23** (Parties to compulsory execution)
1. Compulsory execution by virtue of an obligation title other than an execution document may be effected against or for the following persons:
i. parties designated in the obligation title;
ii. a third person who is represented by one of the parties designated in the obligation title;
iii. a successor to the party or person referred to in the preceding two items after accomplishment of the obligation title (in cases of the obligation title referred to in the preceding Article, items i, ii and vi, successors after the conclusion of oral argument).
2. Compulsory execution by virtue of an execution document may be effected against or for the parties designated in the execution document or successors to such parties after the accomplishment of the execution document.
3. Compulsory execution by virtue of the obligation title prescribed in paragraph 1 may be effected against any person who possesses the subject matter of the claim on behalf of a person referred to in the three items of that paragraph.

**មាត្រា ៣៥២.-** សាលក្រមអនុវត្តសាលក្រម ឬ សាលដីការបស់តុលាការបរទេស

១- ដើម្បីអនុវត្តដោយបង្ខំ ដោយផ្អែកលើសាលក្រម ឬ សាលដីការបស់តុលាការបរទេស ត្រូវទទួលសាលក្រមអនុវត្តពីតុលាការនៃព្រះរាជាណាចក្រកម្ពុជា ។

២- បណ្តឹងទាមទារឱ្យចេញសាលក្រមអនុវត្ត ចំពោះសាលក្រម ឬ សាលដីការបស់តុលាការបរទេស ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើកន្លែងរបស់កូនបំណុលនៃការអនុវត្ត ដែលបានកំណត់នៅក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍) នៃក្រមនេះ ហើយក្នុងករណីដែលមិនអាចកំណត់តុលាការដែលមានសមត្ថកិច្ច តាមមាត្រា ៨ ទេនោះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលកម្មវត្ថុនៃការទាមទារ ឬ ទ្រព្យរបស់កូនបំណុលនៃការអនុវត្តដែលអាចរឹបអូសបានស្ថិតនៅ ។

៣- ប្រសិនបើមិនអាចបញ្ជាក់ថាសាលក្រម ឬ សាលដីការបស់តុលាការបរទេស បានចូលជាស្ថាពរ ឬ ប្រសិនបើសាលក្រម ឬ សាលដីកានេះមិនបានបំពេញល័ក្ខខ័ណ្ឌនានា ដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃមាត្រា ១៩៩ (អានុភាពនៃសាលក្រមស្ថាពររបស់តុលាការបរទេស) នៃក្រមនេះទេ តុលាការត្រូវលើកចោលបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ។

៤- ការចេញសាលក្រមអនុវត្ត ត្រូវធ្វើឡើងដោយមិនស្រាវជ្រាវអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃសាលក្រម ឬ

សាលដីការបស់តុលាការបរទេសទេ ។

៥- ក្នុងសាលក្រមអនុវត្ត តុលាការត្រូវប្រកាសអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ តាមសាលក្រម ឬ សាលដីការបស់តុលាការបរទេស ។

( កំណត់)

គោលគំនិតនៃមាត្រានេះដូចគ្នានឹងគោលគំនិតនៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 24 ដែរ ។

សូមមើលកំណត់នៃមាត្រា ១៩៩ ( អានុភាពនៃសាលក្រមស្ថាពររបស់តុលាការបរទេស) ។

Civil Execution Act (Japan)

**Article 24** (Execution judgment based on foreign judgment)

1. An action for an execution judgment based on the judgment of a foreign court shall be subject to the jurisdiction of the district court which has jurisdiction over the place of the obligor's general forum, and if there is no such general forum, such action shall be subject to the jurisdiction of the district court which has jurisdiction over the place where the subject matte of the claim or attachable property of the obligor is located.
2. The execution judgment shall be rendered without inquiry as to whether the decision is proper or not.
3. In cases where it has not been proved that the judgment of the foreign court has become final and binding or where the judgment of the foreign court does not fulfill the conditions referred to in Article 200 of the Code of Civil Procedure, the action referred to in paragraph 1 must be dismissed.
4. It must be stated in the execution judgment that compulsory execution by virtue of the judgment of the foreign court is permitted.

**មាត្រា ៣៥៣.-** ដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ

១- ដើម្បីធ្វើការអនុវត្តដោយបង្ខំ ដោយផ្អែកលើសេចក្តីសម្រេចមជ្ឈត្តករ ទោះបីជាសេចក្តីសម្រេចមជ្ឈត្តករក្នុងប្រទេសក៏ដោយ សេចក្តីសម្រេចមជ្ឈត្តករបរទេសក៏ដោយ ត្រូវទទួលដីកាសម្រេចអនុវត្តរបស់តុលាការនៅព្រះរាជាណាចក្រកម្ពុជា ។

២- ភាគីដែលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ ត្រូវដាក់លិខិតដូចខាងក្រោមនេះ :

**ក**- ច្បាប់ដើមនៃសេចក្តីសម្រេចមជ្ឈត្តករដែលត្រូវបានបញ្ជាក់ដោយត្រឹមត្រូវ ឬ ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ត្រឹមត្រូវ ។

**ខ**- ច្បាប់ដើមនៃកិច្ចសន្យាមជ្ឈត្តកម្ម ឬ ឯកសារចម្លងនៃកិច្ចសន្យានោះ ដែលមានសេចក្តីបញ្ជាក់ត្រឹមត្រូវ ។

៣- តុលាការអាចបដិសេធការអនុវត្តសេចក្តីសម្រេចមជ្ឈត្តករបាន បើភាគីដែលនឹងទទួលការខូចខាតផលប្រយោជន៍ពីការអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ សំអាងបញ្ជាក់អំពីហេតុដូចខាងក្រោមនេះ :

**ក**- ភាគីនៃកិច្ចសន្យាមជ្ឈត្តកម្ម គ្មានសមត្ថភាព ឬ កិច្ចសន្យាមជ្ឈត្តកម្មនោះ ត្រូវចាត់ទុកថាមោឃៈ តាមបទដ្ឋានគតិយុត្តដែលគូភាគីកំណត់ជាច្បាប់យោង ឬ តាមបទដ្ឋានគតិយុត្តនៃប្រទេសដែលសេចក្តីសម្រេចមជ្ឈត្តករ ត្រូវបានធ្វើឡើង បើគ្មានការកំណត់ដោយគូភាគី ។

**ខ**- ភាគីដែលនឹងទទួលការខូចខាតផលប្រយោជន៍ ពីការអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ មិនបានទទួលសេចក្តី

ជូនដំណឹងសមរម្យអំពីការជ្រើសតាំងមជ្ឈត្តករ ឬ នីតិវិធីមជ្ឈត្តកម្ម ឬ មិនអាចការពារខ្លួនដោយសារមូលហេតុផ្សេងទៀត ។

**គ**- សេចក្តីសម្រេចមជ្ឈត្តករ ទាក់ទងនឹងវិវាទដែលមិនបានកំណត់នៅក្នុងចំណុចដែលត្រូវទទួលមជ្ឈត្តកម្ម ឬ វិវាទក្រៅទំហំនៃចំណុចនោះ ឬ មានសេចក្តីសម្រេចអំពីចំណុចដែលហួសពីទំហំនៃចំណុចដែលត្រូវទទួលមជ្ឈត្តកម្ម ។

**ឃ**- ការរៀបចំអង្គភាពវិនិច្ឆ័យនៃមជ្ឈត្តកម្ម ឬ នីតិវិធីនៃមជ្ឈត្តកម្ម មិនស្របតាមការព្រមព្រៀងរបស់ភាគី ឬ បើគ្មានការព្រមព្រៀងនោះ មិនស្របតាមបទដ្ឋានគតិយុត្តនៃប្រទេសដែលមជ្ឈត្តកម្មត្រូវបានធ្វើឡើង ។

**ង**- សេចក្តីសម្រេចមជ្ឈត្តករ មិនទាន់មានអានុភាពចងភាគី ឬ ត្រូវបានលុបចោល ដោយតុលាការនៃប្រទេសដែលសេចក្តីសម្រេចមជ្ឈត្តករនោះត្រូវបានធ្វើឡើង ឬ ប្រទេសដែលមានបទដ្ឋានគតិយុត្តដែលជាមូលដ្ឋាននៃសេចក្តីសម្រេចមជ្ឈត្តករនោះ ។

៤- តុលាការអាចបដិសេធការអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ ប្រសិនបើយល់ឃើញថា មានហេតុដូចខាងក្រោមនេះ :

**ក**- ចំណុចដែលជាកម្មវត្ថុនៃវិវាទ មិនអាចដោះស្រាយបាន ដោយមជ្ឈត្តកម្ម ។

**ខ**- ការទទួលស្គាល់ ឬ ការអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ។

៥- ពាក្យសុំចេញដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករក្នុងប្រទេស ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើកន្លែងរបស់កូនបំណុលនៃការអនុវត្ត ដែលបានកំណត់នៅក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍) នៃក្រមនេះ ហើយក្នុងករណីដែលមិនអាចកំណត់តុលាការដែលមានសមត្ថកិច្ច តាមមាត្រា ៨ ទេនោះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលកម្មវត្ថុនៃការទាមទារ ឬ ទ្រព្យរបស់កូនបំណុលនៃការអនុវត្តដែលអាចរឹបអូសបានស្ថិតនៅ ។

៦- ពាក្យសុំចេញដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករបរទេស ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍ ។

៧- ការចេញដីកាសម្រេចអនុវត្ត ត្រូវធ្វើឡើងដោយមិនស្រាវជ្រាវអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃសេចក្តីសម្រេចមជ្ឈត្តករ លើកលែងតែករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ និង កថាខណ្ឌទី ៤ ខាងលើនេះ ។

៨- ក្នុងដីកាសម្រេចអនុវត្ត តុលាការត្រូវប្រកាសអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ តាមសេចក្តីសម្រេចមជ្ឈត្តករ ។

៩- ចំពោះដីកាសម្រេចអំពីពាក្យសុំឱ្យចេញដីកាសម្រេចអនុវត្ត អាចប្តឹងជំទាស់បាន ។

១០- ដីកាសម្រេចអនុវត្ត មិនត្រូវមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរទេ ។

(កំណត់)

សូមមើលមាត្រា 35 និង 36 នៃគំរូច្បាប់ស្តីពីមជ្ឈត្តកម្មពាណិជ្ជកម្មអន្តរជាតិ (Model Law on International Commercial Arbitrations) នៃ UNCITRAL ។

មាត្រានេះចែងអំពីបញ្ញត្តិរួមស្តីពីនីតិវិធីអនុវត្ត ក្នុងព្រះរាជាណាចក្រកម្ពុជា នូវសេចក្តីសម្រេចមជ្ឈត្តករទាំងឡាយ

ដូចជាសេចក្ដីសម្រេចមជ្ឈត្តករការងារ សេចក្ដីសម្រេចមជ្ឈត្តករពាណិជ្ជកម្ម សេចក្ដីសម្រេចមជ្ឈត្តករក្នុងប្រទេសផ្សេងទៀត និង សេចក្ដីសម្រេចមជ្ឈត្តករដែលធ្វើឡើង តាមនីតិវិធីមជ្ឈត្តកម្ម នៅបរទេស ។ ចំពោះមូលហេតុដែលតុលាការអាចបដិសេធការអនុវត្តសេចក្ដីសម្រេចមជ្ឈត្តករ មាត្រានេះយកមាត្រា 36 នៃគំរូច្បាប់ស្ដីពីមជ្ឈត្តកម្មពាណិជ្ជកម្មអន្តរជាតិ នៃ UNCITRAL ធ្វើជាមូលដ្ឋាន ។

<u>UNCITRAL Model Law on International Commercial Arbitrations</u>
**Article 35** (Recognition and enforcement)
(1) An arbitral award, irrespective of the country in which it was made, shall be recognized as binding and, upon application in writing to the competent court, shall be enforced subject to the provisions of this article and of article 36.
(2) The party relying on an award or applying for its enforcement shall supply the duly authenticated original award or a duly certified copy thereof, and the original arbitration agreement referred to in article 7 or a duly certified copy thereof. If the award or agreement is not made in an official language of this State, the party shall supply a duly certified translation thereof into such language.
**Article 36** (Grounds for refusing recognition or enforcement)
(1) Recognition or enforcement of an arbitral award, irrespective of the country in which it was made, may be refused only:
(a) at the request of the party against whom it is invoked, if that party furnishes to the competent court where recognition or enforcement is sought proof that:
(i) a party to the arbitration agreement referred to in article 7 was under some incapacity; or the said agreement is not valid under the law to which the parties have subjected it or, failing any indication thereon, under the law of the country where the award was made; or
(ii) the party against whom the award is invoked was not given proper notice of the appointment of an arbitrator or of the arbitral proceedings or was otherwise unable to present his case; or
(iii) the award deals with a dispute not contemplated by or not falling within the terms of the submission to arbitration, or it contains decisions on matters beyond the scope of the submission toarbitration, provided that, if the decisions on matters submitted to arbitration can be separated from those not so submitted, that part of the award which contains decisions on matters submitted to arbitration may be recognized and enforced; or
(iv) the composition of the arbitral tribunal or the arbitral procedure was not in accordance with the agreement of the parties or, failing such agreement, was not in accordance with the law of the country where the arbitration took place; or
(v) the award has not yet become binding on the parties or has been set aside or suspended by a court of the country in which, or under the law of which, that award was made; or
(b) if the court finds that:
(i) the subject-matter of the dispute is not capable of settlement by arbitration under the law of this State; or
(ii) the recognition or enforcement of the award would be contrary to the public policy of this State.
(2) If an application for setting aside or suspension of an award has been made to a court referred to in paragraph (1)(a)(v) of this article, the court where recognition or enforcement is sought may, if it considers it proper, adjourn its decision and may also, on the application of the party claiming recognition or enforcement of the award, order the other party to provide appropriate security.

**មាត្រា ៣៥៤.~** ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្ដល់រូបមន្តអនុវត្ត

១- ការអនុវត្តដោយបង្ខំត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត ។ ប៉ុន្តែ ក្នុងករណីដែលយកឯកសារដែលបានកំណត់ដូចខាងក្រោមនេះជាលិខិតអនុវត្ត ការអនុវត្តដោយបង្ខំដោយយកភាគីដែលបានកំណត់ក្នុងលិខិតអនុវត្តនោះធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្តត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តនោះ :

**ក**- សាលក្រមនៃបណ្ដឹងរឿងក្ដីចំនួនទឹកប្រាក់តិចដែលចូលជាស្ថាពរ ។

**ខ**- សាលក្រមនៃបណ្ដឹងរឿងក្ដីចំនួនទឹកប្រាក់តិចដែលភ្ជាប់ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ។

**គ**- ដីកាសម្រេចដាស់តឿនដែលភ្ជាប់ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ។

២- រូបមន្តអនុវត្ត ត្រូវផ្ដល់ដោយក្រឡាបញ្ជីនៃតុលាការដែលមានសំណុំរឿងនោះ តាមពាក្យសុំ ។ ប៉ុន្តែ ចំពោះលិខិត

អនុវត្តដែលបានកំណត់នៅក្នុងចំណុច ៥ កថាខណ្ឌទី ២ មាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ ត្រូវផ្តល់ដោយសារការី ដែលរក្សាទុកនូវលិខិតដើមនោះ ។

(កំណត់)

(1) ចំពោះកថាខណ្ឌទី ១ និង ទី ៣ សូមមើលមាត្រា 25 ចំពោះកថាខណ្ឌទី ២ សូមមើលមាត្រា 26 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

(2) រូបមន្តអនុវត្តគឺ ក្នុងចំណោមល័ក្ខខ័ណ្ឌនៃការអនុវត្តដោយបង្ខំ ក្រឡាបញ្ជី ឬ សារការីត្រូវធ្វើការពិនិត្យចំណុចដូចជាអត្ថិភាពរបស់លិខិតអនុវត្តដែលមានសុពលភាព លក្ខណៈរបស់ភាគីនៃការអនុវត្ត ការបំពេញល័ក្ខខ័ណ្ឌចំពោះសិទ្ធិទាមទារដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ ជាដើម ហើយសរសេរបន្ថែមនូវលទ្ធផលនោះនៅលើចុងសន្លឹកនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ហើយផ្ញើទៅស្ថាប័នអនុវត្ត ។ ដើម្បីធ្វើការអនុវត្តដោយបង្ខំ ឱ្យបានឆាប់រហ័ស យើងយល់ឃើញថា ការពិនិត្យល័ក្ខខ័ណ្ឌទាំងនោះដោយក្រឡាបញ្ជី ឬ សារការី ជាការសមរម្យជាងដោយស្ថាប័នអនុវត្តផ្ទាល់ ដោយសារក្រឡាបញ្ជី ឬ សារការីនោះ ពាក់ព័ន្ធនឹងការបង្កើតលិខិតអនុវត្តនោះធ្វើការពិនិត្យដែលជាហេតុបង្កើតឱ្យមាននូវប្រព័ន្ធនៃរូបមន្តអនុវត្ត ។

ជាគោលការណ៍ ដើម្បីធ្វើការអនុវត្តដោយបង្ខំ ចាំបាច់ត្រូវមានរូបមន្តអនុវត្ត ប៉ុន្តែ ប្រព័ន្ធនៃរឿងក្តីចំនួនទឹកប្រាក់តិច និង ការដាស់តឿន បង្កើតឡើងក្នុងគោលបំណងធ្វើឱ្យមានភាពងាយស្រួលក្នុងការទទួលលិខិតអនុវត្ត តាមនីតិវិធីសង្ខេប ហេតុដូច្នេះ ចំពោះសាលក្រមនៃរឿងក្តីចំនួនទឹកប្រាក់តិច និង ដីកាសម្រេចដាស់តឿន ពុំចាំបាច់ត្រូវមានរូបមន្តអនុវត្តទេ បើយកភាគីដែលបានកំណត់នៅក្នុងលិខិតអនុវត្តនោះធ្វើជាម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត (វាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រានេះ) ។

(3) រូបមន្តអនុវត្តមាន ២ ប្រភេទ គឺ រូបមន្តអនុវត្តដែលមានចុះសេចក្តីអនុញ្ញាតនៃការអនុវត្តដោយបង្ខំដូចបានកំណត់នៅក្នុងលិខិតអនុវត្ត ("រូបមន្តអនុវត្តសាមញ្ញ") និង រូបមន្តអនុវត្តដែលមានចុះសេចក្តីបញ្ជាក់ថា ល័ក្ខខ័ណ្ឌត្រូវបានបំពេញ ឬ ពេលកំណត់មិនពិតប្រាកដមកដល់ ឬ រូបមន្តអនុវត្តដែលមានចុះសេចក្តីអនុញ្ញាតនៃការអនុវត្តដោយបង្ខំ ដោយយកជនឯទៀតផ្សេងពីគូភាគីដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្តជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត ("រូបមន្តអនុវត្តពិសេស" ដែលបានចែងនៅក្នុងមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស)) ។

(4) ចំពោះលិខិតអនុវត្តដែលចែងនៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រានេះ នីតិវិធីដែលជាមូលដ្ឋាននៃលិខិតនេះ ត្រូវបានរៀបចំតាក់តែងឡើង ក្នុងគោលបំណងដើម្បីធ្វើឱ្យម្ចាស់បំណុលនៃការអនុវត្តទទួលនូវលិខិតអនុវត្តដោយងាយស្រួលជាបន្ទាន់ ហេតុដូច្នេះ ជាគោលការណ៍ ចំពោះការអនុវត្តដោយបង្ខំផងដែរ ចាត់ទុកថា ពុំចាំបាច់មានរូបមន្តអនុវត្តទេ ។ ប៉ុន្តែ ក្នុងករណីនៃការអនុវត្តដោយបង្ខំ ដោយយកជនឯទៀតផ្សេងពីគូភាគីដែលបានកំណត់

នៅក្នុងលិខិតអនុវត្តជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត ចាំបាច់ ត្រូវការរូបមន្តអនុវត្តពិសេស (មាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស)) ។ ម្យ៉ាងទៀត ក្នុងករណីដែលឯកសារចម្លងយថាភូតនៃលិខិតអនុវត្តច្រើនច្បាប់ត្រូវបានផ្តល់ ក្នុងគោលបំណងដើម្បីធ្វើការអនុវត្តដោយបង្ខំចំពោះទ្រព្យសម្បត្តិដែលមានប្រភេទខុសគ្នានៅពេលតែមួយ ជាដើម ត្រូវអនុវត្តដូចគ្នាតាមករណីដែលរូបមន្តអនុវត្តច្រើន ត្រូវបានផ្តល់ដែរ (កថាខណ្ឌទី ៣ នៃមាត្រា ៣៥៥ (ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត) កថាខណ្ឌទី ៣ នៃមាត្រា ៣៥៨ (ការផ្តល់រូបមន្តអនុវត្តច្រើនច្បាប់ជាអាទិ៍) និង កថាខណ្ឌទី ២ នៃមាត្រា ៣៥៩ (ការសរសេរចូលទៅក្នុងច្បាប់ដើមនៃលិខិតអនុវត្ត)) ។

(5) ជាធម្មតា "តុលាការដែលមានសំណុំរឿង" គឺជាសាលាដំបូង ប៉ុន្តែ ក្នុងករណីដែលធ្វើការអនុវត្តដោយបង្ខំដោយយកសាលក្រមដែលភ្ជាប់នឹងការប្រកាសអនុវត្តជាបណ្តោះអាសន្ន មកជាលិខិតអនុវត្ត ហើយរឿងក្តីនោះកំពុងចាត់ការនៅតុលាការជាន់ខ្ពស់ និង សំណុំរឿង ក៏មាននៅតុលាការជាន់ខ្ពស់ "តុលាការដែលមានសំណុំរឿង" សំដៅទៅលើតុលាការជាន់ខ្ពស់ ។ ម្យ៉ាងទៀត នៅពេលរឿងក្តីបានបញ្ចប់នៅតុលាការជាន់ខ្ពស់ សំណុំរឿងក៏នៅតុលាការជាន់ខ្ពស់ដែរ បើគ្មានបញ្ញត្តិពិសេសស្តីពីការរក្សាទុកសំណុំរឿង ។ ហេតុដូច្នេះ ក្រឡាបញ្ជីនៃតុលាការជាន់ខ្ពស់ ត្រូវផ្តល់រូបមន្តអនុវត្ត ។

ប្រសិនបើមានបញ្ហាក្នុងការឱ្យក្រឡាបញ្ជីនៃតុលាការជាន់ខ្ពស់ទទួលបន្ទុកនូវការផ្តល់រូបមន្តអនុវត្ត យើងអាចថែងថាសំណុំរឿងក្តីដែលបានចូលជាស្ថាពរ ត្រូវផ្ញើទៅសាលាដំបូងដើម្បីឱ្យរក្សាទុកនូវសំណុំរឿងនោះ ហើយក្រឡាបញ្ជីនៃសាលាដំបូងត្រូវទទួលបន្ទុកនូវការផ្តល់រូបមន្តអនុវត្ត (សូមមើលមាត្រា 185 មាត្រា 186 និង មាត្រា 205 នៃបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជប៉ុន) ។ បើយកប្រព័ន្ធនេះ ត្រូវមានបញ្ញត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ឬ ច្បាប់ស្តីពីតុលាការ ដូចខាងក្រោម :

"នៅពេលរឿងក្តីបានបញ្ចប់ នៅតុលាការជាន់ខ្ពស់ តុលាការនោះត្រូវផ្ញើសំណុំរឿង ទៅសាលាដំបូង ។"

<u>Civil Execution Act (Japan)</u>

**Article 25** (Effectuation of compulsory execution)

Compulsory execution shall be effected based on an exemplification of the obligation title to which the execution clause is attached, provided that, compulsory execution by virtue of a payment order accompanied by a declaration of provisional execution against or for the parties designated therein shall be effected based on the exemplification thereof.

**Article 26** (Attachment of execution clause)

1. With respect to an obligation title other than an execution document, the execution clause shall be attached to it by the court clerk of the execution court where the record of the case is kept, and with respect to the execution document, the execution clause shall be attached to it by the notary holding the original of such document.

2. The attachment of the execution clause shall be accompanied by a remark at the end of the exemplification of the obligation title stating that the obligee may effect compulsory execution against the obligor by virtue of the obligation title.

**មាត្រា ៣៥៥.-** ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត

១- ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត ត្រូវធ្វើឡើងដោយលិខិតជាលាយល័ក្ខណ៍អក្សរដែលសរសេរចំណុចដូចខាងក្រោមនេះ :

**ក-** ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត ហើយនិង

ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

**ខ**- សញ្ញាណនៃលិខិតអនុវត្ត ។

**គ**- ហេតុការណ៍ និង មូលហេតុ បើការទាមទារឱ្យផ្តល់រូបមន្តអនុវត្តត្រូវធ្វើឡើង តាមបញ្ញត្តិនៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) ឬ កថាខណ្ឌទី ១ នៃមាត្រា ៣៥៨ (ការផ្តល់រូបមន្តអនុវត្តច្រើនច្បាប់ ជាអាទិ៍) នៃក្រមនេះ ។

២- ក្នុងករណីដែលលិខិតអនុវត្តជាសេចក្តីសម្រេចដែលមិនបង្កើតអានុភាពបើមិនចូលជាស្ថាពរទេ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្តដាក់ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត ចំពោះលិខិតអនុវត្តនោះ ម្ចាស់បំណុលនៃការអនុវត្តត្រូវភ្ជាប់មកជាមួយពាក្យសុំនូវលិខិតបញ្ជាក់ការចូលជាស្ថាពរនៃសេចក្តីសម្រេចនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលច្បាស់លាស់ថា សេចក្តីសម្រេចនោះបានចូលជាស្ថាពរហើយ ក្នុងសំណុំរឿង ។

៣- បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បំណុលនៃការអនុវត្តទាមទារឱ្យប្រគល់ថែមទៀតនូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ មាត្រា ៣៥៤ (ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្តល់រូបមន្តអនុវត្ត) នៃក្រមនេះ ។

(កំណត់)

(1) សូមមើលបទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 16 ។

(2) "ហេតុការណ៍" នៅក្នុងចំណុច **គ** កថាខណ្ឌទី ១ សំដៅទៅលើ ហេតុការណ៍ដែលម្ចាស់បំណុលនៃការអនុវត្តទាមទារឱ្យផ្តល់រូបមន្តអនុវត្តត្រូវធ្វើឡើងតាមបញ្ញត្តិនៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) ឬ កថាខណ្ឌទី ១ នៃមាត្រា ៣៥៨ (ការផ្តល់រូបមន្តអនុវត្តច្រើនច្បាប់ ជាអាទិ៍) ។

(3) "លិខិតអនុវត្តដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចដែលមិនបង្កើតអានុភាពបើមិនចូលជាស្ថាពរទេ" គឺជាលិខិតអនុវត្តដែលចែងនៅចំណុច **គ ឆ ឋ** នៃកថាខណ្ឌទី ២ មាត្រា ៣៥០ (លិខិតអនុវត្ត) និង ជាដីកាសម្រេចដែលមិនបង្កើតអានុភាពបើមិនចូលជាស្ថាពរ ដែលចែងនៅចំណុច **គ** នៃកថាខណ្ឌដូចគ្នានេះ ។ ចំពោះការចូលជាស្ថាពរនៃសេចក្តីសម្រេច ភាគី និង ជនដែលធ្វើសេចក្តីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ អាចទាមទារឱ្យក្រឡាបញ្ជីប្រគល់នូវលិខិតបញ្ជាក់អំពីហេតុការណ៍នោះបាន (មាត្រា ២៥៨ (ការទាមទារមើលសំណុំរឿងនៃបណ្តឹង ជាអាទិ៍)) ។

(4) ចំពោះការចាត់ចែងអំពីពាក្យសុំ (ការផ្តល់រូបមន្តអនុវត្ត ឬ បដិសេធការផ្តល់) អាចដាក់ពាក្យសុំតវ៉ាបាន តាមមាត្រា ៣៦២ (ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត ជាអាទិ៍) ។

**មាត្រា ៣៥៦.-** រូបមន្តអនុវត្តពិសេស

១- នៅក្នុងករណីដែលសិទ្ធិទាមទារដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ឬ ពេលកំណត់មិនពិតប្រាកដ ក្រឡាបញ្ជី ឬ សារការីអាចប្រគល់រូបមន្តអនុវត្តបាន លុះត្រាតែម្ចាស់បំណុលនៃការអនុវត្តបានបញ្ជាក់អំពីការបំពេញល័ក្ខខ័ណ្ឌ ឬ ការមកដល់នូវពេលកំណត់មិនពិតប្រាកដនោះ ។

២- ដើម្បីធ្វើការអនុវត្តដោយបង្ខំដោយយកបុគ្គលផ្សេង ក្រៅពីភាគីដែលត្រូវបានសរសេរលើលិខិតអនុវត្ត ធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តត្រូវទទួលការផ្តល់រូបមន្តអនុវត្ត ដែលមានសរសេរនូវហេតុការណ៍នោះ ។

៣- ក្នុងករណីដែលមានភាពច្បាស់លាស់ថា អាចនឹងធ្វើការអនុវត្តដោយបង្ខំ ដោយយកបុគ្គលផ្សេងក្រៅពីភាគីដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត ធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត ឬ ករណីដែលម្ចាស់បំណុលនៃការអនុវត្តបានបញ្ជាក់ដោយលិខិតអំពីហេតុការណ៍នោះ ក្រឡាបញ្ជី ឬ សារការីអាចផ្តល់នូវរូបមន្តអនុវត្តដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះបាន ។

៤- នៅពេលក្រឡាបញ្ជីផ្តល់រូបមន្តអនុវត្តដោយយោលតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ៣ ខាងលើនេះ ក្រឡាបញ្ជីនោះត្រូវទទួលសេចក្តីអនុញ្ញាតពីតុលាការដែលខ្លួនស្ថិតនៅ ។

（កំណត់）

(1) សូមមើលមាត្រា 27 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន និង មាត្រា 520 ចាស់ នៃក្រមនីតិវិធីរដ្ឋប្បវេណីចាស់នៃប្រទេសជប៉ុន ។

(2) កថាខណ្ឌទី ២ នៃមាត្រានេះ គឺជាបញ្ញត្តិដែលត្រូវយកមកអនុវត្តក្នុងករណីដែលការអនុវត្តដោយបង្ខំត្រូវបានអនុញ្ញាតយោងទៅតាមមាត្រា ៣៥១（វិសាលភាពនៃអ្នកដែលអាចអនុវត្តដោយបង្ខំ）ដោយយកបុគ្គល（អ្នកបន្ត ជាដើម）ផ្សេងពីភាគីដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្តនោះធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត ។

(3) ក្នុងករណីដែលរូបមន្តអនុវត្តពិសេសត្រូវបានផ្តល់ ដោយយោងទៅតាមមាត្រានេះ កូនបំណុលនៃការអនុវត្តអាចធ្វើវិវាទលើការផ្តល់រូបមន្តអនុវត្ត តាមការដាក់ពាក្យសុំតវ៉ា（មាត្រា ៣៦២（ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្តជាអាទិ៍））ឬ បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត（មាត្រា ៣៦៤（បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត））បាន ។ ចំពោះទំនាក់ទំនងនៃករណីទាំងពីរ សូមមើលកំណត់（2）នៃមាត្រា ៣៦៤（បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត）។

Civil Execution Act (Japan)
**Article 27** (Attachment of execution clause)
1. In cases where a claim depends on the future occurrence of a fact to be proved by the obligee, the execution clause may be attached only when the obligee submits a document which proves such fact.
2. In cases where a person other than a party designated in the obligation title becomes the obligee or obligor, the execution clause against or for such person may be attached only when it is clear to the court clerk or notary that compulsory execution may be

effected against or for such person or when the obligee submits a document proving this.

**មាត្រា ៣៥៧.-** ចំណុចដែលត្រូវសរសេរក្នុងរូបមន្តអនុវត្ត

១- ការផ្តល់រូបមន្តអនុវត្ត ត្រូវធ្វើឡើងតាមវិធីសរសេរភ្ជាប់បន្ថែម នៅផ្នែកក្រោមនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត នូវចំណុចនីមួយៗដូចខាងក្រោមនេះ :

**ក-** បុគ្គលដែលអាចទាមទារឱ្យធ្វើការអនុវត្តដោយបង្ខំបាន ដោយលិខិតអនុវត្តនោះ និង ភាគីម្ខាងទៀត ។

**ខ-** ហេតុការណ៍ ក្នុងករណីដែលបានផ្តល់រូបមន្តអនុវត្ត តាមបញ្ញត្តិនៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) នៃក្រមនេះ ។

**គ-** ទំហំដែលអាចអនុវត្តដោយបង្ខំបាន បើបានផ្តល់រូបមន្តអនុវត្តតែមួយផ្នែកនៃសិទ្ធិទាមទារដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត ។

**ឃ-** ហេតុការណ៍ ក្នុងករណីដែលផ្តល់រូបមន្តអនុវត្ត តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៣៥៨ (ការផ្តល់រូបមន្តអនុវត្តច្រើនច្បាប់ ជាអាទិ៍) នៃក្រមនេះ ។

២- ក្រឡាបញ្ជី ឬ សារការី ត្រូវចុះហត្ថលេខាលើរូបមន្តអនុវត្ត ដោយសរសេរថ្ងៃ ខែ ឆ្នាំនៃការផ្តល់ ។

(កំណត់)

(1) សូមមើលកថាខណ្ឌទី 2 មាត្រា 26 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណី និង មាត្រា 17 នៃបទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

(2) ចំណុច **ខ** កថាខណ្ឌទី ១ នៃមាត្រានេះ មានអត្ថន័យបញ្ជាក់ច្បាស់ថា នៅក្នុងករណីដែលក្រឡាបញ្ជី ឬ សារការីបានផ្តល់រូបមន្តអនុវត្ត ដោយបញ្ជាក់អំពីការមកដល់នៃពេលកំណត់មិនពិតប្រាកដ ឬ ការបំពេញល័ក្ខខ័ណ្ឌ ឬ នៅក្នុងករណីដែលបានផ្តល់រូបមន្តអនុវត្តដែលយកបុគ្គលផ្សេងពីភាគីដែលត្រូវបានសរសេរនៅក្នុងលិខិតអនុវត្ត ធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត ដោយបញ្ជាក់អំពីការទទួលបន្តសិទ្ធិ ឬ កាតព្វកិច្ច ជាដើម ដោយយោងតាមបញ្ញត្តិនៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) ក្រឡាបញ្ជី ឬ សារការីនោះត្រូវសរសេរហេតុការណ៍នោះនៅក្នុងរូបមន្តអនុវត្ត ។

Civil Execution Act (Japan)
**Article 26** (Attachment of execution clause) (excerpt)
2. The attachment of the execution clause shall be accompanied by a remark at the end of the exemplification of the obligation title stating that the obligee may effect compulsory execution against the obligor by virtue of the obligation title.

**មាត្រា ៣៥៨.-** ការផ្តល់រូបមន្តអនុវត្តច្រើនច្បាប់ ជាអាទិ៍

១- មានតែនៅក្នុងករណីដែលចាំបាច់ត្រូវការឯកសារចម្លងយថាភូតច្រើនច្បាប់នៃលិខិតអនុវត្ត ដែលភ្ជាប់នឹងរូបមន្ត

អនុវត្ត ដើម្បីទទួលសំណងពេញលេញនៃសិទ្ធិទាមទារ ឬ នៅក្នុងករណីដែលឯកសារចម្លងយថាភូតនោះបានបាត់បង់តែប៉ុណ្ណោះទេ ទើបអាចផ្ដល់រូបមន្តអនុវត្តបន្ថែមទៀតបាន ។

២- បើផ្ដល់រូបមន្តអនុវត្ត តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ក្រឡាបញ្ជី ឬ សារការីត្រូវជូនដំណឹងទៅកូនបំណុលនៃការអនុវត្ត អំពីហេតុការណ៍និងមូលហេតុនោះ និង ចំនួននៃឯកសារចម្លងយថាភូតដែលត្រូវបានផ្ដល់រូបមន្តអនុវត្ត ។

៣- បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលប្រគល់បន្ថែមទៀតនូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ មាត្រា ៣៥៤ (ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្ដល់រូបមន្តអនុវត្ត) នៃក្រមនេះ ។

(កំណត់)

(1) សូមមើលមាត្រា 28 នៃច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណី និង បទប្បញ្ញត្តិស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 19 ។

(2) ឃ្លាខាងដំបូងនៃកថាខណ្ឌទី ១ នៃមាត្រានេះ គឺជាបញ្ញត្តិដែលអនុញ្ញាតឱ្យម្ចាស់បំណុលនៃការអនុវត្តកាន់កាប់ឯកសារចម្លងយថាភូតច្រើនច្បាប់នៃលិខិតអនុវត្តដែលភ្ជាប់នឹងរូបមន្តអនុវត្ត (ការផ្ដល់ច្រើនច្បាប់) ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តចាំបាច់ត្រូវធ្វើការអនុវត្តដោយបង្ខំព្រមជាមួយគ្នាចំពោះទ្រព្យសម្បត្តិច្រើន (ចលនវត្ថុ និង សិទ្ធិលើបំណុល ចលនវត្ថុដែលមាននៅទីកន្លែងខុសគ្នា ជាដើម) ដើម្បីទទួលការសងគ្រប់ចំនួនសិទ្ធិលើបំណុលដែលអនុវត្តដោយបង្ខំ ។ ឯឃ្លាខាងក្រោយនៃកថាខណ្ឌទី ១ នៃមាត្រានេះ គឺជាបញ្ញត្តិដែលអនុញ្ញាតឱ្យទទួលនូវការផ្ដល់រូបមន្តអនុវត្តសាជាថ្មី ក្នុងករណីម្ចាស់បំណុលនៃការអនុវត្តបានទទួលការផ្ដល់នូវរូបមន្តអនុវត្តរួចម្ដងហើយ តែបានបាត់បង់ឯកសារចម្លងយថាភូតនេះ (ការផ្ដល់សាជាថ្មី) ។

(3) ដោយហេតុថា ការផ្ដល់រូបមន្តអនុវត្តច្រើនច្បាប់ ឬ ការផ្ដល់សាជាថ្មីនោះអាចបណ្ដាលឱ្យមានគ្រោះវិបត្តិ ក្នុងការអនុវត្តដោយបង្ខំហួសហេតុ បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រានេះ តម្រូវឱ្យផ្ដល់ពត៌មានដល់កូនបំណុលនៃការអនុវត្តអំពីការផ្ដល់រូបមន្តនោះដើម្បីឱ្យធ្វើការប្រុងប្រយ័ត្ន ។

Civil Execution Act (Japan)
**Article 28** (Additional attachment of execution clause)
1. Additional attachment of the execution clause may only be made in cases where two or more exemplifications to which the execution clauses are attached are necessary for complete satisfaction of the obligation-right, or such exemplification has been lost.
2. The provisions of the preceding paragraph shall apply mutatis mutandis to cases where the exemplification of a payment order accompanied by a declaration of provisional execution is to be additionally delivered.

**មាត្រា ៣៥៩.-** ការសរសេរចូលទៅក្នុងច្បាប់ដើមនៃលិខិតអនុវត្ត

១- នៅពេលផ្ដល់រូបមន្តអនុវត្ត ក្រឡាបញ្ជី ឬ សារការី ត្រូវសរសេរនៅក្នុងច្បាប់ដើមនៃលិខិតអនុវត្ត នូវចំណុចដូចខាងក្រោមនេះ :

**ក-** ហេតុការណ៍នៃការផ្ដល់រូបមន្តអនុវត្ត ថ្ងៃ ខែ ឆ្នាំដែលផ្ដល់ និង ចំនួនឯកសារចម្លងយថាភូតដែលត្រូវបានផ្ដល់រូបមន្តអនុវត្ត ។

**ខ-** ទំហំដែលអាចអនុវត្តដោយបង្ខំបាន ក្នុងករណីដែលបានផ្ដល់រូបមន្តអនុវត្ត ចំពោះតែមួយផ្នែកនៃសិទ្ធិទាមទារដែលបានកំណត់ នៅក្នុងលិខិតអនុវត្ត ។

**គ-** ហេតុការណ៍ និង ឈ្មោះ ឬ នាមករណ៍របស់ម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត ក្នុងករណីដែលបានផ្ដល់រូបមន្តអនុវត្ត តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) នៃក្រមនេះ ។

២- បើក្រឡាបញ្ជីបានប្រគល់ឯកសារចម្លងយថាភូតនៃលិខិតអនុវត្តថែមទៀត តាមបញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ មាត្រា ៣៥៤ (ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្ដល់រូបមន្តអនុវត្ត) នៃក្រមនេះ ក្រឡាបញ្ជីនោះត្រូវសរសេរអំពីហេតុការណ៍នៃការផ្ដល់រូបមន្តអនុវត្តនេះ ថ្ងៃ ខែ ឆ្នាំដែលផ្ដល់ និង ចំនួនឯកសារចម្លងយថាភូតដែលបានប្រគល់ នៅក្នុងច្បាប់ដើមនៃសាលក្រម ឬ សាលដីកា ឬ ដីកាសម្រេចដាស់តឿន ។

(កំណត់)

សូមមើលបទប្បញ្ញត្តិស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 18 ។

"ហេតុការណ៍" នៅក្នុងចំណុច **គ** សំដៅទៅលើហេតុការណ៍ដែលបានផ្ដល់រូបមន្តអនុវត្តពិសេស តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) ។

**មាត្រា ៣៦០.-** ការបញ្ជូនលិខិតអនុវត្ត ជាអាទិ៍

ការអនុវត្តដោយបង្ខំ អាចចាប់ផ្ដើមធ្វើបាន តែក្នុងករណីដែលឯកសារចម្លងយថាភូត ឬ ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃលិខិតអនុវត្ត ឬ សេចក្ដីសម្រេចដែលនឹងក្លាយជាលិខិតអនុវត្តនៅពេលចូលជាស្ថាពរ ត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្តជាមុន ។ នៅក្នុងករណីដែលរូបមន្តអនុវត្តត្រូវបានផ្ដល់ តាមបញ្ញត្តិនៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) នៃក្រមនេះ ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃរូបមន្តអនុវត្ត និង ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃឯកសារដែលម្ចាស់បំណុលនៃការអនុវត្តបានដាក់ តាមបញ្ញត្តិនៃមាត្រា ៣៥៦ នោះ ក៏ត្រូវបញ្ជូនទៅជាមុនផងដែរ ។

(កំណត់)

(1) សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 29 ។

(2) មូលហេតុដែលមាត្រានេះតម្រូវឱ្យបញ្ជូននូវលិខិតអនុវត្ត ជាអាទិ៍ នៅពេលចាប់ផ្ដើមការអនុវត្តដោយបង្ខំ គឺ

ដើម្បីជូនដំណឹងទៅកូនបំណុលនៃការអនុវត្តថា នីតិវិធីនៃការអនុវត្តនឹងចាប់ផ្តើមចំពោះសិទ្ធិលើបំណុលណាមួយ ក្នុងគោលបំណងផ្តល់ឱកាសការពារខ្លួនដល់កូនបំណុលនៃការអនុវត្ត ។ ប៉ុន្តែ ក្នុងករណីដែលធ្វើការអនុវត្តដោយបង្ខំ ដោយយកសាលក្រមស្ថាពរ ឬ សាលដីកាស្ថាពរធ្វើជាលិខិតអនុវត្ត សាលក្រម ឬ សាលដីកានោះ ត្រូវបាន បញ្ជូនទៅឱ្យភាគីរួចទៅហើយ (សូមមើលមាត្រា ១៩០ (ការបញ្ជូនលិខិតសាលក្រម) នៃផ្នែកទី ៣ ជំពូកទី ៥ គន្ថីទី ២)) ហេតុដូច្នេះ នៅពេលចាប់ផ្តើមការអនុវត្តដោយបង្ខំ ពុំចាំបាច់បញ្ជូនសាជាថ្មីទៀតទេ ។

(3) ការបញ្ជូននេះចាំបាច់ត្រូវធ្វើ "ជាមុន" ប៉ុន្តែ ចំពោះពេលវេលាច្បាស់លាស់ដែលត្រូវបញ្ជូនវិញ គឺខុសគ្នា ទៅតាមប្រភេទនៃការអនុវត្ត ។ ក្នុងការអនុវត្តចំពោះចលនវត្ថុ ឬ ការអនុវត្តឱ្យប្រគល់ឬចេញ អាជ្ញាសាលា គ្រាន់តែអាចធ្វើការបញ្ជូននៅពេលជាមួយគ្នានឹងការចាប់ផ្តើមការអនុវត្តនៅទីកន្លែងនោះបាន ។ ចំពោះករណីនៃ ការអនុវត្តចំពោះសិទ្ធិលើបំណុល ឬ អចលនវត្ថុវិញ ការបញ្ជូនលិខិតបញ្ជាក់អនុវត្ត ជាដើម គឺជាមូលដ្ឋាន ដែលតុលាការអនុវត្ត ចេញដីកាសម្រេចរឹបអូស ឬ ដីកាសម្រេចចាប់ផ្តើម ហេតុដូច្នេះ ការបញ្ជូន ចាំបាច់ត្រូវធ្វើ នៅមុនពេលដែលម្ចាស់បំណុលដាក់ពាក្យសុំឱ្យអនុវត្ត ។

(4) នៅពេលអនាគតដែលរៀបចំនូវប្រព័ន្ធសារការី ចាំបាច់ត្រូវមានបញ្ញត្តិដូចមាត្រា 20 នៃបទប្បញ្ញត្តិស្តីពីការអនុវត្ត ផ្នែករដ្ឋប្បវេណីជប៉ុន ។

<u>Civil Execution Act (Japan)</u>
**Article 29** (Service of obligation title; Commencement of Compulsory execution)
Compulsory execution may be commenced only when the obligation title or the exemplification or transcript of decision which will become an obligation title upon its becoming final and binding is previously or simultaneously served on the obligor. In cases where the execution clause is issued in accordance with the provisions of Article 27, the execution clause and a transcript of the document submitted by the obligee in accordance with the provisions of the said article must also be previously or simultaneously served.

**មាត្រា ៣៦១.-** ល័ក្ខខ័ណ្ឌនៃការចាប់ផ្តើមអនុវត្តដែលស្ថាប័នអនុវត្តត្រូវស្រាវជ្រាវ

១- ក្នុងករណីសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងលិខិតអនុវត្ត ភ្ជាប់ជាមួយនឹងពេលកំណត់ពិតប្រាកដ ស្ថាប័នអនុវត្ត អាចចាប់ផ្តើមអនុវត្តដោយបង្ខំបាន លុះត្រាតែពេលកំណត់នោះបានមកដល់ហើយ ។

២- ចំពោះការអនុវត្តដោយបង្ខំ ដោយផ្អែកលើលិខិតអនុវត្តដែលមានដាក់ល័ក្ខខ័ណ្ឌត្រូវដាក់ប្រាតិភោគដើម្បីអនុវត្ត ដោយបង្ខំ ស្ថាប័នអនុវត្តអាចចាប់ផ្តើមអនុវត្តដោយបង្ខំបាន លុះត្រាតែម្ចាស់បំណុលនៃការអនុវត្តបានដាក់លិខិតដែល បញ្ជាក់ថា ខ្លួនបានដាក់ប្រាតិភោគនោះរួចហើយ ។

៣- ក្នុងករណីតាវកាលិករបស់កូនបំណុលនៃការអនុវត្ត ត្រូវផ្តល់ដោយប្តូរនឹងតាវកាលិកតប ស្ថាប័នអនុវត្តអាចចាប់ផ្តើម អនុវត្តដោយបង្ខំបាន លុះត្រាតែម្ចាស់បំណុលនៃការអនុវត្តបញ្ជាក់ថា ខ្លួនបានផ្តល់តាវកាលិកតបនោះ ឬ បានស្នើផ្តល់ តាវកាលិកតបនោះ ។

(កំណត់)

(1) សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 30 និង មាត្រា 31 ។

(2) មាត្រានេះបញ្ញត្តអំពីល័ក្ខខ័ណ្ឌនៃការចាប់ផ្តើមអនុវត្ត ។ ល័ក្ខខ័ណ្ឌនៃការចាប់ផ្តើមអនុវត្ត គឺជាល័ក្ខខ័ណ្ឌសារធាតុចាំបាច់ក្នុងការចាប់ផ្តើមអនុវត្តដោយបង្ខំ ប៉ុន្តែ នៅពេលដែលស្ថាប័នអនុវត្តចាប់ផ្តើមធ្វើនីតិវិធីអនុវត្តដោយបង្ខំ ស្ថាប័ននេះស្រាវជ្រាវ និង សម្រេចអំពីល័ក្ខខ័ណ្ឌនោះដោយខ្លួនឯង ។ ចំណុចនេះចែកដាច់ពីគ្នាពីល័ក្ខខ័ណ្ឌនៃការផ្តល់រូបមន្តអនុវត្ត ។ ការមកដល់នូវពេលកំណត់មិនពិតប្រាកដ ជាល័ក្ខខ័ណ្ឌនៃការផ្តល់រូបមន្តអនុវត្ត (កថាខណ្ឌទី ១ មាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស)) ចំណែកឯការមកដល់នូវពេលកំណត់ពិតប្រាកដ គឺជាល័ក្ខខ័ណ្ឌនៃការចាប់ផ្តើមអនុវត្ត (កថាខណ្ឌទី ១ នៃមាត្រានេះ) ដោយហេតុថាជាការងាយស្រួលក្នុងការបញ្ជាក់អំពីការមកដល់នូវពេលកំណត់ពិតប្រាកដ ដូច្នេះបើទុកឱ្យស្ថាប័នអនុវត្តជាអ្នកសម្រេច ក៏មិនមែនជាបន្ទុកដ៏ធ្ងន់ធ្ងរដែរ ។

(3) កថាខណ្ឌទី ៣ នៃមាត្រានេះ ត្រូវយកមកអនុវត្ត ចំពោះករណីនៃការអនុវត្តដោយបង្ខំ ដោយផ្អែកលើសាលក្រម ឬសាលដីកាដែលបង្គាប់ឱ្យផ្តល់តាវកាលិក ដោយប្តូរជាមួយនឹងតាវកាលិកតប ជាដើម ។ មូលហេតុដែលយកការអនុវត្តផ្តល់តាវកាលិកតប ឬ សំណើអនុវត្តតាវកាលិកតប មកធ្វើជាល័ក្ខខ័ណ្ឌនៃការចាប់ផ្តើមអនុវត្តនេះ គឺដើម្បីរក្សាទុកនូវទំនាក់ទំនងនៃការអនុវត្តព្រមគ្នាដែលបានចែងក្នុងច្បាប់សារធាតុ នៅក្នុងការអនុវត្តដោយបង្ខំ ។ បើយកការអនុវត្តតាវកាលិកតប ឬ សំណើអនុវត្តតាវកាលិកតប ជាល័ក្ខខ័ណ្ឌនៃការផ្តល់រូបមន្តអនុវត្តទៅវិញ បណ្តាលឱ្យទាមទារឱ្យម្ចាស់បំណុលនៃការអនុវត្តធ្វើការអនុវត្តមុន ។

Civil Execution Act (Japan)
**Article 30** (Compulsory execution contingent upon time or provision of security)
1. In cases where a claim is contingent upon the advent of a time certain, compulsory execution may be commenced only after the advent of such time.
2. Compulsory execution by virtue of an obligation title, the effectuation of which is conditioned on security being provided, may be commenced only when the obligee has submitted an official document that proves such security has been provided.
**Article 31** (Compulsory execution contingent upon counter-performance)
1. In cases where performance by the obligor is to be made in exchange for a counter-performance, compulsory execution may be commenced only when the obligee has proved the counter-performance or an offer thereof has been made.
2. In cases where the performance by the obligor is to be made in lieu of another performance, if the subject of compulsory execution for the other performance cannot be accomplished, compulsory execution may be commenced only when the obligee has proved that the subject of compulsory execution for the other performance has not been accomplished.

**មាត្រា ៣៦២.-** ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត ជាអាទិ៍

១- ចំពោះការចាត់ចែងពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត បើជាការចាត់ចែងរបស់ក្រឡាបញ្ជី អាចដាក់ពាក្យសុំតវ៉ាទៅតុលាការដែលក្រឡាបញ្ជីនោះស្ថិតនៅ តែបើជាការចាត់ចែងរបស់សារការី អាចដាក់ពាក្យសុំតវ៉ា ទៅសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនៃការិយាល័យរបស់សារការីនោះ ។

២- ការសម្រេចសេចក្តីអំពីពាក្យសុំតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើដោយដីកាសម្រេច ។

៣- បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមាន

ពាក្យសុំឱ្យប្រគល់បន្ថែមទៀតនូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ មាត្រា ៣៥៤ (ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្តល់រូបមន្តអនុវត្ត) នៃក្រមនេះ ។

(កំណត់)

(1) សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 32 ។

(2) ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តតវ៉ាចំពោះការចាត់ចែងដែលបដិសេធការផ្តល់នូវរូបមន្តអនុវត្ត តែត្រូវបានលើកចោល ឬ ក្នុងករណីដែលពាក្យសុំតវ៉ារបស់កូនបំណុលនៃការអនុវត្តចំពោះការផ្តល់រូបមន្តអនុវត្តត្រូវបានទទួលស្គាល់ ហើយការផ្តល់រូបមន្តអនុវត្តនេះត្រូវបានលុបចោល នោះម្ចាស់បំណុលនៃការអនុវត្តពុំអាចធ្វើឧបាស្រ័យថែមទៀតបានទេ ។ ប៉ុន្តែ ម្ចាស់បំណុលនៃការអនុវត្តដែលពុំអាចទទួលនូវការផ្តល់រូបមន្តអនុវត្តពិសេស តាមមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) អាចដាក់ពាក្យបណ្តឹងទាមទារឱ្យផ្តល់តាវកាលិកតាមបណ្តឹងធម្មតា ហើយអះអាង និង បញ្ជាក់អំពីការបំពេញល័ក្ខខ័ណ្ឌ ឬ អង្គហេតុទទួលបន្ត ដើម្បីទទួលសាលក្រមដែលបង្គាប់ឱ្យផ្តល់តាវកាលិកថ្មី (សាលក្រមដែលបង្គាប់ឱ្យផ្តល់តាវកាលិកដោយគ្មានល័ក្ខខ័ណ្ឌ សាលក្រមដែលបង្គាប់ឱ្យផ្តល់តាវកាលិកដែលយកអ្នកបន្តធ្វើជាភាគី) បាន ។

(3) ចំពោះការផ្តល់រូបមន្តអនុវត្តពិសេស (មាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស)) កូនបំណុលនៃការអនុវត្តអាចដាក់ពាក្យសុំតវ៉ា ដោយយោងតាមមាត្រានេះបាន ។ ផ្សេងពីនេះ កូនបំណុលនៃការអនុវត្តក៏អាចដាក់ពាក្យបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្តបានដែរ (តាមមាត្រា ៣៦៤ (បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត)) ។ ចំពោះទំនាក់ទំនងរវាងករណីទាំងពីរខាងលើនេះ សូមមើលទៅកំណត់ (2) នៃមាត្រា ៣៦៤ (បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត) ។

Civil Execution Act (Japan)
**Article 32** (Objection against issuance of execution clause)
1. An objection may be raised against a disposition made by the court clerk concerning a motion for the issuance of an execution clause to the court which such clerk serves, and against a disposition made by a notary concerning a motion for issuance of an execution clause to the district court which has jurisdiction over the place of such notary's office.
2. In cases where an objection has been raised against the issuance of an execution clause, the court may order a stay of compulsory execution either upon or without security being provided, or continuation of compulsory execution upon security being provided until it renders a decision on the objection. In cases of urgency, the presiding judge may also order such disposition.
3. A decision on a motion according to the provisions of paragraph 1 or a decision according to the provisions of the preceding paragraph may be rendered without resorting to oral argument.
4. No appeal may be filed against either decision referred to in the preceding paragraph.
5. The provisions of the preceding paragraphs shall apply mutatis mutandis to delivery of the exemplification of payment order accompanied by a declaration of provisional execution according to the provisions of Article 28, paragraph 2.

## ផ្នែកទី ៥ បណ្តឹងពាក់ព័ន្ធនឹងការអនុវត្ត

**មាត្រា ៣៦៣.-** បណ្តឹងតវ៉ាចំពោះការទាមទារ

១- កូនបំណុលនៃការអនុវត្តដែលមានការតវ៉ាចំពោះអត្ថិភាព ឬ អត្ថន័យនៃសិទ្ធិទាមទារ ដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត អាចដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ដើម្បីកុំឱ្យតុលាការអនុញ្ញាតការអនុវត្តដោយបង្ខំ ដោយផ្អែកលើលិខិតអនុវត្តនោះបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះលិខិតអនុវត្តដែលបានកំណត់នៅក្នុងចំណុច **ខ** ឬ ចំណុច **ឃ** នៃកថាខណ្ឌទី ២ មាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ ហើយមិនទាន់ចូលជាស្ថាពរ ។

២- មូលហេតុនៃការតវ៉ាចំពោះសាលក្រម ឬ សាលដីកាស្ថាពរ ត្រូវបានកម្រិតត្រឹមតែហេតុដែលកើតឡើងនៅក្រោយការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់តែប៉ុណ្ណោះ ។

៣- បណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការ តាមការកំណត់នីមួយៗ យោលទៅតាមផ្នែកនៃលិខិតអនុវត្តដែលបានកំណត់ក្នុងចំណុចនីមួយៗខាងក្រោមនេះ :

- **ក**- លិខិតអនុវត្តដែលបានកំណត់ចាប់ពីចំណុច **ក** រហូតទៅដល់ចំណុច **ឃ** ឬ ចាប់ពីចំណុច **ឆ** រហូតទៅដល់ចំណុច **ឈ** កថាខណ្ឌទី ២ មាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ : សាលាដំបូងនៃនីតិវិធីសម្រេចសេចក្តីនោះ ។
- **ខ**- លិខិតអនុវត្តដែលបានកំណត់នៅចំណុច **ខ** កថាខណ្ឌទី ២ មាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ : តុលាការដែលក្រឡាបញ្ជីចាត់ចែងដូចចំណុចនោះ ស្ថិតនៅ ។
- **គ**- លិខិតអនុវត្តដែលបានកំណត់នៅចំណុច **ច** កថាខណ្ឌទី ២ មាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ : តុលាការដែលមានសមត្ថកិច្ចលើទីកន្លែងរបស់ចុងចម្លើយដែលត្រូវបានកំណត់ដោយមាត្រា ៨ ( សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍) នៃក្រមនេះ ។ បើពុំមានតុលាការដែលមានសមត្ថកិច្ចតាមមាត្រានេះទេ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលកម្មវត្ថុនៃការទាមទារ ឬ ទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ដែលអាចរឹបអូសបាន ស្ថិតនៅ ។

(កំណត់)

(1) សូមមើលមាត្រា 35 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

(2) បណ្តឹងតវ៉ាចំពោះការទាមទារ ជាបណ្តឹងដែលមានគោលបំណងបញ្ជាក់ច្បាស់ដោយយោងតាមនីតិវិធីបណ្តឹងថាការអនុវត្តដោយបង្ខំ មិនត្រូវបានអនុញ្ញាត ដោយផ្អែកលើលិខិតអនុវត្តដែលមានកំណត់ ។ មូលហេតុសំខាន់នៃការតវ៉ា គឺ មូលហេតុនៃច្បាប់សារធាតុ ដូចជាការប្រែប្រួលនៅពេលក្រោយនៃសិទ្ធិទាមទារដែលត្រូវបានសរសេរនៅក្នុងលិខិតអនុវត្ត (ឧទាហរណ៍ : ការសង) ។

(3) ការជំនុំជម្រះត្រូវធ្វើឡើងដោយនីតិវិធីបណ្តឹងធម្មតា ។ ចំពោះលទ្ធផលនៃការជំនុំជម្រះ នៅក្នុងករណីដែលការ

តវ៉ានោះ មានមូលហេតុ តុលាការត្រូវធ្វើការប្រកាសអំពីការពុំអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ ដោយផ្អែកលើលិខិតអនុវត្តនោះ នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រម ។ នៅក្នុងករណីដែលសាលក្រមនេះចូលជាស្ថាពរហើយ ឬ មានភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន លិខិតអនុវត្តនោះ នឹងត្រូវបាត់បង់នូវអានុភាពអនុវត្ត ដែលធ្វើឱ្យម្ចាស់បំណុលនៃការអនុវត្តមិនអាចទទួលរូបមន្តអនុវត្ត ចំពោះលិខិតអនុវត្តនោះបានឡើយ ។ បើនីតិវិធីអនុវត្ត ត្រូវបានចាប់ផ្តើមរួចហើយ កូនបំណុលនៃការអនុវត្ត អាចដាក់ជូនស្ថាប័នអនុវត្តនូវអនុសារសាលក្រមនេះ (ឯកសារចម្លងយថាភូតនៃសាលក្រម) ដើម្បីសុំឱ្យផ្អាក និង លុបចោលការអនុវត្ត (ចំណុច ក កថាខណ្ឌទី ១ មាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ)) ។ ចំពោះការចាត់វិធានការផ្អាកការអនុវត្ត ជាដើម ដោយដាក់ពាក្យបណ្តឹង សូមមើលមាត្រា ៣៦៧ (ការសម្រេចសេចក្តីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍) ។

(4) ចំពោះសាលក្រមដែលចូលជាស្ថាពរហើយ នឹងកើតមានឡើងនូវអានុភាពស្ថាពរ (អាជ្ញាអស់ជំនុំ) ដោយយកទំនាក់ទំនងសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តនៅពេលដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះអង្គហេតុក្នុងនីតិវិធីបណ្តឹងនោះ ធ្វើជាមូលដ្ឋាន (កថាខណ្ឌទី ២ នៃមាត្រា ១៩៤ (អាជ្ញាអស់ជំនុំនៃចំណុចដែលត្រូវបានវិនិច្ឆ័យដោយសាលក្រម)) ផ្នែកទី ៥ ជំពូកទី ៥ គន្ថីទី ២) ហេតុដូច្នេះ កូនបំណុលនៃការអនុវត្តពុំអាចដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ដោយអះអាងអំពីអង្គហេតុ ដែលបានកើតឡើងនៅមុនពេលនោះបានឡើយ (កថាខណ្ឌទី ២ នៃមាត្រានេះ) ។

Civil Execution Act (Japan)
**Article 35** (Action of objection to claim)
1. An obligor who has an objection to the existence or contents of a claim right concerning an obligation title (except for an obligation title which has not become final and binding as referred to in Article 22 items ii and iv; this exception shall apply throughout this paragraph) may institute an action of objection to the claim in order to demand a declaration that compulsory execution by virtue of the obligation title shall not be permitted. The same shall apply to cases where the obligor has some objection to the accomplishment of an obligation title other than one created by a court decision.
2. The grounds for objection to a final and binding judgment shall be restricted to those arising after the conclusion of oral argument, and the grounds for objection to a payment order accompanied by a declaration of provisional execution shall be restricted to those arising after service thereof.
3. The provisions of Article 33, paragraph 2 and the preceding Article, paragraph 2 shall apply mutatis mutandis to the action referred to in paragraph 1.

**មាត្រា ៣៦៤.‐** បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត

១- នៅក្នុងករណីដែលរូបមន្តអនុវត្តត្រូវបានផ្តល់ តាមបញ្ញត្តិនៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) នៃក្រមនេះ កូនបំណុលនៃការអនុវត្តដែលមានការតវ៉ាចំពោះការបំពេញល័ក្ខខ័ណ្ឌ ចំពោះការមកដល់ពេលកំណត់មិនពិតប្រាកដ ឬ ចំពោះលទ្ធភាពដែលអាចធ្វើការអនុវត្តដោយបង្ខំ ដោយយកបុគ្គលក្រៅពីភាគីដែលបានកំណត់ក្នុងលិខិតអនុវត្ត មកធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត អាចដាក់ពាក្យបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ដើម្បីកុំឱ្យអនុញ្ញាតការអនុវត្តដោយបង្ខំបាន ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់នឹងរូបមន្តអនុវត្តនោះ ។

២- បញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ៣៦៣ (បណ្តឹងតវ៉ាចំពោះការទាមទារ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

(1) សូមមើលមាត្រា 34 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

(2) បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ធ្វើឡើងក្នុងគោលបំណងឱ្យកូនបំណុលនៃការអនុវត្ត ទាមទារកុំឱ្យធ្វើការអនុវត្តដោយបង្ខំ ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តពិសេសដែលត្រូវបានផ្តល់ដោយយោងទៅតាមមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) ដោយអាចអះអាងអំពីនត្ថិភាពនៃហេតុដែលត្រូវនឹងល័ក្ខខ័ណ្ឌនៃការផ្តល់រូបមន្តអនុវត្ត (ការបំពេញល័ក្ខខ័ណ្ឌ ការមកដល់នៃពេលកំណត់មិនពិតប្រាកដ ឬ ការអនុញ្ញាតឱ្យយកបុគ្គលក្រៅពីភាគីដែលកំណត់នៅក្នុងលិខិតអនុវត្ត ធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត) ដោយយកម្ចាស់បំណុលនៃការអនុវត្តមកធ្វើជាចុងចម្លើយ ។
ម៉្យាងទៀតក៏អាចធ្វើវិវាទអំពីអង្គហេតុដូចគ្នានេះ ដោយការតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្តបានដែរ (មាត្រា ៣៦២) តែបណ្តឹងនេះមានអត្ថន័យនៅត្រង់កន្លែងថា វិវាទនេះនឹងសម្រេចជាស្ថាពរដោយអាជ្ញាអស់ជំនុំ ។ ទោះបីជាពាក្យសុំតវ៉ា ត្រូវបានលើកចោលក៏ដោយ ក៏បណ្តឹងនេះពុំត្រូវបានគេរាំងស្ទះឡើយ ។ ផ្ទុយទៅវិញ បើបណ្តឹងនេះត្រូវបានចូលជាស្ថាពរ ដោយសាលក្រម ឬ សាលដីកាច្រានចោលការទាមទារវិញ ពុំអាចដាក់ពាក្យសុំតវ៉ាដោយយកមូលហេតុដែលបានកើតឡើងនៅមុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់បានឡើយ ។

(3) ការជំនុំជម្រះត្រូវធ្វើឡើងដោយនីតិវិធីបណ្តឹងធម្មតា ។ ចំពោះលទ្ធផលនៃការជំនុំជម្រះ នៅក្នុងករណីដែលការតវ៉ានោះមានមូលហេតុ តុលាការត្រូវធ្វើការប្រកាសអំពីការពុំអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ ដោយផ្អែកលើលិខិតអនុវត្តដែលភ្ជាប់នឹងរូបមន្តអនុវត្តនោះ នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រម ។ នៅក្នុងករណីដែលសាលក្រមទទួលស្គាល់ការទាមទារនេះចូលជាស្ថាពរហើយ ឬ មានភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន រូបមន្តអនុវត្តនោះនឹងត្រូវបាត់បង់នូវអានុភាព ។ បើនីតិវិធីអនុវត្តត្រូវបានចាប់ផ្តើមរួចហើយ កូនបំណុលនៃការអនុវត្តអាចដាក់ជូនស្ថាប័នអនុវត្ត នូវអនុសារសាលក្រមនេះ ដើម្បីសុំឱ្យផ្អាក និង លុបចោលការអនុវត្ត (ចំណុច ក កថាខណ្ឌទី ១ នៃមាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ)) ។ ចំពោះការចាត់វិធានការផ្អាកការអនុវត្ត ជាដើម ដោយដាក់ពាក្យបណ្តឹង សូមមើលមាត្រា ៣៦៧ (ការសម្រេចសេចក្តីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍) ។

<u>Civil Execution Act (Japan)</u>
**Article 34** (Action of objection to issuance of execution clause)
1. In cases where an execution clause has been issued according to the provisions of Article 27, an obligor who objects to whether the fact to be proved by the obligee has occurred, orwhether compulsory execution may be effected against or for a person other than the parties designated in the obligation title, may institute an action of objection to the issuance of an execution clause in order to demand a declaration that compulsory execution based on the exemplification of the obligation title to which the execution clause

was attached, shall not be permitted.
2. If there are several grounds for the objection, the obligor must allege them simultaneously.
3. The provisions of the preceding Article, paragraph 2 shall apply mutatis mutandis to the action referred to in paragraph 1.

**មាត្រា ៣៦៥.-** បណ្តឹងតវ៉ារបស់តតិយជន

១- តតិយជនដែលមានកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតដែលរាំងស្ទះការធ្វើអនុប្បទាន ឬ ប្រគល់ ចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ អាចដាក់ពាក្យបណ្តឹងតវ៉ា ដើម្បីទាមទារកុំឱ្យអនុញ្ញាតការអនុវត្តដោយបង្ខំ ចំពោះម្ចាស់បំណុលនៃការអនុវត្តនោះបាន ។

២- បណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះការអនុវត្តដោយបង្ខំ ដោយតុលាការអនុវត្តដែលក្លាយជាស្ថាប័នអនុវត្ត ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការអនុវត្តនោះ រីឯចំពោះការអនុវត្តដោយបង្ខំ ដោយអាជ្ញាសាលាដែលក្លាយជាស្ថាប័នអនុវត្ត ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ ។

(កំណត់)

(1) សូមមើលមាត្រា 38 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

(2) បណ្តឹងតវ៉ារបស់តតិយជននេះ ធ្វើឡើងក្នុងគោលបំណងឱ្យតតិយជនក្រៅពីបុគ្គលដែលត្រូវទទួលអានុភាពអនុវត្តនៃលិខិតអនុវត្ត ទាមទារកុំឱ្យធ្វើការអនុវត្តដោយបង្ខំ ដោយនីតិវិធីនៃបណ្តឹងដែលយកម្ចាស់បំណុលនៃការអនុវត្តជាចុងចម្លើយ ក្នុងករណីដែលការអនុវត្តដោយបង្ខំត្រូវបានធ្វើឡើង ចំពោះទ្រព្យសម្បត្តិរបស់តតិយជននោះ ហើយសិទ្ធិរបស់តតិយជននោះត្រូវបានបំពានដោយផ្ទុយនឹងច្បាប់ ។ ក្នុងនីតិវិធីអនុវត្ត ការវិនិច្ឆ័យថាតើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តជាកម្មសិទ្ធរបស់កូនបំណុលមែន ឬ មិនមែន ត្រូវធ្វើឡើង ដោយយកភាពជាក់ស្តែងនៃភិនភាគខាងក្រៅ (ការចុះបញ្ជីនៃអចលនវត្ថុ ការកាន់កាប់ចលនវត្ថុ ជាដើម) មកជាមូលដ្ឋាន ហេតុដូច្នេះការចែងអំពីបណ្តឹងនេះមានគោលបំណងដើម្បីធានាភាពត្រឹមត្រូវផ្នែកសារធាតុនៃនីតិវិធីអនុវត្ត ចំពោះទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្ត ។
ឧទាហរណ៍ថា: A (ដែលជាកូនបំណុលនៃការអនុវត្ត) បានខ្ចីម៉ូតូរបស់ B (ដែលជាតតិយជន) ជិះយកមកដាក់នៅក្នុងផ្ទះរបស់ខ្លួន ។ នៅពេលដែល C (ដែលជាម្ចាស់បំណុលនៃការអនុវត្ត) រឹបអូសយកម៉ូតូនោះ ដោយផ្អែកលើលិខិតអនុវត្តចំពោះ A នោះ B អាចដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជនចំពោះ C ដោយអះអាងថាម៉ូតូនោះជាកម្មសិទ្ធិរបស់ខ្លួន ដើម្បីកុំឱ្យអនុវត្តដោយបង្ខំ (រឹបអូស) ចំពោះម៉ូតូនោះបាន ។

(3) ការជំនុំជម្រះត្រូវធ្វើឡើងដោយនីតិវិធីបណ្តឹងធម្មតា ។ ចំពោះលទ្ធផលនៃការជំនុំជម្រះ នៅក្នុងករណីដែលការតវ៉ានោះ មានមូលហេតុ តុលាការត្រូវធ្វើការប្រកាសអំពីការពុំអនុញ្ញាតឱ្យចុងចម្លើយអនុវត្តចំពោះទ្រព្យសម្បត្តិដែលបានកំណត់នោះ នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រម ។ កូនបំណុលនៃការអនុវត្ត អាចដាក់ជូនស្ថាប័នអនុវត្តនូវអនុសារសាលក្រមនេះ ដើម្បីសុំឱ្យផ្អាក និង លុបចោលការអនុវត្ត (ចំណុច ក កថាខណ្ឌទី ១ មាត្រា ៣៧០

(ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ)) ។ ចំពោះការចាត់វិធានការផ្អាកការអនុវត្ត ដោយដាក់ពាក្យបណ្ដឹង សូមមើលមាត្រា ៣៦៧ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្ដឹងតវ៉ា ចំពោះការទាមទារ ជាអាទិ៍) ។

Civil Execution Act (Japan)
**Article 38** (Action of third person objection)
1. A third person who has ownership of the subject matter of the compulsory execution or any other rights preventing the conveyance or delivery of such subject matter may institute an action of thirdperson objection against the obligee in order to demand a declaration that compulsory execution on such subject matter shall not be permitted.
2. The third person referred to in the preceding paragraph may institute an action on the subject matter of the compulsory execution against the obligor along with an action referred to in the said paragraph.
3. An action under paragraph 1 shall be subject to the jurisdiction of the execution court.
4. The provisions of the preceding two Articles shall apply mutatis mutandis to a decision of stay of execution concerning an action under paragraph 1.

## ផ្នែកទី ៦ ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ

**មាត្រា ៣៦៦.-** ការសម្រេចសេចក្ដីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្ដឹងជំនុំជម្រះសាជាថ្មី ជាអាទិ៍

១- តុលាការអាចបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈ តាមពាក្យសុំ ដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគបាន ក្នុងករណីដែលបានកំណត់ដូចខាងក្រោមនេះ :

**ក-** ក្នុងករណីដែលមានការដាក់ពាក្យបណ្ដឹងឱ្យធ្វើការជំនុំជម្រះសាជាថ្មី បើស្ថានភាពដែលត្រូវបានអះអាងថាជាមូលហេតុឧបាស្រ័យនោះ ហាក់ដូចជាមានមូលហេតុផ្លូវច្បាប់ ហើយមានសេចក្ដីបញ្ជាក់ដំបូងអំពីហេតុការណ៍ពិតនោះ ។

**ខ-** ក្នុងករណីដែលមានការដាក់ពាក្យបណ្ដឹងសាទុក្ខ ចំពោះសាលដីកា ឬ សាលក្រមដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន បើមានសេចក្ដីបញ្ជាក់ដំបូងអំពីស្ថានភាពដែលត្រូវក្លាយជាមូលហេតុនៃការបដិសេធសាលដីកា ឬ សាលក្រមដើមចោល ។

**គ-** ក្នុងករណីដែលមានការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ ចំពោះសាលក្រមដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ឬ ក្នុងករណីដែលមានការដាក់ពាក្យសុំតវ៉ា ចំពោះដីកាសម្រេចដាស់តឿនដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន បើមានសេចក្ដីបញ្ជាក់ដំបូងអំពីស្ថានភាពដែលត្រូវក្លាយជាមូលហេតុនៃការលុបចោល ឬ ផ្លាស់ប្ដូរសាលក្រមដើម ឬ ដីកាសម្រេចដាស់តឿននោះ ។

**ឃ-** ក្នុងករណីដែលមានការដាក់ពាក្យបណ្ដឹងទាស់ ចំពោះសាលក្រមកំបាំងមុខដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន បើមានសេចក្ដីបញ្ជាក់ដំបូងអំពីស្ថានភាពដែលត្រូវក្លាយជាមូលហេតុនៃការលុបចោល ឬ ផ្លាស់ប្ដូរសាលក្រមកំបាំងមុខនោះ ។

២- ក្នុងករណីដែលបានកំណត់នៅក្នុងចំណុចនីមួយៗ នៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចបង្គាប់ឱ្យលុបចោលការ

ចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយនោះ តាមពាក្យសុំ ដោយឱ្យដាក់ប្រាតិភោគ ជាមួយនឹងការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈបាន ។

៣- ក្នុងករណីដែលមានការដាក់ពាក្យបណ្តឹងសាទុក្ខចំពោះសាលដីកា ឬ សាលក្រមដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ឬ ក្នុងករណីដែលមានការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន បើសំណុំរឿងបណ្តឹងនោះស្ថិតនៅតុលាការដើម តុលាការនោះត្រូវធ្វើការសម្រេចសេចក្តីអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ។

(កំណត់)

មាត្រានេះត្រូវនឹងមាត្រា 398 និង កថាខណ្ឌទី 1 នៃមាត្រា 399 នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ។

ក្នុងករណីដែលមានបណ្តឹងឧបាស្រ័យ ចំពោះសេចក្តីសម្រេចដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន តុលាការត្រូវធ្វើយ៉ាងណាឱ្យដើមចោទដែលបានទទួលការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ននោះ អាចទទួលនូវផលប្រយោជន៍នៃសេចក្តីសម្រេចនោះឱ្យបានឆាប់រហ័ស ម្យ៉ាងទៀត ក្នុងករណីដែលមានលទ្ធភាពមួយចំនួនក្នុងការលុបចោលនូវការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ននោះ ក៏តុលាការត្រូវទទួលស្គាល់ថា ភាគីម្ខាងទៀតអាចរួចផុតពីការអនុវត្តតាមការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ននោះដែរ ។ ចំពោះករណីដែលមានពាក្យបណ្តឹងទាមទារឱ្យធ្វើការជំនុំជម្រះសាជាថ្មីចំពោះសាលក្រមស្ថាពរ ឬ សាលដីកាស្ថាពរក៏ដូចគ្នាដែរ ។ មាត្រានេះចែងអំពីល័ក្ខខ័ណ្ឌដើម្បីផ្អាកមួយរយៈនូវការអនុវត្តដោយបង្ខំ ដោយផ្អែកលើសាលក្រមស្ថាពរ ឬ សាលដីកាស្ថាពរ ឬ ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ក្នុងករណីដែលមានបណ្តឹងឧបាស្រ័យចំពោះសាលក្រមស្ថាពរ ឬ សាលដីកាស្ថាពរ ឬ សាលក្រមឬសាលដីកាដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ជាដើម ។

មូលហេតុនៃឧបាស្រ័យហាក់ដូចជាមានមូលហេតុត្រឹមត្រូវតាមច្បាប់ ហើយមានសេចក្តីបញ្ជាក់ដំបូងផងដែរនោះ គឺជាល័ក្ខខ័ណ្ឌនៃការផ្អាក ។ ឧទាហរណ៍ ចំពោះការសុំឱ្យធ្វើការជំនុំជម្រះសាជាថ្មី (ចំណុច ក) សេចក្តីអះអាងនៃដើមចោទហាក់ដូចជាត្រូវនឹងមូលហេតុណាមួយនៃការជំនុំជម្រះសាជាថ្មី (មាត្រា ៣០៧ (មូលហេតុនៃការជំនុំជម្រះសាជាថ្មី (មួយ))) ហើយមានសេចក្តីបញ្ជាក់ដំបូងរបស់ដើមចោទ អំពីអត្ថិភាពនៃហេតុការណ៍ដែលត្រូវនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មីនោះ គឺជាល័ក្ខខ័ណ្ឌនៃការផ្អាកការអនុវត្ត ។ ចំពោះបណ្តឹងឧទ្ធរណ៍ ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន និង បណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ មូលហេតុនៃការប្តឹងឧបាស្រ័យមិនមានកំណត់ទេ ហេតុដូច្នេះសេចក្តីបញ្ជាក់ដំបូង អំពីហេតុការណ៍ដែលត្រូវក្លាយជាមូលហេតុនៃការលុបចោល ឬ ផ្លាស់ប្តូរសេចក្តីសម្រេចដែលជាកម្មវត្ថុនៃឧបាស្រ័យ គឺជាល័ក្ខខ័ណ្ឌ ។

កថាខណ្ឌទី ២ ចែងថា ដើម្បីបង្គាប់ឱ្យលុបចោលនូវការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយ តុលាការត្រូវឱ្យកូនបំណុល ដាក់ប្រាតិភោគ ។

ចំពោះសេចក្តីសម្រេច (ដីកាសម្រេច) អំពីពាក្យសុំដែលបានកំណត់ក្នុងកថាខណ្ឌទី ១ និង ទី ២ មិនអាចធ្វើបណ្តឹងជំទាស់បានទេ ដោយសារពុំមានបញ្ញត្តិពិសេស (មាត្រា ២៥៩ (ប្រភេទនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់) កថាខណ្ឌទី ២) ។

ម្យ៉ាងទៀត មាត្រានេះចែងអំពីអានុភាពអនុវត្តដើម្បីសម្រេចករណីយកិច្ចត្រូវផ្តល់តាវកាលិកដែលបានសរសេរនៅក្នុងលិខិតអនុវត្ត តាមនីតិវិធីនៃការអនុវត្ត (ន័យចង្អៀត) រីឯមាត្រា ៣០៥ (ការផ្អាកអានុភាពនៃដីកាសម្រេចដើម) ចែងអំពីអានុភាពអនុវត្តទាំងឡាយ ដើម្បីសម្រេចខ្លឹមសារ នៃការសម្រេចសេចក្តី (ន័យទូលាយ) ។

<u>Code of Civil Procedure (Japan)</u>
**Article 398** (Decision on stay of execution)
1. In the following cases, the court may, upon motion, order by ruling temporary stay of execution upon security being furnished or without security being furnished, or together with this, order that execution shall be commenced or continued upon furnishing security or that execution measures already taken should be annulled upon security being furnished. Provided that, the order to the effect that execution should be commenced or continued may be given only in the cases mentioned in items iii through iv:

i. Where *jokoku*-appeal under Article 327 paragraph 1 (including the case where it is applied *mutatis mutandis* in Article 380 paragraph 2; hereinafter the same in the following Article or an action for new trial has been filed, when the circumstances insisted on the grounds of appeal are seemed to be legally reasonable, and prima facie proof has been given as to the fact that irreparable damage may arise from the execution;

ii. Where *iokoku*-appeal against a judgment accompanying declaration of provisional execution or an application for acceptance of *iokoku*-appeal has been filed, when prima facie proof has been given as to the circumstances to constitute the grounds for waiver of the original judgment and the fact that irreparable damage may arise from the execution;

iii. Where *koso*-appeal against a judgment accompanying declaration of provisional execution or a protect against the pressing for payment accompanying declaration of provisional execution (excluding the filing of *koso*-appeal and a protest mentioned in the following item) has been filed, when prima facie proof has been given as to the fact that there is no saying that no circumstances to constitute the grounds for revocation or alteration of the original judgment or the pressing for payment exist, or as to the fact that serious damage may arise from the execution;

iv. With respect to claims on monetary payment by bills or cheques and claims on indemnification of damage incurred by legal interest rate incidental thereto, where *koso*-appeal against a judgment accompanying declaration of provisional execution or a protect against the pressing for payment accompanying declaration of provisional execution has been filed, when prima facie proof has been given as to the circumstances to constitute the grounds for revocation or alteration of the original judgment or the pressing for payment;

v. Where an objection against the judgment under litigation of bills or litigation of cheques accompanying declaration of provisional execution or an objection against the judgment under litigation of small claims accompanying declaration of provisional execution has been filed, when prima facie proof has been given as the circumstances to constitute the grounds for revocation or alteration of the original judgment;

vi. Where the action mentioned in Article 177 paragraph 1 has been instituted, when circumstances insisted for alteration are seemed to be legally reasonable, and further, prima facie proof has been given as to an issue of fact.

2. Against a decision on the motion mentioned provided for in the preceding paragraph, no appeal may be filed.

**Article 399** (Decision by original court) (excerpt)
1. In case where *jokoku*-appeal mentioned in Article 327 paragraph 1, *jokoku*-appeal against the judgment accompanying declaration of provisional execution or an application for acceptance of *jokoku*-appeal, or *koso*-appeal against the judgment accompanying declaration of provisional execution has been filed, the original court shall, if the record of proceedings is kept therein, render a decision on the motion provided for in paragraph 1 of the preceding Article.

**មាត្រា ៣៦៧.-** ការសម្រេចសេចក្តីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍

១- នៅក្នុងករណីដែលមានពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ពាក្យបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ឬ ពាក្យបណ្តឹងតវ៉ារបស់តតិយជន បើមានសេចក្តីបញ្ជាក់ដំបូងអំពីមូលហេតុតវ៉ាដែលត្រូវបានអះអាងនោះ តុលាការដែលបានទទួលពាក្យបណ្តឹង អាចបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈ តាមពាក្យសុំ ដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគបាន រហូតដល់ធ្វើការសម្រេចសេចក្តីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣៦៨ (ការសម្រេច

សេចក្តីផ្អាកការអនុវត្តនៅក្នុងសាលក្រម ឬ សាលដីកាចុងក្រោយ ជាអាទិ៍) នៃក្រមនេះ នៅក្នុងសាលក្រមចុងក្រោយ ។

២- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការដែលបានទទួលពាក្យបណ្តឹងអាចបង្គាប់ឱ្យលុបចោលការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយនោះ តាមពាក្យសុំ ដោយឱ្យដាក់ប្រាតិភោគ ជាមួយនឹងការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈបាន ។

៣- នៅក្នុងករណីដែលមានពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ឬ មានពាក្យបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត បើមានសេចក្តីបញ្ជាក់ដំបូងអំពីមូលហេតុតវ៉ាដែលត្រូវបានអះអាងនោះ ហើយមានស្ថានភាពបន្ទាន់ តុលាការអនុវត្ត ឬ សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ អាចចេញដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ ខាងលើនេះបាន ដោយកំណត់អំឡុងពេលត្រូវដាក់ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលធ្វើតាមកថាខណ្ឌទី ១ ខាងលើនេះ ។ ការសម្រេចសេចក្តីនេះ ក៏អាចធ្វើបានដែរនៅមុនពេលដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៤- បើអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះត្រូវបានកន្លងផុត ឬ បើសេចក្តីសម្រេច ដែលធ្វើតាមកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ ខាងលើនេះ ត្រូវបានដាក់ជូនទៅតុលាការអនុវត្ត ឬ អាជ្ញាសាលា នៅក្នុងអំឡុងពេលនោះ ដីកាសម្រេចនៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវបាត់បង់នូវអានុភាព ។

(កំណត់)

មាត្រានេះត្រូវនឹងច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 36 កថាខណ្ឌទី 4 នៃមាត្រា 38 ។ បណ្តឹងតវ៉ាចំពោះការទាមទារមានបញ្ញត្តនៅក្នុងមាត្រា ៣៦៣ (បណ្តឹងតវ៉ាចំពោះការទាមទារ) បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្តមានបញ្ញត្តនៅក្នុងមាត្រា ៣៦៤ (បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត) ហើយបណ្តឹងតវ៉ារបស់តតិយជនមានបញ្ញត្តនៅក្នុងមាត្រា ៣៦៥ (បណ្តឹងតវ៉ារបស់តតិយជន) ។

ការផ្អាកការអនុវត្តដែលបញ្ញត្តនៅក្នុងមាត្រានេះ គឺជាប្រព័ន្ធដែលការពារកូនបំណុលនៃការអនុវត្ត ដោយការផ្អាកការអនុវត្ត នៅក្នុងករណីដែលមានការដាក់ពាក្យបណ្តឹងលើច្បាប់អនុវត្តទាំងឡាយនោះ ហើយស្ថានភាពដែលអះអាងដោយដើមចោទ ហាក់ដូចជាត្រូវនឹងហេតុការណ៍នៃមូលហេតុបណ្តឹងទាមទារការតវ៉ានេះ ហើយមានសេចក្តីបញ្ជាក់ដំបូងអំពីហេតុការណ៍ដែលត្រូវនឹងមូលហេតុនៃការតវ៉ាទាំងនោះ ។ ឧទាហរណ៍ បើមានពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ហើយដើមចោទអះអាងមូលហេតុនៃការតវ៉ាថា ខ្លួនបានសងនៅក្រោយពេលបញ្ចប់បណ្តឹងលើកមុននោះ ហើយធ្វើសេចក្តីបញ្ជាក់ដំបូងអំពីហេតុការណ៍នោះ តុលាការអាចបង្គាប់ឱ្យផ្អាកការអនុវត្ត ដោយឱ្យដាក់ប្រាតិភោគបើចាំបាច់ រហូតដល់ពេលមានសាលក្រមនៃបណ្តឹងតវ៉ាចំពោះការទាមទារ ។

ចំពោះការលុបចោលនូវការចាត់ចែងការអនុវត្តដែលចែងក្នុងកថាខណ្ឌទី ២ សូមមើលកំណត់នៃមាត្រា ៣៦៦ (ការសម្រេចសេចក្តីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹងជំនុំជម្រះសាជាថ្មី ជាអាទិ៍) ។

កថាខណ្ឌទី ៣ នេះចែងថា បើគ្មានពេលគ្រប់គ្រាន់ដើម្បីទទួលការចាត់ចែងផ្អាកការអនុវត្តដោយតុលាការដែលទទួលពាក្យបណ្តឹងទេ តុលាការអនុវត្ត ឬ សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅក្រោម អាចបង្គាប់ឱ្យផ្អាកការអនុវត្តជាបណ្តោះអាសន្នបាន ។ បើមិនអាចគិតបានថា មានករណីច្រើនដែលគ្មានពេលគ្រប់គ្រាន់ដើម្បីឱ្យតុលាការអនុវត្ត ឬ សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅក្រោម អាចផ្អាកការអនុវត្ត ដោយទទួលការចាត់ចែងផ្អាកការអនុវត្តរបស់តុលាការទទួលពាក្យបណ្តឹងទេ នោះអាចលុបកថាខណ្ឌទី ៣ និង កថាខណ្ឌទី ៤ នេះចោលបាន ។

ម្យ៉ាងទៀត ចំពោះសេចក្តីសម្រេច (ដីកាសម្រេច) អំពីពាក្យសុំដែលមានចែងក្នុងកថាខណ្ឌទី ១ ទី ២ និង ទី ៣ មិនអាចធ្វើបណ្តឹងជំទាស់បានទេ ដោយសារពុំមានបញ្ញត្តិពិសេស (មាត្រា ២៩៩ (ប្រភេទនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់) កថាខណ្ឌទី ២) ។

Civil Execution Act (Japan)
**Article 36** (Decision of stay of execution concerning an action of objection)
1. In cases where an action of objection to the issuance of an execution clause or an action of objection to a claim has been instituted and the circumstances alleged as grounds for the objection appear reasonable in law and a preliminary showing on the points of fact has been made, the court in which the action has been brought may, upon motion, order a stay of compulsory execution either upon or without security being provided, or order continuation of compulsory execution upon security being provided, or order annulment of a disposition already made upon security being provided until the decision outlined in the next Article, paragraph 1 is rendered in the final judgment. In cases of urgency, the presiding judge may also order such disposition.
2. The decision on the motion of the preceding paragraph may be rendered without resorting to oral argument.
3. In cases where the grounds mentioned in paragraph 1 are found, if there are urgent circumstances, the execution court may, upon motion, order a disposition referred to in the said paragraph in addition to fixing the period within which the exemplification of the decision according to the said paragraph must be submitted. Such decision may be rendered even before an action of objection to the issuance of an execution clause or an action of objection to a claim is instituted.
4. If the period fixed in accordance with the provisions of the preceding paragraph expires or the decision according to the provisions of paragraph 1 is submitted to the execution court or an execution officer within the said period, the decision of the preceding paragraph shall lose its effect.
5. No complaint may be filed against a decision made on a motion as mentioned in paragraphs 2 and 3.
**Article 38** (Action of third person objection) (excerpt)
4. The provisions of the preceding two Articles shall apply mutatis mutandis to a decision of stay of execution concerning an action under paragraph 1.

**មាត្រា ៣៦៨.-** ការសម្រេចសេចក្តីផ្អាកការអនុវត្តនៅក្នុងសាលក្រម ឬ សាលដីកាចុងក្រោយ ជាអាទិ៍

នៅក្នុងសាលក្រម ឬ សាលដីកាចុងក្រោយអំពីបណ្តឹងតវ៉ាចំពោះការទាមទារ បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ឬ បណ្តឹងតវ៉ារបស់តតិយជន តុលាការដែលទទួលពាក្យបណ្តឹងអាចបង្គាប់ឱ្យធ្វើការចាត់ចែងដែលបានកំណត់ នៅក្នុងកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ នៃមាត្រា ៣៦៧ (ការសម្រេចសេចក្តីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍) នៃក្រមនេះ ឬ អាចលុបចោល ឬ ផ្លាស់ប្តូរ ឬ ទទួលស្គាល់នូវសេចក្តីសម្រេចដែលបានធ្វើរួចហើយតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ នោះបាន ។ ការសម្រេចសេចក្តីនេះត្រូវមានអានុភាព ចាប់ពីពេលដែលសាលក្រម ឬ សាលដីកាចុងក្រោយអំពីបណ្តឹងដែលបានកំណត់នៅក្នុងមាត្រានេះ ត្រូវបានប្រកាស ។

(កំណត់)

មាត្រានេះត្រូវនឹងច្បាប់ស្ដីពីការអនុវត្តផ្ទេករដ្ឋប្បវេណីជប៉ុន មាត្រា 37 ។

ឧទាហរណ៍ថាៈ ក្នុងករណីដែលដើមចោទឈ្នះក្ដីក្នុងបណ្ដឹងតវ៉ាចំពោះការទាមទារ តុលាការអាចបង្គាប់ឱ្យផ្អាកការអនុវត្តបាន ឬ បើដើមចោទនោះចាញ់ អាចលុបចោលនូវការផ្អាកការអនុវត្តដោយយោងតាមមាត្រា ៣៦៧ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍) បាន ។ សេចក្ដីសម្រេចទាំងឡាយនេះចាំបាច់ត្រូវមានអានុភាពដោយពុំរង់ចាំសាលក្រម ឬ សាលដីកាចុងក្រោយចូលជាស្ថាពរទេ ហេតុនេះហើយ មាត្រានេះចែងថា សេចក្ដីសម្រេចនេះមានអានុភាព ចាប់ពីពេលដែលសាលក្រមចុងក្រោយត្រូវបានប្រកាស (ភាគក្រោយនៃមាត្រានេះ) ។ មានន័យថា ដោយសារមានភាពចាំបាច់ក្នុងការទទួលស្គាល់អានុភាពផ្អាកការអនុវត្តភ្លាម១ អានុភាពនឹងកើតឡើង ដោយមិនរង់ចាំការចូលជាស្ថាពរ ដោយខុសពីសាលក្រមធម្មតា ។ម្យ៉ាងទៀត យើងមិនប្រើពាក្យ "ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន" ដោយសារន័យនៃការកើតអានុភាពភ្លាម១នេះ មិនមែនជាការអនុវត្តជាបណ្ដោះអាសន្នឡើយ ។

<u>Civil Execution Act (Japan)</u>
**Article 37** (Decision of stay of execution in final judgment)
1. In the final judgment on an action of objection to the issuance of an execution clause or an action of objection to a claim, the court may order a disposition referred to in the preceding Article, paragraph 1, or may annul, alter or ratify a decision already rendered in accordance with the said paragraph. A declaration of provisional execution must be rendered in such decision.
2. No complaint may be filed against a decision made according to the provisions of the preceding paragraph.

**មាត្រា ៣៦៩.-** ការសម្រេចសេចក្ដីផ្អាកការអនុវត្តដោយការដាក់ពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត ជាអាទិ៍

ក្នុងករណីដែលមានពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត ជាអាទិ៍ បើយល់ឃើញថាចាំបាច់ តុលាការអាចបង្គាប់ឱ្យផ្អាកការអនុវត្ត តាមពាក្យសុំ ដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគ រហូតដល់ធ្វើការសម្រេចសេចក្ដីអំពីការតវ៉ានោះបាន ។

(កំណត់)

មាត្រានេះត្រូវនឹងច្បាប់ស្ដីពីការអនុវត្តផ្ទេករដ្ឋប្បវេណីជប៉ុន មាត្រា 32 កថាខណ្ឌទី 2 ។

មាត្រានេះចែងអំពីការផ្អាកការអនុវត្ត ក្នុងករណីដែលមានការដាក់ពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត យោងតាមបញ្ញត្តិនៃមាត្រា ៣៦២ (ពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត ជាអាទិ៍) ។

<u>Civil Execution Act (Japan)</u>
**Article 32** (Objection against issuance of execution clause) (excerpt)
2. In cases where an objection has been raised against the issuance of an execution clause, the court may order a stay of compulsory execution either upon or without security being provided, or continuation of compulsory execution upon security being provided until it renders a decision on the objection. In cases of urgency, the presiding judge may also order such disposition.

**មាត្រា ៣៧០.-** ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ

១- តុលាការអនុវត្ត ឬ អាជ្ញាសាលាត្រូវផ្អាកនូវការអនុវត្តដោយបង្ខំ ហើយត្រូវលុបចោលការចាត់ចែងការអនុវត្ត ដែលបានធ្វើរួចហើយ បើឯកសារដែលបានកំណត់ខាងក្រោមនេះ ត្រូវបានដាក់ :

**ក**- ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេចដែលកំណត់ថា លុបចោលលិខិតអនុវត្តក្រៅពីលិខិតយថាភូត ដែលបានកំណត់នៅក្នុងចំណុច **ច** កថាខណ្ឌទី ២ នៃមាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ ឬ ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេច ដែលកំណត់ថា លុបចោលការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ។

**ខ**- ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេចដែលកំណត់ថា មិនអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ ។

**គ**- អនុសារសាលក្រមស្ថាពរ ឬ អនុសារសាលដីកាស្ថាពរដែលប្រកាសថា ការផ្សះផ្សា ឬ ការទទួលស្គាល់ ដែលទាក់ទងនឹងលិខិតអនុវត្ត គ្មានអានុភាព ។

**ឃ**- ឯកសារចម្លងយថាភូតនៃកំណត់ហេតុ ឬ ឯកសារផ្សេងទៀតដែលក្រឡាបញ្ជីបានធ្វើ ដែលបញ្ជាក់ថា លិខិតអនុវត្តដែលបានកំណត់ចាប់ពីចំណុច **ខ** រហូតដល់ចំណុច **ង** កថាខណ្ឌទី ២ នៃមាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ បាត់បង់អានុភាពដោយសារការដកពាក្យបណ្ដឹង ឬ មូលហេតុផ្សេងទៀត ។

**ង**- ឯកសារចម្លងយថាភូតនៃកំណត់ហេតុអំពីការផ្សះផ្សាតាមនីតិវិធីនៃការសម្រេចសេចក្ដី ដែលកំណត់ថា មិនអនុវត្តដោយបង្ខំ ឬ ដកពាក្យសុំឱ្យអនុវត្តដោយបង្ខំនោះវិញ ។

**ច**- ឯកសារដែលបញ្ជាក់អំពីការដាក់ប្រាតិភោគ ដើម្បីឱ្យរួចផុតពីការអនុវត្តដោយបង្ខំ ។

**ឆ**- ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេចដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំ និង លុបចោលការចាត់ចែងការអនុវត្ត ។

២- តុលាការអនុវត្ត ឬ អាជ្ញាសាលា ត្រូវផ្អាកនូវការអនុវត្តដោយបង្ខំ បើឯកសារដែលបានកំណត់ខាងក្រោមនេះត្រូវបានដាក់មក ។ ប៉ុន្តែ ចំពោះករណីដែលបានកំណត់នៅក្នុងចំណុច **ខ** ខាងក្រោម អានុភាពផ្អាកមានត្រឹមតែ ២ (ពីរ) ខែប៉ុណ្ណោះ :

**ក**- ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេចដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈ ។

**ខ**- ឯកសារដែលសរសេរថា ម្ចាស់បំណុលទទួលសំណង ឬ បានយល់ព្រមពន្យារពេលត្រូវសង នៅក្រោយពេលលិខិតអនុវត្តត្រូវបានបង្កើត ។

៣- បញ្ញត្តិនៃមាត្រា ៣៤៥ (បណ្ដឹងជំទាស់ចំពោះដីកាសម្រេចលុបចោល ជាអាទិ៍) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលលុបចោលនូវការចាត់ចែងការអនុវត្តតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

មាត្រានេះត្រូវនឹងច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន កថាខណ្ឌទី 1 នៃមាត្រា 39 និង មាត្រា 40 ។

ពេលដែលឯកសារដែលមានចែងក្នុងកថាខណ្ឌ ១ ចំណុច **ក** ដល់ចំណុច **ឆ** ខាងលើនេះ ត្រូវបានដាក់ទៅស្ថាប័ន

អនុវត្ត ស្ថាប័នអនុវត្តនោះចាំបាច់ត្រូវផ្អាកការអនុវត្តដោយបង្ខំ ហើយចាំបាច់ត្រូវលុបចោលនូវការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយផងដែរ ។

"សេចក្តីសម្រេចដែលសរសេរថា លុបចោលនូវលិខិតអនុវត្ត" ដែលមានចែងក្នុងចំណុច **ក** មានដូចជា សាលដីកានៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ឬ សាលក្រមនៃការជំនុំជម្រះសាជាថ្មី ដែលលុបចោលនូវលិខិតអនុវត្ត ។ "សេចក្តីសម្រេចដែលសរសេរថា លុបចោលការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន" គឺជាសេចក្តីសម្រេច ដែលមានចែងក្នុងកថាខណ្ឌទី ១ និង ទី ៣ នៃមាត្រា ១៩៧ (ការបាត់បង់អានុភាពនៃការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន និង បដិទានស្ថានភាពដើម) ។

"សេចក្តីសម្រេចដែលសរសេរថា មិនអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ" នៃចំណុច **ខ** ខាងលើនេះ ពុំគិតទៅលើប្រភេទនៃលិខិតអនុវត្តទេ ឧទាហរណ៍: សាលក្រមចុងក្រោយដែលទទួលស្គាល់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ឬ ពាក្យបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ឬ ពាក្យបណ្តឹងតវ៉ារបស់តតិយជន ។

ចំណុច **គ** សំដៅទៅលើសាលក្រម ឬ សាលដីកាដែលទទួលស្គាល់បណ្តឹងទាមទារឱ្យបញ្ជាក់មោឃភាពនៃការផ្សះផ្សា ឬ ការទទួលស្គាល់ការទាមទារ នៅក្នុងករណីដែលកំណត់ហេតុស្តីពីការផ្សះផ្សា ឬ កំណត់ហេតុស្តីពីការទទួលស្គាល់នោះជាលិខិតអនុវត្ត (សូមមើលមាត្រា ២២២ (អានុភាពនៃកំណត់ហេតុស្តីពីការសះជា ជាអាទិ៍)) ។

ឯកសារដែលមានចែងក្នុងចំណុច **ឃ** នេះ មានដូចជាកំណត់ហេតុដែលក្រឡាបញ្ជីបានសរសេរអំពីការដកពាក្យបណ្តឹងនៅពេលដែលធ្វើការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ឬ អំពីការដកពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ។

ឯកសារដែលមានចែងក្នុងចំណុច **ង** គឺជា កំណត់ហេតុស្តីពីការផ្សះផ្សា នៅក្នុងករណីដែលការព្រមព្រៀងមិនអនុវត្ត ឬ ការព្រមព្រៀងដកពាក្យសុំឱ្យអនុវត្ត បានកើតឡើងក្នុងការផ្សះផ្សាលើការសម្រេចសេចក្តី ។

ឯកសារដែលមានចែងក្នុងចំណុច **ច** គឺជាឯកសារដែលបញ្ជាក់អំពីការដាក់ប្រាតិភោគ នៅក្នុងករណីដែលការប្រកាសថា អាចរួចផុតពីការអនុវត្តជាបណ្តោះអាសន្នបើដាក់ប្រាតិភោគ ត្រូវបានភ្ជាប់នឹងការប្រកាសអនុវត្តជាបណ្តោះ-អាសន្ន តាមកថាខណ្ឌទី ២ នៃមាត្រា ១៩៦ (ការប្រការឱ្យអនុវត្តជាបណ្តោះអាសន្ន) ។

ចំណុច **ឆ** គឺជាសេចក្តីសម្រេចដែលបានកំណត់នៅក្នុងមាត្រា ៣៦៦ (ការសម្រេចសេចក្តីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹងជំនុំជម្រះសាជាថ្មី ជាអាទិ៍) ដល់ មាត្រា ៣៦៩ (ការសម្រេចសេចក្តីផ្អាកការអនុវត្តដោយការដាក់ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត ជាអាទិ៍) នៃផ្នែកនេះ ។

ក្នុងករណីដែលឯកសារដែលមានចែងក្នុងចំណុច **ក** និង **ខ** នៃកថាខណ្ឌទី ២ នេះ ត្រូវបានដាក់ទៅស្ថាប័នអនុវត្ត ស្ថាប័នអនុវត្តនោះចាំបាច់ត្រូវផ្អាកនូវការអនុវត្តដោយបង្ខំ ។

ចំណុច **ក** គឺជាសេចក្តីសម្រេចដែលបានកំណត់នៅក្នុងមាត្រា ៣៦៦ (ការសម្រេចសេចក្តីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹងជំនុំជម្រះសាជាថ្មី ជាអាទិ៍) ដល់ មាត្រា ៣៦៩ (ការសម្រេចសេចក្តីផ្អាកការអនុវត្តដោយការដាក់

ពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្ដអនុវត្ដ ជាអាទិ៍) នៃផ្នែកនេះ ។

សំណង ឬ ការពន្យារពេលត្រូវសងនេះ គួរតែត្រូវបានអះអាងដោយបណ្ដឹងតវ៉ាចំពោះការទាមទារ តែឯកសារដែលបានកំណត់នៅក្នុងចំណុច **២** នេះ មានអានុភាពផ្អាកការអនុវត្ដដោយខ្លួនឯង ។ ប៉ុន្ដែ អានុភាពផ្អាកការអនុវត្ដនេះតាមការពិត មានលក្ខណៈជាបណ្ដោះអាសន្នដោយសារអានុភាពនេះ បើមានរហូតដល់ពេលមានបណ្ដឹងតវ៉ាចំពោះការទាមទារ ជាការគ្រប់គ្រាន់ហើយ ហើយក្នុងករណីពន្យារពេលត្រូវសង ត្រូវទទួលស្គាល់លទ្ធភាពក្នុងការអនុវត្ដបន្ដទៀត ហេតុនេះហើយ បានជាចំណុចទី ២ ខាងលើនេះកម្រិតអានុភាពផ្អាកត្រឹមតែ ២ ខែតែប៉ុណ្ណោះ ។ ចំពោះការសងក៏ដោយ ឬ ការពន្យារពេលក៏ដោយ ការផ្អាកការអនុវត្ដ តាមបញ្ញត្ដិនៃកថាខណ្ឌទី ២ នេះ ត្រូវបានអនុញ្ញាតតែម្ដង ។ ទោះបីការពន្យារពេលត្រូវសង លើសពី ២ ខែក៏ដោយ ក៏ការអនុវត្ដដោយបង្ខំ ត្រូវផ្អាកតែ ២ ខែដែរ ។ ក្នុងករណីដែលភាគីចង់ទាមទារឱ្យផ្អាកការអនុវត្ដដោយបង្ខំ ក្នុងអំឡុងពេលវែងជាង ២ ខែ ដោយយកការសង ឬ ការពន្យារពេលត្រូវសង មកធ្វើជាមូលហេតុ ភាគីនោះចំបាច់ត្រូវដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ហើយទទួលដីកាសម្រេចផ្អាកការអនុវត្ដ (មាត្រា ៣៦៧ (ការសម្រេចសេចក្ដីផ្អាកការអនុវត្ដដោយការដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍)) ។

ចំពោះការលុបចោលនូវការចាត់ចែងការអនុវត្ដ តាមកថាខណ្ឌទី ១ នេះ ដោយសារល័ក្ខខ័ណ្ឌមានភាពច្បាស់លាស់ មិនចាំបាច់ទទួលស្គាល់ឧបាស្រ័យដោយបណ្ដឹងជំទាស់ ដោយខុសនឹងការចាត់ចែងលុបចោលផ្សេងទៀត ។ នេះគឺជាគោលគំនិតនៃកថាខណ្ឌទី ៣ ។

<u>Civil Execution Act (Japan)</u>

**Article 39** (Stay of compulsory execution)

1. Compulsory execution must be stayed in cases where any of the following documents are submitted:
   - i. exemplification of a decision having executory power which states that the obligation title (except for an execution document) or the declaration of provisional execution shall be annulled, or that the compulsory execution shall not be permitted;
   - ii. exemplification of a final and binding judgment which declares that the compromise, acknowledgment or conciliation concerning the obligation title is invalid;
   - iii. exemplification of a record or any other document made by the court clerk which proves that the obligation title referred to in Article 22 items ii to iv inclusive has lost its effect by reason of the withdrawal of the suit or other grounds;
   - iv. exemplification of compromise before the court or conciliation which states that compulsory execution shall not be carried out or that the motion thereof shall be withdrawn;
   - v. document which proves that security to avoid compulsory execution has been provided;
   - vi. exemplification of a decision ordering a stay of compulsory execution or an annulment of the disposition concerning execution;
   - vii. exemplification of a decision ordering a temporary stay of compulsory execution;
   - viii. document which states that the obligee has received performance or that he has granted a period of grace for performance after accomplishment of the obligation title.

**Article 40** (Annulment of disposition concerning execution)

1. In cases where a document referred to in preceding Article, paragraph 1 items i to vi inclusive has been submitted, the execution court or an execution officer shall annul the disposition concerning execution.
2. The provisions of Article 12 shall not apply to cases where a disposition concerning execution is annulled in accordance with the provisions of the preceding paragraph.

## ផ្នែកទី ៧ សោហ៊ុយសម្រាប់ការអនុវត្ត និង ការមើលសំណុំរឿងនៃការអនុវត្ត

**មាត្រា ៣៧១.-** អត្ថន័យនៃសោហ៊ុយសម្រាប់ការអនុវត្ត និង សោហ៊ុយសម្រាប់នីតិវិធី

អត្ថន័យនៃពាក្យដែលកំណត់នៅក្នុងចំណុចនីមួយៗ ត្រូវអនុលោមទៅតាមបញ្ញត្តិក្នុងចំណុចនីមួយៗខាងក្រោមនេះ :

**ក-** សោហ៊ុយសម្រាប់ការអនុវត្ត : សំដៅទៅលើពន្ធដាក់ពាក្យសុំដែលបានកំណត់នៅក្នុងមាត្រា ៣៧២ (ពន្ធដាក់ពាក្យសុំ) សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំដែលបានកំណត់នៅក្នុងមាត្រា ៣៧៣ (សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ) និង សោហ៊ុយភាគីដែលបានកំណត់នៅក្នុងមាត្រា ៣៧៤ (សោហ៊ុយភាគី) នៃក្រមនេះ ។

**ខ-** សោហ៊ុយសម្រាប់នីតិវិធី : សំដៅទៅលើសោហ៊ុយសម្រាប់ផលប្រយោជន៍រួម ក្នុងចំណោមសោហ៊ុយសម្រាប់ការអនុវត្តដែលបានកំណត់នៅក្នុងចំណុច **ក** ខាងលើនេះ ។

(កំណត់)

នៅក្នុងច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន គ្មានមាត្រាដែលត្រូវនឹងចំណុច **ក** ខាងលើនេះទេ ។ រីឯចំណុច **ខ** ខាងលើនេះបានធ្វើឡើងដោយយកកថាខណ្ឌទី 1 មាត្រា 63 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ជាគំរូ ។

សោហ៊ុយសម្រាប់នីតិវិធីដែលមានចែងក្នុងចំណុច **ខ** មានប្រើក្នុងកថាខណ្ឌទី ១ មាត្រា ៣៩២ (ការហាមឃាត់មិនឱ្យរឹបអូសក្នុងករណីដែលប៉ាន់ប្រមាណឃើញថា គ្មានចំនួនសេសសល់) ជាដើម គឺជាសោហ៊ុយដែលមានអាទិភាពក្នុងការសង នៅក្នុងនីតិវិធីអនុវត្ត ។ "សោហ៊ុយសម្រាប់ផលប្រយោជន៍រួម (expenses for the common benefit)" គឺជាសោហ៊ុយចាំបាច់ដើម្បីជម្រុញដំណើរការនៃនីតិវិធីអនុវត្ត ហើយដែលជាផលប្រយោជន៍រួមនៃម្ចាស់បំណុលទាំងអស់ (កថាខណ្ឌទី ៥ មាត្រា ៤៥៩ (ដីកាសម្រេចបង្គាប់ឱ្យប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ នៅមុនពេលដាក់ពាក្យសុំ) ជាដើម) ។

Civil Execution Act (Japan)
**Article 63** (Measures to be taken in cases where surplus is unlikely to arise)
1. In cases where the execution court deems that a surplus is unlikely to arise after satisfying the costs for common benefit out of thee costs of execution (hereinafter referred to as "costs of procedure") and obligation-rights which have priority over the right of an attachment obligee (this refers to an attachment obligee in the first ruling of commencement of compulsory sale by auction; provided that, in cases where a decision continuing the procedure has been rendered in accordance with the provisions of Article 47, paragraph 4, it refers to the attachment obligee to whom such decision has been rendered; hereinafter the same shall apply in this article and such right will be referred to as a "preferential obligation-right"), the court shall notify the attachment obligee thereof.

**មាត្រា ៣៧២.-** ពន្ធដាក់ពាក្យសុំ

១- ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅតុលាការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធចំនួន ១០.០០០ (មួយម៉ឺន) រៀល ទៅតុលាការ ។

២- ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅអាជ្ញាសាលា ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធ តាមបញ្ញត្តិដែលកំណត់ផ្សេង ។

(កំណត់)

មាត្រានេះ ត្រូវនឹងតារាងឧបសម្ព័ន្ធទី ១ កថាខណ្ឌទី 11 និង ទី 11-2 នៃច្បាប់ស្តីពីប្រាក់ប្រដាប់ក្តីរដ្ឋប្បវេណីជប៉ុន ។ ដើម្បីធ្វើការសម្រួលបញ្ញត្តិនេះ ក្នុងករណីដែលបានដាក់ពាក្យសុំទៅតុលាការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធចំនួនដូចគ្នាដោយពុំគិតអំពីពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ឬ ចំពោះសិទ្ធិលើបំណុលដែលមិនមានគោលបំណងសងជាប្រាក់ ហើយដោយពុំគិតការបង្ខំដោយផ្ទាល់ ការអនុវត្តជំនួស ឬ ការបង្ខំដោយប្រយោលទេ ។

កថាខណ្ឌទី ២ ក៏ដូចគ្នានឹងច្បាប់ជប៉ុនដែរ គឺយកការណ៍ដែលអាជ្ញាសាលាជាមន្ត្រីតុលាការ ហើយដែលបានចំណូលពីពន្ធនេះជាមូលដ្ឋាន ។ មិនត្រឹមតែអំពីពន្ធ និង សោហ៊ុយនៃអាជ្ញាសាលាប៉ុណ្ណោះទេ ត្រូវមានច្បាប់ស្តីពីអាជ្ញាសាលាដោយឡែកមួយ ដែលចែងអំពីទំហំការងារនៃអាជ្ញាសាលា ឧបាស្រ័យចំពោះការចាត់ចែងរបស់អាជ្ញាសាលា និង បញ្ហាផ្សេងៗទៀត ។

**មាត្រា ៣៧៣.-** សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ

ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់នូវចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការ ជាសោហ៊ុយចាំបាច់ក្នុងការបញ្ជូនឯកសារ ឬ ធ្វើសកម្មភាពផ្សេងទៀតដើម្បីនីតិវិធីក្នុងការអនុវត្តដោយបង្ខំ ។

(កំណត់)

មាត្រានេះត្រូវនឹងច្បាប់ស្តីពីប្រាក់ប្រដាប់ក្តីរដ្ឋប្បវេណីជប៉ុន មាត្រា 11 ។ សូមមើលបន្ថែមមាត្រា ៦២ (ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ) ។

មាត្រានេះចែងអំពីសោហ៊ុយដែលម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ឱ្យទៅតុលាការក្រៅពីពន្ធនៃការដាក់ពាក្យសុំ ។

**មាត្រា ៣៧៤.-** សោហ៊ុយភាគី

ក្រៅពីសោហ៊ុយដែលបានកំណត់នៅក្នុងមាត្រា ៣៧២ (ពន្ធដាក់ពាក្យសុំ) និង មាត្រា ៣៧៣ (សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ) នៃក្រមនេះ សោហ៊ុយដែលតុលាការទទួលស្គាល់ថាចាំបាច់ដើម្បីធ្វើការអនុវត្តដោយបង្ខំ ត្រូវចាត់ទុកថាជាសោហ៊ុយភាគី ។

(កំណត់)

មាត្រានេះត្រូវនឹងច្បាប់ស្តីពីប្រាក់ប្រដាប់ក្តីរដ្ឋប្បវេណីជប៉ុន មាត្រា 2 ក៏ប៉ុន្តែមិនមែនការចែងរៀបរាប់មួយៗទេ

គឺជាការកំណត់ទូទៅតែម្តង ។ សោហ៊ុយ (ប្រាក់ប្រដាប់ក្តី) ភាគីដែលបានកំណត់ក្នុងមាត្រានេះ គឺជាសោហ៊ុយដែលម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត ត្រូវចេញឱ្យអ្នកផ្សេងក្រៅពីតុលាការអនុវត្ត និង អាជ្ញាសាលា ដើម្បីធ្វើការអនុវត្តដោយបង្ខំនោះ ។ សោហ៊ុយនេះមានឧទាហរណ៍ដូចជា សោហ៊ុយសម្រាប់ធ្វើឯកសារ (ដូចជាពាក្យសុំឱ្យអនុវត្តដោយបង្ខំ) និង សោហ៊ុយដើម្បីដាក់ទៅតុលាការ សោហ៊ុយធ្វើដំណើររបស់ម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត ដើម្បីបង្ហាញខ្លួនតាមកាលបរិច្ឆេទ ប្រាក់ជំនួយប្រចាំថ្ងៃ និង ថ្លៃផ្ទះសំណាក់ ព្រមទាំងសោហ៊ុយដើម្បីទទួលលិខិតចម្លងនៃបញ្ជីអចលនវត្ថុជាដើមពីក្រសួងដែលមានសមត្ថកិច្ច ឬ សោហ៊ុយផ្សេងៗដែលត្រូវបង់ដើម្បីចុះបញ្ជី ជាដើម ។

**មាត្រា ៣៧៥.-** ការបង់សោហ៊ុយជាមុន

១- នៅពេលដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅតុលាការអនុវត្ត អ្នកដែលដាក់ពាក្យសុំត្រូវបង់ជាមុននូវចំនួនទឹកប្រាក់ដែលតុលាការអនុវត្តកំណត់ថាជាសោហ៊ុយចាំបាច់ដើម្បីធ្វើនីតិវិធីនៃការអនុវត្តដោយបង្ខំ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសោហ៊ុយដែលត្រូវបានបង់ជាមុនមានភាពខ្វះ ហើយតុលាការអនុវត្តបង្គាប់ឱ្យបង់ជាមុននូវសោហ៊ុយដែលខ្វះនោះ ។

២- បើអ្នកដាក់ពាក្យសុំមិនបានបង់សោហ៊ុយជាមុនទេ តុលាការអនុវត្តអាចលើកចោលពាក្យសុំឱ្យអនុវត្តដោយបង្ខំ ឬ អាចលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំនោះបាន ។

៣- ចំពោះដីកាសម្រេចលើកចោលពាក្យសុំតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

(កំណត់)

មាត្រានេះត្រូវនឹងច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 14 ។

Civil Execution Act (Japan)
**Article 14** (Advancement of costs)
1. In cases where a person makes a motion for civil execution to the execution court, such person shall advance the costs necessary for proceeding with the execution as fixed by the execution court. In cases where previously advanced costs are not sufficient, the same shall apply to cases where the execution court orders a person to advance the remainder of the costs.
2. In cases where costs have not been advanced, the execution court may dismiss the motion for civil execution or annul the procedure of the civil execution.
3. A kōkoku-appeal concerning execution may be filed against a ruling dismissing the motion referred to in the provisions of the preceding paragraph.

**មាត្រា ៣៧៦.-** បន្ទុកនៃសោហ៊ុយសម្រាប់ការអនុវត្ត

១- សោហ៊ុយសម្រាប់ការអនុវត្ត ជាបន្ទុករបស់កូនបំណុលនៃការអនុវត្ត ។

២- ក្នុងករណីដែលអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ សោហ៊ុយសម្រាប់ការ

អនុវត្ត អាចប្រមូលយកព្រមគ្នាក្នុងនីតិវិធីនៃការអនុវត្តបាន ដោយពុំចាំបាច់មានលិខិតអនុវត្តទេ ។

(កំណត់)

មាត្រានេះត្រូវនឹងច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 42 ។

សោហ៊ុយសម្រាប់ការអនុវត្តសាលក្រម គឺជាសោហ៊ុយដែលបានកំណត់ពីមាត្រា ៣៧២ (ពន្ធដាក់ពាក្យសុំ) ដល់មាត្រា ៣៧៤ (សោហ៊ុយភាគី) ។ ការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើង ដោយសារកូនបំណុលនៃការអនុវត្តមិនសងដោយស្ម័គ្រចិត្ត ហេតុនេះហើយ សោហ៊ុយចាំបាច់ដើម្បីអនុវត្តដោយបង្ខំនេះ ដែលជាសោហ៊ុយដើម្បីសម្រេចនូវសិទ្ធិ គួរឱ្យកូនបំណុលនៃការអនុវត្តត្រូវទទួលបន្ទុក (កថាខណ្ឌទី ១) ។ នេះគឺជាគោលការណ៍នៃការទទួលបន្ទុកនូវសោហ៊ុយសម្រាប់ការអនុវត្តដោយកូនបំណុល ។

កថាខណ្ឌទី ២ ចែងអំពីការប្រមូលយកសោហ៊ុយសម្រាប់ការអនុវត្តព្រមជាមួយគ្នានឹងសិទ្ធិលើបំណុល ។ បញ្ញត្តិនេះផ្អែកលើមូលហេតុថាជាការងាយស្រួលម្យ៉ាង បើអាចប្រមូលយកជាមួយគ្នាតែម្តងនូវសោហ៊ុយសម្រាប់ការអនុវត្ត នៅក្នុងនីតិវិធីអនុវត្តតែមួយ ក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងសងជាប្រាក់ ។

ចំពោះការកំណត់ស្ថាពរអំពីចំនួនសោហ៊ុយសម្រាប់ការអនុវត្ត បញ្ញត្តិនៃមាត្រា ៦៦ (នីតិវិធីដើម្បីកំណត់ជាស្ថាពរនូវចំនួនប្រាក់ប្រដាប់ក្តី) ត្រូវយកមកអនុវត្ត ហេតុដូច្នេះក្រឡាបញ្ជីនៃតុលាការអនុវត្ត ឬ សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ ត្រូវកំណត់ចំនួនសោហ៊ុយនោះ ។

Civil Execution Act (Japan)
**Article 42** (Bearing of execution costs)
1. The costs necessary for compulsory execution (hereinafter referred to as "execution costs") shall be borne by the obligor.
2. In cases where compulsory execution is carried out for an obligation-right the subject matter of which is the payment of money, the execution costs may be simultaneously collected during the execution procedure without an obligation title therefor.
3. In cases where a decision annulling the obligation title (except for an execution document) as the basis of a compulsory execution, or a judgment declaring that the compromise, acknowledgment or conciliation concerning the obligation title is invalid, has become final and binding, the obligee must repay to the obligor an amount corresponding to the execution costs already received.
4. The amount of the execution costs to be borne by the obligor in accordance with the provisions of paragraph 1, except for such costs as are collected in accordance with the provisions of paragraph 2, and the amount of money to be repaid by the obligee in accordance with the provisions of the preceding paragraph shall be fixed by the execution court upon motion.
5. A kōkoku-appeal concerning execution may be filed against a ruling on the motion referred to in the preceding paragraph.
6. A ruling in accordance with the provisions of paragraph 4 shall not be effective until it becomes final and binding.
7. The provisions of Article 100, paragraph 2, Article 101, paragraph 1, and Article 105 of the Code of Civil Procedures shall apply mutatis mutandis to the motion referred to in paragraph 4.

**មាត្រា ៣៧៧.-** ការដាក់ប្រាតិភោគ

ដើម្បីដាក់ប្រាតិភោគតាមបញ្ញត្តិនៃគន្ថីនេះ ភាគីត្រូវធ្វើតាមវិធីផ្ញើប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន ដែលតុលាការទទួលស្គាល់ថាសមរម្យ ទៅតុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគនោះ ឬ តុលាការអនុវត្ត ។

(កំណត់)

មាត្រានេះត្រូវនឹងច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 15 កថាខណ្ឌទី 1 វាក្យខណ្ឌទី 1 ។ វិធីដាក់ប្រាតិភោគ មានចែងនៅក្នុងមាត្រា ៧១ (វិធីដាក់ប្រាតិភោគ និង ការប្តូរប្រាតិភោគ) រីឯមាត្រានេះចែងអំពីតុលាការដែលត្រូវផ្ញើ ។ ម្យ៉ាងទៀត សូមមើលមាត្រា ៥៣៦ (ការផ្តល់នូវប្រាតិភោគ) ។

Civil Execution Act (Japan)
**Article 15** (Provision of security)
1. The providing of security according to the provisions of this Act shall be effected by means of depositing money or valuable instruments which the court ordering the provision of security (hereafter referred to as "ordering court" in this paragraph) deems appropriate with the depository within the jurisdiction of the district court which has jurisdiction over the place of the ordering court or the execution court, and by other means prescribed by the Rules of the Supreme Court. Provided that, if the parties have entered into a special contract which provides otherwise, such contract shall govern.

**មាត្រា ៣៧៨.-** ការមើលសំណុំរឿងនៃរឿងក្តីអនុវត្តដោយបង្ខំ ជាអាទិ៍

១- ជនដែលបានធ្វើសេចក្តីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះការអនុវត្តដោយបង្ខំដែលធ្វើឡើងដោយតុលាការអនុវត្ត អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់ អំពីចំណុចដែលពាក់ព័ន្ធនឹងរឿងក្តីនោះ ពីតុលាការបាន ដោយបង់ពន្ធ ។

២- ជនដែលបានធ្វើសេចក្តីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះការអនុវត្តដោយបង្ខំដែលធ្វើឡើងដោយអាជ្ញាសាលា អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងរឿងក្តីនោះ ពីអាជ្ញាសាលាបាន ដោយបង់ពន្ធ ។

(កំណត់)

មាត្រានេះត្រូវនឹងច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 17 និង ច្បាប់ស្តីពីអាជ្ញាសាលាជប៉ុន មាត្រា 18 ។ សូមមើលកំណត់នៃមាត្រា ២៥៨ (ការទាមទារមើលសំណុំរឿងនៃបណ្តឹង ជាអាទិ៍) ។

Civil Execution Act (Japan)
**Article 17** (Inspection of record of civil execution)
With regard to civil execution carried out by the execution court, an interested person may demand of the court clerk inspection or copying of the records of the case, or delivery of an exemplification, transcript or excerpt thereof, or a certificate with regard to matters relating to the case; provided that, with regard to inspection or the making of a copy, it will not interfere with the performance of the execution court.

## ជំពូកទី ២ ការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់

### ផ្នែកទី ១ ទ្រព្យសម្បត្តិដែលអាចរឹបអូសបាន

**មាត្រា ៣៧៩.-** គោលការណ៍

ការរឹបអូស អាចធ្វើបានចំពោះរូបទ្រព្យ ឬ អរូបទ្រព្យទាំងអស់ដែលធ្លាក់ទៅលើកូនបំណុលនៃការអនុវត្ត លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេង ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តដោយបង្ខំបារាំង មាត្រា 13 វាក្យខណ្ឌទី 1 និង ច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី អនុម័តនៅឆ្នាំ ១៩៥២ មាត្រា ១ ។ បញ្ញត្តិពិសេសក្នុងក្រមនេះ មានដូចជា មាត្រា ៣៨០ (ចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស) និង មាត្រា ៣៨២ (សិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស) ។ ទ្រព្យសម្បត្តិជារូបី សំដៅទៅលើចលនវត្ថុ និង អចលនវត្ថុ រីឯទ្រព្យសម្បត្តិជាអរូបី សំដៅទៅលើសិទ្ធិលើបំណុល ជាដើម ។

Procédure civiles d'execution (Loi n° 91-650 du 9 juillet 1991) (France)
**Article 13.**
Les saisies peuvent porter sur tous les biens appartenant au débiteur alors même qu'ils seraient détenus par des tiers.

**មាត្រា ៣៨០.-** ចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស

ចលនវត្ថុដែលបានកំណត់ដូចខាងក្រោមនេះ មិនអាចត្រូវរឹបអូសបានទេ :

**ក-** ប្រដាប់ស្លៀកពាក់ ប្រដាប់សម្រាប់ដំណេក តុ ទូ ប្រដាប់សម្រាប់ដាំស្ល និង ប្រដាប់សម្រាប់បិទយាំងបន្ទប់ របស់កូនបំណុលនៃការអនុវត្ត និង ញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា ។

**ខ-** គ្រឿងបរិភោគ និង ទហនវត្ថុ ដែលត្រូវការចាំបាច់ដើម្បីចិញ្ចឹមជីវិតក្នុងអំឡុងពេល ២ (ពីរ) ខែ របស់កូនបំណុលនៃការអនុវត្ត និង ញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា ។

**គ-** របបឧបត្ថម្ភជីវភាព របបឧបត្ថម្ភផ្នែកអប់រំ របបឧបត្ថម្ភសុខភាព និង ប្រាក់ ឬ វត្ថុឧបត្ថម្ភផ្សេងទៀតដែលផ្តល់ពីរដ្ឋ ឬ ពីអាជ្ញាធរដែនដី ដើម្បីការពារដល់ជីវភាពរបស់កូនបំណុលនៃការអនុវត្ត ។

**ឃ-** ផ្នែកប្រាក់តិចជាង ឬ ស្មើនឹង ១.០០០.០០០ (មួយលាន) រៀល ក្រៅពីប្រាក់ដែលបានកំណត់នៅក្នុងចំណុច គ ខាងលើនេះ ។

**ង-** ឧបករណ៍ ជី សត្វពាហនៈដែលជាចាំបាច់សម្រាប់ការងារកសិកម្មរបស់ខ្លួន និង ចំណីសត្វទាំងនេះ ព្រមទាំងគ្រាប់ពូជ ឬ កសិផលដែលមានប្រភេទដូចគ្នា ដែលត្រូវការចាំបាច់សម្រាប់បន្តការងារកសិកម្មរហូតដល់រដូវបាន

ផលបន្ទាប់ របស់កសិករក្នុងការប្រកបរបរកសិកម្ម ។

ច- មង សំណាញ់ ឬ នេសាទុបករណ៍ផ្សេងៗចាំបាច់ ចំណី និង កូនត្រី ឬ ជលផលប្រភេទដូចគ្នា ដែលត្រូវការចាំបាច់សម្រាប់រកជលផល ឬ ចិញ្ចឹមជលផលរបស់អ្នកប្រកបរបរនេសាទ ។

ឆ- ឧបករណ៍ និង វត្ថុផ្សេងៗដែលចាំបាច់សម្រាប់អ្នកបច្ចេកទេស សិប្បករ កម្មករ និង អ្នកផ្សេងទៀតដែលប្រកបរបរវិជ្ជាជីវៈ ឬ សាជីវកម្ម ដោយប្រើកម្លាំងប្រាជ្ញា កម្លាំងកាយ ។ ប៉ុន្តែ បើជាវត្ថុដែលអ្នកនោះមានក្នុងគោលបំណងសម្រាប់លក់ ឬ ជួលវិញ អាចរឹបអូសយកបាន ។

ជ- ព្រះពុទ្ធរូប ក្បួនវិធីសាសនា និង វត្ថុផ្សេងៗដែលចាំបាច់សម្រាប់ពិធីក្នុងសាសនា ។

ឈ- ពង្សាវលី កំណត់ប្រចាំថ្ងៃ បញ្ជីប្រកបមុខរបរ និង ឯកសារប្រភេទដូចគ្នា ដែលចាំបាច់របស់កូនបំណុលនៃការអនុវត្ត ។

ញ- គ្រឿងឥស្សរិយយស និង ប័ណ្ណសរសើរផ្សេងទៀតរបស់កូនបំណុលនៃការអនុវត្ត ឬ របស់ញាតិរបស់ជននោះ ។

ដ- ឯកសារ និង ឧបករណ៍ ដែលចាំបាច់ក្នុងការសិក្សា នៅសាលា ឬ នៅស្ថាប័នអប់រំផ្សេងទៀត របស់កូនបំណុលនៃការអនុវត្ត និង ញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា ។

ឋ- វត្ថុដែលទាក់ទងនឹងតក្កកម្ម ឬ ស្នាដៃនិពន្ធ ដែលមិនទាន់បានផ្សាយជាសាធារណៈ ។

ឌ- អវយវៈសិប្បនិមិត្ត សរីរាង្គសិប្បនិមិត្តផ្សេងទៀត និង ឧបករណ៍ជំនួយខ្លួនប្រាណផ្សេងទៀត ដែលចាំបាច់របស់កូនបំណុលនៃការអនុវត្ត និង ញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា ព្រមទាំងវត្ថុផ្សេងៗសម្រាប់ថែទាំអ្នកជម្ងឺ ដែលជាកូនបំណុលនៃការអនុវត្ត និង ញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា ។

ឍ- ម៉ាស៊ីន ឬ ឧបករណ៍ពន្លត់ភ្លើង ឧបករណ៍ជន្លៀសខ្លួនពេលមានអាសន្ន ឬ ឧបករណ៍ផ្សេងទៀត សម្រាប់អាគារ ឬ សំណង់ផ្សេងទៀត ដែលច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងៗតម្រូវឱ្យមានបរិក្ខារ ដើម្បីបង្ការមហន្តរាយ ឬ ការពារសន្តិសុខ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 131 ច្បាប់ការពារជីវភាពរស់នៅជប៉ុន មាត្រា 58 ច្បាប់ស្តីពីការអនុវត្តដោយបង្ខំបារាំង មាត្រា 14 ។

ជាគោលការណ៍ ទ្រព្យសម្បត្តិទាំងអស់របស់កូនបំណុលនៃការអនុវត្ត អាចក្លាយជាកម្មវត្ថុនៃការរឹបអូសបាន (មាត្រា ៣៧៩ (គោលការណ៍)) ប៉ុន្តែ ដោយមានមូលហេតុពាក់ព័ន្ធនឹងគោលនយោបាយ ទ្រព្យសម្បត្តិមួយចំនួន ត្រូវបានហាមឃាត់មិនឱ្យរឹបអូស ។ ប៉ុន្តែ ការហាមមិនឱ្យរឹបអូស ដែលមានចែងក្នុងចំណុចនីមួយៗក្នុងមាត្រានេះ មានមូលហេតុមិនដូចគ្នាទាំងស្រុងទេ ។ ការចែងពីចំណុច **ក** ដល់ **ឃ** គឺដើម្បីការពារជីវភាពយ៉ាងទាបបំផុតរបស់កូនបំណុល

នៃការអនុវត្ត (ចំនួនប្រាក់ដែលមានចែងក្នុងចំណុច **ឃ** គឺស្មើនឹងចំណាយយ៉ាងទាបបំផុតសម្រាប់គ្រួសារមធ្យមមួយដើម្បីអាចចិញ្ចឹមជីវិតបានមួយខែ ។ ម្យ៉ាងទៀត ចំណុច **គ** ហាមឃាត់មិនឱ្យរឹបអូសប្រាក់ ឬ វត្ថុឧបត្ថម្ភទាំងអស់ដូចជារបបឧបត្ថម្ភជីវភាព ជាដើម ដើម្បីគោរពគោលបំណងនៃរបបឧបត្ថម្ភជីវភាព ជាដើម នោះ រីឯចំណុច **ឃ** ហាមឃាត់មិនឱ្យរឹបអូសតែចំនួនប្រាក់ដែលកំណត់ ដើម្បីការពារជីវភាពយ៉ាងទាបបំផុតរបស់កូនបំណុលនៃការអនុវត្តទោះបីកូនបំណុលនៃការអនុវត្តនោះ ទទួលប្រាក់ ឬ វត្ថុឧបត្ថម្ភជីវភាព ជាដើម ឬ មិនទទួលក៏ដោយ) ។ ការចែងពីចំណុច **ខ** ដល់ **ឆ** គឺដើម្បីធានានូវការបន្តមុខរបរ ហើយការចែងពីចំណុច **ជ** ដល់ **ឋ** គឺដោយយោងទៅតាមគោលនយោបាយផ្នែកវប្បធម៌ រីឯការចែងក្នុងចំណុច **ឌ** និង **ឍ** គឺដោយយោងទៅតាមគោលនយោបាយ ផ្នែកសង្គម ។

នៅទីកន្លែងដែលត្រូវអនុវត្តការរឹបអូសជាក់ស្តែង អាជ្ញាសាលាជាអ្នកវិនិច្ឆ័យសម្រេចថា តើវត្ថុដែលមាននៅទីនោះជាវត្ថុដែលត្រូវហាមមិនឱ្យរឹបអូស ឬទេ ។ ទោះបីជាការរឹបអូសនោះបានធ្វើខុសពីបញ្ញត្តិនៃមាត្រានេះក៏ដោយ មិនមែនមានន័យថា ការរឹបអូសនោះត្រូវចាត់ទុកជាមោឃៈទេ ។ ប៉ុន្តែ អ្នកដែលមានទំនាក់ទំនងផលប្រយោជន៍ អាចតវ៉ាចំពោះការអនុវត្ត ទៅសាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ ដើម្បីទាមទារឱ្យលុបការរឹបអូសនោះចោលវិញបាន ។

Civil Execution Act (Japan)
**Article 131** (Movables which may not be seized)

The following movables may not be seized:

i. clothes, bedding, furniture, kitchen utensils, tatami mats and fitting indispensable to the obligor and the like;
ii. food and fuel needed by the obligor and the like to live for two months;
iii. the amount of money established by a Cabinet Order as a month's necessary living costs for a standard household;
iv. implements, manure and livestock to be used for indispensable work by a person engaged in agriculture mainly through his own labor, fodder of such livestock, seeds and any other similar agricultural products indispensable to such person to continue farming until the next harvest;
v. fishing nets and any other fishing implements, bait, fry and any other similar aquatic products indispensable to a person engaged in fishing mainly through his own labor;
vi. implements and any other things (except for goods) indispensable to an engineer, an artisan, a laborer or any other person engaged in an occupation or business mainly through his own mental or physical labor (except for persons referred to in the preceding two paragraph);
vii. a registered seal or any other stamps indispensable for an occupation or living;
viii. a Buddhist image, memorial wooden tablet or any other objects indispensable for worship or a religious rite;
ix. a genealogical record, diary, account books, or any other documents similar to them necessary to the obligor;
x. a decoration or any other honor which the obligor or his relatives have been given;
xi. documents and implements necessary for the obligor and the like to study at a school or any other educational institution;
xii. items concerning an invention or a literary work which has not yet been made public;
xiii. an artificial arm or leg or any other prosthetic devices necessary for the obligor and the like;
xiv. a machine or apparatus for fire-fighting, an apparatus for shelter or any other fixtures with which a building or any other structure must be equipped in accordance with the provisions of laws or ordinances enacted to prevent disaster or preserve security.

Procédure civiles d'execution (Loi n° 91-650 du 9 juillet 1991) (France)
**Article 14.**
Ne peuvent être saisis :

1° Les biens que la loi déclare insaisissables ;

2° Les provisions, sommes et pensions à caractère alimentaire, sauf pour le paiement des aliments déjà fournis par le saisissant à la partie saisie ;

3° Les biens disponibles déclarés insaisissables par le testateur ou le donateur, si ce n' est, avec la permission du juge et pour la portion qu' il détermine, par les créancers postérieurs à l' acte de donation ou à l' ouverture du legs ;

4° Les biens mobilers nécessaires à la vie et au travail du saisi et de sa famille, si ce n' est pour paiement de leur prix, dans les limites fixées par décret en Consel d' Etat et sous réserve des dispositions du septième alinéa du présent article ; ils demeurent cependant saisissables s' ils se trouvent dans un lieu autre que celui où le saisi demeure ou travaille habituellement, s' ils sont des biens de valeurs, en raison notamment de leur importance, de leur matière, de leur rareté, de leur ancienneté ou de leur caractère luxueux, s' ils perdent leur caractère de nécessité en raison de leur quantité ou s' ils constituent des éléments corporels d' un fonds de

commerce ;

5° Les objets indispensables aux personnes handicapées ou destinés aux soins des personnes malades.

Les biens visés au 4° ne peuvent être saisis, même pour paiement de leur prix, lorsqu' ils sont la propriété des bénéficiaires de l'aide sociale à l'enfance prévue aux articles 150 à 155 du Code de la famille et de l'aide sociale.

Les immeubles par destination ne peuvent être saisis indépendamment de l'immeuble, sauf pour paiement de leur prix.

**មាត្រា ៣៨១.-** ការប្តូរទំហំនៃចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស

១- សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ អាចបង្គាប់ឱ្យលុបចោលទាំងអស់ ឬ មួយផ្នែកនូវការរឹបអូសដែលធ្វើឡើងដោយអាជ្ញាសាលា ឬ អាចអនុញ្ញាតឱ្យរឹបអូសនូវចលនវត្ថុ ដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃមាត្រា ៣៨០ (ចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស) នៃក្រមនេះ ដោយពិចារណាទៅលើជីវភាព និង ស្ថានភាពផ្សេងៗរបស់កូនបំណុលនៃការអនុវត្ត និង ម្ចាស់បំណុលនៃការអនុវត្ត តាមពាក្យសុំបាន ។

២- ប្រសិនបើស្ថានភាពមានការផ្លាស់ប្តូរ សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ អាចអនុញ្ញាតឱ្យរឹបអូសចលនវត្ថុដែលត្រូវបានលុបចោលការរឹបអូស តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ឬ អាចបង្គាប់ឱ្យលុបចោលទាំងអស់ ឬ មួយផ្នែកនូវការរឹបអូសតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ដដែលនេះ តាមពាក្យសុំបាន ។

៣- ប្រសិនបើមានពាក្យសុំឱ្យចេញដីកាសម្រេចលុបចោលនូវការរឹបអូសតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ អាចបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំនោះ ដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគបាន រហូតដល់ដីកាសម្រេចនោះមានអានុភាព ។

៤- ចំពោះដីកាសម្រេចលើកចោលពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ ខាងលើនេះ និង ចំពោះដីកាសម្រេចអនុញ្ញាតឱ្យរឹបអូស តាមបញ្ញត្តិទាំងឡាយខាងលើនេះ អាចប្តឹងជំទាស់បាន ។

(កំណត់)

តាមធម្មតា ត្រូវចែងឱ្យច្បាស់លាស់អំពីចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូសបាន (សូមមើលមាត្រា ៣៨០ (ចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស)) ប៉ុន្តែ មានបញ្ហាខ្លះដែលអាចកើតឡើងក្នុងករណីពិតៗ ។ ហេតុនេះហើយ បានជាមាត្រានេះចែងឱ្យតុលាការអាចពង្រីក ឬ កម្រិតនូវទំហំនៃចលនវត្ថុដែលមិនអាចត្រូវរឹបអូសបាន តាមឆន្ទៈរបស់ខ្លួនបាន ដើម្បីតម្រូវទៅតាមស្ថានភាព នៃករណីនីមួយៗ នៅពេលដែលមានពាក្យសុំ ។

ពេលធ្វើការពង្រីក ឬ កម្រិតនូវទំហំនៃចលនវត្ថុដែលមិនអាចត្រូវរឹបអូសនោះ តុលាការត្រូវពិចារណាអំពីជីវភាពរស់នៅ និង ស្ថានភាពផ្សេងៗរបស់កូនបំណុលនៃការអនុវត្ត និង ម្ចាស់បំណុលនៃការអនុវត្តនោះ ។ ឧទាហរណ៍ : ចំពោះករណី ដែលជីវភាពរបស់កូនបំណុលនៃការអនុវត្ត នឹងអាចធ្លាក់ចុះយ៉ាងដុនដាប ដោយសារការរឹបអូសនោះ ជាដើម ទំហំនៃចលនវត្ថុដែលមិនអាចរឹបអូសបានក៏ត្រូវតែពង្រីក រីឯចំពោះករណីដែលម្ចាស់បំណុលនៃការអនុវត្តមានជីវភាពរស់នៅយ៉ាងទាបបំផុត ហើយទាមទារឱ្យអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលដែលជាប្រាក់ដើម្បីគាំទ្រជីវភាពរបស់ខ្លួននោះ ទំហំនៃចលនវត្ថុដែលមិនអាចត្រូវរឹបអូសបាននោះក៏ត្រូវកម្រិតទៅតាមសភាពនោះដែរ ។

ឧទាហរណ៍ជាក់ស្តែងនៃករណី "ស្ថានភាពមានការផ្លាស់ប្តូរ" ដែលមានចែងក្នុងកថាខណ្ឌទី ២ ខាងលើនេះ មានដូចជា ការផ្លាស់ប្តូរមុខរបររបស់កូនបំណុលនៃការអនុវត្ត ស្ថានភាពសេដ្ឋកិច្ចរបស់ម្ចាស់បំណុលនៃការអនុវត្តត្រូវបានធ្លាក់ចុះដុនដាប ករណីដែលកូនបំណុលនៃការអនុវត្តគ្មានឆន្ទៈអនុវត្តតាមកិច្ចសន្យាទាល់តែសោះ ជាដើម ។ កថាខណ្ឌទី ៤ នៃមាត្រានេះចែងឱ្យអំពីលទ្ធភាពអាចធ្វើបណ្តឹងជំទាស់ចំពោះ "ដីកាសម្រេចលើកចោលពាក្យសុំ" និង "ដីកាសម្រេចអនុញ្ញាតឱ្យរឹបអូស" បានតែប៉ុណ្ណោះ ។ នេះមិនមែនមានន័យថា មិនអាចធ្វើបណ្តឹងជំទាស់ចំពោះដីកាសម្រេចលុបចោលនូវការរឹបអូសដែលធ្វើឡើងដោយអាជ្ញាសាលានោះទេ គឺបណ្តឹងជំទាស់ប្រភេទនេះមានចែងនៅ ចំណុច **ខ** កថាខណ្ឌទី ១ មាត្រា ៣៨៥ (បណ្តឹងជំទាស់ចំពោះដីកាសម្រេចលុបចោល ជាអាទិ៍) រួចហើយ ។ ហេតុនេះហើយបានជាមិនចែងក្នុងកថាខណ្ឌទី ៤ នេះទៀត ។

**មាត្រា ៣៨២.‐** សិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស

១- បៀវត្ស ប្រាក់ឈ្នួល និង សិទ្ធិលើបំណុលដែលមានលក្ខណៈដូចប្រាក់បៀវត្សផ្សេងទៀត អាចរឹបអូសបានចំពោះប្រាក់សល់ក្រោយពីបានកាត់នូវពន្ធអាករ និង ប្រាក់ធានារ៉ាប់រងសង្គមកិច្ច ពីចំនួនទឹកប្រាក់ដែលកូនបំណុលនៃការអនុវត្តត្រូវទទួលសំណង នៅពេលកំណត់ត្រូវសងនោះលុះត្រាតែស្របតាមចំណុចនីមួយៗដែលកំណត់ដូចខាងក្រោមនេះ :

- **ក**- ផ្នែកតិចជាង ឬ ស្មើនឹង ២០០.០០០ (ពីរសែន) រៀល ក្នុងមួយខែនោះ ពុំអាចរឹបអូសបានទេ ។
- **ខ**- ផ្នែកក្នុងខ្ទង់លើសពី ២០០.០០០ (ពីរសែន) រៀល ទៅ ៦០០.០០០ (ប្រាំមួយសែន) រៀល ក្នុងមួយខែនោះ ពុំអាចរឹបអូសលើសចំនួនទឹកប្រាក់ ១ ភាគ ៤ (មួយភាគបួន) នៃផ្នែកនេះទេ ។
- **គ**- ផ្នែកក្នុងខ្ទង់លើសពី ៦០០.០០០ (ប្រាំមួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ក្នុងមួយខែនោះ ពុំអាចរឹបអូសលើសចំនួនទឹកប្រាក់ ១ ភាគ ៣ (មួយភាគបី) នៃផ្នែកនេះទេ ។
- **ឃ**- ផ្នែកក្នុងខ្ទង់លើសពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ក្នុងមួយខែនោះ ពុំអាចរឹបអូសលើសចំនួនទឹកប្រាក់ ១ ភាគ ២ (មួយភាគពីរ) នៃផ្នែកនេះទេ ។
- **ង**- ផ្នែកក្នុងខ្ទង់លើសពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ក្នុងមួយខែនោះ ពុំអាចរឹបអូសលើសចំនួនទឹកប្រាក់ ២ ភាគ ៣ (ពីរភាគបី) នៃផ្នែកនេះទេ ។
- **ច**- ផ្នែកលើសពី ៦.០០០.០០០ (ប្រាំមួយលាន) រៀល ក្នុងមួយខែ អាចរឹបអូសយកបានទាំងអស់ ។

២- ចំពោះសិទ្ធិលើបំណុលចំពោះប្រាក់ឧបត្ថម្ភជីវភាព ប្រាក់ឧបត្ថម្ភផ្នែកសិក្សា ប្រាក់ឧបត្ថម្ភសុខភាព និង សិទ្ធិលើបំណុលផ្សេងទៀតដែលមានគោលបំណងការពារជីវភាពរបស់កូនបំណុលនៃការអនុវត្ត ពុំអាចរឹបអូសបានឡើយ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 152 ច្បាប់ការពារជីវភាពរស់នៅជប៉ុន មាត្រា 58 ច្បាប់សំណងព្រហ្មទណ្ឌជប៉ុន មាត្រា 22 ច្បាប់ធានារ៉ាប់រងការខូចខាតរថយន្តជប៉ុន មាត្រា 18 ច្បាប់ស្តីពីការអនុវត្តដោយបង្ខំអាល្លឺម៉ង់ មាត្រា 850c ច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណីកម្ពុជា មាត្រា ២ ជាដើម ។

Civil Execution Act (Japan)
**Article 152** (Obligation-rights which may not be attached)
1. An amount corresponding to three-fourths of the payment to be received at the due date for the following obligation-rights (or if such amount exceeds that provided for by a Cabinet Order in consideration of the living costs necessary for a standard household, then the portion corresponding to the amount provided by the Cabinet Order may not be attached.
   i. an obligation-right concerning periodic payments to be made to the obligor by a person other than the State or a local public entity in order to support him in his living.
   ii. an obligation-right concerning salary, wages, rewards, retirement annuities, bonuses and any other pays of such nature.
2. With regard to retirement allowances and pays of such nature, an amount corresponding to three-fourths of such payment may not be attached.

**មាត្រា ៣៨៣.-** ការផ្លាស់ប្តូរទំហំនៃសិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស
១- តុលាការនៃការអនុវត្តអាចលុបចោលដីកាសម្រេចរឹបអូសទាំងអស់ ឬ មួយផ្នែក ឬ អាចចេញដីកាសម្រេចរឹបអូសសិទ្ធិលើបំណុលទាំងអស់ ឬ មួយផ្នែកដែលត្រូវបានហាមឃាត់ការរឹបអូសតាមបញ្ញត្តិនៃមាត្រា ៣៨២ (សិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស) នៃក្រមនេះ ដោយពិចារណាទៅលើជីវភាព និង ស្ថានភាពផ្សេងៗរបស់កូនបំណុលនៃការអនុវត្ត និង ម្ចាស់បំណុលនៃការអនុវត្ត តាមពាក្យសុំបាន ។
២- ប្រសិនបើស្ថានភាពមានការផ្លាស់ប្តូរ តុលាការនៃការអនុវត្តអាចរឹបអូសសិទ្ធិលើបំណុល ដែលត្រូវបានលុបចោលដីកាសម្រេចរឹបអូសនោះតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើ ឬ អាចលុបចោលនូវដីកាសម្រេចរឹបអូសទាំងអស់ ឬ មួយផ្នែកតាមបញ្ញត្តិនៃកថាខណ្ឌដដែលនេះ តាមពាក្យសុំបាន ។
៣- ប្រសិនបើមានពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ តុលាការនៃការអនុវត្ត អាចបង្គាប់ហាមឃាត់កូនបំណុលទី ៣ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៤០២ (អត្ថន័យនៃការអនុវត្តចំពោះសិទ្ធិលើបំណុល និង តុលាការអនុវត្ត) នៃក្រមនេះ មិនឱ្យបង់ ឬ ផ្តល់តាវកាលិកផ្សេងទៀត ដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគបាន រហូតដល់ដីកាសម្រេចនោះមានអានុភាព ។
៤- ចំពោះដីកាសម្រេចលើកចោលពាក្យសុំឱ្យលុបចោលដីកាសម្រេចរឹបអូស តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 153 ។

គោលបំណងនៃមាត្រានេះ ដូចគ្នានឹងមាត្រា ៣៨១ (ការប្តូរទំហំនៃចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស) ។

Civil Execution Act (Japan)
**Article 153** (Alteration of obligation-rights which may not be attached)
1. The execution court, upon motion, may annul an attachment order in its entirely or in part, or may issue an attachment order with regard to the portion which may not be attached in accordance with the provisions of the preceding Article, in consideration of the living conditions of the obligor and the obligee and other circumstances.
2. If circumstances have changed, the execution court, upon motion, may attach an obligation-right the attachment order of which has been annulled according to the provisions of the preceding paragraph, or annul, wholly or partially an attachment order made according to the preceding paragraph.
3. Where a motion referred to in the preceding two paragraphs has been made, the execution court, either upon or without security being provided, may prohibit the third obligor from payment or making any other performance until the decision becomes effective.
4. A kōkoku-appeal concerning execution may be filed against a ruling dismissing a motion for annulment in accordance with the provisions of paragraph 1 or 2.
5. No complaint may be filed against a ruling in accordance with the provisions of paragraph 3.

## ផ្នែកទី ២ ការអនុវត្តចំពោះចលនវត្ថុ

**មាត្រា ៣៨៤.-** ការចាប់ផ្តើមអនុវត្តចំពោះចលនវត្ថុ

១- ពាក្យសុំអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ត្រូវធ្វើទៅអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំស្ថិតនៅ ។

២- នៅក្នុងពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុ ក្រៅពីចំណុចនីមួយៗដែលកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣៤៩ (របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ) នៃក្រមនេះ ត្រូវសរសេរអំពីទីកន្លែងដែលចលនវត្ថុដែលត្រូវរឹបអូសនោះស្ថិតនៅ ។(1)

៣- ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ នឹងត្រូវចាប់ផ្តើមដោយការរឹបអូសវត្ថុដែលជាកម្មវត្ថុដោយអាជ្ញាសាលា ។(2)

៤- ចលនវត្ថុដែលបានកំណត់ក្នុងគន្ថីនេះ មានរួមបញ្ចូលទាំងផលធម្មជាតិដែលមិនទាន់បំបែកពីដីនៅឡើយ ហើយអាចនឹងទទួលផលបានយ៉ាងច្បាស់នៅក្នុងអំឡុងពេល ១(មួយ) ខែ ។(3)

៥- ប្រសិនបើបានជួបប្រទះកូនបំណុលនៃការអនុវត្តនៅកន្លែងដែលត្រូវរឹបអូស អាជ្ញាសាលាត្រូវដាស់តឿនឱ្យកូនបំណុលនៃការអនុវត្តនោះសងបំណុលដោយស្ម័គ្រចិត្ត នៅមុនពេលចាប់ផ្តើមរឹបអូស ។(4)

៦- ក្នុងការអនុវត្តចំពោះចលនវត្ថុ អាជ្ញាសាលាអាចទទួលសំណងនៃបំណុល និង សំណងសោហ៊ុយសម្រាប់ការអនុវត្តដើម្បីម្ចាស់បំណុលនៃការអនុវត្តបាន ។(5)

(កំណត់)

សូមមើលមាត្រា 122 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន និង មាត្រា ៩៩ នៃបទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

(1) ចំពោះករណីដែលអនុវត្តចំពោះចលនវត្ថុនេះ ខុសគ្នាពីករណីដែលអនុវត្តចំពោះអចលនវត្ថុ ដោយពុំចាំបាច់កំណត់ច្បាស់លាស់ចំពោះចលនវត្ថុដែលត្រូវអនុវត្តនៅដំណាក់កាលដាក់ពាក្យសុំនោះឡើយ ។ មានន័យថា ក្នុងពាក្យសុំនេះ

គ្រាន់តែសរសេរថា រឹបអូសចលនវត្ថុដែលមាននៅកន្លែងនេះ ឬ កន្លែងនោះតែប៉ុណ្ណោះ គឺចលនវត្ថុច្រើនប្រភេទដែលមាននៅកន្លែងនោះគឺជាកម្មវត្ថុនៃការរឹបអូស ។ ចំណុចនេះគឺខុសពីពាក្យសុំការអនុវត្តលើអចលនវត្ថុ ឬ សិទ្ធិលើបំណុលផ្សេងៗទៀត ដោយសារតែមានការលំបាកក្នុងការសរសេរបញ្ជាក់លំអិតនូវវត្ថុនីមួយៗដែលមាននោះ ។ ហេតុនេះហើយ ការកំណត់លំអិតស្តីពីចលនវត្ថុដែលអាចរឹបអូសបាននោះ ត្រូវប្រគល់ជូនអាជ្ញាសាលា សម្រេចពេលទៅដល់កន្លែងដែលត្រូវធ្វើការរឹបអូសនោះ ។

(2) ដោយការអនុវត្តចំពោះចលនវត្ថុនេះ អាជ្ញាសាលាជាស្ថាប័នអនុវត្ត តុលាការអនុវត្តសាលក្រម មិនចាំបាច់ធ្វើការវិនិច្ឆ័យដើម្បីចាប់ផ្តើមធ្វើការរឹបអូសដូចករណីរឹបអូសអចលនវត្ថុនោះទេ ម្ល៉ោះហើយ មាត្រានេះបានចែងថា ការអនុវត្តនេះចាប់ផ្តើមពីពេលដែលអាជ្ញាសាលាបានធ្វើការរឹបអូស ។

(3) ដើម្បីវិនិច្ឆ័យថា ចលនវត្ថុណាមួយសមរម្យនឹងរឹបអូសនោះ អាជ្ញាសាលាត្រូវពិនិត្យមើលថា តើចលនវត្ថុនោះសមរម្យជារបស់ដែលត្រូវរឹបអូសដើម្បីគ្រប់គ្រងដែរឬទេ? ក្នុងច្បាប់រដ្ឋប្បវេណី ជាគោលការណ៍ដែលហៅថា ចលនវត្ថុ គឺជាវត្ថុដែលអាចយកទៅគ្រប់គ្រងបាន ។ រីឯផលធម្មជាតិមុននឹងបំបែក (បេះ) ពីដីនោះ មិនមែនជាចលនវត្ថុទេ ក៏ប៉ុន្តែផលដែលនឹងបានទទួលច្បាស់លាស់ក្នុងអំឡុងពេល ១ ខែនោះ គឺជាទ្រព្យដែលនឹងក្លាយជាចលនវត្ថុឯករាជ្យក្នុងអំឡុង ១ ខែ ហេតុនេះហើយបានជា គួរតែចាត់ទុកជា កម្មវត្ថុនៃការរឹបអូសចលនវត្ថុដែរជាការប្រសើរ ។

(4) បញ្ញត្តិនេះអត់មានចែងក្នុងច្បាប់ជប៉ុនទេ ។ ជាទូទៅ ម្ចាស់បំណុលនៃការអនុវត្តនេះ ច្រើនតែបានទទួលប្រាក់ដែលជាផលនៃការរឹបអូសចលនវត្ថុនោះ បន្តិចបន្តួចតែប៉ុណ្ណោះ ហើយមិនស្របចិត្តទេ ។ ក៏ប៉ុន្តែ ការរឹបអូសចលនវត្ថុនេះ គឺជាវិធីមួយដែលអាចប្រើដើម្បីបង្ខំខាងផ្លូវចិត្តកូនបំណុលនៃការអនុវត្តនោះ ហើយដាស់តឿនឱ្យសងបំណុលនោះបាន ។ ហេតុនេះហើយ ការឱ្យអាជ្ញាសាលាដាស់តឿនទាមទារសំណងនេះ ជាការសមរម្យមួយដែរ ។

(5) អត់មានបញ្ញត្តិណាចែងដូចនេះទេ ចំពោះការរឹបអូសអចលនវត្ថុ ឬ រឹបអូសសិទ្ធិលើបំណុលដែលតុលាការអនុវត្តសាលក្រមមានតួនាទីជាស្ថាប័នអនុវត្តនោះទេ ។ ក៏ប៉ុន្តែ អាជ្ញាសាលាស្ថាប័នអនុវត្តការរឹបអូសចលនវត្ថុ ហើយជួបផ្ទាល់នឹងកូនបំណុល ហេតុនេះហើយ អាជ្ញាសាលានេះអាចយល់ច្បាស់លាស់អំពីកម្មវត្ថុនៃសិទ្ធិទាមទារ ចំពោះកូនបំណុលនៃការអនុវត្ត ។ ដូច្នេះហើយ អាចផ្តល់សិទ្ធិទទួលយកសំណងដល់អាជ្ញាសាលានេះបាន ។ ក្នុងករណីដែលកូនបំណុលនៃការអនុវត្តមានចិត្តសងបំណុល អាចធ្វើឱ្យនីតិវិធីអនុវត្តនោះមានដំណើរការល្អ ហើយអាចបំបាត់នូវអ្វីៗដែលអត់ប្រយោជន៍ក្នុងការអនុវត្តនោះបាន ។

<u>Civil Execution Act (Japan)</u>
**Article 122** (Commencement of execution concerning movables)
1. Compulsory execution against movables (including fixtures on land which may not be registered, natural fruits which have not yet been taken from the land but which will definitely be taken within one month, and valuable instruments other than those valuable instruments whose endorsement is prohibited; this shall apply throughout this Section.) shall be commenced by seizure of the subject matter by the execution officer (hereinafter referred to as "execution against movables").
2. In an execution against movables, the execution officer may receive satisfaction of the obligation-right of the attachment obligee and the costs of execution on behalf of the said obligee.

**មាត្រា ៣៨៥.-** ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត

១- ចំពោះការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត អាជ្ញាសាលាត្រូវធ្វើដោយកាន់កាប់ចលនវត្ថុនោះ ។(1)

២- នៅពេលធ្វើការរឹបអូសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាជ្ញាសាលាអាចចូលទៅក្នុងទីកន្លែងរស់នៅរបស់កូនបំណុលនៃការអនុវត្ត ឬ កន្លែងផ្សេងទៀតដែលកូនបំណុលនៃការអនុវត្តនោះកាន់កាប់ ហើយអាចធ្វើការឆែកឆេររកចលនវត្ថុដែលអាចរឹបអូសនោះបាន ។ ក្នុងករណីនេះ បើមានភាពចាំបាច់ អាជ្ញាសាលាអាចធ្វើការចាត់ចែងចាំបាច់ដើម្បីបើកទ្វារដែលបិទ ទូដែក និង ប្រអប់ផ្សេងទៀតបាន ។(2)

៣- ពេលធ្វើការជ្រើសរើសចលនវត្ថុដែលត្រូវរឹបអូស អាជ្ញាសាលាត្រូវគិតពិចារណាដល់ផលប្រយោជន៍របស់កូនបំណុលនៃការអនុវត្ត ក្នុងល័ក្ខខ័ណ្ឌពុំធ្វើឱ្យមានការខូចខាតដល់ផលប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្ត ។

៤- ប្រសិនបើយល់ឃើញថាសមរម្យ អាជ្ញាសាលាអាចឱ្យកូនបំណុលនៃការអនុវត្តថែរក្សា គ្រប់គ្រងនូវចលនវត្ថុដែលត្រូវបានរឹបអូស ។ នៅក្នុងករណីនេះ ការរឹបអូសនោះមានអានុភាព លុះត្រាតែចលនវត្ថុដែលបានរឹបអូសនោះ ត្រូវបានបិទស្លាក ឬ ដាក់សញ្ញារឹបអូសដោយវិធីផ្សេងទៀត ។(3)

៥- ក្នុងករណីដែលអាជ្ញាសាលាបានឱ្យកូនបំណុលនៃការអនុវត្តថែរក្សា គ្រប់គ្រងនូវចលនវត្ថុដែលបានរឹបអូស តាមបញ្ញត្តិនៃកថាខណ្ឌទី ៤ ខាងលើនេះ ប្រសិនបើយល់ឃើញថាសមរម្យ អាជ្ញាសាលាអាចអនុញ្ញាតឱ្យកូនបំណុលនៃការអនុវត្តប្រើចលនវត្ថុនោះបាន ។

៦- ប្រសិនបើយល់ថាចាំបាច់ អាជ្ញាសាលាអាចថែរក្សាគ្រប់គ្រងដោយខ្លួនឯងវិញនូវចលនវត្ថុដែលបានឱ្យកូនបំណុលនៃការអនុវត្តថែរក្សាគ្រប់គ្រង តាមបញ្ញត្តិនៃកថាខណ្ឌទី ៤ ខាងលើ ឬ អាចលុបចោលនូវការអនុញ្ញាតដែលបានធ្វើតាមបញ្ញត្តិនៃកថាខណ្ឌទី ៥ ខាងលើនេះបាន ។ បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអាជ្ញាសាលាថែរក្សាគ្រប់គ្រងដោយខ្លួនឯងវិញ នូវចលនវត្ថុដែលបានឱ្យកូនបំណុលនៃការអនុវត្តថែរក្សាគ្រប់គ្រងនោះ ។

(កំណត់)

សូមមើលមាត្រា 123 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន និង មាត្រា 100 នៃបញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

(1) ជាគោលការណ៍ ការរឹបអូសចលនវត្ថុ គឺត្រូវធ្វើតែចំពោះចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលតែប៉ុណ្ណោះ ។ ក៏ប៉ុន្តែកម្មសិទ្ធិនៃចលនវត្ថុមានការលំបាកនឹងដឹងណាស់តាមការមើលពីក្រៅ ម្យ៉ាងទៀត ចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្តនោះ ភាគច្រើនជាកម្មសិទ្ធិរបស់កូនបំណុលនោះ ហេតុនេះហើយបានជាចលនវត្ថុ

ដែលកាន់កាប់ដោយកូនបំណុលអាចត្រូវរឹបអូសបានទាំងអស់ ។ ចំពោះករណីដែលអ្នកផ្សេងក្រៅពីកូនបំណុលនៃការអនុវត្ត មានកម្មសិទ្ធិលើចលនវត្ថុដែលរឹបអូសនោះ ម្ចាស់កម្មសិទ្ធិត្រូវប្ដឹងតវ៉ាក្នុងឋានៈជាតតិយជន ដើម្បីការពារវត្ថុរបស់ខ្លួន ។

ការកាន់កាប់ដែលចែងក្នុងមាត្រានេះ សំដៅទៅលើការកាន់កាប់ដោយផ្ទាល់ ហើយមិនមែនក្នុងន័យដោយប្រយោលឡើយ ។

(2) ចំពោះការអនុវត្តលើចលនវត្ថុ អាជ្ញាសាលាមានតួនាទីសម្រេចនូវចលនវត្ថុដែលត្រូវរឹបអូសនៅទីកន្លែងកំណត់ច្បាស់លាស់នោះ ក៏ប៉ុន្តែ គួរតែរឹបអូសនូវចលនវត្ថុណាដែលមិនសូវមានឥទ្ធិពលដល់ជីវភាពរស់នៅ និង វត្ថុដែលស្រួលដាក់លក់ឡាយឡុងដើម្បីប្ដូរជាលុយផង ជាការប្រសើរ ។

(3) ការរឹបអូសចលនវត្ថុ ត្រូវធ្វើឡើងតាមរយៈការកាន់កាប់ចលនវត្ថុដែលបានរឹបអូសនោះ ដោយអាជ្ញាសាលាតាមការចែងក្នុងកថាខណ្ឌទី ១ ហេតុនេះហើយ ជាគោលការណ៍ មន្ត្រីអនុវត្តសាលក្រមនោះជាអ្នកទទួលខុសត្រូវកាន់កាប់ចលនវត្ថុនោះ ។ ដូច្នេះហើយ ការរឹបអូសចលនវត្ថុដូចជាលុយ ឬ គ្រឿងអលង្ការ ជាដើម ដែលជាវត្ថុមានតម្លៃ ហើយស្រួលដឹកជញ្ជូនផងនោះ តាមធម្មតា អាជ្ញាសាលាត្រូវរក្សាទុកវត្ថុនោះ ដោយខ្លួនឯង ។ ក៏ប៉ុន្តែចំពោះចលនវត្ថុដែលមានការពិបាក ឬ អស់សោហ៊ុយច្រើន ក្នុងការដឹកជញ្ជូនឬក្នុងការរក្សាទុកនោះ អាជ្ញាសាលាអាចសម្រួលដោយប្រគល់ឱ្យកូនបំណុលនៃការអនុវត្ត ដែលបានកាន់កាប់រហូតដល់ថ្ងៃរឹបអូសនោះ រក្សាទុកតទៅទៀតបាន ។ ក្នុងករណីនេះ ត្រូវមានផ្លាកបញ្ជាក់ឱ្យដឹងថាជាចលនវត្ថុដែលបានរឹបអូស ដោយវិធីបិទភ្ជិតលើចលនវត្ថុនោះ ជាដើម ។

<u>Civil Execution Act (Japan)</u>

**Article 123** (Seizure of movables in the possession of the obligor)

1. Seizure of movables in the possession of the obligor shall be carried out by the execution officer's taking possession of the movables.
2. When carrying out such a seizure, the execution officer may enter the obligor's dwelling or any other place in the possession of the obligor, and may search the premises, or safes or any other receptacles in the possession of the obligor in order to locate the movable. In such cases, the execution officer may take dispositions necessary to open closed doors, or safes or any other receptacles, if necessary.
3. The execution officer, if he deems reasonable, may have the obligor retain possession of the seized movables (hereinafter referred to as "seized things"). In such cases, the seizure shall be effective only when an indication of seizure is given by either affixing a seal to the seized things or by some other method.
4. Where the execution officer has the obligor retain possession of the seized movables in accordance with the provisions of the preceding paragraph, the execution officer, if he deems it reasonable, may permit the obligor to continue using them.
5. The execution officer, if he deems it necessary, may take possession of the seized things which he originally permitted the obligor to keep in accordance with the provisions of paragraph 3, or may annul the permission mentioned in the proceeding paragraph.

**មាត្រា ៣៨៦.-** ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយបុគ្គលផ្សេងក្រៅពីកូនបំណុលនៃការអនុវត្ត

បញ្ញត្តិនៃកថាខណ្ឌទី ១ ទី ៣ ទី ៤ ទី ៥ និង ទី ៦ នៃមាត្រា ៣៨៥ (ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយម្ចាស់បំណុលនៃការអនុវត្ត ឬ ចលនវត្ថុដែលកាន់កាប់ដោយតតិយជន ក្នុងករណីដែលតតិយជននោះមិនបដិសេធ

អំពីការប្រគល់ ។

(កំណត់)

សូមមើលមាត្រា 124 នៃច្បាប់ស្តីពីការអនុវត្តផ្ទែករដ្ឋប្បវេណីជប៉ុន ។

មាត្រានេះចែងអំពីករណីដែលអ្នកកាន់កាប់ចលនវត្ថុដែលត្រូវរឹបអូសរបស់កូនបំណុលនៃការអនុវត្តនោះ ជាបុគ្គលក្រៅពីកូនបំណុលនៃការអនុវត្ត ។ ជាបឋមបើសិនជាម្ចាស់បំណុលនៃការអនុវត្ត បានកាន់កាប់ដោយផ្ទាល់នូវចលនវត្ថុរបស់កូនបំណុលនៃការអនុវត្ត ម្ចាស់បំណុលនោះអាចប្រគល់វត្ថុនោះ ដោយស្ម័គ្រចិត្ត ដើម្បីឱ្យរឹបអូសបាន ។ បន្ទាប់មក ក្នុងករណីដែលតតិយជនជាអ្នកកាន់កាប់ចលនវត្ថុរបស់កូនបំណុលនៃការអនុវត្តនោះ គេមិនអាចរឹបអូសដោយបង្ខំ នូវចលនវត្ថុដែលកាន់កាប់ដោយតតិយជននោះ ដោយប្រើលិខិតអនុវត្តដែលកូនបំណុលនៃការអនុវត្តជាអ្នកទទួលនោះបានទេ ហេតុនេះហើយ ដើម្បីអាចរឹបអូសចលនវត្ថុនោះបាន ទាល់តែអ្នក (តតិយជន) ដែលកាន់កាប់វត្ថុនោះមិនបដិសេធ ទើបអាចធ្វើបាន ។ ករណីណាក៏ដោយ ក៏មិនត្រូវទទួលស្គាល់ការប្រើអំណាចបង្ខំដោយអាជ្ញាសាលាទេ ដូច្នេះហើយបានជាមិនយកមកអនុវត្តដូចគ្នាតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៨៥ (ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត) ស្តីពីការចូល ការឆែកឆេរ ជាដើម ដោយអំណាចចំពោះករណីទាំងនេះទេ ។ ប្រសិនបើតតិយជននោះមិនយល់ព្រមប្រគល់ចលនវត្ថុនោះដើម្បីរឹបអូសទេ គឺមានតែយកសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុដែលកូនបំណុលនោះមាន មកប្រើក្នុងនីតិវិធីអនុវត្តសិទ្ធិលើបំណុល ដើម្បីរឹបអូសយកវត្ថុនោះ ។ ក្រៅពីចំណុចនេះ នីតិវិធីផ្សេងៗទៀត ត្រូវធ្វើដូចគ្នានឹងនីតិវិធីរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្តដែរ ។

Civil Execution Act (Japan)
**Article 124** (Seizure of movables possessed by a person other than the obligor)
The provisions of the preceding Article, paragraphs 1 and 3to 5 inclusive shall apply mutatis mutandis to the seizure of movables possessed by the obligee or by a third person who agrees to surrender them.

**មាត្រា ៣៨៧.-** បទប្បញ្ញត្តិពិសេសស្តីពីរថយន្ត ជាអាទិ៍ ដែលបានចុះបញ្ជី

១- ប្រសិនបើរថយន្ត ឬ ទោចក្រយានយន្តដែលត្រូវបានរឹបអូស មានចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជី អាជ្ញាសាលាត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចសរសេរនូវហេតុការណ៍នៃការរឹបអូស ចូលទៅក្នុងសៀវភៅចុះបញ្ជីនោះ ។

២- ការរឹបអូសចំពោះរថយន្ត ឬ ទោចក្រយានយន្តដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ នឹងត្រូវមានអានុភាព នៅពេលដែលបានសរសេរនូវហេតុការណ៍នៃការរឹបអូសនោះ ចូលទៅក្នុងសៀវភៅចុះបញ្ជី ។

៣- បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះចលនវត្ថុ ក្រៅពីរថយន្ត ឬ ទោចក្រយានយន្តដែលចាំបាច់ត្រូវចុះបញ្ជី ។

(កំណត់)

ការអនុវត្តដោយបង្ខំចំពោះរថយន្ត ឬ ទោចក្រយានយន្តត្រូវធ្វើទៅតាមវិធីអនុវត្តចំពោះចលនវត្ថុ ។ នៅក្នុងករណីដែលមានពាក្យសុំដែលកំណត់តែកន្លែង ពុំមានកំណត់កម្មវត្ថុនៃការអនុវត្តទេ (សូមមើលកំណត់នៅកថាខណ្ឌទី ២ នៃមាត្រា ៣៨៤ (ការចាប់ផ្ដើមអនុវត្តចំពោះចលនវត្ថុ)) អាជ្ញាសាលាអាចរឹបអូសយករថយន្តដែលនៅទីនោះបាន ហើយក៏អាចកំណត់រថយន្តដែលជាកម្មវត្ថុនៃការអនុវត្តនោះ នៅពេលដាក់ពាក្យសុំបានផងដែរ ។

នៅក្នុង ២ ចំណុចខាងក្រោម មាត្រានេះ ជាបទប្បញ្ញត្តិពិសេសចំពោះការអនុវត្តទៅលើចលនវត្ថុទូទៅ ។ ចំណុចទី ១ ដោយហេតុថាទំនាក់ទំនងនៃសិទ្ធិលើរថយន្ត មានចុះនៅក្នុងបញ្ជី នៅពេលដែលត្រូវបានរឹបអូស អាជ្ញាសាលាចាំបាច់ត្រូវផ្ទុកផ្ដាក់ទៅស្ថាប័នដែលបំពេញកិច្ចការចុះបញ្ជីនោះ ឱ្យសរសេរនូវហេតុការណ៍នៃការរឹបអូស ចូលទៅក្នុងសៀវភៅចុះបញ្ជីនោះ ។ ចំណុចទី ២ ចំពោះរថយន្តជាដើមដែលជាកម្មវត្ថុនៃការរឹបអូសនេះ នៅក្នុងករណីដែលមានចុះបញ្ជីអានុភាពនៃការរឹបអូសនឹងកើតមានឡើង នៅពេលដែលបានសរសេរចុះនូវហេតុការណ៍នៃការរឹបអូសនោះចូលទៅក្នុងសៀវភៅចុះបញ្ជី ។ ចំពោះចលនវត្ថុក្រៅពីរថយន្ត ឬ ទោចក្រយានយន្តដែលចាំបាច់ត្រូវចុះបញ្ជី (តាមច្បាប់បណ្ដាប្រទេសនានា មានឧទាហរណ៍ដូចជា ម៉ាស៊ីនសម្រាប់សាងសង់) ក៏ត្រូវចាត់ទុកដូចរថយន្ត ឬ ទោចក្រយានយន្តដែរ ។

**មាត្រា ៣៨៨.-** ការរួមបញ្ចូលរឿងក្តី

១- ក្នុងករណីដែលមានពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុបន្ថែមទៀត ទៅលើកូនបំណុលនៃការអនុវត្តដែលបានទទួលការរឹបអូសរួចមកហើយ នៅទីកន្លែងនៃការរឹបអូសដដែលនោះ បើមានចលនវត្ថុដែលមិនទាន់បានរឹបអូសនៅឡើយ អាជ្ញាសាលាត្រូវរឹបអូសចលនវត្ថុនោះ ហើយប្រសិនបើគ្មានចលនវត្ថុដែលអាចរឹបអូសបានទេនោះ អាជ្ញាសាលាត្រូវបញ្ជាក់ច្បាស់លាស់អំពីហេតុការណ៍នេះ ហើយត្រូវរួមបញ្ចូលរឿងក្តីអនុវត្តចំពោះចលនវត្ថុថ្មីនេះ និង រឿងក្តីអនុវត្តចំពោះចលនវត្ថុមុនជាមួយគ្នា ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុ ទៅលើកូនបំណុលនៃការអនុវត្តដែលបានទទួលការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន នៅទីកន្លែងនៃការអនុវត្តដដែលនោះ ។(1)

២- បើរឿងក្តីអនុវត្តចំពោះចលនវត្ថុទាំងពីរ ត្រូវបានរួមបញ្ចូលគ្នា តាមបញ្ញត្តិនៃវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ ចលនវត្ថុដែលត្រូវបានរឹបអូសក្នុងរឿងក្តីពេលក្រោយនេះ ត្រូវចាត់ទុកថា បានរឹបអូសក្នុងរឿងក្តីពីមុននៅពេលរួមបញ្ចូលរឿងក្តី ហើយពាក្យសុំនៃរឿងក្តីដែលធ្វើពេលក្រោយនេះ មានអានុភាពជាការទាមទារឱ្យចែកចំណែក ។ បើម្ចាស់បំណុលនៃការអនុវត្តមុន បានដកពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុ ឬ នីតិវិធីដែលបានចាប់ផ្ដើម ដោយពាក្យសុំនោះ ត្រូវបានផ្អាក ឬ ត្រូវបានលុបចោល ចលនវត្ថុដែលត្រូវបានរឹបអូសក្នុងរឿងក្តីមុននេះ ត្រូវចាត់ទុកថាបានរឹបអូសដើម្បីរឿងក្តីនៅពេលក្រោយ នៅពេលរួមបញ្ចូលរឿងក្តី ។

៣- បើរឿងក្ដីនៃការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន និង រឿងក្ដីនៃការអនុវត្តចំពោះចលនវត្ថុ ត្រូវបានរួមបញ្ចូលគ្នា តាមបញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ខាងលើនេះ ចលនវត្ថុដែលត្រូវបានអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ត្រូវចាត់ទុកថា បានរឹបអូសក្នុងរឿងក្ដីនៃការអនុវត្តចំពោះចលនវត្ថុ នៅពេលរួមបញ្ចូលរឿងក្ដី ហើយពាក្យសុំនៃរឿងក្ដីនៃការអនុវត្តរឹបអូសជាបណ្ដោះអាសន្ននេះ មានអានុភាពជាការទាមទារឱ្យចែកចំណែក ។ បើម្ចាស់បំណុលនៃការអនុវត្តបានដកពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុ ឬ នីតិវិធីដែលបានចាប់ផ្ដើម ដោយពាក្យសុំនោះ ត្រូវបានលុបចោល ចលនវត្ថុដែលត្រូវបានរឹបអូសក្នុងរឿងក្ដីនៃការអនុវត្តចំពោះចលនវត្ថុនេះ ត្រូវចាត់ទុកថា បានអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ក្នុងរឿងក្ដីនៃការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន នៅពេលរួមបញ្ចូលរឿងក្ដី ។

៤- នៅពេលដែលបានរួមបញ្ចូលរឿងក្ដី អាជ្ញាសាលាត្រូវជូនដំណឹងអំពីហេតុការណ៍នោះទៅម្ចាស់បំណុលនៃការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន និង កូនបំណុលនៃការអនុវត្ត ។(2)

(កំណត់)

សូមមើលមាត្រា 125 នៃច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន និង មាត្រា 106 បទប្បញ្ញត្តិស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

(1) នេះគឺជាការចែងដើម្បីចាត់ចែងករណីដែលមានពាក្យសុំការរឹបអូសចលនវត្ថុត្រួតគ្នា ។ ពេលណាមានពាក្យសុំទាមទារការរឹបអូសចលនវត្ថុត្រួតគ្នា អាជ្ញាសាលាត្រូវរឹបអូសនូវចលនវត្ថុណាដែលមិនទាន់បានរឹបអូសក្នុងករណីរឹបអូសមុន ហើយប្រសិនបើអត់មានទេ ត្រូវបញ្ជាក់ឱ្យច្បាស់លាស់ ហើយត្រូវបញ្ចូល ករណីរឹបអូសចលនវត្ថុនោះ និង ករណីរឹបអូសចលនវត្ថុមុន ជាករណីមួយ ។ រីឯប្រសិទ្ធិភាពនៃការបញ្ចូលករណីជាមួយនោះ មានចែងក្នុងកថាខណ្ឌទី ២ និង កថាខណ្ឌទី ៣ ។

(2) សូមមើល បទប្បញ្ញត្តិស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 106 ។

Civil Execution Act (Japan)

**Article 125** (Prohibition of double seizure; joinder of cases)

1. The execution officer may not seize any things already seized or any movables against which provisional attachment has already been executed.
2. Where a new motion for execution against movables is made with regard to an obligor against whom a seizure has already been carried out in the place of the seizure, and if there are movables remaining which have not yet been seized, the execution officer shall take possession thereof; and if there are no movables to be seized, the execution officer shall give indication thereof and shall consolidate the latter case of execution against movables with the former case of execution against movables. The same shall apply to the cases where a new motion for execution against movables is made with regard to an obligor against whom a provisional attachment has been already executed in the place of the execution.
3. Where two cases of execution concerning movables have been consolidated as mentioned in the first sentence of the preceding paragraph, the movables seized in the latter case shall be deemed to be seized at the time of the consolidation and the motion of the latter case shall have the effect of a demand for distribution. Where the former attachment obligee has withdrawn a motion for executionagainst movables or the procedure concerning the motion has been stayed or annulled, the movables seized in the former case shall be deemed, in the latter case, to have been seized at the time of the consolidation.
4. Where a case of execution of provisional attachment and a case of execution against movables have been consolidated as referred to in the second sentence of paragraph 2, the movables against which the provisional attachment has been executed shall be deemed to have been seized in the case of execution against movables at the time of the consolidation and a motion for the case of execution of provisional attachment shall have the effect of a demand for distribution. In cases where the attachment obligee has withdrawn a

motion for execution against movables or the procedure concerning the motion has been annulled, the movables seized in the case of execution against movables shall be deemed to have been provisionally attached in the case of execution of provisional attachment at the time of the consolidation.

**មាត្រា ៣៨៩.-** ទំហំដែលការរឹបអូសមានអានុភាព

ការរឹបអូសមានអានុភាពទៅលើផលធម្មជាតិដែលកើតចេញមកពីចលនវត្ថុដែលត្រូវបានរឹបអូស ។

(កំណត់)

សូមមើលមាត្រា 126 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

អានុភាពនៃការរឹបអូសមានទៅលើផលធម្មជាតិដែលបានមកពីចលនវត្ថុរឹបអូសនោះដែរ ទោះបីជាមិនបានធ្វើនីតិវិធីពិសេសក៏ដោយ ។ ដោយសារតែអាជ្ញាសាលាជាអ្នកគ្រប់គ្រងនូវចលនវត្ថុដែលរឹបអូសបាននោះ ហេតុនេះហើយបានជាមិនត្រូវការនីតិវិធីពិសេសថែមទៀត ដើម្បីរឹបអូសផលនោះទេ ។ ឧទាហរណ៍ ក្នុងករណីដែលបានរឹបអូសសត្វពាហនៈ គឺកូនសត្វនោះ ក្នុងករណីដែលបានរឹបអូសមាន់វិញ គឺពងមាន់នោះជាដើម ហើយដែលជាផលធម្មជាតិដែលកើតចេញមកពីចលនវត្ថុនោះ ។

Civil Execution Act (Japan)
**Article 126** (Items covered by seizure)
Seizure shall include natural products of the seized things.

**មាត្រា ៣៩០.-** ដីកាសម្រេចបង្គាប់ឱ្យប្រគល់ចលនវត្ថុដែលត្រូវបានរឹបអូស

១- បើចលនវត្ថុត្រូវបានរឹបអូសរួចហើយ ហើយបែរជាធ្លាក់ទៅនៅក្រោមការកាន់កាប់របស់តតិយជន សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ អាចបង្គាប់ឱ្យតតិយជននោះប្រគល់ចលនវត្ថុដែលត្រូវបានរឹបអូសនោះទៅអាជ្ញាសាលាបាន ដោយដីកាសម្រេច តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ។

២- ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ គិតពីថ្ងៃដែលបានដឹងថា ចលនវត្ថុដែលត្រូវបានរឹបអូសនោះកាន់កាប់ដោយតតិយជន ។

៣- ចំពោះដីកាសម្រេចអំពីពាក្យសុំនៃកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៤- ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំត្រូវអនុវត្តឡើយ បើហួសអំឡុងពេល ២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានជូនដំណឹងទៅឱ្យអ្នកដាក់ពាក្យសុំ ។

៥- ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អាចអនុវត្តបាន ទោះនៅមុនពេលបញ្ជូនដីកាសម្រេចនោះទៅឱ្យតតិយជនដែលកាន់កាប់ចលនវត្ថុដែលត្រូវបានរឹបអូសក៏ដោយ ។

៦- សោហ៊ុយដែលចាំបាច់សម្រាប់ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ជាសោហ៊ុយសម្រាប់ផលប្រយោជន៍រួម ចំពោះនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុនេះ ។

(កំណត់)

សូមមើលមាត្រា 127 នៃច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

អាជ្ញាសាលាអាចប្រគល់ចលនវត្ថុដែលរឹបអូសបាននោះ ឱ្យកូនបំណុលនៃការអនុវត្តនោះរក្សាទុកបាន (មាត្រា ៣៨៥ (ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត) កថាខណ្ឌទី ៤) ក្នុងករណីរឹបអូសចលនវត្ថុរបស់កូនបំណុលនៃការអនុវត្ត ដែលកាន់កាប់ដោយតតិយជនក៏ដោយ ក៏អាចឱ្យតតិយជននោះរក្សាចលនវត្ថុដែលបានរឹបអូសនោះបន្តទៅទៀតបាន (មាត្រា ៣៨៦ (ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយបុគ្គលផ្សេងក្រៅពីកូនបំណុលនៃការអនុវត្ត)) ហេតុនេះហើយបានជាមានបញ្ហាដែលអាចកើតមានឡើងដូចជា កូនបំណុលនៃការអនុវត្ត ឬ តតិយជនដែលបានរក្សាទុកនូវចលនវត្ថុនោះ អាចចាត់ចែងលក់ ឬ ផ្ទេរឱ្យអ្នកផ្សេងទៀតកាន់កាប់ដោយចិត្តឯងបាន ។ ដើម្បីការពារបញ្ហាដែលអាចកើតមានឡើងនេះ មាត្រានេះបានចែងដើម្បីសម្រួលនូវការយកចលនវត្ថុដែលបានរឹបអូសនោះមកវិញបានស្រួល ។ ការបង្គាប់ឱ្យប្រគល់មកវិញនៃមាត្រានេះ គឺជារបបមួយដើម្បីធ្វើបដិទានវិញ ដោយងាយស្រួល និងឱ្យបានឆាប់រហ័ស ហើយទោះបីជាតតិយជននោះបានអះអាងនូវសិទ្ធិកាន់កាប់របស់ខ្លួនក៏ដោយ ក៏សាលាដំបូងអាចចេញបង្គាប់នេះបានដែរ ។ ចំពោះករណីដែលតតិយជននោះមានសិទ្ធិអំណាចកាន់កាប់ ជននោះអាចធ្វើបណ្ដឹងតវ៉ារបស់តតិយជនបាន ។

ពាក្យសុំឱ្យតុលាការបង្គាប់ឱ្យតតិយជនប្រគល់ចលនវត្ថុដែលត្រូវបានរឹបអូស ត្រូវធ្វើក្នុងអំឡុងពេល ១ សប្ដាហ៍ គិតពីថ្ងៃដែលបានដឹងថា ចលនវត្ថុដែលត្រូវបានរឹបអូសនោះកាន់កាប់ដោយតតិយជន តែបើហួសអំឡុងពេលនេះ មិនអាចធ្វើបានឡើយ ដោយហេតុថា បើទុកអំឡុងពេលនេះលើសពី ១ សប្ដាហ៍ នោះធ្វើឱ្យប៉ះពាល់ដល់ស្ថិរភាពនៃទំនាក់ទំនងគតិយុត្ត (ឧ. អាចមានករណីនៃលទ្ធកម្មកម្មសិទ្ធិដោយសុចរិត) ។

<u>Civil Execution Act (Japan)</u>
**Article 127** (Order to deliver the seized things)
1. When the seized things are in the possession of a third person, the execution court, may, upon motion of the attachment obligee, order the third person to deliver the seized things to the execution officer.
2. A motion referred to in the preceding paragraph shall be made within one week of the day when it becomes known that the seized things are in the possession of the third person.
3. A kōkoku-appeal may be filed against a decision on the motion referred to in paragraph 1.
4. The provisions of Article 55, paragraph 6 to 8 inclusive shall apply mutatis mutandis to a ruling in accordance with the provisions of paragraph 1.

**មាត្រា ៣៩១.-** ការហាមឃាត់មិនឱ្យរឹបអូសហួសប្រមាណ

១- ការរឹបអូសចលនវត្ថុ មិនត្រូវធ្វើឱ្យហួសកម្រិតចាំបាច់សម្រាប់សំណងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និង សោហ៊ុយសម្រាប់ការអនុវត្តទេ ។

២- ប្រសិនបើបានដឹងច្បាស់ថាការរឹបអូស លើសពីកម្រិតដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ នៅក្រោយ

ពេលដែលបានរឹបអូសរួចហើយ អាជ្ញាសាលាត្រូវលុបចោលការរឹបអូស ត្រឹមផ្នែកដែលបានហួសកម្រិតនោះ ។

( កំណត់ )

សូមមើលមាត្រា 128 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

Civil Execution Act (Japan)
**Article 128** (Prohibition against excessive seizure)
1. Seizure of movables may not exceed the amount necessary forsatisfaction of the obligation-right of the attachment obligee and the costs of execution.
2. If it appears after the seizure is carried out that the seizure exceeds the amount referred to in the preceding paragraph, the execution officer shall annul the seizure to the proper amount.

**មាត្រា ៣៩២.-** ការហាមឃាត់មិនឱ្យរឹបអូសក្នុងករណីដែលប៉ាន់ប្រមាណឃើញថា គ្មានចំនួនសេសសល់

១- អាជ្ញាសាលាមិនត្រូវរឹបអូសឡើយ ប្រសិនបើប៉ាន់ប្រមាណឃើញថា ចំនួនទឹកប្រាក់ដែលបានមកពីការលក់ចលនវត្ថុដែលត្រូវបានរឹបអូសនោះ គ្មានចំនួនសេសសល់ ក្រោយពីបានសងសោហ៊ុយសម្រាប់នីតិវិធីហើយ ។

២- អាជ្ញាសាលាត្រូវលុបចោលការរឹបអូស ប្រសិនបើប៉ាន់ប្រមាណឃើញថា ចំនួនទឹកប្រាក់ដែលបានមកពីការលក់ចលនវត្ថុ ដែលត្រូវបានរឹបអូសនោះ គ្មានចំនួនសេសសល់ ក្រោយពីបានសងសិទ្ធិលើបំណុលដែលមានអាទិភាពជាងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និង សោហ៊ុយសម្រាប់នីតិវិធីហើយ ។

( កំណត់ )

សូមមើលមាត្រា 129 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន និង មាត្រា ៥១ នៃច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណីកម្ពុជា ។

Civil Execution Act (Japan)
**Article 129** (Prohibition against seizure when surplus over costs is unlikely)
1. If a surplus is unlikely to exist after the procedure costs are satisfied through the proceeds of the movables to be seized, the execution officer may not carry out the seizure.
2. If a surplus is unlikely to exist after the obligation-rights which have priority over the obligation-right of the attachment obligee and the procedure costs are satified throug the proceeds of seized things, the execution officer shall annul the seizure.

**មាត្រា ៣៩៣.-** ការលុបចោលនូវការរឹបអូស ក្នុងករណីដែលប៉ាន់ប្រមាណឃើញថា មិនអាចលក់បាន

អាជ្ញាសាលាអាចលុបចោលការរឹបអូសចលនវត្ថុដែលត្រូវបានរឹបអូសហើយនោះបាន ក្នុងល័ក្ខខ័ណ្ឌដែលបានអនុវត្តការលក់តាមវិធីសមរម្យក៏ដោយ ក៏នៅតែមិនអាចលក់បាន ហើយប៉ាន់ប្រមាណឃើញថា នៅតែមិនអាចលក់បាន នៅពេលអនាគត ។

（កំណត់）

សូមមើលមាត្រា 130 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

Civil Execution Act (Japan)
**Article 130** (Annulment of seizure of things which are unlikely to be sold)
Where the seized things are unlikely to be sold even if the sale were effected in a reasonable manner, the execution officer may annul the seizure.

**មាត្រា ៣៩៤.-** ការទាមទារឱ្យចែកចំណែកពីអ្នកមានឯកសិទ្ធិ ជាអាទិ៍

បុគ្គលដែលមានឯកសិទ្ធិ ឬ មានសិទ្ធិលើការបញ្ចាំ អាចទាមទារឱ្យចែកចំណែកបាន ដោយដាក់ឯកសារដែលបញ្ជាក់អំពីសិទ្ធិនោះ ។

（កំណត់）

សូមមើលមាត្រា 133 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

ក្នុងករណីដែលបានធ្វើការរឹបអូសចលនវត្ថុ អ្នកដែលមានឯកសិទ្ធិ ឬ មានសិទ្ធិលើការបញ្ចាំ អាចទាមទារនូវចំណែករបស់ខ្លួនបាន ក៏ប៉ុន្តែ អ្នកក្រៅពីនេះ មិនអាចទាមទារនូវចំណែករបស់ខ្លួនបានឡើយ ។ ជាគោលការណ៍ច្បាប់ហាមមិនឱ្យធ្វើការរឹបអូសលើស（មាត្រា ៣៩១（ការហាមឃាត់មិនឱ្យរឹបអូសហួសប្រមាណ））គឺការរឹបអូសនេះអាចធ្វើត្រឹមតែទំហំដែលជម្រះចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលតែប៉ុណ្ណោះទេ ហេតុនេះហើយបើទទួលស្គាល់ការទាមទារចំណែកពីម្ចាស់បំណុលធម្មតាផ្សេងទៀត នឹងធ្វើឱ្យម្ចាស់បំណុលដែលបានរឹបអូសនេះមិនអាចទទួលបាននូវសំណងដោយវត្ថុដែលខ្លួនខំទាមទារឱ្យរឹបអូសនោះ ឱ្យស្របនឹងសិទ្ធិលើបំណុលនោះទៅវិញ ។ ហេតុនេះហើយបានជាមិនទទួលស្គាល់ការទាមទារចំណែកធម្មតាទេ លើកលែងតែក្នុងករណីដែលម្ចាស់បំណុលផ្សេងទៀតបានទាមទារឱ្យរឹបអូសត្រួតគ្នាដោយខ្លួនឯង ពេលនោះនឹងទទួលស្គាល់អានុភាពនៃការទាមទារចំណែក បន្ទាប់ពីបានបញ្ចូលករណីទាំងអស់ឱ្យទៅជាមួយ（មាត្រា ៣៨៨（ការរួមបញ្ចូលរឿងក្តី））។ ក៏ប៉ុន្តែ ក្នុងចំណោមម្ចាស់បំណុលទាំងអស់ មានម្ចាស់បំណុលខ្លះមានឯកសិទ្ធិ និង ខ្លះមានសិទ្ធិលើការបញ្ចាំ ចំពោះម្ចាស់បំណុលទាំងនេះ បើមិនទទួលស្គាល់ការទាមទារចំណែករបស់ខ្លួនទេនោះ អ្នកទាំងនេះនឹងមិនអាចប្រើសិទ្ធិដែលខ្លួនមាននោះទៅវិញ ហេតុនេះហើយបានជាមាត្រានេះទទួលស្គាល់ការទាមទារចំណែកពិសេសពីអ្នកទាំងនេះ ។

Civil Execution Act (Japan)
**Article 133** (Demand for distribution by a person who has a preferential right)
A person who has a preferential right or a right of pledge may make a demand for distribution by submitting a document which attests to such right.

**មាត្រា ៣៩៥.-** វិធីលក់

១- ដើម្បីលក់ចលនវត្ថុដែលត្រូវបានរឹបអូស អាជ្ញាសាលាត្រូវលក់តាមវិធីលក់ឡាយឡុង ដោយផ្ទាល់មាត់ ឬ ដោយដាក់ស្រោមសំបុត្រ ។(1)

២- ទោះបីមានបញ្ញត្តិដូចកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បើយល់ឃើញថាសមរម្យ ដោយគិតពិចារណាអំពីប្រភេទ និង ចំនួននៃចលនវត្ថុ ជាអាទិ៍ អាជ្ញាសាលាអាចអនុវត្តការលក់ចលនវត្ថុដែលត្រូវបានរឹបអូសនោះ ក្រៅពីរបៀបលក់តាមវិធីលក់ឡាយឡុងដោយផ្ទាល់មាត់ ឬ ដោយដាក់ស្រោមសំបុត្រ ឬ អាចឱ្យបុគ្គលផ្សេងពីអាជ្ញាសាលា អនុវត្តការលក់ចលនវត្ថុដែលត្រូវបានរឹបអូសនោះបាន ដោយទទួលការអនុញ្ញាតពីសាលាដំបូងដែលខ្លួនស្ថិតនៅ ។

៣- អាជ្ញាសាលាត្រូវជូនដំណឹងជាសាធារណៈអំពីចលនវត្ថុដែលត្រូវដាក់លក់ និង វិធីលក់ចលនវត្ថុនោះ ដោយបិទប្រកាសនៅកន្លែងសម្រាប់បិទប្រកាសរបស់តុលាការ ។

៤- កូនបំណុលនៃការអនុវត្ត មិនអាចធ្វើសំណើទិញចលនវត្ថុនោះបានឡើយ ។(2)

៥- ប្រសិនបើអាជ្ញាសាលាអនុញ្ញាតឱ្យទិញ អ្នកទិញត្រូវបង់ថ្លៃភ្លាមៗ ។

៦- ប្រសិនបើចលនវត្ថុនោះត្រូវបានដាក់លក់ម្តងទៀត ដោយសារអ្នកទិញមិនបានបង់ថ្លៃ អ្នកសុំទិញមុននេះ មិនអាចធ្វើសំណើទិញម្តងទៀតបានឡើយ ។

៧- បើបានរឹបអូសចលនវត្ថុដែលមានតម្លៃខ្ពស់ អាជ្ញាសាលាត្រូវជ្រើសតាំងអ្នកវាយតម្លៃ ហើយឱ្យអ្នកវាយតម្លៃនោះវាយតម្លៃចលនវត្ថុនោះ ។

(កំណត់)

សូមមើលមាត្រា 134 មាត្រា 135 និង មាត្រា 68 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន និង កថាខណ្ឌទី ១ នៃមាត្រា 121 កថាខណ្ឌទី ១ នៃមាត្រា 122 និង មាត្រា 125 នៃបទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

(1) ក្នុងចំណោមវិធីលក់ចលនវត្ថុ ការលក់ឡាយឡុងដោយផ្ទាល់មាត់គឺជាវិធីមួយដែលសមរម្យ ងាយស្រួលក្នុងការអនុវត្ត ។ ក៏ប៉ុន្តែ មានករណីដែលគួរធ្វើការលក់ឡាយឡុងដោយស្រោមសំបុត្រ ដូចជាគ្រឿងម៉ាស៊ីនជាដើម ដែលជាចលនវត្ថុមានតម្លៃខ្ពស់ ហើយអាចកំណត់តម្លៃអប្បបរមា តាមការវាយតម្លៃរបស់អ្នកវាយតម្លៃ ។

(2) ចំពោះកូនបំណុលនៃការអនុវត្តដែលមិនបានសងបំណុល រហូតដល់ត្រូវគេរឹបអូស ហើយចាប់ផ្តើមដាក់ចលនវត្ថុដែលរឹបអូសបាននោះលក់ឡាយឡុង ប្រសិនបើកូនបំណុលនោះមានលុយ ដើម្បីយកទៅដេញថ្លៃ កូនបំណុលនោះត្រូវយកលុយនោះសងបំណុលសិន ។ នេះជាគោលគំនិតនៃកថាខណ្ឌទី ៤ នៃមាត្រានេះ ។

Civil Execution Act (Japan)
**Article 134** (Method of sale)
The execution officer shall effect a sale of the seized things by tender or auction or by a method provided by the Rules of the Supreme Court.
**Article 135** (Mutatis mutandis application of provisions concerning maintenance of order in place of sale)
The provisions of Article 65 and 68 shall apply mutatis mutandis to cases where the sale of seized things is effected.
**Article 68** (Prohibition of obligor's offer to buy)
An obligor may not make an offer to buy the immovable.

**មាត្រា ៣៩៦.-** ការរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់

ចំពោះជនណាដែលធ្វើសកម្មភាពរំខានកុំឱ្យការអនុវត្តការលក់ធ្វើឡើងដោយត្រឹមត្រូវ ដូចជាបានធ្វើឱ្យរំខានដល់ជនដទៃទៀតក្នុងការធ្វើសំណើទិញ ឬ បានឃុបឃិតដើម្បីបញ្ចុះតម្លៃលក់ដោយមិនត្រឹមត្រូវ ឬ ចំពោះជនដែលបានប្រើឱ្យធ្វើសកម្មភាពនោះ អាជ្ញាសាលាអាចកម្រិតមិនឱ្យជននោះចូលកន្លែងលក់ ឬ អាចដេញជននោះចេញពីកន្លែងលក់ ឬ អាចមិនឱ្យស្នើសុំទិញបាន ។

(កំណត់)

សូមមើលមាត្រា 135 និង មាត្រា 65 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

Civil Execution Act (Japan)
**Article 135** (Mutatis mutandis application of provisions concerning maintenance of order in place of sale)
The provisions of Article 65 and 68 shall apply *mutatis mutandis* to cases where the sale of seized things is effected.
**Article 65** (Maintenance of order in place of sale)
The execution officer may prevent the following persons from entering the place of the sale, cause such persons to leave the premises or restrain such persons from offering to buy:

i. any person who has prevented any other person from offering to by or has committed an act which hinders the sale from being fairly effected, such as conspiring for the purpose of reducing the price unreasonably, or any person who has induced another persons to commit such an act;
ii. ny person who has been found guilty of any such acts in a ruling concerning refusal to sell in any other procedure of civil execution and with respect to whom two years have not lapsed since such ruling on refusal to sell became final and binding;
iii. ny person who has been sentenced with regard to a civil execution sale in accordance with the provisions of Articles 95 to 96-3 inclusive, 197 to 197-4 inclusive or 198 of the Criminal Code (Law No. 45, 1907) and with respect to whom two years have not lapsed since such decision became final and binding.

**មាត្រា ៣៩៧.-** ការលក់នៅក្នុងពេលដែលការអនុវត្តកំពុងត្រូវបានផ្អាក

១- ក្នុងករណីដែលមានការដាក់ឯកសារដែលបានកំណត់នៅក្នុងចំណុច **ក** ឬ ចំណុច **ខ** កថាខណ្ឌទី ២ នៃមាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ប្រសិនបើមានការបារម្ភថា តម្លៃលក់ចលនវត្ថុដែលត្រូវបានរឹបអូស នឹងចុះថោកខ្លាំង ឬ បើត្រូវចំណាយសោហ៊ុយច្រើនមិនសមរម្យសម្រាប់រក្សាទុកនូវចលនវត្ថុនោះ អាជ្ញាសាលាអាចដាក់ចលនវត្ថុដែលត្រូវបានរឹបអូសនោះលក់បាន ។

២- បើបានលក់ចលនវត្ថុដែលត្រូវបានរឹបអូស តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អាជ្ញាសាលាត្រូវធ្វើទុកប្រាក់ដែលបានមកពីការលក់នោះនៅសាលាដំបូងដែលខ្លួនស្ថិតនៅ ។

(កំណត់)

សូមមើលមាត្រា 137 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។ កថាខណ្ឌទី ១ នៃមាត្រានេះ មានគោលបំណងការពារតម្លៃនៃចលនវត្ថុដែលត្រូវបានរឹបអូស ហើយជាវត្ថុងាយខូចគុណភាពបណ្តាលឱ្យបាត់បង់តម្លៃ ។

Civil Execution Act (Japan)
**Article 137** (Sale during stay of execution)
1. In cases where a document referred to in Article 39, paragraph 1, item vii or viii has been submitted, and the value of the seized things is likely to diminish significantly, or if disproportionate expenses are necessary for custody thereof, the execution officer may sell the seized things.
2. In cases where the seized things have been sold in accordance with the provisions of the preceding paragraph, the execution officer shall deposit the proceeds.

**មាត្រា ៣៩៨.-** វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែកជាប្រាក់

ម្ចាស់បំណុលដែលត្រូវទទួលចំណែក គឺបុគ្គលដែលបានកំណត់ក្នុងចំណុចនីមួយៗខាងក្រោមនេះ :

**ក-** ម្ចាស់បំណុលនៃការអនុវត្ត ។

**ខ-** ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក រហូតដល់ពេលដែលអាជ្ញាសាលាបានទទួលការប្រគល់ប្រាក់ចំពោះប្រាក់ដែលបានមកពីការលក់ ។

**គ-** ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក រហូតដល់ពេលដែលបានរឹបអូសប្រាក់ ចំពោះប្រាក់ដែលត្រូវបានរឹបអូស ។

(កំណត់)

សូមមើលមាត្រា 140 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

Civil Execution Act (Japan)
**Article 140** (Coverage of persons entitled to distribution and the like)
In addition to the attachment obligee, obligees entitiled to distribution and the like shall be obligees who have made a demand for distribution, with regard to proceeds, before the execution officer receives the proceeds (with regard to the proceeds deposited in accordance with the provisions of Article 137 or Article 177, paragraph 3, before the execution against movables in continued); with regard to seized money, before the money is seized; and with regard to money paid for a bill and the like, before the money is paid.

**មាត្រា ៣៩៩.-** ការចែកចំណែកដោយអាជ្ញាសាលា

១- ក្នុងករណីដែលម្ចាស់បំណុលមានតែម្នាក់ ឬ ក្នុងករណីដែលម្ចាស់បំណុលមានច្រើននាក់ ហើយប្រាក់ដែលបានពីការលក់ ឬ ប្រាក់ដែលត្រូវបានរឹបអូស អាចសងចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បាន អាជ្ញាសាលាត្រូវចែកចំណែក ចំពោះម្ចាស់បំណុល ហើយត្រូវប្រគល់ប្រាក់នៅសេសសល់ទៅឱ្យកូនបំណុលនៃការអនុវត្តវិញ ។(1)

២- ក្រៅពីករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើបានទទួលប្រាក់ដែលបានពីការលក់ ឬ បានរឹបអូសប្រាក់ អាជ្ញាសាលាត្រូវកំណត់ថ្ងៃក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ជាថ្ងៃដែលត្រូវពិភាក្សាគ្នាអំពីការចែកចំណែកនៃប្រាក់ដែលបានមកពីការលក់ ឬ ប្រាក់ដែលត្រូវបានរឹបអូស ហើយត្រូវជូនដំណឹងពីពេលវេលា និង ទីកន្លែង ទៅម្ចាស់បំណុល

នីមួយៗ ។ បើម្ចាស់បំណុលនីមួយៗបានពិភាក្សាគ្នាដាច់ស្រេចហើយ អាជ្ញាសាលាត្រូវចែកចំណែកតាមការពិភាក្សានោះ ។ (2)

៣- ក្នុងករណីដែលមានការដាក់ឯកសារដែលបានកំណត់ចាប់ពីចំណុច **ក** រហូតដល់ចំណុច **ឆ** កថាខណ្ឌទី ១ នៃមាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ក្រោយពេលអ្នកទិញបានបង់ថ្លៃហើយ បើមានម្ចាស់បំណុលដែលត្រូវទទួលចំណែកផ្សេងទៀត ក្រៅពីម្ចាស់បំណុលនៃការអនុវត្ត អាជ្ញាសាលាត្រូវចែកចំណែកឱ្យម្ចាស់បំណុលនោះ ។ (3)

៤- ក្នុងករណីដែលមានការដាក់ឯកសារដែលបានកំណត់នៅក្នុងចំណុច **ក** ឬ ចំណុច **ខ** កថាខណ្ឌទី ២ នៃមាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ក្រោយពេលអ្នកទិញបានបង់ថ្លៃហើយ អាជ្ញាសាលាក៏ត្រូវចែកចំណែកនោះផងដែរ ។ (4)

៥- ចំពោះការចែកចំណែក សិទ្ធិលើបំណុលដែលកំណត់ពេលពិតប្រាកដពុំទាន់មកដល់ ត្រូវចាត់ទុកថា កំណត់ពេលសងនោះបានចូលមកដល់ហើយ ។

(កំណត់)

សូមមើលមាត្រា 139 កថាខណ្ឌទី 3 និង ទី 4 នៃមាត្រា 84 និង មាត្រា 88 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 128 នៃបទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

(1) ទោះបីជាម្ចាស់បំណុលមានតែម្នាក់ក៏ដោយ ឬ មានច្រើននាក់ក៏ដោយ ប្រសិនបើអាចសងបំណុលអ្នកទាំងនោះបានគ្រាន់តែធ្វើការបែងចែកសងបំណុលអ្នកទាំងនោះបានហើយ រីឯលុយដែលនៅសល់ពីការបែងចែក ត្រូវសងទៅកូនបំណុលវិញ ។

(2) ប្រសិនបើម្ចាស់បំណុលមានច្រើននាក់ ហើយមិនអាចសងបំណុលអ្នកទាំងនោះបានគ្រប់ទេ ក៏ប៉ុន្តែក្នុងករណីដែលម្ចាស់បំណុលទាំងអស់បានពិភាក្សាព្រមព្រៀងគ្នា ហើយអត់មានបញ្ហាអ្វីដែលត្រូវវិនិច្ឆ័យទៀតទេ អាជ្ញាសាលាត្រូវធ្វើការចាត់ចែងបែងចែកចំណែក ។ ប្រសិនបើការពិភាក្សាមិនបានលទ្ធផលល្អទេ អាជ្ញាសាលាត្រូវធ្វើកំណត់ហេតុទៅសាលាដំបូងដែលខ្លួនស្ថិតនៅក្រោម ហើយសាលាដំបូងនេះនឹងធ្វើការកំណត់កាលបរិច្ឆេទដើម្បីធ្វើការបែងចែកចំណែក ។

(3) ប្រសិនបើបានទទួលលិខិតលុបចោលនូវការរឹបអូស ដែលមានចែងក្នុងបញ្ញត្តិចាប់ពីចំណុច **ក** ដល់ **ឆ** កថាខណ្ឌទី ១ មាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) ក្រោយពេលអ្នកទិញបានបង់ថ្លៃលក់ហើយ ដែលជាដំណាក់កាលមួយមិនអាចបដិសេធលទ្ធកម្មចលនវត្ថុដោយការបង់ថ្លៃលក់ ហេតុនេះហើយ មិនអាចលុបចោលនូវនីតិវិធីនៃការលក់ដោយបង្ខំបានទេ ។ ក្នុងករណីនេះ មិនអាចបែងចែកចំណែកដល់ម្ចាស់បំណុលដែលមានមូលហេតុត្រូវលុបចោលនូវការអនុវត្តដោយបង្ខំនោះទេ ក៏ប៉ុន្តែ ប្រសិនបើមានម្ចាស់បំណុលផ្សេង ដែលត្រូវ

ទទួលនូវចំណែកនោះ ក្រៅពីម្ចាស់បំណុលដែលមានមូលហេតុមិនអាចទទួលការបែងចែក អាជ្ញាសាលាត្រូវចាត់ចែងការចែកចំណែក ។

(4) លិខិតដែលបានកំណត់នៅក្នុងចំណុច **ក** ឬ **ខ** នៃកថាខណ្ឌទី ២ មាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) គឺជាលិខិតបញ្ឈប់ការអនុវត្ត ប៉ុន្តែ ក្រោយពេលអ្នកទិញបានបង់ថ្លៃលក់ហើយ មិនអាចបដិសេធលទ្ធកម្មចលនវត្ថុដោយការបង់ថ្លៃលក់ឡើយ ហេតុដូច្នេះ កថាខណ្ឌទី ៤ នេះចែងថា មិនអាចបញ្ឈប់ការចែកចំណែកប្រាក់ដែលបានមកពីការលក់ បើគ្រាន់តែបានដាក់លិខិតបញ្ឈប់ការអនុវត្តនោះប៉ុណ្ណោះ ។

Civil Execution Act (Japan)
**Article 139** (Carrying out distribution by execution officer)
1. Where there is only one obligee or every obligation-right of the respective obligees and all costs of execution can be satisfied with the proceeds, seized money and money received for a bill and the like (hereinafter referred to as "proceeds and the like"), the execution officer shall deliver the tender to the obligee and deliver the surplus to the obligor.
2. Except for the case mentioned in the preceding paragraph, if all obligees have agreed with each other on distribution of the proceeds and the like, the execution officer shall carry out distribution according to the agreement.
3. If such agreement has not been reached, the execution officer shall notify the execution court of the circumstances.
4. The provisions of Article 84, paragraphs 3 and 4 and Article 88 shall apply *mutatis mutandis* to cases where distribution is carried out according to the provisions of paragraph 1 or 2.
**Article 84** (Distribution of proceeds) (excerpt)
3. Where a document referred to in items i to vi inclusive of paragraph 1 of Article 39 has been submitted after payment of the purchase price, if there are other obligees entitled to receive distribution or payment of the proceeds (hereinafter referred to as "distribution and the like"), the execution court shall carry out distribution and the like on behalf of the said obligees.
4. Where a document referred to in item vii or viii of paragraph 1 of Article 39 has been submitted after payment of the purchase price, the execution court shall also carry out distribution and the like.
**Article 88** (Distribution for obligation-right with term)
1. An obligation-right the due date of which has not yet arrived shall be deemed to have fallen due when determining distribution.
2. If such obligation-right is non-interest-bearing, the amount of distribution and the like shall be calculated by regarding as the amount of the obligation-right that principal which, if added to the interest at the legal rate from the date for distribution to the due date, would equal the amount of that obligation-right.

**មាត្រា ៤០០.-** ការផ្ញើប្រាក់ទុកនៅតុលាការដោយអាជ្ញាសាលា

១- ក្នុងករណីដែលចែកចំណែក តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ នៃមាត្រា ៣៩៩ (ការចែកចំណែកដោយអាជ្ញាសាលា) នៃក្រមនេះ ប្រសិនបើសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលត្រូវទទួលចំណែកនោះ មានមូលហេតុដូចបានកំណត់នៅក្នុងចំណុចខាងក្រោមនេះ អាជ្ញាសាលាត្រូវដាក់ប្រាក់ដែលស្មើនឹងចំណែកនោះ ផ្ញើទុកនៅសាលាដំបូងដែលខ្លួនស្ថិតនៅ ហើយត្រូវរាយការណ៍អំពីហេតុការណ៍នោះ ទៅសាលាដំបូងនោះ :

**ក**- បើសិទ្ធិលើបំណុលនោះមានភ្ជាប់នូវល័ក្ខខ័ណ្ឌបង្អង់ ឬ កំណត់ពេលមិនពិតប្រាកដ ។

**ខ**- បើសិទ្ធិលើបំណុលនោះជាសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការរឹបអូសជាបណ្ដោះអាសន្ន ។

**គ**- បើមានការដាក់ឯកសារដែលបានកំណត់នៅក្នុងចំណុច **ក** កថាខណ្ឌទី ២ នៃមាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ។

**ឃ**- បើបានដាក់ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេច ដែលហាមឃាត់ការអនុវត្តមួយរយៈនៃឯកសិទ្ធិ ឬ សិទ្ធិលើការបញ្ចាំដែលទាក់ទងនឹងសិទ្ធិលើបំណុលនោះ ។

២- អាជ្ញាសាលាត្រូវធ្វើទុកនូវទឹកប្រាក់ស្មើនឹងចំណែកចំពោះម្ចាស់បំណុល ដែលមិនបានបង្ហាញខ្លួនដើម្បីទទួលចំណែក នៅសាលាដំបូងដែលខ្លួនស្ថិតនៅ ។

(កំណត់)

សូមមើលមាត្រា 141 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

Civil Execution Act (Japan)
**Article 141** (Depositing of money by execution officer)
1. Where the distribution is carried out according to the provisions of Article 139, paragraph 1 or 2, and where the following grounds exist regarding the obligation-right of the obligee entitled to distribution and the like, the execution officer shall deposit money corresponding to the amount of the distribution and the like and shall so notify the execution court:
i. where the obligation-right has a suspensive condition or an indefinite term;
ii. where the obligation-right is an obligation-right of a provisional attachment obligee;
iii. Where a document referred to in Article 39, paragraph 1, item vii or Article 183 paragraph 1, item vi as applied *mutatis mutandis* by Article 192 has been submitted;
iv. where an exemplification of a decision provisionally prohibiting the execution of the preferential right or the right of pledge concerning the obligation-right has been submitted
2. The execution officer shall deposit money corresponding to the amount of the distribution and the like for an obligee who has failed to appear to receive such distribution and the like.

**មាត្រា ៤០១.-** ការជូនដំណឹងទៅសាលាដំបូង

ប្រសិនបើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣៩៩ (ការចែកចំណែកដោយអាជ្ញាសាលា) នៃក្រមនេះ ធ្វើមិនបានដាច់ស្រេចទេ អាជ្ញាសាលាត្រូវរាយការណ៍អំពីហេតុការណ៍នេះ ទៅសាលាដំបូងដែលខ្លួនស្ថិតនៅ ។

(កំណត់)

សូមមើលមាត្រា 142 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន និង មាត្រា 59 និង មាត្រា 60 នៃបទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។ សូមមើលកំណត់នៃមាត្រា ៣៩៩ (ការចែកចំណែកដោយអាជ្ញាសាលា) ត្រង់ចំណុចទី ២ ។

Civil Execution Act (Japan)
**Article 142** (Carrying out of distribution by execution court)
1. In cases where notice has been given according to the provisions of Article 139, paragraph 3, the execution court shall immediately carry out the procedure of distribution and the like, and in cases where notice has been given according to the provisions of paragraph 1 of the preceding article, if the grounds for depositing money nolonger exist, the court shall carry out the procedure of distribution and the like.
2. The provisions of Article 84, 85 and 88 to 92 inclusive shall apply *mutatis mutandis* to the procedure of distribution and the like carried out by the execution court in accordance with the provisions of the preceding paragraph.

# ផ្នែកទី ៣ ការអនុវត្តចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

**មាត្រា ៤០២.-** អត្ថន័យនៃការអនុវត្តចំពោះសិទ្ធិលើបំណុល និង តុលាការអនុវត្ត

១- ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងប្រាក់ ឬ ប្រគល់ចលនវត្ថុ ត្រូវហៅថា ការអនុវត្តចំពោះសិទ្ធិលើបំណុល ។

២- កូនបំណុលនៃសិទ្ធិលើបំណុលដែលនឹងត្រូវរឹបអូស ត្រូវហៅថា កូនបំណុលទី ៣ ។

៣- ក្នុងការអនុវត្តចំពោះសិទ្ធិលើបំណុល សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងរបស់កូនបំណុលនៃការអនុវត្តដែលបានកំណត់នៅក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍) នៃក្រមនេះ គឺជាតុលាការអនុវត្តដែលមានសមត្ថកិច្ច ហើយក្នុងករណីដែលគ្មានកន្លែងខាងលើនោះ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងរបស់កូនបំណុលទី ៣ដែលបានកំណត់នៅក្នុងមាត្រា ៨ គឺជាតុលាការអនុវត្តដែលមានសមត្ថកិច្ចវិញ ។

៤- ក្នុងករណីដែលដីកាសម្រេចរឹបអូសបានចេញម្តងទៀតចំពោះសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស បើតុលាការអនុវត្តដែលបានចេញដីកាសម្រេចរឹបអូសនោះខុសគ្នា តុលាការអនុវត្តអាចផ្ទេររឿងក្តីនោះ ទៅតុលាការអនុវត្តផ្សេងបាន ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 143 និង មាត្រា 144 ។

(1) កថាខណ្ឌទី ១ ចែងអំពីប្រភេទនៃសិទ្ធិលើបំណុលដែលអាចក្លាយជាកម្មវត្ថុនៃការអនុវត្តចំពោះសិទ្ធិលើបំណុល ។ ជាគោលការណ៍ ការអនុវត្តចំពោះសិទ្ធិលើបំណុល អាចធ្វើបានចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ប៉ុន្តែ ប្រសិនបើតតិយជនដែលកាន់កាប់ចលនវត្ថុរបស់កូនបំណុលនៃការអនុវត្ត មិនព្រមប្រគល់ចលនវត្ថុនោះ ការអនុវត្តដោយបង្ខំ ត្រូវធ្វើ មិនមែនតាមការអនុវត្តចំពោះចលនវត្ថុទេ គឺ តាមការអនុវត្តចំពោះសិទ្ធិលើបំណុល (សូមមើលមាត្រា ៣៨៦ (ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយបុគ្គលផ្សេងក្រៅពីកូនបំណុលនៃការអនុវត្ត)) ។ ម្យ៉ាងទៀត តាមច្បាប់ជប៉ុនសព្វថ្ងៃនេះ សិទ្ធិលើបំណុលមួយចំនួនដែលមានឧបករណ៍អាចជួញដូរបាន (valuable instruments) ត្រូវក្លាយជាកម្មវត្ថុនៃការអនុវត្តចំពោះចលនវត្ថុ ប៉ុន្តែ ចំពោះកម្ពុជាវិញ យើងតម្រូវឱ្យអនុវត្តចំពោះសិទ្ធិលើបំណុលវិញ ដោយសារយើងគិតពិចារណាថា ការមិនទទួលស្គាល់ការប្រើវិធីអនុវត្តចំពោះចលនវត្ថុជាការសមរម្យ ។

(2) ជាគោលការណ៍ តុលាការអនុវត្តដែលមានសមត្ថកិច្ចធ្វើការអនុវត្តចំពោះសិទ្ធិលើបំណុល ត្រូវកំណត់តាមលំនៅឋានជាអាទិ៍ របស់កូនបំណុលនៃការអនុវត្ត (សូមមើលមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍)) ។ ប៉ុន្តែ ក្នុងករណីដែលកូនបំណុលនៃការអនុវត្តគ្មានលំនៅឋាន ជាអាទិ៍ ដូចជាករណីដែលកូនបំណុលនៃការអនុវត្តនោះ រស់នៅបរទេស ហើយមិនដែលមានលំនៅឋាននៅកម្ពុជា នោះលំនៅឋាន

ជាអាទិ៍ របស់កូនបំណុលទី ៣ ត្រូវយកមកធ្វើជាមូលដ្ឋានដើម្បីកំណត់តុលាការដែលមានសមត្ថកិច្ច (តាមច្បាប់ជប៉ុន យើងយល់ថា អត្ថិភាពនៃសិទ្ធិលើបំណុល គឺនៅលំនៅឋាន ជាអាទិ៍ របស់កូនបំណុលទី ៣) ។

(3) កថាខណ្ឌទី ៤ នៃមាត្រានេះ មានគោលបំណងធានាស្ថិរភាពនៃនីតិវិធីអនុវត្តដោយបង្ខំ ។

Civil Execution Act (Japan)
**Article 143** (Commencement of execution on an obligation-right)
Compulsory execution on an obligation-right, the subject matter of which is the payment of money or the delivery of a ship or a movable (except for an obligation-right for which a valuable instrument which is the subject matter of the execution against movables has been issued; hereinafter in this subsection "obligation-right" shall follow this definition) shall be commenced by the issuance of an attachment order by the execution court (hereinafter referred to as "execution against an obligation-right")
**Article 144** (Execution court)
1. The district court which has jurisdiction over the place of the obligor's general forum shall as the execution court have jurisdiction over execution against the obligation-right, and, if there is no such general forum, the district court which has jurisdiction over the place where the obligation-right to be attached exists shall as the execution court have jurisdiction over the execution.
2. An obligation-right to be attached shall be deemed to exist at the place of the general forum of the obligation-right's obligor (hereinafter "third party obligor"); provided that an obligation-right the subject matter of which is the delivery of a ship or movable and an obligation-right which is secured by a real security shall be deemed to exist at the place where such things are located.
3. In cases where an attachment order has been re-issued with regard to the obligation-right concerned in the attachment, if such attachment orders were issued by different execution courts, the case may be transferred by one execution court to the other.
4. No complaint may be filed against the ruling referred to in the provisions of the preceding paragraph.

**មាត្រា ៤០៣.-** ដីកាសម្រេចរឹបអូស

១- ពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុល ត្រូវដាក់ទៅតុលាការអនុវត្ត ។

២- នៅក្នុងពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុល ក្រៅពីចំណុចដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ២ មាត្រា ៣៤៩ (របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ) នៃក្រមនេះ ត្រូវបញ្ជាក់អំពីកូនបំណុលទី ៣ផងដែរ ។

៣- ក្នុងករណីដែលសុំឱ្យអនុវត្តចំពោះផ្នែកណាមួយនៃសិទ្ធិលើបំណុល ម្ចាស់បំណុលនៃការអនុវត្ត ត្រូវសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់នូវទំហំនៃការអនុវត្តនោះ ក្នុងពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុល ។

៤- ការអនុវត្តចំពោះសិទ្ធិលើបំណុល ត្រូវចាប់ផ្តើម ដោយដីកាសម្រេចរឹបអូសរបស់តុលាការអនុវត្ត ។

៥- ក្នុងដីកាសម្រេចរឹបអូស តុលាការអនុវត្តត្រូវហាមមិនឱ្យកូនបំណុលនៃការអនុវត្តធ្វើការប្រមូលសិទ្ធិលើបំណុល ឬ ការចាត់ចែងផ្សេងទៀត ហើយហាមមិនឱ្យកូនបំណុលទី ៣ សងបំណុលឱ្យកូនបំណុលនៃការអនុវត្តនោះ ។

៦- ដីកាសម្រេចរឹបអូសត្រូវធ្វើឡើង ដោយមិនត្រូវសួរកូនបំណុលនៃការអនុវត្ត និង កូនបំណុលទី ៣ ទេ ។

៧- ដីកាសម្រេចរឹបអូសត្រូវបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត និង កូនបំណុលទី ៣ ។

៨- អានុភាពនៃការរឹបអូស ត្រូវកើតឡើងនៅពេលដែលដីកាសម្រេចរឹបអូសត្រូវបានបញ្ជូនទៅដល់កូនបំណុលទី ៣ ។

៩- នៅពេលដែលដីកាសម្រេចរឹបអូសត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្ត និង កូនបំណុលទី ៣ ក្រឡាបញ្ជីត្រូវជូនដំណឹងអំពីការណ៍នោះ និង ថ្ងៃ ខែ ឆ្នាំនៃការបញ្ជូននោះ ទៅម្ចាស់បំណុលនៃការអនុវត្ត ។

១០- បើដីកាសម្រេចរឹបអូសចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតដែលបានចុះបញ្ជី បានបង្កើតអានុភាព តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ក្រឡាបញ្ជីត្រូវផ្តុកផ្តាក់ឱ្យស្ថាប័នដែល

មានសមត្ថកិច្ច ចុះបញ្ជីបញ្ជាក់ថា សិទ្ធិលើបំណុលនោះត្រូវបានរឹបអូសហើយ ។

១១- ចំពោះសេចក្តីសម្រេចអំពីពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូស អាចប្តឹងជំទាស់បាន ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 143 144 និង 150 និង បទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 133 និង 134 ។

(1) មានភាពចាំបាច់ត្រូវបញ្ជាក់នូវកូនបំណុលទី ៣ នៅក្នុងពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុល (កថាខណ្ឌទី ២) ហើយព្រមជាមួយគ្នានេះ ត្រូវបញ្ជាក់អ្នកតំណាង កន្លែងដែលត្រូវធ្វើការបញ្ជូន ជាដើមផងដែរ ។ ជាពិសេសចំពោះការរឹបអូសសិទ្ធិលើបំណុលជាប្រាក់បញ្ញើនៅក្នុងធនាគារ ឬ សិទ្ធិលើបំណុលចំពោះប្រាក់បៀវត្ស ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នូវសាខាធនាគារដែលមានគណនីនោះ ឬ ធ្វើកិច្ចការចាត់ចែងប្រាក់បៀវត្សនោះ ដើម្បីឱ្យមានប្រសិទ្ធិភាពក្នុងការរឹបអូស ។ម្យ៉ាងទៀត ចំពោះសិទ្ធិលើបំណុលដែលត្រូវបានរឹបអូសវិញ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ដែរ នូវប្រភេទ ឬ ចំនួនទឹកប្រាក់នោះ ជាដើម ។

(2) បើសួរកូនបំណុលនៃការអនុវត្ត ឬ កូនបំណុលទី ៣ មុននឹងចេញដីកាសម្រេចរឹបអូស កូនបំណុលនៃការអនុវត្តអាចដឹងដំណឹងអំពីការរឹបអូសនោះមុនបាន ហើយគេចពីការអនុវត្ត ដោយប្រមូល ឬ ផ្ទេរ (ធ្វើអនុប្បទាន) សិទ្ធិលើបំណុល ដែលនឹងត្រូវបានរឹបអូសនោះ ហេតុនេះហើយត្រូវហាមមិនឱ្យសួរកូនបំណុលនៃការអនុវត្ត និង កូនបំណុលទី ៣ មុននឹងចេញដីកាសម្រេចរឹបអូស (កថាខណ្ឌទី ៦) ។

(3) ដីកាសម្រេចរឹបអូសត្រូវបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត និង កូនបំណុលទី ៣ (កថាខណ្ឌទី ៧) រីឯអានុភាពនៃដីកាសម្រេចនោះនឹងកើតឡើង នៅពេលបានបញ្ជូនទៅដល់កូនបំណុលទី ៣ (កថាខណ្ឌទី ៨) ហេតុនេះហើយក្នុងកិច្ចការជាក់ស្តែង ត្រូវធ្វើការបញ្ជូនទៅឱ្យកូនបំណុលទី ៣ មុនសិន ដើម្បីការពារកុំឱ្យកូនបំណុលនៃការអនុវត្តអាចចាត់ចែងសិទ្ធិលើបំណុលដែលនឹងត្រូវបានរឹបអូសមុនបាន ។ ម្យ៉ាងទៀត ក្រោយពីដីកាសម្រេចរឹបអូសបានបង្កើតអានុភាពប្រសិទ្ធិភាពហើយ ប្រសិនបើកូនបំណុលទី ៣ បានសងឱ្យកូនបំណុលនៃការអនុវត្ត កូនបំណុលទី ៣ នោះ ត្រូវសងឱ្យម្ចាស់បំណុលនៃការអនុវត្តថែមទៀត ។ ចំណុចនេះមានចែងក្នុងក្រមរដ្ឋប្បវេណី (សូមមើលក្រមរដ្ឋប្បវេណី គន្លឹស្តីពីកាតព្វកិច្ច មាត្រា ៤៣៨ (ការកម្រិតនូវសិទ្ធិទទួលការសងដោយការរឹបអូស) កថាខណ្ឌទី ២) ។

(4) តាមគោលការណ៍នៃភាពបន្ទាប់បន្សំនៃសិទ្ធិប្រាតិភោគប្រត្យក្ស ការរឹបអូសសិទ្ធិលើបំណុល ត្រូវមានអានុភាពលើសិទ្ធិប្រាតិភោគដែលធានាសិទ្ធិលើបំណុលដែលត្រូវបានរឹបអូសនោះ ហើយការចាត់ចែងសិទ្ធិប្រាតិភោគនោះ ក៏ត្រូវបានហាមឃាត់ដែរ ប៉ុន្តែ ដើម្បីតតាំងអានុភាពនៃការហាមឃាត់មិនឱ្យចាត់ចែងនេះចំពោះតតិយជន ចាំបាច់ត្រូវបំពេញល័ក្ខខ័ណ្ឌ ដូចជាការចុះបញ្ជី ជាដើម ហេតុដូច្នេះ ក្រឡាបញ្ជីត្រូវផ្តុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសនូវសិទ្ធិលើបំណុលដែលត្រូវបានធានាដោយវត្ថុប្រាតិភោគនោះ (កថាខណ្ឌទី ១០) ។

Civil Execution Act (Japan)

**Article 143** (Commencement of execution on an obligation-right) >*see the notice for the preceding Article*

**Article 145** (Attachment order)

1. In the attachment order, the execution court shall prohibit the obligor from collecting on the obligation-right or from making any other disposition thereof and shall prohibit the third party obligor from satisfying the obligor.
2. The attachment order shall be issued without interrogating the obligor and the third party obligor.
3. The attachment order shall be served on the obligor and the third party obligor.
4. The attachment shall become effective when the attachment order is served on the third party obligor.
5. A kōkoku-appeal concerning execution may be filed against a decision on a motion for an attachment order.

**Article 150** (Registration of attachment of obligation-right secured by preferential right and the like)

Where an attachment order of an obligation-right secured by a preferential right, a right of pledge or a hypothec which has been recorded or registered (hereinafter referred to as "registration and the like") become effective, the court clerk, upon motion, shall entrust the registrar to make a registration and the like that the obligation-right has been attached.

## **មាត្រា ៤០៤.-** ទំហំនៃការរឹបអូស

១- តុលាការអនុវត្ត អាចចេញដីកាសម្រេចរឹបអូសនូវសិទ្ធិលើបំណុលទាំងអស់ដែលត្រូវរឹបអូសនោះ ។

២- ប្រសិនបើតម្លៃនៃសិទ្ធិលើបំណុលដែលបានរឹបអូស លើសតម្លៃនៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និង សោហ៊ុយសម្រាប់ការអនុវត្ត នោះតុលាការអនុវត្តមិនត្រូវរឹបអូសសិទ្ធិលើបំណុលផ្សេងទៀតឡើយ ។

៣- ក្នុងករណីដែលសិទ្ធិលើបំណុលមួយភាគត្រូវបានរឹបអូស ឬ ត្រូវបានទទួលការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ប្រសិនបើដីកាសម្រេចរឹបអូសផ្សេងទៀតបានចេញ ដោយលើសភាគដែលសល់នោះទៀត អានុភាពនៃការរឹបអូស ឬ ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នទីមួយៗនោះ មានចំពោះសិទ្ធិលើបំណុលទាំងអស់នោះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអានុភាពនៃការរឹបអូស ក្នុងករណីដែលសិទ្ធិលើបំណុលទាំងអស់ត្រូវបានរឹបអូស ឬ បានទទួលការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ហើយមានដីកាសម្រេចរឹបអូសផ្សេងទៀតដែលរឹបអូសមួយភាគនៃសិទ្ធិលើបំណុលនោះ ។

(កំណត់)

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 146 មាត្រា 149 ។

(1) ចំពោះសិទ្ធិលើបំណុលមួយ ទោះបីជាសិទ្ធិលើបំណុលនោះមានតម្លៃលើសតម្លៃនៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និង សោហ៊ុយសម្រាប់ការអនុវត្តក៏ដោយ ក៏អាចរឹបអូសទាំងអស់បានដែរ (កថាខណ្ឌទី ១) ។ នេះគឺទោះជាម្ចាស់បំណុលផ្សេងទៀតទាមទារចំណែកគេក៏ដោយ ក៏អាចតម្រូវចិត្តម្ចាស់បំណុលនៃការអនុវត្តដែរ ។ ប៉ុន្តែ ក្នុងករណីដែលលើសតម្លៃនៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និង សោហ៊ុយសម្រាប់ការអនុវត្តនោះ មិនអាចរឹបអូសសិទ្ធិលើបំណុលផ្សេងទៀតបានទេ (កថាខណ្ឌទី ២) ។ បញ្ញត្តិនេះហាមមិនឱ្យធ្វើការរឹបអូសលើសកម្រិត ដូចករណីរឹបអូសចលនវត្ថុដែរ (សូមមើលមាត្រា ៣៩១ (ការហាមឃាត់មិនឱ្យរឹបអូសហួសប្រមាណ)) ។

(2) ក្នុងករណីដែលការរឹបអូស ឬ ការរឹបអូសជាបណ្ដោះអាសន្នពីរ ឬ ច្រើន ចំពោះសិទ្ធិលើបំណុលតែមួយត្រួតគ្នា

អានុភាពនៃការរឹបអូស ឬ ការរឹបអូសជាបណ្ដោះអាសន្ននីមួយៗ មានទៅលើសិទ្ធិលើបំណុលទាំងអស់ (កថាខណ្ឌទី ៣) ។ ឧទាហរណ៍ ចំពោះសិទ្ធិលើបំណុលដែលមានតម្លៃចំនួន ១០០ ម៉ឺនរៀល ក្រោយពីចំនួន ៧០ ម៉ឺនរៀល ត្រូវបានរឹបអូសសម្រាប់ឈ្មោះ A ហើយបន្ទាប់មកធ្វើការរឹបអូស ៥០ ម៉ឺនរៀល ក្នុងសិទ្ធិលើបំណុលដដែល សម្រាប់ឈ្មោះ B អានុភាពនៃការរឹបអូសសម្រាប់ឈ្មោះ A និង ឈ្មោះ B មានទៅលើសិទ្ធិលើបំណុល ១០០ម៉ឺនរៀល ទាំងអស់ ។

Civil Execution Act (Japan)
**Article 146** (Coverage of attachment)
1. The execution court may issue an order of attachment with regard to the whole of the obligation-right to be attached.
2. If the value of the obligation-right attached exceeds the amount of the obligation-right of the attachment obligee and the costs of execution, the execution court may not attach further obligaion-rights.
**Article 149** (Effect in cases of partial concurrence of attachment)
In cases where a part of the obligation-right has been attached or provisionally attached and if an attachment order which exceeds the remainder is issued, the effect of each attachment or provisional attachment shall extend over the whole of the obligation-right. In cases where the whole of the obligation-right has been attached or provisionally attached, and if a (subsequent) attachment order concerning a part of the obligation-right is issued, such latter attachment shall extend over the whole of the obligation-right.

**មាត្រា ៤០៥.-** ការដាស់តឿនឱ្យកូនបំណុលទី ៣ធ្វើសេចក្ដីថ្លែងការណ៍

១- ប្រសិនបើមានពាក្យសុំពីម្ចាស់បំណុលនៃការអនុវត្ត នៅពេលបញ្ជូនដីកាសម្រេចរឹបអូស តុលាការអនុវត្តត្រូវដាស់តឿនឱ្យកូនបំណុលទី ៣ធ្វើសេចក្ដីថ្លែងការណ៍អំពីចំណុចដែលបានកំណត់ខាងក្រោមនេះ ក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ ចាប់ពីថ្ងៃបញ្ជូនដីកាសម្រេចរឹបអូស :

**ក-** អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិលើបំណុលដែលត្រូវបានរឹបអូសនោះ ហើយប្រភេទចំនួនទឹកប្រាក់ និង ខ្លឹមសារនៃសិទ្ធិលើបំណុល បើមានសិទ្ធិនោះ ។

**ខ-** អត្ថិភាព ឬ នត្ថិភាពនៃឆន្ទៈសង និង ទំហំនៃការសង ឬ មូលហេតុដែលមិនសង ។

**គ-** បើមាន សញ្ញាណនៃជនដែលមានអាទិភាពជាងម្ចាស់បំណុលនៃការអនុវត្ត ចំពោះសិទ្ធិលើបំណុលដែលពាក់ព័ន្ធ និង ប្រភេទនៃសិទ្ធិរបស់ជននោះ និង ទំហំនៃអាទិភាពនោះ ។

**ឃ-** អត្ថិភាព ឬ នត្ថិភាពនៃការរឹបអូស ឬ ការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ចំពោះសិទ្ធិលើបំណុលដែលពាក់ព័ន្ធដោយម្ចាស់បំណុលផ្សេង ។

២- ប្រសិនបើកូនបំណុលទី ៣ មិនបានធ្វើសេចក្ដីថ្លែងការណ៍ តាមការដាស់តឿនដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយចេតនា ឬ ដោយកំហុសរបស់ខ្លួន ឬ បានធ្វើសេចក្ដីថ្លែងការណ៍ខុសពីការពិត កូនបំណុលទី ៣ នោះ ត្រូវទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាតដែលកើតឡើងដោយសារអំពើនេះ ។

(កំណត់)

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 147 និង បទប្បញ្ញត្តិស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន

មាត្រា 135 ។

(1) ដោយគិតពិចារណាថា ដីកាសម្រេចរឹបអូសត្រូវបានចេញ តាមតែពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តដែលគ្មានព័ត៌មានគ្រប់គ្រាន់អំពីសិទ្ធិលើបំណុលដែលនឹងត្រូវរឹបអូសនោះ មាត្រានេះតម្រូវឱ្យកូនបំណុលទី ៣ ដែលមានព័ត៌មានច្រើនជាងគេអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិលើបំណុលដែលនឹងត្រូវរឹបអូស និង អំពីចំនួនទឹកប្រាក់នៃសិទ្ធិនោះ ជាដើម ធ្វើសហការក្នុងនីតិវិធី និង ផ្ដល់ព័ត៌មានចាំបាច់ដើម្បីឱ្យម្ចាស់បំណុលនៃការអនុវត្តអាចធ្វើនីតិវិធីនៅពេលក្រោយនោះ ។ ក្នុងកិច្ចការជាក់ស្ដែងនៅប្រទេសជប៉ុន ក្រឡាបញ្ជីនឹងផ្ញើលិខិតដែលសរសេរអំពីចំណុចនីមួយៗដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ និង ចំណុចដែលត្រូវប្រុងប្រយ័ត្នក្នុងការបំពេញលិខិតនោះ ជូនទៅកូនបំណុលទី ៣ ហើយកូនបំណុលទី ៣ នឹងបំពេញលិខិតនេះ និង ផ្ញើទៅក្រឡាបញ្ជីវិញ ។

(2) ការខូចខាតដែលមានចែងក្នុងកថាខណ្ឌទី ២ មានដូចជា សោហ៊ុយដែលគ្មានប្រយោជន៍ ក្នុងករណីដែលម្ចាស់បំណុលជឿតាមសេចក្ដីថ្លែងការណ៍របស់កូនបំណុលទី ៣ ថា សិទ្ធិលើបំណុលដែលនឹងត្រូវរឹបអូសនោះមានអត្ថិភាព ហើយបានធ្វើនីតិវិធីដើម្បីធ្វើការរឹបអូស ឬ ការខូចខាតដោយមិនបានធ្វើការអនុវត្តចំពោះទ្រព្យផ្សេង ជាដើម ។ ជនដែលទទួលរងការខូចខាត អាចអនុវត្តសិទ្ធិទាមទាររបស់ខ្លួន តាមនីតិវិធីបណ្ដឹង ។

Civil Execution Act (Japan)
**Article 147** (Notice of demand to the third party obligor to make statement)
1. When serving the attachment order, the court clerk, upon motion of the attachment obligee, shall make a notice of demand to the third to the third party obligor to state whether the obligation-right concerned in the attachment exists or not, and about matters provided by the Rules of the Supreme Court within two weeks from the day of service thereof.
2. If the third party obligor intentionally or negligently fails to make a statement, or makes a false statement with regard to the notice of demand referred in the preceding paragraph, he shall be liable for damages incurred thereby.

**មាត្រា ៤០៦.-** ការប្រគល់លិខិតបញ្ជាក់សិទ្ធិលើបំណុល

១- ប្រសិនបើមានលិខិតបញ្ជាក់សិទ្ធិលើបំណុលដែលត្រូវបានរឹបអូស កូនបំណុលនៃការអនុវត្តត្រូវប្រគល់លិខិតបញ្ជាក់នោះ ឱ្យម្ចាស់បំណុលនៃការអនុវត្ត ។

២- ម្ចាស់បំណុលនៃការអនុវត្តអាចទទួលការប្រគល់នូវលិខិតបញ្ជាក់ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តាមការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុដែលបានកំណត់ក្នុងមាត្រា ៥២៥ (ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ) នៃក្រមនេះ ដោយផ្អែកលើដីកាសម្រេចរឹបអូសបាន ។

(កំណត់)

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 148 ។

លិខិតបញ្ជាក់សិទ្ធិលើបំណុល មានដូចជា លិខិតកិច្ចសន្យាខ្ចីបរិភោគ ប័ណ្ណសន្យាសង រូបិយាណត្តិ លិខិតកិច្ចសន្យាខ្ចីប្រើ ជាដើម ។

Civil Execution Act (Japan)
**Article 148** (Delivery of certificate for obligation-right)
1. If there is a document with regard to the obligation-right concerned in the attachment, the obligor must deliver such document to the attachment obligee.
2. The attachment obligee is entitled to have the delivery of such document by way of compulsory execution of delivery of movables as mentioned in Article 169 on the basis of the attachment order.

### **មាត្រា ៤០៧.-** ការរឹបអូសនូវតាវកាលិកដែលទទួលបន្តបន្ទាប់

អានុភាពនៃការរឹបអូសសិទ្ធិលើបំណុលដែលទាក់ទងនឹងប្រាក់បៀវត្ស ឬ តាវកាលិកផ្សេងទៀតដែលទទួលបន្តបន្ទាប់ មានលើតាវកាលិកដែលនឹងទទួលក្រោយពីការរឹបអូសនោះ ត្រឹមកម្រិតនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និង សោហ៊ុយសម្រាប់ការអនុវត្ត ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 151 ។

មាត្រានេះបានចែងដើម្បីសម្រួលដល់ម្ចាស់បំណុលនៃការអនុវត្តថា ចំពោះតាវកាលិកដែលទទួលទៀងទាត់ បើបានទទួលដីកាសម្រេចរឹបអូសម្តងហើយ មិនចាំបាច់ទទួលដីកាសម្រេចរឹបអូស រាល់ពេលកំណត់ត្រូវសងនោះឡើយ ។ "សិទ្ធិលើបំណុលដែលទាក់ទងនឹងតាវកាលិកទៀងទាត់" មានន័យថា ករណីដែលសិទ្ធិលើបំណុលច្បាស់ជានឹងកើតឡើងដោយទៀងទាត់ ឬ ពេលកំណត់សងនឹងត្រូវដល់ដោយទៀងទាត់ នាអនាគត ដោយផ្អែកលើទំនាក់ទំនងគតិយុត្តដែលកំណត់ណាមួយ ដូចជាសិទ្ធិលើបំណុលចំពោះប្រាក់បៀវត្ស សោធននិវត្តន៍ ថ្លៃឈ្នួលដី ថ្លៃឈ្នួលប្រើប្រាស់ ឬ ការប្រាក់ជាដើម ។ ម្យ៉ាងទៀត ចំពោះទំហំនៃសិទ្ធិលើបំណុលចំពោះប្រាក់បៀវត្ស ដែលអាចរឹបអូសបាន សូមមើលមាត្រា ៣៨២ (សិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស) ។

Civil Execution Act (Japan)
**Article 151** (Attachment of periodic payment)
The effect of attachment of an obligation-right concerning a salary or other periodic payment shall extend over payments to be received after the attachment to the extent of the amount of the obligation-right plus the costs of execution.

### **មាត្រា ៤០៨.-** ការជូនដំណឹងអំពីការដកពាក្យសុំ ជាអាទិ៍

១- បើពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុល ត្រូវបានដកវិញ ក្រឡាបញ្ជីត្រូវជូនដំណឹងនេះទៅឱ្យកូនបំណុលទី ៣ ដែលបានទទួលការបញ្ជូនដីកាសម្រេចរឹបអូសផងដែរ ។

២- បើមានដីកាសម្រេចលុបចោលនីតិវិធីនៃការអនុវត្តចំពោះសិទ្ធិលើបំណុល ក្រឡាបញ្ជីត្រូវជូនដំណឹងនេះ ទៅឱ្យកូនបំណុលទី ៣ ដែលបានទទួលការបញ្ជូនដីកាសម្រេចរឹបអូស ។

(កំណត់)

សូមមើលបទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 136 ។

ពេលដែលមានការដកពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុល ឬ មានដីកាសម្រេចលុបចោលនីតិវិធីនៃការអនុវត្ត ដំណឹងនេះនឹងផ្ញើទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត ដែលជាភាគីនៃនីតិវិធីនោះ ហើយក្រៅពីនេះ ដោយសារកូនបំណុលទី ៣ ត្រូវទទួលអានុភាពនៃការហាមមិនឱ្យសងបំណុល ដោយដីកាសម្រេចរឹបអូស (សូមមើលកថាខណ្ឌទី ៥ នៃមាត្រា ៤០៣ (ដីកាសម្រេចរឹបអូស)) មានភាពចាំបាច់ត្រូវជូនដំណឹងទៅកូនបំណុលទី ៣ ថា អានុភាពនេះត្រូវបានរលត់ ។ ហេតុនេះហើយត្រូវចែងឱ្យច្បាស់ក្នុងមាត្រានេះ ។

**មាត្រា ៤០៩.-** ការទាមទារឱ្យចែកចំណែក

១- ម្ចាស់បំណុលដែលមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្ត និង ម្ចាស់បំណុលដែលបញ្ជាក់ដោយឯកសារថា ខ្លួនមានឯកសិទ្ធិ អាចទាមទារឱ្យចែកចំណែកបាន ។

២- នៅពេលដែលមានការទាមទារឱ្យចែកចំណែកដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តត្រូវបញ្ជូនឯកសារដែលបញ្ជាក់អំពីសេចក្តីទាមទារនោះ ទៅឱ្យកូនបំណុលទី ៣ ។

៣- ចំពោះដីកាសម្រេចលើកចោលការទាមទារឱ្យចែកចំណែក អាចប្តឹងជំទាស់បាន ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 154 ។

មាត្រានេះកំណត់ម្ចាស់បំណុលដែលអាចទាមទារឱ្យចែកចំណែក ក្នុងនីតិវិធីនៃការអនុវត្តចំពោះសិទ្ធិលើបំណុល ។ ម្ចាស់បំណុលដែលមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ក្រៅពីការទាមទារឱ្យចែកចំណែក អាចចូលរួម ក្នុងការចែកចំណែក ដោយការរឹបអូសត្រួតគ្នាក៏បានដែរ ។ រីឯឯកសិទ្ធិចំពោះសិទ្ធិលើបំណុលវិញ តាមធម្មតា មានដូចជា ឯកសិទ្ធិទូទៅ ដូចជាសិទ្ធិលើបំណុលចំពោះប្រាក់បៀវត្ស ជាដើម ប៉ុន្តែ សម្រាប់ជនដែលមានឯកសិទ្ធិបែបនេះ ការទាមទារឱ្យមានលិខិតអនុវត្តជាការពិបាក ហេតុនេះហើយ ទោះបីជាមានតែលិខិតឯកជន ដូចជាលិខិតបញ្ជាក់លំអិតអំពីប្រាក់បៀវត្សជាដើមក៏ដោយ បើអាចបញ្ជាក់អំពីឯកសិទ្ធិបាននោះ ក៏បញ្ញត្តិនេះអនុញ្ញាតឱ្យជននោះអាចចូលរួមក្នុងការចែកចំណែកបានដែរ ។ ម្យ៉ាងទៀត ចំពោះពេលដែលអាចចូលរួមក្នុងការចែកចំណែក ដោយការទាមទារឱ្យចែកចំណែកនោះ សូមមើលមាត្រា ៤១៥ (វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក) ។

Civil Execution Act (Japan)
**Article 154** (Demand for distribution)
1. An obligee who has an exemplification of obligation title with the execution power and an obligee who proves by a document that he has a preferential right may make a demand for distribution.
2. In cases where such demand for distribution has been made, a document including a statement thereof shall be served on the third obligor.

3. A kōkoku-appeal concerning execution may be filed against a decision dismissing a demand for distribution.

**មាត្រា ៩១០.-** ការប្រមូលបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់

១- ម្ចាស់បំណុលដែលបានរឹបអូសសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ អាចប្រមូលបំណុលនោះបាន បើ ១ (មួយ) សប្តាហ៍កន្លងហួស ក្រោយពីថ្ងៃដែលដីកាសម្រេចរឹបអូសត្រូវបានបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត ។ ប៉ុន្តែ ម្ចាស់បំណុលនៃការអនុវត្តនោះមិនអាចទទួលការសងលើសតម្លៃនៃសិទ្ធិលើបំណុលរបស់ខ្លួន និង សោហ៊ុយសម្រាប់ការអនុវត្តបានឡើយ ។

២- ពេលដែលម្ចាស់បំណុលនៃការអនុវត្តបានទទួលសំណងពីកូនបំណុលទី ៣ ត្រូវចាត់ទុកថា បំណុលនោះ និង សោហ៊ុយសម្រាប់ការអនុវត្ត ត្រូវបានសង ត្រឹមកម្រិតនៃចំនួនទឹកប្រាក់សំណងដែលខ្លួនបានទទួល ។

៣- ពេលដែលបានទទួលសំណងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវជូនដំណឹងអំពីការណ៍នេះទៅតុលាការអនុវត្ត ។

៤- ម្ចាស់បំណុលនៃការអនុវត្ត ត្រូវទទួលខុសត្រូវចំពោះកូនបំណុលនៃការអនុវត្ត ក្នុងការសងការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តសិទ្ធិលើបំណុល ដែលខ្លួនបានរឹបអូស ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 155 និង មាត្រា 158 ។

(1) ក្នុងការអនុវត្តចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ការលក់សិទ្ធិលើបំណុលទៅតតិយជនដើម្បីប្តូរជាប្រាក់ គឺជាកិច្ចការមួយដែលគ្រាន់តែប្រមូលបំណុលនោះពីកូនបំណុលទី ៣ គឺគ្រប់គ្រាន់ហើយ ។ ហេតុនេះហើយ មាត្រានេះចែងទទួលស្គាល់ឱ្យម្ចាស់បំណុលនៃការអនុវត្ត មានសិទ្ធិប្រមូលដោយខ្លួនឯង នូវសិទ្ធិលើបំណុលដែលត្រូវបានរឹបអូសនោះ ។

(2) សិទ្ធិប្រមូលរបស់ម្ចាស់បំណុលនៃការអនុវត្ត នឹងកើតឡើងមួយអាទិត្យ ក្រោយពីបានធ្វើការបញ្ជូនដីកាសម្រេចរឹបអូសទៅឱ្យកូនបំណុល (កថាខណ្ឌទី ១) ។ នេះគឺដើម្បីធានានូវឱកាសប្តឹងឧបាស្រ័យរបស់កូនបំណុល ចំពោះដីកាសម្រេចរឹបអូសនោះ (កថាខណ្ឌទី ១១ នៃមាត្រា ៩០៣ (ដីកាសម្រេចរឹបអូស)) ។ម្យ៉ាងទៀត ប្រសិនបើមានម្ចាស់បំណុលនៃការអនុវត្តផ្សេងទៀត ឬ មានម្ចាស់បំណុលដែលទាមទារឱ្យចែកចំណែកផ្សេងទៀត កូនបំណុលទី ៣ ត្រូវផ្ញើទុកប្រាក់ (កថាខណ្ឌទី ២ នៃមាត្រា ៩១១ (ការផ្ញើប្រាក់ទុកដោយកូនបំណុលទី ៣)) ហេតុដូច្នេះសិទ្ធិប្រមូលបំណុលដែលបានកំណត់នៅក្នុងមាត្រានេះ មិនកើតឡើងទេ ។

(3) ទំហំនៃការប្រមូលបំណុលមានត្រឹមតែទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និង សោហ៊ុយសម្រាប់ការអនុវត្តប៉ុណ្ណោះ (កថាខណ្ឌទី ១) ហើយភាគនៃសំណងដែលបានទទួល ត្រូវបំពេញនូវតម្រូវចិត្តរបស់ម្ចាស់បំណុលនៃការអនុវត្ត (កថាខណ្ឌទី ២) ។ ហេតុដូច្នេះ នៅពេលដែលការប្រមូលបានសម្រេចចប់សព្វគ្រប់ហើយ

ម្ចាស់បំណុលផ្សេងទៀតមិនអាចទាមទារឱ្យចែកចំណែកបានទេ ឯនីតិវិធីនៃការអនុវត្តក៏បានចប់ដែរ ហើយម្ចាស់បំណុលនៃការអនុវត្តដែលទទួលសំណងនោះ មានករណីយកិច្ចត្រូវជូនដំណឹងអំពីការណ៍នេះទៅតុលាការអនុវត្ត (កថាខណ្ឌ ទី ៣) ។

(4) ការប្រមូលគឺជាសិទ្ធិរបស់ម្ចាស់បំណុលនៃការអនុវត្ត ប៉ុន្តែ កូនបំណុលនៃការអនុវត្តត្រូវបានហាមមិនឱ្យប្រមូល (កថាខណ្ឌទី ៤ នៃមាត្រា ៤០៣ (ដីកាសម្រេចរឹបអូស)) ហេតុនេះហើយការប្រមូលដោយវិធីសមរម្យណាមួយ គឺជាករណីយកិច្ចរបស់ម្ចាស់បំណុលនៃការអនុវត្តដែរ ។ បើម្ចាស់បំណុលនៃការអនុវត្តមិនគោរពករណីយកិច្ចប្រមូលនោះ ម្ចាស់បំណុលនោះត្រូវទទួលខុសត្រូវសងនូវការខូចខាតចំពោះកូនបំណុលនៃការអនុវត្ត (កថាខណ្ឌទី ៤) ។ ការមិនគោរពករណីយកិច្ចនោះ មានដូចជា ករណីដែលម្ចាស់បំណុលនៃការអនុវត្តមិនបានប្រមូលនៅពេលសមរម្យ ហើយសិទ្ធិលើបំណុលដែលត្រូវបានរឹបអូសបានរលត់ដោយអាជ្ញាយុកាល ឬ ករណីដែលម្ចាស់បំណុលនៃការអនុវត្តប្ដឹងទាមទារប្រមូលបំណុលនោះ ចំពោះកូនបំណុលទី ៣ ដោយរបៀបយ៉ាងឆ្គង ហើយបណ្ដាលឱ្យចាញ់ក្ដី ជាដើម ។

Civil Execution Act (Japan)
**Article 155** ( Collection of monetary obligation by attachment obligee)
1. If one week has passed from the day when the attachment order was served on the obligor, an obligee who has attached an obligation-right the subject matter of which is the payment of money (hereinafter referred to as matter "monetary obligation right") may collect the obligation-right; provided that, the attachment obligee may not receive payment which exceeds the amount of his obligation-right and the costs of execution.
2. If the attachment obligee receives payment from the third obligor, his obligation-right and the costs of execution shall be deemed satisfied to the extent of the paid amount.
3. If the payment referred to in the preceding paragraph has been made, the attachment obligee shall immediately notify the execution court thereof.
**Article 158** (Liability of obligee for damages)
The attachment obligee shall be liable to an obligor for damages incurred by failure to exercise the obligation-right attached.

**មាត្រា ៤១១.-** ការផ្ញើប្រាក់ទុកដោយកូនបំណុលទី ៣

១- ពេលដែលសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ត្រូវបានរឹបអូស កូនបំណុលទី ៣ អាចផ្ញើទុកប្រាក់ស្មើនឹងចំនួនប្រាក់ដែលត្រូវបានរឹបអូសក្នុងចំណោមសិទ្ធិលើបំណុលនោះ ឬ ប្រាក់ស្មើនឹងចំនួនប្រាក់នៃសិទ្ធិលើបំណុលនោះទាំងអស់ នៅតុលាការអនុវត្តបាន ។

២- ក្នុងករណីខាងក្រោមនេះ កូនបំណុលទី ៣ត្រូវផ្ញើទុកប្រាក់ស្មើនឹងចំនួនប្រាក់ដែលបានកំណត់ខាងក្រោម នៅតុលាការអនុវត្ត :

**ក-** បើបានចេញដីកាសម្រេចរឹបអូស ឬ ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដោយលើសភាគសំណល់ពីការរឹបអូសសិទ្ធិលើបំណុល ហើយបានទទួលការបញ្ជូននូវដីកាសម្រេចនោះ មុនពេលដែលកូនបំណុលទី ៣ បានទទួលពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤១២ (បណ្ដឹងទាមទារប្រមូលបំណុល) នៃក្រមនេះ : ចំនួនប្រាក់ទាំងអស់នៃសិទ្ធិលើបំណុលនោះ ។

២- បើបានទទួលការបញ្ជូននូវឯកសារដែលបញ្ជាក់ថា មានការទាមទារឱ្យចែកចំណែក ៖ ភាគនៃសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស ។

៣- បើបានធ្វើប្រាក់ទុកតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ ខាងលើនេះ កូនបំណុលទី ៣ ត្រូវជូនដំណឹងអំពីស្ថានភាពនោះ ទៅតុលាការអនុវត្ត ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 156 ។

(1) កូនបំណុលទី ៣ ជាអ្នកត្រូវចូលរួមក្នុងនីតិវិធីនៃការអនុវត្តដោយចៃដន្យដោយសារតែកូនបំណុលនៃការអនុវត្ត ។ ដូច្នេះហើយ មានភាពចាំបាច់ត្រូវទទួលស្គាល់ឱ្យកូនបំណុលទី ៣ អាចដកខ្លួនថយពីនីតិវិធីនៃការអនុវត្ត ដើម្បីរួចផុតពីភាពស្មុគស្មាញ ។ កថាខណ្ឌទី ១ នៃមាត្រានេះ ចែងផ្តល់សិទ្ធិដកខ្លួនថយពីនីតិវិធីនៃការអនុវត្ត ឱ្យកូនបំណុលទី ៣ ដោយធ្វើនូវប្រាក់នៃសិទ្ធិលើបំណុល នៅពេលដែលសិទ្ធិលើបំណុលចំពោះខ្លួនត្រូវបានរឹបអូស (ដែលហៅថាការធ្វើដោយមានសិទ្ធិ) ។ ការធ្វើនេះ មិនមែនជាករណីយកិច្ចរបស់កូនបំណុលទី ៣ ឡើយ ដូចនេះ កូនបំណុលទី ៣ អាចធ្វើក៏បាន ឬ មិនធ្វើក៏បាន ។ម្យ៉ាងទៀត ក្នុងករណីដែលសិទ្ធិលើបំណុលតែមួយភាគត្រូវបានរឹបអូស កូនបំណុលទី ៣ អាចធ្វើប្រាក់ស្មើនឹងចំនួនប្រាក់នៃសិទ្ធិលើបំណុលទាំងអស់បាន ដើម្បីដកខ្លួនថយពីនីតិវិធីនៃការអនុវត្តទាំងស្រុង ។ នាពេលអនាគតដែលបង្កើតរបបតម្កល់ យើងអាចឱ្យកូនបំណុលទី ៣ តម្កល់នៅការិយាល័យតម្កល់ ជំនួសការធ្វើនៅតុលាការអនុវត្តបាន (ដូចច្បាប់ជប៉ុន) ។

(2) ក្នុងករណីដែលមានការរឹបអូស ឬ ការរឹបអូសជាបណ្តោះអាសន្នត្រួតគ្នា ដូចបានចែងក្នុងកថាខណ្ឌទី ២ ឬក្នុងករណីដែលមានការទាមទារឱ្យចែកចំណែក ម្ចាស់បំណុលនឹងអាចមានការប្រណាំងប្រជែងគ្នា តែក្នុងករណីនេះត្រូវធ្វើការចែកចំណែក (សូមមើលមាត្រា ៤១៥ (វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក)) ។ ដូច្នេះកថាខណ្ឌទី ២ នៃមាត្រានេះ ចែងឱ្យកូនបំណុលទី ៣ មានករណីយកិច្ចធ្វើ (ដែលហៅថា ការធ្វើដោយមានករណីយកិច្ច) ។ ទោះបីជាមានករណីយកិច្ចធ្វើ តែកូនបំណុលទី ៣ បានសងបំណុលតាមការទាមទារប្រមូលរបស់ម្ចាស់បំណុលណាម្នាក់ក៏ដោយ ក៏អានុភាពនៃសំណងនោះមិនអាចតតាំងនឹងម្ចាស់បំណុលផ្សេងបានទេ ។

(3) ក្នុងករណីដែលកូនបំណុលទី ៣ ធ្វើការធ្វើ កូនបំណុលទី ៣ នោះ ត្រូវជូនដំណឹងអំពីស្ថានភាពនោះ ទៅតុលាការអនុវត្ត (កថាខណ្ឌទី ៣) ។ ក្នុងការជូនដំណឹងនេះ កូនបំណុលត្រូវសរសេរ សញ្ញាណនៃរឿងក្តី ឈ្មោះ ឬ នាមករណ៍របស់ម្ចាស់បំណុលនៃការរឹបអូស និង កូនបំណុលនៃការរឹបអូស មូលហេតុនៃការធ្វើ (ដោយយោងតាមកថាខណ្ឌទី ១ ឬ ទី ២ ជាដើម) ចំនួនទឹកប្រាក់ដែលខ្លួនធ្វើ ជាដើម (សូមមើលកថាខណ្ឌទី ១ មាត្រា ១៣៨ នៃបទបញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន) ។ ដោយការជូនដំណឹងនេះ តុលាការអាចទទួលនូវព័ត៌មានអំពីម្ចាស់បំណុលនៃការរឹបអូស ជាដើម ក្រៅពីហេតុការណ៍ដែលមានការធ្វើ ហើយអាចសម្រេចអំពីការចាប់ផ្តើម ការចែកចំណែក

ខ្លឹមសារនៃការចែកចំណែក ជាដើម ឱ្យបានងាយស្រួល ។

Civil Execution Act (Japan)
**Article 156** (Deposit of money by the third party obligor)
1. The third party obligor may deposit the money corresponding to the whole amount of the obligation-right concerning the attachment in a depository situated at the place of performance of the obliation-duty.
2. Until the complaint of the action referred to in paragraph 1 of the next Article is served on the third party obligor, if an attachment order or an order of provisional attachment exceeding the part which has not been yet attached out of the monetary obligation-right concerning the attachment is served on the third party obligor, he shall deposit the money corresponding to the whole amount of the obligation-right, and if a document including a statement that a demand for distribution has been made is served on the third party obligor, he shall deposit money corresponding to the part which has been attached in a depository situated at the place of performance.
3. When the third party obligor has made the deposit in accordance with provisions of the two preceding paragraphs, he shall notify the execution court of the circumstances.

**មាត្រា ៤១២.-** បណ្តឹងទាមទារប្រមូលបំណុល

១- បើម្ចាស់បំណុលបានដាក់ពាក្យបណ្តឹងទាមទារឱ្យកូនបំណុលទី ៣ ផ្តល់តាវកាលិកដែលទាក់ទងនឹងសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស តុលាការដែលទទួលពាក្យបណ្តឹងនោះ អាចបង្គាប់ម្ចាស់បំណុលផ្សេងទៀតដែលបានរឹបអូសសិទ្ធិលើបំណុលនោះ មុនពេលដែលពាក្យបណ្តឹងត្រូវបានបញ្ជូនឱ្យចូលរួមក្នុងនាមជាដើមចោទនៃសហបណ្តឹងបាន តាមពាក្យសុំរបស់កូនបំណុលទី ៣ ដោយដីកាសម្រេច ។

២- អានុភាពនៃសាលក្រមដែលពាក់ព័ន្ធនឹងបណ្តឹងដែលបានកំណត់នៅកថាខណ្ឌទី ១ មានចំពោះម្ចាស់បំណុលនៃការអនុវត្ត ដែលទទួលការបង្គាប់ឱ្យចូលរួមតាមបញ្ញត្តិនៃកថាខណ្ឌទី ១ តែមិនបានចូលរួមដែរ ។

៣- ក្នុងបណ្តឹងដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ចំពោះកូនបំណុលទី ៣ ដែលមានករណីយកិច្ចផ្ញើប្រាក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៤១១ (ការផ្ញើប្រាក់ទុកដោយកូនបំណុលទី ៣) នៃក្រមនេះ ប្រសិនបើទទួលស្គាល់នូវការទាមទាររបស់ដើមចោទ តុលាការដែលទទួលពាក្យបណ្តឹង ត្រូវសរសេរបញ្ជាក់នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រមថា ការសងប្រាក់ដែលទាក់ទងនឹងការទាមទារ ត្រូវធ្វើតាមវិធីផ្ញើប្រាក់ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 157 ។

(1) ក្នុងករណីដែលកូនបំណុលទី ៣ មិនព្រមសងតាមការប្រមូលរបស់ម្ចាស់បំណុលនៃការអនុវត្តទេ ម្ចាស់បំណុលនោះអាចធ្វើបណ្តឹងទាមទារឱ្យផ្តល់តាវកាលិកបាន (នេះគេហៅថា បណ្តឹងទាមទារប្រមូលបំណុល) ។ មាត្រានេះចែងបញ្ញត្តិពិសេសអំពីករណីដែលមានម្ចាស់បំណុលច្រើននាក់ ត្រួតគ្នា ។

(2) ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តមានច្រើននាក់ ប្រសិនបើមានបណ្តឹងទាមទារប្រមូលបំណុលផ្សេងៗគ្នា កូនបំណុលទី ៣ ត្រូវតែខំឱ្យឈ្នះបណ្តឹងនោះទាំងអស់ ដើម្បីការពារឋានៈរបស់ខ្លួន ។ ដូច្នេះហើយ កូនបំណុលទី ៣ ដែលបានក្លាយជាចុងចម្លើយនៃបណ្តឹងទាមទារប្រមូលបំណុលនោះ អាចទាមទារឱ្យម្ចាស់បំណុលនៃការអនុវត្តផ្សេង

ចូលរួមក្នុងបណ្ដឹងនោះ (កថាខណ្ឌទី ១) ហើយទោះបីជាម្ចាស់បំណុលទាំងនោះមិនបានចូលរួមក្នុងសហបណ្ដឹងនោះក៏ដោយ ក៏ត្រូវទទួលអានុភាពនៃសាលក្រមសហបណ្ដឹងនោះដែរ (កថាខណ្ឌទី ២) ។

(3) ក្នុងករណីដែលកូនបំណុលទី ៣ មានករណីយកិច្ចផ្ញើ (កថាខណ្ឌទី ២ នៃមាត្រា ៤១១ (ការផ្ញើប្រាក់ទុកដោយកូនបំណុលទី ៣)) ហើយមានបណ្ដឹងទាមទារប្រមូលបំណុល ប្រសិនបើតុលាការចេញសាលក្រមបង្គាប់ឱ្យផ្ដល់តាវកាលិកធម្មតា មានន័យថាមិនចាំបាច់មានការផ្ញើទេ ហេតុនេះហើយក្នុងករណីនេះ តុលាការត្រូវសរសេរក្នុងសេចក្ដីសម្រេចបញ្ចប់នៃសាលក្រមឱ្យបានច្បាស់លាស់ថា ការសងប្រាក់ត្រូវធ្វើតាមវិធីផ្ញើ (កថាខណ្ឌទី ៣) ។

Civil Execution Act (Japan)
**Article 157** (Action for collection)
1. Where the attachment obligee has instituted an action for payment concerning an obligation-right attached (hereinafter referred to as "action for collection") against the third party obligor, the court of the action may, upon motion of the third party obligor, order other obligees who attached the obligation-right prior to the service of the complaint to participate with the plaintiff as joint parties.
2. The decision returned to in the preceding paragraph may be rendered without resorting to oral argument.
3. The effect of judgment on such action for collection shall also extend to the attachment obligees who have been ordered to participate in accordance with the provisions of paragraph 1 but have failed to do so.
4. In an action for collection against a third party obligor obliged to make a deposit according to the provisions of the preceding Article, paragraph 2, if the claim of the plaintiff is admitted, the court of the action shall include a statement in the formal disposition of the judgment that the payment of money concerning the claim shall be made by means of deposit.
5. Where the plaintiff of the judgment referred to in the preceding paragraph is entitled to distribution and the like in a compulsory execution or sale by auction, the money corresponding to the amount of the distribution and the like shall be deposited.

**មាត្រា ៤១៣.-** ដីកាសម្រេចបង្គាប់ឱ្យលក់

១- បើសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស មានល័ក្ខខ័ណ្ឌ ឬ មានកំណត់ពេល ឬ មានការលំបាកក្នុងការប្រមូលដោយសារភ្ជាប់នឹងតាវកាលិកតប ឬ មានហេតុផ្សេងទៀត តុលាការអនុវត្តអាចចេញដីកាសម្រេចបង្គាប់ឱ្យអាជ្ញាសាលាលក់សិទ្ធិលើបំណុលនោះ ដោយវិធីដែលកំណត់ដោយតុលាការអនុវត្ត ហើយឱ្យយកប្រាក់ដែលបានមកពីការលក់នោះទៅឱ្យតុលាការអនុវត្ត តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ។

២- ក្នុងករណីដែលចេញដីកាសម្រេចតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តត្រូវសួរកូនបំណុលនៃការអនុវត្ត ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកូនបំណុលនៃការអនុវត្តនៅបរទេស ឬ មិនដឹងលំនៅឋានកូនបំណុលនោះ ។

៣- ប្រសិនបើយល់ឃើញថា ប្រាក់ដែលបានមកពីការលក់សិទ្ធិលើបំណុលដែលត្រូវបានរឹបអូសបាននោះ ក្រោយពីបានសងបំណុលដែលមានអាទិភាពជាងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត ព្រមទាំងសងសោហ៊ុយសម្រាប់នីតិវិធីហើយមិនសល់ទេនោះ តុលាការអនុវត្តមិនអាចចេញដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះឡើយ ។

៤- ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

៥- ដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ មិនបង្កើតអានុភាពឡើយ បើដីកាសម្រេចនោះ

មិនទាន់ចូលជាស្ថាពរ ។

៦- ក្នុងករណីដែលចេញដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើយល់ឃើញថាចាំបាច់ តុលាការអនុវត្តអាចជ្រើសតាំងអ្នកវាយតម្លៃ និង បង្គាប់ឱ្យធ្វើការវាយតម្លៃសិទ្ធិលើបំណុលបាន ។

៧- អាជ្ញាសាលាមិនអាចលក់សិទ្ធិលើបំណុលបានឡើយ ប្រសិនបើប្រាក់ដែលមកពីការលក់សិទ្ធិលើបំណុលនោះ ក្រោយពីបានសងបំណុលដែលមានអាទិភាពជាងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត ព្រមទាំងសងសោហ៊ុយសម្រាប់នីតិវិធី ហើយមិនសល់ទេនោះ ។

៨- ចំពោះការលក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ កូនបំណុលនៃការអនុវត្តមិនអាចធ្វើសំណើទិញបានឡើយ ។

៩- បើបានលក់សិទ្ធិលើបំណុលដែលត្រូវបានរឹបអូស អាជ្ញាសាលាត្រូវជូនដំណឹងអំពីអនុប្បទាន ដោយលិខិតបញ្ជាក់ដែលមានកាលបរិច្ឆេទស្ថាពរ ចំពោះកូនបំណុលទី ៣ ជំនួសកូនបំណុលនៃការអនុវត្ត ។

១០- បើបានបញ្ចប់ការលក់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ចំពោះសិទ្ធិលើបំណុលដែលបានកំណត់ នៅក្នុងកថាខណ្ឌទី ១០ នៃមាត្រា ៤០៣ (ដីកាសម្រេចរឹបអូស) នៃក្រមនេះ តុលាការត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត សម្រាប់អ្នកទិញដែលបានទទួលសិទ្ធិលើបំណុលនោះ ហើយផ្ទុកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចលុបនូវការចុះបញ្ជីដែលបានធ្វើតាមបញ្ញត្តិនៃកថាខណ្ឌទី ១០ នៃមាត្រា ៤០៣ (ដីកាសម្រេចរឹបអូស) តាមពាក្យសុំរបស់អ្នកទិញ ។

(កំណត់)

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 161 មាត្រា 164 បទប្បញ្ញត្តិស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 139 និង មាត្រា 141 ។

(1) មាត្រានេះចែងអំពីនីតិវិធីបង្គាប់ឱ្យលក់ ដែលជាវិធីប្ដូរជាប្រាក់ពិសេស ក្នុងករណីដែលមានការលំបាកក្នុងការប្រមូលធម្មតា ដោយសារមានមូលហេតុ ដូចជា សិទ្ធិលើបំណុលដែលត្រូវបានរឹបអូសនោះមានល័ក្ខខ័ណ្ឌមានកំណត់ពេល ឬ ភ្ជាប់នឹងតាវកាលិកតប ជាដើម ។ នេះគឺជានីតិវិធីពិសេស ហេតុនេះហើយដើម្បីជ្រើសរើសយកនីតិវិធីនេះ ត្រូវធ្វើការសួរកូនបំណុលនៃការអនុវត្ត (កថាខណ្ឌទី ២) ហើយពុំមានអានុភាពឡើយ បើដីកាសម្រេច មិនចូលជាស្ថាពរ (កថាខណ្ឌទី ៤) ។

(2) នីតិវិធីបង្គាប់ឱ្យលក់នេះ បានចែងឡើងដោយយកនីតិវិធីអនុវត្តចំពោះចលនវត្ថុមកធ្វើជាមូលដ្ឋាន ដូចជាការហាមមិនឱ្យលក់ បើគ្មានសំណល់ (កថាខណ្ឌទី ៣ និង ទី ៧) ការហាមមិនឱ្យកូនបំណុលនៃការអនុវត្តស្នើសុំទិញ (កថាខណ្ឌទី ៨) ។ ប៉ុន្តែ ត្រូវមានបញ្ញត្តិពិសេសសម្រាប់សិទ្ធិលើបំណុលនេះ គឺ ការរៀបចំល័ក្ខខ័ណ្ឌតតាំងដោយអាជ្ញាសាលា ដូចការផ្ទេរអនុប្បទានសិទ្ធិលើបំណុល (កថាខណ្ឌទី ៩) ឬ ការស្នើសុំឱ្យចុះបញ្ជីនូវសិទ្ធិប្រាតិភោគ

ដែលភ្ជាប់នឹងសិទ្ធិលើបំណុល ដោយក្រឡាបញ្ជី (កថាខណ្ឌទី ១០) ដែលជាសេវាក្រោយការចាត់ចែង ។

Civil Execution Act (Japan)
**Article 161** (Transfer order and the like)
1. Where the obligation-right attached is subject to a condition or term, depends on a counter-performance, or is difficult to collect on some other grounds, the execution court may, upon motion of the attachment obligee, issue: an order to transfer such obligation-right at the value fixed by the execution court to the attachment obligee instead of payment (hereinafter referred to as "transfer order"); an order to direct the execution officer to sell such obligation-right by means provided by the execution court rather than collection (hereinafter referred to as "sale order"); an order to appoint an administrator and to direct him to administer such obligation-right (hereinafter referred to as "administration order"); or an order to realize such obligation-right by any other reasonable means.
2. In cases where a ruling in accordance with the provisions of the preceding paragraph is rendered, the execution court must interrogate the obligor; provided that, if the obligor is abroad or the domicile of the obligor is unknown, this shall not apply.
3. A kōkoku-appeal concerning execution may be filed against a ruling on a motion referred to in paragraph 1.
4. The ruling in accordance with the provisions of paragraph 1 shall not become effective until it becomes final and binding.
5. Where the execution officer has sold the obligation-right attached, such execution officer instead of the obligor, must notify the third party obligor of the transfer by an instrument bearing an authenticated.
6. The provisions of Article 159, paragraphs 2 and 3 and the preceding Article shall apply *mutatis mutandis* to transfer order; the provisions of Article 159, paragraph 6 shall apply *mutatis mutandis* to a kōkoku-appeal concerning execution against a transfer order; the provisions of Article 65 and 68 shall apply *mutatis mutandis* to the sale by the execution officer on the basis of a sale order, the provisions of Article 159, paragraph 2 shall apply *mutatis mutandis* to an administration order; and the provisions of Article 84, paragraphs 3 and 4, Article 88, Article 94, paragraph 2, Article 95, paragraphs 1, 3 and 4, Article 98 to 104 inclusive and Articles 106 to 110 inclusive shall apply *mutatis mutandis* to the administration on the basis of an administration order. In such cases, the phrase in paragraphs 3 and 4 of Article 84 "after payment of the purchase price" shall be changed to "after expiration of the period of Article 107, paragraph 1 applied *mutatis mutandis* by Article 161".

**មាត្រា ៤១៤.-** ការអនុវត្តដីកាសម្រេចរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ

១- ម្ចាស់បំណុលដែលរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ អាចទាមទារឱ្យកូនបំណុលទី ៣ ប្រគល់ចលនវត្ថុនោះទៅអាជ្ញាសាលាដែលទទួលពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តបាន បើអំឡុងពេល ១ (មួយ) សប្តាហ៍ បានកន្លងហួស ដោយគិតពីថ្ងៃដែលដីកាសម្រេចរឹបអូសត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្ត ។

២- ពេលដែលទទួលការប្រគល់ចលនវត្ថុ អាជ្ញាសាលាត្រូវលក់ចលនវត្ថុនោះតាមវិធីលក់ចលនវត្ថុ ហើយត្រូវប្រគល់ប្រាក់ដែលបានមកពីការលក់នោះទៅតុលាការអនុវត្ត ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 163 ។

ក្នុងករណីដែលកូនបំណុលទី ៣ កាន់កាប់ចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ហើយបើកូនបំណុលទី ៣ នេះ ប្រកែកមិនប្រគល់ចលនវត្ថុនោះទេ ការអនុវត្តដោយបង្ខំមិនអាចធ្វើតាមវិធីអនុវត្តចំពោះចលនវត្ថុទេ ពេលនោះនឹងត្រូវធ្វើតាមវិធីរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុវិញ ។ ក្នុងករណីនេះ ប្រហាក់ប្រហែលគ្នានឹងករណីរឹបអូសសិទ្ធិលើបំណុលជាប្រាក់ដែរ ម្ចាស់បំណុលនៃការអនុវត្តទាមទារឱ្យកូនបំណុលទី ៣ ប្រគល់ចលនវត្ថុនោះ (កថាខណ្ឌទី ១) អាជ្ញាសាលាដែលបានទទួលការប្រគល់វត្ថុនោះនឹងលក់ចលនវត្ថុនោះតាមវិធីអនុវត្តចំពោះចលនវត្ថុ (កថាខណ្ឌទី ២) ហើយតុលាការអនុវត្តដែលបានទទួលប្រាក់ពីការលក់នោះនឹងចែកចំណែក ។

Civil Execution Act (Japan)
**Article 163** (Execution of claim right to deliver movables)
1. An obligee who has attached a claim right to deliver movables may, if a week has passed since an attachment order was served on the obligor, demand that the third-party obligor deliver the movables to the execution officer to whom the attachment obligee's motion has been made.
2. Where the movables have been delivered to the execution officer, such execution officer shall sell them by the procedure of sale with regard to execution against movables and submit the proceeds to the execution court.

**មាត្រា ៤១៥.-** វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក

ម្ចាស់បំណុលដែលត្រូវទទួលចំណែក គឺម្ចាស់បំណុលដែលបានអនុវត្តការរឹបអូស ឬ ការរឹបអូសជាបណ្ដោះអាសន្ន ឬ ទាមទារឱ្យចែកចំណែក មុនពេលដែលបានកំណត់ខាងក្រោមនេះ :

**ក-** ពេលដែលកូនបំណុលទី ៣ បានធ្វើការផ្ញើតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ នៃមាត្រា ៤១១ (ការផ្ញើប្រាក់ទុកដោយកូនបំណុលទី ៣) នៃក្រមនេះ ។

**ខ-** ពេលដែលពាក្យបណ្ដឹងទាមទារប្រមូលបំណុលត្រូវបានបញ្ជូនទៅកូនបំណុលទី ៣ ។

**គ-** ពេលដែលអាជ្ញាសាលាបានទទួលប្រាក់ពីការលក់តាមដីកាសម្រេចបង្គាប់ឱ្យលក់ ។

**ឃ-** ពេលអាជ្ញាសាលាបានទទួលការប្រគល់ចលនវត្ថុ ក្នុងករណីរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ ។

(កំណត់)

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 165 ។

មាត្រានេះកម្រិតនូវម្ចាស់បំណុលដែលត្រូវទទួលចំណែក ដោយគិតពេលវេលាដែលម្ចាស់បំណុលនោះបានរឹបអូស ឬ ទាមទារចំណែក ជាដើម ។ បើពង្រីកវិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែកនោះ ម្ចាស់បំណុលនៃការអនុវត្តនឹងបាត់ផលប្រយោជន៍ខ្លួន ហេតុនេះហើយ ការអនុវត្តចំពោះសិទ្ធិលើបំណុលនឹងអាចបាត់តម្លៃ ។ ឧទាហរណ៍ ពេលដែលម្ចាស់បំណុលនៃការអនុវត្តបានខំប្រឹងប្រែងធ្វើបណ្ដឹងទាមទារប្រមូលបំណុល ហើយបានឈ្នះក្ដីនោះ ប្រសិនបើទទួលស្គាល់ឱ្យម្ចាស់បំណុលផ្សេងទៀតដែលមានសិទ្ធិលើបំណុលតម្លៃខ្ពស់ អាចទាមទារចំណែកបាន នោះម្ចាស់បំណុលដែលបានខំប្រឹងប្រែងធ្វើបណ្ដឹងមិនអាចទទួលផលតាមការប្រឹងប្រែងរបស់ខ្លួនបាន ទៅជាចំណេញតែម្ចាស់បំណុលដែលអង្គុយចាំមើលពេលគេធ្វើបណ្ដឹងទៅវិញ ។ ហេតុនេះហើយ មាត្រានេះកម្រិតម្ចាស់បំណុលដែលអាចចូលរួមក្នុងការចែកចំណែកនោះ គឺមានន័យថាមិនឱ្យប្រើគោលការណ៍ស្មើភាពខ្លាំងពេកក្នុងករណីនេះ ។

Civil Execution Act (Japan)
**Article 165** (Obligees entitled to distribution and the like)
1. Obligees who have attached, provisionally attached or made a demand for distribution prior to the following times shall be entitled to dividends and the like:
  i. when the third-party obligor made a deposit according to the provisions of Article 156, paragraph 1 or 2;
  ii. when the complaint of an action for collection was served on the third party obligor;
  iii. when the execution officer received the proceeds from an order of sale;
  iv. When the execution officer received the movables in cases of attachment of a claim right to deliver the movables.

**មាត្រា ៤១៦.-** ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេង ក្រៅពីអចលនវត្ថុ នាវា ចលនវត្ថុ និង សិទ្ធិលើបំណុល ត្រូវអនុវត្តតាមវិធីអនុវត្តចំពោះសិទ្ធិលើបំណុល លើកលែងតែមានបញ្ញត្តិពិសេស ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 167 កថាខណ្ឌទី 1 ។

មាត្រានេះចែងអំពីនីតិវិធីអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិ ក្រៅពីអចលនវត្ថុ នាវា ចលនវត្ថុ និង សិទ្ធិលើបំណុល (ហៅថា "សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត") ។ តាមច្បាប់ជប៉ុន សិទ្ធិលើទ្រព្យសម្បត្តិផ្សេងនោះ មានដូចជា សិទ្ធិជួល សិទ្ធិនិពន្ធ សិទ្ធិប្រកាសនីយប័ត្រតក្កកម្ម សិទ្ធិជាសមាជិកនៃក្រុមហ៊ុន សិទ្ធិទាមទារឱ្យប្រគល់នាវា ឬ អចលនវត្ថុ ជាដើម ។ ប្រសិនបើគ្មានបញ្ញត្តិពិសេសទេ ការអនុវត្តចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀតនោះ ត្រូវធ្វើតាមវិធីអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល (ការប្តូរជាប្រាក់ ត្រូវធ្វើតាមការបង្គាប់ឱ្យលក់) ។ ប៉ុន្តែ ការអនុវត្តភាគច្រើនខុសៗគ្នាទៅតាមប្រភេទនៃសិទ្ធិលើទ្រព្យសម្បត្តិនីមួយៗ ។ ឧទាហរណ៍ ចំពោះសិទ្ធិលើទ្រព្យសម្បត្តិ ដែលមិនអាចមានកូនបំណុលទី ៣ ដូចជាសិទ្ធិប្រកាសនីយប័ត្រតក្កកម្ម ជាដើម អានុភាពនៃការរឹបអូសមិនមែនកើតឡើង នៅពេលធ្វើការបញ្ជូនទៅកូនបំណុលទី ៣ ទេ (កថាខណ្ឌទី ៧ នៃមាត្រា ៤០៣ (ដីកាសម្រេចរឹបអូស)) គឺនឹងកើតឡើង នៅពេលធ្វើការបញ្ជូនទៅកូនបំណុលនៃការអនុវត្តវិញ ។ ម្យ៉ាងទៀត ចំពោះសិទ្ធិលើទ្រព្យសម្បត្តិដែលត្រូវចុះបញ្ជី ជាដើម ត្រូវតែមានការផ្ទុកផ្តាក់ឱ្យចុះបញ្ជីស្តីពីការរឹបអូស ដូចអចលនវត្ថុដែរ ។ ចំពោះនីតិវិធីជាក់ស្តែងនីមួយៗ តុលាការត្រូវចាត់ចែង តាមប្រភេទនៃសិទ្ធិលើទ្រព្យសម្បត្តិនីមួយៗនោះ ដោយគិតពិចារណានូវបញ្ញត្តិស្តីពីការអនុវត្ត ចំពោះសិទ្ធិលើបំណុល ។

Civil Execution Act (Japan)
**Article 167** (Compulsory execution against any other property rights) (excerpt)
1. Except as otherwise provided, compulsory execution against a property right other than immovables, ships, movables and obligation-rights (hereinafter referred to as "any other property right" in this Article) shall follow the example of execution against an obligation-right.

## ផ្នែកទី ៤ ការអនុវត្តចំពោះអចលនវត្ថុ

### កថាភាគទី ១ កម្មវត្ថុនៃការអនុវត្តចំពោះអចលនវត្ថុ ស្ថាប័នអនុវត្ត វិធីអនុវត្ត វិធីរឹបអូស មធ្យោបាយប្រកាសជាសាធារណៈ និង ការចាត់ចែងការរក្សាការពារ

**មាត្រា ៤១៧.-** កម្មវត្ថុ និង វិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

១- នៅផ្នែកទី ៤ នេះ អចលនវត្ថុសំដៅទៅលើដី អាគារដែលត្រូវបានចុះបញ្ជី ចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬ អាគារនោះ សិទ្ធិជួលអចិន្ត្រៃយ៍និងផលុបភោគដែលត្រូវបានចុះបញ្ជី និង ចំណែកនៃសិទ្ធិទាំងនេះដែលជាសិទ្ធិរួម ។

២- ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ត្រូវធ្វើតាមវិធីលក់ដោយបង្ខំ ។

៣- ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ត្រូវភ្ជាប់ជាមួយឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត និង ឯកសារខាងក្រោមនេះ :

- **ក**- ចំពោះអចលនវត្ថុដែលត្រូវបានចុះបញ្ជី ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជី និង ក្នុងករណីដែលជនដទៃក្រៅពីកូនបំណុលនៃការអនុវត្ត ត្រូវបានចុះនៅក្នុងសៀវភៅចុះបញ្ជី ថាជាកម្មសិទ្ធិករ ឯកសារដែលបញ្ជាក់ថា អចលនវត្ថុនោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។
- **ខ**- ចំពោះដីដែលមិនបានចុះបញ្ជី ឯកសារដែលបញ្ជាក់ថា ដីនោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។

（កំណត់）

(1) សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 43 និង បទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 23 ។

(2) កថាខណ្ឌទី ១ នៃមាត្រានេះបំភ្លឺថា កម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ មានដី ចំណែកនៃសហកម្មសិទ្ធិលើដី សិទ្ធិជួលអចិន្ត្រៃយ៍ និង ផលុបភោគដែលត្រូវបានចុះបញ្ជី ព្រមទាំងចំណែកនៃសិទ្ធិទាំងនេះ ។ អាគារជាសមាសភាគនៃកម្មសិទ្ធិលើដី ឬ សមាសភាគនៃសិទ្ធិប្រត្យក្សដែលជាសិទ្ធិប្រើប្រាស់ដី（សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ）（សូមមើលក្រមរដ្ឋប្បវេណី） ហេតុដូច្នេះ ពុំអាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំដោយឯកឯងបានទេ ។ អានុភាពនៃការអនុវត្តដោយបង្ខំដែលយកកម្មសិទ្ធិលើដី ឬ សិទ្ធិប្រត្យក្សដែលជាសិទ្ធិប្រើប្រាស់ដី ជាកម្មវត្ថុ មានទៅលើអាគារ ដែលជាសមាសភាគនៃសិទ្ធិទាំងនេះ（មាត្រា ៤២១（អានុភាពនៃការរឹបអូស）） ហើយអាគារក៏ត្រូវបានលក់ដោយបង្ខំជាមួយនឹងសិទ្ធិប្រើប្រាស់ដីដែរ ។

(3) យើងបានទទួលព័ត៌មានថា នៅទីក្រុងភ្នំពេញ ជាដើម កម្មសិទ្ធិឯកជននៃដីធ្លីមិនត្រូវបានទទួលស្គាល់ តែមានករណីដែលកម្មសិទ្ធិឯកជននៃអាគារត្រូវបានទទួលស្គាល់ ហើយត្រូវបានចុះបញ្ជី ។ ហេតុដូច្នេះ យើងរៀបចំបញ្ញត្តិស្តីពីនីតិវិធីលក់ដោយបង្ខំដែលយកអាគារបែបនេះមកជាកម្មវត្ថុ ។

<u>Civil Execution Act (Japan)</u>
**Article 43** (Method of execution against immovables)
1. Compulsory execution on an immovable (except for fixtures on land for which registration may not be made; hereinafter, the same exception shall apply throughout this Section) shall be carried out by way of compulsory sale by auction or compulsory administration (hereinafter referred to as "execution against an immovable"). These methods may be used in conjunction with each other.
2. With regard to execution under an obligation-right, the subject matter of which is the payment of money, shares in an immovable, a registered superficies or an emphytensis and shares of such rights shall be deemed immovables.

**មាត្រា ៤១៨.-** តុលាការអនុវត្ត

ក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ តុលាការដែលបានកំណត់ខាងក្រោមនេះ គឺជាតុលាការអនុវត្តដែលមានសមត្ថកិច្ច :

**ក-** បើយកដី ឬ អាគារដែលបានចុះបញ្ជី ជាកម្មវត្ថុ គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនោះ ។

**ខ-** បើយកចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬ លើអាគារដែលបានចុះបញ្ជី ឬ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគដែលបានចុះបញ្ជី ឬ ចំណែកនៃសិទ្ធិទាំងនេះដែលជាសិទ្ធិរួមជាកម្មវត្ថុ គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលត្រូវចុះបញ្ជី ។

(កំណត់)

(1) សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 44 ។

Civil Execution Act (Japan)
**Article 44** (Execution court)
1. With regard to execution against an immovable, the district court which has jurisdiction over the place of the immovable (or with regard to an immovable according to the provisions of the preceding Article, paragraph 2, the place of its registration) shall be the execution court.
2. In cases where a building is located within the jurisdiction of several district courts, each district court which has jurisdiction over the land on which the building is located shall have jurisdiction as the execution court concerning such building; and a district court which has jurisdiction over the land or a district court to which a motion for execution concerning the building has been made shall have jurisdiction for execution concerning the land.
3. In the cases referred to in the preceding paragraph, the execution court, if it deems necessary, may transfer the case to another court which has jurisdiction.
4. No complaint may be laid against the ruling referred to in the preceding paragraph.

**មាត្រា ៤១៩.-** ដីកាសម្រេចចាប់ផ្តើម ជាអាទិ៍

១- នៅពេលចាប់ផ្តើមនីតិវិធីនៃការលក់ដោយបង្ខំ តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ហើយត្រូវប្រកាសអំពីការរឹបអូសអចលនវត្ថុ ដើម្បីម្ចាស់បំណុលនៃការអនុវត្ត ក្នុងដីកាសម្រេចចាប់ផ្តើមនេះ ។

២- ដីកាសម្រេចចាប់ផ្តើមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត ។

៣- ចំពោះដីកាសម្រេចលើកចោលពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ អាចប្តឹងជំទាស់បាន ។

(កំណត់)

(1) សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 45 ។

(2) តុលាការអនុវត្តដែលបានទទួលពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ត្រូវចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ក្នុងករណីដែលមានល័ក្ខខ័ណ្ឌត្រឹមត្រូវដើម្បីទទួលស្គាល់ពាក្យសុំនោះ ចំណែកឯក្នុងករណីដែលខ្វះល័ក្ខខ័ណ្ឌ តុលាការអនុវត្តត្រូវលើកចោលពាក្យសុំនោះ ។

(3) ចំពោះដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ មិនអាចប្ដឹងជំទាស់ទៅតុលាការជាន់ខ្ពស់បានទេ គ្រាន់តែអាចដាក់ពាក្យសុំតវ៉ាចំពោះតុលាការអនុវត្តប៉ុណ្ណោះ ។ នេះមកពីបារម្ភថា បណ្ដឹងជំទាស់នឹងត្រូវបំពានក្នុងគោលបំណងពន្យារការអនុវត្ត បើអនុញ្ញាតឱ្យធ្វើបណ្ដឹងជំទាស់ក្នុងជំហាននេះ ។ កាលបើនីតិវិធីនៃការលក់ដោយបង្ខំមានដំណើរទៅមុខ ហើយដីកាសម្រេចអនុញ្ញាតឱ្យលក់ត្រូវបានចេញចំពោះអ្នកទិញ គេអាចប្ដឹងជំទាស់ចំពោះដីកាសម្រេចនេះបាន (មាត្រា ៤៤៤ (បណ្ដឹងជំទាស់ចំពោះដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់)) ។

<u>Civil Execution Act (Japan)</u>
**Article 45** (Ruling of commencement)
1. In order to commence proceedings for a compulsory sale by auction, the execution court shall render a ruling for commencement of compulsory sale by auction and declare in such ruling that the immovable shall be attached for the obligee.
2. Such ruling of commencement shall be served on the obligor.
3. A kōkoku-appeal concerning execution may be filed against a decision dismissing a motion for compulsory sale by auction.

## **មាត្រា ៤២០.-** ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូស ជាអាទិ៍

១- បើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំត្រូវបានចេញ ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី អំពីការរឹបអូសដែលពាក់ព័ន្ធនឹងដីកាសម្រេចចាប់ផ្ដើមនោះជាបន្ទាន់ ។

២- បើបានធ្វើការចុះបញ្ជីអំពីការរឹបអូសដោយផ្អែកលើការផ្ទុកផ្ដាក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ស្ថាប័នដែលមានសមត្ថកិច្ចត្រូវផ្ញើឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីនោះទៅក្រឡាបញ្ជី ។

(កំណត់)

(1) សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 48 ។

(2) បើដីមិនទាន់ចុះបញ្ជីត្រូវបានចាប់ផ្ដើមលក់ដោយបង្ខំ ស្ថាប័នដែលមានសមត្ថកិច្ច ជាបឋម ត្រូវចុះបញ្ជីនូវសញ្ញាណដីនោះ និង ចុះបញ្ជីរក្សាទុកកម្មសិទ្ធិដីនោះ ហើយត្រូវចុះបញ្ជីអំពីការរឹបអូស ។

<u>Civil Execution Act (Japan)</u>
**Article 48** (Registration of attachment)
1. If a ruling of commencement of compulsory sale by auction is rendered, the court clerk shall immediately entrust the registrar to register the attachment.
2. When the registrar has registered the attachment by entrustment according to the provisions of the preceding paragraph, he shall send a transcript of the register to the execution court.

## **មាត្រា ៤២១.-** អានុភាពនៃការរឹបអូស

១- អានុភាពនៃការរឹបអូសអចលនវត្ថុ មានទៅលើវត្ថុដែលភ្ជាប់នឹងអចលនវត្ថុ និង ជាផ្នែកមួយនៃអចលនវត្ថុនោះ ព្រមទាំងវត្ថុចំណុះនិងសិទ្ធិចំណុះនៃអចលនវត្ថុនោះ ។

២- អានុភាពនៃការរឹបអូស នឹងកើតឡើងនៅពេលដែលដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំត្រូវបានបញ្ជូន ទៅ

កូនបំណុលនៃការអនុវត្ត ។ ប៉ុន្តែ បើការចុះបញ្ជីអំពីការរឹបអូស ត្រូវបានធ្វើនៅមុនពេលបញ្ជូនដីកាសម្រេចចាប់ផ្តើមនោះ អានុភាពនោះនឹងកើតឡើងនៅពេលបានចុះបញ្ជី ។

៣- ការរឹបអូសពុំត្រូវរារាំងកូនបំណុលនៃការអនុវត្តក្នុងការប្រើប្រាស់ ឬ អាស្រ័យផលពីអចលនវត្ថុ តាមវិធីប្រើធម្មតាឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យបង់ថ្លៃឈ្នួលអចលនវត្ថុ ត្រូវបានរឹបអូស ដោយយោងតាមបញ្ញត្តិនៃមាត្រា ៥១៦ (ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ) និង ករណីដែលការចាត់ចែងរក្សាការពារត្រូវបានបង្គាប់ ដោយយោងតាមបញ្ញត្តិនៃមាត្រា ៤២៩ (ការចាត់ចែងការរក្សាការពារ) នៃក្រមនេះ ។

(កំណត់)

(1) សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 46 ច្បាប់ស្តីពីការលក់ឡាយឡុងដោយបង្ខំ និង ការគ្រប់គ្រងដោយបង្ខំនៃប្រទេសអាល្លឺម៉ង់ មាត្រា 21 និង ក្រមរដ្ឋប្បវេណីប្រទេសកម្ពុជា គន្ថីទី ៦ មាត្រា ៨៤៦ (ទំហំនៃអានុភាពហ៊ីប៉ូតែក) កថាខណ្ឌទី ១ ។

(2) កថាខណ្ឌទី ១ នៃមាត្រានេះ ចែងអំពីទំហំនៃវត្ថុដែលទទួលអានុភាពនៃការរឹបអូសអចលនវត្ថុ ។ "វត្ថុដែលភ្ជាប់នឹង និង ជាផ្នែកមួយនៃអចលនវត្ថុ" មានន័យថា គឺជាអាគារ ផលដែលមិនទាន់ផ្តាច់ចេញ ជាដើម ដែលជាសមាសភាគនៃកម្មសិទ្ធិលើដី ឬ សិទ្ធិប្រត្យក្សដែលជាសិទ្ធិប្រើប្រាស់ដី (សិទ្ធិជួលជាអចិន្ត្រៃយ៍ ឬ ផលុបភោគ) ។ "វត្ថុចំណុះ (នៃអចលនវត្ថុ)" មានន័យថា គឺជាវត្ថុចំណុះនៃអចលនវត្ថុ ឬ វត្ថុចំណុះនៃអាគារដែលជាសមាសភាគនៃអចលនវត្ថុនោះ (ឧទាហរណ៍ : គ្រឿងអាគារ) ហើយ "សិទ្ធិចំណុះ (នៃអចលនវត្ថុ)" មានឧទាហរណ៍ដូចជាសេវភាពដែលកូនបំណុលនៃការអនុវត្តមានចំពោះដីដែលជាកម្មវត្ថុនៃការរឹបអូស ។

(3) កថាខណ្ឌទី ២ នៃមាត្រានេះ ចែងថា អានុភាពនៃការរឹបអូស នឹងកើតឡើងនៅពេលណាមួយមុនគេ រវាងពេលដែលដីកាសម្រេចចាប់ផ្តើមត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្ត និង ពេលដែលបានចុះបញ្ជីអំពីការរឹបអូស ។ ប៉ុន្តែ តាមការជាក់ស្តែង គួរតែឱ្យបញ្ចប់ការចុះបញ្ជីអំពីការរឹបអូសជាមុន ដោយគិតពិចារណាថា ការចុះបញ្ជីជាល័ក្ខខ័ណ្ឌដើម្បីយកអានុភាពនៃការរឹបអូសតតាំងចំពោះតតិយជន (មានន័យថា គួរតែបញ្ជូនដីកាសម្រេចចាប់ផ្តើម ក្រោយពីបានបញ្ជាក់ការបញ្ចប់ការចុះបញ្ជី) ។ តាមការអនុវត្តជាក់ស្តែងនៅប្រទេសជប៉ុន គេអនុវត្តដូច្នេះ ។

(4) កថាខណ្ឌទី ៣ នៃមាត្រានេះ ចែងថា ជាគោលការណ៍ ទោះជានីតិវិធីនៃការលក់អចលនវត្ថុដោយបង្ខំត្រូវបានចាប់ផ្តើមហើយក៏ដោយ ក៏កូនបំណុលនៃការអនុវត្ត (កម្មសិទ្ធិករ) អាចបន្តការប្រើប្រាស់ និង អាស្រ័យផលពីអចលនវត្ថុ រហូតដល់ពេលលក់ (ពេលអ្នកទិញបង់ថ្លៃលក់) បានដែរ ។ ប៉ុន្តែ មានករណីលើកលែង ដូចជាក្នុងករណីដែលថ្លៃឈ្នួលត្រូវបានរឹបអូស ដោយម្ចាស់បំណុលនៃការអនុវត្ត ឬ ការចាត់ចែងរក្សាការពារត្រូវបានបង្គាប់ការប្រើប្រាស់ និង អាស្រ័យផលដោយកូនបំណុលនៃការអនុវត្ត ត្រូវបានកម្រិត ។

(5) ការប្រើប្រាស់ និង អាស្រ័យផល តាម "វិធីប្រើធម្មតា" មានន័យថា ជាការប្រើប្រាស់អចលនវត្ថុដោយខ្លួនឯង ឬ ការទទួលថ្លៃឈ្នួលនៃអចលនវត្ថុដែលខ្លួនបានជួលឱ្យគេហើយ (ឬ បានបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ) ជាដើម ។ ការជួលអចលនវត្ថុឱ្យគេជាថ្មី (ឬ ការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគជាថ្មី) នៅក្រោយការរឹបអូស ពុំត្រូវនឹងបញ្ញត្តិនេះទេ ។

Civil Execution Act (Japan)
**Article 46** (Effective date of attachment)
1. Attachment shall become effective when the ruling of commencement of compulsory sale by auction is served on the obligor; provided, that in cases where the registration of attachment is made before service of the ruling of commencement, the attachment shall become effective when such registration is made.
2. Attachment shall not prevent the obligor from using or earning profits from the immovable in an ordinary manner.

ក្រមរដ្ឋប្បវេណី (កម្ពុជា)
**មាត្រា ៨៤៦** ទំហំនៃអានុភាពហ៊ីប៉ូតែក
១-ហ៊ីប៉ូតែកមានអានុភាពលើវត្ថុដែលភ្ជាប់នឹងដីដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក និង ជាផ្នែកមួយនៃដីដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកនោះ នៅពេលបង្កើតហ៊ីប៉ូតែក រួមទាំងអាគារដែលមាននៅលើដីហ៊ីប៉ូតែកនោះ ។ អានុភាពនេះក៏មានលើវត្ថុ ដែលត្រូវបានភ្ជាប់នៅក្រោយពេលបង្កើតហ៊ីប៉ូតែកផងដែរ ។
២-ភាគីពុំអាចកំណត់ផ្សេងពីបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ នៅក្នុងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកបានឡើយ ។

**មាត្រា ៤២២.-** ការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក និង ការផ្លាស់ប្តូរពេលកំណត់នោះ
១- ក្នុងករណីដែលអានុភាពនៃការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ បានកើតឡើង តុលាការអនុវត្តត្រូវកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ដោយគិតពិចារណានូវអំឡុងពេលចាំបាច់ដើម្បីធ្វើឯកសារលំអិតអំពីវត្ថុ លើកលែងតែករណីដែលបានចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំត្រួតគ្នា ដោយយោងតាមកថាខណ្ឌទី ១ នៃមាត្រា ៤២៤ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា) នៃក្រមនេះ ។
២- នៅពេលដែលពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកត្រូវបានកំណត់ តុលាការអនុវត្តត្រូវប្រកាសជាសាធារណៈអំពីការណ៍ដែលដីកាសម្រេចចាប់ផ្តើមត្រូវបានចេញ និង អំពីពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ហើយត្រូវដាស់តឿនឱ្យជនដែលបានកំណត់ខាងក្រោមនេះ រាយការណ៍ទៅតុលាការអនុវត្ត អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិលើបំណុល និង មូលហេតុនិងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនោះ នៅមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក :

**ក-** ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន នៅមុនការចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំដំបូងចំពោះអចលនវត្ថុនោះ ។

**ខ-** ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគដែលត្រូវបានចុះបញ្ជី នៅមុនការចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំដំបូង ចំពោះអចលនវត្ថុនោះ ។

**គ**- ស្ថាប័នដែលមានសមត្ថកិច្ចលើពន្ធដារ ឬ អាករសាធារណៈផ្សេងទៀត ។

៣- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ តុលាការអនុវត្តត្រូវដាស់តឿនចំពោះជនដែលបានកំណត់នៅក្នុងចំណុច **ខ** នៃកថាខណ្ឌទី ២ អំពីចំណុចដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

**ក**- ការរាយការណ៍អំពីអត្ថិភាព ឬ នត្ថិភាពនៃឆន្ទៈអនុវត្តសិទ្ធិប្រាតិភោគ នៅមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ។

**ខ**- កិច្ចដែលត្រូវដាក់ពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ នៅមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ក្នុងករណីដែលមានឆន្ទៈអនុវត្តសិទ្ធិប្រាតិភោគ ។

៤- បើមិនបានចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកទេ តុលាការអនុវត្តអាចផ្លាស់ប្តូរពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកបាន ។

៥- បើបានផ្លាស់ប្តូរពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៤ ខាងលើនេះ តុលាការអនុវត្តត្រូវប្រកាសជាសាធារណៈអំពីការផ្លាស់ប្តូរនោះ ។

(កំណត់)

(1) សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 49 និង មាត្រា 52 ។

(2) មាត្រា 52 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន កំណត់ថា បើមិនបានចេញដីកាសម្រេចអនុញ្ញាតឱ្យលក់នៅក្នុងអំឡុងពេល ៣ ខែ គិតចាប់ពីកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកទេ កំណត់ពេលចុងក្រោយនោះ ត្រូវពន្យារ ៣ ខែទៅមុខទៀត ដោយស្វ័យប្រវត្តិ ប៉ុន្តែ ក្រមនេះមានគម្រោងសម្រួល និងសម្របតាមកាលៈទេសៈ ។ មាត្រា ៤៥៨ (ការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក និងការផ្លាស់ប្តូរពេលកំណត់នោះ) អំពីការអនុវត្តចំពោះនាវា ក៏មានគោលបំណងដូចគ្នាដែរ ។

(3) ចំណុច **ខ** កថាខណ្ឌទី ២ នៃមាត្រានេះ ទាមទារឱ្យម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគប្រត្យក្សដែលត្រូវបានចុះបញ្ជីនៅមុនការចាប់ផ្តើមការលក់ដោយបង្ខំ រាយការណ៍អំពីសិទ្ធិលើបំណុលនោះ ដោយសារសិទ្ធិប្រាតិភោគប្រត្យក្សដូចនេះ ពុំរលត់ដោយការលក់ដោយបង្ខំទេ គឺ ត្រូវបានទទួលដោយអ្នកទិញ (កថាខណ្ឌទី ១ នៃមាត្រា ៥១០ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគ)) ហើយតម្លៃលក់អប្បបរមានៃអចលនវត្ថុ ទទួលឥទ្ធិពលពីចំនួនប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគប្រត្យក្សនោះ ហេតុដូច្នេះ តុលាការអនុវត្តចាំបាច់ត្រូវយល់ដឹងនូវចំនួនប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានា ដែលជាមូលដ្ឋានដើម្បីសម្រេចតម្លៃលក់អប្បបរមា (អ្នកមានបំណងទិញក៏ចាំបាច់ដឹងអំពីចំនួនប្រាក់ដែលខ្លួននឹងទទួលបន្ទុកពិតប្រាកដ ដោយសារការទទួលបន្តសិទ្ធិប្រាតិភោគប្រត្យក្សនោះ) ។

(4) ចំណុច **គ** កថាខណ្ឌទី ២ នៃមាត្រានេះ គឺជាបញ្ញត្តិដែលទាមទារឱ្យស្ថាប័នដែលមានសមត្ថកិច្ចលើពន្ធដារ ឬ អាករសាធារណៈផ្សេងទៀត រាយការណ៍អំពីសិទ្ធិលើបំណុលពន្ធដារ ជាអាទិ៍ ។ បញ្ញត្តិនេះមានទំនាក់ទំនងជិតស្និទ្ធ ជាមួយនឹងការចាត់ចែងសិទ្ធិលើបំណុលពន្ធដារតាមច្បាប់សារធាតុ (អត្ថិភាព ឬ នត្ថិភាពនៃអាទិភាពជាងសិទ្ធិលើ បំណុលឯកជនទូទៅ និង សិទ្ធិប្រាតិភោគប្រត្យក្ស) និង រចនាសម្ព័ន្ធនៃនីតិវិធីដើម្បីប្រមូលពន្ធដារ ។ ហេតុដូច្នេះ នៅពេលប្រព័ន្ធច្បាប់នៃប្រទេសកម្ពុជាដែលទាក់ទងនឹងសិទ្ធិលើបំណុលពន្ធដារ ត្រូវបានរៀបចំឡើងឱ្យមានលក្ខណៈ ពេញលេញ នាពេលអនាគត អាចត្រូវពិចារណាឡើងវិញថា តើត្រូវរក្សាទុកនូវបញ្ញត្តិនៃមាត្រានេះ ឬ តើត្រូវបន្ថែម បញ្ញត្តិដែលអនុញ្ញាតឱ្យទាមទារឱ្យចែកចំណែក ចំពោះសិទ្ធិលើបំណុលពន្ធដារ នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤២៦ (ការទាមទារឱ្យចែកចំណែក) ឬទេ ជាដើម ។

នៅប្រទេសជប៉ុន បញ្ញត្តិទាំងនេះចែងនៅក្នុងច្បាប់ស្តីពីការប្រមូលរដ្ឋាករ (ហើយពុំមែនតែរដ្ឋាករតែប៉ុណ្ណោះទេ ការ ប្រមូលពន្ធភូមិភាគ និង ប្រាក់ធានារ៉ាប់រងសង្គមកិច្ច ជាដើម ក៏ចែងដោយបញ្ញត្តិនៃច្បាប់ដូចគ្នានេះដែរ) ។ ជាបឋម សិទ្ធិលើបំណុលពន្ធដារចាត់ទុកថា មានអាទិភាពជាងសិទ្ធិលើបំណុលឯកជនទូទៅ ហើយចាត់ទុកថា មានអាទិភាព ដោយមានកម្រិតដែលបានកំណត់ ជាងសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគប្រត្យក្ស ដូចជា ហ៊ីប៉ូតែក ជាអាទិ៍ ដែរ (ច្បាប់ស្តីពីការប្រមូលរដ្ឋាករ មាត្រា 8 មាត្រា 9 និង ចាប់ពីមាត្រា 15) ។ ម្យ៉ាងទៀត ស្ថាប័នដែលមានសមត្ថកិច្ចអាចប្រមូលដោយបង្ខំនូវសិទ្ធិលើបំណុលពន្ធដារនេះ តាមនីតិវិធីចាត់ចែង ចំពោះពន្ធតឹងទារ (arrears, delinquency) (នីតិវិធីដូចការអនុវត្តដោយបង្ខំ) ដោយពុំចាំបាច់ផ្អែកលើលិខិតអនុវត្តទេ (ច្បាប់ដូចគ្នា ចាប់ពីមាត្រា 47) ។ ថែមទៅទៀតនោះ ដើម្បីទទួលការចែកចំណែក ចំពោះសិទ្ធិលើបំណុលពន្ធដារ ក្នុងនីតិវិធីនៃ ការអនុវត្តដោយបង្ខំដែលបានចាប់ផ្តើមរួចហើយ ដើម្បីសម្រេចសិទ្ធិលើបំណុលឯកជន ស្ថាប័នដែលមានសមត្ថកិច្ច ប្រមូល ចាំបាច់ត្រូវធ្វើនីតិវិធីហៅថាការទាមទារឱ្យប្រគល់ (ច្បាប់ដូចគ្នា ចាប់ពីមាត្រា 82) ។ បើនីតិវិធីនេះ ត្រូវបានអនុវត្ត ត្រូវចាត់ទុកដូចគ្នានឹងករណីដែលមានការទាមទារឱ្យចែកចំណែក ចំពោះសិទ្ធិលើបំណុលឯកជនដែរ ។ ក្រៅពីនេះ ក្នុងករណីដែលមានការប្រជែងរវាងការចាត់ចែងចំពោះពន្ធតឹងទារ និង ការអនុវត្តដោយបង្ខំ ចំពោះ ទ្រព្យសម្បត្តិដូចគ្នាតែមួយ ត្រូវអនុវត្តតាមបញ្ញត្តិនៃច្បាប់ពិសេស (នីតិវិធីស្តីអំពីការសម្រួលនីតិវិធីនៃការចាត់ចែង ចំពោះពន្ធតឹងទារ និង ការអនុវត្តដោយបង្ខំ ជាអាទិ៍) ។

(5) ចំពោះប្រទេសកម្ពុជា យើងក៏ចាំបាច់ត្រូវគិតពិចារណាអំពីការអនុវត្តតាមច្បាប់សារធាតុចំពោះសិទ្ធិលើបំណុលពន្ធដារ និង ប្រព័ន្ធនៃនីតិវិធីប្រមូលដោយបង្ខំដែរ ។ ជាបឋម ដើម្បីរៀបចំបញ្ញត្តិយ៉ាងតិចបំផុតដែលឱ្យស្ថាប័នដែលមាន សមត្ថកិច្ចអាចទទួលការចែកចំណែក នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំដែលម្ចាស់បំណុលទូទៅ ឬ ម្ចាស់សិទ្ធិ ប្រាតិភោគបានចាប់ផ្តើម យើងអាចបន្ថែមបញ្ញត្តិដែលចែងថា អាចទាមទារឱ្យចែកចំណែកបាន ចំពោះសិទ្ធិលើបំណុល ពន្ធដារ នៅក្នុងមាត្រា ៤២៦ (ការទាមទារឱ្យចែកចំណែក) ខាងក្រោយ ។

(6) ក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដាក់ពាក្យសុំឱ្យធ្វើការលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគ ក្រោយ

ពេលបានចាប់ផ្ដើមនីតិវិធីនៃការលក់ដោយបង្ខំដែលជាការអនុវត្តដោយបង្ខំដោយម្ចាស់បំណុលធម្មតា តុលាការនឹងចេញដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា (មាត្រា ៥១១ (ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា នៃការអនុវត្តចំពោះអចលនវត្ថុ និង ការអនុវត្តសិទ្ធិប្រាតិភោគ) ។ ប៉ុន្តែ ក្នុងករណីនេះ ដោយសារល័ក្ខខ័ណ្ឌនៃការលក់នឹងប្រែប្រួល បើមានពាក្យសុំឱ្យលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគ នៅក្នុងដំណាក់កាលដែលនីតិវិធីនៃការអនុវត្តដោយបង្ខំមុននោះត្រូវបានធ្វើមួយចំនួនធំរួចមកហើយ តុលាការចាំបាច់ត្រូវធ្វើនីតិវិធី ដូចជាការធ្វើឯកសារលំអិតអំពីវត្ថុឡើងវិញជាដើម ហេតុដូច្នេះ មានការបារម្ភថា ដំណើការនៃនីតិវិធីលក់នោះនឹងមានភាពយឺតយ៉ាវ ។ ដើម្បីជៀសវាងបញ្ហានេះ កថាខណ្ឌទី ៣ នៃមាត្រានេះ មានគោលបំណងជម្រុញឱ្យម្ចាស់សិទ្ធិប្រាតិភោគអនុវត្តសិទ្ធិរបស់ខ្លួនឱ្យបានឆាប់ ។

Civil Execution Act (Japan)

**Article 49** (Public notice of ruling of commencement)

1. In cases where the attachment concerned in the ruling of commencement of compulsory sale by auction has become effective (except where another ruling of commencement of compulsory sale by auction or sale by auction has been rendered prior to the said ruling of commencement), the execution court shall fix the final date for demanding distribution, taking into consideration the period necessary to prepare specifications.

2. If the final date for demanding distribution is fixed, the court clerk shall give public notice of the fact that a ruling of commencement has been rendered and of the final date for demanding distribution, and shall summon the following persons to notify the execution court by the final date for demanding distribution as to whether an obligation-right (including interest and other incidental obligation-rights) exists or not, the grounds of the obligation-right and the amount thereof:

   i. obligees referred to in Article 87, paragraph 1 item iii

   ii. obligees referred to in Article 87, paragraph 1 item iv (with regard to holders of hypothecary certificates, such obligees are restricted to known holders)

   iii. government or public officials in charge of taxes or other public imposts.

3. The execution court, if it deems it especially necessary, may postpone the final date for demanding distribution.

4. In cases where the final date for demanding distribution has been postponed according to the provisions of the preceding paragraph, the court clerk shall give public notice of the new final date thereof.

**Article 52** (Alteration of final date for demanding distribution)

In cases where no ruling granting permission for a sale has been rendered within three months from the final date for demanding distribution, or a ruling granting permission for sale rendered within three months has been annulled or has lost its effect, the final date for demanding distribution shall be deemed to be changed to a day three months from the said final date; provided, that in cases where the ruling granting permission for sale rendered within three months from the final date for demanding distribution has lost its effect, this shall not apply to a ruling granting permission for sale concerning an offer to buy from the next bidder which is rendered according to the provisions of Article 67 (excluded are cases where such ruling has been annulled or has lost its effect).

**មាត្រា ៤២៣.-** ករណីយកិច្ចរបស់ជនដែលត្រូវបានដាស់តឿនក្នុងការរាយការណ៍អំពីសិទ្ធិលើបំណុល

១- ជនដែលបានកំណត់នៅក្នុងចំណុច **ក ខ** ឬ **គ** នៃកថាខណ្ឌទី ២ មាត្រា ៤២២ (ការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក និង ការផ្លាស់ប្ដូរពេលកំណត់នោះ) នៃក្រមនេះ ដែលត្រូវបានដាស់តឿន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ឬ ទី ៣ នៃមាត្រា ៤២២ នោះ ត្រូវរាយការណ៍អំពីចំណុចដែលបានកំណត់នៅក្នុងសេចក្ដីដាស់តឿននោះ នៅមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ។

២- បើមានការផ្លាស់ប្ដូរចំនួនប្រាក់ដើមនៃសិទ្ធិលើបំណុល ដែលទាក់ទងនឹងសេចក្ដីរាយការណ៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ ជនដែលបានធ្វើសេចក្ដីរាយការណ៍នោះ ត្រូវរាយការណ៍អំពីការផ្លាស់ប្ដូរនោះ ។

៣- បើជនដែលត្រូវរាយការណ៍ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ពុំបានធ្វើសេចក្ដីរាយការណ៍នោះ ឬ បានធ្វើសេចក្ដីរាយការណ៍មិនពិត ដោយចេតនា ឬ ដោយមានកំហុស ជននោះត្រូវទទួលខុសត្រូវ

សងការខូចខាតដែលបានកើតឡើងដោយសារហេតុនោះ ។

(កំណត់)

(1) សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 50 ។

Civil Execution Act (Japan)
**Article 50** (Duty to give notice of obligation-right)
1. A person referred to in the preceding Article, paragraph 2 items i or ii who has been summoned according to the provisions of paragraph 2 of the said Article shall give notice requested in the summons.
2. If the amount of principal of the obligation-right covered by such notification has altered, a person who has given the notice referred to in the preceding paragraph, shall give notice of the alteration.
3. As to a person who is required to give notice according to the provisions of the preceding two paragraphs, if such person does not give such notice, either intentionally or negligently, or if he gives false notice, he shall be liable for damages thereby incurred.

**មាត្រា ៤២៤.-** ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា

១- បើមានពាក្យសុំឱ្យអនុវត្តដោយបង្ខំថ្មីទៀត ចំពោះអចលនវត្ថុដែលដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ត្រូវបានសម្រេចរួចហើយ ហើយបើទទួលស្គាល់ពាក្យសុំនោះ តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំថ្មីទៀត ។ ក្នុងករណីនេះ តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្តដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្តើមមុន ។

២- បើពាក្យសុំឱ្យលក់ដោយបង្ខំដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្តើមមុន ត្រូវបានដក ឬ នីតិវិធីនៃការលក់ដោយបង្ខំដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមមុន ត្រូវបានលុបចោល តុលាការអនុវត្តត្រូវបន្តនីតិវិធី ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំក្រោយ ។

៣- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំក្រោយនោះ ផ្អែកលើពាក្យសុំដែលបានដាក់ក្រោយពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក តុលាការអនុវត្តត្រូវកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកជាថ្មី ។ ក្នុងករណីនេះ តុលាការអនុវត្តមិនចាំបាច់ដាស់តឿនដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៤២២ (ការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក និង ការផ្លាស់ប្តូរពេលកំណត់នោះ) ចំពោះជនដែលបានធ្វើសេចក្តីរាយការណ៍ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤២៣ (ករណីយកិច្ចរបស់ជនដែលត្រូវបានដាស់តឿនក្នុងការរាយការណ៍អំពីសិទ្ធិលើបំណុល) នៃក្រមនេះឡើយ ។

៤- បើនីតិវិធីនៃការលក់ដោយបង្ខំដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមមុនត្រូវបានផ្អាក តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្តដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្តើមក្រោយ ។ ក្នុងករណីនេះ តុលាការអនុវត្តអាចចេញដីកាសម្រេចបន្តនីតិវិធី ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ក្រោយដែលផ្អែកលើពាក្យសុំឱ្យអនុវត្តដោយបង្ខំដែលបានធ្វើឡើងនៅមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកតាមពាក្យ

សុំ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការផ្លាស់ប្តូរនឹងកើតឡើងចំពោះចំណុចដែលបានកំណត់ពីចំណុចទី ១ ដល់ចំណុចទី ៣ មាត្រា ៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់) នៃក្រមនេះ បើការលក់ដោយបង្ខំដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្តើមមុនត្រូវបានលុបចោល ។

៥- បើមានដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះទៅឱ្យកូនបំណុលនៃការអនុវត្ត ។

៦- ចំពោះដីកាសម្រេចលើកចោលពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

(កំណត់)

(1) សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 47 និង បទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 25 ។

(2) មាត្រានេះចែងអំពីករណីដែលម្ចាស់បំណុលនៃការអនុវត្តផ្សេងទៀត បានដាក់ពាក្យសុំឱ្យលក់ដោយបង្ខំ ចំពោះអចលនវត្ថុដែលនីតិវិធីនៃការលក់ដោយបង្ខំត្រូវបានចាប់ផ្តើមរួចហើយ ។ ក្នុងករណីនេះ ចំពោះពាក្យសុំទី ២ តុលាការអនុវត្តក៏នឹងចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំដែរ ។ អត្ថន័យនៃដីកាសម្រេចក្រោយនេះ មិនប្លែកអំពីដីកាសម្រេចចាប់ផ្តើមមុន ហើយដីកាសម្រេចនោះត្រូវបញ្ជូនទៅកូនបំណុលនៃការអនុវត្ត និង នីតិវិធីនៃការចុះបញ្ជីអំពីការរឹបអូស ត្រូវអនុវត្ត ។

ក្នុងករណីដែលនីតិវិធីនៃការលក់ដោយបង្ខំដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមមុន មានដំណើរទៅមុខ នីតិវិធីនៃការលក់ក្រោយដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមទី ២ ពុំមានដំណើរទៅមុខទេ ហើយម្ចាស់បំណុលនៃការអនុវត្តដែលទទួលដីកាសម្រេចក្រោយនោះ ត្រូវបានចាត់ទុកដូចគ្នានឹងម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែកចំពោះរឿងក្តីមុនដែរ (ចំណុច ក នៃមាត្រា ៤៩៣ (វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក)) ។ ម្យ៉ាងទៀត ការដែលត្រូវជូនដំណឹងទៅឱ្យម្ចាស់បំណុលនៃការអនុវត្តដែលបានទទួលដីកាសម្រេចចាប់ផ្តើមទី ១ អំពីការណ៍ដែលមានដីកាសម្រេចចាប់ផ្តើមត្រួតគ្នានោះ គឺដោយសារមានការប៉ះពាល់ដល់ចំនួនប្រាក់ដែលម្ចាស់បំណុលនោះអាចទទួលចំណែក និង ដើម្បីផ្តល់ឱកាសរកមធ្យោបាយដោះស្រាយ ដូចជាការទាមទារឱ្យអនុវត្តដោយបង្ខំចំពោះទ្រព្យសម្បត្តិឯទៀត ជាដើម ។

ផ្ទុយទៅវិញ បើពាក្យសុំឱ្យលក់មុនត្រូវបានដក ឬ នីតិវិធីនៃការលក់មុនត្រូវបានលុបចោល ក្រោយមកនោះ នីតិវិធីនៃការលក់ ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមទី ២ ត្រូវបន្តដោយស្វ័យប្រវត្តិ (កថាខណ្ឌទី ២ នៃមាត្រានេះ, ក្នុងករណីដែលម្ចាស់បំណុលឯទៀតបានទាមទារឱ្យចែកចំណែកតែប៉ុណ្ណោះនោះ ពុំមានអានុភាពដូចនេះទេ) ។

ក្នុងករណីដែលនីតិវិធីមុនត្រូវបានផ្អាក តុលាការអនុវត្តត្រូវចេញដីកាសម្រេចបន្តនីតិវិធីនៃការលក់ ដោយផ្អែកលើពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានទទួលដីកាសម្រេចចាប់ផ្តើមទី ២ ហើយយោងតាមដីកាសម្រេចនេះ

នីតិវិធីនៃការលក់ត្រូវបន្ត (កថាខណ្ឌទី ៤ នៃមាត្រានេះ) ។ ប៉ុន្តែ ក្នុងករណីដែលផលុបភោគត្រូវបានបង្កើតឡើង ចំពោះអចលនវត្ថុ ក្រោយការចុះបញ្ជីអំពីការរឹបអូសដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមទី ១ តែមុននឹងការចុះបញ្ជី អំពីការរឹបអូសដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមទី ២ ផលុបភោគនោះពុំអាចតតាំងនឹងការរឹបអូសដោយផ្អែកលើ ដីកាសម្រេចចាប់ផ្តើមទី ១ ទេ តែអាចតតាំងនឹងការរឹបអូសដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមទី ២ បាន ។ បើ អចលនវត្ថុនោះត្រូវបានលក់ ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមទី ១ ផលុបភោគនេះត្រូវរលត់ តែក្នុងករណីដែល អចលនវត្ថុនោះត្រូវបានលក់ ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមទី ២ វិញ ផលុបភោគនៅមានអត្ថិភាព ហើយ អ្នកទិញត្រូវទទួលផលុបភោគនោះ ។ មានន័យថា ល័ក្ខខ័ណ្ឌនៃការលក់នឹងប្រែប្រួល អាស្រ័យតាមការលក់ដែល អនុវត្តដោយអានុភាពនៃដីកាសម្រេចចាប់ផ្តើមណាមួយ ។ ហេតុដូច្នេះ ការបន្តនីតិវិធីនៃការលក់តាមនីតិវិធី ក្រោយពុំត្រូវអនុញ្ញាតទេ គឺត្រូវរង់ចាំដំណោះស្រាយនីតិវិធីមុនដែលត្រូវបានផ្អាក (វាក្យខណ្ឌទី ៣ នៃកថាខណ្ឌទី ៤ មាត្រានេះ) ។

Civil Execution Act (Japan)
**Article 47** (Double rulings of commencement)
1. In cases where a motion for compulsory sale by auction is made concerning an immovable with regard to which a ruling of commencement of compulsory sale by auction or sale by auction as execution of a security right (hereinafter referred to as "sale by auction" in this Section) has been made, the execution court shall again render a ruling of commencement of compulsory sale by auction.
2. In cases where a motion for compulsory sale by auction or sale by auction concerning a former ruling of commencement has been withdrawn or the procedure of compulsory sale by auction or sale by auction concerning a former ruling of commencement has been annulled, the execution court shall continue the procedure on the basis of the latter ruling of commencement of compulsory sale by auction.

**មាត្រា ៤២៥.-** ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តចំពោះអចលនវត្ថុ

បញ្ញត្តិចាប់ពីកថាខណ្ឌទី ១ ដល់កថាខណ្ឌទី ៣ នៃមាត្រា ៤២៤ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលមានពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដែលដីកាសម្រេច ចាប់ផ្តើមការលក់ដោយបង្ខំ ដែលជាការអនុវត្តសិទ្ធិប្រាតិភោគ ត្រូវបានចេញរួចហើយ ។

(កំណត់)

(1) សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 47 និង បទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 25 ។

(2) ក្នុងករណីដែលមានពាក្យសុំឱ្យអនុវត្តដោយបង្ខំ ចំពោះអចលនវត្ថុដែលការលក់ដោយបង្ខំដែលជានីតិវិធីអនុវត្តសិទ្ធិ ប្រាតិភោគ បានចាប់ផ្តើមរួចហើយ តុលាការអនុវត្តនឹងចេញដីកាសម្រេចចាប់ផ្តើមត្រួតគ្នា ហើយជាគោលការណ៍ ត្រូវជម្រុញនីតិវិធីនៃការលក់ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមទី ១ តែក្នុងករណីដែលពាក្យសុំដែលទាក់ទងនឹង ដីកាសម្រេចចាប់ផ្តើមទី ១ ត្រូវបានដក ឬ នីតិវិធីនៃការលក់ត្រូវបានលុបចោល ក្រោយមកនោះ នីតិវិធីនៃការលក់

ត្រូវបន្តដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមទី ២ ដូចករណីនៃមាត្រា ៤២៤ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា) ដែរ ។ ប៉ុន្តែ បញ្ញត្តិចាប់ពីកថាខណ្ឌទី ៤ នៃមាត្រា ៤២៤ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា) ពុំត្រូវយកមកអនុវត្តឡើយ ។ នេះគឺ ក្នុងនីតិវិធីនៃការលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគ សិទ្ធិប្រាតិភោគដែលជាមូលដ្ឋាននៃការអនុវត្តនោះ និង សិទ្ធិប្រត្យក្សដែលពុំអាចតតាំងនឹងសិទ្ធិប្រាតិភោគនោះ ត្រូវរលត់ រីឯក្នុងនីតិវិធីនៃការលក់ដោយបង្ខំ តាមការអនុវត្តដោយបង្ខំ ជាគោលការណ៍ អ្នកទិញត្រូវទទួលនូវសិទ្ធិប្រត្យក្សដែលមានអត្ថិភាពលើអចលនវត្ថុនោះ (មាត្រា ៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់)) ហេតុដូច្នេះ ល័ក្ខខ័ណ្ឌនៃការលក់នឹងប្រែប្រួល រវាងនីតិវិធីទី ១ និង នីតិវិធីទី ២ ។

Civil Execution Act (Japan)
**Article 47** (Double rulings of commencement) > *see the note for Article 424*

## មាត្រា ៤២៦.- ការទាមទារឱ្យចែកចំណែក

១- ជនដែលបានកំណត់ខាងក្រោមនេះ អាចទាមទារឱ្យចែកចំណែកបាន :

**ក-** ម្ចាស់បំណុលដែលមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលអាចអនុវត្តដោយបង្ខំបាន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៣៥៤ (ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្តល់រូបមន្តអនុវត្ត) នៃក្រមនេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគប្រត្យក្សដែលនឹងបន្តអត្ថិភាព ក្រោយការលក់អចលនវត្ថុ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់) នៃក្រមនេះ ។

**ខ-** ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសបណ្តោះអាសន្ន នៅក្រោយពេលចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ។

**គ-** ម្ចាស់បំណុលដែលបានបញ្ជាក់ដោយឯកសារថា មានឯកសិទ្ធិទូទៅ ។

២- ការទាមទារឱ្យចែកចំណែកត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរដោយសរសេរនូវមូលហេតុ និង ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល ដោយរួមបញ្ចូលទាំងការប្រាក់ និង សិទ្ធិលើបំណុលបន្ទាប់បន្សំឯទៀត ។

៣- បើមានការទាមទារឱ្យចែកចំណែក តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត ។

៤- ចំពោះដីកាសម្រេចលើកចោលការទាមទារឱ្យចែកចំណែក អាចប្តឹងជំទាស់បាន ។

(កំណត់)

(1) សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 51 និង បទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន

មាត្រា 26 និង មាត្រា 27 ។

(2) ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគប្រត្យក្សដែលនឹងបន្តអត្ថិភាពក្រោយការលក់អចលនវត្ថុ ពុំអាចទាមទារឱ្យចែកចំណែក នៅក្នុងនីតិវិធីលក់អចលនវត្ថុដោយបង្ខំទេ ។ ទោះបីម្ចាស់បំណុលនោះមានលិខិតអនុវត្តអំពីសិទ្ធិលើបំណុលដែលត្រូវបានធានាក៏ដោយ ក៏ម្ចាស់បំណុលនោះពុំអាចទាមទារឱ្យចែកចំណែក ក្នុងនាមជាម្ចាស់បំណុលទូទៅឡើយ (ចំណុច ក កថាខណ្ឌទី ១ នៃមាត្រានេះ) ។ នេះមកពីមូលហេតុដូចតទៅ : ទី ១ បើម្ចាស់បំណុលនោះចង់ទទួលការសង ក្នុងនាមជាម្ចាស់សិទ្ធិប្រាតិភោគ ម្ចាស់បំណុលនោះអាចចាប់ផ្ដើមដោយខ្លួនឯងនូវនីតិវិធីអនុវត្តសិទ្ធិប្រាតិភោគ ហេតុដូច្នេះ យើងអាចគិតថា ម្ចាស់បំណុលនោះគួរតែទាមទារតាមរបៀបនេះ ទី ២ បើគិតអំពីតម្លៃ តាមគោលការណ៍ទទួលបន្ត កម្មវត្ថុនៃនីតិវិធីនៃការលក់ដោយបង្ខំតាមពាក្យសុំរបស់ម្ចាស់បំណុលទូទៅ គឺជាភាគដែលនៅសល់ ក្រោយការដកតម្លៃនៃសិទ្ធិប្រាតិភោគដែលអ្នកទិញនឹងទទួលបន្ត ចេញពីតម្លៃទាំងមូលនៃអចលនវត្ថុ ហេតុដូច្នេះ ការដែលអ្នកមានសិទ្ធិប្រាតិភោគទទួលចំណែកពីប្រាក់ដែលបានមកពីការលក់តាមនីតិវិធីនោះ អាចគិតថា ជាការមិនសមហេតុសមផល ។

(3) អំពីការចាត់ចែងសិទ្ធិលើបំណុលពន្ធដារ សូមមើល កំណត់ (4) និង (5) នៃមាត្រា ៤២២ (ការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក និង ការផ្លាស់ប្ដូរពេលកំណត់នោះ) ។

Civil Execution Act (Japan)
**Article 47** (Double rulings of commencement) > *see the note for Article 424*

**មាត្រា ៤២៧.-** ការលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដោយសារការបាត់បង់ ជាអាទិ៍ នៃអចលនវត្ថុ

បើមានភាពច្បាស់លាស់អំពីស្ថានភាពដែលបានបាត់បង់អចលនវត្ថុ ឬ ស្ថានភាពផ្សេងដែលរារាំងការផ្ទេរអចលនវត្ថុដោយការលក់ តុលាការអនុវត្តត្រូវលុបចោលនីតិវិធីនៃការលក់ដោយបង្ខំ ។

(កំណត់)

(1) សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 53 ។

(2) ស្ថានភាពផ្សេងដែលរារាំងការផ្ទេរអចលនវត្ថុ ដោយការលក់ មានដូចជា ករណីដែលអចលនវត្ថុនោះស្ថិតនៅក្រោមកម្មសិទ្ធិរបស់តតិយជន ករណីដែលទីតាំងនៃអចលនវត្ថុមិនច្បាស់លាស់ ជាដើម ។

Civil Execution Act (Japan)
**Article 53** (Annulment of proceure of compulsory sale by auction because of destruction or loss)

In cases where an immovable is lost or destroyed or any other circumstances exist which prevent the immovable from being transferred by sale, the execution court shall annul the procedure of compulsory sale by auction.

**មាត្រា ៤២៨.-** ការផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស

១- បើពាក្យសុំឱ្យលក់ដោយបង្ខំត្រូវបានដកចេញ ឬ បើអានុភាពនៃដីកាសម្រេចលុបចោលនីតិវិធីលក់ដោយបង្ខំបានកើតឡើង ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចលុបការចុះបញ្ជីអំពីការរឹបអូស ដែលពាក់ព័ន្ធនឹងដីកាសម្រេចចាប់ផ្ដើមនោះ ។

២- សោហ៊ុយចាំបាច់សម្រាប់ការផ្ទុកផ្ដាក់ដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ជាបន្ទុករបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានដកពាក្យសុំចេញ ឬ ម្ចាស់បំណុលនៃការអនុវត្តដែលបានទទួលដីកាសម្រេចលុបចោលនោះ ។

(កំណត់)

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 54 ។ ជាគោលការណ៍ សោហ៊ុយចំណាយសម្រាប់ការអនុវត្តដោយបង្ខំ ជាបន្ទុករបស់កូនបំណុលនៃការអនុវត្ត តែសោហ៊ុយចាំបាច់សម្រាប់ការផ្ទុកផ្ដាក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នេះ ជាបន្ទុករបស់ម្ចាស់បំណុលនៃការអនុវត្តវិញ ព្រោះម្ចាស់បំណុលបានដកពាក្យសុំឱ្យអនុវត្ត ឬ នីតិវិធីលក់ដោយបង្ខំដែលចាប់ផ្ដើមដោយសារពាក្យសុំរបស់ម្ចាស់បំណុល ត្រូវបានលុបចោល ។

Civil Execution Act (Japan)
**Article 54** (Request for voiding registration of attachment)
1. In cases where a motion for compulsory sale by auction has been withdrawn or a ruling annulling the procedure of compulsory sale by auction has become effective, the court clerk shall entrust the registrar with voiding the registration of attachment under the ruling of commencement.
2. The attachment obligee shall bear the registration tax and any other costs necessary for the entrustment referred to in the preceding paragraph.

**មាត្រា ៤២៩.-** ការចាត់ចែងការរក្សាការពារ

១- ប្រសិនបើកូនបំណុល ឬ អ្នកកាន់កាប់អចលនវត្ថុបានប្រព្រឹត្តអំពើដែលធ្វើឱ្យតម្លៃអចលនវត្ថុចុះថយគួរឱ្យកត់សំគាល់ ឬ ធ្វើឱ្យមានការលំបាកដល់ការលក់ ឬ ការប្រគល់អចលនវត្ថុ ឬ បើមានការបារម្ភថា អ្នកនោះនឹងប្រព្រឹត្តអំពើខាងលើនេះ តុលាការអនុវត្តអាចហាមឃាត់ជនដែលបានប្រព្រឹត្តអំពើទាំងនេះ ឬ ជនដែលត្រូវគេមានការបារម្ភថានឹងប្រព្រឹត្តអំពើទាំងនេះ មិនឱ្យប្រព្រឹត្តអំពើនោះ ឬ បង្គាប់ឱ្យជននោះធ្វើសកម្មភាពណាមួយជាកំណត់ ឬ បង្គាប់ឱ្យជននោះលះបង់ការកាន់កាប់អចលវត្ថុហើយឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងអចលនវត្ថុនោះបាន ដោយដីកាសម្រេចតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកទិញ ដោយឱ្យដាក់ ឬ មិនឱ្យដាក់ប្រាតិភោគ ។ ប៉ុន្តែ មានតែករណីដែលអ្នកកាន់កាប់អចលនវត្ថុ មិនអាចយកមូលហេតុគតិយុត្តនៃសិទ្ធិកាន់កាប់ តតាំងនឹងអ្នកទិញទេ ទើបអាចបង្គាប់ឱ្យជននោះប្រគល់អចលនវត្ថុឱ្យអាជ្ញាសាលា ដើម្បីឱ្យថែរក្សាគ្រប់គ្រងបាន ។

២- ក្នុងករណីចេញដីកាសម្រេចដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ចំពោះអ្នកកាន់កាប់ផ្សេងពីកូនបំណុល តុលាការអនុវត្តត្រូវសួរជននោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមាន

ភាពបន្ទាន់ចាំបាច់ត្រូវចេញដីកាសម្រេចនោះ ។
៣- បើស្ថានភាពមានការប្រែប្រួល តុលាការអនុវត្តអាចលុបចោល ឬ កែប្រែដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តាមពាក្យសុំបាន ។
៤- ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ ទី ៣ ខាងលើនេះ អាចប្តឹងជំទាស់បាន ។
៥- ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ទោះជានៅមុនពេលដែលត្រូវបានបញ្ជូនទៅភាគីម្ខាងទៀតក៏ដោយ ក៏អាចអនុវត្តបានដែរ ។
៦- សោហ៊ុយចាំបាច់សម្រាប់ពាក្យសុំ ឬ ការអនុវត្តដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ទុកជាសោហ៊ុយសម្រាប់ផលប្រយោជន៍រួម ក្នុងនីតិវិធីនៃការលក់ដោយបង្ខំចំពោះអចលនវត្ថុនោះ ។

(កំណត់)

(1) សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 55 និង មាត្រា 57 ។

(2) មាត្រានេះ ចែងអំពីប្រព័ន្ធនៃការចាត់ចែងការរក្សាការពារ ដើម្បីថែរក្សាតម្លៃនៃអចលនវត្ថុដែលកំពុងស្ថិតនៅក្នុងនីតិវិធីអនុវត្ត ។ នៅពេលដែលអចលនវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនត្រូវក្លាយទៅជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ នៅក្នុងករណីភាគច្រើន កូនបំណុលបានបាត់បង់នូវការចាប់អារម្មណ៍លើការថែរក្សាតម្លៃនៃអចលនវត្ថុ ហើយក្នុងករណីលើសពីនេះទៀត មានការបារម្ភថា កូនបំណុលនឹងធ្វើអំពើដែលរារាំងដល់នីតិវិធីអនុវត្តដោយរួមគ្នាជាមួយតតិយជន ។ ត្រង់ចំណុចនេះ មាត្រានេះអនុញ្ញាតឱ្យតុលាការអនុវត្តចេញដីកាសម្រេចចាត់ចែងរក្សាការពារ ដើម្បីឱ្យម្ចាស់បំណុលនៃការរឹបអូស ជាដើម អាចបង្ការនូវអំពើរបស់កូនបំណុល ឬ តតិយជន ដូចនេះ អាចថែរក្សាតម្លៃអចលនវត្ថុ និង អាចលក់អចលនវត្ថុនោះ ។

(3) វិធានការដែលអាចធ្វើឡើងក្នុងនាមជាការចាត់ចែងការរក្សាការពារ គឺ ① ការបង្គាប់ឱ្យហាមឃាត់អំពើដែលនាំឱ្យថយតម្លៃ ឬ នាំឱ្យមានផលវិបាកក្នុងការលក់ ② ការបង្គាប់ឱ្យធ្វើសកម្មភាពដើម្បីធ្វើបដិទានស្ថានភាពដែលបានកើតឡើង ដោយសារអំពើទាំងនេះ ③ការបង្គាប់ឱ្យផ្ទេរការកាន់កាប់ ឬ បង្គាប់ឱ្យរក្សាទុកដោយអាជ្ញាសាលា ជាអាទិ៍ ។ ប៉ុន្តែ ដោយការបង្គាប់នៃចំណុចទី③ នាំឱ្យមានអានុភាពដ៏ធំធេងដែលដកហូតការកាន់កាប់នោះ ក្នុងករណីដែលអ្នកកាន់កាប់ មានមូលហេតុគតិយុត្តនៃសិទ្ធិ (title, titre 権原) ដែលអាចបន្តការកាន់កាប់នៅក្រោយការលក់នោះ ពុំអាចអនុវត្តឡើយ (វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១) ។

(4) ក្នុងនីតិវិធីនៃការបង្គាប់ឱ្យចាត់ចែងការរក្សាការពារ ចំពោះអ្នកកាន់កាប់ផ្សេងពីកូនបំណុល ដើម្បីពិនិត្យលក្ខណៈជាអាទិ៍ នៃមូលហេតុគតិយុត្តនៃសិទ្ធិ (title, titre 権原) នោះ និង ដើម្បីផ្តល់នូវការធានានូវនីតិវិធីសព្វគ្រប់ជាគោលការណ៍ តុលាការអនុវត្តចាំបាច់ត្រូវសួរអ្នកកាន់កាប់នោះ (កថាខណ្ឌទី ២) ។ ម្យ៉ាងទៀត ការចាត់ចែងការរក្សាការពារនឹងថែរក្សាតម្លៃនៃអចលនវត្ថុ និង ធ្វើឱ្យមានលទ្ធភាពអាចលក់ ហើយនាំឱ្យមានផលប្រយោជន៍

ដល់ជនគ្រប់រូបដែលមានការពាក់ព័ន្ធនឹងនីតិវិធីនោះ សោហ៊ុយចាំបាច់សម្រាប់កិច្ចការនេះ ត្រូវបានចាត់ទុកជាសោហ៊ុយសម្រាប់ផលប្រយោជន៍រួម ហើយត្រូវប្រមូលដោយមានអាទិភាព (កថាខណ្ឌទី ៦) ។

Civil Execution Act (Japan)

**Article 55** (Securing disposition on behalf of sale)

1. In cases where the obligor is committing an act which reduces the value of an immovable extremely or threatens to so reduce it, the execution court, upon motion of the attachment obligee (except for an attachment obligee who has made a motion for compulsory sale by auction or sale by auction after the final ate for demanding distribution; the same shall apply to an obligee referred to in the next Article), may prohibit the obligor form doing such act or order the obligor to do a certain protective act, either upon or without security being provided, until the buyer pays the price.
2. In cases where the obligor violates the order referred to in the preceding paragraph, the execution court, upon the motion of the person who has made the motion for the order referred to in that paragraph, may order the obligor to be dispossessed of the immovable and may place it under the custody of the execution officer, upon security being provided, until the buyer pays the price.
3. In cases where circumstances have changed, the execution court, upon motion, may annul or alter a ruling made in accordance with the provisions of the preceding two paragraphs.
4. A kōkoku-appeal concerning execution may be filed against a decision on the motions referred to in the preceding three paragraphs.
5. A ruling made in accordance with the provisions of paragraph 3 shall not become effective until it becomes final and binding.
6. A ruling made in accordance with the provisions of paragraph 2 may not be executed after two weeks from the day when the moving party is notified of such ruling.
7. A ruling made in accordance with the provisions of paragraph 2 may be executed even before such ruling is served on the other party.
8. Expenses incurred with regard to motions referred to in paragraphs 1 or 2, or for execution of ruling referred to in the said paragraphs, shall constitute costs for common benefit. With regard to the compulsory execution against the immovable.

**Article 77** (Securing disposition on behalf of highest bidder or buyer)

1. In cases where the obligor is committing an act which reduces the value of the immovable or makes delivery of the immovable difficult, or threatens to commit such act, the execution court, upon motion of the highest bidder or buyer, upon having such person pay the purchase price or an amount corresponding to such price (in cases where money is tendered as security when an offer to buy is made, an amount obtained by subtracting it therefrom) and either with or without security being provide, may prohibit the obligor from doing such act, order a certain act or order the obligor to be dispossessed of the immovable and shall place it under the custody of the execution officer until execution of an order of delivery.
2. The provisions of Article 55, paragraph 3 and 5 to 7 inclusive shall apply *mutatis mutandis* to a ruling according to the provisions of the preceding paragraph; the provisions of Article 55, paragraph 4 shall apply *mutatis mutandis* to a decision concerning the motion referred to in the preceding paragraph or in Article 55, paragraph 3 which shall apply *mutatis mutandis* by this paragraph.

## កថាភាគទី ២ លំនាំខណ្ឌនៃការលក់

**មាត្រា ៤៣០.-** ការវាយតម្លៃ

១- តុលាការអនុវត្តត្រូវជ្រើសតាំងអ្នកវាយតម្លៃ និង បង្គាប់ឱ្យវាយតម្លៃអចលនវត្ថុ ដោយផ្អែកលើការស្រាវជ្រាវអំពីសណ្ឋាននៃអចលនវត្ថុ ទំនាក់ទំនងនៃការកាន់កាប់ និង ស្ថានភាពបច្ចុប្បន្នឯទៀត ។

២- ដើម្បីសុំជំនួយពីអាជ្ញាសាលាយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលាជា អាទិ៍) នៃក្រមនេះ អ្នកវាយតម្លៃត្រូវទទួលការអនុញ្ញាតពីតុលាការអនុវត្ត ។

៣- នៅពេលស្រាវជ្រាវដើម្បីវាយតម្លៃ អ្នកវាយតម្លៃអាចចូលទៅកាន់អចលនវត្ថុ ឬ អាចសួរសំណួរ ឬ ទាមទារឱ្យបង្ហាញឯកសារ ចំពោះកូនបំណុលនៃការអនុវត្ត ឬ តតិយជនដែលកាន់កាប់អចលនវត្ថុនោះបាន ។

៤- បើមានភាពចាំបាច់ អាជ្ញាសាលាដែលអ្នកវាយតម្លៃបានសុំជាជំនួយ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) នៃក្រមនេះ អាចធ្វើការចាត់ចែងចាំបាច់ដើម្បីបើកទ្វារ

ដែលបិទបាន នៅក្នុងករណីដែលអ្នកវាយតម្លៃចូលទៅកាន់អចលនវត្ថុ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ។

៥- អ្នកវាយតម្លៃត្រូវដាក់ជូនតុលាការអនុវត្តជាលាយល័ក្ខណ៍អក្សរ នូវលទ្ធផលនៃការស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ន នៃអចលនវត្ថុ និង ការវាយតម្លៃអចលនវត្ថុនោះ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 57 និង មាត្រា 58 និង ក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសកម្ពុជា មាត្រា ១៣០ (ការប្រគល់កិច្ចការស្រាវជ្រាវ) ។ មាត្រានេះគឺជាបញ្ញត្តិដូចគ្នានឹងមាត្រា ៤៦៧ (ការវាយតម្លៃ) ដែលចែងអំពីការអនុវត្តចំពោះនាវា ប៉ុន្តែ ខុសពីការអនុវត្តចំពោះនាវា ការជ្រើសតាំង អ្នកវាយតម្លៃគឺជាកិច្ចការចាំបាច់ ។ ចំពោះអ្នកវាយតម្លៃ ពុំមានកំណត់ដោយច្បាប់អំពីជនដែលមានលក្ខណសម្បត្តិទេ តែអ្នកជំនាញក្នុងការវាយតម្លៃអចលនវត្ថុ (estate surveyor) ជាដើម ត្រូវបានជ្រើសតាំងដោយតុលាការអនុវត្ត ។

ជាបន្ថែម ចំពោះរបាយការណ៍នៃការស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ន របាយការណ៍វាយតម្លៃ និង ឯកសារលំអិតអំពីវត្ថុនៃរឿងក្តីជាក់ស្តែងនៃការអនុវត្តចំពោះអចលនវត្ថុនៅប្រទេសជប៉ុន អាចមើលតាមប្រព័ន្ធអ៊ិនធើណេត (Internet) នៅគេហទំព័រ http://bit.sikkou.jp បាន ។

Civil Execution Act (Japan)
**Article 57** (Investigation of present conditions)
1. The execution court shall order the execution officer to investigate the form of the immovable, the possessory relationship involved, and any other present conditions concerning the immovable.
2. When making this investigation, the execution officer may enter the premises of the immovable, question the obligor or any third person in possession of the immovable or demand the production of documents from such persons.
3. When entering the premises of the immovable in accordance with the provisions of the preceding paragraph, the execution officer may, if necessary, make a disposition necessary for opening a closed door.
**Article 58** (Appraisal)
1. The execution court shall appoint an appraiser and order him to assess the value of the immovable.
2. In order to demand the assistance of the execution officer in accordance with the provisions of Article 6, paragraph 2, the appraiser must obtain the permission of the execution court.
3. The provisions of paragraph 2 of the preceding Article shall apply *mutatis mutandis* to cases where the appraiser assesses the value of the immovable.

**មាត្រា ៤៣១.-** សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់

១- ក្នុងចំណោមសិទ្ធិប្រាតិភោគប្រត្យក្ស សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល និង សិទ្ធិជួលដែលមានលើអចលនវត្ថុ ចំពោះសិទ្ធិដែលអាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្តបាន ត្រូវបន្តអត្ថិភាពនៅក្រោយការលក់ ។

២- សិទ្ធិលើអចលនវត្ថុ ក្រៅពីសិទ្ធិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវរលត់ដោយសារការលក់ ។

៣- ការរឹបអូស ការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ដែលពាក់ព័ន្ធនឹងអចលនវត្ថុ និង ការអនុវត្តការចាត់ចែងជាបណ្តោះអាសន្នដែលពុំអាចតតាំងនឹងម្ចាស់បំណុលនៃការអនុវត្ត ឬ ម្ចាស់បំណុលដែលបានធ្វើការរឹបអូសជាបណ្តោះអាសន្ន

ត្រូវបាត់បង់អានុភាព ដោយសារការលក់ ។

៤- មុនពេលដែលតម្លៃលក់អប្បបរមាត្រូវបានកំណត់ បើបុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍បានរាយការណ៍ថា ការព្រមព្រៀងដែលផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវបានធ្វើឡើង ការប្រែប្រួលនៃសិទ្ធិលើអចលនវត្ថុ ដោយការលក់ ត្រូវអាស្រ័យតាមការព្រមព្រៀងនោះ ។

(កំណត់)

ក្នុងករណីដែលបន្ទុកនៃសិទ្ធិប្រាតិភោគប្រត្យក្ស សិទ្ធិប្រើប្រាស់និងអាស្រ័យផល និង សិទ្ធិជួល ដែលមានអាទិភាពជាងសិទ្ធិរបស់ម្ចាស់បំណុលនៃការអនុវត្ត មានអត្ថិភាពលើអចលនវត្ថុ គោលការណ៍នីតិកម្មលើនិន្នាការនៃបន្ទុកទាំងនេះក្រោយការលក់ មានគោលការណ៍លុបចេញ និង គោលការណ៍ទទួលបន្ត ។ គោលការណ៍លុបចេញគឺជាទិសដៅឱ្យអ្នកទិញទទួលនូវអចលនវត្ថុដែលគ្មានបន្ទុក ដោយរំលត់បន្ទុកទាំងអស់នោះដោយការលក់ ។ ច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 59 យកគោលការណ៍នេះ ។ ផ្ទុយទៅវិញ គោលការណ៍ទទួលបន្ត គឺជាទិសដៅឱ្យអ្នកទិញទទួលនូវអចលនវត្ថុដែលភ្ជាប់ដដែលនូវបន្ទុកទាំងនោះ ហើយមាត្រា ៤៣១ នេះផ្អែកលើគោលការណ៍ទទួលបន្តនេះ ។

តាមគោលការណ៍លុបចេញ ឋានៈរបស់អ្នកទិញមានស្ថិរភាព តែម្យ៉ាងវិញទៀត ម្ចាស់សិទ្ធិប្រាតិភោគត្រូវប្រមូលធនដែលខ្លួនបានដាក់ធ្វើវិនិយោគ នៅពេលដែលអ្នកនោះគ្មានបំណងប្រមូល ហើយចំនួនប្រាក់នៃថ្លៃលក់ដែលអ្នកទិញត្រូវបង់នៅក្នុងនីតិវិធីលក់ មានតម្លៃខ្ពស់ ដើម្បីរំលត់បន្ទុកនោះ ។ ផ្ទុយទៅវិញ បើយោងតាមគោលការណ៍ទទួលបន្ត ពុំមានការប្តូរឋានៈរបស់ម្ចាស់សិទ្ធិដែលមានអាទិភាពទេ ហើយក៏មិនជម្រុញឱ្យម្ចាស់សិទ្ធិនោះប្រមូលដោយអឆន្ទៈដែរ ចំណែកឯអ្នកទិញក៏រួចផុតពីការចេញចំនួនប្រាក់ច្រើននៅពេលតែមួយដែរ តែដោយសារបន្សល់នូវលទ្ធភាពអនុវត្តសិទ្ធិប្រាតិភោគនៅក្រោយការទិញ ដែលបណ្តាលឱ្យឋានៈរបស់អ្នកទិញមានអស្ថិរភាព ។ ពោលគឺ គោលការណ៍លុបចេញ យកចិត្តទុកដាក់លើការការពារអ្នកទិញ រីឯគោលការណ៍ទទួលបន្ត យកចិត្តទុកដាក់លើការការពារអ្នកដែលមានសិទ្ធិចំពោះអចលនវត្ថុ ។

ការយកគោលការណ៍មួយណា ចាំបាច់ត្រូវសម្រេច ដោយគិតពិចារណាថា (1) តើម្ចាស់បំណុលហិរញ្ញវត្ថុយល់ឃើញអំពីការខាតប្រយោជន៍ឬយ៉ាងណា នូវការប្រមូលមូលធនដែលខ្លួនបានដាក់ធ្វើវិនិយោគនោះនៅមុនពេលកំណត់ (2) តើមានបរិយាកាសសង្គមដែលអាចទទួលដោយងាយនូវការស្នើសុំទិញអចលនវត្ថុ ទោះជាអចលនវត្ថុនោះភ្ជាប់ជាមួយបន្ទុកក៏ដោយ ជាដើម ។ ក្នុងស្ថានភាពបច្ចុប្បន្ននៃប្រទេសកម្ពុជា ដោយសំអាងទៅលើការមិនអាចក្តាប់ពិតប្រាកដបាននូវបន្ទុកលើអចលនវត្ថុទាំងអស់ តាមការចុះបញ្ជីនោះ ការយកគោលការណ៍ទទួលបន្តមានភាពងាយស្រួល ដោយសារមិនចាំបាច់កំណត់ច្បាស់លាស់នូវសិទ្ធិដែលត្រូវរំលត់នោះ ។ ហេតុដូច្នេះ ក្រុមនេះជ្រើសយកគោលការណ៍ទទួលបន្ត ។

(ឧទាហរណ៍)

តម្លៃនៃអចលនវត្ថុ : 100, ហ៊ីប៉ូតែកលំដាប់ទី ១ (A) : 60, ហ៊ីប៉ូតែកលំដាប់ទី ២ (B) : 30, (សោហ៊ុយសម្រាប់នីតិវិធី : 2)

--គោលការណ៏ទទួលបន្ត

អ្នកទិញបង់ថ្លៃ 10 គឺ 2 ទៅសោហ៊ុយនីតិវិធី, 8 ទៅម្ចាស់បំណុលនៃការអនុវត្ត

ទាំងហ៊ីប៉ូតែកលំដាប់ទី ១ និង ហ៊ីប៉ូតែកលំដាប់ទី ២ នៅបន្តអត្ថិភាព

--គោលការណ៏លុបចេញ

អ្នកទិញបង់ថ្លៃ100 គឺ 60 ទៅ A, 30 ទៅ B, 2 ទៅសោហ៊ុយសម្រាប់នីតិវិធី, 8 ទៅម្ចាស់បំណុលនៃការអនុវត្ត

ទាំងហ៊ីប៉ូតែកលំដាប់ទី ១ និង ទី ២ រលត់

ដោយសារ "ការចាត់ចែងជាបណ្តោះអាសន្ន" ដែលចែងនៅកថាខណ្ឌទី ៣ ទាក់ទងនឹងល័ក្ខខ័ណ្ឌនៃការលក់នោះ "ការចាត់ចែងជាបណ្តោះអាសន្ន" នោះ ពុំមែនចង្អុលបង្ហាញគ្រប់ការចាត់ចែងជាបណ្តោះអាសន្នទេ គឺចង្អុលបង្ហាញតែការអនុវត្តការចាត់ចែងជាបណ្តោះអាសន្នដែលរក្សាការពារសិទ្ធិដែលរារាំងការទទួលកម្មសិទ្ធិដោយអ្នកទិញ ឬ ការអនុវត្តការចាត់ចែងជាបណ្តោះអាសន្នដែលរក្សាការពារសិទ្ធិដែលនឹងក្លាយជាបន្ទុកចំពោះកម្មសិទ្ធិដែលអ្នកទិញទទួលប៉ុណ្ណោះ ។ មានឧទាហរណ៏ដូចជា ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ដើម្បីរក្សាការពារកម្មសិទ្ធិរបស់តតិយជន ។ ផ្ទុយទៅវិញ ការអនុវត្តការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់អចលនវត្ថុ ពុំអាចរារាំងការទទួលកម្មសិទ្ធិដោយអ្នកទិញនោះទេ ហេតុដូច្នេះ នឹងមិនបាត់បង់អានុភាពដោយសារការលក់ទេ ហើយត្រូវបានទទួលបន្តដោយអ្នកទិញ ។

Civil Execution Act (Japan)

**Article 59** (Extinguishment of right by sale)

1. Preferential rights, rights of pledge with provisions neither to use nor to make a profit and hypothecs on the immovable are extinguished by sale.
2. The acquisition of rights concerning the immovable which cannot be set up against those who have a right which will be extinguished in accordance with the provisions of the preceding paragraph, or against an attachment obligee or a provisional attachment oligee, shall lose its effect by the sale.
3. An attachment, execution of provisional attachment, or provisional disposition concerning the immovable which cannot be set up against an attachment obligee, a provisional attachment obligee, or those who have a right which will be extinguished in accordance with the provisions of paragraph 1 shall lose its effect by the sale.
4. In case where a right of retention or right of pledge without provisions prohibiting use or the making of profits and to which the provisions of paragraph 2 do not apply, exists on the immovable, the buyer shall be liable for satisfaction of the obligation-right secured by such right.
5. In cases where an interested person gives notice to the execution court that an agreement deviating from the provisions of paragraphs 1, 2 and 4 has been made pending the fixing of a minimum acceptable price, such agreement shall govern any changes in the rights to the immovable arising from the sale.

**មាត្រា ៤៣២.-** ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា ជាអាទិ៍

១- តុលាការអនុវត្តត្រូវកំណត់តម្លៃលក់អប្បបរមា ដោយផ្អែកលើការវាយតម្លៃរបស់អ្នកវាយតម្លៃ ។

២- បើយល់ឃើញថាចាំបាច់ តុលាការអនុវត្តអាចផ្លាស់ប្តូរតម្លៃលក់អប្បបរមាបាន ។

(កំណត់)

(1) មាត្រានេះត្រូវនឹងមាត្រា 60 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

(2) មាត្រានេះបញ្ញត្តអំពីដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា ជាអាទិ៍ ។ ពាក្យ "បើយល់ឃើញថាចាំបាច់" នៅកថាខណ្ឌទី ២ សំដៅទៅលើករណីដែលតម្លៃលក់អប្បបរមាក្លាយជាតម្លៃមិនសមរម្យ ដោយសារការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ច ព្រមទាំងករណីដែលយល់ឃើញថា តម្លៃលក់អប្បបរមាជាតម្លៃមិនសមរម្យ តាមទស្សនៈក្នុងការធ្វើនីតិវិធីនៃការលក់ឱ្យបានងាយស្រួល ។ មាត្រានេះគឺជាបញ្ញត្តិដូចគ្នានឹងមាត្រា ៤៦៨ (ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា ជាអាទិ៍) ដែលចែងអំពីការអនុវត្តចំពោះនាវា ។

Civil Execution Act (Japan)
**Article 60** (Establishment of minimum acceptable price)
1. The execution court shall establish the minimum acceptable price on the basis of the assessment of the appraiser.
2. The execution court, if it deems necessary, may alter the minimum acceptable price.

## **មាត្រា ៤៣៣.‐** ការលក់សរុប

បើយល់ឃើញថាជាការសមរម្យក្នុងការឱ្យអ្នកទិញណាមួយ ទិញសរុបតែម្តងនូវអចលនវត្ថុ ជាមួយនឹងអចលនវត្ថុផ្សេងទៀត ដោយយោងតាមទំនាក់ទំនងគ្នាក្នុងការប្រើប្រាស់ ទោះបីជាអចលនវត្ថុនីមួយៗនោះមានម្ចាស់បំណុលនៃការអនុវត្តផ្សេងគ្នា ឬ កូនបំណុលនៃការអនុវត្តផ្សេងគ្នាក៏ដោយ ក៏តុលាការអនុវត្តអាចកំណត់ការលក់អចលនវត្ថុទាំងនោះសរុបតែម្តងបាន ។ ប៉ុន្តែ ក្នុងករណីដែលមានលទ្ធភាពអាចសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្តនីមួយៗ និងសោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បាន ដោយការលក់អចលនវត្ថុណាមួយក្នុងតម្លៃលក់អប្បបរមា ក្នុងចំណោមអចលនវត្ថុច្រើន ដែលដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំត្រូវបានសម្រេច តាមពាក្យសុំតែមួយនោះ តុលាការអនុវត្តអាចកំណត់ការលក់សរុបតែម្តងបាន លុះត្រាតែមានការយល់ព្រមពីកូនបំណុលនៃការអនុវត្ត ។

(កំណត់)

មាត្រានេះត្រូវនឹងមាត្រា 61 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។ ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុជាគោលការណ៍ ត្រូវមានដំណើរការ តាមអចលនវត្ថុនីមួយៗ ។ ប៉ុន្តែ មានករណីខ្លះដែលអចលនវត្ថុដែលត្រូវបានរឹបអូសមានច្រើនមុខ ហើយមានភាពសមរម្យឱ្យបុគ្គលតែម្នាក់ទិញអចលនវត្ថុទាំងនោះ តាមការប្រើប្រាស់ទៅវិញទៅមក ដូចជា ដី និង សិទ្ធិប្រើដីនោះដែលមានអាគារជាសមាសភាគ ឬ ដីច្រើនកន្លែងដែលនៅជាប់គ្នា ។ ក្នុងករណីនេះ ការលក់អចលនវត្ថុច្រើនមុខឱ្យស្រេចតែម្តង ពុំគ្រាន់តែសម្រួលចំពោះអ្នកទិញតែប៉ុណ្ណោះទេ ជាធម្មតា អាចលក់ដោយតម្លៃខ្ពស់ជាងការលក់ ដោយផ្សេងៗពីគ្នាផងនោះ ក៏ជាប្រយោជន៍ចំពោះម្ចាស់បំណុលនៃការអនុវត្តផង និង កូនបំណុលនៃការអនុវត្តផង ។

Civil Execution Act (Japan)
**Article 61** (Sale of immovables as undivided whole)

The execution court, if it deems it reasonable, in light of a mutual use, to sell an immovable together with other immovables (including immovables which belong to different obligors or have been attached by different obligees) as an undivided whole to the same buyer may decide to sell those immovables as an undivided whole; provided that, if all the obligation-rights of respective obligees and all costs of execution are likely to be satisfied with the minimum acceptable price of any one of those immovables on which a ruling of commencement of compulsory sale by auction has been rendered upon one motion, this provision shall apply only in cases where the obligor consents.

**មាត្រា ៤៣៤.**~ ឯកសារលំអិតអំពីវត្ថុ

១- តុលាការអនុវត្តត្រូវធ្វើឯកសារលំអិតអំពីវត្ថុ ហើយត្រូវទុកឯកសារចម្លងនៃឯកសារលំអិតអំពីវត្ថុនោះ នៅតុលាការអនុវត្ត ជាមួយគ្នានឹងឯកសារចម្លងនៃរបាយការណ៍វាយតម្លៃ ដើម្បីផ្តល់ឱ្យសាធារណជនមើល ។ ឯកសារលំអិតអំពីវត្ថុត្រូវសរសេរចំណុចដូចខាងក្រោមនេះ :

- **ក-** សញ្ញាណនៃអចលនវត្ថុ ។
- **ខ-** សិទ្ធិលើអចលនវត្ថុដែលនឹងបន្តអត្ថិភាពក្រោយការលក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់) នៃក្រមនេះ និង ការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ន ដែលមិនបាត់បង់អានុភាពដោយការលក់ ។

២- បើយល់ឃើញថាចាំបាច់ ដើម្បីធ្វើឯកសារលំអិតអំពីវត្ថុ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តអាចបង្គាប់ឱ្យអាជ្ញាសាលាស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ ដូចជាសណ្ឋាននៃអចលនវត្ថុ ស្ថានភាពនៃការកាន់កាប់ រចនាសម្ព័ន្ធនៃអាគារបើមានអាគារ ឬ បើកម្មវត្ថុនៃការអនុវត្តគឺជាអាគារ ជាអាទិ៍ ហើយរាយការណ៍លទ្ធផលនៃការស្រាវជ្រាវនោះជាលាយល័ក្ខណ៍អក្សរ ។

៣- នៅពេលធ្វើការស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ តាមការបង្គាប់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាជ្ញាសាលាមានសិទ្ធិអំណាចដូចនឹងសិទ្ធិអំណាចរបស់អ្នកវាយតម្លៃដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ៤៣០ (ការវាយតម្លៃ) នៃក្រមនេះ ។ បើមានភាពចាំបាច់ អាជ្ញាសាលាអាចធ្វើការចាត់ចែងចាំបាច់ដើម្បីបើកទ្វារដែលបិទបាន ។

(កំណត់)

មាត្រានេះត្រូវនឹងមាត្រា 62 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។ ឯកសារលំអិតអំពីវត្ថុ មានសារៈប្រយោជន៍ឱ្យអ្នកដែលមានបំណងទិញ អាចដឹងអំពី "សិទ្ធិលើអចលនវត្ថុដែលនឹងបន្តអត្ថិភាពក្រោយការលក់" ដែលបានកំណត់នៅក្នុងចំណុច **ខ** នៃកថាខណ្ឌទី ១ ដោយសារក្រមនេះ យកគោលការណ៍ទទួលបន្ត (មាត្រា ៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់)) ។

<u>Civil Execution Act (Japan)</u>
**Article 62** (Specifications)
The execution court shall draw up specifications including the following matters and keep a copy of such specifications available for public inspection in the court.

i. description of the immovable;
ii. acquisitions of rights concerning the immovable and executions of provisional dispositions which will not lose effect by the sale;
iii. outline of any superficies deemed to be created by the sale.

**មាត្រា ៤៣៥.-** វិធានការក្នុងករណីដែលមានការបារម្ភថាគ្មានសំណល់

១- ប្រសិនបើយល់ឃើញថា តម្លៃលក់អប្បបរមានៃអចលនវត្ថុ ក្រោយពីបានសងសោហ៊ុយសម្រាប់នីតិវិធីហើយ គ្មានលទ្ធភាពសល់ទេនោះ តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ។

២- តុលាការអនុវត្តត្រូវលុបចោលនូវនីតិវិធីនៃការលក់ដោយបង្ខំ ដែលទាក់ទងនឹងពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត បើម្ចាស់បំណុលនៃការអនុវត្ត មិនបានធ្វើសកម្មភាពដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

- **ក-** សំណើថា ខ្លួននឹងទិញអចលនវត្ថុក្នុងតម្លៃស្នើសុំ ក្នុងករណីដែលគ្មានសំណើទិញក្នុងតម្លៃដែលឡើងដល់តម្លៃស្នើសុំនោះ ។ ប៉ុន្តែ សំណើនោះ ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានទទួលដំណឹងដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ហើយតម្លៃស្នើសុំនោះ ត្រូវលើសពីតម្លៃប៉ាន់ប្រមាណនៃសោហ៊ុយសម្រាប់នីតិវិធី ។
- **ខ-** ការដាក់ប្រាក់ធានាដែលស្មើនឹងតម្លៃស្នើសុំដែលបានកំណត់នៅក្នុងចំណុច **ក** ខាងលើនេះ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 63 ។ ដោយសារតម្លៃលក់អប្បបរមា ផ្អែកលើការវាយតម្លៃរបស់អ្នកវាយតម្លៃ មានលទ្ធភាពស្ទួចស្ទើងដែលមានការស្នើសុំទិញដោយតម្លៃខ្ពស់ឆ្ងាយជាងតម្លៃលក់អប្បបរមានេះ ហេតុដូច្នេះ ក្នុងករណីដែលតម្លៃលក់អប្បបរមាមិនគ្រប់ដើម្បីទូទាត់នឹងសោហ៊ុយសម្រាប់នីតិវិធី ជាគោលការណ៍ នីតិវិធីនៃការលក់ដោយបង្ខំ ត្រូវបានលុបចោល ដោយមិនរង់ចាំកាលបរិច្ឆេទនៃការលក់ ។ ប៉ុន្តែ ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តបានស្នើសុំទិញដោយខ្លួនឯង និង ដាក់ការធានា ដោយសារនីតិវិធីនឹងមិនឥតប្រយោជន៍នោះ បញ្ញត្តិនេះឱ្យនីតិវិធីមានដំណើរការ ។

តាមឧទាហរណ៍នៃមាត្រា ៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់) ពោលគឺជាករណីដែលតម្លៃនៃអចលនវត្ថុដែលត្រូវបានវាយតម្លៃ នៅក្រោម 92 ។

<u>Civil Execution Act (Japan)</u>
**Article 63** (Measures to be taken in cases where surplus is unlikely to arise)
1. In cases where the execution court deems that a surplus is unlikely to arise after satisfying the costs for common benefit out of thee costs of execution (hereinafter referred to as "costs of procedure") and obligation-rights which have priority over the right of an attachment obligee (this refers to an attachment obligee in the first ruling of commencement of compulsory sale by auction; provided that, in cases where a decision continuing the procedure has been rendered in accordance with the provisions of Article 47, paragraph 4, it refers to the attachment obligee to whom such decision has been rendered; hereinafter the same shall apply in this article and such right will be referred to as a "preferential obligation-right"), the court shall notify the attachment obligee thereof.
2. In cases where the attachment obligee fails to make an offer and provide security, prescribed by either of the following items in accordance with the distinction made in the items, after fixing an amount which exceeds the estimated costs of procedure and preferential obligation-rights (hereinafter "amount offered") within a week from the day he receives the notice referred to in the

preceding paragraph, the execution court shall annul the procedure of compulsory sale by auction initiated by the motion of the attachment obligee; provided that. if the attachment obligee proves within such period that the surplus, referred to in the preceding paragraph is likely to arise, this shall not apply.

i. in cases where the attachment obligee may be a buyer of the immovable–

an offer to the effect that the attachment obligee himself will buy the immovable at the amount offered if there is not offer to buy reaching such amount and provision of security corresponding to such amount;

ii. in case where the attachment obligee may not be a buyer of the immovable–

an offer to the effect that the attachment obligee will bear the difference between the amount offered and the amount bid in auction, if the latter does not reach the former, and provision of security corresponding to the difference between the amount offered and the minimum acceptable price set by the court.

3. In cases where the offer and provision of security referred to in item ii of the preceding paragraph have been made, if there is no offer to buy for a price exceeding the minimum acceptable price, the execution court shall annul the procedure of compulsory sale by auction concerning the motion of the attachment obligee.

4. The provision of security referred to in paragraph 2 shall be made to the execution court by the means provided for by the Rules of the Supreme Court.

## កថាភាគទី ៣ វិធីលក់

**មាត្រា ៤៣៦.-** វិធីលក់ ជាអាទិ៍

១- ការលក់អចលនវត្ថុ ត្រូវអនុវត្តតាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

២- តុលាការអនុវត្តអាចកំណត់វិធីលក់ ផ្សេងពីវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ តែក្នុងករណីដែលពុំអាចលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

៣- ប្រសិនបើលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ តុលាការអនុវត្តត្រូវកំណត់កាលបរិច្ឆេទ និង ទីកន្លែងលក់ ហើយត្រូវឱ្យអាជ្ញាសាលាអនុវត្តការលក់នោះ ។

៤- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ក្រឡាបញ្ជីត្រូវផ្សាយជាសាធារណៈនូវសញ្ញាណនៃអចលនវត្ថុដែលត្រូវលក់ តម្លៃលក់អប្បបរមា ព្រមទាំងកាលបរិច្ឆេទ និង ទីកន្លែងលក់ ។

៥- បញ្ញត្តិនៃមាត្រា ៣៩៦ (ការរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 64 និង មាត្រា 65 ។

(1) ការលក់ឡាយឡុងដោយស្រោមសំបុត្រ គឺ វិធីដែលឱ្យអ្នកមានបំណងទិញដែលបានចូលរួមនៅកាលបរិច្ឆេទនៃការលក់ឡាយឡុងស្នើសុំទិញដោយលិខិតឡាយឡុងដែលបានសរសេរនូវតម្លៃឡាយឡុង បន្ទាប់មកធ្វើការបើកលិខិតហើយកំណត់អ្នកសុំទិញតម្លៃអតិបរមានៅទីនោះ ។ បើលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ដោយសារអ្នកមានបំណងទិញផ្សេងទៀតពុំអាចដឹងបានសោះ អំពីការដែលអ្នកមានបំណងទិញបានដេញថ្លៃវត្ថុណាមួយ ដោយតម្លៃប៉ុន្មាននោះ សឹងតែពុំមានឱកាសប្រើស្នៀត ឬ ពិភាក្សាគ្នាទេ ហើយក៏ពុំមានការបារម្ភអំពីបរិយាកាស

នៃកន្លែងលក់ ឬ ការដែលត្រូវគ្របសង្កត់ដោយគូប្រជែងដែលមានលក្ខណៈមិនល្អដែរ ។ អាស្រ័យហេតុនេះ អាចគិតបានថា គឺជាវិធីដែលជាគោលនៅពេលលក់អចលនវត្ថុ ។

(2) ការលក់ឡាយឡុងដោយផ្ទាល់មាត់ គឺ វិធីលក់ដែលកំណត់អ្នកសុំទិញតម្លៃអតិបរមា ដោយឱ្យអ្នកមានបំណងទិញស្នើសុំទិញដោយផ្ទាល់មាត់នៅកាលបរិច្ឆេទ និង ឱ្យប្រជែងថ្លៃនោះ ។ ការលក់ឡាយឡុងដោយផ្ទាល់មាត់មានលក្ខណៈពិសេស ត្រង់ចំណុចដែលអ្នកមានបំណងទិញដឹងនូវតម្លៃស្នើសុំរបស់គូប្រជែងឯទៀតទៅវិញទៅមក ហើយប្រជែងតម្លៃស្នើសុំជាលំដាប់លំដោយ ។ វិធីនេះ មានភាពងាយស្រួលក្នុងការស្នើសុំទិញ ហើយការប្រជែងត្រូវបានអនុវត្តផ្ទាល់ចំពោះមុខ ហេតុដូច្នេះ មានគុណសម្បត្តិដែលអាចសង្ឃឹមនូវការលក់ដោយតម្លៃខ្ពស់ តែផ្ទុយទៅវិញមានគុណវិបត្តិ ដោយសារចាំបាច់មានបច្ចេកទេសជំនាញ និង បទពិសោធន៍ដែលជាស្មៀតមួយ ដែលបណ្តាលឱ្យអ្នកជំនួញដែលមានបទពិសោធន៍ មានប្រៀបជាង និង ជាការលំបាកក្នុងការស្វែងរកការចូលរួមដោយជនទូទៅជាទូលំទូលាយ ។

Civil Execution Act (Japan)

**Article 64** (Method of sale and pubic notice)

1. The sale of an immovable shall be effected by the means provided by the execution court.
2. In addition to sale by tender or auction, the means of sale of an immovable shall be provided for by the Rules of the Supreme Court.
3. In cases where a sale will be effected by tender or auction, the execution court shall fix the date, time and place of the sale and have the execution officer effect the sale.
4. In cases referred to in the preceding paragraph, the court clerk shall give public notice of the description of the immovable to be sold, the minimum acceptable price and the date, time and place of the sale.

**Article 65** (Maintenance of order in place of sale)

The execution officer may prevent the following persons from entering the place of the sale, cause such persons to leave the premises or restrain such persons from offering to buy:

i. any person who has prevented any other person from offering to by or has committed an act which hinders the sale from being fairly effected, such as conspiring for the purpose of reducing the price unreasonably, or any person who has induced another persons to commit such an act;

ii. any person who has been found guilty of any such acts in a ruling concerning refusal to sell in any other procedure of civil execution and with respect to whom two years have not lapsed since such ruling on refusal to sell became final and binding;

iii. any person who has been sentenced with regard to a civil execution sale in accordance with the provisions of Articles 95 to 96-3 inclusive, 197 to 197-4 inclusive or 198 of the Criminal Code (Law No. 45, 1907) and with respect to whom two years have not lapsed since such decision became final and binding.

## មាត្រា ៤៣៧.- ការធានាលើសំណើទិញ

១- ជនដែលបម្រុងនឹងធ្វើសំណើទិញអចលនវត្ថុ ត្រូវដាក់ប្រាក់ធានាដែលមានចំនួន ស្មើនឹងចំនួន ១ ភាគ ១០ (មួយភាគដប់) នៃតម្លៃលក់អប្បបរមា ។ ប៉ុន្តែ បើយល់ឃើញថាសមរម្យ តុលាការអនុវត្តអាចកំណត់ចំនួននៃប្រាក់ធានា លើសពីចំនួននេះបាន ។

២- ប្រសិនបើមានសំណើទិញពីបុគ្គលក្រៅពីអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា តុលាការអនុវត្តត្រូវសងភ្លាមនូវប្រាក់ធានាដែលបានដាក់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ក្រោយពេលបញ្ចប់ការលក់ដែលធ្វើឡើង ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៤៣៦ (វិធីលក់ ជាអាទិ៍) នៃក្រមនេះ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 66 និង បទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 39 មាត្រា 45 កថាខណ្ឌទី 1 និង មាត្រា 50 កថាខណ្ឌទី 4 ។

មាត្រានេះគឺជាបញ្ញត្តិដែលមានអត្ថន័យថា ឱ្យអ្នកដែលបម្រុងស្នើសុំទិញអចលនវត្ថុមានករណីយកិច្ចដាក់ប្រាក់ធានា ។ បញ្ញត្តិនេះមានគោលបំណងការពារកុំឱ្យអ្នកស្នើសុំមិនបង់ថ្លៃលក់ ។ បានសេចក្តីថា ទោះជាអ្នកស្នើសុំទិញ បានទទួលដីកាសម្រេចអនុញ្ញាតឱ្យលក់ ហើយបានក្លាយជាអ្នកទិញក៏ដោយ បើអ្នកនោះមិនបង់ប្រាក់ តុលាការមិនបង្វិលសងប្រាក់ធានានេះដោយបំពេញក្នុងភាគនៃប្រាក់លក់នោះ ។ វិធីនេះ គឺជាការដាក់កម្មវិបាកចំពោះអ្នកទិញដែលមិនបង់ប្រាក់ និង បម្រុងការពារកុំឱ្យអ្នកទិញមិនបង់ប្រាក់ ។

Civil Execution Act (Japan)
**Article 66** (Security for offering to buy)
A person who offers to buy the immovable shall provide security for the amount and by the means established by the execution court in accordance with the provisions of the Rules of the Supreme Court.

## មាត្រា ៤៣៨.- ការហាមឃាត់មិនឱ្យកូនបំណុលនៃការអនុវត្តធ្វើសំណើទិញ

កូនបំណុលនៃការអនុវត្តពុំអាចធ្វើសំណើទិញបានឡើយ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 68 ។

មាត្រានេះចែងថា កូនបំណុលនៃការអនុវត្តពុំអាចក្លាយជាអ្នកទិញបានទេ ក្នុងការលក់អចលនវត្ថុដោយបង្ខំ ។ ពីព្រោះបើកូនបំណុលនៃការអនុវត្តមានលទ្ធភាពទ្រព្យធនដើម្បីស្នើសុំទិញ កូនបំណុលនោះត្រូវសងដោយស្ម័គ្រចិត្តចំពោះម្ចាស់បំណុលនៃការអនុវត្តដោយយកទ្រព្យធននោះ ។

Civil Execution Act (Japan)
**Article 68** (Prohibition of obligor's offer to buy)
An obligor may not make an offer to buy the immovable.

## មាត្រា ៤៣៩.- ការកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ជាអាទិ៍

១- បើការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់បានបញ្ចប់ អាជ្ញាសាលាត្រូវប្រកាសការបញ្ចប់កាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ក្រោយពេលបានកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា និង បានប្រកាសនូវនាម ឬ នាមករណ៍របស់អ្នកទិញ និង ថ្លៃលក់ឡាយឡុងនោះ ។

២- បើអ្នកដេញថ្លៃដោយស្រោមសំបុត្រ ដែលបានធ្វើសំណើទិញក្នុងតម្លៃអតិបរមា មានច្រើននាក់ អាជ្ញាសាលាត្រូវកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ដោយឱ្យអ្នកទាំងនោះដេញថ្លៃដោយស្រោមសំបុត្រម្តងទៀត ។ ក្នុងករណីនេះ អ្នកដេញថ្លៃមិនអាចដេញថ្លៃដោយតម្លៃតិចជាងតម្លៃដែលខ្លួនដេញមុនបានឡើយ ។

៣- បើអ្នកដេញថ្លៃដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ មិនដេញថ្លៃម្តងទៀតទេ អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ត្រូវបានកំណត់ដោយការចាប់ឆ្នោត ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកដេញថ្លៃដោយស្រោមសំបុត្រដែលបានធ្វើសំណើទិញក្នុងតម្លៃអតិបរមា មានច្រើននាក់ នៅក្នុងការលក់ឡាយឡុងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នោះ ។

៤- បើបានអនុវត្តការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ហើយ អាជ្ញាសាលាត្រូវធ្វើកំណត់ហេតុនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ដែលសរសេរនូវចំណុចដូចខាងក្រោម ហើយត្រូវដាក់ទៅតុលាការអនុវត្តភ្លាម :

**ក**- សញ្ញាណនៃអចលនវត្ថុ ។

**ខ**- កាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

**គ**- សញ្ញាណរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា និង អ្នកតំណាង ។

**ឃ**- តម្លៃទិញរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ។

**ង**- ហេតុការណ៍នោះ និង ស្ថានភាព បើមិនអាចកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ។

**ច**- មូលហេតុ និង វិធានការដែលបានចាត់ធ្វើ បើបានចាត់វិធានការដែលបានកំណត់នៅក្នុងមាត្រា ៣៩៦ (ការរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់) នៃក្រមនេះ ។

៥- អាជ្ញាសាលាត្រូវឱ្យអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកតំណាង ចុះហត្ថលេខាលើកំណត់ហេតុនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

(កំណត់)

សូមមើលបទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 41 កថាខណ្ឌទី 3 និង មាត្រា 44 ។

**មាត្រា ៤៤០.-** កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់

១- តុលាការអនុវត្តត្រូវបើកកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ ហើយត្រូវប្រកាសអំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់ ។

២- នៅពេលដែលបានកំណត់កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ តុលាការអនុវត្តត្រូវជូនដំណឹងអំពីកាលបរិច្ឆេទនោះ ទៅជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ។

( កំណត់ )

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 69 និង បទប្បញ្ញត្តិស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 52 និង មាត្រា 53 ។

ស្ថាប័នអនុវត្តការលក់អចលនវត្ថុដោយបង្ខំ គឺតុលាការអនុវត្ត ហើយអាជ្ញាសាលា ជាស្ថាប័នដែលចាត់ចែងកិច្ចការលក់ជាក់ស្ដែងតែប៉ុណ្ណោះ ហេតុដូច្នេះ ក្រោយពេលដែលអាជ្ញាសាលាបានអនុវត្តលក់ តុលាការអនុវត្តត្រូវចេញដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់ ដោយកំណត់កាលបរិច្ឆេទ ។ ម្យ៉ាងទៀត បើប្រៀបធៀបនឹងចលនវត្ថុ ជាដើម អចលនវត្ថុជាទូទៅមានតម្លៃខ្ពស់ណាស់ ហេតុនេះហើយ ដើម្បីឱ្យលក់ដោយហ្មត់ចត់ ក្រោយពេលដែលនីតិវិធីលក់បានបញ្ចប់ដោយអាជ្ញាសាលា តុលាការអនុវត្តគួរតែចេញដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់ ដោយបានពិនិត្យជាថ្មីនូវនីតិវិធីទាំងអស់ចាប់តាំងពីដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ រហូតដល់ការលក់ ។

Civil Execution Act (Japan)
**Article 69** (Date for ruling to sell)
The execution court shall proceed on the date for the ruling to sell to announce permission or refusal to sell.

**មាត្រា ៤៤១.-** ការថ្លែងយោបល់អំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់

បុគ្គលដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់អចលនវត្ថុ អាចថ្លែងយោបល់អំពីហេតុដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ២ មាត្រា ៤៤២ ( ការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់ ) នៃក្រមនេះ ដែលបណ្ដាលឱ្យមានឥទ្ធិពលដល់សិទ្ធិរបស់ខ្លួន នៅក្នុងកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់បាន ។

( កំណត់ )

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 70 ។ "បុគ្គលដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍" មានដូចជា ម្ចាស់បំណុលនៃការអនុវត្ត កូនបំណុលនៃការអនុវត្ត ម្ចាស់បំណុលដែលទាមទារចំណែក អ្នកដែលមានសិទ្ធិប្រត្យក្ស ជាដើម លើអចលនវត្ថុ ដែលអាចតតាំងចំពោះម្ចាស់បំណុលនៃការអនុវត្ត អ្នកដែលស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ ក្រោមអតិបរមា ជាដើម ។

Civil Execution Act (Japan)
**Article 70** (Statement of opinion concerning permission or refusal to sell)
A person interested in the permission or refusal to sell an immovable may state an opinion on the date for the ruling to sell based on any of the grounds mentioned in the next article.

**មាត្រា ៤៤២.-** ការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់

១- លើកលែងតែក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ តុលាការអនុវត្តត្រូវចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ ។

២- តុលាការអនុវត្តត្រូវចេញដីកាសម្រេចមិនអនុញ្ញាតឱ្យលក់ បើទទួលស្គាល់ថា មានហេតុណាមួយដូចកំណត់ក្នុងចំណុចខាងក្រោមនេះ :

**ក-** មិនត្រូវចាប់ផ្តើម ឬ បន្តនូវនីតិវិធីនៃការលក់ដោយបង្ខំ ។

**ខ-** អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ពុំមានលក្ខណសម្បត្តិ ឬ សមត្ថភាពដើម្បីទិញអចលនវត្ថុ ឬ អ្នកតំណាងរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ពុំមានសិទ្ធិនោះ ។

**គ-** មានសេចក្តីស្នើសុំកុំឱ្យអនុញ្ញាតការលក់ ដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៤៤៥ (ការស្នើសុំកុំឱ្យអនុញ្ញាតការលក់ ជាអាទិ៍ ក្នុងករណីដែលអចលនវត្ថុត្រូវបានខូចខាត) នៃក្រមនេះ ។

**ឃ-** មានកំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា ។

**ង-** មានកំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃការលក់ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 71 ។

ក្រោយពេលដែលនីតិវិធីលក់បានបញ្ចប់ដោយអាជ្ញាសាលា តុលាការនឹងចេញដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់ដោយបានពិនិត្យជាថ្មីនូវនីតិវិធីទាំងអស់ចាប់តាំងពីដីកាសម្រេចចាប់ផ្តើមការលក់ រហូតដល់ការបញ្ចប់ការលក់ ។ នៅពេលនោះ ក្នុងករណីដែលមានវិការៈបន្តិចបន្តួច បើឱ្យធ្វើសារឡើងវិញជាថ្មីនូវនីតិវិធី ធ្វើឱ្យខាតបង់ពេលវេលា និងសោហ៊ុយនោះ ហេតុដូច្នេះ កថាខណ្ឌទី ២ នៃមាត្រានេះ រៀបរាប់នូវហេតុជាវិការៈធ្ងន់ធ្ងរដែលមិនត្រូវអនុញ្ញាតឱ្យមានការលក់ ។ បើត្រូវនឹងចំណុចណាមួយក្នុងចំណោមចំណុចទាំងនេះ ការលក់នឹងមិនអនុញ្ញាតទេ ហើយបើគ្មានហេតុទាំងនោះទេ ការលក់នឹងត្រូវអនុញ្ញាត ។ ចំពោះហេតុនៃការមិនអនុញ្ញាតឱ្យលក់ទាំងនេះ បុគ្គលដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍អាចថ្លែងជាយោបល់បាន នៅកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ (សូមមើលមាត្រា ៤៤១ (ការថ្លែងយោបល់អំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់)) ហើយទោះជាមាន ឬ គ្មានសេចក្តីថ្លែងយោបល់នេះក៏ដោយ តុលាការអនុវត្តត្រូវស្រាវជ្រាវអំពីអត្ថិភាពនៃហេតុទាំងនោះ ដោយឆន្ទានុសិទ្ធិ ។

Civil Execution Act (Japan)
**Article 71** (Grounds for refusal to sell)
The execution court, if it finds that any of the following grounds exists, may render a ruling of refusal to sell:
i. hat the procedure of compulsory sale by auction should not be commenced or continued;
ii. that the highest bidder does not have the qualifications or capacity to buy the immovable, or that the representative of the highest bidder has no authority to do so;
iii. that the highest bidder has made the offer to buy for the account of another person who has no qualifications to buy the immovable;

iv. that the highest bidder, his representative or the person on whose behalf the highest bidder offered to buy on his account is:
a. a person who has committed an act referred to in Article 65 item i in the procedure of compulsory sale by auction; or
b. a person who has failed to pay the required price in the procedure of compulsory sale by auction, or a person who has had such person offer to buy on his account in the said procedure; or
c. a person referred to in Article 65 item ii or iii.
v. that an application for refusal to sell has been made in accordance with the provisions of Article 75, paragraph 1;
vi. that there are serious mistakes in the establishment of the minimum sales price, the ruling to sell several immovables as an undivided whole, the drawing up of specifications or in these procedures;
vii. that there are serious mistakes in the procedure of sale.

**មាត្រា ៤៤៣.-** វិធានការក្នុងករណីលក់ហួសកម្រិត

១- ក្នុងករណីដែលបានលក់អចលនវត្ថុច្រើន បើតម្លៃស្នើសុំទិញនៃអចលនវត្ថុណាមួយ ឬ ច្រើន ក្នុងចំណោមអចលនវត្ថុទាំងអស់នោះ ត្រូវបានប៉ាន់ប្រមាណឃើញថា អាចសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បានតុលាការអនុវត្តត្រូវបម្រុងទុកនូវដីកាសម្រេចអនុញ្ញាតឱ្យលក់អចលនវត្ថុផ្សេងទៀត ។

២- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើមានអចលនវត្ថុច្រើនដែលត្រូវបានប៉ាន់ប្រមាណថា តម្លៃស្នើសុំទិញនៃអចលនវត្ថុនីមួយៗនោះ អាចសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បាន ឬ បើសមាយោគនៃអចលនវត្ថុមានច្រើនដែលត្រូវបានប៉ាន់ប្រមាណថា តម្លៃស្នើសុំទិញនៃសមាយោគនីមួយៗនោះ អាចសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បាន តុលាការអនុវត្តត្រូវសួរយោបល់របស់កូនបំណុលនៃការអនុវត្តជាមុន អំពីអចលនវត្ថុដែលត្រូវអនុញ្ញាតឱ្យលក់ ។

៣- អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមានៃអចលនវត្ថុដែលដីកាសម្រេចអនុញ្ញាតឱ្យលក់ត្រូវបានបម្រុងទុក ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អាចលុបចោលសំណើទិញនោះ ដោយជូនដំណឹងទៅតុលាការអនុវត្តបាន ។

៤- បើថ្លៃលក់ត្រូវបានបង់ចំពោះអចលនវត្ថុដែលមានដីកាសម្រេចអនុញ្ញាតឱ្យលក់ តុលាការអនុវត្តត្រូវលុបចោលនូវនីតិវិធីនៃការលក់ដោយបង្ខំ ដែលទាក់ទងនឹងអចលនវត្ថុ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 73 ។

ម្ចាស់បំណុលនៃការអនុវត្តអាចទាមទារឱ្យលក់អចលនវត្ថុច្រើន តាមពាក្យសុំតែមួយ ប៉ុន្តែ នៅក្នុងដំណាក់កាលនៃការរឹបអូស ដោយគ្មានបញ្ញត្តិហាមឃាត់ការរឹបអូសហួសប្រមាណ ដូចជាករណីនៃការអនុវត្តចំពោះចលនវត្ថុ ឬ ការអនុវត្តចំពោះសិទ្ធិលើបំណុល ជាដើម នោះតុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្តើមការលក់ ចំពោះអចលនវត្ថុទាំងនោះ ។ ចំពោះការអនុវត្តចំពោះអចលនវត្ថុ ដោយហេតុថា មិនច្បាស់លាស់អំពីតម្លៃនៃអចលនវត្ថុ ឬ សិទ្ធិលើបំណុលដែលគេនឹងទាមទារឱ្យចែកចំណែក ជាដើម នៅក្នុងដំណាក់កាលនៃដីកាសម្រេចចាប់ផ្តើម នោះស្ថាប័នអនុវត្តមានការលំបាកនឹងធ្វើការប៉ាន់ប្រមាណក្នុងដំណាក់កាលនៃការចាប់ផ្តើមអនុវត្ត ដូចចលនវត្ថុ ឬ សិទ្ធិលើបំណុល ។ ហេតុដូច្នេះ ច្បាប់ចែងថា

នៅក្នុងជំហាននៃការរឹបអូស តុលាការត្រូវជម្រុញនីតិវិធីអនុវត្ត ដោយមិនវិនិច្ឆ័យអំពីការរឹបអូសហួសប្រមាណ ឬ មិនហួសប្រមាណ ។ ប៉ុន្តែ ក្រោយមកនោះ នីតិវិធីមានដំណើរទៅមុខ ហើយក្រោយពីបានអនុវត្តការលក់ អចលនវត្ថុច្រើន បើមានលទ្ធភាពអាចសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្ត ទាំងអស់ ដោយយកប្រាក់លក់អចលនវត្ថុមួយផ្នែកក្នុងចំណោមអចលនវត្ថុទាំងនោះ ការចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ អចលនវត្ថុទាំងអស់ នាំឱ្យខាតប្រយោជន៍ហួសហេតុដល់កូនបំណុល តុលាការអនុវត្តត្រូវចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ ចំពោះតែអចលនវត្ថុមួយផ្នែកនោះ ហើយត្រូវបម្រុងទុកដីកាសម្រេចអនុញ្ញាតឱ្យលក់ (កថាខណ្ឌទី ១) ។ ក្នុងករណីនេះ ឧទាហរណ៍ ករណីដែលចំនួនសរុបនៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលគ្រប់រូប និង សោហ៊ុយសម្រាប់ការអនុវត្ត មាន ១០០ ម៉ឺន រៀល តម្លៃស្នើសុំទិញអតិបរមានៃអចលនវត្ថុ A គឺ ១២០ ម៉ឺន រៀល ហើយតម្លៃអតិបរមានៃអចលនវត្ថុ B ថ្លៃ ៦០ ម៉ឺន រៀល និង តម្លៃអតិបរមានៃអចលនវត្ថុ C ថ្លៃ ៥០ ម៉ឺន រៀល នោះតុលាការអនុវត្តត្រូវសួរយោបល់ ពីកូនបំណុលនៃការអនុវត្ត ថាតើចេញដីកាសម្រេចអនុញ្ញាតឱ្យលក់អចលនវត្ថុ A ឬ ចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ អចលនវត្ថុ B និង អចលនវត្ថុ C (កថាខណ្ឌទី ២) ។ បើអ្នកទិញនៃអចលនវត្ថុដែលដីកាសម្រេចអនុញ្ញាតឱ្យលក់ ត្រូវបានចេញ ក្នុងចំណោមអចលនវត្ថុច្រើន បានបង់ថ្លៃលក់រួចហើយ ចំពោះអចលនវត្ថុឯទៀតដែលដីកាសម្រេចអនុញ្ញាត ឱ្យលក់ត្រូវបានបម្រុងទុក ដោយពុំមានន័យតទៅទៀតនឹងសម្រេចការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់នោះ តុលាការអនុវត្តត្រូវលុបចោលនីតិវិធីនៃការលក់ដោយបង្ខំចំពោះអចលនវត្ថុទាំងនេះ (កថាខណ្ឌទី ៤) ។ បើអ្នកទិញនៃ អចលនវត្ថុដែលដីកាសម្រេចអនុញ្ញាតឱ្យលក់ត្រូវបានចេញ ក្នុងចំណោមអចលនវត្ថុច្រើន មិនបានបង់ថ្លៃលក់នោះ ដីកាសម្រេចអនុញ្ញាតឱ្យលក់អចលនវត្ថុនោះត្រូវបាត់បង់អានុភាព ។ ក្នុងករណីនេះ តុលាការអនុវត្តនឹងចេញដីកាសម្រេច អនុញ្ញាតឱ្យលក់អចលនវត្ថុដែលដីកាសម្រេចអនុញ្ញាតឱ្យលក់ត្រូវបានបម្រុងទុក ។

<u>Civil Execution Act (Japan)</u>
**Article 73** (Measures taken in cases of excessive sale)
1. When several immovables have been sold and all obligation-rights of the respective obligees and execution costs are likely to be satisfied by the price offered for any of the immovables, the execution court shall reserve its ruling of permission to sell the other immovables.

2. In cases referred to in the preceding paragraph, if there are several immovables for each of which the offering price is likely to satisfy every obligation-right of the respective obligees and the execution costs, the execution court shall hear the opinion of the obligor as to which immovable should be permitted to be sold.

3. The highest bidder or bidder in the next order on an immovable on which a ruling of permission to sell has been reserved in accordance with the provisions of paragraph 1 may cancel his offer with the execution court.

4. In cases where the price of an immovable whose sale has been permitted and whose price has been paid, the execution court shall annul the procedure of compulsory sale by auction concerning the immovable refereed to in the preceding paragraph.

**មាត្រា ៤៤៤.-** បណ្តឹងជំទាស់ចំពោះដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់

១- ចំពោះដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចប្តឹងជំទាស់បាន លុះត្រាតែក្នុងករណីដែលដីកាសម្រេចនោះបណ្តាលឱ្យមានខូចខាតដល់សិទ្ធិរបស់ខ្លួន ។

២- បណ្តឹងជំទាស់ចំពោះដីកាសម្រេចអនុញ្ញាតឱ្យលក់ ត្រូវយកហេតុដូចបានកំណត់ក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ២

នៃមាត្រា ៤៤២ (ការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់) នៃក្រមនេះ ឬ កំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃដីកាសម្រេចអនុញ្ញាតឱ្យលក់នោះ មកធ្វើជាមូលហេតុ ។

៣- បើទទួលស្គាល់ថាចាំបាច់ តុលាការនៃបណ្តឹងជំទាស់ អាចកំណត់ភាគីម្ខាងទៀតនៃម្ចាស់បណ្តឹងជំទាស់បាន ។

៤- ដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់នេះ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 74 ។ ករណីនៃកំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃដីកាសម្រេចអនុញ្ញាតឱ្យលក់ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នោះ មានដូចជា ករណីដែលបានចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ ដោយគ្មានការប្រកាស នៅកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ (មាត្រា ៤៤០), ករណីដែលតុលាការមិនអនុញ្ញាតឱ្យជនដែលមានផលប្រយោជន៍ក្នុងការអនុញ្ញាតឱ្យលក់ ឬ ការមិនអនុញ្ញាតឱ្យលក់ធ្វើសេចក្តីថ្លែងការណ៍ ដោយគ្មានមូលហេតុត្រឹមត្រូវ (មាត្រា ៤៤១), ករណីដែលតុលាការនៅតែចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ ទោះបីមានការដាក់ឯកសារដែលតម្រូវឱ្យផ្អាកនីតិវិធីនៃការអនុវត្តដោយបង្ខំ (មាត្រា ៣៧០) ក្រោយពេលលក់ និង មុនពេលចេញដីកាសម្រេចការលក់ ជាដើម ។

Civil Execution Act (Japan)
**Article 74** (Kōkoku-appeal concerning execution against ruling of permission or refusal to sell)
1. A kōkoku-appeal concerning execution may be filed against a ruling of permission or refusal to sell only when the appellant insists that his won rights are infringed thereby.
2. In cases of a kōkoku-appeal concerning execution against a ruling of permission to sell, the grounds therefor must be one of those mentioned in Article 71 or some serious mistake in the procedure of said ruling of permission to sell.
3. The preceding two paragraphs notwithstanding, the grounds referred to in the items of Article 420, paragraph 1 of the Code of Civil Procedure may also be claimed as grounds for a kōkoku-appeal concerning execution against a ruling of permission or refusal to sell.
4. The appellate court, if it deems necessary, may appoint a respondent to the appellant.
5. A ruling of permission of refusal to sell shall not become effective until it becomes final and binding.

**មាត្រា ៤៤៥.-** ការស្នើសុំកុំឱ្យអនុញ្ញាតការលក់ ជាអាទិ៍ ក្នុងករណីដែលអចលនវត្ថុត្រូវបានខូចខាត

១- ក្នុងករណីដែលអចលនវត្ថុបានទទួលការខូចខាតធ្ងន់ធ្ងរ នៅក្រោយពេលធ្វើសំណើទិញដោយសារគ្រោះធម្មជាតិ ឬ ដោយសារមូលហេតុផ្សេងទៀតដែលមិនមែនជាបន្ទុករបស់ខ្លួន អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកទិញអាចស្នើសុំទៅតុលាការអនុវត្តកុំឱ្យអនុញ្ញាតការលក់ ប្រសិនបើនៅមុនពេលចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ ឬ អាចដាក់ពាក្យសុំទៅតុលាការអនុវត្តឱ្យលុបចោលដីកាសម្រេចនោះ នៅមុនពេលបង់ប្រាក់បាន ប្រសិនបើនៅក្រោយពេលចេញដីកាសម្រេចអនុញ្ញាតការលក់ហើយ ។

២- ចំពោះដីកាសម្រេចអំពីពាក្យសុំឱ្យលុបចោលដីកាសម្រេចអនុញ្ញាតឱ្យលក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៣- ដីកាសម្រេចលុបចោលដីកាសម្រេចអនុញ្ញាតឱ្យលក់ តាមពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 75 និង កំណត់នៃមាត្រា ៤៧៦ (ការស្នើសុំកុំឱ្យអនុញ្ញាតការលក់ ជាអាទិ៍ ក្នុងករណីដែលនាវាត្រូវបានខូចខាត) ។

Civil Execution Act (Japan)
**Article 75** (Application for refusal to sell where immovable has been damaged)
1. The highest bidder of the buyer, where the immovable has been damaged through natural disaster or a cause not imputable to either of them after an offer to buy has been made, may make an application for refusal to sell, if a ruling of permission to sell has not yet been rendered, or may make a motion for annulment of such ruling until he has paid the offered price, after such ruling has been rendered; provided that, in cases where damages to the immovbale is slight, this shall not apply.
2. A kōkoku-appeal may be filed against a ruling on the motion for annulment of ruling of permission to sell in accordance with the provisions of the preceding paragraph.
3. The ruling of annulment of ruling of permission to sell referred to in the preceding paragraph shall not become effective until it becomes final and binding.

**មាត្រា ៤៤៦.-** ការដកពាក្យសុំការលក់ដោយបង្ខំ នៅក្រោយពេលមានសំណើទិញ

ដើម្បីដកពាក្យសុំការលក់ដោយបង្ខំ នៅក្រោយពេលដែលមានសំណើទិញហើយ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវទទួលការយល់ព្រមពីសំណាក់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកទិញ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 76 ។

នៅពេលដែលម្ចាស់បំណុលនៃការអនុវត្តដកពាក្យសុំការលក់ដោយបង្ខំ ពុំចាំបាច់មានការយល់ព្រមពីសំណាក់កូនបំណុលនៃការអនុវត្តទេ ។ ម្យ៉ាងទៀត ការយល់ព្រមពីម្ចាស់បំណុលដែលអាចចូលរួមក្នុងការទាមទារឱ្យចែកចំណែក ដូចជាម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគ ជាដើម ក៏មិនចាំបាច់មានដែរ ដោយសារម្ចាស់បំណុលទាំងនេះគ្រាន់តែទទួលបាននូវឋានៈដែលអាចទទួលចំណែកដោយប្រើនូវឱកាសល្អលើនីតិវិធីតែប៉ុណ្ណោះ ។ ប៉ុន្តែ ផ្ទុយទៅវិញ ចំពោះអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកទិញ ម្ចាស់បំណុលនៃការអនុវត្តត្រូវទទួលការយល់ព្រមពីអ្នកទាំងនេះ ។ គឺមកពីហេតុថា ប្រសិនបើបុគ្គលដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍ផ្ទាល់ទៅលើការទិញអចលនវត្ថុ នឹងត្រូវបាត់បង់ឋានៈដែលអាចទទួលយកអចលនវត្ថុនោះ ដោយសារតែការដកពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តតែឯកឯង នោះបណ្តាលឱ្យខ្វះខាតក្នុងការការពារជនទាំងនោះ និង នាំឱ្យបាត់បង់ជំនឿទុកចិត្តយ៉ាងខ្លាំងលើប្រព័ន្ធនៃការលក់ដោយបង្ខំនៃអចលនវត្ថុ ។

Civil Execution Act (Japan)
**Article 76** (Withdrawal of motion for compulsory sale by auction after offer to buy has been made)

1. In order to withdraw a motion for compulsory sale by auction after an offer to buy has been made, the moving party must obtain the consent of the highest bidder or buyer and bidder in the next order. This shall not apply in cases where there is another attachment obligee (except for an attachment obligee who has made a motion for compulsory sale by auction or sale by auction after the final date for demand distribution), if no alteration occurs with respect to matters referred to in Article 62 item ii.
2. The provisions of the preceding paragraph shall apply *mutatis mutandis* to cases where a document referred to in items iv or v of Article 39, paragraph 1 is submitted after an offer to buy has been made.

## កថាភាគទី ៤ អានុភាពនៃការលក់

**មាត្រា ៤៤៧.-** ការបង់ថ្លៃលក់

១- បើដីកាសម្រេចអនុញ្ញាតឱ្យលក់បានចូលជាស្ថាពរ អ្នកទិញត្រូវបង់ថ្លៃលក់ទៅតុលាការអនុវត្ត នៅមុនពេលដែលតុលាការអនុវត្តបានកំណត់ ។ ពេលកំណត់នេះ ត្រូវស្ថិតនៅក្នុងអំឡុងពេល ១ (មួយ) ខែចាប់ពីថ្ងៃដែលដីកាសម្រេចអនុញ្ញាតឱ្យលក់ បានចូលជាស្ថាពរ ។

២- ចំនួនទឹកប្រាក់ដែលអ្នកទិញបានដាក់ដើម្បីធានាលើសំណើទិញ ត្រូវគិតបញ្ចូលក្នុងថ្លៃលក់ ។

៣- បើអ្នកទិញគឺជាម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែកពីប្រាក់លក់ អ្នកទិញនោះអាចបង់ថ្លៃលក់ ដោយដកនូវចំនួនទឹកប្រាក់ដែលខ្លួនត្រូវទទួលពីការចែកចំណែក នៅកាលបរិច្ឆេទនៃការចែកចំណែកបាន ដោយស្នើសុំទៅតុលាការអនុវត្ត នៅមុនពេលបញ្ចប់កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ ។ ក្នុងករណីនេះ បើមានសេចក្ដីថ្លែងតវ៉ាអំពីចំនួនប្រាក់នៃការចែកចំណែកដែលអ្នកទិញត្រូវទទួល អ្នកទិញត្រូវបង់ចំនួនប្រាក់ដែលស្មើនឹងភាគដែលមានការតវ៉ានោះជាបន្ទាន់ ។

៤- អ្នកទិញធ្វើលទ្ធកម្មនូវអចលនវត្ថុ នៅពេលដែលខ្លួនបានបង់ថ្លៃលក់ហើយ ។

(កំណត់)

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 78 និង មាត្រា 79 និង បញ្ញត្តិស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 56 ។

(1) ចំពោះកំណត់ពេលដែលអ្នកទិញត្រូវបង់ថ្លៃលក់ តុលាការអនុវត្តត្រូវកំណត់ដោយយោងទៅតាមរឿងក្ដីនីមួយៗ (កថាខណ្ឌទី ១) ។ ហើយ ពេលដែលអ្នកទិញធ្វើលទ្ធកម្មនូវអចលនវត្ថុ គឺនៅពេលបង់ថ្លៃលក់ (កថាខណ្ឌទី ៤) ។

(2) ក្នុងករណីដែលអ្នកទិញគឺជាម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែកពីប្រាក់លក់ ជាវិធីបង់ប្រាក់ដែលសង្ខេប ច្បាប់អនុញ្ញាតឱ្យអ្នកទិញនោះ បង់តែចំនួនខ្វះ (កថាខណ្ឌទី ៣) ។ ឧទាហរណ៍ ក្នុងករណីដែលម្ចាស់បំណុលដែលមានបំណុល ១០០ ម៉ឺន រៀល បានដេញថ្លៃអចលនវត្ថុនោះបាន ដោយតម្លៃ ២០០ ម៉ឺន រៀល ការដែលបង់ប្រាក់ ២០០ ម៉ឺន រៀលសិន ហើយសឹមទទួលការចែកចំណែក ១០០ ម៉ឺន រៀលពីប្រាក់នោះ គឺជាការឥតប្រយោជន៍ ហើយត្រូវចំណាយសោហ៊ុយដើម្បីផ្គត់ផ្គង់ធនផងនោះ ហេតុដូច្នេះ ច្បាប់អនុញ្ញាតឱ្យអ្នកទិញនោះបង់តែចំនួន ១០០ ម៉ឺន រៀល ដែលជាចំនួនខ្វះ (ជាជំនួសនោះ ពុំអាចទទួលការចែកចំណែកទេ) ។ ប៉ុន្តែ ដោយសារចំនួនប្រាក់ចំណែកចុង

ក្រោយ ពុំអាចកំណត់ជាស្ថាពរ បើមិនបានឆ្លងកាត់តាមកាលបរិច្ឆេទនៃការចែកចំណែកនោះ ហេតុដូច្នេះ ក្នុងករណីដែលម្ចាស់បំណុលឯទៀតមានការតវ៉ាចំពោះចំនួនប្រាក់ចំណែករបស់អ្នកទិញនោះ ការបង់តែចំនួនខ្វះ មិនត្រូវបានអនុញ្ញាត ចំពោះភាគដែលមានការតវ៉ានោះឡើយ (វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ៣) ។ លើឧទាហរណ៍មុន ក្នុងករណីដែលមានម្ចាស់បំណុលឯទៀតអះអាងថា សិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលជាអ្នកទិញនោះ មានចំនួន ៣០ ម៉ឺន រៀល តុលាការនឹងទទួលស្គាល់ករណីយកិច្ចរបស់អ្នកទិញនោះ ក្នុងការបង់ចំនួន ៧០ ម៉ឺន រៀលដែលមានការតវ៉ា ។

<u>Civil Execution Act (Japan)</u>
**Article 78** (Payment of pricel)
1. If a ruling of permission to sell becomes final and binding, the buyer shall pay the price to the execution court by the date provided by such court.
2. The amount of money provided by the buyer as security for an offer to buy and paid in accordance with the provisions of paragraph 1 of the preceding Article shall be allocated to the price.
3. Where the buyer has provided security as mentioned in Article 63, paragraph 2 item i by means other than payment of money, the execution court shall realize such security in accordance with the provisions of the Rules of the Supreme Court and shall allocate the amount after subtracting expenses incurred for realization.
4. Where the buyer is a person who is to receive some distribution of or payment out of the price, such buyer may, until after the date for the ruling to sell, give notice thereof to the execution court, and may pay on the date for distribution or the day for payment due has been subtracted. If an allegation or motion of objection is made with regard to the amount to be distributed to the buyer, such buyer shall immediately make payment equal to the amount objected to.
**Article 79** (Time of acquisition of immovable)
The buyer acquires the immovable when he pays the purchase price.

**មាត្រា ៤៤៨.-** ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជី ដោយការបង់ថ្លៃលក់

១- ប្រសិនបើអ្នកទិញបានបង់ថ្លៃលក់ហើយ ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី និង លុបការចុះបញ្ជីនូវចំណុចដូចកំណត់ខាងក្រោមនេះ :

**ក**- ការចុះបញ្ជី អំពីការផ្ទេរសិទ្ធិដែលអ្នកទិញបានធ្វើលទ្ធកម្ម ។

**ខ**- ការលុបការចុះបញ្ជី អំពីលទ្ធកម្មនូវសិទ្ធិដែលបានរលត់ដោយការលក់ ឬ សិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់ ។

**គ**- ការលុបការចុះបញ្ជី អំពីការចាត់ចែងជាបណ្ដោះអាសន្នដែលបានបាត់បង់អានុភាពដោយការលក់ ។

**ឃ**- ការលុបការចុះបញ្ជី អំពីការរឹបអូស ឬ ការរឹបអូសជាបណ្ដោះអាសន្ន ។

២- ដើម្បីផ្ទុកផ្ដាក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចអនុញ្ញាតឱ្យលក់ ជាមួយនឹងលិខិតផ្ទុកផ្ដាក់នោះ ។

៣- សោហ៊ុយចាំបាច់ដើម្បីផ្ទុកផ្ដាក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ជាបន្ទុករបស់អ្នកទិញ ។

(កំណត់)

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 82 ។

(1) មាត្រានេះចែងអំពីចំណាត់ការក្រោយដំណើរហេតុរបស់តុលាការអនុវត្ត នៅពេលអចលនវត្ថុត្រូវបានផ្ទេរទៅអ្នកទិញ ដែលឱ្យក្រឡាបញ្ជីផ្ញើផ្ញើកផ្ដាក់ឱ្យចុះបញ្ជីអំពីអចលនវត្ថុនោះ ។ ការផ្ញើកផ្ដាក់នេះ ត្រូវអនុវត្តដោយឆន្ទានុសិទ្ធិរបស់ក្រឡាបញ្ជី តែចំពោះសោហ៊ុយចាំបាច់សម្រាប់ការចុះបញ្ជី គឺជាបន្ទុករបស់អ្នកទិញដែលទទួលនូវផលប្រយោជន៍ (កថាខណ្ឌទី ៣) ។

(2) ចំពោះកម្មវត្ថុនៃការផ្ញើកផ្ដាក់ឱ្យចុះបញ្ជី ការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិទៅអ្នកទិញ (ចំណុច **ក** នៃកថាខណ្ឌទី ១) គឺជាចំណុចសំខាន់ តែការផ្ញើកផ្ដាក់ឱ្យលុបការចុះបញ្ជីដែលទាក់ទងនឹងសិទ្ធិដែលរលត់ ឬ បាត់បង់អានុភាពដោយការលក់ ក៏ត្រូវបានអនុវត្តផងដែរ (អំពីសិទ្ធិយ៉ាងណាដែលត្រូវរលត់ ឬ ត្រូវបាត់បង់អានុភាពដោយការលក់ សូមមើលមាត្រា ៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់)) ។ ការចុះបញ្ជីអំពីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ហ៊ីប៉ូតែក ជាដើម ដែលនឹងបាត់បង់អានុភាពដោយការលក់ និង ការចុះបញ្ជីអំពីការចាត់ចែងការរក្សាការពារ ឬ ការរឹបអូស ជាដើម (ចំណុច **ខ គ** និង **ឃ** នៃកថាខណ្ឌទី ១) ។

<u>Civil Execution Act (Japan)</u>
**Article 82** (Registration of payment)
1. When the buyer pays the purchase price, the court clerk shall entrust the register:
  i. to make registration of the transfer of the right acquired by the buyer; and
  ii. to erase registrations of rights extinguished by the sale or the acquisition of a right or provisional disposition which has lost its effect because of the sale; and
  iii. to erase registrations of attachment or provisional attachment.
2. When entrusting the registrar, the court clerk shall append an exemplification of the ruling of permission to sell with the document of entrustment.
3. The buyer shall bear the registration tax and any other costs necessary for entrusting the registrar according to the provisions of paragraph 1.

**មាត្រា ៤៤៩.-** ការទទួលខុសត្រូវរបស់អ្នកទិញ

១- ចំពោះសិទ្ធិប្រាតិភោគដែលនឹងបន្តអត្ថិភាពក្រោយការលក់ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់) នៃក្រមនេះ បើកូនបំណុលនៃការអនុវត្តជាកូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគទាំងនេះ អ្នកទិញត្រូវទទួលខុសត្រូវក្នុងការសងនូវសិទ្ធិលើបំណុលនោះ ។

២- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសិទ្ធិប្រាតិភោគដែលនឹងបន្តអត្ថិភាពក្រោយការលក់ជាហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត អ្នកទិញត្រូវទទួលខុសត្រូវក្នុងការសងនូវសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែតនោះ ក្នុងកម្រិតនៃចំនួនអតិបរមា ។

(កំណត់)

សូមមើលច្បាប់ស្ដីពីការលក់ឡាយឡុងដោយបង្ខំ និង ការគ្រប់គ្រងដោយបង្ខំនៃប្រទេសអាល្លឺម៉ង់ កថាខណ្ឌទី 1 នៃ

មាត្រា 53 និង ច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន កថាខណ្ឌទី 4 នៃមាត្រា 59 ។

ក្នុងក្រមនេះដែលជ្រើសយកគោលការណ៍ទទួលបន្តចំពោះសិទ្ធិប្រាតិភោគ អ្នកទិញអាចទិញអចលនវត្ថុក្នុងតម្លៃថោកជាងតម្លៃពិតប្រាកដនៃអចលនវត្ថុនោះ ដោយយកការទទួលបន្តនូវបន្ទុកនៃកាតព្វកិច្ចដែលត្រូវបានធានាដោយ សិទ្ធិប្រាតិភោគជាល័ក្ខខ័ណ្ឌមូលដ្ឋាន ។ ឧទាហរណ៍ ក្នុងករណីដែលអចលនវត្ថុដែលមានតម្លៃ ១០ លាន រៀល ជាប់ជាមួយនឹងហ៊ីប៉ូតែកដែលធានាសិទ្ធិលើបំណុលចំនួន ៧ លាន រៀល អ្នកទិញអាចទិញអចលនវត្ថុនោះក្នុងតម្លៃ ៣ លាន រៀល តែក្នុងករណីនេះ គួរឱ្យអ្នកទិញទទួលខុសត្រូវសងចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាចំនួន ៧ លាន រៀល ។ ហេតុដូច្នេះ កថាខណ្ឌទី ១ នៃមាត្រានេះចែងអំពីករណីយកិច្ចត្រូវសងចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគដែលអ្នកទិញបានទទួលបន្ត ។

តាមចំណុច **គ** កថាខណ្ឌទី ១ នៃមាត្រា ៨៨៥ (ហេតុដែលនាំឱ្យកំណត់ប្រាក់ដើមជាស្ថាពរ) នៃក្រមរដ្ឋប្បវេណី ការចាប់ផ្ដើមនីតិវិធីនៃការលក់ដោយបង្ខំចំពោះអចលនវត្ថុហ៊ីប៉ូតែក នាំឱ្យកំណត់ប្រាក់ដើមនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែតជាស្ថាពរ ។ ក្នុងករណីនេះ ការណ៍ដែលអ្នកទិញត្រូវទទួលខុសត្រូវក្នុងការសងនូវសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែតនោះ ត្រូវបានចែងនៅក្នុងកថាខណ្ឌទី ១ រួចហើយ ។ កថាខណ្ឌទី ២ បញ្ជាក់ច្បាស់ថា ការទទួលខុសត្រូវក្នុងការសងនោះ មានកម្រិតក្នុងទំហំនៃចំនួនអតិបរមានៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត ។

Civil Execution Act (Japan)
**Article 59** (Extinguishment of right by sale) > *see the note for Article 431*

## មាត្រា ៤៥០.~ ដីកាសម្រេចបង្គាប់ឱ្យប្រគល់អចលនវត្ថុ

១- តុលាការអនុវត្តអាចចេញដីកាសម្រេចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត ឬ អ្នកកាន់កាប់អចលនវត្ថុ ប្រគល់អចលនវត្ថុនោះទៅឱ្យអ្នកទិញ តាមពាក្យសុំរបស់អ្នកទិញដែលបានបង់ថ្លៃលក់ហើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះជនដែលត្រូវបានទទួលស្គាល់ថា កាន់កាប់អចលនវត្ថុនោះ ដោយផ្អែកលើសិទ្ធិដែលអាចតតាំងជាមួយនឹងអ្នកទិញ ដោយយោងទៅតាមសំណុំរឿងនៃការអនុវត្តដោយបង្ខំ ។

២- បើហួសអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃដែលអ្នកទិញបានបង់ថ្លៃលក់ហើយ អ្នកទិញនោះ ពុំអាចដាក់ពាក្យសុំ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបានទេ ។

៣- ក្នុងករណីដែលបានចេញដីកាសម្រេចចំពោះអ្នកកាន់កាប់ ក្រៅពីកូនបំណុលនៃការអនុវត្ត តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តត្រូវសួរជននោះ ។

៤- ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

៥- ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ ។

（កំណត់）

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 83 ។

(1) ដូចករណីនៃមាត្រា ៤៤៩（ការទទួលខុសត្រូវរបស់អ្នកទិញ）មាត្រានេះចែងអំពីចំណាត់ការក្រោយដំណើរហេតុរបស់តុលាការអនុវត្តដែលចែងថា ក្នុងករណីដែលមានអ្នកកាន់កាប់អចលនវត្ថុដែលត្រូវបានលក់ តុលាការអនុវត្តអាចដកការកាន់កាប់របស់ជននោះ ហើយឱ្យអ្នកទិញអាចទទួលនូវការកាន់កាប់នោះ ដោយនីតិវិធីសង្ខេប ។ នេះជារឿងប្រាកដហើយថា អ្នកទិញអាចដាក់ពាក្យបណ្តឹងទាមទារឱ្យប្រគល់ ដែលជាការអនុវត្តសិទ្ធិទាមទារឱ្យប្រគល់ដោយផ្អែកលើកម្មសិទ្ធិតាមច្បាប់សារធាតុ ហើយអាចទទួលសាលក្រម ឬ សាលដីកាដែលបង្គាប់ឱ្យប្រគល់បាន តែដោយសារការធ្វើបណ្តឹងនោះ ត្រូវចំណាយពេលវេលា និង សោហ៊ុយ មាត្រានេះធ្វើឱ្យមានលទ្ធភាពប្រគល់ដោយនីតិវិធីនៃដីកាសម្រេចដែលមានភាពងាយស្រួល ហើយនាំឱ្យមានលទ្ធភាពលក់ក្នុងតម្លៃខ្ពស់ ដោយប្រមូលអ្នកស្នើសុំទិញច្រើន ។

(2) អ្នកដែលនឹងត្រូវបានបង្គាប់ឱ្យប្រគល់ ក្រៅពីកូនបំណុល គឺអ្នកកាន់កាប់ដែលពុំ "ត្រូវបានទទួលស្គាល់ថា កាន់កាប់អចលនវត្ថុនោះ ដោយផ្អែកលើសិទ្ធិដែលអាចតតាំងជាមួយនឹងអ្នកទិញនៅលើសំណុំរឿងក្តីបាន"（កថាខណ្ឌទី ១）។ ចំពោះទំនាក់ទំនងនៃការតតាំង នេះជាការគ្រប់គ្រាន់បើវិនិច្ឆ័យតាម "សំណុំរឿងក្តី" ដូចជារបាយការណ៍នៃការពិនិត្យស្ថានភាពបច្ចុប្បន្នជាដើម ហើយពុំចាំបាច់ធ្វើការវិនិច្ឆ័យអំពីទំនាក់ទំនងតាមច្បាប់សារធាតុតាមវិធីផ្សេងទេ ។ អ្នកកាន់កាប់ដូចនេះប្រហែលជាអាចត្រូវបានទទួលស្គាល់ថា មានសិទ្ធិកាន់កាប់ តាមលទ្ធផលនៃការវិនិច្ឆ័យ ដោយហ្មត់ចត់ តែដោយយកការឱ្យកាន់កាប់ជាបន្ទាន់របស់អ្នកទិញជាអាទិភាព មាត្រានេះបានកំណត់ឱ្យអ្នកកាន់កាប់ដូចនេះដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍ ដោយខ្លួនឯង ចំពោះដីកាសម្រេចបង្គាប់ឱ្យប្រគល់ ។ ប៉ុន្តែដើម្បីធានានីតិវិធីរបស់អ្នកកាន់កាប់ មាត្រានេះបានកំណត់ការសួរជាការដែលចាំបាច់ ក្នុងនីតិវិធីនៃដីកាសម្រេច（កថាខណ្ឌទី ៣）។

(3) ដោយសារដីកាសម្រេចបង្គាប់ឱ្យប្រគល់ ដូចបានរៀបរាប់ខាងលើ គឺជាការចាត់ចែងបន្ទាប់បន្សំដែលភ្ជាប់នឹងនីតិវិធីអនុវត្ត មាត្រានេះកំណត់នូវអំឡុងពេល តែចំនួន ៦ ខែ ក្រោយការបង់ថ្លៃលក់（ការធ្វើលទ្ធកម្មនូវកម្មសិទ្ធិ）（កថាខណ្ឌទី ២）។ ម្យ៉ាងទៀត ដោយជាដីកាសម្រេចដែលប្រកបដោយអានុភាពដ៏សំខាន់នោះ មាត្រានេះបានកំណត់ផងដែរថា អាចប្តឹងជំទាស់（កថាខណ្ឌទី ៤）ហើយពុំមានអានុភាព បើមិនបានចូលជាស្ថាពរ（កថាខណ្ឌទី ៥）។

<u>Civil Execution Act (Japan)</u>
**Article 83** (Order to deliver)
1. Upon motion of a buyer who has paid the purchase price, the execution court may order the obligor, or a possessor of the immovable who, in light of the record of the case, sin not deemed to have been in possession on the basis of title before the attachment became effective, to deliver the immovable to the buyer; provided, this shall not apply to one who, in light of the record of the case, has been in possession of the immovable after the attachment became effective but who is deemed to be in possession of it on the basis of a title which can be set up against the buyer.
2. The buyer may not make a motion referred to in the preceding paragraph if six moths have passed since the purchase price was

paid.
3. Where a ruling is to be rendered pursuant to the provisions of paragraph 1 with regard to a possessor other than the obligor, the execution court shall interrogated the person; provided that, if the person has already been interrogated, this shall not apply.
4. A kōkoku-appeal concerning execution may be filed against a ruling on the motion referred to in paragraph 1.
5. A ruling as mentioned in paragraph 1 shall not become effective until it becomes final and binding.

**មាត្រា ៤៥១.-** អានុភាពនៃការមិនបង់ថ្លៃលក់

១- បើអ្នកទិញមិនបានបង់ថ្លៃលក់ទេ ដីកាសម្រេចអនុញ្ញាតឱ្យលក់នោះ នឹងបាត់បង់អានុភាព ។ ក្នុងករណីនេះ អ្នកទិញមិនអាចទាមទារឱ្យសងទឹកប្រាក់ដែលខ្លួនបានដាក់ជាការធានាលើសំណើទិញបានទេ ។

២- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តត្រូវលក់ដោយបង្ខំសាជាថ្មី ។

៣- ក្នុងការលក់ដោយបង្ខំតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ អ្នកទិញដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ពុំអាចធ្វើសំណើទិញបានឡើយ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា ៨០ ។

(1) ក្នុងករណីដែលអ្នកទិញមិនបានបង់ថ្លៃលក់ ដីកាសម្រេចអនុញ្ញាតឱ្យលក់ ត្រូវបាត់បង់អានុភាព (វាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១) ។ ប៉ុន្តែ មាត្រានេះមិនយកប្រព័ន្ធដែលនីតិវិធីលក់ដោយបង្ខំនោះនឹងក្លាយទៅជា folle enchère ហើយត្រូវលក់ឡាយឡុងសាជាថ្មី តាមពាក្យសុំរបស់ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ទេ ។ ផ្ទុយទៅវិញ នីតិវិធីលក់ត្រូវអនុវត្តម្តងទៀតដោយស្វ័យប្រវត្តិ (កថាខណ្ឌទី ២) ។ ប៉ុន្តែ ក្នុងការលក់នេះ អ្នកទិញនៃការលក់លើកមុនដែលពុំបានបង់ថ្លៃលក់នោះពុំអាចស្នើសុំទិញបានទេ (កថាខណ្ឌទី ៣) ។ នេះមកពីក្រែងបារម្ភថា ជនដូចនេះនឹងមិនបង់ថ្លៃលក់ម្តងទៀត ហើយមានភាពចាំបាច់នូវការដាក់កម្មវិបាកចំពោះអំពើដែលបានរារាំងការលក់ដោយសម្រួល ។

(2) កម្មវិបាកចំពោះអ្នកទិញដែលមិនបានបង់ថ្លៃលក់ មានការរឹបអូសប្រាក់ធានាការស្នើសុំទិញ (វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១) ។ តាមលទ្ធផលនៃការលក់ម្តងទៀតនោះ ទោះបីជាថ្លៃលក់នោះ ចុះថយក្រោមចំនួនប្រាក់ធានានោះក៏ដោយ ខុសពីករណីនៃការលក់ឡាយឡុងសាជាថ្មី ផ្អែកលើប្រព័ន្ធ folle enchère ក៏អ្នកទិញដែលមិនបានបង់ថ្លៃលក់នោះ ពុំទទួលករណីយកិច្ចបង់ចំនួនប្រាក់ខ្វះ (ចំនួនខ្វះដោយប្រៀបធៀបថ្លៃលក់លើកក្រោយ ជាមួយនឹងថ្លៃលក់លើកមុន) ដោយលើសពីប្រាក់ធានានោះឡើយ ។

Civil Execution Act (Japan)
**Article 80** (Effect of failure to pay purchase price)
1. If the buyer fails to pay the purchase price, the ruling of permission to sell shall lose its effect. In such cases, the buyer may not demand return of security provided in accordance with the provisions of Article 66.
2. In cases referred to in the first sentence of the preceding paragraph if there is a second highest offer to buy, the execution court must render a ruling of permission or refusal to sell on such offer.

**មាត្រា ៤៥២.-** ថ្លៃលក់

១- ប្រាក់ដែលកំណត់ដូចខាងក្រោមនេះ ត្រូវចាត់ជាថ្លៃលក់សម្រាប់ការចែកចំណែក :

**ក-** ថ្លៃលក់អចលនវត្ថុ ។

**ខ-** ទឹកប្រាក់ដែលអ្នកទិញពុំអាចទាមទារឱ្យសងមកវិញបាន តាមបញ្ញត្តិនៃវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រា ៤៥១ (អានុភាពនៃការមិនបង់ថ្លៃលក់) នៃក្រមនេះ ។

២- ក្នុងករណីដែលអចលនវត្ថុត្រូវបានលក់ឱ្យស្រេចតែម្តង ដោយយោងតាមបញ្ញត្តិនៃមាត្រា ៤៣៣ (ការលក់សរុប) នៃក្រមនេះ បើចាំបាច់ត្រូវកំណត់ចំនួនថ្លៃលក់នៃអចលនវត្ថុនីមួយៗ ចំនួននោះចាត់ជាចំនួនដែលចែកចំនួនសរុបនៃថ្លៃលក់តាមសមាមាត្រនៃតម្លៃលក់អប្បបរមានៃអចលនវត្ថុនីមួយៗ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបន្ទុកនៃសោហ៊ុយសម្រាប់ការអនុវត្តចំពោះអចលនវត្ថុនីមួយៗ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 86 ។

(1) ចំនួនប្រាក់ដែលចាត់ជាថ្លៃលក់សម្រាប់ការចែកចំណែកឱ្យម្ចាស់បំណុល គឺ ថ្លៃលក់អចលនវត្ថុដែលត្រូវបានបង់ (ចំណុច **ក** នៃកថាខណ្ឌទី ១) ព្រមទាំងប្រាក់ធានាដែលត្រូវបានរឹបអូសក្នុងករណីដែលមិនបានបង់ប្រាក់ពីមុននោះ (សូមមើលមាត្រា ៤៥១ (អានុភាពនៃការមិនបង់ថ្លៃលក់)) (ចំណុច **ខ** នៃកថាខណ្ឌទី ១) ។

(2) ក្នុងករណីដែលការលក់ឱ្យស្រេចតែម្តង (សូមមើលមាត្រា ៤៣៣ (ការលក់សរុប)) ត្រូវបានអនុវត្ត ដីកាសម្រេចអនុញ្ញាតឱ្យលក់ក៏ត្រូវសម្រេចជាសរុបតែម្តងដែរ តែក្នុងករណីដែលវិសាលភាព ឬ លំដាប់ ជាអាទិ៍ នៃម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែកមានភាពខុសគ្នា ចំពោះអចលនវត្ថុនីមួយៗ ថ្លៃលក់សរុបនោះចាំបាច់ត្រូវចែកតាមអចលនវត្ថុនីមួយៗនោះ ។ ឧទាហរណ៍ ចំពោះអចលនវត្ថុពីរ A និង B ដែលត្រូវបានលក់ក្នុងតម្លៃ ១០ លាន រៀល ។ X ជាម្ចាស់បំណុលហ៊ីប៉ូតែកចំពោះអចលនវត្ថុ A និង Y ជាម្ចាស់បំណុលហ៊ីប៉ូតែកចំពោះអចលនវត្ថុ B ។ ចំនួនសិទ្ធិលើបំណុលរបស់ X គឺ ១០ លាន រៀល ហើយចំនួនសិទ្ធិលើបំណុលរបស់ Y ក៏ ១០ លាន រៀលដែរ ។ ក្នុងករណីនេះ ថ្លៃលក់ត្រូវបានចែកតាមសមាមាត្រនៃតម្លៃលក់អប្បបរមា (វាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ២) ។ ក្នុងឧទាហរណ៍មុន បើតម្លៃលក់អប្បបរមានៃអចលនវត្ថុ A គឺ ៦ លាន រៀល ហើយតម្លៃលក់អប្បបរមានៃអចលនវត្ថុ B គឺ ២ លាន រៀល ចំនួន ៧ លាន ៥ សែន រៀល ត្រូវបានចែកទៅអចលនវត្ថុ A ហើយចំនួនប្រាក់ ២ លាន ៥ សែន រៀល ត្រូវ បានចែកទៅអចលនវត្ថុ B ។ ចំនួនប្រាក់នីមួយៗនោះ ត្រូវចែកចំណែកទៅ X (៧.៥ លាន) និង Y (២.៥ លាន) ។ សោហ៊ុយសម្រាប់អនុវត្ត ក៏ត្រូវបានចែកដោយរបៀបដូចគ្នាដែរ (វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២) ។ ក្នុងឧទាហរណ៍ដដែល បើសោហ៊ុយសម្រាប់ការអនុវត្តបានចំណាយអស់ ៨០ ម៉ឺន រៀល

នោះបន្ទុកនៃអចលនវត្ថុ A គឺ ៦០ ម៉ឺន រៀល រីឯបន្ទុកនៃអចលនវត្ថុ B គឺ ២០ ម៉ឺន រៀល ។

Civil Execution Act (Japan)
**Article 86** (Proceeds)
1. Proceeds shall consist of the following:
   i. the price of the immovable;
   ii. a part of the security provided in accordance with the provisions of Article 63, paragraph 2 item ii, equal to the remainder after subtracting the amount of the purchase price from the offering price;
   iii. any security the return of which may not be demanded by the buyer in accordance with the provisions of Article 80, paragraph 1, second sentence.
2. In cases where several immovables have been sold as an undivided whole in accordance with the provisions of Article 61, if it is necessary to determine the proceeds of each immovable, the amount of such proceeds proportionally in accordance with the minimum acceptable price of each immovable. This shall also apply to the bearing of costs of execution concerning each immovable.
3. The provisions of Article 78, paragraph 3 shall apply *mutatis mutandis* to realization in cases where the security referred to in item ii or iii of paragraph 1 has been provided by means other than payment of money.

**មាត្រា ៤៥៣.-** វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក

ម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែកថ្លៃលក់ គឺជាបុគ្គលដែលកំណត់ដូចខាងក្រោមនេះ :

**ក-** ម្ចាស់បំណុលដែលបានដាក់ពាក្យសុំការលក់ដោយបង្ខំ ឬ ការលក់ដោយបង្ខំដែលជាការអនុវត្តឯកសិទ្ធិទូទៅ រហូតដល់កំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ។

**ខ-** ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក រហូតដល់ពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ។

**គ-** ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន មុនការចុះបញ្ជីអំពីការរឹបអូសដែលជាមូលដ្ឋាននៃដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំជាដំបូង ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 87 ។

ក្នុងករណីដែលសិទ្ធិដែលមានលើអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត ត្រូវរលត់ដោយសារការលក់ ដោយផ្អែកលើ មាត្រា ៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់) ម្ចាស់បំណុលដែលមានសិទ្ធិដូចនេះ នឹងទទួលចំណែក ដោយយោងតាមមាត្រានេះ ។

ក្នុងករណីដែលការរឹបអូសមានច្រើន "ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន" ដែលបាន កំណត់នៅក្នុងចំណុច **គ** មានន័យថាជាម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន មុនការចុះបញ្ជី អំពីការរឹបអូសដែលមានលំដាប់មុនគេ ។ ចំពោះម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ននេះ ចំនួនប្រាក់ចំណែក ជាអាទិ៍ សម្រាប់ជននោះ ត្រូវបានផ្ញើទុកនៅតុលាការ រហូតដល់ពេលដែលបណ្តឹងអំពីអង្គសេចក្តី ត្រូវបានសម្រេច ។

Civil Execution Act (Japan)
**Article 87** (Coverage of obligees entitled to receive distribution)
1. Obligees entitled to receive distribution and the like shall be the following persons:
   i. an attachment obligee (only an attachment obligee who has made a motion for compulsory sale by auction or sale by auction in execution of a general preferential right by the final date for remanding distribution);
   ii. an obligee who has made a demand for distribution by the final date for demanding distribution;
   iii. a provisional attachment obligee who has been registered prior to registration of attachment (this refer, as is also true in the next item, to attachment concerning the first ruling of commencement of compulsory sale by auction);
   iv. an obligee who has a preferential right (except for a general preferential right as held by obligees referred to in items i and ii) that has been registered (including provisional registration by provisional disposition pursuant to the Civil Preservation Act (Law No. 91, 1989) before the attachment is registered, a right of pledge or a hypothec which is to be extinguished by the sale (including a holder of a hypothec certificate concerning said hypothec).
2. When the right of the obligee referred to in item iv of the preceding paragraph was registered after the registration of the provisional attachment, such obligee may receive distribution and the like only if the provisional attachment obligees were defeated in the principal suit or the provisional attachment has lost its effectiveness.
3. In cases where the procedure of compulsory sale by auction concerning the attachment was stayed but a decision continuing the procedure was rendered in accordance with Article 47, paragraph 4, if the attachment obligee under the stay of execution was defeated in a suit concerning the said stay, an obligee with a right referred to in paragraph 1, item iv, which was registered prior to registration of the attachment concerned in the said decision continuing the procedure after registration of attachment, may receive distribution and the like;

## ផ្នែកទី ៥ ការអនុវត្តដោយបង្ខំចំពោះនាវា

**មាត្រា ៥៥៤.-** អត្ថន័យនៃនាវា ជាអាទិ៍

១- នៅក្នុងគន្ថីទី ៦ នេះ និង គន្ថីទី ៧ នាវា សំដៅទៅលើជលយានដែលមានចំណុះសរុបជាតោនស្មើនឹង និង លើសពី ២០ (ម្ភៃ) តោន ទោះជាមិនបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជាក៏ដោយ និង ជលយានដែលមានចំណុះសរុបជាតោនក្រោម ២០ (ម្ភៃ) តោន ហើយដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ។

២- នៅក្នុងគន្ថីនេះ និង គន្ថីទី ៧ លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ សំដៅទៅលើឯកសារដែលបញ្ជាក់សញ្ជាតិរបស់នាវា និង ឯកសារផ្សេងទៀតដែលចាំបាច់ដើម្បីបើកបរនាវាដោយស្របច្បាប់ ។

(កំណត់)

នៅក្នុងច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុនពុំមានចែងទេ យើងកំណត់អំពីវិធីប្រើពាក្យនៅក្នុងគន្ថីទី ៦ និង ទី ៧ ។ យោងតាមមូលដ្ឋាននៃអនុសញ្ញាអន្តរជាតិស្តីអំពីវង្វាស់ទម្ងន់គិតជាតោនរបស់នាវា (International Convention on Tonnage Measurement of Ships, 1969) ប្រទេសកម្ពុជាក៏ត្រូវការចាំបាច់រៀបចំច្បាប់ស្តីអំពីវង្វាស់ទម្ងន់គិតជាតោននៃនាវាផងដែរ ។ ក្រោយពេលអនុសញ្ញានេះបានចូលជាធរមាន (ឆ្នាំ 1982) សឹងតែពុំមានភាពខុសគ្នាតាមប្រទេសនីមួយៗលើវង្វាស់ទម្ងន់ គិតជាតោននេះទេ ។ ចំណុះសរុបជាតោននេះហៅថា gross tonnage (GT) ។ បច្ចុប្បន្ននេះ ចំណុះសរុបជាតោន ត្រូវបានប្រើប្រាស់ជាងគេជាទូទៅដើម្បីជាសញ្ញាណនៃទំហំរបស់នាវា ។ ចំណុះសរុបគិតជាតោន គឺ ចំនួនបូកសរុប ចំណុះគ្រប់កន្លែងបិទបើកនៃនាវា ដែលអាចគិតចេញដោយរូបមន្តគណនាកំណត់ ។ ចំណុះសរុប ១ តោន

មានប្រហែល ១០០ feet គីប (100 cubic feet) ។

ពាក្យថា "ឯកសារដែលបញ្ជាក់សញ្ជាតិរបស់នាវា និង ឯកសារផ្សេងទៀតដែលចាំបាច់ដើម្បីបើកបរនាវាដោយស្របច្បាប់" មានឧទាហរណ៍ដូចជា : លិខិតបញ្ជាក់សញ្ជាតិនាវា លិខិតអនុញ្ញាតឱ្យបើកបរ របាយការណ៍ស្តីពីដំណើរនាវា លិខិតត្រួតពិនិត្យនាវា និង បញ្ជីរាយនាមនាវិក ជាដើម ។

International Convention on Tonnage Measurement of Ships (1969)
Annex 1 Regulations for Determining Gross and Net Tonnages of Ships
**Regulation 3** (Gross tonnage)
The gross tonnage (GT) of a ship shall be determined by the following formula:
GT = K1V
where: V = Total volume of all enclosed spaces of the ship in cubic metres,
K1 = 0.2 + 0.02log10V (or as tabulated in Appendix 2).

**មាត្រា ៤៥៥.-** ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា និង របៀបអនុវត្ត

១- ការអនុវត្តដោយបង្ខំចំពោះនាវា ត្រូវធ្វើដោយតុលាការអនុវត្ត តាមវិធីលក់ដោយបង្ខំ ។

២- ក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា ក្រៅពីសរសេរចំណុចនីមួយៗដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣៤៩ (របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ) នៃក្រមនេះ ម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរអំពីទីកន្លែងដែលនាវានោះស្ថិតនៅ ព្រមទាំងឈ្មោះរបស់មេបញ្ជាការ ឬ បរិបាលនាវានោះ និង ទីកន្លែងដែលមេបញ្ជាការ ឬ បរិបាលនាវានោះនៅនាពេលបច្ចុប្បន្ន ។

៣- ក្នុងពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ក្រៅពីឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តត្រូវភ្ជាប់មកជាមួយនូវឯកសារដែលកំណត់ដូចខាងក្រោមនេះ :

**ក**- ចំពោះនាវាកម្ពុជាដែលបានចុះបញ្ជី គឺ ឯកសារចម្លងនៃសៀវភៅចុះបញ្ជីដែលមានសេចក្តីបញ្ជាក់ ។

**ខ**- ចំពោះនាវាកម្ពុជាដែលមិនបានចុះបញ្ជី ឬ ជានាវាផ្សេងទៀតក្រៅពីនាវាកម្ពុជា គឺ ឯកសារដែលបញ្ជាក់ថានាវានោះជានាវាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ មាត្រា ៤៥៤ (អត្ថន័យនៃនាវា ជាអាទិ៍) នៃក្រមនេះ និង ឯកសារបញ្ជាក់ថា នាវានោះស្ថិតនៅជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុនមាត្រា 112 និង បទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុនមាត្រា 74 ។ មាត្រានេះចែងថា ការអនុវត្តដោយបង្ខំចំពោះនាវាដែលមានចំណុះសរុបជាតោនលើសពី ២០ តោន និង នាវាដែលមានចំណុះសរុបជាតោនក្រោម ២០ តោន ហើយដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើតាមវិធីដែលមានលក្ខណៈដូចគ្នានឹងការអនុវត្តចំពោះអចលនវត្ថុ ។ នៅក្នុងច្បាប់រដ្ឋប្បវេណី នាវាជាចលនវត្ថុទេ តែតម្លៃធនធានមានកម្រិតស្មើគ្នានឹងអចលនវត្ថុ ហើយការទទួល បាត់បង់ ឬ ផ្លាស់ប្តូរ ជាអាទិ៍ នូវកម្មសិទ្ធិលើនាវា

ត្រូវប្រកាសជាសាធារណៈយោងតាមការចុះបញ្ជី ។ ម្យ៉ាងទៀតការចុះបញ្ជីជាល័ក្ខខ័ណ្ឌតតាំងចំពោះការទទួល បាត់បង់ ឬ ផ្លាស់ប្តូរ ជាអាទិ៍ នូវកម្មសិទ្ធិលើនាវាដែរ (ច្បាប់ជប៉ុនក៏កំណត់ជាល័ក្ខខ័ណ្ឌតតាំងដែរ ។ សូមមើលច្បាប់ពាណិជ្ជកម្មជប៉ុន មាត្រា 687) ។ ដោយមូលហេតុថាលើបច្ចេកទេសអនុវត្ត គួរឱ្យមានបញ្ញត្តិដូចគ្នានឹងអចលនវត្ថុ យើងបានបង្កើតមាត្រានេះឡើង ។ យើងពុំគិតអំពីសញ្ជាតិនៃនាវា អត្ថិភាព ឬ នត្ថិភាពនៃការចុះបញ្ជី អត្ថិភាព ឬ នត្ថិភាពនៃសមត្ថភាពចុះបញ្ជីទេ ។ ហេតុដូច្នេះ ចំពោះនាវាដែលមានសញ្ជាតិផ្សេងពីសញ្ជាតិរបស់ម្ចាស់នាវា ដោយហេតុថា បង់ពន្ធថោក ជាដើម (ឧ. Panama, Liberia ជាដើម) (ដែលហៅថា flag of convenience) បើនាវានោះស្ថិតនៅក្នុងទំហំអធិបតេយ្យភាពរបស់ព្រះរាជាណាចក្រកម្ពុជា យោងតាមមាត្រានេះ អាចអនុវត្តចំពោះនាវានោះបានដែរ ។ ចំពោះនាវាដែលកំពុងតម្លើងវិញ ត្រូវអនុវត្តតាមវិធីនៃការអនុវត្តចំពោះចលនវត្ថុ ។ រីឯការអនុវត្តដោយបង្ខំចំពោះចំណែកនៃសហកម្មសិទ្ធិលើនាវា ត្រូវធ្វើតាមវិធីអនុវត្តចំពោះសិទ្ធិ (ការអនុវត្តចំពោះសិទ្ធិលើបំណុល) ។

ចំពោះការអនុវត្តដោយបង្ខំ និង ការអនុវត្តការរក្សាការពារ ចំពោះនាវាដែលបានបញ្ចប់ការរៀបចំចេញដំណើរតាមច្បាប់ជប៉ុន ត្រូវបានហាមឃាត់ (ច្បាប់ពាណិជ្ជកម្មជប៉ុន មាត្រា 689) ។ ប៉ុន្តែ មានករណីលើកលែង គឺចំពោះបំណុលដែលកើតឡើងដើម្បីចេញដំណើរនាវាចរណ៍នោះ អាចអនុវត្តបាន ។

ដែលហៅថានាវាក្នុងមាត្រានេះ គឺជាវត្ថុដែលអាចផ្តល់ប្រយោជន៍បម្រើនាវាចរណ៍ផ្លូវទឹក ក្នុងគោលបំណងដឹកជញ្ជូនមនុស្ស ឬ របស់របរ ហើយមានទម្រង់កំណត់ ។ ក្នុងករណីនេះ ដែលហៅថាផ្លូវទឹក ក្រៅអំពីលើទឹក រាប់បញ្ចូលទាំងនៅក្នុងទឹកផងដែរ ។ ដូច្នេះ កប៉ាល់ Hovercraft (កប៉ាល់ air cushion) និង កប៉ាល់ដែលមានស្លាបក្នុងទឹក (hydrofoil boat) គឺជានាវា ។ ចំពោះក្បូន គឺជាការផ្គុំក្តារ ឬ ឈើមូលដើម្បីដឹកជញ្ជូនក្តារ ឬ ឈើនោះ ដូច្នេះពុំមែនជានាវាទេ ។ ទោះជាមានរូបរាងជាកប៉ាល់ក៏ដោយ ដូចជាកប៉ាល់ដែលផ្ទុកបង្គោលភ្លើងហ្វារ ឃ្លាំងលើទឹក ផ្ទះអណ្តែតទឹកជាដើម តែពុំមានគម្រោងនឹងផ្លាស់ប្តូរទីកន្លែង ក៏ពុំអាចថាជានាវាបានដែរ ។ ហើយ កប៉ាល់កំសាន្ត ដែលដើរលើផ្លូវដែក (rail) ក្រាលនៅបាតបឹងសម្រាប់ជិះលេងនោះ ក៏ពុំមែនជានាវាដែរ ។

អ្វីដែលហៅថានាវាកម្ពុជា តើត្រូវមានអ្វីខ្លះនោះ ចាំបាច់ត្រូវកំណត់នៅក្នុងច្បាប់ផ្សេង ។ ចំពោះល័ក្ខខ័ណ្ឌដើម្បីទទួលបាននូវសញ្ជាតិនាវា នៅក្នុងការបង្កើតច្បាប់ គេមានរួមបញ្ចូលទាំង កម្មសិទ្ធិរបស់ពលរដ្ឋ ផលិតកម្មរបស់ពលរដ្ឋ នាវិករបស់ពលរដ្ឋ ជាដើម ដែលមានច្រើនល័ក្ខខ័ណ្ឌ ។ នៅប្រទេសជប៉ុន ច្បាប់ យកកម្មសិទ្ធិរបស់ពលរដ្ឋតែមួយទេ ធ្វើជាល័ក្ខខ័ណ្ឌ (ច្បាប់ស្តីពីនាវាប្រទេសជប៉ុន មាត្រា 1) ។ ហើយកម្មសិទ្ធិករនាវាជប៉ុន ក្រោយពីបានធ្វើការកំណត់ផែនាវា (ច្បាប់ដូចគ្នា មាត្រា 4) ចុះបញ្ជី (ច្បាប់ពាណិជ្ជកម្មជប៉ុន មាត្រា 686) ចុះឈ្មោះលើបញ្ជី (ច្បាប់នាវាប្រទេសជប៉ុន មាត្រា 5 កថាខណ្ឌទី 1) រួចហើយ នឹងទទួលលិខិតបញ្ជាក់សញ្ជាតិនាវា (ច្បាប់ស្តីពីនាវាប្រទេសជប៉ុន មាត្រា 5 កថាខណ្ឌទី 2 បញ្ញត្តិលំអិតស្តីពីការអនុវត្តច្បាប់ស្តីពីនាវាប្រទេសជប៉ុន មាត្រា 30) ។ ដោយការទទួលសញ្ជាតិនាវាកម្ពុជា ធ្វើឱ្យមានការបែងចែកដាច់ពីគ្នា រវាងនាវាកម្ពុជា និង នាវាបរទេស ។

**Article 112** (Execution against a ship)
Compulsory execution against a ship of more than 20 tons gross (except for a boat or any other vessel propelled entirely or mainly by oars; hereinafter referred to as "ship" in this Section) shall be carried out by way of compulsory sale by auction (hereinafter, "execution against a ship").

**មាត្រា ៤៥៦.-** តុលាការអនុវត្ត

ចំពោះការអនុវត្តដោយបង្ខំចំពោះនាវា សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវាស្ថិតនៅ នៅពេលចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ មានសមត្ថកិច្ចជាតុលាការអនុវត្ត ។

(កំណត់)

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 113 ។ មាត្រានេះចែងអំពីតុលាការដែលមានសមត្ថកិច្ច ។ បញ្ញត្តិនេះយកគោលការណ៍នៃទីកន្លែងរបស់នាវា ។

Civil Execution Act (Japan)
**Article 113** (Execution court)
The district court having jurisdiction over the place where a ship is located at the time a ruling to begin compulsory sale by auction is rendered shall have jurisdiction.

**មាត្រា ៤៥៧.-** ដីកាសម្រេចចាប់ផ្ដើម ជាអាទិ៍

១- នៅពេលចាប់ផ្ដើមនីតិវិធីនៃការលក់ដោយបង្ខំ តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ហើយត្រូវបង្គាប់ឱ្យអាជ្ញាសាលាដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវានោះ ជាអាទិ៍ មកប្រគល់ជូនតុលាការអនុវត្ត ។

២- ក្នុងដីកាសម្រេចចាប់ផ្ដើមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តត្រូវប្រកាស អំពីការរឹបអូសនាវានោះជាប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្ត ហើយត្រូវហាមឃាត់កូនបំណុលនៃការអនុវត្ត ចំពោះការចេញដំណើរនៃនាវានោះ ។

៣- ដីកាសម្រេចចាប់ផ្ដើមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត ។

៤- បើបានចេញដីកាសម្រេចចាប់ផ្ដើមដែលយោងទៅតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ចំពោះនាវាកម្ពុជាដែលបានចុះបញ្ជីហើយ ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសដែលពាក់ព័ន្ធនឹងដីកាសម្រេចចាប់ផ្ដើមនោះជាបន្ទាន់ ។

៥- អានុភាពនៃការរឹបអូស នឹងកើតឡើងនៅពេលបានធ្វើការបញ្ជូនដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ។ ប៉ុន្តែ បើការចុះបញ្ជីអំពីការរឹបអូសត្រូវបានធ្វើមុនការបញ្ជូនដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ អានុភាពនោះនឹងកើតឡើងនៅពេលបានចុះបញ្ជី ។

៦- បើអាជ្ញាសាលាបានដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ នៅមុនពេលបញ្ជូនដីកាសម្រេចចាប់ផ្ដើមការ

លក់ដោយបង្ខំ ឬ នៅមុនពេលចុះបញ្ជីអំពីការរឹបអូស អានុភាពនៃការរឹបអូសនោះ កើតឡើងនៅពេលដកហូត ។

៧- ចំពោះដីកាសម្រេចលើកចោលពាក្យសុំការលក់ដោយបង្ខំនេះ អាចប្តឹងជំទាស់បាន ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 114 មាត្រា 45 (ដីកាសម្រេចចាប់ផ្តើម ជាអាទិ៍) មាត្រា 46 (អានុភាពនៃការរឹបអូស) មាត្រា 48 (ការផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសចំពោះនាវាជប៉ុន) ។ មាត្រានេះចែងថា ដើម្បីចាប់ផ្តើមនីតិវិធីលក់ដោយបង្ខំ តម្រូវឱ្យតុលាការបង្គាប់ទៅអាជ្ញាសាលា ឱ្យដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ជាមួយនឹងការចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ។ ការរឹបអូសលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ មានគោលបំណងការពារកុំឱ្យនាវានោះចាកចេញពីទីកន្លែងដែលរឹបអូស និង រក្សាទុក ។ បើមានដីកាសម្រេចចាប់ផ្តើមរួចហើយ នៅមុនពេលចេញដីកាសម្រេចចាប់ផ្តើមអនុវត្តដោយបង្ខំចំពោះនាវា ហើយបើលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ត្រូវបានដកហូតដោយយោងតាមដីកាសម្រេចមុននោះ តើយើងត្រូវបញ្ញត្តថា ពុំចាំបាច់ឱ្យមានការបង្គាប់ទៅអាជ្ញាសាលា ឬ តម្រូវឱ្យមានការបង្គាប់ ហើយបើគ្មានការបង្គាប់ មិនអាចអនុវត្តបាន ឬ យ៉ាងណានោះ យើងសង្ឃឹមថា មានការបកស្រាយ តាមស្ថានភាពពិតនៃប្រទេសកម្ពុជា ។

ម្យ៉ាងទៀត មាត្រានេះបញ្ញត្តថា ពុំអាចប្តឹងជំទាស់ ចំពោះដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំនេះទេ ។ អាស្រ័យហេតុនេះ ចំពោះដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំនេះ អាចធ្វើឧបាស្រ័យបានដោយការតវ៉ាចំពោះការអនុវត្ត តាមបញ្ញត្តិនៃមាត្រា ៣៨៤ (ការតវ៉ាចំពោះការអនុវត្ត) ។ ដោយសារអាចធ្វើវិវាទ ដោយបណ្តឹងជំទាស់ចំពោះដីកាសម្រេចអនុញ្ញាតឱ្យលក់ (មាត្រា ៤៧៥ (បណ្តឹងជំទាស់ចំពោះដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់)) ហេតុដូច្នេះ បើធ្វើដោយបណ្តឹងតវ៉ាចំពោះការអនុវត្តក្នុងដំណាក់កាលនេះ ជាការគ្រប់គ្រាន់ហើយ ។ ចំណុចនេះអាចមានវិធីគិតពិចារណាផ្សេងទៀត ។

<u>Civil Execution Act (Japan)</u>

**Article 114** (Ruling of commencement)

1. In order to commence compulsory sale by auction, the court shall render a ruling of commencement of compulsory sale by auction and shall order the execution officer to obtain a document showing the nationality of the ship or any other document necessary for navigation (hereinafter, "certificate of the ship's nationality and the like") and shall submit such document to the execution court; provided that, in cases where the certificate of the ship's nationality and the like has been taken away by virtue of a ruling of commencement rendered prior to the said ruling of commencement the court need not do so.
2. In the ruling of commencement, the court shall declare that the ship is attached for the obligee and shall prohibit the obligor from allowing the ship to depart.
3. If the execution officer obtains the certificate of the ship's nationality and the like prior to service of the ruling of commencement of compulsory sale by auction or the registration of attachment, the attachment shall become effective when said document is obtained.

**Article 45** (Ruling of commencement)

1. In order to commence proceedings for a compulsory sale by auction, the execution court shall render a ruling for commencement of compulsory sale by auction and declare in such ruling that the immovable shall be attached for the obligee.
2. Such ruling of commencement shall be served on the obligor.
3. A kōkoku-appeal concerning execution may be filed against a decision dismissing a motion for compulsory sale by auction.

**Article 46** (Effective date of attachment)

1. Attachment shall become effective when the ruling of commencement of compulsory sale by auction is served on the obligor;

provided, that in cases where the registration of attachment is made before service of the ruling of commencement, the attachment shall become effective when such registration is made.
2. Attachment shall not prevent the obligor from using or earning profits from the immovable in an ordinary manner.
**Article 48** (Registration of attachment)
1. If a ruling of commencement of compulsory sale by auction is rendered, the court clerk shall immediately entrust the registrar to register the attachment.
2. When the registrar has registered the attachment by entrustment according to the provisions of the preceding paragraph, he shall send a transcript of the register to the execution court.

**មាត្រា ៤៥៨.-** ការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក និង ការផ្លាស់ប្តូរពេលកំណត់នោះ

១- ក្នុងករណីដែលអានុភាពនៃការរឹបអូសដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំ បានកើតឡើង តុលាការអនុវត្តត្រូវកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ។

២- បើមិនបានចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកទេ តុលាការអនុវត្តអាចផ្លាស់ប្តូរកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកនោះបាន ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 121 មាត្រា 49 មាត្រា 52 ។

<u>Civil Execution Act (Japan)</u>
**Article 121** (*Mutatis mutandis* application of provisions concerning compulsory sale by auction of immovable)
The provisions of Division 2 of the preceding Subsection (except for Article 45, paragraph 1; Article 46, paragraph 2, Article 48, Article 54, Article 55, paragraph 2, 6 and 7, and Article 56, 81 and 82) shall apply *mutatis mutandis* to execution against a ship, and the provisions of Articles 48, 54 and 82 shall apply *mutatis mutandis* to compulsory execution against a Japanese ship as provided in Article 1 of the Ships Act (Law No. 46, 1899).
**Article 49** (Public notice of ruling of commencement)
1. In cases where the attachment concerned in the ruling of commencement of compulsory sale by auction has become effective (except where another ruling of commencement of compulsory sale by auction or sale by auction has been rendered prior to the said ruling of commencement), the execution court shall fix the final date for demanding distribution, taking into consideration the period necessary to prepare specifications.
2. If the final date for demanding distribution is fixed, the court clerk shall give public notice of the fact that a ruling of commencement has been rendered and of the final date for demanding distribution, and shall summon the following persons to notify the execution court by the final date for demanding distribution as to whether an obligation-right (including interest and other incidental obligation-rights) exists or not, the grounds of the obligation-right and the amount thereof:
   i. obligees referred to in Article 87, paragraph 1 item iii
   ii. obligees referred to in Article 87, paragraph 1 item iv (with regard to holders of hypothecary certificates, such obligees are restricted to known holders).
   iii. government or public officials in charge of taxes or other public imposts.
3. The execution court, if it deems it especially necessary, may postpone the final date for demanding distribution.
4. In cases where the final date for demanding distribution has been postponed according to the provisions of the preceding paragraph, the court clerk shall give public notice of the new final date thereof.
**Article 52** (Alteration of final date for demanding distribution)
In cases where no ruling granting permission for a sale has been rendered within three months from the final date for demanding distribution, or a ruling granting permission for sale rendered within three months has been annulled or has lost its effect, the final date for demanding distribution shall be deemed to be changed to a day three months from the said final date; provided, that in cases where the ruling granting permission for sale rendered within three months from the final date for demanding distribution has lost its effect, this shall not apply to a ruling granting permission for sale concerning anoffer to buy from the next bidder which is rendered according to the provisions of Article 67 (excluded are cases where such ruling has been annulled or has lost its effect).

**មាត្រា ៤៥៩.-** ដីកាសម្រេចបង្គាប់ឱ្យប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ នៅមុនពេលដាក់ពាក្យសុំ

១- ក្នុងករណីដែលមានការបារម្ភថា នឹងមានការលំបាកខ្លាំងក្នុងការអនុវត្តដោយបង្ខំចំពោះនាវា បើមិនដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវានោះ ជាអាទិ៍ នៅមុនការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវាទេ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះត្រូវបានចុះបញ្ជី អាចចេញដីកាសម្រេចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត ប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ទៅឱ្យអាជ្ញាសាលាបាន តាមពាក្យសុំ ។ បើនាវានោះពុំបានចុះបញ្ជីទេ ឬ បើមានស្ថានភាពជាបន្ទាន់ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះស្ថិតនៅ អាចចេញដីកាសម្រេចនេះបាន ។

២- ដើម្បីដាក់ពាក្យសុំតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវបង្ហាញនូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ហើយត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងអំពីមូលហេតុដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ នេះ ។

៣- ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត ។

៤- ចំពោះដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៥- ចំពោះដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ទោះនៅមុនពេលបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្តក៏ដោយ ក៏អាចអនុវត្តបានដែរ ។ សោហ៊ុយចាំបាច់សម្រាប់ការអនុវត្តនេះ ត្រូវចាត់ជាសោហ៊ុយសម្រាប់ផលប្រយោជន៍រួម ក្នុងនីតិវិធីនៃការលក់ដោយបង្ខំ ។

៦- ដីកាសម្រេចបង្គាប់ឱ្យប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ទៅឱ្យអាជ្ញាសាលា ដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំត្រូវអនុវត្តឡើយ បើហួសអំឡុងពេល ២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានជូនដំណឹងទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ។

៧- បើម្ចាស់បំណុលនៃការអនុវត្តមិនបានដាក់លិខិតដែលបញ្ជាក់ថា ខ្លួនបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវានៅក្នុងអំឡុងពេល ៥ (ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានទទួលការប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍នោះទេ អាជ្ញាសាលាត្រូវសងលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍នោះ ទៅឱ្យកូនបំណុលនៃការអនុវត្តវិញ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 115 ។ មាត្រានេះចែងអំពីការអនុវត្តដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ នៅមុនពេលចេញដីកាសម្រេចការចាប់ផ្តើមអនុវត្តដោយបង្ខំចំពោះនាវា ។ ដោយការអនុវត្តដកហូតជាមុននេះ ធ្វើឱ្យប៉ះពាល់ជាខ្លាំង ដល់ដំណើរនាវាចរណ៍ មាត្រានេះចែងថា ដីកាសម្រេចបង្គាប់ឱ្យប្រគល់នឹងបាត់បង់អានុភាព ដោយស្វ័យប្រវត្តិ ក្នុងល័ក្ខខ័ណ្ឌដែលមានកំណត់នេះ ហើយក្នុងករណីនេះ អាជ្ញាសាលាត្រូវសងលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ទៅឱ្យកូនបំណុលវិញ ។

<u>Civil Execution Act (Japan)</u>

**Article 115** (Order to deliver the certificate of the ship's nationality and the like prior to a motion of execution)
1. Where execution against a ship is likely to be extremely difficult unless the certificate of the ship's nationality and the like is taken away prior to a motion for execution against the ship, the district court having jurisdiction over the place of the ship's registry (in case where the ship is not registered, the place appointed by the Supreme Court), may, upon motion, order the obligor to deliver the certificate of the ship's nationality and the like to the execution officer. In case of urgency, the district court having jurisdiction over the place of the ship may issue this order.
2. A decision pursuant to the provisions of the preceding paragraph may be rendered without oral argument.
3. In order to make the motion referred to in paragraph 1 of this Article, an exemplification of an obligation title with the execution power shall be produced and the necessary grounds for execution shall be stated in a preliminary showing.
4. If the obligee fails to submit a document showing that he has made a motion for execution against the ship within five days from the day of delivery of the certificate of the ship's nationality and the like, the execution officer shall return the certificate to the obligor.
5. An immediate kōkoku-appeal may be filed against a ruling pursuant to the provisions of paragraph 1 of this Article.
6. An immediate kōkoku-appeal referred to in the preceding paragraph shall have no effect to stay an execution.
7. The provisions of Article 55, paragraphs 6 to 8 inclusive shall apply *mutatis mutandis* to a ruling pursuant to the provisions of paragraph 1.

**មាត្រា ៤៦០.-** ការជ្រើសតាំងអ្នកថែរក្សាគ្រប់គ្រង ជាអាទិ៍

១- បើទទួលស្គាល់ថាចាំបាច់ តុលាការអនុវត្តអាចជ្រើសតាំងអ្នកថែរក្សាគ្រប់គ្រង ចំពោះនាវាដែលត្រូវបានចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តបាន ។

២- តុលាការអនុវត្តត្រូវត្រួតពិនិត្យអ្នកថែរក្សាគ្រប់គ្រង ។ អ្នកថែរក្សាគ្រប់គ្រងត្រូវបំពេញមុខនាទីរបស់ខ្លួន ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។ នៅក្នុងករណីដែលអ្នកថែរក្សាគ្រប់គ្រងបានបញ្ចប់ភារកិច្ចនោះ អ្នកនោះត្រូវរាយការណ៍អំពីការគណនានូវចំណូលចំណាយក្នុងការថែរក្សាគ្រប់គ្រងទៅតុលាការអនុវត្ត ដោយគ្មានការយឺតយ៉ាវ ។

៣- អ្នកថែរក្សាគ្រប់គ្រងអាចទទួលជាមុននូវសោហ៊ុយចាំបាច់ក្នុងការថែរក្សាគ្រប់គ្រង និង ប្រាក់បំណាច់ដែលកំណត់ដោយដីកាសម្រេចនៃតុលាការអនុវត្តបាន ។ សោហ៊ុយដែលអ្នកថែរក្សាគ្រប់គ្រងបានចំណាយដើម្បីថែរក្សាគ្រប់គ្រងនាវា និង ប្រាក់បំណាច់ ត្រូវចាត់ជាសោហ៊ុយសម្រាប់នីតិវិធី ។

៤- ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 116 ។ មាត្រានេះចែងអំពីការជ្រើសតាំងអ្នកថែរក្សាគ្រប់គ្រង ជាអាទិ៍ ។ ហើយតាមច្បាប់ជប៉ុនស្តីអំពីការអនុវត្តដោយបង្ខំ ចំពោះនាវា ការគ្រប់គ្រងដោយបង្ខំពុំត្រូវបានអនុញ្ញាតទេ ។ នេះមកពីពិបាកសង្ឃឹមលើភាពពិតប្រាកដក្នុងការទទួលផលប្រយោជន៍ពីនាវាចរណ៍ ។ ចំពោះឧទាហរណ៍នៃច្បាប់បរទេសផ្សេងទៀត (ឧ. កថាខណ្ឌទី 2 មាត្រា 165 នៃច្បាប់អាឡឺម៉ង់ ស្តីពីការលក់ដេញថ្លៃដោយបង្ខំ និង ការគ្រប់គ្រងដោយបង្ខំ) មានច្បាប់ដែលអនុញ្ញាតឱ្យធ្វើការគ្រប់គ្រងដោយបង្ខំ នៅក្រោមល័ក្ខខ័ណ្ឌដែលបានកំណត់ ។

Civil Execution Act (Japan)

**Article 116** (Custodian)
1. The execution court may, when it deems necessary, appoint a custodian concerning a ship with regard to which a ruling for commencement of compulsory sale auction has been rendered upon motion of an attachment obligee.
2. The cost spent by a custodian for holding a ship in custody (including the remuneration referred to in paragraph 1 of Article 101 applied *mutatis mutandis* by paragraph 4 of this Article) shall be included in costs of procedure.
3. A kōkoku-appeal concerning execution may be filed against a ruling concerning the motion referred to in paragraph 1.
4. The provisions of Article 94, paragraph 2, Article 96, and Article 99 to 103 inclusive shall apply *mutatis mutandis* to a custodian referred to in paragraph 1.

**មាត្រា ៤៦១.-** ការលុបចោលនីតិវិធីលក់ដោយបង្ខំ ដោយដាក់ប្រាក់ធានា

១- នៅក្នុងករណីដែលមានការដាក់លិខិតដូចបានកំណត់នៅក្នុងចំណុចទីមួយ១ នៃកថាខណ្ឌទី ២ មាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត បើកូនបំណុលនៃការអនុវត្តបានដាក់ប្រាក់ធានាដែលស្មើនឹងចំនួនទឹកប្រាក់សរុបនៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និង សិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក និង សោហ៊ុយសម្រាប់ការអនុវត្ត នៅមុនពេលមានសំណើទិញ តុលាការអនុវត្តត្រូវលុបចោលនូវនីតិវិធីនៃការលក់ដោយបង្ខំ តាមពាក្យសុំ លើកលែងតែនីតិវិធីចែកចំណែក ។ បើដាក់ប្រាក់ធានានៅមុនពេលផុតកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកវិញ ចំនួនទឹកប្រាក់ដែលកូនបំណុលនៃការអនុវត្តត្រូវដាក់ គឺចំនួនស្មើនឹងចំនួនទឹកប្រាក់សរុបនៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក រហូតដល់ពេលនោះ និង សោហ៊ុយសម្រាប់ការអនុវត្ត ។

២- បើការផ្អាកការអនុវត្តដោយការដាក់លិខិតដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបាត់បង់អានុភាព តុលាការអនុវត្តត្រូវចែកចំណែកឱ្យម្ចាស់បំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះប្រាក់ធានាដែលត្រូវបានដាក់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ។

៣- ចំពោះដីកាសម្រេចលើកចោលពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

៤- បញ្ញត្តិនៃមាត្រា ៧១ (វិធីដាក់ប្រាតិភោគ និង ការប្ដូរប្រាតិភោគ) និង មាត្រា ៧២ (សិទ្ធិរបស់អ្នកដែលទទួលការផ្ដល់ប្រាតិភោគ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការដាក់ប្រាក់ធានាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 117 ។ មាត្រានេះបញ្ញត្តអំពីការលុបចោលនីតិវិធីលក់ដោយបង្ខំដោយដាក់ប្រាក់ធានា ។ គឺសម្រួលទៅលើកូនបំណុលនៃការអនុវត្តដែលប្រាកដជាទទួលការខូចខាតផលប្រយោជន៍ និង ម្ចាស់បំណុលនៃការអនុវត្តដែលទទួលផលប្រយោជន៍ ដោយសារការរឹបអូសចំពោះនាវា ។ មាត្រានេះបញ្ញត្តដោយទាញគំនិតពីប្រព័ន្ធរបៀបដូចគ្នានៃ action in rem នៃច្បាប់អង់គ្លូសាក់សុង ។

Civil Execution Act (Japan)
**Article 117** (Annulment of procedure of compulsory sale by auction by virtue of provision of security)

1. When a document referred to in item vii or viii paragraph 1 of Article 39 has been submitted with regard to an obligation-right of the attachment obligee and if, prior to an offer to buy, the obligor has provided security corresponding to the total of the costs of execution and the obligation-rights of the attachment obligee and of any obligee who made a demand for distribution before the security was provided (or in cases where the security was provided after the final date for demand for distribution, before this final date), the execution court, upon motion, shall annul the procedure of compulsory sale by auction except for the procedure of compulsory sale by auction except for the procedure of distribution and the like.
2. In cases where a stay of execution based on the submission of a document as mentioned in the preceding paragraph has become ineffective, the execution court shall carry out distribution and the like on behalf of the obligees with regard to security provided in accordance with the provisions of that paragraph. In such cases, the court may redeem the valuable instruments deposited as security.
3. A kōkoku-appeal concerning execution may be filed against a decision dismissing the motion referred to in paragraph 1.
4. The provisions of Article 15 shall not apply to a ruling based on the provisions of paragraph 1.
5. The provisions of Article 15 shall apply *mutatis mutandis* to the provision of security referred to in paragraph 1, and the provisions of Article 78, paragraph 3 shall apply *mutatis mutandis* to realization in cases where the security referred to in paragraph 1 has been provided by means other than the depositing of money.

## **មាត្រា ៤៦២.~** ការអនុញ្ញាតឱ្យនាវាធ្វើដំណើរ

១- នៅក្នុងករណីដែលទទួលស្គាល់ថា មានភាពចាំបាច់សម្រាប់អាជីវកម្ម និង មូលហេតុសមរម្យផ្សេងទៀត បើមានការយល់ព្រមពីម្ចាស់បំណុលនីមួយៗ និង អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកទិញ តុលាការអនុវត្តអាចអនុញ្ញាតឱ្យនាវានោះធ្វើដំណើរបាន តាមពាក្យសុំរបស់កូនបំណុលនៃការអនុវត្ត ។
២- ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។
៣- ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះមិនមានអានុភាព បើមិនទាន់ចូលជាស្ថាពរ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 118 ។ មាត្រានេះបញ្ញត្តអំពីការអនុញ្ញាតនាវាចរណ៍ ដោយមានល័ក្ខខ័ណ្ឌនៃសេចក្តីយល់ព្រមពីជនដែលពាក់ព័ន្ធ ជាអាទិ៍ ។ រួមជាមួយនឹងមាត្រា ៤៦១ (ការលុបចោលនីតិវិធីលក់ដេញថ្លៃដោយបង្ខំ ដោយដាក់ប្រាក់ធានា) មាត្រា ៤៦២ នេះ ធ្វើឱ្យមានការងាយស្រួលក្នុងការបណ្តោះនាវាដែលត្រូវបានរឹបអូស ។

ពាក្យថា "អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា" ចង្អុលទៅលើជនដែលបានស្នើសុំទិញក្នុងតម្លៃខ្ពស់ជាងគេ ហើយនៅក្នុងចំណោមអ្នកស្នើសុំទិញក្នុងតម្លៃខ្ពស់ជាងគេទាំងនេះ ជនដែលទទួលបានការអនុញ្ញាតពីតុលាការអនុវត្ត ត្រូវហៅថា អ្នកទិញ ។

<u>Civil Execution Act (Japan)</u>
**Article 118** (Permission to navigate)
1. Where the execution court deems that there is a business necessity or some other justifiable reason, and if every obligee and the highest bidder or buyer and the next highest bidder consent, the court, upon motion of the obligor, may permit the navigation of the ship.
2. A kōkoku-appeal concerning execution may be filed against a decision on a motion referred to in the preceding paragraph.
3. A ruling based on the provisions of paragraph 1 of this Article shall not become effective until it becomes final and binding.

## **មាត្រា ៤៦៣.~** ការផ្ទេររឿងក្តី

ក្នុងករណីដែលនាវាដែលត្រូវបានចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ បែរជាស្ថិតនៅទីកន្លែងផ្សេង ក្រៅពីតំបន់ដែលមានសមត្ថកិច្ច តុលាការអនុវត្តអាចផ្ទេររឿងក្ដីនោះទៅសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះស្ថិតនៅ បាន ។

( កំណត់)

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 119 ។ មាត្រានេះបញ្ញត្តអំពីការផ្ទេររឿងក្ដី ។ ជាវិធានការដើម្បីដោះស្រាយ ក្នុងករណីដែលនាវាជាកម្មវត្ថុនោះចាកចេញដំណើរ ។

Civil Execution Act (Japan)
**Article 119** (Transfer of the case)
1. When the ship which is the subject of a ruling of commencement of compulsory sale by auction comes to be situated outside the jurisdiction of the execution court, such execution court may transfer the case to the district court which has jurisdiction over the place where the ship is located.
2. No complaint may be filed against a ruling based on the provisions of the preceding paragraph.

**មាត្រា ៤៦៤.-** ការលុបចោលនីតិវិធីលក់ដោយបង្ខំ នៅក្នុងករណីដែលពុំអាចដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍

បើអាជ្ញាសាលាពុំអាចដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ នៅក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ គិតចាប់ពីថ្ងៃដែលបានចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំបានទេ តុលាការអនុវត្តត្រូវលុបចោលនូវនីតិវិធីលក់ដោយបង្ខំនោះ ។

( កំណត់)

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 120 ។ មាត្រានេះបញ្ញត្តអំពីការលុបចោលនីតិវិធីលក់ដោយបង្ខំ ក្នុងករណីដែលពុំអាចដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ។ ដើម្បីចាត់ចែងប្ដូរជាប្រាក់ ក្នុងការអនុវត្តចំពោះនាវា តម្រូវឱ្យមានការយកទុកដោយជាក់ស្ដែងនូវនាវា ហេតុដូច្នេះ បើមិនបានចាត់ចែងឱ្យចប់សព្វគ្រប់តាមការកំណត់ នៅក្នុងអំឡុងពេល ពីរ សប្ដាហ៍ទេ មាត្រានេះ ចែងថា នីតិវិធីអនុវត្តនាវានោះត្រូវបានលុបចោល ។

Civil Execution Act (Japan)
**Article 120** (Annulment of procedure of compulsory sale by auction when the certificate of the ship's nationality and the like cannot be obtained)
If the execution officer cannot obtain the certificate of the ship's nationality and the like within two weeks from the day when the ruling of commencement of compulsory sale by auction is rendered, the execution court shall annul the procedure of compulsory sale by auction.

**មាត្រា ៤៦៥.-** ការលុបចោលនីតិវិធីលក់ដោយបង្ខំ ដោយការវិនាសបាត់បង់នាវា ជាអាទិ៍

បើស្ថានភាពដែលបណ្ដាលឱ្យរាំងស្ទះក្នុងការផ្ទេរនាវាដោយការលក់ មានពិតប្រាកដ ដោយសារនាវានោះត្រូវបាន វិនាសបាត់បង់ ឬ ដោយមូលហេតុផ្សេងទៀត តុលាការអនុវត្តត្រូវលុបចោលនីតិវិធីលក់ដោយបង្ខំនោះ ។

( កំណត់)

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 121 និង មាត្រា 53 ។

Civil Execution Act (Japan)
**Article 121** (*Mutatis mutandis* application of provisions concerning compulsory sale by auction of immovable)
The provisions of Division 2 of the preceding Subsection (except for Article 45, paragraph 1; Article 46, paragraph 2, Article 48, Article 54, Article 55, paragraph 2, 6 and 7, and Article 56, 81 and 82) shall apply *mutatis mutandis* to execution against a ship, and the provisions of Articles 48, 54 and 82 shall apply *mutatis mutandis* tocompulsory execution against a Japanese ship as provided in Article 1 of the Ships Act (Law No. 46, 1899).
**Article 53** (Annulment of proceure of compulsory sale by auction because of destruction or loss)
In cases where an immovable is lost or destroyed or any other circumstances exist which prevent the immovable from being transferred by sale, the execution court shall annul the procedure of compulsory sale by auction.

**មាត្រា ៤៦៦.-** ការផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស

១- បើពាក្យសុំលក់ដោយបង្ខំត្រូវបានដកចេញ ឬ បើអានុភាពនៃដីកាសម្រេចលុបចោលនីតិវិធីលក់ដោយបង្ខំ បានកើតឡើង ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចលុបការចុះបញ្ជីអំពីការរឹបអូស ដែលពាក់ព័ន្ធនឹងដីកាសម្រេចចាប់ផ្ដើមនោះ ។

២- សោហ៊ុយចាំបាច់សម្រាប់ការផ្ទុកផ្ដាក់ដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ជាបន្ទុករបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានដកពាក្យសុំចេញ ឬ ម្ចាស់បំណុលនៃការអនុវត្តដែលបានទទួលដីកាសម្រេចលុបចោលនោះ ។

( កំណត់)

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 121 និង មាត្រា 54 ។

Civil Execution Act (Japan)
**Article 121** (*Mutatis mutandis* application of provisions concerning compulsory sale by auction of immovable) > *see the note for the preceding article*
**Article 54** (Request for voiding registration of attachment)
1. In cases where a motion for compulsory sale by auction has been withdrawn or a ruling annulling the procedure of compulsory sale by auction has become effective, the court clerk shall entrust the registrar with voiding the registration of attachment under the ruling of commencement.
2. The attachment obligee shall bear the registration tax and any other costs necessary for the entrustment referred to in the preceding paragraph.

**មាត្រា ៤៦៧.-** ការវាយតម្លៃ

១- តុលាការអនុវត្ត អាចជ្រើសតាំងអ្នកវាយតម្លៃ និង បង្គាប់ឱ្យវាយតម្លៃនាវាបាន ។

២- ដើម្បីសុំជំនួយពីអាជ្ញាសាលាយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) នៃក្រមនេះ អ្នកវាយតម្លៃត្រូវទទួលការអនុញ្ញាតពីតុលាការអនុវត្ត ។
៣- នៅពេលស្រាវជ្រាវដើម្បីវាយតម្លៃ អ្នកវាយតម្លៃអាចចូលទៅក្នុងនាវា ឬ អាចសួរសំណួរ ឬ ទាមទារឱ្យបង្ហាញឯកសារចំពោះកូនបំណុលនៃការអនុវត្ត ឬ តតិយជនដែលកាន់កាប់នាវានោះបាន ។
៤- បើមានភាពចាំបាច់ អាជ្ញាសាលាដែលត្រូវបានសុំជំនួយពីអ្នកវាយតម្លៃ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) នៃក្រមនេះ អាចធ្វើការចាត់ចែងចាំបាច់ដើម្បីបើកទ្វារដែលបិទបាន នៅក្នុងករណីដែលអ្នកវាយតម្លៃចូលទៅក្នុងនាវា ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 121 មាត្រា 57 និង មាត្រា 58 និង ក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសកម្ពុជា មាត្រា ១៣០ (ការប្រគល់កិច្ចការស្រាវជ្រាវ) ។

ចំពោះអ្នកវាយតម្លៃ ច្បាប់មិនកំណត់លក្ខណសម្បត្តិទេ តែជាធម្មតា ក្រុមហ៊ុនជំនាញ ជាដើម ត្រូវបានជ្រើសតាំងដោយតុលាការអនុវត្ត ។

Civil Execution Act (Japan)
**Article 121** (*Mutatis mutandis* application of provisions concerning compulsory sale by auction of immovable) > *see the note for Article 465*
**Article 57** (Investigation of present conditions)
1. The execution court shall order the execution officer to investigate the form of the immovable, the possessory relationship involved, and any other present conditions concerning the immovable.
2. When making this investigation, the execution officer may enter the premises of the immovable, question the obligor or any third person in possession of the immovable or demand the production of documents from such persons.
3. When entering the premises of the immovable in accordance with the provisions of the preceding paragraph, the execution officer may, if necessary, make a disposition necessary for opening a closed door.
**Article 58** (Appraisal)
1. The execution court shall appoint an appraiser and order him to assess the value of the immovable.
2. In order to demand the assistance of the execution officer in accordance with the provisions of Article 6, paragraph 2, the appraiser must obtain the permission of the execution court.
3. The provisions of paragraph 2 of the preceding Article shall apply *mutatis mutandis* to cases where the appraiser assesses the value of the immovable.

**មាត្រា ៤៦៨.-** ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា ជាអាទិ៍
១- បើមានការវាយតម្លៃដោយអ្នកវាយតម្លៃ តុលាការអនុវត្តត្រូវកំណត់តម្លៃលក់អប្បបរមា ដោយផ្អែកលើការវាយតម្លៃនោះ ។
២- បើយល់ឃើញថាចាំបាច់ តុលាការអនុវត្ត អាចផ្លាស់ប្តូរតម្លៃលក់អប្បបរមាបាន ។
៣- បញ្ញត្តិនៃមាត្រា ៤៣៥ (វិធានការក្នុងករណីដែលមានការបារម្ភថាគ្មានសំណល់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តចំពោះនាវា ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 121 និង មាត្រា 60 ។

មាត្រានេះបញ្ញត្តអំពីដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា ជាអាទិ៍ ។ ពាក្យ "បើយល់ឃើញថាចាំបាច់" នៅកថាខណ្ឌទី ២ សំដៅទៅលើករណីដែលតម្លៃលក់អប្បបរមាក្លាយជាតម្លៃមិនសមរម្យ ដោយសារការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ច ព្រមទាំងករណីដែលយល់ឃើញថា តម្លៃលក់អប្បបរមាជាតម្លៃមិនសមរម្យ តាមទស្សនៈក្នុងការធ្វើនីតិវិធីនៃការលក់ឱ្យបានងាយស្រួល ។

<u>Civil Execution Act (Japan)</u>
**Article 121** (*Mutatis mutandis* application of provisions concerning compulsory sale by auction of immovable) > *see the note for Article 465*
**Article 60** (Establishment of minimum acceptable price)
1. The execution court shall establish the minimum acceptable price on the basis of the assessment of the appraiser.
2. The execution court, if it deems necessary, may alter the minimum acceptable price.

**មាត្រា ៤៦៩.-** វិធីលក់ ជាអាទិ៍

១- ការលក់នាវា ក្រៅអំពីវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ត្រូវអនុវត្តតាមវិធីដែលកំណត់ដោយតុលាការអនុវត្ត ។

២- ប្រសិនបើលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ តុលាការអនុវត្តត្រូវកំណត់ថ្ងៃ ពេលវេលា និង ទីកន្លែងលក់ ហើយត្រូវឱ្យអាជ្ញាសាលាអនុវត្តការលក់នោះ ។

៣- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ក្រឡាបញ្ជីត្រូវផ្សាយជាសាធារណៈនូវសញ្ញាណនាវាដែលត្រូវលក់ តម្លៃលក់អប្បបរមា ព្រមទាំងថ្ងៃ ពេលវេលា និង ទីកន្លែងលក់ ។

៤- បញ្ញត្តិនៃមាត្រា ៣៩៦ (ការរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 121 មាត្រា 64 មាត្រា 65 និង កំណត់នៃមាត្រា ៤៣៦ (វិធីលក់ ជាអាទិ៍) ។

<u>Civil Execution Act (Japan)</u>
**Article 121** (*Mutatis mutandis* application of provisions concerning compulsory sale by auction of immovable) > *see the note for Article 465*
**Article 64** (Method of sale and pubic notice)
1. The sale of an immovable shall be effected by the means provided by the execution court.
2. In addition to sale by tender or auction, the means of sale of an immovable shall be provided for by the Rules of the Supreme

Court.
3. In cases where a sale will be effected by tender or auction, the execution court shall fix the date, time and place of the sale and have the execution officer effect the sale.
4. In cases referred to in the preceding paragraph, the court clerk shall give public notice of the description of the immovable to be sold, the minimum acceptable price and the date, time and place of the sale.
**Article 65** (Maintenance of order in place of sale)
The execution officer may prevent the following persons from entering the place of the sale, cause such persons to leave the premises or restrain such persons from offering to buy:

i. any person who has prevented any other person from offering to by or has committed an act which hinders the sale from being fairly effected, such as conspiring for the purpose of reducing the price unreasonably, or any person who has induced another persons to commit such an act;
ii. any person who has been found guilty of any such acts in a ruling concerning refusal to sell in any other procedure of civil execution and with respect to whom two years have not lapsed since such ruling on refusal to sell became final and binding;
iii. any person who has been sentenced with regard to a civil execution sale in accordance with the provisions of Articles 95 to 96-3 inclusive, 197 to 197-4 inclusive or 198 of the Criminal Code (Law No. 45, 1907) and with respect to whom two years have not lapsed since such decision became final and binding.

**មាត្រា ៤៧០.-** ការធានាលើសំណើទិញ

១- ជនដែលបម្រុងនឹងធ្វើសំណើទិញនាវា ត្រូវដាក់ប្រាក់ធានាដែលស្មើនឹង ១ ភាគ ១០ (មួយភាគដប់) នៃតម្លៃលក់អប្បបរមា ។ ប៉ុន្តែ បើយល់ឃើញថាសមរម្យ តុលាការអនុវត្ត អាចកំណត់ចំនួនប្រាក់ធានាលើសពី ១ ភាគ ១០ (មួយភាគដប់) នៃតម្លៃលក់អប្បបរមា នោះបាន ។
២- ប្រសិនបើមានសំណើទិញពីបុគ្គល ក្រៅពីអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា តុលាការអនុវត្តត្រូវសងប្រាក់ធានាដែលត្រូវបានដាក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ភ្លាម ក្រោយពេលបញ្ចប់ការលក់ដែលធ្វើឡើង ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៤៦៩ (វិធីលក់ ជាអាទិ៍) នៃក្រមនេះ ។

(កំណត់)

ចំពោះកថាខណ្ឌទី ១ សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 121 និង មាត្រា 66 ។ ចំពោះកថាខណ្ឌទី ២ សូមមើលមាត្រា 89 និង មាត្រា 39 នៃបទបញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។ ចំពោះកថាខណ្ឌទី ៣ សូមមើលមាត្រា 83 កថាខណ្ឌទី 1 នៃមាត្រា 45 កថាខណ្ឌទី 4 នៃមាត្រា 50 នៃបទបញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។ សូមមើលកំណត់នៃមាត្រា ៤៣៧ (ការធានាលើសំណើទិញ)

<u>Civil Execution Act (Japan)</u>
**Article 121** (*Mutatis mutandis* application of provisions concerning compulsory sale by auction of immovable) > *see the note for Article 465*
**Article 66** (Security for offering to buy)
A person who offers to buy the immovable shall provide security for the amount and by the means established by the execution court in accordance with the provisions of the Rules of the Supreme Court.

**មាត្រា ៤៧១.-** ការហាមឃាត់មិនឱ្យកូនបំណុលនៃការអនុវត្តធ្វើសំណើទិញ

កូនបំណុលនៃការអនុវត្ត ពុំអាចធ្វើសំណើទិញបានទេ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 121 មាត្រា 68 និង កំណត់នៃមាត្រា ៤៣៨ (ការហាមឃាត់មិនឱ្យកូនបំណុលនៃការអនុវត្តធ្វើសំណើទិញ) ។

Civil Execution Act (Japan)
**Article 121** (*Mutatis mutandis* application of provisions concerning compulsory sale by auction of immovable) > *see the note for Article 465*
**Article 68** (Prohibition of obligor's offer to buy)
An obligor may not make an offer to buy the immovable.

**មាត្រា ៤៧២.-** កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់

១- តុលាការអនុវត្តត្រូវបើកកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ ហើយត្រូវប្រកាសអំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់ ។

២- នៅពេលបានកំណត់កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ តុលាការអនុវត្តត្រូវជូនដំណឹងអំពីកាលបរិច្ឆេទនោះទៅជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ។

(កំណត់)

ចំពោះកថាខណ្ឌទី ១ សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 121 និង មាត្រា 69 ។ ចំពោះកថាខណ្ឌទី ២ សូមមើលមាត្រា 52 និង មាត្រា 53 នៃបទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។ សូមមើលកំណត់នៃមាត្រា ៤៤០ (កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់) ។

Civil Execution Act (Japan)
**Article 121** (*Mutatis mutandis* application of provisions concerning compulsory sale by auction of immovable) > *see the note for Article 465*
**Article 69** (Date for ruling to sell)
The execution court shall proceed on the date for the ruling to sell to announce permission or refusal to sell.

**មាត្រា ៤៧៣.-** ការថ្លែងយោបល់អំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់

បុគ្គលដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់នាវា អាចធ្វើសេចក្តីថ្លែងយោបល់អំពីហេតុដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ២ មាត្រា ៤៧៤ (ការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់) នៃក្រមនេះ ហើយដែលបណ្តាលឱ្យមានឥទ្ធិពលដល់សិទ្ធិរបស់ខ្លួន នៅក្នុងកាលបរិច្ឆេទនៃដីកាសម្រេចការលក់ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 121 មាត្រា 70 និង កំណត់នៃមាត្រា ៤៤១ (ការថ្លែងយោបល់អំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់) ។

Civil Execution Act (Japan)
**Article 121** (*Mutatis mutandis* application of provisions concerning compulsory sale by auction of immovable) > *see the note for Article 465*
**Article 70** (Statement of opinion concerning permission or refusal to sell)
A person interested in the permission or refusal to sell an immovable may state an opinion on the date for the ruling to sell based on any of the grounds mentioned in the next article.

**មាត្រា ៤៧៤.-** ការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់

១- លើកលែងតែក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ តុលាការអនុវត្តត្រូវចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ ។

២- តុលាការអនុវត្តត្រូវចេញដីកាសម្រេចមិនអនុញ្ញាតឱ្យលក់ បើទទួលស្គាល់ថា មានហេតុដូចកំណត់ក្នុងចំណុចខាងក្រោមនេះ :

**ក-** មិនត្រូវចាប់ផ្តើម ឬ បន្តនីតិវិធីនៃការលក់ដោយបង្ខំ ។

**ខ-** អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ពុំមានលក្ខណសម្បត្តិ ឬ សមត្ថភាពដើម្បីទិញនាវា ឬ អ្នកតំណាងរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ពុំមានសិទ្ធិនោះ ។

**គ-** មានសេចក្តីស្នើសុំកុំឱ្យអនុញ្ញាតការលក់ ដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៤៧៦ (ការស្នើសុំកុំឱ្យអនុញ្ញាតការលក់ ជាអាទិ៍ ក្នុងករណីដែលនាវាត្រូវបានខូចខាត) នៃក្រមនេះ ។

**ឃ-** មានកំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា ។

**ង-** មានកំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃការលក់ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 121 មាត្រា 71 និង កំណត់នៃមាត្រា ៤៤២ (ការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់) ។

Civil Execution Act (Japan)
**Article 121** (*Mutatis mutandis* application of provisions concerning compulsory sale by auction of immovable) > *see the note for Article 465*
**Article 71** (Grounds for refusal to sell)
The execution court, if it finds that any of the following grounds exists, may render a ruling of refusal to sell:
i. that the procedure of compulsory sale by auction should not be commenced or continued;
ii. that the highest bidder does not have the qualifications or capacity to buy the immovable, or that the representative of the highest bidder has no authority to do so;
iii. that the highest bidder has made the offer to buy for the account of another person who has no qualifications to buy the immovable;
iv. that the highest bidder, his representative or the person on whose behalf the highest bidder offered to buy on his account is:

a. a person who has committed an act referred to in Article 65 item i in the procedure of compulsory sale by auction; or
b. a person who has failed to pay the required price in the procedure of compulsory sale by auction, or a person who has had such person offer to buy on his account in the said procedure; or
c. a person referred to in Article 65 item ii or iii.

v. that an application for refusal to sell has been made in accordance with the provisions of Article 75, paragraph 1;
vi. that there are serious mistakes in the establishment of the minimum sales price, the ruling to sell several immovables as an undivided whole, the drawing up of specifications or in these procedures;
vii. that there are serious mistakes in the procedure of sale.

**មាត្រា ៤៧៥.-** បណ្តឹងជំទាស់ចំពោះដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់

១- ចំពោះដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចប្តឹងជំទាស់បានលុះត្រាតែក្នុងករណីដែលដីកាសម្រេចនោះបណ្តាលឱ្យប៉ះពាល់ដល់សិទ្ធិរបស់ខ្លួន ។

២- បណ្តឹងជំទាស់ចំពោះដីកាសម្រេចអនុញ្ញាតឱ្យលក់ ត្រូវយកហេតុដូចបានកំណត់ក្នុងចំណុចនីមួយៗ នៃកថាខណ្ឌទី ២ មាត្រា ៤៧៤ (ការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់) នៃក្រមនេះ ឬ ហេតុដែលមានកំហុសធ្ងន់ធ្ងរ នៅក្នុងនីតិវិធីនៃដីកាសម្រេចអនុញ្ញាតឱ្យលក់នោះ មកធ្វើជាមូលហេតុ ។

៣- បើទទួលស្គាល់ថាចាំបាច់ តុលាការនៃបណ្តឹងជំទាស់ អាចកំណត់ភាគីម្ខាងទៀតនៃម្ចាស់បណ្តឹងជំទាស់បាន ។

៤- ដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់នេះ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 121 និង មាត្រា 74 ។ បណ្តឹងជំទាស់ដែលបញ្ញត្តនៅក្នុងមាត្រានេះ អាចធ្វើបាន តែក្នុងករណីដែលសិទ្ធិរបស់ខ្លួនត្រូវបានបំពានតែប៉ុណ្ណោះ ហេតុដូច្នេះ ឧទាហរណ៍ៈ ម្ចាស់បំណុលដែលត្រូវទទួលសំណងនៃចំនួនទឹកប្រាក់ទាំងអស់នៃសិទ្ធិលើបំណុលរបស់ខ្លួន បើគ្រាន់តែអះអាងថា តម្លៃលក់អប្បបរមានោះទាបពេក គឺមិនអាចប្តឹងជំទាស់បានទេ ។ សូមមើលបន្ថែមនូវកំណត់នៃមាត្រា ៤៤៤ (បណ្តឹងជំទាស់ចំពោះដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់) ។

Civil Execution Act (Japan)
**Article 121** (*Mutatis mutandis* application of provisions concerning compulsory sale by auction of immovable) > *see the note for Article 465*
**Article 74** (Kōkoku-appeal concerning execution against ruling of permission or refusal to sell)
1. A kōkoku-appeal concerning execution may be filed against a ruling of permission or refusal to sell only when the appellant insists that his won rights are infringed thereby.
2. In cases of a kōkoku-appeal concerning execution against a ruling of permission to sell, the grounds therefor must be one of those mentioned in Article 71 or some serious mistake in the procedure of said ruling of permission to sell.
3. The preceding two paragraphs notwithstanding, the grounds referred to in the items of Article 420, paragraph 1 of the Code of Civil Procedure may also be claimed as grounds for a kōkoku-appeal concerning execution against a ruling of permission or refusal to sell.
4. The appellate court, if it deems necessary, may appoint a respondent to the appellant.
5. A ruling of permission of refusal to sell shall not become effective until it becomes final and binding.

**មាត្រា ៤៧៦.-** ការស្នើសុំកុំឱ្យអនុញ្ញាតការលក់ ជាអាទិ៍ ក្នុងករណីដែលនាវាត្រូវបានខូចខាត

១- ក្នុងករណីដែលនាវាត្រូវបានទទួលការខូចខាតធ្ងន់ធ្ងរ ដោយសារគ្រោះធម្មជាតិ ឬ ដោយសារមូលហេតុផ្សេងទៀត ដែលមិនមែនជាបន្ទុករបស់ខ្លួន ដែលបានកើតឡើងនៅក្រោយពេលធ្វើសំណើទិញ អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកទិញអាចស្នើសុំទៅតុលាការអនុវត្ត កុំឱ្យអនុញ្ញាតការលក់ ប្រសិនបើនៅមុនពេលចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ ឬ បើនៅក្រោយពេលដែលបានចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ហើយ អាចដាក់ពាក្យសុំឱ្យលុបចោលដីកាសម្រេចនោះ ទៅតុលាការអនុវត្ត នៅមុនពេលដែលខ្លួនបង់ប្រាក់បាន ។

២- ចំពោះដីកាសម្រេចអំពីពាក្យសុំឱ្យលុបចោលដីកាសម្រេចអនុញ្ញាតឱ្យលក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៣- ដីកាសម្រេចលុបចោលដីកាសម្រេចអនុញ្ញាតឱ្យលក់ តាមពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 121 និង មាត្រា 75 ។ បើនាវានោះខូចខាតស្រាល ដីកាសម្រេចអនុញ្ញាតឱ្យលក់ពុំអាចលុបចោលតាមបញ្ញត្តិនេះបានឡើយ ។ អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកទិញ អាចទាមទារចុះតម្លៃលក់ ជាដើម ដោយយកការទទួលខុសត្រូវក្នុងការធានាក្នុងក្រមរដ្ឋប្បវេណី មកធ្វើជាមូលហេតុបាន ។ ទោះបីជាមានការខូចខាតធ្ងន់ធ្ងរក៏ដោយ បើអ្នកទិញបង់ថ្លៃលក់រួចហើយ ក្រោយពីដីកាសម្រេចលក់ នោះអ្នកទិញ មិនអាចដាក់ពាក្យសុំឱ្យលុបចោលដីកាសម្រេចឱ្យលក់បានឡើយ ។

Civil Execution Act (Japan)

**Article 121** (*Mutatis mutandis* application of provisions concerning compulsory sale by auction of immovable) > *see the note for Article 465*

**Article 75** (Application for refusal to sell where immovable has been damaged)

1. The highest bidder of the buyer, where the immovable has been damaged through natural disaster or a cause not imputable to either of them after an offer to buy has been made, may make an application for refusal to sell, if a ruling of permission to sell has not yet been rendered, or may make a motion for annulment of such ruling until he has paid the offered price, after such ruling has been rendered; provided that, in cases where damages to the immovbale is slight, this shall not apply.
2. A kōkoku-appeal may be filed against a ruling on the motion for annulment of ruling of permission to sell in accordance with the provisions of the preceding paragraph.
3. The ruling of annulment of ruling of permission to sell referred to in the preceding paragraph shall not become effective until it becomes final and binding.

**មាត្រា ៤៧៧.-** ការដកពាក្យសុំការលក់ដោយបង្ខំ នៅក្រោយពេលមានសំណើទិញ

ដើម្បីដកពាក្យសុំការលក់ដោយបង្ខំ នៅក្រោយពេលដែលមានសំណើទិញហើយ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវទទួលការយល់ព្រមពីសំណាក់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកទិញ ។

(កំណត់)

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 121 និង មាត្រា 76 ។ ម្ចាស់បំណុលនៃការអនុវត្តអាចដកពាក្យសុំការលក់ដោយបង្ខំ ដោយពុំចាំបាច់មានការយល់ព្រមពីកូនបំណុលនៃការអនុវត្តទេ តែត្រូវទទួលការយល់ព្រមពីសំណាក់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកទិញ ។ គឺមកពីហេតុថា បើអ្នកដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍ផ្ទាល់ទៅលើនីតិវិធីអនុវត្តចំពោះនាវា នឹងត្រូវបាត់បង់លក្ខណសម្បត្តិក្នុងការទទួលយកនាវា ដោយសារតែការដកពាក្យសុំរបស់ម្ចាស់បំណុលតែឯកឯងនោះ មានការខ្វះខាតចំពោះការរក្សាការពារជនទាំងនោះ និង នាំឱ្យបាត់បង់ជំនឿជឿជាក់លើប្រព័ន្ធនៃការលក់នាវាដោយបង្ខំ ។ ប៉ុន្តែ ចំពោះម្ចាស់បំណុលដែលចូលរួមក្នុងការចែកចំណែកដូចជាម្ចាស់បំណុលដែលមានឯកសិទ្ធិទូទៅ ឬ ឯកសិទ្ធិនាវា ជាដើម និង ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន មុនពេលចុះបញ្ជីអំពីការរឹបអូស ម្ចាស់បំណុលនៃការអនុវត្តពុំចាំបាច់ទទួលការយល់ព្រមដើម្បីដកពាក្យសុំទេ ។ នេះគឺដោយសារម្ចាស់បំណុលប្រាតិភោគ ជាដើម នោះ គ្រាន់តែឆ្លៀតឱកាសលើនីតិវិធីប៉ុណ្ណោះទេ ។

Civil Execution Act (Japan)
**Article 121** (*Mutatis mutandis* application of provisions concerning compulsory sale by auction of immovable) > *see the note for Article 465*
**Article 76** (Withdrawal of motion for compulsory sale by auction after offer to buy has been made)
1. In order to withdraw a motion for compulsory sale by auction after an offer to buy has been made, the moving party must obtain the consent of the highest bidder or buyer and bidder in the next order. This shall not apply in cases where there is another attachment obligee (except for an attachment obligee who has made a motion for compulsory sale by auction or sale by auction after the final date for demand distribution), if no alteration occurs with respect to matters referred to in Article 62 item ii.
2. The provisions of the preceding paragraph shall apply *mutatis mutandis* to cases where a document referred to in items iv or v of Article 39, paragraph 1 is submitted after an offer to buy has been made.

**មាត្រា ៤៧៨.-** កំណត់ពេលបង់ថ្លៃលក់

បើដីកាសម្រេចអនុញ្ញាតឱ្យលក់ ចូលជាស្ថាពរ តុលាការអនុវត្តត្រូវកំណត់ពេលត្រូវបង់ថ្លៃលក់ ហើយជូនដំណឹងទៅឱ្យអ្នកទិញ ។

(កំណត់)

សូមមើលមាត្រា 83 និង មាត្រា 56 នៃបទប្បញ្ញត្តិស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

**មាត្រា ៤៧៩.-** ការបង់ថ្លៃលក់

១- អ្នកទិញត្រូវបង់ថ្លៃលក់ទៅតុលាការអនុវត្ត មុនពេលកំណត់ដែលតុលាការអនុវត្តបានកំណត់ តាមបញ្ញត្តិនៃមាត្រា ៤៧៨ (កំណត់ពេលបង់ថ្លៃលក់) នៃក្រមនេះ ។

២- ចំនួនទឹកប្រាក់ដែលអ្នកទិញបានដាក់ដើម្បីធានាលើការស្នើសុំទិញ ត្រូវគិតបញ្ចូលក្នុងថ្លៃលក់ ។

(កំណត់)

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 121 មាត្រា 78 និង កំណត់នៃមាត្រា ៤៤៧ (ការបង់ថ្លៃលក់) ។

Civil Execution Act (Japan)
**Article 121** (*Mutatis mutandis* application of provisions concerning compulsory sale by auction of immovable) > *see the note for Article 465*
**Article 78** (Payment of pricel)
1. If a ruling of permission to sell becomes final and binding, the buyer shall pay the price to the execution court by the date provided by such court.
2. The amount of money provided by the buyer as security for an offer to buy and paid in accordance with the provisions of paragraph 1 of the preceding Article shall be allocated to the price.
3. Where the buyer has provided security as mentioned in Article 63, paragraph 2 item i by means other than payment of money, the execution court shall realize such security in accordance with the provisions of the Rules of the Supreme Court and shall allocate the amount after subtracting expenses incurred for realization.
4. Where the buyer is a person who is to receive some distribution of or payment out of the price, such buyer may, until after the date for the ruling to sell, give notice thereof to the execution court, and may pay on the date for distribution or the day for payment due has been subtracted. If an allegation or motion of objection is made with regard to the amount to be distributed to the buyer, such buyer shall immediately make payment equal to the amount objected to.

**មាត្រា ៤៨០.-** ពេលដែលទទួលកម្មសិទ្ធិលើនាវា

អ្នកទិញ ទទួលបាននូវកម្មសិទ្ធិលើនាវា នៅពេលដែលបានបង់ថ្លៃលក់ហើយ ។

(កំណត់)

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 121 និង មាត្រា 79 ។

Civil Execution Act (Japan)
**Article 121** (*Mutatis mutandis* application of provisions concerning compulsory sale by auction of immovable) > *see the note for Article 465*
**Article 79** (Time of acquisition of immovable)
The buyer acquires the immovable when he pays the purchase price.

**មាត្រា ៤៨១.-** អានុភាពនៃការមិនបង់ថ្លៃលក់

១- បើអ្នកទិញមិនបានបង់ថ្លៃលក់ទេ ដីកាសម្រេចអនុញ្ញាតឱ្យលក់នោះ នឹងបាត់បង់អានុភាព ។ ក្នុងករណីនេះ អ្នកទិញមិនអាចទាមទារឱ្យសងប្រាក់ដែលបានដាក់ តាមបញ្ញត្តិនៃមាត្រា ៤៧០ (ការធានាលើសំណើទិញ) នៃក្រមនេះ បានទេ ។

២- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តត្រូវលក់ដោយបង្ខំសាជាថ្មី ។

៣- ក្នុងការលក់ដោយបង្ខំតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ អ្នកទិញដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ មិនអាចធ្វើសំណើទិញបានឡើយ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 121 និង មាត្រា 80 ។ មាត្រានេះមិនយកប្រព័ន្ធដេញថ្លៃសាជាថ្មី ដោយផ្អែកលើប្រព័ន្ធ folle enchère ដូចច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីបារាំងទេ តែថែងថា តុលាការអនុវត្តត្រូវលក់ដោយបង្ខំសាជាថ្មី ដោយផ្អែកលើហេតុថា ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ត្រូវបានចេញ ដោយស្របច្បាប់ ហើយនៅតែមានអានុភាព ។ សូមមើលបន្ថែនូវកំណត់នៃមាត្រា ៤៥១ (អានុភាពនៃការមិនបង់ថ្លៃលក់) ។

<u>Civil Execution Act (Japan)</u>
**Article 121** (*Mutatis mutandis* application of provisions concerning compulsory sale by auction of immovable) > *see the note for Article 465*
**Article 80** (Effect of failure to pay purchase price)
1. If the buyer fails to pay the purchase price, the ruling of permission to sell shall lose its effect. In such cases, the buyer may not demand return of security provided in accordance with the provisions of Article 66.
2. In cases referred to in the first sentence of the preceding paragraph if there is a second highest offer to buy, the execution court must render a ruling of permission or refusal to sell on such offer.

**មាត្រា ៤៨២.-** ការផ្ទុកផ្តាក់ឱ្យចុះបញ្ជី ដោយការបង់ថ្លៃលក់

១- ប្រសិនបើអ្នកទិញបានបង់ថ្លៃលក់ហើយ ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី និង លុបការចុះបញ្ជីនូវចំណុចដូចកំណត់ខាងក្រោមនេះ :

**ក-** ការចុះបញ្ជី អំពីការផ្ទេរកម្មសិទ្ធិដែលអ្នកទិញបានធ្វើលទ្ធកម្ម ។

**ខ-** ការលុបការចុះបញ្ជី អំពីការរឹបអូស ឬ ការរឹបអូសជាបណ្តោះអាសន្ន ។

២- ដើម្បីផ្ទុកផ្តាក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចអនុញ្ញាតឱ្យលក់ ជាមួយនឹងលិខិតផ្ទុកផ្តាក់នោះ ។

៣- សោហ៊ុយចាំបាច់ដើម្បីផ្ទុកផ្តាក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ជាបន្ទុករបស់អ្នកទិញ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 121 មាត្រា 82 និង កំណត់នៃមាត្រា ៤៤៨ (ការផ្ទុកផ្តាក់ឱ្យចុះបញ្ជី ដោយការបង់ថ្លៃលក់) ។

<u>Civil Execution Act (Japan)</u>
**Article 121** (*Mutatis mutandis* application of provisions concerning compulsory sale by auction of immovable) > *see the note for Article 465*
**Article 82** (Registration of payment)
1. When the buyer pays the purchase price, the court clerk shall entrust the register:
   i. to make registration of the transfer of the right acquired by the buyer; and
   ii. to erase registrations of rights extinguished by the sale or the acquisition of a right or provisional disposition which has lost its effect because of the sale and
   iii. to erase registrations of attachment or provisional attachment.
2. When entrusting the registrar, the court clerk shall append an exemplification of the ruling of permission to sell with the document of entrustment.
3. The buyer shall bear the registration tax and any other costs necessary for entrusting the registrar according to the provisions of paragraph 1.

**មាត្រា ៤៨៣.-** ដីកាសម្រេចបង្គាប់ឱ្យប្រគល់នាវា

១- តុលាការអនុវត្តអាចចេញដីកាសម្រេចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត ឬ អ្នកកាន់កាប់នាវា ប្រគល់នាវានោះទៅឱ្យអ្នកទិញ តាមពាក្យសុំរបស់អ្នកទិញដែលបានបង់ថ្លៃលក់ហើយបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះជនដែលត្រូវបានទទួលស្គាល់ថា កាន់កាប់ដោយផ្អែកលើមូលហេតុគតិយុត្តនៃសិទ្ធិ ដែលអាចតតាំងជាមួយនឹងអ្នកទិញ នៅលើសំណុំរឿងក្តីបាន ។

២- បើហួសអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃដែលអ្នកទិញបានបង់ថ្លៃលក់ហើយ អ្នកទិញនោះពុំអាចដាក់ពាក្យសុំ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបានទេ ។

៣- ក្នុងករណីដែលបានចេញដីកាសម្រេចចំពោះអ្នកកាន់កាប់ ក្រៅពីកូនបំណុលនៃការអនុវត្ត តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តត្រូវសួរជននោះ ។

៤- ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៥- ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 121 មាត្រា 83 និង កំណត់នៃមាត្រា ៤៥០ (ដីកាសម្រេចបង្គាប់ឱ្យប្រគល់អចលនវត្ថុ) ។

Civil Execution Act (Japan)

**Article 121** (*Mutatis mutandis* application of provisions concerning compulsory sale by auction of immovable) > *see the note for Article 465.*

**Article 83** (Order to deliver)

1. Upon motion of a buyer who has paid the purchase price, the execution court may order the obligor, or a possessor of the immovable who, in light of the record of the case, sin not deemed to have been in possession on the basis of title before the attachment became effective, to deliver the immovable to the buyer; provided, this shall not apply to one who, in light of the record of the case, has been in possession of the immovable after the attachment became effective but who is deemed to be in possession of it on the basis of a title which can be set up against the buyer.
2. The buyer may not make a motion referred to in the preceding paragraph if six moths have passed since the purchase price was paid.
3. Where a ruling is to be rendered pursuant to the provisions of paragraph 1 with regard to a possessor other than the obligor, the execution court shall interrogated the person; provided that, if the person has already been interrogated, this shall not apply.
4. A kōkoku-appeal concerning execution may be filed against a ruling on the motion referred to in paragraph 1.
5. A ruling as mentioned in paragraph 1 shall not become effective until it becomes final and binding.

**មាត្រា ៤៨៤.-** ថ្លៃលក់

ប្រាក់ដែលកំណត់ដូចខាងក្រោមនេះ ត្រូវចាត់ជាថ្លៃលក់សម្រាប់ការចែកចំណែក :

**ក-** ថ្លៃលក់នាវា ។

**ខ-** ប្រាក់ដែលអ្នកទិញពុំអាចទាមទារឱ្យសងមកវិញបាន តាមបញ្ញត្តិនៃវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រា

៤៨១ (អានុភាពនៃការមិនបង់ថ្លៃលក់) នៃក្រមនេះ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 121 និង មាត្រា 86 ។ មាត្រានេះបញ្ញត្តអំពីអ្វីដែលនៅក្នុងទំហំនៃថ្លៃលក់ ។

Civil Execution Act (Japan)
**Article 121** (*Mutatis mutandis* application of provisions concerning compulsory sale by auction of immovable) > *see the note for Article 465*
**Article 86** (Proceeds)
1. Proceeds shall consist of the following:
   i. the price of the immovable;
   ii. a part of the security provided in accordance with the provisions of Article 63, paragraph 2 item ii, equal to the remainder after subtracting the amount of the purchase price from the offering price;
   iii. any security the return of which may not be demanded by the buyer in accordance with the provisions of Article 80, paragraph 1, second sentence.
2. In cases where several immovables have been sold as an undivided whole in accordance with the provisions of Article 61, if it is necessary to determine the proceeds of each immovable, the amount of such proceeds proportionally in accordance with the minimum acceptable price of each immovable. This shall also apply to the bearing of costs of execution concerning each immovable.
3. The provisions of Article 78, paragraph 3 shall apply *mutatis mutandis* to realization in cases where the security referred to in item ii or iii of paragraph 1 has been provided by means other than payment of money.

**មាត្រា ៤៨៥.-** ការទាមទារឱ្យចែកចំណែក

១- បុគ្គលដែលកំណត់ដូចខាងក្រោមនេះ អាចទាមទារឱ្យចែកចំណែកបាន :

**ក-** ម្ចាស់បំណុលដែលមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលអាចអនុវត្តដោយបង្ខំបាន តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៣៩៤ (ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្តល់រូបមន្តអនុវត្ត) នៃក្រមនេះ ។

**ខ-** ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន នៅក្រោយពេលចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំ ។

**គ-** ម្ចាស់បំណុលដែលបានអនុវត្តការរឹបអូសជាបណ្តោះអាសន្ន យោងតាមវិធីដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ។

**ឃ-** បុគ្គលដែលបញ្ជាក់ដោយឯកសារអំពីឯកសិទ្ធិទូទៅ ឬ ឯកសិទ្ធិលើនាវា ។

២- ចំពោះដីកាសម្រេចលើកចោលការទាមទារឱ្យចែកចំណែកនេះ អាចប្តឹងជំទាស់បាន ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 121 មាត្រា 51 មាត្រា 89 និង ក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសកម្ពុជា មាត្រា ៣៩៤ (ការទាមទារឱ្យចែកចំណែកពីអ្នកមានឯកសិទ្ធិ ជាអាទិ៍) ។

ម្ចាស់បំណុលដែលបានធ្វើការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន មុនពេលចុះបញ្ជីអំពីការរឹបអូសផ្អែកលើដីកា

សម្រេចចាប់ផ្តើមលក់ដោយបង្ខំ អាចទទួលចំណែកបាន ដោយពុំចាំបាច់ទាមទារឱ្យចែកចំណែកតាមមាត្រានេះទេ (សូមមើលមាត្រា ៤៨៦ (វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក)) ។

ឯកសិទ្ធិលើនាវានេះ គឺ ឯកសិទ្ធិពិសេសដើម្បីម្ចាស់បំណុលមួយចំនួនដែលទាក់ទងនឹងនាវា ដែលត្រូវបានទទួលស្គាល់ថា មានអានុភាពទៅលើនាវា និង ឧបករណ៍ដែលភ្ជាប់ជាមួយ ជាដើម ។ ចំពោះការកំណត់សិទ្ធិលើបំណុលដែលត្រូវបានទទួលស្គាល់ថាជាឯកសិទ្ធលើនាវានោះ មានលក្ខណៈខុស១គ្នា យោងទៅតាមច្បាប់នៅក្នុងប្រទេស នៃប្រទេសនីមួយ១ ។ ច្បាប់នៅសហរដ្ឋអាមេរិក សិទ្ធិលើបំណុលនៃកិច្ចការនាវាចរណ៍ជាច្រើនប្រភេទ ត្រូវបានទទួលស្គាល់ថាជាឯកសិទ្ធិលើនាវា តែនៅប្រទេសអង់គ្លេសវិញ គេទទួលស្គាល់តែ សិទ្ធិលើបំណុលនៃសំណងការខូចខាតដោយការប៉ះទង្គិចនាវា សិទ្ធិលើបំណុលចំពោះសោហ៊ុយសង្គ្រោះគ្រោះថ្នាក់លើសមុទ្រ និង សិទ្ធិលើបំណុលនៃប្រាក់ខែរបស់នាវិកទេ ។ នៅប្រទេសជប៉ុនវិញ ច្បាប់ទទួលស្គាល់ឯកសិទ្ធិលើនាវានោះ ចំពោះសិទ្ធិលើបំណុលដែលលើកឡើងដោយច្បាប់ពាណិជ្ជកម្ម (មាត្រា 842) ដូចជា សិទ្ធិលើបំណុលដែលបានកើតឡើងដើម្បីផលប្រយោជន៍រួមរបស់ម្ចាស់បំណុលទាំងឡាយ សិទ្ធិលើបំណុលរបស់នាវិកដែលកើតឡើងដោយសារកិច្ចសន្យាការងារ សិទ្ធិលើបំណុលលើផលប្រយោជន៍សាធារណៈ ដូចជាពន្ធដារដែលបានកំណត់នៅពេលដែលនាវាចូលកំពង់ផែ និង ពន្ធដារផ្សេង១ដែលទាក់ទងនឹងនាវាចរណ៍ ជាដើម ហើយ សិទ្ធិលើបំណុលទាំងនេះ មានអាទិភាពជាងឯកសិទ្ធផ្សេងទៀត ឬ ហ៊ីប៉ូតែកលើនាវា ជាដើម (មាត្រា 845 និង មាត្រា 849) ។

ចំពោះសិទ្ធិប្រាតិភោគលើនាវា និង ការរឹបអូសវិញ មាន "អនុសញ្ញាអន្តរជាតិដើម្បីឯកភាពលើបទប្បញ្ញត្តិមួយចំនួនស្តីពីឯកសិទ្ធិនៃកិច្ចការនាវាចណ៍ និង ហ៊ីប៉ូតែកលើនាវា (International Convention for Unification of Certain Rules on Maritime Liens and Mortgages, 1967, 1993)" និង "អនុសញ្ញាអន្តរជាតិដើម្បីឯកភាពលើបទប្បញ្ញត្តិមួយចំនួនស្តីពីការរឹបអូសនាវា (International Convention for Unification of Certain Rules on Arrest of Ships, 1952, 1999)" ។

Civil Execution Act (Japan)

**Article 121** (*Mutatis mutandis* application of provisions concerning compulsory sale by auction of immovable) > *see the note for Article 465*

**Article 51** (Demand for distribution)

1.An obligee who has an exemplification of an obligation title by virtue of which compulsory execution may be effected according to the provisions of Article 25 (hereinafter referred to as "exemplification of obligation title having the executory power"), a provisional attachment obligee for whom registration of the provisional attachment was made after registration of attachment under a ruling of commencement of compulsory sale by auction, or an obligee who proves by a document referred t in the items of Article 181, paragraph 1 that such obligee has a general preferential right, may make a demand for distribution.

2. A kōkoku-appeal concerning execution may be filed against a decision dismissing a demand for distribution.

**Article 89** (Objection concerning distribution)

1. An obligee or obligor who has an objection concerning an obligation-right or the amount of distribution of any obligee may raise an objection on the date for distribution (hereinafter referred to as an "objection concerning distribution").

2. The execution court shall carry out distribution to the extent that no objection concerning distribution is raised.

Commercial Code (Japan)

**Article 842**

A person who has any of the claims mentioned below has a preferential right over the ship, its appurtenances and the unpaid freight:

- i. Expenses relating to the sale of the ship and its appurtenances by official auction, and the expenses of preservation after the commencement of the proceedings for the sale by auction;
- ii. Expenses of preservation of the ship and its appurtenances at the last port;
- iii. All public dues levied on the ship in respect of the voyage;
- iv. Pilotage dues and towage dues;
- v. Salvage remuneration and the ship's contribution to general average;

vi. Claims which have arisen from the necessity for the continuance of the voyage;
vii. Claims of the master and other mariners which have arisen from their contracts of employment;
viii. Claims which have arisen from the sale or construction and the equipment of the ship, in cases the ship has not yet made any voyage after her sale or construction; and claims in respect of the equipment and food and fuel of the ship for her last voyage.

**Article 845**

In cases of concurrence of the preferential right of a ship's creditor with other preferential rights, the preferential right of a ship's creditor shall take precedence over other preferential rights.

**Article 849**

The preferential right of a ship's creditor can be exercised in precedence to a hypothec.

**មាត្រា ៤៨៦.-** វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក

ម្ចាស់បំណុលដែលត្រូវទទួលចំណែកថ្លៃលក់ គឺជាបុគ្គលដែលកំណត់ដូចខាងក្រោមនេះ :

**ក-** ម្ចាស់បំណុលនៃការអនុវត្ត ។

**ខ-** ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក រហូតដល់កំណត់ពេលចុងក្រោយនៃការទាមទារឱ្យចែកចំណែក ។

**គ-** ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន នៅមុនការចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ។

( កំណត់ )

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 121 និង មាត្រា 87 ។ មាត្រានេះចែងអំពីវិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក ។ម្យ៉ាងទៀត ផ្នែកនេះត្រូវបានរៀបចំឡើង ដោយយកគោលការណ៍ថាអ្នកទិញត្រូវទទួលហ៊ីប៉ូតែកនាវា ( គោលការណ៍ទទួលបន្ត ) ។

<u>Civil Execution Act (Japan)</u>

**Article 121** (*Mutatis mutandis* application of provisions concerning compulsory sale by auction of immovable) > *see the note for Article 465*

**Article 87** (Coverage of obligees entitled to receive distribution)

1. Obligees entitled to receive distribution and the like shall be the following persons:
 i. an attachment obligee (only an attachment obligee who has made a motion for compulsory sale by auction or sale by auction in execution of a general preferential right by the final date for remanding distribution);
 ii. an obligee who has made a demand for distribution by the final date for demanding distribution;
 iii. a provisional attachment obligee who has been registered prior to registration of attachment (this refer, as is also true in the next item, to attachment concerning the first ruling of commencement of compulsory sale by auction);
 iv. an obligee who has a preferential right (except for a general preferential right as held by obligees referred to in items i and ii) that has been registered (including provisional registration by provisional disposition pursuant to the Civil Preservation Act (Law No. 91, 1989) before the attachment is registered, a right of pledge or a hypothec which is to be extinguished by the sale (including a holder of a hypothec certificate concerning said hypothec).
2. When the right of the obligee referred to in item iv of the preceding paragraph was registered after the registration of the provisional attachment, such obligee may receive distribution and the like only if the provisional attachment obligees were defeated in the principal suit or the provisional attachment has lost its effectiveness.
3. In cases where the procedure of compulsory sale by auction concerning the attachment was stayed but a decision continuing the procedure was rendered in accordance with Article 47, paragraph 4, if the attachment obligee under the stay of execution was defeated in a suit concerning the said stay, an obligee with a right referred to in paragraph 1, item iv, which was registered prior to registration of the attachment concerned in the said decision continuing the procedure after registration of attachment, may receive distribution and the like;

# ផ្នែកទី ៦ នីតិវិធីចែកចំណែកដោយតុលាការ

**មាត្រា ៤៨៧.-** តុលាការដែលត្រូវអនុវត្តការចែកចំណែក

តុលាការដែលត្រូវអនុវត្តការចែកចំណែក គឺសាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ ចំពោះការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ឬ តុលាការអនុវត្ត ចំពោះករណីផ្សេងទៀត ។(1)

(កំណត់)

សូមមើលមាត្រា 84 មាត្រា 107 មាត្រា 121 មាត្រា 139 មាត្រា 142 និង មាត្រា 166 ជាដើម នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

(1) ក្នុងចំណោមការអនុវត្តដោយបង្ខំគ្រប់ប្រភេទ ចំពោះការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ (ផ្នែកទី ២ ជំពូកទី ២ គន្ថីទី ៦) ជាបឋម អាជ្ញាសាលាត្រូវធ្វើការអនុវត្តការចែកចំណែក ប៉ុន្តែ យោងតាមមាត្រា ៤០១ (ការជូនដំណឹងទៅសាលាដំបូង) មានករណីដែលសាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅក្រោមឱវាទ ធ្វើការអនុវត្តការចែកចំណែក ។ ចំពោះការអនុវត្តដោយបង្ខំ ផ្សេងពីការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ តុលាការអនុវត្តត្រូវអនុវត្ត ការចែកចំណែក ។

Civil Execution Act (Japan)
**Article 84** (Distribution of proceeds)
1. Where the purchase price has been paid, the execution court, except in those cases mentioned in the next paragraph, shall carry out distribution on the basis of a table of distribution.
2. Where there is only one obligee, or every obligation-right of the respective obligees and costs of execution can be satisfied with the proceeds, the execution court shall draw up account concerning the delivery, deliver the sum(s) due to the obligee(s), and deliver the surplus to the obligor.
3. Where a document referred to in items i to vi inclusive of paragraph 1 of Article 39 has been submitted after payment of the purchase price, if there are other obligees entitled to receive distribution or payment of the proceeds (hereinafter referred to as "distribution and the like"), the execution court shall carry out distribution and the like on behalf of the said obligees.
4. Where a document referred to in item vii or viii of paragraph 1 of Article 39 has been submitted after payment of the purchase price, the execution court shall also carry out distribution and the like.
**Article 107** (Carrying out of distribution by administrator)
1. The administrator shall pay the costs referred to in paragraph 1 of the preceding Article and carry out distribution and the like by calculating the money to be allocated to distribution and the like at each period provided by the execution court.
2. Where there is only one obligee or where every obligation-right of two or more obligees and all costs of execution can be satisfied with the money to be allocated to distribution and the like, the administrator shall deliver all payments due to the obligees and deliver the surplus to the obligor.
3. Except for cases referred to in the preceding paragraph, if all obligees agree on the distribution of money to be allocated to distribute and the like, the administrator shall carry out the distribution in accordance with the agreement.
4. Obligees entitled to distribution and the like shall be attachment obligee and provisional attachment obligee who have made a motion for compulsory administration, and obligees who have made a demand for distribution, prior to the end of the period referred to in paragraph 1.
5. If an agreement as referred to in paragraph 3 has not been reached, the administrator shall so notify the execution court.
**Article 121** (*Mutatis mutandis* application of provisions for compulsory sale by auction of immovable)
The provisions of Division 2 of the preceding subsection (except for paragraph 1of Article 45, paragraph 2 of Article 46, Article 48, Article 54, paragraph 2, 6 and 7 of Article 55, Article 56, Article 81 and Article 82) shall apply *mutatis mutandis* to execution on a ship, and the provisions of Article 48, Article 54 and Article 82 shall apply *mutatis mutandis* to compulsory execution on a Japanese ship prescribed in Article 1 of the Ships Act (Law No. 46, 1899).
**Article 139** (Carrying out distribution by execution officer)
1. Where there is only one obligee or every obligation-right of the respective obligees and all costs of execution can be satisfied with the proceeds, seized money and money received for a bill and the like (hereinafter referred to as "proceeds and the like"), the execution officer shall deliver the tender to the obligee and deliver the surplus to the obligor.

2. Except for the case mentioned in the preceding paragraph, if all obligees have agreed with each other on distribution of the proceeds and the like, the execution officer shall carry out distribution according to the agreement.
3. If such agreement has not been reached, the execution officer shall notify the execution court of the circumstances.
4. The provisions of Article 84, paragraphs 3 and 4 and Article 88 shall apply *mutatis mutandis* to cases where distribution is carried out according to the provisions of paragraph 1 or 2.

**Article 142** (Carrying out of distribution by execution court)
1. In cases where notice has been given according to the provisions of Article 139, paragraph 3, the execution court shall immediately carry out the procedure of distribution and the like, and in cases where notice has been given according to the provisions of paragraph 1 of the preceding article, if the grounds for depositing money nolonger exist, the court shall carry out the procedure of distribution and the like.
2. The provisions of Article 84, 85 and 88 to 92 inclusive shall apply *mutatis mutandis* to the procedure of distribution and the like carried out by the execution court in accordance with the provisions of the preceding paragraph.

**Article 166** (Carrying out of distribution)
1. In addition to the cases referred to in Article 109 applied *mutatis mutandis* by Article 161, paragraph 6, the execution court shall carry out distribution in cases where:
   i. a deposit in accordance with the provisions of Article 156, paragraph 1 or 2 or Article 157, paragraph 5 has been made;
   ii. a sale has been effected through a sale order;
   iii. the proceeds have been submitted in accordance with the provisions of Article 163, paragraph 2.
2. The provisions of Articles 84, 85 and 88 to 92 inclusive shall apply *mutatis mutandis* to this procedure of distribution carried out by the execution court in accordance with the provisions of the preceding paragraph.

**មាត្រា ៤៨៨.-** ការរៀបចំការចែកចំណែក

១- បើមានមូលហេតុដែលចែងនៅចំណុចនីមួយៗខាងក្រោម តុលាការដែលត្រូវចែកចំណែកត្រូវកំណត់កាលបរិច្ឆេទនៃការចែកចំណែក ហើយផ្ដល់ដំណឹងអំពីពេលវេលា និង ទីកន្លែងនោះ ទៅម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែក និង កូនបំណុល : (1)

**ក-** ក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ពេលដែលមូលហេតុនៃការផ្ញើប្រាក់បានរលត់ ក្នុងករណីដែលមានការជូនដំណឹង តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៤០០ (ការផ្ញើប្រាក់ទុកនៅតុលាការដោយអាជ្ញាសាលា) ឬ ពេលដែលមានការជូនដំណឹងតាមបញ្ញត្តិនៃមាត្រា ៤០១ (ការជូនដំណឹងទៅសាលាដំបូង) នៃក្រមនេះ ។

**ខ-** ក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ពេលដែលបានធ្វើការផ្ញើប្រាក់ តាមបញ្ញត្តិនៃមាត្រា ៤១២ (បណ្ដឹងទាមទារប្រមូលបំណុល) ឬ ពេលដែលបានធ្វើការលក់ ដោយដីកាសម្រេចបង្គាប់ឱ្យលក់ តាមបញ្ញត្តិនៃមាត្រា ៤១៣ (ដីកាសម្រេចបង្គាប់ឱ្យលក់) ឬ ពេលដែលប្រាក់ដែលបានមកពីការលក់ ត្រូវបានប្រគល់ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៤១៤ (ការអនុវត្តដីកាសម្រេចរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ) នៃក្រមនេះ ។(2)

**គ-** ក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ពេលដែលមានការបង់ថ្លៃលក់ តាមបញ្ញត្តិនៃមាត្រា ៤៤៧ (ការបង់ថ្លៃលក់) ឬ ពេលដែលដីកាសម្រេចអនុញ្ញាតឱ្យលក់បានចូលជាស្ថាពរ នៅក្នុងករណីដែលមានការស្នើសុំ ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី ១ កថាខណ្ឌទី ៣ មាត្រា ៤៤៧ (ការបង់ថ្លៃលក់) នៃក្រមនេះ ។

**ឃ-** ក្នុងការអនុវត្តដោយបង្ខំចំពោះនាវា ពេលដែលមានការបង់ថ្លៃលក់ ដោយយោងតាមបញ្ញត្តិនៃមាត្រា ៤៧៩ (ការបង់ថ្លៃលក់) នៃក្រមនេះ ។

២- នៅពេលដែលកាលបរិច្ឆេទនៃការចែកចំណែកត្រូវបានកំណត់ហើយ ក្រឡាបញ្ជីត្រូវដាស់តឿនម្ចាស់បំណុលម្នាក់ៗ

ឱ្យផ្តល់លិខិតគណនាអំពីប្រាក់ដើមនៃសិទ្ធិលើបំណុល ការប្រាក់ រហូតដល់កាលបរិច្ឆេទនៃការចែកចំណែក និង សោហ៊ុយសម្រាប់ការអនុវត្ត ទៅតុលាការដែលត្រូវចែកចំណែក ក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ ។ (3)

(កំណត់)

មាត្រានេះតម្រូវនឹងមាត្រា 59 និង មាត្រា 60 នៃបទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

(1) ពេលដែលការចែកចំណែកត្រូវបានអនុវត្ត ចំពោះការអនុវត្តចំពោះវត្ថុដែលមានលក្ខណៈដូចនឹងអចលនវត្ថុ គឺជាករណីដែលមានការបង់ថ្លៃលក់ពីអ្នកទិញ ។ កាលបរិច្ឆេទនៃការចែកចំណែកមានន័យថាជាកាលបរិច្ឆេទដើម្បីធ្វើការចែកចំណែក ដោយផ្អែកលើតារាងចែកចំណែក និង ជាកាលបរិច្ឆេទដើម្បីចែកចំណែកប្រាក់សង ។

(2) តាមមាត្រា ៤១៦ (ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិ ក្រៅពីអចលនវត្ថុ នាវា ចលនវត្ថុ និង សិទ្ធិលើបំណុល (សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) ត្រូវធ្វើឡើងតាមវិធីអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល លើកលែងតែមានបញ្ញត្តិពិសេស ។ ក្នុងទំនាក់ទំនងនៃការអនុវត្តការចែកចំណែក ចំពោះករណីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល មាន ៣ ករណី នៅក្នុងចំណុច **ខ** កថាខណ្ឌទី ១ នៃមាត្រានេះ ដែលការចែកចំណែកត្រូវអនុវត្ត ប៉ុន្តែ ចំពោះការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ក្នុងចំណោម ៣ ករណីនោះ ការចែកចំណែកត្រូវអនុវត្ត ចំពោះតែករណីដែលការលក់ត្រូវបានធ្វើ ដោយការបង្គាប់ឱ្យលក់ តាមមាត្រា ៤១៣ (ដីកាសម្រេចបង្គាប់ឱ្យលក់) ។

(3) បញ្ញត្តិនេះមានគោលបំណងឱ្យម្ចាស់បំណុលម្នាក់ៗ ធ្វើសេចក្តីរាយការណ៍អំពីខ្លឹមសារនៃសិទ្ធិរបស់ខ្លួន នៅពេលនោះ ដើម្បីយកព័ត៌មាននោះមកជាឯកសារមូលដ្ឋាន សម្រាប់រៀបចំសេចក្តីព្រាងដើមនៃតារាងចែកចំណែក ជាដើម ។

**មាត្រា ៤៨៩.-** ការអនុវត្តការចែកចំណែក

១- ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤៨៨ (ការរៀបចំការចែកចំណែក) នៃក្រមនេះ តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវធ្វើការបែងចែក ដោយផ្អែកលើតារាងចែកចំណែក ។ ប៉ុន្តែ ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ មិនចាំបាច់ផ្អែកលើតារាងចែកចំណែកឡើយ ។ (1)

២- ក្នុងករណីដែលម្ចាស់បំណុលមានតែម្នាក់ ឬ ក្នុងករណីដែលម្ចាស់បំណុលមានច្រើននាក់ ហើយទឹកប្រាក់ដែលត្រូវបំពេញការចែកចំណែកនោះ អាចសងសព្វគ្រប់ចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ ព្រមទាំងសោហ៊ុយសម្រាប់ការអនុវត្ត តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវចែកទៅម្ចាស់បំណុលគ្រប់រូប ហើយផ្តល់ទឹកប្រាក់ដែលសេសសល់ ទៅកូនបំណុលនៃការអនុវត្ត ។ (2)

៣- ក្នុងករណីដែលមានការផ្តល់នូវលិខិតដែលបានកំណត់ពីចំណុច **ក** ដល់ចំណុច **ឆ** នៃកថាខណ្ឌទី ១ មាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ក្រោយពេលត្រូវចាប់ផ្តើមអនុវត្តការចែកចំណែក

បើមានម្ចាស់បំណុលដែលត្រូវទទួលចំណែកផ្សេងពីម្ចាស់បំណុលនៃការអនុវត្ត តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវចែកចំណែកឱ្យម្ចាស់បំណុលនោះ ។ (3)

៤- ក្នុងករណីដែលមានការផ្តល់នូវលិខិតដែលបានកំណត់នៅក្នុងចំណុច **ក** និង ចំណុច **ខ** នៃកថាខណ្ឌទី ២ មាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ក្រោយពេលត្រូវចាប់ផ្តើមអនុវត្តការចែកចំណែក តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវធ្វើការចែកចំណែកផងដែរ ។ (4)

(កំណត់)

មាត្រានេះតម្រូវនឹងមាត្រា 84 មាត្រា 121 មាត្រា 139 កថាខណ្ឌទី 2 នៃមាត្រា 142 និង កថាខណ្ឌទី 2 នៃមាត្រា 166 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

(1) ក្នុងករណីដែលត្រូវសម្រេចអនុវត្តការចែកចំណែក (សូមមើលកថាខណ្ឌទី ១ នៃមាត្រា ៤៨៨ (ការរៀបចំការចែកចំណែក)) នីតិវិធីសងទៅម្ចាស់បំណុល មានពីរប្រភេទ គឺ នីតិវិធីអនុវត្តការចែកចំណែក ដោយធ្វើតារាងចែកចំណែក ហើយបើកកាលបរិច្ឆេទនៃការចែកចំណែក (កថាខណ្ឌទី ១ នៃមាត្រានេះ) និង នីតិវិធីអនុវត្តសង្ខេបការចែកចំណែកដោយមិនផ្អែកលើតារាងចែកចំណែក (កថាខណ្ឌទី ២ នៃមាត្រានេះ) ។ ការចែកចំណែកដោយផ្អែកលើតារាងចែកចំណែក នឹងធ្វើឡើង ក្នុងករណីផ្សេងពីការចែកចំណែកនៃករណីខាងក្រោយនេះ ។

(2) នីតិវិធីចែកចំណែកដោយមិនផ្អែកលើតារាងចែកចំណែក នឹងធ្វើឡើង ក្នុងករណីដែលមានម្ចាស់បំណុលតែ ១ នាក់ ឬ លើសពី ២ នាក់ ហើយអាចសងបំណុលទៅម្ចាស់បំណុលនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់ ដោយទឹកប្រាក់បានមកពីការរឹបអូស ឬ ការប្តូរជាប្រាក់ ។ ការចែកចំណែកនេះខុសគ្នាពីការចែកចំណែកដោយផ្អែកលើតារាងចែកចំណែក ដោយសារគ្មានការកំណត់នីតិវិធីពិសេសដែលហៅថា "ការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក" (កថាខណ្ឌទី ១ នៃមាត្រា ៤៩១ (ការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក)) ហេតុដូច្នេះ ប្រសិនបើកូនបំណុលនៃការអនុវត្តធ្វើវិវាទ អំពីអត្ថិភាពនៃបំណុល ឬ តម្លៃ កូនបំណុលនោះត្រូវដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ (មាត្រា ៣៦៣ (បណ្តឹងតវ៉ាចំពោះការទាមទារ)) ឬ បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃសិទ្ធិប្រាតិភោគ ជាដើម ហើយបើមិនបានទទួលការសម្រេចសេចក្តីដែលបង្គាប់ឱ្យផ្អាកការអនុវត្តទេ កូនបំណុលនោះពុំអាចរារាំងការចែកចំណែក ទៅម្ចាស់បំណុលបានឡើយ ។
ម្យ៉ាងទៀត ចំពោះករណីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ការចែកចំណែកដោយមិនផ្អែកលើតារាងចែកចំណែក ត្រូវធ្វើឡើងដោយអាជ្ញាសាលានោះ (មាត្រា ៣៩៩ (ការចែកចំណែកដោយអាជ្ញាសាលា) កថាខណ្ឌទី ១) ហេតុដូច្នេះ តុលាការពុំធ្វើការអនុវត្តការចែងចំណែកនេះទេ ។

(3) ក្រោយពេលដែលត្រូវចាប់ផ្តើមអនុវត្តការចែកចំណែកហើយ (ឧទាហរណ៍ : ករណីនៃការអនុវត្តចំពោះនាវាក្រោយការបង់ថ្លៃលក់) បើមានការផ្តល់នូវលិខិតដែលផ្អាកការអនុវត្ត ហើយលុបចោលការអនុវត្តនោះ

(លិខិតលុបចោលការអនុវត្ត) ម្ចាស់បំណុលដែលទទួលការផ្តល់លិខិតនោះ ពុំអាចទទួលការចែកចំណែកទេ ប៉ុន្តែបើមានម្ចាស់បំណុលផ្សេងទៀត ការចែកចំណែកត្រូវធ្វើឡើងដើម្បីជននោះ ។

(4) ក្រោយពេលដែលត្រូវចាប់ផ្តើមអនុវត្តការចែកចំណែក ហើយក្នុងករណីដែលមានការផ្តល់នូវលិខិតដែលផ្អាកការអនុវត្ត (លិខិតផ្អាកការអនុវត្ត) តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវធ្វើការចែកចំណែក ដោយគិតបញ្ចូលទាំងម្ចាស់បំណុលដែលមានមូលហេតុនៃការផ្អាកការអនុវត្ត ។ ប៉ុន្តែ ចំពោះករណីដែលមានការផ្តល់នូវលិខិតដែលបានកំណត់នៅក្នុងចំណុច **ក** កថាខណ្ឌទី ២ មាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) ចំនួនទឹកប្រាក់ស្មើនឹងចំណែករបស់ម្ចាស់បំណុល ដែលទទួលការផ្តល់លិខិតនោះ ត្រូវផ្អាកទុកនៅតុលាការ (ចំណុច **ក** កថាខណ្ឌទី ១ នៃមាត្រា ៤៩៤ (ការផ្អាកទុកចំនួនប្រាក់ចំណែក)) ឯចំពោះករណីដែលមានការផ្តល់នូវលិខិតដែលបានកំណត់នៅក្នុងចំណុច **ខ** វិញ ការផ្តល់លិខិតនោះត្រូវពុំបានទទួលស្គាល់ទេ ។

Civil Execution Act (Japan)
**Article 84** (Distribution of proceeds) > *see the note for Article 487*
**Article 121** (*Mutatis mutandis* application of provisions for compulsory sale by auction of immovable) > *see the note for Article487*
**Article 142** (Carrying out of distribution by execution court) > *see the note for Article 487*
**Article 166** (Carrying out of distribution) > *see the note for Article 487*

## មាត្រា ៤៩០.- ការធ្វើតារាងចែកចំណែក

១- តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវធ្វើតារាងចែកចំណែក នៅកាលបរិច្ឆេទនៃការចែកចំណែកនោះ លើកលែងតែករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៤៨៩ (ការអនុវត្តការចែកចំណែក) នៃក្រមនេះ ។ (1)

២- នៅកាលបរិច្ឆេទនៃការចែកចំណែក តុលាការត្រូវកោះហៅម្ចាស់បំណុលដែលបានកំណត់ខាងក្រោមនេះ និង កូនបំណុលនៃការអនុវត្ត :

**ក**- ករណីអនុវត្តដោយបង្ខំចំពោះចលនវត្ថុ : ម្ចាស់បំណុលដែលបានកំណត់នៅក្នុងមាត្រា ៣៩៨ (វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែកជាប្រាក់) នៃក្រមនេះ ។

**ខ**- ករណីអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត : ម្ចាស់បំណុលដែលបានកំណត់នៅក្នុងមាត្រា ៤១៥ (វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក) នៃក្រមនេះ ។

**គ**- ករណីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ : ម្ចាស់បំណុលដែលបានកំណត់នៅក្នុងមាត្រា ៤៥៣ (វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក) នៃក្រមនេះ ។

**ឃ**- ករណីអនុវត្តដោយបង្ខំចំពោះនាវា : ម្ចាស់បំណុលដែលបានកំណត់នៅក្នុងមាត្រា ៤៨៦ (វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក) នៃក្រមនេះ ។

៣- ពាក់ព័ន្ធនឹងការធ្វើតារាងចែកចំណែក តុលាការអាចសួរម្ចាស់បំណុល និង កូនបំណុលនៃការអនុវត្តដែលបង្ហាញខ្លួន

ហើយអាចធ្វើការពិនិត្យភស្តុតាងជាឯកសារដែលអាចធ្វើការពិនិត្យភ្លាមៗបាន នៅកាលបរិច្ឆេទនៃការចែកចំណែក ។

៤- នៅលើតារាងចែកចំណែក ទន្ទឹមគ្នានឹងចំនួនទឹកប្រាក់ខាងក្រោមនេះ តុលាការត្រូវសរសេរអំពីចំនួនប្រាក់ដើម ការប្រាក់ សិទ្ធិលើបំណុលបន្ទាប់បន្សំផ្សេងៗនៃសិទ្ធិលើបំណុល សោហ៊ុយសម្រាប់ការអនុវត្ត និង លំដាប់និងចំនួនទឹកប្រាក់នៃការចែកចំណែក :

**ក**- ករណីអនុវត្តដោយបង្ខំចំពោះចលនវត្ថុ : ចំនួនទឹកប្រាក់បានមកពីការលក់វត្ថុ ដែលត្រូវបានរឹបអូស និង ចំនួនទឹកប្រាក់ដែលត្រូវបានរឹបអូស ។

**ខ**- ករណីអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត : ចំនួនទឹកប្រាក់ដែលត្រូវអនុវត្តការចែកចំណែក ។

**គ**- ករណីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ : ចំនួនទឹកប្រាក់ដែលបានមកពីការលក់ ។

**ឃ**- ករណីអនុវត្តដោយបង្ខំចំពោះនាវា : ចំនួនទឹកប្រាក់ដែលបានមកពីការលក់ ។

៥- លំដាប់ និង ចំនួនទឹកប្រាក់នៃការចែកចំណែក ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ ត្រូវសរសេរតាមការព្រមព្រៀង ក្នុងករណីដែលកិច្ចព្រមព្រៀងបានសម្រេចឡើងរវាងម្ចាស់បំណុលគ្រប់រូប នៅកាលបរិច្ឆេទនៃការចែកចំណែក ឯក្នុងករណីផ្សេងទៀត ត្រូវសរសេរតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ច្បាប់ដែលទាក់ទងនឹងពាណិជ្ជកម្ម ឬ ច្បាប់ផ្សេងទៀត ។

៦- ពាក់ព័ន្ធនឹងការចែកចំណែក សិទ្ធិលើបំណុលដែលពេលកំណត់ពិតប្រាកដពុំទាន់ឈានចូលមកដល់ ត្រូវចាត់ទុកថាពេលកំណត់សងបានចូលមកដល់ ។(3)(4)

(កំណត់)

មាត្រានេះត្រូវនឹងមាត្រា 85 មាត្រា 88 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

(1) មាត្រានេះបញ្ញត្តអំពីនីតិវិធីនៃការធ្វើតារាងចែកចំណែក ក្នុងករណីដែលការចែកចំណែកត្រូវធ្វើឡើងដោយផ្អែកលើតារាងចែកចំណែក (កថាខណ្ឌទី ១ នៃមាត្រា ៤៨៩ (ការអនុវត្តការចែកចំណែក)) ។

(2) តារាងចែកចំណែកត្រូវធ្វើទុកជាមុនជាសេចក្តីព្រាងដើម ដោយយកលិខិតគណនាដែលត្រូវបានផ្តល់ជាមុនពីម្ចាស់បំណុលម្នាក់ៗជាមូលដ្ឋាន ហើយនៅកាលបរិច្ឆេទនៃការចែកចំណែក ត្រូវឱ្យម្ចាស់បំណុលម្នាក់ៗ និង កូនបំណុលពិនិត្យមើលសេចក្តីព្រាងនោះ ហើយធ្វើឡើងជាបន្ថែមក្រោយបានទទួលយោបល់ ។

(3) កថាខណ្ឌទី ៦ ចែងអំពីវិធីចាត់ទុកចំពោះសិទ្ធិលើបំណុលដែលភ្ជាប់នឹងពេលកំណត់ពិតប្រាកដ តែពេលកំណត់នោះពុំទាន់ឈានមកដល់ ។ ចំពោះសិទ្ធិលើបំណុលដែលភ្ជាប់នឹងពេលកំណត់ពិតប្រាកដ តែពេលកំណត់ពុំទាន់ឈានមកដល់ ដើម្បីចាត់ចែងឱ្យបានឆាប់រហ័សនូវនីតិវិធី ត្រូវបានចាត់ទុកថា ពេលកំណត់សងនោះបានឈានចូលមកដល់ហើយ ។ ម្ចាស់បំណុលអាចទទួលការប្រាក់ចំពោះតែចំនួនការប្រាក់រហូតដល់កាលបរិច្ឆេទនៃការចែកចំណែកប៉ុណ្ណោះ តែជា

ជំនួស អាចទទួលប្រាក់ចំណែកភ្លាមៗបាន ។ នៅប្រទេសជប៉ុន អំពីសិទ្ធិលើបំណុលដែលគ្មានការប្រាក់ ការចាត់ទុកថាអាចទទួលប្រាក់គ្រប់ចំនួននៅកាលបរិច្ឆេទនៃការចែកចំណែកនោះ មិនសមរម្យ តាមទស្សនវិស័យនៃការមិនលំអៀងរវាងម្ចាស់បំណុល ហេតុដូច្នេះ គេចាត់ទុកចំនួនទឹកប្រាក់ ដែលដកពីចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនូវការប្រាក់តាមអត្រាការប្រាក់ដែលបានកំណត់ដោយច្បាប់ (legal interest rate) គិតពីកាលបរិច្ឆេទនៃការចែកចំណែករហូតដល់ពេលកំណត់ ថាជាចំនួនប្រាក់ដើម ហើយធ្វើការគណនាចំនួនប្រាក់នៃការចែកចំណែក (សូមមើលកថាខណ្ឌទី 2 នៃមាត្រា 88 នៃច្បាប់ស្តីពីការអនុវត្តផ្នែកក្រមរដ្ឋប្បវេណីជប៉ុន) ។

(4) ចំពោះសិទ្ធិលើបំណុលដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌបង្អង់ ឬ ភ្ជាប់នឹងពេលកំណត់មិនពិតប្រាកដ ទឹកប្រាក់ដែលស្មើនឹងចំណែកនោះ ត្រូវផ្អាកទុកនៅតុលាការ រហូតដល់ពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ឬ ពេលកំណត់មិនពិតប្រាកដនោះមកដល់ (ចំណុច ក កថាខណ្ឌទី ១ នៃមាត្រា ៤៩៤ (ការផ្អាកទុកចំនួនប្រាក់ចំណែក)) ។

Civil Execution Act (Japan)

**Article 85** (Drawing up of a table of distribution)

1. The execution court shall draw up a table of distribution on the date for distribution.
2. The obligees referred to in the items of paragraph 1 of Article 87 and the obligor shall be summoned on the date for distribution.
3. The execution court may interrogated the obligees and the obligor present in court and examine documentary evidence which can be immediately examined on the date for distribution with regard to the drawing up of a table of distribution.
4. The amount of proceeds, principal and interest of every obligation-right and any other incidental obligation-right of respective obligees, the costs of execution, and the order and amount of distribution shall be entered in the table of distribution.
5. If the order and amount of distribution referred to in the preceding paragraph is agreed to by all the obligees on the date for distribution, they shall be entered in the table in accordance with such agreement and in other case they shall be entered in accordance with the provisions of the Civil Code, the Commercial Code and any other laws.

**Article 86** (Proceeds)

1. Proceeds shall consist of the following:
   i. the price of the immovable;
   ii. a part of the security provided in accordance with the provisions of Article 63, paragraph 2 item ii, equal to the remainder after subtracting the amount of the purchase price from the offering price;
   iii. any security the return of which may not be demanded by the buyer in accordance with the provisions of Article 80, paragraph 1, second sentence.
2. In cases where several immovables have been sold as an undivided whole in accordance with the provisions of Article 61, if it is necessary to determine the proceeds of each immovable, the amount of such proceeds proportionally in accordance with the minimum acceptable price of each immovable. This shall also apply to the bearing of costs of execution concerning each immovable.
3. The provisions of Article 78, paragraph 3 shall apply *mutatis mutandis* to realization in cases where the security referred to in item ii or iii of paragraph 1 has been provided by means other than payment of money.

**មាត្រា ៤៩១.-** ការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក

១- ម្ចាស់បំណុល និង កូនបំណុលនៃការអនុវត្តដែលមានឧបាស្រ័យ ចំពោះសិទ្ធិលើបំណុល ឬ ចំនួនប្រាក់ចំណែករបស់ម្ចាស់បំណុលម្នាក់ៗដែលត្រូវបានសរសេរលើតារាងចែកចំណែក អាចថ្លែងសេចក្តីតវ៉ាបាន នៅកាលបរិច្ឆេទនៃការចែកចំណែក ។ (1) (2)

២- តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវធ្វើការចែកចំណែកតែផ្នែកដែលគ្មានការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ។ (3)

៣- ជាលទ្ធផលនៃការអនុវត្តការចែកចំណែក បើម្ចាស់បំណុលនៃការអនុវត្ត ឬ ម្ចាស់បំណុលដែលបានទាមទារចំណែក

ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្ត បានទទួលនូវចំណែកគ្រប់ចំនួននៃសិទ្ធិលើបំណុល នោះកូនបំណុលនៃការអនុវត្តអាចទាមទារឱ្យក្រឡាបញ្ជីប្រគល់នូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្តដែលម្ចាស់បំណុលនោះបានផ្តល់ ។ (4)

៤- លើកលែងតែករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ កាលដែលរឿងក្តីបានបញ្ចប់ហើយ ម្ចាស់បំណុលដែលបានកំណត់នៅកថាខណ្ឌទី ៣ នោះ អាចទាមទារឱ្យក្រឡាបញ្ជីប្រគល់នូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្តបាន ។ ប៉ុន្តែ ប្រសិនបើម្ចាស់បំណុលនោះជាជនដែលបានទទួលចំណែកនៃសិទ្ធិលើបំណុលតែមួយផ្នែក ក្រឡាបញ្ជីត្រូវប្រគល់នូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដោយចារនូវចំនួននៃចំណែកដែលម្ចាស់បំណុលនោះបានទទួលលើឯកសារនោះ ។ (5)

(កំណត់)

មាត្រានេះតម្រូវនឹងមាត្រា 89 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណី មាត្រា 62 មាត្រា 83 មាត្រា 97 មាត្រា 132 និង មាត្រា 145 នៃបទបញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

(1) កថាខណ្ឌទី ១ នៃមាត្រានេះចែងអំពីនីតិវិធីនៃបណ្តឹងឧបាស្រ័យដែលត្រូវបានធ្វើដោយម្ចាស់បំណុល ឬ កូនបំណុលនៃការអនុវត្តដែលមានសេចក្តីឧបាស្រ័យចំពោះចំណុចណាដែលបានសរសេរលើតារាងចែកចំណែក ។ ប៉ុន្តែ កូនបំណុលនៃការអនុវត្តដែលមានសេចក្តីឧបាស្រ័យ ចំពោះការចែកចំណែកដែលពុំមានធ្វើតារាងចែកចំណែក (កថាខណ្ឌទី ២ នៃមាត្រា ៤៨៩ (ការអនុវត្តការចែកចំណែក)) នោះ ត្រូវធ្វើបណ្តឹងតវ៉ាចំពោះការទាមទារ (មាត្រា ៣៦៣ (បណ្តឹងតវ៉ាចំពោះការទាមទារ)) ឬ បណ្តឹងទាមទារឱ្យបញ្ជាក់នត្ថិភាពនៃសិទ្ធិប្រាតិភោគ ជាដើម ។

(2) ម្ចាស់បំណុល ឬ កូនបំណុលនៃការអនុវត្តដែលមានឧបាស្រ័យអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលម្នាក់ៗ លំដាប់នៃការចែកចំណែក ឬ ចំនួនតិចច្រើននៃចំណែក ជាដើម ដែលត្រូវបានសរសេរលើតារាងចែកចំណែក អាចបង្ហាញខ្លួននៅកាលបរិច្ឆេទនៃការចែកចំណែក ហើយថ្លែងសេចក្តីតវ៉ា ចំពោះការសរសេរលើតារាងចែកចំណែកបាន ។

ជាបន្ថែម ចំពោះវិការៈនៃនីតិវិធីធ្វើតារាងចែកចំណែក ម្ចាស់បំណុល ឬ កូនបំណុលនៃការអនុវត្ត អាចធ្វើការតវ៉ាចំពោះការអនុវត្ត (មាត្រា ៣៤៤ (ការតវ៉ាចំពោះការអនុវត្ត)) បាន នៅមុនកាលបរិច្ឆេទនៃការចែកចំណែក ឬ នៅកាលបរិច្ឆេទនៃការចែកចំណែក ។

(3) ជាប្រាកដចំពោះករណីដែលគ្មានការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ហើយទោះជាមានការតវ៉ាក៏ដោយ ចំពោះផ្នែកដែលគ្មានការតវ៉ា តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវតែធ្វើការចែកចំណែកជាបន្ទាន់ ។ ទោះជាមានការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកក៏ដោយ ក្នុងករណីដែលការតវ៉ានោះត្រូវបានចាត់ទុកថាបានដក តាមបញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ៤៩២ (បណ្តឹងតវ៉ារបស់ម្ចាស់បំណុលដែលបានថ្លែងសេចក្តីតវ៉ា

ចំពោះការសរសេរលើតារាងចែកចំណែក) ឬ កថាខណ្ឌទី ៤ នៃមាត្រា ៤៩៣ (បណ្ដឹងតវ៉ារបស់កូនបំណុលនៃការអនុវត្តដែលបានថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក) ជាដើម តុលាការត្រូវអនុវត្តការចែកចំណែកចំពោះផ្នែកដែលគ្មានការតវ៉ា បូកបញ្ចូលទាំងផ្នែកដែលត្រូវបានចាត់ទុកនោះផងដែរ ។

(4) លិខិតអនុវត្តដែលចែងនៅកថាខណ្ឌទី ៤ សំដៅទៅលើលិខិតដែលម្ចាស់បំណុលនៃការអនុវត្តបានផ្ដល់ នៅពេលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ (សូមមើលមាត្រា ៣៤៩ (របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ)) ឬ លិខិតដែលម្ចាស់បំណុលធ្វើការទាមទារឱ្យចែកចំណែកបានផ្ដល់នៅពេលទាមទារឱ្យចែកចំណែក (សូមមើលមាត្រា ៤០៩ (ការទាមទារឱ្យចែកចំណែក)) ។ កាលដែលម្ចាស់បំណុលនៃការអនុវត្ត ឬ ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែកដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត បានទទួលការសងគ្រប់ចំនួននូវសិទ្ធិលើបំណុលរបស់ខ្លួន នោះកូនបំណុលនៃការអនុវត្តអាចទាមទារឱ្យក្រឡាបញ្ជីប្រគល់នូវឯកសារចម្លងយថាភូតដែលមានអានុភាពអនុវត្តដែលម្ចាស់បំណុលនោះបានផ្ដល់បាន ។ បើមានការទាមទារនេះ ក្រឡាបញ្ជីត្រូវប្រគល់ឱ្យកូនបំណុលនៃការអនុវត្ត នូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ដែលមាននៅក្នុងសំណុំរឿង ។

(5) លើកលែងករណីដែលចែងនៅកថាខណ្ឌទី ៤ ក្នុងករណីដែលរឿងក្ដីបានបញ្ចប់ (ពោលគឺលើកលែងតែករណីដែលរឿងក្ដីបានបញ្ចប់ដោយទទួលការសងគ្រប់ចំនួននៃសិទ្ធិលើបំណុល) ម្ចាស់បំណុលដែលមិនបានទទួលការសងអាចដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំសាជាថ្មី ឬ ទាមទារឱ្យចែកចំណែកសាជាថ្មី ។ ដើម្បីធ្វើបែបនេះបាន ការអនុញ្ញាតឱ្យម្ចាស់បំណុលនោះ ប្រើប្រាស់សាជាថ្មីនូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្តដែលខ្លួនបានផ្ដល់នោះ ជាការសមរម្យ ហេតុដូច្នេះ ម្ចាស់បំណុលអាចទាមទារឱ្យប្រគល់លិខិតនោះវិញបាន ។ ប៉ុន្តែ ក្នុងករណីដែលម្ចាស់បំណុលដែលទាមទារឱ្យប្រគល់លិខិតអនុវត្តនោះ បានទទួលការសងនូវសិទ្ធិលើបំណុលមួយភាគ ក្រឡាបញ្ជីត្រូវចារបន្ថែមនូវចំណែកដែលបានទទួល លើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ហើយប្រគល់ឯកសារនោះ ។

Civil Execution Act (Japan)
**Article 89** (Objection concerning distribution)
1. An obligee or obligor who has an objection concerning an obligation-right or the amount of distribution of any obligee may raise an objection on the date for distribution (hereinafter referred to as an "objection concerning distribution").
2. The execution court shall carry out distribution to the extent that no objection concerning distribution is raised.

**មាត្រា ៤៩២.-** បណ្ដឹងតវ៉ារបស់ម្ចាស់បំណុលដែលបានថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក

១- ម្ចាស់បំណុលដែលបានថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ត្រូវដាក់ពាក្យបណ្ដឹងតវ៉ា ចំពោះការសរសេរលើតារាងចែកចំណែក ដោយយកម្ចាស់បំណុលដែលជាភាគីម្ខាងទៀតនៃការស្នើសុំតវ៉ាជាចុងចម្លើយ ។(1)

២- បណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលត្រូវអនុវត្ត

ការចែកចំណែក ។ (2)

៣- បើម្ចាស់បំណុលដែលបានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកមិនបញ្ជាក់ថា ខ្លួនបានដាក់ពាក្យបណ្តឹងដែលបានកំណត់នៅកថាខណ្ឌទី ១ ទៅតុលាការ ក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ ចាប់ពីកាលបរិច្ឆេទនៃការចែកចំណែក ការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ត្រូវចាត់ទុកថា បានដកវិញ ។ (3)

៤- ក្នុងសាលក្រមនៃបណ្តឹងដែលបានកំណត់នៅកថាខណ្ឌទី ១ បើយល់ឃើញថាការតវ៉ាមានភាពត្រឹមត្រូវ តុលាការត្រូវធ្វើការផ្លាស់ប្តូរតារាងចែកចំណែក ឬ លុបចោលតារាងចែកចំណែកដើម្បីធ្វើតារាងចែកចំណែកថ្មី ។ (4) (5)

(កំណត់)

សូមមើលមាត្រា 90 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

(1) ម្ចាស់បំណុលដែលបានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ត្រូវដាក់ពាក្យបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ។ ចំពោះកូនបំណុលនៃការអនុវត្តដែលបានធ្វើការស្នើសុំតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក សូមមើលមាត្រា ៤៩៣ (បណ្តឹងតវ៉ារបស់កូនបំណុលនៃការអនុវត្តដែលបានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក) ។

(2) តុលាការដែលមានសមត្ថកិច្ចលើបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក គឺតុលាការដែលត្រូវអនុវត្តការចែកចំណែក (មាត្រា ៤៨៧ (តុលាការដែលត្រូវអនុវត្តការចែកចំណែក)) ។ ដែលហៅថាតុលាការនៅទីនេះ ពុំមែនជាអង្គការចែកចំណែកទេ គឺជាអង្គការសម្រេចសេចក្តី នៅក្នុងស្ថាប័នដែលតុលាការទទួលបន្ទុកនីតិវិធីនៃការចែកចំណែកបច្ចុប្បន្នស្ថិតនៅក្រោមឱវាទ ។

(3) បើគ្មានការបញ្ជាក់អំពីការដាក់ពាក្យបណ្តឹងតវ៉ាចំពោះការសរសេរលើការចែកចំណែកទេ ច្បាប់ត្រូវចាត់ទុកថាការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ត្រូវបានដក ។ នេះមកពីគោលបំណងដែលឱ្យបញ្ចប់បណ្តឹងតវ៉ាចំពោះការសរសេរលើការចែកចំណែកក្នុងរយៈពេលខ្លី ហើយការពារការអនុវត្តការចែកចំណែកពីការរារាំងដោយបណ្តឹងតវ៉ាដែលគ្មានឫសគល់ ។ ដោយសារអានុភាពនៃការចាត់ទុកថា ដកពាក្យបណ្តឹងតវ៉ា តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវតែធ្វើការចែកចំណែក (កថាខណ្ឌទី ២ នៃមាត្រា ៤៩១ (ការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក)) ។

(4) ក្នុងបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក តុលាការវិនិច្ឆ័យអំពីភាពត្រឹមត្រូវនៃការតវ៉ាដែលដើមចោទបានស្នើអំពីសិទ្ធិលើបំណុល និង ចំនួនប្រាក់នៃចំណែករបស់ចុងចម្លើយដែលត្រូវបានសរសេរលើតារាងចែកចំណែក ។ ចំពោះមូលហេតុនៃការតវ៉ា ដើមចោទអាចធ្វើការអះអាងអំពីហេតុសារធាតុ ដូចជា លក្ខណៈមិនពេញលេញ ឬ ការរលត់នៃសិទ្ធិលើបំណុលរបស់ចុងចម្លើយ ការបាត់បង់សិទ្ធិអាទិភាពដែលត្រូវបានសរសេរលើតារាងចែកចំណែក ជាដើម ហើយដើមចោទក៏អាចអះអាងផងដែរ អំពីហេតុដែលទាក់ទងនឹងនីតិវិធី ដូចជា មោឃភាពនៃការរឹបអូស ឬ

ការទាមទារឱ្យចែកចំណែករបស់ចុងចម្លើយ ការបង្កើតអានុភាពនៃលិខិតលុបការអនុវត្តចំពោះសិទ្ធិលើបំណុលរបស់ចុងចម្លើយ ជាដើម ។ ហើយបើការទាមទាររបស់ដើមចោទត្រូវបានទទួលស្គាល់ថា មានមូលហេតុត្រឹមត្រូវ តុលាការត្រូវលុបចោលនូវចំនួនទឹកប្រាក់នៃចំណែកសម្រាប់ចុងចម្លើយដែលបានសរសេរលើតារាងចែកចំណែក ហើយសម្រេចអំពីចំនួនទឹកប្រាក់នៃចំណែកដែលត្រូវបានលុបចោលនោះថា ត្រូវបែងចែកចំនួនប៉ុន្មានសាជាថ្មីដើម្បីម្ចាស់បំណុលណាមួយនោះ ក្នុងសាលក្រម ឬ សាលដីកា ។ ម្យ៉ាងទៀត ក្នុងករណីដែលចំនួនប្រាក់ចំណែកនៃការបែងចែកសាជាថ្មីពុំទាន់សម្រេច ដោយសារមូលហេតុ ដូចជា ស្ថានភាពនៃបណ្ដឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកឯទៀតពុំទាន់បានដោះស្រាយ ជាដើម តុលាការនឹងសម្រេចការលុបចោលចំនួនប្រាក់ចំណែករបស់ចុងចម្លើយក្នុងតារាងចែកចំណែកតែប៉ុណ្ណោះ ហើយតារាងចែកចំណែកថ្មីនឹងធ្វើឡើង ដោយរង់ចាំដំណោះស្រាយ ជាដើម នៃបណ្ដឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកឯទៀត ។

(5) ក្នុងករណីម្ចាស់បំណុលជាដើមចោទ ដូចចែងនៅមាត្រានេះ ការបែងចែកសាជាថ្មីនៃចំនួនប្រាក់ចំណែកខាងលើត្រូវធ្វើឡើងរវាងចុងចម្លើយជាម្ចាស់បំណុលផ្សេងតែប៉ុណ្ណោះ ពុំប៉ះពាល់ដល់ចំនួនប្រាក់ចំណែករបស់ម្ចាស់បំណុលឯទៀតទេ (ម្យ៉ាងទៀត សូមមើលចំណុច ❷ កថាខណ្ឌទី ២ នៃមាត្រា ៤៩៥ (ការអនុវត្តការចែកចំណែកដោយការសម្រេចសិទ្ធិជាស្ថាពរ ជាអាទិ៍) និង កំណត់នៃមាត្រា ៤៩៥ នោះ) ។ ឧទាហរណ៍ ម្ចាស់បំណុលដែលទទួលចំណែកមាន ៣ នាក់ គឺ A B និង C ចំនួនប្រាក់នៃសិទ្ធិលើបំណុលដែលម្ចាស់បំណុលម្នាក់ៗ រាយការណ៍ គឺ ៤00 ម៉ឺន រៀល ៦00 ម៉ឺន រៀល និង ៨00 ម៉ឺន រៀល ហើយបើឧបមាថាចំនួនសរុបនៃទឹកប្រាក់ដែលត្រូវអនុវត្តការចែកចំណែកមាន ៩00 ម៉ឺន រៀល យោលតាមតារាងចែកចំណែក ចំនួនប្រាក់ចំណែកម្នាក់ៗត្រូវជា ២00 ម៉ឺន រៀល ៣00 ម៉ឺន រៀល និង ៤00 ម៉ឺន រៀល ។ ពេលនេះ ឧបមាថា A បានដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ដោយប្ដឹង B និង អះអាងថា B គ្មានសិទ្ធិលើបំណុល ហើយបានទទួលសាលក្រមឈ្នះក្ដី ។ ក្នុងករណីនេះ យោងតាមករណីយុត្តិសាស្ត្រនៅប្រទេសជប៉ុន ចំនួនប្រាក់ចំណែក ៣00 ម៉ឺន រៀលរបស់ B ត្រូវតែចែកទៅឱ្យ A ។ ប៉ុន្តែ សិទ្ធិលើបំណុលរបស់ A មានចំនួន ៤00 ម៉ឺន រៀល ហើយ A បានទទួលការបែងចែកចំនួន ២00 ម៉ឺន រៀលរួចហើយ ហេតុដូច្នេះ ពីចំនួនប្រាក់ចំណែក ៣00 ម៉ឺន រៀលរបស់ B ត្រូវចែកទៅឱ្យ A តែចំនួន ២00 ម៉ឺន រៀលទេ ឯចំនួន ១00 ម៉ឺន រៀលទៀតដែលនៅសល់ ត្រូវផ្ដល់ទៅកូនបំណុលនៃការអនុវត្ត ។

Civil Execution Act (Japan)

**Article 90** (Action of objection concerning distribution)

1. An obligee who has raised an objection concerning distribution or an obligor who has raised an objection concerning distribution against and obligee who has no exemplification of obligation title with execution power must institute an action of objection concerning distribution.

2. The action referred to in the preceding paragraph shall be subject to the jurisdiction of the execution court.

3. If the Plaintiff does not appear on the first date set for oral argument, except in cases where the plaintiff does not appear for causes not imputable to such plaintiff, the action referred to in paragraph 1 shall be dismissed.

4. In order to alter the table of distribution or to draw up a new table of distribution, the table of distribution must be annulled in the judgment of the action referred to in paragraph 1.

5. An obligor who has raised an objection concerning distribution against an obligee who has an exemplification of obligation title with execution power must institute an action of objection to the claim.
6. In cases where the obligee or obligor who has raised an objection concerning distribution fails to prove within a week from the date for distribution (in cases where an objection concerning distribution has been raised against an unknown holder of a hypothec certificate, the day when the holder becomes known) to the execution court that an action referred to in paragraph 1 has been instituted, or fails to submit evidence that an action referred to in the preceding paragraph has been instituted and an exemplification of the decision staying execution with regard to the action, the objection concerning distribution shall be deemed to be withdrawn.

**មាត្រា ៤៩៣.-** បណ្ដឹងតវ៉ារបស់កូនបំណុលនៃការអនុវត្តដែលបានថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក

១- កូនបំណុលនៃការអនុវត្ត ដែលបានថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ចំពោះម្ចាស់បំណុលដែលមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ត្រូវដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ដោយយកម្ចាស់បំណុលដែលជាភាគីម្ខាងទៀតនៃការស្នើសុំតវ៉ាជាចុងចម្លើយ ។(1)

២- កូនបំណុលនៃការអនុវត្ត ដែលបានថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ចំពោះម្ចាស់បំណុលដែលគ្មានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ត្រូវដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ដោយយកម្ចាស់បំណុលដែលជាភាគីម្ខាងទៀតនៃការស្នើសុំតវ៉ាជាចុងចម្លើយ ។(2)

៣- បណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលត្រូវអនុវត្តការចែកចំណែក ។

៤- បើកូនបំណុលនៃការអនុវត្ត ដែលបានថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក មិនបញ្ជាក់ថា ខ្លួនបានដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ទៅតុលាការ ហើយមិនផ្ដល់ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេចបង្គាប់ឱ្យផ្អាកការអនុវត្តដែលទាក់ទងនឹងបណ្ដឹងរបស់ខ្លួន ទៅតុលាការ ឬ មិនបញ្ជាក់ថា ខ្លួនបានដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ទៅតុលាការ ក្នុងអំឡុងពេល ១ (មួយ) សប្ដាហ៍ ចាប់ពីកាលបរិច្ឆេទនៃការចែកចំណែក ការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ត្រូវចាត់ទុកថា បានដកវិញ ។

៥- ក្នុងសាលក្រមនៃបណ្ដឹងដែលបានកំណត់នៅកថាខណ្ឌទី ១ បើយល់ឃើញថាការតវ៉ាមានភាពត្រឹមត្រូវ តុលាការដែលត្រូវអនុវត្តការចែកចំណែកត្រូវធ្វើការផ្លាស់ប្ដូរតារាងចែកចំណែក ឬ លុបចោលតារាងចែកចំណែកដើម្បីធ្វើតារាងចែកចំណែកថ្មី ។

(កំណត់)

សូមមើលមាត្រា 90 មាត្រា 35 នៃច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

(1) ក្នុងករណីដែលភាគីម្ខាងទៀតនៃការតវ៉ា ជាម្ចាស់បំណុលដែលមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្ត កូនបំណុលនៃការអនុវត្តដែលបានថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ត្រូវដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ (មាត្រា ៣៦៣ (បណ្ដឹងតវ៉ាចំពោះការទាមទារ)) ។

(2) ក្នុងករណីដែលភាគីម្ខាងទៀតនៃការតវ៉ា ជាម្ចាស់បំណុលដែលគ្មានឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្ត កូនបំណុលនៃការអនុវត្តដែលបានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ត្រូវដាក់ពាក្យបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ។

Civil Execution Act (Japan)
**Article 90** (Action of objection concerning distribution) > *see the note for the preceding article*
**Article 30** (Compulsory execution contingent upon time or provision of security)
1. In cases where a claim is contingent upon the advent of a time certain, compulsory execution may be commenced only after the advent of such time.
2. Compulsory execution by virtue of an obligation title, the effectuation of which is conditioned on security being provided, may be commenced only when the obligee has submitted an official document that proves such security has been provided.

**មាត្រា ៤៩៤.-** ការផ្អាកទុកចំនួនប្រាក់ចំណែក

១- ចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលត្រូវទទួលចំណែក បើមានមូលហេតុដូចខាងក្រោមនេះ តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវផ្អាកទុកទឹកប្រាក់ដែលស្មើនឹងចំនួននៃចំណែកនោះ : (1)

**ក**- សិទ្ធិលើបំណុលនោះភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ឬ ពេលកំណត់មិនពិតប្រាកដ ។(2)

**ខ**- សិទ្ធិលើបំណុលនោះជាសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការរឹបអូសជាបណ្តោះអាសន្ន ។(3)

**គ**- ឯកសារដែលបានកំណត់នៅក្នុងចំណុច **ក** កថាខណ្ឌទី ២ នៃមាត្រា ៣៧០ (ការផ្អាក និង លុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ត្រូវបានផ្តល់ ។(4)

**ឃ**- ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចហាមឃាត់មួយរយៈនូវការអនុវត្តឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ ឬ ហ៊ីប៉ូតែកដែលទាក់ទងនឹងសិទ្ធិលើបំណុលនោះ ត្រូវបានផ្តល់ ។(5)

**ង**- ពាក្យបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ត្រូវបានដាក់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៤៩២ (បណ្តឹងតវ៉ារបស់ម្ចាស់បំណុលដែលបានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក) ឬ កថាខណ្ឌទី ២ នៃមាត្រា ៤៩៣ (បណ្តឹងតវ៉ារបស់កូនបំណុលនៃការអនុវត្តដែលបានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក) នៃក្រមនេះ ។(6)

២- តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវផ្អាកទុកទឹកប្រាក់ដែលស្មើនឹងចំនួននៃចំណែករបស់ម្ចាស់បំណុលដែលពុំបានបង្ហាញខ្លួនចំពោះមុខតុលាការដើម្បីទទួលចំណែកនោះ ។(7)

(កំណត់)

មាត្រានេះតម្រូវនឹងមាត្រា 91 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

(1) ទោះបីជាម្ចាស់បំណុលត្រូវទទួលចំណែកក៏ដោយ ក៏មានករណីខ្លះដែលម្ចាស់បំណុលមិនអាចទទួលចំណែកភ្លាមៗទេ តែត្រូវផ្អាកទុកទឹកប្រាក់ដែលស្មើនឹងចំនួននៃចំណែកនោះនៅតុលាការ ។ មាត្រានេះរៀបរាប់អំពីករណីនោះ ។

តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវផ្អាកទុកដោយផ្ទាល់នូវចំនួនទឹកប្រាក់នៃចំណែក ក្នុង ① ករណីដែលសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលមានមូលហេតុដែលពុំអាចទទួលចំណែកភ្លាមៗ（ចំណុច ៣ ដល់ ៦ នៃកថាខណ្ឌទី ១） និង ② ករណីដែលម្ចាស់បំណុលមិនបង្ហាញខ្លួនក្នុងតុលាការដែលត្រូវអនុវត្តការចែកចំណែកដើម្បីទទួលចំណែកនោះ（កថាខណ្ឌទី ២） ។

(2) ចំពោះសិទ្ធិលើបំណុលភ្ជាប់ជាមួយល័ក្ខខ័ណ្ឌបង្អង់ ឬ ពេលកំណត់មិនពិតប្រាកដ បើមិនប្រាកដអំពីការបំពេញល័ក្ខខ័ណ្ឌនោះ ឬ ការមកដល់នៃពេលកំណត់មិនពិតប្រាកដនោះទេ តុលាការពុំអាចសម្រេចថា ត្រូវចែកចំណែកជាក់ស្តែង ឬ មិនចែក ហេតុដូច្នេះ ចំនួនទឹកប្រាក់នៃចំណែកត្រូវផ្អាកទុកនៅតុលាការ ។

(3) អត្ថិភាពនៃសិទ្ធិដែលត្រូវបានរក្សាការពារដោយការរឹបអូសជាបណ្តោះអាសន្ន មិនច្បាស់លាស់រហូតដល់ពេលដែលសាលក្រម ឬ សាលដីកាសម្រេចអង្គសេចក្តីដែលឱ្យម្ចាស់បំណុលឈ្នះក្តីចូលជាស្ថាពរ ហេតុនេះហើយ ចំនួនទឹកប្រាក់នៃចំណែកត្រូវផ្អាកទុកនៅតុលាការ ។

(4) ក្នុងករណីដែលឯកសារផ្អាកការអនុវត្ត ដោយការដាក់ពាក្យបណ្តឹង ដូចជាពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ជាដើម ត្រូវបានផ្តល់ បើមិនរង់ចាំដំណោះស្រាយនៃបណ្តឹងនោះទេ តុលាការពុំអាចសម្រេចថា ត្រូវចែកចំណែក ជាក់ស្តែង ឬ មិនចែក ហេតុដូច្នេះ ចំនួនប្រាក់ចំណែកត្រូវផ្អាកទុកនៅតុលាការដែរ ។

(5) បើឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចហាមឃាត់មួយរយៈនូវការអនុវត្តនៃសិទ្ធិប្រាតិភោគ（ឧទាហរណ៍ : ការចាត់ចែងផ្អាកការអនុវត្ត ដោយការដាក់ពាក្យបណ្តឹងជំទាស់ ឬ ពាក្យសុំតវ៉ា ។ សូមមើលចំណុច ៦ កថាខណ្ឌទី ២ នៃមាត្រា ៤៩២（បណ្តឹងតវ៉ារបស់ម្ចាស់បំណុលដែលបានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក） និង កថាខណ្ឌទី ២ នៃមាត្រា ៤៩៣（បណ្តឹងតវ៉ារបស់កូនបំណុលនៃការអនុវត្តដែលបានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក）） ត្រូវបានផ្តល់ ក៏ដូចគ្នានឹងករណីនៃកំណត់ទី（4） ខាងលើនេះផងដែរ ចំនួនប្រាក់ចំណែកត្រូវផ្អាកទុកនៅតុលាការ ។

(6) ក្នុងករណីដែលពាក្យបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៤៩២（បណ្តឹងតវ៉ារបស់ម្ចាស់បំណុលដែលបានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក） ឬ កថាខណ្ឌទី ២ នៃមាត្រា ៤៩៣（បណ្តឹងតវ៉ារបស់កូនបំណុលនៃការអនុវត្តដែលបានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក） បើមិនរង់ចាំដំណោះស្រាយនៃបណ្តឹងនោះទេ តុលាការពុំអាចសម្រេចថា ត្រូវធ្វើការចែកចំណែក ជាក់ស្តែង ឬ មិនចែក ហេតុនេះហើយ ចំនួនប្រាក់ចំណែកត្រូវផ្អាកទុកនៅតុលាការដែរ ។

(7) ប្រសិនបើម្ចាស់បំណុលមិនមកបង្ហាញខ្លួននៅតុលាការដែលត្រូវអនុវត្តការចែកចំណែកដើម្បីទទួលចំណែកទេ មានការលំបាកក្នុងការចែកចំណែកជាក់ស្តែងណាស់ ហេតុនេះតុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវផ្អាកទុកទឹកប្រាក់ដែលស្មើនឹងចំនួននៃចំណែកនោះសិន ។

**Article 91** (Deposit of distribution and the like)

1. In cases where the following grounds exist with respect to an obligation-right of an obligee entitled to distribution and the like, the court clerk shall deposit money corresponding to the distribution and the like:

   i. the obligation-right is conditional or has an indefinite term;
   ii. the obligation-right belongs to a provisional attachment obligee;
   iii. a document referred to in Article 39, paragraph 1, item vii or Article 183 paragraph 1, item vi has been submitted;
   iv. an exemplification of a decision temporarily prohibiting the execution of a preferential right, right of pledge or hypothec concerning the obligation-right (hereinafter in this paragraph referred to as "a preferential right and the like") has been submitted;
   v. a preferential right and the like concerning the obligation-right has been provisionally registered;
   vi. the amount of distribution is indefinite because a preferential right and the like have been registered after the registration of a provisional attachment or an attachment concerning the stay of execution;
   vii. an action of objection concerning distribution has been instituted.

2. The court clerk shall deposit money corresponding to distribution and the like of any obligee who fails to appear in the execution court to receive distribution and the like (including unknown holders of a hypothec certificate).

**មាត្រា ៤៩៥.-** ការអនុវត្តការចែកចំណែក ដោយការសម្រេចសិទ្ធិជាស្ថាពរ ជាអាទិ៍

១- ក្នុងករណីដែលការផ្អាកទុកត្រូវបានអនុវត្ត តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៤៩៤ (ការផ្អាកទុកចំនួនប្រាក់ចំណែក) នៃក្រមនេះ បើហេតុនៃការផ្អាកទុកនោះបានរលត់ តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវធ្វើការចែកចំណែកចំពោះប្រាក់ផ្អាកទុកនោះ ។ (1) (2)

២- ក្នុងករណីដែលត្រូវអនុវត្តការចែកចំណែក តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវធ្វើការផ្លាស់ប្តូរតារាងចែកចំណែក ដើម្បីម្ចាស់បំណុលដែលមិនបានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកផងដែរ បើត្រូវនឹងចំណុចណាមួយខាងក្រោមនេះ : (3) (4)

**ក-** បើមិនអាចធ្វើការចែកចំណែកបាន ចំពោះម្ចាស់បំណុលដែលត្រូវបានផ្អាកទុកចំណែក ដោយមានហេតុដែលបានកំណត់ចាប់ពីចំណុច **ក** ដល់ចំណុច **ឃ** នៃកថាខណ្ឌទី ១ មាត្រា ៤៩៤ (ការផ្អាកទុកចំនួនប្រាក់ចំណែក) នៃក្រមនេះ ។

**ខ-** បើម្ចាស់បំណុលដែលត្រូវបានផ្អាកទុកចំណែក ដោយមានហេតុដែលបានកំណត់នៅក្នុងចំណុច **ខ** នៃកថាខណ្ឌទី ១ មាត្រា ៤៩៤ (ការផ្អាកទុកចំនួនប្រាក់ចំណែក) បានចាញ់ក្តីក្នុងបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ដែលកូនបំណុលនៃការអនុវត្តបានដាក់ពាក្យ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៤៩៣ (បណ្តឹងតវ៉ារបស់កូនបំណុលនៃការអនុវត្តដែលបានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក) នៃក្រមនេះ ។

(កំណត់)

មាត្រានេះតម្រូវនឹងមាត្រា 92 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

(1) ក្នុងករណីដែលការផ្អាកទុកចំនួនប្រាក់ចំណែកត្រូវបានអនុវត្ត យោងតាមកថាខណ្ឌទី ១ នៃមាត្រា ៤៩៤ (ការផ្អាកទុកចំនួនប្រាក់ចំណែក) បើហេតុនៃការផ្អាកទុកបានរលត់ តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវធ្វើការចែកចំណែកចំពោះប្រាក់ផ្អាកទុកនោះ ។ ក្នុងករណីនេះ បើម្ចាស់បំណុលដែលត្រូវបានផ្អាកទុកចំណែក អាចទទួល

ចំណែកនោះ តុលាការនឹងផ្តល់ប្រាក់ផ្អាកទុកនោះ ដើម្បីម្ចាស់បំណុលនោះ ។ ផ្ទុយទៅវិញ បើម្ចាស់បំណុលដែលត្រូវបានផ្អាកទុកចំណែក មិនអាចទទួលចំណែកនោះ តាមទំនាក់ទំនងជាមួយនឹងកូនបំណុលនៃការអនុវត្ត តុលាការត្រូវធ្វើការផ្លាស់ប្តូរតារាងចែកចំណែក ដើម្បីម្ចាស់បំណុលដែលមិនបានថ្លែងសេចក្តីតវ៉ាទៅលើចំណារនៃតារាងចែកចំណែកផងដែរ ដែលនាំឱ្យមានការចាំបាច់ធ្វើការចែកចំណែកបន្ថែម (កថាខណ្ឌទី ២ នៃមាត្រានេះ) ។

(2) ក្នុងករណីដែលមានដំណោះស្រាយអំពីហេតុនៃការផ្អាកទុក ដែលផ្តល់ប្រៀបដល់ម្ចាស់បំណុលដែលត្រូវបានផ្អាកទុកចំណែក ដូចជាករណីដែលល័ក្ខខ័ណ្ឌបង្អង់ត្រូវបានបំពេញ ចំពោះសិទ្ធិលើបំណុលដែលភ្ជាប់ជាមួយល័ក្ខខ័ណ្ឌបង្អង់ ឬ ករណីដែលម្ចាស់បំណុលនៃការរឹបអូសជាបណ្តោះអាសន្ន បានទទួលសាលក្រម ឬ សាលដីកាសម្រេចអង្គសេចក្តីឱ្យឈ្នះបណ្តឹង ឬ ករណីហេតុនៃការផ្អាកការអនុវត្តត្រូវបានបាត់បង់ ជាដើម ម្ចាស់បំណុលនោះនឹងទទួលចំណែកនោះ ។

(3) ក្នុងករណីដែលមានដំណោះស្រាយអំពីហេតុនៃការផ្អាកទុក ដែលមិនផ្តល់ប្រៀបដល់ម្ចាស់បំណុលដែលត្រូវបានផ្អាកទុកចំណែក នីតិវិធីចែកប្រាក់ផ្អាកទុកនោះ ត្រូវធ្វើឡើងវិញដើម្បីម្ចាស់បំណុលដែលគ្មានអាទិភាពជាងម្ចាស់បំណុលដែលត្រូវបានផ្អាកទុកចំណែក ។ ក្នុងករណីនេះ តុលាការត្រូវធ្វើការផ្លាស់ប្តូរតារាងចែកចំណែក ដើម្បីម្ចាស់បំណុលគ្រប់រូប រួមទាំងម្ចាស់បំណុលដែលមិនបានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកផងដែរ និង ចាំបាច់ធ្វើការចែកចំណែកបន្ថែម ។

(4) ឧទាហរណ៍ ម្ចាស់បំណុលដែលចូលរួមក្នុងការចែកចំណែកមាន ៣ នាក់ គឺ A B និង C ហើយចំនួនប្រាក់នៃសិទ្ធិលើបំណុលដែលម្ចាស់បំណុលម្នាក់ៗរាយការណ៍ គឺ ៤០០ ម៉ឺន រៀល ៦០០ ម៉ឺន រៀល និង ៨០០ ម៉ឺន រៀល ហើយចំនួនសរុបនៃទឹកប្រាក់ដែលត្រូវអនុវត្តការចែកចំណែកមាន ៩០០ ម៉ឺន រៀល ។ ក្នុងករណីនេះ យោងតាមតារាងចែកចំណែក ចំនួនប្រាក់ចំណែកម្នាក់ៗត្រូវជា ២០០ ម៉ឺន រៀល ៣០០ ម៉ឺន រៀល និង ៤០០ ម៉ឺន រៀល ។ ពេលនេះ ឧបមាថាកូនបំណុលនៃការអនុវត្តបានដាក់ពាក្យប្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក (កថា-ខណ្ឌទី ២ នៃមាត្រា ៩៩៣ (បណ្តឹងតវ៉ារបស់កូនបំណុលនៃការអនុវត្តដែលបានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក)) ដោយយក B ជាចុងចម្លើយ ដោយអះអាងថា B គ្មានសិទ្ធិលើបំណុល ហើយឈ្នះក្តី ។ ក្នុងករណីនេះ ការវិនិច្ឆ័យអំពីនត្ថិភាពនៃសិទ្ធិលើបំណុលរបស់ B នឹងប៉ះពាល់ដល់ម្ចាស់បំណុលឯទៀត ហើយចំនួនប្រាក់ ៩០០ ម៉ឺន រៀលនោះ ក្លាយទៅជាចំណែករបស់តែ A និង C នាំឱ្យប្រាក់ចំណែករបស់ A មាន ៣០០ ម៉ឺន រៀល និង ប្រាក់ចំណែករបស់ C មាន ៦០០ ម៉ឺន រៀល ។ ម្យ៉ាងទៀត មានសេចក្តីសន្និដ្ឋានដូចគ្នាផងដែរ ក្នុងករណីដែល B ជាម្ចាស់បំណុលដែលមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ហើយកូនបំណុលនៃការអនុវត្ត បានដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ យោងតាមកថាខណ្ឌទី ១ នៃមាត្រា ៩៩៣ (បណ្តឹងតវ៉ារបស់កូនបំណុលនៃការអនុវត្តដែលបានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក) ចំពោះ B ហើយបានឈ្នះក្តី ។

**Article 92** (Carrying out distribution by virtue of confirmation of right)

1. Where a deposit according to the provisions of paragraph 1 of the preceding article has been made, if the grounds therefor have been extinguished, the execution court shall carry out distribution of the deposit money.

2. Where distribution is to be carried out pursuant to the provisions of the preceding paragraph, if the distribution cannot be carried out to an obigee concerning a deposit held on grounds mentioned in items i to v inclusive of paragraph 1 of the preceding article or to a provisional attachment obligee concerning a deposit held under itme 6 of the said paragraph or to an attachment obligee concerning stay of execution, or if an obligee concerning a deposit held on the grounds referred to in item vii of the said paragraph is defeated in an action of objection concerning distribution instituted by the obligor,

# ជំពូកទី ៣ បទប្បញ្ញត្តិពិសេសស្តីពីការអនុវត្តសិទ្ធិប្រាតិភោគ

## ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ

**មាត្រា ៤៩៦.-** លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ

ទោះបីមានបញ្ញត្តិនៃមាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះក៏ដោយ ក៏ការអនុវត្តសិទ្ធិប្រាតិភោគ ត្រូវធ្វើឡើងដោយលិខិតអនុវត្តដែលបានកំណត់ខាងក្រោមនេះ :

**ក-** សាលក្រម ឬ សាលដីកាស្ថាពរ ដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ឬ លិខិតដែលមានអានុភាពដូចសាលក្រម ឬ សាលដីកាស្ថាពរនោះ ។

**ខ-** លិខិតយថាភូតដែលធ្វើឡើងដោយសារការី ហើយដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 22 មាត្រា 181 មាត្រា 190 និង មាត្រា 193 និង ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា មាត្រា ៣៥០ (លិខិតអនុវត្ត) ។

(1) ការអនុវត្តសិទ្ធិប្រាតិភោគ ត្រូវបានចាត់ទុកជាការអនុវត្តដោយបង្ខំមួយប្រភេទ ហេតុនេះហើយ ជាគោលការណ៍ ត្រូវអនុវត្តតាមបទប្បញ្ញត្តិទូទៅនៃការអនុវត្តដោយបង្ខំ ដែលមានចែងក្នុងជំពូកទី ១ នៃគន្ថីទី ៦ ។ តាមធម្មតា ដើម្បីអនុវត្តដោយបង្ខំ ត្រូវមានលិខិតអនុវត្ត (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៣៥០ (លិខិតអនុវត្ត)) រីឯការអនុវត្តសិទ្ធិប្រាតិភោគក៏ដូចគ្នាដែរ គឺត្រូវមានលិខិតអនុវត្តដែលបានកំណត់ដោយច្បាប់ជាចាំបាច់ ។ មាត្រានេះចែងពិសេសអំពីលិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ។ នេះគឺដោយសារតែ ក្នុងករណីអនុវត្តដោយបង្ខំផ្សេងៗទៀត ការអនុវត្តសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកជាបញ្ហាត្រូវបញ្ជាក់ ហេតុនេះហើយ ច្បាប់ទាមទារឱ្យមានលិខិតអនុវត្តដែលជាលិខិតបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកដែលត្រូវអនុវត្ត រីឯចំពោះការអនុវត្តសិទ្ធិប្រាតិភោគវិញ ច្បាប់ទាមទារឱ្យមានលិខិតអនុវត្តដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគដែលត្រូវអនុវត្ត ។

(2) ការអនុវត្តសិទ្ធិប្រាតិភោគ មានការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ និង ការអនុវត្តសិទ្ធិលើប្រាតិភោគចំពោះសិទ្ធិលើបំណុល ឬ សិទ្ធិលើ

ទ្រព្យសម្បត្តិផ្សេងទៀត ។ មាត្រានេះចែងអំពីលិខិតអនុវត្តដែលត្រូវការរួមក្នុងការអនុវត្តសិទ្ធិប្រាតិភោគនីមួយៗនោះ ។ មានដូចជា សាលក្រម ឬ សាលដីកាស្ថាពរ ដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ឬ លិខិតដែលមានអានុភាពដូចគ្នានឹងសាលក្រម ឬ សាលដីកានោះ ដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ (មាត្រានេះ ចំណុច **ក**) និង លិខិតយថាភូតដែលធ្វើឡើងដោយសារការីដើម្បីបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ។ ឧទាហរណ៍នៃចំណុចទី ១ មានដូចជា សាលក្រមស្ថាពរដែលទទួលស្គាល់នូវការទាមទារនៃបណ្ដឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃហ៊ីប៉ូតែក សាលក្រមស្ថាពរដែលច្រានចោលការទាមទារនៃបណ្ដឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃហ៊ីប៉ូតែក សាលក្រមស្ថាពរដែលបង្គាប់ឱ្យចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក កំណត់ហេតុសះជា ឬ កំណត់ហេតុទទួលស្គាល់ការទាមទារដែលមានអត្ថន័យដូចគ្នានឹងសាលក្រមខាងលើនេះ ជាអាទិ៍ ។ រីឯឧទាហរណ៍នៃចំណុចទី ២ មានដូចជា លិខិតយថាភូតនៃកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ។

<u>Civil Execution Act (Japan)</u>
**Article 22** (Obligation title) > see the note for Article 350
**Article 181** (Conditions for sale by auction of immovable)
1. Sale by auction as execution of a security right whose subject matter is an immovable as provided in Article 43, paragraph 1 (including those which are deemed immovables under the provisions of paragraph 2 of that article; hereinafter referred to as an "immovable" in this Chapter) shall be commenced only when one of the following documents is submitted: (such sale shall be referred to as "sale by auction of an immovable" in this Chapter):
   i. a transcript of a final and binding judgment or decision under Article 15 of the Family Affairs Adjudication Act (Law No. 153, 1947) or a document having the same effect showing the existence of a security right;
   ii. a transcript of a document drawn up by a notary showing the existence of a security right;
   iii. a transcript of a register in which the registration of a security right (except provisional registration) has been made;
   iv. in cases of a general preferential right, a document showing the existence thereof.
2. Where a holder of a hypothec certificate makes a motion for sale by auction of an immovable, he shall submit the hypothec certificate.
3. Where a motion for sale by auction of an immovable is made after one has succeeded to the immovable, a document showing the succession must be submitted in cases of inheritance or any other general succession, and a transcript of a decision or an official document showing the succession must be submitted in cases of any other type of succession.
4. Where a ruling of commencement of sale by auction of an immovable has been rendered, when serving the ruling of commencement, the court clerk must send a list of the documents referred to in the preceding three paragraphs which have been submitted in the motion for sale by auction of an immovable, and a copy of the document referred to in item iv of paragraph 1, to the opposing party.
**Article 190** (Conditions for sale by auction of movables)
Sale by auction as execution of a security right whose subject mater is a movable as provided in Article 122, paragraph 1 (hereinafter, the "movable" referred to in this Section) shall be commenced only when the obligee submits the movable or a document showing that the possessor of the movable consents to the seizure.
**Article 193** (Conditions for execution of security right concerning an obligation-right or any other property right)
1. Execution of a security right whose subject matter is an obligation-right as provided in Article 143 or a property right as provided in Article 167, paragraph 1 (hereinafter referred to as "any other property right" in this paragraph) shall be commenced only when a document showing the existence of the security right (or with regard to a security right other than a general preferential right whose subject matter is any other property right which requires registration or the like for its transfer, a document referred to in Article 181, paragraph 1 items i to iii inclusive, paragraphs 2 or 3) is submitted. This shall apply to the exercise of a right according to the provisionsof the Civil Code or any other laws which a person having a security right has concerning the money or anything else to which the obligor is entitled by virtue of sale, lease, loss, damage of the subject matter or creation of a real right on the subject matter or expropriation according to the Land Expropriation Act (Law No. 219, 1951) or any other administrative disposition.
2. The provisions of Chapter II Section II Subsection 4 (except for Article 146, paragraph 2; Articles 152 and 153) and Articles 182 to 184 inclusive shall apply *mutatis mutandis* to execution and exercise of a security right referred to in the preceding paragraph, and the provisions of Articles 146, paragraph 2, 152 and 153 shall apply *mutatis mutandis* to execution and exercise of a general preferential right referred to in that paragraph.

**មាត្រា ៤៩៧.-** បញ្ញត្តិពិសេសស្ដីពីសមត្ថកិច្ចលើបណ្ដឹងតវ៉ាចំពោះការទាមទារ និង បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្ត

អនុវត្ត ដែលពាក់ព័ន្ធនឹងលិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ

១- ទោះបីមានបញ្ញត្តិនៃមាត្រា ៣៦៣ (បណ្តឹងតវ៉ាចំពោះការទាមទារ) នៃក្រមនេះក៏ដោយ បណ្តឹងតវ៉ាចំពោះការទាមទារដែលពាក់ព័ន្ធនឹងលិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការ ដែលបានកំណត់នៅក្នុងចំណុចនីមួយៗ តាមប្រភេទនៃលិខិតអនុវត្តដែលបែងចែកដូចខាងក្រោមនេះ :

- **ក**- ចំពោះលិខិតអនុវត្តដែលបានកំណត់នៅក្នុងចំណុច **ក** នៃមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ : សាលាដំបូងដែលបានធ្វើនីតិវិធីនៃបណ្តឹងនោះ ។
- **ខ**- ចំពោះលិខិតអនុវត្តដែលបានកំណត់នៅក្នុងចំណុច **ខ** នៃមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ : តុលាការមានសមត្ថកិច្ចលើទីកន្លែងរបស់ចុងចម្លើយដែលបានកំណត់នៅក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍) នៃក្រមនេះ ។ បើគ្មានតុលាការដែលមានសមត្ថកិច្ចតាមមាត្រា ៨ នោះទេ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលកម្មវត្ថុនៃសិទ្ធិប្រាតិភោគស្ថិតនៅ ។ បើកម្មវត្ថុនៃសិទ្ធិប្រាតិភោគជាសិទ្ធិលើបំណុល តុលាការដែលមានសមត្ថកិច្ចលើទីកន្លែងរបស់កូនបំណុលទី ៣ ដែលបានកំណត់នៅក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍) នៃក្រមនេះ ។

២- បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 182 និង មាត្រា 35 និង ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា មាត្រា ៣៦៣ (បណ្តឹងតវ៉ាចំពោះការទាមទារ) ។

(1) មាត្រានេះចែងអំពីសមត្ថកិច្ចលើបណ្តឹងតវ៉ាចំពោះការទាមទារ និង បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ដែលត្រូវបានដាក់នៅក្នុងការអនុវត្តសិទ្ធិប្រាតិភោគ ។ ចំពោះសមត្ថកិច្ចលើបណ្តឹងតវ៉ាចំពោះការទាមទារ មានបញ្ញត្តិដែលចែងទូទៅ ក្នុងកថាខណ្ឌទី ៣ នៃមាត្រា ៣៦៣ (បណ្តឹងតវ៉ាចំពោះការទាមទារ) ក៏ប៉ុន្តែ បញ្ញត្តិនៃមាត្រា ៣៦៣ នេះចែងសំដៅលើលិខិតអនុវត្តដើម្បីអនុវត្តដោយបង្ខំនូវសិទ្ធិលើបំណុលដែលត្រូវអនុវត្ត ហេតុនេះហើយ មិនអាចអនុវត្តចំពោះការអនុវត្តសិទ្ធិប្រាតិភោគដែលមានបញ្ញត្តិពិសេសស្តីពីលិខិតអនុវត្ត នៅក្នុងមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) ទេ ។ ដូច្នេះ កថាខណ្ឌទី ១ នៃមាត្រានេះចែងបញ្ញត្តិពិសេសអំពីសមត្ថកិច្ចលើបណ្តឹងតវ៉ាចំពោះការទាមទារ ដែលចែងផ្សេងពីកថាខណ្ឌទី ៣ នៃមាត្រា ៣៦៣ (បណ្តឹងតវ៉ាចំពោះការទាមទារ) ដើម្បីសម្របទៅតាមលិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ។

(2) កថាខណ្ឌទី ២ នៃមាត្រានេះកំណត់ថា បញ្ញត្តិស្តីពីសមត្ថកិច្ចសាលាជម្រះក្តីលើបណ្តឹងតវ៉ាចំពោះការទាមទារដែលពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិប្រាតិភោគ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសមត្ថកិច្ចសាលាជម្រះក្តីលើបណ្តឹងតវ៉ា

ចំពោះការផ្តល់រូបមន្តអនុវត្ត ដែលត្រូវបានដាក់នៅក្នុងការអនុវត្តសិទ្ធិប្រាតិភោគ ។ មាត្រានេះមានអត្ថន័យដូចគ្នានឹង មាត្រា ៣៦៤ (បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត) នៃក្រមនេះ ដែលចែងថា ត្រូវអនុវត្តដូចគ្នាតាមបញ្ញត្តិអំពីសមត្ថកិច្ចសាលាជម្រះក្តីនៃកថាខណ្ឌទី ៣ មាត្រា ៣៦៣ (បណ្តឹងតវ៉ាចំពោះការទាមទារ) ។

(3) មាត្រានេះជាបញ្ញត្តិទូទៅអំពីការអនុវត្តសិទ្ធិប្រាតិភោគ ដែលត្រូវអនុវត្តចំពោះការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ និង ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល ឬ សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ។

Civil Execution Act (Japan)
**Article 35** (Action of objection to claim) > see the note for Article 363
**Article 182** (Objection concerning execution against a ruling of commencement)
When raising an objection concerning execution against a ruling of commencement of sale by auction of an immovable, the obligor or the owner of the immovable (with regard to those items which are deemed immovables, the person who holds the right) may allege as grounds therefor that the security right does not exist or has been extinguished.

**មាត្រា ៤៩៨.-** ការផ្អាក និង ការលុបចោលការអនុវត្តសិទ្ធិប្រាតិភោគ

១- តុលាការអនុវត្ត ឬ អាជ្ញាសាលាត្រូវផ្អាកនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគ ហើយត្រូវលុបចោលការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយ បើឯកសារដែលបានកំណត់ខាងក្រោមនេះត្រូវបានដាក់ :

- **ក-** ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ថា លុបចោលលិខិតអនុវត្ត ដែលបានកំណត់នៅក្នុងចំណុច **ក** នៃមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ ។
- **ខ-** ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ថា មិនអនុញ្ញាតឱ្យអនុវត្តសិទ្ធិប្រាតិភោគ ។
- **គ-** អនុសារសាលក្រមស្ថាពរ ឬ អនុសារសាលដីកាស្ថាពរដែលប្រកាសថា ការផ្សះផ្សា ឬ ការទទួលស្គាល់ដែលទាក់ទងនឹងលិខិតអនុវត្ត ដែលបានកំណត់នៅក្នុងចំណុចទី ១ នៃមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ គ្មានអានុភាព ។
- **ឃ-** ឯកសារចម្លងយថាភូតនៃកំណត់ហេតុអំពីការសះជាតាមនីតិវិធីតុលាការ ដែលកំណត់ថា មិនអនុវត្តសិទ្ធិប្រាតិភោគ ឬ ការដកពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ ។
- **ង-** ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្តសិទ្ធិប្រាតិភោគ និង លុបចោលការចាត់ចែងការអនុវត្ត ។

២- តុលាការអនុវត្ត ឬ អាជ្ញាសាលា ត្រូវផ្អាកនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគ បើឯកសារដែលបានកំណត់ខាងក្រោមនេះ ត្រូវបានដាក់មក :

- **ក-** ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្តសិទ្ធិប្រាតិភោគមួយរយៈ ។
- **ខ-** ឯកសារដែលសរសេរថា ម្ចាស់បំណុលបានទទួលសំណងនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគ ឬ បានយល់ព្រមពន្យារពេលត្រូវសងចំពោះសិទ្ធិលើបំណុលនោះ នៅក្រោយពេលលិខិតអនុវត្ត

ដែលបានកំណត់នៅក្នុងមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ ត្រូវបានបង្កើត ។

ប៉ុន្តែ ចំពោះករណីដែលបានកំណត់នៅក្នុងចំណុច ១ ខាងលើ អានុភាពផ្អាក មានត្រឹមតែ ២ (ពីរ) ខែប៉ុណ្ណោះ ។

៣- បញ្ញត្តិនៃមាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះការអនុវត្តសិទ្ធិប្រាតិភោគ ។

៤- បញ្ញត្តិនៃមាត្រា ៣៤៥ (បណ្តឹងជំទាស់ចំពោះដីកាសម្រេចលុបចោល ជាអាទិ៍) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលលុបចោលការចាត់ចែងការអនុវត្ត ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 183 មាត្រា 39 មាត្រា 40 និង ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា មាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) ។

(1) ដើម្បីឱ្យនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគផ្អាក ឬ លុបចោលនូវការចាត់ចែងការអនុវត្ត ចាំបាច់ត្រូវដាក់នូវឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ។ ចំពោះការផ្អាកនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគ ឬ ការលុបចោលនូវការចាត់ចែងការអនុវត្ត មិនត្រូវអនុវត្តតាមបញ្ញត្តិនៃមាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) ដែលចែងអំពីការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំទេ ។

(2) ចំពោះការលុបចោលនូវការចាត់ចែងការអនុវត្ត តាមកថាខណ្ឌទី ១ នេះ ដោយសារមូលហេតុនៃការលុបចោលមានភាពច្បាស់លាស់ មិនចាំបាច់ទទួលស្គាល់ឧបាស្រ័យដោយបណ្តឹងជំទាស់ ដោយខុសនឹងការចាត់ចែងលុបចោលផ្សេងទៀត ។ នេះគឺជា គោលគំនិតនៃកថាខណ្ឌទី ៤ ។

Civil Execution Act (Japan)

**Article 39** (Stay of compulsory execution) (excerpt) > *see the note for Article 370*

**Article 40** (Annulment of disposition concerning execution) > *see the note for Article 370*

**Article 183** (Stay of procedure of sale by auction of immovable)

1. If any of the following documents has been submitted, the procedure of sale by auction of an immovable must be stayed:
   i. a transcript of a final and binding judgment showing that the security right does not exist (including those judgments which have the same effect as a final and binding judgments which have the same effect as a final and binding judgment; this exception shall apply in this article);
   ii. a transcript of a final and binding judgment which annuls the decision referred to in Article 181, paragraph 1, item i or any judgment which has the same effect, or declares that such decisions or the like have no effect, or an order to erase the registration referred to in item iii of that paragraph;
   iii. a transcript of a record of compromise before the court or any other official document including a statement that the security right may not be executed, that the motion for execution thereof shall be withdrawn, that the obligee has received satisfaction of the obligation-right secured by the security right or that the obligee has granted a grace period;
   iv. a transcript of the register in which the registration of the security has been erased;
   v. a transcript of a decision ordering the stoppage of the procedure of sale by auction of an immovable and voidance of the enforcement disposition;
   vi. a transcript of a decision ordering the provisional stoppage of the procedure of sale by auction of an immovable and voidance of the enforcement disposition;
   vii. a transcript of a decision which provisionally prohibits execution of the security right.
2. In cases where a document referred to in items i to iv inclusive of the preceding paragraph has been submitted, the execution court must also annul the disposition concerning any execution already made.
3. The provisions of Article 12 shall not apply to a ruling made in accordance with the preceding paragraph.

**មាត្រា ៤៩៩.-** ការលក់ដោយបង្ខំដោយសិទ្ធិឃាត់ទុក និង ការលក់ដោយបង្ខំដើម្បីប្តូរជាប្រាក់

ការលក់ដោយបង្ខំដោយសិទ្ធិឃាត់ទុក និង ការលក់ដោយបង្ខំដើម្បីប្តូរជាប្រាក់ ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងទៀត ត្រូវអនុវត្តតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីនេះ ដែលកំណត់អំពីការលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 195 ។

(1) ការលក់ដោយបង្ខំដើម្បីប្តូរជាប្រាក់ សំដៅទៅលើករណីដែលប្តូរទ្រព្យសម្បត្តិជាប្រាក់ មិនមែនដើម្បីប្រមូលសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលទេ (ការអនុវត្តសិទ្ធិប្រាតិភោគ) គឺសម្រាប់ភាពចាំបាច់ផ្សេងទៀត ។ ក្នុងករណីនេះក៏ត្រូវអនុវត្តតាមវិធីលក់ដោយបង្ខំមួយ ដើម្បីប្តូរជាប្រាក់ឱ្យមានសមធម៌ដែរ ។ ចំពោះឧទាហរណ៍ សូមមើលក្រមរដ្ឋប្បវេណីកម្ពុជា មាត្រា ២១២ (វិធីបែងចែកវត្ថុកម្មសិទ្ធិអវិភាគ) មាត្រា ៤៥៨ (សិទ្ធិលក់ ដោយខ្លួនឯង) និង មាត្រា ១២៧១ (ការប្តូរជាប្រាក់ដោយការលក់) ។

(2) ការលក់ដោយបង្ខំដោយសិទ្ធិឃាត់ទុក ត្រូវធ្វើឡើងតាមបញ្ញត្តិនៃក្រមនេះ ដែលចែងអំពីការលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ក៏ប៉ុន្តែមិនចាំបាច់មាន "លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ" ដែលបានកំណត់នៅក្នុងមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) ទេ ។

Civil Execution Act (Japan)
**Article 195** (Sale by auction by virtue of a right of retention; sale by auction for realization according to the provisions of the Civil Code, the Commercial Code or any other laws)
In regard to sale by auction by virtue of a right of retention and sale by auction for realization according to the provisions of the Civil Code, the Commercial Code or any other laws, such sales shall follow the example of sale by auction as execution of a security right.

## ផ្នែកទី ២ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ

**មាត្រា ៥០០.-** ល័ក្ខខ័ណ្ឌនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ

ទោះបីជាក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តមិនដាក់លិខិតអនុវត្តដែលបានកំណត់នៅក្នុងមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ ទៅអាជ្ញាសាលាក៏ដោយ បើបានដាក់ចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ ឬ បានដាក់ឯកសារដែលបញ្ជាក់ថា អ្នកកាន់កាប់ចលនវត្ថុបានយល់ព្រមចំពោះការរឹបអូស ក៏ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ អាចចាប់ផ្តើមបានដែរ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 190 ។

មាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) ចែងថា សាលក្រម ឬ សាលដីកាស្ថាពរ និង លិខិតយថាភូត ជាលិខិតអនុវត្តរួមសម្រាប់ការអនុវត្តសិទ្ធិប្រាតិភោគគ្រប់ប្រភេទ ។ ប៉ុន្តែ តាមការជាក់ស្តែង ដើម្បីធ្វើជំនួញចលនវត្ថុ ដូចជាការលក់ទិញចលនវត្ថុ គេកម្រនឹងធ្វើលិខិតយថាភូតម្តងមួយៗណាស់ លើកលែងតែករណីដែលជួញដូរចលនវត្ថុដែលមានតម្លៃខ្ពស់ ។ម្យ៉ាងទៀត ការទាមទារឱ្យម្ចាស់សិទ្ធិប្រាតិភោគទទួលសាលក្រម ឬ សាលដីកាស្ថាពរ ក៏ជាការពិបាកដល់ម្ចាស់សិទ្ធិប្រាតិភោគនោះដែរ ។ ត្រង់ចំណុចនេះ មាត្រានេះចែងថា ចំពោះតែករណីនៃចលនវត្ថុ អាជ្ញាសាលាអាចចាប់ផ្តើមការអនុវត្តសិទ្ធិប្រាតិភោគបាន បើម្ចាស់សិទ្ធិប្រាតិភោគដាក់ចលនវត្ថុ ដែលជាកម្មវត្ថុនៃប្រាតិភោគទៅអាជ្ញាសាលា ក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគនោះកំពុងកាន់កាប់ដោយខ្លួនឯងនូវចលនវត្ថុនោះ ។ ម្យ៉ាងទៀត ក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគពុំកាន់កាប់ចលនវត្ថុទេ បើម្ចាស់សិទ្ធិប្រាតិភោគបានទទួលនូវឯកសារដែលបញ្ជាក់ថា អ្នកកាន់កាប់បានយល់ព្រមឱ្យរឹបអូស ហើយដាក់ឯកសារនោះជូនទៅអាជ្ញាសាលា ក៏អាចចាប់ផ្តើមការអនុវត្តសិទ្ធិប្រាតិភោគបានដែរ ។

Civil Execution Act (Japan)
**Article 190** (Conditions for sale by auction of movables)
Sale by auction as execution of a security right whose subject mater is a movable as provided in Article 122, paragraph 1 (hereinafter, the "movable" referred to in this Section) shall be commenced only when the obligee submits the movable or a document showing that the possessor of the movable consents to the seizure.

**មាត្រា ៥០១.-** ការតវ៉ាចំពោះការអនុវត្ត នូវការរឹបអូសចលនវត្ថុ

បើការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុត្រូវបានចាប់ផ្តើម ដោយយោងតាមបញ្ញត្តិនៃមាត្រា ៥០០ (ល័ក្ខខ័ណ្ឌនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ) នៃក្រមនេះ កម្មសិទ្ធិករនៃចលនវត្ថុ ឬ កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា អាចយកនត្ថិភាព ឬ ការរលត់នៃសិទ្ធិប្រាតិភោគ មកធ្វើជាមូលហេតុ ក្នុងពាក្យសុំតវ៉ាចំពោះការអនុវត្តនូវការរឹបអូសនោះបាន ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 191 ។

មាត្រា ៥០០ (ល័ក្ខខ័ណ្ឌនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ) គឺជាវិធានការបន្ធូរបន្ថយមួយប្រភេទដើម្បីសម្រួលការអនុវត្តសិទ្ធិប្រាតិភោគរបស់ម្ចាស់សិទ្ធិប្រាតិភោគលើចលនវត្ថុ ។ រីឯចំពោះកូនបំណុល ឬ កម្មសិទ្ធិករវិញ ដើម្បីឱ្យមានភាពមិនលំអៀង មាត្រានេះទទួលស្គាល់ឱ្យជននោះ អះអាងអំពីហេតុតាមច្បាប់សារធាតុ ដូចជានត្ថិភាពនៃសិទ្ធិប្រាតិភោគ ឬ ការរលត់នៃសិទ្ធិប្រាតិភោគ ពុំមែនតែតាមបណ្តឹងតវ៉ាចំពោះការទាមទារតែប៉ុណ្ណោះទេ

គឺតាមការតវ៉ាចំពោះការអនុវត្ត (កថាខណ្ឌទី ២ នៃមាត្រា ៣៨៤ (ការតវ៉ាចំពោះការអនុវត្ត)) ដែលជាវិធីសង្ខេប ។ ជាគោលការណ៍ ការតវ៉ាចំពោះការអនុវត្ត គឺជាវិធីដើម្បីអះអាងអំពីការបំពានលើនីតិវិធី តែមាត្រានេះ គឺជាករណីលើកលែង ។

Civil Execution Act (Japan)
**Article 191** (Objection concerning execution against the seizure of movable)
When raising an objection concerning execution against a seizure with regard to the sale by auction of a movable, the obligor or the owner of the movable may allege as grounds therefor that the security right does not exist or has been extinguished or that the obligation-right secured by the security right has been partially extinguished.

**មាត្រា ៥០២.-** ចំណុចដែលត្រូវសរសេរ ក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ

ក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ អ្នកដាក់ពាក្យសុំត្រូវសរសេរនូវចំណុចខាងក្រោមនេះ :

**ក-** សញ្ញាណនៃម្ចាស់បំណុលនៃការអនុវត្ត កម្មសិទ្ធិករនៃចលនវត្ថុដែលជាកូនបំណុលនៃការអនុវត្ត កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា និង អ្នកតំណាង ។

**ខ-** សញ្ញាណនៃសិទ្ធិប្រាតិភោគ និង សិទ្ធិលើបំណុលដែលត្រូវបានធានា ។

**គ-** សញ្ញាណនៃចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តសិទ្ធិប្រាតិភោគ និង ទីកន្លែងនៃចលនវត្ថុនោះ ។

**ឃ-** ហេតុការណ៍ និង ទំហំនៃផ្នែកនៃសិទ្ធិលើបំណុលដែលត្រូវបានធានា បើធ្វើការអនុវត្តសិទ្ធិប្រាតិភោគ ចំពោះផ្នែកមួយនៃសិទ្ធិលើបំណុលដែលត្រូវបានធានានោះ ។

(កំណត់)

សូមមើលបទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 178 កថាខណ្ឌទី 1 ។

ទោះជាកម្មសិទ្ធិករនៃចលនវត្ថុដែលជាកូនបំណុលនៃការអនុវត្ត និង កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានាជាជនតែមួយរូបក៏ដោយ ឬ ជាជនផ្សេងគ្នាក៏ដោយ ក៏ត្រូវសរសេរអំពីចំណុចទាំងពីរជានិច្ច ។

ពាក្យ "ហេតុការណ៍" នៅក្នុងចំណុច **ឃ** សំដៅទៅលើការបញ្ជាក់អំពីបំណងរបស់អ្នកដែលដាក់ពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ ដែលសុំឱ្យអនុវត្តចំពោះផ្នែកណាមួយនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ។

**មាត្រា ៥០៣.-** បញ្ញត្តិស្តីពីការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដែលមិនត្រូវអនុវត្ត

បញ្ញត្តិនៃមាត្រា ៣៨០ (ចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស) មាត្រា ៣៨១ (ការប្តូរទំហំនៃចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស) និង មាត្រា ៣៩១ (ការហាមឃាត់មិនឱ្យរឹបអូសហួសប្រមាណ) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ។

(កំណត់)

មាត្រានេះ មានអត្ថន័យដូចគ្នានឹងមាត្រា 192 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

ក្នុងគន្ថីនេះ ដោយជំពូកទី ៣ គឺជាបញ្ញត្តិពិសេសចំពោះជំពូកទី ២ បើគ្មានបញ្ញត្តិនៅក្នុងជំពូកទី ៣ នេះ បញ្ញត្តិនៃជំពូកទី ២ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ លើកលែងតែមានភាពផ្ទុយនឹងលក្ខណៈនៃការអនុវត្តសិទ្ធិប្រាតិភោគ ។ ហេតុដូច្នេះ មាត្រានេះចង្អុលតែមាត្រាដែលមិនត្រូវយកមកអនុវត្ត ក្នុងចំណោមបញ្ញត្តិនៃជំពូកទី ២ ប៉ុណ្ណោះ ។ ប៉ុន្តែ ក្នុងករណីនៃការអនុវត្តឯកសិទ្ធិទូទៅ ដោយសារទ្រព្យសម្បត្តិទូទៅរបស់កូនបំណុលអាចក្លាយជាកម្មវត្ថុនៃការអនុវត្តនោះ បញ្ញត្តិទាំងនេះត្រូវយកមកអនុវត្តផងដែរ តាមលក្ខណៈនៃឯកសិទ្ធិទូទៅនោះ ។

Civil Execution Act (Japan)
**Article 192** (*Mutatis mutandis* application of provisions of execution concerning movables)
The provisions of Chapter II Section II Subsection III (except for Article 123, paragraph 2; Articles 128; 131; and 132) and Article 183 shall apply *mutatis mutandis* to sale by auction of a movable, and the provisions of Articles 128, 131 and 132 shall apply *mutatis mutandis* to sale by auction of a movable as execution of a general preferential right.

**មាត្រា ៥០៤.-** នីតិវិធីនៃការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប

១- ម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ អាចដាក់ពាក្យសុំឱ្យចេញដីកាសម្រេចអនុញ្ញាតឱ្យយកវត្ថុបញ្ចាំនោះមកសងផ្ទាល់តែម្តង ទៅសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលត្រូវអនុវត្តកាតព្វកិច្ច ដោយផ្អែកលើបញ្ញត្តិស្តីពីការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេបដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ។

២- ក្នុងការចេញដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវសួរម្ចាស់សិទ្ធិលើការបញ្ចាំ កម្មសិទ្ធិករនៃវត្ថុបញ្ចាំ និង កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ។

៣- បើចេញដីកាសម្រេចអនុញ្ញាតដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវជ្រើសតាំងអ្នកវាយតម្លៃឱ្យវាយតម្លៃនូវវត្ថុបញ្ចាំជាមុន ដោយផ្អែកលើបញ្ញត្តិស្តីពីការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំបានដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយកំណត់តម្លៃនៃវត្ថុបញ្ចាំ តាមការវាយតម្លៃនៃវត្ថុបញ្ចាំដោយខ្លួនឯង ហើយកម្មសិទ្ធិករនៃវត្ថុបញ្ចាំបានយល់ព្រមនឹងតម្លៃនោះ ។

៤- បើតុលាការចេញដីកាសម្រេចអនុញ្ញាតដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ សោហ៊ុយសម្រាប់នីតិវិធីនោះ ត្រូវចាត់ជាបន្ទុករបស់កម្មសិទ្ធិករនៃវត្ថុបញ្ចាំ ។

៥- ក្នុងដីកាសម្រេចអនុញ្ញាតដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវប្រកាសអនុញ្ញាតឱ្យយកវត្ថុបញ្ចាំមកសងដោយផ្ទាល់ ក្នុងចំនួនទឹកប្រាក់ដែលអ្នកវាយតម្លៃ បានវាយតម្លៃ ហើយព្រមជាមួយគ្នានេះ បើចំនួនដែលអ្នកវាយតម្លៃបានវាយតម្លៃនោះ លើសពីចំនួនទឹកប្រាក់សរុបនៃកាតព្វកិច្ចដែលត្រូវសង និង សោហ៊ុយសម្រាប់នីតិវិធី តុលាការត្រូវបង្គាប់ឱ្យសងចំនួនលើសនោះទៅឱ្យកម្មសិទ្ធិករនៃវត្ថុបញ្ចាំវិញ ។

៦- ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។
៧- ដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៥ ខាងលើនេះ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ ។

(កំណត់)

មាត្រានេះចែងអំពីនីតិវិធីនៃការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប ដោយសម្របនឹងបញ្ញត្តិដែលទទួលស្គាល់ការអនុវត្តសិទ្ធិលើការបញ្ចាំបែបនេះ ដែលមានចែងនៅក្នុងគន្ថីទី ៦ នៃក្រមរដ្ឋប្បវេណី ។ នេះគឺជានីតិវិធីផ្សេងពីនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគទូទៅ ។ សូមមើលមាត្រា ៨3-2 នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីដែលពុំមែនជាបណ្ដឹងនៃប្រទេសជប៉ុន ។

កថាខណ្ឌទី ១ ចែងច្បាស់លាស់នូវអត្ថន័យ និង សមត្ថកិច្ចលើពាក្យសុំនៃនីតិវិធីអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប ។

វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ៣ មានគោលគំនិតដែលឱ្យនីតិវិធីមានភាពងាយស្រួល និង សន្សំសំចៃសោហ៊ុយ ។ នេះគឺជាវិធានការលើនីតិវិធី ដែលត្រូវបានយល់ថា មិនផ្ទុយនឹងគោលគំនិតនៃបញ្ញត្តិនៃក្រមរដ្ឋប្បវេណីទេ ។

កថាខណ្ឌទី ៥ មានន័យថា ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវគណនាដកចំនួនសិទ្ធិលើបំណុលដែលត្រូវបានធានា និងសោហ៊ុយសម្រាប់នីតិវិធី ពីចំនួនវាយតម្លៃ ហើយត្រូវសងចំនួនសល់ទៅឱ្យកម្មសិទ្ធិករនៃវត្ថុបញ្ចាំ (សូមមើលកថាខណ្ឌទី ២ នៃមាត្រា ៨៣២ (ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប) នៃក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជា) ។ ម្យ៉ាងទៀតសោហ៊ុយសម្រាប់នីតិវិធីក៏រួមបញ្ចូលទាំងសោហ៊ុយដើម្បីធ្វើការវាយតម្លៃដែរ ។ ដីកាសម្រេចអនុញ្ញាតដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៥ ត្រូវបានបកស្រាយថា ក្លាយជាលិខិតអនុវត្តសម្រាប់កម្មសិទ្ធិករនៃវត្ថុបញ្ចាំ ចំពោះសិទ្ធិទាមទារឱ្យសងប្រាក់សល់ ។

<u>ក្រមរដ្ឋប្បវេណី (កម្ពុជា)</u>

**មាត្រា ៨៣២** ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប

១-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុមិនបានទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនទេ ម្ចាស់សិទ្ធិនោះអាចទាមទារទៅតុលាការឱ្យយកវត្ថុបញ្ចាំមកសងផ្ទាល់តែម្ដង តាមការវាយតម្លៃរបស់អ្នកវាយតម្លៃបាន លុះត្រាតែមានមូលហេតុត្រឹមត្រូវ ។ ក្នុងករណីនេះ ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវជូនដំណឹងអំពីការទាមទារនោះទៅកូនបំណុល ជាមុន ។
២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើចំនួនទឹកប្រាក់ដែលវាយតម្លៃដោយអ្នកវាយតម្លៃនោះ លើសពីចំនួននៃកាតព្វកិច្ចដែលត្រូវសង ម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ ត្រូវសងនូវចំនួនទឹកប្រាក់ដែលនៅសល់ ទៅកម្មសិទ្ធិករនៃវត្ថុបញ្ចាំនោះវិញ ។

## ផ្នែកទី ៣ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

**មាត្រា ៥០៥.-** ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល ជាអាទិ៍

១- ក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងមាត្រា ៤០២ (អត្ថន័យនៃការអនុវត្តចំពោះសិទ្ធិលើបំណុល និង តុលាការអនុវត្ត) ទោះជាមានបញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ មាត្រា ៤០៣ (ដីកាសម្រេចរឹបអូស) នៃក្រមនេះក៏ដោយ ក៏ម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរនូវចំណុចខាងក្រោមនេះ :

- **ក-** សញ្ញាណនៃម្ចាស់បំណុលនៃការអនុវត្ត កូនបំណុលនៃការអនុវត្ត កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា កូនបំណុលទី ៣ និង អ្នកតំណាង ។
- **ខ-** សញ្ញាណនៃសិទ្ធិប្រាតិភោគ និង សិទ្ធិលើបំណុលដែលត្រូវបានធានា ។
- **គ-** សញ្ញាណនៃសិទ្ធិលើបំណុលដែលជាកម្មវត្ថុនៃការអនុវត្តសិទ្ធិប្រាតិភោគ ។
- **ឃ-** ហេតុការណ៍ និង ទំហំនៃផ្នែកនៃសិទ្ធិលើបំណុលដែលត្រូវបានធានា បើធ្វើការអនុវត្តសិទ្ធិប្រាតិភោគ ចំពោះផ្នែកមួយនៃសិទ្ធិលើបំណុលដែលត្រូវបានធានានោះ ។

២- អ្នកដាក់ពាក្យសុំ ត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលបានកំណត់នៅក្នុងមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ ជាមួយនឹងពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

សូមមើលមាត្រា 193 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន និង មាត្រា 179 នៃបទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។ មាត្រានេះចែងអំពីល័ក្ខខ័ណ្ឌនៃនីតិវិធីដើម្បីអនុវត្តសិទ្ធិប្រាតិភោគដែលធានាសិទ្ធិលើបំណុល ។

Civil Execution Act (Japan)
**Article 193** (Conditions for execution of security right concerning an obligation-right or any other property right) > *see the note for Article 496*

**មាត្រា ៥០៦.-** ការរឹបអូសសិទ្ធលើបំណុលដោយផ្អែកលើឧបាទេសកម្មលើវត្ថុ

១- ចំពោះការអនុវត្តសិទ្ធិប្រាតិភោគ ដែលធ្វើឡើងដោយម្ចាស់សិទ្ធិប្រាតិភោគនោះ ចំពោះប្រាក់ ឬ វត្ថុផ្សេងទៀតដែលម្ចាស់បំណុលត្រូវទទួល ដោយការលក់ ការជួល ការបាត់បង់ ឬ ការខូចខាតនៃវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ ឬ ការបង្កើតសិទ្ធិប្រត្យក្សលើវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគនោះ ដោយផ្អែកលើបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងទៀត ក្រៅពីបញ្ញត្តិនៃមាត្រានេះ បញ្ញត្តិនៃមាត្រា ៥០៥ (ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្ត ។

២- ចំពោះការអនុវត្តសិទ្ធិដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ក្រៅពីចំណុចដែលបានកំណត់នៅ

ក្នុងចំណុចទីមួយៗ នៃកថាខណ្ឌទី ១ មាត្រា ៥០៥ (ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល ជាអាទិ៍) នៃក្រមនេះ អ្នកដាក់ពាក្យសុំត្រូវសរសេរអំពីទំនាក់ទំនងរវាងសិទ្ធិលើបំណុលដែលត្រូវបានធានា និង សិទ្ធិលើបំណុលដែលនឹងត្រូវរឹបអូស ។

៣- ចំពោះការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ដោយម្ចាស់សិទ្ធិប្រាតិភោគនោះ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ទោះជាមានបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៥០៥ (ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល ជាអាទិ៍) ក៏ដោយ ក៏ម្ចាស់បំណុលនៃការអនុវត្តអាចភ្ជាប់ឯកសារចម្លងយថាភូតនៃឯកសារដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ជាមួយនឹងពាក្យសុំ ជំនួសឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលបានកំណត់នៅក្នុងមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ បានដែរ ។

(កំណត់)

សូមមើលមាត្រា 193 នៃច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន និង មាត្រា 179 នៃបទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

មាត្រានេះ ចែងអំពីល័ក្ខខ័ណ្ឌនៃនីតិវិធីដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ក្នុងករណីដែលកម្មវត្ថុនៃសិទ្ធិប្រាតិភោគបានប្តូររូបភាពតាមច្បាប់ ឬ តាមការពិត ដោយការលក់ ការជួល ការបាត់បង់ ឬ ការខូចខាត ជាដើម ហើយសិទ្ធិប្រាតិភោគនោះនៅតែមានអានុភាពលើវត្ថុ ឬ សិទ្ធិដែលជាលទ្ធផលនៃការប្តូររូបភាពនោះ (ឧ. សិទ្ធិទាមទារថ្លៃលក់ និង សិទ្ធិទាមទារប្រាក់ធានារ៉ាប់រង) ។ នេះត្រូវហៅថា "ឧបាទេសកម្មលើវត្ថុ" ។ ប្រសិនបើច្បាប់ស្តីពីអស្សាមិករណ៍ (ដកហូត) ដីធ្លីត្រូវបានអនុម័តនៅប្រទេសកម្ពុជា សិទ្ធិទាមទារប្រាក់សំណង ដែលទាក់ទងនឹងកម្មសិទ្ធិ ឬ សិទ្ធិប្រើប្រាស់ដីធ្លី ក៏ក្លាយជាកម្មវត្ថុនៃឧបាទេសកម្មលើវត្ថុផងដែរ ។ តាមក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជា ឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ និង ហ៊ីប៉ូតែក មានអានុភាពនៃឧបាទេសកម្មលើវត្ថុ (មាត្រា ៧៨២ មាត្រា ៨១៧ និង មាត្រា ៨៤៩) ។

Civil Execution Act (Japan)
**Article 193** (Conditions for execution of security right concerning an obligation-right or any other property right) > *see the note for Article 496*

**មាត្រា ៥០៧.-** ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

ការអនុវត្តសិទ្ធិប្រាតិភោគដែលយកសិទ្ធិលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងមាត្រា ៤១៦ (ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) នៃក្រមនេះ ជាកម្មវត្ថុ ត្រូវអនុលោមតាមវិធីអនុវត្តចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងផ្នែកទី ៣ (ការអនុវត្តចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) ជំពូកទី ២ នៃគន្ថីទី ៦ នៃក្រមនេះ លើកលែងតែមានបញ្ញត្តិពិសេស ។

(កំណត់)

សូមមើលមាត្រា ៤១៦ (ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) នៃក្រមនេះ ។ សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 193 និង មាត្រា 167 និង បទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 180 និង មាត្រា 180-2 ។

មាត្រានេះ ចែងអំពីនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើទ្រព្យសម្បត្តិ ក្រៅពីអចលនវត្ថុ នាវា ចលនវត្ថុ និង សិទ្ធិលើបំណុល (ហៅថា "សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត") ។ តាមច្បាប់ជប៉ុន សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀតនោះ មានដូចជា សិទ្ធិជួល សិទ្ធិនិពន្ធ សិទ្ធិប្រកាសនីយប័ត្រតក្កកម្ម សិទ្ធិជាសមាជិកនៃក្រុមហ៊ុន សិទ្ធិទាមទារឱ្យប្រគល់នាវា ឬ អចលនវត្ថុ ជាដើម ។ ប្រសិនបើគ្មានបញ្ញត្តិពិសេសទេ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀតនោះ ត្រូវធ្វើតាមវិធីអនុវត្តចំពោះសិទ្ធិលើបំណុល (នីតិវិធីនៃការប្តូរជាទឹកប្រាក់ ត្រូវអនុវត្តតាមដីកាសម្រេចបង្គាប់ឱ្យលក់) ។ ប៉ុន្តែ ការអនុវត្តភាគច្រើនខុសៗគ្នា តាមប្រភេទនៃសិទ្ធិលើទ្រព្យសម្បត្តិនីមួយៗ ។ ឧទាហរណ៍ ចំពោះសិទ្ធិលើទ្រព្យសម្បត្តិដែលមិនអាចមានកូនបំណុលទី ៣ ដូចជាសិទ្ធិលើប្រកាសនីយប័ត្រតក្កកម្ម ជាអាទិ៍ អានុភាពនៃការរឹបអូសមិនមែនកើតឡើងនៅពេលធ្វើការបញ្ជូនទៅកូនបំណុលទី ៣ ទេ គឺនឹងកើតឡើង នៅពេលធ្វើការបញ្ជូនទៅកូនបំណុលនៃការអនុវត្តវិញ ។ម្យ៉ាងទៀត ចំពោះសិទ្ធិលើទ្រព្យសម្បត្តិដែលត្រូវចុះបញ្ជី ជាដើម ត្រូវតែមានការផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូស ដូចអចលនវត្ថុដែរ ។ ចំពោះនីតិវិធីជាក់ស្តែងនីមួយៗ តុលាការត្រូវចាត់ចែង តាមប្រភេទនៃសិទ្ធិលើទ្រព្យសម្បត្តិនីមួយៗនោះ ដោយគិតពិចារណានូវបញ្ញត្តិស្តីពីការអនុវត្តចំពោះសិទ្ធិលើបំណុល ។

Civil Execution Act (Japan)
**Article 167** (Compulsory execution against any other property rights) > *see the note for Article 416*
**Article 193** (Conditions for execution of security right concerning an obligation-right or any other property right) > *see the note for Article 496*

## មាត្រា ៥០៨.- បញ្ញត្តិដែលមិនត្រូវយកមកអនុវត្ត

បញ្ញត្តិនៃមាត្រា ៣៨២ (សិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស) មាត្រា ៣៨៣ (ការផ្លាស់ប្តូរទំហំនៃសិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស) និង កថាខណ្ឌទី ២ នៃមាត្រា ៤០៤ (ទំហំនៃការរឹបអូស) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះផ្នែកនេះ ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 193 កថាខណ្ឌទី 2 នៃមាត្រា 146 មាត្រា 152 និង មាត្រា 153 ។

Civil Execution Act (Japan)
**Article 146** (Coverage of attachment) > *see the note for Article 404*
**Article 153** (Alteration of obligation-rights which may not be attached) > *see the note for Article 383*
**Article 152** (Obligation-rights which may not be attached) > *see the note for Article 382*
**Article 193** (Conditions for execution of security right concerning an obligation-right or any other property right) > *see the note for Article 496*

## ផ្នែកទី ៤ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ

**មាត្រា ៥០៩.-** ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ជាអាទិ៍

១- ក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ អ្នកដាក់ពាក្យសុំត្រូវសរសេរនូវចំណុចខាងក្រោមនេះ :

**ក-** សញ្ញាណនៃម្ចាស់បំណុលនៃការអនុវត្ត កម្មសិទ្ធិករនៃអចលនវត្ថុដែលជាកូនបំណុលនៃការអនុវត្ត កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា និង អ្នកតំណាង ។

**ខ-** សញ្ញាណនៃសិទ្ធិប្រាតិភោគ និង សិទ្ធិលើបំណុលដែលត្រូវធានា ។

**គ-** សញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តសិទ្ធិប្រាតិភោគ ។

**ឃ-** ហេតុការណ៍ និង ទំហំនៃផ្នែកនៃសិទ្ធិលើបំណុលដែលត្រូវបានធានា បើធ្វើការអនុវត្តសិទ្ធិប្រាតិភោគ ចំពោះផ្នែកមួយនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ។

២- ក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ ក្រៅពីឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលបានកំណត់នៅក្នុងមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ អ្នកដាក់ពាក្យសុំត្រូវភ្ជាប់នូវឯកសារដូចខាងក្រោមនេះ :

**ក-** ករណីដែលអនុវត្តសិទ្ធិប្រាតិភោគផ្សេងពីឯកសិទ្ធិទូទៅ : ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជី ។

**ខ-** ករណីដែលអនុវត្តឯកសិទ្ធិទូទៅ : ចំពោះអចលនវត្ថុដែលបានចុះបញ្ជី ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជី និង ក្នុងករណីដែលជនដទៃក្រៅពីកូនបំណុលនៃការអនុវត្ត បានចុះនៅក្នុងសៀវភៅចុះបញ្ជីថា ជាកម្មសិទ្ធិករ ឯកសារដែលបញ្ជាក់ថា អចលនវត្ថុនោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។ ចំពោះដីធ្លីដែលមិនទាន់បានចុះបញ្ជី ឯកសារដែលបញ្ជាក់ថា ដីធ្លីជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។

(កំណត់)

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 170 និង ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា មាត្រា ៤១៧ (កម្មវត្ថុ និង វិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ) កថាខណ្ឌទី ៣ ។

(1) ការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ត្រូវធ្វើឡើងតាមវិធីលក់ដោយបង្ខំ ។ ការអនុវត្តនេះ ត្រូវធ្វើឡើងតាមវិធីមួយដែលម្ចាស់បំណុលនៃការអនុវត្តដែលមានសិទ្ធិប្រាតិភោគលើអចលនវត្ថុនោះ នឹងធ្វើការលក់ឡាយឡុង

នូវអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគនោះ ដែលជាការអនុវត្តសិទ្ធិប្រាតិភោគ ហើយនឹងទទួលសំណងជាអាទិភាពពីប្រាក់ដែលបានមកពីការលក់នេះ ។ ជាគោលការណ៍ នីតិវិធីនេះដូចគ្នានឹងការលក់ដោយបង្ខំដែលជានីតិវិធីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ក្នុងការអនុវត្តដោយបង្ខំនូវសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ដែរ ។ ហេតុនេះហើយ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ក៏ត្រូវធ្វើតាមនីតិវិធីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដែរ ។ ដូច្នេះ បញ្ញត្តិស្ដីពីនីតិវិធីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ (ផ្នែកទី ៤ ជំពូកទី ២ នៃគន្ថីទី ៦) និង បញ្ញត្តិស្ដីពីនីតិវិធីចែកចំណែក (ផ្នែកទី ៦ ជំពូកទី ២ នៃគន្ថីទី ៦) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ លើកលែងតែមានបញ្ញត្តិពិសេសក្នុងផ្នែកនេះ (សូមមើលមាត្រា ៥២០ (បញ្ញត្តិស្ដីពីការអនុវត្តចំពោះអចលនវត្ថុដែលមិនត្រូវយកមកអនុវត្ត) ខាងក្រោមនេះ) ។

(2) សិទ្ធិប្រាតិភោគដែលមានចែងក្នុងមាត្រានេះ គឺមានហ៊ីប៉ូតែក (ចែងក្នុងក្រមរដ្ឋប្បវេណីកម្ពុជា គន្ថីទី ៦ ចាប់ពីមាត្រា ៨៤៣ ទៅ មានរួមទាំងហ៊ីប៉ូតែកធានាបំណុលអណ្ដែត [ចែងក្នុងក្រមរដ្ឋប្បវេណីកម្ពុជា គន្ថីស្ដីពីការធានាកាតព្វកិច្ចពីមាត្រា ៨៦៧ ដល់មាត្រា ៨៨៧] ផងដែរ) សិទ្ធិលើការបញ្ចាំអចលនវត្ថុ (ចែងក្នុងក្រមរដ្ឋប្បវេណីកម្ពុជា គន្ថីទី ៦ ពីមាត្រា ៨៣៤ ដល់ មាត្រា ៨៣៩) ឯកសិទ្ធិទូទៅ ឬ ឯកសិទ្ធិពិសេស (ឯកសិទ្ធិលើអចលនវត្ថុ) ។ រីឯសិទ្ធិប្រាតិភោគដោយអនុប្បទាន (ចែងក្នុងក្រមរដ្ឋប្បវេណីកម្ពុជា គន្ថីទី ៦ ពីមាត្រា ៨៨៨ ទៅ) វិញ មិនអាចយកមកធ្វើជាសិទ្ធិប្រាតិភោគក្នុងនេះបានឡើយ ។ ជាពិសេស ក្រមរដ្ឋប្បវេណីមិនអនុញ្ញាតឱ្យបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានលើអចលនវត្ថុទេ (សូមមើលក្រមរដ្ឋប្បវេណីកម្ពុជា គន្ថីទី ៦ មាត្រា ៨៨៨ កថាខណ្ឌទី ១) ។ ចំពោះសិទ្ធិឃាត់ទុកវិញ សូមមើលមាត្រា ៤៩៩ (ការលក់ដោយបង្ខំដោយសិទ្ធិឃាត់ទុក និង ការលក់ដោយបង្ខំដើម្បីប្ដូរជាប្រាក់) ។

(3) បញ្ញត្តិនេះចែងអំពីចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ ដែលជាចាំបាច់ក្នុងការសុំឱ្យធ្វើការលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ (កថាខណ្ឌទី ១ នៃមាត្រា ៣៤៩ (របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ)) និង ទម្រង់នៃពាក្យសុំនេះ ។ម្យ៉ាងទៀត ចំពោះពាក្យសុំ សាលាដំបូងដែលមានសមត្ថកិច្ចនៅទីតាំងនៃអចលនវត្ថុ (ចំពោះចំណែកនៃកម្មសិទ្ធិអវិភាគលើអចលនវត្ថុ សិទ្ធិជួលអចិន្ត្រៃយ៍និងផលុបភោគដែលត្រូវបានចុះបញ្ជី និង ចំណែកនៃសិទ្ធិទាំងនេះ គឺទីកន្លែងដែលត្រូវចុះបញ្ជី) ត្រូវមានសមត្ថកិច្ចលើពាក្យសុំនោះក្នុងនាមជាតុលាការអនុវត្ត (បញ្ញត្តិនៃមាត្រា ៤១៨ (តុលាការអនុវត្ត) ត្រូវយកមកអនុវត្តដូចគ្នា ។ សូមមើលមាត្រា ៥២០ (បញ្ញត្តិស្ដីពីការអនុវត្តចំពោះអចលនវត្ថុ ដែលមិនត្រូវយកមកអនុវត្ត) ខាងក្រោមនេះ) ។

(4) ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ ដែលបានកំណត់នៅក្នុងបញ្ញត្តិពីចំណុច **ក** ដល់ **ឃ** នៃកថាខណ្ឌទី ១ នៃមាត្រានេះ គឺជាចំណុចចាំបាច់ត្រូវសរសេរ ។ ក្នុងពាក្យសុំ ទោះជាករណីដែលកម្មសិទ្ធិករនៃអចលនវត្ថុដែលជាកូនបំណុលនៃការអនុវត្ត និង កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ជាមនុស្សតែម្នាក់ក៏ដោយ ឬ ក្នុងករណីដែលកម្មសិទ្ធិករនៃអចលនវត្ថុដែលជាកូនបំណុលនៃការអនុវត្ត និង កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវ

បានធានា ជាមនុស្សផ្សេងគ្នា ដូចក្នុងការធានាដោយវត្ថុក៏ដោយ ក៏ត្រូវសរសេរទាំងកម្មសិទ្ធិករនៃអចលនវត្ថុ ទាំងកូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវធានាជានិច្ចដែរ ។ ម្យ៉ាងទៀត ពាក្យសុំ អាចដាក់ដោយអ្នកតំណាងក៏បាន ហើយក្នុងករណីនេះ ត្រូវសរសេរនូវសញ្ញាណនៃអ្នកតំណាងនេះក្នុងពាក្យសុំផងដែរ (មាត្រានេះ កថាខណ្ឌទី ១ ចំណុច **ក**) ។

(5) ជាគោលការណ៍ ឯកសារដែលត្រូវដាក់ភ្ជាប់ជាចាំបាច់នឹងពាក្យសុំនេះគឺ លិខិតចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ ក្នុងករណីដែលកម្មវត្ថុនៃពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ ជាអចលនវត្ថុដែលត្រូវបានចុះបញ្ជីហើយ ។ នេះគឺដើម្បីបញ្ជាក់ថា អចលនវត្ថុដែលជាកម្មវត្ថុនោះ ជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។ ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តឯកសិទ្ធិទូទៅ ដើម្បីធ្វើការបញ្ជាក់ថា អចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តនោះ ជាទ្រព្យសម្បត្តិទូទៅរបស់កូនបំណុលនៃការអនុវត្ត អ្នកដាក់ពាក្យសុំត្រូវភ្ជាប់ជាចាំបាច់នូវឯកសារដែលបញ្ជាក់ថា កូនបំណុលនៃការអនុវត្ត ជាកម្មសិទ្ធិករនៃអចលនវត្ថុនោះ ។

**មាត្រា ៥១០.-** សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគ

១- សិទ្ធិប្រាតិភោគប្រត្យក្សលើអចលនវត្ថុ សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផលលើអចលនវត្ថុ និង សិទ្ធិជួលអចលនវត្ថុ ដែលអាចតតាំងនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្ត ត្រូវបន្តអត្ថិភាព ក្រោយការលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគ ។

២- ក្រៅពីសិទ្ធិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ សិទ្ធិលើអចលនវត្ថុត្រូវរលត់ដោយការលក់ ។

៣- ការរឹបអូស ការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន និង ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នដែលមិនអាចតតាំងនឹងម្ចាស់បំណុលដែលបានធ្វើការរឹបអូសជាបណ្ដោះអាសន្ន ដែលទាក់ទងនឹងអចលនវត្ថុ នឹងបាត់បង់អានុភាពដោយការលក់ ។

៤- បើអ្នកដែលមានទំនាក់ទំនងផលប្រយោជន៍ បានរាយការណ៍ថា បានធ្វើការព្រមព្រៀងផ្សេងពីបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ មុនពេលតម្លៃលក់អប្បបរមាត្រូវបានកំណត់ការប្រែប្រួលនៃសិទ្ធិលើអចលនវត្ថុ ត្រូវអនុលោមតាមការព្រមព្រៀងនោះ ។

(កំណត់)

សូមមើលមាត្រា ៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់) នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា និង មាត្រា 59 នៃច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន ។

(1) ចំពោះការចាត់ចែងអំពីបន្ទុកលើអចលនវត្ថុ មានគោលការណ៍ ២ គឺ គោលការណ៍ទទួលបន្ត និង គោលការណ៍

លុបចេញ ហើយក្រមនេះយកគោលការណ៍ទទួលបន្ត (ចំពោះមូលហេតុយកគោលការណ៍ទទួលបន្ត សូមមើលកំណត់នៃមាត្រា ៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់)) ។ តាមគោលការណ៍ទទួលបន្ត ក្នុងចំណោមបន្ទុកលើអចលនវត្ថុ បន្ទុកដែលមិនអាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្តបាន នឹងត្រូវរលត់ពេលអចលនវត្ថុត្រូវបានប្តូរជាប្រាក់ រីឯសិទ្ធិផ្សេងៗដែលអាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្ត នឹងត្រូវបន្តអត្ថិភាព ហើយអ្នកទិញនឹងធ្វើលទ្ធកម្មនូវអចលនវត្ថុនោះ ដោយភ្ជាប់នឹងបន្ទុកនោះ ។ បន្ទាប់មក តាមការជាក់ស្តែង តម្លៃដែលដកពីតម្លៃទាំងមូលនៃអចលនវត្ថុ នូវតម្លៃនៃសិទ្ធិដែលមានអាទិភាពជាងសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស នឹងចាត់ទុកជាតម្លៃបច្ចុប្បន្ននៃអចលនវត្ថុ ហើយការណ៍នេះត្រូវបានគិតពិចារណានៅពេលវាយតម្លៃ (មាត្រា ៤៣០ (ការវាយតម្លៃ)) ។ ហេតុនេះហើយ បើពាក្យសុំឱ្យចាប់ផ្តើមនីតិវិធីអនុវត្តសិទ្ធិប្រាតិភោគ ត្រូវបានធ្វើឡើងដោយម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគ នោះសិទ្ធិប្រាតិភោគផ្សេង ជាដើម ដែលមានអាទិភាពជាងសិទ្ធិប្រាតិភោគមុននេះ មិនទទួលឥទ្ធិពលអ្វី ក្នុងនីតិវិធីអនុវត្តក្រោយទេ ហើយត្រូវបានទទួលបន្តដោយអ្នកទិញ (កថាខណ្ឌទី ១ នៃមាត្រានេះ) ។ ផ្ទុយទៅវិញ សិទ្ធិប្រាតិភោគជាដើម ដែលមានអាទិភាពទាបជាងសិទ្ធិប្រាតិភោគមុននោះ ត្រូវរលត់ (កថាខណ្ឌទី ២ នៃមាត្រានេះ) ។ ម្យ៉ាងទៀត ចំពោះការទទួលខុសត្រូវរបស់អ្នកទិញ សូមមើលមាត្រា ៤៤៩ (ការទទួលខុសត្រូវរបស់អ្នកទិញ) ។

(2) ចំពោះកថាខណ្ឌទី ៣ នៃមាត្រានេះ សូមមើលកំណត់នៃមាត្រា ៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់) ។

(3) ចំពោះសិទ្ធិដែលនឹងត្រូវរលត់ដោយការលក់ដោយបង្ខំ ក្នុងករណីដែលមានពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុដែលដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ សម្រាប់ការអនុវត្តចំពោះអចលនវត្ថុ ឬ ការអនុវត្តសិទ្ធិប្រាតិភោគ ត្រូវបានចេញរួចហើយ ហើយមានដីកាសម្រេចចាប់ផ្តើមត្រួតគ្នា សូមមើលមាត្រា ៥១៤ (ការធ្វើឯកសារលំអិតអំពីវត្ថុ ជាអាទិ៍ ក្នុងករណីដែលមានដីកាសម្រេចចាប់ផ្តើមត្រួតគ្នា) ។

Civil Execution Act (Japan)
**Article 59** (Extinguishment of right by sale) > *see the note for Article 431*

**មាត្រា ៥១១.-** ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា នៃការអនុវត្តចំពោះអចលនវត្ថុ និង ការអនុវត្តសិទ្ធិប្រាតិភោគ

១- បើមានពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ដែលដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ត្រូវបានសម្រេចរួចហើយ តាមបញ្ញត្តិនៃមាត្រា ៤១៩ (ដីកាសម្រេចចាប់ផ្តើម ជាអាទិ៍) នៃក្រមនេះ ហើយទទួលស្គាល់ពាក្យសុំនេះ តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំថ្មីទៀត ។ ក្នុងករណីនេះ តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្តដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្តើមមុន ។

២- បើពាក្យសុំឱ្យលក់ដោយបង្ខំដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្តើមមុន ត្រូវបានដក ឬ នីតិវិធីនៃការលក់ដោយបង្ខំ

ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមមុន ត្រូវបានលុបចោល តុលាការអនុវត្តត្រូវបន្តនីតិវិធី ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំក្រោយ ។

៣- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំក្រោយនេះ ផ្អែកលើពាក្យសុំដែលបានដាក់ក្រោយពេលកំណត់ចុងក្រោយ សម្រាប់ការទាមទារឱ្យចែកចំណែក តុលាការអនុវត្តត្រូវកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកជាថ្មី ។ ក្នុងករណីនេះ តុលាការអនុវត្តមិនចាំបាច់ដាស់តឿន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៤២២ (ការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក និង ការផ្លាស់ប្ដូរពេលកំណត់នោះ) នៃក្រមនេះ ចំពោះជនដែលបានធ្វើសេចក្ដីរាយការណ៍ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤២៣ (ករណីយកិច្ចរបស់ជនដែលត្រូវបានដាស់តឿនក្នុងការរាយការណ៍អំពីសិទ្ធិលើបំណុល) ឡើយ ។

៤- បើនីតិវិធីនៃការលក់ដោយបង្ខំដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមមុនត្រូវបានផ្អាក តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្តដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្ដើមក្រោយ ។ ក្នុងករណីនេះ ប្រសិនបើសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តនេះ អាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្តមុនបាន តុលាការអនុវត្តអាចចេញដីកាសម្រេចបន្តនីតិវិធី ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំក្រោយ តាមពាក្យសុំបាន ។

៥- បើមានដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នេះ ទៅឱ្យកូនបំណុលនៃការអនុវត្ត ។

៦- ចំពោះដីកាសម្រេចលើកចោលពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

(កំណត់)

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 188 និង មាត្រា 47 និង ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា មាត្រា ៤២៤ (ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា) និង មាត្រា ៤២៥ (ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តចំពោះអចលនវត្ថុ) ។

(1) មាត្រានេះចែងអំពីករណីដែលមានពាក្យសុំឱ្យលក់ដោយបង្ខំថែមទៀតដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ដែលបានដាក់ដោយម្ចាស់សិទ្ធិប្រាតិភោគ ចំពោះអចលនវត្ថុដែលត្រូវបានដាក់ពាក្យសុំឱ្យលក់ដោយបង្ខំដើម្បីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ (ផ្នែកទី ៤ ជំពូកទី ២ គន្លឹះទី ៦) ហើយត្រូវបានចេញដីកាសម្រេចចាប់ផ្ដើមនីតិវិធីលក់ដោយបង្ខំហើយ ។ ក្នុងករណីនេះ ប្រសិនបើយល់ឃើញថា ពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគនោះត្រឹមត្រូវ តុលាការអនុវត្តនឹងចេញដីកាសម្រេចចាប់ផ្ដើមនីតិវិធីលក់ដោយបង្ខំត្រួតគ្នាចំពោះពាក្យសុំនោះដែរ (ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា) ។ ការជូនដំណឹងអំពីការចេញដីកាសម្រេចចាប់ផ្ដើមត្រួតគ្នានេះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្តដែលបានទទួលដីកា

សម្រេចចាប់ផ្តើមមុននោះ គឺដើម្បីផ្តល់ឱកាសឱ្យម្ចាស់បំណុលនោះអាចរកវិធានការផ្សេង ដូចជាការទាមទារឱ្យអនុវត្តដោយបង្ខំចំពោះទ្រព្យសម្បត្តិផ្សេងទៀត ជាដើម ដោយសារដីកាសម្រេចក្រោយនេះមានឥទ្ធិពលដល់ចំនួនទឹកប្រាក់ដែលម្ចាស់បំណុលនោះអាចទទួលបានតាមការចែកចំណែក (កថាខណ្ឌទី ១ នៃមាត្រានេះ) ។

(2) ជាគោលការណ៍ សិទ្ធិប្រាតិភោគដែលមានលើអចលនវត្ថុដែលត្រូវបានលក់ដោយបង្ខំ នឹងមិនរលត់ ដោយការលក់ ហើយនឹងបន្តអត្ថិភាពក្រោយការលក់ លុះត្រាតែអាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្ត (សូមមើលកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ នៃមាត្រា ៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់)) ។ ប៉ុន្តែ ដូចករណីដែលបានកំណត់នៅក្នុងមាត្រានេះ ក្នុងករណីដែលមានពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ ក្រោយពេលដែលដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំ សម្រាប់ការអនុវត្តចំពោះអចលនវត្ថុត្រូវបានចេញរួចហើយ ហើយដីកាសម្រេចចាប់ផ្តើមត្រួតគ្នាត្រូវបានចេញ នោះសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលដែលបានដាក់ពាក្យសុំក្រោយ ព្រមទាំងសិទ្ធិប្រាតិភោគ (និង សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល សិទ្ធិជួល ជាដើម) ដែលមានអាទិភាពទាបជាងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនោះ ត្រូវរលត់ដោយការលក់ ទោះបីជាសិទ្ធិទាំងនោះអាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលដែលដាក់ពាក្យសុំមុនក៏ដោយ (សូមមើលមាត្រា ៥១៤ (ការធ្វើឯកសារលំអិតអំពីវត្ថុ ជាអាទិ៍ ក្នុងករណីដែលមានដីកាសម្រេចចាប់ផ្តើមត្រួតគ្នា)) ។ ហេតុដូច្នេះ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រានេះ នៅពេលដែលអនុវត្តនីតិវិធីនៃការលក់ដោយបង្ខំដែលត្រូវបានចាប់ផ្តើមដោយផ្អែកលើពាក្យសុំមុន តុលាការត្រូវកំណត់តម្លៃលក់អប្បបរមា (មាត្រា ៤៣២ (ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា ជាអាទិ៍)) និង ធ្វើឯកសារលំអិតអំពីវត្ថុ (មាត្រា ៤៣៤ (ឯកសារលំអិតអំពីវត្ថុ)) ជាដើម ដោយយកការណ៍នោះមកជាមូលដ្ឋាន ។ ឧទាហរណ៍ ក្នុងករណីដែលហ៊ីប៉ូតែកលំដាប់ទី ១ ហ៊ីប៉ូតែកលំដាប់ទី ២ និង ហ៊ីប៉ូតែកលំដាប់ទី ៣ ត្រូវបានបង្កើតឡើង លើអចលនវត្ថុមួយ ហើយម្ចាស់បំណុលដែលមានហ៊ីប៉ូតែកលំដាប់ទី ១ បានដាក់ពាក្យសុំឱ្យលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ក្រោយពេលដែលម្ចាស់បំណុលទូទៅបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុនោះ ហើយបានទទួលដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ នោះមិនមែនតែហ៊ីប៉ូតែកលំដាប់ទី ១ ទេ គឺ ហ៊ីប៉ូតែកលំដាប់ទី ២ និង ទី ៣ ក៏ត្រូវរលត់ ។

(3) ចំពោះនីតិវិធីលក់ដោយបង្ខំដែលបានធ្វើឡើងមុន បើម្ចាស់បំណុលនៃការអនុវត្តបានដកពាក្យសុំនោះ ឬ នីតិវិធីលក់នោះត្រូវបានលុបចោល នីតិវិធីលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគនឹងបន្ត ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមក្រោយ (កថាខណ្ឌទី ២ នៃមាត្រានេះ) ។

(4) ក្នុងករណីដែលនីតិវិធីលក់ដោយបង្ខំមុន ត្រូវបានផ្អាក បើសិទ្ធិប្រាតិភោគដែលជាមូលដ្ឋាននៃពាក្យសុំរបស់ម្ចាស់បំណុលដែលបានទទួលដីកាសម្រេចចាប់ផ្តើមក្រោយ អាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្តមុនបាន ល័ក្ខខ័ណ្ឌនៃការលក់ (ចំណុច ខ កថាខណ្ឌទី ១ នៃមាត្រា ៤៣៤ (ឯកសារលំអិតអំពីវត្ថុ)) គ្មានការផ្លាស់ប្តូរទេ ហេតុនេះហើយ តុលាការអនុវត្តត្រូវចេញដីកាសម្រេចបន្តនីតិវិធីលក់ ដោយផ្អែកលើពាក្យសុំរបស់

ម្ចាស់បំណុលនៃការអនុវត្តក្រោយ ហើយ បន្តនីតិវិធីលក់ (កថាខណ្ឌទី ៤ នៃមាត្រានេះ) ។

Civil Execution Act (Japan)
**Article 47** (Double rulings of commencement) > *see the note for Article 424*
**Article 188** (*Mutatis mutandis* application of provisions of compulsory sale by auction of immovable)
The provisions of Article 44 and Chapter II Section II Subsection II Division 2 (except for Article 81) shall apply *mutatis mutandis* to sale by auction of an immovable.

**មាត្រា ៥១២.-** ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តសិទ្ធិប្រាតិភោគ

១- បើមានពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគថែមទៀត ចំពោះអចលនវត្ថុដែលដីកាសម្រេចចាប់ផ្តើមការអនុវត្តសិទ្ធិប្រាតិភោគ ត្រូវបានសម្រេចរួចហើយ ហើយទទួលស្គាល់ពាក្យសុំនេះ តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំថ្មីទៀត ។ ក្នុងករណីនេះ តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្តដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្តើមមុន ។

២- បើពាក្យសុំឱ្យលក់ដោយបង្ខំដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្តើមមុន ត្រូវបានដក ឬ នីតិវិធីនៃការលក់ដោយបង្ខំដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមមុន ត្រូវបានលុបចោល តុលាការអនុវត្តត្រូវបន្តនីតិវិធី ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំក្រោយ ។

៣- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំក្រោយនេះផ្អែកលើពាក្យសុំដែលបានដាក់ក្រោយពេលកំណត់ចុងក្រោយ សម្រាប់ការទាមទារឱ្យចែកចំណែក តុលាការអនុវត្តត្រូវកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកជាថ្មី ។ ក្នុងករណីនេះ តុលាការអនុវត្តមិនចាំបាច់ដាស់តឿនដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៤២២ (ការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក និង ការផ្លាស់ប្តូរពេលកំណត់នោះ) នៃក្រមនេះ ចំពោះជនដែលបានធ្វើសេចក្តីរាយការណ៍ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤២៣ (ករណីយកិច្ចរបស់ជនដែលត្រូវបានដាស់តឿនក្នុងការរាយការណ៍អំពីសិទ្ធិលើបំណុល) ឡើយ ។

៤- បើនីតិវិធីនៃការលក់ដោយបង្ខំដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមមុនត្រូវបានផ្អាក តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្តដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្តើមក្រោយ ។ ក្នុងករណីនេះ ប្រសិនបើសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តនេះ អាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្តមុនបាន តុលាការអនុវត្តអាចចេញដីកាសម្រេចបន្តនីតិវិធីដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំក្រោយតាមពាក្យសុំបាន ។

៥- បើមានដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នេះទៅឱ្យកូនបំណុលនៃការអនុវត្ត ។

៦- ចំពោះដីកាសម្រេចលើកចោលពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

(កំណត់)

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 188 និង មាត្រា 47 និង ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា មាត្រា ៤២៤ (ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា) និង មាត្រា ៤២៥ (ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តចំពោះអចលនវត្ថុ) ។

(1) មាត្រានេះចែងអំពីករណីដែលមានពាក្យសុំឱ្យលក់ដោយបង្ខំថែមទៀតដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ចំពោះអចលនវត្ថុដែលម្ចាស់សិទ្ធិប្រាតិភោគបានដាក់ពាក្យសុំឱ្យលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគផ្សេង ហើយត្រូវបានចេញដីកាសម្រេចចាប់ផ្ដើមនីតិវិធីលក់ដោយបង្ខំហើយ ។ វិធីចាត់ចែងករណីនេះ ដូចគ្នានឹងវិធីចាត់ចែងករណីដែលមានពាក្យសុំឱ្យលក់ដោយបង្ខំថែមទៀតដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ក្រោយពេលចេញដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំដើម្បីអនុវត្តចំពោះអចលនវត្ថុ (ដែលមានចែងក្នុងមាត្រា ៥១១ (ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នានៃការអនុវត្តចំពោះអចលនវត្ថុ និង ការអនុវត្តសិទ្ធិប្រាតិភោគ)) ។

Civil Execution Act (Japan)
**Article 47** (Double rulings of commencement) > *see the note for Article 424*
**Article 188** (*Mutatis mudandis* application of provisions for compulsory sale of immovable) > *see the note for Article 511*

**មាត្រា ៥១៣.-** សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់ដោយបង្ខំ ដែលជាការអនុវត្តចំពោះអចលនវត្ថុ ឬ ការអនុវត្តសិទ្ធិប្រាតិភោគដែលមានដំណើរការមុន

១- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥១១ (ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា នៃការអនុវត្តចំពោះអចលនវត្ថុ និង ការអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ បើពាក្យសុំឱ្យលក់ដោយបង្ខំក្រោយដែលជាការអនុវត្តសិទ្ធិប្រាតិភោគ ផ្អែកលើសិទ្ធិប្រាតិភោគដែលអាចតតាំងនឹងការរឹបអូសរបស់ម្ចាស់បំណុលនៃការអនុវត្តមុន សិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានដាក់ពាក្យសុំក្រោយនោះ ព្រមទាំងសិទ្ធិប្រាតិភោគផ្សេង សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល និង សិទ្ធិជួល ដែលមិនអាចតតាំងនឹងសិទ្ធិប្រាតិភោគនោះ ត្រូវរលត់ ដោយការលក់ដោយបង្ខំ ។

២- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥១២ (ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ បើពាក្យសុំឱ្យលក់ដោយបង្ខំក្រោយ ផ្អែកលើសិទ្ធិប្រាតិភោគដែលអាចតតាំងនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តមុន សិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានដាក់ពាក្យសុំក្រោយនោះ ព្រមទាំងសិទ្ធិប្រាតិភោគផ្សេង សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល និង សិទ្ធិជួលដែលមិនអាចតតាំងនឹងសិទ្ធិប្រាតិភោគនោះ ត្រូវរលត់ដោយការលក់ដោយបង្ខំ ។

៣- បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលពាក្យសុំក្រោយ ត្រូវបានដាក់នៅក្រោយពេលដែលកាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ការលក់ឡាយឡុងដោយផ្ទាល់មាត់

នៅក្នុងនីតិវិធីដោយផ្អែកលើពាក្យសុំមុនបានចាប់ផ្ដើម ។

(កំណត់)

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 59 និង ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា មាត្រា ៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់) ។

(1) កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ នៃមាត្រានេះ ចែងថាតើសិទ្ធិណាដែលមានលើអចលនវត្ថុ ត្រូវរលត់ ក្នុងករណីដែលមានពាក្យសុំឱ្យលក់ដោយបង្ខំ សម្រាប់ការអនុវត្តសិទ្ធិប្រាតិភោគ ចំពោះអចលនវត្ថុដែលដីកាសម្រេចចាប់ផ្ដើមនៃការអនុវត្តចំពោះអចលនវត្ថុ ឬ ដីកាសម្រេចចាប់ផ្ដើមនៃការអនុវត្តសិទ្ធិប្រាតិភាគ ត្រូវបានសម្រេចរួចហើយ ហើយនីតិវិធីដែលផ្អែកលើដីកាសម្រេចចាប់ផ្ដើមមុន បានចប់ ។

(2) តាមកថាខណ្ឌទី ១ នៃមាត្រានេះ ជាឧទាហរណ៍ ក្នុងករណីដែលហ៊ីប៉ូតែកលំដាប់ទី ១ ហ៊ីប៉ូតែកលំដាប់ទី ២ និង ហ៊ីប៉ូតែកលំដាប់ទី ៣ ត្រូវបានបង្កើតឡើង លើអចលនវត្ថុមួយ ហើយម្ចាស់បំណុលដែលមានហ៊ីប៉ូតែកលំដាប់ទី ១ បានដាក់ពាក្យសុំឱ្យលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ក្រោយពេលដែលម្ចាស់បំណុលទូទៅបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុនោះ ហើយបានទទួលដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ហ៊ីប៉ូតែកលំដាប់ទី ១ នឹងរលត់ ដោយទទួលចំណែកពីប្រាក់ដែលបានមកពីការលក់ នៅក្នុងនីតិវិធីលក់ដោយបង្ខំដែលត្រូវបានចាប់ផ្ដើម ដោយពាក្យសុំរបស់ម្ចាស់បំណុលទូទៅនោះ ។ ជាមួយគ្នានេះ ហ៊ីប៉ូតែកលំដាប់ទី ២ និង ទី ៣ ដែលមានអាទិភាពទាបជាងហ៊ីប៉ូតែកលំដាប់ទី ១ ក៏នឹងរលត់ ក្រោយការលក់ដែរ (ម្ចាស់សិទ្ធិប្រាតិភោគនៃហ៊ីប៉ូតែក លំដាប់ទី ២ និង ទី ៣ នោះ អាចទទួលចំណែកបាន លុះត្រាតែសិទ្ធិនោះអាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលដែលបានដាក់ពាក្យសុំមុន ។ សូមមើលមាត្រា ៥១៩ (វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក)) ។ ផ្ទុយទៅវិញ ក្នុងករណីដែលម្ចាស់បំណុលដែលមានហ៊ីប៉ូតែកលំដាប់ទី ២ បានដាក់ពាក្យសុំក្រោយដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ហ៊ីប៉ូតែកលំដាប់ទី ១ នឹងត្រូវបានទទួលបន្តដោយអ្នកទិញ រីឯហ៊ីប៉ូតែកលំដាប់ទី ២ និង ទី ៣ នឹងត្រូវរលត់ ក្រោយការលក់ដោយបង្ខំ។

(3) តាមកថាខណ្ឌទី ១ នៃមាត្រានេះ ជាឧទាហរណ៍ ក្នុងករណីដែលហ៊ីប៉ូតែកលំដាប់ទី ១ ហ៊ីប៉ូតែកលំដាប់ទី ២ និង ហ៊ីប៉ូតែកលំដាប់ទី ៣ ត្រូវបានបង្កើតឡើង លើអចលនវត្ថុមួយ ហើយម្ចាស់បំណុលដែលមានហ៊ីប៉ូតែកលំដាប់ទី ១ បានដាក់ពាក្យសុំឱ្យលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ក្រោយពេលដែលម្ចាស់បំណុលដែលមានហ៊ីប៉ូតែកលំដាប់ទី ៣ បានដាក់ពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុនោះ ហើយនីតិវិធីនៃការលក់ដោយបង្ខំត្រូវបានចាប់ផ្ដើម ហ៊ីប៉ូតែកលំដាប់ទី ១ ព្រមទាំងហ៊ីប៉ូតែកលំដាប់ទី ២ និង ទី ៣ នឹងរលត់ នៅក្រោយការលក់ដោយបង្ខំ ។ ផ្ទុយទៅវិញ ក្នុងករណីដែលម្ចាស់បំណុលដែលមានហ៊ីប៉ូតែកលំដាប់ទី ២ បានដាក់ពាក្យសុំដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ក្រោយពេលដែលម្ចាស់បំណុលដែលមានហ៊ីប៉ូតែកលំដាប់ទី ៣ បានដាក់ពាក្យសុំឱ្យអនុវត្តសិទ្ធិ

ប្រាតិភោគចំពោះអចលនវត្ថុនោះ ហើយនីតិវិធីនៃការលក់ដោយបង្ខំត្រូវបានចាប់ផ្តើម ហ៊ីប៉ុន្តែកលំដាប់ទី ១ នឹងបន្ត អត្ថិភាព ក្រោយការលក់ដោយបង្ខំ ហើយត្រូវបានទទួលបន្តដោយអ្នកទិញ ។

(4) ការពន្យល់ខាងលើនេះ ចង្អុលទៅលើករណីដែលពាក្យសុំក្រោយដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ត្រូវបានធ្វើឡើង មុនពេលកាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ តាមផ្ទាល់មាត់ ក្នុងនីតិវិធីដែលផ្អែកលើពាក្យសុំឱ្យលក់ដោយបង្ខំមុន ត្រូវបានចាប់ផ្តើមតែប៉ុណ្ណោះ ។ រីឯក្នុងករណីដែលពាក្យសុំក្រោយដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ត្រូវបានធ្វើឡើង ក្រោយកាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ខាងលើនេះ ត្រូវបានចាប់ផ្តើមរួចហើយវិញ កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ នៃមាត្រានេះ មិនត្រូវយកមកអនុវត្តឡើយ ហើយត្រូវបានចាត់ចែង ដោយយោងតាមមាត្រា ៥១៥ (ការចាត់ចែងក្នុងករណីដែលមានពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ ក្រោយពេលដែលកាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ក្នុងនីតិវិធីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ បានចាប់ផ្តើម) ។

Civil Execution Act (Japan)
**Article 59** (Extinguishment of right by sale) < *see the note for Article 431*

**មាត្រា ៥១៤.-** ការធ្វើឯកសារលំអិតអំពីវត្ថុ ជាអាទិ៍ ក្នុងករណីដែលមានដីកាសម្រេចចាប់ផ្តើមត្រួតគ្នា

១- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ ទី ២ នៃមាត្រា ៥១៣ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់ដោយបង្ខំ ដែលជាការអនុវត្តចំពោះអចលនវត្ថុ ឬ ការអនុវត្តសិទ្ធិប្រាតិភោគដែលមានដំណើរការមុន) នៃក្រមនេះ នៅពេលកំណត់តម្លៃលក់អប្បបរមា និង ធ្វើឯកសារលំអិតអំពីវត្ថុ តុលាការអនុវត្តត្រូវពិចារណាអំពីការរលត់នៃសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានដាក់ពាក្យសុំក្រោយ និង សិទ្ធិប្រាតិភោគផ្សេង សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល និង សិទ្ធិជួល ដែលមិនអាចតតាំងនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនោះ ។

២- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើមានភាពចាំបាច់ តុលាការអនុវត្តត្រូវកំណត់តម្លៃលក់អប្បបរមា ឬ ធ្វើឯកសារលំអិតអំពីវត្ថុឡើងវិញ ។

(កំណត់)

សូមមើលមាត្រា ៤៣០ (ការវាយតម្លៃ) មាត្រា ៤៣២ (ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា ជាអាទិ៍) និង មាត្រា ៤៣៤ (ឯកសារលំអិតអំពីវត្ថុ) នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ។

(1) ដូចដែលបានចែងនៅក្នុងមាត្រា ៥១១ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា នៃការអនុវត្តចំពោះអចលនវត្ថុ និង ការអនុវត្តសិទ្ធិប្រាតិភោគ) និង មាត្រា ៥១២ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង

ការអនុវត្តសិទ្ធិប្រាតិភោគ) ក្នុងករណីដែលមានដីកាសម្រេចចាប់ផ្តើមឱ្យអនុវត្តសិទ្ធិប្រាតិភោគ ចំពោះអចលនវត្ថុ ដែលដីកាសម្រេចចាប់ផ្តើមឱ្យលក់ដោយបង្ខំ ត្រូវបានសម្រេចរួចហើយ ការអនុវត្តសិទ្ធិប្រាតិភោគក្រោយ នឹងត្រូវបានធ្វើឡើង នៅក្នុងនីតិវិធីដែលត្រូវបានចាប់ផ្តើមដោយផ្អែកលើពាក្យសុំមុន ។ ប៉ុន្តែ សិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលដែលបានដាក់ពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគក្រោយ និង សិទ្ធិប្រាតិភោគ ជាដើម ដែលមានអាទិភាពទាបជាងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនោះ ត្រូវរលត់ដោយការលក់ ទោះបីជាសិទ្ធិទាំងនោះអាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលដែលបានដាក់ពាក្យសុំមុនក៏ដោយ (សូមមើលមាត្រា ៥១៣ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់ដោយបង្ខំ ដែលជាការអនុវត្តចំពោះអចលនវត្ថុ ឬ ការអនុវត្តសិទ្ធិប្រាតិភោគដែលមានដំណើរការមុន)) ។ ហេតុដូច្នេះ នៅពេលដែលអនុវត្តនីតិវិធីនៃការលក់ដោយបង្ខំដែលត្រូវបានចាប់ផ្តើមដោយផ្អែកលើពាក្យសុំមុន តុលាការត្រូវកំណត់តម្លៃលក់អប្បបរមា និង ធ្វើឯកសារលំអិតអំពីវត្ថុ ជាដើម ដោយយកការណ៍នោះមកធ្វើជាមូលដ្ឋាន ។

ប៉ុន្តែ តាមពេលវេលានៃពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគក្រោយ អាចមានករណីដែលតុលាការបានកំណត់តម្លៃលក់អប្បបរមា និង ធ្វើឯកសារលំអិតអំពីវត្ថុ ជាដើម នៅក្នុងនីតិវិធីនៃការលក់ដោយបង្ខំដែលត្រូវបានចាប់ផ្តើមដោយផ្អែកលើពាក្យសុំមុន ដោយមិនគិតពិចារណាអំពីការរលត់នៃសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលដែលបានដាក់ពាក្យសុំក្រោយ ជាដើម ។ ក្នុងករណីនេះ មានភាពចាំបាច់ក្នុងការធ្វើឡើងវិញនូវនីតិវិធីខាងលើនេះ ។ ហេតុដូច្នេះ តុលាការត្រូវធ្វើវិធានការចាំបាច់ ដោយយោងតាមដំណើការនៃនីតិវិធីលក់ដោយបង្ខំ ដែលផ្អែកលើពាក្យសុំមុន ។ ជាឧទាហរណ៍ បើតម្លៃលក់អប្បបរមា ត្រូវបានកំណត់ ដោយមិនគិតពិចារណាអំពីការណ៍ខាងលើនេះ ហើយកាលបរិច្ឆេទនៃការលក់ ត្រូវបានកំណត់ តុលាការនឹងកែប្រែតម្លៃលក់អប្បបរមា ហើយកំណត់កាលបរិច្ឆេទនៃការលក់ថ្មី ឬ បើមានភាពចាំបាច់ធ្វើការវាយតម្លៃម្តងទៀត ដើម្បីកំណត់តម្លៃលក់អប្បបរមា តុលាការនឹងធ្វើការវាយតម្លៃ ជាដើម ។ នៅពេលនេះ បញ្ញត្តិនៃកថាភាគទី ២ ផ្នែកទី ៤ ជំពូកទី ២ នៃគន្ថីទី ៦ ត្រូវយកមកអនុវត្ត ។

(2) ម្យ៉ាងទៀត ដើម្បីកុំឱ្យមានពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ នៅក្នុងដំណាក់កាលដែលនីតិវិធីនៃការអនុវត្តមុនត្រូវបានធ្វើមួយចំនួនធំហើយ តុលាការត្រូវដាស់តឿនឱ្យម្ចាស់សិទ្ធិប្រាតិភោគ រាយការណ៍អំពីអត្ថិភាព ឬ នត្ថិភាពនៃឆន្ទៈអនុវត្តសិទ្ធិប្រាតិភោគ នៅពេលចេញដីកាសម្រេចចាប់ផ្តើមឱ្យអនុវត្តដោយបង្ខំ តាមកថាខណ្ឌទី ៣ នៃមាត្រា ៤២២ (ការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក និង ការផ្លាស់ប្តូរពេលកំណត់នោះ) ។

ម្យ៉ាងទៀត ក្នុងករណីដែលពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគក្រោយ ត្រូវបានធ្វើឡើង ក្រោយពេលកាលបរិច្ឆេទ នៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ក្នុងនីតិវិធីអនុវត្តដោយបង្ខំមុន នីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគក្រោយ ត្រូវបានផ្អាក ដោយយោងតាមបញ្ញត្តិនៃមាត្រា ៥១៥ (ការចាត់ចែងក្នុងករណីដែលមានពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ ក្រោយពេលដែលកាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ក្នុងនីតិវិធីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ បានចាប់ផ្តើម) ។ ក្នុងករណីនេះ បើអ្នកទិញបង់ថ្លៃលក់

នៅក្នុងនីតិវិធីនៃការលក់ដោយបង្ខំមុន មិនចាំបាច់ធ្វើការវាយតម្លៃអចលនវត្ថុ កំណត់តម្លៃលក់អប្បបរមា ឬ ធ្វើឯកសារលំអិតអំពីវត្ថុឡើងវិញ តាមមាត្រានេះឡើយ ។

**មាត្រា ៥១៥.-** ការចាត់ចែងក្នុងករណីដែលមានពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ ក្រោយពេលដែលកាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ក្នុងនីតិវិធីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ បានចាប់ផ្តើម

១- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥១១ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា នៃការអនុវត្តចំពោះអចលនវត្ថុ និង ការអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ បើពាក្យសុំឱ្យលក់ដោយបង្ខំដើម្បីអនុវត្ត សិទ្ធិប្រាតិភោគត្រូវបានដាក់ ក្រោយពេលកាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ក្នុងនីតិវិធីអនុវត្តដោយបង្ខំមុន បានចាប់ផ្តើម តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំនោះ ហើយព្រមជាមួយគ្នានេះ ត្រូវផ្អាកនីតិវិធីលក់ដោយបង្ខំក្រោយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសិទ្ធិប្រាតិភោគនោះ មិនអាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្តមុនបាន ។

២- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥១២ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ បើពាក្យសុំឱ្យលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគត្រូវបានដាក់ ក្រោយពេលកាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ក្នុងនីតិវិធីអនុវត្តដោយបង្ខំមុន បានចាប់ផ្តើម តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំនោះ ហើយព្រមជាមួយគ្នានេះ ត្រូវផ្អាកនីតិវិធីលក់ដោយបង្ខំក្រោយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានដាក់ពាក្យសុំឱ្យលក់ដោយបង្ខំក្រោយ មិនអាចតតាំងនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តមុនបាន ។

៣- បើមានការបង់ថ្លៃលក់ក្នុងនីតិវិធីលក់ដោយបង្ខំមុន ក្រោយពីបានផ្អាកនីតិវិធីលក់ដោយបង្ខំក្រោយ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ តុលាការអនុវត្តត្រូវលុបចោលដីកាសម្រេចចាប់ផ្តើមដែលទាក់ទងនឹងនីតិវិធីលក់ដោយបង្ខំក្រោយ ។

(កំណត់)

(1) មាត្រា ៥១១ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា នៃការអនុវត្តចំពោះអចលនវត្ថុ និង ការអនុវត្តសិទ្ធិប្រាតិភោគ) ចែងអំពីករណីដែលមានពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ ចំពោះអចលនវត្ថុដែលនីតិវិធីលក់ដោយបង្ខំ កំពុងតែមានដំណើរការ ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមអនុវត្តចំពោះអចលនវត្ថុនោះ ។ ប៉ុន្តែ ប្រសិនបើពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគនោះ ត្រូវបានដាក់ ក្រោយពេលកាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ

ដោយផ្ទាល់មាត់ ក្នុងនីតិវិធីអនុវត្តដោយបង្ខំមុន ត្រូវបានចាប់ផ្តើម យើងត្រូវចាត់ចែងផ្សេងពីបញ្ញត្តិនៃមាត្រា ៥១១ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា នៃការអនុវត្តចំពោះអចលនវត្ថុ និង ការអនុវត្តសិទ្ធិប្រាតិភោគ) ។ នេះមានមូលហេតុថា នីតិវិធីដែលបានធ្វើហើយពីមុនមកនឹងអាចក្លាយជាអសារបង់ ដោយសារតែត្រូវធ្វើឡើងវិញនូវនីតិវិធីនៃការលក់ដែលបានបញ្ចប់រួចហើយ ជាដើម ។ ហេតុដូច្នេះ មាត្រានេះចែងថា នីតិវិធីនៃការលក់ដោយបង្ខំដោយផ្អែកលើពាក្យសុំក្រោយនោះ ត្រូវផ្អាក រហូតដល់ពេលដែលមានភាពច្បាស់លាស់អំពីស្ថានភាពនៃនីតិវិធីលក់ដែលមានដំណើរការមុន ។ ប៉ុន្តែ ក្នុងករណីដែលសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តក្រោយមិនអាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្តមុនទេនោះ បញ្ហាដែលបានពន្យល់ខាងលើនេះ មិនអាចកើតមានឡើងទេ ហេតុនេះហើយមិនចាំបាច់ផ្អាកនីតិវិធីក្រោយនេះទេ ។

(2) មាត្រា ៥១២ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តសិទ្ធិប្រាតិភោគ) ចែងអំពីករណីដែលមានពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ ចំពោះអចលនវត្ថុដែលនីតិវិធីលក់ដោយបង្ខំ កំពុងតែមានដំណើរការ ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុនោះ ។ ប៉ុន្តែ ប្រសិនបើពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគក្រោយនោះ ត្រូវបានដាក់ក្រោយពេលកាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ក្នុងនីតិវិធីអនុវត្តដោយបង្ខំមុន ត្រូវបានចាប់ផ្តើម យើងត្រូវចាត់ចែងផ្សេងពីបញ្ញត្តិនៃមាត្រា ៥១២ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តសិទ្ធិប្រាតិភោគ) ដូចគ្នានឹងកំណត់ (1) ។

(3) យោងតាមកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ ខាងលើនេះ ប្រសិនបើពាក្យសុំនៃនីតិវិធីលក់ដោយបង្ខំមុនត្រូវបានដក ឬនីតិវិធីនោះត្រូវបានលុបចោល នីតិវិធីលក់ដោយបង្ខំក្រោយដែលត្រូវបានផ្អាក នឹងត្រូវធ្វើបន្តឡើងវិញ ។ ប៉ុន្តែក្នុងករណីដែលអ្នកទិញក្នុងនីតិវិធីលក់ដោយបង្ខំមុន បានបង់ថ្លៃលក់ហើយ ដីកាសម្រេចចាប់ផ្តើមនៃនីតិវិធីលក់ដោយបង្ខំក្រោយ នឹងត្រូវបានលុបចោល ។ ហេតុនេះហើយ ពេលដែលដីកាសម្រេចចាប់ផ្តើមត្រូវបានលុបចោល ម្ចាស់បំណុលនៃការអនុវត្តដែលបានដាក់ពាក្យសុំដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ត្រូវដាក់ពាក្យសុំឱ្យអនុវត្តជាថ្មីទៀត ។

**មាត្រា ៥១៦.-** ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ

១- ក្នុងករណីដែលអានុភាពនៃការរឹបអូសកើតឡើង ចំពោះអចលនវត្ថុ ដោយដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ បើម្ចាស់បំណុលនៃការអនុវត្ត ដាក់ពាក្យសុំឱ្យរឹបអូសសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យបង់ថ្លៃឈ្នួលអចលនវត្ថុនោះ តុលាការអនុវត្តអាចចេញដីកាសម្រេចរឹបអូសនោះបាន ។ ដីកាសម្រេចនេះត្រូវធ្វើឡើង ដោយមិនសួរកូនបំណុលនៃការអនុវត្ត និង អ្នកដែលមានករណីយកិច្ចបង់ថ្លៃឈ្នួលអចលនវត្ថុនោះ ។

២- ក្នុងដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តត្រូវហាមឃាត់កូនបំណុលនៃការអនុវត្ត ក្នុងការប្រមូលសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យបង់ថ្លៃឈ្នួល ឬ ធ្វើការចាត់ចែងផ្សេងទៀត ហើយត្រូវ

ហាមឃាត់ជនដែលមានករណីយកិច្ចបង់ថ្លៃឈ្នួល ក្នុងការសងទៅឱ្យកូនបំណុលនៃការអនុវត្ត ហើយត្រូវបង្គាប់ឱ្យជនដែលមានករណីយកិច្ចបង់ថ្លៃឈ្នួលនោះ ផ្ញើនូវប្រាក់ដែលស្មើនឹងចំនួនសរុបនៃសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស នៅតុលាការអនុវត្ត ។

៣- ដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបញ្ជូនទៅកូនបំណុលនៃការអនុវត្ត និង ជនដែលមានករណីយកិច្ចបង់ថ្លៃឈ្នួល ។

៤- អានុភាពនៃការរឹបអូស នឹងកើតឡើង នៅពេលដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានបញ្ជូនទៅដល់ជនដែលមានករណីយកិច្ចបង់ថ្លៃឈ្នួល ។

(កំណត់)

(1) មាត្រានេះចែងអំពីនីតិវិធីសង្ខេបមួយ គឺ ក្នុងករណីដែលនីតិវិធីនៃការលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុបានចាប់ផ្តើម សិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុនោះ រហូតដល់ពេលដែលនីតិវិធីលក់ដោយបង្ខំនឹងបញ្ចប់ (ពេលដែលអ្នកទិញបង់ថ្លៃលក់) ត្រូវបានរឹបអូស តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត (ដែលអនុវត្តសិទ្ធិប្រាតិភោគ) និង បង្គាប់ឱ្យភតិកៈ ផ្ញើថ្លៃឈ្នួលទៅតុលាការអនុវត្ត ហើយចែកចំណែកថ្លៃឈ្នួលជាមួយនឹងថ្លៃលក់អចលនវត្ថុ តាមលំដាប់នៃម្ចាស់បំណុលនីមួយៗចំពោះអចលនវត្ថុនោះ ។
ការដែលអនុញ្ញាតឱ្យម្ចាស់បំណុលនៃការអនុវត្តអាចដាក់ពាក្យបណ្តឹងទាមទារប្រមូល ដើម្បីទាមទារឱ្យធ្វើបញ្ញើតែប៉ុណ្ណោះ មិនសូវមានប្រយោជន៍ដល់ម្ចាស់បំណុលក្នុងការប្តឹង ហើយការជ្រើសតាំងអ្នកគ្រប់គ្រងដើម្បីទារថ្លៃឈ្នួលតែប៉ុណ្ណោះ ក៏មិនសមស្របទៅនឹងភាពជាក់ស្តែង ព្រោះវាអស់សោហ៊ុយច្រើន ។ ម្យ៉ាងទៀត ដោយសារតែនីតិវិធីនេះជានីតិវិធីសម្រាប់រយៈពេលខ្លីរហូតដល់ពេលដែលលក់អចលនវត្ថុនេះ ការចែងត្រឹមតែនីតិវិធីដែលអាចអនុវត្តបានក្នុងករណីដែលភតិកៈផ្ញើថ្លៃឈ្នួលទៅតុលាការអនុវត្តដោយស្ម័គ្រចិត្ត ជាការគ្រប់គ្រាន់ហើយ ។

(2) មាត្រានេះចែងថា ត្រូវរឹបអូសចំនួនទាំងអស់នៃសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួល ដោយមិនគិតពីតម្លៃនៃសិទ្ធិលើបំណុល (សិទ្ធិលើបំណុលដែលត្រូវបានធានា) ដោយគិតពិចារណាអំពីការសម្រួលនូវនីតិវិធី និង វិសាលភាពទូលាយនៃម្ចាស់បំណុល ដែលត្រូវចែកចំណែកក្នុងនីតិវិធីលក់ដោយបង្ខំចំពោះអចលនវត្ថុ ។

**មាត្រា ៥១៧.-** អានុភាពនៃការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួល

១- ម្ចាស់បំណុលនៃការអនុវត្តដែលបានរឹបអូសសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យបង់ថ្លៃឈ្នួលអចលនវត្ថុ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៥១៦ (ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ) នៃក្រមនេះ អាចទាមទារឱ្យអ្នកដែលមានករណីយកិច្ចបង់ថ្លៃឈ្នួល ផ្ញើប្រាក់ដែលស្មើនឹងចំនួនសរុបនៃសិទ្ធិលើបំណុលដែលត្រូវបានរឹបអូសនោះ នៅតុលាការអនុវត្តបាន បើអំឡុងពេល ១ (មួយ) សប្តាហ៍ បានកន្លងហួស ដោយគិតពីថ្ងៃដែល

ដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះ ត្រូវបានបញ្ជូនទៅដល់កូនបំណុលនៃការអនុវត្ត ។
២- ការរឹបអូស ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៥១៦ (ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ) នៃក្រមនេះ ត្រូវមានអានុភាពលើថ្លៃឈ្នួលដែលកូនបំណុលនៃការអនុវត្តត្រូវទទួល ក្រោយការរឹបអូស រហូតដល់ពេលដែលអ្នកទិញបង់ថ្លៃលក់អចលនវត្ថុនោះ ។
៣- ថ្លៃឈ្នួលដែលកូនបំណុលនៃសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យបង់ថ្លៃឈ្នួល បានផ្ញើនៅតុលាការ ត្រូវគិតបញ្ចូលក្នុងថ្លៃលក់ ។

(កំណត់)

(1) អានុភាពនៃការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួល ដោយយោងតាមមាត្រា ៥១៦ (ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ) មានអត្ថិភាព រហូតដល់ពេលផ្ទេរកម្មសិទ្ធិទៅអ្នកទិញ ដោយការបង់ថ្លៃទិញ ។

**មាត្រា ៥១៨.-** ទំនាក់ទំនងរវាងការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ និង នីតិវិធីអនុវត្តចំពោះសិទ្ធិលើបំណុល

១- ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យបង់ថ្លៃឈ្នួលអចលនវត្ថុ បើដីកាសម្រេចរឹបអូសដែលបានកំណត់នៅក្នុងមាត្រា ៤០៣ (ដីកាសម្រេចរឹបអូស) នៃក្រមនេះ ត្រូវបានបញ្ជូនទៅដល់ភតិកៈដែលជួលអចលនវត្ថុ មុនពេលដីកាសម្រេចរឹបអូសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥១៦ (ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ) បង្កើតអានុភាព នោះដីកាសម្រេចរឹបអូសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥១៦ (ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ) មិនត្រូវបង្កើតអានុភាពឡើយ លើកលែងតែករណីដែលសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានទទួលដីកាសម្រេចរឹបអូស ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥១៦ (ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ) ត្រូវបានចុះបញ្ជីមុនពេលបញ្ជូនដីកាសម្រេចរឹបអូសនោះ ។
២- សិទ្ធិលើបំណុលដែលមានគោលបំណងឱ្យបង់ថ្លៃឈ្នួលអចលនវត្ថុ មិនអាចត្រូវបានរឹបអូស ដោយយោងតាមមាត្រា ៤០៣ (ដីកាសម្រេចរឹបអូស) នៃក្រមនេះ បានឡើយ នៅក្រោយពេលដែលដីកាសម្រេចរឹបអូសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥១៦ (ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលនៃអចលនវត្ថុ) បានបង្កើតអានុភាពចំពោះសិទ្ធិលើបំណុលនោះ ។

(កំណត់)

(1) មាត្រានេះចែងអំពីទំនាក់ទំនងរវាងការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួល ក្នុងនីតិវិធីលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ និង ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួល តាមនីតិវិធីនៃការអនុវត្តដោយបង្ខំ

ចំពោះសិទ្ធិលើបំណុល (ផ្នែកទី ៣ ជំពូកទី ២ គន្ថីទី ៦) ។ កថាខណ្ឌទី ១ ចែងអំពីករណីដែលការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួល ដោយការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល បានធ្វើឡើងមុនការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួល ក្នុងនីតិវិធីលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ។ ក្នុងករណីនេះ ប្រសិនបើការបញ្ជូនដីកាសម្រេចរឹបអូសក្នុងនីតិវិធីនៃការអនុវត្តចំពោះសិទ្ធិលើបំណុល ទៅភតិកៈនៃអចលនវត្ថុដែលជាកូនបំណុលទី ៣ បានធ្វើមុនការចុះបញ្ជីដោយម្ចាស់សិទ្ធិប្រាតិភោគ ជាគោលការណ៍ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ត្រូវមានអាទិភាព ហើយដីកាសម្រេចរឹបអូសរបស់ម្ចាស់សិទ្ធិប្រាតិភោគ មិនត្រូវបង្កើតអានុភាពទេ ។ ប៉ុន្តែ ប្រសិនបើការចុះបញ្ជីអំពីសិទ្ធិប្រាតិភោគបានធ្វើមុនការបញ្ជូនដីកាសម្រេចរឹបអូស ក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលទៅឱ្យភតិកៈ ដីកាសម្រេចរឹបអូសរបស់ម្ចាស់សិទ្ធិប្រាតិភោគ នឹងមានអាទិភាពជាង ។

(2) ផ្ទុយទៅវិញ កថាខណ្ឌទី ២ ចែងថា ប្រសិនបើការរឹបអូសដែលបានកំណត់នៅក្នុងមាត្រា ៥១៦ (ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ) ត្រូវបានធ្វើមុន មិនអាចរឹបអូសចំពោះតែថ្លៃឈ្នួល ដោយនីតិវិធីអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលទេ ។

**មាត្រា ៥១៩.-** វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក

ក្រៅពីជនដែលបានកំណត់នៅក្នុងមាត្រា ៤៥៣ (វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក) នៃក្រមនេះ ម្ចាស់បំណុលដែលត្រូវទទួលចំណែកពីប្រាក់ដែលបានមកពីការលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគ គឺនៅមានម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគដែលត្រូវរលត់ដោយការលក់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគដែលបានចុះបញ្ជី ក្រោយពេលអានុភាពនៃការរឹបអូសបានកើតឡើង ។

(កំណត់)

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 87 ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា មាត្រា ៤៥៣ (វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក) ។

(1) ជាលទ្ធផលនៃការលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ សិទ្ធិប្រាតិភោគនោះ ព្រមទាំងសិទ្ធិប្រាតិភោគផ្សេងទៀតដែលមានអាទិភាពទាបជាងសិទ្ធិប្រាតិភោគ ត្រូវរលត់ (មាត្រា ៥១០ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគ)) ។ ហេតុដូច្នេះ ម្ចាស់បំណុលដែលមានឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ ឬ ហ៊ីប៉ូតែក ដែលត្រូវបានចុះបញ្ជីមុនការចុះបញ្ជីអំពីការរឹបអូស ហើយដែលត្រូវរលត់ដោយសារការលក់នេះ អាចទទួលចំណែក ដោយមិនចាំបាច់ធ្វើការទាមទារ ។ នេះគឺជាចំណុចខុសគ្នានឹងមាត្រា ៤៥៣ (វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក) ដែលចែងអំពីករណីនៃការអនុវត្ត

ដោយបង្ខំចំពោះអចលនវត្ថុ ដែលយកគោលការណ៍ទទួលបន្ត ជាមូលដ្ឋាន ។

(2) ក្នុងករណីដែលម្ចាស់បំណុលដែលបានដាក់ពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ ចំពោះអចលនវត្ថុដែលដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំ ត្រូវបានសម្រេចរួចហើយ (មាត្រា ៥១១ (ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា នៃការអនុវត្តចំពោះអចលនវត្ថុ និង ការអនុវត្តសិទ្ធិប្រាតិភោគ) និង មាត្រា ៥១២ (ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តសិទ្ធិប្រាតិភោគ)) សិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានដាក់ពាក្យសុំក្រោយនោះ និង សិទ្ធិប្រាតិភោគផ្សេងទៀតដែលមិនអាចតតាំងនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនោះ ត្រូវរលត់ (កថាខណ្ឌទី ១ និង ទី ២ នៃមាត្រា ៥១៣ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់ដោយបង្ខំ ដែលជាការអនុវត្តចំពោះអចលនវត្ថុ ឬ ការអនុវត្តសិទ្ធិប្រាតិភោគ ដែលមានដំណើរការមុន)) ។ ហេតុដូច្នេះ ម្ចាស់បំណុលទាំងនេះ អាចទទួលចំណែក ដោយមិនចាំបាច់ទាមទារឱ្យចែកចំណែក ។

(3) ប៉ុន្តែ ក្នុងករណីដែលបានកំណត់នៅក្នុង (1) និង (2) បើសិទ្ធិប្រាតិភោគដែលនឹងត្រូវរលត់ ត្រូវបានចុះបញ្ជីក្រោយពេលអានុភាពនៃការរឹបអូស បានកើតឡើង ដោយដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំ ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគនោះ មិនអាចទទួលចំណែក ដោយស្វ័យប្រវត្តិឡើយ ។

<u>Civil Execution Act (Japan)</u>
**Article 87** (Coverage of obligees entitled to receive distribution) > *see the note for Article 453*

**មាត្រា ៥២០.-** បញ្ញត្តិស្ដីពីការអនុវត្តចំពោះអចលនវត្ថុ ដែលមិនត្រូវយកមកអនុវត្ត

បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៣៤៩ (របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ) កថាខណ្ឌទី ៣ នៃមាត្រា ៤១៧ (កម្មវត្ថុ និង វិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ) កថាខណ្ឌទី ១ នៃមាត្រា ៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់) ព្រមទាំងមាត្រា ៤៥៣ (វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ។

(កំណត់)

សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 188 បទប្បញ្ញត្តិស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណី មាត្រា 173 កថាខណ្ឌទី 1 ។

ក្នុងគន្ថីនេះ ដោយជំពូកទី ៣ គឺជាបញ្ញត្តិពិសេសចំពោះជំពូកទី ២ បើគ្មានបញ្ញត្តិនៅក្នុងជំពូកទី ៣ នេះ បញ្ញត្តិនៃជំពូកទី ២ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ (ជាពិសេស បញ្ញត្តិនៃផ្នែកទី ៤ (ការអនុវត្តចំពោះអចលនវត្ថុ) និង ផ្នែកទី ៦ (នីតិវិធីចែកចំណែកដោយតុលាការ) នៃជំពូក ២ គន្ថីទី ៦) លើកលែងតែមានភាពផ្ទុយនឹងលក្ខណៈនៃការអនុវត្តសិទ្ធិប្រាតិភោគ ។ ហេតុដូច្នេះ មាត្រានេះចង្អុលតែមាត្រាដែលមិនត្រូវយកមកអនុវត្ត ក្នុងចំណោមបញ្ញត្តិនៃជំពូកទី

២ ប៉ុណ្ណោះ ។

Civil Execution Act (Japan)
**Article 188** (*Mutatis mudandis* application of provisions for compulsory sale of immovable) > *see the note for Article 511*

## ផ្នែកទី ៥ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា

**មាត្រា ៥២១.-** ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា ជាអាទិ៍

១- ក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៤៥៥ (ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា និង របៀបអនុវត្ត) នៃក្រមនេះក៏ដោយ ក៏ម្ចាស់បំណុលនៃការអនុវត្ត ត្រូវសរសេរនូវចំណុចខាងក្រោមនេះ :

**ក-** សញ្ញាណនៃម្ចាស់បំណុលនៃការអនុវត្ត កម្មសិទ្ធិករនៃនាវាដែលជាកូនបំណុលនៃការអនុវត្ត កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា និង អ្នកតំណាង ។

**ខ-** សញ្ញាណនៃសិទ្ធិប្រាតិភោគ និង សិទ្ធិលើបំណុលដែលត្រូវបានធានា ។

**គ-** សញ្ញាណនៃនាវាដែលជាកម្មវត្ថុនៃការអនុវត្តសិទ្ធិប្រាតិភោគ ។

**ឃ-** ទីកន្លែងដែលនាវាស្ថិតនៅ ព្រមទាំងឈ្មោះរបស់មេបញ្ជាការ ឬ បរិបាលនាវា និង ទីកន្លែងដែលមេបញ្ជាការ ឬ បរិបាលនាវានោះនៅនាពេលបច្ចុប្បន្ន ។

**ង-** ហេតុការណ៍ និង ទំហំនៃផ្នែកនៃសិទ្ធិលើបំណុលដែលត្រូវបានធានា បើធ្វើការអនុវត្តសិទ្ធិប្រាតិភោគ ចំពោះផ្នែកមួយនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ។

២- ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ៤៥៥ (ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា និង របៀបអនុវត្ត) នៃក្រមនេះក៏ដោយ ក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ ក្រៅពីឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលបានកំណត់នៅក្នុងមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) អ្នកដាក់ពាក្យសុំត្រូវភ្ជាប់នូវឯកសារដែលបានកំណត់ដូចខាងក្រោមនេះ :

**ក-** ករណីដែលអនុវត្តសិទ្ធិប្រាតិភោគផ្សេងពីឯកសិទ្ធិទូទៅ : ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជី ។

**ខ-** ករណីដែលអនុវត្តឯកសិទ្ធិទូទៅ : ចំពោះនាវាដែលត្រូវបានចុះបញ្ជី ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជី និង ក្នុងករណីដែលជនដទៃក្រៅពីកូនបំណុលនៃការអនុវត្ត ត្រូវបានចុះនៅក្នុងសៀវភៅចុះបញ្ជីថាជាកម្មសិទ្ធិករ គឺ ឯកសារដែលបញ្ជាក់ថា នាវានោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។ ចំពោះនាវាដែលមិនត្រូវបានចុះបញ្ជី គឺ ឯកសារដែលបញ្ជាក់ថា នាវាជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។

៣- តុលាការអនុវត្តអាចចេញដីកាសម្រេចបង្គាប់ឱ្យអ្នកកាន់កាប់នាវាប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ទៅឱ្យអាជ្ញាសាលា តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះជនដែលត្រូវបានទទួលស្គាល់ថា កំពុងកាន់កាប់ដោយផ្អែកលើមូលហេតុគតិយុត្តនៃសិទ្ធិ ដែលអាចតតាំងនឹងម្ចាស់បំណុលនៃការអនុវត្តបាន ។

៤- ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៥- ចំពោះដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ទោះជានៅមុនពេលបញ្ជូនទៅឱ្យភាគីម្ខាងទៀតក៏ដោយ ក៏អាចអនុវត្តបានដែរ ។

(កំណត់)

សូមមើលបទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 170 និង មាត្រា 174 ក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសកម្ពុជា មាត្រា ៣៤៩ (របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ) កថាខណ្ឌទី ៣ នៃមាត្រា ៤១៧ (កម្មវត្ថុ និងវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ) និង មាត្រា ៥០៩ (ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ជាអាទិ៍) ។

មាត្រានេះ ចែងអំពីរបៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា ជាដើម ព្រមទាំងចែងអំពីដីកាសម្រេចបង្គាប់ឱ្យអ្នកកាន់កាប់នាវាប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ទៅឱ្យអាជ្ញាសាលា ។ ដីកាសម្រេចបង្គាប់ឱ្យអ្នកកាន់កាប់នាវាប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ នេះ គឺមានសារសំខាន់ក្នុងដំណាក់កាលនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា ។ ការអនុវត្តចំពោះនាវា ដោយផ្អែកលើលិខិតអនុវត្ត មិនអាចធ្វើឡើងចំពោះអ្នកកាន់កាប់ដោយឯករាជ្យ ដាច់ផ្សេងពីអ្នកដែលត្រូវបានសរសេរឈ្មោះនៅក្នុងលិខិតអនុវត្តនោះទេ ទោះបីជាមូលហេតុគតិយុត្តនៃសិទ្ធិកាន់កាប់អាច ឬ មិនអាចតតាំងនឹងម្ចាស់បំណុលនៃការអនុវត្តក៏ដោយ ក៏ពុំអាចអនុវត្តបានដែរ ។ ផ្ទុយទៅវិញ ក្នុងករណីនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា បើមិនអាចចេញដីកាសម្រេចបង្គាប់ឱ្យប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ចំពោះជនដែលពុំមានមូលហេតុគតិយុត្តដែលអាចតតាំងនឹងអ្នកដាក់ពាក្យសុំបានទេ នោះមានន័យថាតាមការពិត មិនអាចអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវាបាន ។ ហេតុដូច្នេះ កថាខណ្ឌទី ៣ នៃមាត្រានេះទទួលស្គាល់នូវលទ្ធភាពនៃ "arrest" ដើម្បីសម្របនឹងករណីដូច្នេះ ។

**មាត្រា ៥២២.-** ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ

បញ្ញត្តិនៃផ្នែកទី ៤ (ការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ) ជំពូកទី ៣ គន្ថីទី ៦ នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគដែលយកនាវាជាកម្មវត្ថុ លើកលែងតែមានបញ្ញត្តិពិសេស ។

（កំណត់）

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 189 ។

តាមក្រមរដ្ឋប្បវេណី នាវាជាចលនវត្ថុ តែតម្លៃធនធានមានកម្រិតស្មើគ្នានឹងអចលនវត្ថុ ហើយលទ្ធកម្ម ការបាត់បង់ និង ការកែប្រែបទូវកម្មសិទ្ធិ ជាអាទិ៍ ត្រូវបានប្រកាសជាសាធារណៈ តាមការចុះបញ្ជីដែលជាល័ក្ខខ័ណ្ឌតតាំង ។ ហេតុដូច្នេះ លើបច្ចេកទេសអនុវត្ត គួរឱ្យមានបញ្ញត្តិដូចគ្នានឹងអចលនវត្ថុ ។ ដោយយកការដែលត្រូវអនុវត្តតាមបញ្ញត្តិនៃការអនុវត្ត ចំពោះនាវា ជាមូលដ្ឋាន ហើយការលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគដែលយកនាវាជាកម្មវត្ថុ មានលក្ខណៈ ដូចគ្នានឹងការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ មាត្រានេះចែងអំពីការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីការអនុវត្ត សិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ។ យើងពុំគិតអំពីសញ្ជាតិនៃនាវាទេ ។ ចំពោះនាវាដែលមាន flag of conveninence (នាវាដែលមានសញ្ជាតិផ្សេងពីសញ្ជាតិរបស់ម្ចាស់នាវា ដោយហេតុថាបង់ពន្ធថោក ជាដើម) ក៏ដោយ ក៏យើងអាច អនុវត្តចំពោះនាវានោះបានដែរ លុះត្រាតែនាវានោះស្ថិតនៅក្នុងទំហំអធិបតេយ្យភាពរបស់ព្រះរាជាណាចក្រកម្ពុជា ។

ម្យ៉ាងទៀត បញ្ញត្តិដែលចែងអំពីបញ្ញត្តិស្តីពីការអនុវត្តចំពោះអចលនវត្ថុមួយចំនួនដែលមិនត្រូវយកមកអនុវត្តចំពោះ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ នៅក្នុងផ្នែកទី ៤ ជំពូកទី ៣ គន្ថីទី ៦ ក៏ត្រូវយកមកអនុវត្តដូចគ្នា ចំពោះការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវាដែរ តាមមាត្រានេះ ។

<u>Civil Execution Act (Japan)</u>
**Article 189** (Sale by auction of ship)
The provisions of Chapter II Section II Subsection II and Articles 181 to 187 inclusive shall apply *mutatis mutandis* to sale by auction as execution of a security right whose subject matter is a ship as provided in Article 112. In such cases, the phrase in Article 115. paragraph 3, "an exemplification of an obligation title with execution power", shall be changed to " a document referred to in Article 181, paragraphs 1 to 3 inclusive applied *mutatis mutandis* by Article 189," the phrase in Article 181, paragraph i item iv. "a general preferential right, "shall be changed to "a general preferential right or a preferential right provided in Article 842 of the Commercial Code," and the phrase in Article 185, paragraph 1, "the day when a demand for sale by public auction at a higher price is sent off," shall bechanged to "the day when a motion for sale by auction as execution of a security right whose subject matter is a ship may be made, after a demand for sale by public auction at a higher price is sent off."

**មាត្រា ៥២៣.-** បញ្ញត្តិដែលត្រូវបានបកស្រាយ

ឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៤៥៩ (ដីកាសម្រេចបង្គាប់ឱ្យប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ នៅមុនពេលដាក់ពាក្យសុំ) នៃក្រមនេះ ត្រូវបានបកស្រាយថា ឯកសារដែលបានកំណត់នៅក្នុងមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) ។

（កំណត់）

សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 189 ។

Civil Execution Act (Japan)
**Article 189** (Sale by auction of ship ) > *see the note for Article 522*

## ជំពូកទី ៤ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលគ្មានគោលបំណងឱ្យសងជាប្រាក់

**មាត្រា ៥២៤.-** ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ជាអាទិ៍

១- ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ឬ នាវាឬវត្ថុផ្សេងទៀតដែលមនុស្សរស់នៅក្នុងនោះ ត្រូវធ្វើតាមវិធីដែលអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុស្ថិតនៅ រំលាយការកាន់កាប់វត្ថុដែលជាកម្មវត្ថុរបស់កូនបំណុលនៃការអនុវត្ត ហើយធ្វើឱ្យម្ចាស់បំណុលនៃការអនុវត្ត ទទួលបាននូវការកាន់កាប់នោះ ។

២- ការអនុវត្តដោយបង្ខំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើបាន លុះត្រាតែម្ចាស់បំណុលនៃការអនុវត្ត ឬ អ្នកតំណាងរបស់ម្ចាស់បំណុលនៃការអនុវត្តនោះ បានបង្ហាញខ្លួននៅកន្លែងអនុវត្ត ។

៣- នៅពេលធ្វើការអនុវត្តដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាជ្ញាសាលាអាចចូលទៅក្នុងអចលនវត្ថុ នាវា ឬ វត្ថុផ្សេងទៀតដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត ហើយបើចាំបាច់ អាចធ្វើការចាត់ចែងជាចាំបាច់ដើម្បីបើកទ្វារដែលបិទនោះ ។

៤- នៅក្នុងការអនុវត្តដោយបង្ខំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាជ្ញាសាលាត្រូវដកចេញនូវចលនវត្ថុដែលមិនមែនជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំនោះ ហើយត្រូវប្រគល់ចលនវត្ថុទាំងនោះទៅឱ្យកូនបំណុលនៃការអនុវត្ត ឬ អ្នកតំណាងរបស់កូនបំណុលនោះ ឬ ញាតិនៅជាមួយឬអ្នកបម្រើឬអ្នកផ្សេងដែលធ្វើការនៅទីនោះដែលមានការយល់ដឹងសមរម្យ ។ ក្នុងករណីនេះ ប្រសិនបើមិនអាចប្រគល់ចលនវត្ថុនោះទៅឱ្យជនទាំងឡាយដែលបានរៀបរាប់ខាងលើនេះបានទេ អាជ្ញាសាលាត្រូវថែរក្សាគ្រប់គ្រងចលនវត្ថុនោះ ។

៥- សោហ៊ុយសម្រាប់ថែរក្សាគ្រប់គ្រងតាមបញ្ញត្តិនៃកថាខណ្ឌទី ៤ ខាងលើនេះ ត្រូវចាត់ជាសោហ៊ុយសម្រាប់ការអនុវត្ត ។

៦- បើមិនអាចប្រគល់ចលនវត្ថុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ឱ្យទៅជនដូចបញ្ញត្តិក្នុងកថាខណ្ឌនោះទេ អាជ្ញាសាលាអាចលក់ចលនវត្ថុនោះ តាមវិធីលក់នៃការអនុវត្តចំពោះចលនវត្ថុបាន ។

៧- បើបានលក់ចលនវត្ថុតាមបញ្ញត្តិនៃកថាខណ្ឌទី ៦ ខាងលើនេះ អាជ្ញាសាលាត្រូវដកចេញពីចំនួនទឹកប្រាក់ដែលបានមកពីការលក់នូវសោហ៊ុយដែលបានចំណាយក្នុងការលក់ និង ការថែរក្សាគ្រប់គ្រង ហើយត្រូវធ្វើទុកប្រាក់ដែលនៅសេសសល់នោះ នៅសាលាដំបូងដែលខ្លួនស្ថិតនៅ ។

៨- បើបានបញ្ចប់ការអនុវត្តដោយបង្ខំដូចបញ្ញត្តិក្នុងកថាខណ្ឌទី ១ និង ទី ៤ ខាងលើនេះហើយ អាជ្ញាសាលាត្រូវជូនដំណឹងនោះទៅឱ្យកូនបំណុលនៃការអនុវត្ត ។

(កំណត់)

(1) សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 168 និង បទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 154 ។

(2) មាត្រានេះចែងអំពីវិធីអនុវត្តដោយបង្ខំ ឱ្យប្រគល់អចលនវត្ថុ ឬ នាវាឬវត្ថុផ្សេងទៀតដែលមនុស្សរស់នៅ (ការបង្ខំដោយផ្ទាល់) ។ វត្ថុផ្សេងទៀត មានដូចជា ឡានសម្រាប់ស្នាក់នៅ (camping car) រថសណ្តោង (trailer car) ជាដើម ដែលជាចលនវត្ថុ សម្រាប់មនុស្សរស់នៅ ។

(3) ការអនុវត្តដោយបង្ខំនៃសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ ក្រៅពីចលនវត្ថុដែលបញ្ញត្តនៅក្នុងមាត្រានេះ ត្រូវបានកំណត់នៅក្នុងមាត្រា ៥២៥ (ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ) ។

(4) ការអនុវត្តដោយបង្ខំតាមបញ្ញត្តិនៃមាត្រានេះ គឺ អាជ្ញាសាលាត្រូវរំលាយនូវការកាន់កាប់កម្មវត្ថុរបស់កូនបំណុលនៃការអនុវត្ត ហើយត្រូវធ្វើឱ្យម្ចាស់បំណុលនៃការអនុវត្តនោះទទួលបាននូវការកាន់កាប់នោះ យើងពុំមានគម្រោងធ្វើឱ្យអាជ្ញាសាលានោះទទួលបាននូវការកាន់កាប់ទេ ទោះជាបានកាន់កាប់វត្ថុដែលជាកម្មវត្ថុនោះមួយរយៈក៏ដោយ ។ ហេតុដូច្នេះហើយ ការអនុវត្តតាមមាត្រានេះ មិនអាចធ្វើបានឡើយ ប្រសិនបើគ្មានការចូលរួមរបស់ម្ចាស់បំណុលនៃការអនុវត្ត ឬ អ្នកតំណាងរបស់អ្នកនោះទេ (កថាខណ្ឌទី ២) ។

(5) ចាប់ពីកថាខណ្ឌទី ៤ រហូតដល់ ទី ៧ នៃមាត្រានេះ បញ្ញត្តិអំពីករណីដែលមានចលនវត្ថុដែលមិនមែនជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ដូចជាសង្ហារិម ឬ ម៉ាស៊ីនផ្សេងៗ ជាដើម នៅក្នុងអចលនវត្ថុ ឬ នៅក្នុងនាវា ឬ វត្ថុផ្សេងៗដែលជាលំនៅដ្ឋាន ហើយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ក្នុងករណីនេះ អាជ្ញាសាលាត្រូវយកវត្ថុទាំងនោះចេញ ហើយប្រគល់អចលនវត្ថុ ឬ នាវា ជាដើម ដែលជាកម្មវត្ថុនៃការអនុវត្តនោះទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ។ ជាគោលការណ៍ អាជ្ញាសាលាត្រូវប្រគល់ចលនវត្ថុដែលបានយកចេញនោះឱ្យកូនបំណុលនៃការអនុវត្ត ជាដើម ក៏ប៉ុន្តែបើមិនអាចប្រគល់ឱ្យទេ អាជ្ញាសាលាត្រូវរក្សាទុក ដាក់លក់ ហើយត្រូវដកសោហ៊ុយសម្រាប់ការចាត់ចែងការអនុវត្តដោយបង្ខំនោះចេញ ហើយត្រូវយកលុយដែលនៅសល់នោះទៅផ្ញើទុកនៅសាលាដំបូងដែលខ្លួនស្ថិតនៅ ។ ម្យ៉ាងទៀត ក្នុងករណីដែលចលនវត្ថុដែលបានរៀបរាប់ខាងលើនេះ ត្រូវបានអនុវត្តការរឹបអូស (ឬ ការរឹបអូសជាបណ្តោះអាសន្ន) ការអនុវត្តទាំង ២ ប្រភេទនេះនឹងមានការបះទង្គិចគ្នា ហេតុដូច្នេះ ដើម្បីសម្រួលនីតិវិធីនេះ អាជ្ញាសាលាដែលបានចាត់ចែងការអនុវត្តដូចបញ្ញត្តិនៃមាត្រានេះ ចាំបាច់ត្រូវជូនដំណឹងទៅឱ្យអាជ្ញាសាលាដែលបានរឹបអូសមុន ( ឬ បានរឹបអូសជាបណ្តោះអាសន្នមុន) (បទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 151) ។ ក៏ប៉ុន្តែ ករណីប្រភេទនេះមានកើតឡើងតិចណាស់ ហេតុនេះហើយ មិនចាំបាច់បញ្ញត្តជាមាត្រាទេ ។

(6) ប្រសិនបើមានអាគារសាងសង់លើដីដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំនេះ គេមិនអាចរើយកផ្ទះចេញពីដីនេះតាមនីតិវិធីនៃមាត្រានេះ ដោយការអនុវត្តដោយបង្ខំនៃលិខិតអនុវត្តដែលបង្គាប់ឱ្យប្រគល់ដីនោះទេ ។ ក្នុងករណីនេះ ក្រៅពីការបង្គាប់ឱ្យប្រគល់ដី ត្រូវតែមានលិខិតអនុវត្តបង្គាប់ឱ្យរើអាគារនោះចេញផងដែរ ។ ការអនុវត្តដោយបង្ខំនៃលិខិតអនុវត្តបង្គាប់ឱ្យរើអាគារធ្វើតាមបញ្ញត្តិនៃមាត្រា ៥២៧ (ការអនុវត្តជំនួស) ឬ មាត្រា ៥២៨

(វិធានបង្ខំដោយប្រយោល) ។

(7) ការជូនដំណឹងដែលយោងតាមកថាខណ្ឌទី ៨ នេះ មិនចាំបាច់ធ្វើឱ្យហ្មត់ចត់ដូចការបញ្ជូនទេ គឺអាចធ្វើតាមវិធីធម្មតាណាមួយក៏បានដែរ ។ បើកូនបំណុលនៃការអនុវត្តមានវត្តមាននៅកន្លែងធ្វើការអនុវត្តដោយបង្ខំនោះ គ្រាន់តែជូនដំណឹងអំពីការបញ្ចប់ការអនុវត្តដោយបង្ខំនោះដោយផ្ទាល់មាត់ក៏បានដែរ ។

Civil Execution Act (Japan)
**Article 168** (Compulsory execution of delivery of immovable)
1. Compulsory execution of delivery or surrender of an immovable or a ship or the like in which a person dwells shall be carried out by the execution officer's dispossessing the obligor of the subject matter and having the obligee take possession thereof.
2. A compulsory execution referred to in the preceding paragraph may be carried out only when the obligee or his representative appears at the place of execution.
3. When carrying out a compulsory execution referred to in paragraph 1, the execution officer may enter the immovable or the ship possessed by the obligor and make a disposition necessary to open a closed door, if necessary.
4. In cases of compulsory execution in accordance with paragraph 1, the execution officer shall clear away movables which are not subject matter of the compulsory execution and deliver them to the obligor, his representative, relatives with whom the obligor resides or an obligor's servant or employee acting with due diligence. In such cases, if the execution officer cannot deliver the movables to such person, the execution officer shall keep them in custody.
5. The costs of such custody shall be included in the costs of execution.
6. Where the execution officer cannot deliver the movables mentioned in paragraph 4 to a person referred to in that paragraph, the execution officer may sell them by the procedure of execution against movables.
7. Where the execution officer has sold the movables in accordance with the preceding paragraph, the execution officer must deposit the surplus obtained after subtracting the expenses incurred for sale and custody from the proceeds.

**មាត្រា ៥២៥.-** ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ

១- ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុក្រៅពីចលនវត្ថុ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥២៤ (ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ជាអាទិ៍) នៃក្រមនេះ ត្រូវធ្វើតាមវិធីដែលអាជ្ញាសាលានៃសាលាដំបូង ដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុស្ថិតនៅ ដកយកចលនវត្ថុពីកូនបំណុលនៃការអនុវត្ត ហើយប្រគល់ចលនវត្ថុនោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ។

២- ប្រសិនបើម្ចាស់បំណុលនៃការអនុវត្ត ឬ អ្នកតំណាងពុំបានបង្ហាញខ្លួននៅទីកន្លែងធ្វើការអនុវត្តដោយបង្ខំ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះទេ អាជ្ញាសាលាអាចព្យួរការអនុវត្តដោយបង្ខំនោះបាន បើទទួលស្គាល់ថាពុំអាចជៀសវាងបាន ដោយគិតពិចារណាលើប្រភេទ និង ចំនួន ជាអាទិ៍ នៃចលនវត្ថុដែលពាក់ព័ន្ធនោះ។

៣- ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តដោយបង្ខំ ឬ អ្នកតំណាងពុំបានបង្ហាញខ្លួន នៅទីកន្លែងធ្វើការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុទេ បើបានដកយកចលនវត្ថុនោះពីកូនបំណុលនៃការអនុវត្ត អាជ្ញាសាលាត្រូវថែរក្សាគ្រប់គ្រងចលនវត្ថុនោះ ។

៤- បញ្ញត្តិនៃកថាខណ្ឌទី ៦ នៃមាត្រា ៣៨៤ (ការចាប់ផ្តើមអនុវត្តចំពោះចលនវត្ថុ) កថាខណ្ឌទី ២ នៃមាត្រា ៣៨៥ (ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត) និង បញ្ញត្តិចាប់ពីកថាខណ្ឌទី ៤ រហូតដល់ទី ៨ នៃមាត្រា ៥២៤ (ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តដោយបង្ខំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

(1) សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 169 និង បទប្បញ្ញត្តិស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 155 ។

(2) មាត្រានេះបញ្ញត្តអំពីវិធីអនុវត្តដោយបង្ខំ (ការបង្ខំដោយផ្ទាល់) នៃសិទ្ធិទាមទារឱ្យប្រគល់នូវកម្មវត្ថុដែលជាចលនវត្ថុ ក្រៅពី "នាវា ឬ វត្ថុផ្សេងៗដែលមនុស្សរស់នៅ" ដែលមានបញ្ញត្តិក្នុងមាត្រា ៥២៤ (ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ជាអាទិ៍) ។ ចំណុចដែលខុសគ្នាពីករណីដែលយោងតាមមាត្រា ៥២៤ (ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ជាអាទិ៍) គឺអាជ្ញាសាលាអាចរក្សាទុកនូវចលនវត្ថុ ដែលយកពីកូនបំណុលនៃការអនុវត្តបាន (បានទទួលនូវសិទ្ធិកាន់កាប់មួយរយៈ) (សូមប្រៀបធៀបកថាខណ្ឌទី ១ និង ទី ៣ នៃមាត្រានេះ ។ សូមប្រៀបធៀបនឹងកថាខណ្ឌទី ២ នៃមាត្រា ៥២៤ (ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ជាអាទិ៍)) ។ម្យ៉ាងទៀត ប្រសិនបើម្ចាស់បំណុលនៃការអនុវត្ត ឬ អ្នកតំណាង ពុំបានបង្ហាញខ្លួននៅកន្លែងអនុវត្តទេ ក្នុងករណីដែលមានការលំបាកក្នុងការដឹកជញ្ជូន ឬ រក្សាទុកនូវចលនវត្ថុ ដែលជាកម្មវត្ថុនៃការអនុវត្តនោះ ដោយមានតែអាជ្ញាសាលាម្នាក់ឯង អាជ្ញាសាលាអាចព្យួរការអនុវត្តនោះ ហើយកំណត់កាលបរិច្ឆេទមួយផ្សេង ដើម្បីធ្វើការអនុវត្តម្ដងទៀត (កថាខណ្ឌទី ២ នៃមាត្រានេះ) ។

<u>Civil Execution Act (Japan)</u>
**Article 169** (Compulsory execution of delivery of movables)
1. Compulsory execution of delivery of movables (including valuable instruments) other than movables referred to in paragraph 1 of the preceding Article shall be carried out by the execution officer's taking them from the obligor and delivering them to the obligee.
2. The provisions of Article 122, paragraph 2, Article 123, paragraph 2, and paragraphs 4 to 7 inclusive of the preceding Article shall apply *mutatis mutandis* to compulsory execution referred to in the preceding paragraph.

**មាត្រា ៥២៦.-** ការអនុវត្តដោយបង្ខំឱ្យប្រគល់ ក្នុងករណីវត្ថុដែលជាកម្មវត្ថុ ត្រូវបានកាន់កាប់ដោយតតិយជន

១- ក្នុងករណីដែលតតិយជនកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ហើយតតិយជននោះមានករណីយកិច្ចត្រូវប្រគល់វត្ថុនោះឱ្យទៅកូនបំណុលនៃការអនុវត្ត ការអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុនេះ ត្រូវធ្វើតាមវិធីដែលតុលាការអនុវត្តរឹបអូសសិទ្ធិទាមទារឱ្យប្រគល់របស់កូនបំណុលនៃការអនុវត្តដែលមានចំពោះតតិយជននោះ ហើយចេញដីកាសម្រេចអនុញ្ញាតឱ្យម្ចាស់បំណុលនៃការអនុវត្ត អនុវត្តសិទ្ធិទាមទារនោះ ។

២- បញ្ញត្តិនៃកថាខណ្ឌទី ៣ និង ទី ៤ នៃមាត្រា ៤០២ (អត្ថន័យនៃការអនុវត្តចំពោះសិទ្ធិលើបំណុល និង តុលាការអនុវត្ត) មាត្រា ៤០៣ (ដីកាសម្រេចរឹបអូស) មាត្រា ៤០៥ (ការដាស់តឿនឱ្យកូនបំណុលទី ៣ ធ្វើសេចក្ដីថ្លែងការណ៍) មាត្រា ៤០៦ (ការប្រគល់លិខិតបញ្ជាក់សិទ្ធិលើបំណុល) ព្រមទាំងកថាខណ្ឌទី ១ ទី ២ និង ទី ៤ នៃមាត្រា ៤១០ (ការប្រមូលបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តដោយបង្ខំ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

(1) សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 170 និង បទប្បញ្ញត្តិស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 156 ។

(2) ក្នុងករណីដែលវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ត្រូវតតិយជនក្រៅពីភាគីដែលបានកំណត់នៅក្នុងលិខិតអនុវត្តនោះកាន់កាប់ ការអនុវត្តដោយបង្ខំនៃការប្រគល់ដោយផ្អែកលើលិខិតនៃកាតព្វកិច្ចនោះ មិនអាចធ្វើចំពោះតតិយជននោះបានទេ លើកលែងតែក្នុងករណីដែលលិខិតអនុវត្តមានអានុភាពទៅលើតតិយជននោះ (ដែលមានចែងក្នុងមាត្រា ៣៥១ (វិសាលភាពនៃអ្នកដែលអាចអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច **ខ** ឬ **គ** ឬ កថាខណ្ឌទី ២) ។ មាត្រានេះចែងថា ទោះបីជាករណីដូចខាងលើនេះក៏ដោយ បើតតិយជនកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ មានករណីយកិច្ចត្រូវប្រគល់វត្ថុនោះឱ្យទៅកូនបំណុលនៃការអនុវត្ត ការអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុនេះ អាចធ្វើទៅតាមវិធីរឹបអូសសិទ្ធិទាមទារឱ្យប្រគល់របស់កូនបំណុលនៃការអនុវត្តដែលមានចំពោះតតិយជននោះ ហើយអនុញ្ញាតឱ្យម្ចាស់បំណុលនៃការអនុវត្ត អនុវត្តនូវសិទ្ធិទាមទារឱ្យប្រគល់នោះ ។

(3) ទោះបីជាមានការទាមទារពីម្ចាស់បំណុលនៃការអនុវត្តក៏ដោយ ប្រសិនបើតតិយជនបដិសេធមិនព្រមប្រគល់ឱ្យទេ ម្ចាស់បំណុលនៃការអនុវត្តនោះអាចធ្វើបណ្តឹងទាមទារឱ្យប្រគល់វត្ថុ ដោយយកតតិយជននោះធ្វើជាចុងចម្លើយ (សូមមើលមាត្រា ៤១២ (បណ្តឹងទាមទារប្រមូលបំណុល)) ហើយអនុវត្តដោយបង្ខំ តាមបញ្ញត្តិនៃមាត្រា ៥២៤ (ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ជាអាទិ៍) និង មាត្រា ៥២៥ (ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ) បាន ដោយយកសាលក្រម ឬ សាលដីកាដែលឱ្យម្ចាស់បំណុលឈ្នះក្តីនោះ ធ្វើជាលិខិតអនុវត្ត ។

Civil Execution Act (Japan)
**Article 170** (Compulsory execution of delivery where a third person possesses the subject matter)
1. Where a third person possesses the subject matter of compulsory execution and such third person is obliged to deliver such subject matter to the obligor, compulsory execution of delivery shall be carried out by the execution court's issuing an order to attach the obligor's claim right to delivery against the third person and to permit the obligee to exercise the claim right.
2. The provisions of Article 144, 145, 147, 148, 155, paragraphs 1 and 2, and Article 158 shall apply *mutatis mutandis* to compulsory execution as referred to in the preceding paragraph.

## **មាត្រា ៥២៧.-** ការអនុវត្តជំនួស

១- ក្នុងករណីដែលកាតព្វកិច្ចមានខ្លឹមសារដែលឱ្យធ្វើសកម្មភាពណាមួយ ហើយអាចឱ្យតតិយជនធ្វើជំនួសកូនបំណុលបាន ការអនុវត្តដោយបង្ខំចំពោះកាតព្វកិច្ចនោះ ត្រូវធ្វើតាមវិធីដែលតុលាការអនុវត្តចេញដីកាសម្រេចអនុញ្ញាតឱ្យម្ចាស់បំណុលនៃការអនុវត្ត ឱ្យតតិយជនបំពេញសកម្មភាពនោះជំនួស ដោយប្រើសោហ៊ុយរបស់កូនបំណុលនៃការអនុវត្ត តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត។

២- តុលាការអនុវត្តដែលបញ្ញត្តិនៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ គឺតុលាការដែលបានកំណត់នៅក្នុងចំណុចនីមួយៗ

តាមការបែងចែកនៃលិខិតអនុវត្តដែលបានកំណត់ក្នុងចំណុច **ក** ឬ ចំណុច **គ** កថាខណ្ឌទី ៣ នៃមាត្រា ៣៦៣ (បណ្ដឹងតវ៉ាចំពោះការទាមទារ) នៃក្រមនេះ ។

៣- បើចេញដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តត្រូវសួរកូនបំណុលនៃការអនុវត្ត ។

៤- បើចេញដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តអាចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត បង់សោហ៊ុយដែលត្រូវការចាំបាច់សម្រាប់បំពេញសកម្មភាពដែលបានកំណត់ក្នុងដីកាសម្រេចនោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្តជាមុនបានតាមពាក្យសុំ ។

៥- ចំពោះសេចក្ដីសម្រេចអំពីពាក្យសុំឱ្យអនុវត្តដោយបង្ខំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ អំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

៦- បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអនុវត្តដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៧- បញ្ញត្តិចាប់ពីកថាខណ្ឌទី ១ រហូតដល់កថាខណ្ឌទី ៦ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកាតព្វកិច្ចមានខ្លឹមសារដែលមិនឱ្យធ្វើសកម្មភាពណាមួយ ហើយម្ចាស់បំណុលនៃការអនុវត្តទាមទារឱ្យដកយកចេញនូវលទ្ធផលនៃសកម្មភាពផ្ទុយនឹងករណីយកិច្ចមិនត្រូវធ្វើសកម្មភាព ទាមទារឱ្យបង្កើតការសាងសង់ ដើម្បីបង្ការសកម្មភាពផ្ទុយនោះ ឬ ទាមទារមធ្យោបាយផ្សេងទៀតដែលសមរម្យ ដោយប្រើសោហ៊ុយរបស់កូនបំណុលនៃការអនុវត្ត ។

(កំណត់)

(1) សូមមើលច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 171 ។

(2) ករណីយកិច្ចដែលត្រូវធ្វើសកម្មភាព ដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំតាមមាត្រានេះ គឺជាករណីកិច្ចដែលអាចសម្រេចនូវគោលបំណងបាន តាមខ្លឹមសារនៃករណីយកិច្ចនោះ ទោះបីជាសកម្មភាពនោះបានធ្វើឡើងដោយតតិយជនដែលមិនមែនជាកូនបំណុលនៃការអនុវត្តសាមីក៏ដោយ ។ ឧទាហរណ៍ជាក់ច្បាស់ដូចជា ករណីយកិច្ចត្រូវរើរុះអាគារ ឬ សំណង់ដែលនៅលើដី ជាដើម ។ ចំពោះករណីយកិច្ចត្រូវធ្វើសកម្មភាពដែលមិនអាចសម្រេចនូវគោលបំណងបាន បើកូនបំណុលសាមីមិនបានធ្វើទេនោះ ឧទាហរណ៍ ដូចជាករណីយកិច្ចដែលតួកុន ឬ ល្ខោនត្រូវឡើងលើឆាកដើរតួ ករណីយកិច្ចដែលអ្នកគូររូបត្រូវគូរ ជាដើម ការអនុវត្តដោយបង្ខំចំពោះករណីយកិច្ចទាំងនេះ មានតែធ្វើដោយការបង្ខំដោយប្រយោល តាមបញ្ញត្តិនៃមាត្រា ៥២៨ (វិធានបង្ខំដោយប្រយោល) ។

(3) ការអនុវត្តដោយបង្ខំដោយលិខិតអនុវត្តដែលបង្គាប់មិនឱ្យធ្វើសកម្មភាព ត្រូវធ្វើតាមវិធីអនុវត្តបង្ខំដោយប្រយោល ដើម្បីបង្ខំឱ្យគោរពករណីយកិច្ចដែលមិនឱ្យធ្វើសកម្មភាពនោះ (មាត្រា ៥២៨ (វិធានបង្ខំដោយប្រយោល)) ។ ប៉ុន្តែ ក្នុងករណីដែលបង្គាប់ឱ្យរើលទ្ធផលនៃសកម្មភាពផ្ទុយនឹងករណីយកិច្ច ដែលត្រូវបានធ្វើរួចហើយ ហើយលទ្ធផលនៃ

សកម្មភាពនោះនៅសេសសល់ (ឧទាហរណ៍ ករណីល្មើសនឹងការហាមធ្វើសំណង់នៅលើដី តែបានសាងសង់ហើយ) ឬ ករណីដែលបង្គាប់ឱ្យធ្វើអ្វីមួយដើម្បីការពារកុំឱ្យមានសកម្មភាពផ្ទុយទៀតនាពេលអនាគត (ឧទាហរណ៍ ករណីដែលបង្គាប់ឱ្យធ្វើសំណង់ដើម្បីការពារសម្លេងកុំឱ្យឮខ្លាំងលើសកម្រិត ជាដើម) អាចអនុវត្តតាមវិធីអនុវត្តជំនួស ដែលមានបញ្ញត្តិក្នុងកថាខណ្ឌទី ៧ នៃមាត្រានេះ ។

(4) ចំពោះការអនុវត្តដោយបង្ខំនៃករណីយកិច្ចដែលត្រូវបង្ហាញឆន្ទៈវិញ មានបញ្ញត្តិនៅក្នុងមាត្រា ៥២៩ (ការចាត់ទុកថាបានបង្ហាញឆន្ទៈ) ហើយពុំមាននៅក្នុងចំណោមកម្មវត្ថុនៃមាត្រានេះទេ ។

<u>ក្រមរដ្ឋប្បវេណី (កម្ពុជា)</u>

**មាត្រា ៣៩៦** (ដីកាបង្គាប់ឱ្យអនុវត្តកាតព្វកិច្ចដោយតុលាការ)

ក្នុងករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្តទេ ម្ចាស់បំណុលអាចទាមទារឱ្យអនុវត្តកាតព្វកិច្ចដោយបង្ខំបាន លើកលែងតែករណីដែលកាតព្វកិច្ចមានលក្ខណៈមិនអាចអនុវត្តដោយបង្ខំបាន ។ នីតិវិធីនៃការអនុវត្តដោយបង្ខំ ត្រូវអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណី ។

<u>Civil Execution Act (Japan)</u>

**Article 171** (Compulsory execution of obligation-duty to act or forbear from an act)

1. Compulsory execution concerning a claim provided in paragraph 2 main sentence or paragraph 3 or Article 414 of the Civil Cod shall be carried out by the execution court's rendering a ruling according to the provisions of the Civil Code.
2. The execution court referred to in the preceding paragraph shall be the court provided for in accordance with the distinctions concerning obligation title mentioned in item i or ii of paragraph 2 of Article 33.
3. Where the execution court renders a ruling under paragraph 1, the execution court must interrogate the obligor.
4. Where the execution court renders a ruling under paragraph 1, the execution court may, upon motion, order the obligor to advance the costs necessary to perform the act referred to in the ruling to the obligee.
5. A kōkoku-appeal concerning execution may be filed against a decision on a motion for compulsory execution under paragraph 1 or a motion of the preceding paragraph.
6. The provisions of Article 6, paragraph 2 shall apply *mutatis mutandis* to cases where a ruling in accordance with paragraph 1 is to be executed.

## **មាត្រា ៥២៨.-** វិធានបង្ខំដោយប្រយោល

១- ការអនុវត្តដោយបង្ខំចំពោះកាតព្វកិច្ចដែលមានគោលបំណងឱ្យធ្វើ ឬ មិនឱ្យធ្វើសកម្មភាពណាមួយ ក៏អាចធ្វើបានតាមវិធីដែលតុលាការអនុវត្តចេញដីកាសម្រេចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត បង់នូវចំនួនទឹកប្រាក់ជាកំណត់ដែលទទួលស្គាល់ថាសមរម្យដើម្បីធានាការអនុវត្តកាតព្វកិច្ច ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ស្របទៅតាមអំឡុងពេលនៃការយឺតយ៉ាវ ឬ កំណត់អំឡុងពេលដែលទទួលស្គាល់ថាសមរម្យដើម្បីអនុវត្តកាតព្វកិច្ច ហើយបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត បង់នូវចំនួនទឹកប្រាក់ជាកំណត់ដែលទទួលស្គាល់ថាសមរម្យដើម្បីធានាការអនុវត្តកាតព្វកិច្ច ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ដោយភ្លាមៗ បើពុំបានអនុវត្តក្នុងអំឡុងពេលនោះ ។

២- តុលាការអនុវត្តដែលបញ្ញត្តិនៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ គឺតុលាការដែលកំណត់នៅក្នុងចំណុចនីមួយៗ តាមការបែងចែកនៃលិខិតអនុវត្តដែលបានកំណត់ក្នុងចំណុច **ក** ឬ ចំណុច **គ** កថាខណ្ឌទី ៣ នៃមាត្រា ៣៦៣ (បណ្ដឹងតវ៉ាចំពោះ

ការទាមទារ) នៃក្រមនេះ ។

៣- បើមានការផ្លាស់ប្តូរស្ថានភាព តុលាការអនុវត្តអាចផ្លាស់ប្តូរដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ឬ របស់កូនបំណុលនៃការអនុវត្តបាន ។

៤- បើចេញដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ៣ ខាងលើនេះ តុលាការអនុវត្តត្រូវសួរភាគីម្ខាងទៀតនៃអ្នកដាក់ពាក្យសុំ ។

៥- ក្នុងករណីដែលមានការបង់ប្រាក់ដែលត្រូវបានបង្គាប់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ បើចំនួនទឹកប្រាក់នៃការខូចខាតដែលបានកើតឡើងដោយការមិនអនុវត្តកាតព្វកិច្ច លើសចំនួនទឹកប្រាក់ដែលបានបង់នោះ ម្ចាស់បំណុលនៃការអនុវត្តអាចទាមទារសំណងការខូចខាតចំពោះចំនួនទឹកប្រាក់ដែលលើសនោះបាន ។

៦- ចំពោះសេចក្តីសម្រេចអំពីពាក្យសុំឱ្យអនុវត្តដោយបង្ខំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ អំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

(កំណត់)

(1) សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 172 ។

(2) កម្មវត្ថុនៃការអនុវត្តដោយបង្ខំតាមមាត្រានេះ មានករណីយកិច្ចដែលមានខ្លឹមសារឱ្យធ្វើសកម្មភាព ឬ មិនឱ្យធ្វើសកម្មភាព យ៉ាងទូលាយ លើកលែងតែករណីយកិច្ចត្រូវបង្ហាញឆន្ទៈ (សូមមើលមាត្រា ៥២៩ (ការចាត់ទុកថាបានបង្ហាញឆន្ទៈ)) ។ ទោះបីជា ក្នុងករណីដែលអាចអនុវត្តជំនួសបាន (មាត្រា ៥២៧ (ការអនុវត្តជំនួស)) ក៏ដោយ ក៏អាចធ្វើការអនុវត្តបង្ខំដោយប្រយោល តាមបញ្ញត្តិនៃមាត្រានេះបានដែរ ដោយមិនចាំបាច់ប្រើមាត្រា ៥២៧ ទេ ។ ម្ចាស់បំណុលនៃការអនុវត្តអាចជ្រើសរើសយកតាមវិធីណាមួយក៏បាន នៅពេលដាក់ពាក្យសុំ (មាត្រា ៣៤៩ (របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ) កថាខណ្ឌទី ២ ចំណុច **គ** និង **ខ**) ។

(3) ពាក្យថា "ភាគីម្ខាងទៀតនៃអ្នកដាក់ពាក្យសុំ" នៃកថាខណ្ឌទី ៤ នៃមាត្រានេះ នៅក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តបានដាក់ពាក្យសុំ គឺចង្អុលទៅលើកូនបំណុលនៃការអនុវត្ត បើកូនបំណុលនៃការអនុវត្តជាអ្នកដាក់ពាក្យសុំវិញ គឺចង្អុលទៅលើម្ចាស់បំណុលនៃការអនុវត្ត ។

Civil Execution Act (Japan)
**Article 172** (Ibid)
1. Compulsory execution of an obligation-duty whose subject matter is an act or forbearance from action and which cannot be executed according to the provisions of paragraph 1 of the preceding Article shall be carried out by the execution court's ordering the obligor to pay a certain amount of money deemed reasonable to secure the performance of the obligation-duty to the obligee, either for delayed period, or immediately if the obligation-duty is not performed within a certain period deemed reasonable.
2. If circumstances have changed, the execution court may, upon motion, alter a ruling made in accordance with the provisions of the preceding paragraph.
3. Where the execution court renders a ruling in accordance with the provisions of the preceding two paragraphs, the execution court must interrogate the respondent to the motion.
4. Where a payment of money ordered in accordance with the provisions of paragraph 1 has been made, if the amount of damages incurred by nonperformance of an obligation-duty exceeds the paid amount, the obligee shall be prevented from claiming damages

for the excess.
5. A kōkoku-appeal concerning execution may be filed against a decision on a motion for compulsory execution under paragraph 1 or a motion under paragraph 2.
6. The provisions of paragraph 2 of the preceding Article shall apply *mutatis mutandis* to the execution court referred to in paragraph 1.

**មាត្រា ៥២៩.-** ការចាត់ទុកថាបានបង្ហាញឆន្ទៈ

១- បើសាលក្រម សាលដីកា ឬ ដីកាសម្រេចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្តបង្ហាញឆន្ទៈ បានចូលជាស្ថាពរហើយ ឬ បើលិខិតអនុវត្តដោយផ្អែកលើការផ្សះផ្សា ឬ ការទទួលស្គាល់ដែលមានខ្លឹមសារថា កូនបំណុលនៃការអនុវត្តត្រូវបង្ហាញឆន្ទៈ បានបង្កើតអានុភាពឡើង ត្រូវចាត់ទុកថា កូនបំណុលនៃការអនុវត្តបានបង្ហាញឆន្ទៈ នៅពេលនៃការចូលជាស្ថាពរ ឬ ការបង្កើតអានុភាពនោះ ។ ប៉ុន្តែ បើសិទ្ធិទាមទារឱ្យបង្ហាញឆន្ទៈនោះ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ឬ ពេលកំណត់មិនពិតប្រាកដ ត្រូវចាត់ទុកថា កូនបំណុលនៃការអនុវត្តនោះបានបង្ហាញឆន្ទៈ នៅពេលដែលរូបមន្តអនុវត្តត្រូវបានផ្តល់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) នៃក្រមនេះ ។ បើការបង្ហាញឆន្ទៈរបស់កូនបំណុលនៃការអនុវត្ត ត្រូវធ្វើដោយប្តូរជាមួយនឹងតាវកាលិកតប ត្រូវចាត់ទុកថា កូនបំណុលនៃការអនុវត្តនោះបានបង្ហាញឆន្ទៈ នៅពេលដែលរូបមន្តអនុវត្តត្រូវបានផ្តល់ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រានេះ ។

២- ក្នុងករណីដែលការបង្ហាញឆន្ទៈរបស់កូនបំណុលនៃការអនុវត្ត ត្រូវធ្វើដោយប្តូរជាមួយនឹងតាវកាលិកតបរបស់ម្ចាស់បំណុលនៃការអនុវត្ត រូបមន្តអនុវត្តអាចផ្តល់បាន លុះត្រាតែម្ចាស់បំណុលនៃការអនុវត្តបានដាក់លិខិតបញ្ជាក់ថា ខ្លួនបានផ្តល់ ឬ បានស្នើផ្តល់តាវកាលិកតបនោះហើយ ។

(កំណត់)

(1) សូមមើលច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 173 ។

(2) តាមឧត្តមគតិ ការអនុវត្តដោយបង្ខំនៃលិខិតអនុវត្តដែលបង្គាប់ឱ្យកូនបំណុលនៃការអនុវត្តបង្ហាញឆន្ទៈ ត្រូវចាត់ទុកថា អ្នកនោះបានបង្ហាញឆន្ទៈបន្ទាប់ពីពេលវេលាដែលមានកំណត់មួយបានកន្លងផុតទៅ ។ ប្រសិទ្ធិភាពនៃការចាត់ទុកនេះកើតមានឡើងខុសគ្នាទៅតាមប្រភេទនៃលិខិតអនុវត្ត ជាគោលការណ៍ ចំពោះសាលក្រម ឬ ដីកាសម្រេច គឺនៅពេលដែលសាលក្រម ឬ ដីកាសម្រេចនោះបានចូលជាស្ថាពរ ចំពោះការផ្សះផ្សា ឬ ការទទួលស្គាល់វិញ គឺពេលដែលការផ្សះផ្សា ឬ ការទទួលស្គាល់នោះទទួលបាននូវលទ្ធផល ។

(3) បើសិទ្ធិទាមទារឱ្យបង្ហាញឆន្ទៈនោះមានកំណត់ល័ក្ខខ័ណ្ឌ ឬ ភ្ជាប់នឹងពេលកំណត់មិនពិតប្រាកដវិញ មិនគ្រាន់តែតម្រូវឱ្យស្ថាពរនៃការសម្រេចសេចក្តី ឬ ការទទួលបានលទ្ធផលនៃលិខិតអនុវត្តទេ គឺទាល់តែមានការបញ្ជាក់អំពីរឿងហេតុនៃការផ្តល់រូបមន្តអនុវត្តពិសេស ទើបចាត់ទុកថាបានបង្ហាញឆន្ទៈ ។ម្យ៉ាងទៀត ចំពោះករណីដែលសិទ្ធិទាមទារឱ្យបង្ហាញឆន្ទៈមានពេលកំណត់ពិតប្រាកដ (ក្នុងករណីដែលលិខិតអនុវត្តមានខ្លឹមសារថា "ត្រូវបង្ហាញឆន្ទៈត្រឹមថ្ងៃទី xx ខែ xx ឆ្នាំ xxxx") នោះបើពេលកំណត់ត្រូវអនុវត្ត (បង្ហាញឆន្ទៈ) មិនទាន់ដល់

នៅពេលដែលបង្កើតលិខិតអនុវត្តនោះ ត្រូវចាត់ទុកថា មានការបង្ហាញឆន្ទៈ ដោយការមកដល់នៃពេលកំណត់នោះ ។

(4) តាមធម្មតា ការអនុវត្ត ឬ ការដាក់តាវកាលិកតប មិនមែនជាល័ក្ខខ័ណ្ឌនៃការផ្ដល់រូបមន្តអនុវត្តទេ គឺជាល័ក្ខខ័ណ្ឌចាប់ផ្ដើមអនុវត្ត ដូច្នេះស្ថាប័នអនុវត្តគ្រាន់តែស៊ើបអង្កេតទៅគ្រប់គ្រាន់ហើយ (មាត្រា ៣៦១ (ល័ក្ខខ័ណ្ឌនៃការចាប់ផ្ដើមអនុវត្តដែលស្ថាប័នអនុវត្តត្រូវស្រាវជ្រាវ)) ។ ក៏ប៉ុន្តែ ក្នុងករណីនៃលិខិតអនុវត្តដែលបង្គាប់ឱ្យបង្ហាញឆន្ទៈ ការអនុវត្តនោះត្រូវបានចាត់ទុកជាការបង្ហាញឆន្ទៈនោះ គឺជាឧត្តមគតិមួយ តាមការពិត អត់មាននីតិវិធីអ្វីដែលត្រូវធ្វើទេ ហេតុនេះហើយ យកការអនុវត្ត ឬ ការដាក់តាវកាលិកតប មកជាល័ក្ខខ័ណ្ឌនៃការផ្ដល់រូបមន្តអនុវត្តនេះ ហើយត្រូវស៊ើបអង្កេត មុននឹងប្រសិទ្ធិភាពនៃការចាត់ទុកនោះកើតមានឡើង (កថាខណ្ឌទី ២ នៃមាត្រានេះ) ។

(5) នៅប្រទេសជប៉ុន ឧទាហរណ៍គំរូនៃការអនុវត្តដោយបង្ខំតាមការចាត់ទុកនៃការបង្ហាញឆន្ទៈនោះ គឺ ករណីនៃលិខិតអនុវត្តដែលមានខ្លឹមសារស្ដីពីនីតិវិធីនៃការដាក់ពាក្យសុំចុះបញ្ជី ។ អ្នកទិញអចលនវត្ថុបានឈ្នះក្ដីចុងចម្លើយដែលជាអ្នកលក់ ក្នុងបណ្ដឹងទាមទារឱ្យធ្វើនីតិវិធីដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិ ហើយពេលដែលសាលក្រមនោះបានចូលជាស្ថាពរហើយ គឺជាឧទាហរណ៍នៃករណីរបស់បញ្ញត្តិនេះ ។ នៅប្រទេសជប៉ុន តាមច្បាប់ចុះបញ្ជីអចលនវត្ថុ ការដាក់ពាក្យសុំចុះបញ្ជី គឺត្រូវធ្វើឡើងដោយអ្នកមានសិទ្ធិដាក់ពាក្យសុំចុះបញ្ជី (គឺជាអ្នកទិញនៅក្នុងឧទាហរណ៍ខាងលើនេះ) និង អ្នកមានកាតព្វកិច្ចចុះបញ្ជី (គឺជាអ្នកលក់ នៅក្នុងឧទាហរណ៍នេះ) ត្រូវដាក់ពាក្យចុះបញ្ជី (បង្ហាញឆន្ទៈ) ព្រមគ្នា ដើម្បីផ្ទេរឈ្មោះទៅមន្ត្រីចុះបញ្ជី ហើយមន្ត្រីចុះបញ្ជីនេះនឹងចុះក្នុងបញ្ជី (ចុះបញ្ជីផ្ទេរកម្មសិទ្ធិ) ។ ប្រព័ន្ធនេះហៅថា ប្រព័ន្ធចុះបញ្ជីរួម ។ ក្នុងឧទាហរណ៍ខាងលើនេះ ចុងចម្លើយ (អ្នកលក់) ពេលណាសាលក្រមបង្គាប់ឱ្យធ្វើនីតិវិធីដាក់ពាក្យចុះបញ្ជីផ្ទេរកម្មសិទ្ធិបានចូលជាស្ថាពរហើយ ត្រូវចាត់ទុកថា កូនក្ដីបានធ្វើសកម្មភាពដាក់ពាក្យសុំហើយ ហេតុនេះហើយ ដើមចោទ (អ្នកទិញ) គ្រាន់តែដាក់ពាក្យចុះបញ្ជីតែខ្លួនឯង និង ដាក់សាលក្រមដែលបានចូលជាស្ថាពរហើយនោះទៅឱ្យមន្ត្រីចុះបញ្ជីទៅ នឹងអាចចុះបញ្ជីផ្ទេរកម្មសិទ្ធិហើយ ។ ម្យ៉ាងទៀត ករណីដែលយកមកអនុវត្តតាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រានេះ មានឧទាហរណ៍ដូចជាករណីដែលលិខិតអនុវត្តបង្គាប់ឱ្យធ្វើនីតិវិធីដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិ ដោយប្ដូរជាមួយនឹងការបង់លុយថ្លៃអចលនវត្ថុ ។

<u>Civil Execution Act (Japan)</u>
**Article 173** (Fiction of declaration of intention)
1. If a judgment or any other decision ordering an obligor to declare his intention becomes final and binding, or a compromise, acknowledgment or conciliation ordering the obligor to declare his intention is accomplished, the obligor shall be deemed to have declare his intention at the time the said judgment or other decision became final and binding or at the time of accomplishment of the said compromise, acknowledgment or conciliation; provided that the obligor shall be deemed to have declared his intention, in cases where the declaration of intention of the obligor depends on the future occurrence of a fact to be proved by the obligee, at the time the execution clause is issued in accordance with the provisions of paragraph 1 of Article 27, and in cases where the declaration of intention of the obligor depends on the counter-performance or non-existence of the performance or any other fact to be proved by the obligor, at the time the execution clause is issued in accordance with the provisions of the next paragraph 3, it shall be deemed that the obligor declared his intention.
2. In cases where the declaration of intention of the obligor depends on a counter-performance, the execution clause may be issued only when the obligee submits a document showing that the counter-performance or a tender thereof has been made.
3. In cases where the declaration on intention of the obligor depends on the non-existence of a fact to be proved by the obligor, if a motion for issuance of the execution clause has been made, the court clerk shall demand the obligor submit a document proving the

fact within the designated period and may issue the execution clause only when the obligor fails to submit the document.

# គន្ថីទី ៧ ការចាត់ចែងរក្សាការពារ

## ជំពូកទី ១ បទប្បញ្ញត្តិទូទៅ

**មាត្រា ៥៣០.-** គោលគំនិត

ប្រសិនបើមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬ ប្រសិនបើមានការបារម្ភថា នឹងមានការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ បុគ្គលដែលមានបំណងចង់ការពារសិទ្ធិរបស់ខ្លួន អាចទាមទារការចាត់ចែងរក្សាការពារ តាមបញ្ញត្តិនៃគន្ថីនេះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង ។

(កំណត់)

(1) សូមមើលច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 1 ។

(2) ការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយផ្អែកលើលិខិតបញ្ជាក់កាតព្វកិច្ច ដូចជាសាលក្រមស្ថាពរ ជាអាទិ៍ ហេតុនេះហើយ ដើម្បីឱ្យបានសាលក្រមនេះ ត្រូវដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី ថែមទាំងត្រូវការពេលវេលាច្រើន ។ ក៏ប៉ុន្តែ មុនពេលទទួលសាលក្រមនេះ កូនបំណុលនៃការអនុវត្ត អាចលាក់ ឬ ផ្ទេរទ្រព្យសម្បត្តិរបស់ខ្លួន ដែលជាហេតុធ្វើឱ្យមិនអាច ឬ ធ្វើឱ្យមានការពិបាកនឹងធ្វើការអនុវត្តដោយបង្ខំនៅពេលក្រោយបាន ឬមួយក៏ភាគីណាម្ខាងអាចទទួលនូវការខូចខាតធ្ងន់ ឬ អាចទទួលនូវគ្រោះថ្នាក់ធ្ងន់ដល់ឋានៈរបស់ខ្លួន ដោយសារវិវាទពាក់ព័ន្ធនឹងទំនាក់ទំនងនៃសិទ្ធិ រវាងភាគីទាំងសងខាង ។ ក្នុងករណីនេះ បុគ្គលដែលចង់ការពារសិទ្ធិរបស់ខ្លួននោះ អាចទាមទារឱ្យចាត់ចែងរក្សាការពារសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តរបស់ខ្លួនបាន ។

Civil Provisional Relief Act (Japan)
**Article 1** (Tenor)
The provision of this Act shall govern the provisional attachment of property, and provisional disposition to establish a provisional state of affairs relating to a right in the principal case of civil action (hereinafter referred to jointly as "civil provisional relief"), except as otherwise provided by other laws and ordinances, in order to secure the future execution of a right in the principal case of a civil action.

**មាត្រា ៥៣១.-** ប្រភេទនៃការចាត់ចែងរក្សាការពារ

ការចាត់ចែងរក្សាការពារសំដៅទៅលើការចាត់ចែងនីមួយៗ ដែលមានខ្លឹមសារដូចកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

**ក-** ការរឹបអូសជាបណ្តោះអាសន្ន : ការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បី

រក្សាការពារការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ។

ខ- ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ : ការចាត់ចែងដែលរក្សាទុកនូវស្ថានភាពបច្ចុប្បន្ន នៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ ។

គ- ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន : ការចាត់ចែងដែលកំណត់ស្ថានភាពជាបណ្ដោះអាសន្នរហូតដល់សាលក្រម ឬ សាលដីកាចូលជាស្ថាពរ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ ។

( កំណត់ )

មាត្រានេះចែងអំពីខ្លឹមសារនៃការចាត់ចែងការរក្សាការពារទាំង ៣ ប្រភេទ តាមបញ្ញត្តិនៃច្បាប់ស្ដីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 1 មាត្រា 20 កថាខណ្ឌទី 1 និង កថាខណ្ឌទី 2 នៃមាត្រា 23 ។ មាត្រានេះមានទំនាក់ទំនងជាមួយនឹងមាត្រា ៥៤៥ (ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន) និង មាត្រា ៥៤៨ (ភាពចាំបាច់នៃដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ជាអាទិ៍) ។

ការរឹបអូសជាបណ្ដោះអាសន្ន និង ការចាត់ចែងជាបណ្ដោះអាសន្ន ត្រូវបានចែកទៅតាមលក្ខណៈនៃសិទ្ធិដែលត្រូវបានរក្សាការពារនោះ គឺសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ឬ ក្រៅពីប្រាក់ ។ ប៉ុន្តែ បើមើលខ្លឹមសារវិញ ការរឹបអូសជាបណ្ដោះអាសន្ន និង ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ មានចំណុចរួមមួយ គឺការចាត់ចែងទាំងពីរនេះ ធ្វើឡើងដើម្បីជៀសវាងការលំបាក ឬ អលទ្ធភាពក្នុងការអនុវត្តដោយបង្ខំនាអនាគត ។ ឧទាហរណ៍នៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទមានដូចជា ការចាត់ចែងជាបណ្ដោះអាសន្នដែលហាមការផ្ទេរការកាន់កាប់ចលនវត្ថុណាមួយ (ឬ ដែលអាជ្ញាសាលាគ្រប់គ្រងចលនវត្ថុនោះ) ដើម្បីរក្សាការពារនូវសិទ្ធិទាមទារឱ្យប្រគល់នូវចលនវត្ថុនោះ ។

ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន គឺការចាត់ចែងដែលធ្វើឡើង ដើម្បីជៀសវាងនូវបញ្ហាផ្សេងៗ ក្រៅពីការលំបាក ឬ អលទ្ធភាពក្នុងការអនុវត្តដោយបង្ខំនាអនាគត ក្នុងចំណោមការខូចខាត ឬ ការបាត់ប្រយោជន៍ដែលមកពីការយឺតយ៉ាវក្នុងការសម្រេចទំនាក់ទំនងសិទ្ធិជាស្ថាពរ ។ ឧទាហរណ៍ដូចជាការចាត់ចែងជាបណ្ដោះអាសន្នដែលរក្សាការពារឋានៈជាកម្មករ ឬ ការចាត់ចែងជាបណ្ដោះអាសន្នដែលបង្គាប់ឱ្យបង់ប្រាក់ខែជាបណ្ដោះអាសន្ន ក្នុងករណីដែលមានវិវាទអំពីសុពលភាពនៃការដេញកម្មករនោះ ។ ការចាត់ចែងជាបណ្ដោះអាសន្នដែលបង្គាប់ឱ្យបង់ប្រាក់ខែជាបណ្ដោះអាសន្ននេះ គឺជាការចាត់ចែងរក្សាការពារ ដើម្បីឱ្យទទួលនូវការស្កប់ចិត្តជាបណ្ដោះអាសន្នចំពោះសិទ្ធិដែលត្រូវបានរក្សាការពារ ហេតុនេះហើយបានជាគេហៅថា ការចាត់ចែងជាបណ្ដោះអាសន្នដើម្បីស្កប់ចិត្ត ។

<u>Civil Provisional Relief Act (Japan)</u>
**Article 1** (Tenor) > see the note for the preceding Article
**Article 20** (Necessity of Orders of Provisional Attachment)
1. An order of provisional attachment may be issued when there is a fear that future compulsory execution with respect to a monetary obligation-right would be impossible or that there would be considerable difficulty in enforcing such right.
2. An order of provisional attachment may be issued even if the obligation-right referred to in the preceding paragraph is subject to a condition or not yet due.
**Article 23** (Necessity of Orders of Provisional Disposition) (excerpt)
1. An order of provisional disposition of subject-matter in dispute may be issued when there is a fear that realization of the obligee's right would be impossible or there would be considerable difficulty in enforcing such right due to a change in circumstances.
2. An order of provisional disposition may be issued to establish provisionally the state of affairs of the obligee when it is necessary to avert significant damage or imminent risk to the obligee with respect to the right at issue.

**មាត្រា ៥៣២.–** ស្ថាប័នចាត់ចែងរក្សាការពារជាបណ្ដោះអាសន្ន

១- ដីកាសម្រេចក្នុងការចាត់ចែងរក្សាការពារ ត្រូវធ្វើឡើងដោយតុលាការតាមពាក្យសុំ ។

២- ការអនុវត្តការចាត់ចែងរក្សាការពារ ត្រូវធ្វើឡើងដោយតុលាការ ឬ អាជ្ញាសាលាតាមពាក្យសុំ ។

៣- តុលាការដែលត្រូវអនុវត្តការចាត់ចែងរក្សាការពារ តាមបញ្ញត្តិនៃគន្លីនេះ ត្រូវហៅថា តុលាការអនុវត្តការរក្សាការពារ ។

៤- បញ្ញត្តិនៃកថាខណ្ឌទី ៤ នៃមាត្រា ៣៣៦ (ស្ថាប័នអនុវត្ត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តការចាត់ចែងរក្សាការពារ ដែលធ្វើឡើងដោយអាជ្ញាសាលា ។

(កំណត់)

មាត្រានេះត្រូវនឹងមាត្រា 2 នៃច្បាប់ស្ដីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។ ចំពោះខ្លឹមសារវិញ សូមមើលមាត្រា ៣៣៦ (ស្ថាប័នអនុវត្ត) និង កំណត់នៃមាត្រាដដែលនេះ ។

ប្រសិនបើបណ្ដឹងអំពីអង្គសេចក្ដីកំពុងចាត់ការនៅតុលាការនៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ អាចមានករណីដែលសាលាឧទ្ធរណ៍អនុវត្តការចាត់ចែងរក្សាការពារ ហេតុដូច្នេះ កថាខណ្ឌទី ៣ មិនកំណត់ឱ្យតែសាលាដំបូងជាតុលាការអនុវត្តការរក្សាការពារទេ ។

<u>Civil Provisional Relief Act (Japan)</u>
**Article 2** (Execution Authorities and Court of Provisional Relief)
1. The court may, upon the motion of a party, order civil provisional relief (hereinafter referred to as "order of provisional relief").
2. Civil provisional relief may, upon the motion of a party, be executed by either a court or an execution officer (hereinafter referred to as "execution of provisional relief").
3. In cases where an execution of provisional relief is to be enforced by a court, the court of execution shall be the court which is authorized under this Act to execute it; in cases where executorial disposition of provisional relief is to be enforced by an execution officer, the court of execution shall be the district court to which the execution officer is attached.

**មាត្រា ៥៣៣.–** សមត្ថកិច្ចផ្ដាច់មុខ

សមត្ថកិច្ចរបស់តុលាការដែលបានកំណត់នៅក្នុងគន្ថីនេះ គឺជាសមត្ថកិច្ចផ្តាច់មុខ ។

(កំណត់)

មាត្រានេះត្រូវនឹងមាត្រា 6 នៃច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។ ការចេញដីកាសម្រេចរក្សាការពារ (មាត្រា ៥៤៥ (ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន)) និង ការអនុវត្តការរក្សាការពារ មានភាពចាំបាច់ត្រូវធ្វើជាបន្ទាន់ ហេតុដូច្នេះ មាត្រានេះមិនអនុញ្ញាតឱ្យភាគីផ្លាស់ប្តូរសមត្ថកិច្ចដោយការព្រមព្រៀងទេ ។ មាត្រានេះមានអត្ថន័យដូចគ្នានឹងមាត្រា ៣៤៦ (សមត្ថកិច្ចផ្តាច់មុខ) ។

Civil Provisional Relief Act (Japan)
**Article 6** (Exclusive Jurisdiction)
The jurisdiction of the court provided for under this Act shall be exclusive.

**មាត្រា ៥៣៤.-** របៀបដាក់ពាក្យសុំ

ពាក្យសុំដែលបានកំណត់ខាងក្រោមនេះ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ :

**ក-** ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ។

**ខ-** ពាក្យបណ្តឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ។

**គ-** ពាក្យសុំតវ៉ាចំពោះការរក្សាការពារ ។

**ឃ-** ពាក្យសុំឱ្យលុបចោលដីកាសម្រេចរក្សាការពារ ។

**ង-** ពាក្យបណ្តឹងជំទាស់ដែលបានកំណត់នៅក្នុងមាត្រា ៥៦១ (បណ្តឹងជំទាស់) នៃក្រមនេះ ។

**ច-** ពាក្យសុំឱ្យអនុវត្តការរក្សាការពារ ។

(កំណត់)

មាត្រានេះត្រូវនឹងមាត្រា ១ នៃបទប្បញ្ញត្តិស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។ បញ្ញត្តិនេះតម្រូវឱ្យដាក់ពាក្យដែលជាមូលដ្ឋានក្នុងនីតិវិធីនៃការចាត់ចែងរក្សាការពារជាលាយលក្ខណ៍អក្សរ ដើម្បីធានាភាពច្បាស់លាស់ ។

**មាត្រា ៥៣៥.-** ការសម្រេចសេចក្តីចំពោះនីតិវិធីនៃការរក្សាការពារ ជាអាទិ៍

១- ការសម្រេចសេចក្តីដែលទាក់ទងនឹងនីតិវិធីនៃដីកាសម្រេចរក្សាការពារ និង នីតិវិធីដែលតុលាការធ្វើចំពោះការអនុវត្តរក្សាការពារ ត្រូវធ្វើឡើងដោយដីកាសម្រេច ។

២- បើយល់ឃើញថាចាំបាច់ នៅពេលចាត់ចែងធ្វើការអនុវត្ត តុលាការអនុវត្តការរក្សាការពារ អាចសួរជនដែលមានផលប្រយោជន៍ពាក់ព័ន្ធ ឬ ជនដែលពាក់ព័ន្ធផ្សេងទៀតបាន ។

៣- បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសាលាដំបូងត្រូវសម្រេចសេចក្តីអំពីឧបាស្រ័យចំពោះការចាត់ចែងការអនុវត្ត ដែលធ្វើឡើងដោយអាជ្ញាសាលា ។

(កំណត់)

ជាទូទៅ បញ្ញត្តិនេះចែងដូចគ្នានឹងមាត្រា ៣៣៧ (ការសម្រេចសេចក្តីរបស់តុលាការអនុវត្ត ជាអាទិ៍) ។

កថាខណ្ឌទី ១ ចែងដូចគ្នានឹងមាត្រា 3 នៃច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុនដែរ ។ ដោយសារនីតិវិធីនៃការចាត់ចែងរក្សាការពារត្រូវធ្វើឱ្យបានឆាប់រហ័ស រាល់សេចក្តីសម្រេចត្រូវធ្វើឡើងដោយដីកាសម្រេច ។

Civil Provisional Relief Act (Japan)
**Article 3** (Discretionary Oral Argument)
A decision with respect to proceedings of civil provisional relief may be rendered without hearing oral argument.

## មាត្រា ៥៣៦.- ការផ្តល់នូវប្រាតិភោគ

ដើម្បីដាក់ប្រាតិភោគតាមបញ្ញត្តិនៃគន្ថីនេះ ភាគីត្រូវធ្វើតាមវិធីធ្វើប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន ដែលតុលាការទទួលស្គាល់ថាសមរម្យ ទៅតុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគនោះ ឬ តុលាការអនុវត្តការរក្សាការពារ ។

(កំណត់)

មាត្រានេះត្រូវនឹងច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន មាត្រា 4 កថាខណ្ឌទី 1 វាក្យខណ្ឌទី 1 ។ ឯវិធីដាក់ប្រាតិភោគវិញ មានចែងក្នុងមាត្រា ៧១ (វិធីដាក់ប្រាតិភោគ និង ការប្តូរប្រាតិភោគ) ចំណែកឯមាត្រានេះចែងអំពីតុលាការ ដែលត្រូវផ្ញើ ។ ម្យ៉ាងទៀត សូមមើលមាត្រា ៣៧៧ (ការដាក់ប្រាតិភោគ) ។

Civil Provisional Relief Act (Japan)
**Article 4** (Provisions of Security) (excerpt)
1. The provisions of security pursuant to the provisions of this Act shall be effected by means of depositing money or valuable instruments which the court ordering the provisions of security deems appropriate, with the depository located within the jurisdiction of the district court having jurisdiction over the site of the ordering court or the court of execution or by other means prescribed by the Rules of the Supreme Court. Provided that, if the parties have entered into a special contact which provides otherwise, such contract shall govern.

## មាត្រា ៥៣៧.- សោហ៊ុយនៃការចាត់ចែងរក្សាការពារ ជាអាទិ៍

១- ក្នុងករណីដែលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ អ្នកដែលដាក់ពាក្យសុំត្រូវបង់ពន្ធចំនួន ៥.000 (ប្រាំពាន់) រៀល ទៅតុលាការ ។

២- ពេលដាក់ពាក្យសុំឱ្យធ្វើការអនុវត្តការរក្សាការពារទៅតុលាការអនុវត្តការរក្សាការពារ អ្នកដែលដាក់ពាក្យសុំ ត្រូវបង់ជាមុននូវចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការអនុវត្តការរក្សាការពារ ដែលជាសោហ៊ុយចាំបាច់សម្រាប់នីតិវិធី

អនុវត្តការរក្សាការពារ ។
៣- ប្រសិនបើអ្នកដែលដាក់ពាក្យសុំមិនបានបង់សោហ៊ុយនោះទុកជាមុនទេ តុលាការអនុវត្តការរក្សាការពារ អាចលើកចោលពាក្យសុំឱ្យធ្វើការអនុវត្តការក្សាការពារ ឬ អាចលុបចោលនូវនីតិវិធីអនុវត្តការរក្សាការពារបាន ។
៤- ចំពោះដីកាសម្រេចលើកចោលនូវពាក្យសុំ តាមបញ្ញត្តិនៃកថាខណ្ឌទី ៣ អាចប្ដឹងជំទាស់បាន ។
៥- ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តការរក្សាការពារចំពោះអាជ្ញាសាលា អ្នកដែលដាក់ពាក្យសុំត្រូវបង់ពន្ធ តាមបញ្ញត្តិដែលបានកំណត់ផ្សេង ។

(កំណត់)

ចំពោះសោហ៊ុយសម្រាប់ការចាត់ចែងការរក្សាការពារ ជាគោលការណ៍ បញ្ញត្តិស្ដីពីប្រាក់ប្រដាប់ក្ដី ក្នុងជំពូកទី ៤ នៃគន្ថីទី ១ ត្រូវបានយកមកអនុវត្ត លើកលែងតែបញ្ញត្តិនៃមាត្រា ៦១ (ពន្ធដាក់ពាក្យសុំ) និង កថាខណ្ឌទី ៣ និង កថាខណ្ឌទី ៤ នៃមាត្រា ៦២ (ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ) ។ មានន័យថា ក្នុងនីតិវិធីរក្សាការពារ ការចេញដីកាសម្រេចធ្វើការចាត់ចែងរក្សាការពារ និង ការអនុវត្តការរក្សាការពារ គឺជាកិច្ចការភ្ជាប់នឹងគ្នា ហេតុដូច្នេះ ចំពោះសោហ៊ុយសម្រាប់នីតិវិធីចេញដីកាសម្រេចធ្វើការរក្សាការពារ ព្រមទាំងនីតិវិធីអនុវត្តការរក្សាការពារ សោហ៊ុយទាំងឡាយដូចជាពន្ធនៃការដាក់ពាក្យសុំទៅតុលាការ និង ទៅអាជ្ញាសាលា ប្រាក់ប្រដាប់ក្ដីក្រៅពីពន្ធនៃការដាក់ពាក្យសុំ និង ប្រាក់ប្រដាប់ក្ដីភាគី ជាបន្ទុករបស់ភាគីម្ខាងទៀត ប្រសិនបើតុលាការទទួលស្គាល់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ហើយជាបន្ទុករបស់អ្នកដាក់ពាក្យសុំ ប្រសិនបើពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារនោះ ត្រូវបានច្រានចោល ។

កថាខណ្ឌទី ១ ត្រូវនឹងតារាងឧបសម្ព័ន្ធទី ១ 11-2៉ នៃច្បាប់ស្ដីពីប្រាក់ប្រដាប់ក្ដីរដ្ឋប្បវេណីជប៉ុន ។ ម្យ៉ាងទៀត ក្នុងករណីដែលតុលាការជាស្ថាប័នអនុវត្ត ពន្ធនៃការដាក់ពាក្យសុំនេះត្រូវរាប់បញ្ចូលទាំងសោហ៊ុយអនុវត្តការរក្សាការពារផងដែរ ។

កថាខណ្ឌទី ២ ដល់ កថាខណ្ឌទី ៤ បញ្ជាក់ថា ចំពោះការបង់សោហ៊ុយសម្រាប់ការអនុវត្តការរក្សាការពារជាមុន ត្រូវអនុវត្តដូចគ្នានឹងសោហ៊ុយសម្រាប់ការអនុវត្តដោយបង្ខំ (មាត្រា ៣៧៥ (ការបង់សោហ៊ុយជាមុន)) ដែរ ។ មានន័យថា ចែងអំពីសោហ៊ុយក្រៅពីពន្ធនៃការដាក់ពាក្យសុំដែលបានកំណត់នៅមាត្រា ៣៧៣ (សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ) ។

កថាខណ្ឌទី ៥ ក៏ដូចគ្នានឹងកថាខណ្ឌទី ២ នៃមាត្រា ៣៧២ (ពន្ធដាក់ពាក្យសុំ) ដែរ គឺយកការណ៍ដែលអាជ្ញាសាលាជាមន្ត្រីតុលាការ ហើយដែលបានចំណូលពីពន្ធនេះ ជាមូលដ្ឋាន ។ មិនត្រឹមតែអំពីពន្ធ និង សោហ៊ុយនៃអាជ្ញាសាលាប៉ុណ្ណោះទេ ត្រូវមានច្បាប់ស្ដីពីអាជ្ញាសាលាដោយឡែកមួយ ដែលចែងអំពីទំហំការងារនៃអាជ្ញាសាលា ឧបាស្រ័យចំពោះការចាត់ចែងរបស់អាជ្ញាសាលា និង បញ្ហាផ្សេងៗទៀត ។

**មាត្រា ៥៣៨.-** ការមើលសំណុំរឿងនៃការចាត់ចែងរក្សាការពារ ជាអាទិ៍

១- ជនដែលបានធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះនីតិវិធីទាក់ទងនឹងដីកាសម្រេចរក្សាការពារ ឬ នីតិវិធីដែលតុលាការធ្វើឡើងចំពោះការអនុវត្តរក្សាការពារ អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងរឿងក្ដី ពីតុលាការបាន ដោយបង់ពន្ធ ។

២- ជនដែលបានធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះការអនុវត្តរក្សាការពារដែលធ្វើឡើងដោយអាជ្ញាសាលា អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងរឿងក្ដី ពីអាជ្ញាសាលាបាន ដោយបង់ពន្ធ ។

(កំណត់)

កថាខណ្ឌទី ១ ត្រូវនឹងវាក្យខណ្ឌទី 1 មាត្រា 5 នៃច្បាប់ស្ដីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន រីឯកថាខណ្ឌទី ២ វិញ ត្រូវនឹងមាត្រា 18 នៃច្បាប់ស្ដីពីអាជ្ញាសាលាជប៉ុន ។

ម្យ៉ាងទៀត វាក្យខណ្ឌទី 2 មាត្រា 5 នៃច្បាប់ស្ដីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន មានចែងថា "ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះបុគ្គលក្រៅពីម្ចាស់បំណុល (អ្នកដាក់ពាក្យសុំការចាត់ចែងរក្សាការពារ) រហូតដល់ពេលដែលកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការកោះហៅ និង សួរកូនបំណុល ត្រូវបានកំណត់ ឬ ពេលដែលដីការក្សាការពារត្រូវបានបញ្ជូនទៅកូនបំណុល" ដើម្បីការពារកុំឱ្យមានការចាត់ចែងរក្សាការពារដោយសម្ងាត់ ។ ប៉ុន្តែ យើងគិតថា ករណីដែលបុគ្គលក្រៅពីអ្នកដាក់ពាក្យសុំឱ្យចាត់ចែងរក្សាការពារនោះបានដឹងភ្លាមៗអំពីការដាក់ពាក្យសុំនោះ ហើយទាមទារមើលសំណុំរឿង ជាដើមនោះ មានតិចតួចណាស់ ហេតុនេះហើយបានជាមិនបានបញ្ចូលក្នុងក្រមនេះទេ ។

Civil Provisional Relief Act (Japan)
**Article 5** (Perusal, etc. of Record)
Any interested person may make a request to the court clerk for perusal or copy of the record of the case, or for delivery of an authenticated copy, transcript or excerpt thereof, or for delivery of a certification regarding matters relating to the case, with regard to the proceedings for an order of provisional relief or the proceedings by a court for the execution of such an order. Provided that, this shall not apply to a person other than the obligee until a date for oral argument or for summoning the obligor to appear at a questioning on a motion for civil provisional relief has been set or document granting the order of provisional relief has been served on the obligor.

**មាត្រា ៥៣៩.-** ការអនុវត្តដូចគ្នា តាមបញ្ញត្តិពីគន្ថីទី ២ ដល់ គន្ថីទី ៤

បញ្ញត្តិពីគន្ថីទី ២ ដល់ គន្ថីទី ៤ នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការចាត់ចែងរក្សា

ការពារ លើកលែងតែមានបញ្ញត្តិពិសេស ។

(កំណត់)

ក្នុងចំណោមបញ្ញត្តិនៅក្នុងគន្ថីទី ២ (នីតិវិធីនៃការជម្រះក្តីលើកទី ១) គន្ថីទី ៣ (បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់) និង គន្ថីទី ៤ (ការជំនុំជម្រះសាជាថ្មី) មានបញ្ញត្តិដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការចាត់ចែងរក្សាការពារ តាមលក្ខណៈនៃបញ្ញត្តិទាំងនោះ ។ ហេតុដូច្នេះ មាត្រា ៥៣៩ នេះចែងថា បញ្ញត្តិពីគន្ថីទី ២ ដល់ គន្ថីទី ៤ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការចាត់ចែងរក្សាការពារ លើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងគន្ថីទី ៧ នេះ ។ ឧទាហរណ៍នៃបញ្ញត្តិដែលត្រូវយកមកអនុវត្តដូចគ្នា មានដូចជា វាក្យខណ្ឌទី ១ កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ នៃមាត្រា ១១៤ (ភាពចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់) ដែលចែងអំពីភាពមិនចាំបាច់ក្នុងការធ្វើការទាញហេតុផលដោយផ្ទាល់មាត់នៅក្នុងនីតិវិធីនៃដីកាសម្រេច និង ការសួរ មាត្រា ២១៣ (ការជូនដំណឹងអំពីដីកាសម្រេច) ស្តីពីការជូនដំណឹងអំពីដីកាសម្រេច ជំពូកទី ៨ នៃគន្ថីទី ២ ស្តីពីកាលបរិច្ឆេទ អំឡុងពេល និង ការបញ្ជូន និង ជំពូកទី ៤ នៃគន្ថីទី ៣ ដែលចែងអំពីបណ្តឹងជំទាស់ (លើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងផ្នែកទី ៦ ជំពូកទី ២ នៃគន្ថីទី ៧) ជាដើម ។

## ជំពូកទី ២ ដីកាសម្រេចរក្សាការពារ

### ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ

**មាត្រា ៥៤០.-** តុលាការដែលមានសមត្ថកិច្ច

១- រឿងក្តីនៃដីកាសម្រេចរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទ ស្ថិតនៅ ។

២- តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះលើកទី ១ ។ ប៉ុន្តែ បើអង្គសេចក្តី ត្រូវបានចាត់ការ ក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ។

៣- បើកម្មវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬ កម្មវត្ថុនៃវិវាទ ជាសិទ្ធិលើបំណុល ត្រូវចាត់ទុកថាសិទ្ធិលើបំណុលនោះ ស្ថិតនៅកន្លែងរបស់កូនបំណុលទី ៣ ដែលបានកំណត់នៅក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍) នៃក្រមនេះ ។ ប៉ុន្តែ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងប្រគល់

នាវា ឬ ចលនវត្ថុ ត្រូវចាត់ទុកថា សិទ្ធិលើបំណុលនោះស្ថិតនៅទីកន្លែងដែលវត្ថុនោះស្ថិតនៅ ។

៤- បញ្ញត្តិនៃវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកម្មវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្ដោះអាសន្ន ឬ កម្មវត្ថុនៃវិវាទ ជាសិទ្ធិលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងមាត្រា ៤១៦ (ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) នៃក្រមនេះ ហើយមានកូនបំណុលទី ៣ ឬ បុគ្គលដែលមានលក្ខណៈដូចជាកូនបំណុលទី ៣ ។

(កំណត់)

សូមមើលមាត្រា 12 ច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន និង មាត្រា ៤០២ (អត្ថន័យនៃការអនុវត្តចំពោះសិទ្ធិលើបំណុល និង តុលាការអនុវត្ត) ។

មាត្រានេះបញ្ញត្តអំពីតុលាការដែលមានសមត្ថកិច្ចលើរឿងក្តីនៃដីកាសម្រេចរក្សាការពារ ។

ប្រសិនបើបណ្តឹងអង្គសេចក្តី ត្រូវបានចាត់ការនៅតុលាការនៃបណ្តឹងសាទុក្ខ តុលាការនៃការជំនុំជម្រះលើកទី ១ គឺជា "តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី" ។ ទោះបីជាពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ត្រូវបានដាក់ទៅតុលាការដែលមានលំដាប់ផ្សេងពីតុលាការដែលកំពុងចាត់ការបណ្តឹងអង្គសេចក្តី ហើយវិនិច្ឆ័យដោយតុលាការផ្សេងនោះក៏ដោយ ក៏សំណុំរឿងនៃបណ្តឹងអង្គសេចក្តីមិនត្រូវផ្ញើទៅតុលាការដែលចាត់ការរឿងក្តីនៃការរក្សាការពារទេ ។ ភាគីដែលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ត្រូវដាក់ឯកសារចាំបាច់ជាមុន ។

Civil Provisional Relief Act (Japan)
**Article 12** (Jurisdictional Court)
1. The proceedings of a case with respect to an order of civil provisional relief shall be under the jurisdiction of the court which has jurisdiction over the principal case, or the district court that has jurisdiction over the district where the property to be provisionally attached or the subject-matter in dispute is located.
2. The court which has jurisdiction over the principal case shall be the court of first instance. Provided that however, in cases where the principal case is pending in an appellate court, it shall be the appellate court.
3. Incases where the property to be provisionally attached or the subject-matter in dispute is a claim (as defined in Article 143 of the Civil Execution Act; this definition shall, hereinafter, apply throughout this Article), the claim shall be deemed to exist at the place of the general forum of the obligor of the claim (hereinafter referred to as "the third party obligor"). Provided that, a claim, the subject-matter of which shall be delivery of a ship (as defined in Article 112 of the Civil Execution Act; this definition shall apply throughout this Act), or a movable (as defined in Article 112 of the Civil Execution Act; this definition shall apply throughout this Act), and a claim which is secured by a security right over a thing shall be deemed to exist at the place where such thing is located.
4. The main clause of the preceding paragraph shall apply *mutatis mutandis* to cases where the property to be provisionally attached or subject-matter in dispute is a property right as defined in Article 167, paragraph 1 of the Civil Execution Act (hereinafter referred to as "other property right") and where there is a third party obligor or some similar person (except as provided for in the following paragraph).
5. In cases where the property to be provisionally attached or the subject-matter in dispute is an other property right, the assignment of which requires registration, the property right shall be deemed to exist at the place of registration.

**មាត្រា ៥៤១.-** ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ និង សេចក្តីបញ្ជាក់ដំបូង

១- ក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ត្រូវសរសេរបញ្ជាក់នូវចំណុចដូចបានកំណត់ខាងក្រោមនេះ :

**ក-** ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែល

ច្បាប់បានកំណត់ ។

**ខ**- ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ ។

**គ**- សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ។

**ឃ**- ភាពចាំបាច់នៃការរក្សាការពារ ។

២- ចំពោះចំណុច **គ** និង **ឃ** នៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកដែលដាក់ពាក្យសុំ គប្បីសរសេរឱ្យបានច្បាស់លាស់ និងសរសេរនូវភស្តុតាង តាមហេតុទីមួយៗដែលត្រូវបញ្ជាក់ ។

៣- ចំពោះចំណុច **គ** និង **ឃ** នៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកដែលដាក់ពាក្យសុំត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង ។

(កំណត់)

សូមមើលមាត្រា 13 នៃច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន និង មាត្រា 1 និង មាត្រា 13 នៃបទប្បញ្ញត្តិស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន និង មាត្រា ៧៥ (របៀបដាក់ពាក្យបណ្តឹង និង ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង) នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសកម្ពុជា ។

មាត្រានេះចែងអំពីចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ជាដើម ។ ល័ក្ខខ័ណ្ឌនៃការចេញដីកាសម្រេចរក្សាការពារ គឺអត្ថិភាពនៃសិទ្ធិដែលត្រូវបានរក្សាការពារ និង ភាពចាំបាច់ក្នុងការរក្សាការពារ ហើយអ្នកដែលដាក់ពាក្យសុំ ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងនូវល័ក្ខខ័ណ្ឌទាំងពីរនេះ ។ ចំពោះអត្ថន័យនៃសេចក្តីបញ្ជាក់ដំបូង សូមមើលមាត្រា ១៣១ (សេចក្តីបញ្ជាក់ដំបូង) និង កំណត់នៃមាត្រាដដែល ។

Civil Provisional Relief Act (Japan)

**Article 13** (Motions and preliminary Showing)

1. A motion for provisional relief shall be implemented by stating the relief demanded, the right or relationship involving the rights to be protected and the necessity for such provisional relief.
2. The party shall make a preliminary showing of the existence of the right or the relationship involving the rights to be protected by provisional relief, and of the necessity for such provisional relief.
3. Neither a deposit of security money nor an oath as to the truth of the party's allegations may be substituted for the preliminary showing provided for in the preceding paragraph.

**មាត្រា ៥៤២.-** ប្រាតិភោគសម្រាប់ដីកាសម្រេចរក្សាការពារ

ដីកាសម្រេចរក្សាការពារ អាចធ្វើដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគបាន ។

(កំណត់)

សូមមើលមាត្រា 14 នៃច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។

មាត្រានេះចែងអំពីរបៀបចាត់ចែងប្រាតិភោគ នៅក្នុងដីកាសម្រេចរក្សាការពារ ។

Civil Provisional Relief Act (Japan)
**Article 14** (Security for Orders of Provisional Relief)
1. An order of provisional relief may be issued either with the requirement that the party seeking it provide a security or the condition that the execution of such relief is subject to the provisions of a security within an reasonable time period, or without the requirement that the party provide a security.
2. In case where a security is required under the preceding paragraph, and where it is difficult for the obligee to provide the security without delay to the depository referred to in Article 4, paragraph 1, the obligee may, with the permission of the court, provide the security at the depository located within the jurisdiction of the district court having jurisdiction over the place where the obligor is domiciled or has an office, or in any other place deemed appropriate by the court.

**មាត្រា ៥៤៣.-** ការបញ្ជូន

តុលាការត្រូវបញ្ជូនដីកាសម្រេចរក្សាការពារទៅភាគី ។

(កំណត់)

សូមមើលមាត្រា 17 នៃច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។ យោងតាមកថាខណ្ឌទី ១ នៃមាត្រា ២១៣ (ការជូនដំណឹងអំពីដីកាសម្រេច) នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសកម្ពុជា ដីកាសម្រេចមានអានុភាពដោយការជូនដំណឹង តែដោយសារមានភាពសំខាន់នៃដីកាសម្រេចរក្សាការពារ មាត្រានេះតម្រូវឱ្យតុលាការបញ្ជូនដីកាសម្រេចរក្សាការពារ ដើម្បីឱ្យភាគីយល់ដឹងច្បាស់លាស់អំពីអត្ថន័យនោះ ហើយដើម្បីបន្ស្រល់ឱ្យភាគីនូវមធ្យោបាយបញ្ជាក់នោះ ។

Civil Provisional Relief Act (Japan)
**Article 17** (Service)
An order of provisional relief shall be served directly on the parties.

**មាត្រា ៥៤៤.-** បណ្តឹងជំទាស់ចំពោះសេចក្តីសម្រេចលើកចោល

១- ចំពោះសេចក្តីសម្រេចដែលលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ម្ចាស់បំណុលអាចប្តឹងជំទាស់បានក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ចាប់ពីថ្ងៃដែលខ្លួនបានទទួលការជូនដំណឹង ។

២- អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

(កំណត់)

សូមមើលមាត្រា 19 នៃច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។ យោងតាមមាត្រា ៣០៣ (អំឡុងពេលសម្រាប់ប្តឹងជំទាស់) នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសកម្ពុជា អំឡុងពេលដែលអាចប្តឹងជំទាស់ មានរយៈពេល ១ សប្តាហ៍ តែចំពោះសេចក្តីសម្រេចដែលលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ដោយគិតដល់ភាពស្មុគស្មាញនៃហេតុការណ៍ មាត្រានេះកំណត់រយៈពេល ២ សប្តាហ៍ ។

សេចក្តីសម្រេចដែលលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ រាប់បញ្ចូលទាំងដីកាសម្រេចដែលលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារដែលមិនស្របតាមទម្រង់ដែលច្បាប់បានកំណត់ និង ដីកាសម្រេចដែល

លើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ដោយសន្និដ្ឋានថា គ្មានមូលហេតុត្រឹមត្រូវ (តាមទ្រឹស្តី ជាដីកាសម្រេចច្រានចោល) ។

Civil Provisional Relief Act (Japan)
**Article 19** (Immediate *Kokoku*-appeal of Court's Denial)
1. In cases where a motion for an order of provisional relief is denied, the obligee may file an immediate *kokoku*-appeal within the peremptory term of two weeks from the receipt of notice of denial.
2. In cases where an immediate *kokoku*-appeal filed under the preceding paragraph is denied, there shall be no second immediate *kokoku*-appeal.
3. The main clause of Article 6 (Statement of Grounds) shall apply *mutatis mutandis* to a ruling of an immediate *kokoku*-appeal filed under paragraph 1.

## ផ្នែកទី ២ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

**មាត្រា ៥៤៥.-** ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

១- ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចចេញបានចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ។

២- ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចចេញបាន ទោះបីជាសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ភ្ជាប់នឹងល័ក្ខខ័ណ្ឌ ឬ ពេលកំណត់ក៏ដោយ ។

(កំណត់)

សូមមើលមាត្រា 20 នៃច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន និង កំណត់នៃមាត្រា ៥៣០ (គោលគំនិត) និង ៥៣១ (ប្រភេទនៃការចាត់ចែងរក្សាការពារ) ។

Civil Provisional Relief Act (Japan)
**Article 20** (Necessity of Orders of Provisional Attachment)
1. An order of provisional attachment may be issued where there is a fear that future compulsory execution with respect to a monetary claim would be impossible or that there would be considerable difficulty in enforcing such right.
2. An order or provisional attachment may be issued even if the claim referred to in the preceding paragraph is subject to a condition or not yet due.

**មាត្រា ៥៤៦.-** កម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយកំណត់ជាក់លាក់នូវកម្មវត្ថុ ។ ប៉ុន្តែ ចំពោះដីកាសម្រេចរឹបអូសចលនវត្ថុជាបណ្តោះអាសន្ន អាចចេញបានដោយមិនចាំបាច់កំណត់កម្មវត្ថុ ។

( កំណត់ )

សូមមើលមាត្រា 21 នៃច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។ កម្មវត្ថុក្នុងមាត្រានេះ រួមបញ្ចូលទាំងសិទ្ធិលើបំណុលផងដែរ ។

Civil Provisional Relief Act (Japan)
**Article 21** (Specificity of Orders of Provisional Attachment)
An order of provisional attachment shall be issued specifying the property to be attached. Provided that, an order to attach a movable may be issued without specificity.

**មាត្រា ៥៤៧.-** ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន

១- ក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការត្រូវកំណត់ចំនួនទឹកប្រាក់ដែលកូនបំណុលត្រូវផ្ញើ ដើម្បីទទួលបាននូវការលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ។

២- ការផ្ញើប្រាក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ ត្រូវធ្វើឡើងនៅតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬ តុលាការអនុវត្តការរក្សាការពារ ។

( កំណត់ )

សូមមើលមាត្រា 22 នៃច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។ ដោយសារការរឹបអូសជាបណ្តោះអាសន្នត្រូវធ្វើឡើង ដើម្បីរក្សាការពារការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងសងជាប្រាក់ បើទឹកប្រាក់ដែលស្មើនឹងសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ត្រូវបានផ្ញើ ម្ចាស់បំណុលមិនទទួលការខូចខាតឡើយ ។ ម្យ៉ាងទៀត ប្រសិនបើកូនបំណុលត្រូវបានហាមឃាត់ក្នុងការចាត់ចែងទ្រព្យរបស់ខ្លួន ដោយសារការរឹបអូសនោះ កូនបំណុលទទួលការខូចខាតប្រយោជន៍របស់ខ្លួន ។ ហេតុដូច្នេះ មានផលប្រយោជន៍ច្រើន ក្នុងការដោះពីអានុភាពនៃការរឹបអូសជាបណ្តោះអាសន្ន ដោយការផ្ញើប្រាក់ខាងលើនេះ ។ មាត្រានេះត្រូវរៀបចំឡើង ដោយគិតពិចារណាអំពីផលប្រយោជន៍នេះ ។

Civil Provisional Relief Act (Japan)
**Article 22** (Security Deposit for Release of a Provisional Attachment)
1. An order of provisional attachment shall state the amount of money to be deposited by the obligor in order to either stay the execution of such order of provisional attachment, or to have such order set aside, if executed.
2.The deposit provided for in the preceding paragraph shall be made to wither the court which issued the order of provisional attachment, or the depository in the jurisdiction of the district court having jurisdiction over the place where the court of execution of provisional relief is located.

# ផ្នែកទី ៣ ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន

**មាត្រា ៥៤៨.-** ភាពចាំបាច់នៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ជាអាទិ៍

១- តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទបាន ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ ។

២- តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ ។

៣- បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៥៤៥ (ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ។

៤- តុលាការមិនអាចចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះបានឡើយ បើមិនឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរដែលកូនបំណុលអាចចូលរួមបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានស្ថានភាពពិសេសដែលនាំឱ្យពុំអាចសម្រេចគោលបំណងនៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដោយសារឆ្លងកាត់តាមកាលបរិច្ឆេទនោះ ។

(កំណត់)

សូមមើលមាត្រា 23 នៃច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។

កថាខណ្ឌទី ១ និង ទី ២ នៃមាត្រានេះ ចែងអំពីភាពចាំបាច់នៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដោយបែងចែកដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និង ដីកាសម្រេចចាត់ចែងជាបណ្តោះ-អាសន្ន ដែលកំណត់ឋានៈជាបណ្តោះអាសន្ន ។ កថាខណ្ឌទី ៣ ចែងអំពីការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដែលកំណត់ថា ក្នុងករណីដែលសិទ្ធិលើបំណុលមានភ្ជាប់នឹងល័ក្ខខ័ណ្ឌ ឬ ពេលកំណត់ក៏ដោយក៏តុលាការអាចចេញដីកាសម្រេចដែរ ។ ឯចំពោះកថាខណ្ឌទី ៤ ដំណើរការស្ងាត់ស្ងៀមជាគោលការណ៍នៃការវិនិច្ឆ័យអំពីការចាត់ចែងរក្សាការពារ (ហេតុដូច្នេះ មាត្រា ៣ (សិទ្ធិទាមទារឱ្យសាកសួរ គោលការណ៍ចំពោះមុខ) នៃក្រមនីតិវិធីរដ្ឋប្បវេណីនេះ មិនត្រូវយកមកអនុវត្តចំពោះការវិនិច្ឆ័យអំពីការចាត់ចែងរក្សាការពារទេ) ប៉ុន្តែ ដោយគិតពិចារណាអំពីភាពសំខាន់នៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន កថាខណ្ឌទី ៤ នេះ ធានាគោលការណ៍ដែលផ្តល់ឱកាសការពារខ្លួនដល់ភាគីម្ខាងទៀតក្នុងករណីនេះ ។ ហេតុដូច្នេះ យើងអាចសន្និដ្ឋានថា បញ្ញត្តិនៃ

កថាខណ្ឌទី ៤ នេះ ប្រហាក់ប្រហែលគ្នានឹង référé (កិច្ចការប្រញាប់) របស់ច្បាប់បារាំង ។

Civil Provisional Relief Act (Japan)
**Article 23** (Necessity of Orders of Provisional Disposition)
1. An order of provisional disposition of subject-matter in dispute may be issued where there is a fear that realization of the obligee's right would be impossible or there would be considerable difficulty in enforcing such right due to a change in circumstances.
2. An order of provisional disposition may be issued to establish provisionally the state of affairs of the obligee when it is necessary to avert significant damage or imminent risk to the obligee with respect to the right at issue.
3. Article 20, paragraph 2 (Contingent or Unmatured Claim) shall apply *mutatis mutandis* to an order of provisional disposition.
4. An order of provisional disposition provided for in paragraph 2 may not be issued without holding either oral argument or an questioning which the obligor is entitled to attend. Provided that, this paragraph shall not apply when the purpose of the motion for an order of provisional disposition could not be attained if such argument or questioning were hold.

**មាត្រា ៥៤៩.-** វិធីចាត់ចែងជាបណ្ដោះអាសន្ន

តុលាការអាចចាត់ចែងឱ្យកូនបំណុលធ្វើ ឬ មិនធ្វើអំពើណាមួយជាកំណត់ ឬ ឱ្យកូនបំណុលផ្ដល់តាវកាលិក ឬ ឱ្យអ្នកថែរក្សាគ្រប់គ្រង ថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្ដោះអាសន្ន ឬ ធ្វើការចាត់ចែងផ្សេងទៀតបានតាមកម្រិតនៃភាពចាំបាច់ដើម្បីសម្រេចគោលបំណងនៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ។

(កំណត់)

សូមមើលមាត្រា 24 នៃច្បាប់ស្ដីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។ មាត្រានេះចែងអំពីអត្ថន័យនៃដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដែលតុលាការអាចធ្វើបាន តាមការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និង ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ។ ដោយគិតពិចារណានូវទំហំនៃឥទ្ធិពលដល់កូនបំណុល អត្ថន័យនៃដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដែលតុលាការអាចធ្វើបាន ត្រូវកំណត់តែទំហំចាំបាច់ជាអប្បបរមាដើម្បីសម្រេចគោលបំណងនៃពាក្យសុំរបស់ម្ចាស់បំណុល ។

របៀបជារូបីនៃការចាត់ចែងជាបណ្ដោះអាសន្ន គឺ (1) ការបង្គាប់ឱ្យកូនបំណុលធ្វើអំពើដែលកំណត់ (ឬ ហាមមិនឱ្យធ្វើអំពើនោះ) (2) ការបង្គាប់ឱ្យកូនបំណុលផ្ដល់តាវកាលិក (3) ការបង្គាប់ឱ្យអ្នកថែរក្សាគ្រប់គ្រង (វិសុណ្ឋាប័ន) ថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្ដោះអាសន្ន និង (4) ធ្វើការចាត់ចែងចាំបាច់ផ្សេងទៀត ។

(1) "ការបង្គាប់ឱ្យកូនបំណុលធ្វើអំពើដែលកំណត់ (ឬ ហាមមិនឱ្យធ្វើអំពើនោះ)" គឺជាការបង្គាប់ឱ្យកូនបំណុលធ្វើអំពើណាមួយ ឬ មិនធ្វើអំពើនោះ ។ ឧទាហរណ៍ ការបង្គាប់ឱ្យយកសំណង់ចេញ ការហាមឃាត់ការសាងសង់ ឬ ការហាមឃាត់ធ្វើដំណើរឆ្លងកាត់ ជាដើម ។

(2) "ការបង្គាប់ឱ្យកូនបំណុលផ្ដល់តាវកាលិក" គឺជាការបង្គាប់ឱ្យធ្វើអំពើដែលអាចអនុវត្តតាមការបង្ខំដោយផ្ទាល់ ដូចជាការប្រគល់វត្ថុ ការបង់ជាទឹកប្រាក់ ជាដើម ។

(3) "ការបង្គាប់ឱ្យអ្នកថែរក្សាគ្រប់គ្រង (វិសុណ្ឋាប័ន) ថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុ" គឺជាការផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃវិវាទ ពីកូនបំណុល ទៅអ្នកថែរក្សាគ្រប់គ្រង (វិសុណ្ឋាប័ន) ។ របៀបនេះត្រូវបានអនុវត្ត

ជាញឹកញាប់ ដើម្បីរក្សាស្ថានភាពបច្ចុប្បន្ននៃវត្ថុវិវាទនោះ ។ ការថែរក្សាគ្រប់គ្រងដោយអាជ្ញាសាលាគឺជាគំរូ តែក៏អាចមានការថែរក្សាគ្រប់គ្រងដោយម្ចាស់បំណុល ឬ ដោយតតិយជន ជាដើមដែរ ។ ម្យ៉ាងទៀត ក្នុងករណីដែលអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃវិវាទ មានករណីខ្លះដែលតុលាការចេញដីកាសម្រេចអនុញ្ញាតឱ្យកូនបំណុលប្រើវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ ។

(4) "ការចាត់ចែងផ្សេងទៀត" គឺ ឧទាហរណ៍ ចំពោះករណីនៃដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការប្រមូលបំណុល ការបង្គាប់ហាមឃាត់មិនឱ្យកូនបំណុលទី ៣ សង ជាការចាត់ចែងចាំបាច់ ហើយចំពោះករណីដែលអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃវិវាទ ការបង្គាប់ឱ្យប្រកាសជាសាធារណៈ ជា "ការចាត់ចែងផ្សេងទៀត" ដែរ ។

Civil Provisional Relief Act (Japan)
**Article 24** (Method of Provisional Disposition)
The court may order any disposition that it deems necessary to attain the purpose of a motion for provisional disposition, such as requiring an obligor to perform an act, enjoining an obligor from performing an act, ordering an obligor to deliver specific goods, ordering a sequestrator to take custody of the property at issue or ordering any other disposition.

## ផ្នែកទី ៤ ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

**មាត្រា ៥៥០.-** ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

កូនបំណុលអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ទៅតុលាការដែលបានចេញដីកាសម្រេចនោះ ។

(កំណត់)

សូមមើលមាត្រា 26 នៃច្បាប់ស្ដីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។ ដោយយោងតាមបញ្ញត្តិនៃមាត្រា ៥៣៤ (របៀបដាក់ពាក្យសុំ) ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ។

Civil Provisional Relief Act (Japan)
**Article 26** (Motions for Objection)
The obligor may file an objection to an order of provisional relief with the court that issued the order.

**មាត្រា ៥៥១.-** ការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍

១- ក្នុងករណីដែលមានពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការអាចបង្គាប់ឱ្យផ្អាកការអនុវត្តរក្សាការពារ ឬ លុបចោលការចាត់ចែងការអនុវត្ត តាមពាក្យសុំ ដោយឱ្យដាក់ប្រាតិភោគបាន រហូតដល់ធ្វើការសម្រេចសេចក្ដីតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងក្រោមនេះ ក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ លុះត្រាតែមានសេចក្ដីបញ្ជាក់ដំបូងអំពីស្ថានភាពដែលច្បាស់ថា នឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ និង

អំពីការដែលមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារការអនុវត្តរក្សាការពារ ។
២- ក្នុងករណីដែលតុលាការនៃបណ្តឹងជំទាស់បានចេញដីកាសម្រេចរក្សាការពារ បើមានសំណុំរឿងនៅតុលាការដើម តុលាការដើមនោះក៏អាចធ្វើការសម្រេចសេចក្តី តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបានដែរ ។
៣- នៅក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវលុបចោល ផ្លាស់ប្តូរ ឬ ទទួលស្គាល់នូវសេចក្តីសម្រេចដែលបានធ្វើរួចហើយ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

សូមមើលមាត្រា 27 នៃច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។ មាត្រានេះបញ្ជាក់ថា ជាគោលការណ៍ ការអនុវត្តការរក្សាការពារមិនអាចផ្អាក ដោយការតវ៉ាចំពោះដីកាសម្រេចរក្សាការពារទេ ។ ដើម្បីផ្អាកការអនុវត្តរក្សាការពារ ដោយការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ត្រូវបំពេញល័ក្ខខ័ណ្ឌទាំងពីរ គឺ "ស្ថានភាពដែលច្បាស់ថា នឹងក្លាយជាមូលហេតុ នៃការលុបចោលដីកាសម្រេចរក្សាការពារ" និង "ការដែលមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើង ដោយការអនុវត្តការរក្សាការពារ" ហើយចាំបាច់ត្រូវដាក់ប្រាតិភោគ ។

"ស្ថានភាពដែលច្បាស់ថា នឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ" គឺ ស្ថានភាពដែលច្បាស់ជាផ្ទុយនឹងសិទ្ធិដែលទទួលការរក្សាការពារ និង ភាពចាំបាច់នៃការរក្សាការពារ ដែលជាល័ក្ខខ័ណ្ឌទាំងពីរនៃដីកាសម្រេចរក្សាការពារ ។ ឧទាហរណ៍គឺ ករណីដែលសាលក្រមផ្តន្ទាទោសដែលសន្និដ្ឋានថា ភស្តុតាងជាឯកសារដែលជាមូលដ្ឋាននៃការទទួលស្គាល់អង្គហេតុត្រូវបានក្លែងបន្លំ បានចូលជាស្ថាពរ ករណីដែលភស្តុតាងជាឯកសារដ៏សំខាន់ថ្មីទៀតត្រូវបានរកឃើញ ករណីដែលមានកំហុសក្នុងការបកស្រាយច្បាប់ និង ករណីដែលគ្មានភាពចាំបាច់ក្នុងការរក្សាការពារតទៅទៀត ដោយសារគ្មានឧបសគ្គដល់ជីវភាព ដូចជាករណីដែលជនរងគ្រោះថ្នាក់ចរាចរ បានទទួលការចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់ឱ្យបង់សំណងនៃការខូចខាតជាបណ្តោះអាសន្ន ហើយបានជាសះស្បើយធ្វើការវិញ ជាដើម ។

"ការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើង ដោយការអនុវត្តការរក្សាការពារ" គឺជាការបារម្ភដែលកូនបំណុលនឹងមិនអាចមានសោមនស្សបានដោយសារសំណងជាទឹកប្រាក់ក្រោយការអនុវត្ត ។ ឧទាហរណ៍ ការបារម្ភថា មុខរបររបស់កូនបំណុលនឹងត្រូវទទួលធនក្ស័យ ឬ នឹងបាត់បង់ជំនឿជឿជាក់ដែលពិបាកនឹងស្តារឡើងវិញ ដោយសារការអនុវត្តរក្សាការពារ ជាដើម ។ លទ្ធភាពរបស់ម្ចាស់បំណុលក្នុងការសងក៏ជាកត្តាត្រូវពិចារណាដែរ ។ ហើយក្នុងករណីដែលចំនួននៃប្រាតិភោគដែលត្រូវបានដាក់នៅពេលធ្វើដីកាសម្រេចរក្សាការពារ មិនគ្រប់គ្រាន់ ការណ៍នោះត្រូវបានពិចារណាថាជាស្ថានភាពដែលជាប្រយោជន៏ដល់កូនបំណុល ។

ម្យ៉ាងទៀត មាត្រានេះចែងរួមបញ្ចូលទាំងដីកាសម្រេចរក្សាការពារដែលយកការដាក់ប្រាតិភោគធ្វើជាល័ក្ខខ័ណ្ឌ ។

<u>Civil Provisional Relief Act (Japan)</u>
**Article 27** (Orders to Stay or Void)
1. In cases where a motion got objection to an order of provisional relief is filed, the court may, upon the motion of the obligor, order

a stay of execution of the order of provisional relief or a voidance of an executorial disposition already executed until the court rendered a ruling under paragraph 3 of this Article, on the condition that the obligor makes a clear preliminary showing that circumstances constituting grounds for setting aside the order of provisional relief exist and that there is a fear that the execution of the order of provisional relief would cause irreparable damage to the obligor.
2. In cases where the *kokoku*-appeal court issued the order of provisional relief and the record of the case is still in the custody of the original court, the original court may grant an order provided for under the preceding paragraph.
3. The court shall void, modify or affirm an order provided for in paragraph 1 of this Article, in a ruling rendered in response to a motion for objection to an order of provisional relief.
4. No objection may be filed o a ruling rendered under paragraphs 1 or 3 of this Article.
5. Article 13, paragraph 3 (No Substitute for Preliminary Showing) shall apply *mutatis mutandis* to a preliminary showing under paragraph 1 of this Article, and Article 15 (Order by the Presiding Judge) shall apply *mutatis mutandis* to a ruling rendered uneer paragraph 1 or this Article.

**មាត្រា ៥៥២.-** ការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

តុលាការមិនអាចចេញដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារបានឡើយ បើមិនបានឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន ។

(កំណត់)

សូមមើលមាត្រា 29 នៃច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។

ជាធម្មតា តុលាការចេញដីកាសម្រេចរក្សាការពារ ដោយផ្អែកតែលើពាក្យសុំ និង សេចក្តីបញ្ជាក់ដំបូងរបស់អ្នកដាក់ពាក្យសុំប៉ុណ្ណោះ ហើយកូនបំណុលមិនមានឱកាសឆ្លើយតបបានទេ ។ ហេតុដូច្នេះហើយ មាត្រានេះតម្រូវឱ្យមានកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបានមុននឹងចេញដីកាសម្រេចអំពីពាក្យសុំតវ៉ានោះ ។

Civil Provisional Relief Act (Japan)
**Article 29** (Investigation of Objections to Provisional Relief)
The Court shall not make a ruling with respect to any objection to an order of provisional relief without holding a questioning which both parties are entitled to attend or oral argument.

**មាត្រា ៥៥៣.-** ការបញ្ចប់ការវិនិច្ឆ័យ

ដើម្បីបញ្ចប់ការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ ។ ប៉ុន្តែ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន តុលាការអាចប្រកាសដោយភ្លាមៗថា បញ្ចប់ការវិនិច្ឆ័យ ។

(កំណត់)

សូមមើលមាត្រា 31 នៃច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។

ជាទូទៅ ក្នុងនីតិវិធីនៃដីកាសម្រេច តុលាការអាចប្រកាសបញ្ចប់ការវិនិច្ឆ័យនៅពេលណាក៏បាន ។ ប៉ុន្តែ នៅក្នុងនីតិវិធីនៃការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ ដើម្បីឱ្យភាគីមានឱកាសផ្តល់សំអាងបន្ថែមទៀត សម្រាប់ការពារផលប្រយោជន៍របស់ខ្លួន ។ ប៉ុន្តែ តុលាការអាចប្រកាសដោយភ្លាមថា បញ្ចប់ការវិនិច្ឆ័យ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទ នៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន ។

<u>Civil Provisional Relief Act (Japan)</u>
**Article 31** (Conclusion of Cases)
The court shall decide the date to conclude a case with a grace period as it deems appropriate. Provided that, it may conclude the case immediately on the date set for a questioning which both parties are entitled to attend or oral argument.

**មាត្រា ៥៥៤.-** ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

១- នៅក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវទទួលស្គាល់ ផ្លាស់ប្តូរ ឬ លុបចោលនូវដីកាសម្រេចរក្សាការពារ ។

២- ចំពោះដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារដែលធ្វើឡើងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចដាក់ល័ក្ខខ័ណ្ឌឱ្យកូនបំណុលដាក់ប្រាតិភោគបាន ។

៣- បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

សូមមើលមាត្រា 32 នៃច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។

មាត្រានេះចែងថា ចំពោះដីកាសម្រេចរក្សាការពារដែលបានធ្វើពីមុនមក បើយល់ឃើញថាត្រឹមត្រូវ តុលាការត្រូវទទួលស្គាល់ដីកានេះ បើមានចំណុចដែលត្រូវកែតម្រូវ ត្រូវធ្វើការផ្លាស់ប្តូរ ហើយបើយល់ឃើញថាមិនត្រឹមត្រូវ តុលាការត្រូវលុបចោល ។ ចំពោះពាក្យ "ផ្លាស់ប្តូរ" ដែលកំណត់នៅក្នុងកថាខណ្ឌទី ១ រួមមានករណីដែលកំណត់ល័ក្ខខ័ណ្ឌនៃការអនុវត្ត ឬ បន្តការអនុវត្តរក្សាការពារថា តម្រូវឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ ក្នុងអំឡុងពេលដែលទទួលស្គាល់ថាសមរម្យ ឬ ករណីដែលបន្ថែមចំនួននៃប្រាតិភោគដែលបានកំណត់តាមបញ្ញត្តិនៃមាត្រា ៥៤២ (ប្រាតិភោគសម្រាប់ដីកាសម្រេចរក្សាការពារ) ហើយកំណត់ល័ក្ខខ័ណ្ឌនៃការអនុវត្ត ឬ បន្តការអនុវត្តថា តម្រូវឱ្យម្ចាស់បំណុលដាក់ប្រាតិភោគចំពោះចំនួនបន្ថែមនោះ ក្នុងអំឡុងពេលដែលទទួលស្គាល់ថា សមរម្យ ។

<u>Civil Provisional Relief Act (Japan)</u>
**Article 32** (Rulings Rendered in Response to a Motion for Objection)
1. The court shall void, modify, or affirm an order of provisional relief in response to a motion for objection to such order of provisional relief.

2. The court may, in a ruling rendered in accordance with the preceding paragraph, require as a condition for the execution or continuation of the execution of the order of provisional relief that the obligee provide a security within the period that court deems appropriate, in addition to any security provided pursuant to Article 14, paragraph 1.
3. In cases where the court decides by ruling to void an order of provisional relief in accordance with the provisions of paragraph 1 of this Article, it may require the obligor to provide a security.
4. The main clause of Article 16 (Statement of Grounds) and Article 17 (Service) shall apply *mutatis mutandis* to a ruling provided for under paragraph 1 of this Article.

**មាត្រា ៥៥៥.-** ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន

បើម្ចាស់បំណុលបានទទួលការប្រគល់វត្ថុ ឬ ការបង់ប្រាក់ ឬ ប្រើប្រាស់ឬថែរក្សាគ្រប់គ្រងវត្ថុ ដោយផ្អែកលើដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន តុលាការអាចបង្គាប់ឱ្យម្ចាស់បំណុលបង្វិលសងវត្ថុដែលកូនបំណុលបានប្រគល់ ឬ សងប្រាក់ដែលកូនបំណុលបានបង់ ឬ បង្វិលសងវត្ថុដែលម្ចាស់បំណុលកំពុងប្រើប្រាស់ឬថែរក្សាគ្រប់គ្រងបាន តាមពាក្យសុំរបស់កូនបំណុល នៅក្នុងដីកាសម្រេចដែលលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ។

(កំណត់)

សូមមើលមាត្រា 33 នៃច្បាប់ស្ដីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។

Civil Provisional Relief Act (Japan)
**Article 33** (Orders to Recover)
In cases where an obligee has been delivered property, has received possession of property, has received the payment of money, or has been given the use or custody of property pursuant to an order of provisional disposition, the court may, upon the motion of the obligor, order the obligee to return such property or money in a ruling to void the order of provisional relief in accordance with the provisions of paragraph 1 of the preceding Article.

**មាត្រា ៥៥៦.-** អានុភាពនៃដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ

ដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ ។ ប៉ុន្តែ បើយល់ឃើញថា ចាំបាច់ពិសេស តុលាការអាចប្រកាសថា ដីកាសម្រេចនោះមានអានុភាពភ្លាមៗ ។

(កំណត់)

សូមមើលមាត្រា 34 នៃច្បាប់ស្ដីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។

ជាទូទៅ ដីកាសម្រេចមានអានុភាព នៅពេលជូនដំណឹង (មាត្រា ២១៣ (ការជូនដំណឹងអំពីដីកាសម្រេច)) ។ ដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ មានន័យថា ដីកាសម្រេចរក្សាការពារនៅតែមានអានុភាព ។ គោលបំណងនៃវាក្យខណ្ឌទី ១ នៃមាត្រានេះ សំដៅការពារផលប្រយោជន៍

របស់ម្ចាស់បំណុលដែលបានទទួលដីកាសម្រេចរក្សាការពារ (ឧ. មិនឱ្យកូនបំណុលចាត់ចែងវត្ថុដែលជាកម្មវត្ថុនៃការរក្សាការពារ នៅពេលដែលម្ចាស់បំណុលអាចប្ដឹងជំទាស់) ។ ប៉ុន្តែ បើយល់ឃើញថា ចាំបាច់ពិសេសដើម្បីការពារផលប្រយោជន៍របស់កូនបំណុល តុលាការអាចប្រកាសថា ដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារ មានអានុភាពភ្លាមៗ ។

<u>Civil Provisional Relief Act (Japan)</u>
**Article 34** (Effect of Rulings to Void Orders of Provisional Relief)
In a ruling to void an order of provisional relief in accordance with the provisions of Article 32, paragraph 1, the court may declare that the order shall not come into effect until the passage of an appropriate period within two weeks from the service thereof, as fixed by the court. Provided that, this shall not apply to a ruling against which no *kokoku*-appeal for provisional relief may be filed.

## ផ្នែកទី ៥ ការលុបចោលដីកាសម្រេចរក្សាការពារ

**មាត្រា ៥៥៧.-** ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ជាអាទិ៍

១- តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ត្រូវបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ហើយឱ្យដាក់ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្ដឹងនោះ ក្នុងអំឡុងពេលដែលទទួលស្គាល់ថាសមរម្យ តាមពាក្យសុំរបស់កូនបំណុល ។

២- អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវមានរយៈពេលមិនតិចជាង ២ (ពីរ) សប្ដាហ៍ ។

៣- បើម្ចាស់បំណុលមិនដាក់ឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងអំឡុងពេលដែលត្រូវបានកំណត់ តាមបញ្ញត្តិនៃកថាខណ្ឌដដែលនោះ តុលាការត្រូវលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុល ។

៤- ក្នុងករណីដែលពាក្យបណ្ដឹងអង្គសេចក្ដីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានដកវិញ ឬ ត្រូវបានលើកចោល នៅក្រោយពេលដែលឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនោះ ត្រូវបានដាក់ ត្រូវចាត់ទុកថាឯកសារនោះមិនបានដាក់ឡើយ ។

៥- ចំពោះការអនុវត្តបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ៣ ខាងលើនេះ បើមានកិច្ចសន្យាមជ្ឈត្តកម្មអំពីអង្គសេចក្ដី ការចាប់ផ្ដើមនីតិវិធីមជ្ឈត្តកម្ម ត្រូវចាត់ទុកជាការដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ។

៦- បើនីតិវិធីមជ្ឈត្តកម្មដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៥ ខាងលើនេះ បានចប់មិនមែនដោយសេចក្ដីសម្រេចមជ្ឈត្តករ ម្ចាស់បំណុលត្រូវដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ក្នុងអំឡុងពេលដូចគ្នានឹងអំឡុងពេលដែលបានកំណត់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ចាប់ពីថ្ងៃដែលនីតិវិធីមជ្ឈត្តកម្មនោះបានចប់ ។

៧- បញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បំណុលមិនបានដាក់ពាក្យបណ្ដឹងអង្គសេចក្ដីតាមបញ្ញត្តិនៃកថាខណ្ឌទី ៦ ហើយបញ្ញត្តិនៃកថាខណ្ឌទី ៤ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបណ្ដឹងអង្គសេចក្ដីត្រូវបានដាក់តាមបញ្ញត្តិនៃកថាខណ្ឌទី ៦ តែក្រោយមកត្រូវបានដកវិញ ឬ ត្រូវបាន

លើកចោល ។

៨- បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចតាមកថាខណ្ឌទី ៣ និង ទី ៧ ។

(កំណត់)

សូមមើលមាត្រា 37 នៃច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។

ដីកាសម្រេចរក្សាការពារធ្វើឡើងក្នុងគោលបំណងការពារសិទ្ធិរបស់ម្ចាស់បំណុលជាបណ្តោះអាសន្ន ដោយតុលាការមិនទាន់សម្រេចអំពី អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិនោះ តាមនីតិវិធីនៃបណ្តឹងឡើយ ប៉ុន្តែ វាក៏អាចប៉ះពាល់ដល់ផលប្រយោជន៍របស់កូនបំណុលផងដែរ ប្រសិនបើមានការអូសបន្លាយពេលវេលាមិនសមរម្យ ហេតុនេះហើយ ទើបមាត្រានេះកំណត់ថា តុលាការត្រូវបង្គាប់ម្ចាស់បំណុលឱ្យដាក់ពាក្យបណ្តឹងអង្គសេចក្តី និង ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្តឹង ដោយកំណត់អំឡុងពេលមិនតិចជាង ២ សប្តាហ៍ តាមពាក្យសុំរបស់កូនបំណុល ។

ប្រសិនបើបណ្តឹងអង្គសេចក្តីកំពុងត្រូវបានចាត់ការហើយ ការចេញដីកាសម្រេចបង្គាប់ឱ្យដាក់ឯកសារដែលបញ្ជាក់អំពីការចាត់ការបណ្តឹងនោះ ជាការគ្រប់គ្រាន់ហើយ ។

Civil Provisional Relief Act (Japan)

**Article 37** (Voidance of an Order of Provisional Relief Due to Failure to Institute a Civil Action on the Principal Case)

1. The court that issued an order of provisional relief shall, upon the motion of the obligor, order that the obligee institute a civil action on the principal case and submit documentation to prove its institution, or submit documentation to prove the pendency of such action in cases where the obligee has already instituted it, within the appropriate period as fixed by such court.
2. The period provided for in the preceding paragraph shall be not less than two weeks.
3. The court shall, upon the motion of the obligor, void an order of provisional relief in cases where the obligee fails to submit the documentation within the period provided for in paragraph 1 of this Article.
4. The documentation submitted pursuant to paragraph 1 of this Article shall be deemed not to have been submitted in cases where the civil action on the principal case provided for in the same paragraph has been withdrawn or dismissed.
5. In cases where the principal case is one of those provided for in Article 18, paragraph 1 of the Domestic Causes Inquiries Act (Law No. 152, 1947), or involves an arbitration clause, or involves damages with regard to environmental pollution provided for in Article 2 of the Pollution Disputes Settlement Act (Law No. 108, 1970), a motion for conciliation in a family court, a motion for commencement of an arbitration procedure, or a motion for an award with respect to liability for damages (referred to as "liability award" in the following paragraph) provided for in Article 42-12, paragraph 1 of the Pollution Disputes Settlement Act, shall respectively be construed as institution of a civil action on the principal case provided for in paragraphs 1 and 3 of this Article.
6. In cases where a conciliation procedure referred to in the preceding paragraph ends without agreement of the parties, or an arbitration procedure referred to in the same paragraph ends without an arbitral award or a procedure for a liability award referred to in the same paragraph ends without an award (including the agreement of the parties provided for in Article 42-24, paragraph 2 of the Pollution Disputes Settlement Act), the obligee shall institute a civil action on the principal case from the day such procedure ends, within the period provided for under paragraph 1 of this Article.
7. Paragraph 3 of this Article shall apply *mutatis mutandis* when the obligee fails to institute a civil action on the principal case, and paragraph 4 of this Article shall apply *mutatis mutandis* when a civil action on the principal case referred to in the preceding paragraph has been withdrawn or dismissed once instituted.
8. The main clause of Article 16 (Statement of Grounds) and Article 17 (Service) shall apply *mutatis mutands* to a ruling rendered under paragraph 3 of this Article (including the cases too which paragraph 3 shall apply *mutatis mutandis* under the preceding paragraph).

**មាត្រា ៥៥៨.-** ការលុបចោលដីកាសម្រេចរក្សាការពារ ដោយសារការផ្លាស់ប្តូរស្ថានភាព

១- បើមានការរលត់សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ ឬ ភាពចាំបាច់ក្នុងការរក្សាការពារ ឬ ការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាព តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ឬ តុលាការនៃបណ្តឹងអង្គសេចក្តី អាចលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុលបាន ។

២- ចំពោះការផ្លាស់ប្តូរស្ថានភាពដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ កូនបំណុលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង ។

៣- បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) និង កថាខណ្ឌទី ២ នៃមាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

សូមមើលមាត្រា 38 នៃច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។

ករណីដែលអាចលុបចោលដីកាសម្រេចរក្សាការពារ ដោយយកមូលហេតុនៃការផ្លាស់ប្តូរស្ថានភាព មានករណីធំពីរ ។ ករណីទី ១ គឺ ករណីដែលមានហេតុថ្មីដែលនាំឱ្យដីកាសម្រេចរក្សាការពារមានភាពមិនត្រឹមត្រូវ កើតឡើងក្រោយពេលចេញដីកាសម្រេចរក្សាការពារនោះ ។ ឯករណីមួយទៀត គឺ ករណីដែលហេតុនោះបានកើតឡើងរួចហើយនៅពេលចេញដីកាសម្រេចរក្សាការពារ តែកូនបំណុលបានដឹងអំពីហេតុនោះ ឬ អាចធ្វើសេចក្តីបញ្ជាក់ដំបូង ក្រោយពេលចេញដីកាសម្រេចរក្សាការពារនោះ ។

ដែលជាឧទាហរណ៍គឺ ករណីដែលសិទ្ធិដែលត្រូវបានរក្សាការពារបានរលត់ដោយសារការសង ជាដើម និង ករណីដែលភាពចាំបាច់នៃការរក្សាការពារបានរលត់ ដោយសារស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុលគ្រាន់បើឡើងវិញ ។ ចំពោះការចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់ឱ្យបង់ប្រាក់ជាបណ្តោះអាសន្ន មានករណីដែលភាពចាំបាច់នៃការរក្សាការពារបានរលត់ ដោយសារស្ថានភាពទ្រព្យសម្បត្តិរបស់ម្ចាស់បំណុលគ្រាន់បើឡើងវិញ ។

<u>Civil Provisional Relief Act (Japan)</u>

**Article 38** (Voindance of Provisional Relief Due to a Change in Circumstances)

1. The court that issued an order of provisional relief, or the court of the principal case may, upon the motion of the obligor, void the order of provisional relief, in cases where the right or the relationship involving rights to be provisionally protected has been extinguished, or where the necessity for the provisional relief has ceased to exist, or where the circumstances have otherwise changed.
2. An obligor shall make a preliminary showing of the circumstances provided for in the preceding paragraph.
3. Article 13, paragraph 3 (No Substitute for Preliminary Showing) shall apply *mutatis mutandis* to the provision of the preceding paragraph on preliminary showing; the main clause of Article 16 (Statement of Grounds), Article 17 (Service) and Article 32, paragraph 2 and 3 (Continuation or Voidance Subject to Provision of Security) shall apply *mutatis mutandis* to a ruling on a motion referred to in paragraph 1 of this Article.

**មាត្រា ៥៥៩.-** ការលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដោយសារស្ថានភាពពិសេស

១- ប្រសិនបើមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ឬ មានស្ថានភាពពិសេសផ្សេងទៀត តុលាការដែលបានចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ឬ តុលាការនៃបណ្ដឹងអង្គសេចក្ដី អាចលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ននោះបាន ដោយមានល័ក្ខខ័ណ្ឌតម្រូវឱ្យដាក់ប្រាតិភោគ តាមពាក្យសុំរបស់កូនបំណុល ។
២- ចំពោះស្ថានភាពពិសេសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ កូនបំណុលត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូង ។
៣- បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

សូមមើលមាត្រា 39 នៃច្បាប់ស្ដីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។

ករណីដែលអាចលុបចោលដីកាសម្រេចរក្សាការពារ ដោយមានស្ថានភាពពិសេស មានករណីធំពីរ ។ ករណីទី ១ គឺ ស្ថានភាពដែលអាចសម្រេចគោលបំណងនៃការចាត់ចែងជាបណ្ដោះអាសន្ន ដោយការសងជាទឹកប្រាក់ទៅម្ចាស់បំណុល ។ ករណីមួយទៀត គឺ ករណីដែលកូនបំណុលទទួលការខូចខាតមិនធម្មតាហួសហេតុ តាមទស្សនៈនៃសមភាពរវាងភាគីទាំងសងខាង ។

មានការជជែកវែកញែកអំពីករណីទី ១ ចំពោះស្ថានភាពដែលអាចសម្រេចបាននូវគោលបំណងនៃការចាត់ចែងជាបណ្ដោះអាសន្ន ដោយការសងជាទឹកប្រាក់ទៅម្ចាស់បំណុល ។ ទោះបីជាយល់ឃើញថា អាចលុបចោលតាមមាត្រានេះ ដោយសារមានលទ្ធភាពនៃការសងជាទឹកប្រាក់ក៏ដោយ ក៏ត្រូវអនុវត្តដោយហ្មត់ចត់ដែរ ។ បានសេចក្ដីថា មានតែករណីដែលមានសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ដែលជាមូលដ្ឋាននៃសិទ្ធិរបស់ម្ចាស់បំណុល (ធម្មតាជាសិទ្ធិលើបំណុលដែលមិនមានគោលបំណងសងជាប្រាក់) ហើយមានទំនាក់ទំនងរវាងសិទ្ធិទាំងពីរដែលមានខ្លឹមសារថា អាចទទួលការជម្រះនូវសិទ្ធិដែលត្រូវបានរក្សាការពារ ដោយសងប្រាក់នោះទេ ទើបអាចលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នបាន ។

ម្យ៉ាងទៀត យើងមិនយកប្រព័ន្ធនៃ "ប្រាក់រំដោះពីការចាត់ចែងជាបណ្ដោះអាសន្ន" ដូច "ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន" ដែលបានកំណត់នៅក្នុងមាត្រា ៥៤៧ (ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន) ទេ ប៉ុន្តែអត្ថន័យនៃប្រព័ន្ធខាងលើ អាចត្រូវបានសម្រេច ដោយការអនុវត្តមាត្រានេះ ។

<u>Civil Provisional Relief Act (Japan)</u>
**Article 39** (Voindance Due to Special Circumstances)
1. The court which issued an order or provisional relief or the court of the principal case may, upon the motion of the obligor, void the provisional relief on the condition that the obligor provide a security, in cases where special circumstances exist such that, *inter alia*, there is a fear that the execution of the order of provisional relief would cause irreparable dames to the obligor.
2. The obligor shall make a preliminary showing of the special circumstances proviede for in the preceding paragraph.
3. Article 13, paragraph 3 (No Substitute for Preliminary Showing) shall apply *mutatis mutandis* to the provision of the preceding paragraph on preliminary showing; the main clause of Article 16 (Statement of Grounds), Article 17 (Service) shall apply *mutatis*

*mutandis* to a ruling on a motion referred to in paragraph 1 of this Article.

**មាត្រា ៥៦០.-** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្ដីពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ជាអាទិ៍

១- បញ្ញត្តិពីមាត្រា ៥៥១ (ការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) ដល់មាត្រា ៥៥៣ (ការបញ្ចប់ការវិនិច្ឆ័យ) មាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) និង មាត្រា ៥៥៦ (អានុភាពនៃដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការសម្រេចសេចក្ដីអំពីការលុបចោលដីកាសម្រេចរក្សាការពារ លើកលែងតែចំពោះការសម្រេចសេចក្ដី តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៤៧ (ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ជាអាទិ៍) ។

២- ចំពោះការសម្រេចសេចក្ដីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ (ការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងករណីដែលពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ ត្រូវបានដាក់ទៅតុលាការនៃបណ្ដឹងអង្គសេចក្ដី ផ្សេងពីតុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ហើយមានសំណុំរឿងនៅតុលាការដែលបានចេញដីកាសម្រេចរក្សាការពារ តុលាការដែលបានចេញដីកាសម្រេចរក្សាការពារនោះ ក៏អាចធ្វើការសម្រេចសេចក្ដី តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ នោះបានដែរ ។

(កំណត់)

សូមមើលមាត្រា 40 នៃច្បាប់ស្ដីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។

<u>Civil Provisional Relief Act (Japan)</u>
**Article 40** (*Mutatis Mutandis* Application to the Provisions on Objection to Orders of Provisional Relief)
1. The provisions of Articles 27 to 31 inclusive (Stay or Voidance of Orders of Execution, Transfer of Cases, Methods of Investigation, etc.), and Articles 33 to 36 inclusive (Orders to Recover, Effect of Rulings to Void Orders, Withdrawal of a Motion for Objection, Powers of Assistant Judge) shall apply *mutatis mutandis* to a decision to void provisional relief; provided that Articles 27 to 31 inclusive, and Articles 33, 34 and 36 shall not apply *mutatis mutandis* to a decision rendered under Article 37, paragraph 1 (Voidance of an Order Due to Failure to Institute a Civil Action on the Principal Case).
2. In cases where a motion for voidance of an order of provisional relief is filed with the court of principal action other than the court that issued the order of provisional relief, if the record of the case is still in the custody of that court, that court may also render a decision under Article 27, paragraph 1 applied *mutatis mutandis* through the preceding paragraph.

## ផ្នែកទី ៦ បណ្ដឹងជំទាស់

**មាត្រា ៥៦១.-** បណ្ដឹងជំទាស់

១- ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ អាចប្ដឹងជំទាស់ក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ ចាប់ពីថ្ងៃដែលបានទទួលការបញ្ជូននោះ :

**ក-** ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ឬ ពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរក្សាការពារ ។

**ខ-** ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃមាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) នៃក្រមនេះ ។

**គ-** ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃមាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា នៅក្នុងកថាខណ្ឌទី ១ មាត្រា ៥៦០ (ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ជាអាទិ៍) ។

ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសេចក្តីសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ដែលបានធ្វើឡើងដោយតុលាការនៃបណ្តឹងជំទាស់ ។

២- អំឡុងពេលដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ ពុំអាចពន្យារបានទេ ។

៣- បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) និង មាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចអំពីបណ្តឹងជំទាស់ ហើយបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ (ការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) មាត្រា ៥៥២ (ការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) មាត្រា ៥៥៣ (ការបញ្ចប់ការវិនិច្ឆ័យ) និង មាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការសម្រេចសេចក្តីដែលពាក់ព័ន្ធនឹងបណ្តឹងជំទាស់ ហើយបញ្ញត្តិនៃមាត្រា ៣១៧ (ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីចំពោះដីកាសម្រេច) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសេចក្តីសម្រេចដែលអាចប្តឹងជំទាស់បាន បានចូលជាស្ថាពរ ។

៤- ចំពោះការសម្រេចសេចក្តីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ (ការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ក្នុងករណីដែលមានសំណុំរឿងនៅតុលាការដើម តុលាការដើមនោះក៏អាចធ្វើការសម្រេចសេចក្តីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ នោះបានដែរ ។

(កំណត់)

សូមមើលមាត្រា 41 នៃច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន និង មាត្រា ៣០១ (របៀបប្តឹងជំទាស់) នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសកម្ពុជា ។

ក្នុងករណីដែលតុលាការនៃបណ្តឹងជំទាស់ចេញដីកាសម្រេចរក្សាការពារជាលើកទី ១ យើងអាចយល់ថា ការជំនុំជម្រះ ២ លើក ក្នុងការចេញដីកាសម្រេច ត្រូវបានបំពេញសព្វគ្រប់ហើយ ហេតុដូច្នេះមិនអនុញ្ញាតឱ្យប្តឹងជំទាស់ទេ ។

ក្នុងករណីដែលបណ្តឹងអង្គសេចក្តីកំពុងចាត់ការនៅសាលាឧទ្ធរណ៍ បើសាលាឧទ្ធរណ៍បានចេញដីកាសម្រេចរក្សាការពារ

ឬ ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ឬ ដីកាសម្រេចដែលលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ភាគីអាចប្ដឹងជំទាស់ទៅតុលាការកំពូលបាន ។

Civil Provisional Relief Act (Japan)
**Article 41** (*Kokoku*-appeal for Provisional Relief)
1. A *kokoku*-appeal for provisional relief may be filed for any decision rendered in response to a motion got objection to or voidance of an order of provisional relief (this shall include a decision rendered under Article 33 (including the cases where Article 33 shall apply *mutatis mutandis* through paragraph 1 of the preceding Article) within the peremptory term of two weeks from the receipt the service of process of the order. Provided that, this shall not apply to a decision rendered in response to a motion for objection to an order of provisional relief issued by the *kokoku*-appeal court.
2. The original court shall transfer a case to the *kokoku*-appeal court without judging the existence of reasonable grounds for the appeal, upon a *kokoku*-appeal for provisional relief being filed with the original court.
3. No *kokoku*-appeal may be filed for decisions rendered in response to a *kokoku*-appeal.
4. The main clause of Article 16 (Statement of Grounds), Article 17 (Service) and Article 32, paragraph 2 and 3 (Continuation or Voidance Subject to Provision of Security) shall apply *mutatis mutandis* to a ruling rendered in response to a *kokoku*-appeal for provisional relief; Article 27, paragraph 1,4 and 5 (Stay or Voidance of Orders of Execution, etc.), Articles 29 to 31 inclusive (Methods of Investigation, Conclusion of Cases) and Article 33 (Orders to Recover) shall apply *mutatis mutandis* to proceedings of *kokoku*-appeal for provisional relief; and Article 429 of the Code of Civil Procedure (Retiral Against *Kokoku*-appeal) shall apply *mutatis mutandis* to cases where a ruling for which a *kokoku*-appeal for provisional relief might have been filed becomes final.
5. The original court also may render a ruling under Article 27, paragraph 1, applied *mutatis mutandis* through paragraph 3, in cases where the record of the case is still in the custody of the original court.

## ជំពូកទី ៣ ការអនុវត្តរក្សាការពារ

**មាត្រា ៥៦២.-** ល័ក្ខខ័ណ្ឌនៃការអនុវត្តរក្សាការពារ

១- ការអនុវត្តរក្សាការពារត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ ។ ប៉ុន្តែ ការអនុវត្តរក្សាការពារចំពោះ ឬ សម្រាប់ជនក្រៅពីភាគី ដែលត្រូវបានកំណត់នៅក្នុងដីកាសម្រេចរក្សាការពារ ត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារដែលភ្ជាប់នឹងរូបមន្តអនុវត្ត ។

២- ការអនុវត្តរក្សាការពារ មិនត្រូវធ្វើឡើយ បើអំឡុងពេល ២ (ពីរ) សប្ដាហ៍ បានកន្លងហួស ចាប់ពីថ្ងៃដែលដីកាសម្រេចរក្សាការពារ ត្រូវបានបញ្ជូនទៅម្ចាស់បំណុល ។

៣- ទោះបីនៅមុនពេលដែលដីកាសម្រេចរក្សាការពារ ត្រូវបានបញ្ជូនទៅកូនបំណុលក៏ដោយ ក៏ការអនុវត្តរក្សាការពារអាចធ្វើបានដែរ ។

(កំណត់)

សូមមើលមាត្រា 43 នៃច្បាប់ស្ដីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។

ដោយសារការអនុវត្តរក្សាការពារ ចាំបាច់មានភាពជាបន្ទាន់នោះ ជាគោលការណ៍ ពុំចាំបាច់មានការផ្ដល់រូបមន្តអនុវត្តទេ (កថាខណ្ឌទី ១) ។ម្យ៉ាងទៀត ការចាត់ចែងរក្សាការពារត្រូវបានបង្គាប់ជាវិធានការសម្រាប់ឱ្យទាន់ស្ថានភាពជាបន្ទាន់ ហើយត្រូវអនុវត្តភ្លាម ហេតុដូច្នេះ មានការកម្រិតពេល ២ សប្ដាហ៍នៃអំឡុងពេលអនុវត្ត (កថាខណ្ឌទី ២) ។

ប៉ុន្តែ បើចាប់ផ្តើមសកម្មភាពអនុវត្តក្នុងអំឡុងពេល ២ សប្តាហ៍នោះជាការគ្រប់គ្រាន់ ហើយចំពោះសកម្មភាពការអនុវត្តបន្ត ពេលក្រោយមកនោះ ពុំចាំបាច់ធ្វើក្នុងអំឡុងពេលអនុវត្តនោះទេ ។ ជាបន្ថែម ដោយសារចាំបាច់មានភាពបន្ទាន់ និង ភាពសម្ងាត់នៃការចាត់ចែងរក្សាការពារ មាត្រានេះមិនយកការបញ្ជូនជាមុននូវដីកាសម្រេចរក្សាការពារ ទៅកូនបំណុល មកធ្វើជាល័ក្ខខ័ណ្ឌនៃការអនុវត្តទេ (កថាខណ្ឌទី ៣) ។

Civil Provisional Relief Act (Japan)
**Article 43** (Requirements for Execution)
1. Execution of provisional relief shall be effected based on an authenticated copy of the order of provisional relief. Provided that, execution of provisional relief on behalf of or against a person other than the one designated in the order of provisional relief shall be effected based on an authenticated copy of the order of provisional relief to which the execution clause was attached.
2. An order of provisional relief may be executed no later than two weeks after the date of service of the order on the obligee.
3. An order of provisional relief may be executed even prior to service of the order on the obligor.

**មាត្រា ៥៦៣.-** ករណីពិសេសនៃតុលាការដែលមានសមត្ថកិច្ចលើបណ្តឹងតវ៉ារបស់តតិយជន

ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៦៥ (បណ្តឹងតវ៉ារបស់តតិយជន) នៃក្រមនេះក៏ដោយ ក៏បណ្តឹងតវ៉ារបស់តតិយជន ចំពោះដីកាសម្រេចរក្សាការពារដែលសាលាឧទ្ធរណ៍បានធ្វើ ក្នុងនាមជាតុលាការអនុវត្តរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែង ដែលវត្ថុត្រូវរឹបអូសជាបណ្តោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ ។

(កំណត់)

សូមមើលមាត្រា 45 នៃច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។

តុលាការអនុវត្តរក្សាការពារត្រូវបានកំណត់តាមវិធីអនុវត្ត ដោយយោងទៅតាមបញ្ញត្តិនៃមាត្រា ៥៦៥ (ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ) ទៅ តែក្នុងចំណោមករណីដែលតុលាការដែលចេញដីកាសម្រេចរក្សាការពារ ក្លាយទៅជាតុលាការអនុវត្តរក្សាការពារ (ឧទាហរណ៍ សូមមើលកថាខណ្ឌទី ២ នៃមាត្រា ៥៦៦ (ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត)) មានករណីដែលតុលាការអនុវត្តរក្សាការពារជាសាលាឧទ្ធរណ៍ ។ ចំពោះបណ្តឹងតវ៉ារបស់តតិយជនក្នុងករណីនេះ បើយោងតាមគោលការណ៍ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍ (កថាខណ្ឌទី ២ នៃមាត្រា ៣៦៥ (បណ្តឹងតវ៉ារបស់តតិយជន)) តែការដែលការជំនុំជម្រះលើកទី ១ អំពីបណ្តឹងខាងលើនេះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍នោះ ជាការមិនសមហេតុសមផល ហេតុដូច្នេះហើយ ចំពោះករណីដូចបានរៀបរាប់ខាងលើនេះ បញ្ញត្តិនៃមាត្រានេះកំណត់សាលាដំបូងនៅទីកន្លែងដែលមានកម្មវត្ថុ ជាតុលាការមានសមត្ថកិច្ច ។

Civil Provisional Relief Act (Japan)
**Article 45** (Exception to Jurisdictional Court over Actions of Third Party Objections)
An action of third party objection to the execution of provisional relief enforced by an appellate court acting as the court of execution

of provisional relief shall be subject to the jurisdiction of the district court which has jurisdiction over the district where the property to be provisionally attached or subject-matter in dispute is located.

**មាត្រា ៥៦៤.-** ការអនុវត្តដូចគ្នា តាមបញ្ញត្តិនៃគន្ថីទី ៦

លើកលែងតែករណីដែលមានបញ្ញត្តិពិសេសក្នុងជំពូកនេះ បញ្ញត្តិពីមាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) ដល់ មាត្រា ៣៤៥ (បណ្ដឹងជំទាស់ចំពោះដីកាសម្រេចលុបចោល ជាអាទិ៍) បញ្ញត្តិនៃមាត្រា ៣៤៨ (អ្នកតំណាងដោយអាណត្តិក្នុងនីតិវិធីទាក់ទងនឹងការអនុវត្តដោយបង្ខំ) បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៣៤៩ (របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ នៃមាត្រា ៣៥១ (វិសាលភាពនៃអ្នកដែលអាចអនុវត្តដោយបង្ខំ) កថាខណ្ឌទី ២ នៃមាត្រា ៣៥៤ (ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្ដល់រូបមន្តអនុវត្ត) កថាខណ្ឌទី ១ និង ទី ៣ នៃមាត្រា ៣៥៥ (ពាក្យសុំឱ្យផ្ដល់រូបមន្តអនុវត្ត) ពីកថាខណ្ឌទី ២ ដល់ កថាខណ្ឌទី ៤ នៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) ពីមាត្រា ៣៥៧ (ចំណុចដែលត្រូវសរសេរក្នុងរូបមន្តអនុវត្ត) ដល់ មាត្រា ៣៥៩ (ការសរសេរចូលទៅក្នុងច្បាប់ដើមនៃលិខិតអនុវត្ត) មាត្រា ៣៦២ (ពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត ជាអាទិ៍) បញ្ញត្តិនៃមាត្រា ៣៦៤ (បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត) និង មាត្រា ៣៦៥ (បណ្ដឹងតវ៉ារបស់តតិយជន) និង បញ្ញត្តិពីមាត្រា ៣៦៧ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍) ដល់ មាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរក្សាការពារ ។

(កំណត់)

សូមមើលមាត្រា 46 នៃច្បាប់ស្ដីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។

បញ្ញត្តិស្ដីពីការអនុវត្តដោយបង្ខំ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តការរក្សាការពារ លុះត្រាតែមិនផ្ទុយពីលក្ខណៈនៃការអនុវត្តការរក្សាការពារនោះ ។ មាត្រានេះកំណត់អំពីបញ្ញត្តិដែលត្រូវយកមកអនុវត្តដូចគ្នាចំពោះការអនុវត្តការរក្សាការពារ ក្នុងចំណោមបញ្ញត្តិស្ដីពីបទប្បញ្ញត្តិទូទៅនៃជំពូកទី ១ នៃគន្ថីទី ៦ ។

Civil Provisional Relief Act (Japan)
**Article 46** (*Mutatis Mutandis* Application of Civil Execution Act)
Except as otherwise provided in this Chapter, Articles 5 to 14 inclusive (Interrogation, Insuring Performance of Execution Officer's Duty, Witness, Execution on Holidays or at Night, Identification, *Kokoku*-appeal From or Objection to Execution, Representatives, Advancement of Costs), Article 16 (Service of Process), Article 18 (Assistance of Government Office), Article 23, paragraph 1 (Parties to Execution), Article 26 (Execution Clause), Article 27, paragraph 2 (Execution Clause in Cases of Succession), Article 28 (Additional Attachment of Execution Clause), Article 30, paragraph 2 (Execution Subject to Provision of Security), Article 32 to 34 inclusive)Objection to or Action for Issuance of Execution Clause), Articled 36 to 38 inclusive (Decisions of Stay of Execution, Actions of Third Party Objection), Article 39, paragraph 1, items i to iv inclusive, items vi and vii (Documents for Stay of Execution or Voidance of Executorial Disposition) and Article 41 (Execution after Obligor's Death) of the Civil Execution Act shall apply *mutatis mutandis* to the execution of provisional relief.

**មាត្រា ៥៦៥.-** ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ

១- ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ត្រូវធ្វើតាមរបៀបកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុនោះស្ថិតនៅ ។

២- អាជ្ញាសាលាត្រូវធ្វើប្រាក់ដែលបានមកពីការអនុវត្តរឹបអូសជាបណ្តោះអាសន្ន នៅតុលាការដែលខ្លួនស្ថិតនៅ ។

៣- បើមានការបារម្ភថា ចលនវត្ថុដែលការរឹបអូសជាបណ្តោះអាសន្នត្រូវបានអនុវត្ត នឹងចុះតម្លៃយ៉ាងខ្លាំង ឬ បើត្រូវការសោហ៊ុយច្រើនហួសហេតុដើម្បីរក្សាទុកចលនវត្ថុនោះ អាជ្ញាសាលាត្រូវលក់ចលនវត្ថុនោះ តាមនីតិវិធីលក់នៃការអនុវត្តចំពោះចលនវត្ថុដែលបានកំណត់នៅក្នុងផ្នែកទី ២ ជំពូកទី ២ នៃគន្ថីទី ៦ នៃក្រមនេះ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការរឹបអូសជាបណ្តោះអាសន្ន ឬ កូនបំណុល ហើយធ្វើប្រាក់ដែលបានមកពីការលក់នោះនៅតុលាការដែលខ្លួនស្ថិតនៅ ។

៤- បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៨៤ (ការចាប់ផ្តើមអនុវត្តចំពោះចលនវត្ថុ) ពីមាត្រា ៣៨៥ (ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត) ដល់ មាត្រា ៣៩២ (ការហាមឃាត់មិនឱ្យរឹបអូសក្នុងករណីដែលប៉ាន់ប្រមាណឃើញថា គ្មានចំនួនសេសសល់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ។

(កំណត់)

សូមមើលមាត្រា 49 នៃច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។

ការរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ត្រូវអនុវត្តដោយអាជ្ញាសាលា ហើយ ជាមូលដ្ឋាន របៀបនេះដូចគ្នានឹងការរឹបអូសចលនវត្ថុដែរ (កថាខណ្ឌទី ១ និង កថាខណ្ឌទី ៤) ។ ប៉ុន្តែ ក្នុងករណីដែលកម្មវត្ថុនៃការរឹបអូសជាប្រាក់ពុំត្រូវផ្តល់ផ្ទាល់ទៅម្ចាស់បំណុលនៃការរឹបអូសទេ គឺត្រូវធ្វើនៅតុលាការ (កថាខណ្ឌទី ២) ហើយក្នុងករណីដែលកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន ច្បាស់ជានឹងចុះថោក ឬ ជាវត្ថុដែលត្រូវការសោហ៊ុយដើម្បីរក្សាទុក ត្រូវធ្វើការលក់ជាបណ្តោះអាសន្ន និង ត្រូវធ្វើប្រាក់លក់នោះនៅតុលាការ (កថាខណ្ឌទី ៤) ។ ម្យ៉ាងទៀត អំពីការរឹបអូសជាបណ្តោះអាសន្នចំពោះរថយន្ត និង ទោចក្រយានយន្តដែលមានចុះបញ្ជី បញ្ញត្តិនៃមាត្រា ៣៨៧ (បទប្បញ្ញត្តិពិសេសស្តីពីរថយន្ត ជាអាទិ៍ ដែលបានចុះបញ្ជី) ត្រូវយកមកអនុវត្ត ហេតុដូច្នេះ អាជ្ញាសាលាដែលបានអនុវត្តរឹបអូសជាបណ្តោះអាសន្ន ត្រូវផ្ទុកផ្តាក់ឱ្យសរសេរនូវហេតុការណ៍នៃការរឹបអូស ចូលទៅក្នុងសៀវភៅចុះបញ្ជី ហើយការរឹបអូសមានអានុភាពនៅពេលដែលបានសរសេរហេតុនោះហើយ ។

Civil Provisional Relief Act (Japan)

**Article 49** (Execution of Orders of Provisional Attachment against Movables)

1. Execution of orders of provisional attachment against movables shall be enforced by the execution officer's taking possession of the subject matter.
2. The execution officer shall deposit money obtained through execution of an order of provisional attachment. The same shall apply to money which is paid to the execution officer for provisionally attached bills, checks, or any other valuable instruments for

payment of money which must be demanded, during a period designated for the exercise of a right.
3. In cases where remarkable depreciation of the value of the movables concerned in an execution of provisional attachment is threatened or where unreasonable expense is necessary for the custody thereof, the execution officer shall sell the movables by the procedure of sale of execution against movables provided for in the provisions of the Civil Execution Act and deposit the proceeds.
4. The provisions of Article 123 to 129 inclusive (Methods and Effect of Provisional Attachment of Movables, Orders of Delivery of Attached Property, Prohibition of Double Attachment or Excessive Attachment, and Prohibition of Attachment without Surplus), Article 131 (Movables which may not be Attached), Article 132 (Alteration of List of Movables which may not be Attached) and Article 136 (Duty to Present a Bill, etc.) of the Civil Execution Act shall apply *mutatis mutandis* to the execution of an order of provisional attachment against a movable.

**មាត្រា ៥៦៦.-** ការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

១- ការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងមាត្រា ៤០២ (អត្ថន័យនៃការអនុវត្តចំពោះសិទ្ធិលើបំណុល និង តុលាការអនុវត្ត) នៃក្រមនេះ ត្រូវធ្វើតាមរបៀបដែលតុលាការអនុវត្តរក្សាការពារចេញដីកាសម្រេចដែលហាមឃាត់មិនឱ្យកូនបំណុលទី ៣ សងទៅកូនបំណុល ។

២- ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្នដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការដែលបានចេញដីកាសម្រេចរឹបអូសបណ្ដោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ ។

៣- ក្នុងករណីដែលការរឹបអូសជាបណ្ដោះអាសន្ន ត្រូវបានអនុវត្តចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ បើកូនបំណុលទី ៣ បានផ្ញើប្រាក់ដែលស្មើនឹងចំនួនប្រាក់នៃសិទ្ធិលើបំណុលនៅតុលាការ ត្រូវចាត់ទុកថា កូនបំណុលបានផ្ញើប្រាក់ដែលស្មើនឹងចំនួនប្រាក់ដែលត្រូវបានកំណត់តាមបញ្ញត្តិនៃមាត្រា ៥៤៧ (ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន) នៃក្រមនេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះភាគដែលលើសពីចំនួនប្រាក់នោះ ។

៤- បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ។

៥- បញ្ញត្តិនៃកថាខណ្ឌទី ២ ទី ៣ ទី ៦ ទី ៧ ទី ៨ ទី ១០ និង កថាខណ្ឌទី ១១ នៃមាត្រា ៤០៣ (ដីកាសម្រេចរឹបអូស) បញ្ញត្តិពីមាត្រា ៤០៤ (ទំហំនៃការរឹបអូស) ដល់មាត្រា ៤០៨ (ការជូនដំណឹងអំពីការដកពាក្យសុំ ជាអាទិ៍) មាត្រា ៤១១ (ការផ្ញើប្រាក់ទុកដោយកូនបំណុលទី ៣) និង មាត្រា ៤១៦ (ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត។

(កំណត់)

សូមមើលមាត្រា 50 នៃច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។

ការរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុល ត្រូវធ្វើដោយតុលាការអនុវត្តរក្សាការពារ ហើយជាមូលដ្ឋានរបៀបនោះដូចគ្នានឹងការរឹបអូសសិទ្ធិលើបំណុលដែរ (កថាខណ្ឌទី ១ និង កថាខណ្ឌទី ៥) ។ម្យ៉ាងទៀត បើកូនបំណុលទី ៣ ដែលបានទទួលការរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុល បានផ្ញើសិទ្ធិលើបំណុលនោះទាំងអស់ ឬ មួយផ្នែក

ចំនួនប្រាក់ដែលស្មើនឹងប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន ក្នុងចំណោមប្រាក់ផ្ញើនោះ ត្រូវចាត់ទុកថាជាការផ្ញើប្រាក់រំដោះ តែចំពោះភាគដែលលើសចំនួនប្រាក់ដែលស្មើនឹងប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ននោះ ការផ្ញើនៅតុលាការបង្កើតឱ្យមានអានុភាពនៃការសងទៅកូនបំណុលនៃការអនុវត្ត (កថាខណ្ឌទី ៣) ។ អំពីការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ក្នុងករណីដែលប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន ត្រូវបានផ្ញើ សូមមើលមាត្រា ៥៦៩ (ការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ដោយផ្ញើប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន) ។

Civil Provisional Relief Act (Japan)

**Article 50** (Execution of Orders of Provisional Attachment against Claims and Other Property Rights)

1. Execution of an order of provisional attachment against a claim as provided in Article 143 of the Civil Execution Act shall be enforced by means of issuance by the court of execution of an order prohibiting the third party obligor from satisfying the obligor.
2. With regard to execution of an order or provisional attachment referred to in the preceding paragraph, the court that issued the order of provisional attachment shall have jurisdiction thereof as the court of execution of provisional relief.
3. If the third party obligor has deposited money corresponding to the amount of the claim for payment of money provisionally attached, the obligor shall be deemed to have deposited money corresponding to the amount designated in the order of provisional attachment in accordance with the provisions of Article 22, paragraph 1. Provided that, this shall not apply to any portion of such deposited money exceeding such amount.
4. The provisions of paragraph 1 and 2 of this Article shall apply *mutatis mutandis* to the execution of an order of provisional attachment against any property right other than a claim.
5. The provisions of Article 145, paragraph 2 to 5 inclusive (Orders of Attachment), Article 146 to 153 inclusive (Coverage of Attachment, Effect, Exemption of Attachment of a Claim), Article 156 (Deposit by a Third Party Obligor), Article 164, paragraph 4 and 5 (Entrustment of Erasure of Registration) and Article 167 (Execution Against Other Property Rights) of the Civil Execution Act shall apply *mutatis mutandis* to the execution of an order of provisional attachment against a claim or any other property right provided for in paragraph 1 of this Article.

**មាត្រា ៥៦៧.-** ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

១- ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤១៧ (កម្មវត្ថុ និង វិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ) នៃក្រមនេះ ត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ។

២- ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្ន តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ ។

៣- ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ។

៤- បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៤២០ (ការផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូស ជាអាទិ៍) វាក្យខណ្ឌទី ១ កថាខណ្ឌទី ៣ នៃមាត្រា ៤២១ (អានុភាពនៃការរឹបអូស) កថាខណ្ឌទី ១ នៃមាត្រា ៤២៤ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា) មាត្រា ៤២៥ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តចំពោះអចលនវត្ថុ) មាត្រា ៤២៧ (ការលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដោយសារការបាត់បង់ ជាអាទិ៍ នៃអចលនវត្ថុ) និង មាត្រា ៤២៨ (ការផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ។

(កំណត់)

សូមមើលមាត្រា 47 នៃច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។

ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ត្រូវបានអនុវត្ត តាមការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន (កថាខណ្ឌទី ១) ដោយតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន (កថាខណ្ឌទី ២) ហើយជាមូលដ្ឋានរបៀបនោះ ដូចគ្នានឹងការរឹបអូសអចលនវត្ថុដែរ (កថាខណ្ឌទី ៤) ។

**មាត្រា ៥៦៨.-** ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះនាវា

១- ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះនាវា ត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ឬតាមរបៀបដែលបង្គាប់ឱ្យអាជ្ញាសាលាដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ហើយផ្តល់លិខិតនោះទៅ តុលាការអនុវត្តរក្សាការពារ ។ របៀបទាំងនេះ អាចអនុវត្តរួមគ្នាបាន ។

២- ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ រីឯការអនុវត្តរឹបអូសជាបណ្តោះអាសន្នតាមរបៀបដែលបង្គាប់ឱ្យដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះស្ថិតនៅ ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ ។

៣- ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ។

៤- បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៤៥៥ (ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា និង របៀបអនុវត្ត) មាត្រា ៤៦៥ (ការលុបចោលនីតិវិធីលក់ដោយបង្ខំ ដោយការវិនាសបាត់បង់នាវា ជាអាទិ៍) និង មាត្រា ៤៦៦ (ការផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្ន តាមរបៀបចុះបញ្ជី ហើយបញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ៤៥៥ (ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា និង របៀបអនុវត្ត) កថាខណ្ឌទី ៧ នៃមាត្រា ៤៥៧ (ដីកាសម្រេចចាប់ផ្តើម ជាអាទិ៍) មាត្រា ៤៦០ (ការជ្រើសតាំងអ្នកថែរក្សាគ្រប់គ្រង ជាអាទិ៍) និង មាត្រា ៤៦២ (ការអនុញ្ញាតឱ្យនាវាធ្វើដំណើរ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្ន តាមរបៀបដែលបង្គាប់ឱ្យដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ។

(កំណត់)

សូមមើលមាត្រា 48 នៃច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។

ការរឹបអូសជាបណ្តោះអាសន្នចំពោះនាវា ត្រូវអនុវត្តដោយតុលាការអនុវត្តរក្សាការពារ ហើយជាមូលដ្ឋានរបៀបនោះ ដូចគ្នានឹងការរឹបអូសនាវាដែរ (កថាខណ្ឌទី ១ និង កថាខណ្ឌទី ៤) ។ ចំពោះអត្ថន័យនៃនាវា សូមមើល

កថាខណ្ឌទី ១ មាត្រា ៤៥៤ ( អត្ថន័យនៃនាវា ជាអាទិ៍ ) ។

Civil Provisional Relief Act (Japan)
**Article 48** (Execution of Orders of Provisional Attachment against Ships)
1. Execution of provisional attachment against a ship shall be enforced through registration of the provisional attachment, or by ordering the execution officer to seize the document evidencing the nationality of the ship or any other document necessary for navigation (hereinafter referred to as "certificate of ship nationality, etc.") and to submit them to the court of execution of provisional relief. These methods may be used in conjunction with each other.
2. With regard to an execution of provisional attachment by means of registration of the provisional attachment, the court that issued the order of provisional attachment shall have jurisdiction thereof as the court of execution of provisional relief; and with regard to execution of provisional attachment by means of an order to seize the certificate of ship nationality, etc., the district court having jurisdiction over the place where the ship is located shall have jurisdiction as the court of execution of provisional relief.
3. The provisions of paragraph 3 of the preceding Article, Article 46, paragraph 2 (Obligor's Use of or Profit from Attached Property), Article 47, paragraph 1 (Double Rulings of Commencement), Article 48, paragraph 2 (Remittance of Transcript by Registrar), Article 53 (Voidance of Proceedings due to Destruction of Immovables) and Article 54 (Entrustment to Erase Registration) of the Civil Execution Act shall apply *mutatis mutandis* to the execution of an order of provisional attachment by means of registration of provisional attachment; Article 45, paragraph 3 (*Kokoku*-appeal Concerning Execution against Ruling to Dismiss a Motion for Compulsory Sale by Auction), Article 47, paragraph 1, Article 53, Article 116 (Appointment of Custodian of Ship) and Article 118 (Permission to Navigate) of the Civil Execution Act shall apply *mutatis mutandis* to the execution of an order of provisional attachment by means of an order to seize the certificate of ship nationality, etc.

**មាត្រា ៥៦៩.-** ការលុបចោលការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ដោយផ្ញើប្រាក់រំដោះពីការរឹបអូសជាបណ្ដោះ-អាសន្ន

១- បើកូនបំណុលបានផ្ញើប្រាក់ស្មើនឹងចំនួនប្រាក់ដែលបានកំណត់តាមបញ្ញត្តិនៃមាត្រា ៥៤៧ ( ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន) នៃក្រមនេះ នៅតុលាការ តុលាការអនុវត្តរក្សាការពារ ឬ សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ ត្រូវលុបចោលនូវការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ។

២- ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៨៥ ( បណ្ដឹងជំទាស់ចំពោះដីកាសម្រេចលុបចោល ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកអនុវត្តដូចគ្នា នៅក្នុងមាត្រា ៥៦៤ ( ការអនុវត្តដូចគ្នា តាមបញ្ញត្តិនៃគន្ថីទី ៦) ក៏ដោយ ក៏ដីកាសម្រេចដែលធ្វើឡើង តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មានអានុភាពភ្លាមៗដែរ ។

( កំណត់)

សូមមើលមាត្រា 51 នៃច្បាប់ស្ដីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។

បើប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្នត្រូវបានផ្ញើនៅតុលាការ ការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ត្រូវបានលុបចោល ( កថាខណ្ឌទី ១ ។ អំពីអត្ថន័យនៃប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន សូមមើលកំណត់នៃមាត្រា ៥៤៧ ( ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន) ) ។ ចំពោះដីកាសម្រេចលុបចោលការអនុវត្តរឹបអូសជាបណ្ដោះអាសន្ននោះ អាចប្ដឹងជំទាស់បាន តែមាត្រានេះកំណត់ថា ទោះបីជាដីកាសម្រេចនេះពុំទាន់ចូលជាស្ថាពរក៏ដោយ ក៏ដីកាសម្រេចនេះមានអានុភាពនៃការលុបចោលការអនុវត្តដែរ ដោយផ្អែកលើភាពច្បាស់លាស់នៃល័ក្ខខ័ណ្ឌនៃការវិនិច្ឆ័យនោះ ( កថាខណ្ឌទី ២) ។

Civil Provisional Relief Act (Japan)
**Article 51** (Voidance of a Provisional Attachment due to Security Deposit for Release of Provisional Attachment)
1. In cases where the obligor proves that he or she has deposited money corresponding to the amount designated in accordance with the provisions of Article 22, paragraph 1, the court of execution of provisional relief shall void the execution of provisional attachment.
2. A ruling rendered in accordance with the preceding paragraph shall be of immediate effect, notwithstanding the provisions of Article 12, paragraph2 of the Civil Execution Act applied *mutatis mutandis* through Article 46.

**មាត្រា ៥៧០.-** ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន

ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន ត្រូវអនុវត្តតាមវិធីដូចគ្នានឹងវិធីអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ឬ វិធីអនុវត្តដោយបង្ខំ ។

(កំណត់)

សូមមើលកថាខណ្ឌទី 1 មាត្រា 52 នៃច្បាប់ស្ដីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។

ចំពោះការចាត់ចែងជាបណ្ដោះអាសន្ន ដោយវិធីនោះមានច្រើនប្រភេទ (សូមមើលមាត្រា ៥៤៩ (វិធីចាត់ចែងជាបណ្ដោះអាសន្ន)) យើងពុំរៀបចំបញ្ញត្តិស្ដីពីវិធីអនុវត្តជារូបីទេ តែចែងថា ត្រូវអនុវត្តតាមវិធីដូចគ្នានឹងវិធីអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ឬ វិធីអនុវត្តដោយបង្ខំ ដោយសារវិធីអនុវត្តចាត់ចែងនោះ អាស្រ័យទៅតាមសេចក្ដីសម្រេចបញ្ចប់នៃដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ។

Civil Provisional Relief Act (Japan)
**Article 52** (Execution of Orders of Provisional Disposition) (excerpt)
1. Except as provided in this Section, execution of an order of provisional disposition shall proceed in the same manner as execution of an order of provisional attachment or compulsory execution.

**មាត្រា ៥៧១.-** អានុភាពនៃការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់

១- បើដីកាសម្រេចដែលហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាប់កាប់វត្ថុ និង បង្គាប់ឱ្យកូនបំណុលប្រគល់វត្ថុទៅអាជ្ញាសាលា ដោយដកហូតការកាន់កាប់នោះ ហើយបង្គាប់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ ដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យប្រគល់វត្ថុនោះ ត្រូវបានចេញ អាជ្ញាសាលាត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាប់កាប់វត្ថុនោះ ហើយអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ ដោយបិទលិខិតប្រកាសជាសាធារណៈតាមរបៀបដែលពុំងាយបកចេញ ឬ តាមរបៀបសមរម្យផ្សេងទៀត ។

២- បើការចាត់ចែងជាបណ្ដោះអាសន្នដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានអនុវត្ត ម្ចាស់បំណុលអាចធ្វើការអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុបាន ដោយផ្អែកលើលិខិតអនុវត្តនៃអង្គសេចក្ដី ។ ប៉ុន្តែ ម្ចាស់បំណុលអាចអនុវត្តបានតែចំពោះជនដែលកាន់កាប់វត្ថុនោះ ដោយដឹងថា ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននោះត្រូវបានធ្វើហើយ ។

៣- ជនដែលកាន់កាប់វត្ថុដែលពាក់ព័ន្ធក្រោយពេលការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានសន្មតថា កាន់កាប់វត្ថុនោះ ដោយដឹងថា ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ននោះត្រូវបានធ្វើហើយ ។

(កំណត់)

សូមមើលមាត្រា 61 និង មាត្រា 62 នៃច្បាប់ស្ដីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន និង មាត្រា 44 នៃបទប្បញ្ញត្តិស្ដីពីការរក្សាការពារផ្នែករដ្ឋប្បវេណីជប៉ុន ។

ក្នុងបណ្ដឹងទាមទារឱ្យប្រគល់វត្ថុ ក្រោយការដាក់ពាក្យបណ្ដឹង បើធ្វើបណ្ដឹងដោយយកអ្នកដែលកាន់កាប់វត្ថុនោះនៅពេលបណ្ដឹងចាត់ការ មកធ្វើជាចុងចម្លើយ ទោះជាមានការបន្តទំនាក់ទំនងនៃការកាន់កាប់វត្ថុនោះ ក្រោយការដាក់ពាក្យបណ្ដឹងក៏ដោយ ក៏អានុភាពនៃសាលក្រម ឬ សាលដីកានោះនឹងមានទៅលើអ្នកកាន់កាប់បន្តដែរ (ចំណុច **គ** នៃមាត្រា ១៩៨ (វិសាលភាពបុគ្គលដែលត្រូវទទួលអានុភាពរបស់សាលក្រមស្ថាពរ) និង ចំណុច **គ** កថាខណ្ឌទី ១ នៃមាត្រា ៣៥១ (វិសាលភាពនៃអ្នកដែលអាចអនុវត្តដោយបង្ខំ)) ។ ប៉ុន្តែ សាលក្រម ឬ សាលដីកាពុំមានអានុភាពទៅលើអ្នកកាន់កាប់ ដែលមិនបានបន្តទំនាក់ទំនងនៃការកាន់កាប់ ពីអ្នកកាន់កាប់វត្ថុនៅពេលដាក់ពាក្យបណ្ដឹងនោះ (ឧ. : អ្នកកាន់កាប់ដោយខុសច្បាប់ ជាអាទិ៍) ទេ ហើយចំពោះករណីនៃចលនវត្ថុ អាចនាំឱ្យមានអ្នកទទួលដោយសុច្ឆរិតដែរ ។ ក្នុងករណីដែលធ្វើការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ ដោយដកហូតការកាន់កាប់ជាក់ស្ដែងពីកូនបំណុលនោះ គ្មានបញ្ហាដូចខាងលើនេះកើតឡើងទេ ប៉ុន្តែ តាមការអនុវត្តជាក់ស្ដែង មានករណីច្រើនដែលតុលាការចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ ដោយអនុញ្ញាតឱ្យកូនបំណុលប្រើប្រាស់វត្ថុ ។ ហេតុដូច្នេះ ការឱ្យមានវិធីដែលអ្នកដែលបានដាក់ពាក្យបណ្ដឹង ឬ អ្នកដែលបម្រុងដាក់ពាក្យបណ្ដឹងទាមទារឱ្យប្រគល់កម្មវត្ថុ អាចកំណត់ ដោយភាពមិនប្រែប្រួលនូវទំនាក់ទំនងនៃការកាន់កាប់បច្ចុប្បន្ន គឺគោលបំណងនៃមាត្រានោះ ។

ដោយការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ ត្រូវបានចេញ ហើយត្រូវបានប្រកាសជាសាធារណៈ (កថាខណ្ឌទី ១) អាចជៀសវាងការនាំឱ្យមានអ្នកបន្តដោយសុចរិត និង គ្មានកំហុស ហើយព្រមជាមួយគ្នានេះ អានុភាពនៃសាលក្រម ឬ សាលដីកា ក៏លាតសន្ធឹងទៅលើជនទុច្ចរិតដែលពុំមែនជាអ្នកបន្តដែរ (កថាខណ្ឌទី ២) ។ ហើយអ្នកដែលកាន់កាប់ក្រោយការប្រកាសជាសាធារណៈ នូវការចាត់ចែងជាបណ្ដោះអាសន្ន ត្រូវបានសន្មតថាជាអ្នកកាន់កាប់ដោយទុច្ចរិត (កថាខណ្ឌទី ៣) ។ ម្យ៉ាងទៀត វិធីប្រកាសជាសាធារណៈ ត្រូវបង្កើតឡើង ស្របតាមស្ថានភាពជាក់ស្ដែងនៅប្រទេសកម្ពុជា ។ នៅប្រទេសជប៉ុន (1) បើអាគារជាកម្មវត្ថុ ហើយត្រូវប្រកាសអំពីការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ជាសាធារណៈ នៅក្នុងអាគារនោះ អាជ្ញាសាលាដាក់លិខិតប្រកាសជាសាធារណៈនោះក្នុងសឺមីប្លាស្ទិក ជាដើម និង បិទលើកន្លែងដែលងាយស្រួលមើល ដូចជាលើជញ្ជាំង ដោយប្រើបង់ស្អិតបិទសងខាង ឬ ដំដែកគោល ជាដើម (2) បើអាគារជាកម្មវត្ថុ ហើយត្រូវប្រកាសជាសាធារណៈ ក្រៅអាគារនោះ

អាជ្ញាសាលាសរសេរអត្ថន័យប្រកាសជាសាធារណៈលើក្ដារ ហើយបោះបង្គោលក្ដារប្រកាសនោះលើដី ឬ បិទក្ដារប្រកាសនោះលើជញ្ជាំងខាងក្រៅនៃអាគារ ដោយប្រើដែកគោល ឬ ខ្សែលួស ជាដើម ឬ បិទលិខិតប្រកាសជាសាធារណៈ ដោយជៀសវាងការខូចខាតពីពន្លឺថ្ងៃ និង ភ្លៀង តាមរបៀបដូច (1) លើកម្មវត្ថុ ។ល។

ក្នុងករណីដែលអ្នកកាន់កាប់ កាន់កាប់វត្ថុដោយផ្អែកលើមូលហេតុគតិយុត្តនៃសិទ្ធិដែលអាចតតាំងចំពោះម្ចាស់បំណុល (ឧទាហរណ៍ ជននោះមានសិទ្ធិជួលដែលអាចតតាំងនឹងម្ចាស់បំណុល ជាអាទិ៍) ឬ ករណីដែលអ្នកកាន់កាប់ ពុំដឹងអំពីការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន ហើយមិនមែនជាអ្នកបន្តទំនាក់ទំនងនៃការកាន់កាប់ពីកូនបំណុល (ឧទាហរណ៍ ជននោះកាន់កាប់វត្ថុនោះ ដោយមិនដឹងអំពីការចាត់ចែងជាបណ្ដោះអាសន្នមែន ដោយសារសេចក្ដីប្រកាសជាសាធារណៈបានបកចេញ ជាអាទិ៍) ជននោះអាចអះអាងអំពីហេតុទាំងនេះ ក្នុងពាក្យសុំតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត (មាត្រា ៣៦២ (ពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត ជាអាទិ៍)) ។

<u>Civil Provisional Relief Act (Japan)</u>

**Article 62** (Effect of Orders of Provisional Disposition Prohibiting Transfer of Possession)

1. In cases where an order of provisional disposition has been issued that directs an obligor to dispossess and deliver possession of the subject-matter at issue to the execution officer, prohibits the obligor from transferring possession of the property to other persons, directs the execution officer to take the property into custody and directs the execution officer to make public that the obligor is prohibited from transferring possession of the property or that the property is in the custody of the execution officer, in order to protect a right to delivery or surrender of the property, a compulsory execution of delivery or surrender of the property may be issued against a person who takes possession of the property with knowledge of the execution of the order, upon a motion of an obligee based on an obligation title in the principal action. The same shall apply to a person who, without knowledge of the execution, succeeds to possession of an obligor's property at issue after an order of provisional disposition has been enforced against it.
2. Any person who takes possession of the property at issue after an order of provisional disposition provided for in the preceding paragraph has been enforced against it, is deemed to have taken possession of the property with knowledge of the execution.

**Article 63** (Grounds for Objection of Issuance of Execution Clauses)

In cases where an execution clause against a person other than an obligor is attached to an obligation title in the principal action as provided for in paragraph 1 of the preceding Article, the person may raise to the court an objection to the issuance of the execution clause on the grounds that the person has taken possession of the property at issue based upon a title that may be set up against the obligee, or that the person takes possession of the property without knowledge of the execution and is not the obligor's successor in possession.

# គន្ថីទី ៨ អន្តរប្បញ្ញត្តិ

## ជំពូកទោល អន្តរប្បញ្ញត្តិ

(កំណត់)

(1) អត្ថន័យនៃអន្តរប្បញ្ញត្តិ និង វិធានការអន្តរកាល

ពេលដែលមានការអនុម័តច្បាប់ថ្មី ឬ ពេលដែលបានធ្វើវិសោធនកម្ម ឬ លុបចោលនូវច្បាប់ចាស់ណាមួយ ប្រព័ន្ធច្បាប់នោះនឹងមានការផ្លាស់ប្តូរ ហើយសណ្តាប់ធ្នាប់នៃច្បាប់ក៏មានការផ្លាស់ប្តូរដែរ ។ ក្នុងករណីនេះ ប្រសិនបើអនុវត្តច្បាប់ថ្មីភ្លាមតែម្តងទៅ នឹងអាចធ្វើឱ្យខូចដល់ស្ថិរភាពច្បាប់ដោយមិនសមរម្យបាន ហើយអាចបង្កើតឱ្យមានចលាចលដល់ជីវភាពក្នុងសង្គម ឬ ដល់នីតិវិធីច្បាប់ក៏មានដែរ ។ ដូច្នេះហើយ ដើម្បីឱ្យមានភាពរលូនក្នុងការប្តូរពីសណ្តាប់ធ្នាប់ច្បាប់ចាស់ទៅសណ្តាប់ធ្នាប់ច្បាប់ថ្មី ចាំបាច់ត្រូវមានការសម្រួលរវាងសណ្តាប់ធ្នាប់នៃច្បាប់ចាស់ និង សណ្តាប់ធ្នាប់នៃច្បាប់ថ្មី ហើយទទួលស្គាល់នូវការអនុវត្តច្បាប់ចាស់ដែលមានពីមុនមកជាបណ្តោះអាសន្ន ឬ ចាំបាច់មានបញ្ញត្តិអំពីវិធានការពិសេសជាបណ្តោះអាសន្ន ស្តីពីការអនុវត្តបញ្ញត្តិនៃច្បាប់ថ្មី ។ វិធានការស្តីពីការសម្រួលនូវសណ្តាប់ធ្នាប់រវាងច្បាប់ចាស់ និង ច្បាប់ថ្មីដូចនេះ ហៅថា "វិធានការអន្តរកាល" រីឯបញ្ញត្តិដែលកំណត់នូវវិធានការទាំងនេះ ហៅថា "អន្តរប្បញ្ញត្តិ" ។

(2) គោលការណ៍នៃការអនុវត្តតាមច្បាប់ចាស់ និង គោលការណ៍នៃការអនុវត្តតាមច្បាប់ថ្មី ក្នុងវិធានការអន្តរកាល

ក្នុងច្បាប់នីតិវិធី ដូចជាក្រមនីតិវិធីរដ្ឋប្បវេណី ជាអាទិ៍ នីតិវិធីដែលជាកម្មវត្ថុនៃច្បាប់នេះ គឺជាទម្រង់នៃសកម្មភាពបណ្តឹងដែលមានជាបន្តបន្ទាប់ ដែលធ្វើឡើងដោយតុលាការ ឬ ដោយភាគី ហើយមានការពាក់ព័ន្ធនឹងការកន្លងផុតទៅនៃពេលវេលាដែលកំណត់មួយ ក្នុងអំឡុងពេលដែលចាប់ផ្តើម រហូតដល់ពេលបញ្ចប់នីតិវិធីបណ្តឹង ហេតុនេះហើយចាំបាច់ត្រូវកំណត់នូវការអនុវត្តនូវនីតិវិធីចាស់ ឬ នីតិវិធីថ្មី ចំពោះរឿងក្តីដែលត្រូវបានចាប់ផ្តើមចាត់ការមុនពេលធ្វើវិសោធនកម្មច្បាប់ ។ ចំពោះបញ្ហានេះ មានគំនិតមូលដ្ឋានពីរ គឺ "គោលការណ៍នៃការអនុវត្តតាមច្បាប់ថ្មី" និង "គោលការណ៍នៃការអនុវត្តតាមច្បាប់ចាស់" ។

ជាទូទៅ "គោលការណ៍នៃការអនុវត្តតាមច្បាប់ថ្មី" គឺ ជាគំនិតមួយដែលមានខ្លឹមសារថា ត្រូវអនុវត្តតាមនីតិវិធីនៃច្បាប់ក្រោយធ្វើវិសោធនកម្ម ចំពោះរឿងក្តីដែលត្រូវបានដាក់មុនពេលចូលជាធរមាននៃច្បាប់ដែលបានធ្វើវិសោធនកម្មនោះ ឬ មុនពេលអនុវត្តច្បាប់ថ្មីនេះ(ឬ ចំណុចដែលកើតមានឡើងមុនការអនុវត្តច្បាប់ថ្មី) ។

រីឯ "គោលការណ៍នៃការអនុវត្តតាមច្បាប់ចាស់" វិញ គឺជាគំនិតមួយដែលមានខ្លឹមសារថា ត្រូវអនុវត្តតាមច្បាប់ថ្មីចំពោះតែរឿងក្តីដែលត្រូវបានដាក់ក្រោយការចូលជាធរមាននៃច្បាប់ដែលបានធ្វើវិសោធនកម្ម ហើយត្រូវអនុវត្តតាមនីតិវិធីមុនពេលធ្វើវិសោធនកម្ម ចំពោះរឿងក្តីដែលបានដាក់មុនពេលច្បាប់ថ្មីត្រូវចូលជាធរមាន ឬ ត្រូវបានអនុវត្ត (ឬ ចំណុចដែលកើតមានឡើងមុនការអនុវត្តច្បាប់ថ្មី) ។ ម្យ៉ាងទៀត ស្តីពីទោសប្បញ្ញត្តិវិញ ដោយសារមាន "គោលការណ៍

នៃការផ្តន្ទាទោសតាមបញ្ញត្តិនៃច្បាប់ដែលជាធរមាននៅពេលធ្វើសកម្មភាព" ហេតុនេះហើយ មិនអាចអនុវត្តដោយប្រតិសកម្មនូវច្បាប់ដែលបានធ្វើវិសោធនកម្មបានឡើយ ។

(3) នៅក្នុងកំណត់នៃគន្ថីនេះ និង គន្ថីទី ៩ ពាក្យ "ក្រមថ្មី" គឺជាក្រមនីតិវិធីរដ្ឋប្បវេណីថ្មី ហើយនីតិវិធីស្តីពីរឿងក្តីរដ្ឋប្បវេណីមុនពេលអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណីថ្មីនេះ ហៅថា "នីតិវិធីចាស់" ។

**មាត្រា ៥៧២.-** គោលការណ៍នៃវិធានការអន្តរកាល

ចំពោះបណ្តឹងដែលបានដាក់មុនពេលក្រមនេះត្រូវបានអនុវត្ត នីតិវិធីពាក់ព័ន្ធនឹងបណ្តឹង ក្រោយពេលក្រមនេះ ត្រូវបានអនុវត្ត ត្រូវបន្តអនុវត្តបញ្ចប់តាមក្រមនេះ លើកលែងតែករណីដែលមានចែងពិសេសនៅក្នុងគន្ថីទី ៨ (អន្តរប្បញ្ញត្តិ) នេះ ។ ក្នុងករណីនេះ បញ្ញត្តិនេះ ពុំរារាំងអានុភាពដែលបានកើតឡើងនៅក្នុងនីតិវិធីដែលបានធ្វើ មុនពេលដែលក្រមនេះត្រូវបានអនុវត្តឡើយ ។

(កំណត់)

(1) មាត្រានេះចែងអំពីគោលការណ៍នៃរបៀបអនុវត្តនីតិវិធីចាស់ និង នីតិវិធីថ្មី ចំពោះរឿងក្តីដែលកំពុងត្រូវបានចាត់ការនៅពេលអនុវត្តក្រមថ្មី ។

មាត្រានេះ បានជ្រើសរើសយកគោលការណ៍អនុវត្តតាមក្រមថ្មី ដែលមានពន្យល់ដូចខាងលើនេះ ជាគោលការណ៍នៃវិធានការអន្តរកាល ហេតុនេះហើយ ចំពោះរឿងក្តីដែលកំពុងចាត់ការ ត្រូវអនុវត្តតាមបញ្ញត្តិនៃក្រមថ្មី ដោយមានការកម្រិតនូវវិសាលភាពនៃការអនុវត្តក្រមថ្មី តាមរយៈការទទួលស្គាល់នូវអានុភាពដែលកើតមានឡើងមុនពេលអនុវត្តក្រមថ្មី ។

(2) ចំពោះរឿងក្តីដែលកំពុងចាត់ការពេលអនុវត្តក្រមថ្មី ប្រសិនបើពុំមានបញ្ញត្តិពិសេសនៅក្នុងគន្ថីនេះទេ ត្រូវអនុវត្តតាមបញ្ញត្តិនៃក្រមថ្មី ហើយត្រូវបញ្ចប់នីតិវិធីដោយក្រមថ្មី (វាក្យខណ្ឌទី ១ នៃមាត្រានេះ) ។ មានន័យថា ចំពោះរឿងក្តីដែលកំពុងចាត់ការ ប្រសិនបើនីតិវិធីដែលបានធ្វើមុនពេលនោះ ជានីតិវិធីស្របច្បាប់ តាមនីតិវិធីចាស់ ត្រូវគោរពនីតិវិធីទាំងនោះ ហើយនីតិវិធីក្រោយការអនុវត្តក្រមថ្មី ត្រូវអនុវត្តតាមក្រមថ្មី ហើយត្រូវបញ្ចប់តាមក្រមថ្មី ដោយយកនីតិវិធីដែលបានធ្វើហើយពីមុន មកធ្វើជាមូលដ្ឋាន ។

ក្នុងករណីនេះ អានុភាពនៃនីតិវិធីដែលបានកើតឡើងនៅពេលក្រមថ្មីត្រូវបានអនុវត្ត ត្រូវរក្សាទុក (វាក្យខណ្ឌទី ២ នៃមាត្រានេះ) ។ ដូច្នេះហើយ ចំពោះការកោះហៅតាមកាលបរិច្ឆេទ ប្រសិនបើការអនុវត្តនីតិវិធីកោះហៅនេះស្របតាមនីតិវិធីចាស់ទេ ទោះជាមិនបានធ្វើនីតិវិធីនេះតាមក្រមថ្មីក៏ដោយ ក៏អានុភាពនៃការកោះហៅដែលបានធ្វើមុនការអនុវត្តក្រមថ្មី នៅតែមានដដែលដែរ ។ ម្យ៉ាងទៀត ចំពោះការសម្រេចអំពីការជ្រើសរើសសាក្សីក៏ដូចគ្នាដែរ គឺអានុភាពនៃការជ្រើសរើសនេះនៅមានដដែល ហើយមិនចាំបាច់ចេញដីកាសម្រេចយកសាក្សីជាថ្មីម្តងទៀត តាមក្រមថ្មីនេះ

ទេ ហើយអាចធ្វើការពិនិត្យភស្តុតាងតែម្តងបាន ។

ម្យ៉ាងទៀត កាលបរិច្ឆេទនៃការជំនុំជម្រះដែលកំណត់ហើយនៅពេលអនុវត្តក្រមនេះ ត្រូវចាត់ទុកថា បានកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់តាមបញ្ញត្តិនៃក្រមនេះ ( មាត្រា ៥៧៨ កថាខណ្ឌទី ១) ហេតុនេះហើយ អាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់នៅកាលបរិច្ឆេទដែលបានកំណត់ហើយ ជាកាលបរិច្ឆេទនៃការជំនុំជម្រះបាន ។

**មាត្រា ៥៧៣.-** វិធានការអន្តរកាលស្តីពីសមត្ថកិច្ច

ចំពោះសមត្ថកិច្ចនៃបណ្តឹង និង ការផ្ទេរបណ្តឹង ដែលកំពុងចាត់ការនៅពេលដែលក្រមនេះត្រូវបានអនុវត្ត ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។

( កំណត់)

មាត្រានេះបានជ្រើសរើសយកគោលការណ៍នៃការអនុវត្តតាមក្រមចាស់ ចំពោះវិធានការអន្តរកាលស្តីពីសមត្ថកិច្ច ដូច្នេះហើយ ចំពោះសមត្ថកិច្ច និង ការផ្ទេរបណ្តឹងដែលកំពុងចាត់ការនៅពេលដែលក្រមនេះត្រូវបានអនុវត្ត ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។ មូលហេតុគឺ មានដូចតទៅ ។

ប្រសិនបើធ្វើការជ្រើសរើសគោលការណ៍អនុវត្តតាមក្រមថ្មី ចំពោះសមត្ថកិច្ច និង ការផ្ទេរបណ្តឹងដែលកំពុងចាត់ការនៅពេលដែលក្រមនេះត្រូវបានអនុវត្តទៅ សមត្ថកិច្ចដែលត្រូវបានទទួលស្គាល់ដោយនីតិវិធីចាស់ នឹងអាចលែងត្រូវបានទទួលស្គាល់តាមក្រមថ្មី ឬ ផ្ទុយទៅវិញ កំហុសនៃសមត្ថកិច្ចដោយនីតិវិធីចាស់ នឹងអាចក្លាយទៅជាសមត្ថកិច្ចត្រឹមត្រូវតាមក្រមថ្មី ឬ បណ្តឹងដែលមិនស្របលក្ខខណ្ឌដើម្បីផ្ទេរនៅក្នុងនីតិវិធីចាស់ នឹងអាចក្លាយទៅជាស្របនឹងលក្ខខណ្ឌដើម្បីផ្ទេរតាមក្រមថ្មីទៅវិញ ជាអាទិ៍ ដែលធ្វើឱ្យខូចស្ថិរភាពនៃនីតិវិធី ហើយអាចធ្វើឱ្យបាត់បង់ផលប្រយោជន៍របស់ភាគីដោយមិនអាចគិតទុកជាមុនបាន ។ ម្យ៉ាងទៀត សមត្ថកិច្ចសាលាជម្រះក្តី ត្រូវគិតតាមពេលដាក់ពាក្យបណ្តឹង ( មាត្រា ១៧) ដូច្នេះហើយ ប្រសិនបើវិធានដើម្បីធ្វើការវិនិច្ឆ័យអំពីសមត្ថកិច្ច ត្រូវបានផ្លាស់ប្តូរដោយក្រមថ្មី មានន័យជាសារធាតុថា ការណ៍នេះនឹងខុសទៅនឹងគោលគំនិតនៃមាត្រា ១៧ នេះ ។

ហេតុនេះហើយ មាត្រានេះបានចែងថា ចំពោះសមត្ថកិច្ចនៃបណ្តឹង និង ការផ្ទេរបណ្តឹង ដែលកំពុងចាត់ការនៅពេលដែលក្រមនេះត្រូវបានអនុវត្ត ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។ ដូច្នេះហើយ ចំពោះសមត្ថកិច្ច និង ការផ្ទេរបណ្តឹងដែលកំពុងចាត់ការនៅពេលដែលក្រមនេះត្រូវបានអនុវត្ត ត្រូវចាត់ចែងជាបន្ត តាមគំនិតនៃនីតិវិធីចាស់ ដោយពុំមានទទួលឥទ្ធិពលអ្វីទាំងអស់ពីការអនុវត្តក្រមថ្មីនេះទេ ។

**មាត្រា ៥៧៤.-** វិធានការអន្តរកាលស្តីពីការបែងចែករឿងក្តី

១- នៅក្រោយពេលដែលពាក្យបណ្តឹងត្រូវបានដាក់ ប្រសិនបើក្រមនេះត្រូវបានអនុវត្ត នៅមុនការចាត់តាំងចៅក្រម

ទទួលបន្ទុកស៊ើបសួរ ឬ នីតិវិធីផ្សះផ្សា (ខាងក្រោមនេះ ហៅថា "ចៅក្រមទទួលបន្ទុកអង្កេតស៊ើបសួរ ជាអាទិ៍") ត្រូវចាត់ទុកថា បានដាក់ពាក្យបណ្ដឹងនៅពេលដែលក្រមនេះត្រូវបានអនុវត្ត ហើយត្រូវយកបញ្ញត្តិនៃមាត្រា ២៦ (ការបែងចែករឿងក្ដី) នៃក្រមនេះ មកអនុវត្ត ។

២- នៅក្រោយពេលដែលចៅក្រមទទួលបន្ទុកអង្កេតស៊ើបសួរ ជាអាទិ៍ ត្រូវបានចាត់តាំងរួចហើយ ប្រសិនបើក្រមនេះត្រូវបានអនុវត្ត នៅមុនពេលចាត់តាំងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬ ចៅក្រមនៅក្នុងថ្នាក់ជំនុំជម្រះក្ដីនោះ ត្រូវចាត់ទុកថា ចៅក្រមទទួលបន្ទុកអង្កេតស៊ើបសួរ ជាអាទិ៍ នោះ បានទទួលការបែងចែករឿងក្ដី តាមបញ្ញត្តិនៃមាត្រា ២៦ (ការបែងចែករឿងក្ដី) នៃក្រមនេះ ។ ប៉ុន្តែ ប្រសិនបើប្រធានសាលាដំបូងទទួលបន្ទុកផ្សះផ្សា ត្រូវចាត់ទុកថា ប្រធាននោះបានទទួលការបែងចែករឿងក្ដី តាមបញ្ញត្តិនៃមាត្រា ២៦ (ការបែងចែករឿងក្ដី) ។

៣- ក្នុងករណីនៃកថាខណ្ឌទី ២ ខាងលើនេះ ចំពោះរឿងក្ដីដែលបានបញ្ញត្តិនៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ២៣ (ការជម្រះក្ដីលើកទី ១ ដោយចៅក្រមមួយរូប ឬ ដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម) នៃក្រមនេះ ត្រូវចាត់ទុកថា បានដាក់ពាក្យបណ្ដឹងនៅពេលដែលក្រមនេះត្រូវបានអនុវត្ត ហើយត្រូវយកបញ្ញត្តិនៃមាត្រា ២៦ (ការបែងចែករឿងក្ដី) មកអនុវត្ត ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ។

៤- ក្រោយពេលដែលរឿងក្ដីត្រូវបានទទួល នៅក្នុងការជំនុំជម្រះក្ដីលើបណ្ដឹងឧទ្ធរណ៍ ប្រសិនបើក្រមនេះត្រូវបានអនុវត្ត នៅមុនពេលចាត់តាំងចៅក្រមនៅក្នុងថ្នាក់ជំនុំជម្រះក្ដីនោះ ត្រូវចាត់ទុកថា បានទទួលរឿងក្ដីនោះ នៅពេលដែលក្រមនេះត្រូវបានអនុវត្ត ហើយត្រូវយកបញ្ញត្តិនៃមាត្រា ២៦ (ការបែងចែករឿងក្ដី) នៃក្រមនេះ មកអនុវត្ត ។

៥- បញ្ញត្តិនៃកថាខណ្ឌទី ៤ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការបែងចែករឿងក្ដី ក្នុងការជំនុំជម្រះក្ដីលើបណ្ដឹងសាទុក្ខ ។

(កំណត់)

(1) តាមកិច្ចការដែលបានធ្វើពីមុនមក ចៅក្រមដែលទទួលបន្ទុករឿងក្ដី ត្រូវបានចាត់តាំងដោយប្រធានតុលាការ ហេតុនេះហើយ ការបែងចែករឿងក្ដីត្រូវបានធ្វើឡើងដោយប្រធានតុលាការ ។ ផ្ទុយទៅវិញ មាត្រា ២៦ កថាខណ្ឌទី ១ នៃក្រមថ្មីនេះ មានចែងថា ការបែងចែករឿងក្ដីនៅតុលាការ ត្រូវកំណត់ទុកជាមុនជារៀងរាល់ឆ្នាំ ដោយដីកាសម្រេចរបស់ប្រធានតុលាការនោះ ហើយក្នុងកថាខណ្ឌទី ២ នៃមាត្រាដដែលនេះមានចែងថា រឿងក្ដីនីមួយៗត្រូវបានបែងចែកដោយស្វ័យប្រវត្តិឱ្យចៅក្រមម្នាក់ៗ តាមការកំណត់អំពីការបែងចែកដែលត្រូវបានសម្រេចដោយប្រធានតុលាការ ។

ការបែងចែករឿងក្ដី ត្រូវធ្វើឡើងពេលដាក់ពាក្យបណ្ដឹង ក៏ប៉ុន្តែ ក្នុងករណីដែលក្រមថ្មីត្រូវបានអនុវត្តនៅក្រោយពេលដាក់ពាក្យបណ្ដឹង នឹងមានចម្ងល់ថា តើត្រូវធ្វើការបែងចែករឿងក្ដីតាមបញ្ញត្តិនៃក្រមថ្មីនេះ ឬ ត្រូវចាត់តាំងចៅក្រមតាមនីតិវិធីចាស់នោះ ឬ ចម្ងល់ផ្សេងទៀតថា ប្រសិនបើត្រូវបែងចែករឿងក្ដីតាមបញ្ញត្តិនៃក្រមថ្មីនេះទៅ តើត្រូវបែងចែករឿងក្ដីដោយយកពេលណាមួយមកធ្វើមូលដ្ឋាននៃពេលវេលា ។ ដូច្នេះហើយ មាត្រានេះ មានចែងអំពី

បញ្ញត្តិស្តីពីវិធានការអន្តរកាលក្នុងការអនុវត្ត ឬ មិនអនុវត្តក្រមថ្មី ព្រមទាំងកំណត់មូលដ្ឋាននៃពេលវេលា ក្នុងការអនុវត្ត ឬ មិនអនុវត្តក្រមថ្មី ជាអាទិ៍ ក្នុងករណីដែលមានចម្ងល់ក្នុងការអនុវត្តមាត្រា ២៦ ។

(2) ខ្លឹមសារនៃវិធានការអន្តរកាលដែលមានចែងក្នុងមាត្រានេះមានដូចតទៅ :

ក្រោយការទទួលពាក្យបណ្តឹង ក្នុងករណីដែលក្រមនេះត្រូវបានអនុវត្ត នៅមុនពេលដែលចៅក្រមទទួលបន្ទុកនីតិវិធីស៊ើបសួរ ឬ ផ្សះផ្សា ត្រូវបានជ្រើសតាំង នោះត្រូវធ្វើការបែងចែករឿងក្តី ដោយចាត់ទុកថា បានដាក់ពាក្យបណ្តឹងនៅពេលដែលក្រមថ្មីត្រូវបានអនុវត្ត ( កថាខណ្ឌទី ១ នៃមាត្រានេះ ) ។

ក្នុងករណីដែលក្រមនេះត្រូវបានអនុវត្ត ក្រោយពេលជ្រើសតាំងចៅក្រមទទួលបន្ទុកនីតិវិធីស៊ើបអង្កេត ឬ ផ្សះផ្សា តែមុនពេលជ្រើសតាំងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬ ចៅក្រមជំនុំជម្រះ ត្រូវចាត់ទុកថា ចៅក្រមទទួលបន្ទុកនីតិវិធីស៊ើបសួរ ឬ ផ្សះផ្សានោះ បានទទួលការបែងចែករឿងក្តីនោះតាមក្រមថ្មី ( កថាខណ្ឌទី ២ នៃមាត្រានេះ ) ។ ក៏ប៉ុន្តែ ក្នុងករណីដែលរឿងក្តីនោះជារឿងក្តីស្តីពីការដកហូតសមត្ថកិច្ចជំនុំជម្រះ ឬ បណ្តឹងជិតចិត្ត ( មាត្រា ៣០ កថាខណ្ឌទី ១) ឬ រឿងក្តីផ្សេងទៀតដែលត្រូវចាត់ការដោយក្រុមប្រឹក្សាជំនុំជម្រះ ដូចជារឿងក្តីដែលត្រូវច្បាប់កំណត់ថា ត្រូវវិនិច្ឆ័យ និង ជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះ (មាត្រា ២៣ កថាខណ្ឌទី ២) មិនអាចចាត់ការដោយចៅក្រមម្នាក់បានទេ ហេតុនេះហើយ ត្រូវធ្វើការបែងចែករឿងក្តី ដោយចាត់ទុកថា ពាក្យបណ្តឹងនោះត្រូវបានដាក់ នៅពេលដែលក្រមថ្មីនេះត្រូវបានអនុវត្ត ( កថាខណ្ឌទី ៣ នៃមាត្រានេះ) ។

ក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ឬ ការជំនុំជម្រះបណ្តឹងសាទុក្ខ ក្នុងករណីដែលក្រមនេះត្រូវបានអនុវត្ត មុនការជ្រើសតាំងចៅក្រមជំនុំជម្រះ ត្រូវធ្វើការបែងចែករឿងក្តីដោយចាត់ទុកថា ពាក្យបណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងសាទុក្ខ ត្រូវបានដាក់នៅពេលក្រមថ្មីនេះត្រូវបានអនុវត្ត ( កថាខណ្ឌទី ៤ និង កថាខណ្ឌទី ៥ នៃមាត្រានេះ) ។

(3) ប្រសិនបើចៅក្រមជំនុំជម្រះត្រូវបានជ្រើសតាំងនៅពេលអនុវត្តក្រមថ្មីនេះ នៅក្នុងមាត្រា ៥៧៤ នេះ ពុំមានចែងទេ តែយោងតាមគោលការណ៍នៃវិធានការអន្តរកាលនៃមាត្រា ៥៧២ ចៅក្រមជំនុំជម្រះត្រូវក្លាយជាចៅក្រមទទួលបន្ទុកនូវរឿងក្តីនោះដដែល ហើយធ្វើការជំនុំជម្រះបន្ត ហេតុនេះហើយ មិនចាំបាច់ធ្វើការបែងចែករឿងក្តីជាថ្មីទេ ។

**មាត្រា ៥៧៥.-** វិធានការអន្តរកាលស្តីពីការសម្រេចសេចក្តីអំពីពាក្យសុំដកហូត ឬ បណ្តឹងជិតចិត្ត

នៅក្នុងសាលាដំបូងដែលមិនមានចៅក្រមគ្រប់គ្រាន់ដើម្បីធ្វើការវិនិច្ឆ័យ និង សម្រេចសេចក្តីដោយក្រុមប្រឹក្សាជំនុំជម្រះ អំពីពាក្យសុំដកហូត ឬ បណ្តឹងជិតចិត្តទេ បញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៣០ (ការសម្រេចសេចក្តីអំពីពាក្យសុំដកហូត ឬ បណ្តឹងជិតចិត្ត) នៃក្រមនេះ ត្រូវយកមកអនុវត្ត ដោយប្តូរពីឃ្លាថា "ក្រុមប្រឹក្សាជំនុំជម្រះនៅតុលាការដែលចៅក្រមនោះស្ថិតនៅក្រោម" មកជា "ចៅក្រមផ្សេងទៀតនៅតុលាការដែលចៅក្រមនោះស្ថិតនៅក្រោម" សម្រាប់មួយរយៈពេល ។

(កំណត់)

មាត្រា ៣០ (ការសម្រេចសេចក្តីអំពីពាក្យសុំដកហូត ឬ បណ្តឹងជិតចិត្ត) កថាខណ្ឌទី ១ ចែងថា ចំពោះការដកហូតចៅក្រម ឬ បណ្តឹងជិតចិត្តចំពោះចៅក្រម ក្រុមប្រឹក្សាជំនុំជម្រះនៅតុលាការដែលចៅក្រមនោះស្ថិតនៅក្រោម ត្រូវសម្រេចសេចក្តី ដោយដីកាសម្រេច ហេតុនេះហើយ រឿងក្តីសុំដកហូតចៅក្រម ឬ បណ្តឹងជិតចិត្ត គឺជារឿងក្តីដែលច្បាប់កំណត់ថា ត្រូវធ្វើការវិនិច្ឆ័យ និង ជម្រះដោយក្រុមប្រឹក្សានៃចៅក្រម (មាត្រា ២៣ កថាខណ្ឌទី ២ ចំណុច ខ) ។ ក៏ប៉ុន្តែ ចំពោះសាលាដំបូងដែលពុំមានចៅក្រមគ្រប់ចំនួន ដើម្បីអាចបង្កើតក្រុមប្រឹក្សាជំនុំជម្រះ ដោយមិនគិតអំពីចៅក្រមដែលត្រូវបានសុំដកហូត ឬ ប្តឹងជិតចិត្ត មិនអាចបង្កើតក្រុមប្រឹក្សាជំនុំជម្រះក្នុងស្ថានភាពនេះបានទេ ម្យ៉ាងទៀត មានការពិបាកក្នុងការជ្រើសតាំងចៅក្រមជាបណ្តោះអាសន្ន ដើម្បីបង្កើតក្រុមប្រឹក្សាជំនុំជម្រះឱ្យបានគ្រប់ចំនួន ដើម្បីធ្វើការជំនុំជម្រះរឿងនោះ ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ តាមវិធានការពិសេសតាមផ្លូវច្បាប់ចាត់តាំងតុលាការ ។

ដូច្នេះហើយ មាត្រានេះចែងអំពីវិធានការពិសេស សម្រាប់ករណីនៃតុលាការបែបនេះ ដើម្បីឱ្យអាចធ្វើការសម្រេចសេចក្តីអំពីពាក្យសុំដកហូត ឬ បណ្តឹងជិតចិត្ត ដោយចៅក្រមតែម្នាក់ ក្នុងមួយរយៈពេល ដូចដែលបានធ្វើពីមុនមក ។ ហេតុនេះហើយ នៅតុលាការដែលត្រូវបានអនុវត្តតាមមាត្រានេះ ករណីនៃការសុំដកហូត ឬ នៃបណ្តឹងជិតចិត្តនេះ មិនមែនជារឿងក្តីដែលច្បាប់កំណត់ថា ត្រូវធ្វើការវិនិច្ឆ័យ និង ជម្រះសេចក្តីដោយក្រុមប្រឹក្សានៃចៅក្រម (មាត្រា ២៣ កថាខណ្ឌទី ២ ចំណុច ខ) ទេ ។

ម្យ៉ាងទៀត "មួយរយៈពេល" ដែលមានក្នុងនេះ គឺជាពាក្យដែលប្រើសម្រាប់ករណីដែលអំឡុងពេល មិនអាចកំណត់ឱ្យបានច្បាស់លាស់ ហើយនេះបង្ហាញថាជាវិធានការបណ្តោះអាសន្នតែប៉ុណ្ណោះ ។ ក៏ប៉ុន្តែ មាត្រានេះ មិនមែនជាបញ្ញត្តិដែលមានកំណត់ពេលអនុវត្ត (មានន័យថា ច្បាប់ ឬ បញ្ញត្តិដែលកម្រិតអំឡុងពេលដែលមានសុពលភាព) ទេ ហេតុនេះហើយ ដើម្បីធ្វើឱ្យបញ្ញត្តិនេះបាត់បង់អានុភាព ចាំបាច់ត្រូវធ្វើនិរាករណ៍ដោយច្បាប់ ។

**មាត្រា ៥៧៦.-** វិធានការអន្តរកាលស្តីពីនីតិវិធីអង្កេតស៊ើបសួរ ឬ នីតិវិធីក្រោយនីតិវិធីអង្កេតស៊ើបសួរ

១- ក្នុងករណីដែលក្រមនេះត្រូវបានអនុវត្តនៅពេលដែលនីតិវិធីអង្កេតស៊ើបសួរកំពុងត្រូវបានប្រតិបត្តិ តុលាការត្រូវបញ្ឈប់នីតិវិធីអង្កេតស៊ើបសួរនោះភ្លាម ហើយត្រូវកំណត់កាលបរិច្ឆេទដើម្បីធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយកោះហៅភាគីឱ្យមកចូលរួមដោយគ្មានការយឺតយ៉ាវ ។

២- ក្រោយពីនីតិវិធីអង្កេតស៊ើបសួរត្រូវបានបញ្ចប់ ក្នុងករណីដែលក្រមនេះត្រូវបានអនុវត្តនៅមុនពេលបើកកាលបរិច្ឆេទនៃសវនាការ តុលាការត្រូវកំណត់កាលបរិច្ឆេទដើម្បីធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយកោះហៅភាគីឱ្យមកចូលរួម ដោយគ្មានការយឺតយ៉ាវ ។ ប៉ុន្តែ បញ្ញត្តិនេះពុំត្រូវយកមកអនុវត្តឡើយ ក្នុងករណីដែលតុលាការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៥៧៨ (វិធានការអន្តរកាលស្តីពី

កាលបរិច្ឆេទនៃការជំនុំជម្រះ) នៃក្រមនេះ ។

៣- នៅក្នុងករណីនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ សកម្មភាពបណ្តឹងដែលបានធ្វើនៅក្នុងនីតិវិធីអង្កេតស៊ើបសួរ ត្រូវចាត់ទុកថា បានធ្វើនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក្នុងទំហំនៃសិទ្ធិអំណាចរបស់តុលាការ ដូចបាន បញ្ញត្តិនៅក្នុងមាត្រា ១០៦ (សកម្មភាពនៃបណ្តឹង ជាអាទិ៍ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) នៃក្រមនេះ ។

៤- ក្នុងករណីដែលក្រមនេះត្រូវបានអនុវត្ត ក្រោយការបើកកាលបរិច្ឆេទនៃសវនាការ ចំពោះសាក្សីដែលត្រូវបាន សាកសួរនៅក្នុងនីតិវិធីអង្កេតស៊ើបសួរដោយភាគី ឬ សាមីភាគីដែលមិនត្រូវបានសាកសួរនៅក្នុងថ្នាក់ជំនុំជម្រះក្តី ប្រសិនបើភាគីបានស្នើសុំឱ្យសាកសួរនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវធ្វើការសាកសួរ ។

(កំណត់)

(1) នីតិវិធីស៊ើបសួរ នៅក្នុងនីតិវិធីចាស់ ពេលខ្លះមានលក្ខណៈជាការរៀបចំនូវចំណុចវិវាទ ដែលជាការត្រៀមនៃការ ជំនុំជម្រះផង ពេលខ្លះមានលក្ខណៈជាការពិនិត្យភស្តុតាងផង ហើយនោះគឺជានីតិវិធីមួយដែលមានលក្ខណៈខុសគ្នាឆ្ងាយ ពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលក្នុងក្រមនេះ ។

ម្យ៉ាងទៀត ក្រមថ្មីនេះ បានបែងចែកដាច់ដោយឡែកនូវការរៀបចំចំណុចវិវាទ និង ការពិនិត្យភស្តុតាង នៅក្នុងនីតិវិធី ដោយធ្វើនីតិវិធីផ្សេងពីគ្នា ហើយពេលដែលពាក្យបណ្តឹងត្រូវបានដាក់ មុននឹងធ្វើការកំណត់កាលបរិច្ឆេទនៃ ការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីពិនិត្យភស្តុតាង និង ធ្វើសកម្មភាពជំនុំជម្រះផ្សេងទៀត ត្រូវធ្វើការកំណត់ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាមុនសិន ដើម្បីរៀបចំការអះអាងរបស់ភាគី ភស្តុតាង និង ចំណុចវិវាទផ្សេង ទៀត (មាត្រា ៨០) ។ ម្យ៉ាងទៀត នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺត្រូវធ្វើឡើងសម្រាប់ការត្រៀមនៃ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយសកម្មភាពទាំងនោះពុំមែនយកមកធ្វើជាមូលដ្ឋាននៃការវិនិច្ឆ័យ ទេ ហើយតាមរយៈការធ្វើសេចក្តីថ្លែងការណ៍ស្តីពីលទ្ធផលនៃការត្រៀមសម្រាប់ការទាញហេតុផល នៅកាលបរិច្ឆេទនៃ ការទាញហេតុផលដោយផ្ទាល់មាត់ពេលក្រោយនោះ ទើបអាចក្លាយជាមូលដ្ឋាននៃការវិនិច្ឆ័យបាន (មាត្រា ១១៦) ។

ដោយសារតែទម្រង់នៃនីតិវិធីនេះ និង ដោយសារនីតិវិធីនៃការស៊ើបសួរ ជាគោលការណ៍ មានលក្ខណៈ និង ខ្លឹមសារ ខុសគ្នាទាំងស្រុង ពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហេតុដូច្នេះ លើកលែងតែករណីដែលកាលបរិច្ឆេទនៃការ ជំនុំជម្រះត្រូវបានចាប់ផ្តើមរួចហើយ ហើយលទ្ធផលនៃនីតិវិធីស៊ើបសួរត្រូវបានក្លាយជាមូលដ្ឋាននៃការវិនិច្ឆ័យរួចហើយ នៅពេលដែលក្រមនេះត្រូវបានអនុវត្ត ក្នុងករណីដែលក្រមនេះត្រូវបានអនុវត្តមុនកាលបរិច្ឆេទនៃការជំនុំជម្រះ មិនគួរ បន្តនីតិវិធីសម្រាប់ការទាញហេតុផលពីនីតិវិធីស៊ើបសួរ ដោយអនុវត្តតាមគោលការណ៍នៃវិធានការអន្តរកាលនៃមាត្រា ៥៧២ ចំពោះនីតិវិធីស៊ើបសួរទេ ។

ដូច្នេះ មាត្រានេះចែងស្តីពីវិធានការអន្តរកាលពិសេសសម្រាប់នីតិវិធីស៊ើបសួរ ។

(2) ក្នុងករណីដែលក្រមនេះត្រូវបានអនុវត្តពេលដែលកំពុងធ្វើនីតិវិធីស៊ើបសួរ ការបន្តនីតិវិធីស៊ើបសួរនេះ ឬ ការបន្ត

នីតិវិធីដោយភ្ជាប់នីតិវិធីស៊ើបសួរទៅនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជាការធ្វើខុសនឹងគោលគំណិតនៃក្រមនេះ ហេតុនេះហើយ តុលាការត្រូវបញ្ឈប់ជាបន្ទាន់នូវនីតិវិធីស៊ើបសួរ ហើយកំណត់នូវកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយកុំឱ្យមានការយឺតយ៉ាវ ហើយធ្វើការកោះហៅភាគី (កថាខណ្ឌទី ១ នៃមាត្រានេះ) ។

នីតិវិធីបន្ទាប់មកទៀត ក៏ដូចគ្នានឹងករណីដែលបានប្រតិបត្តិតាមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តាំងពីដំបូងដែរ ក៏ប៉ុន្តែ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ អាចចេញដីកាសម្រេចអំពីការស្នើដាក់ភស្តុតាង ឬ ដីកាសម្រេចផ្សេងទៀតដែលអាចធ្វើទៅបានក្រៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយអាចធ្វើការពិនិត្យនូវភស្តុតាងឯកសារដែលចាំបាច់ត្រឹមកម្រិតសម្រាប់រៀបចំចំណុចវិវាទ និង រៀបចំភស្តុតាង ហេតុនេះហើយ លទ្ធផល ជាអាទិ៍ នៃការពិនិត្យភស្តុតាងដែលបានធ្វើឡើងក្នុងនីតិវិធីស៊ើបសួរ អាចចាត់ទុកថា មានអានុភាពដែរ ត្រឹមទំហំនៃសិទ្ធិរបស់តុលាការនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលខាងលើនេះ ។ ដូច្នេះ កថាខណ្ឌទី ៣ នៃមាត្រានេះ ចែងទទួលស្គាល់នូវអានុភាពនៃសកម្មភាពបណ្តឹង ដែលបានធ្វើឡើងក្នុងនីតិវិធីស៊ើបសួរ ក្នុងទំហំនៃសិទ្ធិអំណាចរបស់តុលាការដែលមានចែងក្នុងមាត្រា ១០៦ (សកម្មភាពនៃបណ្តឹង ជាអាទិ៍ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) ។

(3) ក្នុងករណីដែលក្រមនេះត្រូវបានអនុវត្ត ក្រោយការបញ្ចប់កាលបរិច្ឆេទស៊ើបសួរ តែមុនការបើកកាលបរិច្ឆេទនៃការជំនុំជម្រះ លទ្ធផលនៃនីតិវិធីនៃការស៊ើបសួរ មានរួចហើយ ក៏ប៉ុន្តែ មិនសមរម្យនឹងទទួលស្គាល់នូវលទ្ធផលនៃនីតិវិធីនៃការស៊ើបសួរនេះ ហើយចាប់ផ្តើមវិនិច្ឆ័យដោយការទាញហេតុផលដោយផ្ទាល់មាត់ ដោយមិនឆ្លងកាត់តាមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីរៀបចំនូវចំណុចវិវាទ និង រៀបចំភស្តុតាងទេ ។ ដូច្នេះហើយ កថាខណ្ឌទី ២ នៃមាត្រានេះ មានចែងថា ក្នុងករណីដែលក្រមនេះត្រូវបានអនុវត្ត ក្រោយពេលបញ្ចប់នីតិវិធីស៊ើបសួរ តែមុនពេលបើកកាលបរិច្ឆេទដើម្បីធ្វើការជំនុំជម្រះ ត្រូវអនុវត្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាថ្មី ហើយបន្ទាប់មក ធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ។

ហេតុនេះហើយ ក្នុងករណីនេះ ត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយកោះហៅភាគី កុំឱ្យមានការយឺតយ៉ាវ (វាក្យខណ្ឌទី ១ កថាខណ្ឌទី ១ នៃមាត្រានេះ) ។ ក៏ប៉ុន្តែ ប្រសិនបើកាលបរិច្ឆេទនៃការជំនុំជម្រះលើកទី ១ ត្រូវបានកំណត់ក្រោយពីបានបញ្ចប់នីតិវិធីស៊ើបសួរ តុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន មុនពេលចាប់ផ្តើមកាលបរិច្ឆេទ (យោងតាមមាត្រា ៥៧៨ កថាខណ្ឌទី ១ កាលបរិច្ឆេទនៃការជំនុំជម្រះដែលបានកំណត់ហើយ ត្រូវបានចាត់ទុកថា បានកំណត់ជាកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់) ហេតុនេះហើយ ក្នុងករណីនេះ មិនចាំបាច់កំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ (វាក្យខណ្ឌទី ២ កថាខណ្ឌទី ២ នៃមាត្រានេះ) ។

នីតិវិធីបន្ទាប់មកទៀត មានដូចគ្នានឹងករណីដែលបានប្រតិបត្តិនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តាំងពីដំបូងដែរ ក៏ប៉ុន្តែ ចំពោះអានុភាពនៃសកម្មភាពបណ្តឹងដែលបានធ្វើឡើងនៅក្នុងនីតិវិធីស៊ើបសួរ ត្រូវបានចាត់ទុកដូចគ្នានឹង

ករណីដែលក្រមនេះត្រូវបានអនុវត្តនៅពេលកំពុងប្រតិបត្តិនីតិវិធីស៊ើបសួរដែរ ( កថាខណ្ឌទី ៣ នៃមាត្រា នេះ) ។

(4) ក្នុងករណីដែលក្រមថ្មីត្រូវបានអនុវត្តនៅក្រោយពេលបើកកាលបរិច្ឆេទនៃការជំនុំជម្រះ ចម្លើយជាកសិណសាក្សីរបស់សាក្សី ឬ លទ្ធផលនៃការសាកសួរសាមីភាគី នៅក្នុងការពិនិត្យភស្តុតាងនៃដំណាក់កាលនៃនីតិវិធីស៊ើបសួរ នឹងក្លាយទៅជាភស្តុតាងតែម្តង ហើយនឹងអាចប្រើសម្រាប់ទទួលស្គាល់អង្គហេតុ ជាមួយគ្នានឹងភស្តុតាងផ្សេងទៀតដែលត្រូវបានពិនិត្យនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ក្រោយពេលនោះ ។ ក្នុងករណីនេះ ប្រសិនបើអាចបញ្ចប់ការវិនិច្ឆ័យ និង ជំនុំជម្រះ ដោយមិនធ្វើការសាកសួរសាក្សី ឬ សាមីភាគីនៅក្នុងការជំនុំជម្រះបានទៅ ចំពោះសាមីភាគី គឺមិនផ្តល់ឱកាសឱ្យធ្វើការសាកសួរសាក្សី ឬ ភាគីទាំងនោះ នៅក្នុងដំណាក់កាលនៃការជំនុំជម្រះ ហើយនឹងទទួលនូវសាលក្រម ដូច្នេះហើយ នេះគឺជាការណ៍មួយដែលអាចធ្វើឱ្យមានកង្វះខាតក្នុងការធានានូវនីតិវិធីចំពោះភាគី ។

ដូច្នេះហើយ ដើម្បីធានានូវសិទ្ធិសាកសួររបស់ភាគី កថាខណ្ឌទី ៤ នៃមាត្រានេះ មានចែងថា ត្រូវធ្វើការសាកសួរសាក្សី ឬ ភាគី ប្រសិនបើនៅក្នុងការជំនុំជម្រះ មិនបានធ្វើការសាកសួរសាក្សី ឬ សាកសួរសាមីភាគី ដែលបានសាកសួរហើយនៅក្នុងនីតិវិធីនៃការស៊ើបសួរ ហើយបើភាគីស្នើសុំឱ្យធ្វើការសាកសួរ នៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ។

**មាត្រា ៥៧៧.-** វិធានការអន្តរកាលស្តីពីប្រាក់ប្រដាប់ក្តី

១- ចំពោះប្រាក់ប្រដាប់ក្តីនៃបណ្តឹងរដ្ឋប្បវេណី ដែលភាគី ឬ បុគ្គលពាក់ព័ន្ធផ្សេងទៀត ត្រូវទទួលបន្ទុក ទាក់ទងទៅនឹងបណ្តឹងដែលបានដាក់នៅមុនពេលដែលក្រមនេះត្រូវបានអនុវត្ត ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។

២- បញ្ញត្តិស្តីពីប្រាតិភោគនៃប្រាក់ប្រដាប់ក្តី មិនត្រូវយកមកអនុវត្តឡើយ ចំពោះបណ្តឹងដែលបានដាក់នៅមុនពេលដែលក្រមនេះត្រូវបានអនុវត្ត ។

( កំណត់)

(1) បណ្តឹងរដ្ឋប្បវេណី មានទម្រង់ជានីតិវិធីដែលមានជាបន្តបន្ទាប់ ដែលមានសកម្មភាពបណ្តឹងជាច្រើន រួមទាំងសកម្មភាពដែលចាំបាច់ត្រូវបង់ពន្ធ ឬ សោហ៊ុយ ហើយការសម្រេចសេចក្តីអំពីបន្ទុកនៃប្រាក់ប្រដាប់ក្តី ត្រូវធ្វើឡើង ចំពោះប្រាក់ប្រដាប់ក្តីសរុបនៃការជម្រះក្តីនៃថ្នាក់នីមួយៗ ឬ ចំពោះសោហ៊ុយសរុបតាមថ្នាក់ទាំងអស់នៃការជម្រះក្តី ( មាត្រា ៦៥) ហើយត្រូវកំណត់ជាស្ថាពរនូវចំនួនទឹកប្រាក់នៃប្រាក់ប្រដាប់ក្តីនេះ ភ្ជាប់ជាមួយគ្នានឹងរឿងក្តីនីមួយៗ ហើយត្រូវធ្វើការចាត់ចែងទូទាត់រវាងប្រាក់ប្រដាប់ក្តីរបស់ភាគីទាំងសងខាង ( មាត្រា ៦៦) ។

យោងតាមស្ថានភាពទាំងនេះ ចំពោះពន្ធ និង ប្រាក់ប្រដាប់ក្តីផ្សេងទៀត ដែលភាគី ឬ បុគ្គលដែលមានទំនាក់ទំនងនឹងរឿងក្តីដែលបានដាក់មុនពេលអនុវត្តក្រមនេះ ត្រូវទទួលបន្ទុក ការផ្លាស់ប្តូរទំហំ និង ចំនួនទឹកប្រាក់ ទៅតាមពេលដែលកើតមានឡើងមុន ឬ ក្រោយការអនុវត្តក្រមនេះទៅ នឹងអាចធ្វើឱ្យបាត់បង់នូវស្ថិរភាពច្បាប់ និង សមភាពរវាង

ភាគីបាន ។ ឧទាហរណ៍ ពន្ធដើម្បីដាក់ពាក្យបណ្តឹង ត្រូវបង់នៅពេលដាក់ពាក្យបណ្តឹង ។ ប្រសិនបើធ្វើការផ្លាស់ប្តូរពន្ធនេះតាមវិសោធនកម្មច្បាប់ ក្រោយពេលដាក់ពាក្យបណ្តឹងហើយទៅ នឹងធ្វើឱ្យបាត់បង់ស្ថិរភាពច្បាប់ ។

ដូច្នេះហើយ ចំពោះប្រាក់ប្រដាប់ក្តីនៃបណ្តឹងរដ្ឋប្បវេណី មាត្រានេះបានជ្រើសរើសយកគោលការណ៍អនុវត្តតាមច្បាប់ចាស់ ហើយចំពោះពន្ធ និង ប្រាក់ប្រដាប់ក្តីផ្សេងទៀត ដែលត្រូវទទួលបន្ទុកដោយភាគីដែលមានទំនាក់ទំនងនឹងរឿងក្តី ឬ បុគ្គលដែលមានទំនាក់ទំនងនឹងរឿងក្តី ដែលបានដាក់ឡើងមុនការអនុវត្តក្រមថ្មីនេះ ដោយអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ហើយមិនអនុវត្តតាមបញ្ញត្តិនៃក្រមថ្មីនេះ ។

ចំពោះពន្ធ និង ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធ សម្រាប់ពាក្យសុំក្នុងដំណើការពាក់កណ្តាលទី ឬ ពាក្យសុំបន្ទាប់បន្សំនៃរឿងក្តីដែលបានដាក់ឡើងមុនការអនុវត្តក្រមថ្មីនេះ ក៏ត្រូវបកស្រាយដូចនេះដែរ ។

ចំពោះរឿងក្តីដែលបានដាក់មុនពេលអនុវត្តក្រមនេះ ក្នុងករណីដែលសាលាដំបូងបានចេញសាលក្រមហើយ ហើយមានការប្តឹងឧទ្ធរណ៍ចំពោះសាលក្រមនេះ ទាក់ទងនឹងប្រាក់ប្រដាប់ក្តី ត្រូវបកស្រាយថាជា "រឿងក្តី" ផ្សេងគ្នាក្នុងថ្នាក់នៃការជំនុំជម្រះនីមួយៗ ហេតុនេះហើយ ក្នុងករណីដែលមានបណ្តឹងឧទ្ធរណ៍ ក្រោយការសម្រេចសេចក្តីនៃសាលាដំបូង ប្រាក់ប្រដាប់ក្តី ជាអាទិ៍ នៃបណ្តឹងនោះ ត្រូវអនុវត្តតាមក្រមថ្មី ។

(2) នៅក្នុងនីតិវិធីចាស់ គ្មានរបបនៃប្រាតិភោគលើប្រាក់ប្រដាប់ក្តីទេ ក៏ប៉ុន្តែ ក្រមថ្មីចែងថា ប្រសិនបើដើមចោទពុំមានលំនៅឋាន ទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនៅកម្ពុជាទេ តុលាការត្រូវបង្គាប់ឱ្យដើមចោទដាក់ប្រាតិភោគលើប្រាក់ប្រដាប់ក្តី តាមពាក្យសុំរបស់ចុងចម្លើយ ដោយដីកាសម្រេច ហើយក្នុងករណីដែលមានកង្វះនូវប្រាតិភោគនោះក៏ដូចគ្នាដែរ ( មាត្រា ៦៧ កថាខណ្ឌទី ១) ។

ចំពោះប្រាតិភោគលើប្រាក់ប្រដាប់ក្តី ពេលដែលដាក់ពាក្យបណ្តឹង ពុំមានកាតព្វកិច្ចដាក់ទេ តែក្រោយមក កាតព្វកិច្ចដាក់ប្រាតិភោគនោះកើតមានឡើងដោយសារវិសោធនកម្មច្បាប់ ក្នុងករណីនេះ ប្រសិនបើលើកចោលនូវបណ្តឹងនោះដោយសារការមិនផ្តល់ប្រាតិភោគទៅ អាចធ្វើឱ្យខូចដល់ផលប្រយោជន៍របស់ដើមចោទ ដែលមិនអាចគិតទុកជាមុនបាន ហេតុនេះហើយ កថាខណ្ឌទី ២ នៃមាត្រានេះ បានជ្រើសរើសយកគោលការណ៍អនុវត្តតាមច្បាប់ចាស់ សម្រាប់រឿងក្តីដែលបានដាក់ឡើងមុនពេលអនុវត្តក្រមថ្មីនេះ ដោយមិនអនុវត្តនូវបញ្ញត្តិតាមប្រាតិភោគលើប្រាក់ប្រដាប់ក្តីទេ ។

**មាត្រា ៥៧៨.-** វិធានការអន្តរកាលស្តីពីកាលបរិច្ឆេទនៃការជំនុំជម្រះ

១- កាលបរិច្ឆេទនៃការជំនុំជម្រះក្តីដែលបានកំណត់ហើយ នៅពេលដែលក្រមនេះត្រូវបានអនុវត្ត ត្រូវចាត់ទុកថាបានកំណត់ជាកាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ តាមបញ្ញត្តិនៃក្រមនេះ ។

២- ក្នុងករណីនៃកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើកាលបរិច្ឆេទនៃការជំនុំជម្រះក្តីនោះ គឺជាកាលបរិច្ឆេទទី ១ បន្ទាប់ពីការបញ្ចប់នីតិវិធីអង្កេតស៊ើបសួរ តុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅមុនការចាប់ផ្តើមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់បាន ។

៣- ក្នុងករណីនៃកថាខណ្ឌទី ២ ខាងលើនេះ ប្រសិនបើតុលាការពុំអាចបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានទេ តុលាការត្រូវកំណត់កាលបរិច្ឆេទមួយទៀតសម្រាប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយលុបចោល ឬ លើកកាលបរិច្ឆេទសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ។

(កំណត់)

ក្នុងក្រមថ្មីនេះ ការវិនិច្ឆ័យ និង ជំនុំជម្រះបណ្តឹងយ៉ាងសកម្មត្រូវប្រតិបត្តិក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយពុំមានយកទស្សនៈនៃកាលបរិច្ឆេទនៃការជំនុំជម្រះក្នុងនីតិវិធីចាស់មកប្រើទេ ហេតុនេះហើយ ក្រោយការអនុវត្តក្រមថ្មីនេះ មិនអាចបើកកាលបរិច្ឆេទនៃការជំនុំជម្រះនោះបានទេ ។ ក៏ប៉ុន្តែ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ និង កាលបរិច្ឆេទនៃការជំនុំជម្រះ មានចំណុចរួមមួយ ត្រង់ចំណុចស្តីពីកាលបរិច្ឆេទនៃការវិនិច្ឆ័យ និង ជំនុំជម្រះយ៉ាងសកម្ម ហេតុនេះហើយ ទោះបីជាធ្វើការទាញហេតុផលដោយផ្ទាល់មាត់ នៅកាលបរិច្ឆេទដែលត្រូវបានកំណត់សម្រាប់ការជំនុំជម្រះក៏ដោយ ក៏ពុំមានបញ្ហាអ្វីឡើយ ។

ដូច្នេះ កថាខណ្ឌទី ១ នៃមាត្រានេះ ចែងថា កាលបរិច្ឆេទនៃការជំនុំជម្រះក្តីដែលបានកំណត់ហើយ នៅពេលដែលក្រមនេះត្រូវបានអនុវត្ត ត្រូវចាត់ទុកថា បានកំណត់ជាកាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ តាមបញ្ញត្តិនៃក្រមនេះ ។ ហេតុនេះហើយ ក្នុងករណីដែលបានកំណត់កាលបរិច្ឆេទនៃការជំនុំជម្រះរួចហើយ មិនចាំបាច់ធ្វើការកំណត់ជាថ្មីឡើងវិញ នូវកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ទេ គឺអាចធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅកាលបរិច្ឆេទដែលត្រូវបានកំណត់សម្រាប់ការជំនុំជម្រះនោះបាន ។

ម្យ៉ាងទៀត ក្នុងករណីដែលក្រមនេះត្រូវបានអនុវត្តក្រោយការបញ្ចប់នីតិវិធីស៊ើបសួរ តែមុនពេលបើកកាលបរិច្ឆេទនៃការជំនុំជម្រះ ត្រូវប្រតិបត្តិនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាថ្មីសិន ទើបអាចបើកកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់បាន (កថាខណ្ឌទី ២ នៃមាត្រានេះ) ។ ក៏ប៉ុន្តែ ប្រសិនបើបានកំណត់កាលបរិច្ឆេទនៃការជំនុំជម្រះលើកទី ១ ក្រោយការបញ្ចប់នីតិវិធីស៊ើបសួររួចហើយ តុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន មុននឹងចាប់ផ្តើមកាលបរិច្ឆេទនៃការជំនុំជម្រះនោះ ។ ដូច្នេះ ក្នុងករណីនេះ ពុំចាំបាច់កំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ (មាត្រា ៥៧៦ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២) ។

**មាត្រា ៥៧៩.-** វិធានការអន្តរកាលស្តីពីទណ្ឌកម្មនៅក្នុងការពិនិត្យភស្តុតាង

១- បញ្ញត្តិស្តីពីពិន័យស៊ីវិល ដែលមានចែងនៅក្នុងជំពូកទី ៣ (ភស្តុតាង) នៃគន្ថីទី ២ នៃក្រមនេះ ត្រូវយកមកអនុវត្តចំពោះករណីដែលដីកាសម្រេចពិនិត្យភស្តុតាង ត្រូវបានចេញ ដោយអនុលោមតាមបញ្ញត្តិនៃក្រមនេះ ឬ ចំពោះករណីដែលភាគី ឬ អ្នកតំណាងរបស់ភាគី ប្រកែកនឹងភាពត្រឹមត្រូវក្នុងការធ្វើឯកសារ ក្រោយពេលក្រមនេះត្រូវបានអនុវត្ត ។

២- ចំពោះបញ្ញត្តិនៃជំពូកទី ៣ (ភស្តុតាង) នៃគន្ថីទី ២ ដែលត្រូវយកទៅអនុវត្តដូចគ្នាផងដែរ ដោយមាត្រា ២៧៣

(ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីនីតិវិធីនៃការជំនុំជម្រះលើកទី ១) និង មាត្រា ២៨៦ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍) នៃក្រមនេះ ក៏ត្រូវអនុវត្តដូចគ្នានឹងកថាខណ្ឌទី ១ ដែរ ។

(កំណត់)

ការដាក់ទណ្ឌកម្មទៅលើសាក្សី ជាអាទិ៍ ដែលមានចែងក្នុងក្រមថ្មីនេះ គន្ថីទី ២ ជំពូកទី ៣ (ភស្តុតាង) ត្រូវបានបង្កើតឡើងដោយយកការអនុវត្តនីតិវិធីនៃការកោះហៅ ដែលត្រូវបានធ្វើឡើងស្របទៅនឹងក្រមថ្មី មកធ្វើជាមូលដ្ឋាន ហេតុនេះហើយ មាត្រានេះកម្រិតការអនុវត្តទណ្ឌកម្មនោះចំពោះតែសាក្សី ជាដើម ដែលត្រូវបានសម្រេចដើម្បីធ្វើការពិនិត្យភស្តុតាង ក្រោយការអនុវត្តក្រមនេះប៉ុណ្ណោះ ។

ម្យ៉ាងទៀត ការអនុវត្តប្រតិសកម្មនូវបញ្ញត្តិនៃមាត្រា ១៩៧ (ប្រាក់ពិន័យចំពោះអ្នកប្រកែកនឹងភាពត្រឹមត្រូវក្នុងការធ្វើឯកសារ) ចំពោះករណីដែលមានវិវាទអំពីភាពត្រឹមត្រូវនៃការធ្វើឯកសារ មុនពេលអនុវត្តក្រមថ្មីនេះ គឺជាការមួយមិនសមរម្យទេ ហេតុនេះហើយ មាត្រានេះ ក៏ដូចការដាក់ទណ្ឌកម្មនៃមាត្រានេះដែរ គឺ ត្រូវអនុវត្តចំពោះករណីដែលភាគី ឬ អ្នកតំណាងដោយអាណត្តិ មានវិវាទស្តីពីភាពត្រឹមត្រូវនៃការធ្វើឯកសារ ក្រោយការអនុវត្តក្រមនេះតែប៉ុណ្ណោះ ។

**មាត្រា ៥៨០.-** វិធានការអន្តរកាលស្តីពីសាលក្រមកំបាំងមុខ

ចំពោះនីតិវិធី នៅក្នុងករណីដែលដើមចោទ ឬ ចុងចម្លើយមិនបានបង្ហាញខ្លួននៅក្នុងកាលបរិច្ឆេទ តាមនីតិវិធីនៃការកោះហៅ នៅមុនពេលដែលក្រមនេះត្រូវបានអនុវត្ត ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក ។

(កំណត់)

សាលក្រមកំបាំងមុខ គឺជាសាលក្រមដែលត្រូវបានប្រកាសឡើង ដោយផ្អែកទៅលើតែការអះអាងរបស់ភាគីម្ខាងដែលមានវត្តមាន ក្នុងករណីដែលភាគីនៃបណ្តឹងម្ខាងទៀតអវត្តមានក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ (សូមមើលគន្ថីទី ២ ជំពូកទី ៥ ផ្នែកទី ៥ (សាលក្រមកំបាំងមុខ)) ។ ចំពោះសាលក្រមកំបាំងមុខ អាចដាក់បណ្តឹងទាស់បាន ដើម្បីធ្វើឱ្យនីតិវិធីនៃបណ្តឹងនោះត្រឡប់ទៅសភាពដើមវិញ ពីត្រឹមពេលអវត្តមាននោះកើតមានឡើង (មាត្រា ២០៨) ក៏ប៉ុន្តែ ក្នុងបណ្តឹងទាស់នេះ ចាំបាច់ត្រូវស្របនឹងល័ក្ខខ័ណ្ឌ ដូចដែលមានចែងក្នុងមាត្រា ២០៤ ដូចជាការអវត្តមាននោះកើតមានឡើងដោយសារមូលហេតុដែលមិនអាចព្យាករបាន ជាអាទិ៍ ដែលបានធ្វើឱ្យមិនអាចបង្ហាញខ្លួននៅកាលបរិច្ឆេទ ។

ក្នុងករណីដែលអនុវត្តបញ្ញត្តិស្តីពីសាលក្រមកំបាំងមុខ ទៅតាមគោលការណ៍នៃវិធានការអន្តរកាលនៃមាត្រា ៥៧២ នៃក្រមនេះ ទោះជាករណីដែលបានអវត្តមាននៅកាលបរិច្ឆេទមុនពេលអនុវត្តក្រមនេះក៏ដោយ ប្រសិនបើការប្រកាសសាលក្រមមិនទាន់បានធ្វើនៅឡើយទេ គឺអាចអនុវត្តតាមបញ្ញត្តិស្តីពីសាលក្រមកំបាំងមុខនៃក្រមនេះបាន ។

ក៏ប៉ុន្តែ ប្រសិនបើអនុវត្តជាប្រតិសកម្ម នូវបញ្ញត្តិស្ដីពីសាលក្រមកំបាំងមុខនេះ ចំពោះករណីដែលបានអវត្តមាននៅកាលបរិច្ឆេទមុនពេលអនុវត្តក្រមថ្មីនេះទៅ ភាគីដែលអវត្តមានត្រូវទទួលសាលក្រមកំបាំងមុខ ដោយមិនអាចគិតទុកជាមុនបាន ហើយអាចបាត់បង់ផលប្រយោជន៍ដោយមិនអាចព្រាងទុកបាន ដោយសារការកម្រិតនូវការដាក់បណ្ដឹងឧបាស្រ័យដូចខាងលើនេះ ។

ដូច្នេះ មាត្រានេះចែងកម្រិតថា ត្រូវអនុវត្តមាត្រានេះចំពោះករណីដែលដើមចោទ ឬ ចុងចម្លើយ បានអវត្តមាននៅកាលបរិច្ឆេទដែលនីតិវិធីកោះហៅត្រូវបានធ្វើឡើង ក្រោយពេលអនុវត្តក្រមនេះតែប៉ុណ្ណោះ ហើយចំពោះករណីដែលបានអវត្តមាននៅកាលបរិច្ឆេទដែលនីតិវិធីនៃការកោះហៅត្រូវបានធ្វើឡើង មុនពេលអនុវត្តក្រមថ្មីនេះ មិនត្រូវអនុវត្តតាមក្រមនេះទេ គឺត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។

**មាត្រា ៥៨១.-** វិធានការអន្តរកាលស្ដីពីការអាច ឬ មិនអាចធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង អំឡុងពេលនៃបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

១- ការអាច ឬ មិនអាចធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង អំឡុងពេលនៃបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចំពោះសាលក្រម ឬ សាលដីកា ដែលត្រូវបានសម្រេចដោយផ្អែកលើការដេញដោលដែលបានចប់នៅមុនពេលដែលក្រមនេះត្រូវបានអនុវត្ត ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក ។

២- ការអាច ឬ មិនអាចធ្វើបណ្ដឹងសាទុក្ខ និង អំឡុងពេលនៃបណ្ដឹងសាទុក្ខ ចំពោះសាលដីកាដែលសាលាឧទ្ធរណ៍បានសម្រេចជាថ្មីឡើងវិញ អំពីរឿងក្ដីដែលតុលាការកំពូលបានសម្រេចបញ្ជូនត្រឡប់វិញនៅមុនពេលដែលក្រមនេះត្រូវបានអនុវត្ត ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក ។

៣- ចំពោះរឿងក្ដីដែលតុលាការកំពូលបានសម្រេចទុកជាមោឃៈនូវសាលដីកាដែលសាលាឧទ្ធរណ៍បានសម្រេច ដោយផ្អែកលើការដេញដោលដែលបានចប់នៅមុនពេលដែលក្រមនេះត្រូវបានអនុវត្ត និង បញ្ជូនត្រឡប់ទៅសាលាឧទ្ធរណ៍វិញ ការអាច ឬ មិនអាចធ្វើបណ្ដឹងសាទុក្ខ និង អំឡុងពេលនៃបណ្ដឹងសាទុក្ខ ចំពោះសាលដីកាដែលសាលាឧទ្ធរណ៍បានសម្រេចជាថ្មីឡើងវិញ ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក ។

៤- ចំពោះសេចក្ដីសម្រេច ក្រៅពីសាលក្រម និង សាលដីកា ដែលត្រូវបានជូនដំណឹងនៅមុនពេលក្រមនេះត្រូវបានអនុវត្ត ការអាច ឬ មិនអាចធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង អំឡុងពេលនៃបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក ។

(កំណត់)

(1) មាត្រានេះចែងអំពីវិធានការអន្តរកាលស្ដីពីការអាច ឬ មិនអាចធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង អំឡុងពេលនៃបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ។

ស្តីពីការអាច ឬ មិនអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង អំឡុងពេលធ្វើបណ្តឹងឧបាស្រ័យ ក្រមថ្មីមានចែងថា អំឡុងពេលនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះសាលក្រម ឬ សាលដីកា គឺមាន ១ (មួយ) ខែ ដោយគិតពីថ្ងៃដែលបានទទួលការបញ្ជូននូវលិខិតសាលក្រម ឬ សាលដីកា (មាត្រា ២៦៤ កថាខណ្ឌទី ១, មាត្រា ២៨៦) ហើយស្តីពីបណ្តឹងសាទុក្ខ ចាំបាច់ត្រូវមានមូលហេតុដែលកំណត់ដោយច្បាប់ ដើម្បីធ្វើបណ្តឹងសាទុក្ខ (មាត្រា ២៨៤, មាត្រា ២៨៥) ជាអាទិ៍ ដែលជាការផ្លាស់ប្តូរច្រើនពីនីតិវិធីចាស់ ។ ហេតុនេះហើយ ចំពោះរឿងក្តីដែលកំពុងចាត់ការ ប្រសិនបើទទួលស្គាល់នូវការអនុវត្តតាមក្រមថ្មីនេះទាំងអស់ទៅ នឹងអាចបង្កើតជាបញ្ហា ដូចជាធ្វើឱ្យបាត់បង់នូវស្ថិរភាពនៃច្បាប់ ឬ ធ្វើឱ្យមានការបាត់បង់នូវផលប្រយោជន៍របស់ភាគីបាន ។ ដូច្នេះ មាត្រានេះចែងនូវករណីពិសេសនៃគោលការណ៍នៃការអនុវត្តតាមច្បាប់ថ្មីស្តីពីវិធានការអន្តរកាល (មាត្រា ៥៧២) ដោយមានខ្លឹមសារថា មិនអនុវត្តតាមបញ្ញត្តិនៃក្រមថ្មី ហើយអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ចំពោះករណីដូចតទៅនេះ ។

(2) ចំពោះសាលក្រម ឬ សាលដីកានៃរឿងក្តីដែលការជំនុំជម្រះត្រូវបានបញ្ចប់មុនពេលក្រមនេះត្រូវបានអនុវត្ត ប្រសិនបើទទួលស្គាល់នូវការអនុវត្តតាមបញ្ញត្តិនៃក្រមថ្មីស្តីពីការអាច ឬ មិនអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង អំឡុងពេលនៃការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ទៅ ការអាច ឬ មិនអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង អំឡុងពេលនៃការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ នឹងត្រូវផ្លាស់ប្តូរក្រោយការបញ្ចប់នូវការជំនុំជម្រះ ហើយអាចធ្វើឱ្យបាត់បង់ស្ថិរភាពច្បាប់ ព្រមជាមួយគ្នានេះ អាចធ្វើឱ្យមានការជ្រួលច្របល់ដល់នីតិវិធី និង ធ្វើឱ្យខូចផលប្រយោជន៍ដល់ភាគី ដោយមិនអាចគ្រោងទុកជាមុនបាន ។

ដូច្នេះ កថាខណ្ឌទី ១ នៃមាត្រានេះ មានចែងថា ការអាច ឬ មិនអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង អំឡុងពេលនៃការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចំពោះសាលក្រម ឬ សាលដីកាដែលត្រូវបានប្រកាសឡើងដោយផ្អែកលើការជំនុំជម្រះ ដែលបានបញ្ចប់មុនពេលក្រមនេះត្រូវបានអនុវត្ត មិនត្រូវអនុវត្តតាមបញ្ញត្តិនៃក្រមថ្មីនេះទេ គឺត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។

មានន័យលំអិតថា យោងតាមមាត្រានេះ ចំពោះសាលក្រម ឬ សាលដីកាដែលត្រូវបានប្រកាសឡើងដោយផ្អែកលើការជំនុំជម្រះ ដែលបានបញ្ចប់មុនពេលក្រមនេះត្រូវបានអនុវត្ត មិនត្រូវអនុវត្តបញ្ញត្តិនៃក្រមថ្មី ស្តីពីការអាច ឬ មិនអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង អំឡុងពេលនៃការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ទេ គឺត្រូវអនុវត្តតាមនីតិវិធីចាស់ ហេតុនេះហើយ ចំពោះសាលក្រម ឬ សាលដីកាដែលមិនអនុញ្ញាតឱ្យប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ក្នុងនីតិវិធីចាស់ ហើយទោះជាក្នុងក្រមថ្មី អាចអនុញ្ញាតឱ្យប្តឹងឧបាស្រ័យក៏ដោយ ក៏មិនទទួលស្គាល់នូវការប្តឹងឧបាស្រ័យនេះឡើយ ។ ផ្ទុយទៅវិញ ទោះជាក្នុងក្រមថ្មី គេមិនទទួលស្គាល់នូវការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ក៏ដោយ តែប្រសិនបើនៅក្នុងនីតិវិធីចាស់ គេទទួលស្គាល់ឱ្យធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់វិញ គឺអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន ។ ចំពោះអំឡុងពេលនៃការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់វិញ ត្រូវអនុវត្តតាមនីតិវិធីចាស់ ហើយអំឡុងពេលនៃការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលមានចែងក្នុងក្រមថ្មីនេះ ពុំមានឥទ្ធិពលទៅលើករណីនេះ

ទេ ដូច្នេះហើយ បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដែលបានធ្វើឡើងក្រោយការកន្លងផុតទៅនៃអំឡុងពេលអាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលមានចែងក្នុងនីតិវិធីចាស់នោះ គឺត្រូវចាត់ទុកថា ខុសច្បាប់ ដោយសារការកន្លងផុតទៅនៃអំឡុងពេលអាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ។

ផ្ទុយទៅវិញ ក្នុងករណីដែលការជំនុំជម្រះបានបញ្ចប់ក្រោយពេលក្រមនេះត្រូវបានអនុវត្តវិញ ជាគោលការណ៍ ការអាច ឬ មិនអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង អំឡុងពេលនៃការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់នេះ ត្រូវអនុវត្តតាមបញ្ញត្តិនៃក្រមថ្មីនេះ (កថាខណ្ឌទី ១ នៃមាត្រានេះ, មាត្រា ៥៧២) ក៏ប៉ុន្តែ ដូចដែលបានរៀបរាប់ខាងក្រោមនេះ ចំពោះសាលដីកាមួយចំនួន ដូចជាសាលដីកានៃសាលាឧទ្ធរណ៍ ដែលត្រូវតុលាការកំពូលបញ្ជូនត្រឡប់មកវិញ មុនពេលក្រមនេះត្រូវបានអនុវត្ត អាចមានករណីដែលត្រូវអនុវត្តតាមនីតិវិធីចាស់ដែរ (កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣ នៃមាត្រានេះ) ។

(3) ចំពោះសាលដីកាដែលសាលាឧទ្ធរណ៍បានប្រកាសជាថ្មីចំពោះរឿងក្តីដែលទទួលនូវការបញ្ជូនត្រឡប់មកវិញពីតុលាការកំពូល មុនពេលក្រមនេះត្រូវបានអនុវត្ត (កថាខណ្ឌទី ២ នៃមាត្រានេះ) តាមទំនាក់ទំនងទៅនឹងរបបប្តឹងសាទុក្ខនៅក្នុងនីតិវិធីចាស់ ការទទួលស្គាល់នូវចំណងនៃសាលដីកានៃរឿងក្តីនេះ ដែលតុលាការកំពូលបានសម្រេចទុកជាមោឃៈ មិនត្រឹមត្រូវទេ (មាត្រា ៥៨៣, មាត្រា ៥៨២ កថាខណ្ឌទី ២) ដូច្នេះហើយ ទោះបីជាការជំនុំជម្រះ ដើម្បីសម្រេចសាលដីកាសាជាថ្មីនៃសាលាឧទ្ធរណ៍ ត្រូវបានបញ្ចប់មុន ឬ ក្រោយពេលក្រមនេះត្រូវបានអនុវត្តក៏ដោយ ក៏ត្រូវជ្រើសរើសយកគោលការណ៍នៃការអនុវត្តតាមច្បាប់ចាស់ ដោយចាំបាច់ត្រូវរក្សាដដែលនូវការដាក់ពាក្យបណ្តឹងឧបាស្រ័យតាមនីតិវិធីចាស់ដែរ ។

ដូច្នេះ ស្តីពីការអាច ឬ មិនអាចប្តឹងសាទុក្ខចំពោះសាលដីកានេះ និង អំឡុងពេលនៃការប្តឹងសាទុក្ខនេះ យោងតាមកថាខណ្ឌទី ២ នៃមាត្រានេះ គឺមិនអនុវត្តតាមបញ្ញត្តិនៃក្រមថ្មីទេ ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។ម្យ៉ាងទៀត ចំពោះបណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ ក៏មានបញ្ញត្តិពិសេសដែលមានគោលគំនិតដូចគ្នានេះដែរ (មាត្រា ៥៨២ កថាខណ្ឌទី ២) ។

(4) ក្នុងរឿងក្តីដែលតុលាការកំពូលបានសម្រេចទុកជាមោឃៈនូវសាលដីកា ដែលសាលាឧទ្ធរណ៍បានសម្រេចដោយផ្អែកលើការដេញដោលដែលត្រូវបានបញ្ចប់មុនពេលក្រមថ្មីត្រូវបានអនុវត្ត ហើយបានចេញសាលដីកាបញ្ជូនរឿងក្តីនោះទៅសាលាឧទ្ធរណ៍វិញ ចំពោះសាលដីកាដែលសាលាឧទ្ធរណ៍បានសម្រេចសាជាថ្មី តាមទំនាក់ទំនងទៅនឹងរបបប្តឹងសាទុក្ខក្នុងនីតិវិធីចាស់ ការទទួលស្គាល់នូវចំណងនៃសាលដីកាទុកជាមោឃៈ ដែលសម្រេចដោយតុលាការកំពូល ក្នុងរឿងក្តីនោះ គឺមិនត្រឹមត្រូវទេ ដូចសាលដីកាដែលសាលាឧទ្ធរណ៍បានសម្រេចជាថ្មីឡើងវិញ អំពីរឿងក្តីដែលតុលាការកំពូលបានសម្រេចបញ្ជូនត្រឡប់វិញនៅមុនពេលដែលក្រមថ្មីត្រូវបានអនុវត្តដែរ (មាត្រា ៥៨៣, មាត្រា ៥៨២ កថាខណ្ឌទី ៣) ដូច្នេះហើយ ចំពោះបណ្តឹងឧបាស្រ័យ ទោះជាការជំនុំជម្រះដើម្បីសម្រេចសាលដីកាសាជាថ្មី នៃសាលាឧទ្ធរណ៍ ត្រូវបានបញ្ចប់មុន ឬ

ក្រោយពេលក្រមថ្មីត្រូវបានអនុវត្តក៏ដោយ ក៏ត្រូវជ្រើសរើសយកគោលការណ៍នៃការអនុវត្តតាមច្បាប់ចាស់ ដោយចាំបាច់ត្រូវរក្សាដដែលនូវការដាក់ពាក្យបណ្តឹងឧបាស្រ័យតាមនីតិវិធីចាស់ ។

ដូច្នេះ ស្តីពីការអាច ឬ មិនអាចប្តឹងសាទុក្ខចំពោះសាលដីកានេះ និង អំឡុងពេលនៃការប្តឹងសាទុក្ខនេះ យោងតាមកថាខណ្ឌទី ៣ នៃមាត្រានេះ គឺមិនអនុវត្តតាមបញ្ញត្តិនៃក្រមថ្មីទេ ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។ ចំពោះបណ្តឹងសាទុក្ខចំពោះសាលដីកានេះ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខនោះ ក៏មានបញ្ញត្តិពិសេសដែលមានគោលគំនិតដូចគ្នានេះដែរ ( មាត្រា ៥៨២ កថាខណ្ឌទី ៣) ។

(5) ចំពោះសេចក្តីសម្រេច ក្រៅពីសាលក្រម និង សាលដីកា ពុំមានទស្សនៈនៃការបញ្ចប់នៃការជំនុំជម្រះ ដូចករណីនៃសាលក្រម និង សាលដីកាទេ ហេតុនេះហើយ កថាខណ្ឌទី ៤ នៃមាត្រានេះ បានយកពេលវេលានៃការជូនដំណឹងដែលជាពេលវេលាដែលសេចក្តីសម្រេចក្រៅពីសាលក្រម និង សាលដីកា បង្កើតអានុភាពចំពោះខាងក្រៅ មកធ្វើជាមូលដ្ឋាន ហើយស្តីពីការអាច ឬ មិនអាចប្តឹងឧបាស្រ័យវិញ ព្រមទាំងអំឡុងពេលដែលអាចធ្វើបណ្តឹងឧបាស្រ័យ ចំពោះសេចក្តីសម្រេចក្រៅពីសាលក្រម និង សាលដីកាដែលត្រូវបានជូនដំណឹងមុនពេលក្រមថ្មីត្រូវបានអនុវត្ត គឺមិនត្រូវអនុវត្តតាមបញ្ញត្តិនៃក្រមថ្មីទេ ហើយត្រូវអនុវត្តតាមនីតិវិធីចាស់ ។

មានន័យលំអិតថា ចំពោះសេចក្តីសម្រេច ក្រៅពីសាលក្រម និង សាលដីកា ដែលត្រូវបានជូនដំណឹងមុនពេលក្រមថ្មីត្រូវបានអនុវត្ត មិនត្រូវអនុវត្តតាមបញ្ញត្តិនៃក្រមថ្មី ស្តីពីការអាច ឬ មិនអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង អំឡុងពេលនៃការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ទេ គឺត្រូវអនុវត្តតាមនីតិវិធីចាស់ ហេតុនេះហើយ ចំពោះសេចក្តីសម្រេចដែលមិនអនុញ្ញាតឱ្យប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ តាមនីតិវិធីចាស់ ទោះបីជាសេចក្តីសម្រេចនោះ អាចអនុញ្ញាតឱ្យប្តឹងឧបាស្រ័យតាមបញ្ញត្តិនៃក្រមថ្មីក៏ដោយ ក៏មិនទទួលស្គាល់នូវការប្តឹងឧបាស្រ័យនេះឡើយ ។ ផ្ទុយទៅវិញ ទោះបីជាសេចក្តីសម្រេចដែលគេមិនត្រូវបានទទួលស្គាល់នូវការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់តាមបញ្ញត្តិនៃក្រមថ្មីក៏ដោយ តែប្រសិនបើនីតិវិធីចាស់ទទួលស្គាល់ឱ្យធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់វិញ គឺអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន ។ ស្តីពីអំឡុងពេលនៃការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ក៏ត្រូវអនុវត្តតាមនីតិវិធីចាស់ដែរ ហើយអំឡុងពេលនៃការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលមានចែងក្នុងក្រមថ្មីនេះ ពុំមានឥទ្ធិពលទៅលើករណីនេះទេ ដូច្នេះហើយ បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដែលបានធ្វើឡើងក្រោយការកន្លងផុតនៃអំឡុងពេលអាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលមានចែងក្នុងនីតិវិធីចាស់នោះ គឺត្រូវចាត់ទុកថា ខុសច្បាប់ដោយសារការកន្លងផុតនៃអំឡុងពេលអាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ។

**មាត្រា ៥៨២.-** វិធានការអន្តរកាលស្តីពីបណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ

១- បណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ ចំពោះសាលដីកាដែលត្រូវបានសម្រេច ដោយផ្អែកលើការដេញដោល ដែលបានចប់នៅមុនពេលដែលក្រមនេះត្រូវបានអនុវត្ត ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើ

ពីមុនមក ។
២- បណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ ចំពោះសាលដីកាដែលសាលាឧទ្ធរណ៍បានសម្រេចជាថ្មីឡើងវិញ អំពីរឿងក្តីដែលតុលាការកំពូលបានសម្រេចបញ្ជូនត្រឡប់វិញទៅមុនពេលដែលក្រមនេះត្រូវបានអនុវត្ត ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក ។
៣- ចំពោះរឿងក្តីដែលតុលាការកំពូលបានសម្រេចទុកជាមោឃៈនូវសាលដីកាដែលសាលាឧទ្ធរណ៍បានសម្រេច ដោយផ្អែកលើការដេញដោលដែលបានចប់នៅមុនពេលដែលក្រមនេះត្រូវបានអនុវត្ត និង បញ្ជូនត្រឡប់ទៅសាលាឧទ្ធរណ៍វិញ បណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ ចំពោះសាលដីកាដែលសាលាឧទ្ធរណ៍បានសម្រេចជាថ្មីឡើងវិញ ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក ។

(កំណត់)

(1) មាត្រានេះចែងអំពីវិធានការអន្តរកាលស្តីពីបណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ ដែលមានខ្លឹមសារថា ចំពោះបណ្តឹងសាទុក្ខ និង នីតិវិធីធ្វើការវិនិច្ឆ័យបណ្តឹងសាទុក្ខ ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។

(2) ចំពោះបណ្តឹងសាទុក្ខ និង នីតិវិធីធ្វើការវិនិច្ឆ័យបណ្តឹងសាទុក្ខ នៃករណីដែលមានបណ្តឹងសាទុក្ខចំពោះសាលដីកានៃសាលាឧទ្ធរណ៍ ដែលបានសម្រេចដោយផ្អែកលើការដេញដោលដែលត្រូវបានបញ្ចប់មុនពេលក្រមថ្មីត្រូវបានអនុវត្ត ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក (កថាខណ្ឌទី ១ នៃមាត្រានេះ) ។ ហេតុនេះហើយ ស្តីពីការប្តឹងសាទុក្ខចំពោះសាលដីកានេះ មិនត្រូវអនុវត្តបញ្ញត្តិស្តីពីបណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខនៃក្រមថ្មីទេ ដូច្នេះត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។ មូលហេតុដែលត្រូវមានវិធានការអន្តរកាលដូចនេះ គឺមានដូចតទៅ :

ស្តីពីបណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ ក្រមថ្មីមានចែងថា អង្គហេតុដែលបានចូលជាស្ថាពរដោយត្រឹមត្រូវតាមច្បាប់ ដោយតុលាការដើម នឹងចងតុលាការនៃបណ្តឹងសាទុក្ខ (មាត្រា ២៩៦ កថាខណ្ឌទី ១) ហើយការវិនិច្ឆ័យបណ្តឹងសាទុក្ខ គឺជាការវិនិច្ឆ័យទៅលើអង្គច្បាប់តែម្តង ហើយមានការកែប្រែពីនីតិវិធីចាស់ជាច្រើនចំណុច ដែលមានដូចជា ការកំណត់ដោយច្បាប់អំពីវិធីដាក់ពាក្យបណ្តឹងឧបាស្រ័យ ឬ ចំណុចដែលសរសេរនៅក្នុងឯកសារបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ជាដើម ។

ហេតុនេះហើយ ប្រសិនបើអនុវត្តគោលការណ៍នៃវិធានការអន្តរកាលនៃមាត្រា ៥៧២ នេះ ហើយ អនុវត្តតាមបញ្ញត្តិនៃក្រមថ្មី ក្រោយពេលបណ្តឹងសាទុក្ខត្រូវបានចាត់ការ នឹងធ្វើឱ្យមានការផ្លាស់ប្តូរនូវមូលដ្ឋាននៃទម្រង់នៃនីតិវិធីជំនុំជម្រះបណ្តឹងសាទុក្ខ នៅពេលដែលនីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខនោះ កំពុងតែមានដំណើរការ ហើយដែលជាកត្តាមួយធ្វើឱ្យមានការបាត់បង់នូវស្ថិរភាពនៃនីតិវិធី ហើយអាចនាំឱ្យមានការជ្រួលច្របល់ដល់នីតិវិធីនោះ ។ មូលដ្ឋាននៃពេលវេលានៃការអនុវត្តក្រមថ្មីមានដូចជា ពេលបញ្ចប់ការជំនុំជម្រះ និង ពេលប្រកាសសាលដីកា ក៏ប៉ុន្តែ ក្នុងករណីដែលយកកាលបរិច្ឆេទនៃការប្រកាសសាលដីកា មកធ្វើជាមូលដ្ឋាននៃពេលវេលា ទោះជារឿងក្តីដែលត្រូវបានបញ្ចប់ជំនុំជម្រះ

ពេលដូចគ្នាក៏ដោយ តែការប្រកាសសាលដីកានោះត្រូវធ្វើឡើងមុន ឬ ក្រោយការអនុវត្តក្រមថ្មី នឹងធ្វើឱ្យបណ្ដឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្ដឹងសាទុក្ខ មានភាពខុសគ្នា ជាអាទិ៍ ដែលជាបញ្ហា ។ ដូច្នេះ កថាខណ្ឌទី ១ នៃមាត្រានេះ បានជ្រើសរើសយកពេលបញ្ចប់ការជំនុំជម្រះនៅតុលាការនៃបណ្ដឹងសាលាឧទ្ធរណ៍ មកធ្វើជាមូលដ្ឋាននៃពេលវេលា ហេតុនេះហើយ ក្នុងករណីដែលមានបណ្ដឹងសាទុក្ខចំពោះសាលដីការបស់សាលាឧទ្ធរណ៍ ដែលបានសម្រេចដោយផ្អែកទៅលើការវិនិច្ឆ័យដែលត្រូវបានបញ្ចប់មុនពេលអនុវត្តក្រមថ្មី បណ្ដឹងសាទុក្ខនោះ និង នីតិវិធីនៃការវិនិច្ឆ័យបណ្ដឹងសាទុក្ខនោះ ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។

ផ្ទុយទៅវិញ ចំពោះបណ្ដឹងសាទុក្ខចំពោះសាលដីការបស់សាលាឧទ្ធរណ៍ ដែលបានសម្រេចដោយផ្អែកទៅលើការវិនិច្ឆ័យ ដែលត្រូវបានបញ្ចប់ក្រោយពេលអនុវត្តក្រមថ្មី ពុំមានបញ្ញត្តិពិសេសទេ ហេតុនេះហើយ ដោយយោងតាមគោលការណ៍នៃវិធានការអន្តរកាលនៃមាត្រា ៥៧២ ត្រូវអនុវត្តតាមបញ្ញត្តិនៃក្រមថ្មី ។ ក៏ប៉ុន្តែ ចំពោះបណ្ដឹងសាទុក្ខលើកទី ២ អាចមានករណីដែលត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ដូចដែលមានរៀបរាប់តទៅនេះ (មាត្រា ៥៨២ កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣) ។

(3) ក្នុងករណីដែលមានបណ្ដឹងសាទុក្ខ ចំពោះសាលដីកាដែលសាលាឧទ្ធរណ៍បានសម្រេចសាជាថ្មី អំពីរឿងក្ដីដែលទទួលនូវការបញ្ជូនត្រឡប់មកវិញ នៅមុនពេលក្រមថ្មីត្រូវបានអនុវត្ត ដោយតុលាការកំពូល មិនត្រូវអនុវត្តបញ្ញត្តិស្ដីពីបណ្ដឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្ដឹងសាទុក្ខនៃក្រមថ្មីនេះ ចំពោះករណីនេះទេ (កថាខណ្ឌទី ២ នៃមាត្រានេះ) ។

មូលហេតុដែលមានបញ្ញត្តិស្ដីពីវិធានការអន្តរកាលនេះ មានដូចតទៅ :

ជាបឋម កិច្ចការស្ដីពីបណ្ដឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្ដឹងសាទុក្ខសព្វថ្ងៃនេះ គឺមានដូចតទៅ ។ មានន័យថា ចំពោះបណ្ដឹងសាទុក្ខលើកទី ១ ជាគោលការណ៍ (លើកលែងតែករណីពិសេស គឺ ករណីនៃការសម្រេចសេចក្ដីស្ដីពីកំហុសនៃសមត្ថកិច្ច និង ស្ដីពីវិវាទអំពីប្រាក់ប្រដាប់ក្ដី) តុលាការកំពូលមិនអាចសម្រេចទុកជាមោឃៈ ហើយវិនិច្ឆ័យដោយខ្លួនឯងបានឡើយ ដូច្នេះក្នុងករណីដែលយល់ឃើញថា មានកំហុសក្នុងការវិនិច្ឆ័យនៃសាលដីកាដើម តុលាការកំពូលត្រូវសម្រេចទុកជាមោឃៈនូវសាលដីកាដើមនោះ ហើយបញ្ជូនរឿងក្ដីនោះ ទៅសាលាឧទ្ធរណ៍វិញ ។

ក៏ប៉ុន្តែ នៅក្នុងនីតិវិធីចាស់ ពុំមានបញ្ញត្តិណាមួយដែលចងនូវការវិនិច្ឆ័យរបស់តុលាការកំពូល ចំពោះសាលាឧទ្ធរណ៍ ដូចដែលមានចែងក្នុងក្រមថ្មី មាត្រា ២៩៩ កថាខណ្ឌទី ២ ទេ ។ ដូច្នេះ ការវិនិច្ឆ័យនៃតុលាការកំពូល ពុំមានអ្វីចងសាលាឧទ្ធរណ៍ដែលជាតុលាការវិនិច្ឆ័យរឿងក្ដីដែលត្រូវបានបញ្ជូនត្រឡប់មកវិញ តាមផ្លូវច្បាប់ទេ ហេតុនេះហើយ សាលាឧទ្ធរណ៍អាចធ្វើការសម្រេចសេចក្ដីដូចមុនម្ដងទៀត ដោយមិនធ្វើតាមការវិនិច្ឆ័យរបស់តុលាការកំពូលបាន ។ ចំពោះបញ្ហានេះ មានករណីច្រើន ដែលភាគីនឹងធ្វើបណ្ដឹងសាទុក្ខជាលើកទី ២ ទៀត ហើយចំពោះការវិនិច្ឆ័យនៃបណ្ដឹងសាទុក្ខជាលើកទី ២ តុលាការកំពូលមានសិទ្ធិធ្វើការវិនិច្ឆ័យទៅលើអង្គហេតុផង ទៅលើអង្គច្បាប់ផង ហើយនឹងធ្វើនីតិវិធីសាជាថ្មីឡើងវិញទាំងអស់ តាំងពីការពិនិត្យភស្តុតាងឡើងវិញ ដោយខ្លួនឯង ។ ម្យ៉ាងទៀត ប្រសិនបើយោងតាមរបបនេះ ក្នុងករណីដែលមានការមិនពេញចិត្តនឹងលទ្ធផលនៃសាលដីការបស់សាលាឧទ្ធរណ៍ ដែលទទួលការបញ្ជូនរឿងក្ដីមកវិញ

ពីតុលាការកំពូល ភាគីនឹងធ្វើបណ្តឹងសាទុក្ខជាលើកទី ២ ទៀត ដោយរំពឹងថា តុលាការកំពូលនឹងធ្វើនីតិវិធីសាជាថ្មីវិញ ដូច្នេះ ជាលទ្ធផល មានករណីជាច្រើន ដែលភាគីណាម្ខាងបានប្តឹងសាទុក្ខពីរដង ដូចស្ថានភាពសព្វថ្ងៃនេះ ហេតុនេះហើយ មានករណីជាច្រើនដែលគេប្តឹងសាទុក្ខទៅតុលាការកំពូល ដើម្បីរង់ចាំឱ្យតុលាការកំពូលធ្វើការវិនិច្ឆ័យទៅលើអង្គហេតុម្តងទៀត ។

តាមកិច្ចការទាំងអស់ដែលបានពន្យល់ខាងលើនេះ យើងយល់ឃើញថា តាមការជាក់ស្តែង ការវិនិច្ឆ័យបណ្តឹងសាទុក្ខលើកទី ១ គឺជាការវិនិច្ឆ័យទៅលើអង្គច្បាប់ ហើយការវិនិច្ឆ័យបណ្តឹងសាទុក្ខលើកទី ២ គឺជាការវិនិច្ឆ័យទៅលើអង្គហេតុ ហើយចំពោះសាលដីកាសម្រេចទុកជាមោឃៈនូវសាលដីកាសាលាឧទ្ធរណ៍ ក្នុងការវិនិច្ឆ័យបណ្តឹងសាទុក្ខលើកទី ១ គេមិនទទួលស្គាល់នូវចំណងនៃសាលដីកាសម្រេចទុកជាមោឃៈនេះទេ ហេតុនេះហើយ តួនាទីនៃការវិនិច្ឆ័យទៅលើអង្គច្បាប់នៃបណ្តឹងសាទុក្ខទី ១ ដែលត្រូវធ្វើឱ្យទៅជាស្ថាពរនូវការវិនិច្ឆ័យតាមផ្លូវច្បាប់ទៅលើរឿងក្តីនេះ តាមរយៈសាលដីកានៃការវិនិច្ឆ័យនៃបណ្តឹងសាទុក្ខលើកទី ១ ហើយធ្វើការបញ្ជូនត្រឡប់វិញនូវបណ្តឹងនោះទៅឱ្យសាលាឧទ្ធរណ៍ ដើម្បីឱ្យធ្វើការវិនិច្ឆ័យ ក្នុងកម្រិតនៃការវិនិច្ឆ័យនៃបណ្តឹងសាទុក្ខលើកទី ១ ពុំមានដំណើរការល្អទេ តាមភាពជាក់ស្តែង ។

ផ្ទុយទៅវិញ ក្រមនីតិវិធីរដ្ឋប្បវេណីលើកនេះ បានឱ្យតួនាទីទៅលើការវិនិច្ឆ័យនៃបណ្តឹងសាទុក្ខ ជាការវិនិច្ឆ័យទៅលើអង្គច្បាប់ទាំងស្រុងតែម្តង ហើយការទទួលស្គាល់អង្គហេតុ គឺជាសិទ្ធិរបស់តុលាការវិនិច្ឆ័យអង្គហេតុ ដូច្នេះ អង្គហេតុដែលបានចូលជាស្ថាពរដោយត្រឹមត្រូវតាមច្បាប់នោះ ត្រូវចងតុលាការនៃបណ្តឹងសាទុក្ខ ( មាត្រា ២៩៦) ហើយដើម្បីធ្វើបណ្តឹងសាទុក្ខ ចាំបាច់ត្រូវមានមូលហេតុនៃបណ្តឹងសាទុក្ខ ព្រមជាមួយគ្នានេះ បានកម្រិតមូលហេតុនៃបណ្តឹងសាទុក្ខនេះត្រឹមតែភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬ ផ្ទុយនឹងច្បាប់ ឬ បទដ្ឋានគតិយុត្ត ឬ ខុសធ្ងន់នឹងនីតិវិធីប៉ុណ្ណោះ ( មាត្រា ២៨៤, មាត្រា ២៨៥) ហើយការវិនិច្ឆ័យទៅលើអង្គហេតុ និង អង្គច្បាប់ ដែលជាមូលហេតុនៃការបដិសេធរបស់តុលាការនៃបណ្តឹងសាទុក្ខ ត្រូវចងតុលាការដែលទទួលការបញ្ជូនបណ្តឹងនោះមកវិញ ( មាត្រា ២៩៩ កថាខណ្ឌទី ២) ។

ហេតុនេះហើយ វិសោធនកម្មលើកនេះ គឺជាវិសោធនកម្មមួយដ៏ធំពាក់ព័ន្ធទៅនឹងទម្រង់ជាមូលដ្ឋាននៃបណ្តឹងសាទុក្ខ ហើយមានឥទ្ធិពលយ៉ាងខ្លាំងទៅលើរបៀបធ្វើការវិនិច្ឆ័យនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ព្រមទាំងទៅលើសកម្មភាពបណ្តឹងរបស់ភាគី ។ ម្យ៉ាងទៀត សម្រាប់ភាគី ប្រសិនបើមុនពេលបញ្ចប់ការដោញដោលក្នុងបណ្តឹងឧទ្ធរណ៍ គេអាចធ្វើសកម្មភាពបណ្តឹងរបស់ខ្លួន ដោយគិតដល់ចំណុចវិសោធនកម្មនេះ ។ ប៉ុន្តែ ប្រសិនបើការកែទម្រង់បណ្តឹងសាទុក្ខនេះត្រូវបានធ្វើឡើងក្រោយការបញ្ចប់នៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ នៅពេលនោះ ភាគីមិនអាចចាត់ចែងដោយគិតពិចារណានូវមូលដ្ឋាននៃក្រមថ្មីនេះបានទេ ហើយភាគីអាចយកត្រឹមតែមូលហេតុនៃការខុសនឹងច្បាប់ ឬ បទដ្ឋានគតិយុត្តប៉ុណ្ណោះមកធ្វើជាមូលហេតុនៃការប្តឹងឧបាស្រ័យ ហើយមិនអាចប្តឹងឧបាស្រ័យ ដោយយកការទទួលស្គាល់អង្គហេតុមកធ្វើជាមូលហេតុបានឡើយ ជាដើម ។ ដូច្នេះ តាមរយៈការអនុវត្តក្រមថ្មីក្រោយពេលនោះ ភាគីអាចទទួលនូវការខូចផលប្រយោជន៍ដោយមិនអាចគ្រោងទុកជាមុនបាន ។

ដូច្នេះ ចំពោះបណ្ដឹងសាទុក្ខចំពោះសាលដីការបស់តុលាការបណ្ដឹងឧទ្ធរណ៍ ដែលបានសម្រេចឡើងដោយផ្អែកលើការដេញដោលដែលត្រូវបានបញ្ចប់មុនពេលអនុវត្តក្រមថ្មី កថាខណ្ឌទី ២ នៃមាត្រានេះ បានជ្រើសរើសយកគោលការណ៍នៃការអនុវត្តតាមច្បាប់ចាស់ ចំពោះនីតិវិធីនៃការវិនិច្ឆ័យបណ្ដឹងសាទុក្ខ ហើយអនុលោមតាមនីតិវិធីចាស់ ចំពោះបញ្ហានេះ ។

(4) ចំពោះរឿងក្ដីដែលតុលាការកំពូលបានសម្រេចទុកជាមោឃៈនូវសាលដីកា ដែលសាលាឧទ្ធរណ៍បានសម្រេចដោយផ្អែកលើការដេញដោលដែលត្រូវបានបញ្ចប់មុនការអនុវត្តក្រមថ្មី ហើយដែលតុលាការកំពូលបានចេញសាលដីកាបញ្ជូនរឿងក្ដីនោះត្រឡប់ទៅសាលាឧទ្ធរណ៍វិញ ក្នុងករណីដែលមានបណ្ដឹងសាទុក្ខចំពោះសាលដីកាដែលសាលាឧទ្ធរណ៍បានសម្រេចជាថ្មីស្ដីពីបណ្ដឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្ដឹងសាទុក្ខ ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។ ដូច្នេះហើយ ចំពោះករណីនេះ ត្រូវអនុវត្តតាមនីតិវិធីចាស់ ដោយពុំអនុវត្តតាមនីតិវិធីថ្មីទេ (កថាខណ្ឌទី ៣ នៃមាត្រានេះ) ។

មូលហេតុដែលមានវិធានការអន្តរកាលរបៀបនេះ គឺ មានដូចដែលបានពន្យល់នៅក្នុង (3) ខាងលើនេះដែរ ។ មានន័យថា នៅក្នុងនីតិវិធីចាស់ ពេលដែលធ្វើការវិនិច្ឆ័យទៅលើបណ្ដឹងសាទុក្ខជាលើកទី ២ តុលាការកំពូលមានសិទ្ធិពេញលេញក្នុងការវិនិច្ឆ័យជាថ្មីឡើងវិញ ទាំងលើអង្គហេតុ ទាំងលើអង្គច្បាប់ ហើយតាមកិច្ចការជាក់ស្ដែង នឹងធ្វើនីតិវិធីទាំងអស់ឡើងវិញ ព្រមទាំងពិនិត្យភស្តុតាងដោយខ្លួនឯងឡើងវិញ ។ ប្រសិនបើអនុវត្តក្រមថ្មី ទៅលើការវិនិច្ឆ័យនៃបណ្ដឹងសាទុក្ខនោះទៅ តុលាការកំពូលអាចធ្វើការវិនិច្ឆ័យតែចំពោះអង្គច្បាប់ប៉ុណ្ណោះ ដូច្នេះហើយ ទម្រង់មូលដ្ឋាននៃនីតិវិធីចុងក្រោយ ក្នុងចំណោមនីតិវិធីនានានៃករណីនេះ នឹងមានការផ្លាស់ប្ដូរ ហើយការនេះអាចធ្វើឱ្យបាត់បង់នូវស្ថិរភាពច្បាប់ ហើយនឹងធ្វើឱ្យខូចដល់សេចក្ដីសង្ឃឹមរបស់ភាគី ។

ដូច្នេះ កថាខណ្ឌទី ៣ នៃមាត្រានេះចែងថា ចំពោះរឿងក្ដីដែលតុលាការកំពូលបានសម្រេចទុកជាមោឃៈនូវសាលដីកាដែលសាលាឧទ្ធរណ៍បានសម្រេចដោយផ្អែកលើការដេញដោលដែលបានចប់នៅមុនពេលដែលក្រមនេះត្រូវបានអនុវត្ត និង បញ្ជូនត្រឡប់ទៅសាលាឧទ្ធរណ៍វិញ បណ្ដឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្ដឹងសាទុក្ខចំពោះសាលដីកាដែលសាលាឧទ្ធរណ៍បានសម្រេចជាថ្មីឡើងវិញ ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក ។

## **មាត្រា ៥៨៣.-** វិធានការអន្តរកាលស្ដីពីអានុភាពចំណងនៃសាលដីការបស់តុលាការកំពូលដែលទុកជាមោឃៈនូវសាលដីកាសាលាឧទ្ធរណ៍

ក្នុងករណីដែលបណ្ដឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្ដឹងសាទុក្ខ ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក ដោយយោងតាមបញ្ញត្តិនៃមាត្រា ៥៨២ (វិធានការអន្តរកាលស្ដីពីបណ្ដឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្ដឹងសាទុក្ខ) នៃក្រមនេះ ប្រសិនបើតុលាការកំពូលសម្រេចទុកជាមោឃៈនូវសាលដីកាដើម ហើយបញ្ជូនត្រឡប់ទៅសាលាឧទ្ធរណ៍វិញ ឬ ផ្ទេរទៅតុលាការផ្សេង បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ២៩៩ (ការបដិសេធចោល ហើយបញ្ជូនត្រឡប់ទៅតុលាការដើមវិញ ជាអាទិ៍) មិនត្រូវយកមកអនុវត្តឡើយ ចំពោះសាលដីកានោះ ។

(កំណត់)

មាត្រានេះបញ្ញត្តអំពីវិធានការអន្តរកាលស្តីពីអានុភាពចំណងនៃសាលដីការបស់តុលាការកំពូលដែលបានបដិសេធនូវសាលក្រម ឬ សាលដីកាដើម ហើយកំណត់អំពីករណីដែលមិនអនុវត្តតាមបញ្ញត្តិនៃមាត្រា ២៩៩ កថាខណ្ឌទី ២ ស្តីពីអានុភាពនៃសាលដីកាបដិសេធចោលសាលក្រម សាលដីកាដើម ហើយបញ្ជូនត្រឡប់ទៅតុលាការដើមវិញ ។

មាត្រា ៥៨២ ចែងអំពីករណីដែលត្រូវធ្វើតាមនីតិវិធីចាស់ ដោយមិនអនុវត្តតាមបញ្ញត្តិនៃក្រមថ្មី ចំពោះនីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ ។ ក្នុងករណីដែលនីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ ត្រូវធ្វើតាមនីតិវិធីចាស់ ដោយសារនៅក្នុងនីតិវិធីចាស់ គេមិនទទួលស្គាល់អានុភាពនៃចំណងនៃសាលដីកាដែលតុលាការកំពូលបានទុកជាមោឃៈនូវសាលដីកានៃសាលាឧទ្ធរណ៍ ហេតុនេះហើយ ក្រោមនីតិវិធីនេះ ចាំបាច់ត្រូវចែងថា មិនត្រូវអនុវត្តតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ២៩៩ (ការបដិសេធចោល ហើយបញ្ជូនត្រឡប់ទៅតុលាការដើមវិញ ជាអាទិ៍) ស្តីពីអានុភាពនៃចំណងនៃសាលដីកាបដិសេធចោល ។

ហេតុដូច្នេះ មាត្រានេះចែងថា ក្នុងករណីដែលបណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក ដោយយោងតាមបញ្ញត្តិនៃមាត្រា ៥៨២ (វិធានការអន្តរកាលស្តីពីបណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ) នៃក្រមនេះ ប្រសិនបើតុលាការកំពូលសម្រេចទុកជាមោឃៈនូវសាលដីកាដើម ហើយបញ្ជូនត្រឡប់ទៅសាលាឧទ្ធរណ៍វិញ ឬ ផ្ទេរទៅតុលាការផ្សេង បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ២៩៩ (ការបដិសេធចោល ហើយបញ្ជូនត្រឡប់ទៅតុលាការដើមវិញ ជាអាទិ៍) មិនត្រូវយកមកអនុវត្តឡើយ ចំពោះសាលដីកានោះ ដើម្បីមិនឱ្យអនុវត្តតាមបញ្ញត្តិនៃក្រមថ្មី មិនត្រឹមតែចំពោះនីតិវិធីនៃបណ្តឹងទេ រួមទាំងចំពោះអានុភាពនៃចំណងនៃសាលដីកាបដិសេធចោលផងដែរ ។

**មាត្រា ៥៨៤.-** វិធានការអន្តរកាលស្តីពីការជំនុំជម្រះសាជាថ្មី

បញ្ញត្តិនៃគន្ថីទី ៤ (ការជំនុំជម្រះសាជាថ្មី) នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះការសម្រេចសេចក្តីដែលចូលជាស្ថាពរ នៅក្រោយពេលដែលក្រមនេះត្រូវបានអនុវត្តតែប៉ុណ្ណោះ ។

(កំណត់)

មាត្រានេះចែងអំពីវិធានការអន្តរកាលស្តីពីការជំនុំជម្រះសាជាថ្មី ដែលមានខ្លឹមសារថា ការសម្រេចសេចក្តី ដែលអាចដាក់ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មី គឺមានតែការជំនុំជម្រះដែលបានចូលជាស្ថាពរ ក្រោយពេលអនុវត្តក្រមថ្មីតែប៉ុណ្ណោះ ។

តើត្រូវទទួលស្គាល់នូវការជំនុំជម្រះសាជាថ្មីចំពោះករណីណាខ្លះ គឺជាបញ្ហាពាក់ព័ន្ធនឹងអានុភាពនៃសាលក្រម ឬ សាលដីកាស្ថាពរ ហេតុនេះហើយ ប្រសិនបើជ្រើសរើសយកគោលការណ៍អនុវត្តតាមច្បាប់ថ្មី ចំពោះចំណុចនេះ ហើយទទួល

ស្គាល់នូវការជំនុំជម្រះសាជាថ្មី ដែលគេមិនទទួលស្គាល់នៅក្នុងនីតិវិធីចាស់ មានន័យថា បានផ្លាស់ប្តូរនៅពេលក្រោយ នូវអានុភាពនៃសាលក្រម ឬ សាលដីកាដែលចូលស្ថាពរ តាមនីតិវិធីចាស់ ហើយដែលអាចធ្វើឱ្យបាត់បង់នូវស្ថិរភាពច្បាប់ ។

ហេតុដូច្នេះ មាត្រានេះចែងទទួលស្គាល់នូវការជំនុំជម្រះសាជាថ្មី ចំពោះតែការជំនុំជម្រះដែលបានចូលជាស្ថាពរក្រោយការអនុវត្តក្រមថ្មីប៉ុណ្ណោះ ។

**មាត្រា ៥៨៥.-** វិធានការអន្តរកាលស្តីពីការអនុវត្តដោយបង្ខំ

១- ចំពោះរឿងក្តីនៃការអនុវត្តដោយបង្ខំ ដែលបានដាក់ពាក្យសុំនៅមុនពេលក្រមនេះត្រូវបានអនុវត្ត ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក លើកលែងតែបញ្ញត្តិដែលមានចែងនៅក្នុងជំពូកទី ៣ (អំពីការដាក់គុកបង្ខំដល់រូបកាយ) នៃច្បាប់ស្តីអំពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

២- សេចក្តីសម្រេចបង្គាប់ឱ្យដាក់គុកបង្ខំដល់រូបកាយ ដែលបានចេញដោយអនុលោមតាមបញ្ញត្តិនៃជំពូកទី ៣ (អំពីការដាក់គុកបង្ខំដល់រូបកាយ) នៃច្បាប់ស្តីអំពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី នៅមុនពេលក្រមនេះត្រូវបានអនុវត្ត ត្រូវបាត់បង់អានុភាព ចាប់ពីថ្ងៃដែលក្រមនេះ ត្រូវបានអនុវត្ត ។

៣- នៅពេលដែលក្រមនេះត្រូវបានអនុវត្ត ប្រសិនបើកូនបំណុលទទួលការដាក់គុកបង្ខំដល់រូបកាយ តាមបញ្ញត្តិនៃជំពូកទី ៣ (អំពីការដាក់គុកបង្ខំដល់រូបកាយ) នៃច្បាប់ស្តីអំពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ប្រធានក្រុមប្រឹក្សាជំនុំជម្រះដែលបានបង្គាប់ឱ្យដាក់គុកបង្ខំដល់រូបកាយ ឬ ប្រធានតុលាការត្រូវបង្គាប់ឱ្យដោះលែងកូនបំណុលនោះភ្លាម ។

(កំណត់)

មាត្រានេះបានជ្រើសរើសយកគោលការណ៍អនុវត្តតាមច្បាប់ចាស់ ចំពោះវិធានការអន្តរកាលស្តីពីការអនុវត្តដោយបង្ខំ ។

ចំពោះនីតិវិធីនៃការអនុវត្តដោយបង្ខំក្នុងនីតិវិធីចាស់ ត្រូវអនុវត្តតាមច្បាប់ស្តីអំពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។ ក៏ប៉ុន្តែ នីតិវិធីនៃការអនុវត្តដោយបង្ខំដែលមានចែងក្នុងក្រមថ្មី មានភាពខុសគ្នាខ្លាំងពីនីតិវិធីចាស់ ហើយពុំសូវមានភាពបន្តគ្នាទៅវិញទៅមក រវាងនីតិវិធីចាស់ និង នីតិវិធីថ្មីទេ ។ ក្នុងស្ថានភាពនេះ ប្រសិនបើជ្រើសរើសយកគោលការណ៍នៃការអនុវត្តតាមច្បាប់ថ្មីទៅ ករណីដែលពុំអាចប្តឹងឧបាស្រ័យពីមុន នឹងក្លាយទៅជាអាចប្តឹងឧបាស្រ័យបាន ឬ ពេលកំពុងតែធ្វើនីតិវិធីលក់ វិធីលក់នោះត្រូវផ្លាស់ប្តូរ ជាដើម ហើយចំពោះភាគដែលមានភាពខុសពីមុននោះ តើត្រូវធ្វើយ៉ាងណា ដើម្បីបន្តទៅនីតិវិធីថ្មី ជាអាទិ៍ ដែលជាបញ្ហាស្មុគស្មាញពិបាកដោះស្រាយ ។

ហេតុដូច្នេះ តាមទស្សនៈស្ថិរភាព និង ភាពងាយស្រួលនៃនីតិវិធី កថាខណ្ឌទី ១ នៃមាត្រានេះ ជ្រើសរើសយកគោលការណ៍អនុវត្តតាមច្បាប់ចាស់ ដោយចែងថា ចំពោះករណីអនុវត្តដោយបង្ខំដែលបានដាក់ពាក្យសុំក្រោយការអនុវត្តក្រមថ្មី ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។

ក៏ប៉ុន្តែ ចំពោះការឃាត់ខ្លួន ដោយយោងតាមបញ្ញត្តិនៃជំពូកទី ៣ (អំពីការដាក់គុកបង្ខំដល់រូបកាយ) នៃច្បាប់ស្តីអំពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណីវិញ មិនគួររក្សាទុកប្រើដដែល ក្រោយការរៀបចំនូវរបបនៃការអនុវត្តដោយបង្ខំដោយក្រមថ្មីនេះទេ ហេតុនេះហើយ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ នៃមាត្រានេះមានចែងថា បញ្ញត្តិដែលមានចែងនៅក្នុងជំពូកទី ៣ (អំពីការដាក់គុកបង្ខំដល់រូបកាយ) នៃច្បាប់ស្តីអំពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តក្រោយក្រមថ្មីត្រូវបានអនុវត្តទេ ។

លើសពីនេះ ដើម្បីឱ្យបានសម្រេចច្បាស់លាស់នូវគោលគំនិតដែលមានក្នុងកថាខណ្ឌទី ១ វាក្យខណ្ឌទី ២ នោះមាត្រានេះមានចែងបន្ថែមថា សេចក្តីសម្រេចបង្គាប់ឱ្យដាក់គុកបង្ខំដល់រូបកាយ ដែលបានធ្វើឡើង នៅក្នុងនីតិវិធីមុនពេលអនុវត្តក្រមថ្មី នឹងបាត់បង់អានុភាពចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត (កថាខណ្ឌទី ២ នៃមាត្រានេះ) ហើយនៅពេលដែលក្រមនេះត្រូវបានអនុវត្តហើយ ប្រសិនបើកូនបំណុលត្រូវជាប់គុកបង្ខំដល់រូបកាយ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬ ប្រធានតុលាការដែលបានបង្គាប់ដាក់គុកបង្ខំដល់រូបកាយ ត្រូវបង្គាប់ឱ្យដោះលែងកូនបំណុលនោះជាបន្ទាន់ (កថាខណ្ឌទី ៣ នៃមាត្រានេះ) ។

**មាត្រា ៥៨៦.-** វិធានការអន្តរកាលស្តីពីការចាត់ចែងរក្សាការពារ

១- ក្នុងករណីដែលក្រមនេះត្រូវបានអនុវត្ត នៅមុនពេលចេញសេចក្តីសម្រេចលើរឿងក្តីចាត់ចែងរក្សាការពារ ដែលបានដាក់ពាក្យសុំនៅមុនពេលក្រមនេះត្រូវបានអនុវត្ត នីតិវិធីបន្ទាប់ ត្រូវបន្តអនុវត្តបញ្ចប់ ដោយក្រមនេះ ។ ក្នុងករណីនេះនីតិវិធីដែលបានធ្វើនៅមុនពេលក្រមនេះត្រូវបានអនុវត្ត ពុំត្រូវបាត់បង់អានុភាពឡើយ ។

២- ក្នុងករណីដែលក្រមនេះត្រូវបានអនុវត្ត នៅក្រោយពេលចេញសេចក្តីសម្រេចលើរឿងក្តីចាត់ចែងរក្សាការពារ នីតិវិធីបន្ទាប់ ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក ។

(កំណត់)

មាត្រានេះចែងអំពីវិធានការអន្តរកាលស្តីពីការចាត់ចែងរក្សាការពារ ដែលមានករណីត្រូវអនុវត្តតាមក្រមថ្មី និងករណីដែលត្រូវអនុវត្តតាមនីតិវិធីចាស់ ចំពោះរឿងក្តីដែលមានពាក្យសុំដាក់មុនពេលក្រមថ្មីត្រូវបានអនុវត្ត ។

ចំពោះការចាត់ចែងរក្សាការពារក្នុងនីតិវិធីចាស់វិញ ពុំមានបញ្ញត្តិច្បាប់ណាចែងទេ តាមភាពជាក់ស្តែង នីតិវិធីនេះត្រូវបានអនុវត្តដោយយោងតាមសារាចរលេខ ០៤ សរច ៨៤ របស់ក្រសួងយុត្តិធម៌ ដែលបានចេញនៅឆ្នាំ ១៩៨៤ ក្នុងចំណុចស្តីពី "វិធានការបណ្តោះអាសន្ន" ក៏ប៉ុន្តែ បញ្ហាដែលមានគឺ ខ្លឹមសារនោះខ្លីៗ ហើយនីតិវិធី និង ខ្លឹមសារ ជាអាទិ៍ នៃការចាត់ចែងរក្សាការពារ ក៏មិនសូវច្បាស់លាស់ទេ ។

ក្នុងក្រមថ្មីនេះ ដើម្បីរៀបចំឱ្យបានស្រួលបួល បញ្ញត្តិផ្សេងៗស្តីពីការចាត់ចែងរក្សាការពារ ត្រូវបានបញ្ចូលទៅក្នុងគន្ថីទី ៧ ហេតុនេះហើយតាមទស្សនៈនៃការតម្រូវឱ្យមានភាពច្បាស់លាស់ ក្នុងនីតិវិធី និង ខ្លឹមសារនៃការចាត់ចែងរក្សាការពារ គួរតែអនុវត្តតាមបញ្ញត្តិនៃក្រមថ្មី តាមដែលអាចធ្វើទៅបាន ជាការល្អ ។

ប៉ុន្តែ នីតិវិធីនៃការចាត់ចែងរក្សាការពារ គឺជានីតិវិធីមួយស្មុគស្មាញ ដែលមានរួមទាំងនីតិវិធីនៃការសម្រេចសេចក្តី និង នីតិវិធីអនុវត្តផងដែរ ហេតុនេះហើយ ប្រសិនបើអនុវត្តតាមក្រមថ្មីនេះទាំងស្រុង ចំពោះករណីនៃការចាត់ចែងរក្សាការពារ ដែលត្រូវបានដាក់ពាក្យសុំមុនពេលអនុវត្តក្រមថ្មីនេះទៅ នឹងធ្វើឱ្យមានការផ្លាស់ប្តូរដល់វិធីប្តឹងឧបាស្រ័យនៅពាក់កណ្តាលទី ហើយអាចបង្កើតឱ្យមានអស្ថិរភាពដល់នីតិវិធីអនុវត្តផងដែរ ។

ដូច្នេះ ដោយពិចារណាជាទូទៅ មាត្រានេះបានបែងចែក នីតិវិធីនៃការចាត់ចែងរក្សាការពារ ជាពីរ គឺ នីតិវិធីក្រោយពេលមានការសម្រេចសេចក្តីស្តីពីការចាត់ចែងរក្សាការពារ ដែលមានបញ្ហាទាក់ទងនឹងការប្តឹងឧបាស្រ័យ និង ការអនុវត្តរក្សាការពារ ជាដើម និង នីតិវិធីមុនពេលមានការសម្រេចសេចក្តីនោះ ដែលជានីតិវិធីងាយស្រួល ។ ចំពោះករណីដែលបានអនុវត្តក្រមនេះ មុនការសម្រេចសេចក្តីអំពីពាក្យសុំចាត់ចែងរក្សាការពារ មាត្រានេះបានជ្រើសរើសយកគោលការណ៍នៃការអនុវត្តតាមច្បាប់ថ្មី គឺ នីតិវិធីបន្ទាប់ពីនោះ ត្រូវបញ្ចប់ដោយក្រមនេះ រីឯចំពោះករណីដែលក្រមនេះត្រូវបានអនុវត្ត ក្រោយការសម្រេចសេចក្តីអំពីពាក្យសុំចាត់ចែងរក្សាការពារវិញ មាត្រានេះបានជ្រើសរើសយកគោលការណ៍នៃការអនុវត្តតាមច្បាប់ចាស់ គឺ នីតិវិធីបន្ទាប់ពីនោះ ត្រូវបន្តតាមនីតិវិធីចាស់ ។

# គន្ថីទី ៩ អវសានប្បញ្ញត្តិ

## ជំពូកគោល អវសានប្បញ្ញត្តិ

**មាត្រា ៥៨៧.-** ការអនុវត្តក្រមនេះ

ក្រោយពីចូលជាធរមាន ក្រមនេះត្រូវផ្សព្វផ្សាយរយៈពេល ១ (មួយ) ឆ្នាំ ទើបអនុវត្ត ។

(កំណត់)

មាត្រានេះចែងអំពីកាលបរិច្ឆេទនៃការអនុវត្តក្រមថ្មីនេះ ដែលមានខ្លឹមសារថា ក្រមថ្មីនេះត្រូវអនុវត្ត ក្រោយការផ្សព្វផ្សាយឱ្យបានជ្រួតជ្រាបរយៈពេល ១ ឆ្នាំ បន្ទាប់ពីបានចូលជាធរមាន ។

ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តប្រកាសឱ្យប្រើ នឹងត្រូវចូលជាធរមាន ១០ ថ្ងៃគត់ នៅភ្នំពេញ ក្រោយថ្ងៃឡាយព្រះហស្តលេខា ហើយ ២០ ថ្ងៃគត់ នៅទូទាំងប្រទេស ក្រោយថ្ងៃឡាយព្រះហស្តលេខា (ច្បាប់រដ្ឋធម្មនុញ្ញ មាត្រា ៩៣ កថាខណ្ឌទី ១) ហេតុនេះហើយ ក្រមថ្មីនេះនឹងត្រូវអនុវត្ត ១ ឆ្នាំ និង ១០ ថ្ងៃក្រោយ នៅភ្នំពេញ ហើយ ១ ឆ្នាំ និង ២០ ថ្ងៃក្រោយ នៅទូទាំងប្រទេស ដោយគណនាពីថ្ងៃដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខា ។

ការទុករយៈពេល ១ ឆ្នាំ សម្រាប់ធ្វើការផ្សព្វផ្សាយក្រមថ្មី ក្រោយពេលចូលជាធរមាននេះ មានមូលហេតុដូចតទៅ :

ជាទូទៅ ពេលច្បាប់ណាមួយចូលជាធរមានទៅ អានុភាពនៃច្បាប់នោះនឹងកើតមានឡើងជាក់ស្តែង ហើយអាចអនុវត្តភ្លាមៗ ។ យោងតាមរដ្ឋធម្មនុញ្ញកម្ពុជា ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញ ក្នុងរយៈពេល ១០ ថ្ងៃគត់ ក្រោយថ្ងៃប្រកាសឱ្យប្រើ និង នៅទូទាំងប្រទេស ក្នុងរយៈពេល ២០ ថ្ងៃគត់ ក្រោយថ្ងៃប្រកាសឱ្យប្រើ (រដ្ឋធម្មនុញ្ញ មាត្រា ៩៣ វាក្យខណ្ឌទី ១) ។ ប៉ុន្តែ បើច្បាប់បានចែងថា ជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាម នៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសឱ្យប្រើ (រដ្ឋធម្មនុញ្ញ មាត្រា ៩៣ វាក្យខណ្ឌទី ២) ។

ដូច្នេះហើយ ក្រមថ្មីនេះក៏ដូចគ្នាដែរ គឺក្រោយការអនុម័តរបស់សភាហើយ ព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខា ហើយយ៉ាងយឺតបំផុតក៏ក្រមនេះនឹងមានអានុភាពជាក់ស្តែង ២០ ថ្ងៃក្រោយពីថ្ងៃដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាដែរ ។ ក៏ប៉ុន្តែ ក្រមថ្មីនេះ មានការផ្លាស់ប្តូរនូវនីតិវិធីយ៉ាងច្រើន ពីនីតិវិធីនៃបណ្តឹងរដ្ឋប្បវេណីចាស់ និង នីតិវិធីនៃការអនុវត្តដោយបង្ខំចាស់ ជាអាទិ៍ ហេតុនេះហើយ មុននឹងចាប់ផ្តើមអនុវត្ត ចាំបាច់ត្រូវធ្វើការផ្សព្វផ្សាយឱ្យជ្រួតជ្រាបដល់ប្រជាជនគ្រប់ៗរូប ម្យ៉ាងទៀត ចាំបាច់ត្រូវមានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំត្រៀមនូវរបបពាក់ព័ន្ធនឹងតុលាការ អាជ្ញាសាលា ជាដើម ដែលជាអ្នកចាំបាច់ត្រូវដឹកនាំនីតិវិធីនៃក្រមនេះឱ្យមានភាពរមូតនោះផងដែរ ដូច្នេះ

ការផ្តល់អានុភាពជាក់ស្តែងនៅក្នុងពេលវេលាដ៏ខ្លី មិនសមរម្យទេ គឺត្រូវទុកពេលវេលាវែងមួយ ដើម្បីធ្វើការផ្សព្វផ្សាយ និង រៀបចំ ទើបអនុវត្តទៅមានប្រសិទ្ធភាពល្អ ។

ហេតុដូច្នេះ ដោយពិនិត្យមើលតាមស្ថានភាពទាំងនេះហើយ បានជាមាត្រានេះបានកំណត់ថា ក្រោយពីថ្ងៃចូលជាធរមាន ត្រូវធ្វើការផ្សព្វផ្សាយរយៈពេល ១ ឆ្នាំ ទើបអនុវត្តក្រមនេះ ។

**មាត្រា ៥៨៨.-** ការធ្វើឱ្យនិរាករណ៍នូវច្បាប់ផ្សេង ជាអាទិ៍

១- ច្បាប់ដែលបានកំណត់ដូចខាងក្រោមនេះ ត្រូវបាត់បង់អានុភាព ចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត :

**ក-** ច្បាប់ស្តីអំពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៥១ ក្រ ចុះថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ១៩៩២ ។

**ខ-** ច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ដែលត្រូវបានប្រកាសឱ្យប្រើដោយក្រឹត្យលេខ ០៧ ក្រ ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

២- បញ្ញត្តិនៃច្បាប់ផ្សេងទៀត ដែលមានអានុភាពនៅពេលក្រមនេះត្រូវបានអនុវត្ត ហើយផ្ទុយនឹងបញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកថា គ្មានអានុភាព ត្រឹមទំហំដែលផ្ទុយនឹងក្រមនេះ ចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត ។

(កំណត់)

មាត្រានេះចែងអំពីច្បាប់ដែលត្រូវធ្វើនិរាករណ៍ និង ច្បាប់ដែលត្រូវបាត់បង់អានុភាព ដោយសារការអនុវត្តក្រមនេះ ។

ក្រមថ្មីនេះ ត្រូវបានតាក់តែងឡើងជាច្បាប់មូលដ្ឋាន ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី រួមទាំងការអនុវត្តដោយបង្ខំ និង ការរក្សាការពារផ្នែករដ្ឋប្បវេណីផងដែរ (សូមមើលមាត្រា ១) ។ ហេតុនេះហើយ ច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី (កថាខណ្ឌទី ១ ចំណុច **ក** នៃមាត្រានេះ) និង ច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី (កថាខណ្ឌដដែល ចំណុច **ខ**) ដែលជាច្បាប់ទាក់ទងនឹងនីតិវិធីរដ្ឋប្បវេណីកន្លងមក ត្រូវបាត់បង់អានុភាព ចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត (កថាខណ្ឌទី ១ នៃមាត្រានេះ) ។

លើសពីនេះ នៅព្រះរាជាណាចក្រកម្ពុជា មុនពេលក្រមនេះត្រូវបានអនុម័ត ច្បាប់មូលដ្ឋានស្តីពីនីតិវិធីរដ្ឋប្បវេណី ពុំមានទេ គឺមានតែបទដ្ឋានស្តីពីនីតិវិធីរដ្ឋប្បវេណី ដែលជាសារាចរ ជាដើម របស់ក្រសួងយុត្តិធម៌ប៉ុណ្ណោះ ក៏ប៉ុន្តែ បទដ្ឋានទាំងនេះ ត្រូវបានធ្វើឡើងក្រោមមូលដ្ឋានរបបចាស់ ដែលមានមុនពេលអនុវត្តក្រមថ្មីនេះ ហេតុនេះហើយ នៅពេលព្រមជាមួយគ្នានឹងការអនុវត្តក្រមថ្មីនេះ បទដ្ឋានទាំងនេះត្រូវបាត់បង់នូវអត្ថិភាពជាសារធាតុ ហើយក្រោយពេល អនុវត្តក្រមថ្មីនេះ ក្រមថ្មីនេះ ព្រមទាំងច្បាប់ជាលាយលក្ខណ៍អក្សរដែលយកក្រមថ្មីនេះជាមូលដ្ឋាន គឺជាច្បាប់កំណត់នូវ នីតិវិធីរដ្ឋប្បវេណី ។

ក្នុងករណីដែលក្នុងច្បាប់ផ្សេងណាមួយ មានបញ្ញត្តិដែលផ្ទុយនឹង ឬ ប៉ះពាល់ដល់បញ្ញត្តិនៃក្រមថ្មីនេះ ត្រូវអនុវត្តជាអាទិភាពនូវបញ្ញត្តិនៃក្រមថ្មីនេះ ហេតុដូច្នេះ បញ្ញត្តិនៃច្បាប់ផ្សេងទៀត ដែលមានអានុភាពនៅពេលក្រមនេះត្រូវបានអនុវត្ត ហើយផ្ទុយនឹងបញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកថា គ្មានអានុភាព ត្រឹមទំហំដែលផ្ទុយនឹងក្រមនេះ (កថាខណ្ឌទី ២ នៃមាត្រានេះ) ។